# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ
# និង
# បរមត្ថមញ្ជូសាមហាដីកា
# បញ្ញានិទ្ទេស
# ភាគទី ១

ដឹកនាំបកប្រែដោយ

ខ្ញុំព្រះករុណា

អាត្មាភាព យង់ សុជាត

ថ្ងៃ ៨ កើត ខែពិសាខ ពុទ្ធសករាជ ២៥៥៥

# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

# និង

# បរមត្ថមញ្ជូសាមហាដីកា

# បញ្ញានិទ្ទេស

# ភាគទី ១

ដឹកនាំបកប្រែដោយ

ខ្ញុំព្រះករុណា

អាត្មាភាព យង់ សុជាត

ថ្ងៃ ៨ កើត ខែពិសាខ ពុទ្ធសករាជ ២៥៥៥

*ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុជាត*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ២២.៥ សជណ

រាជធានីភ្នំពេញ,ថ្ងៃទី.០៤...ខែ.......ឆ្នាំ២០១០

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ពិតថេរដីកា
## ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត

**<u>កម្មវត្ថុ</u>** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ ។

**<u>យោង</u>** : លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

***<u>ចម្លងជូន</u>*** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
" <u>ដើម្បីជូនជ្រាប</u> "
- សាលាខេត្តបាត់ដំបង
" <u>ដើម្បីមុខការ</u> "
-ឯកសារ-កាលប្បវត្តិ

# និទានវចនៈ

**វិសុទ្ធិមគ្គ** ជាបករណ៍វិសេស ដែលព្រះថេរៈ **អ្នកស្រុកជម្ពូទ្វីប** មានឈ្មោះ ពោះសំឡេងមួយរូប បានរចនាឡើង កាលព្រះពុទ្ធសាសនាកន្លងទៅហើយបាន ប្រមាណ ១.០០០ ឆ្នាំ **នៅកោះលង្កាទ្វីប** ព្រះថេរៈរូបនេះ គឺព្រះពុទ្ធឃោសៈ ឯលោកក៏បានរចនាគម្ពីរទុកជាច្រើន នៅក្នុងបវរនៃព្រះពុទ្ធសាសនា ជាការងារ ដ៏ធំ និងជាមរតក រហូតមកដល់សព្វថ្ងៃ ។ ការប្រែ **គម្ពីរព្រះត្រៃបិដក អដ្ឋកថា** ពី **ភាសាសីហឡៈ** មកជា **ភាសាមគធៈ** ឬ **ភាសាបាលី** ព្រះពុទ្ធឃោសៈបាន ប្រមូលធម៌នៅក្នុងព្រះត្រៃបិដក មកសម្ដែងទុកជាពួកៗ តាំងពី **សីល សមាធិ** និង **បញ្ញា** តាមលំដាប់ ។

ឯការរៀបរៀងជាការតែងសំណួរ ឬលំដាប់នៃការឆ្លើយសំណួរធម៌ក្នុង បច្ចុប្បន្ន គឺអធិប្បាយសេចក្ដីសង្ខេបឲ្យពិស្ដារ បទសំណួររបស់ **វិសុទ្ធិមគ្គ** ពោលដោយត្រៃសិក្ខា ដែលជាមាតិកាធំក្នុងព្រះពុទ្ធសាសនា បទសំណួរទាំង អស់ គឺជាបេះដូងនៃការបដិបត្តិតែម្យ៉ាង ព្រោះព្រះពុទ្ធឃោសៈ បានអធិប្បាយ ដោយវិចិត្រពិស្ដារ និងមានរបៀបរៀបរយ បានអាងព្រះពុទ្ធវចនៈជាអាគតដ្ឋាន ទុកក្នុងទីនោះៗ ទូទៅ នេះសម្ដែងឲ្យដឹងថា លោកមានការបែកធ្លាយក្នុងព្រះ ត្រៃបិដក អាចលើកយកធម៌ ដែលពោលដោយសីល មករួបរួមទុកក្នុងពួក សីល លើកយកធម៌ដែលទាក់ទងជាមួយសមាធិ មករួបរួមទុកក្នុងពួកសមាធិ លើកយកធម៌ដែលទាក់ទងជាមួយបញ្ញា មករួមទុកជាមួយពួកបញ្ញា ដោយ

ចែកជានិទ្ទេសៗ រួមទាំងអស់មាន **២៣ និទ្ទេស**, រីឯប្រវត្តិនៃការតែងវិសុទ្ធិមគ្គ ក៏បានក្លាយជាការប្រឡងដេញដោល, ព្រោះព្រះថេរៈ ជាអ្នកស្រុកសីហឡៈ បានផ្ដើមបញ្ហាឲ្យលោកតែងជាមុន កាលបើលោកធ្វើបានជាទីពេញចិត្ត នឹងលើក **គម្ពីរអដ្ឋកថាភាសាសីហឡៈ** ឲ្យលោកប្រែជាភាសាមគធៈតទៅ ព្រះពុទ្ធឃោសាចារ្យបានធ្វើយ៉ាងរហ័ស និងល្អក្រៃលែង ជាទីពេញចិត្តរបស់ព្រះថេរៈអ្នកស្រុកសីហឡៈទាំងពួង, ដូច្នោះ **គម្ពីរវិសុទ្ធិមគ្គនេះ** ជាវិជ្ជានិពន្ធ ដើម្បីសាកល្បងចំណេះដឹងរបស់ព្រះពុទ្ធឃោសៈ ។

ព្រះពុទ្ធឃោសៈ មានដើមកំណើតនៅ **ប្រទេសឥណ្ឌា នាតំបន់ពុទ្ធគយា** បានសិក្សាជំនាញនៅក្នុងព្រះពុទ្ធវចនៈ ទ្រទ្រង់ព្រះត្រៃបិដក មានបញ្ញាដ៏ក្រៃលែង លោកបានធ្វើដំណើរទៅ **លង្កាទ្វីប** ក្នុងរវាងពុទ្ធសករាជ ៩៥០-១០០០ ហើយបានរចនាគម្ពីរវិសុទ្ធិមគ្គនៅទីនោះ និងប្រែ **ព្រះបាលីអដ្ឋកថា** ពីភាសាសីហឡៈ មកជាភាសាមគធៈ ( ភាសាបាលី ) ។

ព្រះថេរៈ មានឈ្មោះដែលគ្រូទាំងឡាយកាន់យកហើយថា **ពុទ្ធឃោសៈ** ជាអ្នកមានភាពបរិសុទ្ធបរិបូណ៌ ប្រដាប់ដោយសទ្ធា វិជ្ជា និងសេចក្ដីព្យាយាមដ៏បរិសុទ្ធយ៉ាងក្រៃលែង ជាបុគ្គលរុងរឿងដោយធម៌ ជាហេតុកើតនៃសេចក្ដីល្អ មានសីលាចារៈទៀងត្រង់ និងការឱនលំទោនជាដើម អាចឈោងចុះកាន់ជជៈ គឺលទ្ធិរបស់ខ្លួន និងលទ្ធិរបស់បុគ្គលដទៃ ប្រកបដោយការមុតស្រួចនៃបញ្ញា មានចំណេះដឹង មិនទើសទាក់ក្នុងសត្ថុសាសនៈ ដោយបរិយត្តិផ្សេងៗ គឺព្រះ

ត្រៃបិដក ព្រមទាំង **អដ្ឋកថា** ជា **មហាវេយ្យាករណ៍** ប្រកបដោយភាពវិចិត្រនៃពាក្យសម្ដី ទាំងទន់ភ្លន់ទូលំទូលាយ បន្លឺចេញបានស្ទាត់ជំនាញ សន្សំឲ្យកើតករណសម្បត្តិ មានវាទៈប្រសើរត្រឹមត្រូវ បុគ្គលដទៃយល់បានងាយ ជាមហាកវី ហៅហាមដោយបដិសម្ភិទាដែលបែកធ្លាយ ជាអលង្ការនៃវង្ស ព្រះថេរៈដែលនៅក្នុងមហាវិហារទាំងឡាយ ដែលជាប្រទីបនៃថេរវង្ស មានការដឹងតាំងមាំល្អហើយ ក្នុង **ឧត្តរិមនុស្សធម្ម** ដែលប្រដាប់ដោយគុណផ្សេងៗ មាន **អភិញ្ញា ៦** ជាដើម ហៅហាមដោយ **បដិសម្ភិទា** បានរចនាវិសុទ្ធិមគ្គនេះចប់ហើយ ។

វិសុទ្ធិមគ្គនេះ តាំងនៅក្នុងលោក សម្ដែងន័យដល់កុលបុត្រទាំងឡាយដែលស្វែងរកធម៌ ជាគ្រឿងដកចេញនូវលោក ដរាបប៉ុនដែលព្រះនាមថា **ពុទ្ធោ** របស់ព្រះលោកជេដ្ឋៈ ដែលស្វែងរកគុណដ៏ធំ មានព្រះទ័យដ៏បរិសុទ្ធ ជាតាទិបុគ្គលប្រព្រឹត្តទៅក្នុងលោក ។

គម្ពីរវិសុទ្ធិមគ្គនេះបានរចនាដោយ

ព្រះពុទ្ធឃោសាចារ្យ

# ព្រះធម្មបាលត្ថេរ

## ព្រះថេរៈជាអ្នករចនា

## ព្រះគម្ពីរបរមត្ថមញ្ជូសាមហាដីកាវិសុទ្ធិមគ្គ

ខ្ញុំម្ចាស់ ( ព្រះធម្មបាលត្ថេរ ) ដែលព្រះទាឋានាគត្ថេរ ជាអ្នកមានសីល និងអាចារៈដល់ព្រមហើយ មានបញ្ញាជាគ្រឿងទ្រទ្រង់ មានការប្រព្រឹត្តបរិសុទ្ធ មានចិត្តតាំងមាំ អារាធនាហើយ ។ សូមថ្វាយវន្ទា ព្រះពុទ្ធជាម្ចាស់ប្រៀបដូចជាព្រះអាទិត្យ ទ្រង់មានព្រះសទ្ធម្មដូចជាកួងរស្មី ទ្រង់កម្ចាត់ងងឹត គឺមោហៈធំអស់ហើយ ទ្រង់ញ៉ាំងពួកវេនេយ្យសត្វ ដែលប្រៀបដូចជាផ្កាឈូកឲ្យដឹងវិសេស ទ្រង់មានព្រះបញ្ញាគុណដ៏វិសេស ដូចដួងព្រះអាទិត្យ មានព្រះវិសុទ្ធិគុណ និងព្រះករុណាគុណ ដូចជាពន្លឺអរុណដែលមិនមានភាពសៅហ្មងរះឡើងក្នុងលោក គួរដល់ការបូជា សូមថ្វាយវន្ទាព្រះធម៌ដែលបំភ្លឺដល់លោករុងរឿងដោយរស្មី គឺព្រះគុណ និងសូមនមស្ការព្រះអរិយសង្ឃ ដែលដូចជាផ្កាឈូកបរិសុទ្ធហើយ ដោយតេជៈនៃបុណ្យ ចំពោះការថ្វាយវន្ទាព្រះរតនត្រ័យដែលកើតឡើងហើយ ដោយប្រការនោះៗ សូមប្រាសចាកអន្តរាយក្នុងទីគ្រប់ស្ថាន ខ្ញុំម្ចាស់នឹងអាស្រ័យបោរាណកថាមគ្គ ដើម្បីពណ៌នាខ្លឹមសារនៃបករណ៍វិសេស ឈ្មោះ **វិសុទ្ធិមគ្គ** ដែលប្រដាប់ដោយន័យដ៏បរិសុទ្ធ មានលំដាប់បទយ៉ាងប្រណីត ដែលព្រះអាចារ្យពុទ្ធឃោសៈបានពោលដើម្បីជាឧបាយក្នុងការសម្រេចភាពបរិសុទ្ធិដែលលោកជា **នាថ** មានព្រះចរិយាបរិសុទ្ធ មានហឫទ័យ

ដែលព្រះករុណាឲ្យឧស្សាហ៍ហើយ លោកបានសម្រេចហើយ សម្ដែងទុកមិនឲ្យខុសពីលទ្ធិរបស់ព្រះថេរៈឯសម្នាក់មហាវិហារ ឲ្យបរិសុទ្ធយ៉ាងល្អ មិនរាត់រាយមានវិនិច្ឆ័យសេចក្ដីដ៏សុខុម ឲ្យបរិសុទ្ធ និងប្រកបដោយរបៀបរៀបរយ ។

សូមសាធុជនទាំងឡាយ តាំងចិត្តសិក្សានូវខ្លឹមសារនៃព្រះវិសុទ្ធិមគ្គនេះឲ្យបានល្អ ខ្ញុំប្រាថ្នាឲ្យព្រះសទ្ធម្មតាំងនៅអស់កាលយូរ ដោយប្រការដូច្នេះចុះ ។

**ព្រះធម្មបាលត្ថេរ** ជាជនជាតិស្រីលង្កា លោកបានសិក្សានៅក្នុងសំណាក់ **មហាវិហារ** នាក្រុង **អនុរាធបុរៈ** ក្នុង **លង្កាទ្វីប** បានចូលរួមរចនា **គម្ពីរអដ្ឋកថា** ជាមួយព្រះពុទ្ធឃោសាចារ្យដែរ, លោកបានរចនាអដ្ឋកថា និងមហាដីកា ទើបបានទទួលការលើកសរសើរថាជា **ព្រះអដ្ឋកថាចារ្យ** និង **ព្រះដីកាចារ្យ** នៅ **កោះលង្កាទ្វីប** ក្នុងរវាងពុទ្ធសករាជ ៩៥០-១០០០ ។

គម្ពីរបរមត្ថមញ្ជូសាមហាដីកានេះរចនាដោយ

**ព្រះធម្មបាលត្ថេរ**

# អារម្ភកថា

ការបកប្រែរៀបរៀងឡើងនូវ **គម្ពីរវិសុទ្ធិមគ្គ** និង **បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស ភាគ ១ នេះ** យើងខ្ញុំបានរៀបរៀងដោយល្អមកជាខេមរភាសា និង រៀបរៀងទៅតាមលំដាប់នៃមាតិកានីមួយៗ យ៉ាងផ្ចិតផ្ចង់បំផុត មិនឲ្យឃ្លៀង ឃ្លាតពីច្បាប់ដើម ដើម្បីជាប្រយោជន៍ដល់កុលបុត្តអ្នកជ្រះថ្លាក្នុងព្រះរតនត្រ័យ និងជាពិសេសដើម្បីជាប្រយោជន៍ដល់ការសិក្សាផងខ្លួន ។

សូមសាធុជនទាំងឡាយ ដែលមានចិត្តភក្តីចំពោះព្រះរតនត្រ័យនោះ **អនុមោទនា** នូវបុណ្យរបស់ខ្ញុំ ដែលសម្រេចហើយដោយប្រការយ៉ាងនេះ ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាម **ខេត្ត ក្រុង** ជាច្រើន នៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណា អាត្មាភាពបានសម្តែងព្រះធម៌ នៅកន្លែងណាៗ ក៏តែងតែបានទុកដាក់ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗ កន្លែង ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥០** ប្រាក់ខ្មែរបាន ១៨.៤៩៥០០០ រៀល ( **១៨ លាន ៤ សែន ៩ ម៉ឺន ៥ ពាន់រៀល** ) និងប្រាក់ដុល្លារ **៦៤៥ ដុល្លារសហរដ្ឋអាមេរិក** ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះ ករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌា** ដែលមានពុទ្ធបរិស័ទទៅ **ប្រមាណ ៦៥ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ១០** ព្រះអង្គផងដែរ ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុង

ការដឹកនាំគណៈធម្មយាត្រានោះ ដោយទៅថ្វាយបង្គំបាន ៥១ កន្លែង បានការឧបត្ថម្ភមកអំពីឧបាសក ឡាយ សុខុម និងឧបាសិកា ឱម លក្ខណា នៅក្នុង ព.ស. ២៥៥០ ( ១០.០២.២០០៧ ) ។

## នឹកឃើញស្រុកព្រះ

នឹកឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្តា
សិរសាលំទោន ទុកដូចឈូកផ្កា បូជាសាស្តា
ជ្រះថ្លាក្រៃលែង ។
៦៥ អង្គា គាល់ព្រះភគវា ៥១ កន្លែង
នៅស្រុកឥណ្ឌា ចងចាំមិនលែង សោមនស្សពន់ពេក
ក្នុង ព.ស. ២៥៥០ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥១ ផ្នែកខាងសម្តែងព្រះធម៌ដូចគ្នានឹង ព.ស. ២៥៥០ផងដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥១ ប្រាក់ខ្មែរបាន ១៥.៨៣១០០០ រៀល ( ១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់រៀល ) និងប្រាក់ដុល្លារ ៤៥ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង ប្រទេសស្រីលង្កា ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ

១២១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៤ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១៩ កន្លែង បានការជួយជ្រោមជ្រែងឧបត្ថម្ភអំពីឧបាសក ឡាយ សុខុម និងឧបាសក សោម រតនៈ ឧបាសិកា ស៊ុប វណ្ណា នៅក្នុង ព.ស. ២៥៥១ ( ០៤.០៤.២០០៨ ) ។

## នឹកឃើញលង្កា

| | | |
|---|---|---|
| នឹកឃើញលង្កា | នឹកឃើញកាលណា | ជ្រះថ្លាក្រៃលែង |
| នៅពុទ្ធស្ថាន | ១៩ កន្លែង | ដែលខ្ញុំបានស្វែង |
| | ទៅថ្វាយបង្គំ ។ | |
| ១២១ អង្គា | គាល់ព្រះបាទា | នាស្ថានមនោរម |
| លើសុមនកូដ | ជេស្ដាឧត្ដម | ជាកំពូលភ្នំ |
| | ក្នុងប្រវត្តិពុទ្ធ ។ | |
| ទឹកដីលង្កា | ទឹកដីអស្ចារ្យ | ពេញពោរដោយឫទ្ធិ |
| នឹកឃើញកាលណា | ជ្រះថ្លាក្រៃពិត | ធម្មយាត្រាប្រណីត |
| | ក្នុង ព.ស. ២៥៥១ ។ | |

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥២ ផ្នែកខាងសម្ដែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥១ ផងដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥២ ប្រាក់ខ្មែរបាន ២៧.១២៨០០០ រៀល ( ២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់

វៀល ) និងប្រាក់ដុល្លារ ១៩៥ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺ បុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានា នៅក្នុង ប្រទេសឥណ្ឌាជាលើកទីពីរ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស មានលោកគ្រូធម្មបណ្ឌិត រស់ សុផាត និងលោកគ្រូធម្មាចារ្យ អឿ សៅ ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ៦៧ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ បានការឧបត្ថម្ភមក អំពីឧបាសក យឹត សូណាត ឧបាសិកា ហ៊ុន ម៉ារ៉ានី M.SUSOKUNORAetMmeINN VISAL + NARITA et RAKSA. ក្រោមការជ្រោមជ្រែងរបស់ឧបាសិកា អ៊ីង រិទ្ធារី ឧបាសិកា ស្លួន កល្យាណ ឧបាសិកា ស្លួន ចរណៃ នៅក្នុង ព.ស. ២៥៥២ ( ១៦.០២.២០០៩ ) ។

## ជ្រះថ្លាខ្លាំងណាស់

ជ្រះថ្លាខ្លាំងណាស់ ព្រះពុទ្ធជាម្ចាស់ គុណធំក្រៃលែង
ច្រើនពុទ្ធសករាជ សាសនាអង្វែង ល្អហួសការថ្លែង
ឱ ! ព្រះសាសនា ។

នៅស្រុកឥណ្ឌា ៦៧ អង្គា រួមគ្នានមស្ការ
១០៩ ពុទ្ធស្ថាន ព្រមចិត្តផ្គង់ថ្វា បីតិអស្ចារ្យ
ក្នុង ព.ស. ២៥៥២ ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ប្រទេសស្រីលង្កាជា លើកទី ២** ដែលមានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៣៦ នាក់** នៅក្នុងនោះទៀត ក៏មាន **ព្រះសង្ឃ ៣** ព្រះអង្គផងដែរ បានការឧបត្ថម្ភមក អំពីឧបាសក **ឆាយ អ៊ីវស៊ាង** ឧបាសិកា **ហុង គឹមសែ** ក្រោមការជ្រោមជ្រែង របស់ឧបាសក **យន្ត សួន** នៅក្នុង **ព.ស. ២៥៥២** ( ១១.០៣.២០០៩ ) ។

នៅមានបុណ្យកុសលនៅក្នុង **ព.ស. ២៥៥៣** ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង **ព.ស. ២៥៥២** ដែរ ដោយសរុបប្រាក់នៅក្នុង **ព.ស. ២៥៥៣** ប្រាក់ខ្មែរបាន ១៣.០៨០០០០ រៀល ( **១៣ លាន ០ សែន ៨ ម៉ឺន** ) និងប្រាក់ដុល្លារ **២០៨ ដុល្លារ** ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែល ខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេស ឥណ្ឌាជាលើកទី ៣** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១១១ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៦** ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន **៩៦ កន្លែង** បានការជ្រោមជ្រែងអំពីឧបាសក **ឡាយ សុខុម** នៅក្នុង **ព.ស. ២៥៥៣** ( ២៥.០១.២០១០ ) ។

# ស្រណោះស្រុកព្រះ

ស្រណោះស្រុកព្រះ ធ្លាប់តែល្អល្អះ ឥឡូវអនិច្ចា !
យើងខ្ញុំទាំងឡាយ បានទៅនមស្ការ ស្ងប់ស្ងៀមអស្ចារ្យ
ឱ៎ះ ឱ ! ពុទ្ធស្ថាន ។
នឹកឃើញកាលណា ចិត្តខ្ញុំជ្រះថ្លា គ្មានអ្វីប្រៀបបាន
១១១ អង្គា ៩៦ ពុទ្ធស្ថាន ព.ស.រាប់បាន
២៥៥៣ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៤ ផ្នែកខាងសម្តែងព្រះធម៌ដូចគ្នានឹង ព.ស. ២៥៥៣ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៤ ប្រាក់ខ្មែរបាន ៣១.៩៩០០០០ រៀល ( ៣១ លាន ៩ សែន ៩ ម៉ឺន ) និងប្រាក់ដុល្លារ ៧២០ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង ប្រទេសឥណ្ឌាជាលើកទី ៤ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១១១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងមកពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៤ ( ២៧.០២.២០១១ ) ។

# គួរឱ្យសង្វេគ

គួរឲ្យសង្វេគ ស្រណោះពន់ពេក ពេលឃើញពុទ្ធស្ថាន
ធ្លាប់តែរុងរឿង ចម្រើនថ្កើងថ្កាន ឥឡូវប្រែប្រាំង
ប្រៀបបានព្រៃស្ងាត់ ។

២៧៧ អង្គ ប្រណម្យវន្ទា បង្គំថ្វាយថ្វាត់
បូជនីយដ្ឋាន ១២ នាដែនពុទ្ធរដ្ឋ ធម្មយាត្រាកំណត់
ក្នុងពុទ្ធសករាជ ២៥៥៤ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៥ ផ្នែកខាងសម្ដែងព្រះធម៌ដូចគ្នានឹង ព.ស. ២៥៥៤ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៥ ប្រាក់ខ្មែរបាន ៣៥,២៨២០០០ រៀល ( ៣៥ លាន ២ សែន ៨ ម៉ឺន ២ ពាន់រៀល ) និងប្រាក់ដុល្លារ **២៧៥៨** ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុងប្រទេសឥណ្ឌា ជាលើកទី ៥ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ៦៨ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១៤ កន្លែងធំៗ បានការជ្រោមជ្រែងមកពីឧបាសិកា **អ៊ឹង រិទ្ធារី** នៅក្នុង ព.ស. ២៥៥៥ ( ០២.០២.២០១២ ) ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណាអាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង ប្រទេសស្រីលង្កាជាលើកទី ៣ ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១៤០** នាក់ នៅក្នុងនោះទៀត ក៏មាន **ព្រះសង្ឃ ១៥** ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩ កន្លែងធំៗ បានការឧបត្ថម្ភមកអំពីឧបាសិកា **អ៊ឹង រិទ្ធារី** នៅក្នុង **ព.ស. ២៥៥៥** ( ២៧.០៣.២០១២ ) ។

## បានយល់ស្រុកព្រះ

ជ្រះថ្លាខ្លាំងណាស់　បានយល់ស្រុកព្រះ　ជាតិភូមិសាស្ដា
១៤ កន្លែង　៦៨ អង្គា　បានក្រាបវន្ទា
បូជាគ្រប់ប្រាណ ។
សិរីលង្កា　១៤០ អង្គា　៩ ពុទ្ធស្ថាន
ជ្រះថ្លាខ្លាំងណាស់　ដែលពួកខ្ញុំបាន　នមស្ការពុទ្ធស្ថាន
ក្នុងពុទ្ធសករាជ ២៥៥៥ ។

ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិសមហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស **យង់ សុង** ( ស្លាប់ ) និងញោមស្រី **ឈឹម ហយ** ( ស្លាប់ ) ម្យ៉ាងទៀត ញាតិកានៅក្នុងសង្សារវដ្ដ ជាពិសេស

នោះ សូមលើកមហាកុសលទាំងអស់នេះ ជូនចំពោះលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** លោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **គាំ អ៊ីវ** ជាដើម សូមឲ្យបាននូវចំណែកបុណ្យកុសលនេះស្មើនឹងអាត្មាភាពផងដែរ សូម **អនុមោទនា !!!** ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសលនៃធម្មទាននេះគ្រប់ៗគ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសលនេះ ឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។

ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជាអនាគត កុំបីអាក់ខានឡើយ ( **សូមឲ្យបានជាសាវកបារមីញាណ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធអង្គណានីមួយ ដែលជាឯតទគ្គៈផ្នែកខាងពហុស្សុត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុបដ្ឋាក ១** ) សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយ៍សុផាត

# ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកដ៏មានអាយុ ម៉ី សាលួន ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ សឿន កុសល ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ គឹម ម៉ានិត ជួយប្រែ

លោកអ្នកដ៏មានអាយុ ម៉ុន បូរ៉ា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ អ៊ឹម សុជាន ជួយប្រែ

លោកអ្នកដ៏មានអាយុ មាន វឌ្ឍនា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ ពេជ្រ ឧត្តម ជួយវាយកុំព្យូទ័រ

ឧបាសក អ៊ឹម វ៉ៃយ៉ា ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ឡាន សុខុម ជួយប្រែ

ឧបាសក ជិម ជំនិត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក បូ ស៊ីផូ ជួយពិនិត្យអក្ខរាវិរុទ្ធ

# សមាជិកសមាគមធម្មទានអរិយទ្រព្យចំស្ទាត

សម្ដេចព្រះសង្ឃរាជគណមហានិកាយ នន្ទ ង៉ែត ជាប្រធានកិត្តិយស

ភិក្ខុ អគ្គបណ្ឌិតោ យង់ សុផាត ជាប្រធានសមាគម

លោកអភិបាលស្រុក ស្រេង ស្រ៊ាង ជាទីប្រឹក្សាសមាគម

ឧបាសក អ៊ុម វ៉ៃយ៉ា ជាអនុប្រធានសមាគម

ឧបាសិកា ង៉ែត យូអេង ជាអនុប្រធានសមាគម

សាមណេរ ម៉ី សាលួន ជាលេខាធិការ

ឧបាសក ឡាន សុខុម ជាលេខាធិការរង

ឧបាសិកា តាំង ប៉េងជីង ជាហេរញ្ញិក

ឧបាសិកា ជា នាង ជាបេឡា

លោកគ្រូធម្មបណ្ឌិត អឿ សៅ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ឡាយ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា អ៊ុង រិទ្ធារី សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហោ ភាព សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា គួ ប៊ុនគាង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឈុំ គីមហួយ សមាជិកកិត្តិយស និងឧបការគុណ

| | |
|---|---|
| ឧបាសិកា ប៉ែន រមណីយ | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា ឱម លក្ខណា | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសក អ៊ឹង ប៊ុនហួរ | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា បួ ម៉ាឡា | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសក ប៊ុន ហេង | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា ជុំ សុខុម | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា មាស ម៉ូនីកា | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា ឡឹក ពេញចិត្ត | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា សៀក ឆាយគីម | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសក បញ្ញា | សមាជិកកិត្តិយស និងឧបការគុណ |
| ឧបាសិកា កែវ កល្យាណ | ជាសមាជិកសកម្ម |
| ឧបាសិកា ឡេង ធីតា | ជាសមាជិកសកម្ម |
| ឧបាសិកា ម៉ៅ នី | ជាសមាជិកសកម្ម |
| ឧបាសិកា ហេង ចន្ទបុញ្ញាវតី | ជាសមាជិកសកម្ម |
| ឧបាសក ហុង សុវណ្ណារិទ្ធ | ជាសមាជិកសកម្ម |
| ឧបាសក ហុង សុវណ្ណារ៉េត | ជាសមាជិកសកម្ម |

# មាតិកាធម៌

មាតិកា លេខទំព័រ

ខន្ធ .................................................... ១
អ្វីជាបញ្ញា .................................................... ២
ឈ្មោះថាបញ្ញាព្រោះអត្ថដូចម្តេច .............................. ២
អ្វីជាលក្ខណៈ ។បេ។ របស់បញ្ញា .............................. ៥
កថាពណ៌នាពោលដោយបញ្ញា .............................. ៦
បញ្ញាមានប៉ុន្មានយ៉ាង .............................................. ១៤
បញ្ញា ២ .................................................... ១៤
បញ្ញា ៣ .................................................... ១៦
បញ្ញា ៤ .................................................... ១៨
អត្ថប្បដិសម្ភិទា ............................................ ១៩
ធម្មប្បដិសម្ភិទា ............................................ ១៩
និរុត្តិប្បដិសម្ភិទា ............................................ ២១
បដិភាណប្បដិសម្ភិទា ........................................ ២១
ភូមិបដិសម្ភិទាមាន ២ ........................................ ២១
បដិសម្ភិទាផ្សំផ្សងដោយអាការ ៥ .............................. ២២
កថាពណ៌នាដោយប្រភេទរបស់បញ្ញា .............................. ២៤

បញ្ញានឹងគប្បីបំពេញឡើងបានដូចម្តេច ...................... ៤០

ពណ៌នាការចែកភូមិ មូល និងសរីរៈនៃបញ្ញា .............. ៤១

ភូមិរបស់បញ្ញា ...................................................... ៤៣

អធិប្បាយភូមិរបស់បញ្ញា ........................................ ៤៤

ឧបាទាយរូប ........................................................ ៤៨

អធិប្បាយឧបាទាយរូប ........................................... ៥៥

គោចររូប ៤ ........................................................ ៧១

អធិប្បាយគោចររូប ៤ ............................................ ៧២

ភាវរូប ២ ............................................................ ៧៣

អធិប្បាយភាវរូប ២ ................................................ ៧៤

ជីវិតរូប ១ .......................................................... ៧៧

អធិប្បាយជីវិតរូប ១ .............................................. ៧៩

ហទយរូប ............................................................ ៨១

អធិប្បាយហទយរូប ................................................ ៨២

វិញ្ញត្តិរូប ២ ....................................................... ៨៥

អធិប្បាយវិញ្ញត្តិរូប ២ ........................................... ៨៧

បរិច្ឆេទរូប ១ ..................................................... ៩៣

អធិប្បាយបរិច្ឆេទរូប ១ ......................................... ៩៤

វិការរូប ៣ .......... ៩៦

អធិប្បាយវិការរូប ៣ .......... ៩៨

លក្ខណរូប ៤ .......... ១០០

អធិប្បាយលក្ខណរូប ៤ .......... ១០២

ឱជារូប .......... ១០៦

អធិប្បាយឱជារូប .......... ១០៧

ឧបាទាយរូបបន្ថែមតាមមតិកេចិអាចារ្យ .......... ១០៨

អធិប្បាយឧបាទាយរូបបន្ថែមតាមមតិកេចិអាចារ្យ .......... ១០៩

រូប ១ .......... ១១៣

អធិប្បាយរូប ១ .......... ១១៤

រូប ២ .......... ១១៥

អធិប្បាយរូប ២ .......... ១១៧

រូប ៣ .......... ១១៩

អធិប្បាយរូប ៣ .......... ១២១

រូប ៤ .......... ១២៣

អធិប្បាយរូប ៤ .......... ១២៤

រូប ៥ .......... ១២៨

អធិប្បាយរូប ៥ .......... ១៣០

វិញ្ញាណក្ខន្ធ ........................................................ ១៣៥
អធិប្បាយវិញ្ញាណក្ខន្ធ ........................................... ១៥៣
វេទនាខន្ធ ............................................................ ២០០
អធិប្បាយវេទនាខន្ធ ................................................ ២០៣
សញ្ញាខន្ធ ............................................................ ២១០
អធិប្បាយសញ្ញាខន្ធ ................................................ ២១២
សង្ខារក្ខន្ធ ........................................................... ២១៤
អធិប្បាយសង្ខារក្ខន្ធ ................................................ ២៣៩
ចែកខន្ធដោយកាលតាមន័យព្រះសូត្រ ........................ ២៦៩
អធិប្បាយចែកខន្ធដោយកាលតាមន័យព្រះសូត្រ .......... ២៨០
ន័យសម្រាប់វិនិច្ឆ័យខន្ធ ៦ ប្រការ ............................ ២៩៩
អធិប្បាយន័យសម្រាប់វិនិច្ឆ័យខន្ធ ៦ ប្រការ .............. ៣០៧
អាយតនៈ ............................................................... ៣២០
អធិប្បាយអាយតនៈ ................................................. ៣២៩
ធាតុ ...................................................................... ៣៤២
អធិប្បាយធាតុ ........................................................ ៣៥៣
ឥន្ទ្រិយ ................................................................. ៣៦៨
អធិប្បាយឥន្ទ្រិយ ..................................................... ៣៧៥

សច្ចៈ ........................................................ ៣៨៦
អធិប្បាយសច្ចៈ ........................................................ ៣៩៧
ជាតិទុក្ខ ........................................................ ៤១១
អធិប្បាយជាតិទុក្ខ ........................................................ ៤១៨
ជរាទុក្ខ ........................................................ ៤២៣
អធិប្បាយជរាទុក្ខ ........................................................ ៤២៥
មរណទុក្ខ ........................................................ ៤២៦
អធិប្បាយមរណទុក្ខ ........................................................ ៤២៨
សោកៈ ........................................................ ៤៣០
អធិប្បាយសោកៈ ........................................................ ៤៣១
បរិទេវៈ ........................................................ ៤៣២
អធិប្បាយបរិទេវៈ ........................................................ ៤៣៣
ទុក្ខ ........................................................ ៤៣៤
អធិប្បាយទុក្ខ ........................................................ ៤៣៥
ទោមនស្ស ........................................................ ៤៣៦
អធិប្បាយទោមនស្ស ........................................................ ៤៣៧
ឧបាយាស ........................................................ ៤៣៨
អធិប្បាយឧបាយាស ........................................................ ៤៣៩

អប្បិយសម្បយោគទុក្ខ .............................................. ៤៤០
អធិប្បាយអប្បិយសម្បយោគទុក្ខ ............................... ៤៤១
បិយវិប្បយោគទុក្ខ ..................................................... ៤៤២
អធិប្បាយបិយវិប្បយោគទុក្ខ ...................................... ៤៤៣
ឥច្ឆិតាលាភទុក្ខ ........................................................ ៤៤៤
អធិប្បាយឥច្ឆិតាលាភទុក្ខ ........................................... ៤៤៥
បញ្ចុបាទានក្ខន្ធទុក្ខ ..................................................... ៤៤៦
អធិប្បាយបញ្ចុបាទានក្ខន្ធទុក្ខ ...................................... ៤៤៨
ទុក្ខសមុទយៈ ........................................................... ៤៥០
អធិប្បាយទុក្ខសមុទយៈ .............................................. ៤៥១
ទុក្ខនិរោធ ............................................................... ៤៥៣
អធិប្បាយទុក្ខនិរោធ .................................................. ៤៦០
ទុក្ខនិរោធគាមិនីបដិបទា ............................................. ៤៨០
អធិប្បាយទុក្ខនិរោធគាមិនីបដិបទា .............................. ៤៨៩
ដោយប្រភេទផ្សេងៗ មានតែម្យ៉ាងជាដើម ..................... ៥០៦
អធិប្បាយដោយប្រភេទផ្សេងៗ មានតែម្យ៉ាងជាដើម ....... ៥១២

# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

## ១ឆ្ននិទ្ទេស

ឥឡូវនេះ ព្រោះហេតុដែលសមាធិ ព្រះមានព្រះភាគ ទ្រង់សម្ដែងចែកទុកដោយមាតិកា គឺចិត្ត ក្នុងបាទព្រះគាថា ( ត្រង់និក្ខេបៈទុកខាងដើម ) ថា **សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ...** នោះ ជាការដែលភិក្ខុប្រកបព្រមដោយសមាធិភាវនាដែលមិនញាប់ញ័រ មានអានិសង្សដែលបានទទួលហើយ ដោយភាព ( ដែលបានសម្រេច ) អភិញ្ញាដូចពោលមកនេះ បានបំពេញស្រេចហើយ ដោយអាការទាំងពួង ។ ឯបញ្ញាដែលនៅក្នុងលំដាប់នៃសមាធិនោះ ភិក្ខុដែលប្រកបព្រមដោយសមាធិភាវនានោះហើយ គប្បីបំពេញ ( តទៅ ) តែបញ្ញានោះ ព្រោះទ្រង់សម្ដែងទុកសង្ខេបពេក ដូច្នោះក៏មិនជាការងាយ សូម្បីតែនឹងយល់ ( ទៅហើយ ) នឹងពោលថ្វីដល់ការបំពេញនោះ ព្រោះហេតុនោះ ដើម្បីនឹងសម្ដែងភាពពិស្ដារនៃបញ្ញានោះ និងន័យ ( វិធី ) ក្នុងការបំពេញផង ទើបមានបញ្ហាកម្ម ដូច្នេះ គឺ

១- អ្វីជាបញ្ញា ?

២- ឈ្មោះថាបញ្ញា ព្រោះអត្ថដូចម្ដេច ?

៣- អ្វីជាលក្ខណៈ ជារស ជាបច្ចុប្បដ្ឋាន និងបទដ្ឋានរបស់បញ្ញានោះ ?

៤- បញ្ញាមានប៉ុន្មានយ៉ាង ?

៥- បញ្ញាគប្បីបំពេញបានដូចម្ដេច ?

៦- អ្វីជាអានិសង្សនៃការបំពេញបញ្ញា ?

តទៅនេះជាពាក្យវិសជ្ជនាក្នុងបញ្ហាកម្មនោះ

## ១-អ្វីជាបញ្ញា

បញ្ហាកម្មដំបូងថា អ្វីជាបញ្ញានោះ មានវិសជ្ជនាថា បញ្ញាមានច្រើនយ៉ាងច្រើនប្រការ ដែលនឹងវិសជ្ជនា ព្យាយាមចង្អុលបង្ហាញបញ្ញានោះតទៅគ្រប់យ៉ាង នឹងមិនគប្បីញុំាងប្រយោជន៍ ដែលបំណងឲ្យសម្រេច ទាំងនឹងគប្បីប្រព្រឹត្តទៅដើម្បីភាពស្មុគស្មាញក្រៃលែងឡើងផង ព្រោះដូច្នោះ ខ្ញុំនឹងពោលសំដៅយកបញ្ញា ដែលបំណងក្នុងទីនេះប៉ុណ្ណោះ គឺ **វិបស្សនាញាណ** ដែលសម្បយុត្តដោយកុសលចិត្ត នោះឯងជាបញ្ញា ។

## ២- ឈ្មោះថាបញ្ញាព្រោះអត្ថដូចម្តេច

បញ្ហាកម្មទី ២ ថា ឈ្មោះថា **បញ្ញា** ព្រោះអត្ថដូចម្តេច ? មានវិសជ្ជនាថា ធម្មជាតិដែលបានឈ្មោះថា **បញ្ញា** ព្រោះអត្ថថា **ដឹងទូទៅ** ឯការដឹងទូទៅនេះ គឺដឹងអ្វី គឺដឹងដោយប្រការផ្សេងៗ វិសេសជាងអាការដែលដឹង និងអាការដែលដឹងច្បាស់ ពិតណាស់ សូម្បី **សញ្ញា** ( ការសម្គាល់ ) **វិញ្ញាណ** ( ការដឹងច្បាស់ ) និង **បញ្ញា** ( ការដឹងទូទៅ ) ជាការដឹងដូចគ្នា តែសញ្ញាគ្រាន់តែជាការសម្គាល់អារម្មណ៍ថា រូបនោះ មានពណ៌ខៀវ មានពណ៌លឿងជាដើមប៉ុណ្ណោះ មិនអាចឲ្យដល់នូវភាពយល់គ្រប់វត្ថុ គឺពិចារណាលក្ខណៈ គឺ **អនិច្ចំ ទុក្ខំ អនត្តា** បានឡើយ ។ វិញ្ញាណដឹងអារម្មណ៍ថា រូបខៀវ លឿងជាដើមផង ធ្វើឲ្យដល់នូវការយល់គ្រប់វត្ថុ ពិចារណាលក្ខណៈផង តែមិនអាចខំបញ្ចាំងឲ្យដល់នូវការកើតប្រាកដឡើងនៃមគ្គបាន ។ ចំណែកបញ្ញាដឹងអារម្មណ៍ និងធ្វើឲ្យដល់នូវការយល់ចូលចិត្តគ្រប់វត្ថុ គឺពិចារណាលក្ខណៈ តាមន័យដែលពោលហើយផង ខំបញ្ចាំងឲ្យដល់នូវការកើតប្រាកដឡើងនៃមគ្គបានផង ឧបមាដូចបុគ្គល ៣ នាក់ គឺបុគ្គលម្នាក់

ជាទារក មិនទាន់ដឹងក្តី ម្នាក់ជាបុរសអ្នកស្រុក ម្នាក់ជាហេរញ្ញិក សម្លឹងមើលគំនរកហាបណៈដែលតាំងទុកលើបន្ទះក្តាររបស់ហេរញ្ញិក ទារកដែលមិនទាន់ដឹងក្តី ដឹងតែភាពល្អប្លែកៗ វែង ខ្លី ៤ ជ្រុង មូលនៃកហាបណៈទាំងឡាយប៉ុណ្ណោះ មិនដឹងថា វត្ថុនេះគេសន្មតគ្នាថា ជាកែវ ជាគ្រឿង ( ទិញដូរ ) ឧបភោគ និងបរិភោគនៃមនុស្សទាំងឡាយបាននោះឡើយ បុរសអ្នកស្រុកដឹងនូវភាពស្រស់ស្អាតប្លែកៗ ជាដើមផង ដឹងវត្ថុនេះគេសន្មតគ្នាថា ជាកែវ ជាគ្រឿងរបស់ (ទិញដូរ) ឧបភោគ និងបរិភោគនៃមនុស្សទាំងឡាយបានផង តែមិនដឹង គឺបែកមិនបានយ៉ាងនេះថា កហាបណៈនេះពិត កហាបណៈនេះក្លែងក្លាយ កហាបណៈនេះលាយ មានសាច់ប្រាក់ពាក់កណ្តាលជាដើម ហេរញ្ញិកដឹងប្រការទាំងពួងនោះគ្រប់យ៉ាង កាលដឹងសោត សូម្បីសម្លឹងមើលកហាបណៈក៏ដឹង សូម្បីស្តាប់សំឡេងកហាបណៈដែលគេគោះក៏ដឹង សូម្បីហិតក្លិនមើលក៏ដឹង សូម្បីលិទ្ធរសមើលក៏ដឹង សូម្បីថ្លឹងមើលដោយដៃក៏ដឹង ហេរញ្ញិកនោះដឹងផងថា កហាបណៈនោះធ្វើត្រង់ស្រុកឈ្មោះនោះ ឬត្រង់និគម ត្រង់នគរ ត្រង់ភ្នំ ឬត្រង់ច្រាំងស្ទឹងឈ្មោះនោះៗ និងថែមទាំងដឹងថា អាចារ្យឈ្មោះនោះធ្វើដូច្នេះ យ៉ាងណា សេចក្តីឧបមេយ្យនេះក៏គប្បីជ្រាបយ៉ាងនោះ ៗ មែនពិត **សញ្ញា** ( ការសម្គាល់ ) ក៏ប្រៀបដូចការសម្លឹងមើលកហាបណៈនៃកុមារដែលមិនទាន់ដឹងក្តី ព្រោះកាន់យកត្រឹមតែអាការដែលប្រាកដនៃអារម្មណ៍ ដោយភាពជាពណ៌ខៀវជាដើម **វិញ្ញាណ** (ការដឹងច្បាស់) ដូចជាការមើលកហាបណៈនៃបុរសអ្នកស្រុក ព្រោះកាន់អាការនៃអារម្មណ៍ ( ដែលប្រាកដ) ដោយភាពជាពណ៌ខៀវជាដើមផង ឲ្យដល់នូវការយល់ដល់វត្ថុ គឺពិចារណាលក្ខណៈ

ខ្ពស់ឡើងទៅ ក៏បានផង **បញ្ញា** ដូចជាការមើលកហាបណៈនៃហេរញ្ញិក ព្រោះកាន់យកអាការនៃអារម្មណ៍ ដោយភាពជាពណ៌ខៀវជាដើមក៏បាន នឹងឲ្យដល់នូវការយល់ទូទៅ គឺពិចារណានូវលក្ខណៈក៏បានផង សូម្បីឲ្យដល់នូវភាពកើតប្រាកដនៃមគ្គខ្ពស់ឡើងទៅជាងនោះក៏បានផង ព្រោះហេតុនោះ ការដឹងដោយប្រការផ្សេងៗ ពិសេសជាង អាការដែលស្គាល់ និងអាការដែលដឹងច្បាស់នោះ ការដឹងនេះឯងគប្បីជ្រាបថាជាការដឹងទូទៅ ពាក្យថា **ឈ្មោះថាបញ្ញា** ព្រោះអត្ថថា ដឹងទូទៅនោះ ខ្ញុំពោលសំដៅយកការដឹងទូទៅនេះឯង ។

ឯបញ្ញានេះ សញ្ញា និងវិញ្ញាណមាននៅក្នុងចិត្តុប្បាទណា បញ្ញាមិនមែនមានក្នុងចិត្តុប្បាទនោះ ដោយចំណែកមួយដែរនោះទេ តែកាលណាបញ្ញាមាន កាលនោះក៏ញែកចាកធម៌ ( គឺសញ្ញា និងវិញ្ញាណ ) ទាំងនោះមិនបាន ទើបជាធម្មជាតិដែលល្អិតឃើញបានដោយលំបាក ព្រោះមានការផ្សេង ដែលនឹងគប្បីញែកចេញមិនបានថា នេះសញ្ញា នេះវិញ្ញាណ នេះបញ្ញា ព្រោះហេតុនោះ ទើបព្រះនាគសេនថ្វាយព្រះពរ ព្រះបាទមិលិន្ទថា មហាបពិត្រ កិច្ចដែលធ្វើបានដោយលំបាក ព្រះសាស្តាទ្រង់បានធ្វើហើយ ព្រះបាទមិលិន្ទត្រាស់បញ្ជាក់ថា ព្រះនាគសេនដ៏ចម្រើន កិច្ចដែលធ្វើបានដូចម្តេច ដែលព្រះមានព្រះភាគទ្រង់បានធ្វើហើយ ? ព្រះនាគសេនថ្វាយវិសជ្ជនាថា មហាបពិត្រ កិច្ចដែលធ្វើបានដោយលំបាក ដែលព្រះមានព្រះភាគទ្រង់បានធ្វើ គឺត្រាស់ប្រាប់ការកំណត់ញែកធម៌ទាំងឡាយ ដែលមិនមានរូប គឺចិត្ត និងចេតសិកទាំងនេះ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍តែមួយជាមួយគ្នាថា នេះផស្សៈនេះវេទនា នេះសញ្ញានេះចេតនា នេះចិត្ត

ដូច្នេះ ។

## ៣-អ្វីជាលក្ខណៈ ។បេ។ របស់បញ្ញា

ចំណែកក្នុងបញ្ហាកម្មប្រការទី ៣ នេះថា អ្វីជាលក្ខណៈ ជារស ជាបច្ចុប្បដ្ឋាន និងជាបទដ្ឋានរបស់បញ្ញានោះ មានវិសជ្ជនាថា បញ្ញាមានការត្រាស់ដឹងសភាវធម៌ ជាលក្ខណៈ មានការកម្ចាត់បង់នូវភាពងងឹត គឺមោហៈដែលបិទបាំងនូវសភាវធម៌ ទាំងឡាយជារស (គឺជាកិច្ច) មានការមិនវង្វេងជាបច្ចុប្បដ្ឋាន ( គឺជាគ្រឿងប្រាកដ ឬជាផល ) ចំណែកសមាធិចាត់ជាបទដ្ឋាន ( គឺហេតុជិត ) របស់បញ្ញានោះ ដោយព្រះបាលីថា **សមាហិតោ យថា ភូតំ ជានាតិ បស្សតិ** បុគ្គលមានចិត្តជាសមាធិ រមែងឃើញតាមសេចក្តីពិត ។

# មហាដីកា

## ពណ៌នាឧទ្ទេសនិទ្ទេស

## កថាពណ៌នាពោលដោយបញ្ញា

ពាក្យថា **ដោយអាការទាំងពួង** គឺដោយអាការនៃការចម្រើនទាំងពួង មានអាទិយ៉ាងនេះ គឺអាការ គឺឧបចារៈ អាការ គឺអប្បនា អាការ គឺវសីភាវៈ អាការ គឺការឈានកន្លងអង្គឈាន មានវិតក្កជាដើម អាការ គឺការប្រាសចាកតម្រេកអំពីរូបធម៌ជាដើម អាការ គឺការទូន្មានចិត្ត ១៤ យ៉ាង អាការ គឺការសម្រេចអានិសង្ស ៥ យ៉ាង ។

បទថា **តទនន្តរា** សេចក្តីថា ក្នុងលំដាប់នៃសមាធិនោះ ដោយលំដាប់នៃទេសនាយ៉ាងនេះថា **ចិត្តំ បញ្ញំ** និងដោយលំដាប់នៃការបដិបត្តិ ។ សម្ពន្ធសេចក្តីថា ភិក្ខុប្រកបដោយសមាធិភាវនា គប្បីចម្រើនបញ្ញា ។ **ខាងដើមមិនមែនធ្វើបានងាយឡើយ សូម្បីដោយការយល់** ដោយសភាវៈថា នេះ គឺបញ្ញានោះ **ព្រោះព្រះសាស្តាទ្រង់សម្តែងទុកដោយបង្រួញពន់ពេក** យ៉ាងនេះថា ចម្រើនបញ្ញាខ្លះ ព្រោះលោកអាចារ្យបានពោលទុកក្នុងវណ្ណនានៃគាថា ដោយបង្រួញពន់ពេកយ៉ាងនេះថា សស្រ្តា គឺវិបស្សនាបញ្ញាដែលសំលៀងល្អហើយដោយថ្ម គឺសមាធិ សម្ពន្ធសេចក្តីថា មិនមែនធ្វើបានងាយឡើយ ដើម្បីនឹងចម្រើនមុននោះឯង ព្រោះលោកមិនបានសម្តែងវិធីចម្រើនទុក ។ ឈ្មោះថាបញ្ហា ដោយអត្ថថា សួរ, កម្ម គឺកិរិយា បានដល់ ការធ្វើ, កម្ម គឺបញ្ហា ឈ្មោះថា **បញ្ហាកម្ម,** អធិប្បាយថា ប្រយោគ គឺការសួរ ។

ពីរបទថា **កា បញ្ញា** បានដល់ ការសួរដោយសរុប ។ ពីរបទថា **កេនដ្ឋេន បញ្ញា** សេចក្តីថា ដែលហៅថា បញ្ញា ដោយអត្ថដូចម្តេច ? អធិប្បាយថា បទថា **បញ្ញា** អាស្រ័យអត្ថន័យដែលគប្បីពោលចំពោះអ្វីដែលនឹងប្រព្រឹត្តទៅ ។ បញ្ញានេះ គប្បីដឹង

បានដូចម្ដេច ? ដោយសភាវៈ ដោយកិច្ច ដោយអាការប្រាកដ និងដោយហេតុជិត ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **អ្វីជាលក្ខណៈ រស បច្ចុប្បដ្ឋាន និងបទដ្ឋាននៃបញ្ញានោះ** ។ បទថា **កតិវិធា** ជាពាក្យសួរដល់ប្រភេទ ។ ក្នុងបញ្ហាកថានេះ ហេតុអ្វីទើបលោកអាចារ្យមិនកាន់យកពាក្យសួរដល់ការសៅហ្មង និងការផូរផង់ផង ? ឆ្លើយថា ខាងដើមបញ្ញាដែលជាលោកុត្តរមិនមានភាពសៅហ្មងនោះឯង ។ កាលមិនមានការសៅហ្មងនោះ នឹងមានពាក្យសួរដល់ភាពផូរផង់មកអំពីណា ព្រោះដូច្នោះ ទើបលោកអាចារ្យមិនកាន់យកទាំងពីរយ៉ាងនោះ ។ ចំណែកបញ្ញាដែលជាលោកិយ ការសៅហ្មងនិងការផូរផង់ទាំងនោះ លោកអាចារ្យក៏មិនបានកាន់យកទុកជាផ្នែកមួយ សង្គ្រោះចូលក្នុងមគ្គាមគ្គញាណទស្សនវិសុទ្ធិ ដោយអធិប្បាយថា សង្គ្រោះចូលក្នុងវិធីចម្រើននោះឯង ។ មួយវិញទៀត លោកអាចារ្យមិនបានកាន់យក ព្រោះគប្បីជ្រាបតាមគន្ថន័យដែលពោលហើយ ក្នុងការចម្រើនសមាធិ ។ ធម្មតាការបដិបត្តិរមែងមានក្នុងអានិសង្សដែលបានឃើញនោះឯង ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ការចម្រើនភាវនា មានអានិសង្សដូចម្ដេច** ? ធម្មតាការបដិបត្តិរមែងមានក្នុងអានិសង្សដែលបានឃើញហើយនោះឯង ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ការចម្រើនភាវនា មានអានិសង្សដូចម្ដេច** ?

បទថា **តត្រ** ប៉ុន្តែគ្មានឹង **តស្មឹ** ឬប៉ុន្តែគ្មានឹង **តស្ស** ប្រែថា ក្នុងបញ្ហាកម្មនោះ ឬនូវបញ្ហាកម្មនោះ ។ បទថា **វិស្សជ្ជនំ** សេចក្ដីថា ការបើកផ្សារ ។ ពិតណាស់ អត្ថន័យដែលត្រូវសួរហើយ ជាអត្ថន័យដែលអាថ៌កំបាំង ព្រោះមិនបានធ្វើឲ្យជាក់ច្បាស់ រមែងតាំងនៅដូចក្ដាប់ទុកក្នុងដៃ ការបើកផ្សារអត្ថន័យនោះ ឈ្មោះថា ជាការវិសជ្ជនា ព្រោះការធ្វើឲ្យជាអត្ថន័យប្រាកដច្បាស់ ។ ឯពាក្យថា **អ្វី** ឈ្មោះថា **បញ្ញា** ? នេះជាពាក្យសួរដោយសរុបពិតៗ សូម្បីយ៉ាងនោះ ការអធិប្បាយសភាវៈរបស់ធម៌ដែល

មានវិភាគទាំងឡាយរមែងសម្រេចដោយមាតិកា គឺការសម្តែងវិភាគនោះឯង ព្រោះដូច្នោះ វិភាគគួរសម្តែងដោយមិនមានសេសសល់មុន ។ លោកអាចារ្យពោលពាក្យឆ្លើយថា **បញ្ញាមានច្រើនយ៉ាង** ដូច្នេះជាដើម ដើម្បីនឹងសម្តែងថា ក៏ដោយការសម្តែងវិភាគរបស់បញ្ញានោះនឹងមានទោស ដូច្នេះ ។ បណ្តាបទទាំងនោះ ពាក្យថា **មានច្រើនយ៉ាង** សេចក្តីថា មានច្រើនយ៉ាង ដោយអំណាចកុសលបញ្ញាជាដើម ។ ពាក្យថា **មានប្រការផ្សេងៗ** គឺមានច្រើនយ៉ាង ដោយប្រភេទនៃបញ្ញា មាន **អត្ថ ជាបិកាបញ្ញា** គឺបញ្ញាដែលឲ្យកើតប្រយោជន៍ជាដើមនិងដោយប្រភេទនៃញាណមានសុតមយញ្ញាណជាដើម ។ ពីរបទថា **តំ សព្វំ** ប្រែថា វិភាគនៃបញ្ញាមិនមាន ចំណែកសល់នោះ ។ ពាក្យថា **មិនគប្បីញ៉ាំងប្រយោជន៍ឲ្យសម្រេច** សេចក្តីថា មគ្គភាវនា និងវិបស្សនាភាវនាជាប្រយោជន៍ដែលបំណងយកក្នុងទីនេះ ។ ឯការក្តារ ជជ: គឺតណ្ហា រមែងមានដោយមគ្គភាវនានោះ ឯ ( ការវិសជ្ជនា ) មិនគប្បីញ៉ាំងប្រយោជន៍ ដែលបំណងនោះឲ្យសម្រេច ។ ឯលោកអាចារ្យវិសជ្ជនាប្រភេទនៃបញ្ញា ដោយមិនមានសេសសល់ប្រភេទនៃបញ្ញា ដែលមកហើយក្នុងព្រះគម្ពីរញាណវត្ថុវិភង្គទាំងអស់ ដែលមានពាក្យផ្តើមថា **ឯកវិធេន ញាណវត្ថុ** និងដែលមកហើយក្នុងបាឋ:នោះៗ ក្នុងព្រះសូត្រទាំងឡាយក្តី ។ ន័យដែលមកក្នុងព្រះអភិធម្មទាំងអស់ក្តី ក៏ប្រពៃ ដែលលោកអាចារ្យនឹងគប្បីនាំមកវិសជ្ជនាផង ហើយកាលបើដូច្នោះ ក៏នឹងមិនគប្បីមានឱកាសឡើយ ដែលនឹងវិសជ្ជនាវិធីនៃបញ្ញាភាវនាដែលបំណងយកក្នុងទីនេះ ។ ពាក្យបន្តិចបន្តួចនៅមានទៀត សូម្បីការផ្សេងគ្នានៃការកើតរបស់បញ្ញាក្នុងវិស័យ មានឋាន: អឋាន: កម្មជទៃ វិបាកជទៃជាដើម ក៏នឹងគប្បីជាប្រការដែលលោកអាចារ្យ គប្បីវិសជ្ជនាចែកដោយភាពផ្សេងគ្នានៃផលតូចផលធំតាមសមគួរ ។ ឯការផ្សេងគ្នានៃការកើតរបស់បញ្ញានោះ កាលអាចារ្យកំពុងវិសជ្ជនា ក៏នឹងគប្បីប្រព្រឹត្តទៅ ដើម្បីភាពស្មុគស្មាញដោយពិត ទាំងនេះព្រោះមិន

នៅក្នុងវិស័យ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **គប្បីប្រព្រឹត្តទៅដើម្បីភាពស្អុតស្អាញក្រៃលែងឡើង** ។ ដោយ កុសល-ស័ព្ទ ក្នុងពាក្យថា **វិបស្សនាញាណដែលសម្បយុត្តដោយកុសលចិត្ត** នេះ លោកអាចារ្យរមែងហាមបង់នូវបញ្ញាដែលជាអព្យាកតៈទាំង ២ យ៉ាង ម្យ៉ាងទៀត រមែងបដិសេធមិច្ឆាវាទៈដែលប្រព្រឹត្តទៅយ៉ាងនេះថា **បញ្ញាដែលសៅហ្មងក៏មាន** ។ ដោយស័ព្ទថា **វិបស្សនាញាណ** លោកអាចារ្យរមែងហាមនូវបញ្ញាដែលជាកុសលដ៏សេស ។

បទថា **សញ្ជាននវិជាននាការវិសិដ្ឋំ** ប្រែថា ការដឹងដែលមានភាពល្អក្រៃលែងជាងអាការ គឺការចាំបាន និងអាការ គឺការដឹងច្បាស់ ។ ព្រោះ **ការដឹងដោយប្រការផ្សេងៗ** គឺការៈដែលដឹង គឺអាការដែលទទួលអារម្មណ៍បាន ។ ឯការៈនោះរបស់ធម៌ទាំង ៣ នោះ ស្មើគ្នា មិនមែនអាការ មានការចាំបានជាដើម ។ **ឥតិ**-ស័ព្ទ ក្នុងពាក្យថា **បីតកន្តិ** នេះ មានន័យថា ជាដើម ដោយ **ឥតិ**-ស័ព្ទ លោកសង្គ្រោះអាការដែលសញ្ញាគប្បីកាន់យកថា **ក្រហម ស វែង ខ្លី** ជាដើម ។ ការដឹងធ្វើឲ្យ មានសញ្ញាជាហេតុ មានឬមិនមានក្នុងអារម្មណ៍ជាដើមថា **ខៀវ លឿង** ឈ្មោះថា **ការចាំបាន** ក្នុងសេចក្តីនេះថា **ត្រឹមតែជាការចាំបានប៉ុណ្ណោះ** ។ ពិតយ៉ាងនោះ សញ្ញានេះមានការចាំបានជាបច្ច័យ និងមានការធ្វើឲ្យជានិមិត្តជារស ។ ដោយ **មត្ត**-ស័ព្ទ ដែលមានការហាមសេចក្តីផ្សេងគ្នាជាអត្ថ លោកអាចារ្យរមែងហាមឃាត់នូវអាការ គឺការដឹងច្បាស់ និងការដឹងប្រាកដ ដោយ **ឯវ**-ស័ព្ទ លោកអាចារ្យក៏រមែងឃាត់ថា សូម្បីក្នុងការណាៗ ភាពពិសេសទាំងនោះរបស់សញ្ញានេះក៏មិនមានឡើយ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា **អនិច្ចំ ទុក្ខំ** ជាដើម ។ បណ្តាធម៌ទាំង ៣ យ៉ាងនោះ សញ្ញាកាលមិនអាចធ្វើកិច្ចរបស់វិញ្ញាណបាន នឹងគប្បីធ្វើកិច្ចរបស់បញ្ញាបានអំពីណា ។ ដូច្នោះ ទើបលោកពោលទុកថា **មិនអាចធ្វើឲ្យដល់នូវការចាក់ធ្លុះលក្ខណៈបាន** ដូច្នេះទុកប៉ុណ្ណោះ តែមិនពោល

ថា **មិនអាចឲ្យដល់នូវភាពប្រាកដនៃមគ្គ** ។ វិញ្ញាណដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ រមែងប្រព្រឹត្តទៅ ដោយអំណាចការចាំបាននូវអារម្មណ៍ មានពណ៌ខៀវ និងពណ៌លឿង ជាដើមប៉ុណ្ណោះ ដូចសញ្ញាដែលប្រព្រឹត្តទៅក្នុងអារម្មណ៍នោះក៏ទេ ដោយពិត រមែង ប្រព្រឹត្តទៅដឹងនូវការផ្សេងគ្នាដទៃក្នុងអារម្មណ៍នោះផង ដូច្នោះ ទើបលោកពោលពាក្យ ជាដើមថា **វិញ្ញាណ** ។សួរថា វិញ្ញាណឲ្យដល់ការចាក់ធ្លុះលក្ខណៈបានដូចម្ដេច ?ឆ្លើយ ថា ឲ្យដល់បានដោយមគ្គ ដែលបញ្ញាឃើញហើយ ។ ពិតហើយ វិបស្សនារមែងមាន សូម្បីដោយចិត្តដែលជាញាណវិប្បយុត្ត ដោយអំណាចភាពស្និទ្ធស្នាល ព្រោះវិបស្សនា ដែលមានលក្ខណៈជាអារម្មណ៍ចាក់ធ្លុះហើយចាក់ធ្លុះទៀត នូវលក្ខណៈច្រើនវារៈប្រព្រឹត្ត ទៅ ជាធម្មជាតិដែលមានការស្ទាត់ជំនាញ ដូចគ្នាក្នុងការដែលស្វាធ្យាយគម្ពីរស្ទាត់ជំនាញ ហើយ វារៈ សូម្បីមកហើយដោយត្រឹមត្រូវបុគ្គលស្វាធ្យាយ ក៏មិនដឹង ។ ឯពាក្យថា **លក្ខណបដិវេធំ** លោកពោលសំដៅត្រឹមតែការធ្វើលក្ខណៈឲ្យជាអារម្មណ៍ មិនបាន ពោលសំដៅដល់ការចាក់ធ្លុះ ។ បទថា **ឧស្សក្កិត្វា** សេចក្ដីថា ប្រមូលមកតាមលំដាប់ **ឧទយព្វយញ្ញាណ** ។ ឈ្មោះថា **មិនអាចឲ្យដល់នូវភាពប្រាកដនៃមគ្គ** ព្រោះមិនមែន មានការត្រាស់ដឹងជាសភាវៈ ។ ពាក្យថា **ដោយអំណាចន័យដែលពោលមកហើយ** សេចក្ដីថា រមែងដឹងអារម្មណ៍ដោយអំណាចន័យដែលពោលហើយក្នុងវិញ្ញាណ និង ឲ្យដល់នូវការចាក់ធ្លុះលក្ខណៈ ។ម្យ៉ាងទៀត **ញ៉ាំងឲ្យឈានទៅដល់ភាពប្រាកដនៃមគ្គ** ដោយអានុភាពដែលជាអនញ្ញសាធារណៈរបស់ខ្លួន ។

ឥឡូវនេះ លោកអាចារ្យនឹងញ៉ាំងអត្ថន័យតាមដែលពោលហើយ ឲ្យតាំងនៅ បានចំពោះដោយឧបមា ទើបពោលពាក្យថា **យថា ហិ** ដូច្នេះជាដើម ។ បណ្ដាបទ ទាំងនោះ បទថា **អជាតពុទ្ធិ** សេចក្ដីថា ដែលនៅមិនទាន់កើតការដឹងក្នុងការដោះ ដូរតម្លៃ ។ បទថា **ឧបភោគបរិភោគំ** សេចក្ដីថា គួរដល់គ្រឿងឧបភោគ និងបរិភោគ

អធិប្បាយថា គួរដល់ការបានមកនូវវត្ថុដែលជាគ្រឿងឧបភោគ និងវត្ថុ ដែលជាគ្រឿងបរិភោគ ។ ពាក្យថា **ពិត** បានដល់ មានតម្លៃច្រើន ។ ពាក្យថា **ក្លែងក្លាយ** បានដល់ ធ្វើកហាបណៈក្លែងក្លាយ គឺធ្វើដោយទង់ដែង និងសំរឹទ្ធជាដើម ។ពាក្យថា **មានតម្លៃពាក់កណ្តាល** បានដល់ មានតម្លៃពាក់កណ្តាល ។ **ឥតិ-ស័ព្ទ** មានអាទិ៍ជាអត្ថ ។ ដោយឥតិស័ព្ទនោះសង្គ្រោះប្រាក់ដែលមានតម្លៃមួយបាទ ប្រាក់ដែលមានតម្លៃប៉ុនគ្នានឹងមួយបាទ និងប្រាក់ដែលមានតម្លៃទាបជាងមួយបាទ ។ ពាក្យថា **ប្រការទាំងនោះ** បានដល់ ប្រការ មានផ្កាឈើក្លែងក្លាយ និងផ្កាឈើពិតប្រាកដជាដើម និងប្រការដែលមានប្រាក់ពិត ( សុទ្ធ ) ជាដើម ។

ពាក្យថា **សញ្ញា ហិ** ជាដើម ជាពាក្យប្រៀបធៀបជាមួយពាក្យឧបមា ។ គប្បីឃើញថា **សញ្ញា** លោកពោលថា ដូចការមើលកហាបណៈរបស់កូនក្មេង ព្រោះកាន់យកអារម្មណ៍ ដោយអំណាចរួមគ្នាតែម្យ៉ាង មិនបានធ្វើការបែក ។ ពិតយ៉ាងនោះ សញ្ញានោះលោកពោលថា មានអារម្មណ៍តាមដែលប្រាកដជាបទដ្ឋាន ។ **វិញ្ញាណ** លោកពោលថា ដូចការមើលកហាបណៈរបស់បុរសអ្នកស្រុក ព្រោះអាចកាន់យកភាពពិសេសខ្លះៗ ក្នុងអារម្មណ៍បាន ។ **បញ្ញា** លោកពោលទុក ដូចការមើលប្រាក់របស់ហេរញ្ញិក ព្រោះស្ទង់ដឹងដល់ភាពផ្សេង មិនមានចំណែកសេសសល់ក្នុងអារម្មណ៍ ។ ដោយពាក្យថា **ការដឹងដោយប្រការផ្សេងៗ** នេះ លោកអាចារ្យសម្តែងថា ការពិចារណាដឹងតាមសេចក្តីពិតនូវធម៌ដែលគួរដឹងនោះថា ធម៌ដែលគួរដឹងទាំងឡាយតែម្យ៉ាង មានប្រការផ្សេងៗ គ្នា ឈ្មោះថា បញ្ញា ។ សេចក្តីនេះសមដូចភាសិត ដែលព្រះធម្មសេនាបតីសារីបុត្រពោលទុកថា **ធម៌ទាំងពួងរមែងមកកាន់គន្លងក្នុងមុខ គឺព្រះញាណរបស់ព្រះមានព្រះភាគ ដោយប្រការទាំងពួង ដូច្នេះ** ។

បទថា **យត្ថ** ប៉ុនគ្នានឹង **យស្មឹ យោគ ចិត្តុប្បាទេ** ប្រែថា ក្នុងចិត្តុប្បាទណា ។

ពាក្យថា **ន តត្ថ ឯកំសេន ហោតិ** ប្រែថា បញ្ញារមែងមិនមានដោយចំណែកមួយក្នុងចិត្តុប្បាទនោះ ។ ព្រោះក្នុងចិត្តុប្បាទដែលជាទុហេតុកៈ និងអហេតុកៈ មិនមានបញ្ញាកើតឡើងឡើយ ។ បទថា **អវិនិព្ភុត្តា** ប្រែថា មិនបែក ។ បទថា **តេហិ យោគសញ្ញាវិញ្ញាណេហិ** ដែលប្រែថា អំពីសញ្ញា និងវិញ្ញាណទាំងនោះ ។ ដូចសុខ និង បីតិ មិនបែកគ្នាដោយពិតប្រាកដក៏ទេ យ៉ាងណា សញ្ញា វិញ្ញាណ និងបញ្ញាមិនបែកគ្នាដោយពិតប្រាកដ ក៏ដូច្នោះ ។ម្យ៉ាងទៀត បីតិ និងសុខ មិនបែកគ្នាដោយពិតប្រាកដ យ៉ាងណា បញ្ញាក្តី សញ្ញាក្តី និងវិញ្ញាណក្តី ក៏មិនបែកគ្នា ដោយពិតប្រាកដដូច្នោះ ។ ព្រោះដូច្នោះ ក្នុងបណ្តាធម៌ទាំង ៣ យ៉ាងនេះ ដែលមិនបែកគ្នាយ៉ាងនេះ ការញែកធម៌ទាំង ៣ នោះ ទើបធ្វើបានដោយលំបាក ព្រោះហេតុនោះ ទើបលោកលើកឧបមាដូចការមើលកហាបណៈរបស់បុគ្គល ៣ ពួក ។ ដើម្បីនឹងសម្តែងដល់ភាពដែលធម៌ទាំង ៣ មានការផ្សេងគ្នាដែលគប្បីដឹងបានដោយលំបាកនោះឯង សូម្បីដោយពាក្យពោលដទៃ ទើបលោកអាចារ្យពោលពាក្យថា **តេនាហ** ដូច្នេះជាដើម ។ ក្នុងសេចក្តីនោះ លោកអាចារ្យ កាលនឹងសម្តែងថា ខាងដើមសូម្បីក្នុងបណ្តារូបធម៌ទាំងឡាយទឹកក្នុងស៊ីងផ្សេងៗ ក្តី ប្រេងប្រភេទផ្សេងៗ ក្តី ដែលគេដាក់លាយគ្នា ទុកក្នុងភាជនៈជាមួយគ្នា ការដែលនឹងបង្ហាញដោយសរុបបង្ហាញទៅថា **នេះជាទឹករបស់ស៊ីងឈ្មោះនោះ នេះជាប្រេង ប្រភេទនោះ** ដូច្នេះ ជារឿងដែលធ្វើបានដោយលំបាក នឹងពោលទៅថ្វីក្នុងអរូបធម៌ទាំងឡាយនោះ ដូច្នេះ ទើបពោលពាក្យថា **យំ ឥមេសំ អរូបីនំ ចិត្តចេតសិកានំ** ដូច្នេះ ជាដើម ។

ភាវៈរបស់ខ្លួនផង ភាវៈដែលស្មើគ្នាផង នៃធម៌ទាំងឡាយ ឈ្មោះថា **ធម្មសភាវៈ** ។ ក្នុងវិកប្បទាំង ២ នោះ ដោយវិកប្បដំបូង លោកកាន់យកលក្ខណៈរបស់ខ្លួន មានភាពរឹង និងការពាល់ត្រូវជាដើម ដោយវិកប្បប្រការទី ២ លោកកាន់យកសាមញ្ញលក្ខណៈ

មានអនិច្ចតា និងទុក្ខតាជាដើម ។ បញ្ញាមានលក្ខណៈ ចាក់ធ្លុះតាមសេចក្ដីពិតនូវលក្ខណៈទាំង ២ នោះ ព្រោះហេតុនោះ ទើបលោកពោលថា **បញ្ញាមានការចាក់ធ្លុះសភាវៈនៃធម៌ជាលក្ខណៈ** ។ **មានការកម្ចាត់នូវភាពងងឹត គឺមោហៈ** ដែលបិទបាំងសភាវៈនៃធម៌តាមដែលបានពោលមកហើយ **ជារស** ដូចពន្លឺនៃប្រទីបជាដើម កម្ចាត់ភាពងងឹតខាងក្រៅដែលបិទបាំងវត្ថុ មានផ្ទាំងទឹក និងផ្ទាំងសំពត់ជាដើមទុកដូច្នោះ ពិតណាស់ ពន្លឺ គឺបញ្ញាកាលកំពុងកើតឡើងនោះឯង រមែងទម្លាយភាពងងឹតក្នុងហទយៈកើតឡើងយ៉ាងនេះ ព្រោះហេតុនោះឯង ទើបបញ្ញាចូលទៅតាំងទុកចំពោះដោយអាការ គឺការមិនវង្វេងក្នុងសភាវៈនៃធម៌ទាំងឡាយ ហេតុនោះ ទើបឈ្មោះថា **មានអសម្មោហជាបច្ចុប្បដ្ឋាន** ។ ម្យ៉ាងទៀត បញ្ញាជាតួហេតុ រមែងញ៉ាំងអសម្មោហៈដែលជាតួផល ឲ្យចូលទៅតាំងទុកចំពោះខ្លួនឯង ហេតុនោះ ទើបឈ្មោះថា **មានអសម្មោហៈជាបច្ចុប្បដ្ឋាន** យ៉ាងនេះក៏បាន ។ ព្រោះក្នុងទីនេះ លោកមានបំណងយកវិបស្សនាបញ្ញា ទើបលោកអាចារ្យពោលថា **សមាធិជាបទដ្ឋាន របស់បញ្ញានោះ** ។ សេចក្ដីនេះសមដូចព្រះបាលីដែលជាបទព្រះសូត្រមកដោយភាពជានិពន្ធពុទ្ធភាសិតថា **សមាហិតោ យថាភូតំ បជានាតិ បស្សតិ បុគ្គលមានចិត្ត តាំងមាំ រមែងឃើញតាមសេចក្ដីពិត** ដូច្នេះ ។

# វិសុទ្ធិមគ្គ

## ៤-បញ្ញាមានប៉ុន្មានយ៉ាង

បញ្ញាកម្មក្នុងប្រការទី ៤ នេះថា បញ្ញាមានប៉ុន្មានយ៉ាង មានវិសជ្ជនាថា ដោយលក្ខណៈ គឺការត្រាស់ដឹងសភាវធម៌ បញ្ញាក៏មានតែមួយប៉ុណ្ណោះ ។

បញ្ញាមាន ២ យ៉ាង ដោយចែកជាលោកិយ និងលោកុត្តរ ជាពីរយ៉ាងដែរនោះ ចែកដោយជា **សាសវៈ** ( មានអាសវៈ ) **អនាសវៈ** ( មិនមានអាសវៈ ) ជាដើម ដោយចែកជា **នាមវវត្ថាបន** ( កំណត់នាម ) និង **រូបវវត្ថាបន** ( កំណត់រូប ) ដោយចែកជាសោមនស្សសហគតៈ រួមនឹងសោមនស្ស និងឧបេក្ខាសហគតៈ រួមនឹងឧបេក្ខា និងដោយចែកជាទស្សនភូមិ ( ថ្នាក់ឃើញ ) និងភាវនាភូមិ ( ថ្នាក់ចម្រើន ) ។

បញ្ញាមាន ៣ យ៉ាង ដោយចែកជា **ចិន្តាមយៈ សុតមយៈ និងភាវនាមយៈ** ជាបីយ៉ាង ន័យដូចគ្នានោះ ដោយចែកជាបរិត្តារម្មណៈ មហគ្គតារម្មណៈ និងអប្បមាណារម្មណៈ ដោយចែកជាអាយកោសល្ល អបាយកោសល្ល និងឧបាយកោសល្ល និងដោយចែកជាអភិនិវេស ៣ មានអជ្ឈត្តាភិនិវេស ( បំណងប្រាថ្នាខាងក្នុង ) ជាដើម ។

បញ្ញាមាន ៤ យ៉ាង ដោយចែកជាញាណក្នុងអរិយសច្ច ៤ និងដោយបដិសម្ភិទា ( ញាណ ) ៤ ដូច្នេះ ។

ក្នុងចំណែកនៃបញ្ញាទាំងឡាយនោះ ចំណែកនៃបញ្ញា ដែលជាចំណែកមួយមានអត្ថងាយយល់ស្រាប់ហើយ ។

### បញ្ញា ២

ក្នុងចំណែកនៃបញ្ញា ដែលចែកជា ២ យ៉ាង មានអធិប្បាយដូច្នេះ

ក្នុងទុកៈទី ១ បញ្ញាជា ២ យ៉ាង ដោយជាលោកិយ និងលោកុត្តរ ដូច្នេះ

គឺបញ្ញាដែលសម្បយុត្តដោយលោកិយមគ្គ ជាលោកិយបញ្ញា បញ្ញាដែលសម្បយុត្តដោយលោកុត្តរមគ្គ ជាលោកុត្តរបញ្ញា ។

ក្នុងទុកៈទី ២ បញ្ញាដែលជាអារម្មណ៍នៃអាសវៈទាំងឡាយ ( គឺឧបការៈដល់អាសវៈ ) ជាសាសវបញ្ញា បញ្ញាដែលមិនជាអារម្មណ៍នៃអាសវៈទាំងនោះ ( គឺមិនឧបការៈដល់អាសវៈ ) ជាអនាសវបញ្ញា បញ្ញា ២ នេះ ដោយន័យក៏ជាលោកិយបញ្ញា និងលោកុត្តរបញ្ញានោះឯង សូម្បីន័យក្នុងសាសវទុកៈដទៃ ដូចជាបញ្ញាដែលប្រកបជាមួយអាសវៈ ជាសាសវបញ្ញា បញ្ញាដែលមិនប្រកបជាមួយអាសវៈ ជាអនាសវបញ្ញា ដូច្នេះក្តី ក៏មានន័យដូច ( គឺដោយអត្ថជាលោកិយ លោកុត្តរដូចគ្នា ) ដូច្នេះ បញ្ញាជា ២ យ៉ាង ដោយជាសាសវៈ និងអនាសវៈ ។

ក្នុងទុកៈទី ៣ បញ្ញាចែកជា ២ យ៉ាង ដោយជានាមវវត្ថាបន និងរូបវវត្ថាបន ដូច្នេះ គឺបញ្ញាក្នុងការកំណត់នាមខន្ធ ៤ នៃភិក្ខុដែលប្រាថ្នានឹងផ្តើមធ្វើវិបស្សនាឯណា បញ្ញាបែបនេះជានាមវវត្ថាបនបញ្ញា បញ្ញាក្នុងការកំណត់រូបខន្ធ ( នៃភិក្ខុនោះ ) ឯណា បញ្ញានេះ ជារូបវវត្ថាបនបញ្ញា ។

ក្នុងទុកៈទី ៤ បញ្ញាចែកជា ២ យ៉ាង ដែលជាសោមនស្សសហគតៈ និងឧបេក្ខាសហគតៈ ដូច្នេះ គឺបញ្ញាក្នុងកាមាវចរកុសលចិត្ត ២ ដួង និងក្នុងមគ្គចិត្ត ដែលប្រព្រឹត្តទៅក្នុងចតុក្កជ្ឈានដោយបញ្ចកន័យ ១៦ ដួង ជាសោមនស្សសហគតបញ្ញា បញ្ញាក្នុងកាមាវចរកុសលចិត្ត ២ ដួង និងក្នុងមគ្គចិត្តដែលប្រព្រឹត្តទៅក្នុងបញ្ចមជ្ឈាន ៤ ដួង ជាឧបេក្ខាសហគតបញ្ញា ។

ក្នុងទុកៈទី ៥ បញ្ញាក្នុងបឋមមគ្គ ជាទស្សនភូមិបញ្ញា បញ្ញាក្នុងមគ្គ ៣ ដ៏សេស ជាភាវនាភូមិបញ្ញា បញ្ញាចែកជា ២ យ៉ាង ដែលជាទស្សនភូមិ និងភាវនាភូមិ ដូច្នេះឯង ។

# បញ្ញា ៣

*ក្នុងតិកៈទាំងឡាយ ( បញ្ញាពួក ៣ ) មានអធិប្បាយដូច្នេះ*

*ក្នុងតិកៈទី ១ បញ្ញាដែលមិនបានស្តាប់អំពីអ្នកដទៃ បានមកជាចិន្តាមយបញ្ញា ព្រោះសម្រេចដោយគំនិតរបស់ខ្លួនឯង បញ្ញាដែលស្តាប់អំពីអ្នកដទៃហើយ ទើបបានមកជាសុតមយបញ្ញា ព្រោះសម្រេចដោយអំណាចការស្តាប់ បញ្ញាដែលដល់អប្បនា ដែលសម្រេចដោយអំណាចភាវនាឯណាមួយ ជាភាវនាមយបញ្ញា សមដូចពាក្យក្នុងវិភង្គពោលទុកថា ក្នុងបញ្ញា ៣ នោះ ចិន្តាមយបញ្ញាដូចម្តេច ? បុគ្គលមិនបានស្តាប់អំពីអ្នកដទៃ ហើយបាននូវកម្មស្សកតាញាណ ឬនូវសច្ចានុលោមិកញ្ញាណ គឺវិបស្សនាញាណ ដែលប្រព្រឹត្តទៅដោយន័យថា រូបមិនទៀងក្តី ជាវេទនា សញ្ញា សង្ខារ វិញ្ញាណមិនទៀងក្តី ឬនូវ* ***ខន្តិ*** *( ការអត់ធន់បាន )* ***ទិដ្ឋិ*** *( ការយល់ឃើញ )* ***រុចិ*** *( ការពេញចិត្ត )* ***មុតិ*** *( ការដឹង )* ***បេក្ខៈ*** *( ការត្រិះរិះឃើញ )* ***ធម្មនិជ្ឈានខន្តិ*** *( ភាពអត់ធន់ចំពោះការសម្លឹងនៃធម៌ ) ដែលជាអនុលោមិក គឺគួរដល់ធម៌ដែលមានបំណងនឹងធ្វើមិនឲ្យជំទាស់គ្នា រួមជាមួយគ្នានោះ ក្នុងកម្មាយតនៈ ( អាយតនៈ គឺការងារ ) ទាំងឡាយ ដែលបុគ្គលចាត់ចែងធ្វើដោយយោគៈ គឺបញ្ញាក្តី ក្នុងសិប្បាយតនៈ ( អាយតនៈ គឺវិជ្ជាជីវៈ ) ទាំងឡាយ ដែលបុគ្គលចាត់ចែងធ្វើដោយយោគៈ គឺបញ្ញាក្តី ក្នុងវិជ្ជាឋានៈ ( គឺមន្តវិជ្ជា ) ទាំងឡាយ ដែលបុគ្គលចាត់ចែងធ្វើដោយយោគៈ គឺបញ្ញាក្តី ឯណា ការចេះដឹងនេះ ហៅថា* ***ចិន្តាមយបញ្ញា*** *។*

*សុតមយបញ្ញាដូចម្តេច ? បុគ្គលបានស្តាប់អំពីអ្នកដទៃហើយ ទើបបាននូវកម្មស្សកតាញាណ ។បេ។ ឯណា ការចេះដឹងនេះ ហៅថា* ***សុតមយបញ្ញា*** *។*

*ភាវនាមយបញ្ញាដូចម្តេច ? ការដឹងរបស់បុគ្គលចូលសមាបត្តិគ្រប់យ៉ាង ហៅថា* ***ភាវនាមយបញ្ញា*** *។*

បញ្ញាជា ៣ ដែលជាចិន្តាមយបញ្ញា សុតមយបញ្ញា និងភាវនាមយបញ្ញា ដូចបានពោលមក ដូច្នេះ ។

ក្នុងតិកៈទី ២ បញ្ញាជា ៣ ដែលជាបរិត្តារម្មណបញ្ញា មហគ្គតារម្មណបញ្ញា និងអប្បមាណារម្មណបញ្ញាយ៉ាងនេះ គឺបញ្ញាដែលប្រារព្ធធម៌ទាំងឡាយ ដែលជាកាមាវចរៈប្រព្រឹត្តទៅជាបរិត្តារម្មណបញ្ញា ដែលប្រារព្ធធម៌ទាំងឡាយ ជារូបាវចរៈ និងអរូបាវចរៈប្រព្រឹត្តទៅ ជាមហគ្គតារម្មណបញ្ញា បញ្ញា ២ នោះ ជាលោកិយវិបស្សនាបញ្ញា បញ្ញាដែលប្រារព្ធព្រះនិព្វានប្រព្រឹត្តទៅ ជាអប្បមាណារម្មណបញ្ញា អប្បមាណារម្មណបញ្ញានោះ ជាលោកុត្តរវិបស្សនាបញ្ញា ។

ក្នុងតិកៈទី ៣ សេចក្តីចម្រើន ឈ្មោះថា **អាយ** ការចម្រើននោះមាន ២ ផ្លូវ គឺវត្ថុដែលមិនជាប្រយោជន៍ វិនាសទៅផ្លូវមួយ ប្រយោជន៍កើតឡើងផ្លូវមួយ ភាពឈ្លាសក្នុងផ្លូវ ២ យ៉ាងនោះ ឈ្មោះអាយកោសល្ល ដូចបាលីថា ក្នុងកោសល្ល ៣ នោះ អាយកោសល្លដូចម្តេច ? បុគ្គលមានបញ្ញាដឹងថា កាលយើងកំពុងធ្វើទុកក្នុងចិត្តនូវមនសិការធម៌ទាំងពួងនេះ អកុសលធម៌ទាំងឡាយដែលមិនទាន់កើត ក៏មិនកើតឡើងផង អកុសលធម៌ទាំងឡាយដែលកើតឡើងហើយ ក៏លះទៅផង ម្យ៉ាងទៀត កាលអាត្មាអញកំពុងធ្វើនូវមនសិការធម៌ពួកនេះ កុសលធម៌ទាំងឡាយ ដែលមិនទាន់កើត ក៏កើតឡើងផង កុសលធម៌ទាំងឡាយដែលកើតឡើងហើយ ចម្រើនទៅជាភិយ្យោភាព បរិបូណ៌ពេញទីផង បញ្ញា គឺការដឹងទូទៅ ។បេ។ ការមិនវង្វេង ការវិនិច្ឆ័យធម៌បាន ការឃើញត្រឹមត្រូវក្នុងភាវៈមិនកើតឡើង និងការវិនាសទៅនៃអកុសលធម៌ទាំងឡាយ និងការកើតឡើង និងការចម្រើននៃកុសលធម៌ទាំងឡាយផង នៃបុគ្គលដែលមានបញ្ញានោះឯណា នេះហៅថា អាយកោសល្ល ដូច្នេះ ។

ចំណែកសេចក្តីសាបសូន្យ ឈ្មោះថា **អបាយ** ការមិនចម្រើននោះក៏មាន ២

ផ្លូវ គឺប្រយោជន៍វិនាសទៅផ្លូវមួយ វត្ថុដែលមិនជាប្រយោជន៍កើតឡើងផ្លូវមួយ ភាពឈ្លាសក្នុងផ្លូវ ២ នោះ ឈ្មោះថាអបាយកោសល្ល ដូចព្រះបាលីថា ក្នុងកោសល្ល ៣ នោះ អបាយកោសល្លដូចម្តេច ? បុគ្គលមានបញ្ញាដឹងថា កាលអាត្មាអញកំពុងធ្វើទុកមនសិការ ធម៌ពួកនេះ កុសលធម៌ទាំងឡាយដែលមិនទាន់កើត ក៏មិនកើតឡើងផងដូច្នេះ ជាដើម ។

ចំណែកដែលពោលថា ភាពឈ្លាសដែលប្រព្រឹត្តទៅមួយរំពេច គឺកើតឡើងរួសរាន់ក្នុងឧបាយ គឺហេតុនៃការសម្រេចនៃធម៌ទាំងឡាយនោះៗ គ្រប់អន្លើ ឈ្មោះថាឧបាយកោសល្ល ដូចព្រះបាលីថា បញ្ញាដែលជាឧបាយក្នុងការលះអកុសលធម៌ និងការចម្រើនកុសលធម៌ទាំងនោះគ្រប់យ៉ាង ឈ្មោះថា ឧបាយកោសល្ល ដូច្នេះ ។

បញ្ញាជា ៣ ដែលជាអាយកោសល្ល អបាយកោសល្ល និងឧបាយកោសល្ល ដូចបានពោលមកហើយ ដូច្នេះឯង ។

ក្នុងតិកៈទី ៤ បញ្ញា ៣ យ៉ាង ដែលជាអជ្ឈត្តាភិនិវេសជាដើមយ៉ាងនេះ គឺវិបស្សនាបញ្ញា ដែលកំណត់យកខន្ធរបស់ខ្លួនឲ្យប្រារព្ធទៅជាអជ្ឈត្តាភិនិវេសបញ្ញា ដែលកំណត់កាន់យកខន្ធរបស់អ្នកដទៃ ឬរូបខាងក្រៅ ដែលមិនទាក់ទង ដោយឥន្ទ្រិយ ប្រារព្ធទៅជាពហិទ្ធាភិនិវេសបញ្ញា (បញ្ញាដែលមានបំណងប្រាថ្នាខាងក្រៅ) ដែលកំណត់កាន់យកខន្ធខាងក្នុង និងខន្ធខាងក្រៅទាំង ២ ប្រារព្ធទៅជាអជ្ឈត្តពហិទ្ធាភិនិ-វេសបញ្ញា ។

## បញ្ញា ៤

ក្នុងចតុក្កៈទាំងឡាយ ( បញ្ញាពួក ៤ ) មានអធិប្បាយដូច្នេះ

ក្នុងចតុក្កៈទី ១ បញ្ញា ៤ យ៉ាង ដែលជាញាណក្នុងអរិយសច្ច ៤ ដូច្នេះ គឺការដឹងដែលប្រារព្ធទុក្ខសច្ចប្រព្រឹត្តទៅ ជាញាណក្នុងទុក្ខ ការដឹងដែលប្រារព្ធទុក្ខសមុទយៈ

ប្រព្រឹត្តទៅ ជាញាណក្នុងទុក្ខសមុទយៈ ការដឹងដែលប្រារព្ធទុក្ខនិរោធប្រព្រឹត្តទៅ ជាញាណក្នុងទុក្ខនិរោធ បញ្ញាដែលប្រារព្ធទុក្ខនិរោធគាមិនីបដិបទាប្រព្រឹត្តទៅ ជាញាណក្នុងទុក្ខនិរោធគាមិនីបដិបទា ។

ក្នុងចតុក្កៈទី ២ ការដឹង ៤ យ៉ាង ដែលដល់នូវការបែកធ្លាយក្នុងវត្ថុ ៤ មានអត្ថជាដើម ឈ្មោះថា បដិសម្ភិទា ៤ សមដូចព្រះបាលីថា ការដឹងក្នុងអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទា ការដឹងក្នុងធម៌ឈ្មោះថា ធម្មប្បដិសម្ភិទា ការដឹងក្នុងការពោលធម្មនិរុត្តិ ( គឺភាសាដែលល្អ ភាសាដែលត្រឹមត្រូវ ) ឈ្មោះថា និរុត្តិប្បដិសម្ភិទា ការដឹងក្នុងភាព ឆ្លាតឈ្លាសទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ដូច្នេះ ។

## អត្ថប្បដិសម្ភិទា

ក្នុងវត្ថុ ៤ នោះ ពាក្យថា **អត្ថ** នោះ ដោយសង្ខេបជាពាក្យហៅផលដែលកើតមកអំពីហេតុ ពិតណាស់ ផលដែលកើតមកអំពីហេតុ លោកហៅថា **អត្ថ** ព្រោះហេតុដែលដល់ គឺបានសម្រេចដោយទំនងនៃហេតុ គឺប្រព្រឹត្តទៅតាមហេតុ តែពោលដោយប្រភេទធម៌ ៥ នេះ គឺវត្ថុដែលកើតព្រោះបច្ច័យឯណាមួយ ព្រះនិព្វាន អត្ថន័យភាសិត វិបាក កិរិយាគប្បីជ្រាបថា ឈ្មោះថា អត្ថ ការដឹងដែលដល់នូវភាពបែកធ្លាយក្នុងអត្ថនោះ នៃបុគ្គលដែលពិចារណាអត្ថនោះ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។

## ធម្មប្បដិសម្ភិទា

ពាក្យថា ធម្មៈ នោះសោត ដោយសង្ខេបក៏ជាពាក្យហៅបច្ច័យ ពិតណាស់ បច្ច័យ លោកហៅថា **ធម្មៈ** ព្រោះហេតុដែលចាត់ចែងផលនោះៗ គឺញ៉ាំងផលនោះៗ ឲ្យប្រព្រឹត្តទៅ ឬជួយឲ្យដល់ផលនោះៗ តែពោលដោយប្រភេទធម៌ ៥ នេះ គឺហេតុដែលញ៉ាំងផលឲ្យកើតយ៉ាងណាមួយ អរិយមគ្គ ភាសិត កុសល អកុសល គប្បី

ជ្រាបថា ឈ្មោះថា ធម៌ ការដឹងដែលដល់នូវភាពបែកធ្លាយក្នុងធម៌នោះ នៃបុគ្គលដែលពិចារណាធម៌នោះ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។

មែនពិត ការដែលចែកធម៌ជាប្រាំៗ នេះឯង លោកចែកសម្តែងទុកក្នុងព្រះអភិធម្ម ដោយន័យថា ការដឹងក្នុងទុក្ខ ជាអត្ថប្បដិសម្ភិទា ការដឹងក្នុងទុក្ខសមុទយៈ ជាធម្មប្បដិសម្ភិទា ការដឹងក្នុងទុក្ខនិរោធ ជាអត្ថប្បដិសម្ភិទា ការដឹងក្នុងទុក្ខនិរោធគាមិនីបដិបទា ជា **ធម្មប្បដិសម្ភិទា** ។

ការដឹងក្នុងហេតុ ជាធម្មប្បដិសម្ភិទា ការដឹងក្នុងផលដែលកើតអំពីហេតុ ជា **អត្ថប្បដិសម្ភិទា** ។

ធម៌ពួកណា កើតហើយ កើតព្រមហើយ បានកំណើតកើតសម្រេចហើយ ប្រាកដឡើងមកហើយ ការដឹងក្នុងធម៌ទាំងនេះជាអត្ថប្បដិសម្ភិទា ធម៌ទាំងនោះ កើតហើយ កើតព្រមហើយ... អំពីធម៌ណា ការដឹងក្នុងធម៌នោះ ជាធម្មប្បដិសម្ភិទា ។

ការដឹងក្នុងជរាមរណៈ ជាអត្ថប្បដិសម្ភិទា ការដឹងក្នុងជរាមរណៈសមុទយៈ ជាធម្មប្បដិសម្ភិទា ។បេ។ ការដឹងក្នុងសង្ខារនិរោធ ជាអត្ថប្បដិសម្ភិទា ការដឹងក្នុងសង្ខារនិរោធគាមិនីបដិបទា ជា **ធម្មប្បដិសម្ភិទា** ។

ភិក្ខុក្នុងធម្មវិន័យនេះ រមែងដឹងនូវធម៌ដែលជាសុត្តៈ គេយ្យ ។បេ។ វេទល្ល ការដឹងធម៌នេះ ហៅថា ធម្មប្បដិសម្ភិទា ភិក្ខុនោះរមែងដឹងអត្ថន័យនៃភាសិតនោះៗ នុ៎ះឯង ថានេះជាសេចក្តីនៃភាសិតនេះ នេះជាសេចក្តីនៃភាសិតនេះ ការដឹងអត្ថន័យនៃភាសិតដូច្នេះ ហៅថា **អត្ថប្បដិសម្ភិទា** ។

ធម៌ទាំងឡាយដែលជាកុសលដូចម្តេច ? សម័យណាចិត្តជាកាមាវចរកុសលកើតឡើង ។បេ។ ធម៌ទាំងនេះជាកុសល ការដឹងក្នុងធម៌ទាំងនេះជាធម្មប្បដិសម្ភិទា ការដឹងក្នុងវិបាកនៃធម៌ទាំងនោះជាអត្ថប្បដិសម្ភិទា ដូច្នេះជាដើម ។

## និរុត្តិប្បដិសម្ភិទា

ប្រការថា **អត្ថធម្មនិរុត្តាភិលាបេ ញាណំ** អធិប្បាយថា សភាវនិរុត្តិ ( ភាសាដែលពិត ) គឺអព្យាភិចារិវោហារ ( វោហារដែលសន្មតប្រើមិនវិបរិត ) ឯណា ក្នុងអត្ថនិងធម៌នោះ ការដឹងក្នុងការពោលពាក្យសម្តីនោះ គឺក្នុងការនិយាយ ក្នុងការបន្លឺឡើងនូវពាក្យនោះ បានដល់ ការដឹងដែលដល់នូវភាពបែកធ្លាយ ក្នុងមូលភាសារបស់សត្វសត្វទាំងឡាយ គឺភាសាមគធៈ ដែលជាសភាវនិរុត្តិ (ភាសាពិត) ដែលបានឈ្មោះថា ធម្មនិរុត្តិ (ភាសាល្អ) នោះ ដោយន័យថា លុះបានឮពាក្យដែលនិយាយ ដែលពោលដែលបន្លឺឡើងនោះ ក៏ដឹងថា នេះជាសភាវនិរុត្តិ នេះមិនមែនសភាវនិរុត្តិ ដូច្នេះ ជានិរុត្តិប្បដិសម្ភិទា ពិតណាស់ អ្នកដល់និរុត្តិប្បដិសម្ភិទា លុះបានឮពាក្យថា **ផស្សោ វេទនា** ដូច្នេះជាដើម ក៏រមែងដឹងបានថា នេះជាសភាវនិរុត្តិ តែបានឮពាក្យថា **ផស្សា វេទនោ** ដូច្នេះជាដើម ក៏ដឹង បានថា នេះមិនមែន សភាវនិរុត្តិ ។

## បដិភាណប្បដិសម្ភិទា

ពាក្យថា **ញាណេសុ ញាណំ** អធិប្បាយថា ការដឹងដែលមានញាណ ជាអារម្មណ៍នៃបុគ្គលដែលពិចារណា ដោយធ្វើការដឹងក្នុងញាណទាំងពួងឲ្យជាអារម្មណ៍ ឬការដឹងដោយទូលំទូលាយដោយអំណាចអារម្មណ៍ និងកិច្ចរបស់ខ្លួនជាដើម ក្នុងការដឹងទាំងឡាយតាមដែលពោលមកនោះ ជា **បដិភាណប្បដិសម្ភិទា** ។

## ភូមិបដិសម្ភិទាមាន ២

ឯបដិសម្ភិទាទាំង ៤ នោះ រមែងដល់នូវភាពបែកធ្លាយក្នុងភូមិ ២ គឺក្នុងសេក្ខភូមិ ១ អសេក្ខភូមិ ១ ក្នុងភូមិ ២ នោះ បដិសម្ភិទារបស់ព្រះអគ្គសាវក និងរបស់ព្រះមហាសាវកទាំងឡាយ ដល់នូវភាពបែកធ្លាយក្នុងអសេក្ខភូមិ បដិសម្ភិទារបស់ព្រះ

សេក្ខអរិយសាវកទាំងឡាយ ដូចជាព្រះអានន្ទ ( កាលនៅជាព្រះសេក្ខៈ ) ចិត្តគហបតី ខុជ្ជុត្តរាឧបាសិកាដល់នូវភាពបែកធ្លាយក្នុងសេក្ខភូមិ ។

## បដិសម្ភិទាផូរផង់ដោយអាការ ៥

ម្យ៉ាងវិញទៀត បដិសម្ភិទានោះ ដល់នូវភាពបែកធ្លាយក្នុងភូមិ ២ យ៉ាងនេះ និងផូរផង់ឡើងដោយអាការ ៥ នេះ គឺដោយអធិគម ដោយបរិយត្តិ ដោយសវនៈ ដោយបរិបុច្ឆា និងដោយបុព្វយោគ ក្នុងអាការទាំងនោះ ។ ការសម្រេចព្រះអរហត្ត ឈ្មោះថា **អធិគម** ការសូធ្យរៀនព្រះពុទ្ធវចនៈ ឈ្មោះថា **បរិយត្តិ** ការដាក់ចិត្តស្តាប់ព្រះសទ្ធម្មដោយគោរព ឈ្មោះថា **សវនៈ** ការពោលវិនិច្ឆ័យគណ្ឋិបទ និងអត្ថបទក្នុងគម្ពីរទាំងឡាយ មានព្រះពុទ្ធដីកា និងអដ្ឋកថាជាដើម ឈ្មោះថា **បរិបុច្ឆា** ការប្រកបរឿយៗ នូវវិបស្សនា ដល់លំដាប់ជិតអនុលោមញ្ញាណ និងគោត្រភូញាណ ដោយភាវៈនៃព្រះយោគាវចរដែលមានការ ( អន្ទោល ) ទៅមកៗ នៅក្នុងសាសនារបស់ព្រះពុទ្ធអង្គមុនៗ ឈ្មោះថា **បុព្វយោគ** ។

អាចារ្យពួកមួយដទៃទៀតពោលថា

បច្ច័យ ( គ្រឿងឧបការៈ ) របស់បដិសម្ភិទាមាន ៨ គឺបុព្វយោគ ១ ពហុសច្ចៈ ១ ទេសភាសា ១ អាគម ១ បរិបុច្ឆា ១ អធិគម ១ គរុសន្និស្ស័យ ១ មិត្តសម្បត្តិ ១ ។

ក្នុងបច្ច័យទាំងនោះ បុព្វយោគមានន័យដូចពោលហើយនោះឯង ការឈ្លាសក្នុងគម្ពីរ និងសិប្បាយតនៈ ( ក្បួនសិប្បៈ ) ទាំងឡាយនោះៗ ឈ្មោះថា **ពហុសច្ចៈ** ការឈ្លាសក្នុងវោហារ ( ភាសា ) ១០១ ( នគរ ) ឈ្មោះថា **ទេសភាសា** តែបើពោលដោយពិសេស គឺការឈ្លាសក្នុងវោហាររបស់អ្នកមគធៈនោះឯង ឈ្មោះថា **ទេសភាសា** ការសូធ្យរៀនព្រះពុទ្ធវចនៈ ដោយហោចសូម្បីត្រឹមឱបម្មវ ( ត្រឹមតែ ១ វគ្គ ) ឈ្មោះថា **អាគម** ការសាកសួរដល់ពាក្យវិនិច្ឆ័យអត្ថន័យនៃគាថា សូម្បី ១

គាថា ឈ្មោះថា **បរិបុច្ឆា** ភាពជាព្រះសោតាបន្នក្តី ភាពជាព្រះសកទាគាមីក្តី ភាពជាព្រះអនាគាមីក្តី ភាពជាព្រះអរហន្តក្តី ឈ្មោះថា **អធិគម** ការនៅក្នុងសម្នាក់របស់គ្រូទាំងឡាយ ដែលមានសុត្តបដិភាណច្រើន ឈ្មោះថា **គរុសន្និស្សយ** ។ ការបានមិត្តទាំងឡាយបែបនោះនុ៎ះឯង ឈ្មោះថា **មិត្តសម្បត្តិ** ដោយប្រការដូច្នេះ ។

ក្នុងបច្ច័យទាំងនោះ ព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធទាំងឡាយ អាស្រ័យបុព្វយោគ និងអធិគមប៉ុណ្ណោះ ទ្រង់សម្រេចបដិសម្ភិទា ព្រះសាវកទាំងឡាយអាស្រ័យហេតុ គឺបច្ច័យទាំងនោះគ្រប់យ៉ាងទើបបានសម្រេច ម្យ៉ាងការប្រកបកម្មដ្ឋានភាវនា ជាចំណែកមួយសម្រាប់សម្រេចបដិសម្ភិទាមិនមាន តែការសម្រេចបដិសម្ភិទាសម្រាប់ព្រះសេក្ខៈទាំងឡាយ ក៏មានឡើងក្នុងទីបំផុតនៃផលវិមោក្ខជាន់សេក្ខៈ សម្រាប់ព្រះអសេក្ខៈទាំងឡាយប៉ុណ្ណោះទេ ក៏មានឡើងក្នុងទីបំផុតនៃផលវិមោក្ខជាន់អសេក្ខៈនោះឯង ពិតណាស់ បដិសម្ភិទាទាំងឡាយ សម្រេចដល់ព្រះតថាគតទាំងឡាយ ក៏ដោយអរិយផលនៃអរិយបុគ្គលទាំងឡាយនោះឯង ដូចគ្នានឹងទសពលញ្ញាណទាំងឡាយ ( ក៏សម្រេចដល់ព្រះតថាគតដោយអរិយផលនៃអរិយបុគ្គលទាំងឡាយដូចគ្នា ) ។

ពាក្យថា បញ្ញាជា ៤ យ៉ាង ដោយជាបដិសម្ភិទា ៤ ដែលខ្ញុំពោលសំដៅយកបដិសម្ភិទាដូច្នេះឯង ។

# មហាដីកា

## ពណ៌នាខន្ធនិទ្ទេស

## កថាពណ៌នាដោយប្រភេទរបស់បញ្ញា

ធម្មតាការចាក់ធ្លុះនូវសភាវធម៌ ជាសភាវៈពិសេសរបស់បញ្ញា ដោយការចាក់ធ្លុះសភាវធម៌នោះ ទើបចែកអ្វីៗ ចេញទៅបាន ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ខាងដើមបញ្ញាមាន ១ ដោយលក្ខណៈ គឺការចាក់ធ្លុះនូវសភាវធម៌** ។ វដ្ដៈ ហៅថា **លោក** ដោយអត្ថថា បែកធ្លាយ និងវិនាសទៅ បញ្ញាដែល ឈ្មោះថា **លោកិយ** ដោយអត្ថថា ប្រកបនៅក្នុងលោក ព្រោះជាធម៌ដែលទាក់ទង នៅក្នុងលោកនោះ ឬដោយអត្ថថា ប្រាកដនៅក្នុងលោកនោះ ។ បញ្ញា ឈ្មោះថា **លោកុត្តរ** ព្រោះអត្ថថា ឆ្លងឡើង គឺឆ្លងឡើងហើយអំពីលោក ព្រោះមិនជាធម្មជាតិ ទាក់ទងនៅក្នុងលោកនោះ ។ ពិតណាស់ សូម្បីបញ្ញាដែលជាជាន់លោកុត្តរ ដែលសម្បយុត្តដោយមគ្គ ក៏គួរចម្រើន ។ សូម្បីពាក្យដែលជាបរិយាយថា វិបស្សនា ក៏រមែងបាន ដូចគ្នាដល់បញ្ញាដែលជាលោកុត្តរនោះ ព្រោះដូច្នោះ ការប្រើស័ព្ទថា **លោកុត្តរ** ទើបមិនខុស ។ បញ្ញា ឈ្មោះថា **សាសវៈ** ដោយអត្ថថា ប្រព្រឹត្តទៅ ជាមួយអាសវៈទាំងឡាយ ដែលធ្វើខ្លួនឲ្យជាអារម្មណ៍ប្រព្រឹត្តទៅហើយ ឈ្មោះថា **អនាសវៈ** ដោយអត្ថថា **មិនមានអាសវៈ** សូម្បីដោយអំណាចការធ្វើឲ្យជាអារម្មណ៍ ។ ដោយអាទិស័ព្ទ គប្បីឃើញការសង្គ្រោះទុកៈទាំងឡាយ មានអាសវវិប្បយុត្តទុកៈ និងសាសវទុកៈជាដើម ។ បទថា **នាមរូបវវត្ថានវសេន** សេចក្តីថា ដោយអំណាចការកំណត់នាម និងដោយអំណាចការកំណត់រូប ។ បញ្ញា ឈ្មោះថា **ទស្សនៈ** ព្រោះឃើញព្រះនិព្វានគ្រាដំបូង និងឈ្មោះថា **ភូមិ** ដោយអត្ថថា ជាលំនៅរបស់សម្បយុត្ត ធម៌ទាំងឡាយ ដោយភាវៈដែលជានិស្សយ-

បច្ច័យ ឬដោយអត្ថថា សូម្បីខ្លួនឯងមាន ឬកើតឡើង មិនមែនមានដូចជាព្រះនិព្វាន ដែលជាសភាវៈមិនប្រាកដក៏ទេ ព្រោះដូច្នោះ ទើបឈ្មោះថា **ទស្សនភូមិ** បានដល់ **បឋមមគ្គ** ។ ចំណែកមគ្គ ៣ ដ៏សេស ឈ្មោះថា ជាភាវនា ព្រោះកើតឡើង ដោយអំណាចភាវនាក្នុងធម៌ដែលបឋមមគ្គឃើញហើយនោះឯង និងឃើញអ្វីៗ ដែលមិនធ្លាប់ឃើញក៏ទេ និងនៅមានឈ្មោះថា ជាភូមិដោយអត្ថតាមដែលបានពោលហើយ ហេតុនោះ ទើបឈ្មោះថា **ភាវនាភូមិ** ។ បញ្ញាក្នុងភូមិទាំងនោះ លោកពោលថាមាន ២ យ៉ាង គឺទស្សនភូមិ និងភាវនាភូមិ ។ បញ្ញាដែលកើតឡើងដោយគំនិត មិនបានសម្លឹងដល់កិច្ច មានការស្តាប់ជាដើម ឈ្មោះថា **ចិន្តាមយបញ្ញា** ។ **សុតមយបញ្ញា** និង **ភាវនាមយបញ្ញា** ក៏យ៉ាងនេះ ។ **មយ**-ស័ព្ទ គប្បីភ្ជាប់ចូលគ្នាចំពោះតែមួយបទ ។ ភាពឈ្លាសក្នុងការចម្រើន គឺក្នុងការដុះដាល ឈ្មោះថា **អាយកោសល្ល** ការឈ្លាសក្នុងសេចក្តីវិនាស គឺក្នុងការមិនរីកចម្រើន ឈ្មោះថា **អបាយកោសល្ល** ការឈ្លាសក្នុងហេតុកើតឡើងរបស់ប្រយោជន៍នោះៗ ឈ្មោះថា **ឧបាយកោសល្ល** គប្បីភ្ជាប់បទថា កោសល្លចូលក្នុងបទនីមួយៗ ដូចបានពោលមកនេះ ។ ការប្រកាន់មាំ គឺការបដិបត្តិខាងក្នុងនៃបញ្ញានេះមាន ហេតុនេះ បញ្ញានេះ ឈ្មោះថា **អជ្ឈត្តាភិនិវេស** ប្រែថា មានការប្រកាន់មាំក្នុងខាងក្នុង ។ គប្បីជ្រាបបញ្ញា ដែលឈ្មោះថា **ពហិទ្ធាភិនិវេស** ដែលប្រែថា មានការប្រកាន់មាំខាងក្រៅ ។ និងបញ្ញាដែលឈ្មោះថា **ឧភយាភិនិវេស** ដែលប្រែថា មានការប្រកាន់មាំទាំងពីរចំណែក យ៉ាងនេះ ។

ពាក្យថា បញ្ញាដែលសម្បយុត្តដោយលោកិយមគ្គ បានដល់ បញ្ញាដែលសម្បយុត្តដោយមគ្គក្នុងចិត្តុប្បាទដែលជាកុសលខាងលោកិយ ដោយពិសេស បានដល់ បញ្ញាដែលសម្បយុត្តដោយមគ្គ ដែលលោកសង្គ្រោះដោយពួក ៤ នៃវិសុទ្ធិ មានទិដ្ឋិវិសុទ្ធិជាដើម ។ ឈ្មោះដែលប្រព្រឹត្តទៅក្នុងអត្ថន័យរួម រមែងប្រព្រឹត្តទៅបាន សូម្បីក្នុង

ឯកទេសនៃការរួមនោះ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **បញ្ញាដែលសម្បយុត្ត ដោយមគ្គ** ម្យ៉ាងទៀត លោកពោលទុកយ៉ាងនេះ ព្រោះអធិប្បាយថា មគ្គទាំងឡាយ មានសម្មាទិដ្ឋិជាដើម សូម្បីចំពោះតែម្យ៉ាង ក៏មានឈ្មោះថា មគ្គ ។

កាលមិនមានភាពផ្សេងគ្នានៃធម៌ ពាក្យក្នុងទុកៈដទៃ រមែងមានដោយគ្រាន់តែសេចក្ដីផ្សេងគ្នានៃអត្ថន័យរបស់បទ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ដោយអត្ថ** បញ្ញានេះ ទាំងលោកិយ និងលោកុត្តរនោះឯង ។ សូម្បីក្នុងទុកៈទាំងឡាយ មានអាសវវិប្បយុត្តសាសវទុកៈជាដើម ក៏ផ្សេងគ្នាចំពោះសត្វ មានភាពជាវិប្បយុត្តជាដើម ដោយអត្ថថា បញ្ញា ក៏ជាលោកិយ និងលោកុត្តរប៉ុណ្ណោះ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា មានន័យដូចនេះនោះឯង ។ ដោយអាទិសត្ថ គប្បីឃើញការសង្គ្រោះទុក មានឱយនិយទុកៈ និងឱយវិប្បយុត្ត ឱយនិយទុកៈជាដើម ។ ក្នុងមគ្គចិត្ត ១៦ ដួងនេះ គឺមគ្គចិត្ត ៤ ដួង ដែលប្រព្រឹត្តទៅក្នុងបឋមជ្ឈាន និងមគ្គចិត្តដែលប្រព្រឹត្តទៅក្នុងទុតិយជ្ឈានជាដើមក៏ដូចគ្នា ។ ព្រោះក្នុងទីនេះមានបំណងយកវិបស្សនាបញ្ញា ទើបលោកអាចារ្យមិនកាន់យកបញ្ញាដែលជាចំណែកមហគ្គតៈ ។

ពាក្យថា ដោយអំណាចការគិតរបស់ខ្លួន គឺដោយអំណាចការគិតរកឧបាយរបស់ខ្លួនតែម្យ៉ាង វៀរចាកពាក្យដឹកនាំរបស់អ្នកដទៃក្នុងការដែលនឹងញុំាងប្រយោជន៍ដែលប្រាសចាកទោសនោះៗ ឲ្យសម្រេច ។ ពាក្យថា **ដោយអំណាចការស្ដាប់** គឺដោយអំណាចពាក្យដឹកនាំរបស់អ្នកដទៃតាមដែលបានស្ដាប់មក ។ បទថា **យថា តថា វា** សេចក្ដីថា របស់បុគ្គលដែលបានស្ដាប់ក្ដី មិនបានស្ដាប់ក្ដី នូវពាក្យដឹកនាំអំពីបុគ្គលដទៃប្រកបរឿយៗ នូវភាវនាដោយខ្លួនឯងតែម្យ៉ាង ។ ពាក្យថា **ដែលដល់នូវអប្បនា** នេះ លោកអាចារ្យពោលទុកដើម្បីនឹងសម្ដែងដល់ភាវនាមយបញ្ញា ដែលដល់កំពូល តែមិនមែនពោលថា បញ្ញាដែលដល់ថ្នាក់អប្បនាតែម្យ៉ាង ជាភាវនាមយបញ្ញា

ដូច្នេះឡើយ ។

បទថា **យោគវិហិតេសុ** ប្រែថា ដែលធ្វើដោយបញ្ញា គឺដែលបង្អោនទៅដោយបញ្ញា ដែលឲ្យសម្រេចដោយឧបាយ ។ ក្នុងបទថា **កម្មាយតនេសុ** នេះ មានវិគ្គហៈថា កម្ម ( ការងារ ) នោះឯង ឈ្មោះថា **កម្មាយតនៈ** ម្យ៉ាងទៀត ឈ្មោះថា កម្មាយតនៈ ដោយអត្ថថា ការងារនោះជាអណ្តូង (ប្រភព ) កើតនៃអាជីវៈទាំងឡាយ ។ សូម្បីក្នុង **សិប្បាយតនៈ** ក៏ដូចន័យនេះ ។ ក្នុងកម្មាយតនៈ និងសិប្បាយតនៈទាំងនោះ ការងារមាន ២ យ៉ាង គឺការងារថោកទាប បានដល់ ការងាររបស់ជាងឈើជាដើម និងការងារខ្ពង់ខ្ពស់ មានកសិកម្ម និងពាណិជ្ជកម្មជាដើម ។ សូម្បីសិប្បៈ ក៏មាន ២ យ៉ាង គឺសិប្បៈថោកទាប មានសិប្បៈរបស់ជាងតម្បាញកន្ទេលជាដើម និងសិប្បៈខ្ពង់ខ្ពស់ មានការគណនាដោយមេដៃជាដើម ។ វិជ្ជានោះឯងឈ្មោះថា **វិជ្ជាឋានៈ** ប្រែថា ឋានៈ គឺវិជ្ជា ។ វិជ្ជាឋានៈនោះ ដែលប្រកបដោយធម៌នោះឯង គប្បីជ្រាបដូចគ្នានឹងមន្តស្តោះផ្លុំទៅ ដើម្បីការពារក្នុងទីលានជំរឺជាដើម ។ ការងារសិប្បៈ និងវិជ្ជាទាំងនេះ បណ្ឌិតពួកខ្លះ ដូចជាព្រះពោធិសត្វជាដើម ក្នុងបំណងឲ្យការរស់នៅយ៉ាងផាសុករបស់ពួកមនុស្សទាំងឡាយ ខណៈដែលអ្នកដទៃគេកំពុងធ្វើក៏មិនបានឃើញ ឬអ្នកដទៃធ្វើសម្រេចហើយ ក៏មិនបានរៀនយក កាលគេកំពុងនិយាយគ្នាក៏មិនបានស្តាប់ រមែងធ្វើបានដោយគំនិត តាមធម្មតារបស់ខ្លួនដោយពិត ។ សូម្បីបុគ្គលមានបញ្ញាទាំងឡាយ ធ្វើដោយការគិត តាមធម្មតារបស់ខ្លួនក៏ធ្វើបានដូចគ្នា ដូចដែលបុគ្គលដទៃគេរៀនមកហើយធ្វើនោះឯង ។

ពាក្យថា **កម្មស្សកតាញាណ** សេចក្តីថា ញាណដែលដឹងយ៉ាងនេះថា កម្មនេះជារបស់ខ្លួនឯងនៃសត្វទាំងឡាយ កម្មនេះមិនមែនជារបស់នៃខ្លួន ។ ពាក្យថា **សច្ចានុលោមិកញ្ញាណ** បានដល់ វិបស្សនាញាណ ។ ពិតណាស់ វិបស្សនាញាណនោះ

លោកហៅថា **សច្ចានុលោមិកញ្ញាណ** ព្រោះអនុលោមដល់ការចាក់ធ្លុះសច្ចៈ ។ឥឡូវនេះ លោកអាចារ្យមានបំណងនឹងសម្តែងអាការប្រព្រឹត្តទៅ របស់សច្ចានុលោមិកញ្ញាណនោះ ទើបពោលពាក្យថា **រូបំ អនិច្ចន្តិ វា** ដូច្នេះជាដើម ។ក្នុងបណ្តាពាក្យទាំងនោះ ដោយ **វា**-ស័ព្ទ ដែលមានអត្ថជាអនិយមៈ គប្បីឃើញថា ទ្រង់កាន់យកទាំងទុក្ខលក្ខណៈ និងអនត្តលក្ខណៈផងនោះឯង ព្រោះត្រៃលក្ខណ៍ ជាធម្មជាតិ ដែលមិនមានវត្ថុណាមករារាំង ។ ព្រោះវត្ថុណាមិនទៀង វត្ថុនោះក៏ជាទុក្ខ វត្ថុណាជាទុក្ខ វត្ថុនោះក៏ជាអនត្តា ។ ពីរបទថា **យំ ឯវរូបឹ** សេចក្តីថា ដែលមានសភាវៈ មិនបានសម្តែងទុកហើយក្នុងខាងដើមយ៉ាងនេះឯណា ។ ពាក្យថា **អនុលោមិកំ ខន្តឹ** ជាដើម ជាវេវចនៈរបស់បញ្ញា ។ ពិតណាស់ បញ្ញានោះឈ្មោះថា **អនុលោមិកា** ដោយអត្ថថា ចូលគ្នាបាន ព្រោះចូលគ្នាបាន ដោយការឃើញដែលមិនជាបដិបក្ខគ្នាដល់ការងារជាដើម ដែលបានពោលទុកហើយខាងដើម និងព្រោះមិនជំទាស់ដល់មគ្គសច្ច បរមត្ថសច្ច និងដល់ព្រះនិព្វាន ដោយការប្រព្រឹត្តជាប្រយោជន៍ឧបការៈដល់សត្វទាំងឡាយ ។ បញ្ញាឈ្មោះថា **ខន្តិ** ដោយអត្ថថា អាច គឺអាចឃើញហេតុទាំងអស់នេះបាន ។ ឈ្មោះថា **ទិដ្ឋិ** ដោយអត្ថថា ឃើញ ។ឈ្មោះថា **រុចិ** ដោយអត្ថថា ប្រពៃ ។ឈ្មោះថា **មុតិ** ដោយអត្ថថា ដឹង ។ ឈ្មោះថា **បេក្ខា** ដោយអត្ថថា សម្លឹង ។ ធម៌ទាំងឡាយ មានការងារជាដើមនោះ ដែលបុគ្គលប្រើបញ្ញានោះសម្លឹងពិនិត្យ ក៏អត់ធន់បាន សម្លឹងពិនិត្យបាន ព្រោះហេតុនោះ ទើបឈ្មោះថា **ធម្មនិជ្ឈានក្ខន្តិ** ប្រែថា អត់ធន់ ការសម្លឹងពិនិត្យធម៌បាន ។ ពាក្យថា **មិនបានស្តាប់អំពីបុគ្គលដទៃ** ក៏រមែងបាន សេចក្តីថា មិនបានស្តាប់ពាក្យណែនាំរបស់អ្នកដទៃ គិតដោយខ្លួនឯងតែម្យ៉ាង ក៏រមែងបាន ។ ពាក្យថា **នេះហៅថា** សេចក្តីថា បញ្ញានេះហៅឈ្មោះថា **ចិន្តាមយបញ្ញា** ។ ចិន្តាមយបញ្ញានេះ រមែងកើតឡើងដល់ព្រះពោធិសត្វទាំងឡាយ ដែលមានឈ្មោះបោះសំឡេងច្រើនប៉ុណ្ណោះ ។ សូម្បីក្នុងបណ្តា

ព្រះពោធិសត្វ ដែលមានឈ្មោះបោះសំឡេងទាំងនោះ សច្ចានុលោមិកញ្ញាណរមែង កើតឡើងដល់ព្រះពោធិសត្វ ដែលកើតក្នុងភពចុងក្រោយ ២ ពួកប៉ុណ្ណោះ បញ្ញា ដ៏សេសរមែងកើតឡើងដល់ព្រះពោធិសត្វគ្រប់ពួកដែលបានបំពេញបារមីហើយមាន បញ្ញាច្រើន ។ ពាក្យថា **ស្តាប់អំពីអ្នកដទៃហើយទើបបាន** សេចក្តីថា ការងារជាដើម ដែលអ្នកដទៃ កំពុងធ្វើក្តី ធ្វើស្រេចហើយក្តី បានឃើញមកខ្លះ កាលបុគ្គលដទៃគេ ជជែកគ្នា ក៏បានឮពាក្យគេនិយាយខ្លះ បានរៀនយកក្នុងសម្នាក់របស់អាចារ្យមកខ្លះ បញ្ញាដែលបានមកទាំងអស់ គប្បីជ្រាបថា ឈ្មោះថា បញ្ញាដែលបានមកព្រោះស្តាប់អំពី អ្នកដទៃ ។ ពាក្យថា **របស់អ្នកបានសមាបត្តិ** សេចក្តីថា របស់អ្នកដែលព្រមព្រៀង ដោយសមាបត្តិ ក៏ពាក្យនេះត្រឹមតែជាតួយ៉ាងប៉ុណ្ណោះ ។ ក្នុងទីនេះលោកមានបំណង យកវិបស្សនាបញ្ញា និងមគ្គប្បញ្ញាថា ជា **ភាវនាមយបញ្ញា** ។

បទថា **សា យោគបរិត្តារម្មណា មហគ្គតារម្មណា តិវុត្តបញ្ញា** ប្រែថា បញ្ញា ដែលពោលថា ឈ្មោះថា បរិត្តារម្មណ៍ ឈ្មោះថា មហគ្គតារម្មណ៍នោះ ។ ពាក្យថា ជាលោកិយវិបស្សនា បានដល់ ជាវិបស្សនាបញ្ញាដែលជាលោកិយ ។ ពីរបទថា **សា លោកុត្តរវិបស្សនា** សេចក្តីថា បញ្ញាណាប្រារព្ធព្រះនិព្វានឲ្យប្រព្រឹត្តទៅ លោកហៅថា ជាអប្បមាណារម្មណ៍ បញ្ញានោះជាលោកុត្តរវិបស្សនា ព្រោះដូច្នោះ ទើបលោកអាចារ្យ ពោលសំដៅដល់បញ្ញាក្នុងមគ្គ ។ ពិតណាស់ បញ្ញាក្នុងមគ្គនោះ សូម្បីមិនបានកាន់យក នូវសភាវៈ មានភាពជារបស់មិនទៀងជាដើមនៃសង្ខារ ក៏រមែងឃើញដោយពិសេស នូវលក្ខណៈដែលពិតនៃភាពបរិបូណ៌ដោយកិច្ចនៃវិបស្សនា ឬនៃព្រះនិព្វាន ព្រោះដូច្នោះ ទើបលោកហៅថា វិបស្សនា ។ ចំណែកគោត្រភូញាណ ជាអប្បមាណារម្មណ៍ សូម្បី ដូច្នោះ ក៏មិនបានការបញ្ញត្តហៅថា វិបស្សនាឡើយ ព្រោះជាទីតាំងនៃអាវជ្ជនៈរបស់ មគ្គ ។

ការចម្រើន ឈ្មោះថា **អាយ** ដោយអត្ថថា ជាហេតុប្រព្រឹត្តទៅនៃសម្បត្តិទាំងឡាយ ។ ពីរបទថា **តត្ថ កោសល្លំ** សេចក្តីថា កោសល្ល គឺភាពជាបុគ្គលឈ្លាស ឬភាពជាបុគ្គលមុតស្រួចក្នុងការចម្រើននោះ ដែលមានលក្ខណៈវិនាសទៅ របស់វត្ថុដែលមិនជាប្រយោជន៍ និងការកើតឡើងនៃវត្ថុដែលជាប្រយោជន៍ ។

ដើម្បីនឹងសម្តែងអាយកោសល្ល ដែលប្រព្រឹត្តទៅ ដោយចំណែកមួយនោះ ទាក់ទងដោយព្រះបាលីនោះឯង ទើបលោកអាចារ្យពោលពាក្យថា **ឥមេ ធម្មេ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ឥទំ វុច្ចតិ** សេចក្តីថា បញ្ញាក្នុងការលះដោយមិនកើតឡើងនៃអកុសលធម៌ទាំងឡាយនេះ និងក្នុងការកើតឡើង តាំងនៅនៃកុសលធម៌ទាំងឡាយណា នេះហៅថា **អាយកោសល្ល** ។

ការមិនចម្រើន ឈ្មោះថា **អបាយ** ព្រោះជាសភាពទៅប្រាសចាកអាយដែលមានការចម្រើនជាលក្ខណៈ ។ ពីរបទថា **តត្ថ កោសល្លំ** កោសល្ល គឺភាពជាអ្នកឈ្លាសក្នុងអបាយនោះ ដែលមានលក្ខណៈសាបសូន្យទៅនៃប្រយោជន៍ និងការកើតឡើងនៃវត្ថុដែលមិនជាប្រយោជន៍ ឈ្មោះថា **អបាយកោសល្ល** ។ ដើម្បីសម្តែងអបាយកោសល្លនោះ ដែលទាក់ទងនឹងព្រះបាលីនោះឯង ទើបលោកអាចារ្យពោលពាក្យថា **ឥមេ ធម្មេ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ ពីរបទថា **ឥទំ វុច្ចតិ** សេចក្តីថា បញ្ញាក្នុងការរលត់ដោយមិនកើតឡើងនៃកុសលធម៌ទាំងនេះ ឬក្នុងការកើតឡើង តាំងនៅនៃអកុសលធម៌ទាំងឡាយណា នេះឈ្មោះថា អបាយកោសល្ល ។ សួរថា អាយកោសល្លជាបញ្ញាចូរលើកទុកសិន អបាយកោសល្ល ឈ្មោះថា ជាបញ្ញាបានដូចម្តេច ? បុគ្គលណាមួយ ក៏រមែងសម្គាល់យ៉ាងនេះថា ភាពជាអ្នកអាចនឹងញ៉ាំងការមិនចម្រើនឲ្យកើតឡើង គួរនឹងឈ្មោះថា ជាអបាយកោសល្ល តែសេចក្តីនោះ គ្រាន់តែជាមតិរបស់បុគ្គលនោះ ព្រោះហេតុអ្វី ? ព្រោះបុគ្គលមានបញ្ញាប៉ុណ្ណោះ

រមែងដឹងច្បាស់ថា កាលអញកំពុងធ្វើនូវមនសិការយ៉ាងនេះ កុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងមិនកើតឡើង ដែលកើតឡើងហើយ ក៏រមែងរលត់ទៅ ។ អកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើង ដែលកើតឡើងហើយ ក៏រមែងចម្រើនដោយទូទៅ ។ បុគ្គលកាលដឹងយ៉ាងនេះ រមែងមិនញុំាងអកុសលដែលមិនទាន់កើតឲ្យកើតឡើង និងរមែងលះអកុសលដែលកើតឡើងហើយ ។ រមែងញុំាងកុសលដែលមិនទាន់កើតឲ្យកើតឡើង ដែលកើតឡើងហើយ ក៏រមែងឲ្យដល់នូវភាពបរិបូណ៌ដោយភាវនា ។ សូម្បីអបាយកោសល្លយ៉ាងនេះ ក៏ចាត់ជាបញ្ញាដូចគ្នា ដោយប្រការដូច្នេះឯង ។

បទថា **សព្វត្ថ** បានដល់ **សព្វេសុ** ប្រែថា ទាំងពួង ។ ពាក្យថា **តេសំ តេសំ ធម្មានំ** បានដល់ ធម៌ គឺប្រយោជន៍ឧបការៈ និងសេចក្ដីសុខនោះៗ របស់សត្វទាំងឡាយ ។ បទថា **តំខណប្បវត្តំ** សេចក្ដីថា កាលកើតកិច្ច ឬភ័យឡើង មួយរំពេចណា ក៏ប្រព្រឹត្តទៅក្នុងខណៈនោះៗ ឯង ដើម្បីនឹងដោះស្រាយកិច្ច ឬភ័យនោះបាន ។ ការកើតឡើងដោយឋានៈមានដល់កោសល្លនេះ ហេតុនោះ កោសល្លនេះ ឈ្មោះថា **ឋានុប្បត្តិកំ** ប្រែថា មានការកើតឡើងតាមឋានៈ បានដល់ ការកើតឡើងតាម ឋានៈនោះឯង ។ បទថា **តត្រុបាយា** សេចក្ដីថា ជាឧបាយក្នុងករណីនោះៗ ។

បទថា **គហេត្វា** ប្រែថា កាន់យកដោយអំណាចការកំណត់ ដោយន័យថា នេះរូប រូបមានប៉ុណ្ណោះជាដើម ។ បទថា **ឧភយំ គហេត្វា** សេចក្ដីថា កំណត់កាន់យកទាំង ២ យ៉ាង គឺខាងក្នុង និងខាងក្រៅដោយលំដាប់ ។ម្យ៉ាងទៀត សេចក្ដីថា កំណត់កាន់យកដោយមិនញែកខន្ធ ៥ ទាំងអស់ព្រមគ្នាតែម្ដងថា ធម៌ឯណាមួយ មានការកើតឡើងជាធម្មតា ធម៌ទាំងអស់នោះ មានការរលត់ទៅជាធម្មតា ។នេះចាត់ជាវិបស្សនាភិនិវេសរបស់ភិក្ខុអ្នកមានបុណ្យច្រើន ដែលជាអ្នកបំពេញវិបស្សនាមុតស្រួច (តិក្ខបុគ្គល) ។

ពាក្យថា **បុរាវត្តទុក្ខសច្ច** សេចក្តីថា **ញាណដែលប្រព្រឹត្តទៅ** ដោយអំណាចការធ្វើទុក្ខសច្ចឲ្យជាអារម្មណ៍ និងដោយអំណាចការកម្ចាត់សម្មោហៈដែលបិទបាំងទុក្ខសច្ចនោះ ឈ្មោះថា **ញាណក្នុងទុក្ខ** ។ សូម្បីក្នុងពាក្យថា **បុរាវត្តទុក្ខសមុទយៈ** ក៏មានន័យនេះដូចគ្នា ។ សូម្បីក្នុងពីរបទដ៏សេសក៏ដូចគ្នា ។ ពិតណាស់ បច្ចវេក្ខណញ្ញាណឈ្មោះថា ជាញាណដែលបុរាវត្តសច្ចៈទី ៤ ឲ្យប្រព្រឹត្តទៅ ចំណែកញាណ ដែលបុរាវត្តសច្ចៈទី ៣ ឲ្យប្រព្រឹត្តទៅចាត់ជាមគ្គញ្ញាណ គឺញាណដែលបុរាវត្តសច្ចៈក្រៅអំពីនេះនឹងប្រព្រឹត្តទៅ ប្រាកដថា ជាវិបស្សនាញាណនោះឯង ។

ដើម្បីលម្អិតអត្ថន័យដែលលោកពោលទុកដោយបម្រួញថា ញាណ ៤ ដែលដល់នូវភាពបែកធ្លាយក្នុងអត្ថជាដើម ទាក់ទងដោយព្រះបាលីនោះឯង ទើបលោកអាចារ្យពោលពាក្យថា **វុត្តញ្ហេតំ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ ពាក្យថា **ញាណក្នុងអត្ថ** ឈ្មោះថា **អត្ថប្បដិសម្ភិទា** សេចក្តីថា ញាណដែលដល់នូវភាពបែកធ្លាយក្នុងអត្ថ ដែលអាចធ្វើការកំណត់ ការអធិប្បាយ និងវែកញែកនូវប្រភេទនៃអត្ថណា នេះឈ្មោះថា **អត្ថប្បដិសម្ភិទា** ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ ញាណដែលដល់នូវការបែកធ្លាយក្នុងធម៌ ដែលអាចធ្វើការកំណត់ការអធិប្បាយ និងការវែកញែកនូវប្រភេទនៃធម៌ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។ ញាណដែលដល់នូវការបែកធ្លាយក្នុងការពោលដល់និរុត្តិ ដែលអាចធ្វើការកំណត់ការអធិប្បាយ និងការវែកញែកនូវប្រភេទនៃនិរុត្តិ ឈ្មោះថា **និរុត្តិប្បដិសម្ភិទា** ។ ញាណដែលដល់នូវការបែកធ្លាយក្នុងបដិភាណ អាចធ្វើការកំណត់ការអធិប្បាយ និងការវែកញែកនូវប្រភេទនៃបដិភាណ ឈ្មោះថា **បដិភាណ-ប្បដិសម្ភិទា** ។ ប្រភេទនៃនិរុត្តិ និងបដិភាណ គប្បីជ្រាបញែកគ្នា ដោយការចែកការៈ និងដោយអត្ថជាដើម ដែលមាននិរុត្តិ និងបដិភាណនោះជាអារម្មណ៍ ជាការៈដែលជាបច្ច័យ និងកើតអំពីបច្ច័យជាដើម ។

សូម្បីនិព្វានក៏ឈ្មោះថា **អត្ថ** ដោយអត្ថថា ដែលបុគ្គលដល់ គឺចាក់ចុះតាមគន្លងនៃហេតុឲ្យដល់ព្រម ( សម្បាបកហេតុ ) ។ ដោយពាក្យថា ធម៌ឯណាមួយកើតអំពីបច្ច័យ នេះលោកកាន់យកសច្ចៈ មានទុក្ខជាដើម ដែលមកក្នុងសច្ចវារៈ ហេតុវារៈ ធម្មវារៈ និងបច្ចយាការវារៈ ។ និព្វានដែលមកក្នុងសច្ចវារៈ និងបច្ចយាការវារៈ អត្ថនៃភាសិតដែលមកក្នុងបរិយត្តិវារៈ វិបាក និងកិរិយាដែលមកក្នុងអភិធម្មភាជនីយ៍ គប្បីជ្រាបអត្ថ ៥ យ៉ាង ដោយអំណាចនៃពាក្យដែលលោកបានពោលទុកហើយក្នុងព្រះបាលីនោះឯង ដោយប្រការដូចពោលមកនេះ ។ បទថា **ទហតិ** ប្រែថា រមែងចាត់ចែងពាក្យនេះជាវិគ្គហៈដែលទូទៅដល់ហេតុទាំងឡាយ មានហេតុកើត ( និព្វត្តកហេតុ ) ជាដើម ។ ដើម្បីអធិប្បាយសេចក្ដីប្រការនេះ ទើបលោកអាចារ្យពោលថា រមែងឲ្យប្រព្រឹត្តទៅខ្លះ រមែងឲ្យដើម្បីការដល់ព្រមខ្លះ ។ ក្នុងបណ្ដាអត្ថ ៥ យ៉ាងនោះ អត្ថខាងដើម បណ្ឌិតគប្បីឃើញក្នុងធម៌ដែលវៀរចាកមគ្គទាំងឡាយ ។ សូម្បីភាសិតក៏រមែងញ៉ាំងអត្ថន័យឲ្យប្រព្រឹត្តទៅ ដោយអំណាចការធ្វើឲ្យពិចារណាដឹង ចំណែកមគ្គរមែងធ្វើឲ្យដល់និព្វាន ព្រោះដូច្នោះ ទើបជាអត្ថខាងក្រោយ ក្នុងអត្ថខាងដើមនោះ ។ សេចក្ដីពិត អត្ថមាន ៣ យ៉ាង យ៉ាងនេះគឺ ១- និព្វាន ជាអត្ថដែលគប្បីសម្រេច ២- អត្ថនៃភាសិតជាអត្ថដែលគប្បីធ្វើឲ្យដឹង ៣- ក្រៅអំពីនេះជាអត្ថ ដែលគប្បីធ្វើឲ្យកើតឡើង ។

គប្បីជ្រាបធម៌ ៥ យ៉ាង ទាក់ទងនឹងធម៌ដែលបានពោលទុកហើយក្នុងព្រះបាលីនោះឯង យ៉ាងនេះ គឺអរិយសច្ច មានសមុទយៈជាដើម ដែលមកហើយក្នុងសច្ចវារៈ ហេតុវារៈ ធម្មវារៈ និងបច្ចយាការវារៈ លោកអាចារ្យកាន់យកហើយ ដោយពាក្យនេះថា ហេតុដែលញ៉ាំងផលឲ្យកើតឡើងឯណានីមួយ មគ្គដែលមកហើយ ក្នុងសច្ចវារៈ និងបច្ចយាការវារៈ ភាសិតដែលមកហើយក្នុងបរិយត្តិវារៈ កុសល អកុសល ដែលមកហើយក្នុងអភិធម្មភាជនីយ៍ ។ ក្នុងធម៌ ៥ យ៉ាងនោះ គប្បីជ្រាបហេតុ ៣ យ៉ាងនេះ

គឺមគ្គ ឈ្មោះថា **សម្បាបកហេតុ** ( ហេតុដែលឲ្យដល់ព្រម ) ភាសិត ឈ្មោះថា **ញាបកហេតុ** ( ហេតុដែលធ្វើឲ្យដឹង ) ក្រៅអំពីនេះឈ្មោះ **និព្វត្តកហេត** ( ហេតុដែលធ្វើផលឲ្យកើតឡើង ) ។ ក្នុងអធិការនេះ លោកមិនបានពោលភាពដែលកិរិយាថាជាធម៌ ព្រោះភាពដែលកិរិយាមិនមានវិបាក ។ បើយ៉ាងនោះ ក៏មិនគួរនឹងពោល សូម្បីកិរិយាថា ជាអត្ថព្រោះវិបាកមិនមានក៏ទេ ព្រោះកិរិយាជាបច្ចយុប្បន្នធម៌ ។ ប្រសិនបើមានពាក្យសួរថា កាលបើយ៉ាងនេះ សូម្បីកុសល និងអកុសល ក៏នឹងត្រូវជាអត្ថដែរ សេចក្ដីនេះក៏មិនខុស ព្រោះមិនបានសម្រេចដោយចំពោះ ។ លោកពោលថា កុសល និងអកុសលនោះជាធម៌នោះឯង ព្រោះជាសភាវៈប្រាកដដោយជាហេតុ ដែលជាប្រធាននៃវិបាក ។ ប្រសិនបើសួរថា កិរិយាក៏ត្រូវ តែជាធម៌ដែរ ព្រោះជាបច្ច័យនេះ សេចក្ដីនេះក៏មិនខុស ព្រោះមិនមែនសម្រេចចំពោះ ។ តែលោកមិនបានពោលថាជាធម៌ ព្រោះមិនមានភាពជាហេតុនៃភាពសម្ពន្ធជាមួយកម្ម និងផលរបស់កម្ម ។ ម្យ៉ាងទៀត គប្បីឃើញថា កាលពិចារណាកុសល អកុសល និងធម៌ គឺវិបាក និងកិរិយាតែម្យ៉ាង មិនបានធ្វើការចែកយ៉ាងនេះថា ធម៌នេះជាបច្ច័យរបស់ធម៌នេះ ធម៌នេះកើតអំពីបច្ច័យ ដូច្នេះ ។ ធម្មប្បដិសម្ភិទា និងអត្ថប្បដិសម្ភិទា ក៏រមែងសម្រេចបាន ព្រោះដូច្នោះ ទើបលោកមិនពោលថា កុសលធម៌ អកុសលធម៌ គឺវិបាក និងកិរិយាទាំងនោះជាអត្ថថាជាធម៌ ។

បទថា **អយមេវ ហិ អត្ថោ** ក្នុងសេចក្ដីថា អត្ថន័យនេះ ដែលលោកអាចារ្យពោលទុកដោយអំណាចការចែកអត្ថ និងធម៌មួយ ជាប្រាំៗ អត្ថន័យនេះឯង ព្រះសាស្ដាទ្រង់សម្ដែងចែកហើយក្នុងព្រះអភិធម្ម ។

លោកអាចារ្យពោលថា **សភាវនិរុត្តិ** សេចក្ដីថា និរុត្តិដែលមិនវិបរិត ព្រោះអធិប្បាយថា **ធម្ម**-ស័ព្ទ ក្នុងបទថា **ធម្មនិរុត្តាភិលាបេ** នេះ ជាស័ព្ទប្រាប់ដល់សភាវៈ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា ជាវោហារដែលមិនមានការប្រែប្រួល

សេចក្តីថា ជាសទ្ទវោហារដែលមានសម្ពន្ធពិតប្រាកដចំពោះ ក្នុងការដែលនឹងឲ្យយល់សេចក្តីនោះៗ ។ បទថា **តទភិលាបេ** សេចក្តីថា ក្នុងការពោលវោហារដែលមិនមានការប្រែប្រួលនោះ ដែលសន្មតគ្នាហៅថា **សភាវនិរុត្តិ** ។ សភាវនិរុត្តិនេះ បានដល់ភាសារបស់អ្នកមគធៈ ។ អាចារ្យទាំងឡាយពោលដោយអត្ថ បានដល់ នាមបញ្ញត្តិ ។ ចំណែកអាចារ្យមួយពួកទៀតពោលថា ប្រសិនបើសភាវនិរុត្តិ ជាបញ្ញត្តិសោត កាលបើដូច្នេះ បញ្ញត្តិក៏នឹងត្រូវប្រើនិយាយចរចាគ្នា ក៏ត្រូវនិយាយថា មិនមែនជាពាក្យពោល ។ តែពាក្យដែលគប្បីចរចាគ្នា ដែលនឹងបន្ទឺចេញមកផ្សេងទៅ អំពីពាក្យពោលដែលមានក៏ទេ កាលបើដូច្នោះពាក្យសម្តីដែលនឹងគប្បីឲ្យយល់បាន ដោយពាក្យសម្តីមានផស្សៈជាដើម ក៏នឹងគប្បីជាពាក្យសម្តីប្រើចរចាគ្នា និងកាលបើយ៉ាងនេះ សូម្បីអត្ថ និងធម៌ក៏នឹងត្រូវឲ្យយល់ ដូច្នោះ អត្ថ និងធម៌ទាំងនេះ ក៏នឹងត្រូវជានិរុត្តិ ។ លោកសម្តែងអត្ថទុក ដូច្នេះនោះឯងថា ក៏ពាក្យថា **ផស្សោ** ជាសភាវនិរុត្តិ ពាក្យថា **ផស្សំ ផស្សា** មិនមែនសភាវនិរុត្តិ ។ វត្ថុដែលមិនមែន ពាក្យពោលមានប្រការយ៉ាងនេះ នឹងមានក៏ទេ ។ ព្រោះដូច្នោះ គប្បីឃើញអត្ថថា ក្នុងការចរចា គឺក្នុងការបន្ទឺនូវសភាវនិរុត្តិនោះដែលជាពាក្យកំពុងពោលនោះឯង ។

ញាណដែលដល់ភាពបែកធ្លាយក្នុងការចរចាសភាវនិរុត្តិនោះ របស់លោកដែលធ្វើសំឡេង គឺសភាវនិរុត្តិនោះឲ្យជាអារម្មណ៍ ពិចារណាឈ្មោះថា **និរុត្តិប្បដិសម្ភិទា** ។ ព្រោះលោកពោលទុកក្នុងអដ្ឋកថាថា និរុត្តិប្បដិសម្ភិទានេះ ឈ្មោះថា មានសំឡេងជាអារម្មណ៍ មិនមែនមានបញ្ញត្តិជាអារម្មណ៍ទេ ដូច្នេះ ទើបលោកអាចារ្យទាំងឡាយពោលថានិរុត្តិប្បដិសម្ភិទាមែងប្រព្រឹត្តទៅក្នុងមនោទ្វារ ខាងមុខតអំពីសោតវិញ្ញាណវិថីដែលមានសំឡេង គឺនិរុត្តិជាអារម្មណ៍ ។ ពាក្យថា **និរុត្តិប្បដិសម្ភិទាមានអារម្មណ៍ជាបច្ចុប្បន្ន** ត្រាស់សំដៅដល់ការចាប់យកសំឡេង គឺពាក្យពោលហើយដឹងក្នុងកាល

ជាក្រោយ ។ កាលបើដូច្នេះ ក៏ត្រូវពោលថា ពោលអារម្មណ៍បច្ចុប្បន្នមយ៉ាង ក្នុងអារម្មណ៍បច្ចុប្បន្នមយ៉ាងទៀត ។ ឧបមាដូចទិព្វសោតញ្ញាណ ដែលជាបច្ច័យនៃការកាត់សម្រេចប្រភេទសំឡេងរបស់សត្វ មានមនុស្សជាដើម ធ្វើឲ្យយល់សំឡេងនោះៗបានយ៉ាងណា ញាណដែលជាបច្ច័យនៃការកាត់សម្រេចថា សការនិវុត្តិ ឬមិនមែនសការនិវុត្តិ មានសំឡេង គឺសការនិវុត្តិដែលជាបច្ចុប្បន្នជាអារម្មណ៍ ធ្វើឲ្យយល់សំឡេង គឺសការនិវុត្តិនោះបាន ឈ្មោះថា និវុត្តិប្បដិសម្ភិទាក៏ដូច្នោះ កាលពោលដូច្នេះក៏មិនខុសអំពីព្រះបាលីអ្វីឡើយ ។ ពាក្យថា **របស់អ្នកដែលធ្វើសំឡេង គឺសការ-និវុត្តិនោះឲ្យជាអារម្មណ៍ឲ្យពិចារណា** មិនអាចនឹងពោលថា របស់លោកដែលញ៉ាំងការពិចារណា ដែលមានសំឡេងបច្ចុប្បន្នជាអារម្មណ៍ឲ្យប្រព្រឹត្តទៅ ។ ពិតណាស់ញាណនោះ កាលធ្វើឲ្យយល់សការនិវុត្តិនោះឯង រមែងកើតឡើងចាក់ធ្លុះវែកញែកនិវុត្តិបាននោះឯង ព្រោះភាពជាហេតុកាត់សម្រេចប្រភេទនោះៗ ក្នុងលំដាប់ការពិចារណាសំឡេងនោះៗ ។ ព្រោះដូច្នោះ ទើបជាញាណទាំងដែលដល់នូវភាពបែកធ្លាយផងដូច្នេះឯង ។

ពីរបទថា **សព្វត្ថ ញាណំ** សេចក្តីថា ញាណក្នុងអារម្មណ៍គ្រប់យ៉ាង អធិប្បាយថា ញាណទាំងអស់ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ញាណ មានញាណជាអារម្មណ៍** ។ មយ៉ាងទៀត បទថា **សព្វត្ថ** ប៉ុនគ្នានឹង **សព្វេសុ យោគ អត្ថាទីសុ** ប្រែថា ក្នុងពាក្យទាំងពួង បានដល់ ពាក្យទាំងឡាយ មានអត្ថជាដើម លោកអាចារ្យពោលថា **សព្វត្ថ ញាណំ** ព្រោះប្រព្រឹត្តទៅហើយក្នុងធម៌ទាំង ៣ ឬក្នុងធម៌ទាំង ៤ ឬព្រោះប្រព្រឹត្តទៅហើយក្នុងធម៌ទាំង ៣ ប៉ុណ្ណោះ ព្រោះបដិភាណប្បដិសម្ភិទាដែលជាកុសលចិត្ត ចាត់ជាធម៌ដែលជាកិរិយាចិត្ត ចាត់ជាអត្ថ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **យថា វុត្តេសុ វា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **សគោចរ-**

**កិច្ចាទិវសេន** សេចក្តីថា ញាណនេះធ្វើអារម្មណ៍ឈ្មោះនេះប្រព្រឹត្តទៅដោយកិច្ចឈ្មោះនេះ ដូច្នេះ ដោយអំណាចអារម្មណ៍របស់ខ្លួន និងកិច្ចជាដើម ។ ដោយ **អាទិ**-ស័ព្ទ លោកអាចារ្យសង្គ្រោះយកលក្ខណៈ បច្ចុប្បដ្ឋានបទដ្ឋាន និងភូមិជាដើម ។ ដោយហេតុនោះឯង ទើបត្រាស់ថា ញាណទាំងនេះ ធ្វុះបញ្ចាំងសេចក្តីទាំងនេះឲ្យភ្លឺស្វាងដូច្នេះជាដើម ។

ពីរបទថា **បភេទំ គច្ឆន្តិ** សេចក្តីថា រមែងចូលដល់ភាពជាអ្នកអាចស្ទង់ដឹងប្រភេទនោះៗ តាមសេចក្តីពិតក្នុងអារម្មណ៍ទាំងឡាយ ដែលផ្សេងគ្នាដោយប្រភេទមិនមែនតិចតួច ។

លោកប្រើស័ព្ទថា **អានន្ទត្ថេរ** ដើម្បីនឹងហាមឃាត់ការពោលជំទាស់នូវអត្ថដែលសម្តែងទុកដោយវិធីសាមញ្ញថា ឯបដិសម្ភិទារបស់ព្រះមហាសាវកទាំងឡាយដល់នូវភាពបែកធ្លាយក្នុងអសេក្ខភូមិ ដូច្នេះ ។

**ឯតា យោគ បដិសម្ភិទា** ការដល់នូវភាពបែកធ្លាយក្នុងសេក្ខភូមិមានវិស័យតិចក្នុងអសេក្ខភូមិ មានវិស័យច្រើន ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា ការសម្រេចព្រះអរហត្ត ឈ្មោះថា ការសម្រេច ម្យ៉ាងទៀត លោកអាចារ្យពោលទុកយ៉ាងនេះសំដៅដល់ការសម្រេចដែលល្អក្រៃលែង ព្រោះបដិសម្ភិទាទាំងនេះ សូម្បីព្រះសេក្ខៈសម្រេចហើយ នឹងដល់នូវភាពផូរផង់បាន ក៏ដោយការសម្រេចព្រះអរហត្ត ។ តែការសម្រេចព្រះអរហត្ត នឹងមិនជាបច្ច័យដល់ភាពផូរផង់នៃបដិសម្ភិទាដល់ព្រះអរហន្ត ដូចបុព្វយោគទេ ដូច្នោះ បណ្ឌិតគប្បីប្រកបសេចក្តីដែលអាការទាំង ៥ ជាហេតុនៃភាពផូរផង់នៃបដិសម្ភិទារបស់សេក្ខបុគ្គល និងអសេក្ខបុគ្គលតាមសមគួរចុះ ។ ធម៌មានបរិយត្តិជាដើម ដែលមានព្រះពុទ្ធវចនៈជាវិស័យ លោកសម្តែងទុកហើយ ព្រោះសង្គ្រោះទុកមិនឲ្យមានចំណែកសេសសល់នូវធម៌ មានអត្ថ និងធម៌ជាដើម ។ ការស្វាធ្យាយ

ព្រះបាលី ឈ្មោះថា **ការសួចរៀន** ការស្ដាប់អត្ថរបស់ព្រះបាលីនោះ ឈ្មោះថា **ការស្ដាប់** ការប្រាថ្នាដើម្បីដឹងដោយជុំវិញ គឺដោយប្រការទាំងពួង ឈ្មោះថា **បរិបុច្ឆា** ព្រោះហេតុនោះ ទើបលោកពោលថា **ការពោលវិនិច្ឆ័យក្នុងគណ្ឋីបទ នៃអត្ថបទក្នុងព្រះបាលី និងអត្ថបទជាដើម** ដូច្នេះ អធិប្បាយថា ការពោលប្រការយល់ព្រមដោយពិស្ដារនៃបទដែលមានឋានៈលំបាកនឹងយល់ដោយអត្ថចំពោះបទ និងដោយអធិប្បាយៗពិតណាស់ អត្ថនៃបទណាដែលលំបាកយល់ បទនោះ ឈ្មោះថា **គណ្ឋីបទ** ពាក្យអធិប្បាយបទណាគប្បីយល់បានលំបាក បទនោះ ឈ្មោះថា **អត្ថបទ** ។ ដោយ **អាទិ-ស័ព្ទ** លោកសង្គ្រោះកថាមគ្គទាំងឡាយ ដែលបដិសំយុត្តដោយធម៌ មានខន្ធជាដើមចូលផង ។ ការទៅ និងការថយក្រោយ ដែលប្រកបដោយភាវនានុយោគមានដល់បុគ្គលនេះ ហេតុនោះ បុគ្គលនេះ ឈ្មោះថា **គតបច្ចាគតិកោ** ភាវៈនៃបុគ្គលដែលមានការទៅ និងការថយក្រោយនោះ ដោយភាវៈដែលមានការទៅ និងការថយក្រោយនោះ ។ អធិប្បាយថា ដែលប្រកបរឿយៗ នូវកម្មដ្ឋានអំពីលំនៅ រហូតដល់គោចរគ្រាម និងអំពីគោចរគ្រាមនោះរហូតដល់ទីលំនៅ ។ លោកអាចារ្យពោលដល់សង្ខារុបេក្ខាញាណថា **រហូតដល់ជិតអនុលោមញ្ញាណ និងគោត្រភូញាណ** ពាក្យនោះប្រព្រឹត្តទៅជិតរបស់ញាណទាំងនោះ ។

ពាក្យថា **ក្នុងសាស្ត្រទាំងឡាយ** បានដល់ ក្នុងគម្ពីរទាំងឡាយដែលមិនមានទោស គឺនាំប្រយោជន៍មកឲ្យដល់សត្វទាំងឡាយ ។ សូម្បីក្នុងបទថា **អាយតន គឺសិប្បៈ** នេះ ក៏ដូចគ្នា ។ ភាសាកំណើតរបស់ព្រះរាជា ១០១ អង្គ ក្នុងកាលមុន ឈ្មោះថា **វោហារ ១០១** ។ អាចារ្យទាំងឡាយពោលថា យមកវគ្គ ក្នុងធម្មបទ ឈ្មោះថា **ឱបម្មវគ្គ** អាចារ្យមួយពួកទៀតពោលថា ក្នុងគម្ពីរមូលបណ្ណាសកៈឈ្មោះថា ឱបម្មវគ្គ ដូចគ្នា ។ ពាក្យថា **បុគ្គលចម្រើនដោយសុតៈ និងបដិភាណ** គឺជាពហុសូត មានបដិភាណ ។

បទថា **សព្វានិ** បានដល់ ហេតុ ៥ យ៉ាងដែលពោលទុកខាងដើម ឬហេតុ ៨ យ៉ាងដែលពោលទុកខាងចុងក៏បាន ។ ការសម្រេចបដិសម្ភិទា មានក្នុងទីបំផុតនៃវិមោក្ខ ដែលជាផលនៃព្រះសេក្ខៈ ឈ្មោះថា **សេក្ខផលវិមោក្ខន្តិកា** ប្រែថា មានក្នុងទីបំផុតនៃវិមោក្ខ ដែលជាផលនៃព្រះសេក្ខៈ ។ កម្លាំងទាំងអស់ មានឋានាឋានញ្ញាណជាដើម ប្រាកដច្បាស់ដោយកិច្ចរបស់ខ្លួន ក្នុងព្រះពុទ្ធគុណទាំងអស់ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដូចកម្លាំងទាំង ១០ របស់ព្រះតថាគត** ។ មួយវិញទៀត ព្រះគុណវិសេសទាំងឡាយរបស់ព្រះមានព្រះភាគទាំងអស់ មានព្រះសព្វញ្ញុតញ្ញាណជាដើមដទៃពីនេះក៏ឈ្មោះថា **អសេក្ខផលវិមោក្ខន្តិកា** ដែលប្រែថា មាននៅក្នុងទីបំផុតនៃវិមោក្ខ ដែលជាផលនៃព្រះអសេក្ខៈដូចគ្នា ។

# វិសុទ្ធិមគ្គ

## ៥ បញ្ញានឹងគប្បីបំពេញឡើងបានដូចម្ដេច

ចំណែកក្នុងបញ្ហាកម្មទី ៥ ថា បញ្ញានឹងគប្បីបំពេញឡើងបានដូចម្ដេចនេះ មានពណ៌នាថា ព្រោះហេតុដែលធម៌ទាំងឡាយដែលចែកប្រភេទជាខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ សច្ចៈ និងបដិច្ចសមុប្បាទជាដើម ជាភូមិ ( ទីកើត ) របស់បញ្ញានេះ វិសុទ្ធិ ២ គឺសីលវិសុទ្ធិ និងចិត្តវិសុទ្ធិជាមូល ជាឫសគល់ ។ វិសុទ្ធិ ៥ នេះ គឺទិដ្ឋិវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ បដិបទាញាណទស្សនវិសុទ្ធិ ញាណទស្សនវិសុទ្ធិ ជាសរីរៈ ( ជាកាយ ឬតួ ) របស់បញ្ញានេះ ព្រោះហេតុនោះ បញ្ញានោះ ភិក្ខុដែលធ្វើការសន្សំការដឹងដោយសួរៀន និងសាកសួរក្នុងធម៌ទាំងឡាយ ដែលជាភូមិទាំងនោះហើយ ញុំាងវិសុទ្ធិ ២ ដែលជាមូលឲ្យដល់ព្រមហើយធ្វើវិសុទ្ធិ ៥ ដែលជាសរីរៈឲ្យដល់ព្រមនោះឯង និងគប្បីបំពេញឡើងបាន នេះជាសេចក្ដីសង្ខេប ក្នុងបញ្ហាកម្មនេះចំណែក សេចក្ដីតទៅនេះ ជាសេចក្ដីពិស្ដារ ។

# មហាដីកា

## ពណ៌នាការចែកភូមិ មូល និងសរីរៈនៃបញ្ញា

ពាក្យថា នៃបញ្ញានេះ បានដល់ នៃវិបស្សនាបញ្ញា ។ ឈ្មោះថា ភូមិ ព្រោះភាវៈគឺជាទីតាំងនៃការប្រព្រឹត្តទៅដោយអំណាចនៃការកាន់យកអាការ មានការកំណត់ជាដើម ។ ដោយ **អាទិ**-ស័ព្ទ គប្បីឃើញការសង្គ្រោះអាហារជាដើមចូលផង ។ សួរថា ក៏ធម៌ច្រើនយ៉ាងទាំងនេះលោកកាន់យកដោយភាវៈជាភូមិ ព្រោះហេតុអ្វី ក្នុងបណ្ដាធម៌ទាំងឡាយ មានខន្ធជាដើម សូម្បីដោយធម៌ ១ ក៏មានការសម្រេចប្រយោជន៍ មិនមែនឬ ? ឆ្លើយថា មិនមែនទេ ត្រូវធ្វើការកាន់យកធម៌ ៣ ពួក មានខន្ធជាដើម ដើម្បីអនុគ្រោះសត្វ ៣ ជំពូក កាលកាន់យកអត្ថ ដោយប្រការដទៃ ក៏មិនគប្បីជាការធ្វើការអនុគ្រោះទូទៅដល់សត្វគ្រប់ជំពូក ។ ពិតណាស់ សត្វទាំងឡាយមាន ៣ ជំពូក គឺពួកដែលវង្វេង ( លិចចុះ ) ក្នុងរូប ១ ពួក ដែលវង្វេងនៅក្នុងអរូប ១ ពួក ដែលវង្វេងទាំង ២ ចំណែក ១ ពួក ។ ក្នុងបណ្ដាសត្វ ៣ ពួកនោះ លោកកាន់យកខន្ធដើម្បីជាប្រយោជន៍ដល់សត្វជំពូក ដែលវង្វេងនៅក្នុងអរូប ព្រោះអរូបធម៌ទាំងឡាយចែកបានជា ៤ ប្រការ ។ លោកកាន់យកអាយតនៈដើម្បីជាប្រយោជន៍ដល់សត្វជំពូកដែលវង្វេងនៅក្នុងរូប ព្រោះរូបធម៌ទាំងឡាយចែកបានជា ១០ ប្រការកន្លះ ។ ចំណែកលោកកាន់យកធាតុទាំងឡាយ ក៏ដើម្បីជាប្រយោជន៍ដល់សត្វជំពូក ដែលវង្វេងនៅក្នុងទាំង ២ ចំណែក ព្រោះលោកចែកទុកទាំង ២ ចំណែក ។ម្យ៉ាងសត្វទាំងឡាយមាន ៣ ជំពូកដោយភាពផ្សេងគ្នានៃឥន្ទ្រិយ គឺពួកដែលមានឥន្ទ្រិយចាស់ក្លា ពួកដែលមានឥន្ទ្រិយជាកណ្ដាល ពួកដែលមានឥន្ទ្រិយទន់ខ្សោយ និងមាន ៣ ពួកទៀត គឺពួកដែលពេញចិត្តក្នុងអត្ថយ៉ាងសង្ខេប ពួកដែលពេញចិត្តក្នុងអត្ថយ៉ាងកណ្ដាល ពួកដែល

ពេញចិត្តក្នុងអត្ថយ៉ាងពិស្តារ លោកធ្វើការកាន់យកធម៌ មានខន្ធជាដើមទុកជាលំដាប់ ដើម្បីជាប្រយោជន៍ដល់សត្វទាំងនោះ ។ ម្យ៉ាងទៀត ការកាន់យកឥន្ទ្រិយក៏ដើម្បីនឹងកាន់យកបានដោយងាយនូវអនត្តលក្ខណៈថា ធម៌ទាំងនេះរមែងញុំាងឥស្សរិយៈ គឺភាពជាធំក្រៃលែងឲ្យប្រព្រឹត្តទៅនៅក្នុងសហជាតធម៌ទាំងឡាយ ដូចលោកអ្នកដែលជាធំទាំងឡាយក៏ពិត សូម្បីយ៉ាងនោះ ឥស្សរិយៈនោះក៏បានសម្រេចហើយដោយធម្មសភាវៈរបស់សហជាតធម៌ទាំងនោះ មិនមែនសភាវៈដែលធម៌ណាមួយ នឹងទៅមានអំណាចនៅក្នុងសហជាតធម៌ទាំងនោះឡើយ ទើបសហជាតធម៌ទាំងនោះទទេមិនធ្លាក់នៅក្នុងអំណាចអ្វីឡើយ ។ ម្យ៉ាងទៀត សច្ចៈទាំង ៤ នេះ ដែលឃើញហើយដោយអំណាចទុក្ខសច្ច និរោធសច្ច និងហេតុនៃទុក្ខសច្ច និងនិរោធសច្ចទាំង ២ នោះប៉ុណ្ណោះ ទើបនាំមកនូវឧបការៈដែលឃើញដោយប្រការដទៃ មិននាំមកនូវឧបការៈឡើយ ព្រោះដូច្នោះ ទើបលោកកាន់យកធម៌ ២ យ៉ាង មានសច្ចៈជាដើម ។ ន័យនេះគប្បីប្រើក្នុងធម៌ ដែលកាន់យកដោយ **អាទិ-ស័ព្ទ** ។ ឈ្មោះថា **ជាមូល** ព្រោះភាវៈជាទីតាំងអាស្រ័យ ។ ព្រោះថា កាលមានសីលវិសុទ្ធិ និងចិត្តវិសុទ្ធិ បញ្ញានេះក៏រមែងជាធម្មជាតិមានមូលកើតហើយ កាលមិនមាន ក៏មិនកើតឡើង ដូច្នេះ ។ ឈ្មោះថា **ជាសរីរៈ** ព្រោះគប្បីពង្រីកទៅដោយជុំវិញ ។ ដោយវិសុទ្ធិទាំង ៥ នេះ មានទិដ្ឋិវិសុទ្ធិជាដើមនៅក្នុងឋានៈជាជើង ជាដៃ និងជាក្បាលរបស់បញ្ញានេះ ដែលប្រព្រឹត្តទៅដោយអំណាចការបន្តគ្នា គប្បីជ្រាបថា ឈ្មោះថា **ជាសរីរៈ** ដោយអវយវៈ គឺដោយន័យនៃការចូលទៅកំណត់សេចក្តីរួម ។

# វិសុទ្ធិមគ្គ

## ភូមិរបស់បញ្ញា

ពាក្យណា ខ្ញុំពោលទុកថា ធម៌ទាំងឡាយដែលចែកប្រភេទជាខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ សច្ចៈ និងបដិច្ចសមុប្បាទ ជាភូមិរបស់បញ្ញានេះដូច្នេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យសេចក្ដីក្នុងពាក្យនោះជាលំដាប់ដំបូង ។

## ខន្ធ

ពាក្យថា ខន្ធ បានដល់ ខន្ធ ៥ គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ។

## រូបក្ខន្ធ

ក្នុងខន្ធ ៥ នោះ ធម្មជាតិដែលមានការបែកធ្លាយទៅ ទ្រោមទៅព្រោះបច្ច័យដែលជាសត្រូវទាំងឡាយ មានត្រជាក់ជាដើមជាលក្ខណៈគ្រប់យ៉ាង គប្បីជ្រាបថាឈ្មោះថា រូបក្ខន្ធ ( គំនររូប ) ព្រោះហៅរួមធម្មជាតិទាំងពួងនោះ ចូលជាមួយគ្នា ឯធម្មជាតិនេះមាន ១ដោយលក្ខណៈគឺការបែកធ្លាយ តែមាន ២ ដោយចែកជាភូតរូប និងឧបាទាយរូប ។

## ភូតរូប

ក្នុងរូប ២ យ៉ាងនោះ ភូតរូបមាន ៤ គឺបឋវីធាតុ អាបោធាតុ តេជោធាតុ និងវាយោធាតុ ។ លក្ខណៈ រស បច្ចុប្បដ្ឋានរបស់ធាតុ ៤ នោះ បានពោលទុកហើយក្នុងចតុធាតុវវដ្ឋាន តែពោលដោយបទដ្ឋាន ធាតុគ្រប់យ៉ាងនោះ ធាតុនីមួយៗ ក៏មានធាតុដ៏សេស ៣ ទៀតជាបទដ្ឋាន ។

# មហាដីកា

ពាក្យថា ៥ ក្នុងពាក្យថា ខន្ធ ៥ នេះជាពាក្យកំណត់ការរាប់ ពាក្យថា ៥ នោះ ព្រះមានព្រះភាគទ្រង់សម្ដែងថា មិនតិចជាងនោះ មិនច្រើនជាងនោះ ។ ពាក្យថា **ខន្ធ** ជាពាក្យសម្ដែងលម្អិតធម៌ ដែលទ្រង់កំណត់ទុក ។ ព្រោះក្នុងទីនេះ **ខន្ធ**-សព្ទ មានអត្ថថា គំនរ ដូចក្នុងពាក្យទាំងឡាយថា **មហាឧទកក្ខន្ធោ** ប្រែថា អន្លង់ទឹកធំជាដើម ដូច្នេះ គប្បីកាន់យករូបទាំងអស់ដែលចែកដោយវិភាគ មានរូបអតីតជាដើម ជាពួកជាមួយគ្នាតាមការត្រាស់ដឹង ដោយអំណាចជាគំនរ ហើយគប្បីឃើញជាសមាសដែលជាសមានាធិករណៈថា **រូបមេវ ខន្ធោ រូបក្ខន្ធោ** គំនរ គឺរូប ឈ្មោះថា រូបក្ខន្ធ ។ សួរថា ម្យ៉ាងទៀត ក្នុងខន្ធសព្ទ មានអត្ថថា ចំណែក ដូចក្នុងប្រយោគថា **តីហិ ខន្ធេហិ ឥណំ ទស្សាម** ប្រែថា អញនឹងចែកបំណុលចេញជា ៣ ចំណែកដូច្នេះជាដើម សូម្បីនិព្វានក៏នឹងត្រូវជាខន្ធមួយទៀតឬ ? ឆ្លើយថា មិនត្រឹមត្រូវទេ ព្រោះនិព្វាន មិនមានការចែកជាអតីតជាដើម ដូច្នេះ ព្រោះថា និព្វានជាធម៌ឯក ជាធម្មជាតិទៀង ទើបមិនមានការចែកជាអតីតជាដើមឡើយ ដូច្នេះ ។ តាមអត្ថប្រការទី ១ មានអត្ថថា គំនរ គឺរូប តាមអត្ថប្រការទី ២ មានន័យថា ចំណែក គឺរូប ។ សូម្បីក្នុងពាក្យថា **វេទនាខន្ធ** ជាដើម ក៏មានន័យនេះដូចគ្នា ។ សួរថា ព្រោះហេតុអ្វី ទើបខន្ធទាំងនេះត្រាស់ទុក ៥ ប៉ុណ្ណោះ និងត្រាស់ទុកតាមលំដាប់នេះប៉ុណ្ណោះឬ ? ឆ្លើយថា ព្រោះសម្ដែងការចែកទុកដូចជាភាជនៈ ដូចជាភោជន ដូចម្ហូប ដូចចុងភៅ និងដូចអ្នកបរិភោគ និងព្រោះទ្រង់ណែនាំទៅតាមខន្ធដែលគ្រោតគ្រាត និងខន្ធដែលសៅហ្មង ។ វេទនា និងសញ្ញា

លោកសម្តែងទុកជាខន្ធ មួយចំណែកទៀត បំបែកចេញទៅអំពីសង្ខារក្ខន្ធ ដោយទ្រង់ពិចារណាដល់ភាពជាហេតុនៃវិវាទមូល ភាពជាហេតុនៃសង្សារវដ្ត និងភាពជាហេតុនៃកម្ម ។

## កថាពណ៌នាដោយរូបក្ខន្ធ

បទថា **តត្ថ** ប៉ុនគ្នានឹង **តេសុ យោគ បញ្ចសុ ខន្ធេសុ** ប្រែថា ក្នុងបណ្តាខន្ធទាំង ៥ នោះ ។ បទថា **យង្កិញ្ចិ** ជាពាក្យកំណត់កាន់យកដោយមិនមានសេសសល់ ។ ពាក្យថា **រុប្បនលក្ខណំ** ជាពាក្យកំណត់សេចក្តីបំណងយ៉ាងក្រៃលែង ។ កាលត្រូវបំណងយ៉ាងក្រៃលែងដោយការៈដែលប្រាកដ **កឹ**-ស័ព្ទ មានអត្ថជាអនិយម ដែលលោកប្រើ **យំ**-ស័ព្ទ និង **កឹ**-ស័ព្ទ ព្រមទាំងនិបាត **រុប្បន**-ស័ព្ទ ក៏រមែងហាមឃាត់នូវការៈ ដែល **យង្កិញ្ចិ**-ស័ព្ទ មានអត្ថជាអនិយមនោះ ដោយ **រុប្បន**-ស័ព្ទនោះ ក៏ត្រូវ លោកអាចារ្យធ្វើការកំណត់កាន់យករូប មិនមានចំណែកសេសសល់ ។ បទថា **សីតាទីហិ** សេចក្តីថា ព្រោះវិរោធិប្បច្ច័យ មានត្រជាក់ ក្តៅ ឃ្លាន និងស្រេកជាដើម ។ ពាក្យនេះជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃហេតុ ។ ការប្រែប្រួលជាលក្ខណៈ របស់ធម្មជាតិនេះ ហេតុនោះ ធម្មជាតិនេះ ឈ្មោះថា **រុប្បនលក្ខណំ** ។ ធម៌នោះឯង ឈ្មោះថា **ធម្មជាតិ** ។ ការប្រែប្រួលក្នុងទីនេះ បានដល់ ការកើតឡើងមិនដូចគ្នា ក្នុងកាលវិរោធិប្បច្ច័យ មានត្រជាក់ជាដើមប្រជុំគ្នា ។ សួរថា ការកើតឡើង មិនដូចគ្នា ក្នុងកាលវិរោធិប្បច្ច័យប្រជុំគ្នា ក៏រមែងនឹងបាន សូម្បីដល់អរូបធម៌ទាំងឡាយ មិនមែនឬ ? ឆ្លើយថា បានពិត តែមិនច្បាស់ណាស់ណាទេ ។ ព្រោះក្នុងទីនេះលោកមានបំណងយកការប្រែប្រួលដែលច្បាស់លាស់

ព្រោះប្រើស័ព្ទថា វិភេជិប្បច្ច័យ មានត្រជាក់ជាដើម ។បើយ៉ាងនោះក្នុងព្រហ្មលោក នឹងមានឈ្មោះថា រូបបានដូចម្ដេច ? សូម្បីក្នុងព្រហ្មលោកក៏មានឈ្មោះថារូបដូចគ្នា ព្រោះមិនកន្លងផុតសភាវៈនោះទៅបាននោះឯង ម្យ៉ាងទៀត ដោយអំណាចដែលជាបច្ច័យ ឧបការៈ ។ អាចារ្យពួកដទៃពោលថា ភាវៈដែលជាហេតុកើតឡើងមិនដូចគ្នា នៃរូបដែល កំពុងបែកធ្លាយទៅនោះឯង ក្នុងកាលភាពបន្តរបស់ខ្លួនបែកធ្លាយទៅហើយឯណា ក្នុង កាលវិភេជិប្បច្ច័យប្រជុំគ្នានោះ ឈ្មោះថា ការប្រែប្រួល ។ ក្នុងចំណែកដំបូងឈ្មោះថា រូប ដោយអត្ថថា ធ្វើឲ្យផ្លាស់ប្ដូរ គឺឲ្យដល់នូវវិការ ឯក្នុងចំណែកដំបូងឈ្មោះថា រូប ដោយអត្ថថា ប្រែប្រួល ។ អាចារ្យពួកខ្លះ ពោលថា **រុប្បន-ស័ព្ទ** ជាស័ព្ទរត់មាត់ ប្រើក្នុងការដល់នូវភាពវិការ ដោយការប៉ះខ្ទប់ ។ ក្នុងចំណែកនេះការទាក់ទងគ្នា ឈ្មោះ ថា រូបនោះឯង មិនមានក្នុងអរូបធម៌ឡើយ ព្រោះមិនមានការប៉ះខ្ទប់គ្នា ។ អាចារ្យ មួយពួកទៀតពោលថា ការប៉ះខ្ទប់ចំពោះ ឈ្មោះថា ការប្រែប្រួល ។ បទថា **សព្វន្តំ ឯកតោ កត្វា** លោកអាចារ្យ រមែងពោលតាំងអត្ថថា គំនរ ទុកក្នុងចិត្តថា រួមធម្មជាតិ ទាំងអស់នោះ ចូលជាមួយគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ភូតោបាទាយភេទតោ** នេះតទៅ ឈ្មោះថា **ភូតរូប** ដោយអត្ថថា ជាទីនៅរបស់ឧបាទាយរូប ព្រោះជាធម្មជាតិមានការប្រព្រឹត្តទៅទាក់ទង នឹងឧបាទាយរូបនោះ ឈ្មោះថា **ឧបាទាយរូប** ដោយអត្ថថា អាស្រ័យភូតរូបទាំងឡាយ តែម្យ៉ាង តែខ្លួនឯងមិនបានត្រូវភូតរូបទាំងនោះ ឬរូបពួកដទៃចូលទៅអាស្រ័យឡើយ ។

លោកអាចារ្យពោលថា ខ្ញុំបានពោលលក្ខណៈ រស និងបច្ចុប្បដ្ឋានទុកហើយ

**ក្នុងចតុធាតុវវដ្ឋាន** ដូច្នេះ ព្រោះអធិប្បាយថា ភូតរូបទាំងឡាយបានអធិប្បាយទុកហើយ ក្នុងចតុធាតុវវដ្ឋាន សូម្បីដោយបកិណ្ណកៈមានអត្ថនៃពាក្យជាដើមក៏ពិត សូម្បីយ៉ាងនោះ ក៏នឹងមានការអធិប្បាយបកិណ្ណកៈ មានលក្ខណៈជាដើម របស់សភាវៈទាំងឡាយ ។ព្រោះលោកមិនបានពោលបទដ្ឋានទុកក្នុងចតុធាតុវវដ្ឋាននោះទើបលោកពោលពាក្យថា **តែដោយបទដ្ឋាន** ដូច្នេះជាដើម ។ ការដែលលោកមិនបានពោលបទដ្ឋាននោះទុក គប្បីឃើញថា ព្រោះសេចក្តីប្រការនោះ លោកអធិប្បាយទុកហើយដោយប្រការដទៃ ក្នុងពាក្យថា ដោយបច្ច័យនេះជាដើម ។ បទថា **សព្វាបិ យោគចតស្សោបិ ធាតុយោ** សេចក្តីថា ធាតុទាំង ៤ ។ បឋវីធាតុ មានអាបោឃ្លាំឃុំគ្រងតេជោតាមរក្សា វាយោតាមបក់ផាត់ទៅមកប៉ុណ្ណោះ ទើបប្រព្រឹត្តទៅបានមិនមែនដទៃឡើយ ព្រោះដូច្នោះ ទើបបឋវីធាតុនោះ មានភូតរូប ៣ ដ៏សេសជាបទដ្ឋាន សូម្បីធាតុក្រៅអំពីនេះក៏ក្នុងន័យនោះ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **មានធាតុ ៣ ដ៏សេសជាបទដ្ឋាន** ។

# វិសុទ្ធិមគ្គ

## ឧបាទាយរូប

ឧបាទាយរូបមាន ២៤ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ រូប សំឡេង ក្លិន រស ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ហទយវត្ថុ កាយវិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ រូបស្សលហុតា ( ភាពស្រាលនៃរូប ) រូបស្សមុទុតា ( ការទន់នៃរូប ) រូបស្សកម្មញ្ញតា ( ភាពរហ័សរហួននៃរូប ) រូបស្សឧបចយ ( ភាពចម្រើនឡើងនៃរូប ) រូបស្សសន្តតិ ( ភាពបន្តនៃរូប ) រូបស្សជរតា ( ភាពទ្រុឌទ្រោមនៃរូប ) រូបស្សអនិច្ចតា ( ការមិនស្ថិតស្ថេរនៃរូប ) កវឡិង្ការាហារ ។

## លក្ខណៈ ។បេ។ នៃឧបាទាយរូប

## បសាទរូប ៥

ក្នុងឧបាទាយរូបទាំងនោះ ភ្នែកមានភាពថ្លានៃភូតរូប អាចប៉ះខ្ទប់រូបបានជាលក្ខណៈ ន័យម្យ៉ាងទៀត មានសភាពថ្លានៃភូតរូប ដែលមានកម្ម ( ដែលកើតអំពីកម្ម ) ដែលមានការប្រាថ្នា នឹងឃើញជាដើមហេតុ ជាសមុដ្ឋាន ជាលក្ខណៈ មានការទាញយកនូវរូបជារស មានភាពជាទម្រដែលទទួលចក្ខុវិញ្ញាណ ជាបច្ចុប្បដ្ឋាន មានភូតរូបដែលកើតអំពីកម្ម ដែលមានការប្រាថ្នានឹងឃើញជាដើមហេតុ ជាបទដ្ឋាន។

ត្រចៀកមានភាពថ្លានៃភូតរូបអាចប៉ះខ្ទប់សំឡេងបានជាលក្ខណៈន័យមួយទៀត មានភាពថ្លានៃភូតរូបដែលមានកម្ម មានការប្រាថ្នានឹងស្តាប់ជាដើមហេតុ ជាសមុដ្ឋាន ជាលក្ខណៈ មានការទាញយកនូវសំឡេងទាំងឡាយជារស មានភាពទម្រដែលទទួលសោតវិញ្ញាណជាបច្ចុប្បដ្ឋាន មានភូតរូបដែលកើតអំពីកម្ម មានការប្រាថ្នានឹងស្តាប់ជាដើមហេតុ ជាបទដ្ឋាន ។

ប្រមុះ មានភាពថ្លានៃភូតរូបល្មមអាចធុំក្លិនបានជាលក្ខណៈ ន័យមួយទៀត មានសភាពថ្លានៃភូតរូបដែលកើតអំពីកម្ម មានការប្រាថ្នានឹងហិតជាដើមហេតុ ជាសមុដ្ឋានជាលក្ខណៈ មានការទាញយកនូវក្លិនទាំងឡាយជារស មានភាពជាបល្ល័ង្ក ( ទម្រ ) ដែលរងទទួលឃានវិញ្ញាណជាបច្ចុប្បដ្ឋាន មានភូតរូបដែលកើតអំពីកម្ម ដែលមានការប្រាថ្នានឹងហិតជាដើមហេតុ ជាបទដ្ឋាន ។

អណ្ដាត មានភាពថ្លានៃភូតរូប អាចប៉ះរសបានជាលក្ខណៈ ន័យមួយទៀត មានសភាពថ្លានៃភូតរូបដែលមានកម្ម មានការប្រាថ្នានឹងលិទ្ធជាដើមហេតុ ជាសមុដ្ឋានជាលក្ខណៈ មានការទាញយកនូវរសទាំងឡាយ ជារស មានភាពជាបល្ល័ង្កដែលរងទទួលជិវ្ហាវិញ្ញាណជាបច្ចុប្បដ្ឋាន មានភូតរូបដែលកើតអំពីកម្ម មានការប្រាថ្នានឹងលិទ្ធជាដើមហេតុ ជាបទដ្ឋាន ។

កាយ មានភាពថ្លានៃភូតរូប អាចប៉ះខ្ទប់ផោដ្ឋព្វៈបានជាលក្ខណៈ ន័យម្យ៉ាងទៀត មានសភាពថ្លានៃភូតរូបដែលមានកម្ម មានការប្រាថ្នានឹងប៉ះពាល់ជាដើមហេតុ ជាសមុដ្ឋាន ជាលក្ខណៈ មានការទាញយកនូវផោដ្ឋព្វៈទាំងឡាយជារស មានភាពជាបល្ល័ង្ក ដែលរងទទួលកាយវិញ្ញាណជាបច្ចុប្បដ្ឋាន មានភូតរូបដែលកើតអំពីកម្ម មានការប្រាថ្នានឹងប៉ះពាល់ជាដើមហេតុ ជាបទដ្ឋាន ។

## លក្ខណៈភ្នែក ។បេ។ តាមមតិកេចិអាចារ្យ

ចំណែកអាចារ្យពួកខ្លះពោលថា ភ្នែក គឺភាពថ្លានៃភូតរូបទាំងឡាយ ជាចំណែកដែលច្រើនដោយធាតុភ្លើង ត្រចៀក ប្រមុះ អណ្ដាត គឺភាពថ្លានៃភូតរូបទាំងឡាយ ជាចំណែកដែលច្រើនដោយធាតុខ្យល់ ធាតុដី និងធាតុទឹក ( តាមលំដាប់ ) កាយ គឺសភាពថ្លានៃភូតរូបគ្រប់យ៉ាងស្មើគ្នា ។

អាចារ្យមួយពួកទៀតពោលថា ភ្នែក គឺភាពថ្លានៃភូតរូបទាំងឡាយ ដែលច្រើនទៅដោយធាតុភ្លើង ត្រចៀក ច្រមុះ អណ្តាត កាយ គឺភាពថ្លានៃភូតរូបទាំងឡាយ ដែលច្រើនដោយប្រហោង គឺអាកាស ខ្យល់ ទឹក និងដីតាមលំដាប់ ។

អាចារ្យទាំងនោះគួរប្រាប់ឲ្យលើកព្រះសូត្រមកអាង លោកនឹងមិនជួបព្រះសូត្រដោយពិតនោះឯង ។

នៅមានអាចារ្យមួយពួកជួយអាងហេតុ ក្នុងពាក្យរបស់គេថាអាចារ្យ ដែលពោលមកនោះថា ព្រោះធាតុទាំងឡាយ មានធាតុភ្លើងជាដើម ជាវត្ថុដែលជាគុណ មានរូបជាដើម ត្រូវជួយអនុគ្រោះ ។ អាចារ្យពួកនេះ បណ្ឌិតគប្បីពោលជំទាស់បានថា នរណាហ្ន៎ពោលដូច្នេះថា សភាវៈមានរូបជាដើម ជាគុណដល់ធាតុ មានភ្លើងជាដើម ព្រោះថាក្នុងភូតរូបទាំងឡាយដែលមានការប្រព្រឹត្តទៅ បែកគ្នាមិនបាន បុគ្គលណាមួយ ក៏ពោលមិនបានថា វត្ថុនេះជាគុណដល់វត្ថុនេះ វត្ថុនោះជាគុណដល់វត្ថុនោះ ។

សូម្បីអាចារ្យពួកនោះនឹងគប្បីពោលតទៅទៀតថា លោកទាំងឡាយមានបំណងយកកិច្ច គឺនាទី ដូចជាការទ្រទ្រង់ទុករបស់ធាតុដីជាដើមបាន ព្រោះការដែលភូតរូប គឺធាតុនោះៗ មានច្រើនក្នុងសម្ភារៈ គឺអង្គអវយវៈនោះៗ យ៉ាងណា ប្រការដែលថារូបជាដើមជាគុណដល់ធាតុភ្លើងជាដើមនោះ ក៏គួរនឹងមានបំណងយកបាន ព្រោះរូបជាដើម ប្រាកដជាមានចំនួនច្រើនក្នុងសម្ភារៈដែលក្រៃលែងដោយធាតុភ្លើង គឺភ្នែកជាដើម ក៏ដូច្នោះ ។

អាចារ្យទាំងនោះ យើងគប្បីពោលជំទាស់ថា ខ្ញុំទាំងឡាយក៏នឹងគប្បីមានបំណងប្រសិនបើក្លិនក្នុងគ្រាប់កប្បាសដែលច្រើនដោយដី នឹងគប្បីជាក្លិនក្រៃលែង គឺធួលខ្លាំងជាងក្លិនរបស់ជ្រក់ដែលច្រើនដោយទឹក ហើយពណ៌របស់ទឹកត្រជាក់នឹងគប្បីចាំង (ថ្លា) ជាងពណ៌របស់ទឹកក្តៅដែលច្រើនដោយភ្លើងខ្វះទៅគ្រាន់ តែព្រោះទាំងពីរនោះ

មិនមាន ព្រោះហេតុនោះ លោកទាំងឡាយគប្បីលើកការគិតកំណត់សេចក្តីប្លែកគ្នា នៃភូតរូបដែលជាទីអាស្រ័យរបស់បសាទរូប មានភ្នែកជាដើម ទាំងនោះចោលចុះ គួរកាន់យកយុត្តិនេះថា រូបរសជាដើមនៃភូតរូបទាំងឡាយ សូម្បីក្នុងកលាបៈជាមួយគ្នា មិនមានអ្វីពិសេសជាងគ្នា គង់មិនដូចគ្នាយ៉ាងណា បសាទទាំងឡាយ មានចក្ខុបសាទជាដើម សូម្បីហេតុនៃភាពពិសេសជាងគ្នាដទៃមិនមាន វាក៏មិនដូចគ្នាដូច្នោះ ។

ប្រសិនបើមានពាក្យសួរថា បើមិនមានការប្លែកនៃភាពក្រៃលែងជាងគ្នារបស់ភូតរូប ដូចពោលនោះសោត អ្វីវិញជាហេតុឲ្យបសាទរូបទាំងនោះមិនជាសាធារណៈដល់គ្នានឹងគ្នា ? ពាក្យដោះស្រាយគប្បីមានថា កម្មនោះឯងជាហេតុនៃការប្លែកគ្នារបស់បសាទរូប មានចក្ខុជាដើមទាំងនោះ ព្រោះហេតុនោះ ភាពប្លែកគ្នានៃបសាទរូបទាំងនោះ រមែងកើតព្រោះសភាពប្លែកគ្នារបស់កម្ម និងកើតព្រោះសភាពប្លែកគ្នារបស់ភូតរូបក៏ទេ ព្រោះថា កាលភូតរូបកើតមានភាពប្លែកគ្នាតិចច្រើនជាងគ្នាឡើង ភាពថ្លា (បសាទ) រមែងមិនសុទ្ធតែកើតឡើង ពិតណាស់ បុរាណាចារ្យទាំងឡាយក៏ពោលទុកថា កាលភូតរូបទាំងឡាយស្មើគ្នា ភាពថ្លា (បសាទ) ទើបមាន កាលភូតរូបទាំងឡាយមិនស្មើគ្នា ភាពថ្លាក៏មិនមានដូច្នេះ ។ ក្នុងបសាទរូបទាំងនោះក៏មានភាពប្លែកគ្នា ព្រោះភាពប្លែកគ្នា នៃកម្មយ៉ាងនេះ ចក្ខុ និងសោតៈទទួលវិសយរូប គឺអារម្មណ៍ បានដល់រូប និងសំឡេង ដែលមិនមកដល់ខ្លួនបាន ព្រោះភ្នែក និងត្រចៀកជាហេតុនៃវិញ្ញាណក្នុងវិសយរូបដែលមានទីអាស្រ័យមិនជាប់នឹងទីអាស្រ័យរបស់ខ្លួនឡើយ ចំណែកឃានៈ ជិវ្ហា និងកាយ ទទួលបានតែវិសយរូបដែលមកដល់ខ្លួន ព្រោះឃានៈ ជិវ្ហា កាយជាហេតុនៃវិញ្ញាណ ក្នុងវិសយរូបជាប់ទីអាស្រ័យរបស់ខ្លួនទីមួយៗ ហើយនោះឯងដែលជាទីអាស្រ័យរបស់វិសយរូប និងជាវិសយរូបក្នុងខ្លួនឯងផង ។

## ទីតាំង ។បេ។ នៃបសាទរូប

## ចក្ខុ

ក្នុងបសាទរូប ៥ នេះ វត្ថុដែលក្នុងលោកហៅថា ចក្ខុ លម្អដោយរោមភ្នែក ចែងចាំងដោយកែវភ្នែកខ្មៅ និង.ស សណ្ឋានស្រដៀងនឹងត្របកឈូក តែតួចក្ខុពិតៗនោះ តូច ដោយប្រមាណប៉ុនក្បាលសុច បានទទួលឧបការៈដែលធាតុទាំង ៤ មាននាទីផ្សើមក្ខាសរបស់ភ្នែកទាំង ៧ ជាន់ ដូចប្រេងដែលបុគ្គលស្រោចចុះទៅក្នុងប៉ុយសំឡី ៧ ជាន់ សើមប៉ុយសំឡីគ្រប់ជាន់ដូច្នោះ ហើយ ( ធាតុដី ) ទ្រទ្រង់ទុក ( ធាតុទឹក ) ទាញផ្គុំឲ្យជាប់គ្នាទុក ធាតុភ្លើងធ្វើឲ្យក្តៅទុក ធាតុខ្យល់បក់ទ្រទុក ធ្វើឲ្យដូចខត្តិយកុមារ មានឧបការៈដែលធ្វើស្រីស្នំទាំង ៤ ដែលមាននាទី(ម្នាក់) បី-ពរ នាងម្នាក់ឲ្យស្រោចស្រព នាងម្នាក់តុបតែងខ្លួន នាងម្នាក់នៅបក់ផាត់ ថ្វាយដូច្នោះ ។ ហើយ ចក្ខុនោះដែលឧតុ ចិត្ត និងអាហារឧបត្ថម្ភទុក ដែលអាយុអនុបាលទុក ដែលអវិនិព្ភោគរូប មានពណ៌ ក្លិន រស ជាដើមចោមរោម ញ៉ាំងភាពជាវត្ថុ និងជាទ្វារតាមគួរដល់វីថិចិត្តទាំងឡាយ មានចក្ខុវិញ្ញាណជាដើម ឲ្យសម្រេចតាំងនៅក្នុងតំណែង (ក្នុងរាងកាយ)ដែលកើតឡើងនៃស្រមោល ទ្រទ្រង់រាងកាយរបស់រូបទាំងឡាយ ដែលនៅត្រង់មុខ ក្នុងកណ្តាលកែវភ្នែកខ្មៅ ដែលកែវភ្នែកពណ៌.ស នៅជុំវិញសសម្ភារចក្ខុ ( ចក្ខុព្រមទាំងសម្ភារៈ គឺគ្រឿងប្រកប ) នោះ ។ ពិតណាស់ សូម្បីព្រះធម្មសេនាបតីសារីបុត្រក៏បានពោលពាក្យនេះទុកថា

បុគ្គលរមែងឃើញរូបទាំងឡាយ ដោយចក្ខុបសាទណា ចក្ខុបសាទនោះ ជារបស់តូចល្អិត ប្រៀបបាននឹងក្បាលសុច ដូច្នេះ ។

## សោតៈ

ចំណែកសោតៈក៏បានឧបការៈដែលធាតុ មានប្រការដូចពោលហើយធ្វើឲ្យ

ដែលឧតុ ចិត្ត និងអាហារ ឧបត្ថម្ភទុក ដែលអាយុអនុបាលទុក ដែលអវិនិព្ភោគរូប មានពណ៌ជាដើមចោមរោម ញុំាងភាពជាវត្ថុ និងជាទ្វារតាមគួរដល់វីថិចិត្តទាំងឡាយ មានសោតវិញ្ញាណជាដើមឲ្យសម្រេចតាំងនៅក្នុងតំណែង ( ក្នុងរាងកាយ ) មានសណ្ឋានដូចវង់ចិញ្ចៀន មានរោមទន់ ពណ៌ស្ករដុះឡើង គឺចម្រើនច្រើនខាងក្នុងប្រហោងសសម្ភារសោត: ( សោត: ព្រមទាំងសម្ភារ: គឺគ្រឿងប្រកប ) ។

## ឃានៈ

ឃាន:ក៏បានការឧបការ: ការឧបត្ថម្ភ ការអនុបាល និងគ្រឿងចោមរោមមានប្រការដូចពោលមកហើយ ញុំាងភាពជាវត្ថុ និងជាទ្វារតាមគួរដល់វីថិចិត្ត មានឃានវិញ្ញាណជាដើម ឲ្យសម្រេចតាំងនៅក្នុងតំណែង ( ក្នុងរាងកាយ ) មានសណ្ឋានដូចក្រចកពពែ នៅខាងក្នុងប្រហោងសសម្ភារឃាន: ( ឃាន: ព្រមទាំងសម្ភារ: គឺគ្រឿងប្រកប ) ។

## ជិវ្ហា

ជិវ្ហា ក៏បានភាពឧបការ: ការឧបត្ថម្ភ ការអនុបាល និងគ្រឿងចោមរោមមានប្រការដូចពោលមកហើយ ញុំាងភាពជាវត្ថុ និងជាទ្វារតាមគួរដល់វីថិចិត្ត មានជិវ្ហាវិញ្ញាណជាដើមឲ្យសម្រេចតាំងនៅក្នុងតំណែង ( ក្នុងរាងកាយ ) មានសណ្ឋានដូចចុងត្របកផ្កាឧប្បលត្រង់ផ្នែកខាងលើ នៃចំណែកកណ្តាលសសម្ភារជិវ្ហា ( ជិវ្ហា ព្រមទាំងសម្ភារ: គឺគ្រឿងប្រកប ) ។

## កាយ

ឯឈ្មោះថា ឧបាទិន្នរូបក្នុងកាយនេះ នៅមានដរាបណា ដរាបនោះ កាយបសាទក៏ត្រូវបានភាពឧបការ: ការឧបត្ថម្ភ ការអនុបាល និងគ្រឿងចោមរោមមានប្រការ

ដូចពោលមកហើយដូចគ្នា ដូចប្រេងសើមនៅក្នុងសរសៃប៉ុយសំឡីដូច្នោះ ញុំាងភាពជាវត្ថុ និងជាទ្វារតាមគួរដល់វីថិចិត្ត មានកាយវិញ្ញាណជាដើមឲ្យសម្រេចតាំងនៅក្នុងគ្រប់តំណែងនៃរាងកាយ ។

ម្យ៉ាងទៀត បសាទរូប មានចក្ខុជាដើមនោះ បណ្ឌិតគប្បីជ្រាបថា វាក៏បង្អោនទៅកាន់គោចរ ( ទីទៅ ) របស់វា មានរូបជាដើមនោះឯង ដូចពស់ ក្រពើ បក្សី ឆ្កែស្រុក និងឆ្កែព្រៃ ទន្ទឹងតែនឹងទៅរកគោចររបស់ខ្លួន ពោល គឺដំបូក ទឹក អាហារស្រុក ភូមិ និងព្រៃខ្មោចស្រស់ ដូច្នោះ ។

# មហាដីកា

បទថា **ចតុវីសតិវិធំ** ជាពាក្យកំណត់ចំនួនមានអត្ថហាមឃាត់នូវរូបទាំងឡាយមានពលរូបជាដើម ។ ពាក្យដែលគប្បីពោលក្នុងសេចក្ដីនោះ ពាក្យនោះ នឹងមានជាក់ច្បាស់ខាងមុខ ។ ធម្មជាតិដែលឈ្មោះថា **ចក្ខុ** ដោយអត្ថថា ប្រពៃ អធិប្បាយថាដែលវិញ្ញាណអាស្រ័យហើយ រមែងដូចជាពេញចិត្តនូវរូប ។ នឹងអធិប្បាយបទថា **ចក្ខតិ** តទៅ ។ **ចក្ខតិ**-ស័ព្ទនេះ មានអត្ថថា ពេញចិត្ត ដូចក្នុងប្រយោគថា **មធុំ ចក្ខតិ** ( ពេញចិត្តទឹកឃ្មុំ ) **ព្យញ្ជនំ ចក្ខតិ** ( ពេញចិត្តបាយ ) ។ សមដូចព្រះពុទ្ធតម្រាស់ដែលត្រាស់ទុកថា ម្នាលមាគណ្ឌិយៈ ចក្ខុនេះឯង មានរូបជាទីត្រេកអរ ត្រេកអរហើយក្នុងរូបសរសើរហើយក្នុងរូប ។ សូម្បីក្នុងអដ្ឋកថាលោកក៏ពោលទុកថាមានការទាញមកក្នុងរូបទាំងឡាយ ជារស ។ គប្បីឃើញថា សូម្បីកាលភាវៈដែលមានសោតៈជាដើម ប្រែសភាពដែលមានសំឡេងជាអារម្មណ៍ជាដើម មានចក្ខុស័ព្ទក៏រមែងប្រព្រឹត្តទៅ ព្រោះជាស័ព្ទជាប់មាត់ ដូចស័ព្ទ មាន **បង្កជ** ជាដើម ប្រើក្នុងផ្កាឈូកជាដើម ដូច្នោះ ។ ម្យ៉ាងទៀត បទថា **ចក្ខតិ** សេចក្ដីថា ធម្មជាតិដែលវិញ្ញាណ តាំងអាស្រ័យហើយ រមែងហាក់ដូចជាប្រាប់ផ្លូវ ដែលរាបស្មើ និងមិនរាបស្មើហាក់បីដូចជាប្រាប់ឲ្យជាក់ច្បាស់យ៉ាងក្រៃលែង ។ ចំណែកក្នុងអដ្ឋកថាលោកពោលថា នឹងរមែងធ្វើឲ្យជាក់ច្បាស់ ។ ពាក្យក្នុងអដ្ឋកថានោះ លោកពោលទុកព្រោះអធិប្បាយថា សូម្បីចក្ខតិស័ព្ទ មានអត្ថថា ធ្វើឲ្យជាក់ច្បាស់ ក៏រមែងមានបាន ព្រោះធាតុទាំងឡាយមានអត្ថច្រើនយ៉ាង ។ ធម្មជាតិដែលឈ្មោះថា **សោតៈ** ដោយអត្ថថាជាហេតុស្ដាប់ ម្យ៉ាងទៀត ដោយអត្ថថា ខ្លួនឯងដែលវិញ្ញាណ តាំងអាស្រ័យ ហើយស្ដាប់បាន ។ ធម្មជាតិដែលឈ្មោះថា **ឃានៈ** ដោយអត្ថថា ជាហេតុហិតក្លិន ម្យ៉ាងទៀត

ដោយអត្ថថា ហិតក្លិនខ្លួនឯង ។ រសរបស់អាហារ ឈ្មោះថា ជីវិត ព្រោះជាហេតុនៃការរស់នៅ ព្រោះការស៊ី លេប មានការទទួលរសជាមូល ធម្មជាតិណា រមែងជញ្ជោយហៅជីវិតនោះ ព្រោះជាធម្មជាតិ ដែលបង្អោនទៅក្នុងរសអាហារនោះ ហេតុនោះ ធម្មជាតិនោះឈ្មោះថា ជិវ្ហា ដោយនិរុត្តិន័យ ។ ដោយទីកើត គឺស្ថានទីកើតឡើងនៃធម៌ដែលគួរស្អៀសទាំងឡាយ បានដល់ សាសវធម៌ទាំងឡាយ ហេតុនោះ ឈ្មោះថា **កាយ** ព្រោះកាលឃាន: ជិវ្ហា និងកាយដែលកើតអំពីកម្ម ដែលមានកាមរាគ:ជាហេតុ និងនៅជាបច្ច័យពិសេសនៃកាមរាគ:ផង នៅមិនមកដល់ការ:ដែលជាហេតុ ដែលជាអនុត្តរិយ:កាយក៏ជាសាសវបច្ច័យដោយពិសេសផងដែរ ។ ហេតុនោះឯង សត្វទាំងឡាយកាលពេញចិត្តក្នុងសុខដែលកើតអំពីផោដ្ឋព្វ: ទើបសេពមេថុន ។ មួយ៉ាងទៀត ខន្ធ ៤ ដែលមានកាយិន្ទ្រិយជាទីតាំងប្រព្រឹត្តទៅ ដោយអាសវ: ដោយពិសេស ព្រោះភាពជាហេតុនៃអាសវ: មានកាមាសវ:ដែលមានកម្លាំងជាដើម ហេតុនោះ ទើបលោកហៅថា **កាយ** ដោយអត្ថថា ជាទីកើតរបស់ធម៌ដែលបណ្ឌិតស្អៀស គឺសាសវធម៌ទាំងឡាយ ។ឈ្មោះថា *រូប* ដោយអត្ថថា ដល់នូវភាពវិការនៃវណ្ណ: ( ពណ៌សម្បុរ ) រមែងសម្តែងការ:ត្រង់ហទយ: អធិប្បាយថា ធ្វើការប្រកាស ដូចជារូប គឺសម្តែងដូចជាកំពុងមានកាយ ។ ម្យ៉ាងទៀត គប្បីឃើញរូប ស័ព្ទថា មានន័យថា ប្រកាសនោះឯង ព្រោះធាតុទាំងឡាយមានអត្ថច្រើនយ៉ាង ។

ឈ្មោះថា **សទ្ទ:** ដោយអត្ថថា ទៅ អធិប្បាយថា បន្លឺសំឡេងចេញទៅ ម្យ៉ាងទៀត គប្បីអធិប្បាយថា ត្រូវបច្ច័យរបស់ខ្លួនឯងទៅ គឺនាំទៅកាន់ការ:ដែលសោត:គប្បីដឹងបាន ។ ឈ្មោះថា **គន្ធ:** ដោយអត្ថថា ប្រាប់ អធិប្បាយថា បញ្ជាក់ដល់វត្ថុរបស់ខ្លួន គឺជាផ្កាឈើ ឬផ្លែឈើជាដើម ដែលមិនប្រាកដ ក៏ប្រកាសថា នេះក្លិនក្រអូប នេះក្លិនស្អុយ ឬដែលគេលាក់ទុក ក៏ធ្វើដូចជាណែនាំថា នេះនៅត្រង់នេះ ។ ឈ្មោះថា

រស ដោយអត្ថថា ជាទីត្រេកអរ គឺជាទីពេញចិត្តរបស់សត្វទាំងឡាយ ។

ឥន្ទ្រិយរបស់ស្រីនោះឯង ឈ្មោះថា **ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ** ក៏ដូចគ្នា ។ ដែលឈ្មោះថា ជីវិត ដោយអត្ថថា ជាហេតុរស់នៅនៃសហជាតធម៌ទាំងឡាយ ឥន្ទ្រិយ គឺជីវិតនោះឯងឈ្មោះថា ជីវិតិន្ទ្រិយ ។ ហទយៈនោះផង ជាវត្ថុផង ឬជាវត្ថុនៃហទយៈ គឺមនោវិញ្ញាណ ព្រោះហេតុនោះ ទើបឈ្មោះថា **ហទយវត្ថុ** ។ ឈ្មោះថា កាយនោះ ព្រោះភាពជាកាយដែលធ្វើឲ្យរំកិលបាន និងឈ្មោះថា វិញ្ញត្តិ ព្រោះធ្វើឲ្យដឹងបំណងបាន ហេតុនោះ ទើបឈ្មោះថា **កាយវិញ្ញត្តិ** ។ វចីនោះផង ឈ្មោះថា ជាវិញ្ញត្តិផង ព្រោះភាពជាវាចាដែលធ្វើឲ្យកម្រើក និងធ្វើឲ្យយល់បំណងបាន ហេតុនោះ ទើបឈ្មោះថា **វចីវិញ្ញត្តិ** ។ ធម្មជាតិណាដែលធ្វើឲ្យជាស្នាមមិនបាន ព្រោះមិនមានកាយ គឺមិនអាចនឹងធ្វើឲ្យមានស្នាមបាន គឺមិនអាចនឹងកាត់បាន ធម្មជាតិនោះឈ្មោះថា អាកាស ម្យ៉ាងទៀត ធម្មជាតិណារមែងភ្លឺ គឺរុងរឿង ហេតុនោះ ធម្មជាតិនោះឈ្មោះថា អាកាស អាកាសនោះឯងប៉ុនគ្នានឹងអាកាស អាកាសនោះឈ្មោះថា **អាកាសធាតុ** ដោយអត្ថថា ជានិស្សត្តនិជ្ជីវៈ ។ បទថា **រូបស្ស** បានដល់ និប្ផន្នរូប ។ ភាពស្រាលឈ្មោះថា **លហុតា** ។ បទថា **រូបស្ស** នេះ លោកធ្វើឲ្យផ្សេងគ្នា ព្រោះភាពជាធម្មជាតិដែលមិនសម្រេចដោយខ្លួនឯង ។ ន័យសូម្បីក្នុងបទដ៏សេសក៏ក្នុងន័យនេះ ។ ចំណែកភាពផ្សេងគ្នាដូចតទៅនេះថា ការសម្រេចប្រយោគក្នុងការងារ ឈ្មោះថា កម្មញ្ញៈ ភាវៈនៃកម្មញ្ញៈនោះ ឈ្មោះថា **កម្មញ្ញតា** ។ ការកកើតឡើង គឺការប្រព្រឹត្តទៅ គ្រាដំបូង និងតៗ ទៅ ឈ្មោះថា **ឧបចយៈ** ។ ការផ្សាយទៅ គឺការប្រព្រឹត្តទៅ ដែលទាក់ទងដោយអំណាចខាងដើម និងខាងចុង ឈ្មោះថា **សន្តតិ** ។ ភាវៈនៃវត្ថុ ដែលមិនទៀង គឺវត្ថុដែលមានភាពវិនាស ឈ្មោះថា **អនិច្ចតា** ។ ដែលឈ្មោះថា **កពឡិង្ការៈ** ដោយអត្ថថា ដែលបុគ្គលធ្វើឲ្យទៅជាពំនូត ។ ដែលឈ្មោះថា **អាហារ** ដោយអត្ថថានាំមក ។ ឧបាទាយរូបគប្បីជ្រាប

តាមន័យនៃសព្ទយ៉ាងនេះមុន ។

ពោលតាមលំដាប់ លោកអាចារ្យលើកភូតរូបឡើងសម្ដែងមុន ព្រោះជាមូលដោយភាវៈដែលជាទីអាស្រ័យរបស់រូបធម៌ទាំងអស់ ។ ក្នុងបណ្ដាឧបាទាយរូបក្រៅពីនេះ លោកអាចារ្យលើករូប ៥ យ៉ាង មានចក្ខុជាដើមនោះសម្ដែងអំពីខាងដើម ព្រោះភាវៈដែលជាមូលនៃការសន្មតថា ជាអត្តភាព ដោយភាវៈដែលជាអវយវៈមាននៅខាងក្នុង ។ លោកអាចារ្យលើករូប ៤ មានរូបជាដើមឡើងសម្ដែង ដើម្បីនឹងសម្ដែងថា រូបជាដើមទាំងនេះ ជាអារម្មណ៍របស់រូបដែលទទួលអារម្មណ៍ទាំងនោះ ។ ចំណែកផោដ្ឋព្វៈលោកមិនបានកាន់យកទុកក្នុងទីនេះ ព្រោះមិនចាត់ជាឧបាទាយរូប ព្រោះលោកកាន់យកដោយការកាន់យកថា ជាភូតរូប ។ ដើម្បីសម្ដែងថា អត្តភាពនេះដល់នូវការរាប់ថា ស្រី ក្ដី ថា ប្រុស ក្ដី ដោយឥន្ទ្រិយទាំងនេះ ទើបលោកលើកឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយឡើងសម្ដែងតាមលំដាប់នៃរូបទាំងនោះ ។ ដើម្បីសម្ដែងថា សត្វរមែងបានការបញ្ញត្តិថា មានជីវិតដោយឥន្ទ្រិយនេះ ទើបលោកលើកជីវិតិន្ទ្រិយនោះសម្ដែង.ត អំពីនោះ ។ ដើម្បីសម្ដែងថា ជីវិតិន្ទ្រិយនោះ នឹងសម្រេចប្រយោជន៍ឧបការៈ មានប្រយោជន៍ឧបការៈដល់ខ្លួនជាដើម ក្នុងកាលវិញ្ញាណប្រព្រឹត្តទៅ ព្រោះអាស្រ័យហទយវត្ថុនេះ ទើបលោកលើកហទយវត្ថុឡើងមកសម្ដែង ។ ដើម្បីសម្ដែងថា ហទយវត្ថុនោះ មានកាយបយោគ និងវចីបយោគទាំងអស់ ដោយអំណាចវិញ្ញត្តិទាំងនេះ ទើបលោកលើកវិញ្ញត្តិទាំង ២ ឡើងសម្ដែង ។ ដើម្បីសម្ដែងថា អាកាសធាតុ ជាខេត្តកំណត់ និងជាផ្លូវរបស់រូបកាយនេះ ទើបលោកលើកអាកាសធាតុឡើងមកសម្ដែង ។ ដើម្បីសម្ដែងថា ការប្រព្រឹត្តទៅនៃសេចក្ដីសុខ និងអាការទាំងឡាយ មានការកើតឡើងជាដើមរបស់រូបកាយនេះនឹងមានបាន ក៏ដោយរូបទាំងនេះ ទើបលោកលើករូបទាំងឡាយមានលហុតារូបជាដើមឡើងមកសម្ដែង ។ ដើម្បីសម្ដែងថា ការបន្តនៃសន្តតិរូបទាំង ៤

នេះ ដែលកពឡដ្ឋិការហារនេះឧបត្ថម្ភ ទើបកពឡដ្ឋិការហារគប្បីជ្រាបថា លោកលើកឡើងសម្ដែងទុកក្នុងវគ្គចុងបំផុត ។

ឥឡូវនេះ លោកអាចារ្យមានបំណងសម្ដែងលម្អិតឧបាទាយរូបតាមដែលលើកឡើង សម្ដែងទុកហើយដោយបកិណ្ណកៈ មានលក្ខណៈជាដើម ទើបផ្ដើមពាក្យថា **តត្ថ រូបាភិឃាតារហភូតប្បសាទលក្ខណំ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **តត្ថ** ប៉ុនគ្នានឹង **តេសុ យោគ ឧបាទាយរូបេសុ** ប្រែថា ក្នុងបណ្ដាឧបាទាយរូបទាំងនោះ ។ អធិប្បាយថា ការប៉ះខ្ទប់ត្រង់រូប ឈ្មោះថា **រូបាភិឃាតោ** មា៉ងទៀត ការប៉ះខ្ទប់នូវរូប ក៏ឈ្មោះថា **រូបាភិឃាតោ** ប្រែថា ការប៉ះខ្ទប់រូប សភាវៈណារមែងគួរដល់ការប៉ះខ្ទប់នូវរូបនោះ ហេតុនោះសភាវៈនោះ ឈ្មោះថា **រូបាភិឃាតារហោ** ប្រែថា គួរដល់ការប៉ះខ្ទប់នូវរូប ការប៉ះខ្ទប់រូបនឹងមាន ឬមិនមានក៏ដោយភាពថ្លារបស់ភូតរូប ទាំង ៤ ដែលមានសភាវៈយ៉ាងនេះ ឈ្មោះថា **រូបាភិឃាតារហភូតប្បសាទោ** ប្រែថា ភាពថ្លារបស់ភូតរូប ដែលគួរដល់ការប៉ះខ្ទប់រូប ចក្ខុមានភាពថ្លានៃភូតរូប បានដល់ ការប៉ះខ្ទប់រូបយ៉ាងនេះជាលក្ខណៈ ។ ព្រោះចក្ខុបសាទប្រកបដោយបច្ច័យដទៃប៉ុណ្ណោះ រមែងប្រព្រឹត្តទៅដោយអំណាចការប៉ះខ្ទប់រូប មិនមែនចក្ខុបសាទសុទ្ធៗ ទេ ។ ព្រោះដូច្នោះ ដើម្បីនឹងសម្ដែងថា ភាវៈដែលចក្ខុមានភាពថ្លានៃភូតរូប ដែលគួរប៉ះខ្ទប់រូបនោះ ជាសភាវៈប៉ុណ្ណោះជាប្រមាណ មិនមែនការប៉ះខ្ទប់រូបជាប្រមាណនោះទេ ទើបលោកអាចារ្យពោលថា ចក្ខុបសាទគួរប៉ះខ្ទប់រូប ដូចដែលពោលថា កុសល និងអកុសល គួរដល់វិបាក ។ ព្រោះអធិប្បាយថា ការប៉ះខ្ទប់គ្នា គឺភាវៈដែលអារម្មណ៍ និងចិត្ត ដែលទទួលអារម្មណ៍ប្រឈមមុខគ្នា ដូចគ្នានឹងកិរិយារបស់យាន និងផែនដី ដែលជាទីតាំងធ្លាក់ប៉ះខ្ទប់គ្នាដូច្នោះ ។ ការប៉ះខ្ទប់នោះ រមែងមានដល់ចក្ខុព្រោះរូប ឬមានដល់រូបព្រោះចក្ខុ ។ ដោយហេតុនោះ ទើបត្រាស់ថា ចក្ខុណាមានការឃើញមិនបាន មានការប៉ះខ្ទប់បានប៉ះខ្ទប់

ហើយក្តី ត្រង់រូបដែលមានការឃើញមិនបាន មានការប៉ះខ្ទប់បានក្តី ដូច្នេះ នឹងថា រូបដែលមានការឃើញបាន មានការប៉ះខ្ទប់ បានប៉ះខ្ទប់ហើយក្តី កំពុងប៉ះខ្ទប់ក្តី ត្រង់ចក្ខុដែលឃើញមិនបាន តែប៉ះខ្ទប់បាន ដូច្នេះជាដើម ។ កាមតណ្ហា និងរូបតណ្ហា ដែលជាហេតុនៃកម្មឲ្យកើតអត្តភាពដែលមានអាយតនៈគ្រប់គ្រាន់ មិនគ្រប់គ្រាន រមែងគួរដល់វោហារថា ភាពត្រូវការនឹងឃើញជាដើមព្រោះភាវៈ គឺការប្រាថ្នាភពដែលប្រកបដោយអាយតនៈ ដែលគ្រប់ចំនួន និងមិនគ្រប់ចំនួននោះ ព្រោះដូច្នោះ ទើបលោកពោលន័យទី ២ ទុកក្នុងទីគ្រប់អន្ទើ ។ គប្បីជ្រាបវិគ្គហៈក្នុងន័យទី ២ នោះ កម្មដែលជាហេតុនៃភាពជាអ្នកប្រាថ្នានឹងឃើញជាសមុដ្ឋាននៃភូតរូបទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **ទដ្ឋុកាមតានិទានកម្មសមុដ្ឋានានិ** ។ភាពថ្លារបស់ភូតរូប ដែលមានបែបយ៉ាងនេះឈ្មោះថា **ទដ្ឋុកាមតា ។បេ។ បសាទោ** ប្រែថា ភាពថ្លានៃភូតរូបដែលមានកម្មជាហេតុនៃភាពជាអ្នកប្រាថ្នាដើម្បីនឹងឃើញជាសមុដ្ឋាន ចក្ខុក៏មានភាពថ្លានៃភូតរូបដែលមានកម្មជាហេតុនៃភាពជាអ្នកប្រាថ្នា ដើម្បីនឹងឃើញជាលក្ខណៈ ។ ពិតណាស់ តណ្ហាដែលជាមូលនៃភពនោះៗ រមែងជាធម្មជាតិ ឈ្មោះថា ជាវិស័យនៃអាយតនៈ គួរដល់ការកើតឡើងក្នុងភពនោះៗ ក៏បាន ដូច្នោះ ទើបលោកពោលភាវៈដែលតណ្ហាទាំងឡាយ មានកាមតណ្ហាជាដើម គួរនូវវោហារថា មានភាពជាអ្នកប្រាថ្នានឹងឃើញជាដើម ។

ឯការប្រាថ្នានឹងឃើញ ដោយអត្ថថា បានដល់ រូបតណ្ហា ឈ្មោះថា **ភាពជាអ្នកត្រូវការនឹងឃើញ** ។ ក្នុងអធិការនេះ គប្បីឃើញសេចក្តីថា កាលមានភាពជាអ្នកប្រាថ្នានឹងឃើញ និងភាពជាអ្នកប្រាថ្នានឹងស្តាប់ជាដើមដ៏សេសកើតឡើងមុន តែខណៈដែលប្រមូលមកនៃកម្មដែលនឹងឲ្យកើតអត្តភាពនោះៗ ក៏មិនមានពាក្យដែលនឹងត្រូវនិយាយដល់ តែកាលមិនមានភាវៈដែលភាពជាអ្នកប្រាថ្នានឹងឃើញ ដែលមគ្គដកឡើងមិនបាន នោះឯងជាហេតុ ។ ព្រោះកាលមានការបានហេតុ ដែលមគ្គដកមិនទាន់បាន ហេតុក៏នៅ

មាននោះឯង ព្រោះកើតឡើងចូលដល់ភាពជាបច្ច័យដល់ផលរបស់ខ្លួន ហេតុនោះ ភាវៈដែលជាធម៌កើតឡើងហើយ ភាវៈដែលជាធម៌នៅមាន ព្រះមានព្រះភាគត្រាស់ទុកដោយពាក្យជាបរិយាយទាំងឡាយ ដូចក្នុងប្រយោគទាំងឡាយ មានយ៉ាងនេះថា ភិក្ខុចម្រើនអរិយមគ្គមានអង្គ ៨ ធ្វើអរិយមគ្គមានអង្គ ៨ ឲ្យចម្រើន រមែងញ៉ាំងអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ឲ្យអន្តរធានទៅក្នុងរវាងនោះឯង នឹងថា ភិក្ខុរមែងដឹងកាមច្ឆន្ទៈដែលមាននៅខាងក្នុងថា អញមានកាមច្ឆន្ទៈនៅខាងក្នុងដូច្នេះ ។

ចក្ខុ មានការទាញមកនូវរូបដល់បុគ្គល ឬដល់វិញ្ញាណជារស ។ ឈ្មោះថា **មានភាវៈជាទីទទួល ជាបច្ចុប្បដ្ឋាន** ព្រោះភាពជានិស្សយប្បច្ច័យ ។ ឈ្មោះថា **មានភូតរូបដែលកើតអំពីកម្ម មានភាពជាអ្នកប្រាថ្នានឹងឃើញជាហេតុ ជាបទដ្ឋាន** ព្រោះអធិប្បាយថា ភូតរូបទាំងឡាយដែលមានសភាពថានោះឯង ជាហេតុជិតរបស់បសាទនោះ ។ ក្នុងអធិការនេះលោកពោលលក្ខណៈ នៃចក្ខុប្រការខាងដើមទុកដោយអំណាចនៃកម្មដែលទូទៅ ញ៉ាំងអត្ថភាពនោះៗ ឲ្យសម្រេច ព្រោះមិនបានប្រារព្ធភាពផ្សេងគ្នារបស់ហេតុទុក និងលក្ខណៈរបស់ចក្ខុប្រការទី ២ ទុកដោយអំណាចកម្មវិសេស ដែលឲ្យកើតឡើងហើយយ៉ាងនេះថា សូមចក្ខុឃើញបែបនេះ មានដល់អញ ។ ម្យ៉ាងទៀតគប្បីឃើញថា សូម្បីកាលភាពដែលរូបទាំង ៥ មានចក្ខុជាដើម មានភាពស្មើគ្នា ដោយភាពជាបសាទរូបមាន លោកពោលលក្ខណៈរបស់ចក្ខុប្រការដំបូងទុកដោយអំណាចកិច្ច គឺសភាពថាពោល គឺការច្នះបញ្ចាំងអារម្មណ៍របស់ខ្លួនឲ្យច្បាស់ឡើង ។ សូម្បីកាលភាពដែលហេតុគឺភាពស្មើគ្នាដោយភាវៈដែលជាកម្ម ឬជាភាវៈដូចគ្នា លោកក៏ពោលលក្ខណៈចក្ខុប្រការទី ២ ទុកដោយអំណាចការសម្ដែងភាពផ្សេង ដោយភាពផ្សេងគ្នានៃហេតុរបស់ខ្លួន ។ គប្បីជ្រាបអត្ថក្នុងបកិណ្ណកៈ មានលក្ខណៈជាដើមរបស់សោតៈជាដើមតាមន័យដែលបានពោលហើយនោះឯង ។

ក្នុងអធិការនេះមានអាចារ្យអ្នកចោទសួរពោលថា

ឥន្ទ្រិយ មានចក្ខុជាដើមកើតឡើងដោយកម្មតែមួយឬ ឬដោយកម្មផ្សេងៗ ? ឆ្លើយថា បុរាណាចារ្យទាំងឡាយពោលទុកថា កើតឡើងបានដោយកម្មទាំង ២ ប្រការ ។ ក្នុងកម្ម ២ ប្រការនោះ ខាងដើមក្នុងប្រការដែលកើតឡើងដោយកម្មផ្សេងៗ ប្រការ ដែលគប្បីពោលក្នុងភាពផ្សេងរបស់ឥន្ទ្រិយ មានចក្ខុជាដើមមិនមាន ព្រោះហេតុផ្សេងគ្នា ។ តែក្នុងប្រការដែលកើតឡើងដោយកម្មតែមួយ ឥន្ទ្រិយមានចក្ខុជាដើមទាំងនោះ នឹងផ្សេងគ្នាដូចម្ដេច ? ឆ្លើយថា ផ្សេងគ្នាព្រោះហេតុផ្សេងគ្នានោះឯង ។ ពិតណាស់ តណ្ហាជាតួប្រាថ្នាភពនោះៗ ព្រោះភាពជាធម្មជាតិជាប់ចិត្តក្នុងអាយតនៈ ដែលទាក់ទងក្នុងភពនោះៗ ទើបខ្លួនឯងមានរូបផ្សេងៗ ចាត់ចែងកម្មដែលញ៉ាំងភពនោះៗ ឲ្យកើតឡើងជាធម្មជាតិមានប្រភេទផ្សេងៗ ដោយភាពជាឧបនិស្សយប្បច្ច័យ ។ ព្រោះតណ្ហានោះបង្កើតផលដែលមានសភាវៈផ្សេងៗ មិនមែនតិច ដូចជាកម្មដែលឲ្យកើតឡើង ក្នុងភពនោះៗ តែងមានភាពផ្សេងគ្នា ដែលមានភាពផ្សេងគ្នានៃហេតុនោះ មកតាំងទុកដល់ភាពជារូបមិនមែនតិច ដោយការប្រកប ដោយភាពជាធម្មជាតិ ដែលមានសមត្ថភាពបែបនោះ ។ ការដែលតណ្ហាជាធម្មជាតិ មានអំណាចក្នុងរឿងនេះ មិនគប្បីជ្រាបថាជាដទៃទៅអំពីសមត្ថភាព ព្រោះត្រឹមតែជាភាវៈដែលភាពផ្សេង ត្រូវការភាពផ្សេងនៃហេតុមកតាំងទុក ជាវត្ថុដែលគួរឲ្យសម្រេចផលផ្សេងគ្នា ។ ឯកម្មសូម្បីតែមួយប្រកបភាពផ្សេងដោយភាវៈ ដែលជាហេតុនៃឥន្ទ្រិយមិនមែនតិចនេះ នឹងមានមកខាងមុខដោយភាពសមគួរ និងដោយទី.មក ។ ម្យ៉ាងទៀត លោកពោលដល់ភាពដែលកុសលចិត្ត ១ ដួងប៉ុណ្ណោះ ជាហេតុឲ្យវិបាកចិត្ត ១៦ ដួងជាដើមកើតឡើង ។ សូម្បីក្នុងផ្លូវលោកភាវៈ ដែលគ្រាន់តែពូជស្រូវសាលីមួយគ្រាប់ប៉ុណ្ណោះ ជាហេតុបង្កើតផល គឺអង្ករគ្រាប់តូចគ្រាប់ធំ ដែលបរិបូណ៌ និងមិនបរិបូណ៌ គង់ឃើញស្រាប់នោះឯង ប្រការមួយទៀត

នឹងមានប្រយោជន៍អ្វីដោយការគិតដល់យុត្តិនេះនោះ ។ ព្រោះផលនៃកម្មរមែងឲ្យកើតចក្ខុជាដើម និងកម្មវិបាក ក៏ជាវិស័យនៃព្រះញាណរបស់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះដោយប្រការទាំងពួង ដូច្នេះ ។

ពាក្យថា **អាចារ្យពួកខ្លះ** បានដល់ អាចារ្យពួកខ្លះក្នុងគណៈមហាសង្ឃិកទាំងឡាយ ។ បណ្ដាអាចារ្យពួកខ្លះទាំងនោះ លោកអាចារ្យឈ្មោះថា **សុធម្ម** ពោលទុកយ៉ាងនេះថា ក្នុងចក្ខុ តេជោមានច្រើន ក្នុងសោតៈ វាយោមានច្រើន ក្នុងឃានៈ បឋវីមានច្រើន ក្នុងជិវ្ហា អាបោមានច្រើន ក្នុងកាយ ភូតរូបទាំងអស់ប៉ុនៗ គ្នា ។ លោកអាចារ្យសុធម្ម កាលនឹងសម្ដែងថា ដែលឈ្មោះថា ភាវៈដែលភូតរូប មានតេជោជាដើមមានច្រើនក្នុងរូប មានចក្ខុជាដើម ព្រោះភាពដែលភូតរូបជាទីអាស្រ័យរបស់ចក្ខុនោះ មានតេជោជាដើមច្រើន ទើបពោលពាក្យថា **សភាពថ្លានៃភូតរូបដែលច្រើនទៅដោយតេជោ ជាចក្ខុ** ដូច្នេះជាដើម ។ ក្នុងពាក្យថា **កាយោ សព្វេសំ** នេះ ភាពថ្លារបស់ភូតរូបទាំងអស់ជាកាយ នឹងមានសេចក្ដីផ្សេងដូចម្ដេច សភាពថ្លារបស់ភូតរូប ដែលច្រើនទៅដោយតេជោជាដើម ជារបស់ភូតរូបទាំងអស់នោះឯងមិនមែនឬ ? សេចក្ដីនេះពិត តែពាក្យថា **សព្វេសំ** ( របស់ភូតរូបទាំងអស់ ) នេះ សម្ដែងអត្ថនេះថា **សមានានំ** ប្រែថា ប៉ុនៗ គ្នា ព្រោះលោកពោលទុកដោយអំណាចការឃាត់ភាវៈ ដែលច្រើនទៅដោយឯកទេសដែលប្រព្រឹត្តទៅ ។ សូម្បីកាលភាវៈដែលភូតរូប ២-៣ មានច្រើនទៅដូចជាក្នុងភាវៈដែលតេជោជាដើមមានច្រើនទៅតែម្យ៉ាងសូម្បីកាលភូតរូបមានតិចទៅដែលបានដោយអំណាចភូតរូបពួកមួយជាដើម ដោយភាវៈដែលមានច្រើនទៅតាមដែលពោលទុកហើយនោះឯង កាយបសាទក៏មានមិនបាន ព្រោះដូច្នោះ សេចក្ដីប្រការនេះជាក់ច្បាស់ហើយ ។ ហេតុនោះ កាយបសាទនឹងមានបាន ក៏ដោយភាវៈទាំង ៤ មានស្មើគ្នា ព្រោះដូច្នោះ **សព្វ-ស័ព្ទ** ក្នុងបទថា **សព្វេសំ** នេះ គប្បីឃើញថា សម្ដែងដល់

ភាវៈដែលមានស្មើគ្នា ។ បទថា **តេជាទីនំ** សេចក្តីថា ព្រោះភាវៈដែលភូតរូបទាំងឡាយមានតេជោជាដើម ដែលគោចររូបទាំងឡាយ មានរូបជាដើមជាគុណរបស់ភូតរូបនោះៗ គឺរូប គឺពន្លឺភ្លឺស្វាងជាគុណរបស់តេជោ ពោល គឺប្រទីប សំឡេងដែលជាគុណរបស់វាយោ ក្លិនដែលជាគុណរបស់បឋវី រសជាគុណរបស់ទឹក ពោល គឺខេឡៈ ( ទឹកមាត់ ) អនុគ្រោះតាមសមគួរ ក្នុងវាទៈដំបូង និងក្នុងវាទៈខាងចុង អធិប្បាយថា ព្រោះគប្បីជួយលើកឡើងក្នុងការទទួលអារម្មណ៍ មានរូបជាដើម ។ លទ្ធិរបស់អាចារ្យទាំងនោះថា ការដែលបសាទរូប មានចក្ខុជាដើម ប្រកបដោយហេតុដែលធ្វើរួមគ្នា មានពន្លឺជាដើមនោះឯង ជាធម្មជាតិអាចធ្វើអារម្មណ៍ មានរូបជាដើម និងភាវៈត្រង់អាកាសជាឧបនិស្ស័យនៃសោតវិញ្ញាណ ឈ្មោះថា ជាគុណ ។ លោកប្រើពាក្យថា តាមគួរ ព្រោះអាកាសមិនមានភាពជាភូតរូបដូចតេជោជាដើម ។ម្យ៉ាងទៀតសូម្បីអាកាសក៏ជាគុណរបស់ភូតរូប ដូចជារូបជាដើម ព្រោះដូច្នោះ ទើបក្នុងបំណាងដទៃមានពាក្យប្រកបថា រូបជាដើមដែលជាគុណរបស់ភូតរូបនោះៗ យ៉ាងនេះ គឺរូប គឺពន្លឺដែលជាគុណរបស់តេជោ សំឡេងជាគុណរបស់ប្រហោង ពោល គឺអាកាស ក្លិនជាគុណរបស់វាយោ រសជាគុណរបស់ទឹក ផោដ្ឋព្វៈជាគុណរបស់បឋវី អនុគ្រោះតាមគួរ ។

ពាក្យថា **ព្រោះសម្តែងដល់ភាពជាធម៌ មានរូបជាដើមមានច្រើន** សេចក្តីថា លោកអាចារ្យមានវាទៈដំបូងពោលថា ធម៌ទាំងឡាយមានរូបជាដើម ជាគុណរបស់ភូតរូប មានតេជោជាដើមទាំងនោះ ព្រោះសម្តែងដល់រូបទាំងនេះដែលប្រកបដោយភាពផ្សេងគ្នា គឺពន្លឺនៃរូបនៅក្នុងភ្លើង សំឡេងនៅក្នុងខ្យល់ ទើបឮបានដោយសភាវៈក្លិន មានក្លិនក្រអូបជាដើមនៅក្នុងដី និងរសឆ្ងាញ់ ជារសនៅក្នុងទឹក ដូច្នេះ ។ លោកអាចារ្យពោលឲ្យក្រៃលែងឡើងទៅដោយពាក្យថា **ពួកយើងគប្បីប្រាថ្នា** ដូច្នេះជាដើមដល់លោកអាចារ្យដែលមានវាទៈដំបូងនោះឯង ។ ដោយឧបាយនេះឯង រមែងជាការ

ដែលសន្តត់សន្តិនអាចារ្យស្មូម្បីអ្នកមានវាទៈទី ២ ដូច្នេះ ។ ម្យ៉ាងទៀត គប្បីឃើញ ថា ដើម្បីនឹងលើកយកវាទៈរបស់លោក **កណាទៈ** ( កណាទៈ ជាអាចារ្យបង្រៀន បរជ្ជញា គោលនៃការដឹង និងសេចក្ដីពិត ជាជាតិឥណ្ឌា ស្រុកនឹងអាចារ្យកបិល ) អ្នកពោលថា ចក្ខុជាដើមដែលគេជា អាកាស បឋវី អាបោ និងវាយោ ដែលមានភាព ផ្សេងគ្នានៃធម៌ មានរូបជាដើម ជាគុណតែងលើកឡើងសន្តត់សន្តិនអាចារ្យដែលមាន វាទៈទី ២ នោះ ទើបលោកអាចារ្យបានពោលពាក្យថា **អថាបិ វទេយ្យុំ** ដូច្នេះជាដើម ។ ប្រសិនបើមានពាក្យសួរថា ក្លិនដែលមាននៅក្នុងរបស់ត្រាំ មាននៅក្នុងដី ដែលផ្សំនឹង ទឹក ដែលផ្សេងអំពីកប្បាស ព្រោះដូច្នោះ ក្លិនរបស់កប្បាសក៏នឹងត្រូវ ជាក្លិនដែលចូល ច្រើនជាងមែនឬ ? ឆ្លើយថា មិនមែន ព្រោះក្លិនរបស់កប្បាស មិនត្រូវទឹកគ្របសង្កត់ ។ ពិតណាស់ក្នុងរបស់ត្រាំដីដែលផ្សំនឹងទឹក ឈ្មោះថា ត្រូវទឹកគ្របសង្កត់ហើយ មិនមែន ដីផ្សំនឹងកប្បាស ព្រោះដូច្នោះ ក្លិនរបស់កប្បាសនោះឯង នឹងត្រូវចូលច្រើន ។ និងព្រោះ ធ្វើការអធិប្បាយថា ភ្លើងដែលផ្សំនឹងទឹកក្ដៅ ដែលបានជារបស់ធំ ពណ៌របស់ភ្លើងនោះ ក៏នឹងគប្បីបានជាពណ៌ផូរផង់ ដូចផស្សៈ ព្រោះដូច្នោះ ពណ៌របស់ទឹកនោះ ដែលមិន បានត្រូវភ្លើង មកពាក់ព័ន្ធផង ក៏នឹងក្រៃលែង ជាងពណ៌ក្នុងទឹកក្ដៅ ។ បទថា **តស្មា** ប្រែថា ព្រោះទាំងពីរនោះមិនមាន ។ ដោយភាពមិនមានទាំងពីរយ៉ាងនោះ ទើបលោក បដិសេធរូបជាដើម ជាគុណផ្សេងគ្នានៃភូតរូប មានតេជោជាដើម ដោយការបដិសេធ ភាវៈនោះ ។ ទើបលោកពោលបដិសេធហេតុប្រការនេះថា ព្រោះភាពដែលភូតរូប ទាំងឡាយ មានតេជោជាដើម ដែលធម៌ទាំងឡាយ មានរូបជាដើម ដែលជាគុណ អនុគ្រោះ ព្រោះដូច្នោះ ការមិនមានទាំងពីរយ៉ាងដោយតៗ គ្នា មកដូចពោលមកនេះ រមែងជាហេតុនៃការលះបង់ការគិតប្រការផ្សេងគ្នា ហេតុនោះ ទើបលោកអាចារ្យពោល ពាក្យថា ព្រោះដូច្នោះ **ចូរលះការគិតដល់ការបែកផ្សេងគ្នានេះចេញ** ដូច្នេះជាដើម ។

ដើម្បីនឹងសម្ដែងថា រូបនិងរសជាដើម ក្នុងកលាបៈជាមួយគ្នាក៏គង់ផ្សេងគ្នា នឹងពោលថ្វី ដល់ចក្ខុជាដើម ក្នុងកលាបៈផ្សេងៗ គ្នា ព្រោះការមិនមានភាពផ្សេងគ្នានៃភូតរូប ទើបលោកអាចារ្យពោលនិទស្សនៈ មានរូប និងរសជាដើមទុក ។

បើភាពផ្សេងគ្នារបស់ភូតរូបមិនមាន អ្វីវិញជាហេតុនៃភាពផ្សេងគ្នារបស់ចក្ខុជាដើម ព្រោះដូច្នោះ ដើម្បីនឹងសម្ដែងហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា **ធម្មជាតិជាហេតុមិនទូទៅនៃគ្នានឹងគ្នា** ដូច្នេះជាដើម ។ កម្មតែមួយ ក៏សម្រេចដោយការប្រាថ្នាកត ដែលមានអត្តភាពប្រកបដោយអាយតនៈ ៥ គប្បីឃើញថា លោកពោលថា ជាហេតុមិនទូទៅនៃគ្នានឹងគ្នា ព្រោះភាពជាហេតុនៃសភាពផ្សេងគ្នា របស់ចក្ខុជាដើម និងគប្បីឃើញថា លោកពោលថា ជាសភាពផ្សេងគ្នានៃកម្ម ។ ពិតណាស់ កម្មនោះជាបច្ច័យដល់ចក្ខុ ដោយភាពផ្សេងគ្នាឯណា និងជាបច្ច័យដល់សោតៈ ដោយភាពផ្សេងគ្នានេះនោះឯងក៏ទេ ព្រោះដល់នូវការមិនមាននៃឥន្ទ្រិយដទៃ ។ ចេតនា ១ ដួងក៏រមែងឲ្យដឹងថា ជាកម្មប្បច្ច័យដល់កដត្តារូបទាំងអស់ ដែលមាននៅក្នុងបដិសន្ធិក្ខណៈ ដោយព្រះបាលីថា ចេតនាក្នុងចំណែកមហគ្គតៈ ក្នុងបដិសន្ធិក្ខណៈជាបច្ច័យ ដោយកម្មប្បច្ច័យដល់កដត្តារូបទាំងឡាយ ។ កាលការកើតឡើងនៃឥន្ទ្រិយ ក្នុងវេលានោះ ដោយចេតនាផ្សេងៗ ក៏នឹងត្រូវជាកដត្តារូបដែលកម្ម ចំណែកកាមាវចរៈ និងចំណែកមហគ្គតៈឲ្យកើតឡើងហើយ ដូច្នេះ ។ បដិសន្ធិមួយ នឹងជាធម្មជាតិកើតអំពីកម្មច្រើនយ៉ាងក៏ទេ ព្រោះដូច្នោះ ទើបសម្រេចការយល់ថា ការកើតឡើងនៃឥន្ទ្រិយច្រើនយ៉ាងរមែងមានបានដោយកម្មតែ ១ ។

ទីអាស្រ័យមិនជាប់គ្នា មាននៅដល់អារម្មណ៍នេះ ហេតុនោះ អារម្មណ៍នេះ ឈ្មោះថា **អនល្លីនទិស្សយោ** ប្រែថា មានទីអាស្រ័យមិនជាប់គ្នា បានដល់ អារម្មណ៍ គឺរូប និងសំឡេង ។ ទីអាស្រ័យរបស់ក្លិន និងរសជាប់គ្នានឹងទីអាស្រ័យរបស់ឃានៈ និងជិវ្ហា ព្រោះដូច្នោះ ក្លិន និងរសទាំងនោះ ទើបឈ្មោះថា ជាប់គ្នា ដោយអំណាចទីអាស្រ័យ ។ ផោដ្ឋព្វៈក៏ជាប់នឹងទីអាស្រ័យរបស់កាយដោយខ្លួនឯង ព្រោះជាភូតរូប ។ ន័យម្យ៉ាងទៀត ចក្ខុ និងសោតៈទទួលអារម្មណ៍ដែលមិនដល់ខ្លួនបាន ព្រោះជាហេតុកើតឡើងនៃវិញ្ញាណបាន ក្នុងអារម្មណ៍ដែលមានរវាងចន្លោះ និងដែលក្រៃលែង ។ អាចារ្យ ពួកខ្លះពោលថា សូម្បីសោតៈក៏ទទួលអារម្មណ៍ដែលដល់ខ្លួន ។ បើសោតៈទទួលអារម្មណ៍ដែលដល់ខ្លួន សំឡេងដែលកើតអំពីចិត្ត ក៏មិនគប្បីជាអារម្មណ៍របស់សោតវិញ្ញាណដែរ ។ ព្រោះរូបមានចិត្តជាសមុដ្ឋាន មិនមានការកើតឡើងខាងក្រៅ ហើយក្នុងព្រះបាលី ក៏ត្រាស់ដល់ភាវៈដែលសទ្ទារម្មណ៍ ជាអារម្មណ៍របស់សោត-វិញ្ញាណទុកដោយមិនផ្សេងគ្នា ។ នៅមានបន្តិចទៀត ឯការកំណត់ទិស និងស្ថានទីក៏នឹងមិនគប្បីមានដល់សំឡេងដូចគ្នានឹងក្លិន ព្រោះគួរកាន់យកចំពោះប្រកពឥន្ទ្រិយរបស់ខ្លួនប៉ុណ្ណោះ ព្រោះហេតុនោះ សំឡេងកើតឡើងក្នុងទីណា ក៏នៅក្នុងទីនោះៗ ឯង ។ ចោទថា បើសំឡេងមកកាន់គន្លងក្នុងសោតទ្វារសោត សំឡេងរបស់ជាងជ្រលក់ ( លាប ) ជាដើម បុគ្គលដែលនៅឆ្ងាយរមែងបានឮយឺតមិនមែនឬ ? ឆ្លើយថា មិនមែន ព្រោះបុគ្គលដែលនៅឆ្ងាយ និងនៅជិតទទួលសំឡេងតាមដែលប្រាកដបានផ្សេងគ្នា ។ ប្រៀបដូចជាភាពផ្សេងគ្នានៃអាការ ដោយភាពផ្សេងគ្នានៃការទទួល សំឡេងរបស់ពាក្យ

ពោលតាមដែលប្រាកដសម្រាប់បុគ្គលឆ្ងាយទទួលមិនបាន តែបុគ្គលនៅជិត រមែងទទួលបាន យ៉ាងណា សូម្បីក្នុងសំឡេងរបស់ជាងជ្រលក់ជាដើម ក៏ដូច្នោះ សម្រាប់បុគ្គលនៅជិតជាក់ច្បាស់ដោយលំដាប់តាំងអំពីដើមរហូតដល់ចប់ តែសម្រាប់អ្នកនៅឆ្ងាយក៏ជាក់ច្បាស់ ដោយប្រព្រឹត្តទៅជាអន្ទើ ជាវគ្គ ក្នុងទីបញ្ចប់ខ្លះ ក្នុងរយៈកណ្តាលខ្លះ សំឡេងដែលបានឮស្រាល ដោយភាពផ្សេងរបស់ការចាប់ចិត្ត ការបានដែលប្រព្រឹត្តទៅតអំពីសោតវិញ្ញាណវីថិ រមែងមានការយល់ថា បានឮយឺត ។ ឯសំឡេងនោះកើតឡើងហើយក្នុងទីណាអាស្រ័យ ទីនោះឯងមកកាន់គន្លងនៃសោតៈ ក្នុងខណៈដែលសំឡេងកំពុងតាំងនៅ ។ សួរថា បើសំឡេងមិនមានការកើតឡើង ដោយជុំវិញ ដោយបន្តគ្នានៃភូតរូបសោត ហើយសំឡេងខ្ទរនឹងកើតឡើងដូចម្តេច ? ឆ្លើយថា គប្បីឃើញថា សំឡេងសូម្បីនៅឆ្ងាយ ក៏រមែងជាបច្ច័យឲ្យសំឡេងខ្ទរកើតឡើងក្នុងទីដទៃណានឹងឲ្យភាជនៈជាដើមញ័របាន ដូចការគាត់ដែកជាបច្ច័យ ឲ្យដែកញ័របានដូច្នោះដែរ ។

ចក្ខុសូម្បីបានអធិប្បាយទុកហើយ ដោយបកិណ្ណកៈមានលក្ខណៈជាដើមក្នុងកាលមុន ទើបលោកអាចារ្យផ្តើមពាក្យថា **ចក្ខុ ពេច្ចត្ថ** ជាដើម ដើម្បីនឹងអធិប្បាយដោយបកិណ្ណកៈ មានស្ថានទីតាំងជាដើម ។ ក្នុងពាក្យនោះសម្ពន្ធសេចក្តីក្នុងព្រះបាលីថា **ចក្ខុ សាធយមានំ តិដ្ឋតិ** ប្រែថា ចក្ខុញ៉ាំងភាពជាវត្ថុ និងទ្វារឲ្យសម្រេចតាំងនៅ ។ **ច** អក្ខរៈ មានអត្ថជា **ព្យតិរេក** ដោយ **ច** អក្ខរៈនោះ លោកអាចារ្យរមែងញ៉ាំងភាពផ្សេងគ្នាដែលកំពុងពោលនោះឯងរបស់ចក្ខុនោះឲ្យភ្លឺច្បាស់ ។ បទថា **ឯត្ថ** ប៉ុនគ្នានឹង **ឯតេសុ** យថា **និទ្ទិដ្ឋេសុ** **បញ្ចសុ** **ឧបាទារូបេសុ** ប្រែថា ក្នុងបណ្តាឧបាទាយរូប

៥ តាមដែលបានសម្ដែងទុកហើយនេះ ។ ដោយពាក្យថា ក្នុងប្រភពដែលកើតសរីរសណ្ឋាននោះ លោកអាចារ្យហាមវង់ភ្នែកខ្មៅដែលសល់ ។ **ធាតុទាំង ៤** ជាទីអាស្រ័យរបស់ខ្លួនដែលជ្រួតជ្រាបក្នុងភ្នាសភ្នែក៧ជាន់ដូចជាជរស្អិតតាំងនៅនោះឯង **ធ្វើឧបការៈហើយ** ដែលអាយុ វណ្ណៈជាដើម អាស្រ័យធាតុទាំង ៤ នោះឯងតាមរក្សាហែហមហើយ ដែល **ឧតុ ចិត្ត** និង **អាហារ** ដែលញ៉ាំងសន្តតិរូប ៣ ឲ្យតាំងឡើង **ឧបត្ថម្ភទុករមែងតាំងនៅ** ។ ដោយការពោលដល់ការផ្សើមភ្នាសភ្នែក ៧ ជាន់នោះឯង លោកសម្ដែងថា ចក្ខុដល់នូវភាពជាកលាបៈច្រើនកលាបៈទុក ។ ពាក្យថា **ដោយប្រមាណប៉ុនក្បាលសុច** លោកពោលទុកព្រោះកើតក្នុងប្រភព ( អាយតនៈ ) ប៉ុនក្បាលសុច ។ លោកពោលថា ចក្ខុវិញ្ញាណ **ជាទីនៅ** ដែលជាទីអាស្រ័យ នឹងថាទីបំផុតតទាលម្ពណៈ ដែលជាអាវជ្ជនៈ និងសម្បដិច្ឆន្នៈ **ជាទ្វារ** ព្រោះជាទីឈោងចុះស្មើគ្នា ។ចក្ខុនេះជាធម្មជាតិមានច្រើនយ៉ាង ដោយភាពផ្សេងនៃទីតាំងអាស្រ័យ ដោយក្នុងសភាពផ្សេងដែលតាំងអាស្រ័យនោះតែម្យ៉ាង ក៏ចាត់ជាកលាបៈបានមិនមែនតិច លោកក៏ពោលសង្គ្រោះទុកតែមួយ ព្រោះជាការដូចគ្នានឹងអាវជ្ជនវីថិ ដោយសម្ដែងដល់ភាពស្មើគ្នា និងព្រោះចក្ខុដូចគ្នានោះឯង ធ្វើកិច្ចបានក្នុងខណៈដូចគ្នា ។ ក្នុងបណ្ដាចក្ខុច្រើនយ៉ាងនេះ ភាពដែលចក្ខុតែមួយនោះឯង ជាធម្មជាតិធ្វើកិច្ចដូចម្ដេច ? ក្នុងបណ្ដាចក្ខុច្រើនយ៉ាងនោះ ចក្ខុណាជាធម្មជាតិបរិសុទ្ធ គួរប៉ះខ្ទប់រូបបាន ចក្ខុនោះគួរកាន់យកថា ជាទីអាស្រ័យនៃវិញ្ញាណ ។ ដូចផោដ្ឋព្វៈមួយប្រភេទក្នុងភាពជាអារម្មណ៍របស់កាយ វិញ្ញាណ ។

ម អក្ខរៈថា មនុបស្សតិ ធ្វើបទសន្ធិ ម្យ៉ាងទៀត មនុ ប៉ុនគ្នានឹង មច្ចោ ប្រែថា សត្វមានការស្លាប់ជាសភាវៈ ។

**អង្គុលីវេធកំ** ប្រែថា វង់ចិញ្ចៀន ។ លោកអាចារ្យកាលនឹងសម្តែងថា ចក្ខុគប្បី ឃើញដូចជាពស់ដែលចូលចិត្តរន្ធក្នុងដំបូក ព្រោះភាពជាធម្មជាតិពេញចិត្តរូប ដែលមិនរាបស្មើ សោតៈគប្បីឃើញដូចជាក្រពើ ដែលចូលចិត្តរូងក្នុងទឹក ព្រោះជាធម្មជាតិពេញចិត្តប្រហោង ឃានៈគប្បីឃើញប្រៀបដូចជាបក្សីដែលត្រេកអរក្នុងអជជាកាស ព្រោះជាធម្មជាតិពេញចិត្តអាកាស ជិវ្ហាគប្បីឃើញប្រៀបដូចឆ្កែស្រុក ដែលពេញចិត្តស្រុក ព្រោះជាធម្មជាតិពេញចិត្តស្រុក កាយគប្បីឃើញប្រៀបដូចឆ្កែចចកដែលពេញចិត្តព្រៃខ្មោច ព្រោះជាធម្មជាតិពេញចិត្តរូប ដែលមានវិញ្ញាណគ្រប់គ្រង ទើបពោលថា **វម្មិ ។បេ។ ទដ្ឋព្វា** ដូច្នេះ ។ សេចក្តីដែលចក្ខុជាធម្មជាតិ ចូលចិត្តរូបមិនស្មោះស្មើ លោកពោលទុកព្រោះអធិប្បាយថា ដូចជាមានអធ្យាស្រ័យ ក្នុងរូបមិនស្មើ ន័យម្យ៉ាងទៀត គប្បីឃើញចក្ខុថា មានការពេញចិត្តរូបមិនស្មើ ដោយអំណាចអធ្យាស្រ័យរបស់បុគ្គល ដែលមានចក្ខុ ។ ក្នុងសោតៈជាដើមដ៏សេសក៏មានន័យនេះដូចគ្នា ។ ចំណែកសេចក្តីពិស្តារតាមដែលពោលទុកហើយទាំងអស់គប្បីជ្រាបតាមសមគួរក្នុងសោតៈជាដើម ។

# វិសុទ្ធិមគ្គ

## គោចររូប ៤

ក្នុងគោចររូបទាំងឡាយ មានរូបជាដើម តអំពីបសាទរូបនោះទៅ មានវិនិច្ឆ័យ ដូច្នេះថា

រូប មានការប៉ះខ្ទប់ចក្ខុជាលក្ខណៈ មានភាពជាវិស័យនៃចក្ខុវិញ្ញាណជារស (គឺកិច្ច) ដែលមានភាពជាគោចរនៃចក្ខុវិញ្ញាណនោះឯងជាបច្ចុប្បដ្ឋាន (គឺផល) មានមហាភូតរូប ៤ ជាបទដ្ឋាន ( គឺហេតុជិត ) ។

ឯប្រការ ( ដែលរូបមានមហាភូតរូប ៤ ជាបទដ្ឋាន ) នេះយ៉ាងណា ?

ឧបាទាយរូបទាំងពួងក៏ដូច្នោះដែរ តែក្នុងទីណាមានសភាពប្លែក ទើបខ្ញុំពោលសេចក្តីដែលប្លែកក្នុងទីនោះ ។

រូបនេះមានច្រើនយ៉ាង ដោយអំណាចនៃពណ៌ មានពណ៌ខៀវ ពណ៌លឿងជាដើម ។

សំឡេង មានការប៉ះខ្ទប់សោតៈជាលក្ខណៈ មានភាពជាវិស័យនៃសោតវិញ្ញាណជារស មានភាពជាគោចរនៃសោតវិញ្ញាណនោះឯងជាបច្ចុប្បដ្ឋាន មានច្រើនយ៉ាង ដោយន័យជាដើមថា សំឡេងស្គរ សំឡេងសម្ភោរ ។

ក្លិន មានការប៉ះខ្ទប់ឃានៈជាលក្ខណៈ មានភាពជាវិស័យនៃឃានវិញ្ញាណជារស មានភាពជាគោចរនៃឃានវិញ្ញាណនោះឯងជាបច្ចុប្បដ្ឋាន មានច្រើនយ៉ាងដោយន័យជាដើម ក្លិនឫស ( ឈើ ) ក្លិនខ្លឹម ( ឈើ ) ។

រស មានការប៉ះខ្ទប់ជិវ្ហាជាលក្ខណៈ មានភាពជាវិស័យនៃជិវ្ហាវិញ្ញាណជារស មានភាពជាគោចរនៃជិវ្ហាវិញ្ញាណនោះឯងជាបច្ចុប្បដ្ឋាន មានច្រើនយ៉ាង ដោយន័យជាដើមថា រសឫសឈើ រសដើមឈើ ។

# មហាដីកា

*ការប៉ះខ្ទប់ត្រង់ចក្ខុឈ្មោះថា **ចក្ខុបដិហននំ** ម្យ៉ាងទៀត ការប៉ះខ្ទប់នូវចក្ខុ ឈ្មោះថា **ចក្ខុបដិហននំ** ដែលប្រែថា ការប៉ះខ្ទប់ចក្ខុ ការប៉ះខ្ទប់ចក្ខុនោះជាលក្ខណៈរបស់រូបនោះ ហេតុនោះ ទើបរូបនេះឈ្មោះថា **ចក្ខុបដិហននលក្ខណំ** ប្រែថា មានការប៉ះខ្ទប់ចក្ខុជាលក្ខណៈ ។ ឯការប៉ះខ្ទប់ក្នុងទីនេះ បានដល់ **អភិឃាត** ដែលប្រែថា ការប៉ះខ្ទប់ដូចគ្នា តាមដែលពោលហើយ ។ **ភាពជាវិស័យ** បានដល់ ភាពជាអារម្មណប្បច្ច័យ ។ ភាពជាអារម្មណប្បច្ច័យនោះឯង គឺភាពជាគោចរដោយពិត សូម្បីយ៉ាងនោះ វិស័យ និងគោចរក៏មានភាពផ្សេងគ្នា ដូច្នេះ ។*

*គឺការៈដែលចក្ខុវិញ្ញាណមិនមាននៅក្នុងអារម្មណ៍ដទៃ និងការៈដែលចក្ខុវិញ្ញាណជាធម្មជាតិត្រាច់ទៅច្រើនក្នុងរូបារម្មណ៍នោះ ពាក្យដែលគួរពោលក្នុងការៈ ដែលរូបនោះជាវិស័យនឹងមានច្បាស់ខាងមុខ ។*

# វិសុទ្ធិមគ្គ

## ភាវរូប ២

ឥត្ថិន្ទ្រិយ មានភាវៈនៃស្រីជាលក្ខណៈ មានការប្រកាសថាស្រីជារស មានភាវៈគឺការធ្វើ ( ឥត្ថិលិង្គ ) ភេទនៃស្រី ( ឥត្ថិនិមិត្ត ) និមិត្តនៃស្រី ( ឥត្ថីកុត្តៈ ) កិរិយានៃស្រី និង ( ឥត្ថាកប្បៈ ) អាកប្បៈនៃស្រីជាបច្ចុប្បដ្ឋាន ។

បុរិសិន្ទ្រិយ មានភាវៈនៃបុរសជាលក្ខណៈ មានការប្រកាសថាជាប្រុសជារស មានភាវៈ គឺការធ្វើ ( បុរិសលិង្គ ) ភេទនៃបុរស ( បុរិសនិមិត្ត ) និមិត្តនៃបុរស ( បុរិសកុត្តៈ ) កិរិយានៃបុរស និង ( បុរិសាកប្បៈ ) អាកប្បៈនៃបុរសជាបច្ចុប្បដ្ឋាន។

ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយទាំង ២ នោះ ផ្សព្វផ្សាយទៅពេញសរីរៈ ( របស់ស្ត្រីបុរស ) ដូចកាយបសាទដូចគ្នា តែមិនដល់គ្នា នឹងការពោលបានថា វាតាំងនៅក្នុងឱកាសដែលកាយបសាទតាំងនៅ ឬថា រូបនេះតាំងនៅក្នុងឱកាសដែលកាយ បសាទមិនបានតាំងនៅក៏ដោយ ការលាយឡំគ្នានឹងគ្នានៃភាវរូប និងកាយបសាទ ក៏មិនមានដូចរូប និងរសជាដើម ក៏មិនបានលាយឡំគ្នា ដូច្នោះ ។

# មហាដីកា

*ឈ្មោះថា* ***ឥត្ថីភាវៈ*** *ដោយអត្ថថា ភាវៈរបស់ស្រី ឬដោយអត្ថថា សភាពដែលជាហេតុ មានការគិត និងមានឈ្មោះថា ជាស្រី ។ ឥត្ថីភាវៈទាំង ២ វិគ្គហៈនោះជាលក្ខណៈរបស់ឥត្ថិន្ទ្រិយនេះ ព្រោះហេតុនោះ ឥន្ទ្រិយនេះ ឈ្មោះថា* ***មានឥត្ថីភាវៈជាលក្ខណៈ*** *។ ព្រោះឥត្ថិន្ទ្រិយ មានឥត្ថីភាវៈជាលក្ខណៈនោះៗ ឯង ឥត្ថិន្ទ្រិយទើបរមែងហាក់ដូចជាប្រកាសសន្តានដែលប្រកបដោយឥត្ថីភាវៈនោះថាជាស្រី ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា* ***មានការប្រកាសថា ជាស្រីជារស*** *។ ភាពជាអ្នកមានស្នាមូលរលីង និងភាពជាអ្នកមានដៃ និងជើងមិនអង់អាចជាដើម ឈ្មោះថា* ***ឥត្ថីលិង្គៈ*** *។ ភាពជាអ្នកមានដោះប៉ោង ភាពជាអ្នកមិនមានពុកមាត់ ការចងសក់ និងការប្រើសំពត់ ឈ្មោះថា* ***ឥត្ថីនិមិត្ត*** *ព្រោះជាបច្ច័យដល់ការសម្គាល់ថា ជាស្រី ។ ការលេងដោយចង្អេរ និងអង្រែជាដើម ការរវៃអំបោះដោយដីស្អិត និងទឹកដោះជូរក្នុងវេលាដែលជាកុមារឈ្មោះថា ឥត្ថីកុត្តៈ អធិប្បាយថា កិរិយារបស់ស្ត្រី ។ អាការមានការឈរ និងការដើរជាដើមមិនអង់អាច ឈ្មោះថា* ***ឥត្ថីអាកប្បៈ*** *។ ន័យម្យ៉ាងទៀត ទ្វារបស្សាវៈរបស់ស្រី ឈ្មោះថា* ***ឥត្ថីលិង្គ*** *។ ឈ្មោះថា* ***ឥត្ថីនិមិត្ត*** *ព្រោះបំណងយកសំឡេង ។ កិរិយាមានការឈរ ការដើរ ការអង្គុយ ការទំពា និងការបរិភោគជាដើម ដែលមិនអង់អាចឈ្មោះថា* ***ឥត្ថីកុត្តៈ*** *។ ទ្រង់ទ្រាយរបស់ស្រី ឈ្មោះថា* ***ឥត្ថីអាកប្បៈ*** *។ លោកអាចារ្យពោលថា* ***មានភាពជាហេតុនៃឥត្ថីលិង្គ ឥត្ថីនិមិត្ត ឥត្ថីកុត្តៈ និងឥត្ថីអាកប្បៈជាបច្ចុប្បដ្ឋាន*** *ព្រោះអធិប្បាយថា ឥត្ថីលិង្គ ជាដើមនេះ កាលកើតឡើងដោយបច្ច័យ មានកម្មជាដើមតាមសមគួរដល់ខ្លួន ក៏រមែងជាអាការនៃឥត្ថីលិង្គជាដើមនោះៗ កើតឡើងក្នុងសន្តាន ដែលប្រកបដោយឥត្ថិន្ទ្រិយនោះឯង*

ដោយច្រើន ព្រោះដូច្នោះ ទើបឥត្ថិន្ទ្រិយជាហេតុនៃឥត្ថីលិង្គជាដើមនោះ ។ លោកពោលថា ឥត្ថិន្ទ្រិយនោះជាឥត្ថិន្ទ្រិយដោយភាវៈជាអធិបតី ពោល គឺភាពជាហេតុក្នុងឥត្ថីលិង្គជាដើមនោះឯង ព្រោះមិនទាន់ជាបច្ច័យនៃរូប ដែលអាការនៃឥត្ថីលិង្គជាដើមឲ្យកើតឡើងដោយប្រការដទៃ ក្នុងសន្តានដែលប្រកបដោយឥត្ថិន្ទ្រិយ និងព្រោះការប្រកាន់ថាជាស្រី ជាបច្ច័យដល់រូបទាំងនោះ ។

ព្រោះឥត្ថិន្ទ្រិយមិនបានញ៉ាំងរូបក្នុងភាវទសកៈឲ្យកើតទាំងមិនបានតាមរក្សាឬឃ្លាំឧបត្ថម្ភ និងមិនញ៉ាំងរូបកលាបៈដទៃឲ្យកើត ព្រោះដូច្នោះ ទើបឥត្ថិន្ទ្រិយនោះ មិនបានត្រាស់ទុកក្នុងព្រះបាលីថា ជាឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ដូចជាជីវិតិន្ទ្រិយដែលជាបច្ច័យដល់រូបកលាបៈរបស់ខ្លួន ឬដូចអាហារ ជាបច្ច័យដល់រូបកលាបៈដទៃ ។ ព្រោះហេតុដែលលិង្គជាដើមអាស្រ័យបច្ច័យដទៃ ដូច្នោះ ភាពជាធំគប្បីមានបានក្នុងលិង្គជាដើមណា សូម្បីក្នុងរូបដែលធ្វើឲ្យវិចិត្ររបស់បុគ្គលដែលស្លាប់ហើយ ដូចគ្នានឹងលិង្គជាដើមនោះ ក៏ឃើញបានថា មានសណ្ឋាន ដូចលិង្គជាដើមនោះ ។ ក្នុងបុរិសិន្ទ្រិយក៏មានន័យនេះ ។ ចំណែកក្នុងអធិការនេះពាក្យណាដែលផ្សេងគ្នាពាក្យនោះគប្បីជ្រាបតាមគន្លងនៃន័យ ដែលបានពោលទុកហើយ ឥន្ទ្រិយទាំង ២ នេះ ព្រោះមិនកើតរួមនៅក្នុងសន្តានជាមួយគ្នា ដោយព្រះបាលីថា សួរថា ឥត្ថិន្ទ្រិយកើតឡើងដល់សត្វណា បុរិសិន្ទ្រិយ រមែងកើតឡើង ដល់សត្វនោះឬ ? ឆ្លើយថា មិនមែនទេ ដូច្នេះជាដើម ដូច្នោះ ទើបគប្បីជ្រាបថា សូម្បីឧភតោព្យញ្ជនកៈ ក៏រមែងមានឥន្ទ្រិយមួយប៉ុណ្ណោះក្នុងខណៈមួយ ។ ចំណែកអាចារ្យពួកណាពោលថា ការប្រព្រឹត្តទៅដោយឯកទេសនៃសរីរៈជាភាវរូប ដើម្បីនឹងសម្តែងថា ពាក្យរបស់លោកអាចារ្យនោះទាំងនោះខុស ទើបលោកអាចារ្យពោលថា **ឥន្ទ្រិយទាំង ២ យ៉ាងជ្រួតជ្រាបទៅពេញសរីរៈទាំងអស់នោះ ដូចកាយបសាទ** កាលនឹងហាមឃាត់នូវសេចក្តីសង្ស័យថា បើដូច្នោះ

ការលាយឡំគ្នាដោយកាយបសាទក៏នឹង គប្បីមាន ទើបពោលពាក្យថា **តែមិនដល់ការៈដែលនឹងពោលបានថា តាំងនៅក្នុងឱកាសដែលកាយបសាទតាំងនៅ** ដូច្នេះជាដើម ។ ពាក្យរបស់លោកអាចារ្យនោះ មានអធិប្បាយថា មិនដល់ការៈដែលគួរនឹងពោលថា តាំងនៅក្នុងឱកាសដែលកាយបសាទមិនបានតាំងនៅ ព្រោះជាធម្មជាតិជ្រួតជ្រាបទៅពេញសរីរៈទាំងមូល ដោយពិត ដូច្នោះ ក៏មិនដល់ការៈដែលគួរនឹងពោលថា តាំងនៅក្នុងឱកាសដែលកាយបសាទតាំងនៅ ព្រោះមានទីអាស្រ័យផ្សេងគ្នា ពាក្យដូចដែលពោលមកនេះ ជាពាក្យដែលពោលដោយត្រង់ក្នុងមាតិកានេះ ។ ដោយពាក្យថា ដូចជា **រូប** និង **រស** ជាដើមនេះ លោកអាចារ្យ រមែងសម្តែងថា **ការលាយឡំគ្នា រមែងមិនមាន** ក្នុងរូបដែលមានទីអាស្រ័យស្មើគ្នា ព្រោះលក្ខណៈផ្សេងគ្នា នឹងពោលថ្វីដល់សការៈនៃរូប ដែលមានទីអាស្រ័យផ្សេងគ្នានោះ ។

# វិសុទ្ធិមគ្គ

## ជីវិតរូប ១

ជីវិតិន្ទ្រិយ មានការតាមរក្សាសហជរូប ( រូបដែលកើតរួមគ្នានឹងខ្លួន ) ទុកជាលក្ខណៈ មានការញ៉ាំងសហជរូបទាំងនោះឲ្យប្រព្រឹត្តទៅជារស មានការតម្កល់ទុកបាននូវសហជរូបទាំងនោះឯងជាបច្ចុប្បដ្ឋាន មានភូតរូបដែលខ្លួនគប្បីឲ្យប្រព្រឹត្តទៅដោយអំណាចការតាមរក្សាជាបទដ្ឋាន ។

ឯជីវិតិន្ទ្រិយនោះ កាលវិធាន ( ការធ្វើការ ) មានលក្ខណៈ គឺការតាមរក្សាជាដើមនៅមាន ក៏រមែងតាមរក្សាសហជរូបទាំងឡាយ តែក្នុងខណៈដែល ( សហជរូបដែលខ្លួននឹងគប្បីតាមរក្សានោះ ) នៅមានប៉ុណ្ណោះ ដូចទឹករក្សាវារីជាតិទាំងឡាយមានឧប្បលជាដើម ( តែក្នុងខណៈដែលឧប្បលជាដើមនោះនៅមាន ) ដូច្នោះ ម្យ៉ាងទៀត រមែងរក្សាតែធម៌ គឺវត្ថុទាំងឡាយដែលជាបច្ចុប្បន្នកើតឡើងចំពោះមុខ តាមដែលជារបស់ខ្លួនរៀងៗ ខ្លួន ( ដែលនៅក្នុងវិស័យដែលខ្លួននឹងគប្បីចិញ្ចឹមរក្សា ) ដូចនាងស្នំ រមែងបីបាច់រក្សាតែព្រះកុមារដែលបានព្រះកំណើតមកចំពោះមុខហើយ តាមដែលនៅក្នុងកិច្ចរបស់ខ្លួនប៉ុណ្ណោះ ។ម្យ៉ាងទៀត ជីវិតិន្ទ្រិយនោះ រមែងប្រព្រឹត្តទៅដោយសម្ពន្ធនឹងធម៌ គឺវត្ថុដែលខ្លួនឲ្យប្រព្រឹត្តទៅឯងប៉ុណ្ណោះ ដូចនាយទូក រមែងប្រព្រឹត្តទៅដោយពាក់ព័ន្ធនឹងវត្ថុដែលខ្លួនឲ្យប្រព្រឹត្តទៅ គឺទូកដូច្នោះ មិនប្រព្រឹត្តទៅចំពោះតែការបែកធ្លាយឡើយ ( ព្រោះកាលបែកធ្លាយហើយ ) ក៏មិនមានខ្លួន និងវត្ថុទាំងឡាយដែលខ្លួនគប្បីឲ្យប្រព្រឹត្តទៅផងដែរ ម្យ៉ាងទៀត រមែងមិនទ្រទ្រង់សហជរូបទុកបានក្នុង

កន្តក្ខណៈ ព្រោះខ្លួនឯង ក៏កំពុងបែកធ្លាយ ដូចប្រទេះ និងប្រេងកំពុងអស់ រមែង មិនទំនុកបម្រុងអណ្តាត ប្រទីបទុកបាន ដូច្នោះ តែគប្បីឃើញថា ជីវិតិន្ទ្រិយនោះ មិនមែនគ្មានអានុភាពក្នុងការចិញ្ចឹមរក្សាសហជរូប ការញ៉ាំងសហជរូបឲ្យប្រព្រឹត្តទៅ និងការទ្រទ្រង់ទុកនូវសហជរូបនោះឡើយ ព្រោះជីវិតិន្ទ្រិយញ៉ាំងកិច្ចនោះៗ មានការ ចិញ្ចឹមរក្សាជាដើម ឲ្យសម្រេចក្នុងខណៈតាមដែលពោលហើយ ។

# មហាដីកា

ពាក្យថា **មានការតាមរក្សាសហជរូបជាលក្ខណៈ** គឺមានការតាមរក្សារូប ដែលកើតរួមនឹងខ្លួនទាំងឡាយជាលក្ខណៈ ។ ព្រោះជីវិតិន្ទ្រិយជាកម្មជរូប ដោយចំណែកមួយ រូបទាំងឡាយដែលជីវិតិន្ទ្រិយតាមរក្សា ក៏សម្រេចភាពជាកម្មជរូប ដោយសព្ទថា **សហជៈ** នោះឯង ព្រោះដូច្នោះ ទើបលោកមិនប្រើសព្ទថា **កម្មជៈ** ។ ជីវិតិន្ទ្រិយនោះឈ្មោះថា តាមរក្សាដោយភាពជាហេតុ ប្រព្រឹត្តទៅរបស់កម្មជរូប ដែលតាំងនៅមួយជួរខណៈតាមសមគួរដល់ខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថា មានការតាមរក្សាសហជរូបជាលក្ខណៈ ។ កម្មតែម្យ៉ាងមិនល្មមជាហេតុតាំងនៅរបស់កម្មជរូបទាំងឡាយ ដូចអាហារជាដើមមិនល្មមនឹងជាហេតុតាំងនៅរបស់អាហារជរូបជាដើម ។ ព្រោះហេតុអ្វី ព្រោះមិនមាននៅក្នុងខណៈនោះ ។ បទថា **តេសំ យោគ សហជរូបានំ** ។ **បវត្តនំ** ប្រែថា ការឲ្យប្រព្រឹត្តទៅ ។ **ឋបនំ** ប្រែថា ភាពជាហេតុទ្រទ្រង់ ។ ភូតរូបទាំងឡាយដែលខ្លួន ( គឺរូបជីវិតិន្ទ្រិយ ) គប្បីឲ្យប្រព្រឹត្តទៅ គឺគប្បីឲ្យដំណើរទៅ ដោយអំណាចការតាមរក្សា ជាបទដ្ឋានរបស់រូបជីវិតិន្ទ្រិយនេះ ហេតុនោះ រូបជីវិតិន្ទ្រិយនេះឈ្មោះថា **យាបេតព្វ ភូតបទដ្ឋានំ** ប្រែថា មានភូតរូប ដែលខ្លួនគប្បីឲ្យប្រព្រឹត្តទៅជាបទដ្ឋាន ។ ដោយ **អាទិ**-សព្ទថា **អនុបាលនលក្ខណាទិម្හិ** លោកអាចារ្យរមែងសង្គ្រោះបកិណ្ណកៈ មានជីវិតិន្ទ្រិយដែលមានការញ៉ាំងសហជាតរូប ទាំងនោះឲ្យប្រព្រឹត្តទៅជារសជាដើមនោះឯង ។ បទថា **អត្ថិក្ខណេ យេវ** ប្រែថា ក្នុងខណៈដែលនៅមានសហជរូប ដែលខ្លួនគប្បីតាមរក្សានោះឯង ។ កាលវារិជាតិ មានឧប្បលជាដើមដែលទឹកគប្បីតាមរក្សា

មិនមាន ទីកនឹងគប្បីតាមរក្សាអ្វីទៅ ? បើកម្មជរូបទាំងឡាយមិនមានការតាំងនៅ ដោយវាងហេតុនៃការតាំងនៅ អ្វីនឹងជាហេតុនៃការទ្រទ្រង់របស់ជីវិតិន្ទ្រិយនោះ ? ព្រោះដូច្នោះទើបលោកអាចារ្យពោលថា **សយំ** ជាដើម ។ បើឋានៈរបស់កម្មជរូបទាំងឡាយទាក់ទងដោយជីវិតិន្ទ្រិយសោត កាលបើដូច្នោះ ហេតុអ្វី ទើបមិនតាំងនៅអស់កាលហ្នឹ ព្រោះដូច្នោះ ទើបលោកពោលពាក្យថា មិនប្រព្រឹត្តទៅផុតចាកអំពីការបែកធ្លាយទៅ ដូច្នេះជាដើម ។ **ព្រោះឲ្យសម្រេចកិច្ច** មានការតាមរក្សាសហជាតរូបនោះៗ ជាដើម ។ និងការឲ្យសម្រេចកិច្ចនោះ ក៏ព្រោះភាវៈដែលជាបច្ច័យដល់ភាពពិសេស គឺភាវៈដែលកំពុងកើត ។ ពិតណាស់ រូបដែលទាក់ទងដោយឥន្ទ្រិយមានភាពផ្សេងដែលជីវិតិន្ទ្រិយសាងឡើងអំពីរូបរបស់មនុស្សស្លាប់ កម្មជរូប និងរូបដែលពាក់ព័ន្ធតាមកម្មជរូប ក៏មានភាពផ្សេងដែលជីវិតិន្ទ្រិយនោះអំពីរូប មានរូបដែលមានឧតុជាសមុដ្ឋានជាដើម គប្បីឃើញថា ជីវិតិន្ទ្រិយជាហេតុនៃការតាំងនៅ ១ ជូរខណៈប៉ុណ្ណោះនៅមិនទាន់សព្វគ្រប់ នៅជាហេតុចូលទៅកាត់ភាពតជាប់គ្នាផង កាលកាន់យកសេចក្តីដោយប្រការក្រៅអំពីនេះ ការស្លាប់ ព្រោះអស់អាយុក៏មិនគួរយុត្តិបាន ។

# វិសុទ្ធិមគ្គ

## ហទយរូប

*ហទយវត្ថុ មានភាពជាទីអាស្រ័យនៃមនោធាតុ និងមនោវិញ្ញាណធាតុជាលក្ខណៈ មានការទទួលទ្រធាតុទាំងនោះទុកជារស មានការទ្រទ្រង់ធាតុទាំងពីរនោះជាបច្ចុប្បដ្ឋាន ។*

*ហទយវត្ថុនោះ អាស្រ័យលោហិតមានប្រការដូចពោលហើយ ក្នុងកាយគតាសតិកថា បានឧបការៈដែលភូតរូប ៤ ដែលមាននាទីគាំពារទុកជាដើមធ្វើឲ្យ ដែលឧតុ ចិត្ត និងអាហារឧបត្ថម្ភ អាយុឃ្លាំចិញ្ចឹមរក្សា ញុំាងភាពជាវត្ថុ ( ទីតាំង ) នៃមនោធាតុ និងមនោវិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តនឹងធាតុទាំង ២ នោះ ឲ្យសម្រេចតាំងនៅខាងក្នុងនៃបេះដូង ។*

# មហាដីកា

សួរថា ពាក្យថា ហទយវត្ថុមានភាពជាទីអាស្រ័យរបស់មនោធាតុ និងមនោវិញ្ញាណធាតុជាលក្ខណៈ នេះ គប្បីដឹងបានដូចម្តេច ? ឆ្លើយថា គប្បីដឹងបានដោយព្រះបាលីដែលជាទីមកដោយភាពត្រឹមត្រូវ ។ ព្រះបាលីដែលជាទីមក មានអាទិយ៉ាងនេះថា មនោធាតុ និងមនោវិញ្ញាណធាតុអាស្រ័យរូបណាប្រព្រឹត្តទៅ រូបនោះជាបច្ច័យដោយនិស្សយប្បច្ច័យដល់មនោធាតុ ដល់មនោវិញ្ញាណធាតុ និងធម៌ដែលសម្បយុត្តដោយធាតុទាំង ២ នោះ ។ សួរថា បើយ៉ាងនោះព្រោះហេតុអ្វី ទើបក្នុងរូបកណ្ឌ មិនបានត្រាស់ហទយវត្ថុរូបនោះទុក ? ឆ្លើយថា ដែលមិនបានត្រាស់ទុកក្នុងរូបកណ្ឌនោះ មានហេតុដទៃ ។ សួរថា ហេតុដទៃនោះ គឺអ្វី ? គឺការផ្សេងគ្នានៃទេសនា ។ ដូចជាចក្ខុវិញ្ញាណជាដើម មានចក្ខុជាដើមជាទីអាស្រ័យដោយចំណែកមួយ យ៉ាងណា មនោវិញ្ញាណធាតុមានហទយវត្ថុជាទីអាស្រ័យដោយចំណែកមួយដូច្នេះក៏ទេ ។ ទេសនាពោលដោយវត្ថុទុកៈជាដើម ប្រព្រឹត្តទៅដោយអំណាចនិស្សិតវោហារ ដោយន័យជាដើមថា រូបជាវត្ថុ ( ជាទីអាស្រ័យ ) របស់ចក្ខុវិញ្ញាណក៏មាន រូបមិនជាវត្ថុរបស់ចក្ខុវិញ្ញាណក៏មាន ។ សូម្បីកាលពោលដល់ទុកៈជាដើម ដោយន័យមានអាទិថា រូបជាវត្ថុរបស់មនោវិញ្ញាណក៏មាន ដោយអំណាចនៃមនោវិញ្ញាណដែលមានហទយវត្ថុជាទីអាស្រ័យដោយចំណែកមួយ ក៏រមែងនឹងមិនមានទុកៈទាំងឡាយមានអារម្មណទុកៈជាដើម ដែលមានគុណសមគួរដល់មនោវិញ្ញាណនោះ ។ ព្រោះមិនអាចពោលបានថា រូបជាអារម្មណ៍របស់មនោវិញ្ញាណក៏មាន រូបមិនជាអារម្មណ៍របស់មនោវិញ្ញាណក៏មាន ដូច្នោះ ទុកៈដែលកំណត់ដោយវត្ថុ និងអារម្មណ៍ នឹងគប្បីជាទុកៈមានគតិផ្សេងគ្នា ដូច្នោះ ទេសនាដែលមានរសតែមួយ ក៏នឹងមិនគប្បីមាន ។ ការ

សម្តែងទេសនាដែលមានរសតែមួយ ជាអធ្យាស្រ័យរបស់ព្រះសាស្តា ក្នុងអធិការនេះ ។ ព្រោះដូច្នោះ គប្បីឃើញថា មិនបានត្រាស់ហទយវត្ថុទុកក្នុងរូបកណ្ឌ ព្រោះមិនមានក៏ទេ ។

ចំណែកភាពត្រឹមត្រូវគប្បីជ្រាបយ៉ាងនេះ ធាតុទាំង ២ មានឧបាទាយរូប ( ហទយវត្ថុ ) ដែលជានិប្ផន្នរូបជាទីអាស្រ័យមាននៅក្នុងបញ្ចវោការភព ។ ក្នុងបញ្ចវោការភពនោះ អាយតនៈទាំងឡាយ មានរូបាយតនៈជាដើម និងឱជា ជាធម្មជាតិ មានឧបាទាយរូប ( ហទយវត្ថុ ) ដែលជានិប្ផន្នរូបនោះជាទីអាស្រ័យ គង់មិនត្រឹមត្រូវ ព្រោះសម្តែងដល់ការប្រព្រឹត្តទៅខាងក្រៅអំពីអាការដែលទាក់ទងដោយឥន្ទ្រិយ សូម្បីឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ មានឧបាទាយរូប ( ហទយវត្ថុ ) ដែលជានិប្ផន្នរូបនោះជាទីអាស្រ័យក៏មិនត្រឹមត្រូវ ព្រោះសម្តែងដល់ធាតុទាំង ២ មាននៅក្នុងសន្តាន សូម្បីវៀរចាកឥន្ទ្រិយទាំង ២ នោះ សូម្បីជីវិតិន្ទ្រិយ មានឧបាទាយរូប ( ហទយវត្ថុ ) ដែលជានិប្ផន្នរូបនោះជាទីអាស្រ័យ ក៏មិនត្រឹមត្រូវដូចគ្នា ព្រោះនៅមានកិច្ចដទៃ ព្រោះដូច្នោះ ពោលដោយបរិសេសន័យ ទើបហទយវត្ថុដឹងបានថា ជាទីអាស្រ័យរបស់មនោធាតុ និងមនោវិញ្ញាណធាតុ ទាំង ២ នោះ ។ ព្រោះអាចពោលដល់ធាតុទាំង ២ ដែលមានឧបាទាយរូប ( ហទយវត្ថុ ) ដែលជានិប្ផន្នរូបជាទីអាស្រ័យដោយការៈដែលមានការប្រព្រឹត្តទៅទាក់ទងដោយរូប ក្នុងបញ្ចវោការភព ។ ធម្មជាតិណាមួយ មានការប្រព្រឹត្តទៅទាក់ទងដោយរូប ធម្មជាតិនោះៗ ក៏ឃើញបានថា មានឧបាទាយរូប ( ហទយវត្ថុ ) ដែលជានិប្ផន្នរូបជាទីអាស្រ័យ ដូចពាក្យថា ចក្ខុវិញ្ញាណធាតុ ។ ចំណែកពាក្យដែលធ្វើឲ្យផ្សេងចេញទៅថា ក្នុងបញ្ច-វោការភព លោកប្រើដោយអំណាចមនោវិញ្ញាណធាតុ ។ មនោធាតុរមែងមិនមាននោះឯងក្នុងចតុវោការភព ។ សួរថា ព្រោះឲ្យសម្រេចជាឥន្ទ្រិយប្បច្ច័យ និងនិស្សយ-

ប្បច្ច័យ ក៏ត្រូវជាហេតុដែលខុសទៅមិនមែនឬ ? ឆ្លើយថា មិនមែនទេ ព្រោះមានភាពជំទាស់ដែលឃើញបាន ។ ឯការជំទាស់ដែលឃើញបាននេះ បានដល់ ការដែលធាតុទាំង ២ មិនធ្វើតាមកិច្ច មានទន់ និងរឹងជាដើមរបស់វត្ថុ ដូចចក្ខុវិញ្ញាណ ។ពិតយ៉ាងនោះ ទើបក្នុងព្រះបាលីលោកមិនបានត្រាស់ថា ធាតុទាំង ២ នោះជាឥន្ទ្រិយ-ប្បច្ច័យ រមែងជំទាស់ភាពជាឥន្ទ្រិយប្បច្ច័យ និងនិស្សយប្បច្ច័យ ពោល គឺការធ្វើតាមភាពទន់ និងភាពរឹងជាដើមនោះ ។ ទីអាស្រ័យរបស់ធាតុទាំង ២ បានដល់ ហទយវត្ថុ និងឧបាទាយរូបចូរលើកទុក ក៏ហទយវត្ថុនឹងដឹងបានដូចម្តេចថា មានកម្មជាសមុដ្ឋាន មានកិច្ចពិតប្រាកដដោយចំពោះតាំងនៅក្នុងហទយប្រទេសតែម្យ៉ាង ?ខ្ញុំនឹងឆ្លើយថា ហទយវត្ថុ ឈ្មោះថា **មានកម្មជាសមុដ្ឋាន** ព្រោះជាវត្ថុរូប ដូចចក្ខុ ឈ្មោះថា **មានកិច្ចពិតប្រាកដដោយចំពោះ** ព្រោះជាវត្ថុរូបនោះឯង ឯពាក្យថា ព្រោះភាពជាវត្ថុរូប មានន័យថា ព្រោះភាពជាទីអាស្រ័យរបស់វិញ្ញាណ ។ ហទយវត្ថុនេះឈ្មោះថា តាំងចុះក្នុងហទយវត្ថុប្បទេសនោះ ព្រោះកាលបុគ្គលគិតអ្វីមួយ ប្រមូលមកដោយចិត្តទាំងអស់ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត បេះដូងក៏នឹងនឿយលំបាក រមែងដឹងបានដូចពោលមកនេះ ។ ពាក្យថា **របស់ធាតុទាំង ២ នោះៗ ឯង** បានដល់ របស់មនោធាតុ និងមនោវិញ្ញាណធាតុនោះឯង ។ ឈ្មោះថា មានការនាំទៅជាបច្ចុប្បដ្ឋាន ព្រោះអត្ថថា រមែងប្រាកដដូចជាលើកដាក់ពីលើនាំទៅ ព្រោះភាពជាទីអាស្រ័យ ។ ពាក្យដ៏សេសបានពោលទុកហើយក្នុងខាងដើមនោះឯង ។

# វិសុទ្ធិមគ្គ

## វិញ្ញត្តិរូប ២

## កាយវិញ្ញត្តិ

ការផ្លាស់ប្តូរអាការ ដែលជាបច្ច័យនៃការប្រឹត្តកាយ ការទ្រទ្រង់កាយ និងការកម្រើកកាយ ដែលជាសហជរូបនៃវាយោធាតុ ដែលមានចិត្តញ៉ាំងកិរិយា មានការឈានជាដើមឲ្យប្រព្រឹត្តទៅជាសមុដ្ឋាន ឈ្មោះថា កាយវិញ្ញត្តិ ( កាយវិញ្ញត្តិនោះ ) មានការប្រកាសនូវបំណងជារស មានភាពជាហេតុនៃការកម្រើកកាយជាបច្ចុប្បដ្ឋាន មានវាយោធាតុដែលមានចិត្តជាសមុដ្ឋាន ជាបទដ្ឋាន ក៏កិរិយានេះ លោកហៅថា កាយវិញ្ញត្តិ ព្រោះជាហេតុឲ្យអ្នកដទៃដឹងនូវបំណង ដោយការកម្រើកកាយ និងព្រោះខ្លួនឯង ក៏គប្បីដឹងបានដោយកាយ ពោល គឺភាពកម្រើកកាយនោះផង ។ ឯកិរិយាទាំងឡាយ មានឈានទៅមុខ និងថយក្រោយជាដើម បណ្ឌិតគប្បីជ្រាបថា រមែងប្រព្រឹត្តទៅបានព្រោះការកម្រើកសូម្បីឧតុជរូបជាដើម ដែលសម្ពន្ធគ្នាដោយចំពោះនឹងចិត្តជរូបដែលកម្រើកព្រោះវិញ្ញត្តិនោះ ។

## វចីវិញ្ញត្តិ

ការផ្លាស់ប្តូរអាការ ដែលជាបច្ច័យនៃការប៉ះខ្ទប់គ្នានៃឧបាទិន្នករូប នៃបឋវីធាតុដែលមានចិត្តញ៉ាំងការបន្លឺវាចាឲ្យប្រព្រឹត្តទៅជាសមុដ្ឋាន ឈ្មោះថា វចីវិញ្ញត្តិ មានការប្រកាសនូវបំណងជារស មានភាពជាហេតុនៃការបន្លឺវាចាជាបច្ចុប្បដ្ឋាន មានបឋវីធាតុដែលមានចិត្តជាសមុដ្ឋាន ជាបទដ្ឋាន ។ កិរិយានេះលោកហៅថា វចីវិញ្ញត្តិ ព្រោះជាហេតុ

ឲ្យអ្នកដទៃដឹងនូវបំណងដោយការបន្លឺវាចា និងព្រោះខ្លួនឯង ក៏ដឹងបានដោយវាចាពោល គឺការបន្លឺវាចានោះ ។

ដូចជាបុគ្គលឃើញសញ្ញាសម្គាល់អណ្តូងទឹកមានរូបឈើ ដែលធ្វើជាក្បាលគោជាដើម ដែលគេលើកឡើងចងទុកត្រង់ចុងដងសម្រាប់យោងទឹក ក្នុងព្រៃក៏ដឹងបានថាទឹកមាននៅក្នុងទីនោះ យ៉ាងណា កាយវិញ្ញត្តិ និងវចីវិញ្ញត្តិ បុគ្គលសម្គាល់ការកម្រើកកាយ និងការបន្លឺវាចាបាន ក៏ដឹងបានដូច្នោះ ។

# មហាដីកា

ការឈានទៅខាងមុខជាដើមរបស់អាការណា អាការទាំងនោះ ឈ្មោះថា **អភិក្កមាទី** ប្រែថា មានការឈានទៅខាងមុខជាដើម ដោយ **អាទិ**-ស័ព្ទលោកកំណត់កាន់យកកិរិយាទាំងអស់ មានការថយក្រោយ ការបត់ចូល ការលាតចេញ ការលើកឡើង និងការដាក់ចុះជាដើម ។ ចិត្តដែលញុំាងអាការមានការឈានទៅខាងមុខជាដើមទាំងនោះឲ្យប្រព្រឹត្តទៅជាសមុដ្ឋានរបស់ធាតុណា ធាតុនោះឈ្មោះថា **ចិត្តដែលញុំាងអាការ មានការឈានទៅមុខជាដើមឲ្យប្រព្រឹត្តទៅជាសមុដ្ឋាន** បានដល់ វាយោធាតុ លោកអាចារ្យកាលសម្តែងថា វាយោធាតុនោះមាននាទី គឺការឧបត្ថម្ភ ការទ្រទ្រង់ និងការកម្រើករបស់រូបកាយដែលកើតរួមគ្នាឯណា ភាពផ្សេងនៃអាការ ដែលជាហេតុធ្វើរួមគ្នារបស់កិច្ចនោះ ឈ្មោះថា កាយវិញ្ញត្តិ ទើបពោលថា **ភាពផ្សេងនៃអាការ ដែលជាបច្ច័យដល់ការឧបត្ថម្ភ ការទ្រទ្រង់ទុក និងការកម្រើកញ័ររបស់រូបកាយ ដែលកើតរួមគ្នានៃវាយោធាតុដែលមានចិត្តអាចញុំាងអាការ មានការឈានទៅខាងមុខជាដើមឲ្យប្រព្រឹត្តទៅជាសមុដ្ឋាន ឈ្មោះថា កាយវិញ្ញត្តិ** ដូច្នេះ ។

សួរថា ការផ្លាស់ប្តូរអាការរបស់អ្នកណា ? ឆ្លើយថា របស់មហាភូតរូប ដែលកើតអំពីចិត្ត ដែលច្រើនទៅដោយវាយោធាតុ ដោយការអាច ។ ការអាចនោះ បានដល់អ្វី ? បានដល់ ភាពជាធម្មជាតិកើតអំពីចិត្ត និងភាពជាឧបាទាយរូប ។ ម្យ៉ាងទៀត គប្បីភ្ជាប់សេចក្តីថា ការផ្លាស់ប្តូរអាការរបស់វាយោធាតុដែលជាបច្ច័យ ដល់ការឧបត្ថម្ភ ការទ្រទ្រង់ទុក និងការកម្រើករូបដែលកើតរួមគ្នា ។ បើយ៉ាងនោះ ភាពដែលវិញ្ញត្តិ ជាឧបាទាយរូបក៏មិនត្រូវ ។ ព្រោះឧបាទាយរូបមានភូតរូបតែម្យ៉ាង ជាទីអាស្រ័យ មានក៏ទេ ។ ប្រការនេះសមដូចព្រះបាលីដែលត្រាស់ទុកថា **ចតុន្នំ មហាភូតានំ ឧបាទាយ**

រូបំ ប្រែថា រូបអាស្រ័យមហាភូតរូបទាំង ៤ ដូច្នេះ សេចក្ដីនេះមិនខុសទេ ការប្រែប្រួលរបស់មហាភូតរូបទាំង ៤ រមែងមានដល់មហាភូតរូប ១ ក្នុងបណ្ដាមហាភូតរូបទាំង ៤ ដូចទ្រព្យដែលមានទូទៅដល់បុគ្គល ៤ នាក់ ។ ព្រោះភាពដែលកលាបៈ ជាធម្មជាតិច្រើនទៅដោយវាយោធាតុ ពាក្យថា **វាយោធាតុយា** ទើបមិនខុស ។ ភាពជាធម្មជាតិច្រើនទៅយ៉ាងនេះ ក៏ដោយភាពអាច មិនមែនដោយប្រមាណ ។ កាលកាន់យកអត្ថដោយប្រការដទៃ ភាពជាធម្មជាតិ មានការប្រព្រឹត្តទៅដោយការមិនញែកគ្នា មិនគួរនឹងត្រឹមត្រូវ ។ អាចារ្យពួកខ្លះពោលថា **វាយោធាតុយា ឯវ** ។ តាមមតិរបស់អាចារ្យពួកនោះ ភាពដែលវិញ្ញត្តិជាឧបាទាយរូប ជាកិរិយាដែលកើតឡើង បានដោយលំបាក ។ ព្រោះការផ្លាស់ប្ដូររបស់មហាភូតរូបតែមួយ នឹងមានដល់មហាភូតរូប ទាំង ៤ ក៏មានមិនបាន ។ វិញ្ញត្តិនេះរមែងកាន់យកបានដោយជវនតាមមនោទ្វារ ក្នុងលំដាប់ការទទួលវណ្ណៈដែលកំពុងកម្រើក សឹងដឹងបានដោយការកម្រើកដៃជាដើម ។ នឹងមានការផ្លាស់ប្ដូរអ្វី ដែលផុតអំពីវណ្ណៈដែលកំពុងកម្រើកនោះ ។ សួរថា ពាក្យថា ការកាន់យកភាពផ្លាស់ប្ដូរនោះ មាននៅក្នុងលំដាប់ការកាន់យកវណ្ណៈដែលកំពុងកម្រើកនោះ នេះនឹងដឹងបានដូចម្ដេច ? ឆ្លើយថា ដឹងបានដោយការចាប់យកបំណង ។ ព្រោះក្នុងកាលដើមឈើជាដើមកម្រើក ដែលវៀរចាកការផ្លាស់ប្ដូររបស់វិញ្ញត្តិ ក៏នឹងមិនឃើញការកាន់យកបំណងថា ដើមឈើនេះ ប្រហែលជាឲ្យធ្វើវត្ថុនេះ ។ តែក្នុងការកម្រើកដៃជាដើមឃើញបាន ។ ព្រោះហេតុនោះ នឹងមានការផ្លាស់ប្ដូរអ្វីដែលផុតទៅអំពីវណ្ណៈ ដែលកំពុងកម្រើក រមែងឲ្យយល់បានថា ឲ្យដឹងបំណង ។ ឯហេតុដែលឲ្យដឹងការយកដោយខ្លួនឯងហើយនោះឯង រមែងឲ្យដឹងអត្ថដែលគប្បីឲ្យដឹង មិនមែនដោយត្រឹមតែភាវៈដែលមាននោះទេ ព្រោះដូច្នោះ សូម្បីការកាន់យកភាពផ្លាស់ទីក្នុង លំដាប់នៃការកាន់យកវណ្ណៈ រមែងឲ្យដឹងបានដោយអនុមាន។សមដូចបុរាណាចារ្យ ទាំងឡាយពោលទុកថា

សំឡេងទាំងឡាយ ដែលមិនទាន់ដល់នូវភាពជាអារម្មណ៍ មិនធ្វើឲ្យដឹងន័យបាន ឡើយ សត្វទាំងឡាយមិនយល់ន័យ ដោយប្រមាណអត្ថទាំងនោះ ដែលជាក់ច្បាស់ ទើបសត្វទាំងឡាយយល់បានសព្វគ្រប់ ។

សួរថា បើការកាន់យកការផ្លាស់ប្តូរប៉ុណ្ណោះ ជាហេតុនៃការកាន់យកនូវបំណង សោត ហេតុអ្វី ទើបការកាន់យកនូវបំណងមិនមានដល់បុគ្គលដែលប្រកាន់យកការ កំណត់មិនបានទៅវិញ ? ឆ្លើយថា គប្បីឃើញថា ការកាន់យកការផ្លាស់ប្តូរតែម្យ៉ាង ជាហេតុនៃការកាន់យកបំណងមិនទាន់សព្វគ្រប់ ដែលពិតនោះ ការកាន់យកដែល សម្រេចដំបូង និងដែលសម្ពន្ធគ្នា ជាឧបនិស្ស័យនៃការកាន់យកនូវបំណងនេះ ។ លោក ពោលការគាំពារការទ្រទ្រង់ទុក ការកម្រើកបានដល់វាយោធាតុ ដែលប្រកបដោយ ការផ្លាស់ប្តូរនៃវិញ្ញត្តិ ។ សួរថា វាយោធាតុទាំងអស់ធ្វើកិច្ចទាំងអស់នោះឬ ? សេចក្តី នេះមិនគួរឃើញយ៉ាងនោះ ព្រោះវាយោធាតុដែលកើតពីជវនទី ៧ បានវាយោធាតុ ដែលកើតអំពីជវនដំបូងៗ ជាឧបត្ថម្ភកប្បច្ច័យ រមែងញ៉ាំងចិត្តជរូបឲ្យកម្រើក ដោយ ភាវៈដែលជាហេតុកើតឡើងក្នុងចំណែកដទៃ ធាតុក្រៅអំពីនេះមិនដូច្នោះឡើយ ចំណែក ធាតុក្រៅអំពីនេះ កាលធ្វើត្រឹមតែការឧបត្ថម្ភ និងការទ្រទ្រង់ទុក រមែងមានដើម្បី ឧបការៈដល់វាយោធាតុនោះ ការកើតក្នុងចំណែកដទៃនោះឯងជាការកម្រើក ព្រោះ ដូច្នោះ គប្បីឃើញថា លោកលើកភាពជាកត្តុការកៈទុកក្នុងនិមិត្ត ។ កាលកាន់យក សេចក្តីដោយប្រការដទៃ ភាវៈដែលធម៌ទាំងឡាយ មិនមានភាពក្រវល់ក្រវាយ ខ្នះខ្នែង និងប្រព្រឹត្តទៅមួយជួរខណៈ ក៏នឹងមិនគប្បីមាន ។ក្នុងរឿងនេះលោកលើកយករទេះ ដែលអូសមកដោយគោ ៧ នឹម ជាតួយ៉ាងទុកក្នុងអដ្ឋកថា ។ កាលចិត្តជរូបកម្រើក សូម្បីឧតុជរូប កម្មជរូប និងអាហារជរូប ក៏រមែងកម្រើក ព្រោះជាធម្មជាតិដែលទាក់ ទងគ្នា នឹងចិត្តជរូបនោះ ប្រៀបដូចដុំអាចម៍គោស្ងួត ដែលចាក់ចុះទៅក្នុងខ្សែទឹក ព្រោះ

សព្ទថា វិញ្ញត្តិ លោកពោលទុកក្នុងលំដាប់របស់សព្ទថា វណ្ណៈដែលកំពុងកម្រើក ។ សួរថា វាយោធាតុ ដែលធ្វើភាពញ៉ាំងកម្រើកនោះឯង ប្រកបដោយភាពផ្លាស់ប្តូរទីនៃវិញ្ញត្តិឬ ? ឆ្លើយថា សេចក្តីនេះមិនគួរឃើញយ៉ាងនោះ គប្បីកាន់យកថា វាយោធាតុទាំងឡាយមិនអាច នឹងឲ្យកម្រើកបានយ៉ាងនោះ ធ្វើត្រឹមតែការឧបត្ថម្ភគាំទ្រ ការទ្រទ្រង់ទុក ដែលកើតអំពីជវនទី ១ ជាដើម ប្រកបដោយភាពផ្លាស់ប្តូរទីនៃវិញ្ញត្តិប៉ុណ្ណោះ ការរំកិលនេះនឹងញ៉ាំងអាការ មានការឈានទៅមុខជាដើមឲ្យប្រព្រឹត្តទៅដោយចំណែកនៃទិសណា ព្រោះមានភាពផ្លាស់ប្តូរ ដែលឆ្ពោះមុខចំពោះចំណែកនៃទិសនោះ ។ ដោយការផ្លាស់ប្តូរ ដែលមានព្រមជាមួយនឹងបំណង ទើបជាវិញ្ញត្តិ ។ ព្រោះអធិប្បាយយ៉ាងនេះការពោលថា មនោទ្វារាវជ្ជនៈញ៉ាំងវិញ្ញត្តិឲ្យតាំងឡើង រមែងត្រឹមត្រូវដោយល្អ ។បំណងរបស់បុគ្គលដែលមានសេចក្តីព្រមព្រៀងដោយវិញ្ញត្តិនោះរមែងដឹងបានដោយការកាន់យកភាពផ្លាស់ប្តូរ តាមដែលពោលហើយជាសំខាន់ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **កាយវិញ្ញត្តិមានការប្រកាសបំណងជារស** ។

ព្រោះវាយោធាតុ ដែលជាហេតុនៃការកម្រើកកាយជាការផ្លាស់ប្តូរ ទើបវិញ្ញត្តិលោកពោលថា **មានភាពជាហេតុនៃការកម្រើកកាយ ជាបច្ចុប្បដ្ឋាន** ដោយបរិយាយ ។ លោកពោលថា **មានវាយោធាតុដែលមានចិត្តជាសមុដ្ឋានជាបទដ្ឋាន** ព្រោះវាយោធាតុជាធាតុដែលច្រើនទៅដោយកិច្ច ។ ពាក្យថា **ព្រោះជាហេតុឲ្យដឹងនូវបំណង ដោយការកម្រើកកាយ** ភ្ជាប់សេចក្តីថា កិរិយានេះហៅថា កាយវិញ្ញត្តិ ព្រោះភាពជាហេតុឲ្យដឹងបំណង ដោយការកម្រើកកាយដែលជាតួធ្វើ ។ ក្នុងអធិការនេះ មានអត្ថដូច្នេះ ។

ឈ្មោះថា វិញ្ញត្តិ ដោយអត្ថថា ឲ្យដឹង ។ ឲ្យដឹងអ្វី ? ឲ្យដឹងបំណង ។ ដោយអ្វី ? ដោយកាយ ។ ដោយកាយដូចម្តេច ? ដោយកាយដែលកំពុងកម្រើក ដូច្នេះ ។ ចំណែកក្នុងន័យទី ២ សេចក្តីថា ឈ្មោះថា **កាយវិញ្ញត្តិ** ដោយអត្ថថា ដឹងបានដោយកាយ

តាមដែលពោលហើយ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

សេចក្តីផ្សេងគ្នារបស់វាចា ដែលអាចឲ្យយល់អត្ថ ឈ្មោះថា **វចីភេទ** ។ ដោយវចីភេទនោះ រមែងហាមសំឡេងព្យុះ សំឡេងរបស់ដើមឈើ ម្ចាស់ព្រៃ ( ម្ចាស់ព្រៃ វចនានុក្រមដាក់ថា មានខ្លាជាដើម តែក្នុងទីនេះគួរដាក់ថា សំឡេងខ្យល់ ក្នុងព្រៃក៏គួរ ព្រោះមិនមែនវចីភេទ ) និងសំឡេងស្ទឹងជាដើម ។ ចិត្តដែលញុំាងវចីភេទនោះ ឲ្យប្រព្រឹត្តទៅជាសមុដ្ឋានរបស់ធាតុណា ធាតុនោះឈ្មោះថា **មានចិត្ត ដែលញុំាងវចីភេទឲ្យប្រព្រឹត្តទៅជាសមុដ្ឋាន** បានដល់ បឋវីធាតុ ។ លោកអាចារ្យ កាលនឹងសម្តែងថា បឋវីធាតុនោះមានកិច្ចដែលយើងដឹងថា ជាការប៉ះខ្ទប់ ឋាន:ជាទីកើតរបស់អក្ខរ: ពោល គឺឧបាទិន្នករូបណា ភាពផ្សេងនៃអាការដែលជាហេតុផ្ទើរមគ្នារបស់កិច្ចនោះ ឈ្មោះថា វចីវិញ្ញត្តិ ទើបពោលថា **ការផ្លាស់ប្តូរនៃអាការ ដែលជាបច្ច័យ នៃការប៉ះខ្ទប់របស់ឧបាទិន្នករូបនៃបឋវីធាតុដែលមានចិត្ត ញុំាងវចីភេទឲ្យប្រព្រឹត្តទៅ ជាសមុដ្ឋាន ឈ្មោះថា វចីវិញ្ញត្តិ** ដូច្នេះ ។

គ្រានេះ ពាក្យថា ភាពផ្លាស់ប្តូរអាការរបស់នរណា ដូច្នេះជាដើម គប្បីជ្រាបតាមន័យដែលបានពោលទុកហើយក្នុងកាយវិញ្ញត្តិនោះឯង ។ ចំណែកសេចក្តីផ្សេងគ្នាមានដូច្នេះ ក្នុងកាយវិញ្ញត្តិនោះ លោកអាចារ្យពោលទុកក្នុងលំដាប់នៃការកាន់យកវណ្ណ:ដែលកំពុងកម្រើក យ៉ាងណា ក្នុងវចីវិញ្ញត្តិនេះក៏គប្បីប្រកបថា ក្នុងលំដាប់នៃការស្តាប់សំឡេងដែលបានឮ ដូច្នោះ ។ ក្នុងវចីវិញ្ញត្តិនេះ ព្រោះមិនមាននាទី មានការគាំទ្រជាដើម ទើបមិនបានន័យថា កើតអំពីជវនទី ៧ ជាដើម ។ សំឡេងរមែងកើតព្រមនឹងការប៉ះខ្ទប់ ហើយការប៉ះខ្ទប់ក៏រមែងបានក្នុងជវនទី ១ ជាដើមនោះឯង **ការប៉ះខ្ទប់** បានដល់ ការដែលកលាប:របស់ភូតរូបទាំងឡាយកើតឡើងជិតគ្នានឹងគ្នា ដោយអំណាចជាបច្ច័យ ។ **ការកម្រើក** បានដល់ ការ:ដែលកលាប:របស់ភូតរូប តែមួយកើតឡើងតៗ គ្នាទៅក្នុង

ចំណែកដទៃ ដែលពោលមកនេះ ជាភាពផ្សេងគ្នានៃការប៉ះខ្ទប់ និងការកម្រើកទាំងនេះ ។ ឯការកម្រើកជាកិច្ចរបស់វាយោធាតុ យ៉ាងណា ការប៉ះខ្ទប់ក៏ជាកិច្ចរបស់បឋវីធាតុ ក៏យ៉ាងនោះ ។ ដោយហេតុនោះឯង ទើបលោកអាចារ្យពោលថា **ជាបច្ច័យនៃការប៉ះខ្ទប់ឧបាទិន្នករូបរបស់បឋវីធាតុ** ។ ពាក្យដ៏សេសមានន័យដូចដែលពោលហើយនោះឯង ។ ពាក្យថា ដូចជា... យ៉ាងណាជាដើម ជាពាក្យអធិប្បាយដល់ការៈដែលកាយវិញ្ញត្តិ និងវចីវិញ្ញត្តិ ដែលគប្បីកាន់យកបាន ទាក់ទងនឹងការអនុមានយក ។ ដូចជាការដែលបានឃើញ **រូប មានក្បាលគោជាដើម ដែលលើកឡើងចងទុក** ក៏នឹងកាន់យកការដែលរូបក្បាលគោជាដើមថា ជានិមិត្ត សញ្ញាបង្ហាញដល់វិធីដែលមានទឹកដោយមនោទ្វារវីថិ ដែលកើតឡើងមួយរំពេចនោះ ទាំងដែលនៅមិនទាន់ដឹង ក៏យកទឹកមកបាន យ៉ាងណា ការដែលកំណត់រូបដែលកំពុងកម្រើក និងសំឡេងដែលកំពុងបន្លឺក៏យ៉ាងនោះ ក៏នឹងកាន់យកការផ្លាស់ប្តូរ ដែលមានបំណងដោយមនោទ្វារវីថិ ដែលកើតឡើងក្នុងរំពេចនោះ ទាំងដែលមិនទាន់ដឹង ដែលប្រកបដោយឧបនិស្សយប្បច្ច័យនៃការកាន់យកដែលសម្រេច និងទាក់ទងគ្នាអំពីកាលមុន រមែងមានបាន ។

# វិសុទ្ធិមគ្គ

## បរិច្ឆេទរូប ១

*អាកាសធាតុ មានការឃាំងផ្ដាច់នូវរូបជាលក្ខណៈ មានការប្រកាសទីបំផុតរបស់រូបជារស មានព្រំរបស់រូបជាបច្ចុប្បដ្ឋាន ឬថា មានភាពដែលមិនត្រូវក្ងូតរូបប៉ះពាល់ និងភាពជាប្រហោង ជារន្ធ ជាបច្ចុប្បដ្ឋាន មានរូបដែលត្រូវកាត់ផ្ដាច់ហើយជាបទដ្ឋាន ។ ក្នុងរូបទាំងឡាយដែលត្រូវអាកាសធាតុណាកាត់ផ្ដាច់ហើយ រមែងមានការកំណត់បានថា រូបនេះ នេះលើ នេះក្រោម នេះទទឹង ( ខាងៗ ) ។*

# មហាដីកា

សភាវៈដែលកាត់ផ្ដាច់រូបទាំងឡាយ ឈ្មោះថា បរិច្ឆេទរូប ម្យ៉ាងទៀត ខ្លួនឯងត្រូវរូបទាំងនោះកាត់ផ្ដាច់ទៅ ឈ្មោះថា រូបបរិច្ឆេទ ន័យម្យ៉ាងទៀត គ្រាន់តែជាការកាត់ផ្ដាច់នូវរូបទាំងឡាយ ឈ្មោះថា រូបបរិច្ឆេទ អាកាសធាតុ ឈ្មោះថា **រូបបរិច្ឆេទ-លក្ខណា** ដោយអត្ថថា អាកាសធាតុនេះមានលក្ខណៈដែលកាត់ផ្ដាច់រូបម្យ៉ាង មានលក្ខណៈដែលខ្លួនឯងត្រូវរូបកាត់ផ្ដាច់ម្យ៉ាង មានលក្ខណៈត្រឹមតែជាការកាត់ផ្ដាច់រូបម្យ៉ាងនោះ ។ ពិតណាស អាកាសធាតុនេះរមែងដូចជាកំពុងកាត់ផ្ដាច់នូវរូបកលាបៈនោះ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **មានការប្រកាសទីបំផុតជុំវិញរបស់រូបជារស** ។ តែដោយអត្ថ លោកអាចារ្យពោលថា **មានព្រំដែនរបស់រូបជាបច្ចុប្បដ្ឋាន** ដូច្នេះ ព្រោះលោកកាន់យកត្រឹមតែការកាត់ផ្ដាច់រូបទាំងឡាយ ។ ក្នុងកលាបៈណាមានការកាត់ផ្ដាច់ភូតរូបទាំងឡាយ កលាបៈនោះឈ្មោះថា អាកាសធាតុមានសភាវៈដែលភូតរូបទាំងនោះឯង **មិនពាល់ត្រូវជាបច្ចុប្បដ្ឋាន** ។ ពិតណាស់ កាលភាវៈដែលភូតរូបក្នុងកលាបៈដទៃត្រូវភូតរូបក្នុងកលាបៈដទៃ ពាល់ត្រូវមានភាវៈ ដែលទទេរបស់ភូតរូបនោះៗ គឺទីបំផុតជុំវិញរបស់រូប ឈ្មោះថា អាកាស ព្រោះដូច្នោះការកាត់ផ្ដាច់រូបនោះរបស់ភូតរូបពួកណា ការកាត់ផ្ដាច់នោះ ដែលភូតរូបទាំងនោះមិនពាល់ត្រូវនោះឯង ។ កាលកាន់យកដោយប្រការដទៃ ភាវៈដែលកាត់ផ្ដាច់ទៅ ក៏នឹងមិនគប្បីមាន ព្រោះភូតរូបទាំងនោះដល់នូវភាវៈដែលជ្រួតជ្រាបទៅ ។ ភាវៈដែលមិនជ្រួតជ្រាបទៅ ជាភាវៈដែលមិនត្រូវភូតរូបពាល់ត្រូវ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគ

តាស់ថា រូបដែលមហាភូតរូប ៤ មិនពាល់ត្រូវ ៗ **និងនៅមានភាវៈ** ដែលជាប្រហោង **ជារន្ធ ជាបច្ចុប្បដ្ឋានក៏បាន** ដូចជាប្រហោងត្រចៀក ប្រហោងមាត់ជាដើម ។ រូបពួកណាមានការកាត់ផ្តាច់ លោកក៏រមែងបានដោយភាវៈដែលជាការកាត់ផ្តាច់របស់រូបទាំងនោះក្នុងអាកាសធាតុនោះៗ ឯង ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **មានរូបដែលត្រូវកាត់ផ្តាច់ជាបទដ្ឋាន** ។ ដោយពាក្យថា **ក្នុងបណ្តារូបដែលត្រូវអាកាសធាតុណាកាត់ផ្តាច់ហើយ** ជាដើម លោកអាចារ្យរមែងសម្តែងដល់ភាព ដែលអាកាសធាតុជាហេតុមិនប្រឡូំលាយឡូំគ្នារបស់កលាបៈនោះៗ នឹងកលាបៈដទៃ ។

# វិសុទ្ធិមគ្គ

## វិការរូប ៣

*លហុតា* ( *ភាពស្រាល* ) នៃរូប មានការមិនខ្ជិលច្រអូសជាលក្ខណៈ មានការបន្ទោបង់នូវភាពធ្ងន់នៃរូបទាំងឡាយជារស មានការប្តូរឥរិយាបថបានរហ័សជាបច្ចុប្បដ្ឋាន មានរូបដែលស្រាលជាបទដ្ឋាន ។

*មុទុតា* ( *ភាពទន់* ) នៃរូប មានការមិនរឹងជាលក្ខណៈ មានការបន្ទោបង់នូវភាពរឹងគ្រោតគ្រាតនៃរូបទាំងឡាយជារស មានការមិនជំទាស់ក្នុងកិរិយាទាំងពួងជាបច្ចុប្បដ្ឋាន មានរូបដែលទន់ជាបទដ្ឋាន ។

*កម្មញ្ញតា* ( *ភាពគួរដល់ការងារ* ) នៃរូប មានការស្ទាត់ជំនាញ ដែលអនុកូលដល់កិរិយាផ្អែករាងកាយជាលក្ខណៈ មានការបន្ទោបង់នូវភាពមិនស្ទាត់ជំនាញជារស មានការមិនទុព្វលភាពជាបច្ចុប្បដ្ឋាន មានរូបដែលប្រើការបាន ជាបទដ្ឋាន ។

*វិការតា* ( *ភាពដែលរូបមានអាការផ្សេងអំពីរូបរបស់បុគ្គលស្ងាប់* ) ៣ នេះ រមែងមិនលះបង់គ្នានឹងគ្នា សូម្បីកាលបើដូច្នោះ ការប្លែកគ្នានៃវិការតា ៣ នោះ ក៏គប្បីជ្រាបបានដូច្នេះ គឺ

វិការរូបណា ជាភាពស្រាលនៃរូបទាំងឡាយ ដូចរូបរបស់អ្នកមិនមានរោគ មានការមិនខ្ជិលច្រអូស និងការប្តូរឥរិយាបថបានរហ័ស ជាអាការទូទៅ មានបច្ច័យដែលជាចំណែកទប់ទល់នូវការកម្រើកនៃធាតុ ដែលធ្វើឲ្យរូបធ្ងន់ជាសមុដ្ឋាន រូបវិការរូបនោះចាត់ជារូបស្សលហុតា ( ភាពស្រាលនៃរូប ) ។

វិការរូបណា ជាការទន់នៃរូបទាំងឡាយ ដូចស្បែកសត្វដែលខាត់ល្អហើយ មានការទន់ដោយទីបង្គាប់បានក្នុងកិរិយាទាំងពួងប្លែកៗ គ្នា ជាអាការទូទៅ មានបច្ច័យដែលជាចំណែកប្រឆាំងនូវការកម្រើកនៃធាតុដែលធ្វើឲ្យរូបរឹង ជាសមុដ្ឋាន វិការរូបនោះចាត់ជារូបស្សមុទុតា ( ភាពទន់នៃរូប ) ។

ចំណែកវិការរូបណា ជាភាពប្រើការបាននៃរូបទាំងឡាយ ដូចមាសដែលរំលាយល្អហើយ មានការអនុកូលដល់កិរិយាផ្នែករាងកាយ ជាអាការទូទៅ មានបច្ច័យ ដែលជាចំណែកទប់ទល់ការកម្រើកនៃធាតុ ដែលធ្វើការមិនអនុកូលដល់កិរិយាផ្នែករាងកាយ ជាសមុដ្ឋាន វិការរូបនោះ ចាត់ជារូបស្សកម្មញ្ញតា ( ភាពគួរដល់ការងារនៃរូប ) ។

# មហាដីកា

*ពាក្យថា **ការមិនខ្ជិលច្រអូស** គឺការមិនធ្ងន់ ។ **ការបន្ទោបង់** គឺការកម្ចាត់ទៅ អធិប្បាយថា ការនាំទៅប្រាស ។ ពាក្យថា **ការមិនរឹង** បានដល់ ការមិនរឹង ។ **ការមិនជំទាស់** ក្នុងកិរិយាគ្រប់យ៉ាង ក៏ដោយការៈដែលខ្វះនូវរូបទន់នោះឯង ។ ពិតណាស់ រូបដែលទន់ រមែងមិនទាស់ក្នុងទីណាៗ ។ អាចារ្យពួកខ្លះពោលថា **អ**-អក្ខរៈក្នុងឋានៈទាំង ៣ កន្លែង ប្រព្រឹត្តទៅក្នុងអត្ថថា ជាបដិបក្ខ ព្រោះភាពដែលរូបទាំងឡាយ មានលហុតារូបជាដើម ជាធម្មជាតិមានភាពជាបដិបក្ខចំពោះហេតុ មានភាពជារូបច្រអូស ( យឺតយ៉ាវ ) ជាដើម ជាសមុដ្ឋាន ។ ចំណែកអាចារ្យមួយពួកទៀតពោលថា **អ** អក្ខរៈប្រព្រឹត្តទៅក្នុងអត្ថថា មិនបដិសេធសត្វ ។ ការៈ គឺការគួរដល់ការងារ ពោល គឺការសមគួរដល់កិរិយាដែលរាងកាយនឹងគប្បីធ្វើជាលក្ខណៈរបស់កម្មញ្ញតារូបនេះ ហេតុនោះ កម្មញ្ញតារូបនេះឈ្មោះថា **មានការៈ គឺភាពគួរដល់ការងារដែលសមគួរដល់កិរិយាផ្អែករាងកាយជាលក្ខណៈ** ។ ភាពមិនគួរដល់ការងារឈ្មោះថា ជាភាពទុព្វល ហេតុនោះ ទើបកម្មញ្ញតារូប លោកពោលថា **មានភាពជារូបមិនទុព្វលជាបច្ចុប្បដ្ឋាន** ។*

*លោកពោលការៈដែលមានវិការរូបទាំងឡាយ មានលហុតារូបជាដើម ជារូបដែលមានភាពផ្សេងគ្នា ដែលគប្បីដឹងបានដោយលំបាក ព្រោះការមិនលះបង់នូវគ្នានឹងគ្នា ហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា **កាលបើយ៉ាងនេះ** ដូច្នេះ ដើម្បីនឹងប្រកាសភាពផ្សេងគ្នារបស់វិការរូបទាំង ៣ នោះ ដោយរូបដែលក្រៃលែងដោយវិការនោះៗ ។ ការកម្រើកនៃធាតុ បានដល់ ការកម្រើកនៃខ្យល់ ប្រមាត់ និងស្លេស្ម ឬបានដល់កិរិយាដែលតាំងចុះនៃភាពផ្លាស់ប្តូររបស់ធាតុ មានរសធាតុជាដើម ។ ការកម្រើកនៃធាតុ ពោលទុកជា ២ យ៉ាង ដោយអត្ថ គប្បីឃើញថា ជាភាពវិការនៃធាតុ*

ទាំងឡាយ មានបឋវីធាតុជាដើមនោះឯង ។ បច្ច័យដែលជាចំណែកទប់ទល់ទាំងឡាយ បានដល់ ឧតុដែលជាទីសប្បាយ អាហារដែលជាទីសប្បាយ ភាពជាបុគ្គលមានចិត្តរាយមាយ ។បច្ច័យដែលជាចំណែកទប់ទល់ទាំងនោះ លោកពោលទុក ព្រោះជាបច្ច័យដែលផ្សេងគ្នារបស់ការផ្លាស់ប្តូរនោះៗ តែដោយមិនផ្សេងគ្នាគ្រប់យ៉ាងជាបច្ច័យរបស់គ្រប់យ៉ាង ។ ព្រោះវិការរូបទាំងនោះមិនលះបង់នូវគ្នានឹងគ្នា ប្រការរបស់ភាពទន់ ដូចជាបញ្ញាបានក្នុងឫទ្ធិជាដើម ស័ព្ទថា ស្បែក ដែលសម្ងាប់ល្អហើយ និងមាសដែលដេញមន្ទិលល្អហើយក្នុងទីនេះ ត្រឹមតែជានិទស្សនៈរបស់រូប ដែលដូចគ្នានឹងរូបដែលទន់និងរូប ដែលប្រើការបាន ក្នុងទីនេះមិនបានបំណងយកស័ព្ទថា ស្បែក ឬមាសនោះទេ ព្រោះមានភាវៈដែលជារូបទន់ និងជារូប ដែលប្រើការបាន ។

លហុតារូបជាដើម រមែងកើតក្នុងសន្តានដែលមិនទាក់ទងដោយឥន្ទ្រិយក៏ទេ ក្នុងរូបភពដែលទាក់ទង ដោយឥន្ទ្រិយក៏មិនមាន ព្រោះមិនមានការកម្រើកនៃធាតុដែលធ្វើភាពយឺតយ៉ាវជាដើម ។ អាចារ្យពួកខ្លះពោលថា កាលកម្រើកនៃធាតុដូច្នោះមានលហុតារូបជាដើម ដែលមានបច្ច័យតទល់នូវការកម្រើកនៃធាតុនោះជាសមុដ្ឋាន ក៏នឹងគប្បីមានពាក្យរបស់អាចារ្យពួកខ្លះនោះមិនមានហេតុ ។ ព្រោះថា ការកើតឡើងនៃធម៌ដែលជាបដិបក្ខ ចំពោះការកម្រើកនៃធាតុនោះ សំដៅដល់ធម៌ដែលជាសត្រូវដែលគប្បីឲ្យចូលទៅស្ងប់ក៏ទេ កាលបើដូច្នោះ ភាពមិនមាននៃការស្រោលកាយជាដើមនោះ ក៏នឹងគប្បីមាននៅក្នុងចិត្តុប្បាទដែលជាកិរិយាសហេតុកៈ ។ សួរថា លហុតារូបជាដើម មិនមាននៅក្នុងកម្មជរូបទាំងឡាយ ព្រោះហេតុអ្វី ព្រោះសំដៅដល់បច្ច័យដែលជាបច្ចុប្បន្ន ។ កាលកាន់យកអត្ថដោយប្រការដទៃក៏ប្រពៃ ដែលគប្បីមានលហុតារូបជាដើម ដែលមាននៅសព្វកាល ដូច្នេះឯង ។

# វិសុទ្ធិមគ្គ

## លក្ខណរូប ៤

**ឧបចយ** ( ភាពចម្រើន ) នៃរូប មានភាពចម្រើនឡើងជាលក្ខណៈ មានការញ៉ាំងរូបទាំងឡាយឲ្យផុសឡើង គឺធំឡើងទៅខាងមុខជារស មានការប្រគល់ឲ្យ គឺដូចជាអញ្ជើញឲ្យកាន់យកជាបច្ចុប្បដ្ឋាន ឬថា មានភាពជារូបបរិបូណ៌ជាបច្ចុប្បដ្ឋាន មានរូបដែលធំហើយជាបទដ្ឋាន ។

**សន្តតិ** ( ការបន្ត ) នៃរូប មានការប្រព្រឹត្តទៅជាលក្ខណៈ មានការបន្តទុកជារស មានការមិនដាច់ខ្សែជាបច្ចុប្បដ្ឋាន មានរូបដែលបន្តគ្នាមកបានជាបទដ្ឋាន ។

រូបទាំង ២នេះក៏ជាឈ្មោះនៃជាតរូបទាំងអស់ប៉ុណ្ណោះឯង តែការសម្តែងឧទ្ទេស លោកធ្វើជា ២ ថា ឧបចយ សន្តតិ ក៏ដោយជាតរូបនោះមានអាការប្រព្រឹត្តទៅផ្សេងគ្នា និងដោយអំណាចនៃវេនេយ្យសត្វផង តែព្រោះហេតុថា ភាពផ្សេងគ្នា ដោយន័យក្នុងបទទាំង ២ នោះមិនមាន ព្រោះហេតុនោះ ក្នុងនិទ្ទេសនៃបទទាំងនេះ ទើបពោលទុកថា **អាចយ** ( ការកឡើង ) នៃអាយតនៈទាំងឡាយ យ៉ាងណា **រូបស្សឧបចយ** ( ការធំចម្រើននៃរូប ) ក៏យ៉ាងនោះ រូបស្សឧបចយយ៉ាងណា **រូបស្សសន្តតិ** ( ការបន្តនៃរូប ) ក៏យ៉ាងនោះ ដូច្នេះ ក្នុងអដ្ឋកថាក៏ពោលថា ការកើតឡើងឈ្មោះថា **អាចយ** ការធំឡើងឈ្មោះថា **ឧបចយ** ការប្រព្រឹត្តទៅឈ្មោះថា **សន្តតិ** ហើយ ធ្វើឧបមាថា **អាចយ** បានដល់ការកើតដូចពេលដែលទឹកជ្រាបឡើងក្នុងរណ្តៅដែលគេជីកទុកត្រង់មាត់ប្រាំងទឹក **ឧបចយ** បានដល់ ការធំចម្រើនឡើងដូចពេលដែលទឹកពេញរណ្តៅ **សន្តតិ** បានដល់ ការប្រព្រឹត្តទៅ ដូចពេលដែលទឹកហៀររណ្តៅទៅ ដូច្នោះ ក្នុងទីបំផុតនៃឧបមា លោកពោលថា សួរថា ដោយពាក្យនិទ្ទេសថា **អាចយ** ការកឡើង

នៃអាយតនៈទាំងឡាយជាដើមយ៉ាងនោះ ជាការដែលលោកពោលអត្ថអ្វី ? ឆ្លើយថា លោកពោលអាចយដោយអាយតនៈ ពោល គឺអាយតនៈ ដោយ **អាចយ** ដូច្នេះ ព្រោះហេតុនោះ ការកើតឡើងដំបូងនៃរូបទាំងឡាយឯណានោះ គប្បីជ្រាបចុះថា ហៅថា **អាចយ** ការកើតឡើងនៃរូបពួកដទៃដែលកើតតបន្ថែម រូបទាំងនោះឡើងទៅឯណានោះ គប្បីជ្រាបចុះថា ឈ្មោះថា **ឧបចយ** ព្រោះប្រាកដដោយអាការធំឡើង ការកើតឡើងនៃរូបដទៃៗ ដែលកើតតបន្ថែមរូបទាំងនោះឡើង ទៅទៀតរឿយៗ យ៉ាងណា គប្បីជ្រាបចុះថា ហៅថា **សន្តតិ** ព្រោះប្រាកដដោយអាការបន្តគ្នាយ៉ាងនោះ ។

**ជរតា** ( ភាពទ្រុឌទ្រោម ) នៃរូប មានការចាស់ទៅនៃរូបជាលក្ខណៈ មានការនាំចូលទៅរកភាពបែកធ្លាយជារស មានការដែលសភាវៈ ( មានការរឹងជាដើម ) មិនទាន់វិនាសទៅ តែការថ្មីនៃរូបក៏វិនាសទៅបានជាបច្ចុប្បដ្ឋាន ដូចការចាស់នៃគ្រាប់ស្រូវ ដូច្នោះ មានរូបដែលកំពុងចាស់ជាបទដ្ឋាន ។

ការចាស់ដែលពោលមកនេះ ពោលសំដៅយកបាកដជរា ( ជរាដែលមិនកំបាំង ) ព្រោះសម្តែងភាពវិការក្នុងអវយវៈ មានធ្មេញជាដើម ដោយភាវៈមានការបាក់ជាដើម ចំណែកការចាស់នៃអរូបធម៌ទាំងឡាយ ចាត់ជាបដិច្ឆន្នជរា ( ជរាកំបាំង ) ភាពវិការ មានការបាក់ជាដើមនោះនឹងមានដល់បដិច្ឆន្នជរានោះក៏ទេ ម្យ៉ាងទៀត ការជរាដែលនៅមានក្នុងផែនដី ទឹក ភ្នំ ព្រះចន្ទ ព្រះអាទិត្យជាដើម ដែលបានឈ្មោះថា **អវីចិជរា** ( ជរាមិនមានកម្លប ) នោះ ភាពវិការនោះក៏មិនមានដូចគ្នា ។

**អនិច្ចតា** ( ការមិនស្ថិតស្ថេរ ) នៃរូប មានការបែកធ្លាយជាលក្ខណៈ មានការទ្រោមចុះទៅជារស មានការអស់ទៅ ការវិនាសទៅជាបច្ចុប្បដ្ឋាន មានរូបដែលកំពុងបែកធ្លាយជាបទដ្ឋាន ។

# មហាដីកា

ការក.កើតឡើងខាងដើម ឬការកកើតឡើងបន្តិចបន្តួច ហេតុនោះ ឈ្មោះថា **អាចយោ** ប្រែថា ( ក.កើតឡើងខាងដើម ឬក.កើតឡើងបន្តិចបន្តួច ) ម្យ៉ាងទៀត ការក.កើតឡើង ដូចរូបដែលមកហើយអំពីចំណែកនោះៗ តាមបច្ច័យ ហេតុនោះ ឈ្មោះថា **អាចយោ** ប្រែថា ( ការកកើតឡើង ដូចរូបដែលមកហើយ ) **អាចយ** ជាលក្ខណៈរបស់ឧបចយនេះ ដោយកាន់យកអត្ថទាំង ២ នោះមករួមចូលគ្នា ហេតុនោះ ឧបចយនេះ ឈ្មោះថា **អាចយលក្ខណោ** ប្រែថា ( មានអាចយជាលក្ខណៈ គឺមានការកកើតឡើងខាងដើម ក.កើតឡើងបន្តិចបន្តួច ឬក.កើតឡើងរបស់រូបដែលមកហើយអំពីចំណែកនោះៗ ជាលក្ខណៈ ) ។ **ឧបចយរូប** បានដល់ រូបដែលកើតឡើងគ្រាដំបូង និងរូបដែលធំចម្រើនឡើង ព្រោះ **ឧប**-ស័ព្ទសម្តែងលម្អិតដល់អត្ថថាពីដំបូង និងក្រៃលែងឡើងៗ ទៅ ដូចក្នុងពាក្យថា **ឧបញ្ញត្តំ** ប្រែថា ដឹងទីដំបូង **ឧបសិត្តំ** ប្រែថា ស្រោចតៗ ទៅជាដើម ។ បទថា **បុព្វន្តតោ** អត្ថប៉ុនគ្នា **បុព្វកោដ្ឋាសតោ** ប្រែថា ក្នុងចំណែកខាងមុខ ន័យថា ក្នុងភាពជាអនាគត ។ ការកើតឡើងរមែងដូចជាញុំាងរូបធម៌ទាំងឡាយ ដែលកំពុងកើតឡើងឲ្យផុសឡើងទៅ ក្នុងខណៈដែលជាអនាគត ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **មានការញុំាងរូបទាំងឡាយឲ្យផុសឡើងជារស** ។ ម្យ៉ាងទៀត ការកើតឡើងនោះ លោកកាន់យកដូចកំពុងប្រគល់ឲ្យជារូបធម៌ទាំងនេះ ហេតុនោះទើបលោកពោលថា **មានការប្រគល់ឲ្យជាបច្ចុប្បដ្ឋាន** ។ ការៈដែលមាន **ភាពជារូបបរិបូណ៌ជាបច្ចុប្បដ្ឋាន** គប្បីជ្រាបដោយអត្ថយ៉ាងនេះថា ការកើតឡើងតៗ ទៅ ឈ្មោះថា **ឧបចយ** ។ ពាក្យថា **មានការប្រព្រឹត្តទៅជាលក្ខណៈ** បានដល់ គប្បីកំណត់ថា ការប្រព្រឹត្តទៅរបស់រូបទាំងឡាយ ។ ពាក្យថា **មានការបន្តគ្នា**

រឿយៗ ជារស បានដល់ មានការទាក់ទងគ្នារឿយៗ ដោយអំណាចខាងដើមខាងចុង ជាកិច្ច ។ ឈ្មោះថា **មានការមិនដាច់ខ្សែជាបច្ចុប្បដ្ឋាន** ព្រោះគប្បីកាន់យកបានដោយអំណាចការមិនដាច់ខ្សែ ដែលមានការបន្តទុកជារសនោះឯង ។

បទថា **ឧភយម្បិ** ប្រែថា រូបទាំង ២ គឺឧបចយរូប សន្តតិរូប ។ បទថា **ជាតិរូបស្សេវ** ប្រែថា ជាឈ្មោះរបស់ការកើតឡើងនៃរូបនោះឯង ។ លោកអាចារ្យពោលថា **ដោយភាពផ្សេងគ្នានៃអាការ** ដូច្នេះ ដើម្បីនឹងចៀសវាងនូវពាក្យសួរថា កាលបើយ៉ាងនេះ ហេតុអ្វី ទើបលោកពោលញែកទុកទៅវិញ ? សេចក្តីថា ដោយការផ្សេងគ្នានៃអាការ គឺការប្រព្រឹត្តទៅរបស់ជាតរូប ។ ហេតុក្នុងការពោលញែកគ្នាទុកដោយអំណាចវេនេយ្យសត្វនឹងមានជាក់ច្បាស់ខាងមុខ ។ លោកអាចារ្យកាលនឹងសម្តែងថា សួរថា សេចក្តីប្រការនេះដែលថា ភាពផ្សេងគ្នានៃជាតរូបមាន ព្រោះផ្សេងគ្នានៃអាការ គឺការប្រព្រឹត្តទៅ មិនមែនដោយសភាវៈ ដូច្នោះ នឹងគប្បីដឹងបានដូចម្តេច ? ឆ្លើយថា គប្បីដឹងបានដោយនិទ្ទេស ទើបពោលពាក្យថា **យស្មា បទ** ជាដើម ។ ក្នុងបណ្តាបទទាំងនោះ បទថា **យោ អាយតនានំ** សេចក្តីថា សភាវធម៌ណាដែលហៅថា **អាចយ** ព្រោះជាភាពកកើតខ្លួនឡើងខាង ដើមរបស់រូបាយតនៈ ១០ អាយតនៈកន្លះ ។ សភាវធម៌នោះៗ ឯងឈ្មោះថា **ឧបចយ** ព្រោះជាភាវៈដែលកើតឡើងដំបូង ព្រោះធ្វើពាក្យអធិប្បាយថា **ឧប-ស័ព្ទ** មានអត្ថថា ដំបូង ។ ចំណែកសភាវធម៌ណា ឈ្មោះថា **ឧបចយ** ព្រោះជាភាពកកើតខ្លួនឡើងតៗ ទៅរបស់រូបាយតនៈដែលកើតឡើងនៅក្នុងទីនោះៗ ឯង **សន្តតិ** ក៏ដូច្នោះនោះឯង ព្រោះជាការកើតឡើងដោយអំណាចការទាក់ទងគ្នារឿយៗ ។ ម្យ៉ាងទៀត ***សភាវធម៌ណាជាការកកើតដំបូងរបស់អាយតនៈទាំងឡាយ*** បានដល់ ការកើតឡើងដែលកំណត់ទុកដោយភាពជាដំបូង ក៏សភាវធម៌នោះ ឈ្មោះថា **ឧបចយ** ព្រោះជាការកកើតឡើងតៗ ទៅរបស់រូបាយតនៈ

ទាំងឡាយ ដែលកើតឡើងនៅក្នុងទីនោះៗ ឯង អធិប្បាយថា បានដល់ ការធំចម្រើន ។ **ឧបចយ** បានដល់ ការដែលកើតឡើង ដែលកំណត់ដោយភាវៈ គឺការធំចម្រើន **សន្តតិ** ក៏យ៉ាងនោះៗ ឯង ព្រោះភាវៈដែលកើតឡើងដោយអាការដែលសម្ពន្ធគ្នា ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **សូម្បីក្នុងអដ្ឋកថា** ដូច្នេះជាដើម ។

ក្នុងបណ្តាបទទាំងនោះ ពាក្យថា **ឯវំ កឹ កថិតំ** សេចក្តីដោយនិទ្ទេស គឺការ ក.កើតឡើងដើមដំបូងរបស់អាយតនៈទាំងឡាយឯណាជាដើម ជាការដែលលោក ពោលដល់អត្ថអ្វីទុក ជាការដែលលោកពោលដល់អាចយ ការក.កើតឡើងដំបូង ដោយអាតយនៈ ។ ពិតណាស់ **អាចយ** គឺការក.កើតឡើងដំបូង **ឧបចយ** ការក.កើត ឡើងតៗ ទៅ និង **សន្តតិ** ការបន្តក៏ជាអាចយនោះឯង ដោយភាវៈដែលជាការកើត ឡើង ព្រោះដូច្នោះ ទើបជាការដែលពោលដល់អាចយ ដោយអាការទាំងនោះ ព្រោះ លោកប្រកាសដល់អាចយជាដើមដោយអាយតនៈទាំងឡាយ ។ អាយតនៈទាំងឡាយ មានអាចយ ការកកើតឡើងដំបូងជាសភាវៈ មានការកើតឡើងជាធម្មតា ដោយការ ពោលដល់អាចយ ការកកើតឡើងដំបូងជាដើមនៃអាយតនៈទាំងឡាយនោះឯង ព្រោះ ដូច្នោះ ទើបជាការដែលពោលដល់អាយតនៈដែលមានអាចយ ការក.កើតឡើងដំបូង នោះជាតួដើម ដោយ **អាចយ** ។ ពិតណាស់ លក្ខណរូបជាតួកើតឡើង រូបមិនជាតួ កើតឡើងឡើយ ដូច្នេះ ។

ការឆ្អិនរបស់រូប បានដល់ ការចាស់របស់រូបធម៌ទាំងឡាយ ។ ពាក្យថា **មាន ការនាំចូលទៅជារស** បានដល ការនាំចូលទៅរកការបែកធ្លាយជាកិច្ច ។ ពាក្យថា **កាលសភាវៈនៅមិនទាន់ប្រាសទៅ** បានដល់ កាលសភាវៈ មានការគ្រោតគ្រាត ការរឹងជាដើមមិនទាន់ប្រាសទៅ ។ ដោយជរាមានក្នុងឋិតិក្ខណៈ ធម៌ក្នុងវេលានោះ ឈ្មោះថា លះសភាវៈក៏ទេ ។ **ភាពថ្មី** បានដល់ កិរិយាដែលតាំងចុះរបស់ការកើតឡើង

ជរតារូបរមែងនឹងកាន់យកបានដោយការប្រាសទៅរបស់ភាពថ្មីនោះ ព្រោះដូច្នោះ ទើបលោកពោលថា **មានភាពថ្មីប្រាសទៅជាបច្ចុប្បដ្ឋាន** ។ ពាក្យថា **នៃអរូបធម៌ទាំងឡាយ**នេះ លោកពោលទុកព្រោះភាពចាស់របស់អរូបធម៌ទាំងនោះ ត្រូវបិទបាំងទុកយ៉ាងល្អ ។ ឯខណិកជរា របស់រូបទាំងឡាយក៏ត្រូវបិទបាំងដូចគ្នា ដែលតែងហៅថា **អវីចិជរា** ក៏មាន ។ លោកអាចារ្យពោលដល់វិការ មានការបាក់ជាដើមថា **ឯសវិការោ** ព្រោះវិការនោះ ក្នុងអរូបធម៌ទាំងឡាយក៏ទេ ។ គប្បីសម្ពន្ធអត្ថ បាលីថា **យា អាវីចិជរា នាម តស្សាបិ ឯសវិការោ នត្ថិ** ប្រែថា ឈ្មោះថា **អវីចិជរាណា** វិការនេះមិនមានដល់អវីចិជរានោះ ។ សេចក្តីថា ឈ្មោះថា **អវីចិជរា** ព្រោះអត្ថថា ជរាដែលមិនមានអណ្តាត ( ចំហាយ ឬកម្ពស់ ) អធិប្បាយថា ភាពចាស់ក្នុងរវាងដែលគប្បីដឹងបានលំបាក ព្រោះជាភាពថ្មី ។

អនិច្ចតារូប ឈ្មោះថា **បរិភេទលក្ខណា** ប្រែថា **មានការបែកធ្លាយជាលក្ខណៈ** ដោយអត្ថថា គប្បីកំណត់បានថា បែកធ្លាយដោយជុំវិញ គឺដោយប្រការទាំងពួង ។ ការស្ថិតស្ថេរ ឈ្មោះថា **និច្ចំ** ប្រែថា ទៀង ចំណែករូបមិនជានិច្ចំ ដោយការបែកធ្លាយណា ព្រោះជាធម្មជាតិមានការបែកធ្លាយទៅគ្រប់ខណៈ ព្រោះដូច្នោះ ទើបពោលថា **អនិច្ចំ** ប្រែថា មិនទៀង ភាវៈរបស់រូបដែលមិនទៀងនោះ ព្រោះដូច្នោះ ទើបពោលថា **អនិច្ចតា** ។ អនិច្ចតានោះ ព្រោះដូចកំពុងទ្រុឌទ្រោមដោយភាវៈ ដែលញ៉ាំងរូបដែលដល់ឋិតិក្ខណៈឲ្យវិនាសទៅ ដូច្នោះ ទើបលោកពោលថា **មានការទ្រុឌទ្រោមជារស** ។ ម្យ៉ាងទៀត ព្រោះអនិច្ចតានោះ លោកកាន់យកដោយអាការ គឺការអស់ទៅ ការវិនាសទៅនោះឯង ព្រោះជាការបែកធ្លាយរបស់រូបធម៌ទាំងឡាយ ដូច្នោះ ទើបលោកពោលថា **មានការអស់ទៅ ការវិនាសទៅជាបច្ចុប្បដ្ឋាន** ។

# វិសុទ្ធិមគ្គ

## ឱជារូប

កពឡិង្ការាហារ មានឱជាជាលក្ខណៈ មានការនាំមកនូវរូបជារស មានការឧបត្ថម្ភរាងកាយទុកជាបច្ចុប្បដ្ឋាន មានវត្ថុដែលគប្បីធ្វើឲ្យជាពំនូតហើយបរិភោគ ជាបទដ្ឋាន ។

សត្វទាំងឡាយញុំាងជីវិតឲ្យប្រព្រឹត្តទៅដោយឱជាណា ពាក្យថា លពឡិង្ការាហារនេះ ជាឈ្មោះនៃឱជានោះឯង ។

រូបដែលមកក្នុងបាលីមានប៉ុណ្ណោះឯង ។

# មហាដីកា

*ក្នុងបទថា **មានឱជាជាលក្ខណៈ** នេះ អធិប្បាយថា គុណវិសេសម្យ៉ាង ដែលជាសារៈរបស់រសដែលជ្រួតជ្រាបទៅតាមអវយវៈតូចធំ ធ្វើការឧបត្ថម្ភនូវកម្លាំងអាស្រ័យភូតរូប ឈ្មោះថា **ឱជា** ។ អាហារដែលជាពំនូតៗ ឈ្មោះថា **កពឡិង្ការាហារ** ។ ឈ្មោះថា **អាហារ** ដោយអត្ថថា ទំពាលេបចូលទៅ អធិប្បាយថា ធ្វើជាពំនូតៗហើយលេបចូលទៅ ។ ពាក្យថា កពឡិង្ការាហារនេះលោកពោលទុកដើម្បីសម្តែងដល់ឱជា ព្រមដោយវត្ថុ ។ អាហារខាងក្នុងបានអាហារខាងក្រៅជាបច្ច័យហើយនោះឯង រមែងញ៉ាំងរូបឲ្យកើតឡើង អាហារខាងក្នុងនោះ ឈ្មោះថា អាហារ ដោយអត្ថថា នាំរូបមក ។ ដោយហេតុនោះ ទើបលោកពោលថា **មានការនាំរូបមកជារស** ។ ព្រោះអាហារនាំរូបមកជារសនោះឯង ទើបឈ្មោះថា **មានការឧបត្ថម្ភ** កាយនេះ **ជាបច្ចុប្បដ្ឋាន** ដោយការញ៉ាំងរូបដែលមានឱជាជាគម្រប់ ៨ ឲ្យកើតឡើង ។ កិច្ចគឺការនាំមករបស់ឱជាអាស្រ័យវត្ថុខាងក្រៅ ព្រោះដូច្នោះ ទើបលោកពោលថា មានវត្ថុដែលនឹងគប្បីទំពាលេប **ជាបច្ចុប្បដ្ឋាន** ។*

# វិសុទ្ធិមគ្គ

## ឧទាហរណ៍រូបបន្ថែមតាមមតិកេចិអាចារ្យ

*តែក្នុងអដ្ឋកថាលោកនាំយករូបដទៃៗ ទៀតមកពោលបន្ថែមទុកយ៉ាងនេះ គឺ **ពលរូប** ( រូប គឺកម្លាំង ) **សម្ភវរូប** ( រូប គឺទឹកសម្ភវ ) **ជាតិរូប** ( រូប គឺការកើត ) **រោគរូប** ( រូប គឺរោគ ) និងតាមមតិរបស់អាចារ្យពួកខ្លះមួយរូបទៀត គឺ **មិទ្ធរូប** ( រូប គឺការងុយដេក ) ដូច្នេះហើយ ទាញយកពាក្យបាលីមកពោលជាលក្ខដ្ឋានថា*

***អទ្ធាមុនីសិ សម្ពុទ្ធោ នត្ថិ នីវរណា តវ** ព្រះអង្គជាព្រះមុនីដែលត្រាស់ដឹងឯងពិតមែន នីវរណៈទាំងឡាយ មិនមានដល់ព្រះអង្គឡើយ ដូច្នេះជាដើម ហើយជំទាស់ថា មិទ្ធរូបមិនមានតែម្យ៉ាងប៉ុណ្ណោះទេ ។*

*តែសេចក្តីពិត ក្នុងរូបក្រៅអំពីនេះ រោគរូបក៏ជាការកាន់យកហើយ ដោយជរតា និងអនិច្ចតាជាគោល ជាតិរូបក៏ជាការកាន់យកហើយដោយឧបចយ និងសន្តតិជាគោល សម្ភវរូបក៏ជាការកាន់យកហើយដោយកាន់យកអាបោធាតុជាគោល ពលរូប ក៏ជាការកាន់យកហើយដោយកាន់យកវាយោធាតុជាគោលពិត ព្រោះដូច្នោះ ទើបសន្និដ្ឋានបានថា រូបទាំងនោះ មិនមានរូបដែលបំបែកជាចំណែកមួយ សូម្បីតែរូបមួយ ។*

*ឧបាទាយរូបនេះមាន ២៤ និងភូតរូបដែលពោលមកមុន ៤ យ៉ាង ព្រោះដូច្នោះ ទើបជារូប ២៨ យ៉ាង មិនខ្វះមិនលើស ដោយប្រការដូច្នេះ ។*

# មហាដីកា

*ក្នុងពាក្យថា **ពលរូប** ជាដើមមានអធិប្បាយថា ក្នុងកាយនេះមានរូបឈ្មោះថា **ពលរូប** (រូបកម្លាំង) មានរូបឈ្មោះថា **សម្ភវរូប** (រូបទឹកសម្ភវ) មានរូប ឈ្មោះថា **រោគរូប** ( រូប គឺរោគ ) មានរូបឈ្មោះថា **ជាតិរូប** ( ការកើត ) ដោយមានព្រះបាលីថា **ជាតិ** ( ការកើត ) **សញ្ជាតិ** ( ការកើតព្រម ) រូបទាំង ៤ នេះ គួរជាឧបាទាយរូប ព្រោះមិនវៀរចាកមហាភូតរូប ៤ ឡើយ ។ ពាក្យថា **របស់ អាចារ្យពួកខ្លះ** បានដល់ របស់អាចារ្យសម្នាក់អភយគិរីវិហារ ។ ក្នុងពាក្យថា **ត្រូវជំទាស់**នេះ គប្បីជ្រាបការបដិបក្ខយ៉ាងនេះ ។*

***មិទ្ធៈ** មិនបានជារូបឡើយ ព្រោះទ្រង់សម្តែងទុកក្នុងជំពូកនីវរណៈ ។ ធម្មជាតិណាដែលទ្រង់សម្តែងទុកក្នុងជំពូកនីវរណៈ ធម្មជាតិនោះមិនមែនរូប ដូចជា **កាមច្ឆន្ទៈ** ។ គប្បីមានពាក្យសួរថា មិទ្ធៈនេះមាន ២ យ៉ាង គឺជារូប និងអរូប ។ សួរថា ក្នុងមិទ្ធៈ ២ យ៉ាងនោះ មិទ្ធៈណាជាអរូប មិទ្ធៈនោះទ្រង់សម្តែងទុកក្នុងជំពូកនីវរណៈថា មិនមែនរូបឬ ? ឆ្លើយថា ប្រការនោះមិនដូច្នោះឡើយ ព្រោះមិនមានការពោលពីភាពផ្សេងគ្នាទុក ។ មិទ្ធៈទ្រង់មិនសម្តែងទុកក្នុងជំពូកនីវរណៈឲ្យផ្សេងគ្នាឡើយ ព្រោះដូច្នោះ ទើបមិនអាចកំណត់សេចក្តីដែលមិទ្ធៈមាន ២ យ៉ាង ហើយឃាត់ភាពជានីវរណៈបាន ព្រោះអាចពោលបានថា មិទ្ធៈនោះដែលកំណត់ទុកជាយ៉ាងដទៃទៅអំពីអរូប មិទ្ធៈនោះក៏ជានីវរណៈ ព្រោះមានសភាពជាមិទ្ធៈ ដូចមិទ្ធៈក្រៅអំពីនេះ ។*

*ប្រសិនបើមានពាក្យសួរថា មិទ្ធៈជានីវរណៈចូរលើកទុក ប្រការខុសគ្នាដូចម្តេច ? ឆ្លើយថា មិទ្ធៈជានីវរណៈក៏ត្រូវលះបង់ ។ លះនីវរណៈទាំង ៥ ដោយមានព្រះបាលីថា ព្រះអង្គជាព្រះមុនីអ្នកត្រាស់ដឹងឯង មែនពិត ព្រះអង្គមិនមាននីវរណៈ ។*

ចំណែករូបមិនត្រូវលះ ព្រោះព្រះបាលីថា ធម៌ដែលសោតាបត្តិមគ្គ និងមគ្គជាន់ខ្ពស់ ៣ មិនគប្បីលះដូចម្តេច ? គឺកុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយាអព្យាកតៈ ក្នុងភូមិ ៣ រូប និងនិព្វាន ។ ធម៌ទាំងនេះដែលសោតាបត្តិមគ្គ និងមគ្គខាងដើម ៣ មិនគប្បីលះ ។ ក្នុងព្រះបាលីនេះមិនបានបំណងយកការលះកិលេស ដែលមានរូបនោះជាអារម្មណ៍ ព្រោះទ្រង់មិនមានបំណងយកការលះនីវរណៈ មានកាមច្ឆន្ទៈជាដើមយ៉ាងនោះ ដូចក្នុងព្រះបាលីជាដើមថា ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់រូបនោះចេញ ដូច្នេះ ។ ព្រោះដូច្នោះ មិទ្ធៈ ទើបមិនមែនរូប ។ សួរថា បើអ្នកមិនព្រមទទួលថា មិទ្ធៈជារូប ព្រះមានព្រះភាគជាម្ចាស់ទ្រង់មានការផ្ទំលក់បានដូចម្តេច ដោយមិទ្ធៈជាការលក់ ព្រោះទ្រង់បានចែក ក្នុងវិភង្គដោយព្រះបាលីថា ការលក់ ការងោកងក់ ដូច្នេះជាដើមមិនមែនឬ ? ឆ្លើយថា មិទ្ធៈ មិនមែនការលក់ តែមិទ្ធៈនោះទ្រង់ចែកទុកថា ការលក់ ព្រោះជាហេតុនៃការលក់ ដូចពាក្យមានពាក្យថា ឥត្ថីលិង្គជាដើម ។ សួរថា សូម្បីយ៉ាងនេះ ការផ្ទំលក់របស់ព្រះមានព្រះភាគនឹងគប្បីមានដូចម្តេច ព្រោះទ្រង់មិនមានមិទ្ធៈ ដែលជាហេតុនៃការលក់ ( និទ្រា ) មិនមែនឬ ? ឆ្លើយថា ការនិទ្រាជាការសម្រាកព្រះសរីរៈរបស់ព្រះមានព្រះភាគ មិនមែនព្រោះមិទ្ធៈ ។ ការនិទ្រានោះមិនអាចពោលបានថា មិនមាន ព្រោះមានព្រះបាលីថា តថាគតលំបាកខ្នង តថាគតនឹងសណ្តូក ( ឈាត ) ខ្នងនោះ ។ ក្នុងអធិការនេះមិនមានពាក្យកំណត់សេចក្តីទុកយ៉ាងនេះថា គួរមានពាក្យកំណត់សេចក្តីយ៉ាងនេះថា ហេតុនៃការនិទ្រា គឺមិទ្ធៈ ថាមិទ្ធៈក៏គឺហេតុនៃការនិទ្រានោះឯង ។ សួរថា ព្រោះដូច្នោះ ហេតុនៃការនិទ្រា សូម្បីយ៉ាងដទៃក៏មាន ហេតុនៃការនិទ្រា គឺអ្វីហ្ន៎ ? គឺការលំបាកសរីរៈ ។ ដោយហេតុនោះ ទើបលោកពោលថា ការនិទ្រាជាការលំបាក ព្រះសរីរៈរបស់ព្រះមានព្រះភាគ មិនមែនព្រោះមិទ្ធៈ ។

មិនអាចនឹងពោលបានថា ការនិទ្រាមិនមានដល់ព្រះមានជោគ ព្រោះមានព្រះបាលីថា ម្នាលអគ្គិវេស្សនៈ តថាគតរមែងដឹងដែលនឹងសម្ដែងធម៌ ។បេ។ អគ្គិវេស្សនៈក្រាបទូលថា ព្រះគោតមរមែងដឹងចំពោះថា ព្រះអង្គជាអ្នកនិទ្រាក្នុងកណ្ដាលថ្ងៃខ្លះឬ ? ដូច្នេះ ព្រោះព្រះបាលីថា ព្រោះហេតុនេះ ទើបរូបមិនមែនមិទ្ធៈ ព្រោះពោលដល់ការប្រកប ។ ប្រការនេះសមដោយព្រះពុទ្ធវចនៈដែលត្រាស់ទុកថា ថីនមិទ្ធនីវរណៈជាតួនីវរណៈ និងប្រកបជាមួយនីវរណៈ ដោយអវិជ្ជានីវរណៈជាដើម ។ ក្នុងអធិការនេះមិនអាចនឹងជឿការមានតាមដែលបាន ព្រោះភាពជារូប ជាការៈដែលសម្រេចបានតិចតួច ដូចពាក្យថា ទាំងក្រួស និងអំបែង ទាំងហ្វូងត្រីកំពុងត្រាច់ទៅក៏មាន ឈប់ក៏មានជាដើម ។ កាលសម្រេចការៈ ដែលមិទ្ធៈនោះជារូប ក៏គួរនឹងប្រកបបច្ច័យតាមដែលបាន ព្រោះមានដូច្នេះ ។ ព្រោះហេតុនេះ ទើបមិទ្ធៈមិនមែនរូប ព្រោះកើតឡើងក្នុងអរូបទាំងឡាយ សេចក្ដីនេះសមដូចព្រះពុទ្ធវចនៈដែលត្រាស់ទុកថា ធម៌ដែលជានីវរណៈអាស្រ័យធម៌ដែល ជានីវរណៈកើតឡើង មិនមែនព្រោះបុរេជាតប្បច្ច័យ ។ ក្នុងវិភង្គនៃព្រះពុទ្ធវចនៈនេះ មានសេចក្ដីពិស្ដារថា ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈអវិជ្ជានីវរណៈ អាស្រ័យកាមច្ឆន្ទនីវរណៈកើតឡើងក្នុងអរូប ដូច្នេះជាដើម ព្រោះដូច្នោះ ពាក្យណាដែលលោកបដិសេធទុកក្នុងអដ្ឋកថាទាំងឡាយថា មិទ្ធៈមិនមែនរូប ពាក្យនោះលោកបដិសេធទុកប្រពៃហើយនោះឯង ។

បទថា **ឥតរេសុ យោគ ពលរូបាទីសុ** ប្រែថា ក្នុងបណ្ដារូបទាំងឡាយ មានពលរូបជាដើមក្រៅអំពីនេះ ។ ការកម្រើកនៃធាតុដែលកើតឡើងដោយបច្ច័យថាជាវិសភាគគ្នា ជាហេតុជិតរបស់រោគ ដែលមានកម្មជាសមុដ្ឋានខ្លះ សម្រាប់រោគក្រៅអំពីនេះពុំបាច់និយាយដល់ឡើយ ។ ការកម្រើកនៃធាតុនោះ ដោយអត្ថ គប្បីមានបានចំពោះកិរិយាដែលតាំងចុះនៃការផ្លាស់ប្ដូររបស់រូបធម៌ទាំងឡាយ និងឋិតិក្ខណៈ

កក្ខឡភាវៈ ព្រោះដូច្នោះ ទើបលោកពោលថា **ជរារូប រូប គឺជរា លោកកាន់យក ដោយជរតា ស័ព្ទ និងអនិច្ចតា ស័ព្ទនោះឯង** ។ ទើបលោកអាចារ្យពោលថា **ជាតិរូប លោកកាន់យកដោយឧបចយស័ព្ទ និងសន្តតិស័ព្ទនោះឯង** ព្រោះការកើតឡើងនៃរូបដែលផុតទៅអំពីឧបចយ និងសន្តតិនោះមិនមាន ។ ហើយបានឈ្មោះថា ជាតិនឹងជាដទៃទៅអំពីកិរិយាដែលតាំងចុះនៃការកើតឡើងក៏មិនមានដូចគ្នា ។ ទឹកសម្ភារៈដែលមានសភាពចាស់នៃឥន្ទ្រិយរបស់សត្វជំពូកខ្លះក្នុងកាមធាតុជាបច្ច័យ ជាភាពពិសេសនៃអាការដែលប្រព្រឹត្តទៅរបស់អាបោធាតុ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **សម្ភវរូប រូប គឺទឹកសម្ភវៈ លោកកាន់យកដោយស័ព្ទថា អាបោធាតុនោះឯង** ។ ដែលបានឈ្មោះថា កម្លាំងកាយ ដោយអត្ថ បានដល់ ភាពពិសេសនៃអាការដែលប្រព្រឹត្តទៅរបស់វាយោធាតុ ព្រោះភាពដែលវាយោធាតុ មានភាពផ្សាយទៅ ព្រោះវាយោធាតុនោះ គេតែងហៅថា កម្លាំងកាយ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ពលរូប រូប គឺកម្លាំង លោកកាន់យកដោយស័ព្ទថា វាយោធាតុនោះឯង** ។ សួរថា ព្រោះហេតុអ្វី ទើបលោកធ្វើការជំទាស់រូបទាំងនោះមិនតាមលំដាប់ ? ឆ្លើយថា ព្រោះលោកធ្វើភាពអនុលោមទុកថា **មិនមានសូម្បីត្រឹមតែរូបមួយដទៃ** ទើបមិនសម្ដែងនូវការមិនអើពើ ម្យ៉ាងទៀត ការបដិសេធមិទ្ធៈថា ជារូបមានបញ្ហាច្រើន ព្រោះដូច្នោះ ទើបលោកធ្វើទុកមុន ។ គប្បីជ្រាបថា លោកពោលភាពមិនមានរបស់រូប មានពលរូបជាដើម សូម្បីក្រៅអំពីនេះទុកដោយន័យដែលជាបដិលោមតាមគន្លងនៃការជំទាស់នោះ ។

បទថា **ឥតិ** នេះ គប្បីសម្ពន្ធចូលជាមួយបទថា **អដ្ឋវីសតិ វិធំ** នេះ សេចក្ដីថា មាន ២៨ យ៉ាងតាមលំដាប់ដែលបានពោលទុកហើយនេះ ។ លំដាប់ដែលបានពោលទុកហើយនោះឯង មានតាមន័យដែលមកក្នុងព្រះបាលីនោះឯង ព្រោះដូច្នោះ គប្បីជ្រាបថា ជាភាពមិនខ្វះ ។ ចំណែកភាពមិនលើស ខ្ញុំសម្ដែងទុកហើយនោះឯង ។

# វិសុទ្ធិមគ្គ

## *រូប ១*

*រូបទាំងពួងចែកជាមយ៉ាង ដោយន័យជាដើមថា រូបជា **នហេតុ** ( មិនមែនហេតុ ) ប៉ុណ្ណោះ ជា **អហេតុកៈ** ( មិនមានហេតុ ) ជា **ហេតុវិប្បយុត្ត** ( មិនប្រកបជាមួយហេតុ ) ជា **សប្បច្ចយៈ** ( ប្រព្រឹត្តទៅជាមួយបច្ច័យ ) ជា **លោកិយ** ( ត្រូវប្រកបទុកក្នុងលោក ) ជា **សាសវៈ** ( ប្រព្រឹត្តទៅជាមួយអាសវៈ ) ប៉ុណ្ណោះ ។*

# មហាដីកា

ធម៌ឈ្មោះថា **ហេតុ** ដោយអត្ថថា ជាហេតុតាំងនៅ គឺតម្រង់នៅនៃគំនរសម្បយុត្តធម៌ បានដល់ **ធម៌** មានលោភៈជាដើម និងធម៌ មានអលោភៈជាដើម ដោយអត្ថថា ជាមូល **រូប** ឈ្មោះថា **នហេតុ** ដោយអត្ថថា ហេតុនោះមិនមាន ។ **រូប** ឈ្មោះថា **អហេតុកៈ** ដោយអត្ថថា មិនមានហេតុ អធិប្បាយថា មិនកើតព្រមនឹងហេតុ ព្រោះជាធម្មជាតិមានការប្រកបផ្ទុយគ្នានឹងធម៌ដែលជាសហេតុកៈ ។ រូបដែលឈ្មោះថា អហេតុកៈនោះឯង ឈ្មោះថា **ហេតុវិប្បយុត្ត** ព្រោះមិនប្រកបជាមួយហេតុ ។ បទពីរនេះត្រាស់ដោយអំណាចបទដែលជាទុកៈ ព្រោះកាលភាពផ្សេងនៃធម៌មិនមាន ទ្រង់មានការសម្តែងទុកក្នុងទុកៈដទៃ ទាក់ទងនឹងវេនេយ្យសត្វ ដោយសេចក្តីផ្សេងគ្នានៃអត្ថរបស់ស័ព្ទ ។ រូប ឈ្មោះថា **សប្បច្ចយៈ** ដោយអត្ថថា ប្រព្រឹត្តទៅដោយបច្ច័យ ព្រោះមានការប្រព្រឹត្តទៅអាស្រ័យនូវបច្ច័យ ។ រូប ឈ្មោះថា **លោកិយ** ដោយអត្ថថា ប្រកបនៅក្នុងលោក ឬដោយអត្ថថា ប្រាកដនៅក្នុងលោកដោយបច្ច័យទាំងឡាយរបស់ខ្លួន ។ ធម៌ដែលឈ្មោះថា **អាសវៈ** ដោយអត្ថថា ហូរទៅរហូតដល់ភវគ្គព្រហ្ម ឬដោយអត្ថថា ហូរទៅរហូតដល់ **គោត្រភូញាណ** រូប ឈ្មោះថា **សាសវៈ** ដោយអត្ថថា ប្រព្រឹត្តទៅដោយអាសវៈទាំងឡាយ អធិប្បាយថា ជារូបដែលអាសវៈទាំងឡាយគប្បីហួងហែង (ប្រកាន់ស្អិត) ។ ដោយ **អាទិ**-ស័ព្ទ គប្បីឃើញការសង្គ្រោះរូបទាំងឡាយ មានអាទិយ៉ាងនេះ គឺរូបជាសំយោជនៈ ជាឱឃនិយៈ ជាយោគនិយៈ ជានីវរណិយ ជាសង្កិលេសិក ជាបរាមដ្ឋៈ ជាអចេតសិក ជាចិត្តវិប្បយុត្ត ជានរូបាវចរៈ ជានអរូបាវចរៈ ជានអបរិយាបន្ន ជាអនិយតៈ ជាអនិយ្យានិក ជាអនិច្ចៈ ។

# វិសុទ្ធិមគ្គ

## រូប២

រូបចែកជា ២ យ៉ាង ដោយអំណាចនៃរូប ( ពួក ២ ) មានរូប គឺ **អជ្ឈត្តិកៈ** ( រូបខាងក្នុង ) **ពាហិរៈ** ( រូបខាងក្រៅ ) **ឱឡារិកៈ** ( រូបគ្រោតគ្រាត ) **សុខុម** ( រូបល្អិត ) **ទូរេ** ( រូបក្នុងទីឆ្ងាយ ) **សន្តិកេ** ( រូបក្នុងទីជិត ) **និប្ផន្ន** ( រូបសម្រេចហើយ គឺរូបសម្បូណ៌ ) **អនិប្ផន្ន** ( រូបមិនសម្រេច គឺមិនសម្បូណ៌ ) **បសាទរូប** ( រូបថ្លា ) **នបសាទរូប** ( រូបមិនថ្លា ) **ឥន្ទ្រិយ** ( រូបជាធំ ) **អនិន្ទ្រិយ** ( រូបមិនជាធំ ) **ឧបាទិន្ន** ( រូបដែលកម្មគ្រប់គ្រង ) **អនុបាទិន្ន** ( រូបដែលកម្មមិនបានគ្រប់គ្រង ) ជាដើម ។

ក្នុងរូបទាំងនោះ រូប ៥ យ៉ាង មានចក្ខុរូបជាដើម ចាត់ជាអជ្ឈត្តិករូប ព្រោះប្រព្រឹត្តទៅចំពោះអត្តភាព រូបដ៏សេស ២៣ ចាត់ជា **ពាហិររូប** ព្រោះប្រព្រឹត្តទៅខាងក្រៅអត្តភាពនោះ ។

រូប ១២ យ៉ាង គឺរូប ៩ មានចក្ខុរូបជាដើម ( មានរសរូបជាទីបំផុត ) និងធាតុ ៣ វៀរអាបោធាតុ ចាត់ជាឱឡារិករូប ព្រោះជាវត្ថុគប្បីកាន់យកដោយអំណាចការប៉ះខ្ទប់បាន រូបដ៏សេស ១៦ ចាត់ជាសុខុមរូប ព្រោះជាវត្ថុផ្ទុយគ្នាអំពីឱឡារិករូបនោះ គឺមិនជាវត្ថុដែលគប្បីកាន់យកបានដោយការប៉ះខ្ទប់ ។

រូបដែលជាសុខុមរូបនោះឯង ចាត់ជាទូររូប ព្រោះជារូបមានសភាពដែលដឹងបានដោយលំបាក រូបក្រៅអំពីនេះ គឺឱឡារិករូប ចាត់ជាសន្តិកេរូប ព្រោះជារូបមានសភាពដែលដឹងបានងាយ ។

រូប ១៨ យ៉ាង គឺធាតុ ៤ និងរូប ១៣ មានចក្ខុរូបជាដើម មានហទយវត្ថុរូបជាទីបំផុត និងកពឡិង្កាហារ ចាត់ជានិប្ផន្នរូប ព្រោះកន្លងភាពជាបរិច្ឆេទរូប វិការរូប និងលក្ខណរូបចេញ ហើយកំណត់កាន់យកបានដោយសភាពតែមួយ ( ដូចជាសភាពរឹងជាដើម ) រូបដ៏សេស ១០ ចាត់ជាអនិប្ផន្នរូប ព្រោះជារូបផ្ទុយអំពីនិប្ផន្នរូបនោះ គឺកំណត់កាន់យកដោយសភាវៈមិនបាន ។

រូប ៥ យ៉ាង មានចក្ខុរូបជាដើម ឈ្មោះថា បសាទរូប ព្រោះជារូបថ្លាផូរផង់ដូចកញ្ចក់ ដោយភាពជាបច្ច័យឲ្យទទួលអារម្មណ៍ទាំងឡាយ មានរូបជាដើមបាន រូបក្រៅអំពីនេះឈ្មោះថា នបសាទរូប ព្រោះជារូបផ្ទុយអំពីបសាទរូបនោះ ( គឺមិនថ្លា ) ។

បសាទរូបនោះឯងរួមជាមួយឥន្ទ្រិយរូប ៣ មានឥត្ថិន្ទ្រិយជាដើម ឈ្មោះថា ឥន្ទ្រិយរូប ព្រោះអត្ថថា ជាធំ រូបដ៏សេសឈ្មោះថា អនិន្ទ្រិយរូប ព្រោះជារូបផ្ទុយអំពីឥន្ទ្រិយរូបនោះ ។

រូបដែលខ្ញុំនឹងពោលខាងមុខថា កម្មជរូប ចាត់ជាឧបាទិន្នរូប ព្រោះជារូបដែលកម្មគ្រប់គ្រង រូបដ៏សេសចាត់ជា អនុបាទិន្នរូប ព្រោះជារូបផ្ទុយអំពី ឧបាទិន្នរូបនោះ ។

# មហាដីកា

សភាវៈ ឈ្មោះថា **អត្តា** ដោយអត្ថថា ជាទីតាំងរបស់មានះថា អញ បានដល់ អត្តភាព ។ ធម៌ទាំងឡាយដែលប្រព្រឹត្តឈមទៅ គឺឆ្ពោះទៅរកអត្តានោះ ឈ្មោះថា អជ្ឈត្តា បានដល់ ធម៌ដែលទាក់ទងដោយឥន្ទ្រិយ រូបដែលមានក្នុងធម៌ ប្រព្រឹត្តទៅ សំដៅចំពោះដល់អត្តាទាំងនោះ **ជាអជ្ឈត្តិកៈ** ប្រែថា មានខាងក្នុង បានដល់ បសាទរូប មានចក្ខុជាដើម ។ លោកអាចារ្យពោលថា **រូប ឈ្មោះថា អជ្ឈត្តិកៈ** ( ខាងក្នុង ) **ព្រោះប្រព្រឹត្តទៅដោយធ្វើភាពជាខ្លួនឲ្យធំក្រៃលែង** ដូច្នេះ សំដៅយកសេចក្តីប្រការនេះថា ក៏ **អជ្ឈត្តំ** នោះឯង ជា **អជ្ឈត្តិកំ** តាមន័យដែលបានពោលទុកហើយ ក្នុងអដ្ឋកថា ដូចពាក្យថា **វេនយិកោ** ។ **រូបដ៏សេស** បានដល់ រូប ២៣ ។ ពាក្យថា **ព្រោះជារូបនៅក្រៅអត្តភាពនោះ** នេះលោកពោលទុក ព្រោះមិនមានលក្ខណៈរបស់រូបដែលជាខាងក្នុង ។ ពាក្យថា ដោយអំណាចការប៉ះខ្ទប់បាន គឺដោយអំណាចជាបសាទរូប និងជាគោចររូបប៉ះខ្ទប់បាន ។ **រូបដ៏សេស** បានដល់ រូប ១៦ យ៉ាង ។

ពាក្យថា **ព្រោះជារូបដែលផ្ទុយគ្នា** បានដល់ ព្រោះជារូបដែលគប្បីកាន់យកមិនបាន ដោយអំណាចការប៉ះខ្ទប់ ។ ពាក្យថា **ព្រោះមានសភាពដែលចាក់ធ្លុះបានលំបាក** គឺព្រោះមានសភាព ដែលគប្បីដឹងបានលំបាក ដោយភាវៈដែលជារូបល្អិត ឈ្មោះថា **ទូររូប** ដោយអត្ថថា មិនមាននៅក្នុងទីជិតនៃញាណ ។ **រូប ១៣** មានហទយវត្ថុជាទីបំផុត ។ ពាក្យថា **ដោយសភាពនោះឯង** គឺព្រោះមិនគប្បីកាន់យកដោយន័យជាដើមថា ជាបរិច្ឆេទរូប ជាវិការរូប ជាឧបចយរូប ហើយកំណត់កាន់យកដោយញាណ ដោយសភាពនោះឯង គឺដោយសភាព មានភាពជារូបរឹងគ្រោតគ្រាតជាដើមរបស់ខ្លួន ។ **រូបដ៏សេស** បានដល់ រូប ១០ យ៉ាង ។ ពាក្យថា **ព្រោះជារូបដែលផ្ទុយអំពីនិប្ផន្នរូប**

នោះ គឺព្រោះជារូបដែលគប្បីកំណត់កាន់យកមិនបានតាមសភាព ។ លោកអាចារ្យកាលនឹងសម្ដែងថា រូបទាំងឡាយ មានសោតៈជាដើម ក៏ជារូបដែលមានការទទួលអារម្មណ៍តាមសមគួរដល់ខ្លួនជាបច្ច័យ ព្រោះជារូបមានសភាពថ្លាដូចគ្នានឹងចក្ខុនោះឯង ទើបពោលថា **រូប ៥ យ៉ាង មានចក្ខុជាដើម ជាបសាទរូប ព្រោះជាសភាពថ្លាដូចផ្ទៃកញ្ចក់ដោយការៈ ដែលមានការទទួលអារម្មណ៍ទាំងឡាយ មានរូបជាដើមជាបច្ច័យ** ។ ពាក្យថា **ព្រោះជាទីផ្ទុយគ្នា** គឺព្រោះជារូបដែលមានទាទីផ្សេងអំពីបសាទរូបនោះជាសភាវៈ ។ ក្នុងពាក្យថា **ដោយអត្ថថា ជាធំ** នេះខាងដើម បសាទរូប ៥ មានចក្ខុជាដើម ឈ្មោះថា ជាធំ ក្នុងវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ព្រោះប្រព្រឹត្តទៅតាមការៈដែលរហ័សរហួន និងយឺតយ៉ាវរបស់បសាទរូបទាំងនោះ ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយទាំង ២ រូប ជាធំក្នុងកិច្ចរបស់ខ្លួន ជីវិតិន្ទ្រិយជាធំក្នុងការតាមរក្សាសហជាតរូប ។ ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយទាំង ២ រូបនោះ ខ្ញុំបានពោលទុកហើយខាងដើមនោះឯង ។ ពាក្យថា **ព្រោះជារូបដែលត្រូវកម្មគ្រប់គ្រង** គឺព្រោះជារូបដែលត្រូវកម្មប្រកាន់ទុក ។ ពិតណាស់ រូបដែលកើតឡើងអំពីកម្ម រមែងដូចជាត្រូវកម្មប្រកាន់ទុកថា នេះជាផលរបស់អញ ព្រោះភាពមិនបាន ។

# វិសុទ្ធិមគ្គ

## រូប៣

រូបទាំងពួងចែកជា ៣ យ៉ាង ដោយអំណាចនៃតិកៈ ( រូបពួក ៣ ) គឺ សនិទស្សនតិកៈ និងកម្មជាទិត្តិកៈ ក្នុងរូបទាំងនោះ រូប គឺរូបាយតនៈ ក្នុងឱឡារិករូប ១២ ជាសនិទស្សនសប្បដិឃរូប រូបដែលឃើញបានផង និងប៉ះខ្ទប់បានផង ឱឡារិករូប ដ៏សេស ១១ ជាអនិទស្សនសប្បដិឃរូប រូបដែលឃើញមិនបាន តែប៉ះខ្ទប់បាន សុខុមរូបទាំងអស់ជាអនិទស្សនអប្បដិឃរូប រូបដែលឃើញមិនបាន និងប៉ះខ្ទប់ ក៏មិនបាន រូបចែកជា ៣ យ៉ាង ដោយអំណាចនៃសនិទស្សនតិកៈ ដូចពោលមកនេះ ជាលំដាប់ដំបូង ។

រូបចែកជា ៣ ដោយអំណាចនៃកម្មជាទិត្តិកៈ គប្បីជ្រាបដូច្នេះ គឺ

រូបដែលកើតអំពីកម្ម ឈ្មោះថា កម្មជរូប រូបដែលកើតអំពីបច្ច័យដទៃ អំពីកម្ម នោះ ( គឺកើតអំពីឧតុ ចិត្ត និងអាហារ ) ឈ្មោះថា អកម្មជរូប រូបដែលមិនកើតអំពី បច្ច័យណាមួយ ឈ្មោះថា នេវកម្មជនាកម្មជរូប បានដល់ លក្ខណរូប ។

រូបដែលកើតអំពីចិត្ត ឈ្មោះថា ចិត្តជរូប រូបដែលកើតអំពីបច្ច័យដទៃ ក្រៅ អំពីចិត្តនោះ ឈ្មោះថា អចិត្តជរូប រូបដែលមិនកើតអំពីបច្ច័យណាមួយ ឈ្មោះថា នេវចិត្តជនាចិត្តជរូប ។

រូបដែលកើតអំពីអាហារ ឈ្មោះថា អាហារជរូប រូបដែលកើតអំពីបច្ច័យដទៃ ក្រៅអំពីអាហារនោះ ឈ្មោះថា អនាហារជរូប រូបដែលមិនកើតអំពីបច្ច័យណាមួយ

ឈ្មោះថា នេវអាហារជ្ជនអនាហារជ្ជរូប ។

រូបដែលកើតអំពីរដូវ ឈ្មោះថា ឧតុជ្ជរូប រូបដែលកើតអំពីបច្ច័យដទៃ ក្រៅអំពីរដូវ ឈ្មោះថា អនុតុជ្ជរូប រូបដែលមិនកើតអំពីបច្ច័យណាមួយ ឈ្មោះថា នេវឧតុជ្ជនអនុតុជ្ជរូប ។

រូបចែកជា ៣ យ៉ាង ដោយអំណាចនៃកម្មជ្ជាទិត្តិកៈដូចពោលមក ដូច្នេះ ។

# មហាដីកា

ពីរបទថា **សនិទស្សនកម្មជាទីនំ តិកានំ** សេចក្តីប៉ុនគ្នានឹង **សនិទស្សនត្តិកស្ស កម្មជាទិត្តិកានញ្ច** ប្រែថា នៃសនិទស្សនតិកៈ និងនៃកម្មជាទិត្តិកៈ ។ ពាក្យថា **ឱឡារិកេ** បានដល់ ក្នុងឱឡារិករូប ១២ យ៉ាង ។ ពាក្យថា **រូប** បានដល់ រូបាយតនៈ ។ រូប ឈ្មោះថា សនិទស្សនៈ ដោយអត្ថថា ប្រព្រឹត្តទៅជាមួយដោយនិទស្សនៈ គឺភាពដែល គប្បីឃើញបាន រូបឈ្មោះថា សប្បដិឃៈ ដោយអត្ថថា ប្រព្រឹត្តទៅជាមួយបដិឃៈ គឺការៈដែលប៉ះខ្ទប់បាន រូបឈ្មោះថា **សនិទស្សនសប្បដិឃៈ** ដោយអត្ថថា មានការ ឃើញបាន និងមានការប៉ះខ្ទប់បាន ។ ក្នុងបណ្តាសនិទស្សនៈ និងសប្បដិឃៈនោះ រូបណាមានភាពដែលនឹងគប្បីឃើញបាន រូបនោះ ឈ្មោះថា **សនិទស្សនៈ** គឺមាន ការឃើញបាន ។ ការៈដែលជាអារម្មណ៍របស់ចក្ខុវិញ្ញាណនោះឯង ឈ្មោះថា **ភាព ដែលនឹងគប្បីឃើញបាន** ។ កាលភាពដែលនឹងគប្បីឃើញបាននោះមិនមែនដទៃអំពី រូបាយតនៈ លោកអាចារ្យមានបំណងនឹងធ្វើរូបាយតនៈ ឲ្យផ្សេងទៅអំពីធម៌ពួកដទៃ ទើបពោលថា រូបប្រព្រឹត្តទៅដោយនិទស្សនៈ គឺការៈដែលគប្បីឃើញបាន ឈ្មោះថា សនិទស្សនៈ ប្រែថា មានការឃើញបាន ដូច្នេះ ព្រោះធ្វើឲ្យដូចជារូបដទៃ ។ ព្រោះ បណ្តាធម៌ដែលដូចគ្នា ដែលជាការៈស្មើគ្នា ដោយភាពជាធម៌ប្លែកគ្នា ដែលធ្វើភាព ផ្សេងគ្នាឯណា ខប្លែកគ្នានោះគួរពោលប្រៀបធៀបធ្វើឲ្យដូចជាធម៌ដទៃ ។ ព្រោះដូច្នេះ រមែងមានការយល់ចូលចិត្តភាពផ្សេងគ្នារបស់អត្ថបាន ដូច្នេះ ។ ការៈដែលសម្បត្តរូប និងអសម្បត្តរូបមកប្រឈមមុខគ្នាដោយខ្លួនឯង និងដោយអំណាចរបស់វត្ថុដែល អាស្រ័យឯណា បានដល់ មកប្រជួបគ្នានឹងគ្នា ។ ការៈនោះឈ្មោះថា **ការៈដែល ប៉ះខ្ទប់គ្នា** ដែលជាហេតុកើតការផ្លាស់ប្តូរក្នុងអារម្មណ៍នៃចក្ខុជាដើម ដែលប្រកប

ដោយបច្ច័យដទៃនៃការផ្លាស់ប្តូរ មានការខ្វល់ខ្វាយជាដើម ។ **រូបដ៏សេស** បានដល់ ឱឡារិករូប ១១ យ៉ាង ។ ពិតណាស់ ឱឡារិករូបនោះ ឈ្មោះថា **អនិទស្សនៈ** ព្រោះមិនមានភាវៈដែលមាន ការឃើញបាន ឈ្មោះថា **សប្បដិឃៈ** តាមន័យដែលបានពោលទុកហើយនោះឯង ។ សុខុមរូប ឈ្មោះថា **អនិទស្សនអប្បដិឃៈ** ព្រោះការបដិសេធទាំង ២ យ៉ាង ។ ក្នុងពាក្យថា **រូបដែលកើតអំពីកម្ម** នេះ គប្បីជ្រាបសេចក្តីថា រូបណាដែលមានកម្មជាសមុដ្ឋានដោយចំណែកមួយ បានដល់ រូប ៩ យ៉ាង គឺឥន្ទ្រិយរូប ៨ និងហទយរូប ១ និងរូបណាក្នុងបណ្តារូបដែលមានសមុដ្ឋាន ៤ ប្រាំបួនយ៉ាង ជារូប ៩ យ៉ាងដូចគ្នា ដែលមានកម្មជាសមុដ្ឋាន សរុបរូបដូចពោលមកនេះជារូប ទាំង ១៨ យ៉ាង ឈ្មោះថា **កម្មជរូប** ។ ពិតណាស់ រូបណាកើតមកហើយផង រូបណាកំពុងកើតផង រូបណានឹងកើតតទៅផង រូបទាំងអស់នោះហៅថា កម្មជរូប ដូចទឹកដោះដែលរីតមកហើយ ។ បទថា **តទញ្ញបច្ចយជាតំ** ប្រែថា រូបដែលកើតអំពីបច្ច័យដទៃអំពីកម្ម បានដល់ ឧតុជរូប ចិត្តជរូប និងអាហារជរូប ។ លោកអាចារ្យពោលដល់លក្ខណរូបថា **រូបដែលមិនកើតអំពីបច្ច័យណាមួយ** ។ រូប ១៥ យ៉ាងនេះ គឺវិញ្ញត្តិរូប ២ សទ្ទរូប ១ អាកាសធាតុ ១ វិការរូប ៣ មានលហុតារូបជាដើម អវិនិព្ភោគរូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ឈ្មោះថា **ចិត្តជរូប** ។ រូប ១២ យ៉ាងនេះ គឺអាកាសធាតុ ១ វិការរូប ៣ មានលហុតារូបជាដើម អវិនិព្ភោគរូបទាំងឡាយ ដែលមានអាហារជាសមុដ្ឋានឈ្មោះថា **អាហារជរូប** ។ ក្នុងអាហារជរូប ១២ យ៉ាងនេះ បន្ថែមសទ្ទរូបចូលទៅត្រូវជារូប ១៣ យ៉ាង តាំងឡើងអំពីឧតុឈ្មោះថា **ឧតុជរូប** ។ រូបដ៏សេសគប្បីជ្រាបតាមគន្លង មានន័យដូចបានពោលទុកហើយ កម្មជតិកៈនោះឯង ។

# វិសុទ្ធិមគ្គ

## រូប ៤

រូបទាំងពួងនោះចែកជារូប ៤ យ៉ាង ដោយអំណាចនៃទិដ្ឋាទិចតុក្កៈ ( រូប ៤ មានទិដ្ឋរូបជាដើម ) រូបរូបាទិចតុក្កៈ ( រូប ៤ មានរូបរូបជាដើម ) និងវត្ថាទិចតុក្កៈ ( រូប ៤ មានវត្ថុរូបជាដើម ) ។

លំដាប់ដំបូង រូបជា ៤ យ៉ាង ដោយអំណាចនៃទិដ្ឋាទិចតុក្កៈ គប្បីជ្រាបដូច្នេះគឺ

ក្នុងរូបទាំងនោះ រូបាយតនៈ ឈ្មោះទិដ្ឋរូប ព្រោះជាវិស័យនៃការឃើញ សទ្ទាយតនៈ ឈ្មោះសុតរូប ព្រោះជាវិស័យនៃការបានឮ អាយតនៈ ៣ គឺគន្ធៈ រស ផោដ្ឋព្វៈ ឈ្មោះមុតរូប ព្រោះជាវិស័យនៃឥន្ទ្រិយដែលទទួលអារម្មណ៍ ចូលដល់ រូបដ៏សេសឈ្មោះវិញ្ញាតរូប ព្រោះជាវិស័យនៃមនោវិញ្ញាណប៉ុណ្ណោះ ។

រូបចែកជា ៤ ដោយអំណាចនៃរូបរូបាទិចតុក្កៈគប្បីជ្រាបដូច្នេះ គឺក្នុងរូបទាំងនេះ រូបដែលហៅថា និប្ផន្នរូប ឈ្មោះរូបរូប ( រូបពិត ) អាកាសធាតុ ឈ្មោះ បរិច្ឆេទរូប រូបមានកាយវិញ្ញត្តិជាដើម មានកម្មញ្ញតាជាទីបំផុត ឈ្មោះថា វិការរូប ការកើត ការចាស់ និងការបែកធ្លាយ ឈ្មោះថា លក្ខណរូប ។

រូបចែកជា ៤ ដោយអំណាចនៃវត្ថាទិចតុក្កៈ គប្បីជ្រាបដូច្នេះ គឺក្នុងរូបទាំងនេះ រូបណាឈ្មោះហទយរូប រូបនោះជាវត្ថុរូប ព្រោះជាទីអាស្រ័យនៃមនោធាតុ និង មនោវិញ្ញាណធាតុ មិនជាទ្វាររូប វិញ្ញត្តិរូបទាំង ២ ជាទ្វាររូប មិនជាវត្ថុរូប បសាទរូប ជាវត្ថុរូបផង និងជាទ្វាររូបផង រូបដ៏សេសមិនជាវត្ថុរូប ទាំងមិនជាទ្វាររូប ។

រូបចែកជា ៤ យ៉ាង ដោយអំណាចនៃវត្ថាទិចតុក្ករូបដូចពោលមក ដូច្នេះ ។

# មហាដីកា

សព្វថា **ចតុក្ក** ចូលតែមួយបទថា **ទិដ្ឋាទិចតុក្កវសេន រូបរូបាទិចតុក្កវសេន វត្តាទិចតុក្កវសេន** ។ ចក្ខុបានឃើញរូបាយតនៈណា កំពុងឃើញរូបាយតនៈណា និងឃើញរូបាយតនៈណា គប្បីឃើញរូបាយតនៈណា រូបាយតនៈទាំងអស់នោះ ឈ្មោះថា **ទិដ្ឋំ** ព្រោះមិនប្រព្រឹត្តទៅកន្លងសភាពដែលត្រូវឃើញបាន ដូចពាក្យថា **ទុទ្ធំ** ប្រែថា ទឹកដោះ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។ បទថា **ទស្សនវិសយត្តា** សេចក្តីថា ព្រោះធម្មជាតិដែលចក្ខុវិញ្ញាណគប្បីដឹង ។ បទថា **សវនវិសយត្តា** សេចក្តីថា ព្រោះជាធម្មជាតិដែលសោតវិញ្ញាណគប្បីដឹង ។ បទថា **គន្ធរសផោដ្ឋព្វត្តយំ** សេចក្តីថា អាយតនៈទាំង ៣ នេះ គឺក្លិន រស ផោដ្ឋព្វៈ ។ ឈ្មោះថា **មុតរូប** ព្រោះជាធម៌ដែលគប្បីដឹង គឺជ្រាបហើយកាន់យក ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះជាវិស័យនៃឥន្ទ្រិយដែលទទួលអារម្មណ៍ដែលមកដល់បាន** ។

សួរថា ដែលឈ្មោះថា ផោដ្ឋព្វៈនេះ គឺអ្វី ? គឺធាតុ ៣ បានដល់ បឋវី តេជោ វាយោ ។ សួរបន្តទៀតថា ហេតុអ្វី ទើបលោកមិនកាន់យកអាបោធាតុទុកក្នុងផោដ្ឋព្វៈនេះផង ភាពត្រជាក់ក៏ប៉ះពាល់បានមិនមែនឬ ហើយភាពត្រជាក់នោះ ក៏គឺអាបោធាតុមិនមែនឬ ? ប៉ះពាល់បានពិត តែភាពត្រជាក់នោះមិនមែនអាបោធាតុ ។ សួរថា ជាធាតុអ្វីវិញ ? ឆ្លើយថា ជាតេជោធាតុនោះឯង ព្រោះកាលភាពក្តៅថយចុះ ក៏នឹងដឹងថា ត្រជាក់ ។ ព្រោះឈ្មោះថា ភាពត្រជាក់មិនមានគុណអ្វីឡើយ តែព្រោះភាពក្តៅថយចុះ ទើបដឹងថា ត្រជាក់តែម្យ៉ាង ។ ប្រសិនបើមានពាក្យសួរថា សេចក្តីនេះនឹង

គប្បីដឹងបានដូចម្តេច ? ដឹងបានព្រោះការដឹងថា ត្រជាក់មិនតាំងមាំនៅបាន ដូចជាត្រើយ (ប្រាំង) នាយ និងត្រើយអាយ ។ ពិតយ៉ាងនោះ បុគ្គលដែលស្ថិតនៅកណ្តាលថ្ងៃ ក្នុងរដូវក្តៅ ពេលចូលទៅកាន់ម្លប់ ក៏រមែងមានអារម្មណ៍ថាត្រជាក់ តែកាលក្រោកឡើងចេញអំពីបន្ទប់ដែលធ្វើដោយដី ធ្វើដំណើរទៅក្នុងកណ្តាលថ្ងៃនោះឯង ក៏នឹងមានភាពដឹងខ្លួនថា ក្តៅ ។ បើភាពត្រជាក់នឹងគប្បីជាអាបោធាតុសោត ក៏មិនគប្បីបានព្រមជាមួយភាពក្តៅ ក្នុងកលាបៈតែមួយដូច្នោះឡើយ ។ ព្រោះដូច្នោះ គប្បីដឹងបានថា ភាពត្រជាក់មិនមែនអាបោធាតុ ។ ការនេះ ជាពាក្យពោលឆ្លើយរបស់អាចារ្យទាំងឡាយដែលប្រាថ្នាភាព ដែលភូតរូបទាំងឡាយ មានការប្រព្រឹត្តទៅដោយអវិនិព្ភោគរូប ចំណែកអាចារ្យទាំងឡាយមិនប្រាថ្នា ក៏មានពាក្យវិសជ្ជនាដូចតែគ្នា ក្នុងកាលយល់ភាពដែលភូតរូប ទាំង ៤ មានការប្រព្រឹត្តទៅសមស្មួនគ្នា ដោយសម្តែងដល់កិច្ចក្នុងកលាបៈជាមួយគ្នា ។ ចំណែកអាចារ្យពួកណាពោលថា ភាពត្រជាក់ជាលក្ខណៈរបស់វាយោធាតុ អាចារ្យទាំងនោះ ក៏មានពាក្យវិសជ្ជនានេះដូចគ្នា ។ ព្រោះវាយោធាតុនឹងជាភាពត្រជាក់ ភាពត្រជាក់ក៏នឹងបានព្រមជាមួយភាពក្តៅក្នុងកលាបៈជាមួយគ្នាដូច្នោះក៏ទេ ។ ព្រោះដូច្នោះ ទើបដឹងបានថា ភាពត្រជាក់មិនមែនជាវាយោធាតុ ។ ចំណែកអាចារ្យពួកណាមានការឃើញថា ភាពរាវជាអាបោធាតុ ហើយភាពរាវនោះក៏ប៉ះពាល់ឯងបាន ។ អាចារ្យពួកនោះគួរនឹងត្រូវជំទាស់ថា ត្រឹមតែការយល់របស់ពួកលោកដែលពោលថាប៉ះពាល់ ការរាវបាន ក៏ដូចជាការយល់ថា អញប៉ះពាល់សណ្ឋានបាន ។ សេចក្តីនេះសមដូចពាក្យដែលបុរាណាចារ្យពោលទុកថា

សត្វលោកកាលប៉ះពាល់ភូតរូប ៣ ដែលមានការប្រព្រឹត្តទៅព្រមជាមួយភាព
រាវ រមែងយល់ថា យើងប៉ះពាល់ភាពរាវ បណ្ឌិតគប្បីជ្រាបភាពជារបស់រាវ ដូចគ្នានឹង
បុគ្គល កាលប៉ះពាល់ភូតរូប រមែងទាញយកសណ្ឋានទ្រង់ទ្រាយ ដោយនឹកក្នុងចិត្តថា
យើងពាល់ត្រូវដោយប្រចក្ស ដូច្នេះ ។

បទថា **សេសំ** បានដល់រូប២១ដ៏សេសវៀររូប៧មានរូបតាមដែល
ពោលទុកហើយជាដើម ។ បទថា **វិញ្ញាណសេវ្វ** ប្រែថា នៃមនោវិញ្ញាណនោះឯង ។
ដោយអវធារណៈ លោកអាចារ្យសម្តែងភាពមិនមានការលាយឡំគ្នាថា ក្នុងកាល
រូបាយតនៈជាដើម ដែលមនោវិញ្ញាណនឹងគប្បីដឹងបាន ក៏ឈ្មោះថា ជាវិញ្ញត្តិរូបក៏ទេ
ព្រោះមិនមានការនិយម ។

ពាក្យថា **និប្ផន្នរូបំ បនេត្ថ រូបរូបំ នាម** សេចក្តីថា ក្នុងបណ្តារូប ២៨ យ៉ាងនេះ
រូប គឺនិប្ផន្នរូបនោះឯង ឈ្មោះថា រូប ព្រោះប្រកបដោយលក្ខណៈនៃរូប ។ការប្រែប្រួល
ឈ្មោះថា រូប ធម្មជាតិឈ្មោះថា រូប ដោយអត្ថថា មានការប្រែប្រួលនោះ ដូចស័ព្ទ
ថា **អរិសេហ្វា** ប្រែថា បុគ្គលមានរោគឫសដូងបាត ម្យ៉ាងទៀត ឈ្មោះថា រូប ព្រោះ
ប្រកបដោយគុណរបស់រូប ដូចសំពត់ ឈ្មោះថា **នីលំ** ប្រែថា ពណ៌ខៀវ ព្រោះ
ប្រកបដោយគុណ គឺពណ៌ខៀវដូច្នេះ ។ លោកហៅថា **រូបរូប** ឲ្យផ្សេងគ្នាដោយរូប
ស័ព្ទ មួយស័ព្ទទៀត ព្រោះរូបស័ព្ទនេះ រមែងប្រព្រឹត្តទៅក្នុងសភាវៈដែលមិនមែន
មានរូបនោះបាន ដែលជាស័ព្ទជាប់មាត់ ដូចពាក្យថា **តិលតេលំ** ប្រែថា ប្រេងល្ង
និងពាក្យថា **ទុក្ខទុក្ខំ** ប្រែថា ទុក្ខពិតៗ សេចក្តីថា រូបមានការប្រែប្រួលជាសភាវៈ ។

សួរថា បើយ៉ាងនោះ អាកាសធាតុជាដើម នឹងជារូបបានដូចម្ដេច ? ឆ្លើយថា ហៅថា ជារូបដូចគ្នា ព្រោះមានគតិរបស់រូបនោះឯង ព្រោះនិប្ផន្នរូប ជាបរិច្ឆេទរូប ជាវិការរូប និងជាលក្ខណរូប ។

ឈ្មោះថា វត្ថុ ដោយអត្ថថា ជាទីនៅ គឺជាទីប្រព្រឹត្តទៅរបស់ចិត្ត និងចេតសិក បានដល់ រូបដែលជាទីទ្រទ្រង់របស់ចិត្ត និងធម៌ ដែលសម្បយុត្តជាមួយនឹងចិត្តនោះ ។ រូបនោះមាន ៦ យ៉ាង ក្នុងបណ្ដារូប ៦ យ៉ាងនោះ ហទយរូបជាវត្ថុម្យ៉ាង ព្រោះភាវៈ ដែលជាទីអាស្រ័យរបស់មនោធាតុ និងមនោវិញ្ញាណធាតុ ។ មិនបានជាទ្វារ ដូចចក្ខុរូប ជាដើម បណ្ដារូបដែលជាទីអាស្រ័យយ៉ាងដទៃ ។ ដូចជាចក្ខុជាដើម រមែងជាទ្វារនៃ ការប្រព្រឹត្តទៅរបស់វីថិចិត្ត មានសម្បដិច្ឆន្នៈជាដើម យ៉ាងណា ហទយវត្ថុ នឹងជា ដូច្នោះក៏ទេ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ក្នុងបណ្ដារូបទាំងនេះ រូបណាឈ្មោះថា ហទយរូប រូបនោះជាវត្ថុ មិនមែនជាទ្វារ ។ វិញ្ញត្តិរូបទាំង ២** ឈ្មោះថា **ជាទ្វារ** ព្រោះជាទ្វារនៃកម្ម ។ **មិនបានឈ្មោះថាជាវត្ថុ** ព្រោះមិនមាន ចិត្តុប្បាទដែលអាស្រ័យវិញ្ញត្តិរូបទាំង ២ នោះ ។ **បសាទរូបទាំងជាវត្ថុ** នៃចក្ខុវិញ្ញាណ ជាដើម ដែលអាស្រ័យខ្លួន **ទាំងជាទ្វារ** នៃវីថិចិត្ត មានសម្បដិច្ឆន្នៈជាដើម ដែល អាស្រ័យរូបដទៃ ។ **រូបដ៏សេស** បានដល់ រូប ២១ **មិនបានជាវត្ថុ និងមិនបានជា ទ្វារផងដែរ** ដោយបរិយាយផ្សេងអំពីដែលពោលហើយ ។

# វិសុទ្ធិមគ្គ

## រូប៥

រូបទាំងពួងនោះចែកជា ៥ ទៀត ដោយអំណាចនៃរូបទាំងនេះ គឺ **ឯកជរូប** ( រូបកើតអំពីបច្ច័យ ១ ) **ទ្វិជរូប** ( រូបកើតអំពីបច្ច័យ ២) **តិជរូប** ( រូបកើតអំពីបច្ច័យ ៣) **ចតុជរូប** ( រូបកើតអំពីបច្ច័យ ៤ ) **នកុតោចិជាតរូប** ( រូបដែលមិនបានកើតអំពីបច្ច័យណាមួយឡើយ ) ។

ក្នុងរូប ៥ យ៉ាងនោះ រូបដែលកើតអំពីកម្មតែម្យ៉ាង និងរូបដែលកើតអំពីចិត្តតែម្យ៉ាង ឈ្មោះថា ឯកជរូប ។ ក្នុងរូបដែលកើតអំពីកម្ម និងរូបដែលកើតអំពីចិត្តនោះ ឥន្ទ្រិយរូប និងហទយវត្ថុជារូបដែលកើតអំពីកម្មតែម្យ៉ាង វិញ្ញត្តិរូបទាំង ២ ជារូបដែលកើតអំពីចិត្តតែម្យ៉ាង ។

ចំណែករូបណាកើតអំពីចិត្តក៏មាន អំពីឧតុក៏មាន រូបនោះឈ្មោះថា ទ្វិជរូប ទ្វិជរូបនោះ បានដល់ សទ្ទាយតនៈតែម្យ៉ាង ។

រូបណាដែលកើតអំពីឧតុ ចិត្ត និងអាហារ រូបនោះឈ្មោះតិជរូប ឯតិជរូបនោះបានដល់ វិការរូប ៣ មានលហុតាជាដើមនោះឯង ។

រូបណាកើតអំពីបច្ច័យទាំង ៤ មានកម្មជាដើម រូបនោះឈ្មោះចតុជរូប ចតុជរូបនោះក៏បានដល់ រូបដ៏សេស វៀរលក្ខណរូប ( គឺជាតិ ជរា ភង្គៈ ឬមរណៈ ) ។

ចំណែកលក្ខណរូប ជានកុតោចិជាតរូប ព្រោះហេតុអ្វី ព្រោះការកើតនៃការកើតមិនមាន និង ២ ទៀតក៏គ្រាន់តែភាពចាស់នៃរូបដែលកើតហើយ

សូម្បីជាតិកើតអំពីបច្ច័យណា ដែលលោករចនាទុកក្នុងបាលីថា ធម៌ទាំងឡាយ គឺ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សឧបចយ រូបស្ស-សន្តតិ កពឡិង្ការាហារទាំងនេះ មានចិត្តជាសមុដ្ឋាន ដូច្នេះជាដើម គប្បីជ្រាបថា ( ដែលលោកអនុលោមឲ្យ ) ព្រោះជនកប្បច្ច័យនៃរូបទាំងឡាយ ប្រាកដក្នុងលក្ខណៈ គឺអានុភាពនៃកិច្ច ។

នេះជាកថាមុខយ៉ាងពិស្តារក្នុងរូបក្ខន្ធជាលំដាប់ដំបូង ។

# មហាដីកា

រូបដែលកើតអំពីបច្ច័យតែម្យ៉ាងប៉ុណ្ណោះ ឈ្មោះថា **ឯកជរូប** ។ សួរថា ធម៌ដែលកើតអំពីបច្ច័យ កើតឡើងអំពីបច្ច័យម្យ៉ាងប៉ុណ្ណោះមិនមាន មិនមែនឬ ? ឆ្លើយថា ពិត មិនមាន បំណងក្នុងសេចក្តីនេះមានដូច្នេះថា កើតអំពីបច្ច័យតែម្យ៉ាង ក្នុងបណ្តាបច្ច័យដែលធ្វើឲ្យរូបទាំងឡាយកើត ។ ព្រោះការកើតឡើងរបស់រូប រមែងសម្រឹងបច្ច័យដទៃ អំពីបច្ច័យដែលធ្វើឲ្យរូបកើតក៏ទេ ។ សូម្បីក្នុងបទថា **ទ្វិជរូប** ជាដើម ក៏មានន័យដូចនេះឯង ។ បទថា **ឥមេសំ** ប្រែថា ដោយអំណាចនៃប្រភេទទាំងនេះ។ បទថា **កម្មជមេវ** ប្រែថា កើតអំពីកម្មនោះឯង ។ សូម្បីក្នុងបទថា **ចិត្តជមេវ** ក៏មានន័យដូចនេះឯង ។ ពាក្យថា ដែលកើតអំពីចិត្ត និងអំពីឧតុ គប្បីឃើញរូបដែលកើតអំពីចិត្ត និងអំពីឧតុយ៉ាងនេះ គឺគ្រាខ្លះកើតអំពីចិត្ត គ្រាខ្លះ កើតអំពីឧតុ ។ រូបនោះឈ្មោះថា **ទ្វិជ** ប្រែថា កើតអំពីបច្ច័យ ២ ដូច្នេះ ។ សូម្បីរូប ២ ទៀតខាងមុខក៏មានន័យនេះដូចគ្នា ។ ក្នុងពាក្យថា គឺ **សទ្ទាយតនៈនោះឯង** នេះ អាចារ្យពួកមួយពោលថា រូបណាកើតអំពីចិត្តជាសទ្ទាយតនៈ ។ រូបនោះប្រកបដោយវិញ្ញត្តិតែម្យ៉ាង ។ បុរាណាចារ្យទាំងឡាយពោលទុកថា សំឡេងដែលកើត ដោយការផ្សាយទៅនៃវិតក្កសូម្បីមិនមានវិញ្ញត្តិក៏មាន ។

សេចក្តីពិត សំឡេងដែលមានចិត្តជាសមុដ្ឋាន សូម្បីវៀរចាកវិញ្ញត្តិក៏កើតឡើងបាន គួរនឹងប្រាថ្នាដោយអាស្រ័យវាទៈរបស់មហាអដ្ឋកថា ដែលប្រព្រឹត្តទៅ ហើយយ៉ាងនេះថា សំឡេងដែលកើតដោយការផ្សាយទៅនៃវិតក្ក មិនមែនសំឡេង ដែលគប្បីដឹងបានតាមត្រចៀក ព្រោះថា វិញ្ញត្តិរមែងកើតឡើងព្រមនឹងសំឡេង ដែលមិនគប្បីដឹងបានតាមត្រចៀក ដោយមានពាក្យថា **កាយវាចាយ វិញ្ញត្តិ** ប្រែថា កាយ

វិញ្ញត្តិ វាចាវិញ្ញត្តិ ដូច្នេះមិនមាន កាលបើដូច្នោះ សូម្បីរូបដែលកើតអំពីចិត្ត ត្រូវជាសទ្ទនវករូប ។ ព្រះសង្គីតិកាចារ្យទាំងឡាយដែលយល់ថា ពាក្យថា សំឡេងរមែងកើតមាន នឹងមិនមែនគប្បីដឹងដោយសោតៈនេះខុស បានជំទាស់វាចានោះទុកហើយ ។ ចំណែកអាចារ្យមួយពួកទៀត មិនបានជំទាស់វាទៈក្នុងមហាអដ្ឋកថាដែលពណ៌នាភាពបំណងនៃវាទៈ ក្នុងមហាអដ្ឋកថានោះ ។ ពណ៌នាទុកដូចម្តេច ពណ៌នាទុកថា សំឡេងដែលកើតអំពីការផ្សាយទៅនៃវិតក្ក គប្បីដឹងមិនបានតាមសោតៈ ដោយបំណងនេះក្នុងព្រះសូត្រថា បានស្តាប់សំឡេងល្អិត ដែលមានការញ័ររបស់អណ្តាត និងពិតានជាខាងដើម ដែលតាំងឡើងដោយវិតក្ក កើតរួមនឹងវិញ្ញត្តិនោះឯង តាមទិព្វសោត ហើយមកសម្តែងអាងដូច្នេះ និងក្នុងគម្ពីរបដ្ឋានក៏ទ្រង់សំដៅដល់សំឡេង ដែលគ្រោតគ្រាតហើយត្រាស់ថា ជាអារម្មណប្បច្ច័យដល់សោតវិញ្ញាណ ។ **តំ យោគ ចតុជ្ជំ** ។ លោកពោលដល់អាកាសធាតុ និងអវិនិព្ភោគរូបថា **ជារូបដ៏សេស** ។

ពាក្យថា **ចំណែកលក្ខណរូបជានកុលតោចិជាតរូប** សេចក្តីថា មិនកើតអំពីបច្ច័យសូម្បីណាមួយឡើយ ទាំងមិនកើតឯងផង ព្រោះរូបទាំងអស់ដែលវៀរចាកបច្ច័យទាំងឡាយ នឹងកើតឯងតែម្យ៉ាងមិនមាន ដោយប្រការទាំងពួង ។ សួរថា ពាក្យថាលក្ខណរូបមិនកើតនេះ គប្បីដឹងបានដូចម្តេច ? ឆ្លើយថា គប្បីដឹងបាន ព្រោះមិនមានលក្ខណៈ ។ ពិតណាស់ ធម៌ទាំងឡាយមានរូបាយតនៈជាដើម ដែលមានការកើត រមែងមានលក្ខណរូបទាំងឡាយ មានជាតរូបជាដើម ជាតរូបជាដើមនឹងមានលក្ខណៈ យ៉ាងនេះក៏ទេ ។ ព្រោះដូច្នោះ គួរជ្រាបយ៉ាងនេះថា ជាតិរូបជាដើមមិនកើត ។ ចំណែកពាក្យថា ធម៌ទាំងឡាយមានជាតិរូបជាដើម នឹងមានលក្ខណរូបមានជាតិរូបជាដើម ដូច្នេះគប្បីមានឬ ? ពាក្យនោះមិនមាន ព្រោះហេតុអ្វី ព្រោះកាលបើដូច្នោះ ក៏នឹងដល់នូវភាពមិនពិតប្រាកដ ។ បើជាតិរូបជាដើមនឹងគប្បីមាន

ការកើតជាដើមសោត សូម្បីការកើតនោះក៏នឹងមានការកើតជាដើម សូម្បីការកើតជាដើមនោះ ក៏នឹងមានការកើតជាដើមនោះ ព្រោះហេតុនោះ ទើបដល់នូវភាពមិនពិតប្រាកដតែម្យ៉ាង ។ ព្រោះដូច្នោះ ពាក្យថា ជាតិរូបជាដើមមិនកើតដូច្នេះ លោកពោលទុកល្អហើយ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះការកើតនៃការកើតមិនមាន និង ២ ទៀតក្រៅពីនេះ ក៏គ្រាន់តែជាភាពផ្អិនទៅ និងបែកទៅរបស់រូបដែលកើតឡើងហើយ** ដោយអត្ថថា មានការចាស់ និងការស្លាប់ ។

ក្នុងបទទាំងនោះ ដោយបទថា **មានការកើតក៏ទេ** នេះ លោកអាចារ្យពោលថា ការមិនមានជរា និងមរណៈរបស់ការកើតឡើង ។ **កាលមិនមានការកើត ជរា និងមរណៈនឹងមានអំពីណា** ព្រោះដូច្នោះ ទើបលោកពោលថាការមិនមាននៃការកើតរបស់ជរា និងមរណៈ ដោយ **មត្ត-ស័ព្ទ** ។ លោកអាចារ្យពោលពាក្យថា **យម្បិ** ជាដើម ដើម្បីនឹងចៀសវាងពាក្យសួរថា បើយ៉ាងនោះ ការពោលថា ជាតរូបជាកុតោចិជាតិរូបបានដូចម្តេច ?

ក្នុងបណ្តាបទទាំងនោះ បទថា **ព្រោះប្រាកដក្នុងខណៈអានុភាពនៃចិត្ត** សេចក្តីថា ការដែលជាតរូបជាធម៌កើតអំពីបច្ច័យណាមួយ ព្រះសម្ពុទ្ធទ្រង់រមែងសម្តែងទុកក្នុងព្រះបាលីដូចគ្នានឹងរូបទាំងឡាយ មានវិញ្ញត្តិរូបជាដើម ជាធម៌ដែលមានចិត្ត ជាសមុដ្ឋានជាដើម ដោយអំណាចវេនេយ្យសត្វ ទ្រង់សំដៅដល់ធម៌ទាំងឡាយ មានចិត្តជាដើមជាជនកបច្ច័យរបស់រូបទាំងឡាយ មានរូបាយតនៈជាដើម ដែលមានការខ្នះខ្នែងរបស់ធម៌នោះតាមទៅខាងក្រោយ ព្រោះញ៉ាំងរូបទាំងនោះឲ្យកើតឡើងជាធម៌ដែលនឹងបានដោយការៈប្រែប្រួលរបស់ធម៌ទាំងឡាយមានរូបាយតនៈជាដើមដែលកើតឡើងនៅក្នុងខណៈអានុភាពនៃកិច្ច ដែលនឹងគប្បីចូលទៅកំណត់ភាពជាបច្ច័យនោះ ។ អធិការនេះមានសេចក្តីសង្ខេបដូចទៅនេះថា

ធម៌ទាំងឡាយ មានរូបជាដើម ដែលនឹងគប្បីកើតឡើងដោយបច្ច័យធម៌ពួកណា រូបជាដើមដែលបាននៅក្នុងខណៈ ចូលដល់ភាពជាបច្ច័យរបស់ធម៌ទាំងឡាយនោះ រមែងដឹងបានថា កើតឡើងមុននោះ និងដែលមិនបាននៅក្នុងខាងក្រោយ ក៏រមែងដឹងបានថា កើតឡើង តអំពីនោះ សូម្បីជាតិរូបក៏គប្បីដឹងយ៉ាងនេះ ។ សួរថា បើដូច្នោះ ភាពដែលជាតិរូបជាធម៌ ដែលកើតអំពីបច្ច័យណាមួយ ក៏សម្រេចហើយ ដោយនិប្បរិយាយ បើដូច្នោះ ព្រោះហេតុអ្វី ទើបលោកពោលថា ដោយអំណាចរបស់វេនេយ្យបុគ្គលទៅវិញ ? ឆ្លើយថា សេចក្ដីនេះមិនគួរឃើញយ៉ាងនោះ ព្រោះជារូបដែលបានដោយភាវៈដែលជាភាពប្រែប្រួលរបស់ធម៌ដែលកំពុងកើត ។ បើជាតិរូបនឹងគប្បីបានដូចជាធម៌ដែលកំពុងកើត ភាពដែលជាតិរូបជាធម៌ដែលកើតអំពីបច្ច័យណាមួយ ក៏ជានិប្បរិយាយនោះឯង តែមិនមែនដូច្នោះឡើយ ដោយពិត បានដោយភាវៈជាភាពប្រែប្រួល ។ ព្រោះដូច្នោះ ទើបលោកពោលថា **ដោយអំណាចនៃវេនេយ្យ-បុគ្គល** ។

បានឮថា ក្នុងវេលានោះអ្នកសិក្សាទាំងឡាយកើតការយល់ថា ជាតិរូបនេះជាតួកើតមុនរបស់សព្វវត្ថុទាំងឡាយ និងខ្លួនឯង ក៏មិនបានកើតអំពីបច្ច័យណាមួយ ដូចគ្នានឹងការប្រព្រឹត្តរបស់ពួកលទ្ធិបកតិវាទ ដូច្នោះ ដោយហេតុនោះ ព្រះសាស្ដាកាលទ្រង់កម្ចាត់ការប្រកាន់ខុសរបស់អ្នកសិក្សាទាំងនោះ ទើបទ្រង់សម្ដែងជាតិរូបចែកជា ២ ប្រភេទ គឺឧបចយ ១ សន្តតិ ១ និងធ្វើឲ្យជាធម៌ដែលកើតអំពីបច្ច័យណាមួយផង ចំណែកជរា និងមរណៈ ទ្រង់មិនបានសម្ដែងទុក ព្រោះបច្ច័យធម៌ទាំងឡាយមិនប្រាកដក្នុងខណៈអានុភាពនៃកិច្ច ។ បើដូច្នោះព្រះមានជោគត្រាស់ទុកក្នុងព្រះសូត្រ ដោយបរិយាយថា ជរា និងមរណៈអាស្រ័យគ្នាកើតឡើងបាន ដូច្នេះ ព្រោះហេតុអ្វី ? ត្រាស់ទុកក្នុងព្រះសូត្រ ដោយបរិយាយថា ជរា និងមរណៈអាស្រ័យគ្នានឹងគ្នាកើត

ឡើងបាន ដូច្នេះ ទ្រង់សំដៅដល់កាលដែលជរា និងមរណៈជាធម្មជាតិ ដែលមានជាតិជាបច្ច័យនោះ ព្រោះកាលធម៌ដែលជាបច្ច័យទាំងនោះមាន ជរា និងមរណៈទើបមាន ព្រោះថាធម៌ដែលអាស្រ័យគ្នានឹងគ្នាកើតឡើងទាំងឡាយជាសភាវៈ ដែលផ្អិន(ជរា) នឹងបែកធ្លាយទៅកាលធម៌ជាបច្ច័យទាំងនោះ មិនមានជរានិងមរណៈ ក៏មិនមាន ។ ព្រោះថា ធម្មជាតិដែលមិនកើត មិនផ្អិន ឬបែកធ្លាយទៅមិនមាន ។ ប្រភេទនៃការប្រព្រឹត្តទៅរបស់រូបធម៌ទាំងឡាយក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាល ដោយការចែកកំណើត ដោយបច្ច័យ មានកម្មជាដើម ក្នុងភពទាំងឡាយ មានកាមភពជាដើម ដែលគួរនឹងពោលក្នុងអធិការនេះ គប្បីឃើញថា លោកអាចារ្យមិនបានពោលទុក ព្រោះមានចែងច្បាស់ក្នុងបដិច្ចសមុប្បាទកថាខាងមុខ ។

ពណ៌នាកថាមុខដោយពិស្តារក្នុងរូបក្ខន្ធ ដោយប្រការដូច្នេះ ។

# វិសុទ្ធិមគ្គ

## ខន្ធ ៤

ឯក្នុងខន្ធក្រៅពីនេះ វេទនាខន្ធ គប្បីជ្រាបថា ( ដែលហៅយ៉ាងនោះ ) ព្រោះរួមធម្មជាតិដែលមានការសោយ ( រសអារម្មណ៍ ) ជាលក្ខណៈ គ្រប់យ៉ាងបញ្ចូលគ្នា សញ្ញាខន្ធ... ព្រោះរួមធម្មជាតិ ដែលមានការចាំជាលក្ខណៈគ្រប់យ៉ាងបញ្ចូលគ្នា សង្ខារក្ខន្ធ... ព្រោះរួមធម្មជាតិដែលមានការផ្សំគ្នា ( ចេតសិក ) ជាលក្ខណៈបញ្ចូលគ្នា វិញ្ញាណក្ខន្ធ... ព្រោះរួមធម្មជាតិដែលមានការដឹងច្បាស់ ( ដឹងក្នុងទ្វារទាំង ៦ ) ជាលក្ខណៈគ្រប់យ៉ាងបញ្ចូលគ្នា ។

ក្នុងខន្ធទាំង ៤ នោះ ព្រោះហេតុដែលវិញ្ញាណក្ខន្ធ កាលដែលបុគ្គលយល់ហើយ ខន្ធក្រៅពីនេះ ក៏ជាវត្ថុដែលគប្បីយល់បានដោយងាយដែរ ព្រោះហេតុនោះ ទើបខ្ញុំធ្វើការពណ៌នាចាប់ផ្តើមពីវិញ្ញាណក្ខន្ធជាដើមតទៅ ។

## វិញ្ញាណក្ខន្ធ

ពាក្យថា វិញ្ញាណក្ខន្ធ គប្បីជ្រាបថា ( ហៅយ៉ាងនោះ ) ព្រោះរួមធម្មជាតិដែលមានការដឹងច្បាស់ជាលក្ខណៈគ្រប់យ៉ាងបញ្ចូលគ្នា ដូច្នេះ ខ្ញុំពោលទុកហើយ សួរថា ធម្មជាតិដែលមានការដឹងច្បាស់ជាលក្ខណៈឈ្មោះថា វិញ្ញាណដូចម្តេច ? ឆ្លើយថា ធម្មជាតិដែលមានការដឹងច្បាស់ជាលក្ខណៈ ឈ្មោះថា វិញ្ញាណ ដូចព្រះសារីបុត្តត្ថេរពោលដល់ព្រះមហាកោដ្ឋិតៈថា ម្នាលអាវុសោ ព្រោះហេតុដែលធម្មជាតិនោះរមែងដឹងច្បាស់ រមែងដឹងផ្សេងៗ ព្រោះហេតុនោះ ទើបហៅថា វិញ្ញាណ ដូច្នេះ ពាក្យថា វិញ្ញាណ ចិត្ត មនោ ខ្ញុំមសារក៏មានន័យតែមួយ វិញ្ញាណនោះ មានតែមួយតាមសភាវៈ

ដោយលក្ខណៈ គឺការដឹងច្បាស់ តែបើពោលដោយជាតិ មាន ៣ យ៉ាង គឺជាកុសល អកុសល និងអព្យាកតៈ ។

## កុសលវិញ្ញាណ

ក្នុងវិញ្ញាណ ៣ យ៉ាងនោះ កុសលវិញ្ញាណមាន ៤ ដោយចែកផ្សេងគ្នា ក្នុងភូមិ គឺកាមាវចរៈ រូបាវចរៈ អរូបាវចរៈ និងលោកុត្តរ ក្នុងភូមិ ៤ នោះ កាមាវចរៈមាន ៨ ដោយប្រភេទនៃសោមនស្ស ឧបេក្ខា ញាណ និងសង្ខារ កាមាវចរវិញ្ញាណ ៨ នេះ គឺអ្វីខ្លះ គឺវិញ្ញាណសោមនស្សសហគតញាណសម្បយុត្ត ជាអសង្ខារិក ១ ជាសសង្ខារិក ១ ដែលជាញាណវិប្បយុត្តក៏យ៉ាងនោះ ជាអសង្ខារិក ១ ជាសសង្ខារិក ១ ( រួមខាងផ្នែកសោមនស្សសហគតៈ ៤ ) វិញ្ញាណឧបេក្ខាសហគតញាណសម្បយុត្ត ជាអសង្ខារិក ១ សសង្ខារិក ១ ដែលជាញាណវិប្បយុត្ត ក៏យ៉ាងនោះ គឺជាអសង្ខារិក ១ សសង្ខារិក ១ ( រួមមានផ្នែកខាងឧបេក្ខាសហគតៈ ៤ រួមបូលគ្នាទាំង ២ ផ្នែក ទើបមាន ៨ ) ។

ក្នុងកាលណាបុគ្គលអាស្រ័យការព្រមព្រៀងនៃទេយ្យធម៌ និងបដិគ្គាហកៈជាដើម ឬហេតុនៃសោមនស្សប្រភេទដទៃ ( ដូចជាឃើញអានិសង្សក៏កើតសទ្ធាឡើងជាដើម ) ហើយជាអ្នកក្បៀវក្លាត្រេកអរ ធ្វើនូវការពេញចិត្តប្រព្រឹត្តទៅដោយន័យថា ផលទានដែលឲ្យហើយមាន ជាដើមឲ្យចេញមុខ មិនស្ទាក់ស្ទើរ បុគ្គលដទៃណាមួយក៏មិនបានដឹកនាំធ្វើ បុណ្យទាំងឡាយ មានទានជាដើម ( បានខ្លួនឯង ) ក្នុងកាលនោះចិត្តរបស់បុគ្គលនោះ ជាសោមនស្សសហគតញាណសម្បយុត្តអសង្ខារ រួមជាមួយសោមនស្សប្រកបដោយបញ្ញាមិនមានអ្នកដទៃដឹកនាំ តែថា ក្នុងកាលណាបុគ្គលជាអ្នករីករាយធ្វើនូវការយល់ត្រូវឲ្យចេញមុខដោយន័យដែលបានពោលហើយ តែថាស្ទាក់ស្ទើរដោយអំណាចនៃទោស មានអមុត្តចាគតា ការមិនដាច់ស្រឡះក្នុងការ

លះបង់ គឺមានការអាល័យក្នុងទេយ្យធម៌ជាដើមក្តី បុគ្គលដទៃអូសទាញទើបធ្វើក្តី ក្នុងកាលនោះ ចិត្តនោះរបស់បុគ្គលនោះជាសសង្ខារិក ( មានអ្នកដទៃដឹកនាំ ) ។

ឯបទថា **សង្ខារ** ក្នុងអត្ថនេះ ជាពាក្យហៅបុព្វយោគ ( ការផ្តើមធ្វើ ) ដែលប្រព្រឹត្តទៅដោយអំណាចនៃខ្លួន ឬនៃអ្នកដទៃក៏ដោយ ។

ឯក្នុងកាលណាពួកក្មេងៗ ដែលធ្លាប់បានឃើញការបដិបត្តិនៃបុគ្គលដែលជាញាតិ ជួបភិក្ខុទាំងឡាយគេក៏កើតសោមនស្ស ថ្វាយរបស់របរនៅក្នុងដៃសូម្បីបន្តិចបន្តួចក្តី ថ្វាយបង្គំក្តី ភ្លាមៗ នោះ ក្នុងកាលនោះចិត្តដួងទី ៣ ( គឺជាញាណវិប្បយុត្តអសង្ខារិក ) រមែងកើតឡើងដល់ក្មេងទាំងឡាយនោះ តែក្នុងកាលណាក្មេងទាំងឡាយនោះ ញាតិទាំងឡាយដឹកនាំប្រាប់ឲ្យថ្វាយរបស់របរឲ្យថ្វាយបង្គំ ទើបបដិបត្តិ យ៉ាងនោះបាន ក្នុងកាលនោះចិត្តដួងទី ៤ ( គឺដែលជាញាណវិប្បយុត្តសសង្ខារ ) រមែងកើតឡើងដល់ក្មេងទាំងឡាយនោះ ។

ឯក្នុងកាលណាបុគ្គលអាស្រ័យការមិនព្រមព្រៀងនៃទេយ្យធម៌ និងបដិគ្គាហកៈជាដើម ឬការមិនមាននៃហេតុរបស់សោមនស្សដទៃ ជាអ្នកប្រាសចាកសោមនស្ស ក្នុងវិកប្បទាំង ៤ ក្នុងកាលនោះ ទើបឧបេក្ខាសហគតចិត្ត ៤ ដ៏សេសកើតឡើង ។

កាមាវចរកុសលមាន ៨ ដោយប្រភេទនៃសោមនស្ស ឧបេក្ខា ញាណ និងសង្ខារ គប្បីជ្រាបតាមន័យដូចដែលពោលមក ដូច្នេះ ។

ឯរូបាវចរកុសលមាន ៥ ដោយន័យផ្សេងគ្នា នៃការប្រកបរបស់អង្គឈានរូបាវចរៈ ៥ តើដូចម្តេច ? រូបាវចរៈ ៥ គឺ ( រូបជ្ឈាន ) ទី ១ ប្រកបដោយអង្គ គឺ វិតក្ក វិចារៈ បីតិ សុខ និងសមាធិ ទី ២ វិតក្កកន្លងទៅ បន្ទាប់ពីនោះ ទី ៣ វិចារៈកន្លងទៅ បន្ទាប់ពីនោះទី ៤ បីតិកន្លងទៅ ទី ៥ សុខកន្លងទៅ ប្រកបដោយឧបេក្ខា និងសមាធិ ។

អរូបាវចកុសលមាន ៤ ដោយអំណាចការប្រកបនៃអរូប ៤ គឺថា អរូបទី ១ ប្រកបដោយអាកាសានញ្ចាយតនជ្ឈានតាមប្រការដែលពោលហើយ អរូបទី ២ ទី ៣ និងទី ៤ ក៏ប្រកបដោយឈានដ៏សេស មានវិញ្ញាណញ្ចាយតនជ្ឈានជាដើម ។

លោកុត្តរកុសលមាន ៤ ដោយប្រកបនឹងមគ្គ ៤ ។

កុសលវិញ្ញាណទាំងអស់នោះមាន ២១ យ៉ាង ដូចពោលមកដូច្នេះជាលំដាប់ដំបូង ។

## អកុសលវិញ្ញាណ

ឯអកុសលវិញ្ញាណដោយភូមិក៏តែម្យ៉ាង គឺជាកាមាវចរៈប៉ុណ្ណោះ ដោយមូលមាន ៣ គឺលោភមូល ទោសមូល និងមោហមូល ។

ក្នុងមូល ៣ នោះ លោភមូលមាន ៨ ដោយប្រភេទនៃសោមនស្ស ឧបេក្ខា ទិដ្ឋិគតៈ ( ការយល់ខុស ) និងសង្ខារលោភមូលនេះ តើដូចម្តេច ? លោភមូល ៨ គឺ ( អកុសលចិត្ត ) ជាសោមនស្សសហគតទិដ្ឋិគតសម្បយុត្ត ជាអសង្ខារ ១ ជាសសង្ខារ ១ ដែលជាទិដ្ឋិគតវិប្បយុត្តក៏យ៉ាងនោះ គឺជាអសង្ខារ ១ សសង្ខារ ១ (ផ្នែកខាងសោមនស្សសហគតៈ ៤ ) ជាឧបេក្ខាសហគតទិដ្ឋិគតសម្បយុត្តជាអសង្ខារ ១ សសង្ខារ ១ ដែលជាទិដ្ឋិគតវិប្បយុត្តក៏យ៉ាងនោះ គឺជាអសង្ខារ ១ សសង្ខារ ១ ( ផ្នែកខាងឧបេក្ខាសហគតៈ ៤ រួមទាំង ២ ផ្នែកជា ៨ ) ។

ក្នុងកាលណាបុគ្គលធ្វើការយល់ខុស ( ឲ្យប្រព្រឹត្តទៅ ) ដោយន័យថា ទោសក្នុងកាមទាំងឡាយមិនមានជាដើមឲ្យចេញមុខ ជាអ្នករីករាយបរិភោគកាមទាំងឡាយក្តី ជឿនូវមង្គលទាំងឡាយ មានទិដ្ឋមង្គល ( វត្ថុដែលបានឃើញជាមង្គល ) ជាដើម ព្រោះថា ជាសារៈក្តី មានចិត្តក្សេវក្លាដោយខ្លួនឯង មិនបានត្រូវអ្នកដទៃដឹកនាំក្តី ក្នុងកាលនោះអកុសលចិត្តដួងទី ១ ( គឺសោមនស្សសហគតទិដ្ឋិគតសម្បយុត្តអសង្ខារ

រួមជាមួយសោមនស្សប្រកបដោយការយល់ខុស មិនមានអ្នកដឹកនាំ ) រមែងកើតឡើងក្នុងកាលណា បុគ្គល... មានចិត្តខ្ជិលប្រអូស អ្នកដទៃដឹកនាំ ( ទើបធ្វើយ៉ាងនោះ ) ក្នុងកាលនោះអកុសលចិត្តដួងទី ២ រមែងកើតឡើង ។

ក្នុងកាលណា បុគ្គលមិនបានធ្វើការយល់ខុសឲ្យចេញមុខ គ្រាន់តែក្មៀវក្លាត្រេកអរសេពមេថុនក្តី សម្លឹងរំពៃប្រាថ្នាចង់បានសម្បត្តិរបស់អ្នកដទៃក្តី លួចទ្រព្យរបស់អ្នកដទៃក្តី មានចិត្តខ្លាំងក្លាដោយខ្លួនឯង មិនបានត្រូវអ្នកដទៃដឹកនាំក្តី ក្នុងកាលនោះ អកុសលចិត្តដួងទី ៣ រមែងកើតឡើង ។ ក្នុងកាលណាបុគ្គលមានចិត្តខ្ជិលប្រអូស បុគ្គលដទៃដឹកនាំ ( ទើបធ្វើយ៉ាងនោះ ) ក្នុងកាលនោះអកុសលចិត្តដួងទី ៤ រមែងកើតឡើង ។

ឯក្នុងកាលណា បុគ្គលជាអ្នកប្រាសចាកសោមនស្សក្នុងវិកប្បទាំង ៤ ព្រោះអាស្រ័យការមិនព្រមព្រៀងនៃកាមទាំងឡាយក៏ដោយ ព្រោះការមិនមាននៃហេតុរបស់សោមនស្សដទៃក៏ដោយ ក្នុងកាលនោះឧបេក្ខាសហគតចិត្ត ៤ ដួងដ៏សេសទើបកើតឡើង ។

លោភមូល ៨ ដោយប្រភេទនៃសោមនស្ស ឧបេក្ខា ទិដ្ឋិគតៈ និងសង្ខារ គប្បីជ្រាបតាមន័យដូចពោលមក ដូច្នេះ ។

ឯទោសមូលមាន ២ប៉ុណ្ណោះ គឺជាទោសសហគតបដិឃសម្បយុត្តអសង្ខារ ១ សសង្ខារ ១ ការកើតឡើងនៃទោសមូលចិត្តនោះ គប្បីជ្រាបក្នុងកាលដែលប្រព្រឹត្តទៅខ្លាំងក្លា និងការខ្ជិលប្រអូសនៃចិត្តក្នុងទោសទាំងឡាយ មានបាណាតិបាតជាដើម ។

មោហមូលក៏មាន ២ គឺជាឧបេក្ខាសហគតវិចិកិច្ឆាសម្បយុត្ត ១ ឧទ្ធច្ចសម្បយុត្ត ១ ការប្រព្រឹត្តទៅនៃមោហមូលចិត្តនោះ គប្បីជ្រាបក្នុងកាលដែលស្មាក់ស្មើរ និងរាយមាយ ( នៃចិត្ត ) ។

អកុសលវិញ្ញាណមាន ១២ តាមន័យដែលពោលមកមានដូច្នេះឯង ។

## អព្យាកតវិញ្ញាណ

អព្យាកតវិញ្ញាណ ដោយប្រភេទនៃជាតិមាន ២ គឺវិបាក ១ កិរិយា ១ ក្នុង ២ ប្រភេទនោះ វិបាកដោយភូមិមាន ៤ គឺកាមាវចរៈ រូបាវចរៈ អរូបាវចរៈ និងលោកុត្តរ ក្នុងភូមិ ៤ នោះ កាមាវចរៈមាន ២ គឺកុសលវិបាក ១ អកុសលវិបាក ១ ។

## កាមាវចរកុសលវិបាក-អហេតុកៈ

កុសលវិបាកទាំងឡាយក៏មាន ២ គឺជាអហេតុកៈ ១ សហេតុកៈ ១ ក្នុងកុសលវិបាក ២នោះ វិញ្ញាណវៀរចាកវិបាកហេតុ (ហេតុនៃវិបាក) មានអលោភៈជាដើម ឈ្មោះថា អហេតុកៈ អហេតុកៈនោះមាន ៨ គឺចក្ខុវិញ្ញាណ សោតៈ... ឃានៈ... ជិវ្ហា... កាយវិញ្ញាណ មនោធាតុដែលធ្វើសម្បដិច្ឆន្នកិច្ច (ទទួលអារម្មណ៍) និងមនោវិញ្ញាណធាតុ ២ ដែលធ្វើសន្តីរណកិច្ច ( ពិចារណាអារម្មណ៍ ) ជាដើម ។

ក្នុងអហេតុកកុសលវិបាក ៨ នោះ ចក្ខុវិញ្ញាណមានចក្ខុជាទីអាស្រ័យ ហើយដឹងច្បាស់នូវរូបជាលក្ខណៈ មានការធ្វើតែរូបម្យ៉ាងឲ្យជាអារម្មណ៍ជាកិច្ច មានភាពជាធម្មជាតិឆ្ពោះមុខចំពោះរូបជាបច្ចុប្បដ្ឋាន មានការប្រាសទៅនៃកិរិយាមនោធាតុដែលមានរូបជាអារម្មណ៍ ( ដែលហៅម្យ៉ាងទៀតថាអាវជ្ជនចិត្ត ) ជាបទដ្ឋាន ។

សោតៈ... ឃានៈ... ជិវ្ហា... កាយវិញ្ញាណមានការអាស្រ័យសោតៈជាដើម ហើយដឹងច្បាស់នូវសំឡេងជាដើមជាលក្ខណៈ មានការធ្វើតែសំឡេងជាដើមតែម្យ៉ាងឲ្យជាអារម្មណ៍ជាកិច្ច មានភាពជាធម្មជាតិបែរមុខឆ្ពោះសំឡេងជាដើមជាបច្ចុប្បដ្ឋាន មានការប្រាសទៅនៃកិរិយាមនោធាតុទាំងឡាយ ដែលមានសំឡេងជាដើមជាអារម្មណ៍ជាបទដ្ឋាន ។

មនោធាតុ មានការដឹងច្បាស់នូវអារម្មណ៍មានរូបជាដើមក្នុងលំដាប់នៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើមជាលក្ខណៈ មានការទទួលយកអារម្មណ៍ មានរូបជាដើម ជាកិច្ច មានភាពជាយ៉ាងនោះ ( គឺជាសម្បដិច្ឆនៈ ) ជាបច្ចុប្បដ្ឋាន មានការប្រាសទៅ នៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើមជាបទដ្ឋាន ។

មនោវិញ្ញាណធាតុ ដែលធ្វើសន្តីរណកិច្ចជាដើមទាំង ២ មានការដឹងច្បាស់ នូវអារម្មណ៍ ៦ ក្នុងលំដាប់នៃអហេតុកវិបាកវិញ្ញាណជាលក្ខណៈ មានការពិចារណា អារម្មណ៍ជាដើមជាកិច្ច មានភាពជាយ៉ាងនោះ ( គឺជាសន្តីរណៈជាដើម ) ជាបច្ចុប្បដ្ឋាន មានហទយវត្ថុជាបទដ្ឋាន ឯភាពផ្សេងគ្នា ( មាន ២ ) នៃមនោវិញ្ញាណធាតុនោះ ព្រោះ ប្រកបដោយសោមនស្ស ១ និងឧបេក្ខា ១ និងព្រោះបែកគ្នាជាទ្វិឋាន និងបញ្ចឋាន ពិតហើយ ក្នុងមនោវិញ្ញាណធាតុ ២ នោះ ១ ដួង ឈ្មោះថា ជាសោមនស្សសម្បយុត្ត ព្រោះមានការប្រព្រឹត្តទៅក្នុងឯកន្តឥដ្ឋារម្មណ៍ ( អារម្មណ៍ជាទីប្រាថ្នាក្រៃលែង ) ជា សភាវៈចាត់ជាទ្វិឋាន ព្រោះប្រព្រឹត្តទៅក្នុងបញ្ចទ្វារ និងក្នុងវិថីវិញ្ញាណ មានជវនជា ទីបំផុត ដោយអំណាចនៃសន្តីរណៈ និងតទាលម្ពណៈ ១ ដួង ឈ្មោះថា ជាឧបេក្ខា សម្បយុត្ត ព្រោះមានការប្រព្រឹត្តទៅក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ ( អារម្មណ៍ដែលគួរប្រាថ្នា ជាកណ្តាល)ជាសភាវៈ ចាត់ជាបញ្ចឋាន ព្រោះប្រព្រឹត្តទៅដោយអំណាចនៃសន្តីរណៈ តទាលម្ពណៈ បដិសន្ធិ ភវង្គ និងចុតិ ។

ម្យ៉ាងទៀត អហេតុកវិបាកវិញ្ញាណទាំង ៨ នេះ បែកជា ២ ព្រោះជានិយតារម្មណ៍ ( មានអារម្មណ៍ពិតប្រាកដ ) និងអនិយតារម្មណ៍ ( មានអារម្មណ៍មិនពិតប្រាកដ ) និងជា ៣ ព្រោះផ្សេងគ្នាដោយ ( ការប្រកប ) ឧបេក្ខា សុខ សោមនស្ស ពិតហើយ ក្នុងវិញ្ញាណទាំងឡាយនោះ វិញ្ញាណទាំង ៥ ( ខាងដើម ) ចាត់ជានិយតារម្មណ៍ ព្រោះប្រព្រឹត្តទៅក្នុងអារម្មណ៍ ៥ មានរូបជាដើមនោះតាមលំដាប់ វិញ្ញាណដ៏សេស

ជាអនិយតារម្មណ៍ ព្រោះក្នុងវិញ្ញាណដែលអនិយតារម្មណ៍នោះ មនោធាតុប្រព្រឹត្តទៅក្នុងអារម្មណ៍ មានរូបជាដើមទាំង ៥ មនោវិញ្ញាណធាតុទាំង ២ ប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង ៦ ឯក្នុងវិញ្ញាណដែលមាន ៣ នោះ កាយវិញ្ញាណប្រកបដោយសុខ មនោវិញ្ញាណធាតុដែលជាទ្វិហេតុប្រកបដោយសោមនស្ស វិញ្ញាណដ៏សេស ៦ ទៀតប្រកបដោយឧបេក្ខា ដូច្នេះ ។

វិញ្ញាណ ៨ ដួងជាអហេតុកៈផ្នែកខាងកុសលវិបាក គប្បីជ្រាបដោយប្រការដូចដែលបានពោលមកដូច្នេះជាលំដាប់ដំបូង ( ក្នុងអព្យាកតវិញ្ញាណកាមាវចរភូមិ ) ។

## កាមាវចរកុសលវិបាក-សហេតុកៈ

ឯអព្យាកតវិញ្ញាណ ដែលប្រកបដោយវិបាកហេតុ មានអលោភៈជាដើម ឈ្មោះថា សហេតុកៈ សហេតុកអព្យាកតៈនោះមាន ៨ ផ្សេងគ្នាដោយសម្បយុត្តធម៌មានសោមនស្សជាដើម ដូចកាមាវចរកុសលវិញ្ញាណ តែសហេតុកអព្យាកតៈនេះមិនដូចកុសលវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ ៦ ដោយអំណាចនៃបុញ្ញកិរិយាមានទានជាដើមទេ ដោយសហេតុកអព្យាកតវិញ្ញាណនេះ ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៦ ដែលទាក់ទងក្នុងបរិត្តធម៌ ( គឺកាមាវចរៈ ) ប៉ុណ្ណោះ ដោយអំណាចនៃកិច្ច គឺបដិសន្ធិ ភវង្គ ចុតិ និងតទាលម្ពណៈ ឯភាពជាសសង្ខារ និងអសង្ខារក្នុងសហេតុកអព្យាកតវិញ្ញាណនេះ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃទី.មកជាដើម ម្យ៉ាងទៀត កាលភាពផ្សេងគ្នានៃសម្បយុត្តធម៌ទាំងឡាយមិនមាន ក៏គប្បីជ្រាបថា វិបាកវិញ្ញាណ ជាធម្មជាតិមិនមាន ( ឧហ្បាហៈ ) កំពុងអួសទាញ ដូចស្រមោលមុខនៅក្នុងផ្ទៃកញ្ចក់ជាដើម ( ឯ ) អកុសលវិញ្ញាណមានឧហ្បាហៈ កំពុងអួសទាញ ដូចមុខរបស់មនុស្សទី ២ មើលស្រមោលមុខ ។

## កាមាវចរអកុសលវិបាក

ឯអកុសលវិបាកវិញ្ញាណ ជាអហេតុកៈម្យ៉ាងប៉ុណ្ណោះ អកុសលវិបាកវិញ្ញាណនោះមាន ៧ គឺចក្ខុវិញ្ញាណ សោតៈ... ឃានៈ... ជិវ្ហា... កាយវិញ្ញាណ មនោធាតុដែលធ្វើសម្បដិច្ឆន្នកិច្ច និងមនោវិញ្ញាណធាតុប្រភេទបញ្ចឋានដែលធ្វើសន្តីរណកិច្ចជាដើម អកុសលវិបាក ៧ នោះ ដោយភាពប្លែកគ្នាមានលក្ខណៈជាដើម គប្បីជ្រាបតាមន័យដែលបានពោលហើយ ក្នុងអហេតុកវិបាកផ្នែកកុសលនោះចុះ តែកុសលវិបាកវិញ្ញាណទាំងឡាយ ជាឥដ្ឋារម្មណ៍ និងឥដ្ឋមជ្ឈត្តារម្មណ៍ទាំងអស់ អកុសលវិបាកវិញ្ញាណទាំងឡាយនេះ ក៏ជាអនិដ្ឋារម្មណ៍ និងអនិដ្ឋមជ្ឈត្តារម្មណ៍ទាំងអស់ ម្យ៉ាងទៀតកុសលវិបាកទាំងឡាយនោះមាន ៣ដោយប្រភេទនៃវេទនា គឺឧបេក្ខា សុខ សោមនស្ស ។ អកុសលវិបាកទាំងឡាយនេះមាន ២ ដោយអំណាចនៃទុក្ខ និងឧបេក្ខា ក្នុងអកុសលវិបាកវិញ្ញាណនេះ កាយវិញ្ញាណប៉ុណ្ណោះជាទុក្ខសហគតៈ វិញ្ញាណដ៏សេសជាឧបេក្ខាសហគតៈ ឧបេក្ខាក្នុងអកុសលវិបាកវិញ្ញាណទាំងឡាយនោះ ក៏ជាឧបេក្ខាយ៉ាងខ្សោយមិនខ្លាំងក្លា ស្រដៀងនឹងទុក្ខ ឧបេក្ខាក្នុងផ្នែកកុសលវិបាកទាំងឡាយជាឧបេក្ខាប្រណីតតែក៏មិនខ្លាំងក្លាដូចជាសុខបានដែរ ។

កាមាវចរវិបាកវិញ្ញាណមាន ២៣ ដោយរួមអកុសលវិបាក ៧ នេះ និងកុសលវិបាក ១៦ ដែលពោលមកខាងដើមដោយប្រការដូច្នេះ ។

## រូបាវចរៈ អរូបាវចរៈ និង លោកុត្តរវិបាក

ឯរូបាវចរវិបាកវិញ្ញាណក៏មាន ៥ ដូចរូបាវចរកុសល តែរូបាវចរកុសលប្រព្រឹត្តទៅក្នុងជវនវិថីដោយសមាបត្តិ ( គឺចូលឈាន ) រូបាវចរវិបាកនេះប្រព្រឹត្តទៅក្នុងឧបត្តិ គឺចូលដល់បដិសន្ធិ ភវង្គ និងចុតិ ។

ម្យ៉ាងទៀត រូបាវចរវិបាកយ៉ាងណា សូម្បីអរូបាវចរវិបាកក៏មាន ៤ ដូច ( រូបាវចរៈ ) កុសលដូច្នោះ សូម្បីប្រភេទនៃការប្រព្រឹត្តទៅរបស់អរូបាវចរវិបាក ក៏មានន័យដូចពោលហើយក្នុងរូបាវចរវិបាកដូចគ្នា ។

លោកុត្តរវិបាក មាន ៤ ព្រោះជាផលរបស់ចិត្តដែលប្រកបដោយមគ្គ ៤ លោកុត្តរវិបាកនោះប្រព្រឹត្តទៅ ២ ផ្លូវ គឺមគ្គវិថី ១ ផលសមាបត្តិ ១ ដូច្នេះ ។

វិបាកវិញ្ញាណទាំងអស់មាន ៣៦ ក្នុងភូមិ ៤ ដូចពោលមកដូច្នេះឯង ។

## កិរិយាវិញ្ញាណ

ឯកិរិយាវិញ្ញាណ ដោយប្រភេទនៃភូមិមាន ៣ គឺកាមាវចរៈ រូបាវចរៈ អរូបាវចរៈ ក្នុងភូមិ ៣ នោះ កាមាវចរៈមាន ២ គឺអហេតុកៈ និងសហេតុកៈ ក្នុង ២ នោះ កាមាវចរកិរិយាវិញ្ញាណដែលវៀរចាកកិរិយហេតុ មានអលោភៈជាដើម ឈ្មោះថា អហេតុកៈ អហេតុកៈនោះក៏មាន ២ ដោយចែកចេញជាមនោធាតុ និងមនោវិញ្ញាណធាតុ ក្នុងអហេតុកៈ ២ នោះ មនោធាតុមានភាពជាបុរេចរ ( នាំមុខ ) នៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ហើយដឹងច្បាស់នូវអារម្មណ៍ មានរូបជាដើម ជាលក្ខណៈ មានការរំពឹងគិតជាកិច្ច មានភាពជាធម្មជាតិបែរមុខឆ្ពោះអារម្មណ៍ មានរូបជាដើមជាបច្ចុប្បដ្ឋាន មានការដាច់នៃភវង្គជាបទដ្ឋាន មនោធាតុនោះជាធម្មជាតិ ប្រកបដោយឧបេក្ខាប៉ុណ្ណោះ ។

ឯមនោវិញ្ញាណធាតុមាន ២ គឺសាធារណៈ ( ទូទៅដល់ព្រះសេក្ខៈ ព្រះអសេក្ខៈ និងបុថុជ្ជន ) ១ អសាធារណៈ ( មិនទូទៅ គឺចំពោះព្រះអសេក្ខៈ ) ១ ក្នុង ២ នោះ មនោវិញ្ញាណដែលជាសាធារណៈ គឺអហេតុកកិរិយាដែលសហគតៈជាមួយឧបេក្ខា មានការដឹងច្បាស់នូវអារម្មណ៍ ៦ ជាលក្ខណៈ មានវោដ្ឋព្វនៈ និងអាវជ្ជនៈក្នុងបញ្ចទ្វារ និងមនោទ្វារ ដោយអំណាចនៃកិច្ច ( គឺវោដ្ឋព្វនៈធ្វើកិច្ចក្នុងបញ្ចទ្វារ ចំណែក

អាវជ្ជនៈធ្វើកិច្ចក្នុងមនោទ្វារ ) ជាកិច្ច មានភាពជាដូច្នោះ ( គឺជាវោដ្ឋព្វនៈ និង អាវជ្ជនៈ ) ជាបច្ចុប្បដ្ឋាន មានការប្រែប្រួលទៅនៃអហេតុកវិបាកមនោវិញ្ញាណធាតុ ( ក្នុងវោដ្ឋព្វនកាល ) និងភវង្គ ( ក្នុងអាវជ្ជនកាល ) ណានីមួយជាបទដ្ឋាន ( ចំណែកមនោវិញ្ញាណធាតុដែលជា ) អសាធារណៈ បានដល់ អហេតុកកិរិយាដែលសហគតៈជាមួយសោមនស្ស មានការដឹងច្បាស់នូវអារម្មណ៍ ៦ ជាលក្ខណៈ មានការញុំាងភាពញញឹម ព្រោះវត្ថុទាំងឡាយដែលគ្រោតគ្រាត ( គឺមិនល្អ ) ឲ្យកើតឡើងដល់ព្រះអរហន្តទាំងឡាយ ដោយអំណាចនៃកិច្ច ( គឺចិត្តប្រភេទនេះធ្វើកិច្ចហសិតុប្បាទ ) ជាកិច្ច មានភាពជាយ៉ាងនោះ ( គឺជាហសិតុប្បាទ ) ជាបទដ្ឋាន មានហទយវត្ថុជាបទដ្ឋានតែម្យ៉ាង ( ព្រោះកើតតែក្នុងបញ្ចវោការភពប៉ុណ្ណោះ ) ដូច្នេះ ។

កាមាវចរកិរិយាវិញ្ញាណដែលជាអហេតុកៈមាន ៣ ដូចពោលមកដូច្នេះ ។

ឯដែលជាសហេតុកៈមាន ៨ ដោយសេចក្តីផ្សេងគ្នានៃសម្បយុត្តធម៌ មានសោមនស្សជាដើម ដូចកុសលវិញ្ញាណ តែនេះជាសេចក្តីផ្សេងគ្នាក្នុងកុសលវិញ្ញាណនិងកិរិយាវិញ្ញាណនេះគឺកុសលវិញ្ញាណរមែងកើតដល់ព្រះសេក្ខៈនិងបុថុជ្ជនទាំងឡាយប៉ុណ្ណោះ កិរិយាវិញ្ញាណនេះកើតដល់ព្រះអរហន្តទាំងឡាយតែម្យ៉ាង ។

កិរិយាវិញ្ញាណដែលជាកាមាវចរៈមាន ១១ ដូច្នេះជាបទដំបូង ។

ចំណែកដែលជារូបាវចរៈ និងអរូបាវចរៈក៏មាន ៥ និង ៤ ដូចកុសលវិញ្ញាណ និងភាពផ្សេងគ្នាអំពីកុសលវិញ្ញាណនៃកិរិយាវិញ្ញាណទាំង ២ នោះ ក៏គប្បីជ្រាបដោយន័យពោលដោយការកើតឡើងដល់ព្រះអរហន្តទាំងឡាយប៉ុណ្ណោះ ដូច្នេះ ។

កិរិយាវិញ្ញាណទាំងអស់ ក្នុងភូមិ ៣ មាន ២០ ដូច្នេះ ។

## វិញ្ញាណទាំងពួងប្រព្រឹត្តទៅដោយអាការ ១៤

ដោយប្រការដូចពោលមកនេះ វិញ្ញាណទាំងអស់ គឺកុសលវិញ្ញាណ ២១ អកុសលវិញ្ញាណ ១២ វិបាកវិញ្ញាណ ៣៦ កិរិយាវិញ្ញាណ ២០ ទើបជាវិញ្ញាណ ៨៩ ដែលប្រព្រឹត្តទៅដោយអាការ ១៤ ដោយអំណាចនៃបដិសន្ធិ ភវង្គ អាវជ្ជនៈ ទស្សនៈ សវនៈ ឃាយនៈ សាយនៈ ផុស្សនៈ សម្បដិច្ឆនៈ សន្តីរណៈ វោដ្ឋពូនៈ ជវន តទាលម្ពណៈ និងចុតិ ។ សួរថា តើសេចក្តីនេះដូចម្តេច ?

## ១ បដិសន្ធិ

ឆ្លើយថា ក្នុងកាលណាសត្វទាំងឡាយកើតក្នុង ( កំណើត ) ទេវតា និង មនុស្សដោយអានុភាពនៃកាមាវចរកុសល ៨ ក្នុងកាលនោះវិបាកចិត្ត ៩ ដួង គឺ សហេតុកកាមាវចរវិបាក ៨ និងអហេតុកមនោវិញ្ញាណធាតុដែលជាឧបេក្ខាសហគតៈ ដែលជាវិបាក នៃទ្វិហេតុកកុសលយ៉ាងខ្សោយរបស់ពួកសត្វ ដែលដល់នូវភាពជា បុគ្គលវិកល មានភាពជាខ្ទើយជាដើមក្នុងពួកមនុស្ស រមែងធ្វើកម្ម កម្មនិមិត្ត និង គតិនិមិត្តណាទីមួយ ដែលចូលទៅប្រាកដក្នុងកាលជិតនឹងស្លាប់នៃសត្វទាំងឡាយនោះ ជាអារម្មណ៍ ប្រព្រឹត្តទៅដោយអំណាចនៃបដិសន្ធិ ក្នុងកាលណាសត្វទាំងឡាយ កើត ក្នុងរូបភព និងអរូបភព ដោយអានុភាពនៃរូបាវចរកុសល និងអរូបាវចរកុសល ក្នុង កាលនោះ រូបាវចរវិបាកចិត្ត និងអរូបាវចរវិបាកចិត្ត ៩ ដួង រមែងធ្វើកម្មនិមិត្តតែ ម្យ៉ាងដែលចូលទៅប្រាកដក្នុងកាលជិតនឹងស្លាប់ នៃសត្វទាំងឡាយនោះជាអារម្មណ៍ ប្រព្រឹត្តទៅដោយអំណាចបដិសន្ធិ ម្យ៉ាងទៀត ក្នុងកាលណា សត្វទាំងឡាយកើត ក្នុងអបាយដោយអានុភាពនៃអកុសល ក្នុងកាលនោះ អហេតុកមនោវិញ្ញាណធាតុ ដែលជាវិបាកនៃអកុសល ១ ដួង រមែងធ្វើកម្ម កម្មនិមិត្ត និងគតិនិមិត្តណាទីមួយ

ដែលចូលទៅប្រាកដក្នុងកាលជិតនឹងស្លាប់នៃសត្វទាំងឡាយនោះជាអារម្មណ៍ ប្រព្រឹត្តទៅដោយអំណាចបដិសន្ធិ ដូច្នេះ ។

ការប្រព្រឹត្តទៅនៃវិបាកវិញ្ញាណ ១៩ ដួង ដោយអំណាចបដិសន្ធិ បណ្ឌិតគប្បីជ្រាបដូចពោលមកក្នុងវិញ្ញាណក្ខន្ធនិទ្ទេសនេះ ជាលំដាប់ដំបូង ( ក្នុងអាការ ១៤ )។

## ២ ភវង្គ

ឯកាលបដិសន្ធិវិញ្ញាណរលត់ ( គឺធ្វើកិច្ចស្រេច ) ហើយ វិញ្ញាណ ឈ្មោះថាភវង្គដែលចាំជាប់តាមបដិសន្ធិវិញ្ញាណនោះៗ ដែលជាវិបាកនៃកម្មនោះៗ ( ដូចគ្នាជាមួយបដិសន្ធិវិញ្ញាណ ) នោះឯង បានជាដូច្នោះ ( គឺដូចគ្នាជាមួយបដិសន្ធិវិញ្ញាណ ) ក្នុងអារម្មណ៍ ( មានកម្មជាដើម ) នោះឯងរមែងប្រព្រឹត្តទៅ កាលចិត្តុប្បាទដទៃ ( គឺអាវជ្ជនៈ) ដែលជាហេតុញ៉ាំងការបន្ត (នៃភវង្គ) ឲ្យធ្លាក់ចុះ (គឺឲ្យភវង្គដាច់ទៅ) មិនមានភវង្គវិញ្ញាណរមែងប្រព្រឹត្តទៅក្នុងកាលទាំងឡាយ មានកាលដែលដេកលក់ជាដើមនៃបុគ្គលដែលមិនយល់សប្តិ ដោយអាការ ( បន្ត ) គឺជាដូច្នោះទៀត ហើយក៏ជាដូច្នោះទៀតទៅ ដូច្នេះ នឹងរាប់ប្រមាណ ( ចំនួនចិត្ត ) មិនបានដោយពិត ដូចក្រសែទឹកដូច្នោះឯង ។

ការប្រព្រឹត្តទៅនៃវិញ្ញាណទាំងឡាយនោះ សូម្បីដោយអំណាចនៃភវង្គ គប្បីជ្រាបដូចពោលមកដូច្នេះ ។

## ៣ អាវជ្ជនៈ

កាលការបន្តគ្នានៃភវង្គប្រព្រឹត្តទៅយ៉ាងនោះ ក្នុងកាលណាឥន្ទ្រិយរបស់សត្វទាំងឡាយគួរដល់ការទទួលអារម្មណ៍បាន ក្នុងកាលនោះ កាលរូបមកកាន់គន្លងចក្ខុ ការផ្សារភ្ជាប់នៃចក្ខុបសាទទាក់ទងនឹងរូបក៏មានឡើង បន្ទាប់ពីនោះ ដោយអំណាច

នៃការផ្សារភ្ជាប់គ្នា ភវង្គចលនៈ ( ការញ័រនៃភវង្គ ) ក៏កើតឡើង បន្ទាប់ពីនោះ កាល ភវង្គរលត់ទៅ កិរិយាមនោធាតុធ្វើរូបនោះឲ្យជាអារម្មណ៍ ដូចជាកាត់ខ្សែភវង្គ ញុំាង អាវជ្ជនកិច្ច (កិច្ច គឺការរំពឹងដល់អារម្មណ៍ ) ឲ្យសម្រេចកើតឡើង ន័យសូម្បីក្នុង សោតទ្វារជាដើមក៏មានន័យដូច្នេះ តែក្នុងមនោទ្វារកាលអារម្មណ៍ទាំង ៦ មកកាន់គន្លង ( នៃមនោទ្វារ ) អហេតុកកិរិយាមនោវិញ្ញាណធាតុដែលសហគតៈ ជាមួយឧបេក្ខា ជាការកាត់ខ្សែភវង្គ ញុំាងអាវជ្ជនកិច្ចឲ្យសម្រេចកើតឡើងក្នុងលំដាប់នៃភវង្គចលនៈ ដូច្នេះ ។

ការប្រព្រឹត្តទៅនៃកិរិយាវិញ្ញាណ ២ ដួង ដោយអំណាចអាវជ្ជនៈ គប្បីជ្រាប ដូចពោលមកដូច្នេះ ។

## ៤-៨ ទស្សនៈ សវនៈ ឃាយនៈ សាយនៈ ផុស្សនៈ

ក្នុងលំដាប់នៃអាវជ្ជនៈ ដំបូង ចក្ខុវិញ្ញាណដែលមានចក្ខុបសាទជាទីតាំងញុំាង ទស្សនកិច្ច ( កិច្ច គឺការឃើញ ) ឲ្យសម្រេចប្រព្រឹត្តទៅក្នុងចក្ខុទ្វារ សោតៈ... ឃានៈ... ជិវ្ហា... កាយវិញ្ញាណ ( ដែលមានសោតបសាទ... ឃានបសាទ... ជិវ្ហាបសាទ... កាយបសាទជាទីតាំង ) ញុំាងកិច្ច មានសវនកិច្ច ( កិច្ច គឺការបានឮ ) ជាដើម ឲ្យសម្រេចប្រព្រឹត្តទៅក្នុងទ្វារ មានសោតទ្វារជាដើម វិញ្ញាណទាំងឡាយនោះ ( ដែល ប្រព្រឹត្តទៅ ) ក្នុងអារម្មណ៍ទាំងឡាយដែលជាឥដ្ឋៈ ( គួរប្រាថ្នា ) និងឥដ្ឋមជ្ឈត្តៈ ( គួរប្រាថ្នាជាមធ្យម ) ក៏ជាកុសលវិបាក ( ដែលប្រព្រឹត្តទៅ ) ក្នុងអារម្មណ៍ទាំងឡាយ ដែលជាអនិដ្ឋៈ ( មិនគួរប្រាថ្នា ) និងអនិដ្ឋមជ្ឈត្តៈ ( មិនគួរប្រាថ្នាជាមធ្យម) ក៏ជា អកុសលវិបាក ដូច្នេះ ។

ការប្រព្រឹត្តទៅនៃវិបាកវិញ្ញាណ ១០ ( គឺកុសលវិបាក ៥ អកុសលវិបាក ៥ )

ដោយអំណាចនៃទស្សនៈ សវនៈ ឃាយនៈ សាយនៈ ផុស្សនៈ គប្បីជ្រាបដូចពោល មកដូច្នេះឯង ។

## ៩ សម្បដិច្ឆន្នៈ

ដោយព្រះបាលីថា ចិត្តំ មនោ មានសំ ។បេ។ មនោធាតុដែលកើតពីចិត្តនោះ ដែលជាការប្រព្រឹត្តទៅក្នុងលំដាប់នៃចក្ខុវិញ្ញាណធាតុ ដែលកើតឡើងរលត់ទៅហើយ រមែងកើតឡើង ដូច្នេះជាដើម មនោធាតុដែលប្រព្រឹត្តទៅក្នុងលំដាប់នៃវិញ្ញាណ មាន ចក្ខុវិញ្ញាណជាដើម (បើប្រព្រឹត្តទៅ) ក្នុងលំដាប់នៃកុសលវិបាក វិញ្ញាណក៏ជាកុសល វិបាក ( បើប្រព្រឹត្តទៅ ) ក្នុងលំដាប់នៃអកុសលវិបាក វិញ្ញាណក៏ជាអកុសលវិបាក ( ធ្វើកិច្ច ) ទទួលអារម្មណ៍នៃវិញ្ញាណទាំងឡាយនោះ ហើយកើតឡើង ។

ការប្រព្រឹត្តទៅនៃវិបាកវិញ្ញាណ ២ ដោយអំណាចនៃសម្បដិច្ឆន្នៈ (ទទួលយក) គប្បីជ្រាបដូចពោលមក ដូច្នេះ ។

## ១០ សន្តីរណៈ

មយ៉ាងទៀត ដោយព្រះបាលីថា ចិត្តំ មនោ មានសំ ។បេ។ មនោវិញ្ញាណធាតុ កើតបន្ទាប់ពីចិត្តនោះរមែងកើតឡើងក្នុងលំដាប់នៃមនោធាតុដែលកើតឡើងនិងរលត់ ទៅហើយដូច្នេះជាដើម វិបាកាហេតុកមនោវិញ្ញាណធាតុដែលមានលំដាប់នៃអកុសល វិបាកមនោធាតុក៏ជាអកុសលវិបាក ដែលកើតបន្ទាប់ពីកុសលវិបាកមនោធាតុ ក៏ជា កុសលវិបាក ( ដែលប្រព្រឹត្តទៅ ) ក្នុងឥដ្ឋារម្មណ៍ ក៏ជាសោមនស្សសហគតៈ (ដែលប្រព្រឹត្តទៅ) ក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ក៏ជាឧបេក្ខាសហគតៈ (ធ្វើកិច្ច) ពិចារណា អារម្មណ៍ដែលមនោធាតុទទួលទុកហើយ កើតឡើង ។

ការប្រព្រឹត្តទៅនៃវិបាកវិញ្ញាណ ៣ ដោយអំណាចនៃសន្តីរណៈ គប្បីជ្រាប

ដូច្នេះឯង ។

## ១១ វោដ្ឋព្វនៈ

ចំណែកកិរិយាហេតុកមនោវិញ្ញាណធាតុ ជាឧបេក្ខាសហគតៈវិគ្រោះមើលអារម្មណ៍នោះឯងកើតក្នុងលំដាប់នៃសន្តីរណៈ ។

ការប្រព្រឹត្តទៅនៃកិរិយាមនោវិញ្ញាណ ១ ដួង ដោយអំណាចនៃវោដ្ឋព្វនៈ ( វិគ្រោះមើល ) គប្បីជ្រាបមកដូច្នេះឯង ។

## ១២ ជវន

ចំណែកក្នុងលំដាប់នៃវោដ្ឋព្វនៈ ប្រសិនបើអារម្មណ៍ មានរូបជាដើមជាមហន្តារម្មណ៍ ( អារម្មណ៍ធំ ) សោត ពេលនោះជវន ៦ ឬ ៧ ដួង រមែងស្ទុះទៅក្នុងអារម្មណ៍តាមដែលវោដ្ឋព្វនៈកំណត់ទុកហើយ ដោយអំណាចនៃកាមាវចរកុសល ៨ ខ្វះ អកុសល ១២ ខ្វះ កាមាវចរកិរិយាដ៏សេស ៩ ខ្វះ ណាទីមួយ នេះជាន័យក្នុងបញ្ចទ្វារប៉ុណ្ណោះ ចំណែកក្នុងមនោទ្វារ កាមាវចរជវន ២៩ ទាំងនោះឯង រមែងស្ទុះទៅក្នុងលំដាប់មនោទ្វារាវជ្ជនៈ បន្ទាប់ពីគោត្រភូស្ទុះទៅ បណ្តាជវនទាំងឡាយនេះ គឺរូបាវចរកុសលជវន ៥ កិរិយាជវន ៥ អរូបាវចរកុសលជវន ៤ កិរិយាជវន ៤ លោកុត្តរមគ្គចិត្ត ៤ ផលចិត្ត ៤ ជវនណាបានបច្ច័យហើយ ជវននោះៗ រមែងស្ទុះទៅ ។ ការប្រព្រឹត្តទៅនៃវិបាកវិញ្ញាណជាកុសល អកុសល និងកិរិយា មាន ៥៥ ដួង ដោយអំណាចជវន គប្បីជ្រាបមកដូច្នេះឯង ។

## ១៣ តទាលម្ពណៈ

ក្នុងទីបំផុតនៃជវន បើអារម្មណ៍នោះជាអតិមហន្តារម្មណ៍ ( អារម្មណ៍ធំក្រៃលែង ) ក្នុងបញ្ចទ្វារ និងជាវិភូតារម្មណ៍ ( អារម្មណ៍ដែលប្រាកដច្បាស់ ) ក្នុងមនោទ្វារសោត

ពេលនោះវិបាកវិញ្ញាណ ក្នុងបណ្ដាសហេតុកកាមាវចរវិបាក ៨ និងវិបាកាហេតុកមនោវិញ្ញាណធាតុ ៣ ណាទីមួយ ដែលជាប់តាមជវនក៏ស្ទុះទៅក្នុងអារម្មណ៍ដទៃបន្ទាប់អំពីអារម្មណ៍របស់ភវង្គ ដូចទឹកដែលហូរបញ្ច្រាស់ក្រសែ ក្នុងរវាងខណៈដែលតិចតួច ជាប់តាមទូកដែលស្ទុះទៅបញ្ច្រាស់ក្រសែទឹក រមែងកើតឡើង ២ ខណៈ ឬ ១ ខណៈ ដោយអំណាចនៃបច្ច័យនោះៗ តាមដែលខ្ជួន បានដោយអំណាចនៃអារម្មណ៍មានឥដ្ឋារម្មណ៍ជាដើម និងនៃបុរិមកម្ម និងចិត្ត មានជវនចិត្តជាដើម ក្នុងទីបំផុតនៃកាមាវចរជវនរបស់កាមាវចរសត្វទាំងឡាយ វិបាកវិញ្ញាណនេះ ជាចិត្តគួរដល់ការប្រព្រឹត្តទៅក្នុងអារម្មណ៍របស់ភវង្គ ក្នុងទីបំផុតនៃជវន តែព្រោះវាធ្វើអារម្មណ៍របស់ជវននោះឲ្យជាអារម្មណ៍ប្រព្រឹត្តទៅ ទើបហៅថា តទាលម្ពណៈ ( មានអារម្មណ៍របស់ជវននោះជាអារម្មណ៍ ) ។

ការប្រព្រឹត្តទៅនៃវិបាកវិញ្ញាណ ១១ ដួង ដោយអំណាចនៃតទាលម្ពណៈ គប្បីជ្រាបដូចពោលមក ដូច្នេះចុះ ។

## ១៤ ចុតិ

ក្នុងទីបំផុតនៃតទាលម្ពណៈ ភវង្គនោះឯងប្រព្រឹត្តទៅទៀត កាលភវង្គដាច់វិថីវិញ្ញាណទាំងឡាយ មានអាវជ្ជនៈជាដើមក៏ប្រព្រឹត្តទៅទៀតដែរ ។

ចិត្តសន្តានដែលមានបច្ច័យបានហើយយ៉ាងនេះ រមែងប្រព្រឹត្តទៅរឿយៗ ដោយអំណាចនៃចិត្តនិយម គឺអាវជ្ជនៈរមែងមានក្នុងលំដាប់នៃភវង្គ វិញ្ញាណ កិច្ច មានការឃើញរូបជាដើម រមែងមានក្នុងលំដាប់នៃអាវជ្ជនៈ ដូច្នេះជាដើមនោះឯង រហូតភវង្គក្នុងភពមួយអស់ទៅ ពិតហើយ ក្នុងភពមួយភវង្គចិត្តដួងណាជាដួងចុងក្រោយបំផុតភវង្គចិត្តដួងនោះលោកហៅថា ចុតិ ព្រោះឃ្លាតចាកភពនោះៗ ព្រោះដូច្នោះ សូម្បីចុតិចិត្តនោះក៏មាន ១៩ ដួងដូចគ្នា ( ដូចបដិសន្ធិ និងភវង្គចិត្ត ) ។

ការប្រព្រឹត្តទៅនៃវិបាកវិញ្ញាណ ១៩ ដួង ដោយអំណាចនៃចុតិគប្បីជ្រាបដូចពោលមកដូច្នេះចុះ ។

ចិត្តសន្តានដែលមិនដាច់ខ្សែរបស់សត្វទាំងឡាយ ជាអ្នកដែលត្រាច់រង្គាត់ទៅក្នុងភព គតិ ឋិតិ និងនិវាសទាំងឡាយ រមែងប្រព្រឹត្តទៅដូច្នេះ គឺបន្ទាប់ពីចុតិ ក៏បដិសន្ធិទៀត បន្ទាប់ពីបដិសន្ធិក៏ភវង្គទៀត... ដូច្នោះឯង តែក្នុងសត្វទាំងឡាយនោះ លោកអ្នកណាបានសម្រេចព្រះអរហត្ត កាលចុតិចិត្តរបស់អ្នកនោះរលត់ហើយ ចិត្ត (របស់លោក) ក៏រលត់ទៅនោះឯង ។ នេះជាកថាមុខ (ពាក្យអធិប្បាយដែលសំខាន់) យ៉ាងពិស្តារក្នុងវិញ្ញាណក្ខន្ធ ។

# មហាដីកា

## ពណ៌នាវិញ្ញាណក្ខន្ធ

ដោយបទទាំងពីរដែលសម្ដែងដល់ការកំណត់កាន់យក ដោយមិនមានចំណែកសេសសល់ថា **យង្កិញ្ចិ** លោកអាចារ្យកាលសម្ដែងថា ការសោយអារម្មណ៍ មានច្រើនប្រភេទ រមែងលើកយកសេចក្ដីសំដៅថា គំនរដែលកំពុងនឹងពោលដល់ ។ ការសោយអារម្មណ៍ គឺការសោយរសនៃអារម្មណ៍ ជាលក្ខណៈរបស់ធម្មជាតិនេះ ហេតុនោះ ធម្មជាតិនេះឈ្មោះថា **វេទយិតលក្ខណំ** ប្រែថា មានការសោយអារម្មណ៍ជាលក្ខណៈ អធិប្បាយថា **សព្វន្តំ យោគ ធម្មជាតំ** ប្រែថា ធម្មជាតិទាំងអស់នោះម្យ៉ាងទៀត គប្បីនាំយកពាក្យដែលបានពោលទុកក្នុងកថាពោលដោយរូបក្ខន្ធក្នុងខាងដើម មកភ្ជាប់ចូលដោយអធិការ ( អធិការ គឺជាពាក្យដែលជាគោល ឬព្រះសូត្រដែលជាគោល មាន ៣ គឺ **សីហគតិ** ជាសូត្រ ឬពាក្យដែលក្រសោបទាំងអស់ និយមហៅថា **សីហគត្យាធិការសូត្រ** ។ **មណ្ឌូកគតិ** ជាសូត្រ ឬពាក្យដែលជាគោលធំៗ ឆ្លងទៅជាចំណែកៗ ដូចកង្កែបលោត ។ **យថានុបុព្វិកា** ជាសូត្រ ឬពាក្យដែលជាគោលតាមលំដាប់ ) ។

ពីរបទថា **ឯកតោ កត្វា** សេចក្ដីថា ធ្វើធម្មជាតិនោះទាំងអស់នោះដែលផ្សេងដោយប្រភេទ មានការសោយអារម្មណ៍ដែលជាអតីតជាដើមឲ្យចូលគ្នាដោយការដឹង។ សំដៅយកសេចក្ដីថា គំនរមានយ៉ាងនេះឯង ។

ការដឹងនូវអារម្មណ៍ដែលផ្សេងដោយពណ៌ មានពណ៌ខៀវជាដើម និងការដឹង គឺការកាន់យកដោយអំណាចការចាំបាន ដោយន័យថា ពណ៌ខៀវ ពណ៌លឿង វែង ខ្លីជាដើម ជាលក្ខណៈរបស់ធម្មជាតិនេះ ហេតុនោះ ធម្មជាតិនេះ ឈ្មោះថា

**សញ្ជាននលក្ខណំ** ប្រែថា មានការចាំបានជាលក្ខណៈ ។ **ការទំនុកបម្រុង** តាក់តែង គឺការប្រមូលទុក បានដល់ មានការខ្វាយខ្វល់ ម្យ៉ាងទៀត បានដល់ ការព្រមព្រៀងគ្នា លោកពោលទុកយ៉ាងនេះថា **អភិសង្ខរណលក្ខណំ** ប្រែថា មានការតាក់តែងក្រៃលែង ជាលក្ខណៈ ព្រោះការដែលសង្ខារក្ខន្ធជាចេតនាជាប្រធាន សូម្បីដោយប្រការទាំង ២ ។ ពិតយ៉ាងនោះ ព្រះមានព្រះភាគទ្រង់ចែកសង្ខារក្ខន្ធ ក្នុងសុត្តន្តភាជនីយ៍ ទ្រង់ បានចែកចេតនាតែម្យ៉ាង ដោយន័យថា ចេតនាកើតអំពីចក្ខុសម្ផស្សជាដើម ។ វិញ្ញាណ រមែងទទួលអារម្មណ៍បានដោយអាការដ៏ពិសេស ជាងអាការ គឺការចាំបាន យ៉ាងណា ដូចបុរសប្រើនាឡិវាល់វត្ថុដែលគប្បីវាល់បាន ដូច្នោះ ការដឹងច្បាស់ ពោល គឺការ បានអារម្មណ៍យ៉ាងនោះ ជាលក្ខណៈរបស់ធម្មជាតិនេះ ហេតុនោះ ធម្មជាតិនេះ ឈ្មោះថា **វិជាននលក្ខណំ** ប្រែថា មានការដឹងច្បាស់ ជាលក្ខណៈ ។ បទថា **ឥតរេ យោគ វេទនាខន្ធាទយោ** ប្រែថា វេទនាខន្ធជាដើម ក្រៅអំពីនេះក៏គប្បីដឹងបាន ដោយងាយ ព្រោះជាសភាវធម៌ដែលមានការកើតរួមគ្នាជាដើម និងចែកជាបកិណ្ណកៈ មានធម្មជាតិស្មើគ្នាជាដើម និងវិញ្ញាណដោយប្រការ ដូច្នេះ ។

លោកអាចារ្យពោលពាក្យថា **យន្តិញ្ចិ** ជាដើម ដើម្បីនឹងញ៉ាំងសេចក្តីដែលខ្លួន បានពោលទុក ហៅថា **វិជាននលក្ខណំ** ឲ្យសម្រេចដោយសូត្រ ។ លោកអាចារ្យ ពោលដោយអំណាចការសាធនថា **វិជាននលក្ខណំ** ដើម្បីសម្តែងថា ធម្មជាតិណា គឺសភាវធម៌ ធម្មជាតិនេះត្រឹមតែជាការប្រព្រឹត្តតាមបច្ច័យ ។ ឈ្មោះថា **កត្តុ** ណាមួយ ដែលផុតទៅអំពីសភាវៈនៃធម៌ រមែងមិនមាន ព្រោះដូច្នោះ ទើបព្រះសារីបុត្រពោលថា **វិជានាតិ** ដើម្បីនឹងសម្តែងភាពជាកត្តុរបស់ធម្មជាតិនោះៗ ឯង ។ ធម្មជាតិណាឈ្មោះ ថា វិញ្ញាណ ដោយអត្ថថា ដឹងច្បាស់នូវធម្មជាតិនោះៗ ឯង ឈ្មោះថា **ចិត្ត** ដោយ អត្ថថា គិតជាដើម ឈ្មោះថា **មនះ** ដោយអត្ថថា ដឹង ព្រោះដូច្នេះ លោកអាចារ្យ

រមែងធ្វើឲ្យយល់ច្បាស់នូវវិញ្ញាណនោះ សូម្បីដោយពាក្យជាបរិយាយ ។ ដោយពាក្យមានប្រមាណប៉ុណ្ណោះ វិញ្ញាណ គឺលោកធ្វើឲ្យជាក់ច្បាស់ដោយខន្ធ ដោយប្រភេទ និងពាក្យជាបរិយាយ ។

ធម្មជាតិឈ្មោះថា **ជាតិ** ដោយអត្ថថា ជាទីកើតរបស់ធម៌ដែលផ្សេងគ្នា ដែលមានអាការដូចគ្នា បានដល់ អាការស្មើគ្នា ។ ជាតិនេះ មានច្រើនប្រការ ពិតមែន ព្រោះដូច្នោះ លោកអាចារ្យកាលសម្ដែងដល់ជាតិនោះ ដោយបំណងយកក្នុងទីនោះប៉ុណ្ណោះ ទើបពោលថា កុសល អកុសល និងអព្យាកតៈ ។ បណ្ដាជាតិ ទាំង ៣ យ៉ាងនោះ ជាតិឈ្មោះថា **កុសល** ដោយអត្ថថា កុសល ។ ដែលឈ្មោះថា អត្ថ គឺកុសលនេះ បានដល់ អ្វី ? បានដល់ អត្ថ គឺ **អរោគ្យ** ប្រែថា មិនមានរោគ គឺមានសេចក្ដីសប្បាយ ១ ដោយអត្ថថា **អនវជ្ជ** ប្រែថា មិនមានទោស ១ អត្ថថា **សុខវិបាក** ប្រែថា មានសេចក្ដីសុខជាផល ១ ។ មែនពិត លោកហៅកុសល ដោយអត្ថថា **អរោគ្យ** ការមិនមានរោគ ឬសប្បាយក៏មាន ដូចក្នុងពាក្យថា **កច្ចិ នុ ភោតោ កុសលំ** ប្រែថា លោកដ៏ចម្រើន មានសេចក្ដីសុខស្រួលដែរឬ ជាដើម ។ លោកហៅថា កុសល ដោយអត្ថថា **អនវជ្ជ** ប្រែថា មិនមានទោសក៏មាន ដូចក្នុងពាក្យថា **កតមោ បន ភន្តេ កុសលោ កាយសមាចារោ យោ ខោ មហារាជ អនវជ្ជោ កាយសមាចារោ** ជាដើម ប្រែថា បពិត្រលោកដ៏ចម្រើន ចុះកាយសមាចារដែលជាកុសល គឺមិនមានទោសដូចម្ដេច ? បពិត្រមហារាជ បានដល់ កាយសមាចារដែលមិនមានទោសឯណា ។ លោកហៅ កុសល ដោយអត្ថថា មានផលជាសុខក៏មាន ដូចក្នុងពាក្យថា **កុសលានំ ភិក្ខវេ ធម្មានំ សមាទានហេតុ ឯវមិទំ បុញ្ញំ បវឌ្ឍតិ** ប្រែថា ម្នាលភិក្ខុទាំងឡាយ បុណ្យនេះ រមែងចម្រើនឡើង ព្រោះហេតុនៃការសមាទាននូវកុសលធម៌ទាំងឡាយ យ៉ាងនេះ ។ មែនពិត កុសលចិត្តក៏ឈ្មោះថា **អរោគ្យ** គឺមិនមានរោគ ព្រោះជាបដិបក្ខ

ចំពោះ រោគផ្លូវចិត្តទាំងឡាយ មានរាគៈជាដើម ឈ្មោះថា **អនវជ្ជ** មិនមានទោស ព្រោះជាបដិបក្ខចំពោះសភាវៈដែលមានទោសទាំងឡាយ និងឈ្មោះថា **សុខវិបាក** មានផលជាសុខ ព្រោះឲ្យផលជាសុខ ដូច្នោះឯង ។

ដោយអត្ថរបស់ស័ព្ទ ចិត្ត ឈ្មោះថា **កុសល** ដោយអត្ថថា ញុំាងធម៌ដែលបណ្ឌិតស្អប់ខ្ពើម បានដល់ បាបធម៌ទាំងឡាយឲ្យកម្រើក គឺឲ្យញាប់ញ័រ ឲ្យរញ្ជួយឲ្យបែកធ្លាយទៅ ។ ម្យ៉ាងទៀត បាបធម៌ទាំងឡាយឈ្មោះថា **កុស** ដោយអត្ថថា ដេកនៅដោយអាការដែលបណ្ឌិតស្អប់ខ្ពើម ចិត្ត ឈ្មោះថា **កុសល** ដោយអត្ថថា កាត់ គឺកម្ចាត់នូវកុសទាំងនោះ ។ ម្យ៉ាងទៀត ញាណ ឈ្មោះថា **កុស** ព្រោះញុំាងធម៌ដែលបណ្ឌិតទាំងឡាយស្អប់ឲ្យអស់ទៅ គឺនឹងធ្វើឲ្យស្រោលស្តើង ចិត្ត ឈ្មោះថា **កុសល** ដោយអត្ថថា ញាណ ឈ្មោះថា **កុស** នោះ បណ្ឌិតគប្បីកាន់យក គឺគប្បីទាញទុក គប្បីឲ្យប្រព្រឹត្តទៅ ។ ន័យម្យ៉ាងទៀត ស្បូវក្លាំង ឈ្មោះថា **កុស** គឺស្បូវក្លាំងរមែងមុតដោយចំណែកនៃខាងទាំងពីរ យ៉ាងណា ចិត្តនេះក៏រមែងមុត គឺរមែងកាត់ក្រុមនៃសង្កិលេសទាំងពីរចំណែក គឺដែលកើតឡើងហើយ និងមិនទាន់កើតឡើងក៏យ៉ាងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **កុសល** ដោយអត្ថថា កាត់បាន ដូចស្មៅឈ្មោះកុសៈ ( ស្បូវក្លាំង ) ។ ម្យ៉ាងទៀត ឈ្មោះថា **កុសល** ព្រោះរាំងទុក គឺហាមឃាត់នូវធម៌ដែលបណ្ឌិតទាំងឡាយស្អប់ខ្ពើម បានដល់ ធម៌ដែលជាទោសទាំងឡាយ មែនពិត អកុសលធម៌ទាំងឡាយ រមែងត្រូវបានបុគ្គលសង្រួមហើយ បិទបាំងបានហើយ ដើម្បីមិនឲ្យប្រព្រឹត្តទៅក្នុងទ្វារទាំងឡាយ មានចិត្តជាគម្រប់ ៦ ដោយការហាមនូវការប្រព្រឹត្តទៅ និងមិនឲ្យប្រព្រឹត្តទៅបាន ដោយអំណាចនៃកុសលធម៌ ។ ម្យ៉ាងទៀត ចិត្ត ឈ្មោះថា **កុសល** ដោយអត្ថថា កម្ចាត់ គឺធ្វើឲ្យវិនាស គឺឲ្យប្រាសទៅនូវធម៌ ដែលបណ្ឌិតស្អប់ខ្ពើម គឺបាបធម៌ទាំងឡាយ ។ ន័យម្យ៉ាងទៀត កិលេស

មានទោសៈ និងលោភៈជាដើម ឈ្មោះថា កុសៈ ព្រោះញ៉ាំងធម៌ដែលបណ្ឌិតខ្ពើម គឺ បាបធម៌ មានបាណាតិបាតជាដើមឲ្យមុត គឺឲ្យស្រួច ឲ្យរឹងក្រៃលែងឡើង ។ មែនពិត ភាវៈនៃបាបធម៌ មានបាណាតិបាតជាដើម មានទោសច្រើន ព្រោះចេតនាដល់នូវភាវៈ ដ៏រឹងមាំ ដោយអំណាចនៃកិលេស មានទោសៈជាដើម ចិត្ត ឈ្មោះថា **កុសល** ដោយ អត្ថថា កាត់ គឺកាត់ផ្តាច់នូវកិលេស ឈ្មោះថា **កុស** នោះ ។ ម្យ៉ាងទៀត ឥន្ទ្រិយ ទាំងឡាយ មានសទ្ធាជាដើមដែលប្រព្រឹត្តទៅដោយអំណាចបុញ្ញកិរិយាវត្ថុ ឈ្មោះថា **កុស** ព្រោះញ៉ាំងធម៌ដែលបណ្ឌិតស្អប់ខ្ពើមទាំងឡាយឲ្យអស់ទៅ គឺធ្វើឲ្យដល់ទីបំផុត ឲ្យវិនាសទៅ ចិត្ត ឈ្មោះថា **កុសល** ដោយអត្ថថា ដែលឥន្ទ្រិយ គឺកុសលទាំងនោះ គប្បីកាន់យក គឺគប្បីឲ្យប្រព្រឹត្តទៅ ។ ន័យម្យ៉ាងទៀត ទីកន្លែង ឈ្មោះថា កុ កិលេស មានរាគៈជាដើម ឈ្មោះថា **កុស** ដោយអត្ថថា ធ្វើទីកន្លែងដែលឈ្មោះថា កុ ឲ្យវិនាសទៅ ព្រោះធ្វើឲ្យអន្តរធានទៅ ដោយការតាមដុតបំផ្លាញ ទាំងក្នុងបច្ចុប្បន្ន និងអនាគត នូវសភាវៈដែលអាស្រ័យដោយរូប និងនាមជាទីអាស្រ័យរបស់ខ្លួន ដូចគ្នា នឹងទីកន្លែងដែលឈ្មោះថា កុ នោះ ដោយភាវៈជាទីតាំងអាស្រ័យ ចិត្តដទៃឈ្មោះថា **កុសល** ព្រោះកាត់ គឺកាត់ផ្តាច់នូវសភាវៈ ដែលជាប់ដោយរូប និងនាមជាទីអាស្រ័យ របស់ខ្លួន ដូចកិលេស មានរាគៈជាដើម ឈ្មោះថា **កុស** ។ មែនពិត កុសលធម៌ ទាំងឡាយ ដែលដល់ព្រមហើយ ដោយបយោគសម្បត្តិ រមែងកាត់ផ្តាច់នូវរូបធម៌ និងអរូបធម៌ ដោយការមិនធ្វើឲ្យប្រព្រឹត្តទៅដោយពិតប្រាកដនោះឯង ដូច្នេះ ។

ចិត្ត ឈ្មោះថា **អកុសល** ដោយអត្ថថា មិនមែនកុសល អធិប្បាយថា ជា បដិបក្ខចំពោះកុសល ។ មែនពិត កាលពោលដល់សេចក្តីនៃអកុសលបទ ដោយ ចែកបកិណ្ណកៈ ដោយការបដិសេធកុសលថា មិនមែនជាកុសល ក៏ឈ្មោះថា លោក សម្តែងសេចក្តីនេះថា ធម្មជាតិណាមិនមានការញ៉ាំងធម៌ដែលបណ្ឌិតស្អប់ខ្ពើមឲ្យរកម្រើក

ជាសភាវៈមិនមានការកាត់បាបធម៌ដែលឈ្មោះថា កុស ជាសភាវៈមិនមែនជាញាណឈ្មោះថា កុស ឬធម៌ទាំងឡាយ ឈ្មោះថា កុស ទើបឲ្យប្រព្រឹត្តទៅ និងមិនមែនកាត់ចេញដូច កុស ធម្មជាតិនោះ ឈ្មោះថា អកុសល ដូចលោកសម្ដែងសេចក្ដីនេះថា ធម្មជាតិណាដែលមានរោគ មិនមែនជាធម្មជាតិដែលមិនមានទោស មិនមែនជាធម្មជាតិដែលមានសុខជាផល និងមិនមែនជាធម្មជាតិ ដែលកើតអំពីភាពជាអ្នកឈ្លាស ធម្មជាតិនោះឈ្មោះថា អកុសល ។ ក្នុងអធិការនេះ ព្រោះហេតុកុសលជាសត្រូវចំពោះអកុសលដែលជាហេតុឲ្យយល់បាន ដោយពាក្យបរិយាយថា **អរោគ្យ** ប្រែថា មិនមានរោគជាដើម ព្រោះភាពបដិបក្ខចំពោះរោគដែលប្រព្រឹត្តទៅតាមផ្លូវចិត្តជាដើម ដូច្នោះ ទើបអកុសលជាសត្រូវចំពោះកុសល ព្រោះដូច្នោះ ទើបលោកអាចារ្យពោលអធិប្បាយថា ជាបដិបក្ខចំពោះកុសល ។ តែកុសល និងអកុសលនោះ គប្បីជ្រាបថាលោកពោលទុកដោយភាវៈដែលជាធម៌សម្រាប់លះ និងជាធម៌ ដែលគប្បីលះតាមលំដាប់នោះឯង ។

ចិត្ត ឈ្មោះថា **អព្យាកតៈ** ដោយអត្ថថា ព្យាករមិនបាន អធិប្បាយថា ដែលពោលមិនបានដោយភាវៈថាជាកុសល ឬអកុសលនោះឯង ។ បណ្ដាភាវៈទាំងពីរនោះ **ភាវៈដែលជាកុសល** ដោយអត្ថថា មិនមានទោស និងមានសេចក្ដីសុខជាផល ។ **ភាវៈដែលជាអកុសល** ដោយអត្ថថា មានទោស និងមានទុក្ខជាផល អធិប្បាយថាដែលពោលមិនបានដោយភាវៈទាំងពីរនោះ ។ កិរិយាដែលពោលមិនបាន ក៏គប្បីជ្រាបថា លោកពណ៌នាទុកហើយ ដោយភាវៈទាំងពីរនេះឯង និងដោយភាវៈដែលមិនមានរោគ និងមានរោគជាដើម ។ ក្នុងអធិការនេះ លោកអាចារ្យពោលទុកថា កុសល និងអកុសល ដូច្នេះ ទើបពោលថា អព្យាកតៈ រមែងធ្វើឲ្យយល់ដល់កិរិយាដែលលោកមិនបានពោលទុក ដោយភាវៈជាកុសល និងអកុសលនោះឯង មិនមែនឲ្យយល់ដោយ

ប្រការដទៃទេ ។ សេចក្តីដែលលោកមិនបានពោលទុកក្នុងទីនេះ មិនមែនធ្វើឲ្យដឹងត្រឹមតែសេចក្តីដែលពោលមិនបានយ៉ាងនេះទេ តាមពិត គប្បីជ្រាបថា សេចក្តីដែលលោកមិនបានពោលទុក ព្រោះសេចក្តីនៃធម៌ទាំងនោះ មានសភាពផុតហើយ ពីសភាវៈទាំងពីរនោះ ។ ពិតដូច្នោះ អព្យាកតៈនោះ លោកហៅថា មានការមិនមានវិបាកជាលក្ខណៈ ។

ពាក្យថា **ដោយការផ្សេងគ្នានៃភូមិ** អធិប្បាយថា ឋានៈ គឺទីតាំងមួយ **អវត្ថា** គឺកិរិយាដែលតាំងចុះមួយ ឈ្មោះថា **ភូមិ** ដោយអត្ថថា ជាទីនៅនៃធម៌ទាំងឡាយ ។ មែនពិត **អវត្ថា** គឺកិរិយាតាំងចុះ លោកក៏កាន់យក ដូចជាការតាំងចុះនៃការប្រព្រឹត្តទៅរបស់ពាក្យដែលមានកិរិយាតាំងចុះទាំងឡាយ ដោយអាការយ៉ាងនេះ រមែងនឹងមានការកាន់យកបានងាយដល់ឋានៈ គឺទីតាំងចុះ និងអវត្ថា គឺកិរិយាតាំងចុះទាំងនោះឯង ។ បណ្តាភូមិទាំងពីរយ៉ាងនោះ ភូមិដែលជាលោកិយ គប្បីជ្រាបដោយអំណាចនៃឋានៈ គឺទីតាំងនោះឯង ភូមិដែលជាលោកុត្តរ គប្បីជ្រាបដោយអំណាចនៃ **អវត្ថា** គឺកិរិយាដែលតាំងចុះ។

ន័យម្យ៉ាងទៀត ភូមិដែលជាលោកិយ គប្បីជ្រាបដោយអំណាចនៃឋានៈ គឺទីតាំង និង **អវត្ថា** គឺកិរិយាដែលតាំងចុះ ភូមិដែលជាលោកុត្តរ គប្បីជ្រាបដោយអំណាចនៃ **អវត្ថា** តែម្យ៉ាង ។ ក្នុងបទថា **កាមាវចរ** នេះ កាមមាន ២ យ៉ាង គឺវត្ថុកាម ១ កិលេសកាម ១ ។ បណ្តាកាមទាំង ២ យ៉ាងនោះ **វត្ថុកាម** ដោយពិសេស បានដល់កាមគុណ ៥ ព្រោះអត្ថថា សត្វប្រាថ្នា **កិលេសកាម** បានដល់ តណ្ហា ព្រោះអត្ថថា ញុំាងសត្វឲ្យប្រាថ្នា ។ កាមទាំង ២ យ៉ាងនោះ ជាសភាវៈ ដែលប្រព្រឹត្តទៅវិលវល់ជាមួយធម្មជាតិណា ធម្មជាតិនោះ ឈ្មោះថា **កាមាវចរៈ** ។

សួរថា កាមាវចរៈនោះ បានដល់ អ្វី ? បានដល់ កាមភព ១១ ជាន់ ។ ចិត្តនេះ

រមែងត្រាច់ទៅ គឺប្រព្រឹត្តទៅក្នុងកាមភពនោះដោយច្រើន ហេតុនោះ ទើបឈ្មោះថា **កាមាវចរៈ** ព្រោះធ្វើការដក **អវចរ**-ស័ព្ទមួយចេញ ។ សូម្បីចិត្តដែលជា **រូបាវចរៈ** និង **អរូបាវចរៈ** ក៏គប្បីជ្រាបយ៉ាងនេះ ព្រោះអធិប្បាយថា រូបតណ្ហា ឈ្មោះថា រូប អរូបតណ្ហា ឈ្មោះថា អរូប ។

ម្យ៉ាងទៀត កាមតណ្ហា ឈ្មោះថា កាម ដោយការដកបទក្រោយ ឈ្មោះថា **អវចរ** ដោយអត្ថថា ជាការត្រាច់ទៅ ការត្រាច់ទៅនៃកាម ឈ្មោះថា **កាមាវចរៈ** ។ ចិត្តសូម្បីដែលជា **រូបាវចរៈ** និង **អរូបាវចរៈ** គប្បីជ្រាបយ៉ាងនេះ ។ ចិត្ត ឈ្មោះថា **លោកុត្តរ** ដោយអត្ថថា ឆ្លងផុតអំពីលោក ព្រោះបំណាំងយកនូវកុសលចិត្ត ។ ចំណែកចិត្តក្រៅអំពីនេះ ឈ្មោះថា **លោកុត្តរ** ដោយអត្ថថា ឆ្លងផុតហើយអំពីលោក ។

បទថា **សោមនស្សុបេក្ខាញាណសង្ខារភេទតោ** មានវិនិច្ឆ័យដូចតទៅនេះ សួរថា សេចក្តីផ្សេងនៃសោមនស្ស និងឧបេក្ខាសមគួរមុន ព្រោះសោមនស្ស និងឧបេក្ខានោះមានសភាពផ្សេងគ្នា ចំណែកសេចក្តីផ្សេងគ្នានៃញាណ និងសង្ខារ នឹងសមគួរដូចម្តេច ? ឆ្លើយថា សេចក្តីនេះមិនខុសនឹងសេចក្តីផ្សេងគ្នានៃញាណ និងសង្ខារទេ ឈ្មោះថា សេចក្តីផ្សេងគ្នានៃញាណ និងសង្ខារ ព្រោះអធិប្បាយថា សេចក្តីផ្សេងគ្នានៃញាណ និងសង្ខារនោះ ធ្វើសេចក្តីមាន និងមិនមាននៃញាណ និងសង្ខារទាំងនោះ។ ឈ្មោះថា **សុមន** ដោយអត្ថថា ចិត្តល្អ ឬដោយអត្ថថា បុគ្គលអ្នកមានចិត្តល្អ ភាវៈនៃ **សុមន** នោះ ឈ្មោះថា សោមនស្ស បានដល់ សុខវេទនា ប្រព្រឹត្តទៅតាមផ្លូវចិត្តតាមពាក្យដែលជាប់មាត់ ចិត្តដែលសហគតៈ គឺប្រព្រឹត្តទៅលាយឡំគ្នា អធិប្បាយថា សម្បយុត្តដោយសោមនស្ស តាំងពីកើតឡើង រហូតដល់រលត់ទៅ ។ កុសលចិត្តនោះ **ជាចិត្តប្រកបដោយសោមនស្ស** បណ្ឌិតគប្បីជ្រាបដោយអំណាចនៃអារម្មណ៍ ។ មែនពិត ចិត្តក្នុងឥដ្ឋារម្មណ៍ រមែងសហគតៈ ដោយសោមនស្ស ។ សួរថា ឥដ្ឋារម្មណ៍

ជាវត្ថុដែលតាំងនៅនៃលោកៈមិនមែនឬ កុសលមានក្នុងឥដ្ឋារម្មណ៍នោះបានដូចម្ដេច ? ឆ្លើយថា សេចក្ដីនេះមិនមែនប្រព្រឹត្តទៅ ដោយចំណែកតែមួយទេ ព្រោះកុសលកើតឡើងបាន ដោយអំណាចនៃការចងចិត្តជាដើម សូម្បីក្នុងឥដ្ឋារម្មណ៍ ។ មែនពិត បុគ្គលណាមានការចងចិត្តដោយឧបាយដ៏ឈ្លាសវៃនោះឯង ដោយអំណាចនៃការប្រកបដោយចក្រ គឺសមាបត្តិ ៤ ជាដើម គឺកំណត់ចិត្តទុកក្នុងការធ្វើកុសលថា អញគួរធ្វើតែកុសលប៉ុណ្ណោះប្រការ ១ ហាមចិត្ត ចាកការប្រព្រឹត្តទៅនៃអកុសល ហើយធ្វើចិត្តឲ្យបង្អោនទៅក្នុងការធ្វើកុសលតែម្យ៉ាង ប្រការ ១ ប្រមូលផ្ដុំចិត្តទុក ដោយការធ្វើឲ្យរឿយៗ ប្រការ ១ បុគ្គលនោះរមែងមានចិត្តសម្បយុត្ត ដោយអលោភៈជាដើមតែម្យ៉ាង សូម្បីក្នុងឥដ្ឋារម្មណ៍មិនមែនសម្បយុត្ត ដោយលោភៈជាដើមទេ ។

ចិត្ត ឈ្មោះថា **ញាណសម្បយុត្ត** ដោយអត្ថថា ប្រកបដោយប្រការទាំងឡាយព្រមជាមួយញាណ ។ អាការទាំងឡាយមានការកើតព្រមគ្នាជាដើមនោះឯង គប្បីជ្រាបថា ជាប្រការក្នុងទីនេះ ។ បណ្ដាចិត្តទាំងនោះ **កម្មុប្បត្តិ** ការចាស់ក្លានៃឥន្ទ្រិយ និងភាពជាអ្នកឆ្ងាយចាកកិលេស ជាហេតុនៃចិត្តដែលជាញាណសម្បយុត្ត ។ មែនពិត បុគ្គលណារមែងធ្វើកម្ម ដែលញុំាងបញ្ញាឲ្យប្រព្រឹត្តទៅព្រមជាដើមយ៉ាងនេះគឺសម្ដែងធម៌ដល់បុគ្គលដទៃ ឲ្យគេបានសិក្សា សិល្បៈ ការងារ និងវិជ្ជាដែលមិនមានទោស កុសលចិត្តរបស់បុគ្គលនោះ កាលកើតឡើងដោយអំណាចនៃកម្មប្បច្ច័យ និងឧបនិស្សយប្បច្ច័យ រមែងជាញាណសម្បយុត្ត ។ ម្យ៉ាងទៀត កុសលចិត្តអាស្រ័យឧប្បត្តិរបស់បុគ្គលកើតឡើងក្នុងលោក ដែលប្រាសចាកការបៀតបៀន រមែងជាញាណសម្បយុត្ត ពាក្យនេះសមដូចពុទ្ធដីកាត្រាស់ទុកថា បទនៃធម៌របស់សត្វនោះ អ្នកមានសេចក្ដីសុខក្នុងលោកនោះ រមែងអណ្ដែត ម្នាលភិក្ខុទាំងឡាយ សតិក៏កើតឡើងបានយឺតយូរ តែសត្វនោះរមែងជាអ្នកមានចំណែកនៃគុណវិសេស បានឆាប់រួសរាន់

នោះឯង ។ ម្យ៉ាងទៀត កុសលអាស្រ័យភាពចាស់ក្លានៃឥន្ទ្រិយរបស់អ្នកដែលចម្រើនវ័យ ដែលជាបញ្ញាទសកៈកើតឡើង គឺជាញាណសម្បយុត្តដូចគ្នា ។ ម្យ៉ាងទៀត កិលេសដែលបុគ្គលសង្កត់សង្កិនបានហើយ កុសលចិត្តអាស្រ័យភាពជាអ្នកឆ្ងាយចាកកិលេសរបស់បុគ្គលនោះ ក៏ជាញាណសម្បយុត្ត ។

ពាក្យនេះ សមដូចគាថាពន្ធដែលត្រាស់ទុកថា បញ្ញារមែងកើតអំពីការប្រកប សេចក្តីវិនាសនៃបញ្ញារមែងកើតអំពីការមិនប្រកប ។ ការបម្រុងតាក់តែង ពោល គឺការប្រកបចិត្តដែលញ៉ាំងឧស្សាហ៍ដោយល្អ ឲ្យកើតដល់ខ្លួន ឬបុគ្គលដទៃ ឈ្មោះថា សង្ខារ ចិត្ត ឈ្មោះថា **អសង្ខារ** ដោយអត្ថថា មិនមានសង្ខារនោះ ។ ចិត្តណាដែលរមែងប្រព្រឹត្តទៅដោយសង្ខារនោះ ហេតុនោះ ចិត្តនោះ ឈ្មោះថា **សសង្ខារ** ។ ចិត្តណាដែលប្រាសចាក គឺវៀរចាកញាណ ហេតុនោះ ចិត្តនោះ ឈ្មោះថា **ញាណវិប្បយុត្ត** ។ គប្បីជ្រាបថា ការមិនមាន គឺការមិនប្រព្រឹត្តទៅនៃញាណនោះឯង ឈ្មោះថា **ប្រាសចាក** ក្នុងបទថា **ញាណវិប្បយុត្តំ** នេះ ។ ធម្មជាតិ ឈ្មោះថា ឧបេក្ខា ដោយអត្ថថា ព្រងើយ អធិប្បាយថា សូម្បីសោយអារម្មណ៍ ក៏ឈ្មោះថា ព្រងើយដល់អារម្មណ៍ ព្រោះជាធម្មជាតិស្ថិតនៅដោយអាការជាកណ្តាលៗ ។ ម្យ៉ាងវិញទៀត ធម្មជាតិដែលឈ្មោះថា ឧបេក្ខា ព្រោះអត្ថថា ចូលដល់ គឺឃើញ បានដល់ ការសោយនូវអារម្មណ៍មិនខុសអំពីសុខ និងទុក្ខ ។

ម្យ៉ាងទៀត ធម្មជាតិដែលឈ្មោះថា ឧបេក្ខា ដោយអត្ថថា សម៉ឹង គឺសោយអារម្មណ៍ដែលកើតឡើង គឺដោយសមគួរ មិនមានការធ្លាក់ទៅក្នុងចំណែកនៃឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ចិត្តប្រកបដោយឧបេក្ខានោះ ព្រោះហេតុនោះ ទើបឈ្មោះថា **ឧបេក្ខាសហគតំ** គឺប្រកបដោយឧបេក្ខា ពាក្យដ៏សេសទាំងអស់ មានន័យដូចបានពោលទុក ហើយក្នុងខាងដើមនោះឯង ។

លោកអាចារ្យកាលនឹងលើកកាមាវចរកុសលចិត្ត ៨ ដួងឡើង សម្តែងយ៉ាងនេះហើយ ឥឡូវនេះ ប្រាថ្នានឹងសម្តែងអាការ គឺការប្រព្រឹត្តទៅនៃកាមាវចរកុសលចិត្តទាំងនោះ ទើបផ្តើមពាក្យថា **យទា ហិ** ជាដើម ។ បណ្តាបទទាំងនោះ ដោយ **អាទិ**-ស័ព្ទក្នុងបទថា **បដិគ្គាហកាទិសម្បត្តិំ** នេះ លោកអាចារ្យសង្គ្រោះនូវសម្បត្តិមានទេសៈ កាលៈ និងកល្យាណមិត្តជាដើម ។ ដោយ **អញ្ញ**-ស័ព្ទក្នុងពាក្យថា **អញ្ញំ វា សោមនស្សហេតុំ** នេះ លោកសង្គ្រោះហេតុទាំងឡាយ ភាពជាអ្នកច្រើនទៅដោយសទ្ធា ភាពជាអ្នកមានទិដ្ឋិបរិសុទ្ធ ភាពជាអ្នកមានប្រក្រតីឃើញអានិសង្សក្នុងការធ្វើកុសល ភាពជាអ្នកមានបដិសន្ធិប្រកបដោយសោមនស្ស ធម៌ដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គ ១១ ប្រការជាដើម ។ ដោយ **អាទិ**-ស័ព្ទក្នុងបទថា **អាទិនយប្បវត្តំ** នេះ លោកកាន់យកទីតាំងនៃសម្មាទិដ្ឋិ ៩ ប្រការនោះឯង មានការបូជារមែងមានផលជាដើម ដូច្នេះ មិនទាន់គ្រប់គ្រាន់ទេ ដោយពិតនោះ គប្បីមានការសង្គ្រោះនូវធម៌ដែលជាទីតាំងនៃធម្មវិចយសម្ពោជ្ឈង្គចូលផង ។ បទថា **បុរក្ខិត្វា** សេចក្តីថា ការធ្វើឲ្យជាប្រធាន ។ ធ្វើឲ្យជាខាងមុខនោះឯង ទាក់ទងជាមួយនឹងប្រធាន ដែលកើតរួមគ្នា ព្រោះលោកប្រាថ្នាយកសម្បយោគ ដូចក្នុងព្រះបាលីទាំងឡាយថា **មនោបុព្វង្គមា ធម្មា** ធម៌ទាំងឡាយមានចិត្តជាប្រធាន ដូច្នេះជាដើម ។ បទថា **អសំសីទន្តោ** សេចក្តីថា មិនដល់នូវការលិចចុះ គឺការស្ទាក់ស្ទើរចិត្តក្នុងការធ្វើបុណ្យ ដោយអំណាចនៃលោភៈនិងមច្ឆរិយៈជាដើម ដោយបទថា **អសំសីទន្តោ** នោះ លោកសម្តែងដល់ភាពជាអ្នកលះបង់បានដាច់ស្រេចជាដើម ។ បទថា **អនុស្សាហិតោ** ប្រែថា សូម្បីមនុស្សពួកខ្លះក៏មិនធ្វើសេចក្តីឧស្សាហ៍ព្យាយាម ។ ពាក្យថា **អនុស្សាហិតោ** នេះ ជាពាក្យសម្តែងដល់ការបំពេញបុណ្យដោយសភាវៈ ។ ចំណែកបទថា **បរេហិ** ជាពាក្យសម្តែងដល់ការឧស្សាហ៍យ៉ាងប្រាកដ ។

ពាក្យថា **មានទានជាដើម** បានដល់ បុញ្ញកិរិយាវត្ថុ ១០ ប្រការ មានទានជាដើម គឺទាន សីល រហូតដល់ទិដ្ឋុជុកម្ម ម្យ៉ាងទៀត ពាក្យថា **ទានជាដើម** បានដល់ បុណ្យដែលសម្រេចដោយទាន សីល ភាវនា និងបុញ្ញកិរិយាវត្ថុ ៧ ដទៃទៀត ក៏ចាត់ចូលទៅក្នុងបុណ្យ ដែលសម្រេចដោយទាន សីល ភាវនានោះឯង ។ ឈ្មោះថា បុណ្យទាំងឡាយ ដោយអត្ថថា រមែងជម្រះសន្តានចិត្ត ដែលជាទីញុំាងបុណ្យឲ្យកើតឡើងដល់ខ្លួនឯង ឬដោយអត្ថថា ញុំាងផលនៃភពដែលគួរបូជាឲ្យកើតឡើង ។ **អស្ស យោគ បុញ្ញចេតនាយ សមង្គិនោ** ។ **ភាពជាអ្នកលះបង់មិនដាច់ស្រេច** បានដល់ ភាពជាអ្នកមានចិត្តនៅអាល័យក្នុងទេយ្យធម៌ ។ ដោយ **អាទិ-ស័ព្ទ** លោកសង្គ្រោះដល់ភាពជាអ្នកបង្អោនទៅក្នុងការសមាទានសីលជាដើម ។

បទថា **តទេវ** លោកពោលទុក ព្រោះជាចិត្តដូចគ្នានឹងចិត្តដែលប្រកបព្រម ដោយសោមនស្សជាដើម ។ មែនពិត សូម្បីវត្ថុដែលដូចគ្នា លោកក៏ប្រើវោហារថា **តទេវ** គឺ **ត-ស័ព្ទ** និង **ឯវ-ស័ព្ទ** ដូចពាក្យថា **សា ឯវ តិត្តិរី** ប្រែថា សត្វទទាញី ក៏ដូចគ្នានោះឯង ពាក្យថា **តានិយេវ ឱសថានិ** ប្រែថា តួឱសថទាំងឡាយនោះឯង ។ ពីរបទថា **ឥមស្មិញ្ហិ អត្ថេ** សេចក្តីថា ក្នុងអត្ថ ពោល គឺការតាំងប្រយោគដែលធ្វើចិត្ត រួញរាឲ្យឧស្សាហ៍ឡើង ។ បទថា **ឯតំ** ប្រែថា បទថា **សង្ខារ** នេះ ។ បទថា **បុព្វបយោគស្ស** សេចក្តីថា ការប្រកបចិត្តដែលប្រព្រឹត្តទៅ ដោយអំណាចនៃចិត្ត ដែលស្ទាក់ស្ទើរក្នុងការធ្វើបុណ្យ ក៏ដោះចេញអំពីការរួញរាចិត្តនោះ ហើយធ្វើសេចក្តីឧស្សាហ៍ ឲ្យកើតឡើងដោយល្អ ស័ព្ទថា **បុព្វ** ក្នុងពាក្យថា **បុព្វបយោគស្ស** នេះ លោកពោលទុក ព្រោះអធិប្បាយថា សង្ខារនោះ រមែងមានដោយអំណាចនៃការតាក់តែងខាងដើម ដែលប្រព្រឹត្តទៅយ៉ាងនោះ មិនមែនពោលទុកព្រោះសង្ខារនោះ ប្រព្រឹត្តទៅក្នុងកាលមុនទេ ។ លោកប្រើស័ព្ទថា កុមារមិនទាន់ដឹងក្តី ដើម្បីសម្តែងសេចក្តីមិនមានសម្មាទិដ្ឋិ

ដែលប្រព្រឹត្តទៅដោយន័យថា ទានដែលឲ្យហើយ រមែងមានផលជាដើម ។ លោកប្រើស័ព្ទថា **ដោយរួសរាន់** ដើម្បីសម្តែងនូវការមិនមានការរួញរា និងការឧស្សាហ៍ ។ អធិប្បាយថា **រមែងជាអ្នកវៀរចាកសោមនស្ស** ហើយធ្វើបុណ្យ ។ ពាក្យថា **អាស្រ័យសេចក្តីមិនមានហេតុនៃសោមនស្ស** នេះ គប្បីជ្រាបថា ត្រឹមតែនិទស្សនៈ ។ ព្រោះថា សូម្បីមជ្ឈត្តារម្មណចិត្ត និងសង្ខារបែបនោះជាដើម រមែងជាហេតុនៃចិត្តប្រកបដោយឧបេក្ខានោះឯង ។

បទថា **ឯវំ** ជាដើម ជាពាក្យនិគម ។ កាមាវចរកុសលចិត្តទាំង ៨ ដួងនេះ គប្បីជ្រាបថា គោងយកអារម្មណ៍ណាមួយ បណ្តាអារម្មណ៍ទាំង ៦ គឺរូបារម្មណ៍ រហូតដល់ ធម្មារម្មណ៍ ហើយកើតឡើងដោយអំណាចនៃកាយកម្មជាដើម ដោយទ្វារទាំង ៣ មានកាយទ្វារជាដើម ក្នុងលំដាប់នៃមនោវិញ្ញាណធាតុ ដែលជាអហេតុកវិបាកប្រកបដោយឧបេក្ខា ។ បណ្តាកាមាវចរកុសលចិត្តទាំង ៨ ដួងនោះ កាមាវចរកុសលចិត្តដែលជាញាណសម្បយុត្ត ៤ ដួង រមែងឲ្យកើតតិហេតុកបដិសន្ធិឡើងក្នុងកាលណា កាលនោះវិបាកចិត្តទាំង ១៦ ដួង រមែងឲ្យផល ។ តែក្នុងកាលណាទុហេតុកបដិសន្ធិកើតឡើង ក្នុងកាលនោះ វិបាកចិត្ត ១២ ដួង ដែលវៀរតិហេតុកៈចេញហើយ រមែងឲ្យផល ។ វិបាកចិត្តដែលជាតិហេតុកៈ រមែងមិនញ៉ាំងអហេតុកបដិសន្ធិឲ្យកើតទេ ចំណែកវិបាកចិត្តដែលជាទុហេតុកៈ ក្នុងកាលដែលទុហេតុកបដិសន្ធិ រមែងឲ្យផល ១២ ដួង ក្នុងកាលដែលអហេតុកបដិសន្ធិរមែងឲ្យផល ៨ ដួង ។ តិហេតុកបដិសន្ធិ រមែងមិនមានដោយវិបាកចិត្ត ដែលជាទុហេតុកៈឡើយ ។ ពាក្យថា **ឲ្យផល ៨ ដួង** នេះ លោកពោលទុកដោយអំណាចកម្ម ដែលញ៉ាំងបដិសន្ធិឲ្យកើត ។ ម្យ៉ាងទៀត សូម្បីវិបាកចិត្តដែលជាសហេតុកៈក៏រមែងមានដល់សត្វ ដែលមានអហេតុកបដិសន្ធិបានដូចគ្នា ដោយកម្មដទៃ ដូចមានព្រះបាលីថា កវគ្គដែលជាសហេតុកៈ ជាបច្ច័យ

ដោយអនន្តរប្បច្ច័យដល់ភវង្គ ដែលជាអហេតុកៈ ។ ក្នុងចំណែកនេះ គប្បីជ្រាបថា ចិត្តដែលកើតឡើងដោយបច្ច័យមានកម្លាំងខ្លាំងក្លាជាអសង្ខារ ដែលកើតឡើងដោយបច្ច័យមានកម្លាំងខ្សោយជាសសង្ខារ ។ ចំណែកអាចារ្យពួកណា ប្រាថ្នានូវសេចក្តីនៃវិបាកចិត្ត ដែលជាអសង្ខារ និងសសង្ខារ ដោយបករណ៍ដែលមានមកតាមមតិរបស់អាចារ្យពួកនោះ គប្បីប្រកបថា រមែងឲ្យផល ១២ ដួង និង ៨ ដួង ។ វិបាកចិត្តនេះ កាលឲ្យផល ៣ ប្រការយ៉ាងនេះ រមែងកើតក្នុងសុគតិភព ដែលជាកាមាវចរៈ និងការបរិបូណ៌ដោយភោគៈទាំងក្នុងសុគតិភូមិ និងទុគ្គតិភូមិ ។ មែនពិត ភោគសម្បត្តិ ដូចជាភោគសម្បត្តិរបស់ទេវតា រមែងកើតឡើងសូម្បីដល់នាគ និងគ្រុឌជាដើម ។ ព្រោះផលដែលគួរប្រាថ្នារបស់អកុសលមិនមានឡើយ ដូច្នេះ ។

**បទ-ស័ព្ទ** ក្នុងបទថា **រូបាវចរំ បទ** ជានិបាតវិសេសជោតក ។ ដោយ **បទ** ស័ព្ទនោះ លោកអាចារ្យរមែងបំភ្លឺអត្ថដោយន័យផ្សេងពីនេះ គឺដែលកំពុងពោលដល់ថា រូបាវចរកុសលនេះ មិនដូចជាកាមាវរកុសលដែលធ្វើនាទីត្រឹមតែតទង្គប្បហានដល់កិលេសទាំងឡាយ ចំណែករូបាវចរកុសលនេះ ធ្វើនាទីជាវិក្ខម្ភនប្បហាន ។ ម្យ៉ាងទៀត រូបាវចរកុសលនេះ មិនដូចជាកាមាវចរកុសលនោះ ដែលចែកចេញជា ៨ ដួង ដោយសេចក្តីផ្សេងគ្នានៃវេទនា ញាណ និងសង្ខារ ចំណែករូបាវចរកុសលនេះ ចែកដោយប្រការដទៃអំពីកាមាវចរកុសលនោះឯង ។ កុសលចិត្តនេះ ប្រកបដោយវត្ថុមានអាសវៈ និងប្រាសចាកនីវរណៈ គប្បីឃើញថា ជារូបាវចរៈ ។ ដោយពាក្យថា **ប្រកបដោយវត្ថុនោះឯង** នេះ លោកហាមនូវអរូបាវចរៈ ដោយពាក្យថា **មានអាសវៈ** នេះ លោកហាមមគ្គចិត្តដួងទី ១ ព្រោះពាក្យថា **ប្រាសចាកនីវរណៈ** នេះ លោកហាមមគ្គចិត្ត ២ ដួង ( គឺសោតាបត្តិមគ្គចិត្ត និងសកទាគាមិមគ្គចិត្ត ) ដែលប្រកបដោយបដិឃៈ ។ លោកអាចារ្យផ្តើមពាក្យថា **សេយ្យថីទំ** ជាដើម ដើម្បីនឹង

បើកផ្លូវនូវសេចក្ដីដែលពោលទុកដោយសង្ខេបថា រូបាវចរកុសលចិត្តមាន ៥ ដួង ដោយសេចក្ដីផ្សេងគ្នានៃការប្រកបដោយអង្គឈាន យ៉ាងនេះ គឺឈានមានអង្គ ៥ ខ្លះ មានអង្គ ៤ ខ្លះ មានអង្គ ៣ ខ្លះ មានអង្គ ២ ខ្លះ និងឈានមានអង្គ ២ ក្រៅពីនេះទៀត ។ ពាក្យដែលគួរនឹងពោលក្នុងពាក្យនោះ លោកអាចារ្យពោលទុកហើយក្នុង **ឈានកថា** ខាងដើមនោះឯង ។ រូបាវចរកុសលនេះ ជាចំណែកការនាមយកុសលតែម្យ៉ាង តោងយកកសិណា មានបឋវីកសិណាជាដើមមកជាអារម្មណ៍ តាមន័យដែលបានពោលទុកហើយ កើតឡើងក្នុងលំដាប់នៃកុសល ដែលជាឈានសម្បយុត្តតាមសមគួរ ម្យ៉ាងទៀត រូបាវចរកុសលនេះចែកដោយប្រភេទ មានឈានថ្នាក់ទាបជាដើម គប្បីឃើញថា ឲ្យសម្រេចការកើតឡើង ក្នុងព្រហ្មលោកទាំង ១៦ ជាន់ មានព្រហ្មបារិសជ្ជាតាមលំដាប់ ។

ចិត្តដែលគប្បីសម្រេចដោយល្អ ដោយការឈានកន្លងរូបសញ្ញាជាដើម ឈ្មោះថា **អរូបាវចរៈ** ។ ពីរបទថា **ចតុន្នំ អារុប្បានំ** ប្រែថា ដោយអរូបជ្ឈានទាំង ៤ ពោល គឺឧបេក្ខា និងសមាធិ ។ បទថា **អារុប្បានំ** នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងករណៈ ។ ម្យ៉ាងទៀត ការប្រកប គឺសេចក្ដីផ្សេងគ្នានៃការប្រកបធ្វើអរូបទាំងឡាយឲ្យជាអារម្មណ៍ជាដើម យ៉ាងណា ដោយអំណាចនៃការប្រកបនោះ ។

ពាក្យថា **មានប្រការដូចពោលហើយ** គឺមានប្រការដូចបានពោលទុកហើយក្នុង**អរូបកថា** ខាងដើម ។ពាក្យថា **ដួងទី ១** បានដល់ អរូបាវចរកុសលចិត្តដួងទី ១ ។ សូម្បីក្នុងពាក្យថា **ដួងទី ២ ដួងទី ៣ ដួងទី ៤** នេះ ក៏មានន័យនេះដូចគ្នា ។ អរូបាវចរកុសលចិត្តទាំង ៤ ដួងនេះ ជាការនាមយៈតែម្យ៉ាង តោងចាប់យកអារម្មណ៍ទាំងនេះ គឺកសិណុគ្ឃាដិមាកាស ( អាកាសដែលបើកកសិណា) អរូបវិញ្ញាណដួងទី ១ **នត្ថិភាវបញ្ញត្តិ** អាកិញ្ចញ្ញាយតនៈមកជាអារម្មណ៍តាមលំដាប់កើតឡើងក្នុងលំដាប់

នៃកុសល ដែលជាញាណសម្បយុត្ត ប្រកបព្រមដោយឧបេក្ខា ឲ្យវិបាកក្នុងបដិសន្ធិកាល និងបវត្តិកាល ក្នុងព្រហ្មលោកជាន់អរូបព្រហ្ម ៤ ។ ចំណែកពាក្យដ៏សេសដែលនឹងគប្បីពោលក្នុងអធិការនេះខ្ញុំបានពោលទុកហើយខាងដើមនោះឯង ។ ចិត្តនឹងគប្បីសម្រេចដោយល្អ ព្រោះបន្តគ្នានៃវិសុទ្ធិទាំង ៦ ឈ្មោះថា **លោកុត្តរ** ។ ពាក្យដែលនឹងគប្បីនិយាយក្នុងលោកុត្តរនោះ នឹងមានមកខាងមុខ ។ បទថា **ចតុមគ្គសម្បយោគតោ** បានដល់ ការប្រកបដោយអរិយមគ្គ ៤ ទាំងនេះ គឺសោតាបត្តិមគ្គ រហូតដល់អរហត្តមគ្គ ។ លោកុត្តរចិត្តទាំង ៤ ដួងនេះ ជាការនាមយៈតែម្យ៉ាង តោងចាប់យកព្រះនិព្វានមកជាអារម្មណ៍ឲ្យកើតឡើង ដោយឈ្មោះថា **សុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ** គប្បីឃើញថា បដិសេធដល់ការកើតក្នុងភព មានភពនៃសត្វជាដើម ។ អធិប្បាយថា **មាន ២១ ដួង** ដោយន័យមិនសង្ខេប និងមិនពិស្តារពេក ។

ក្នុងបទថា **កាមាវចរមេវ** នេះ អធិប្បាយថា អាចារ្យទាំងឡាយនៅក្នុងនិកាយដទៃ រមែងប្រាថ្នាសូម្បីរូបាវចរៈ និងអរូបាវចរៈថាជាកុសល ព្រោះដូច្នោះ ទើបលោកប្រើសព្ទថា **កាមាវចរ** ដើម្បីនឹងបដិសេធនូវមតិរបស់អាចារ្យក្នុងនិកាយដទៃនោះ ។ លោកប្រើសព្ទ **អវធារណ** ដើម្បីសម្តែងថា សូម្បីចិត្តកើតឡើងក្នុងមហគ្គតភូមិ ញុំាងវិបាកឲ្យកើតក្នុងបវត្តិកាល ក្នុងរូបធាតុ ក្នុងមហគ្គតភូមិនោះ ក៏ជាកាមាវចរៈដោយចំណែកមួយប៉ុណ្ណោះ ។ សួរថា បើយ៉ាងនោះ ព្រោះហេតុអ្វី ទើបជាកាមាវចរៈប៉ុណ្ណោះ ? ក្នុងសេចក្តីនោះ ខ្ញុំបានពោលហេតុទុកហើយ ។ ពោលទុកដូចម្តេច ? ពោលទុកថា កាមតណ្ហា ឈ្មោះថា កាម ដោយការលុបបទខាងចុង ឈ្មោះថា **អវចរ** ដោយអត្ថថា ជាទីត្រាច់ទៅ ការអន្ទោលទៅរបស់កាម ឈ្មោះថា កាមាវចរៈ ។ ក្នុងបទថា **កាមាវចរ** នេះ ជាវិស័យនៃកាមតណ្ហា លោកពោលថា ជាហេតុនៃកាមាវចរៈ

ដូចជាវិស័យនៃរូបតណ្ហា និងអរូបតណ្ហា លោកពោលថា ជាហេតុនៃរូបាវចរៈ និងអរូបាវចរៈ ។ កាមាវចរៈនេះក្នុងបំណងយ៉ាងនេះដោយចំណែកមួយ ។ លក្ខណៈដែលជ្រួតជ្រាបទៅ មិនគប្បីមានដោយប្រការដទៃ ។ បើនរណាមួយនឹងគប្បីធ្វើការកំណត់ភូមិដោយអំណាចនៃធម៌ ដែលនឹងគប្បីតោងយកជាអារម្មណ៍ កាលបើយ៉ាងនេះ ការរួបរួមធម៌ដែលមិនជាអារម្មណ៍ទាំងឡាយ ក៏មិនគប្បីមានបាន ។

បើធ្វើការកំណត់ភូមិ ដោយអំណាចការញ៉ាំងវិបាកឲ្យកើតឡើង កាលបើយ៉ាងនេះ ការរួបរួមធម៌ដែលមិនមែនជាវិបាក ក៏មិនគប្បីមាន ។ ព្រោះដូច្នោះ គប្បីធ្វើវិស័យនៃកាមតណ្ហានោះ ដល់បរិយាបន្នធម៌ទាំងឡាយ ( លោកិយធម៌ ) ដោយអំណាចនៃធម៌ដែលជាអារម្មណ៍ ចំណែកអបរិយាបន្នធម៌ទាំងឡាយ ( លោកុត្តរធម៌ ) គប្បីជ្រាបថា ឈ្មោះថា លោកុត្តរ ព្រោះជាធម៌ឆ្លងហើយចាកលោក និងគប្បីជ្រាបថាជាធម៌ឈ្មោះថា អនុត្តរៈ ព្រោះមិនមានធម៌ដែលក្រៃលែងជាង ។

បទថា **បរិយាបន្នា** សេចក្តីថា តណ្ហាដែលធ្វើដែនកំណត់ បានដល់ ការកំណត់កាន់យកហើយ គឺទាញទុកហើយ ។ សួរថា ក្នុងពាក្យថា កាមាវចរៈនេះ កាមតណ្ហាដូចម្តេច ? បានដល់ តណ្ហា ដែលមានកាមាវចរធម៌ជាអារម្មណ៍ តើកាមាវចរធម៌ដូចម្តេច ? បានដល់ ធម៌ដែលជាវិស័យរបស់កាមតណ្ហា ព្រោះដូច្នោះ ភាវៈនៃធម៌ក្រៅពីនេះ ជាទីអាស្រ័យរបស់ធម៌ក្រៅពីនេះ ទើបជាការខុសឆ្គងមិនមែនឬ ? ឆ្លើយថា សេចក្តីនេះបណ្ឌិតមិនគប្បីឃើញយ៉ាងនោះទេ គប្បីកាន់យកតណ្ហាយ៉ាងស្តើង ដោយសភាពជាកាមតណ្ហា ព្រោះថា ជាធម្មជាតិ បង្អោនទៅក្នុងឱកាស ( ភូមិ ) ១១ មានអវីចីនរកជាដើម ហើយកំណត់កាន់យកធម៌ដែលជាកាមាវចរៈ ដោយភាវៈជានិស្ស័យនៃតណ្ហា ដែលមានកាមតណ្ហានោះ ជាសភាវៈ ។ ពាក្យថា **ឯត្ថាវចរា** ( ត្រាច់ទៅក្នុងធម៌នេះ) សូម្បីក្នុងនិក្ខេបកណ្ឌ ក៏គប្បីកាន់យកថា ទ្រង់ត្រាស់សំដៅដល់ភាវៈជាវិស័យ

នៃកាមតណ្ហា ដែលមានឱកាសកំណត់ដោយអវីចិនរក និងទេវលោកជាន់បរនិម្មិត ។ ចំណែកឱកាសរបស់កាមាវចរធម៌នោះ គប្បីជ្រាបដោយសេចក្ដីដែលតណ្ហាបង្អោនទៅក្នុងឱកាសនោះ ។

បទថា **មូលតោ តិវិធំ** បានដល់ អកុសលមូល ៣ មានលោភមូលជាដើម អកុសលចិត្តសូម្បីប្រកបដោយអកុសលមូលនោះ ក៏មាន ៣ យ៉ាង ដោយអំណាចនៃអកុសលមូល ៣ នោះឯង ។ អកុសលមូលទាំងនោះ ឈ្មោះថា មូល ដោយសេចក្ដីថា ជាឫសគល់ ព្រោះជាហេតុនៃសេចក្ដីតាំងមាំដោយល្អ ។ លោភៈជាមូលរបស់ចិត្តនេះ ហេតុនោះ ទើបចិត្តនេះឈ្មោះថា **លោភមូល** ។ លោកសម្ដែងទុកដោយពាក្យដែលជាអសាធារណៈ ដូចពាក្យថា សំឡេងស្គរ ពន្លកស្រូវដំណើប ។ **ទោសមូល** ក៏ដូចគ្នា ។ មោហៈតែម្យ៉ាងជាមូលរបស់ចិត្តនេះដទៃក៏ទេ ព្រោះដូច្នោះ ទើបឈ្មោះថា មោហមូល ។

បទថា **សោមនស្សុបេក្ខាទិដ្ឋិគតសង្ខារភេទតោ** គប្បីប្រកបភេទសព្ទចូលត្រង់បទមួយថា **សោមនស្សុបេក្ខាភេទតោ** ប្រែថា ដោយប្រភេទនៃសោមនស្ស និងឧបេក្ខា **ទិដ្ឋិគតភេទតោ** ប្រែថា ដោយប្រភេទនៃទិដ្ឋិ **សង្ខារភេទតោ** ប្រែថា ដោយប្រភេទនៃសង្ខារ ។ ពាក្យណាដែលគួរនឹងពោលក្នុងទីនេះ ពាក្យនោះមានន័យដូចបានពោលទុកខាងដើមនោះឯង ។ បទថា **ទិដ្ឋិគតសម្បយុត្តំ** អធិប្បាយថា ទិដ្ឋិនោះឯង ឈ្មោះថា **ទិដ្ឋិគតំ** ដូចបទថា **គូថគតំ** ប្រែថា លាមក **មុត្តគតំ** ប្រែថា ទឹកមូត្រ ។ ម្យ៉ាងទៀត ទិដ្ឋិតែមួយ ព្រោះជាការកាន់យកខុស មិនមែនវត្ថុដែលទៅក្នុងទិដ្ឋិនេះឡើយ គឺសភាវៈយ៉ាងនោះឯង ព្រោះដូច្នោះ ទើបឈ្មោះថា **ទិដ្ឋិគតំ** ប្រែថា ទៅក្នុងទិដ្ឋិ ។ ទិដ្ឋិនេះប្រព្រឹត្តទៅជាមួយនឹងលោភៈប៉ុណ្ណោះ មិនមែនជាមួយទោសៈទេ ព្រោះជាការប្រកាន់មាំថា ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។

បទថា **ក្នុងកាលណា** ជាដើម ជាពាក្យសម្តែងអាការប្រព្រឹត្តទៅនៃលោភមូលចិត្តទាំងឡាយ ។ បទថា **មិច្ឆាទិដ្ឋិ** បានដល់ មិច្ឆាទិដ្ឋិ មានឧច្ឆេទទិដ្ឋិ ។ សត្វទាំងឡាយមានចិត្តវិបល្លាសដោយមិច្ឆាទិដ្ឋិនោះ បដិសេធនូវបរលោកថា វិស័យរបស់ជីវៈមានដរាបណា អារម្មណ៍របស់ឥន្ទ្រិយមានដរាបនោះ ដូច្នេះ រមែងបានដល់ភាពជាអ្នកធ្លាក់ទៅ ក្នុងកាមទាំងឡាយដោយប្រការណាមួយ ដោយយល់ថា ទោសក្នុងកាមទាំងឡាយមិនមានដូច្នេះ ។ ដោយ **អាទិ**-ស័ព្ទ លោកអាចារ្យរមែងរួមយកមិច្ឆាទិដ្ឋិមានជាអាទិយ៉ាងនេះ គឺការឃើញមុខរបស់បុត្រ ក៏ជាផ្លូវនៃស្ថានសួគ៌ និងព្រះនិព្វានបាន ដោយពាក្យថា នេះជាផ្លូវដែលជាហេតុនាំឲ្យមនុស្សមានបុត្រទាំងឡាយ ប្រាសចាកសេចក្តីសោកដើរទៅដល់បានរៀបចំទុកក្នុងយានរបស់ទេព្តាមុននោះឯងជាដើម ។ បសុសត្វទាំងឡាយ និងបក្សីទាំងឡាយរមែងឃើញផ្លូវនោះ ដោយហេតុនោះ ទើបវាប្រព្រឹត្តមេថុន សូម្បីក្នុងមាតាបាន ។

**វា**-ស័ព្ទក្នុងបទថា **កាមេ វា** នេះ មានអត្ថជាអនិយម ដោយ **វា**-ស័ព្ទ នោះ លោកអាចារ្យរមែងរួមយកការកាន់យកខុស មានជាអាទិយ៉ាងនេះ ជាការនាំយកមាសរបស់ព្រាហ្មណ៍ទាំងឡាយទៅនោះឯង ព្រោះអទិន្នាទានមានទោស ក្រៅអំពីនេះមិនមានទោស ។ មុសាវាទ ដើម្បីប្រយោជន៍ដល់គ្រូទាំងឡាយ ដល់គោទាំងឡាយ ដល់ខ្លួន ដល់ជីវិត និងដល់ការប្រៀបការមិនមានទោស ក្រៅអំពីនេះ គឺមានទោស ។ ការញុះញង់ និងការនាំទៅដើម្បីជាប្រយោជន៍ដល់គ្រូជាដើមមិនមានទោស ក្រៅអំពីនេះមានទោស ។ ការនិទានរឿងមហាភារតយុទ្ធ និងរឿងដណ្តើមនាងសិតាជាដើម រមែងមានដើម្បីស្ងប់រម្ងាប់បាប លោកអាចារ្យរមែងសង្គ្រោះការកាន់យកខុសជាដើមដូចពោលមកនេះឯង ។ បទថា **ទិដ្ឋមង្គលជាដើម** បានដល់ ទិដ្ឋមង្គល សុតមង្គល និងមុតមង្គល ។ ពាក្យថា **ភៀវក្វាដោយសភាវៈ** បានដល់ ភៀវក្វា គឺមុតស្រួច ដោយ

កិច្ចរបស់ខ្លួននោះឯង ដោយអំណាចនៃលោកៈ ឬការប្រកាន់ខុស ។ បទថា **យឺតយូរ** គឺបង្អែបង្អង់ មិនក្លាហានរឹងមាំ ។ ចិត្តដូច្នោះ រមែងប្រព្រឹត្តទៅដោយការដឹកនាំរបស់ខ្លួនឯងខ្លះ របស់អ្នកដទៃខ្លះ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា ត្រូវដឹកនាំ ។ ដោយ វា-ស័ព្ទថា **បរភណ្ឌំ វា ហរតិ** គប្បីឃើញការរួម សូម្បីមុសាវាទដែលប្រព្រឹត្តទៅយ៉ាងនោះជាដើម ។ បទថា **កាមទាំងឡាយ** បានដល់ កាមទាំងឡាយដែលកំពុងសោយក្តី ។ ដោយ **វា-ស័ព្ទ** លោកអាចារ្យរមែងសង្គ្រោះការកាន់យកជាដើមថា វត្ថុណាដែលបានមក ព្រោះជាភាពជាទ្រព្យរបស់បុគ្គលដទៃ មិនមែនជាវត្ថុដែលប្រព្រឹត្តទៅតាមសេចក្តីប្រាថ្នា វត្ថុនោះគួរកាន់យកបាន ។

ឈ្មោះថា **មានពីរយ៉ាងប៉ុណ្ណោះ** ព្រោះមិនមានសេចក្តីផ្សេងគ្នា ដោយអំណាចនៃសម្បយុត្តធម៌ ។ សួរថា បើយ៉ាងនោះ ហេតុអ្វី ទើបលោកពោលថា ប្រកបព្រមដោយទោមនស្សសម្បយុត្តដោយបដិឃៈទៅវិញ ? ឆ្លើយថា លោកពោលទុកដើម្បីកំណត់ចិត្តនោះ ដោយធម៌ដែលមិនទូទៅ ។ បទថា **បាណាតិបាតាទីសុ** សេចក្តីស្មើនឹងព្រះបាលីថា **បាណាតិបាតនាទីសុ** ប្រែថា មានការធ្វើជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វជាដើម ។ **អាទិ-ស័ព្ទ** លោករួមដល់អទិន្នាទាន មុសាវាទ បិសុណាវាទ ផរុសវាទ សម្ផប្បលាប និងព្យាបាទចូលផងដែរ ។ លោកអាចារ្យពោលថា **ក្នុងកាលដែលប្រព្រឹត្តទៅក្លៀវក្លា និងមិនក្លៀវក្លា** ដោយបំណងថា ចិត្តដែលជាធម្មជាតិក្លៀវក្លាដោយសភាវៈប្រព្រឹត្តទៅជាអសង្ខារនោះឯង ចិត្តក្រៅអំពីនេះជាសសង្ខារ ។ ចំណែកចិត្តដែលជាធម្មជាតិយឺតយ៉ាវ ប្រព្រឹត្តទៅជាសសង្ខារតែម្យ៉ាងប៉ុណ្ណោះ ។ ព្រោះដូច្នោះ ទើបមិនអាចដឹងបាន ។ គប្បីឃើញថា លោកពោលទុកយ៉ាងនេះ ព្រោះអធិប្បាយថា ចិត្តណាប្រព្រឹត្តទៅដោយសសង្ខារ ដែលប្រកបព្រមដោយបយោគ ចិត្តនោះជាធម្មជាតិយឺតយ៉ាវតែម្យ៉ាង ។

ចិត្តដែលមានហេតុតែ ១ គឺមោហៈ ជាចិត្តដែលវង្វេងក្រៃលែង ព្រោះវៀរចាកមូលដទៃ និងជាចិត្តកម្រើកញាប់ញ័រ ព្រោះប្រកបដោយវិចិកិច្ឆា និងឧទ្ធច្ចៈ ព្រោះដូច្នោះ **ទើបជាចិត្តដែលសហគតៈដោយឧបេក្ខាតែម្យ៉ាង** ការមានចិត្តដែលមានហេតុតែ ១ គឺមោហៈនោះ ជាធម្មជាតិក្លាហានដោយសភាវៈ និងមិនមានសូម្បីក្នុងកាលខ្លះឡើយ ។ ចិត្ត ២ ដួងដែលប្រព្រឹត្តទៅដោយការសង្ស័យ និងដោយអំណាចការរាយមាយក្នុងអារម្មណ៍ នឹងត្រូវមានភាពជាធម្មជាតិក្លៀវក្លាដោយសភាវៈ ឬជាធម្មជាតិដែលនឹងត្រូវឲ្យឧស្សាហ៍ក្នុងកិច្ចយ៉ាងណា ព្រោះដូច្នោះ សេចក្តីផ្សេងគ្នានៃសង្ខារក្នុងចិត្ត ២ ដួងនោះ រមែងមិនមាន ។

ឧទ្ធច្ចៈ សូម្បីមាននៅក្នុងអកុសលចិត្តដទៃ ជាធម្មជាតិមានកម្លាំងក្នុងចិត្តដួងនេះប៉ុណ្ណោះដោយពិសេស ព្រោះហេតុដូច្នោះឯង ទើបជាប្រធានប្រព្រឹត្តទៅក្នុងសម្បយុត្តធម៌ទាំងឡាយ ព្រោះហេតុនោះ ទើបចិត្តដួងនេះ លោកពោលទុកយ៉ាងពិសេសដោយឧទ្ធច្ចៈថា **សម្បយុត្តដោយឧទ្ធច្ចៈ** ។

ពិតយ៉ាងនោះ ក្នុងព្រះបាលី ឧទ្ធច្ចៈមានមកហើយដោយសរុបក្នុងទីនេះ ចិត្តមានមោហៈជាមូលដោយអំណាចនៃធម៌ដែលជាប្រធាន ដែលមិនទូទៅយ៉ាងនេះ គប្បីឃើញថា លោកពោលទុក ២ យ៉ាង គឺសម្បយុត្តដោយវិចិកិច្ឆា ១ សម្បយុត្តដោយឧទ្ធច្ចៈ ១ ។ **ការធ្លាក់ចុះនៃចិត្តមិនបាន** បានដល់ សេចក្តីសង្ស័យ ។ សេចក្តីរាយមាយបានដល់ ការមិនចូលទៅស្ងប់ អធិប្បាយថា ភាវៈដែលរវើរវាយ ។

អកុសលចិត្តទាំង ១២ ដួងនេះ គប្បីជ្រាបថា តោងយកអារម្មណ៍ណាមួយក្នុងចំណោមអារម្មណ៍ទាំង ៦ ឲ្យកើតឡើង ដោយអំណាចកម្មបថ មានបាណាតិបាតជាដើម និងដោយអំណាចកម្មបថតាមសមគួរដោយអាស្រ័យកាយកម្មជាដើម ក្នុងទ្វារទាំង ៣ មានកាយទ្វារជាដើម ក្នុងលំដាប់នៃមនោវិញ្ញាណធាតុ ដែលជាអហេតុកកិរិយា

ប្រកបព្រមដោយឧបេក្ខា ។

បណ្ដាអកុសលទាំង ១២ ដួងនោះ វៀរតែអកុសលចិត្តដែលប្រកបដោយឧទ្ធច្ចៈចេញ អកុសលចិត្តទាំង ១១ ដួងដ៏សេស រមែងបដិសន្ធិក្នុងអបាយទាំង ៤ និងឲ្យវិបាកក្នុងបវត្តិកាល ក្នុងសុគតិភូមិ ។ ចំណែកអកុសលចិត្ត ដែលប្រកបដោយឧទ្ធច្ចៈ ឲ្យវិបាកក្នុងបវត្តិកាលតែម្យ៉ាង ។ ក្នុងអធិការនេះ ប្រសិនបើមានអ្នកសង្ស័យថា ហេតុអ្វី អកុសលចិត្តដែលសម្បយុត្តដោយវិចិកិច្ឆា ដែលមានកម្លាំងខ្សោយជាងអកុសលចិត្តទាំងពួង រមែងឲ្យបដិសន្ធិបាន ហើយអកុសលចិត្តដែលប្រកបព្រមដោយឧទ្ធច្ចៈសូម្បីមានកម្លាំងខ្លាំងជាងអកុសលចិត្ត ដែលសម្បយុត្តដោយវិចិកិច្ឆានោះ ព្រោះមានសភាពកាត់នូវអារម្មណ៍បាន មិនឲ្យបដិសន្ធិឬ ? ឆ្លើយថា ព្រោះអកុសលចិត្តដែលប្រកបព្រមដោយឧទ្ធច្ចៈ មិនបានត្រាស់ទុកក្នុងធម៌ ដែលសោតាបត្តិមគ្គគប្បីលះទេ ។ ព្រោះថា អកុសលចិត្តដែលប្រកបព្រមដោយឧទ្ធច្ចៈនេះ កាលឲ្យបដិសន្ធិក៏នឹងគប្បីឲ្យបដិសន្ធិក្នុងអបាយទាំងឡាយ និងធម៌ដែលញុំាងសត្វឲ្យទៅកាន់អបាយក៏ជាធម៌ដែលសោតាបត្តិមគ្គគប្បីលះ ព្រោះដូច្នោះ គួរត្រាស់ទុកក្នុងធម៌ ដែលសោតាបត្តិមគ្គនឹងគប្បីលះនោះ ប៉ុន្តែមិនបានត្រាស់ទុកទេ ។ ព្រោះដូច្នោះ ទើបមិនឲ្យបដិសន្ធិ ចំណែកការឲ្យផលក្នុងបវត្តិកាលរបស់អកុសលចិត្ត ដែលប្រកបព្រមដោយឧទ្ធច្ចៈនោះបុគ្គលណាមួយក៏មិនអាចបដិសេធបានឡើយ ។ ព្រោះព្រះអង្គត្រាស់ទុកក្នុងបដិសម្ភិទាវិភង្គថា ញាណក្នុងធម៌ដែលប្រកបព្រមដោយឧទ្ធច្ចៈ ឈ្មោះថាធម្មប្បដិសម្ភិទា ញាណក្នុងវិបាកនៃធម៌ដែលប្រកបព្រមដោយឧទ្ធច្ចៈនោះ ឈ្មោះថាអត្ថប្បដិសម្ភិទា ។

ចំណែកអាចារ្យមួយពួកទៀតពោលថា អកុសលចិត្តដែលប្រកបព្រមដោយឧទ្ធច្ចៈ ដែលកើតឡើងដល់បុថុជ្ជន រមែងញុំាងវិបាកទាំង ២ ឲ្យកើតឡើង ព្រោះមាន

ធម៌ដែលសោតាបត្តិមគ្គនឹងគប្បីលះជាសម្ភាញ់ សម្រាប់ព្រះសេក្ខបុគ្គលមិនដូច្នោះទេ ព្រោះមិនមានធម៌ដែលសោតាបត្តិមគ្គនឹងគប្បីលះជាសម្ភាញ់នោះ ។ ក្នុងសេចក្តីនេះ គួរពិចារណាដូច្នេះ សួរថា លោកពោលដល់ការឲ្យនូវវិបាកដល់ធម៌ណា ធម៌នោះ ដែលមគ្គ ៣ ខាងលើគប្បីលះ ឬមិនគប្បីលះ ? ឆ្លើយថា ក្នុងសេចក្តីនេះ មានពាក្យ ដែលត្រូវពោលបន្តិចបន្តួចថា បើមគ្គ ៣ ក្នុងខាងលើនឹងគប្បីលះមុនសោត ក្នុងគម្ពីរ បដ្ឋាន ក៏ព្រះអង្គត្រាស់ដល់ភាវៈនៃធម៌ដែលមគ្គ ៣ ខាងលើគប្បីលះ ជាកម្មប្បច្ច័យ មានខណៈផ្សេងគ្នា ។ បើមគ្គទាំង ៣ ខាងលើមិនគប្បីលះក្នុងទស្សនេនបហាតព្វតិកៈ ក៏នឹងគប្បីត្រាស់ទុកក្នុងវិភង្គនៃបទនេះថា **នេវទស្សនេន ភាវនាយ បហាតព្វំ** ប្រែថា ដែលសោតាបត្តិមគ្គគប្បីលះ ក៏មិនមែន ដែលមគ្គ ៣ ខាងលើ គប្បីលះក៏មិនមែន ។ បើមិនត្រាស់ទុកក្នុងទស្សនេនបហាតព្វតិកៈនេះ ព្រោះមានសភាពផ្សេងគ្នាអំពីបទនោះ សោតយ៉ាងនេះ បទនោះក៏ត្រូវជាបទមិនគួរពោលក្នុងតិកៈនោះទៅហើយឬ ឬថា មិនបានពោល តើហេតុអ្វី ? ព្រោះមិនមាន ចិត្តុប្បាទណាមួយដោយការប្រកបចូល ដែលត្រូវសម្តែងចែកហេតុ ដែលអកុសលចិត្តុប្បាទទាំង ១២ ដួង មកហើយ ក្នុង **ចិត្តុប្បាទកណ្ឌ** ទ្រង់សង្គ្រោះចូលដោយបទទាំង ២ ភាវៈនៃធម៌មានអតីតជាដើម ជាធម៌ដែលមិនត្រូវពោល គឺលោកមិនបានត្រាស់ទុកក្នុងឧប្បន្នត្តិកៈ យ៉ាងណា សូម្បី ភាវៈនៃធម៌ដែលមានមគ្គ ៣ ខាងលើ គប្បីលះនេះ ក៏ដូច្នោះ យ៉ាងនោះ ។ ប្រការ មួយទៀត ព្រោះអកុសលចិត្តដែលប្រកបព្រម ដោយឧទ្ធច្ចៈនោះ ប្រព្រឹត្តទៅក្នុង បុថុជ្ជន សូម្បីមិនអាចលះបានដោយមគ្គ ៣ ខាងលើ ជាធម៌ដែលស្មើគ្នាដោយសភាវៈ គប្បីលះដោយមគ្គ ៣ ខាងលើ ដែលជាធម៌មានទោស ទើបមានពាក្យបរិយាយថា ជាធម៌ដែលមគ្គ ៣ ខាងលើនឹងគប្បីលះ ព្រោះដូច្នោះ ទើបមិនមានសេចក្តីខូចក្នុងការ ទាក់ទងនឹងភាពជាធម៌ដែលមិនគួរពោលដល់ ។ តែបើពោលដោយត្រង់ ក៏មិនមែន

ជាធម៌ដែលមគ្គ ៣ ខាងលើត្រូវលះ ព្រោះដូច្នោះ ទើបលោកមិនពោលថា ជាកម្មប្បច្ច័យ ដែលមាននៅក្នុងខណៈផ្សេងគ្នា ដោយអំណាចអកុសលចិត្ត ដែលកើតរួមដោយឧទ្ធច្ចៈនោះ ។ សោតាបត្តិមគ្គ ក៏ធ្វើកិច្ចត្រឹមតែធ្វើឲ្យធម៌ដែលជាសម្ភាញ់របស់អកុសលចិត្ត ដែលប្រកបព្រមដោយឧទ្ធច្ចៈ មានធម៌ដែលសោតាបត្តិមគ្គនឹងគប្បីលះជាបច្ច័យមិនគ្រប់គ្រាន់ប៉ុណ្ណោះ មិនមានធម៌ណាមួយដែលសោតាបត្តិមគ្គនឹងធ្វើឲ្យដល់អកុសលចិត្ត ដែលប្រកបព្រមដោយឧទ្ធច្ចៈនោះ មានការមិនកើតឡើងជាធម្មតា ព្រោះដូច្នោះ ទើបលោកពោលថា អកុសលចិត្តដែលប្រកបព្រមដោយឧទ្ធច្ចៈនោះ ជាធម៌ដែលមគ្គ ៣ ខាងលើគប្បីលះដោយចំណែកមួយ ។ម៉្យាងទៀតពាក្យដែលពោលដល់ធម៌ដែលសោតាបត្តិមគ្គនឹងគប្បីលះ សំដៅដល់ធម៌ដែលញ៉ាំងសត្វទៅកាន់អបាយ ព្រោះដូច្នោះ ទើបលោកពោលសំដៅចំណែកនៃពាក្យនោះទុកថា ព្រោះជាធម៌ដែលញ៉ាំងសត្វឲ្យទៅកាន់អបាយនោះ ។

ការសម្តែងជានបុំសកលិង្គ មាន **អព្យាកតំ វិបាកំ** ជាដើម សំដៅដល់បទថា **វិញ្ញាណំ** ព្រោះការសម្តែងជានបុំសកលិង្គនោះឯង ទើបលោកពោលថា **ទុវិធំ** ដោយសំដៅដល់វិញ្ញាណមានចំនួនច្រើន និងជាអព្យាកតៈ ។ កាលកាន់យកដោយប្រការដទៃ អព្យាកតៈនោះក៏ត្រឹមត្រូវ ដែលគួរពោលថា **ចតុព្វិធំ** ព្រោះរូប និងនិព្វានក៏ជាអព្យាកតៈផងដែរ ។

ការៈនៃវិបាកដែលជាកាមាវចរៈជាដើម គប្បីជ្រាបតាមន័យដែលពោលហើយក្នុងកុសលនោះឯង ។ ការៈនៃចិត្តដែលជាអហេតុកៈ ដោយអំណាចសម្បយុត្តហេតុដូចគ្នានឹងសហេតុកៈ មិនមែនដោយអំណាចនិព្វត្តកហេតុទេ ។ មែនពិត វិបាកដែលជាសហេតុកៈ សម្រេចដោយអំណាចនៃកម្មដែលជាសហេតុកៈ លោកក៏ពោលទុកដោយអំណាចសម្បយុត្តហេតុតែម៉្យាង កាលកាន់យកសេចក្តីដទៃ សូម្បីអហេតុកៈ

ទាំងឡាយ ក៏នឹងត្រូវជាសហេតុកៈដែរ ។

សួរថា ព្រោះហេតុអ្វី បានជាអហេតុកៈជាវិបាករបស់សហេតុកៈ ? ឆ្លើយថា ហេតុក្នុងសេចក្តីនោះ គឺលោកបានពោលទុកហើយ ។ នៅមានតទៅទៀត ក្នុងវិញ្ញាណ ៥ កាលបែរមុខទៅកាន់អារម្មណ៍ ក៏មិនទាន់មានការប្រកបដោយហេតុ មានអលោភៈជាដើម យ៉ាងណា ក្នុងសម្បដិច្ឆនៈ និងសន្តីរណៈដែលមានកិច្ចទន់ខ្សោយជាងក៏យ៉ាងនោះ ព្រោះហេតុនោះ គប្បីឃើញថា ភាវៈនៃវិបាកចិត្តទាំងនោះ ជាអហេតុកៈ ព្រោះការមិនមានការកើតឡើងរបស់ហេតុទាំងឡាយ ។

ធាតុត្រឹមតែ **មនោ** ព្រោះមានកិច្ច គឺការដឹងពិសេសដោយកើតឡើង តាមមនោវិញ្ញាណ ឈ្មោះថា **មនោធាតុ** ។

ធម្មជាតិដែលអាស្រ័យចក្ខុដឹងច្បាស់នូវរូប ជាលក្ខណៈរបស់ចក្ខុវិញ្ញាណនេះ ហេតុនោះ ចក្ខុវិញ្ញាណឈ្មោះថា **ចក្ខុសន្និស្សិតរូប វិជានន លក្ខណំ** ប្រែថា ធម្មជាតិដែលមានការដឹងច្បាស់ ព្រោះអាស្រ័យនូវរូបជាលក្ខណៈ ។ ក្នុងសេចក្តីនោះ ពាក្យថា អាស្រ័យចក្ខុ លោកអាចារ្យរមែងហាមវិញ្ញាណដទៃ ដែលមានរូបជាអារម្មណ៍ ។ ដោយស័ព្ទថា ដឹងច្បាស់ លោកអាចារ្យរមែងហាមធម៌ទាំងឡាយ មានផស្សៈជាដើម ដែលអាស្រ័យចក្ខុ ។ ដោយស័ព្ទថា ចក្ខុ និងរូប លោកអាចារ្យ រមែងធ្វើវិញ្ញាណឲ្យជាក់ច្បាស់ ដោយការអាស្រ័យ និងដោយអារម្មណ៍ ព្រោះមានការប្រព្រឹត្តទៅអាស្រ័យដល់ចក្ខុ និងរូបទាំងពីរ ។ ប្រសិនបើឈ្មោះថា ចក្ខុមិនមានសោត សូម្បីមនុស្សខ្វាក់ទាំងឡាយក៏នឹងគប្បីឃើញរូប ប៉ុន្តែបែរជាមើលមិនឃើញ ។ ប្រសិនបើឈ្មោះថា រូបមានពណ៌ខៀវជាដើម មិនមានសោត ការកំណត់ទេសជាដើម ក៏មិនមានតែការកំណត់មាននោះឯង លោកក៏ពោលថា ចិត្តប្រព្រឹត្តទៅដោយអារម្មណ៍ជាចំណែកមួយ ព្រោះដូច្នោះ គប្បីជ្រាបថា វាទៈដែលប្រព្រឹត្តទៅយ៉ាងនេះ គឺចិត្តដែលញុំាងរូប

មានពណ៌ទៀវជាដើមឲ្យប្រាកដវៀរចាកអារម្មណ៍ក៏ប្រព្រឹត្តទៅបាន ដូច្នេះ ជាមិច្ឆាវាទៈ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ចក្ខុវិញ្ញាណកើតឡើងអាស្រ័យចក្ខុបសាទប៉ះខ្ទប់នឹងរូបារម្មណ៍ជាដើម ។

សួរថា ក្នុងព្រះបាលីនេះ ព្រះមានព្រះភាគទ្រង់ធ្វើសេចក្តីផ្សេងគ្នានៃវចនៈទុកព្រោះហេតុអ្វី ? ឆ្លើយថា ដើម្បីសម្តែងសេចក្តីផ្សេងគ្នាដូច្នេះថា ចក្ខុតែម្យ៉ាងជាបច្ច័យដល់វិញ្ញាណបាន ចំណែករូបប្រមូលគ្នាច្រើនយ៉ាងនោះឯង ទើបកើតឡើងបាន ។ សួរថា ហេតុដូចម្តេចបានជាចក្ខុតែម្យ៉ាងជាបច្ច័យដល់វិញ្ញាណ ឯរូបត្រូវច្រើនទៅវិញ ? ឆ្លើយថា ព្រោះសេចក្តីផ្សេងគ្នានៃបច្ច័យ ។

មែនពិត ចក្ខុជាបច្ច័យដោយនិស្សយបច្ច័យ បុរេជាតបច្ច័យ ឥន្ទ្រិយបច្ច័យ និងវិប្បយុត្តបច្ច័យដល់ចក្ខុវិញ្ញាណ រមែងមានដោយភាពជាអត្ថិបច្ច័យប៉ុណ្ណោះ ព្រោះកាលបើចក្ខុនោះមាន វិញ្ញាណនោះក៏មាន ចក្ខុនោះមិនមាន វិញ្ញាណនោះក៏មិនមានដែរ ។ ព្រោះចក្ខុនោះ លោកពោលថា ជាបច្ច័យដល់វិញ្ញាណនោះ ដោយអត្ថិបច្ច័យ និងអវិគតបច្ច័យ នឹងមិនត្រូវប្រាថ្នា កាលវិញ្ញាណនោះមានចក្ខុជាទីអាស្រ័យ ដោយអំណាចសេចក្តីជាប់គ្នាដោយឯកទេស ព្រោះវិញ្ញាណនោះជាអរូបដោយពិត ព្រោះវិញ្ញាណនោះមានការប្រព្រឹត្តទៅអាស្រ័យដោយចក្ខុនោះ ដូចគ្រូ និងសិស្ស ព្រះរាជា និងរាជបុត្រជាដើម មានការអាស្រ័យគ្នានឹងគ្នា ។ ចំណែកបច្ច័យក្រៅអំពីនេះគប្បីជ្រាបដោយសេចក្តីផ្សេងគ្នានោះៗ ។ បច្ច័យទាំងនេះ រមែងមិនសម្រេចក្នុងវត្ថុជាមួយគ្នាឡើយ ព្រោះដូច្នោះ ចក្ខុសូម្បីតែម្យ៉ាង ក៏រមែងជាបច្ច័យដល់វិញ្ញាណបាន ព្រោះដូច្នោះ ទើបទ្រង់និទ្ទេសដោយឯកវចនៈថា **ចក្ខុញ្ច បដិច្ច** ។

ចំណែករូប សូម្បីជាបច្ច័យដោយបុរេជាតបច្ច័យ អត្ថិបច្ច័យ និងអវិគតបច្ច័យដូចចក្ខុ ព្រោះជាធម្មជាតិមានមុន ទើបជាឧបការៈក្នុងខណៈដែលកំពុងមាន

នោះឯង សូម្បីមានយ៉ាងនោះ ក៏ជាធម្មជាតិដែលរួមគ្នាច្រើនយ៉ាង ទើបជាបច្ច័យបាន ព្រោះជាអារម្មណ៍ ។ មែនពិត រូបណាជាបច្ចយធម៌ ជាសភាវៈ ឬត្រឹមតែជាអាការ ដែលកំណត់កាន់យក រមែងញ៉ាំងវិញ្ញាណឲ្យជាក់ច្បាស់ប្រព្រឹត្តទៅ សូម្បីពួកធម៌ដទៃ អំពីរូបនោះ ជាបច្ច័យនៃសភាវៈនោះ ឈ្មោះថា ជាអារម្មណ៍ ព្រោះវិញ្ញាណនោះ មិនអាចនឹងកាន់យកធម្មជាតិណាមួយ ជាអារម្មណ៍ឲ្យប្រព្រឹតទៅបាន ព្រោះជាធម៌ ដែលមានសភាវៈ ជាធម៌ដែលទទួលអារម្មណ៍បាន ជាធម្មជាតិទាញយកមកជាអារម្មណ៍ ដោយភាវៈដែលកាន់យកឲ្យប្រព្រឹត្តទៅ ។ កាលវិញ្ញាណនោះ បាននូវអារម្មណាប្បច្ច័យ ក៏ដោយអំណាចការបាននូវសភាវៈណានីមួយ ព្រោះដូច្នោះ ចក្ខុវិញ្ញាណប្រារព្ធរូបឲ្យ ប្រព្រឹត្តទៅ ញ៉ាំងសភាវៈរបស់រូបនោះឲ្យជាក់ច្បាស់នោះឯង ។ កាលដែលវិញ្ញាណ នោះ មានការប្រព្រឹត្តអាស្រ័យឥន្ទ្រិយដោយសភាវៈ គឺអារម្មណ៍ ក៏យ៉ាងនោះ រមែង មិនមានដោយអំណាចវណ្ណៈដែលចាត់ជាកលាបៈ ១ និងកលាបៈ ២ ឡើយ ហើយ ក៏មិនមានដោយអំណាចវណ្ណៈ ដែលមាននៅក្នុងកលាបៈតិចតួចទេ តាមពិត រមែង មានដោយអំណាចវណ្ណៈដែលដល់គន្លង តាមសមគួរដល់ការនឹកគិត ព្រោះដូច្នោះ ព្រះមានព្រះភាគកាលនឹងទ្រង់សម្ដែងថា រូបច្រើនយ៉ាង រមែងជាបច្ច័យដល់វិញ្ញាណ ព្រោះជាធម្មជាតិដែលរួមគ្នាធ្វើ ទើបទ្រង់សម្ដែងខែ ដោយពហុវចនៈថា រូបេ ច ។

សួរថា ចំណែកពាក្យណាដែលត្រាស់ទុកថា រូបាយតនៈជាអារម្មណាប្បច្ច័យ ដល់ចក្ខុវិញ្ញាណធាតុផង ដល់ពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុផង ពាក្យនោះ តើដូចម្ដេច ? ឆ្លើយថា ពាក្យនោះ ព្រះសាស្ដា ទ្រង់សំដៅយកចំពោះរូបាយតនៈដែល ជាបច្ច័យដោយអារម្មណាប្បច្ច័យដល់ចក្ខុវិញ្ញាណនោះប៉ុណ្ណោះ ។ សួរថា រូបាយតនៈ នោះដូចម្ដេច ? ឆ្លើយថា រូបាយតនៈដែលរួមគ្នា ព្រោះដូច្នោះ អត្ថនេះជាក់ច្បាស់ ហើយ ។ ព្រោះអធិប្បាយយ៉ាងនេះ អាចារ្យមួយពួកពោលពាក្យណាទុកថា ធម៌ទាំង

ឡាយ មានចក្ខុវិញ្ញាណជាដើម មានការកំណត់បានជាអារម្មណ៍ ដោយអំណាចការកំណត់អាយតនៈ មិនមែនដោយអំណាចការកំណត់ទ្រព្យឡើយ សូម្បីពាក្យនោះក៏រមែងត្រឹមត្រូវនោះឯង ។ ក្នុងសេចក្ដីនេះ មិនត្រូវសង្ស័យនូវធម៌ដែលមានការរួមគ្នាជាអារម្មណ៍ ព្រោះមិនមានកន្លល់ដល់ធម៌ដែលរួមគ្នានោះឯង ។ ធម៌ គឺវណ្ណៈទាំងឡាយដែលរួមគ្នាហើយ រមែងជាអារម្មណប្បច្ច័យបាន ។ សួរថា តើធម៌ គឺវណ្ណៈទាំងឡាយ ដែលមិនអាចរួមចូលគ្នាតែម្យ៉ាង ជាអារម្មណប្បច្ច័យបានដូចម្ដេច មនុស្សខ្វាក់ទាំងឡាយ មិនអាចមើលឃើញបានដោយខ្លួនតែម្នាក់ឯង ទោះរួមចូលគ្នាហើយក៏នៅតែឃើញមិនបានឬ ? ឆ្លើយថា សេចក្ដីនេះមិនប្រព្រឹត្តទៅដោយចំណែកណាមួយទេ ព្រោះមនុស្សខ្វាក់មិនមានសមត្ថភាពម្នាក់ឯង តែគង់សម្ដែងភាពជាអ្នកអាចក្នុងការសែងគ្រែស្នែងជាដើមទៅបាន ។ ម្យ៉ាងទៀត គ្មានបុគ្គលណាអាចកាន់យកវណ្ណៈតែមួយរបស់កោដ្ឋាស មានសក់ជាដើម ដែលមាននៅក្នុងទីណា តែអាចកាន់យកវណ្ណៈរបស់កោដ្ឋាស មានសក់ជាដើមដែលរួមគ្នានៅក្នុងទីនោះៗ ឯងបាន ព្រោះដូច្នោះ ភាវៈនៃកោដ្ឋាស មានសក់ជាដើមទាំងនោះរួមគ្នា ទើបប្រាកដច្បាស់ក្រៃលែងបាន ។ ព្រោះហេតុនោះ គប្បីជ្រាបថា លោកបដិសេធនូវការចោទជាដើមថា រូបបរិមាណូ ជាអារម្មណ៍របស់ចក្ខុវិញ្ញាណ ឬការរួមចូលគ្នារបស់រូបបរិមាណូនោះជាអារម្មណ៍ជាដើម ក្នុងពាក្យថា **សោតញ្ច បដិច្ច សទ្ទេ ច** សោតវិញ្ញាណកើតឡើងជាដើម ក៏មានន័យនេះដូចគ្នា ។ ព្រោះមានការប្រព្រឹត្តទៅអាស្រ័យពីរពាក្យយ៉ាងនេះ ទើបលោកអធិប្បាយទុក ដោយនិស្សយប្បច្ច័យ និងដោយអារម្មណប្បច្ច័យដល់ចក្ខុវិញ្ញាណ សូម្បីក្នុងសោតវិញ្ញាណជាដើម ក៏គប្បីពោលតាមគួរយ៉ាងនេះ ។

បទថា **រូបមត្តារម្មណរសំ** ប្រែថា មានការធ្វើត្រឹមតែរូបាយតនៈតែម្យ៉ាងឲ្យជាអារម្មណ៍ជារស ។ ដោយ **មត្ត-ស័ព្ទ** លោកអាចារ្យរមែងហាមដល់សេចក្ដីផ្សេង

គ្នាទាំងឡាយណាមួយ ដែលមានសូម្បីក្នុងរូបាយតនៈ ដូចជាបដិសេធអារម្មណ៍ដទៃដែរ ។ ព្រោះចក្ខុវិញ្ញាណមិនអាចកាន់យកការផ្សេងគ្នាណាមួយ ដទៃអំពីអារម្មណ៍ត្រឹមតែវណ្ណៈទុក ក្នុងរូបាយតនៈនោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា វៀរចាកអាការត្រឹមតែការបែរមុខទៅ រមែងមិនដឹងច្បាស់លាស់ចំពោះធម៌ណាមួយ តាមវិញ្ញាណទាំង ៥ ឡើយ ។ ចក្ខុវិញ្ញាណកាលកើតឡើង លោករមែងកាន់យកដោយការបែរមុខទៅរករូបារម្មណ៍នោះ ព្រោះកើតឡើងក្នុងរូបារម្មណ៍នោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **មានការបែរមុខទៅរករូបជាបច្ចុប្បដ្ឋាន** ។ លោកអាចារ្យកាលនឹងសម្ដែងថា អរូបធម៌ទាំងឡាយ ដែលជាសមនន្តរប្បច្ច័យ និងវិគតប្បច្ច័យរបស់អរូបធម៌ទាំងឡាយ ដែលកើតឡើងក្នុងលំដាប់នៃខ្លួនជាហេតុជិត ដូចជាធម៌ដែលជានិស្សយប្បច្ច័យ និងអារម្មណប្បច្ច័យដែលជាឧបការៈដោយអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ដោយការឲ្យឱកាសក្នុងបវត្តិកាល ទើបពោលថា **មានការប្រាសទៅនូវកិរិយាមនោធាតុដែលមានរូបជាអារម្មណ៍ជាបទដ្ឋាន** ។ សូម្បីក្នុងសោតវិញ្ញាណជាដើម ក៏គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។ លោកពោលថា **មនោធាតុមានការទទួលអារម្មណ៍មានរូបជាដើមជារស** ដូច្នេះ ។ ព្រោះមានការទទួល គឺកាន់យកអារម្មណ៍ មានរូបជាដើម ដែលវិញ្ញាណ មានចក្ខុវិញ្ញាណជាដើមកាន់យកហើយ ធ្វើមិនឲ្យធ្លាក់ទៅក្នុងលំដាប់នៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើមនោះៗ ឯង ។ ឈ្មោះថា **មានការៈយ៉ាងនោះជាបច្ចុប្បដ្ឋាន** ដោយអត្ថថា ចូលទៅតាំងចំពោះដោយភាវៈយ៉ាងនោះ គឺដោយភាពជាសម្បដិច្ឆន្នៈ ។

មនោវិញ្ញាណធាតុ សូម្បីមានការដឹងនូវអារម្មណ៍ ៥ យ៉ាង ក្នុងចំណោមអារម្មណ៍ទាំង ៦ បានក្នុងគ្រាខ្លះ ឬដឹងនូវអារម្មណ៍បន្តិចបន្តួចអំពីអារម្មណ៍ទាំង ៥

នោះ លោកពោលថា មានការដឹងនូវអារម្មណ៍ទាំង ៦ ជាលក្ខណៈ ព្រោះមិនប្រព្រឹត្ត កន្លងផុតចាកសភាវៈយ៉ាងនោះទៅបាន ឬព្រោះឈានចុះក្នុងអារម្មណ៍ក្រៅអំពីនេះ ក្នុងបណ្តាអារម្មណ៍ទាំង ៦ នោះឯង ។ បទថា **សន្តីរណៈជាដើមជាកិច្ច** អធិប្បាយថា មានសន្តីរណៈ តទាលម្ពណៈជាកិច្ចក៏មាន មានសន្តីរណៈ តទាលម្ពណៈ បដិសន្ធិ ភវង្គ និងចុតិ ជាកិច្ចក៏មាន ។ បទថា **មានហទយជាបទដ្ឋាន** នេះ លោកពោលទុក ព្រោះមនោវិញ្ញាណធាតុទាំង ២ ដួងនេះ មានហទយវត្ថុជាទីអាស្រ័យដោយចំណែក មួយនោះឯង ។ តែនឹងពោលសូម្បីមានការប្រាសទៅចាកវិញ្ញាណដែលជាអតីតរបស់ មនោវិញ្ញាណធាតុនោះៗ ជាបទដ្ឋាន តាមន័យដែលបានពោលទុកហើយ ខាងដើម ក៏គួរដូចគ្នា ។ បទថា **ការផ្សេងគ្នានៃមនោវិញ្ញាណធាតុនោះ** បានដល់ សេចក្តីផ្សេងគ្នា ពោល គឺសេចក្តីផ្សេងគ្នា ២ ដួង នៃមនោវិញ្ញាណធាតុដែលជាវិបាកនោះ ទើបលោក ពោលថាមាន ២ ដួង ។ បទថា **ឯកន្តមិដ្ឋារម្មណេ** ប្រែថា ក្នុងឥដ្ឋារម្មណ៍ដោយចំណែក មួយនោះឯង អធិប្បាយថា ក្នុងឥដ្ឋារម្មណ៍ដែលប្រៀបធៀបបាន ។ ក្នុងបទថា **ក្នុង បញ្ចទ្វារ និងក្នុងវិញ្ញាណវិថី ដែលមានជវនវិថីជាទីបំផុតនោះឯង** សេចក្តីថា ចាត់ជា ទ្វិឋានយ៉ាងនេះ គឺក្នុងបញ្ចទ្វារមានឋានក្នុងសម្បដិច្ឆន្នៈ និងវោដ្ឋព្វនៈ ក្នុងវិថីវិញ្ញាណ ក្រៅអំពីនេះ ក៏មានស្ថានក្នុងវាងជវន និងភវង្គ ។ មនោវិញ្ញាណក្រៅអំពីនេះ ក៏មាន ស្ថានតាម ដែលពោលហើយនោះឯង ក្នុងកាលនៃសន្តីរណៈ និងតទាលម្ពណៈ ចំណែក ក្នុងបដិសន្ធិកាលជាដើមនៅចន្លោះចុតិ និងភវង្គ គប្បីជ្រាបថា ជាស្ថានរបស់បដិសន្ធិ ក្នុងចន្លោះ បដិសន្ធិ និងអាវជ្ជនៈ តទាលម្ពណៈ និងអាវជ្ជនៈ ជវន និងអាវជ្ជនៈ វោដ្ឋព្វនៈ និងអាវជ្ជនៈ គប្បីជ្រាបថា ជាស្ថានរបស់ភវង្គ ក្នុងចន្លោះតទាលម្ពណៈ និងបដិសន្ធិ ឬចន្លោះជវន និងបដិសន្ធិ គប្បីជ្រាបថាជាស្ថានរបស់ចុតិ ។

ក្នុងបទថា **អារម្មណ៍ ៦** នេះគប្បីជ្រាបវិភាគ គឺការចែកតាមន័យដែលបាន

ពោលទុកហើយ ក្នុងគ្រាមុននោះឯង ។ បទថា **កាយវិញ្ញាណ** ឈ្មោះថា សម្បយុត្ត ដោយសុខ ព្រោះការប៉ះខ្ទប់ និងការប៉ះពាល់កូតរូបដែលជាទីអាស្រ័យរបស់កាយ ជាផោដ្ឋព្វៈ ដែលមិនមែនអតិឥដ្ឋារម្មណ៍ ជាអាការដ៏មានកម្លាំង ។ ការប៉ះខ្ទប់របស់ ឧបាទាយរូបទាំងឡាយ មានកម្លាំងខ្សោយ ព្រោះដូច្នោះ វិញ្ញាណទាំងឡាយ មាន ចក្ខុវិញ្ញាណជាដើម ទើបកើតរួមដោយឧបេក្ខា ។ ព្រោះហេតុនោះ ទើបលោកអាចារ្យ ពោលថា **វិញ្ញាណដ៏សេស ប្រកបដោយឧបេក្ខា** ។ ពាក្យថា **វិញ្ញាណដ៏សេស** បានដល់ វិញ្ញាណទាំង ៦ ។

អលោភៈ អទោសៈ អមោហៈ និងអលោភៈ អទោសៈ ឈ្មោះថា វិបាកហេតុ មានអលោភៈជាដើម អព្យាកតចិត្តដែលសម្បយុត្តដោយវិបាកហេតុទាំងឡាយ មាន អលោភៈជាដើមទាំងនោះ ឈ្មោះថា **អលោភាទិ វិបាកហេតុសម្បយុត្តំ** ប្រែថា ដែល សម្បយុត្តដោយវិបាកហេតុ មានអលោភៈជាដើម ។ បទថា **ដោយសេចក្ដីផ្សេងគ្នា នៃសម្បយុត្តធម៌ មានសោមនស្សជាដើម ដូចកាមាវចរកុសល** សេចក្ដីថា អព្យាកត ចិត្តនេះ ដូចជាកាមាវចរកុសលចិត្ត ៨ ដួង ដោយភាពផ្សេងគ្នានៃសោមនស្ស ឧបេក្ខា ញាណ និងសង្ខារ ព្រោះដូច្នោះ ទើបលោកអាចារ្យសម្ដែងសេចក្ដីដូចគ្នាដោយ សភាវៈមាន ៨ ដួង ។ ពោលដោយភាពជាកាមាវចរៈ ឈ្មោះថា ដូចគ្នា ដោយភាវៈ ជាធម្មជាតិថោកទាបជាដើម និងដោយការកើតឡើង ក្នុងកំណើតទាំងឡាយ តែបើ ពោលដោយសម្បយុត្តធម៌នោះ គឺផ្សេងគ្នាដោយអារម្មណ៍ផង និងដោយអាការប្រព្រឹត្ត ទៅផង ។ មែនពិត កុសលចិត្តរមែងប្រព្រឹត្តទៅដោយអំណាចកម្ម និងទ្វារ អព្យាកត ចិត្តនេះ មិនដូច្នោះទេ ព្រោះវិបាកចិត្តទាំងឡាយនឹងមិនញុំាងវិញ្ញត្តិឲ្យកើតឡើងទេ ។ តែសេចក្ដីផ្សេងគ្នានៃការប្រព្រឹត្តទៅ ក៏នៅតែមានដល់អព្យាកតចិត្តនេះ ដោយអំណាច នៃការកើតឡើង នឹងទ្វារ ព្រោះមហាវិបាកចិត្តទាំងឡាយ មានការប្រព្រឹត្តទៅដោយ

អំណាចតទាលម្ពណៈក្នុងបញ្ចទ្វារ និងមនោទ្វារ ។ កុសលចិត្តមាន ៥ យ៉ាង ដោយអំណាចនៃគតិ និងមាន ៧ យ៉ាង ដោយអំណាចនៃវិញ្ញាណដ្ឋិតិ យ៉ាងណា តែអព្យាកតចិត្តនេះមិនដូច្នោះទេ ព្រោះកើតឡើង ក្នុងឯកទេសនៃកុសលចិត្តនោះប៉ុណ្ណោះ ។ ដើម្បីនឹងសម្តែងសេចក្តីផ្សេងគ្នាដោយអារម្មណ៍ និងដោយអាការនៃការប្រព្រឹត្តទៅក្នុងចំណែកខ្លះ ទើបលោកអាចារ្យពោលពាក្យថា **យថា បទ** ជាដើម ក្នុងសហេតុកព្យាកតចិត្តនោះ ។ បទថា **អារម្មណ៍ ៦** បានដល់ អារម្មណ៍ ៦ ដែលមានប្រភេទជាបរិត្តារម្មណ៍ជាដើម អតីតារម្មណ៍ជាដើម និងអជ្ឈត្តារម្មណ៍ជាដើម ។

បទថា **អំណាចនៃដែលមកជាដើម** បានដល់ដោយអំណាចដែលមកនឹងបច្ច័យ ។ បណ្តាសេចក្តី ២ យ៉ាងនោះ ដោយអំណាចនៃហេតុដែលមកយ៉ាងនេះថា តាមមតិរបស់អាចារ្យទាំងឡាយពួកខ្លះ កុសលវិបាកដែលជាអសង្ខារ ក៏ជាអសង្ខារ វិបាករបស់កុសលដែលជាសសង្ខារក៏ជាសសង្ខារ ប្រៀបដូចកាលបើមុខញ័រហើយ ស្រមោលមុខលើផ្ទៃកញ្ចក់ក៏ញ័រដែរ ។ ចំណែកដោយអំណាចនៃបច្ច័យយ៉ាងនេះថា បើតាមមតិរបស់អាចារ្យទាំងឡាយពួកខ្លះ វិបាកដែលកើតអំពីកម្មជាដើម ដែលជាបច្ច័យជាក់ច្បាស់ មានកម្លាំងជាអសង្ខារ ដែលកើតអំពីកម្មជាដើម ដែលខ្សោយកម្លាំង ក៏ជាសសង្ខារ ។ បទថា **នៃសម្បយុត្តធម៌ទាំងឡាយ** គឺសម្បយុត្តធម៌ដែលមកហើយ ដោយសរុបក្នុងព្រះបាលី ។ ព្រោះវិបាកមិនមានភាពផ្សេងគ្នាអំពីកុសល ដោយអំណាចនៃសម្បយុត្តធម៌ទាំងឡាយនោះ ។

ក្នុងបទថា **និរុស្សាហំ** នេះ អធិប្បាយថា ដែលឈ្មោះថា ឧស្សាហៈ បានដល់សេចក្តីខ្វល់ខ្វាយ ពោល គឺភាពជាធម្មជាតិអាចញ៉ាំងវិបាកឲ្យកើតឡើង ក្នុងសន្តានរបស់សត្វអ្នកមានអវិជ្ជា តណ្ហា និងមានះ នៅមិនទាន់កាត់ផ្តាច់បានឧស្សាហៈនោះរមែងមិនមានក្នុងវិបាកចិត្តទាំងឡាយ ព្រោះដូច្នោះ ទើបវិបាកចិត្តនោះ ឈ្មោះថា

**និរុស្សាហំ** ប្រែថា មិនមានឧស្សាហះ ។ តែក្នុងកុសលទាំងឡាយ សូម្បីមានការប្រព្រឹត្តទៅដោយអំណាចនៃអភិញ្ញា ក៏គង់មានឧស្សាហះនោះឯង ព្រោះដូច្នោះ ទើបឈ្មោះថា **សឧស្សាហំ** ប្រែថា មានឧស្សាហះ ។

ភាវៈនៃវិបាក រមែងមិនមានដល់ចិត្ត ដែលជាអយោនិសោមនសិការជាហេតុ ព្រោះធម៌ទាំងឡាយ មានលោភៈជាដើម មានទោសដោយចំណែកមួយ ភាវៈនៃអកុសលវិបាកក៏មិនមានដូចគ្នា ព្រោះជាហេតុនៃធម៌ សូម្បីមានអលោភៈជាដើម ដែលជាសភាវៈមិនមានទោសដោយចំណែកមួយ ជាហេតុផ្សេងអំពីធម៌ មានលោភៈជាដើមនោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ជាអកុសលវិបាកចិត្តជាអហេតុកៈតែម្យ៉ាង** ដូច្នេះ ។

មនោវិញ្ញាណធាតុដែលជាកុសលវិបាកមាន ២ យ៉ាង គឺប្រកបព្រមដោយសោមនស្ស ១ ប្រកបព្រមដោយឧបេក្ខា ១ ព្រោះមានសេចក្ដីផ្សេងគ្នានៃវេទនា ក្នុងអតិឥដ្ឋារម្មណ៍ និងក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ យ៉ាងណា សេចក្ដីផ្សេងគ្នានៃវេទនាក្នុងអតិអនិដ្ឋារម្មណ៍ និងក្នុងអនិដ្ឋមជ្ឈត្តារម្មណ៍មិនដូច្នោះឡើយ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **អកុសលវិបាកចិត្តមាន ៧ យ៉ាង** ។ កាលបើសេចក្ដីផ្សេងគ្នានៃវេទនាក្នុងមនោវិញ្ញាណធាតុដែលជាអកុសលវិបាកនោះមាន ក៏គួរមានទោមនស្សក្នុងអតិអនិដ្ឋារម្មណ៍ តែទោមនស្សវៀរបដិឃៈ រមែងមិនកើតឡើង ។

ភាវៈនៃកាយវិញ្ញាណ ដែលប្រកបព្រមដោយទុក្ខ គប្បីជ្រាបដោយសេចក្ដីផ្ទុយគ្នាជាបរិយាយដូចដែលពោលហើយក្នុងកុសលវិបាក ។ បទថា **ជាឧបេក្ខាយ៉ាងថោកទាប** សេចក្ដីថា ជាឧបេក្ខាដ៏ថោកទាបនោះឯង ព្រោះមានសភាវៈជាទុក្ខ ព្រោះជាវិបាក របស់អកុសលដ៏ថោកទាបដោយចំណែកមួយ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **មិនខ្លាំងក្លាដូចជាទុក្ខទេ** ។ **ទុក្ខ** គឺជាវេទនាដែលមានសភាពខ្លាំងក្លា

ក្តៅក្រហាយដ៏ក្រៃលែង ហួសប្រៀបបាន យ៉ាងណា ឧបេក្ខានេះមិនដូច្នោះឡើយ សូម្បីយ៉ាងនោះ ក៏រមែងប្រព្រឹត្តទៅដោយសភាវៈជាទុក្ខនោះឯង ។ ព្រោះថា វិបាករបស់អកុសល រមែងជាទុក្ខ ។ សភាវៈនៃអកុសលវិបាកនោះជាឧបេក្ខា គប្បីឃើញថាប្រៀបដូចជាបុរសទុព្វលភាព ដែលត្រូវមនុស្សមានកម្លាំងបៀតបៀន មិនអាចនឹងតបតបាន ក៏ព្រងើយកន្តើយចំពោះការបៀតបៀនដែលគេធ្វើមកលើខ្លួនដូច្នោះ ។ បទថា **ឥតរេសុ យោគ កុសលវិបាកេសុ** ប្រែថា ក្នុងកុសលវិបាកចិត្តក្រៅអំពីនេះ ។

បទថា **រូបាវចរំ** ប្រែថា រូបាវចរចិត្ត និងវិបាកចិត្ត ។ កថានេះ ជាកថាពោលអំពីវិបាក ។ បទថា **កុសលំ វិយ** ប្រែថា ដូចរូបាវចរកុសល ។ ព្រោះរូបាវចរវិបាកមិនដូចនឹងកុសលដទៃអំពីរូបាវចរកុសលនោះទេ ។ ប្រការមួយទៀត ស័ព្ទទាំងនេះគឺ **កុសលំ** និង **វិបាកោ** ជាស័ព្ទដែលត្រូវមានសម្ពន្ធនឹងឆដ្ឋីវិភត្តចូលមកប្រកបផង ។ ព្រោះដូច្នោះ ដូចជានិយាយថា **មាតរំ បយិរុបាសតិ** ប្រែថា ចូលទៅរកមាតា សូម្បីមិនបាននិយាយថា **អត្តនោ មាតរំ** ប្រែថា មាតារបស់ខ្លួន សេចក្តីនេះ គេក៏យល់បានគ្រប់គ្នា យ៉ាងណា សូម្បីក្នុងពាក្យថា **កុសលំ វិបាកោ** នេះ ក៏ដូច្នោះដែរ ព្រោះដូច្នោះ ទើបមានសេចក្តីស្មើគ្នានឹងស័ព្ទថា **អត្តនោ កុសលំ វិយ** ( ដូចជាកុសលរបស់ខ្លួន ) ។

សេចក្តីដូចគ្នានឹងកុសលក្នុងរូបាវចរវិបាកចិត្តនេះ គប្បីជ្រាបដោយធម៌ និងដោយអារម្មណ៍ ។ មែនពិត ធម៌ទាំងឡាយ មានផស្សៈជាដើមណា រមែងមានក្នុងកុសលធម៌ទាំងឡាយនោះ ក៏មានក្នុងវិបាកដែរ ។ កុសលរមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ណា វិបាកនេះក៏ប្រព្រឹត្តទៅក្នុងអារម្មណ៍នោះដែរ ។ម្យ៉ាងវិញទៀត ក្នុងរូបាវចរវិបាកចិត្តនេះ បញ្ចមជ្ឈានចិត្តណាជលអភិញ្ញា វិបាកនៃបញ្ចមជ្ឈានចិត្តនោះឯង រមែងមិនមាន ។ មិនមានព្រោះហេតុអ្វី ? ព្រោះមិនកើត និងព្រោះជាអានិសង្ស ព្រោះថា បញ្ចមជ្ឈាន

ចិត្តនោះ កាលនឹងឲ្យផល ក៏នឹងគប្បីឲ្យចំពោះតែរូបាវចរៈប៉ុណ្ណោះ ព្រោះកម្មដែលប្រព្រឹត្តទៅក្នុងភូមិដទៃ មិនឲ្យវិបាកដែលប្រព្រឹត្តទៅក្នុងភូមិដទៃឡើយ ។ ម្យ៉ាងវិញទៀត លោកពោលថា រូបាវចរវិបាក មានកម្មនិមិត្តជាអារម្មណ៍ ព្រោះដូច្នោះ បញ្ចមជ្ឈានចិត្តនោះ មិនប្រារព្ធវិបាកដទៃឲ្យប្រព្រឹត្តទៅឡើយ ។ម្យ៉ាងទៀត បញ្ចមជ្ឈានចិត្តនោះដែលមានអារម្មណ៍ មានបរិត្តារម្មណ៍ជាដើម រមែងមិនមាន ព្រោះដូច្នោះទើបមិនមានការកើត ។ ឈ្មោះថា ជាអានិសង្សរបស់ឈាន ឧបមាដូចបានបច្ច័យក្នុងអត្តភាពនោះ ជាអានិសង្សរបស់ទានជាដើម ។

ពោលដោយការប្រព្រឹត្តទៅនៃភាពផ្សេងគ្នារបស់វិបាក និងរបស់កុសលនោះមាន ព្រោះដូច្នោះ ដើម្បីនឹងសម្តែងភាពផ្សេងនោះ ទើបលោកអាចារ្យពោលថា **ចំណែករូបាវចរកុសល** ជាដើម ។( អរូបាវចរកុសល ) មាន ៤ យ៉ាង ដោយភាពផ្សេងនៃអារម្មណ៍ មានកសិណុគ្ឃាដិមាកាសជាដើម ដូចជាកុសល ។ ភាពផ្សេងនៃការប្រព្រឹត្តទៅ មានន័យដូចបានពោលមកហើយនោះឯង ព្រោះប្រព្រឹត្តទៅដោយអំណាចនៃជវនវិថី និងដោយអំណាចនៃបដិសន្ធិជាដើម ។

បទថា **ព្រោះជាផលរបស់ចិត្តដែលប្រកបដោយមគ្គទាំង ៤** សេចក្តីថា ជាផលរបស់កុសលចិត្ត ដែលសម្បយុត្តដោយអរិយមគ្គទាំង ៤ អធិប្បាយថា ព្រោះជាធម្មជាតិដែលសម្បយុត្តដោយសាមញ្ញផល ៤ យ៉ាង ។ លោកុត្តរវិបាកចិត្តសូម្បីប្រព្រឹត្តទៅក្នុងមគ្គវិថី ២ ឬ ៣ ខណៈក្តី ប្រព្រឹត្តទៅក្នុងផលសមាបត្តិ មានបរិមាណកំណត់ មិនបានក្តី លោកក៏ពោលថា **ប្រព្រឹត្តទៅ ២ ចំណែក** ព្រោះប្រព្រឹត្តទៅក្នុងស្ថានទាំង ២ យ៉ាង ។ បទថា **ទាំងអស់** សេចក្តីថា វិបាកចិត្តទាំងអស់ ពោលដោយន័យ យ៉ាងពិស្តារ មិនសង្ខេបពេក មានចំនួន ៣៦ ដួង គឺកាមាវចរវិបាកចិត្ត ២៣ ដួង រូបាវចរវិបាកចិត្ត ៥ ដួង អរូបាវចរវិបាកចិត្ត ៤ លោកុត្តរវិបាកចិត្ត ៤ ដួង

ដូចគ្នា ។

ពោលដោយភាពផ្សេងគ្នានៃភូមិមាន ៣ ព្រោះលោកុត្តរមិនមាន ។ មែនពិត កិរិយាចិត្តជាលោកុត្តរមិនមាន ព្រោះជាធម្មជាតិឲ្យផលភ្លាមៗ ដោយចំណែកមួយ ។ សេចក្ដីនេះសមដូចព្រះបាលីពោលទុកថា **សមាធិមានន្តរិកញ្ញមាហុ** បណ្ឌិតទាំងឡាយពោលនូវសមាធិណាថា ជាអនន្តរិកសមាធិ គឺសមាធិដែលឲ្យផលភ្លាមៗ ។ សួរថា កុសល ជាលោកុត្តរដែលកើតឡើងដល់ព្រះសេក្ខៈទាំងឡាយ មានផលដោយការនាំចូលទៅកាន់ភាពជាបុគ្គលដទៃបាន សូមលើកទុកសិន បើកើតឡើងដល់ព្រះអរហន្ត មិនមានផល ដោយអាការនាំចូលទៅកាន់ភាពជាបុគ្គលដទៃបាន ការដែលលោកុត្តរកុសលនោះជាកិរិយា សួរថា ហេតុអ្វី ទើបមិនគប្បីប្រាថ្នាទៅវិញ ? ឆ្លើយថា គួរប្រាថ្នាពិត បើលោកុត្តរកុសលនោះ គប្បីកើតឡើងរឿយៗ តែលោកុត្តរកុសលរមែងប្រព្រឹត្តទៅមួយដងប៉ុណ្ណោះ ។ ព្រោះបើកើតឡើងរឿយៗ មគ្គចិត្តក៏នឹងប្រព្រឹត្តទៅ សូម្បីដល់ព្រះអរហន្ត ព្រោះដូច្នោះ កិរិយាចិត្ត ដែលជាលោកុត្តរក៏គប្បីមាន តែកិរិយាចិត្តដែលជាលោកុត្តរនេះមិនដូច្នោះឡើយ ព្រោះមិនមានប្រយោជន៍ ។ ព្រោះដូច្នោះ ទើបកិរិយាចិត្តដែលជាលោកុត្តរមិនមាន ។ ពាក្យថា កិរិយាចិត្ត បានដល់ ចិត្តដែលត្រឹមតែជាកិរិយា អធិប្បាយថា បានដល់ ចិត្តដែលកើតឡើងត្រឹមតែជាកិរិយាប៉ុណ្ណោះ មិនបានឲ្យកើតវិបាកណាមួយ ដូចកុសល និងអកុសលឡើយ ។ សួរថា ព្រោះហេតុអ្វី ទើបកិរិយាចិត្តនេះ មិនឲ្យវិបាកកើតឡើង ? សេចក្ដីនេះសូមឆ្លើយ ដូច្នេះក្នុងអធិការនេះ អាវជ្ជនៈទាំងពីរនេះ ប្រព្រឹត្តទៅក្នុងសន្តាន សូម្បីមានមូលនៃភពកាត់មិនបាននោះឯង ក៏រមែងមិនមានផល ដូចជាផ្កាឈើដែលមិនអាចប្រើជាពូជបាន ព្រោះជាធម្មជាតិទុព្វល ដែលមិនមានអាសេវនៈ ។ ចំណែកចិត្ត ១៨ ដួង ដែលប្រព្រឹត្តទៅក្នុងសន្តតិ ដែលមានមូលនៃភព ដែលកាត់បានហើយនោះ ក៏គប្បីជ្រាបថា មិនជា

ធម្មជាតិឲ្យផល ដូចជាផ្កាល្ហុងដែលត្រូវកាត់ឫសហើយ ។ ព្រោះមិនមានហេតុយ៉ាង ដទៃ ឈ្មោះថា ហេតុដែលជាកិរិយា ទើបជាហេតុដែលមានអលោភៈជាដើមប៉ុណ្ណោះ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **វៀរចាកកិរិយាហេតុ មានអលោភៈជាដើម** ។

មនោធាតុមានភាព ជាបុរេចរនៃវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើម ដឹងច្បាស់នូវអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើមជាលក្ខណៈ ឈ្មោះថា **ចក្ខុវិញ្ញាណាទិបុរេចររូបាទិ វិជាននលក្ខណា** ប្រែថា មានភាពជាបុរេចរនៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ដឹងច្បាស់នូវអារម្មណ៍ មានរូបជាដើម ជាលក្ខណៈ ។ ធាតុនេះ សូម្បីកើតឡើងអំពីមនោវិញ្ញាណក៏ត្រឹមតែជាធាតុ ព្រោះមិនមានកិច្ច គឺការដឹងដ៏ពិសេស ព្រោះដូច្នោះ ទើបឈ្មោះថា មនោធាតុ ។ ពិតយ៉ាងនោះ មនោធាតុនោះ មិនមែនជាបច្ច័យដល់មនោវិញ្ញាណទេ ។ នេះជាសេចក្ដីសង្ខេប ចំណែកសេចក្ដីពិស្ដារ នឹងមានមកក្នុងធាតុនិទ្ទេស ។

បទថា **អាវជ្ជនរសា** ប្រែថា មានការរំពឹងជារស ឬមានការបង្អោនទៅ ដោយប្រការដទៃអំពីអាការដើមរបស់សន្ដានចិត្តជារស ។ បទថា **មានការដាច់នៃភវង្គជាបទដ្ឋាន** សេចក្ដីថា មានការដាច់នៃការបន្តរបស់ភវង្គជាបទដ្ឋាន ។ មនោធាតុដែលមិនធ្លាប់សោយអារម្មណ៍មកពីមុន ប្រព្រឹត្តទៅតែម្ដងប៉ុណ្ណោះ មិនអាចសោយរសនៃអារម្មណ៍ដោយប្រការទាំងពួងបានទេ ព្រោះដូច្នោះ **ទើបជាធម្មជាតិប្រកបដោយឧបេក្ខាតែម្យ៉ាង** ក្នុងអារម្មណ៍ទាំងពួង មានឥដ្ឋារម្មណ៍ជាដើម ។

បទថា **សាធារណា** បានដល់ ទូទៅដល់ព្រះសេក្ខៈ ព្រះអសេក្ខៈ និងបុថុជ្ជន ។ បទថា **ជាអសាធារណ** គឺជាចំណែកដល់ព្រះអសេក្ខៈប៉ុណ្ណោះ ។ បទថា **មានវោដ្ឋព្វនៈ និង អាវជ្ជនៈជារស** បានដល់ មានវោដ្ឋព្វនៈក្នុងបញ្ចទ្វារជារស ព្រោះជាធម្មជាតិកំណត់អារម្មណ៍ ដែលសន្តីរណៈឲ្យគ្រាន់យកហើយប្រព្រឹត្តទៅ និងមានអាវជ្ជនៈក្នុង

មនោទ្វារ ជារសតាមន័យដូចបានពោលទុកហើយ ។ មនោវិញ្ញាណធាតុ រមែងប្រាកដ ដោយសភាវៈយ៉ាងនោះ គឺដោយសភាវៈដែលជាវោដ្ឋព្វនៈក្នុងបញ្ចទ្វារ និងអាវជ្ជនៈ ក្នុងមនោទ្វារតាមលំដាប់ ព្រោះដូច្នោះ ឈ្មោះថា **តថាភាវប្បច្ចុប្បដ្ឋានា** ប្រែថា មាន ភាវៈយ៉ាងនោះជាបច្ចុប្បដ្ឋាន ។ ការប្រាសទៅនៃចិត្តទាំងនេះណាមួយ គឺអហេតុក វិបាកមនោវិញ្ញាណធាតុ ៣ ដួង ដែលមានសន្តីរណៈជាកិច្ច ក្នុងកាលនៃវោដ្ឋព្វនៈ និងភវង្គណាមួយ ក្នុងកាលនៃអាវជ្ជនៈជាហេតុជិតនៃមនោវិញ្ញាណធាតុនេះ ព្រោះ ហេតុនោះ ទើបលោកពោលថា **មានការប្រាសទៅនៃអហេតុកវិបាកមនោវិញ្ញាណធាតុ និងភវង្គណាមួយជាបទដ្ឋាន** ។ ពាក្យថា **ដល់ព្រះអរហន្តទាំងឡាយ** គឺដល់ព្រះ អរហន្តទាំងឡាយ ព្រោះជាអសាធារណៈ ។ បទថា **មិនឱឡារ** បានដល់ វត្ថុទាំងឡាយ មានរូបប្រេតដែលមានតែគ្រោងឆ្អឹងជាដើម ឬវត្ថុដទៃដែលមិនប្រណីត ។ បទថា **ហសិតុប្បាទនរសា** ប្រែថា មានការញុំាងភាពញញឹមប៉ុណ្ណោះឲ្យកើតឡើងជារស ។ ពិតដូច្នោះ ចិត្តដួងនោះ លោកហៅថា ហសិតុប្បាទចិត្តនោះឯង ព្រោះមិនមានចិត្ត ដទៃញុំាងការញញឹមឲ្យកើតឡើង ។ ព្រោះថា កាមាវចរកុសលចិត្ត អកុសលចិត្ត និងកាមាវចរកិរិយាចិត្តដែលកើតរួមដោយសោមនស្ស ១២ ដួង សូម្បីពួកដទៃដែល ឲ្យកើតការរីករាយក៏មានដល់បុថុជ្ជនជាដើមតាមសមគួរ ចំណែកចិត្តដួងនេះវៀរចាក វិចារណបញ្ញា រមែងកើតឡើង ធ្វើឲ្យកើតឡើងត្រឹមតែសោមនស្សដល់ព្រះអរហន្ត ទាំងឡាយ ព្រោះអារម្មណ៍ទាំងឡាយដែលជាកាមាវចរមិនប្រណីត ។ អាចារ្យមួយ ពួកពោលថា ពាក្យដែលលោកពោលទុកក្នុងអដ្ឋកថាថា ចិត្តដួងនេះរមែងកើតឡើង សូម្បីដល់ព្រះមានព្រះភាគ ពាក្យនោះគួរពិចារណា ព្រោះពោលដល់ញាណដែល មិនទើសទាក់ក្នុងចំណែកអតីតជាដើម ហើយពោលថា កាយកម្មទាំងពួងរបស់ព្រះ មានព្រះភាគ ជាម្ចាស់អ្នកប្រកបដោយធម៌ ៣ ប្រការ មានញាណជាប្រធានប្រព្រឹត្តទៅ

តាមញាណ ។ ក្នុងពាក្យរបស់អាចារ្យមួយពួកនោះ មានការប្រព្រឹត្តទៅតាមញាណនោះថា ភាពញញឹមរបស់ព្រះមានព្រះភាគ សូម្បីដោយហសិតុប្បាទចិត្តឲ្យប្រព្រឹត្តទៅ ឈ្មោះថា ប្រព្រឹត្តទៅតាមញាណនោះឯង ព្រោះប្រព្រឹត្តទៅតាមបុព្វេនិវាសញ្ញាណ អនាគតំសញ្ញាណ និងសព្វញ្ញុតញ្ញាណ ទើបមិនខុសពីព្រះបាលី និងអដ្ឋកថា ។ ការអធិប្បាយយ៉ាងនេះ ទើបលោកពោលទុកក្នុងអដ្ឋកថាថា ចិត្តដួងនេះរមែងកើតឡើងក្នុងទីបំផុតនៃញាណទាំងនោះ ដែលបានប្រព្រឹត្តហើយ ។ ចិត្តដួងនោះត្រូវប្រាថ្នាយ៉ាងនេះពិតប្រាកដ កាលកាន់យកអត្ថដោយប្រការដទៃ អហេតុកចិត្តដែលញុំាងវិញ្ញត្តិឲ្យតាំងឡើង សូម្បីដល់ព្រះមានព្រះភាគនោះមិនត្រឹមត្រូវទេ ។ព្រោះភាវៈនៃអហេតុកចិត្តដែលញុំាងវិញ្ញត្តិឲ្យតាំងឡើងដោយវិញ្ញត្តិ អហេតុកចិត្តនោះជាកាយកម្មជាដើម ក៏មិនរាកំងឡើយ ដូច្នេះ ។ ឈ្មោះថា **មានហទយវត្ថុជាបទដ្ឋានដោយចំណែកមួយ** ព្រោះកើតឡើងក្នុងបញ្ចវោការភពប៉ុណ្ណោះ ។

បទថា **អយមេត្ថ វិសេសោ** កាត់បទជា **អយំ ឯត្ថ វិសេសោ** បទថា **អយំ** ខែចេញមកជា **អយំ សេក្ខបុថុជ្ជនានំ ។បេ។ ឧប្បត្តិ សមុបលក្ខិតោ** ពាក្យថា **ឯត្ថ យោគ កុសលកិរិយវិញ្ញាណេសុ** ប្រែថា សេចក្ដីផ្សេងគ្នានៅក្នុងកុសលចិត្ត និងកិរិយាចិត្តនេះ គឺការកំណត់ដោយការកើតឡើងក្នុងសន្តានបុគ្គលពីរជំពូក គឺភាពអាចក្នុងការញុំាងវិបាកឲ្យកើតឡើង និងដោយការកើតឡើងដល់ព្រះសេក្ខៈ និងបុថុជ្ជន ការមិនមានវិបាកនោះ ដោយការកើតឡើងដល់ព្រះអរហន្ត ។ ព្រោះការធ្វើអធិប្បាយយ៉ាងនេះ រមែងជាការហាមដល់ការទាក់ទងនៃកុសលចិត្ត និងអកុសលចិត្ត សូម្បីមិនមានវិបាក ព្រោះសេចក្ដីខ្វះខាតនៃបច្ច័យថា ជាកិរិយាចិត្ត ។ សូម្បីក្នុងបទថា **សេចក្ដីផ្សេងគ្នាអំពីកុសលចិត្ត** នេះ នៅខាងមុខ ក៏មានន័យនេះដូចគ្នា ។

អធិប្បាយថា **ចិត្តទាំងអស់** មានកុសល អកុសល អព្យាកតៈ រួមជាចិត្ត ៨៩

ដួង ដោយន័យដែលមិនសង្ខេប និងពិស្តារពេក ។ ការប្រព្រឹត្តទៅដោយអាការ មានការបន្តភពជទៃជាដើម ឈ្មោះថា កិច្ចនៃបដិសន្ធិចិត្តជាដើមនោះឯង ។ កិច្ចដទៃរបស់ចិត្តដែលផុតអំពីកិច្ច ១៤ នោះ មិនមាន ព្រោះដូច្នេះ ទើបលោកអាចារ្យពោលថា រមែងប្រព្រឹត្តទៅដោយអាការ ១៤ យ៉ាង ។

បទថា **ដោយអានុភាព** គឺដោយអំណាច ។ មែនពិត កម្មដែលសត្វបានធ្វើហើយ សន្សំហើយ កាលនឹងឲ្យវិបាកក្នុងការព្រមព្រៀងនៃបច្ច័យដ៏សេស រមែងដូចជាបណ្ដោយអានុភាពរបស់ខ្លួន ។ បទថា **ក្នុងពួកទេវតា និងមនុស្ស** បានដល់កាមាវចរទេវតា ៦ ជាន់ និងពួកមនុស្ស ។ ក្នុងបទថា **កម្មនិមិត្ត និងគតិនិមិត្ត** នេះ អធិប្បាយថា ឈ្មោះថា កម្ម បានដល់ កម្មដែលជាកាមាវចរកុសល ដែលសត្វធ្វើហើយ និងសន្សំហើយ កម្មនោះឯងបានឱកាសដើម្បីនឹងឲ្យផល ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដែលចូលទៅប្រាកដ** ។ ឈ្មោះថា **កម្មនិមិត្ត** បានដល់ទេយ្យធម៌ជាដើម ជាបច្ច័យនៃចេតនាក្នុងខណៈដែលសត្វធ្វើកម្ម ។ ឈ្មោះថា **គតិនិមិត្ត** បានដល់ រូបាយតនៈ ដែលជាប់អាស្រ័យដោយគតិជាទីទៅកើត ។ បទថា **ភាពជាខ្វើយជាដើម** បានដល់ ភាពជាខ្វើយ មនុស្សគ និងមនុស្សត្រជិតជាដើម ។ អហេតុកមនោវិញ្ញាណធាតុ ដែលប្រកបព្រមដោយឧបេក្ខា ដែលជាវិបាកនៃទ្វិហេតុកកុសល មានកម្លាំងខ្សោយ ឈ្មោះថា **ទុព្វល ។បេ។ មនោវិញ្ញាណធាតុ** ប្រែថា អហេតុកមនោវិញ្ញាណធាតុ ដែលប្រកបដោយឧបេក្ខា ជាវិបាកនៃទ្វិហេតុកកុសល មានកម្លាំងខ្សោយ ។ បទថា **នេសំ យោគ ការិតរូបា រូបាវចរកុសលានំ សត្តានំ** ប្រែថា ពួកសត្វបំពេញនូវរូបាវចរកុសល និងអរូបាវចរកុសលនោះ ។ បទថា **កម្មនិមិត្តតែម្យ៉ាង** បានដល់ អារម្មណ៍ គឺកម្មរបស់ខ្លួន មានបឋវីកសិណជាដើមតែម្យ៉ាង ។

បទថា **ឯវន្តាវេត្ថ** ក្នុងពាក្យថា ឯត្ថ យោគ វិញ្ញាណក្ខន្ធនិទ្ទេសេ និងពាក្យ

ថា **ឯវំ យោគ សង្ខេបតោ សរុបទស្សនមត្តេនេវ** ប្រែថា គប្បីជ្រាបការប្រព្រឹត្តទៅដោយអំណាចនៃវិបាកបដិសន្ធិចិត្ត ១៩ ដួង ក្នុងវិញ្ញាណក្ខន្ធនិទ្ទេសយ៉ាងនោះ គឺសង្ខេប មានត្រឹមតែសម្ដែងដោយសរុបប៉ុណ្ណោះ ។ ចំណែកពាក្យដែលគួរពោលក្នុងនិទ្ទេសនេះ ដោយការចែកកត និងអារម្មណ៍ជាដើម ពាក្យនោះនឹងមកក្នុងបដិច្ចសមុប្បាទកថា ។

បទថា **តំ តំ** សេចក្ដីថា ក្នុងបណ្ដាបដិសន្ធិចិត្ត ១៩ ដួង បដិសន្ធិចិត្តណាមួយកើតហើយក៏រលត់ទៅ ភវង្គចិត្តក៏ជាប់តាមភវង្គចិត្តនោះៗ ក៏កើតឡើងបន្តគ្នា ។ បទថា **នៃកម្មនោះៗ** គឺនៃកម្មដែលមានបដិសន្ធិចិត្តជាវិបាកនោះៗ ។ បទថា **តស្មឹ យេវ យោគ កម្មាទិកេ ឯវ** ប្រែថា ក្នុងអារម្មណ៍ មានកម្មជាដើមនោះឯង ។ អធិប្បាយថា ប្រសិនបើកម្មជាអារម្មណ៍របស់បដិសន្ធិចិត្ត ប្រព្រឹត្តទៅក្នុងកម្មនោះ បើជាកម្មនិមិត្ត និងគតិនិមិត្ត រមែងប្រព្រឹត្តទៅក្នុងកម្មនិមិត្ត និងគតិនិមិត្តនោះឯង ។ បទថា **តាទិសមេវ** សេចក្ដីថា បដិសន្ធិចិត្តមានហេតុ និងសម្បយុត្តធម៌ដ៏សេស យ៉ាងណា ភវង្គចិត្តយ៉ាងនោះឯង ។ បទថា **សន្តានវិនិវត្តកេ** បានដល់ ដែលកាត់ផ្ដាច់នូវការបន្តនៃភវង្គ ។ ចិត្តុប្បាទដទៃហៅថា អាវជ្ជនៈ ។ ការសុបិនឃើញ រមែងមានដោយចិត្ត ដែលសម្រេចអំពីកិរិយានោះឯង (កាមជវនដែលកើតក្នុងសុបិនវិថី) ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **របស់បុគ្គលមិនយល់សប្ដិ ។ រមែងប្រព្រឹត្តទៅមានចំនួនប្រមាណមិនបាននោះឯង** ។ ពិតយ៉ាងនោះ ចិត្តនេះហៅថា ភវង្គ ព្រោះប្រព្រឹត្តទៅ ដោយអង្គនៃឧបបត្តិភព ។ បទថា **តេសញ្ញេវ** គឺបដិសន្ធិចិត្តប៉ុណ្ណោះ ។

ពាក្យថា **ឥន្ទ្រិយទាំងឡាយ** បានដល់ ឥន្ទ្រិយទាំងឡាយ មានចក្ខុជាដើម ។ ពាក្យថា **គួរដល់ការទទួលនូវអារម្មណ៍** បានដល់ អាចទទួលអារម្មណ៍ មានរូបជាដើម ។ មែនពិត សូម្បីក្នុងវេលាដែលប្រសូតចេញទៅខាងក្រៅ ឥន្ទ្រិយនឹងធ្វើនាទីរបស់ខ្លួន

ក៏ទេ ដូចវេលាដែលសត្វនៅក្នុងគភ៌មាតា តែក្នុងវេលាដែលរឹងប៉ឹងនោះឯងដោយលំដាប់ ទើបធ្វើនាទីរបស់ខ្លួនបាន ។

ព្រោះហេតុនោះឯង ទើបលោកអាចារ្យពោលថា ព្រោះអាយតនៈទាំងឡាយក្នុងលោកនេះចាស់ក្លាហើយ ។ បទថា **មកប្រាកដ** គឺតាំងចុះក្នុងចំណែកដែលប្រកប ។ ការប៉ះខ្ទប់ គឺការបានបច្ច័យ ព្រោះអាស្រ័យរូបដែលតាំងចុះក្នុង ចំណែកដែលប្រកបនោះឯង ។ បទថា **ឃដ្ដនា** ប្រែថា ការប៉ះខ្ទប់ ដែលជាហេតុកើតការប្រែប្រួល កើតសេចក្ដីផ្សេងគ្នាក្នុងអារម្មណ៍របស់ចក្ខុវិញ្ញាណ ដែលប្រកបទៅដោយបច្ច័យដ៏ពិសេសដទៃ មានការខ្វល់ខ្វាយជាដើម អធិប្បាយថា បានដល់ ការធ្វើឧបការៈ និងការកាត់ផ្ដាច់ដោយភាពជាឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។ បទថា **តអំពីនោះ** បានដល់ បន្ទាប់ពីការប៉ះខ្ទប់ ។ បទថា **ដោយអានុភាពនៃការប៉ះខ្ទប់** បានដល់ ដោយកម្លាំងនៃការប៉ះខ្ទប់ ។ បទថា **ភវង្គចលនំ** បានដល់ ការកម្រើកនៃភវង្គចិត្ត អធិប្បាយថា ការចូលដល់ភាពជាហេតុនៃចិត្តដែលផ្សេងគ្នា ព្រោះការកើតឡើង ២ ខណៈយ៉ាងនោះ ។ មែនពិត ភវង្គចិត្តនោះ ហៅថា **ចលនៈ** ព្រោះដូចជាការកម្រើកទៅ ដោយហេតុនៃកិរិយាតាំងនៅផ្សេងគ្នា ចាកកិរិយាតាំងនៅមុននៃចិត្តសន្តាន ។ សួរថា ការប៉ះខ្ទប់នូវបសាទរូបដោយភាវៈ ដែលប្រឈមមុខចំពោះអារម្មណ៍តាមធម្មតាដែលសម្រេចដោយអារម្មណ៍ និងបសាទរូបដែលទទួលអារម្មណ៍ ចូរលើកទុកសិនចុះ តែការកម្រើកនៃភវង្គ ដែលអាស្រ័យវត្ថុដទៃនឹងមានដូចម្ដេច ? ឆ្លើយថា មាន ព្រោះមានសម្ពន្ធគ្នាជាមួយវត្ថុនោះ ។ បណ្ដាដុំក្រួសដែលដាក់ទុកលើផ្ទៃស្គរ កាលដុំក្រួសមួយដុំនោះប៉ះត្រូវសត្វរុយ ដែលទំលើដុំក្រួសដទៃអំពីដុំនោះ ក៏កម្រើកខ្លួន ជាឧទាហរណ៍ក្នុងរឿងនោះឯង ពាក្យថា **រូបនោះឯង** បានដល់ រូបាយតនៈនោះៗ ឯង ដែលមកប្រាកដជាបច្ច័យដល់ភវង្គចលនៈ ។ ពាក្យថា **ដូចជាការកាត់ផ្ដាច់ភវង្គ** គឺដូចជាការកាត់តំណ

នៃកវគ្គ ។ ព្រោះកវគ្គកើតឡើងតអំពីការកើតឡើងនៃតទាលម្ពណៈ ទើបលោកប្រើសព្ទ ថា **អារម្មណ៍** កាលបានពោលដល់បញ្ចទ្វារាវជ្ជនៈហើយ គួរនឹងពោលដល់ការឃើញ ជាដើម ក្នុងលំដាប់តអំពីបញ្ចទ្វារាវជ្ជនៈនោះ តែក៏មិនបានពោលការឃើញជាដើម ទាំងនោះ ការកាន់យកមនោទ្វារាវជ្ជនៈ ព្រោះក្នុងឧទ្ទេសលោកកាន់យកអាវជ្ជនៈទាំង ២ ដោយភាពជាអាវជ្ជនៈស្មើគ្នា ។

ពាក្យថា **ក្នុងលំដាប់នៃអាវជ្ជនៈ** បានដល់ ក្នុងលំដាប់នៃបញ្ចទ្វារាវជ្ជនៈ ។ អាចារ្យ ទាំងឡាយណា ដែលមិនព្រមឲ្យសូម្បីតែវិថីចិត្ត មានសម្បដិច្ឆន្នចិត្តជាដើម ដូចជា ហទយវត្ថុ មានព្រះបាលីមកអាងក្នុងទីនោះៗ ដោយន័យជាដើមថា **សម្បដិច្ឆន្នាយ ចក្ខុវិញ្ញាណធាតុយា** ។ ព្រោះគ្មានបុគ្គលណាមួយអាចបដិសេធព្រះបាលីបាននោះទេ ។

ពាក្យថា **បើជាមហន្តារម្មណ៍** នេះ លោកពោលទុក ព្រោះកំពុងពោលដល់ ការប្រព្រឹត្តទៅនៃចិត្ត ដែលមានជវនជាទីបំផុត ។ អារម្មណ៍ដែលមានអាយុ ១៤ ខណៈចិត្ត លោកប្រាថ្នាយកមហន្តារម្មណ៍ក្នុងទីនេះ ហើយមហន្តារម្មណ៍នោះ គប្បី ជ្រាបថា កើតឡើងហើយរលត់ទៅ ២-៣ ខណៈចិត្ត ទើបមកប្រាកដ ។

ពាក្យថា **ក្នុងអារម្មណ៍តាមដែលចែកទុក** គឺមានការចែក ត្រង់វោដ្ឋពូនៈបាន ធ្វើហើយដោយអាការដែលបានពោលទុក ។ ព្រោះលោកពោលដល់អាវជ្ជនៈ និង វោដ្ឋពូនៈ ទើបលោកធ្វើ **អវសេស**-សព្ទថា **អវសេសកាមាវចរកិរិយានំ** ។ ដោយ **វា**-សព្ទថា **ឆ សត្ត វា** សូម្បីពាក្យថា **បញ្ច វា** នេះ ក៏គប្បីឃើញថា លោកពោល ទុកហើយដូចគ្នា ។ ព្រោះក្នុងពេលដេកលក់ និងក្នុងពេលសន្លប់ជាដើម ជវនរមែង ស្ទុះទៅ ៥ ខណៈ ។

បទថា **តានិយេវ** បានដល់ កាមាវចរចិត្ត ២៩ ដួងនោះឯង ដែលបានពោល ទុកដោយពាក្យជាដើមថា ៨ ដួងក៏មាន ។ លោកប្រើសព្ទថា **ឯវ** អក្ខរៈ ដើម្បីនឹង

សម្ដែងថា ឈ្មោះថា ចិត្តកើតឡើងក្នុងលំដាប់មនោទ្វារាវជ្ជនៈដទៃអំពីនេះមិនមាន ។ ពាក្យថា **គោត្រភូ** នេះ លោកកាន់យកបរិកម្ម និងវោទាន ដែលតាំងនៅក្នុងឋានៈជាគោត្រភូ មិនមែនកាន់យកតែគោត្រភូតែម្យ៉ាង ។ ពាក្យថា **ផលចិត្ត** នេះ បានដល់ផលចិត្ត ដែលប្រព្រឹត្តទៅដោយអំណាចផលសមាបត្តិ ។ ពាក្យថា **ជវនណាមួយបានបច្ច័យហើយ** សេចក្ដីថា ជវនណាមួយបានបច្ច័យហើយ ព្រោះកើតឡើងក្នុងលំដាប់នៃគោត្រភូ ដោយអំណាចនៃរូបាវចរជវនជាដើម ។

ពាក្យថា **អតិមហន្តារម្មណ៍** នោះ បានដល់ អារម្មណ៍ដែលមានអាយុ ១៦ ខណៈ ចិត្ត ។ តាមពិត តទាលម្ពណចិត្តរមែងកើតក្នុងអារម្មណ៍ដែលមានអាយុ ១៦ ខណៈ ចិត្តនោះ មិនកើតក្នុងអារម្មណ៍ដទៃទេ ។ ពាក្យថា **អារម្មណ៍ដែលប្រាកដច្បាស់** បានដល់ ការប្រាកដជាក់ច្បាស់ ហើយវិភូតារម្មណ៍នោះ ជាកាមាវចរៈតែម្យ៉ាង ។ ការពិត តទាលម្ពណចិត្ត ក៏កើតឡើងក្នុងវិភូតារម្មណ៍នោះដែរ ។ បទថា **កាមាវចរ-ជវនាវសានេ** ប្រែថា ទីបំផុតនៃកាមាវចរជវននោះឯង ។ ការពិត តទាលម្ពណចិត្តនោះ មិនកើតឡើង អំពីកម្មដែលមានកាមតណ្ហាជាហេតុ រមែងជាប់តាមជវនដែលជាមហគ្គតៈ និងលោកុត្តរទេ ព្រោះមិនមែនតួធ្វើឲ្យកើត និងមិនដូចតួធ្វើឲ្យកើត ។ ឧបមាដូចក្មេងតូច ដែលត្រូវការទៅក្រៅផ្ទះ រមែងតាមឪពុក ឬមនុស្សដែលដូចគ្នានឹងឪពុក មិនតាមមនុស្សដទៃ យ៉ាងណា សូម្បីតទាលម្ពណចិត្តនេះក៏ដូច្នោះដែរ ។ សូម្បីក្នុងអធិការពោលដោយតទាលម្ពណៈនោះ ព្រោះតទាលម្ពណៈកំណត់ដោយជវនទាំងអស់ អំពីវេទនាទាំងអស់ ហើយវេទនាមិនប្រព្រឹត្តទៅតាមអារម្មណ៍ទេ ។ ក្នុងពាក្យនោះ មានសេចក្ដីកំណត់ដូច្នេះ ក្នុងលំដាប់នៃកាមាវចរកុសល លោភមូលចិត្ត មោហមូលចិត្ត និងកិរិយាជវន ដែលប្រកបព្រមដោយសោមនស្សដួងណាមួយ រមែងកើតតទាលម្ពណៈដួងណាមួយ បណ្ដាតទាលម្ពណៈដែលប្រកបព្រមដោយសោមនស្ស ៥ ដួង ក្នុង

អតិមហន្តារម្មណ៍ ក្នុងលំដាប់កាមាវចរកុសល អកុសល និងកិរិយាជវន ដែលប្រកបព្រមដោយឧបេក្ខាដួងណាមួយ បណ្ដាតទាលម្ពណៈ ៦ ដួង ប្រកបព្រមដោយឧបេក្ខាដូចគ្នា។ បទថា **ឥដ្ឋារម្មណាទីនំ** សម្ពន្ធចូលជាមួយបទថា **វសេន** សេចក្ដីថា ដោយអំណាចនៃឥដ្ឋារម្មណ៍ ឥដ្ឋមជ្ឈត្តារម្មណ៍ និងអនិដ្ឋារម្មណ៍ ។ បទនេះលោកពោលទុកដើម្បីសម្ដែងការប្រែប្រួលវេទនាដោយអារម្មណ៍ ។ ពាក្យថា **ដោយអំណាចកម្មចាស់**នេះ លោកពោលទុកដើម្បីសម្ដែងពីភាពផ្សេងនៃតទាលម្ពណៈ ។ មែនពិត កម្មដែលឲ្យកើតបដិសន្ធិប៉ុណ្ណោះ នឹងមិនញុំាងតទាលម្ពណៈឲ្យកើតឡើយ ដោយពិត សូម្បីកម្មដទៃក៏ដូចគ្នា ។ តែកម្មដទៃនោះ រមែងឲ្យកើត សូម្បីអារម្មណ៍ដែលផ្សេងគ្នាអំពីតទាលម្ពណៈដែលជាកម្មញុំាងឲ្យបដិសន្ធិគប្បីឲ្យកើតឡើង ។ ពាក្យថា **ដោយអំណាចជវន** នេះ លោកពោលទុក ដើម្បីសម្ដែងការកំណត់តទាលម្ពណៈ ។ សមដូចពាក្យដែលលោកពោលទុកថា គប្បីកំណត់តទាលម្ពណៈដោយជវន ។ ដោយ **អាទិ-សព្ទ** លោកអាចារ្យរួមបដិសន្ធិចិត្តចូលផង ។ មែនពិត បដិសន្ធិចិត្តនោះ មិនមែនជាបច្ច័យដល់តទាលម្ពណៈ ដែលឧក្រិដ្ឋជាងខ្លួនទេ ។ ពាក្យថា **បច្ច័យណាមួយដែលបានហើយ** សេចក្ដីថា បច្ច័យដើម្បីការកើតឡើងនៃតទាលម្ពណៈណាមួយ ដែលប្រជុំគ្នាហើយក្នុងឥដ្ឋារម្មណ៍ជាដើម តាមដែលពោលហើយ ។ពីរបទថា **កិញ្ចិ អន្តរំ** ប្រែថា ក្នុងខណៈបន្តិចបន្តួច ។ ពាក្យថា **ដូចទឹក** គឺដូចទឹកដែលទៅបញ្ច្រាស់ក្រសែទឹក ។ ពាក្យថា **២ ខណៈ ឬ ១ ខណៈ** លោកពោលទុកដោយអំណាចជាពាក្យស្អាត ដូចក្នុងពាក្យថា ៨ ក្ដី ១០ ក្ដីជាដើម ។ តែអាចារ្យទាំងឡាយពណ៌នាជាពីរវារៈប៉ុណ្ណោះ ។ អារម្មណ៍របស់ជវននោះ ជាធម្មជាតិគួរប្រព្រឹត្តទៅក្នុងអារម្មណ៍របស់ភវង្គ ព្រោះជាវិបាកចិត្ត ១ ព្រោះអាវជ្ជនៈនៅឆ្ងាយ ១ ព្រោះមានសេចក្ដីស្មើគ្នាជាមួយភវង្គ មានភវង្គដើមជាដើម ១ ជាអារម្មណ៍របស់វិបាកចិត្តនេះ ហេតុនោះ ទើបវិបាកចិត្តនោះ

លោកហៅថា តទាលម្ពណៈ ប្រែថា មានអារម្មណ៍របស់ជវនទោះជាអារម្មណ៍ ព្រោះលុប **តទារម្មណា** ស័ព្ទចេញមួយ ដូចពាក្យថា **កាមាវចរំ** ប្រែថា ធម្មជាតិជាទីត្រាច់ទៅនៃកាមតណ្ហា ( លុបតណ្ហាស័ព្ទចេញមួយស័ព្ទ ) និងដូចពាក្យថា **អូដ្ឋមុខំ** ប្រែថា មានមុខដូចមុខអូដ្ឋ ( លុបមុខស័ព្ទចេញមួយស័ព្ទ ) ។ ក្នុងអធិការនេះ អាចារ្យពួកខ្លះមិនប្រាថ្នាទុកក្នុងលំដាប់នៃកិរិយាជវនថា ក្នុងគម្ពីរបដ្ឋានត្រាស់តទាលម្ពណៈទុកក្នុងលំដាប់នៃធម៌ ដែលមានវិបាកជាធម្មតាថា កាលបើកុសល និងអកុសលរលត់ទៅហើយ វិបាកដែលជាតទាលម្ពណៈក៏កើតឡើង ។ មែនពិត ជវនដែលមានការផ្សាយទៅរមែងជាប់តាមភវង្គទៅ ដូចក្រសែទឹកជាប់តាមទូកទៅដូច្នោះ តែកិរិយាជវនដែលមានការប្រព្រឹត្តទៅស្ងប់របស់អ្នកមានធម្មឡូង្គុបេក្ខា មិនជាប់តាមភវង្គទេ ដូចក្រសែទឹកមិនជាប់តាមកញ្ចប់នៃស្លឹកឈើ ។

ការមិនពោលកិរិយាជវន ដែលបាននេះ ក៏គង់ប្រាកដក្នុងទីកន្លែងខ្លះ ដោយបំណងណាមួយ ដូចអធិបតី សូម្បីមានក្នុងអកុសលនិទ្ទេស ក៏មិនបានត្រាស់ទុក ក្នុង **គម្ពីរធម្មសង្គណី** ។ សូម្បីកញ្ចប់ស្លឹកឈើដែលបានលើកយកមកជាតួយ៉ាងនោះ ក៏មិនស្មើគ្នាជាមួយពាក្យ ដែលនឹងគប្បីលើកមកជាតួយ៉ាង ។ ព្រោះទូកជាមួយកញ្ចប់ស្លឹកឈើធ្វើឲ្យក្រសែទឹកវិល តែកិរិយាទៅមិនដូចគ្នា ព្រោះដូច្នោះ ទើបក្រសែទឹកទៅតាមទូក តែមិនទៅតាមកញ្ចប់ស្លឹកឈើទេ ចំណែកក្នុងទីនេះ កិរិយាជវន និងជវនក្រៅអំពីនេះធ្វើក្រសែនៃភវង្គឲ្យវិល និងកិរិយាទៅក៏ដូចគ្នា ព្រោះដូច្នោះ ទើបកិរិយាជវននេះមិនជាប់ទៅតាម ហើយជវនក្រៅអំពីនេះជាប់ទៅតាមក៏មិនត្រឹមត្រូវ ។ ព្រោះដូច្នោះ បណ្ឌិតគួរតាមពិចារណាសេចក្តីនេះចុះ ។ ពាក្យហាមអត្ថដទៃថា **ភវង្គប៉ុណ្ណោះ** លោកពោលទុក មិនមែនព្រោះបំណងក្នុងទីបំផុតនៃកពក្នុងទីនេះឡើយ ។ ពោលដោយប្រការដទៃ សូម្បីចុតិចិត្តក៏នឹងមិនមានឡើយ ក្នុងទីបំផុតនៃតទាលម្ពណៈ ។ ពាក្យថា **ទស្សនកិច្ច**

ជាដើម បានដល់ កិច្ច មានការឃើញ ការស្ដាប់ ការហិតក្លិន ការលិទ្ធ និងការពាល់ត្រូវ ។ **ឥតិ-ស័ព្ទមានអាទិជាអត្ថ** ដោយ **ឥតិ-ស័ព្ទនោះ** បណ្ឌិតគប្បីឃើញថា រួមយកសម្បដិច្ឆន្នកិច្ចជាដើម ។ ដោយអំណាចចិត្តនិយមដែលប្រព្រឹត្តទៅយ៉ាងនេះថា បន្ទាប់អំពីបដិសន្ធិក៏ជាភវង្គនោះឯង បន្ទាប់អំពីភវង្គក៏ជាអាវជ្ជនៈនោះឯង ដូច្នេះជាដើម ។ បទថា **តម្បិ យោគ ចុតិចិត្តម្បិ** ប្រែថា សូម្បីចុតិចិត្តនោះ ។ **ចុតិចិត្តនោះមាន ១៩ ដួងប៉ុណ្ណោះ** ដូចគ្នានឹងបដិសន្ធិចិត្ត និងភវង្គចិត្ត ព្រោះមិនមានសេចក្ដីផ្សេងគ្នាដោយអត្ថ ។

បទថា **ភវគតិឋិតិនិវាសេសុ** ប្រែថា ក្នុងភព ៣ ក្នុងគតិ ៥ ក្នុងវិញ្ញាណដ្ឋិតិ ៧ ក្នុងសត្តាវាស ៩ ។ បណ្ដាសត្វទាំងនេះ សត្វណាមិនមានចិត្ត សត្វនោះ មិនគួរកាន់យកក្នុងទីនេះ ព្រោះមិនបាននិយាយដល់វិញ្ញាណ ។ បទថា **ឯត្ថ** នេះ គប្បីសម្ពន្ធចូលនឹងបទនេះថា **សំសរមានានំ សត្តានំ** ។ អធិប្បាយថា **ឯត្ថ** ស្មើនឹង **ឯតេសុ យោគ វុត្តនយេន សំសរមានេសុ សត្តេសុ** ប្រែថា បណ្ដាសត្វទាំងឡាយអ្នកត្រាច់ទៅដោយន័យដែលពោលហើយទាំងនេះ សត្វណាអាស្រ័យសម្មាបដិបត្តិ សម្រេចព្រះអរហត្ត ។ **តស្ស យោគ អរហតោ** សេចក្ដីថា ចិត្តរបស់ព្រះអរហន្តនោះ ក៏ជាការរលត់តែម្ដង ព្រោះជាធម្មជាតិមិនមានការបដិសន្ធិ ។

ពណ៌នាកថាមុខដោយពិស្ដារក្នុងវិញ្ញាណក្ខន្ធ ចប់ដោយប្រការដូច្នេះឯង ។

# វិសុទ្ធិមគ្គ

## វេទនាខន្ធ

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងសេចក្តី ដែលខ្ញុំពោលទុកហើយថា វេទនាខន្ធគប្បីជ្រាបយ៉ាងនេះថា ព្រោះជាការរួមធម្មជាតិ ដែលមានការសោយ ( រសនៃអារម្មណ៍ ) ជាលក្ខណៈទាំងអស់ឲ្យរួមចូលជាមួយគ្នាដូចតទៅនេះ ។

ធម្មជាតិដែលមានការសោយ ( រសនៃអារម្មណ៍ ) ជាលក្ខណៈ ឈ្មោះថា វេទនានោះឯង ។ សមដូចព្រះសារីបុត្រពោល ( ដល់ព្រះមហាកោដ្ឋិតៈ ) ថា ម្នាលអាវុសោ ព្រោះធម្មជាតិនោះរមែងសោយ ( រសនៃអារម្មណ៍ ) រមែងដឹង ( សុខទុក្ខ ) ព្រោះហេតុនោះ ទើបហៅថា វេទនាដូច្នេះ ។

## វេទនា ១ វេទនា ៣

វេទនានោះ បើពោលតាមសភាវៈ មានតែម្យ៉ាងដោយលក្ខណៈ គឺសោយ ( រសអារម្មណ៍ ) តែបើពោលដោយជាតិមាន ៣ គឺកុសល អកុសល និងអព្យាកតៈ ។ បណ្តាវេទនា ៣ នោះ គប្បីជ្រាបថា វេទនាដែលសម្បយុត្តដោយកុសលវិញ្ញាណ ដែលពោលទុកដោយន័យថា កាមាវចរវិញ្ញាណមាន ៨ ព្រោះផ្សេងដោយសោមនស្ស ឧបេក្ខា ញាណ និងសង្ខារ ដូច្នេះជាដើម ចាត់ជាកុសលវេទនា ដែលសម្បយុត្តដោយអកុសលវិញ្ញាណ ចាត់ជាអកុសលវេទនា ដែលសម្បយុត្តដោយអព្យាកតវិញ្ញាណ ចាត់ជាអព្យាកតវេទនា ។

## វេទនា ៥

វេទនានោះចែកតាមសភាវៈក៏មាន ៥ គឺសុខ ទុក្ខ សោមនស្ស ទោមនស្ស ឧបេក្ខា ។ វេទនាទាំង ៥ នោះ សុខវេទនា គឺសម្បយុត្តដោយកាយវិញ្ញាណ ដែលជាកុសលវិបាក ទុក្ខវេទនា គឺសម្បយុត្តដោយកាយវិញ្ញាណដែលជាអកុសលវិបាក សោមនស្សវេទនា គឺសម្បយុត្តដោយវិញ្ញាណទាំង ៦២ ដូច្នេះ គឺកាមាវចរវិញ្ញាណកុសល ៤ សហេតុកវិបាក ៤ អហេតុកវិបាក ១ សហេតុកកិរិយា ៤ អហេតុកកិរិយា ១ អកុសល ៤ ( ជា ១៨ ) ចំណែករូបាវចរវិញ្ញាណ វៀរបញ្ចមជ្ឈានវិញ្ញាណកុសល ៤ វិបាក ៤ កិរិយា ៤ ( ជា ១២ ) ចំណែកលោកុត្តរវិញ្ញាណ ព្រោះលោកុត្តរវិញ្ញាណមិនមែនមិនប្រកបដោយឈានទេ ព្រោះហេតុនោះ លោកុត្តរវិញ្ញាណ ៨ ទើបជា ៤០ ដោយអំណាចនៃឈាន ៥ ក្នុងលោកុត្តរវិញ្ញាណ ៤០ នោះ វៀរវិញ្ញាណដែលប្រព្រឹត្តទៅក្នុងបញ្ចមជ្ឈាន ៨ ចេញ សល់កុសលវិបាក ៣២ ( រួមជា ៦២ ) ទោមនស្សវេទនា គឺសម្បយុត្តដោយអកុសលវិញ្ញាណ ២ ឧបេក្ខាវេទនា គឺសម្បយុត្តដោយវិញ្ញាណ ៥៥ ដ៏សេស ។

## លក្ខណាទិចតុក្កៈរបស់វេទនា ៥

បណ្តាវេទនា ៥ នោះ សុខវេទនា មានការសោយផោដ្ឋព្វៈដែលគួរប្រាថ្នាជាលក្ខណៈ មានការធ្វើសម្បយុត្តធម៌ទាំងឡាយឲ្យចម្រើនជារស មានការសប្បាយតាមផ្លូវកាយជាបច្ចុប្បដ្ឋាន មានកាយិន្ទ្រិយជាបទដ្ឋាន ។ ទុក្ខវេទនា មានការសោយផោដ្ឋព្វៈដែលមិនគួរប្រាថ្នាជាលក្ខណៈ មានការធ្វើសម្បយុត្តធម៌ទាំងឡាយឲ្យថយចុះ

ជារស មានការមិនសប្បាយតាមផ្លូវកាយជាបច្ចុប្បដ្ឋាន មានកាយិន្ទ្រិយ ជាបទដ្ឋាន ។ សោមនស្សវេទនា មានការសោយឥដ្ឋារម្មណ៍ជាលក្ខណៈ មានការសោយ ( រស ) របស់អារម្មណ៍ល្អណាមួយជារស មានការសប្បាយតាមផ្លូវចិត្ត ជាបច្ចុប្បដ្ឋាន មានបស្សទ្ធិ ( សេចក្ដីរម្ងាប់នៃកាយ ) ជាបទដ្ឋាន ។ ទោមនស្សវេទនា មានការសោយអនិដ្ឋារម្មណ៍ជាលក្ខណៈ មានការសោយ ( រស ) របស់អារម្មណ៍ដែលមិនល្អណាមួយជារស មានការមិនសប្បាយតាមផ្លូវចិត្តជាបច្ចុប្បដ្ឋាន មានហទយវត្ថុជាបទដ្ឋាន ដោយចំណែកមួយប៉ុណ្ណោះ ។ ឧបេក្ខាវេទនាមានការសោយមជ្ឈត្តារម្មណ៍ជាលក្ខណៈ មានការរក្សាសម្បយុត្តធម៌មិនឲ្យចម្រើន និងមិនឲ្យថយចុះជារស មានការស្ងប់ជាបច្ចុប្បដ្ឋាន មានចិត្តដែលប្រាសចាកបីតិជាបទដ្ឋាន ។

នេះជាកថាមុខយ៉ាងពិស្ដារក្នុងវេទនាខន្ធ ។

# មហាដីកា

## កថាពណ៌នាអំពីវេទនាខន្ធ

***វេទន*** *ស្មើនឹង* ***អនុភវនាការេន,*** ***អយិតំ*** *ស្មើនឹង* ***បវត្តំ*** *ប្រែថា ការប្រព្រឹត្តទៅ គឺការធ្វើដំណើរទៅដោយការសោយអារម្មណ៍ គឺដោយអាការ គឺការសោយអារម្មណ៍ ឈ្មោះថា* ***វេទយិតំ*** *ប្រែថា ការប្រព្រឹត្តទៅដោយការសោយរសអារម្មណ៍ ធម្មជាតិដែលគប្បីកំណត់បានថា ការប្រព្រឹត្តទៅដោយការសោយរសអារម្មណ៍ ឈ្មោះថា* ***វេទយិតលក្ខណំ*** *ប្រែថា ធម្មជាតិដែលគប្បីកំណត់បានថា ការប្រព្រឹត្តទៅដោយការសោយរសអារម្មណ៍ ។ ការប្រព្រឹត្តទៅដោយការសោយរសអារម្មណ៍នោះ ដោយអត្ថបានដល់វេទនានោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ឈ្មោះថា* ***ធម្មជាតិដែលកំណត់ថា ការប្រព្រឹត្តទៅ ដោយការសោយរសអារម្មណ៍*** *បានដល់វេទនានោះឯង ។ ម្យ៉ាងទៀត លោកពោលដល់វេទនានោះឯង សូម្បីដោយអំណាចការសង្ខេបនៃអញ្ញបទ ព្រោះអាស្រ័យសេចក្តីផ្សេងគ្នាដែលសម្រេចដោយការកំណត់ថា ធម្មជាតិមានការប្រព្រឹត្តទៅដោយការសោយរសអារម្មណ៍ជាលក្ខណៈ ដូច្នេះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា* ***ធម្មជាតិមានការប្រព្រឹត្តទៅ ដោយការសោយរសអារម្មណ៍ជាលក្ខណៈ*** *បានដល់ វេទនានោះឯង ។ ពាក្យដែលលោកពោលដោយប្រាថ្នានឹងឲ្យយល់ជ្រួតជ្រាបថា* ***វេទយតិ វេទយតិ*** *ដូច្នេះ ដើម្បីនឹងសម្តែងដល់ការប្រព្រឹត្តទៅជារឿយៗ ក្នុងអារម្មណ៍របស់ខ្លួននៃវេទនា ។ លោកនិទ្ទេសជាកត្តុទុកដើម្បីសម្តែងថា កត្តុដទៃអំពីសភាវធម៌មិនមាន ។ សព្ទថា* ***ឥតិ*** *មានហេតុដូចជាអត្ថដោយមិនកំណត់ ។ សព្ទថា* ***ខោ*** *ត្រឹមតែជាវចនាលង្ការ ។ បទថា* ***តស្មា*** *ជាពាក្យកំណត់របស់ពាក្យនោះ ។ សេចក្តីនោះមានអធិប្បាយថា ធម្មជាតិនេះហៅថា វេទនា*

ព្រោះសោយរសនៃអារម្មណ៍តាមបច្ច័យ ។

ពាក្យថា **សម្បយុត្តដោយកុសលចិត្ត** នេះ គប្បីឃើញថា ជាពាក្យចូលទៅកំណត់វេទនាដែលជាកុសល ។ វេទនាដែលជាកុសលណាមួយ ទាំងអស់នោះសម្បយុត្តដោយកុសលចិត្ត តែមិនមែនដើម្បីសម្តែងនូវការសម្រេចនៃវេទនានោះជាកុសលទេ ។ មែនពិត ភាវៈនៃវេទនាជាកុសល ឈ្មោះថា កុសល មិនមែនប្រកបដោយកុសលចិត្តទេ តាមពិត ឈ្មោះថា កុសល ព្រោះជាសភាវធម៌ ដែលមានយោនិសោមនសិការជាដើម ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដោយអំណាចនៃជាតិ** ដូច្នេះ ។ សូម្បីក្នុងអកុសលជាដើម ក៏ក្នុងន័យនេះដូចគ្នា ។ ដូចជាវេទនាមាន ៣ យ៉ាង ព្រោះសម្បយុត្តដោយចិត្ត មានអកុសលចិត្តជាដើម ដោយអំណាចនៃជាតិ យ៉ាងណា គប្បីជ្រាបថា វេទនាមាន៨៩ដួង ព្រោះសម្បយុត្តជាមួយនឹងចិត្ត ៨៩ ដួងយ៉ាងនោះ ។ ពាក្យថា **ដោយភាពផ្សេងគ្នានៃសភាវៈ** សេចក្តីថា ដោយសេចក្តីផ្សេងគ្នានៃសភាវៈ ដែលធ្វើហើយតែម្យ៉ាងនោះឯង មិនកាន់យកសេចក្តីផ្សេងដោយអំណាចនៃសម្បយុត្តធម៌ មានភូមិ និងអារម្មណ៍ជាដើម ។

លោកអាចារ្យពោលថា មាន ៥ យ៉ាង ហើយមានបំណងនឹងសម្តែងនូវវេទនា ៥ យ៉ាងនោះ ទើបពោលថា **សុខ** ដូច្នេះជាដើម ។ បណ្តាពាក្យទាំងនោះ ឈ្មោះថា សុខ ដោយអត្ថថា ធ្វើឲ្យសុខ អធិប្បាយថា ធ្វើកាយ និងសម្បយុត្តធម៌ទាំងឡាយឲ្យរីករាយ ។ម្យ៉ាងទៀត ឈ្មោះថា សុខ ដោយអត្ថថា រមែងទំពាស៊ីដោយល្អ ឬថារមែងកាត់ដោយល្អនូវការឈឺចាប់ ដែលប្រព្រឹត្តទៅតាមផ្លូវកាយ ។ អាចារ្យមួយពួកទៀត ពោលថា ឈ្មោះថា សុខ ដោយអត្ថថា មានការផ្តល់ឱកាសដែលធ្វើបានងាយ ។ ឈ្មោះថា **ទុក្ខ** ដោយអត្ថថា ធ្វើឲ្យជាទុក្ខ អធិប្បាយថា រមែងបៀតបៀនសម្បយុត្តធម៌ទាំងឡាយឲ្យលំបាក ។ម្យ៉ាងទៀត ឈ្មោះថា **ទុក្ខ** ដោយអត្ថថា រមែងទំពាស៊ី ដោយ

លំបាក ឬកាត់បានដោយលំបាកនូវសេចក្តីសុខសាន្តដែលប្រព្រឹត្តទៅតាមផ្លូវកាយ ។ អាចារ្យមួយពួកទៀតពោលថា ឈ្មោះថា ទុក្ខ ដោយអត្ថថា មានការផ្តល់ឱកាសដែលធ្វើបានលំបាក ។ **អត្ថនៃស័ព្ទរបស់សោមនស្ស និងឧបេក្ខា** ខ្ញុំបានពោលទុកហើយឯខាងដើមនោះឯង ។ ទោមនស្សគប្បីជ្រាបតាមន័យដែលបានពោលទុក ហើយក្នុងសោមនស្ស ។

សួរថា មានហេតុដូចម្តេចហ្ន៎ ទើបលោកអាចារ្យចែកសុខ និងទុក្ខ ដោយអំណាចនៃសេចក្តីសុខសាន្ត និងមិនសុខសម្រាន្តផ្លូវចិត្ត និងផ្លូវកាយក្រៅអំពីនេះថា **សុខ សោមនស្ស ទុក្ខ ទោមនស្ស** ចំណែកឧបេក្ខាផ្លូវចិត្ត និងផ្លូវកាយក្រៅអំពីនេះ លោកពោលទុកតែម្យ៉ាងប៉ុណ្ណោះ ? ឆ្លើយថា ព្រោះមិនមានសេចក្តីផ្សេងគ្នា ។ ដូចជាសុខ ទុក្ខ ព្រោះជាគ្រឿងទំនុកបម្រុង និងជាតួបៀតបៀន រមែងធ្វើការឧបការៈ និងការបៀតបៀនដល់កាយ និងចិត្តតែម្យ៉ាង យ៉ាងណា ឧបេក្ខាមិនមែន ដូច្នោះឡើយ ។ ព្រោះដូច្នោះទើបលោកពោលឧបេក្ខាទុកតែម្យ៉ាងប៉ុណ្ណោះ ព្រោះមិនមានសេចក្តីផ្សេងគ្នា ។

ក្នុងសេចក្តីនេះ វេទនាមាន ៥ យ៉ាង ផ្សេងដោយសភាវៈណា វេទនានោះកាលសម្តែងឋានៈដែលកើតហើយ រមែងជាក់ច្បាស់ ព្រោះដូច្នោះ លោកអាចារ្យមានបំណងនឹងសម្តែងឋានៈដែលកើតមុន ទើបបន្ថែមពាក្យថា **តត្ថ** ជាដើម ។ ពីរបទថា **កាយវិញ្ញាណេន សម្បយុត្តំ** គប្បីសម្ពន្ធចូលក្នុងបទថា **អកុសលវិបាកេន** នេះ ។ កាយវិញ្ញាណប្រកបព្រមដោយសុខក្នុងឥដ្ឋារម្មណ៍ និងឥដ្ឋមជ្ឈត្តារម្មណ៍ និងប្រកបព្រមដោយទុក្ខក្នុងអនិដ្ឋារម្មណ៍ និងអនិដ្ឋមជ្ឈត្តារម្មណ៍ ព្រោះការប៉ះទង្គិច និងការប៉ះខ្ទប់ដែលមានកម្លាំង ដូចកាលដាក់ប៉ុយគទុកលើដែកទ្រនាប់ ហើយយកញញួរដំញញួររមែងហួសប៉ុយគទៅត្រូវដែកទ្រនាប់ ការប៉ះខ្ទប់រមែងមានកម្លាំងដូច្នោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **សុខដែលសម្បយុត្តដោយកាយវិញ្ញាណជា**

កុសលវិបាក ទុក្ខដែលសម្បយុត្តដោយកាយវិញ្ញាណជាអកុសលវិបាក ។ កាមាវចរវិបាកចិត្ត ៥ ប្រកបព្រមដោយសោមនស្ស ដោយអំណាចកម្ម និងអារម្មណ៍ រូបាវចរវិបាកចិត្ត ៤ ប្រកបព្រមដោយសោមនស្សដោយអំណាចកម្ម ចិត្តដ៏សេស គឺកាមាវចរចិត្ត ១៣ ដួង រូបាវចរចិត្ត ៨ លោកុត្តរចិត្ត ៣២ រមែងប្រកបព្រមដោយសោមនស្សដោយអំណាចធម៌ គឺសភាវៈដែលតាក់តែងចិត្ត អារម្មណ៍ និងធម៌ដែលជាបាទជាដើមតាមសមគួរ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **សោមនស្សសម្បយុត្តដោយចិត្ត ៦២ ដួង** ។ ទោមនស្សសម្បយុត្តដោយចិត្តដែលជាអកុសល ២ ដួង ដោយអំណាចចេតោកិសង្ខារ និងអារម្មណ៍ជាដើម ។

បទថា **អវសេសបញ្ចបញ្ញាសាយ** ប្រែថា សម្បយុត្តដោយចិត្ត ៥៥ ដួងដ៏សេស វៀរចិត្ត ៦៦ ដួងតាមដែលពោលហើយ ។ ក្នុងចិត្ត ៥៥ ដួងនោះ ចិត្តទាំង ៨ ដួងដែលអាស្រ័យចក្ខុបសាទជាដើម ជាកុសលវិបាក និងអកុសលវិបាក មិនមានការកំណត់ពិតប្រាកដក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ សូម្បីគួរប្រកបដោយសុខ និងទុក្ខ ក៏ប្រកបដោយឧបេក្ខាតែម្យ៉ាងក្នុងអារម្មណ៍ទាំងអស់ ព្រោះការប៉ះទង្គិច និងការប៉ះខ្ទប់នៃឧបាទាយរូបទាំង ២ យ៉ាង ២ ចំណែកជាធម្មជាតិទុព្វលដូចប៉ុយគ ២ ដុំប៉ះគ្នាដូច្នោះ ព្រោះសុខ និងទុក្ខជាបច្ច័យដ៏មានកម្លាំងយ៉ាងនោះ និងព្រោះសុខទុក្ខទាំងនោះមិនមានជាឧបេក្ខា ។ អាវជ្ជនចិត្ត និងសម្បដិច្ឆន្នចិត្ត ដែលមានការប្រព្រឹត្តទៅក្នុងអារម្មណ៍ និងវត្ថុជាទីអាស្រ័យ ដែលមិនធ្លាប់មានមកពីមុន វោដ្ឋព្វនៈដែលជាខាងដើមរបស់ការចាប់ផ្ដើមនៃកិរិយាចិត្ត ដែលមានអនន្តរប្បច្ច័យមិនដូចគ្នា អកុសលវិបាក

បដិសន្ធិចិត្តជាដើម ដែលមានផលនៃអកុសលនោះជាឧបនិស្ស័យ ព្រោះផលរបស់អកុសល មានទុក្ខតាមផ្លូវកាយជាប្រធាន និងកាមាវចរកុសលវិបាកចិត្ត ដែលមានការប្រព្រឹត្តទៅក្នុងអជ្ឈត្តារម្មណ៍ ក៏រមែងប្រកបព្រមដោយឧបេក្ខាទាំងអស់ ។ មួយ៉ាងទៀត ការសោយវិបាកជាអទុក្ខមសុខក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ដោយអំណាចនៃកម្មនោះឯងគួរហើយ ។កាលដែលឧបេក្ខា ជាវិបាក ជាកណ្តាលៗ របស់សុខ និងទុក្ខក៏គប្បីជ្រាបឧបេក្ខាជាកុសលវិបាក ជាឥដ្ឋារម្មណ៍ និងអកុសលវិបាកជាអនិដ្ឋារម្មណ៍ដោយអំណាចនៃកម្ម និងអារម្មណ៍ ។ ចំណែកចិត្ត ៣៧ ដួងដ៏សេស ជាឧបេក្ខាសម្បយុត្តដោយអំណាចចេតោកិសង្ខារ អារម្មណ៍ និងធម៌ដែលជាបាទជាដើម ព្រោះដូច្នោះបណ្ឌិតគប្បីជ្រាបឧបេក្ខាដែលសម្បយុត្តដោយចិត្ត ៥៥ ដួង ដូចពណ៌នាមកដូច្នេះ ។

សភាវៈដែលមិនទូទៅដល់ធម៌ដទៃនៃធម៌ទាំងឡាយ ឈ្មោះថា **សលក្ខណំ** ( លក្ខណៈរបស់ខ្លួន ) ការសោយអារម្មណ៍ដោយលក្ខណៈទូទៅរបស់វេទនាទាំងឡាយ ព្រោះដូច្នោះ លោកអាចារ្យកាលនឹងកំណត់សម្តែងលក្ខណៈ ទើបពោលថា **សុខវេទនាមានការសោយផោដ្ឋព្វៈ ដែលគួរប្រាថ្នាជាលក្ខណៈ** ព្រោះសុខនោះមិនមានការផ្លាស់ប្តូរ ។ ការបន្ថែម គឺការចម្រើនយ៉ាងច្រើន ឈ្មោះថា **ឧបព្រូហនំ** ប្រែថា ធ្វើឲ្យចម្រើនឡើង ។ការធ្វើឲ្យចម្រើនឡើងនេះ រមែងមានសូម្បីក្នុងសុខតាមផ្លូវចិត្តក៏ពិតមែនហើយ ក៏ប៉ុន្តែការចម្រើនឡើងនោះ ក៏នៅមានការកំណត់រមែងមានបានដោយអំណាចចេតោកិសង្ខារ ។ ចំណែកសុខនេះ មិនមានការកំណត់ មានសេចក្តីពិសេសក្រៃលែង

ជាឯការចម្រើននេះ ព្រោះសម្រេចដោយសភាវៈ ហេតុនោះ ទើបលោកអាចារ្យពោលថា មានការធ្វើឲ្យចម្រើនឡើងនូវសម្បយុត្តធម៌ទាំងឡាយជារស ។ ឈ្មោះថា **អស្សាទ** ដោយអត្ថថា ដែលបុគ្គលត្រេកអរ បានដល់ សុខវេទនា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សុខសោមនស្សអាស្រ័យឧបាទានក្ខន្ធ ៥ កើតឡើង យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ទាំងនេះ តថាគតហៅថា **អស្សាទ** ក្នុងឧបាទានក្ខន្ធ ៥ ។ មានក្នុងកាយ អាស្រ័យកាយ ឈ្មោះថា **កាយិកោ** ប្រែថា មានក្នុងកាយ អស្សាទដែលមានក្នុងកាយនោះឯង រមែងចូលទៅប្រាកដដោយប្រការនោះ ព្រោះហេតុនោះ ទើបសុខឈ្មោះថា **កាយិកអស្សាទបច្ចុប្បដ្ឋានំ** ប្រែថា មានការត្រេកអរដែលប្រព្រឹត្តទៅក្នុងកាយជាបច្ចុប្បដ្ឋាន ។ ឈ្មោះថា មានកាយិន្ទ្រិយ ជាបទដ្ឋាន ព្រោះមិនមានធម៌ដទៃជាវត្ថុ ។

បកិណ្ណកៈទាំងឡាយ មានលក្ខណៈជាដើមនៃទុក្ខ គប្បីជ្រាបតាមន័យរបស់ពាក្យមានន័យដូចបានពោលទុកហើយ ។

សុខមានការសោយឥដ្ឋារម្មណ៍ដោយសភាវៈ ឬដោយបរិកប្បជាជាលក្ខណៈ ឈ្មោះថា **ឥដ្ឋារម្មណានុភាវលក្ខណំ** ប្រែថា មានការសោយឥដ្ឋារម្មណ៍ជាលក្ខណៈ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **មានការសោយអារម្មណ៍ ដោយអាការដែលគួរប្រាថ្នាយ៉ាងណាមួយជារស** អធិប្បាយថា មានការសោយជារស បានដល់ មានការសោយនូវអារម្មណ៍ ដោយអាការដែលគួរប្រាថ្នាតាមពិត ឬមិនពិតជាកិច្ច ។ បទថា **មានបស្សទ្ធិជាបទដ្ឋាន** នេះ លោកអាចារ្យពោលទុកដោយអាស្រ័យបាទនៃ

ព្រះសូត្រថា ភិក្ខុដែលមានកាយស្ងប់ តែងសោយនូវសុខ ពាក្យនោះគប្បីជ្រាបដោយអំណាចសោមនស្សដែលមិនអាស្រ័យអាមិស ។

គប្បីជ្រាបបកិណ្ណកៈមានលក្ខណៈជាដើមនៃទោមនស្ស ដោយផ្ទុយគ្នានឹងពាក្យដែលបានពោលលម្អិតទុកហើយក្នុងសោមនស្ស ។ ការៈនៃទោមនស្សមានហទយវត្ថុជាបទដ្ឋាន ដោយចំណែកមួយ ព្រោះកើតឡើងក្នុងកាមធាតុ ជាសេចក្ដីផ្សេងអំពីសោមនស្សនោះឯង ។

ការសោយ គឺការសោយអារម្មណ៍ដែលជាកណ្ដាលៗ នៃមជ្ឈត្តារម្មណ៍ ជាលក្ខណៈរបស់ឧបេក្ខានេះ ហេតុនោះ ទើបឧបេក្ខានេះ ឈ្មោះថា **មជ្ឈត្តវេទយិត-លក្ខណា** ប្រែថា មានការសោយនូវអារម្មណ៍ជាកណ្ដាលៗ នៃមជ្ឈត្តារម្មណ៍ជាលក្ខណៈ ព្រោះការសោយអារម្មណ៍ដែលជាកណ្ដាលៗ នោះឯង ទើបឧបេក្ខា ឈ្មោះថា មានការរក្សាសម្បយុត្តធម៌ទាំងឡាយ មិនឲ្យចម្រើន និងមិនឲ្យសៅហ្មង ជារស ។ ពាក្យថា **មានការស្ងប់ជាបច្ចុប្បដ្ឋាន** នេះ គប្បីជ្រាបដោយអំណាចនៃឧបេក្ខាដែលមិនមានទោសដែលមិនអាស្រ័យអាមិស មិនមែនដោយឧបេក្ខាទាំងអស់ទេ ។

ពណ៌នាកថាមុខដោយពិស្ដារ ក្នុងវេទនាខន្ធចប់ហើយ ដោយប្រការដូច្នេះ ។

# វិសុទ្ធិមគ្គ

## សញ្ញាខន្ធ

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យដែលខ្ញុំបានពោលទុកថា សញ្ញាខន្ធ គប្បីជ្រាបថា ( ហៅយ៉ាងនោះ ) ព្រោះរួមធម្មជាតិដែលមានការចាំបានជាលក្ខណៈ ទាំងអស់ឲ្យរួមចូលគ្នាដូច្នេះតទៅ ធម្មជាតិដែលមានការចាំបានជាលក្ខណៈ គឺសញ្ញានោះឯង ។ សមដូចព្រះសារីបុត្តត្ថេរពោល ( នឹងព្រះមហាកោដ្ឋិតៈ ) ថា ម្នាលអាវុសោ ព្រោះធម្មជាតិនោះកត់សម្គាល់ កត់ចំណាំ ហេតុនោះ ទើបហៅថា សញ្ញា ដូច្នេះ ។

## សញ្ញា ១ សញ្ញា ៣

សញ្ញានេះ ពោលដោយសភាវៈមានតែ ១ ដោយលក្ខណៈ គឺការចាំបាន តែបើពោលដោយជាតិ មាន ៣ គឺកុសល អកុសល និងអព្យាកតៈ ។ បណ្តាសញ្ញា ៣ នោះ ( គប្បីជ្រាបថា ) សញ្ញាដែលសម្បយុត្តដោយកុសលវិញ្ញាណ ជាកុសលសញ្ញា ដែលសម្បយុត្តដោយអកុសលវិញ្ញាណ ជាអកុសលសញ្ញា ដែលសម្បយុត្តដោយអព្យាកតវិញ្ញាណ ជាអព្យាកតសញ្ញា ។ ព្រោះថា វិញ្ញាណដែលមិនប្រកបដោយសញ្ញាមិនមានទេ ព្រោះដូច្នោះ ប្រភេទនៃវិញ្ញាណមានប្រមាណប៉ុនណា ប្រភេទនៃសញ្ញាក៏មានប្រមាណប៉ុណ្ណោះឯង ។

## លក្ខណាទិចតុក្កៈរបស់សញ្ញា

ឯសញ្ញានេះ មានប្រភេទស្មើគ្នាដោយវិញ្ញាណយ៉ាងនេះ ដោយអាការ មាន

លក្ខណៈជាដើម សញ្ញាទាំងពួងនោះឯង មានការចាំបានជាលក្ខណៈ មានការធ្វើគ្រឿងសម្គាល់ទុកថា នុ៎ះជាវត្ថុនោះជារសេ ដូចជាងឈើអ្នកស្ទាត់ជំនាញជាដើម ការធ្វើគ្រឿងចំណាំទុកក្នុងវត្ថុ មានឈើជាដើមដូច្នេះ មានការចាំបានក្នុងរបស់ដែលសម្គាល់ទុកជាបច្ចុប្បដ្ឋាន ដូចមនុស្សខ្វាក់ស្ទាបដំរីទាំងឡាយ កំណត់តាមគ្រឿងដែលខ្លួនចាប់បានថា ដំរីយ៉ាងដូច្នេះ មានអារម្មណ៍ដែលប្រាកដយ៉ាងណា ជាបទដ្ឋាន ដូចសត្វម្រឹគកាលសម្គាល់ក្នុងរូប ដែលធ្វើអំពីស្មៅ ( ទីងមោង ) ថាជាមនុស្សពិត ដូច្នោះ ។

នេះជាកថាមុខយ៉ាងពិស្ដារក្នុងសញ្ញាខន្ធ ។

# មហាដីកា

## ពណ៌នាអំពីសញ្ញាខន្ធ

ពាក្យណាដែលគួរពោលក្នុងពាក្យថា **ធម្មជាតិ** ឈ្មោះថា **មានការចាំបាន ជាលក្ខណៈ** ឈ្មោះថា **សញ្ញា** នោះឯងជាដើម ពាក្យនោះគប្បីជ្រាបតាមន័យនៃពាក្យដែលបានពោលទុកហើយក្នុងវេទនាខន្ធនិទ្ទេសនោះឯង ។

ចិត្តដែលមិនប្រកបដោយវេទនា មិនមានក៏ពិតមែនហើយ ក៏ប៉ុន្តែវេទនានោះជាធម្មជាតិចែកគ្នាហើយដោយសភាវៈ ព្រោះថា ចិត្តប្រកបដោយវេទនាខ្លះ និងមិនប្រកបដោយវេទនាខ្លះ ។ ប៉ុន្តែសម្រាប់សញ្ញា ចិត្តមិនដូច្នោះឡើយ ព្រោះហេតុនោះទើបលោកអាចារ្យពោលថា ចិត្តឯណាដែលមិនប្រកបដោយសញ្ញា ចិត្តនោះរមែងមិនមាន ព្រោះដូច្នោះ ប្រភេទនៃចិត្តមានប៉ុនណា ប្រភេទនៃសញ្ញាក៏មានប៉ុណ្ណោះដែរ ។

ពាក្យថា **សញ្ញាទាំងអស់នោះឯង** បានដល់ សញ្ញាដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៤ ។ ម្យ៉ាងទៀត វេទនាដែលលោកពោលទុកដោយបកិណ្ណកៈ មានការចែកគ្នា ជាលក្ខណៈជាដើម ព្រោះមានសភាវៈផ្សេងគ្នា យ៉ាងណា សញ្ញានេះមិនដូច្នោះទេ សញ្ញាទាំងអស់នេះ មានការចាំបានជាលក្ខណៈ ការដឹងដោយការចំណាំ គឺការសម្គាល់នូវអារម្មណ៍ ដែលផ្សេងដោយអារម្មណ៍ មានពណ៌ខៀវជាដើម ជាលក្ខណៈរបស់សញ្ញានេះ ហេតុនោះ ទើបសញ្ញានេះឈ្មោះថា **សញ្ជាននលក្ខណា** ប្រែថា មានការចាំបានជាលក្ខណៈ ។ ពិតដូច្នោះ សញ្ញានោះលោកពោលថា មានការចាំបានដោយចំពោះជារស ព្រោះការចាំបានជាគ្រឿងសម្គាល់ ។ ពិតហើយ សញ្ញាដែលមានការចាំបានដោយគ្រឿងសម្គាល់ជាកិច្ច ឈ្មោះថា មានការចាំបានដោយចំពោះជារស ។ គប្បីជ្រាបការប្រព្រឹត្តទៅរបស់សញ្ញានោះ ដូចពេលដែលជាងឈើធ្វើគ្រឿងសម្គាល់ទុក

ត្រង់តួនៃឈើ ហើយចាំបានដោយចំពោះតាមស្នាមនោះ ។ ហេតុនោះ ទើបលោកអាចារ្យពោលថា **នុំះគឺវត្ថុនោះឯង** ជាដើម ។ បច្ច័យនៃការចាំបានតទៅ ឈ្មោះថា **បុនសញ្ជាននបច្ចយោ** ការធ្វើគ្រឿងសម្គាល់ គឺបច្ច័យនៃការចាំបានតទៅនោះ ឈ្មោះថា **បុនសញ្ញាននបច្ចយនិមិត្តំ** ការធ្វើគ្រឿងសម្គាល់ គឺបច្ច័យនៃការចាំបានតទៅនោះ ឈ្មោះថា **បុនសញ្ញាននបច្ចយនិមិត្តករណំ** ម្យ៉ាងទៀត ការធ្វើគ្រឿងសម្គាល់ដែលជាបច្ច័យនៃការចាំបានតទៅ ឈ្មោះថា **បុនសញ្ញាបច្ចយនិមិត្តករណំ** ការធ្វើគ្រឿងសម្គាល់ គឺបច្ច័យនៃការចាំបានតទៅ ឬការធ្វើគ្រឿងសម្គាល់ដែលជាបច្ច័យនៃការចាំបានតទៅនោះ ជាកិច្ចរបស់សញ្ញានោះ ហេតុនោះ ទើបសញ្ញានោះ ឈ្មោះថា **បុនសញ្ជាននបច្ចយនិមិត្តករណរសា** ប្រែថា មានការធ្វើគ្រឿងសម្គាល់ គឺបច្ច័យនៃការចាំបានតទៅជារស ឬមានការធ្វើគ្រឿងសម្គាល់ ដែលជាបច្ច័យនៃការចាំបានជារស ។ ការធ្វើគ្រឿងសម្គាល់ដែលជាបច្ច័យនៃការចាំបានតទៅ គប្បីប្រកបឲ្យស្មើគ្នានឹងសញ្ញាទាំងអស់ដែលជាគ្រឿងសម្គាល់ និងជាការចាំបានដោយគ្រឿងសម្គាល់ ។ ការធ្វើការប្រកាន់មាំ គប្បីឃើញដោយអាការត្រឹមតែការប្រកាន់មាំនៃសញ្ញាថា **នេះប៉ុណ្ណោះពិត** ។ សញ្ញាមានអារម្មណ៍តាមដែលប្រាកដជាបទដ្ឋាន ព្រោះមានសភាវៈដែលមិនបានកំណត់ ។ សញ្ញាដែលប្រកបដោយញាណ រមែងប្រព្រឹត្តទៅតាមញាណនោះឯង ព្រោះដូច្នោះ ទើបជាធម្មជាតិមិនប្រកាន់មាំ និងមិនប្រកាន់ខុស ។ ព្រោះហេតុនោះឯង គប្បីជ្រាបថា សេចក្តីដែលសញ្ញាមានការតាំងនៅយូរមិនបាន រមែងមិនមាន ព្រោះជាធម្មជាតិប្រកបដោយសមាធិ ។ ភាវៈនៃសញ្ញាដែលប្រកបដោយកិលេស មានរាគៈ ទិដ្ឋិ មានះជាដើម ឈ្មោះថា **មានការប្រព្រឹត្តទៅតាមកិលេស** មានរាគៈជាដើម ដោយប្រការដូច្នេះឯង ។

កថាមុខដោយពិស្តារក្នុងសញ្ញាខន្ធ ចប់ដោយប្រការដូច្នេះឯង ។

# វិសុទ្ធិមគ្គ

## សង្ខារក្ខន្ធ

ចំណែកពាក្យណាដែលខ្ញុំពោលទុកថា សង្ខារក្ខន្ធ គប្បីជ្រាបថាយ៉ាងនោះ ព្រោះរួមធម្មជាតិដែលមានការប្រជុំ ( ចេតសិក ) ជាលក្ខណៈទាំងអស់ចូលគ្នាតែមួយ ដូច្នេះ បណ្ឌិតគប្បីជ្រាបក្នុងសេចក្ដីនោះដូចតទៅ ។ ធម្មជាតិដែលមានការធ្វើឲ្យជាក្រុមជាលក្ខណៈ ឈ្មោះថា ធម្មជាតិដែលមានការប្រជុំជាលក្ខណៈ ។ ធម្មជាតិនោះគឺអ្វីខ្លះ ? ធម្មជាតិ គឺសង្ខារនោះឯង ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សភាវៈទាំងឡាយណា តាក់តែងនូវសង្ខតធម៌ សភាវៈទាំងឡាយនោះហៅថា សង្ខារ ដូច្នេះ ។

## លក្ខណាទិចតុក្កៈរបស់សង្ខារ

សង្ខារទាំងនោះមានការប្រជុំតាក់តែងជាលក្ខណៈ មានការប្រមូលចូលគ្នា ជារស មានការផ្សាយទៅជាបច្ចុប្បដ្ឋាន មានខន្ធ ៣ ដ៏សេសជាបទដ្ឋាន ។

## សង្ខារ ១ សង្ខារ ៣

សង្ខារទាំងឡាយ សូម្បីមានតែម្យ៉ាងដោយលក្ខណៈជាដើមយ៉ាងនេះ តែបើពោលដោយជាតិក៏មាន ៣ គឺកុសល អកុសល អព្យាកតៈ ។ បណ្ដាសង្ខារ ៣ នោះ សង្ខារដែលសម្បយុត្តដោយកុសលវិញ្ញាណ ជាកុសលសង្ខារដែលសម្បយុត្ត ដោយអកុសលវិញ្ញាណ ជាអកុសលសង្ខារ ដែលសម្បយុត្តដោយអព្យាកតវិញ្ញាណ ជាអព្យាកតសង្ខារ ។

## កុសលសង្ខារ ៣៦

បណ្តាសង្ខារទាំងនោះ សង្ខារដែលសម្បយុត្តដោយកាមាវចរកុសលចិត្តដួងទី ១ មាន ៣៦ គឺជានិយត មក ( ក្នុងព្រះបាលី ) ដោយរូបរបស់ខ្លួន និងឈាយឡើគ្នា ២៧ ជាយេវាបនក ៤ ជាអនិយត ៥ ។ បណ្តាសង្ខារ ៣៦ នោះ សង្ខារ ២៧ គឺ ផស្សៈ ចេតនា វិតក្ក វិចារៈ បីតិ វិរិយៈ ជីវិត សមាធិ សទ្ធា សតិ ហិរិ ឱត្តប្បៈ អលោភៈ អទោសៈ អមោហៈ កាយបស្សទ្ធិ ចិត្តបស្សទ្ធិ កាយលហុតា ចិត្តលហុតា កាយមុទុតា ចិត្តមុទុតា កាយកម្មញ្ញតា ចិត្តកម្មញ្ញតា កាយបាគុញ្ញតា ចិត្តបាគុញ្ញតា កាយុជុកតា ចិត្តុជុកតា ទាំងនេះជានិយតៈ មកក្នុងព្រះបាលីដោយរូបរបស់ខ្លួន ។ សង្ខារ ៤ គឺឆន្ទៈ អធិមោក្ខ មនសិការ តត្រមជ្ឈត្តតា នេះជាយេវាបនកៈ ( ជាកុសលក៏បាន អកុសលក៏បាន ) ។ សង្ខារ ៥ គឺករុណា មុទិតា កាយទុច្ចរិតវិរតិ វចីទុច្ចរិតវិរតិ មិច្ឆាជីវវិរតិ នេះជាអនិយត ។ សង្ខារ ៥ នោះ រមែងកើតម្តងម្កាល សូម្បីកាលកើត ក៏កើតមិនរួមគ្នា ( ទើបឈ្មោះថា អនិយត ) ។

## អធិប្បាយ សង្ខារ ៣៦ អនិយតសង្ខារ ២៧

### ១- ផស្សៈ

ការវិនិច្ឆ័យក្នុងផស្សៈទាំងនោះ សភាវធម៌ណា រមែងពាល់ត្រូវ ហេតុនេះ ទើបសភាវធម៌នោះ ឈ្មោះថា ផស្សៈ ( ធម្មជាតិពាល់ត្រូវ ) ។ ផស្សៈនេះមានការពាល់ត្រូវជាលក្ខណៈ មានការធ្វើឲ្យប៉ះគ្នាជារស មានការប្រជុំព្រមគ្នា ( នៃចិត្ត និងអារម្មណ៍ ) ជាបច្ចុប្បដ្ឋាន មានអារម្មណ៍ដែលមកកាន់គន្លងជាបទដ្ឋាន ។ ពិតហើយ ផស្សៈនេះ សូម្បីជាអរូបធម៌ ក៏រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ដោយអាការហាក់ដូចជាពាល់ត្រូវ ( ទើបមានការប៉ះខ្ទប់ជាលក្ខណៈ ) ។ ម្យ៉ាងទៀត ផស្សៈនេះ មិនជាប់នៅទីណាមួយ

កន្លែង ក៏ញុំាងចិត្ត និងអារម្មណ៍ឲ្យប៉ះខ្ទប់គ្នាបាន ដូចរូបប៉ះចក្ខុ ដូចសំឡេងប៉ះត្រចៀក ដូច្នោះ ( ទើបឈ្មោះថា មានការធ្វើឲ្យប៉ះខ្ទប់គ្នាជារស ) ឈ្មោះថា មានការរួមចូលគ្នា ជាបច្ចុប្បដ្ឋាន ព្រោះប្រាកដដោយអំណាចហេតុរបស់ខ្លួន ពោល គឺតិកសន្និបាត ( សេចក្ដីរួមចូលគ្នានៃធម៌ ៣ គឺអាយតនៈខាងក្នុងអាយតនៈខាងក្រៅ និងវិញ្ញាណ ) ។ ឈ្មោះថា មានអារម្មណ៍ដែលមកកាន់គន្លងជាបទដ្ឋាន ព្រោះកើតឡើងក្នុងអារម្មណ៍ ដែលពាក់ព័ន្ធដោយសមន្នាហារ ( ប្រមូលការគិត ) ដែលគួរដល់ផស្សៈនោះ និង ឥន្ទ្រិយ ដោយជួយគ្នាទំនុកបម្រុង មិនឲ្យមានអន្តរាយនោះឯង ។ តែពោលដោយ ភាពជាទីតាំងនៃវេទនា ផស្សៈនេះ បណ្ឌិតគប្បីឃើញដូចជាមេគោមិនមានស្បែក ។

## ២- ចេតនា

ធម្មជាតិណារមែងគិត ឈ្មោះថា ចេតនា អធិប្បាយថា រមែងពាក់ព័ន្ធនឹង ( អារម្មណ៍ ) ហេតុនេះ ទើបធម្មជាតិនោះ ឈ្មោះថា ចេតនា ។ ចេតនានោះ មានការៈ គឺការតាំងចិត្តជាលក្ខណៈ មានការរំកិលឃ្លាតជារស មានការចាត់ចែងជាបច្ចុប្បដ្ឋាន គឺការញុំាងកិច្ចរបស់ខ្លួន និងកិច្ចរបស់អ្នកដទៃឲ្យសម្រេច ដូចជាសិស្សឯក ( របស់ អាចារ្យទិសាបាមោក្ខ ) និងសិស្សឯកនៃជាងឈើជាដើម ។ ចេតនានេះ កាល ប្រព្រឹត្តទៅសការៈដែលសម្បយុត្តធម៌ទាំងឡាយឲ្យឧស្សាហ៍ឡើង រមែងប្រាកដក្នុង កាលនឹកដល់ការងារប្រញាប់ប្រញាល់ជាដើម ។

## ៣-៤-៥ វិតក្ក វិចារៈ បីតិ

ពាក្យណា ដែលជាពាក្យគួរពោលក្នុងវិតក្ក វិចារៈ និងបីតិ ពាក្យទាំងអស់ នោះ ខ្ញុំបានពោលទុកហើយក្នុងវគ្គនៃការពណ៌នាបឋមជ្ឈាន ក្នុងបឋវីកសិណនិទ្ទេស ឯណោះ ។

## ៦- វីរិយៈ

សេចក្តីក្លាហាន ឈ្មោះថា វីរិយៈ ។ វីរិយៈនោះ មានការប្រឹងប្រែងជាលក្ខណៈ មានការគាំទ្រសហជាតធម៌ទាំងឡាយជារស មានសភាវៈដែលមិនលិចចុះជាបច្ចុប្បដ្ឋាន មានសេចក្តីសង្វេគជាបទដ្ឋាន ។ តាមព្រះបាលីថា អ្នកតក់ស្លុត តម្កល់ការព្យាយាមដោយប្រាជ្ញា ឬថា មានវត្ថុនៃវីរិយារម្ភជាបទដ្ឋានក៏បាន វីរិយៈនេះ បណ្ឌិតគប្បីឃើញថា បុគ្គលធ្វើដោយត្រូវផ្លូវហើយ រមែងជាមូលនៃសម្បត្តិទាំងពួង ។

## ៧- ជីវិត

សហជាតធម៌ទាំងឡាយ រមែងតាំងនៅដោយធម្មជាតិនោះ ហេតុនេះ ធម្មជាតិនោះ ឈ្មោះថា ជីវិត ( ប្រែថា ធម្មជាតិជាគ្រឿងរស់នៅនៃសហជាតធម៌ ) ។ ម្យ៉ាងទៀត ធម្មជាតិនោះ រស់នៅឯង ហេតុនោះ ទើបឈ្មោះថា ជីវិត ។ ន័យម្យ៉ាងទៀត ធម្មជាតិនោះ ត្រឹមតែជាការរស់នៅប៉ុណ្ណោះ ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ជីវិត ។ ចំណែកលក្ខណៈជាដើមនៃជីវិតនោះ គប្បីជ្រាបដោយន័យដែលពោលក្នុងជីវិតនៃរូបចុះ ។ សេចក្តីផ្សេងគ្នាក្នុងជីវិត ២ នោះ គឺជីវិតរបស់រូបធម៌ទាំងឡាយ និងជីវិតរបស់អរូបធម៌ទាំងឡាយប៉ុណ្ណោះឯង ។

## ៨- សមាធិ

## អត្ថនៃសមាធិសព្ទ

ធម្មជាតិណាតាំងទុកស្មើក្នុងអារម្មណ៍ ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សមាធិ ។ន័យម្យ៉ាងទៀតធម្មជាតិណាតម្កល់ចិត្តទុកដោយប្រពៃក្នុងអារម្មណ៍ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សមាធិ ។ ន័យម្យ៉ាងទៀត ធម្មជាតិ ដែលឈ្មោះថាសមាធិនោះ គឺការតាំងមាំនៃចិត្តប៉ុណ្ណោះឯង ។

## លក្ខណាទិចតុក្កៈរបស់សមាធិ

សមាធិនោះ មានការមិនប្រឫកប្របល់ ឬថា មានការមិនរាយមាយជាលក្ខណៈ មានការប្រមូលសហជាតធម៌ទាំងឡាយទុកជារស ដូចទឹកផ្ដុំនូវលម្អិតសម្រាប់ងូតទឹកទុក ( ឲ្យជាដុំ ) ដូច្នោះ មានការស្ងប់រម្ងាប់ជាបច្ចុប្បដ្ឋាន មានសេចក្ដីសុខដ៏ប្រសើរជាបទដ្ឋាន សមាធិនេះបណ្ឌិតគប្បីឃើញថា ជាការតាំងនៅនៃចិត្ត ដូចជាការតាំងនៅនៃអណ្ដាតប្រទីបក្នុងទីដែលមិនមានខ្យល់ ដូច្នោះ ។

## ៩- សទ្ធា

បុគ្គលទាំងឡាយរមែងជឿដោយធម្មជាតិនោះ ហេតុនេះ ទើបធម្មជាតិនោះឈ្មោះថា សទ្ធា ។ ន័យម្យ៉ាងទៀត ធម្មជាតិនោះ រមែងជឿឯង ហេតុនេះ ទើបធម្មជាតិនោះ ឈ្មោះថា សទ្ធា ។ ន័យម្យ៉ាងទៀត ធម្មជាតិនោះត្រឹមតែជាការជឿប៉ុណ្ណោះ ហេតុនេះ ទើបធម្មជាតិនោះ ឈ្មោះថា សទ្ធា ។

## លក្ខណាទិចតុក្កៈរបស់សទ្ធា

សទ្ធានោះមានការជឿជាលក្ខណៈ ឬមានការដាក់ចិត្តជាលក្ខណៈ មានការធ្វើឲ្យស្រស់ថ្លា ដូចកែវមណីធ្វើទឹកឲ្យថ្លាល្អជារស ឬមានការស្ទុះទៅតាមអារម្មណ៍ដែលជាទីតាំងនៃការជឿជារស ដូចជាការស្ទុះទៅ គឺហូរអណ្ដែតតាមក្រសែទឹកដែលហូរខ្លាំង ដូច្នោះ មានការមិនកករល្អក់ ឬមានអធិមុត្តិ គឺការដាក់ចិត្តជឿជាបច្ចុប្បដ្ឋាន មានសទ្ធេយ្យវត្ថុ គឺវត្ថុដែលគួរជាបទដ្ឋាន ឬមានសោតាបត្តិយង្គ មានការស្ដាប់ធម៌ជាដើមជាបទដ្ឋាន ។

សទ្ធានេះ បណ្ឌិតគប្បីជ្រាបថា ដូចដៃ ដូចទ្រព្យ និងដូចពូជ ដូច្នេះ ។

## ១០- សតិ

បុគ្គលទាំងឡាយ រមែងរឭកបានដោយធម្មជាតិនោះ ហេតុនេះ ធម្មជាតិនោះ ទើបឈ្មោះថា សតិ ។ ន័យម្យ៉ាងទៀត ធម្មជាតិនោះ រមែងរឭកបានខ្លួនឯង ហេតុនេះ ធម្មជាតិនោះ ទើបឈ្មោះថា សតិ ។ ន័យម្យ៉ាងទៀត ធម្មជាតិនោះ ត្រឹមតែជាការរឭកបានប៉ុណ្ណោះ ហេតុនេះ ធម្មជាតិនោះ ទើបឈ្មោះថា សតិ ។

## លក្ខណាទិចតុក្កៈរបស់សតិ

សតិនោះមានការមិនភ្លេចភ្លាំងជាលក្ខណៈ មានការមិនវង្វេងជារស មានការរក្សា ( ចិត្ត ) ទុកបាន ជាបច្ចុប្បដ្ឋាន ឬមានមុខឆ្ពោះទៅកាន់អារម្មណ៍ ជាបច្ចុប្បដ្ឋាន មានការចាំយ៉ាងមាំជាបទដ្ឋាន ឬមានសតិប្បដ្ឋាន មានកាយជាដើមជាបទដ្ឋាន ។

សតិនេះ បណ្ឌិតគប្បីជ្រាបថាដូចជាសសរខឿន ព្រោះផ្តោតចុះមាំក្នុងអារម្មណ៍ និងដូចជាឆ្មាំទ្វារ ចាំរក្សាទ្វារទាំងឡាយ មានចក្ខុទ្វារជាដើម ។

## ១១-១២ ហិរិ ឱត្តប្បៈ

ធម្មជាតិណា រមែងខ្មាស ព្រោះការប្រព្រឹត្តអាក្រក់ មានកាយទុច្ចរិតជាដើម ហេតុនេះ ទើបធម្មជាតិនោះ ឈ្មោះថា ហិរិ ។ ពាក្យថា ហិរិនោះ ជាពាក្យហៅចំពោះការខ្មាស ។ ធម្មជាតិណា រមែងខ្លាច ព្រោះការប្រព្រឹត្តអាក្រក់ទាំងនោះឯង ហេតុនេះ ទើបធម្មជាតិនោះ ឈ្មោះថា ឱត្តប្បៈ ។ ពាក្យថា ឱត្តប្បៈនោះ ជាពាក្យហៅចំពោះការខ្លាចបាប ។

## លក្ខណាទិចតុក្កៈរបស់ហិរោត្តប្បៈ

បណ្តាហិរិ និងឱត្តប្បៈនោះ ហិរិមានការខ្មាសបាបជាលក្ខណៈ ឱត្តប្បៈមានការតក់ស្លុតចំពោះបាបជាលក្ខណៈ ។ **ហិរិ** មានការមិនធ្វើបាបទាំងឡាយ ដោយអាការ

ខ្មាសជារស ឱត្តប្បៈ មានការមិនធ្វើបាបទាំងឡាយ ដោយអាការខ្លាចជារស ។ ម្យ៉ាងទៀត ហិរិ និងឱត្តប្បៈទាំងនោះ មានការរួញរាចេញពីបាបតាមប្រការដែលបានពោលហើយនោះជាបច្ចុប្បដ្ឋាន មានការគោរពចំពោះខ្លួន និងគោរពចំពោះអ្នកដទៃជាបទដ្ឋាន ។ ពិតហើយ បុគ្គលធ្វើខ្លួនឲ្យជាទីគោរព ទើបលះបាបបាន ដោយសេចក្ដីខ្មាស ដូចស្រីដែលមានត្រកូល ។ បុគ្គលធ្វើមនុស្សដទៃឲ្យជាទីគោរព ទើបលះបាបបាន ដោយការខ្លាច ដូចស្រីពេស្យាដូច្នោះ ។ ធម៌ ២ ប្រការនេះ បណ្ឌិតគប្បីជ្រាបថា ជាលោកបាលធម៌ ។

## ១៣-១៤-១៥ អលោភៈ អទោសៈ អមោហៈ

សត្វទាំងឡាយមិនលោភដោយធម៌នោះជាហេតុ ទើបធម៌នោះ ឈ្មោះថា អលោភៈ ( ធម៌ជាហេតុមិនលោភ ) ។ ម្យ៉ាងទៀត ធម៌ណាមិនលោភខ្លួនឯង ធម៌នោះ ឈ្មោះថា អលោភៈ ( ធម៌ដែលមិនលោភ ) ។ ន័យម្យ៉ាងទៀត ធម្មជាតិនោះត្រឹមតែជាធម៌មិនលោភប៉ុណ្ណោះ ហេតុនោះ ទើបឈ្មោះថា អលោភៈ ( ការមិនលោភ ) ។ ន័យក្នុងអទោសៈ និងអមោហៈក៏ដូចគ្នា ។

## លក្ខណាទិចតុក្កៈរបស់អលោភៈ អទោសៈ អមោហៈ

បណ្ដាធម៌ ៣ ប្រការនោះ អលោភៈ មានចិត្តមិនត្រេកអរក្នុងអារម្មណ៍ ជាលក្ខណៈ ។ ន័យម្យ៉ាងទៀត មានចិត្តដែលមិនជាប់ជំពាក់នៅក្នុងអារម្មណ៍ជាលក្ខណៈ ដូចតំណក់ទឹក មិនជាប់នៅលើស្លឹកឈូកដូច្នោះ មានការមិនហួងហែង ( នូវអារម្មណ៍ ) ជារស ដូចភិក្ខុរួចផុតហើយអំពីយកវាសកិច្ច មិនហួងហែងវត្ថុនៃយកវាស ដូច្នោះ ។ មានការមិនជាប់ជំពាក់ក្នុងអារម្មណ៍ជាបច្ចុប្បដ្ឋាន ប្រៀបដូចបុគ្គលដែលធ្លាក់ទៅក្នុង

ទីស្មោកគ្រោក មិនជាប់ជំពាក់នៅក្នុងទីនោះ ដូច្នោះ ។

អទោសៈ មានការមិនកាចជាលក្ខណៈ ន័យម៉្យាងទៀត មានការមិនប្រកាន់កំហុសជាលក្ខណៈ ដូចមិត្តជួយទំនុកបម្រុងដូច្នោះ មានការកម្ចាត់នូវអាឃាតចេញបានជារស ន័យម៉្យាងទៀត មានការកម្ចាត់សេចក្ដីក្ដៅក្រហាយចេញបានជារស ប្រៀបដូចខ្លឹមចន្ទន៍ មានរសត្រជាក់ដូច្នោះ មានសោមភាវៈ គឺការត្រជាក់ស្រទន់ជាបច្ចុប្បដ្ឋាន ដូចព្រះចន្ទពេញវង់ មានរស្មីត្រជាក់ ដូច្នោះ ។

អមោហៈ មានសភាពចាក់ធ្លុះតាមសភាវៈជាលក្ខណៈ ន័យម៉្យាងទៀត មានការចាក់ធ្លុះមិនខុសក្លាត់ជាលក្ខណៈ ដូចជាការចាក់នៃគ្រាប់ព្រួញ ដែលនាយខ្មាន់ធ្នូអ្នកឈ្លាសវៃ បាញ់ទៅត្រង់ក្ដារប៉ាយ ដូច្នោះ មានការធ្លុះបញ្ចាំងឲ្យឃើញតាមសភាវៈពិតជារស ដូចជាប្រទីបដូច្នោះ មានការមិនវង្វេងជាបច្ចុប្បដ្ឋាន ដូចមគ្គុទ្ទេសក៏ដ៏ជំនាញប្រាប់ផ្លូវដល់មនុស្សក្នុងព្រៃ ដូច្នោះ ។

ធម៌ទាំង ៣ នេះ បណ្ឌិត គប្បីឃើញថា ជាមូលនៃកុសលធម៌ទាំងពួង ។

## ១៦-១៧ កាយបស្សទ្ធិ និង ចិត្តបស្សទ្ធិ

ការស្ងប់នៃកាយ ឈ្មោះថា កាយបស្សទ្ធិ ។ ការស្ងប់នៃចិត្ត ឈ្មោះថា ចិត្តបស្សទ្ធិ ។ តែពាក្យថា កាយក្នុងបទថា **កាយបស្សទ្ធិ** នេះ បំណងយកខន្ធ ៣ មានវេទនាជាដើម ។ កាយបស្សទ្ធិ និងចិត្តបស្សទ្ធិរួមចូលគ្នាទាំង ២ នោះ មានការស្ងប់នូវការក្រវល់ក្រវាយកាយ និងចិត្តជាលក្ខណៈ មានការកម្ចាត់នូវការក្រវល់ក្រវាយកាយ និងចិត្តជារស មានភាពត្រជាក់ ព្រោះមិនមានការក្រវល់ក្រវាយកាយ និងចិត្តជាបច្ចុប្បដ្ឋាន មានកាយ និងចិត្តជាបទដ្ឋាន ។ កាយបស្សទ្ធិ និងចិត្តបស្សទ្ធិនេះ បណ្ឌិតគប្បីជ្រាបថា ជាបដិបក្ខចំពោះកិលេស មានឧទ្ធច្ចៈជាដើម ដែលធ្វើកាយ និងចិត្តមិនឲ្យស្ងប់រម្ងាប់ ។

## ១៨-១៩ កាយលហុតា និង ចិត្តលហុតា

ភាពស្រាលនៃកាយ ឈ្មោះថា កាយលហុតា ។ ភាពស្រាលនៃចិត្ត ឈ្មោះថា ចិត្តលហុតា ។ កាយលហុតា និងចិត្តលហុតានោះ មានការស្ងប់ចាកភាពធ្ងន់នៃកាយ និងចិត្តជាលក្ខណៈ មានការកម្ចាត់នូវភាពធ្ងន់នៃកាយ និងចិត្តជារស មានភាពរហ័សរហួននៃកាយ និងចិត្តជាបច្ចុប្បដ្ឋាន មានកាយ និងចិត្តជាបទដ្ឋាន ។ កាយលហុតា និងចិត្តលហុតានេះបណ្ឌិតគប្បីជ្រាបថា ជាបដិបក្ខចំពោះកិលេស មានថីនមិទ្ធៈជាដើម ដែលធ្វើនូវភាពធ្ងន់នៃកាយ និងចិត្ត ។

## ២០-២១ កាយមុទុតា និង ចិត្តមុទុតា

ភាពទន់នៃកាយ ឈ្មោះថា កាយមុទុតា ។ ភាពទន់នៃចិត្ត ឈ្មោះថា ចិត្តមុទុតា ។ កាយមុទុតា និងចិត្តមុទុតានោះ មានការចូលទៅរម្ងាប់នូវភាពរឹងត្អឹងនៃកាយ និងចិត្តជាលក្ខណៈ មានការកម្ចាត់នូវភាពរឹងត្អឹងនៃកាយ និងចិត្តជារស មានការមិនមានអាឃាតជាបច្ចុប្បដ្ឋាន មានកាយ និងចិត្តជាបទដ្ឋាន ។ កាយមុទុតា និងចិត្តមុទុតានេះបណ្ឌិតគប្បីជ្រាបថា ជាបដិបក្ខចំពោះកិលេស មានទិដ្ឋិ មានះជាដើម ដែលធ្វើនូវភាពរឹងត្អឹងនៃកាយ និងចិត្ត ។

## ២២-២៣ កាយកម្មញ្ញតា និង ចិត្តកម្មញ្ញតា

ភាពគួរដល់ការងារនៃកាយ ឈ្មោះថា កាយកម្មញ្ញតា ។ ភាពគួរដល់ការងារនៃចិត្ត ឈ្មោះថា ចិត្តកម្មញ្ញតា ។ កាយកម្មញ្ញតា និងចិត្តកម្មញ្ញតានោះ មានការរម្ងាប់នូវភាពមិនគួរដល់ការងារនៃកាយ និងចិត្តជាលក្ខណៈ មានការកម្ចាត់នូវភាពមិនគួរដល់ការងារនៃកាយ និងចិត្តជារស មានការដល់ព្រមនូវការធ្វើកាយ និងចិត្តជាអារម្មណ៍ជាបច្ចុប្បដ្ឋាន មានកាយ និងចិត្តជាបទដ្ឋាន ។ កាយកម្មញ្ញតា និង

ចិត្តកម្មញ្ញតានេះ បណ្ឌិតគប្បីជ្រាបថា ជាបដិបក្ខចំពោះកិលេស មាននីវរណៈដ៏សេស ជាដើម ដែលធ្វើនូវភាពមិនគួរដល់ការងារនៃកាយ និងចិត្ត នាំមកនូវសេចក្ដីជ្រះថ្លា ក្នុងវត្ថុជាទីតាំងនៃសេចក្ដីជ្រះថ្លាទាំងឡាយ នាំមកនូវសេចក្ដីគួរដល់ការប្រកបដោយ ប្រការផ្សេងៗ ក្នុងការធ្វើប្រយោជន៍ទាំងឡាយ ដូចសភាពបរិសុទ្ធ ( បាកមន្ទិល ) នៃមាស ( គួរដល់ការប្រកបជាអលង្ការគ្រប់ប្រភេទ ) ដូច្នោះ ។

## ២៤-២៥ កាយបាគុញ្ញតា និងចិត្តបាគុញ្ញតា

ការស្ទាត់ជំនាញនៃកាយ ឈ្មោះថា កាយបាគុញ្ញតា ។ ការស្ទាត់ជំនាញនៃចិត្ត ឈ្មោះថា ចិត្តបាគុញ្ញតា ។ កាយបាគុញ្ញតា និងចិត្តបាគុញ្ញតានេះ មានការមិនឈឺកាយ និងចិត្តជាលក្ខណៈ មានការកម្ចាត់នូវជំងឺនៃកាយ និងចិត្តជារស មានការមិនមានទោស ជាបច្ចុប្បដ្ឋាន មានកាយ និងចិត្តជាបទដ្ឋាន ។ កាយបាគុញ្ញតា និងចិត្តបាគុញ្ញតានេះ បណ្ឌិតគប្បីជ្រាបថា ជាបដិបក្ខចំពោះបាបធម៌ មានអសទ្ធិយជាដើម ដែលជាជំងឺ នៃកាយ និងចិត្ត ។

## ២៦-២៧ កាយុជុកតា និង ចិត្តុជុកតា

ភាពត្រង់នៃកាយ ឈ្មោះថា កាយុជុកតា ។ ភាពត្រង់នៃចិត្ត ឈ្មោះថា ចិត្តុជុកតា ។ កាយុជុកតា និងចិត្តុជុកតានោះ មានភាពត្រង់នៃកាយ និងចិត្តជាលក្ខណៈ មានការកម្ចាត់នូវភាពកោងនៃកាយ និងចិត្តជារស មានភាពត្រង់ ( នៃកាយ និងចិត្ត ) ជាបច្ចុប្បដ្ឋាន មានកាយ និងចិត្តជាបទដ្ឋាន ។ កាយុជុកតា និងចិត្តុជុកតានេះ បណ្ឌិតគប្បីជ្រាបថា ជាបដិបក្ខចំពោះឧបក្កិលេស មានមាយា និងសាថេយ្យជាដើម ដែល ធ្វើនូវភាពកោងនៃកាយ និងចិត្ត ។

# យេវាបនកសង្ខារ ៤

## ១- ឆន្ទៈ

ពាក្យថា ឆន្ទៈនោះ ជាពាក្យហៅកត្តុកម្យតា ( ការប្រាថ្នានឹងធ្វើ ) ។ ព្រោះហេតុនោះ ឆន្ទៈនោះមានសេចក្តីប្រាថ្នានឹងធ្វើជាលក្ខណៈ មានការស្វែងរកអារម្មណ៍ ជារស មានសេចក្តីត្រូវការដោយអារម្មណ៍ជាបច្ចុប្បដ្ឋាន មានអារម្មណ៍នោះឯង ជាបទដ្ឋានរបស់ឆន្ទៈនោះ ។

ឆន្ទៈនេះក្នុងការកាន់យកអារម្មណ៍ បណ្ឌិតគប្បីជ្រាបថា ដូចជាការលាតដៃចេញទៅដូច្នោះ ។

## ២- អធិមោក្ខ

ការបង្អោនចិត្តជឿ ឈ្មោះថា អធិមោក្ខ ។ អធិមោក្ខនោះ មានការសន្និដ្ឋានជាលក្ខណៈ មានការមិនសង្ស័យជារស មានការសម្រេចចិត្តជាបច្ចុប្បដ្ឋាន មានសន្និដ្ឋេយ្យធម៌ គឺធម៌ដែលគប្បីសន្និដ្ឋានជាបទដ្ឋាន ។

អធិមោក្ខនេះ បណ្ឌិតគប្បីជ្រាបថា ដូចជាសសរខឿន ព្រោះការមិនកម្រើកក្នុងអារម្មណ៍ ។

## ៣- មនសិការ

ការធ្វើ ឈ្មោះថា ការៈ ។ ការធ្វើ ( អារម្មណ៍ទុក ) ក្នុងចិត្ត ឈ្មោះថា មនសិការ ។ ន័យម្យ៉ាងទៀត ចេតសិកធម៌ណា រមែងធ្វើចិត្តមិនឲ្យដូចចិត្តដើម ហេតុនោះ ទើបចេតសិកធម៌នោះ ឈ្មោះថា មនសិការ ( ប្រែថា ចេតសិកធម៌ ដែលធ្វើចិត្តឲ្យខុសភាពដើម ) ដូច្នេះ ។ មនសិការនេះ មាន ៣ ប្រការ គឺអារម្មណបដិបាទក (មនសិការដែលធ្វើទុកក្នុងចិត្តចំពោះអារម្មណ៍ ) ១ វិថីបដិបាទក ( មនសិការដែលជា

បាទនៃវិថីចិត្ត ) ១ ជវនបដិបាទក ( មនសិការដែលជាបាទនៃជវនចិត្ត ) ១ ។

បណ្តាមនសិការ ៣ នោះ អារម្មណបដិបាទក ឈ្មោះថា មនសិការ ព្រោះធ្វើទុកក្នុងចិត្ត ។ អារម្មណបដិបាទកមនសិការនោះ មានការញ៉ាំងសម្បយុត្តធម៌ទាំងឡាយឲ្យស្ទុះទៅជាលក្ខណៈ មានការចងសម្បយុត្តធម៌ទាំងឡាយក្នុងអារម្មណ៍ជារស មានការឆ្ពោះមុខទៅរកអារម្មណ៍ជាបច្ចុប្បដ្ឋាន មានអារម្មណ៍ជាបទដ្ឋាន ។

មនសិការនេះ បណ្ឌិតគប្បីជ្រាបថា ជាធម៌រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ព្រោះជាធម៌ ញ៉ាំងសម្បយុត្តធម៌ឲ្យប្រព្រឹត្តទៅក្នុងអារម្មណ៍ ដូចជាសារថី ( ញ៉ាំងសេះឲ្យស្ទុះទៅ ) ដូច្នោះ ។ ចំណែកពាក្យថា វិថីបដិបាទកនោះ ជាពាក្យហៅបញ្ចទ្វារាវជ្ជនៈ ។ ពាក្យថា ជវនបដិបាទកនោះ ជាពាក្យហៅមនោទ្វារាវជ្ជនៈ ។ មនសិការទាំង ២នេះ គឺលោកមិនប្រាថ្នាយកក្នុងទីនេះទេ ។

## ៤– តត្រមជ្ឈត្តតា

ភាពជាកណ្តាលក្នុងធម៌ទាំងនោះ ឈ្មោះថា តត្រមជ្ឈត្តតា ។ តត្រមជ្ឈត្តតានោះ មានការនាំចិត្ត និងចេតសិកទាំងឡាយទៅដោយស្មើជាលក្ខណៈ មានការហាមឃាត់នូវការលើសខ្វះជារស ន័យម្យ៉ាងទៀត មានការកាត់ផ្តាច់នូវការធ្លាក់ទៅក្នុងចំណែកណាមួយជារស មានភាពជាកណ្តាលជាបច្ចុប្បដ្ឋាន ។

តត្រមជ្ឈត្តតានេះ ជាសភាពព្រងើយនៃចិត្ត និងចេតសិកទាំងឡាយ បណ្ឌិតគប្បីជ្រាបថា ដូចជាសារថីសម្លឹងមើលព្រងើយៗ នូវសេះអាជានេយ្យដែលរត់ទៅល្អហើយ ដូច្នោះ ។

## អនិយតសង្ខារ ៥

## ១–២ ករុណា និង មុទិតា

ករុណា និងមុទិតា គប្បីជ្រាបតាមន័យដែលបានពោលហើយក្នុងព្រហ្មវិហារ

និទ្ទេសចុះ ។ មែនពិត សេចក្តីប្លែកគ្នាក៏មានត្រឹមតែករុណា មុទិតា ( ក្នុងព្រហ្មវិហារ ) នោះ ជារូបាវចរដែលដល់អប្បនា ចំណែកករុណា មុទិតា ( ក្នុងអនិយតសង្ខារ ) នេះ ជាកាមាវចរប៉ុណ្ណោះឯង ។ តែអាចារ្យពួកខ្លះ ក៏ប្រាថ្នាយកមេត្តា និងឧបេក្ខា ចូលក្នុងអនិយតសង្ខារនេះផងដែរ ពាក្យរបស់អាចារ្យពួកនោះ មិនគប្បីកាន់យកទេ ។ ព្រោះថា ដោយអត្ថ មេត្តា គឺអទោសៈ ឧបេក្ខា គឺតត្រមជ្ឈត្តុបេក្ខានោះឯង ។

## ៣-៤-៥ កាយទុច្ចរិតវិរតិ វចីទុច្ចរិតវិរតិ និង មិច្ឆាជីវវិរតិ

ការវៀរចាកកាយទុច្ចរិត ឈ្មោះថា កាយទុច្ចរិតវិរតិ ។ សូម្បីក្នុងវិរតិដ៏សេស ក៏ដូចន័យនេះ ។ បើពោលដោយអាការ មានលក្ខណៈជាដើម វិរតិទាំង ៣ នោះ មានការមិនឈានកន្លងវត្ថុនៃទុច្ចរិត មានកាយទុច្ចរិតជាដើម អធិប្បាយថា មិនទម្លាយ ( វត្ថុទាំងនោះ ) ជាលក្ខណៈ ។ មានការបងចិញ្ចើមចំពោះវត្ថុនៃទុច្ចរិត មានកាយទុច្ចរិត ជាដើមជារស មានការមិនធ្វើជាបច្ចុប្បដ្ឋាន មានគុណ គឺសទ្ធា ហិរិ ឱត្តប្បៈ និង អប្បិច្ឆតាជាដើមជាបទដ្ឋាន ។ វិរតិនេះ បណ្ឌិតគប្បីជ្រាបថា ជាសភាវៈនៃចិត្ត ដែល បែរមុខចេញអំពីការធ្វើបាប ។

## សង្ខារណាសម្បយោគនឹងកុសលចិត្តដួងណា

សង្ខារ ៣៦ ដូចបានពោលមកនេះ គប្បីជ្រាបថា ដល់នូវការសម្បយោគនឹង កាមាវចរកុសលវិញ្ញាណដួងទី ១ (សោមនស្សសហគតញាណសម្បយុត្តអសង្ខារ) ។ សង្ខារដែលសម្បយោគនឹងកាមាវចរកុសលវិញ្ញាណ ដួងទី ១ យ៉ាងណា សូម្បីដែល សម្បយោគនឹងកាមាវចរកុសលវិញ្ញាណដួងទី ២ ក៏យ៉ាងនោះ ។ សេចក្តីប្លែកក្នុង វិញ្ញាណដួងទី ២ នេះ មានត្រឹមតែជាសសង្ខារប៉ុណ្ណោះ ។ ចំណែកសង្ខារដែលវៀរ អមោហៈដ៏សេស ( ៣៥ ) គប្បីជ្រាបថា សម្បយោគនឹងវិញ្ញាណដួងទី ៣ ( គឺ

សោមនស្សសហគតញាណវិប្បយុត្តអសង្ខារ ) ។ ការសម្បយោគនឹងវិញ្ញាណដួងទី ៤ ក៏ដូចគ្នា ។ ប្លែកតែក្នុងវិញ្ញាណដួងទី ៤ នេះជាសសង្ខារប៉ុណ្ណោះ ។ ចំណែកក្នុងសង្ខារទាំងឡាយ ដែលពោលក្នុងវិញ្ញាណដួងទី ១ សង្ខារវៀរបីតិដ៏សេស រមែងដល់ការសម្បយោគនឹងវិញ្ញាណដួងទី ៥ (គឺឧបេក្ខាសហគតញាណសម្បយុត្តអសង្ខារ) ។ សូម្បីការសម្បយោគនឹងវិញ្ញាណដួងទី ៦ ក៏ដូចគ្នានឹងការសម្បយោគនឹងវិញ្ញាណដួងទី ៥ ។ ក្នុងវិញ្ញាណដួងទី ៦ នោះ ក៏មានសភាពប្លែកត្រឹមតែជាសសង្ខារប៉ុណ្ណោះ ។ ចំណែកសង្ខារដែលវៀរអមោហៈដ៏សេស គប្បីជ្រាបថា ការសម្បយោគនឹងវិញ្ញាណដួងទី ៧ ( គឺឧបេក្ខាសហគតញាណវិប្បយុត្តអសង្ខារ) ការសម្បយោគនឹងវិញ្ញាណដួងទី ៨ ក៏យ៉ាងនោះ ។ សេចក្តីប្លែកគ្នាក្នុងវិញ្ញាណដួងទី ៨ នោះត្រឹមតែជាសសង្ខារប៉ុណ្ណោះ ។

ចំណែកសង្ខារទាំងឡាយ ដែលពោលក្នុងកាមាវចរកុសលវិញ្ញាណដួងទី ១ សង្ខារវៀរវិរតិ ៣ ដ៏សេស ( ៣៣ ) រមែងដល់ការសម្បយោគនឹងបឋមវិញ្ញាណក្នុងរូបាវចរកុសល ។ បន្ទាប់អំពីនោះ សង្ខារទាំងឡាយ វៀរវិតក្ក ( សល់ ៣២ ) សម្បយោគនឹងទុតិយវិញ្ញាណ ។ បន្ទាប់អំពីនោះ សង្ខារវៀរវិចារៈ ( សល់ ៣១) សម្បយោគនឹងតតិយវិញ្ញាណ ។ បន្ទាប់អំពីនោះ សង្ខារវៀរ បីតិ ( សល់ ៣០ ) សម្បយោគនឹងចតុត្ថវិញ្ញាណ ។ បន្ទាប់អំពីនោះ សង្ខារវៀរករុណា មុទិតា ក្នុងចំណែកអនិយតសង្ខារ ( សល់ ២៨ ) សម្បយោគនឹងបញ្ចមវិញ្ញាណ ។

សង្ខារក្នុងអារុប្បកុសលវិញ្ញាណ ៤ គឺសង្ខារ (ក្នុងរូបាវចរបញ្ចមវិញ្ញាណ) ទាំងនោះឯង ។ អរូបាវចរប៉ុណ្ណោះ ជាសេចក្តីប្លែកក្នុងអារុប្បកុសលនោះ ។

ក្នុងលោកុត្តរវិញ្ញាណទាំងឡាយ សង្ខារក្នុងមគ្គវិញ្ញាណ ដែលមានបឋមជ្ឈាន គប្បីជ្រាបដោយន័យ ដែលពោលក្នុងបឋមរូបាវចរវិញ្ញាណជាសេចក្តីដំបូង (សេចក្តី

តទៅ ) សង្ខារក្នុងមគ្គវិញ្ញាណ ដែលផ្សេងដោយមគ្គវិញ្ញាណ មានទុតិយជ្ឈានជាដើម គប្បីជ្រាបដោយន័យ ដែលបានពោលក្នុងវិញ្ញាណជាលំដាប់តទៅ មានទុតិយរូបាវចរវិញ្ញាណជាដើមដូចគ្នា ។ នេះជាសេចក្តីប្លែកក្នុងលោកុត្តរវិញ្ញាណនេះ គឺករុណា និងមុទិតាមិនមាន ១ វិរតិជានិយត ១ ជាលោកុត្តរ ១ ។

សង្ខារទាំងឡាយ ដែលជាកុសលប៉ុណ្ណោះ បណ្ឌិតគប្បីជ្រាបដោយប្រការដែលពោលមក ដូច្នេះ ជាលំដាប់ដំបូង ។

## អកុសលសង្ខារលោភមូល ១៧

អកុសលសង្ខារទាំងឡាយ សង្ខារដែលសម្បយុត្តដោយអកុសលវិញ្ញាណដួងទី ១ ក្នុងលោភមូល ( គឺវិញ្ញាណដែលជាសោមនស្សសហគតទិដ្ឋិគតសម្បយុត្ត-អសង្ខារ ) មាន ១៧ គឺជាអនិយត មកដោយរូបរបស់ខ្លួន ១៣ ជាយេវាបនក ៤ ។ ក្នុងអកុសលសង្ខារ ១៧ នោះ សង្ខារ ១៣ គឺផស្សៈ ចេតនា វិតក្កៈ វិចារៈ បីតិ វីរិយៈ ជីវិត សមាធិ អហិរិកៈ អនោត្តប្បៈ លោភៈ មោហៈ មិច្ឆាទិដ្ឋិ ទាំងនេះជានិយតមកដោយរូបរបស់ខ្លួន ។ សង្ខារ ៤ គឺឆន្ទៈ អធិមោក្ខ ឧទ្ធច្ចៈ មនសិការនេះជាយេវាបនក ។

## អធិប្បាយ អកុសលសង្ខារលោភមូល

ការអធិប្បាយក្នុងអកុសលសង្ខារទាំងនោះ បណ្ឌិតគប្បីជ្រាបដូចតទៅនេះ

### អហិរិកៈ អនោត្តប្បៈ

បណ្តាធម៌ទាំងនោះ បុគ្គលណាមិនខ្មាស ហេតុនេះ ទើបបុគ្គលនោះឈ្មោះថា អហិរិកោ ប្រែថា អ្នកមិនខ្មាស ។ ភាពនៃអ្នកមិនខ្មាស ឈ្មោះថា អហិរិកំ ប្រែថា

សេចក្ដីមិនខ្មាស ។ សេចក្ដីមិនខ្លាច ឈ្មោះថា អនោត្តប្បៈ ។ បណ្ដាធម៌ទាំង ២ យ៉ាងនោះ អហិរិកៈ មានការមិនខ្ពើមនូវទុច្ចរិត មានកាយទុច្ចរិតជាដើមជាលក្ខណៈ ឬមានការមិនខ្មាសនូវទុច្ចរិតទាំងឡាយជាលក្ខណៈ ។ អនោត្តប្បៈ មានការមិនខ្លាច នូវទុច្ចរិតទាំងឡាយនោះឯងជាលក្ខណៈ ឬមានការមិនតក់ស្លុតចំពោះទុច្ចរិតទាំងឡាយ នោះជាលក្ខណៈ ។ នេះជាសេចក្ដីសង្ខេបក្នុងអហិរិកៈ និងអនោត្តប្បៈនោះ ។

ចំណែកសេចក្ដីពិស្ដារ បណ្ឌិតគប្បីជ្រាបដោយទំនងដែលផ្ទុយគ្នានឹងហិរិ និង ឱត្តប្បៈដែលពោលហើយនោះចុះ ។

## លោភៈ មោហៈ

សត្វទាំងឡាយ រមែងលោភដោយចេតសិកធម៌នោះជាហេតុ ទើបចេតសិក ធម៌នោះ ឈ្មោះថា លោភៈ ( ធម៌ជាហេតុលោភនៃសត្វទាំងឡាយ ) ។ ន័យម្យ៉ាងទៀត ចេតសិកធម៌ណា រមែងលោភខ្លួនឯង ចេតសិកធម៌នោះ ឈ្មោះថា លោភៈ ( ធម៌ ដែលលោភ ) ។ ន័យម្យ៉ាងទៀត ធម្មជាតិនោះ ត្រឹមតែជាការលោភប៉ុណ្ណោះ ហេតុនេះ ទើបឈ្មោះថា លោភៈ ( ការលោភ ) ។

សត្វទាំងឡាយរមែងវង្វេងដោយចេតសិកធម៌នោះជាហេតុ ទើបចេតសិកធម៌ នោះ ឈ្មោះថា មោហៈ ( ធម៌ជាហេតុវង្វេងនៃសត្វទាំងឡាយ ) ។ ន័យម្យ៉ាងទៀត ចេតសិកធម៌ណារមែងវង្វេងខ្លួនឯង ចេតសិកធម៌នោះ ឈ្មោះថា មោហៈ ( ធម៌ ដែលវង្វេង ) ។ ម្យ៉ាងទៀត ធម្មជាតិនោះត្រឹមតែជាការវង្វេងនោះប៉ុណ្ណោះ ហេតុនេះ ទើបឈ្មោះថា មោហៈ ( ការវង្វេង ) ។

បណ្ដាលោភៈ និងមោហៈនោះ លោភៈមានការប្រកាន់យកនូវអារម្មណ៍ជា លក្ខណៈ ដូចស្វាជាប់ជ័រ មានការជាប់ក្នុងអារម្មណ៍ជារស ដូចដុំសាច់ដែលដាក់លើ

អំបែងដ៏ក្តៅ មានការមិនលះបង់ជាបច្ចុប្បដ្ឋាន ដូចការប្រឡាក់ប្រេង និងថ្នាំបន្តក់ភ្នែក មានការឃើញថា គួរត្រេកអរក្នុងសំយោជនិយធម៌ទាំងឡាយជាបទដ្ឋាន ។

លោភៈនេះ បណ្ឌិតគប្បីជ្រាបថា កាលចម្រើនឡើង ដូចស្ទឹង គឺតណ្ហាតែងនាំទៅកាន់នរកប៉ុណ្ណោះ ដូចស្ទឹងមានក្រសែទឹកដ៏លឿន រមែងហូរនាំទៅកាន់មហាសមុទ្រតែម្យ៉ាង ដូច្នោះ ។

មោហៈ មានសភាពងងឹតនៃចិត្តជាលក្ខណៈ ម្យ៉ាងទៀត មានការមិនដឹងជាលក្ខណៈ មានការមិនចាក់ធ្លុះជារសន័យម្យ៉ាងទៀត មានការបិទបាំងសភាវៈនៃអារម្មណ៍ជារស មានការមិនបដិបត្តិដោយប្រពៃជាបច្ចុប្បដ្ឋាន ន័យម្យ៉ាងទៀត មានងងឹត គឺការល្ងង់ខ្លៅ ជាបច្ចុប្បដ្ឋាន មានការធ្វើទុកក្នុងចិត្តដោយឧបាយមិនត្រូវទំនងជាបទដ្ឋាន ។ មោហៈនេះ បណ្ឌិតគប្បីជ្រាបថា ជាមូលនៃអកុសលទាំងពួង ។

## មិច្ឆាទិដ្ឋិ

សត្វទាំងឡាយ រមែងយល់ខុសដោយធម្មជាតិនោះជាហេតុ ទើបធម្មជាតិនោះឈ្មោះថា មិច្ឆាទិដ្ឋិ ( ហេតុនៃការយល់ខុស ) ។ ម្យ៉ាងទៀត ធម្មជាតិណារមែងយល់ខុសខ្លួនឯង ធម្មជាតិនោះ ឈ្មោះថា មិច្ឆាទិដ្ឋិ ( ធម្មជាតិដែលយល់ខុស )។ ន័យម្យ៉ាងទៀត ធម្មជាតិនោះត្រឹមតែជាការយល់ខុស ហេតុនោះ ធម្មជាតិនេះ ឈ្មោះថា មិច្ឆាទិដ្ឋិ ( ការយល់ខុស ) ។

មិច្ឆាទិដ្ឋិនោះ មានការប្រកាន់ខុសដោយឧបាយមិនត្រូវទំនងជាលក្ខណៈ មានការប្រកាន់ខុសចាកសភាវៈជារស មានការផ្តោតចិត្តខុសជាបច្ចុប្បដ្ឋាន មានការមិនប្រាថ្នាដើម្បីឃើញព្រះអរិយបុគ្គលទាំងឡាយជាដើមជាបទដ្ឋាន ។មិច្ឆាទិដ្ឋិនេះបណ្ឌិតគប្បីជ្រាបថា ជាបរមវជ្ជ ( ទោសយ៉ាងក្រៃលែង ) ។

## ឧទ្ធច្ចៈ

ការរាយមាយនៃចិត្ត ឈ្មោះថា ឧទ្ធច្ចៈ ។ ឧទ្ធច្ចៈនោះ មានការមិនចូលទៅស្ងប់ជាលក្ខណៈ ដូចរលកទឹករញ្ជួយព្រោះខ្យល់បក់ត្រូវ ដូច្នោះ មានការមិនតាំងមាំជារស ដូចទង់ និងផ្សែងសំពត់បក់បោកព្រោះខ្យល់ មានការច្រេច្រាជាបច្ចុប្បដ្ឋាន ដូចផេះហុយទ្រលោម ព្រោះត្រូវដុំថ្មធ្លាក់លើ ដូច្នោះ មានការមិនចូលទៅស្ងប់ក្នុងចិត្ត មានអយោនិសោមនសិការ ព្រោះការមិនស្ងប់ក្នុងចិត្តជាបទដ្ឋាន ។

ឧទ្ធច្ចៈនេះ បណ្ឌិតគប្បីជ្រាបថា ជាការរវើរវាយចិត្ត ។

អកុសលសង្ខារដ៏សេស គប្បីជ្រាបដោយន័យដែលបានពោលហើយ ក្នុងកុសលសង្ខារចុះ ។ ព្រោះថា ភាពជាអកុសល និងចេតសិកធម៌អាក្រក់ ដោយភាពជាអកុសលប៉ុណ្ណោះ នេះជាសេចក្តីប្លែករបស់កុសលសង្ខារទាំងនោះ ។

## សង្ខារណាសម្បយោគនឹងអកុសលចិត្តដួងណា

សង្ខារ ១៧ ដូចពោលមកនេះ គប្បីជ្រាបថា ដល់នូវការសម្បយោគជាមួយនឹងអកុសលចិត្តដួងទី ១ ។ សង្ខារដែលសម្បយោគនឹងអកុសលចិត្តដួងទី ១ យ៉ាងណា សូម្បីការសម្បយោគនឹងអកុសលចិត្តដួងទី ២ ក៏យ៉ាងនោះ ។ ចំណែកសេចក្តីផ្សេងនៃអកុសលចិត្តដួងទី ២ នេះ ជាសសង្ខារ និងថីនមិទ្ធៈ ជាអនិយត ។

## ថីនមិទ្ធៈ

បណ្តាធម៌ទាំងនោះ មានការស្មូកស្មើរចិត្ត ឈ្មោះថា ថីនៈ ។ ការងោកងុយឈ្មោះថា មិទ្ធៈ សេចក្តីថា ថីនៈ គឺកិរិយារួញត្រឡប់ដោយមិនមានឧស្សាហ៍ មិទ្ធៈ គឺទម្លាយ គឺបោះបង់ចោលនូវសភាពអាច ។ ថីនៈផង មិទ្ធៈផង រួមគ្នា ឈ្មោះថា ថីនមិទ្ធៈ ។ បណ្តាធម៌ ២ យ៉ាងនោះ ថីនៈ មានការមិនឧស្សាហ៍ជាលក្ខណៈ មានការ

ដាក់ចុះនូវសេចក្តីព្យាយាមជារស មានការលិចចុះជាបច្ចុប្បដ្ឋាន មិទ្ធៈមានការមិនគួរដល់ការងារជាលក្ខណៈ មានការបិទ ( ទ្វារ ) ជារស មានការរួញរាជាបច្ចុប្បដ្ឋាន ឬមានការងោកងុយជាបច្ចុប្បដ្ឋាន ។ ថីនមិទ្ធៈទាំង ២ មានអយោនិសោមនសិការក្នុងការមិនត្រេកអរ ( ក្នុងកុសលធម៌ ) និងសេចក្តីខ្ជិលច្រអូសកាយជាដើម ជាបទដ្ឋាន ។

ក្នុងសង្ខារទាំងឡាយដែលពោលក្នុងអកុសលចិត្តដួងទី ១ សង្ខារវៀរមិច្ឆាទិដ្ឋិដ៏សេស ( ១៦ ) គប្បីជ្រាបថា សម្បយោគនឹងអកុសលចិត្តដួងទី ៣ ( គឺសោមនស្សសហគតទិដ្ឋិគតវិប្បយុត្តអសង្ខារ ) តែមានះជាអនិយត ក្នុងអកុសលចិត្តដួងទី ៣ នេះជាសេចក្តីប្លែកគ្នា ។

## មានះ

មានះនោះមានការក្រអឺតក្រអោងជាលក្ខណៈ មានការលើកតម្កើងខ្លួនជារស មានសេចក្តីប្រាថ្នាខ្ពស់ ដូចជាទង់ដែលគេលើកឡើង ជាបច្ចុប្បដ្ឋាន មានលោភៈដែលមិនប្រកបដោយទិដ្ឋិជាបទដ្ឋាន មានះនេះ បណ្ឌិតគប្បីជ្រាបថាដូចមនុស្សឆ្កួត ។

ក្នុងសង្ខារទាំងឡាយ ដែលពោលក្នុងអកុសលចិត្តដួងទី ២ វៀរមិច្ឆាទិដ្ឋិ សង្ខារដ៏សេសគប្បីជ្រាបថា សម្បយោគនឹងអកុសលចិត្តដួងទី ៤ ។ សូម្បីក្នុងអកុសលចិត្តដួងទី ៤ នេះសោត មានះក៏ជាសង្ខារក្នុងជំពូកអនិយតដូចគ្នា ។ ចំណែកក្នុងសង្ខារទាំងឡាយ ដែលពោលក្នុងអកុសលចិត្តដួងទី ១ វៀរបីតិ សង្ខារដ៏សេសដល់នូវការសម្បយោគនឹងអកុសលចិត្តដួងទី ៥ ។ សូម្បីសង្ខារដែលសម្បយោគនឹងអកុសលចិត្តដួងទី ៦ ក៏ដូចគ្នានឹងសង្ខារដែលសម្បយោគនឹងអកុសលចិត្តដួងទី ៥ ប្លែកគ្នាតែក្នុងដួងទី ៦ នេះជាសសង្ខារ ថីនមិទ្ធៈជាអនិយត ។ ក្នុងសង្ខារទាំងឡាយ ដែលពោលក្នុងអកុសលចិត្តដួងទី ៥ វៀរទិដ្ឋិសង្ខារដ៏សេសគប្បីជ្រាបថា សម្បយោគនឹងអកុសល

ចិត្តដួងទី ៧ ។ តែក្នុងអកុសលចិត្តដួងទី ៧ នេះ មានៈជាអនិយត ។ ក្នុងសង្ខារទាំងឡាយ ដែលពោលក្នុងអកុសលចិត្តដួងទី ៦ វៀរទិដ្ឋិសង្ខារដ៏សេសគប្បីជ្រាបថាសម្បយោគនឹងអកុសលចិត្តដួងទី ៨ ។ សូម្បីក្នុងអកុសលចិត្តដួងទី ៨ នេះសោតមានៈក៏ជាសសង្ខារ ក្នុងពួកអនិយតដូចគ្នា ។

## អកុសលសង្ខារទោសមូល ១៨

ចំណែកក្នុងទោសមូល ២ ដែលជាលំដាប់ដំបូង សង្ខារដែលសម្បយុត្ត ដោយអកុសលចិត្តដួងទី ១ មាន ១៨ គឺជាអនិយត មកដោយរូបរបស់ខ្លួន ១១ ជាយេវាបនក ៤ ជាអនិយត ៣ ក្នុងអកុសលសង្ខារ ១៨ នោះ សង្ខារ ១១ គឺផស្សៈ ចេតនា វិតក្ក វិចារៈ វីរិយៈ ជីវិត សមាធិ អហិរិកៈ អនោត្តប្បៈ ទោសៈ មោហៈ ទាំងជាអនិយត មកដោយរូបរបស់ខ្លួន សង្ខារ ៤ គឺឆន្ទៈ អធិមោក្ខ ឧទ្ធច្ចៈ មនសិការ នេះជាយេវាបនក សង្ខារ ៣ គឺឥស្សា មច្ឆរិយៈ កុក្កុច្ចៈ នេះជាអនិយត ។

## អធិប្បាយ អកុសលសង្ខារទោសមូល

### ទោសៈ

គប្បីជ្រាបអត្ថក្នុងបទទាំងនោះដូច្នេះថា សត្វទាំងឡាយ រមែងប្រទូស្តដោយចេតសិកធម៌នោះ ហេតុនេះ ទើបចេតសិកធម៌នេះ ឈ្មោះថា ទោសៈ ( ហេតុនៃការប្រទូស្ត ) ម្យ៉ាងទៀត ធម្មជាតិណាតែងតែប្រទូស្តដោយខ្លួនឯង ហេតុនេះ ទើបចេតសិកធម៌នោះ ឈ្មោះថា ទោសៈ ( ធម៌ដែលប្រទូស្ត ) ។ ម្យ៉ាងទៀត ធម្មជាតិនោះ ត្រឹមតែជាកាប្រទូស្តប៉ុណ្ណោះ ទើបឈ្មោះថា ទោសៈ ( ការប្រទូស្ត ) ។

ទោសៈនោះមានសភាពកាចជាលក្ខណៈ ដូចអាសិរពិសដែលត្រូវគេវាយ មានការក្រហល់ក្រហាយជារស ដូចពិសជ្រាបចូល ន័យម្យ៉ាងទៀត មានការដុតទីអាស្រ័យ

របស់ខ្លួនជារស ដូចភ្លើងព្រៃ មានការប្រទូស្តជាបច្ចុប្បដ្ឋាន ដូចសត្រូវបានឱកាស មានអាឃាតវត្ថុ ( រឿងដែលឲ្យកើតអាឃាត ) ជាបទដ្ឋាន ។

ទោសៈនេះបណ្ឌិតគប្បីជ្រាបថា ដូចជាទឹកមូត្រស្អុយលាយដោយថ្នាំពិស ដូច្នោះ។

## ឥស្សា

ការប្រព្រឹត្តច្រណែនឫស្យា ឈ្មោះថា **ឥស្សា** ឥស្សានោះមានការអត់ធន់មិនបានចំពោះសម្បត្តិរបស់អ្នកដទៃជាលក្ខណៈ មានការមិនត្រេកអរចំពោះសម្បត្តិអ្នកដទៃនោះឯងជារស មានការបែរមុខចេញអំពីសម្បត្តិរបស់អ្នកដទៃនោះ ជាបច្ចុប្បដ្ឋាន មានសម្បត្តិរបស់អ្នកដទៃជាបទដ្ឋាន ។

ឥស្សានេះបណ្ឌិតគប្បីជ្រាបថា ជាសំយោជនៈ ( គ្រឿងចងចិត្ត ) ។

## មច្ឆរិយៈ

សេចក្តីកំណាញ់ ឈ្មោះថា **មច្ឆរិយៈ** ។ មច្ឆរិយៈនោះ មានការលាក់ទុកសម្បត្តិទាំងឡាយរបស់ខ្លួនដែលបានមកហើយ ឬដែលគប្បីបានជាលក្ខណៈ មានសេចក្តីមិនពេញចិត្តចំពោះសម្បត្តិទាំងឡាយរបស់ខ្លួននោះ ដែលជារបស់ទូទៅដល់មនុស្សដទៃៗ ជារស មានការធ្វើមុខក្រញូវ ឬថា មានការហួងហែងប្រុងប្រយ័ត្នជាបច្ចុប្បដ្ឋាន មានសម្បត្តិរបស់ខ្លួនជាបទដ្ឋាន ។

មច្ឆរិយៈនេះ បណ្ឌិតគប្បីជ្រាបថា ជាសភាពពិការនៃចិត្ត ។

## កុក្កុច្ចៈ

ការធ្វើចិត្តដែលបណ្ឌិតស្អប់ ( គឺមិនល្អ ) ឈ្មោះថា **កុកត** ។ភាវៈនៃកុកតៈនោះ ឈ្មោះថា **កុក្កុច្ចៈ** ( ប្រែថា ការធ្វើចិត្តដែលបណ្ឌិតស្អប់ ) ។ កុក្កុច្ចៈនោះ មានការធ្វើ

ឲ្យក្តៅចិត្តក្នុងកាលជាខាងក្រោយជាលក្ខណៈ មានការសោកស្តាយនូវកិច្ច ដែលធ្វើនិងមិនបានធ្វើជារស មានសេចក្តីក្តៅក្រហាយស្តាយក្រោយជាបច្ចុប្បដ្ឋាន មានការធ្វើនិងមិនបានធ្វើជាបទដ្ឋាន ។

កុក្កុច្ចៈនេះ បណ្ឌិតគប្បីជ្រាបថា ដូចជាទាសៈ ។

អកុសលសង្ខារដ៏សេសក៏មានប្រការដូចពោលហើយនោះឯង ។

សង្ខារ ១៨ ដែលពោលមកនេះឯងបណ្ឌិតគប្បីជ្រាបថាដល់នូវការសម្បយោគនឹងអកុសលចិត្ត ដែលជាទោសមូលដួងទី ១ ។ ឯសង្ខារដែលដល់ការសម្បយោគនឹងអកុសលចិត្តទោសមូលដួងទី ១ យ៉ាងណា សូម្បីដែលដល់នូវការសម្បយោគនឹងទោសមូលដួងទី ២ ក៏ដូច្នោះដែរ ។ តែសេចក្តីប្លែក ( ក្នុងដួងទី ២ នេះ ) ក៏ជាសសង្ខារ និងក្នុងពួកអនិយត មានថីនមិទ្ធៈផង ។

## អកុសលសង្ខារមោហមូល ១៣

ចំណែកក្នុងមោហមូល ២ ពោលក្នុងវិចិកិច្ឆាសម្បយុត្តមុន សង្ខារ ( ជាវិចិកិច្ឆាសម្បយុត្ត ) ១៣ គឺ ( ជាអនិយត ) មកដោយរូបរបស់ខ្លួន ១១ គឺផស្សៈ ចេតនា វិតក្ក វិចារៈ វីរិយៈ ជីវិត ចិត្តដ្ឋិតិ ( ការឈប់នៃចិត្ត ) អហិរិកៈ អនោត្តប្បៈ មោហៈ វិចិកិច្ឆា និងជាយេវាបនក ២ គឺឧទ្ធច្ចៈ មនសិការ ។

បណ្តាបទទាំងនោះ បទថា **ចិត្តដ្ឋិតិ** សំដៅអាការត្រឹមតែការឈប់នៃបវត្តិចិត្ត ( ជាខណៈៗ ) បានដល់ សមាធិមានកម្លាំងខ្សោយ ។

ការមិនប្រាកដក្នុងចិត្ត ហេតុនោះ ទើបឈ្មោះថា វិចិកិច្ឆា ។ វិចិកិច្ឆានោះ មានការសង្ស័យជាលក្ខណៈ មានការកម្រើកជារស មានការកាត់ចិត្តមិនបាន ឬថា មានការកាន់យកច្រើនជាបច្ចុប្បដ្ឋាន មានការធ្វើទុកក្នុងចិត្តដោយមិនត្រូវទំនង ព្រោះការស្ទាក់ស្ទើរនៃចិត្តជាបទដ្ឋាន ។

វិចិកិច្ឆានេះ បណ្ឌិតគប្បីជ្រាបថា ជាធម្មជាតិធ្វើសេចក្ដីអន្តរាយដល់ការបដិបត្តិ ។ សង្ខារ ( វិចិកិច្ឆាសម្បយុត្ត ) ដ៏សេស ក៏មានប្រការដូចពោលមកហើយនេះឯង ។

ឧទ្ធច្ចសម្បយុត្តក្នុងសង្ខារទាំងឡាយដែលពោលក្នុងវិចិកិច្ឆាសម្បយុត្ត សង្ខារ វៀរវិចិកិច្ឆាដ៏សេស ១២ ជាឧទ្ធច្ចសម្បយុត្ត តែព្រោះឧទ្ធច្ចសម្បយុត្តនេះមិនមាន វិចិកិច្ឆា ទើបអធិមោក្ខកើតឡើង រួមជាមួយនឹងអធិមោក្ខនោះក៏ជា ១៣ ដូចគ្នា ។ ព្រោះ អធិមោក្ខរួមនឹង ( ចិត្តដ្ឋិតិ ) ទើបជាសមាធិមានកម្លាំងខ្លាំងជាង ម្យ៉ាងទៀត ឧទ្ធច្ចៈណា មានមកក្នុងឧទ្ធច្ចសម្បយុត្តនេះ មកដោយរូបរបស់ខ្លួនពិត ។ អធិមោក្ខ និងមនសិការ មកដោយអំណាចយេវាបនក ដូច្នេះ ។

បណ្ឌិតជ្រាបអកុសលសង្ខារទាំងឡាយ ដោយប្រការដូចបានពោលមកយ៉ាង នេះឯង ។

## អព្យាកតសង្ខារចំណែកវិបាក

## អហេតុកវិបាក

ក្នុងអព្យាកតសង្ខារទាំងឡាយដែលជាលំដាប់ដំបូង អព្យាកតសង្ខារចំណែក វិបាកមាន ២ ដោយចែកជាអហេតុកៈ និងសហេតុកៈ ។ បណ្ដាវិបាក ២ យ៉ាងនោះ អព្យាកតសង្ខារដែលសម្បយុត្តដោយអហេតុកវិបាកវិញ្ញាណ ចាត់ជាអហេតុកសង្ខារ ។ ក្នុងអហេតុកសង្ខារទាំងឡាយនោះ ដំបូងសង្ខារដែលសម្បយុត្តដោយចក្ខុវិញ្ញាណ ទាំងកុសលវិបាក និងអកុសលវិបាក មាន ៥ គឺសង្ខារដែលមកដោយប្រក្រតីរបស់ខ្លួន មាន ៤ គឺផស្សៈ ចេតនា ជីវិត ចិត្តដ្ឋិតិ ដែលជាយេវាបនក មានតែមនសិការ ១ ប៉ុណ្ណោះ ដែលសម្បយុត្តដោយសោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និង កាយវិញ្ញាណ ៥ នេះឯង ។ ក្នុងមនោធាតុដែលជាវិបាកទាំង ២ ចំណែក ( គឺកុសល

និងអកុសល ) មាន ៨ គឺសង្ខារ ៥ នោះ ( គឺផស្សៈ ចេតនា ជីវិត ចិត្តដ្ឋិតិ មនសិការ ) និងវិតក្ក វិចារៈ អធិមោក្ខ សូម្បីក្នុងអហេតុកមនោវិញ្ញាណធាតុ ទាំង ៣ ( គឺឧបេក្ខាសហគតៈ សុខសហគតៈ សោមនស្សសហគតៈ ) ក៏យ៉ាងនោះ ។ តែក្នុងអហេតុកមនោវិញ្ញាណធាតុនេះ មនោវិញ្ញាណធាតុណាជាសោមនស្សសហគតៈ បីតិ ( ដែលកើត ) ព្រមនឹងមនោវិញ្ញាណធាតុនោះ គប្បីជ្រាបថា ជាអធិកបីតិ ( បីតិ យ៉ាងក្រៃលែង ) ។

## សហេតុកវិបាក

ចំណែកអព្យាកតសង្ខារ ដែលសម្បយុត្តដោយសហេតុកវិបាកចិត្ត ចាត់ជាសហេតុកសង្ខារ ។ ក្នុងសហេតុកសង្ខារទាំងឡាយនោះ សេចក្តីដំបូង សង្ខារដែលសម្បយុត្តដោយកាមាវចរវិបាកចិត្ត ៨ ក៏ដូចនឹងសង្ខារដែលសម្បយុត្តដោយកាមាវចរកុសលចិត្ត ៨ នោះឯង ។ តែករុណា និងមុទិតាណា ក្នុងពួកអនិយតសង្ខារ ករុណានិងមុទិតានោះ មិនមានក្នុងពួកវិបាកសង្ខារ ព្រោះករុណា និងមុទិតា ជាសត្តារម្មណ៍ ( មានសត្វជាអារម្មណ៍ ) ។ ចំណែកកាមាវចរវិបាកសង្ខារទាំងឡាយ ជាបរិត្តារម្មណ៍ ( មានកាមធម៌ជាអារម្មណ៍ ) ដោយចំណែកមួយ ។ មិនត្រឹមតែករុណា និងមុទិតាប៉ុណ្ណោះទេ សូម្បីវិរតិទាំងឡាយ ក៏មិនមានក្នុងពួកវិបាកសង្ខារ ព្រោះលោកពោលថា សិក្ខាបទ ៥ ជាកុសលប៉ុណ្ណោះ ។ ចំណែកអព្យាកតសង្ខារទាំងឡាយ ដែលសម្បយុត្តដោយវិបាកចិត្តដែលជារូបាវចរៈ អរូបាវចរៈ និងលោកុត្តរ ក៏ដូចគ្នានឹងសង្ខារ ដែលសម្បយុត្តដោយកុសលចិត្តនៃវិបាកចិត្តទាំងនោះឯង ។

## អព្យាកតសង្ខារជាកិរិយា

សូម្បីអព្យាកតសង្ខារជាកិរិយា ក៏មាន ២ ដោយចែកជាអហេតុកៈ និង

សហេតុកៈ ។ បណ្ដាអព្យាកតសង្ខារ ២ យ៉ាងនោះ អព្យាកតសង្ខារទាំងឡាយ ដែលសម្បយុត្តដោយអហេតុកកិរិយាចិត្ត ចាត់ជាអហេតុកៈ ។ អហេតុកកិរិយាសង្ខារទាំងនោះ ស្មើនឹងសង្ខារដែលប្រកបដោយកុសលវិបាកមនោធាតុ និងអហេតុកមនោ-វិញ្ញាណធាតុទាំង ២ ។ តែវីរិយៈប្រកបដោយមនោវិញ្ញាណធាតុទាំង ២ ជាអធិកវីរិយៈ ( វីរិយៈយ៉ាងក្រៃលែង ) ។ សមាធិដែលដល់ព្រមដោយកម្លាំង ព្រោះមានវីរិយៈកើតរួមនេះ ជាសភាពប្លែកគ្នាក្នុងសង្ខារ ដែលប្រកបដោយមនោវិញ្ញាណធាតុទាំង ២ នោះ ។

ចំណែកអព្យាកតសង្ខារទាំងឡាយ ដែលសម្បយុត្តដោយសហេតុកកិរិយាចិត្ត ជាសហេតុកៈ ។ ក្នុងសហេតុកកិរិយាសង្ខារទាំងនោះ សេចក្ដីដំបូង សង្ខារដែលសម្បយុត្តដោយកាមាវចរកិរិយាចិត្ត ៨ វៀរវិរតិ ក៏ដូចនឹងសង្ខារដែលសម្បយុត្តដោយកាមាវចរកុសល ៨ ។ សង្ខារដែលសម្បយុត្តដោយរូបាវចរកិរិយាចិត្ត និងអរូបាវចរកិរិយាចិត្តសោត ក៏ដូចគ្នានឹងសង្ខារ ដែលសម្បយុត្តដោយកុសលចិត្តនៃកិរិយាចិត្តទាំងនោះ គ្រប់ប្រការដូចគ្នានោះឯង ។ សង្ខារទាំងឡាយដែលជាអព្យាកតៈ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលមកយ៉ាងនេះឯង ។

នេះជាកថាមុខ យ៉ាងពិស្ដារក្នុងសង្ខារក្ខន្ធ

នេះជាកថាមុខ យ៉ាងពិស្ដារក្នុងខន្ធទាំងឡាយ

តាមន័យនៃបទភាជនីយ៍ ក្នុងព្រះអភិធម្មប៉ុណ្ណោះសិន

# មហាដីកា

## កថាពណ៌នាអំពីសង្ខារក្ខន្ធ

ពាក្យថា **ធម្មជាតិដែលមានការធ្វើឲ្យជាគំនរជាលក្ខណៈ** បានដល់ ធម្មជាតិដែលមានការរួមគ្នាជាលក្ខណៈ ព្រោះដូច្នោះ ទើបសង្ខារនោះលោកពោលថា មានការប្រមូលគ្នាជារស ។ ធម៌ គឺសង្ខារក្ខន្ធលោកពោលទុកយ៉ាងនេះ ព្រោះជាធម៌មានចេតនាជាប្រធាន ។ ព្រោះហេតុនោះឯង ទើបលោកអាចារ្យពោលថា សួរថា ធម្មជាតិនោះ គឺអ្វី ? ឆ្លើយថា គឺសង្ខារនោះឯង ដូច្នេះជាដើម ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **រមែងតាក់តែងសង្ខតធម៌** សេចក្ដីថា រមែងទំនុកបម្រុងតាក់តែងដោយប្រការដែលសង្ខតធម៌ជាផលរបស់ខ្លួន ជាធម្មជាតិសម្រេចហើយដោយប្រពៃនោះឯង ។ ពាក្យថា **មានការផ្សាយទៅជាបច្ចុប្បដ្ឋាន** នេះ បានដល់ ធម្មជាតិមានការផ្សាយទៅ ឈ្មោះថា ការផ្សាយទៅ ព្រោះដូច្នោះ ទើបមានសេចក្ដីថា មានការខ្វល់ខ្វាយជាបច្ចុប្បដ្ឋាន ។

សង្ខារទាំងឡាយ ឈ្មោះថា **និយត** ព្រោះកើតឡើងដោយពិតប្រាកដក្នុងចិត្តដួងនោះៗ ដែលកើតឡើង ។ ពាក្យថា **មកហើយដោយរូបរបស់ខ្លួន** គឺមកហើយដោយប្រក្រតីរបស់ខ្លួននៃព្រះបាលីនោះឯង មិនបានធ្វើដល់ក្រោយគ្នាយ៉ាងនេះ ។ សង្ខារទាំងឡាយឈ្មោះថា **អនិយត** ព្រោះមិនពិតប្រាកដ គឺកើតឡើងក្នុងគ្រាខ្លះប៉ុណ្ណោះ ។ ប្រសិនបើសង្ខារដែលជាអនិយតមិនកើតឡើងជាមួយគ្នាក៏ពិត ដូច្នោះ លោកពោលថា សង្ខារ ៣៦ ព្រោះមានការកើតឡើងក្នុងចិត្តនោះជាធម្មតា ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា សូម្បីកាលកើតឡើង ក៏មិនកើតព្រមគ្នា ។

បទថា **ផុសតិ** ជានិទ្ទេសនៃកត្តុ ។ ហេតុក្នុងនិទ្ទេសនៃកត្តុនោះ ខ្ញុំបានពោលទុកហើយខាងដើមនោះឯង ។ ម្យ៉ាងទៀត មានវិគ្គហៈថា **ផុសន្តិ ឯតេនាតិ ផស្សោ**

ប្រែថា សភាវធម៌ឈ្មោះថា ផស្សៈ ព្រោះអត្ថថា ជាហេតុពាល់ត្រូវ ។ មែនពិត សម្បយុត្តធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ រមែងដូចជាត្រូវអារម្មណ៍ នោះពាល់ត្រូវ ដែលមានការពាល់ត្រូវជាលក្ខណៈ ។ ម្យ៉ាងទៀត មានវិគ្គហៈថា **អារម្មណំ ផុសនមត្តំ ផស្សោតិ** ប្រែថា ត្រឹមតែការពាល់ត្រូវនូវអារម្មណ៍ ឈ្មោះថា ផស្សៈ ព្រោះដូច្នោះ រមែងគួរដល់សាធនទាំង ៣ នោះឯង ។ ការពោលកត្តុសាធន និងករណសាធនទុកក្នុងសភាវធម៌ទាំងឡាយ ជាការពោលដោយបរិយាយ ព្រោះលើកអាការនោះឡើងមក ការពោលភាវសាធនតែម្យ៉ាង ជាការពោលដោយត្រង់ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **មានការពាល់ត្រូវជាលក្ខណៈ** ។ បទថា **អយញ្ហិ** ជាដើម ជាបទដែលធ្វើឲ្យយល់ដល់បកិណ្ណកៈ មានលក្ខណៈតាមដែលពោលហើយជាដើម ។ លោកអាចារ្យតាំងពាក្យសួរដែលលាក់ទុកក្នុងចិត្តថា បើធម៌នេះជាចេតសិកសោត ធម៌នោះជាអរូបធម៌ និងសភាវៈដែលមានការពាល់ត្រូវជាលក្ខណៈ និងមានការប៉ះខ្ទប់គ្នាជាដើមបានដូចម្តេច ? ទើបពោលថា **សូម្បីជាអរូបធម៌** ជាដើម ដើម្បីនឹងឆ្លើយពាក្យសួរនោះ ។ បណ្តាពាក្យទាំងនោះ ដោយពាក្យថា **រមែងកើតដោយអាការគឺការពាល់ត្រូវនោះឯង** នេះ លោកអាចារ្យសម្តែងថា ធម៌នោះសូម្បីនឹងជាអរូបធម៌ក៏មានសភាវៈយ៉ាងនេះ ។ ការកើតឡើងដោយអាការពាល់ត្រូវរបស់ផស្សៈនោះ ជាអាការដែលជាក់ច្បាស់ ដូចក្នុងឧទាហរណ៍ជាដើមយ៉ាងនេះថា កាលមនុស្សម្នាក់ឃើញគេស៊ីរបស់ជូរ មានស្វាយទុំជាដើម ក៏ស្រក់ទឹកមាត់មក បុគ្គលអ្នកមានចិត្តទន់ កាលឃើញមនុស្សដទៃកំពុងត្រូវគេបៀតបៀន ក៏ញ័រខ្លួន មនុស្សកំសាកញី កាលឈរនៅលើផ្ទៃដី ឃើញមនុស្សឈរលើចុងរ៉ាវ ក៏ញ័រជង្គង់ បុគ្គលឃើញវត្ថុដែលគួរខ្លាចមានបិសាចជាដើមក៏រឹងជើង ។

បទថា **ឯកទេសេន** ប្រែថា ដោយចំណែកមួយរបស់ខ្លួន ដូចឈើ ២ កំណាត់

ជាដើម ។ បទថា **អនល្លីយមានោបិ** ប្រែថា សូម្បីមិនជាប់ ។ ភាវៈនៃផស្សៈជាធម្មជាតិស្មើគ្នានឹងរូប និងសំឡេង ក៏ជាការមិនជាប់គ្នា តែប៉ះគ្នាបាន មិនមែនជាអារម្មណ៍ ។ រូបមិនជាប់នឹងចក្ខុ សំឡេងមិនជាប់នឹងត្រចៀកនោះឯង លោកហៅដោយពាក្យថា **ត្រូវប៉ះពាល់គ្នាបាន** ជាដើម យ៉ាងណា សូម្បីផស្សៈក៏មានការប៉ះខ្ទប់ដោយអាការពាល់ជាមួយនឹងអារម្មណ៍ដូច្នោះឯង ។ ឈ្មោះថា **ការប៉ះខ្ទប់** បានដល់ ភាវៈដែលផស្សៈរួមចិត្ត និងអារម្មណ៍ចូលគ្នានោះឯង ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **រមែងធ្វើចិត្ត និងអារម្មណ៍ឲ្យប៉ះគ្នា** ។ លោកពោលភាពដែលផស្សៈមានការប៉ះគ្នាជារស ដោយរសដែលមានកិច្ចជាអត្ថ ម្យ៉ាងទៀត ផស្សៈរមែងសម្រេចបានដោយការរួមវត្ថុ និងអារម្មណ៍ ព្រោះដូច្នោះ ផស្សៈដែលមានការប៉ះគ្នាជាសម្បត្តិ ទើបលោកពោលថា មានការប៉ះគ្នាជារស ។ បាតដៃប៉ះបាតដៃ ដូចក្នុងពាក្យថា **ទះបាតដៃទាំងពីរ** ជាដើម គប្បីឃើញថា ជារូបធម៌មួយប្រភេទរបស់ការប៉ះនោះ យ៉ាងណា ចិត្តប៉ះខ្ទប់អារម្មណ៍ក៏គប្បីជ្រាបថា ជាចេតសិកធម៌ម្យ៉ាង ដែលជាប្រភេទមួយនៃការប៉ះខ្ទប់នោះយ៉ាងនោះ ។ លោកអាចារ្យពោលពាក្យជាដើមថា **ពោល គឺការរួមគ្នានៃធម៌ ៣ យ៉ាង** ព្រោះធម៌ មានចក្ខុ រូប និងវិញ្ញាណជាដើម ជាសភាវៈ ដែលនឹងគប្បីកាន់យកបានដោយអំណាចការរួមគ្នា ព្រោះព្រះបាលីថា ការរួមគ្នានៃធម៌ ៣ យ៉ាង ឈ្មោះថា ផស្សៈ ។

ការប្រមូលមកជាហេតុផស្សៈនោះ គឺការសមគួរដល់ផស្សៈនោះ ឈ្មោះថា **តជ្ជាសមន្នាហារោ** ប្រែថា ការប្រមូលដែលកើតអំពីផស្សៈនោះ ។ ភាវៈនៃឥន្ទ្រិយប្រឈមមុខចំពោះផស្សៈនោះ និងការធ្វើអាវជ្ជនៈឲ្យជាអារម្មណ៍ ឈ្មោះថា សេចក្តីដែលអារម្មណ៍ត្រូវព័ទ្ធជុំវិញ គឺត្រូវទំនុកបម្រុងតាក់តែង អធិប្បាយថា ធ្វើឲ្យជាអារម្មណ៍របស់វិញ្ញាណ ។ មេគោដែលមិនមានស្បែកសូម្បីចូលទៅកាន់ស្ថានទីណាៗ រមែង

ទឹងដល់នូវសេចក្ដីទុក្ខក្នុងទីនោះៗ យ៉ាងណា កាលមានផស្សៈ វេទនាក៏រមែងកើតឡើង នោះឯងយ៉ាងនោះ ។ វេទនាមានកូនសរ គឺសេចក្ដីទុក្ខជាដើម ជាសភាវៈ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ផស្សៈគប្បីឃើញដូចជាមេគោមិនមានស្បែក ព្រោះជាទីតាំងនៃវេទនា** ។

បទថា **អភិសន្ទហតិ** ប្រែថា រមែងរួមគ្នា លម្អិតសេចក្ដីថា **បពន្ធតិ** ប្រែថា រមែងត្រូវពាក់ព័ន្ធ **បវត្តេតិ** រមែងធ្វើឲ្យប្រព្រឹត្តទៅ ។ ការចងចិត្ត បានដល់ ការខ្វល់ខ្វាយ ។ **អាយូហនំ** ការប្រមូលមក ស្មើនឹង **ចេតយនំ** ការធ្វើឲ្យគិត **ព្យាបារណំ** ធ្វើឲ្យប្រព្រឹត្តទៅ ។ **សំវិទហនំ** ការចាត់ចែង បានដល់ ការចាត់ការ ។ កាលបើចេតនាមានការប្រមូលគ្នាជារសឲ្យប្រព្រឹត្តទៅ សម្បយុត្តធម៌ទាំងអស់ ក៏រមែងជាសភាវៈខ្វល់ខ្វាយក្នុងកិច្ចរបស់ខ្លួន ព្រោះដូច្នោះ ទើបចេតនានោះលោកពោលថា **មានការធ្វើកិច្ចរបស់ខ្លួន និងកិច្ចរបស់ធម៌ដទៃឲ្យសម្រេច** ។ សិស្សច្បង កាលបបួលឲ្យសិស្សដទៃសូត្រ ស្ងួនឯងក៏រមែងសូត្រទៅផង ។ កាលបើមេជាងផ្ដើមធ្វើការងារ សូម្បីកូនជាងក្រៅអំពីនេះ ក៏រមែងធ្វើដែរ ។ ពាក្យថា **ដោយភាវៈដែលធ្វើឲ្យឧស្សាហ៍** គឺដោយភាវៈដែលធ្វើនូវការអើពើ ។ ពិតហើយ ចេតនានោះ មានការអើពើដោយខ្លួនឯង ក៏ធ្វើសម្បយុត្តធម៌ទាំងឡាយ ឲ្យអើពើតាមផង ។ គប្បីជ្រាបថា ការឧស្សាហ៍ដោយអំណាចការប្រមូលគ្នានោះឯង មិនមែនដោយអំណាចនៃការឧស្សាហ៍ដែលកើតអំពីការព្យាយាមទេ ។

ពាក្យថា **សេចក្ដីក្លាហាន** សេចក្ដីថា ធម៌ដែលជាហេតុឲ្យបុគ្គលមានឈ្មោះថាជាអ្នកក្លាហាន ។ ម្យ៉ាងទៀត ឈ្មោះថា **វីរិយៈ** ដោយអត្ថថា គប្បីឲ្យមានដំណើរទៅគប្បីឲ្យប្រព្រឹត្តទៅតាមវិធី បានដល់ ការឧស្សាហ៍ ឬការផ្ដួចផ្ដើមក្នុងកិច្ចនោះ ឬការប្រឹងប្រែង ។ ការគាំទ្រ បានដល់ ការទ្រទ្រង់ទុក មិនឲ្យសម្បយុត្តធម៌ធ្លាក់ទៅក្នុង

ចំណែកកោសជ្ជៈ គឺការតាមបន្ថែមកម្លាំងឲ្យ ឬថា បីបាច់ទុក ។ ធម៌ដែលជាបដិបក្ខចំពោះការលិចចុះ ឈ្មោះថា ការមិនលិចចុះ មិនមែនមានត្រឹមតែមិនមានការលិចចុះប៉ុណ្ណោះទេ ព្រោះដូច្នោះ ទើបប្រាកដដោយភាវៈដែលមិនលិចចុះ ហេតុនោះ ទើបលោកអាចារ្យពោលថា **មានភាវៈដែលមិនរួញរាជាបច្ចុប្បដ្ឋាន** ។ ពាក្យថា **មានសេចក្ដីសង្វេគជាបទដ្ឋាន** បានដល់ វត្ថុជាទីតាំងនៃការផ្ដើមព្យាយាមក្នុងការធ្វើកុសល មានសង្វេគវត្ថុ ៨ ជាខាងដើមជាបទដ្ឋាន ។ វត្ថុនៃការប្រារព្ធសេចក្ដីព្យាយាមមាន ៨ ប្រកបដោយការពិចារណាដែលសមគួរទាំងនេះគឺលោកពោលទុកយ៉ាងនេះថា ផ្លូវគួរដល់ ១ បានដើរផ្លូវរួចហើយ ១ កម្មគួរធ្វើ ១ បានធ្វើកម្មហើយ ១ អាពាធបន្តិចបន្តួចកើតឡើងហើយ ១ កាលជាពីរោគ ១ ការរួចផុតពីជំងឺតម្កាត់ហើយមិនយូរ កាលត្រាច់ទៅបិណ្ឌបាតក្នុងស្រុក ឬនិគម រមែងមិនបានភោជនដែលសៅហ្មង ឬប្រណីតបរិបូណ៌ ល្មមដល់សេចក្ដីត្រូវការ ១ រមែងបានភោជនដែលសៅហ្មង ឬប្រណីតបរិបូណ៌ល្មមដល់សេចក្ដីត្រូវការ ១ ក្ដី ពិចារណានូវវត្ថុនៃការប្រារព្ធព្យាយាមនោះជាមូលក្ដី ។

ការតាមរក្សាសហជាតធម៌ដែលខ្លួនគប្បីរក្សា ជានាទីរបស់ជីវិត ការតាមរក្សានោះ ជាហេតុរស់នៅរបស់សហជាតធម៌ទាំងនោះ ព្រោះហេតុនោះ ទើបការតាមរក្សានោះ លោកពោលដល់ភាវៈនៃជីវិតនោះជាតួហេតុថា **ជាហេតុរស់នៅ** ។ ម្យ៉ាងទៀត សូម្បីការតាមរក្សារបស់ជីវិតនោះ ដោយអត្ថ គឺការរស់នៅនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ម្យ៉ាងទៀត ជីវិតនោះត្រឹមតែជាការរស់នៅប៉ុណ្ណោះ** ។

បទថា **អាធិយតិ** គឺរមែងតាំងទុក ។ **អវិសារោ** ប្រែថា សេចក្ដីមិនស្ទុះទៅបានដល់ សភាវៈ គឺការមិនស្ទុះទៅរបស់ខ្លួននោះឯង ។ **អវិក្ខេបោ** ប្រែថា ការមិនរាយមាយ បានដល់ សម្បយុត្តធម៌ទាំងឡាយដែលមិនរាយមាយ ។ ធម៌ដែលជាហេតុ

ឲ្យសម្បយុត្តធម៌មិនរាយមាយ ក៏ឈ្មោះថា **អវិក្ខេបោ** ប្រែថា ធម៌ដែលជាហេតុមិនឲ្យរាយមាយ ដូច្នេះ ។ សមាធិណា រមែងចូលទៅតាំងនៅចំពោះដោយអាការ គឺការចូលទៅកាត់សេចក្តីស្ងប់នៃចិត្ត ព្រោះជាបដិបក្ខចំពោះការរាយមាយ មានការមិនចូលទៅធ្វើឲ្យស្ងប់ ជាលក្ខណៈ ព្រោះហេតុនោះ សមាធិនោះ ឈ្មោះថា **ឧបសមបច្ចុប្បដ្ឋានោ** ប្រែថា មានការចូលទៅធ្វើឲ្យស្ងប់ជាបច្ចុប្បដ្ឋាន ។ ពាក្យថា **ដោយវិសេស** សេចក្តីថា ដោយច្រើន ។ មែនពិត សមាធិ សូម្បីវៀរសុខចេញ ក៏រមែងមាន ។ លោកអាចារ្យសម្តែងភាពនៃសមាធិ មានការតាំងនៅដោយការបន្តគ្នា ប្រៀបដូចជាអណ្តាតភ្លើង ។

លោកអាចារ្យរមែងសម្តែងសទ្ធាជាបច្ច័យដល់ធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅដោយកិរិយា គឺការជឿដោយភាពជាធំក្នុងធម៌ទាំងនោះថា **សទ្ទហន្តិ ឯតាយ** ប្រែថា ធម្មជាតិជាហេតុជឿ ។ មែនពិត កាលដែលសទ្ធានោះជាបច្ច័យមានដល់ធម៌ទាំងឡាយយ៉ាងនោះ ដល់ធម៌ទាំងឡាយមាន ក៏រមែងមានក្នុងវោហារថា បុគ្គលរមែងជឿ ។ ការជឿ បានដល់ ការប្រព្រឹត្តទៅក្នុងវត្ថុដែលគួរជឿ ការជឿនោះជាលក្ខណៈរបស់សទ្ធានោះ ហេតុនោះ សទ្ធានោះឈ្មោះថា **សទ្ទហនលក្ខណា** ប្រែថា មានការជឿជាលក្ខណៈ ។ បទថា **ឱកប្បនលក្ខណា** សេចក្តីថា មានការចូលទៅកំណត់ថា នេះជាយ៉ាង នេះជាលក្ខណៈ ។ ការកម្ចាត់មន្ទិលដែលមានភាពស្រអាប់ឬធ្វើសម្បយុត្តធម៌ ឬធ្វើបុគ្គលតែម្យ៉ាងឲ្យថ្លា គឺធ្វើការមិនឲ្យល្អក់កករ ជារសនៃសទ្ធានេះ ហេតុនោះទើបសទ្ធានេះ ឈ្មោះថា **មានការធ្វើសេចក្តីជ្រះថ្លាជារស** ។ **បក្ខន្ទន** ការស្ទុះទៅ គឺការចូលទៅកាន់អារម្មណ៍ដោយអំណាចនៃការបង្អោនចិត្តទៅ ។ **អកាលុសភាវោ** ជា **អកាលុស្សិយំ** សេចក្តីថា ការមិនល្អក់កករ ។

អកុសលដែលផ្ទុយគ្នាក្នុងឋានៈដែលជាទីតាំងនៃសទ្ធា ឈ្មោះថា អស្សទ្ធិយ និងមិច្ឆាធិមុត្តិ ការជឿស៊ប់ដែលប្រព្រឹត្តទៅក្នុងវត្ថុដែលជាទីជ្រះថ្លា ជាសត្រូវចំពោះ

អស្សទ្ធិយ និងមិច្ឆាធិមុត្តិនោះឯង ឈ្មោះថា អធិមុត្តិ មិនមែនជាអធិមោក្ខយេវាបនកចេតសិកទេ ។ ព្រះរតនត្រ័យ កម្ម និងផលនៃកម្ម ឈ្មោះថា វត្ថុដែលគួរជឿ ។ **សប្បុរិសសំសេវន** ការគប់រកសប្បុរស ១ **សទ្ធម្មសវន** ការស្តាប់ព្រះធម៌ ១ **យោនិសោមនសិការ** ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ១ **ធម្មានុធម្មប្បដិបត្តិ** ការបដិបត្តិធម៌សមគួរដល់ធម៌ ១ ឈ្មោះថា **សោតាបត្តិយង្គ** ។ គប្បីជ្រាបថា សទ្ធាប្រៀបដូចជា **ដៃ** ក្នុងការកាន់យកនូវកុសលធម៌ទាំងឡាយ ប្រៀបដូចជា **ទ្រព្យ** ជាទីត្រេកអរនៃចិត្តក្នុងការប្រគល់ឲ្យនូវសម្បត្តិទាំងពួង ប្រៀបដូចជា **ពូជ** ក្នុងការបានផលពីការធ្វើស្រែ គឺអមតៈ ។

លោកអាចារ្យសម្តែងភាវៈនៃសតិជាបច្ច័យដល់ធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅដោយកិរិយា គឺការរឭកបានដោយភាពជាធំក្នុងធម៌ទាំងនោះថា **សរន្តិឯតាយ** ប្រែថា ធម្មជាតិជាហេតុរឭក ។ មែនពិត កាលសតិនោះ ជាបច្ច័យមានដល់ធម៌ទាំងឡាយដូច្នោះ រមែងមានវោហារថា បុគ្គលអ្នកមានសេចក្តីព្រមព្រៀងដោយសតិនោះ រមែងរឭកបាន ។ ការមិនឲ្យអណ្តែតទៅដូចឃ្លោកក្នុងទឹក ហើយទប់អារម្មណ៍ ឲ្យនឹងដូចជាថ្ម ឈ្មោះថា ការរឭក បានដល់ ការធ្វើមិនឲ្យរាយមាយ ឈ្មោះថា ការមិនអណ្តែតអណ្តូង ។

កិច្ចដែលជាសត្រូវចំពោះការរាយមាយ ឈ្មោះថា ការមិនរាយមាយ មិនមែនត្រឹមតែជាការរាយមាយទេ ។ ឈ្មោះថា **មានការគ្រប់គ្រងចិត្តទុកជាបច្ចុប្បដ្ឋាន** ព្រោះមានព្រះបាលីថា **មានចិត្តដែលសតិគ្រប់គ្រងទុក** ។ ធម៌ដែលមកអំពីទីដទៃ បែរមុខទៅកាន់អារម្មណ៍របស់ចិត្ត រមែងមានដោយធម្មជាតិនេះ ហេតុនោះ ធម្មជាតិនេះឈ្មោះថា **មានភាពជាហេតុបែរមុខចំពោះអារម្មណ៍** បានដល់ សតិ ។ ធម៌ទាំងឡាយមានកាយជាដើមនោះឯង ជាទីតាំងនៃសតិ ឈ្មោះថា **សតិប្បដ្ឋាន** **មានកាយជាដើម**

ម្យ៉ាងទៀត សតិដែលកើតមុននោះឯង ជាបទដ្ឋានរបស់សតិដែលកើតខាងក្រោយ ។

បទថា **កាយទុច្ចរិតាទីហិ** ជាតតិយាវិភត្តិចុះក្នុងហេតុ ។ បទថា **ហិរិយតិ** ប្រែថា រមែងស្អប់ដោយអាការខ្ពើមរអើម ។ បទថា **តេហិ យេវ យោគ កាយទុច្ចរិតាទីហិ** នោះឯង ។ បទថា **ឱត្តប្បតិ** ប្រែថា រមែងញាប់ញ័រតក់ស្លុត ។ **ហិរិ** រមែងខ្ពើមបាបធម៌ទាំងឡាយ ដូចឃើញលាមក រមែងខ្ពើមរអើម ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ហិរិមានការខ្ពើមបាប ជាលក្ខណៈ** ។ ឱត្តប្បៈឃើញបាបធម៌ទាំងនោះ ដូចជារបស់ក្តៅ រមែងតក់ស្លុតចំពោះបាបធម៌នោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ឱត្តប្បៈមានការខ្លាចជាលក្ខណៈ** ។ ពាក្យថា **ដោយប្រការដែលបានពោលទុកហើយ** បានដល់ អាការ គឺសេចក្តីខ្មាស និងអាការ គឺការខ្លាចក្រែង ។ ហិរិឈ្មោះថា មានការគោរពខ្លួនជាបទដ្ឋាន ព្រោះមានហេតុខាងក្នុងជាសមុដ្ឋាន និងព្រោះជាអត្តាធិបតី គឺប្រាព្ធខ្លួនឯងជាធំ ។ ឱត្តប្បៈ ឈ្មោះថា **មានការគោរពអ្នកដទៃជាសមុដ្ឋាន** ព្រោះមានហេតុខាងក្រៅជាសមុដ្ឋាន និងលោកាធិបតី ។ ដើម្បីនឹងធ្វើអត្ថនោះឯងឲ្យប្រាកដច្បាស់ ទើបលោកអាចារ្យពោលថា **អត្តានញ្ហិ** ជាដើម ។ សេចក្តីដែលហិរិឱត្តប្បៈមានហេតុខាងក្នុងជាសមុដ្ឋានជាដើម លោកពោលទុកដោយសេចក្តីដែលហិរិឱត្តប្បៈប្រាកដច្បាស់ក្នុងទីនោះៗ មិនមែនពោលទុកព្រោះហិរិឱត្តប្បៈទាំងនេះបែកគ្នានឹងគ្នាក្នុងកាលខ្លះក៏ទេ ។ ពិតហើយ ការខ្មាសដែលមិនមានការខ្លាច ឬសេចក្តីខ្លាចបាបដែលមិនមានការអៀនខ្មាស រមែងមិនមាន ។

គួរលើកយកព្រះសូត្រមកអាងថា ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំង ២ នេះ រមែងរក្សានូវលោក ។ និងគួរលើកយកបទព្រះសូត្រមួយទៀតថា បុគ្គលនោះធ្វើខ្លួនឯងប៉ុណ្ណោះ ឲ្យជាធំ ក្នុងភាពជាអត្តាធិបតី និងថា បុគ្គលធ្វើលោកប៉ុណ្ណោះឲ្យជាធំក្នុងភាពជាលោកាធិបតី មកពោលទុកក្នុងពាក្យថា លោកបាលធម៌នេះ ។

ធម៌ដែលជាសត្រូវចំពោះលោភៈ ឈ្មោះថា អលោភៈ ហេតុនោះ ធម៌ណា ប្រកបនឹងអលោភៈនោះ ឬថា ពួកសត្វអ្នកមានសេចក្ដីដល់ព្រមដោយធម៌ទាំងនោះ ក៏មិនលោភដោយអលោភៈនោះ សូម្បីក្នុងកាលណាក៏ដោយ អលោភៈខ្លួនឯងក៏មិនលោភឡើយ បើពោលដោយសេចក្ដី បានដល់ អាការ គឺសេចក្ដីមិនលោភនោះឯង ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **រមែងមិនលោភ** ជាដើម ។ ពាក្យថា **មានន័យនេះឯង** លោកអាចារ្យសម្ដែងដល់ការប្រកបអ្នកធ្វើទាំង ៣ ដោយបទថា **ទុស្សន្តិ តេន** ជាដើម ។ **អគេធោ** ប្រែថា ការមិនមានតម្រេក បានដល់ ការមិនសង្ឃឹមយ៉ាងក្រៃលែង ។ **អលគ្គភាវោ** ប្រែថា ភាវៈដែលមិនជាប់ ។ **អបរិគ្គហោ** ប្រែថា មិនហួងហែង បានដល់ ការមិនប្រកាន់វត្ថុណាមួយ ថាជារបស់អញ ។ សេចក្ដីប្រាថ្នារបស់អ្នកមិនជាប់មានដល់បុគ្គលនេះ ហេតុនោះ បុគ្គលនេះ ឈ្មោះថា **អនល្លីនភាវោ** ប្រែថា អ្នកមានសេចក្ដីប្រាថ្នារបស់អ្នកមិនជាប់ ។ ភាពជាអ្នកមិនជាប់ជំពាក់ ទើបសមនឹងពាក្យឧបមាហ្នឹងឯង ។

ភាវៈរបស់បុគ្គលអ្នកកាច ឈ្មោះថា **ចណ្ឌិក្កំ** ប្រែថា សេចក្ដីកាច បានដល់ សេចក្ដីក្រោធ ។ ធម៌ដែលជាបដិបក្ខចំពោះសេចក្ដីកាចនោះ ឈ្មោះថា **អចណ្ឌិក្កំ** ប្រែថា សេចក្ដីមិនឃោរឃៅ បានដល់ អព្យាបាទ ។ **អវិរោធោ** ប្រែថា សេចក្ដីមិនប្រកាន់ខុស បានដល់ ការមិនប្រណាំងប្រជែងគ្នា ។ល។ **អនុកូលមិត្តោ** ប្រែថា មិត្តដែលអនុកូល បានដល់ មិត្តដែលស្របតាម ។ បទថា **វិនយរសោ** ស្មើនឹង **វិនយរសោ** ប្រែថា មានការកម្ចាត់ (ការអាឃាត) ជារស ។ **សោមភាវោ** ប្រែថា ភាពត្រជាក់ បានដល់ ផាសុកផ្លូវចិត្ត ដោយអំណាចនៃសេចក្ដីស្រឡាញ់ ។

**យថា សភាវោ** មានវិគ្រោះថា **ធម្មានំ យោ យោ សភាវោ យថា សភាវោ** សភាវៈណាមួយនៃធម៌ទាំងឡាយ ឈ្មោះថា **យថា សភាវោ** ប្រែថា ភាវៈដូចម្ដេច

កាន់យកសេចក្ដីថា តាមសភាវៈ ការចាក់ធ្លុះសភាវៈណាមួយនោះ ឈ្មោះថា **យថាសភាវបដិវេធោ** ប្រែថា ការចាក់ធ្លុះនូវសភាវៈណាមួយ ។ **អក្ខលិតំ** ស្មើនឹង **អវិរជ្ឈិត្វា** ចូលនឹង **បដិវេធោ** ប្រែថា ការចាក់ធ្លុះមិនខុស ឈ្មោះថា **អក្ខលិតបដិវេធោ** ប្រែថា មានការចាក់ធ្លុះមិនខុស ។ ការបំភ្លឺអារម្មណ៍ បានដល់ ការកម្ចាត់នូវភាពងងឹត គឺសម្មោហៈដែលបិទបាំងធម៌នោះ ឈ្មោះថា **វិសយោភាសនំ** ប្រែថា ការបំភ្លឺអារម្មណ៍ ។ ឈ្មោះថា **អសម្មោហបច្ចុប្បដ្ឋានោ** ប្រែថា មានការមិនវង្វេងជាបច្ចុប្បដ្ឋាន ព្រោះអត្ថថា ចូលទៅតាំងទុកចំពោះដោយអាការ គឺសេចក្ដីមិនវង្វេងក្នុងអារម្មណ៍ណាមួយនោះឯង ឬញ៉ាំងការមិនមាននៃសម្មោហៈនោះ ឲ្យចូលទៅតាំងទុកចំពោះ ព្រោះជាបដិបក្ខនឹងសម្មោហៈ ។ ពាក្យថា **ជាមូលនៃកុសលធម៌ទាំងអស់** សេចក្ដីថា ជាទីតាំងអាស្រ័យដោយឲ្យសម្រេចនូវភាវៈនៃកុសលទាំងអស់ គឺកុសលធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ តាំងនៅដោយល្អ មិនមែនញ៉ាំងកុសលធម៌ទាំងនោះឲ្យសម្រេចដោយភាពជាកុសលឡើយ ។បើធម៌ទាំងនោះ ជាកុសល គប្បីជាធម៌ដែលជាប់អាស្រ័យដោយកុសលមូលសោត កាលបើយ៉ាងនោះ កុសលធម៌ទាំងនោះ ជាហេតុបច្ច័យក្នុងរូបដែលមានធម៌ទាក់ទង ដោយកុសលធម៌នោះជាសមុដ្ឋាន ក៏មិនគប្បីមាន ។ មែនហើយ កុសលធម៌ទាំងនោះរមែងមិនញ៉ាំងនូវភាវៈនៃកុសលជាដើមឲ្យសម្រេចដល់កុសលធម៌ទាំងនោះឡើយ និងមិនជាបច្ច័យឡើយ ។ សមដូចព្រះពុទ្ធវចនៈដែលត្រាស់ទុកដូច្នេះថា ហេតុទាំងឡាយ ៦ ជាបច្ច័យ ដោយភាពជាហេតុប្បច្ច័យដល់ធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយហេតុ និងដល់រូបទាំងឡាយ ដែលកើតអំពីធម៌ ដែលសម្បយុត្តជាមួយហេតុនោះ ។ ដូចអព្យាកតធម៌ជាធម៌ដែលទាក់ទងនឹងអព្យាកតមូល ក៏នឹងមិនគប្បីមានដូចភាពជាកុសលធម៌ ដូច្នោះ កាលបើដូច្នេះ អហេតុកចិត្ត មិនគប្បីជាអព្យាកតធម៌បានឡើយ ចំណែកក្នុងអកុសលចិត្តទាំងឡាយ អកុសលចិត្ត ដួងណាមានមូល ១

ប៉ុណ្ណោះ អកុសលនោះមិនគប្បីជាអកុសល គឺត្រូវមានមូលទាំង ២ ទើបជាអកុសល ។ ព្រោះដូច្នោះ ភាវៈនៃធម៌ជាកុសលជាដើម ដែលមិនជាប់អាស្រ័យនឹងមូល តាមពិត ភាពជាកុសលជាដើមជាធម៌ ដែលអាស្រ័យនឹងយោនិសោមនសិការជាដើម ។ តែអ្នកសិក្សាគួរកាន់យកសេចក្តីថា ជាមូលដែលឲ្យសម្រេចដល់កុសលធម៌ទាំងនោះតាំងនៅដោយល្អហើយ ។

ពាក្យថា **ការរម្ងាប់** បានដល់ ការចូលទៅធ្វើឲ្យស្ងប់រម្ងាប់នូវសេចក្តីខ្វល់ខ្វាយ ។ **កាយ**-ស័ព្ទជាស័ព្ទប្រាប់ដល់ការប្រជុំ កាយស័ព្ទនោះឯងទាក់ទងដោយខន្ធ ៣ មានវេទនាខន្ធជាដើម ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ខន្ធ ៣ មានវេទនាជាដើម** ឈ្មោះ ថា កាយក្នុងទីនេះ ។ ព្រោះហេតុនោះឯង ទើបព្រះសាស្តាត្រាស់ថា បណ្តាធម៌ទាំងនោះ សេចក្តីស្ងប់កាយ កើតមានក្នុងសម័យនោះតើដូចម្តេច ? បានដល់ការស្ងប់នៃវេទនាខន្ធក្នុងសម័យនោះឯណា ដូច្នេះជាដើម ។ ពាក្យថា **ការក្រវល់ក្រវាយ** បានដល់ សេចក្តីជ្រួលច្របល់ចិត្ត ពាក្យនេះជាឈ្មោះរបស់កិលេសដែលច្រើនទៅដោយឧទ្ធច្ចៈ ដែលជាបច្ច័យដល់ទោមនស្ស ម្យ៉ាងទៀត ពាក្យនេះជាឈ្មោះរបស់ខន្ធ ៤ ដែលប្រព្រឹត្តទៅយ៉ាងនោះ ។ ភាពត្រជាក់ដែលវៀរចាកការខ្វល់ខ្វាយ គឺសេចក្តីក្តៅក្រហាយ ដោយការសង្កត់សេចក្តីក្រវល់ក្រវាយឲ្យអស់ទៅ ឈ្មោះថា **ការធ្វើឲ្យត្រជាក់ ដោយមិនមានសេចក្តីក្រវល់ក្រវាយ** ។ កិលេសមានឧទ្ធច្ចៈជាប្រធាន ឈ្មោះថា **ឧទ្ធច្ចាទិកិលេសា** កិលេសមានឧទ្ធច្ចៈជាខាងដើម ម្យ៉ាងទៀត លោកអាចារ្យសង្គ្រោះយកកិលេសទាំងអស់ ដោយធ្វើឧទ្ធច្ចៈជាខាងដើមទុក ។ ក្នុងបទដ៏សេស ក៏មានដូចន័យ នេះឯង ។

ពាក្យថា **សភាពធ្ងន់** បានដល់ ភាពខ្ជិលច្រអូស ពាក្យថា សភាពធ្ងន់នេះជាឈ្មោះរបស់កិលេសដែលក្រៃលែងទៅដោយថីនមិទ្ធៈ ឬជាឈ្មោះរបស់ខន្ធទាំង ៤

ដែលប្រព្រឹត្តទៅយ៉ាងនោះ ។ ធម៌ដែលជាបដិបក្ខចំពោះភាពខ្ជិលច្រអូស ឈ្មោះថា ភាពមិនខ្ជិលច្រអូស តែមិនមែនមានសភាពខ្ជិលច្រអូសតែម្យ៉ាងប៉ុណ្ណោះទេ ។ ភាពរឹង ជាឈ្មោះរបស់ការធ្វើឲ្យរឹងត្អឹង ពាក្យថា ការធ្វើឲ្យរឹងត្អឹងនេះ ជាឈ្មោះរបស់កិលេស ដ៏ក្រៃលែង ដោយទិដ្ឋិ និងមានះ ឬជាឈ្មោះរបស់ខន្ធ ៤ ដែលមានសភាពរឹងត្អឹងនោះ ជាប្រធាន ។ ឈ្មោះថា មានការមិនជំទាស់ជាបច្ចុប្បដ្ឋាន ព្រោះសេចក្តីថា រមែង ប្រាកដដោយអាការមិនជំទាស់ក្នុងអារម្មណ៍ណាមួយឡើយ ព្រោះមានការកម្ចាត់ ភាពរឹងត្អឹងចេញទៅ ឬថា ញ៉ាំងការមិនជំទាស់ក្នុងអារម្មណ៍ឲ្យចូលទៅតាំងទុក ចំពោះ សម្បយុត្តធម៌ទាំងឡាយ ។

ការសម្រេចប្រយោជន៍ក្នុងការងារ ឈ្មោះថា **កម្មញ្ញំ** ប្រែថា ការសម្រេច ក្នុងការងារ ការមិនសម្រេចប្រយោជន៍ក្នុងការងារ ឈ្មោះថា **អកម្មញ្ញំ** ប្រែថា ការ មិនសម្រេចប្រយោជន៍ក្នុងការងារ ភាវៈនៃការមិនសម្រេចប្រយោជន៍ក្នុងការងារនោះ ឈ្មោះថា **អកម្មញ្ញភាវោ** បានដល់ ការមិនសមគួរក្នុងការបំពេញបុណ្យ មានទាន និងសីលជាដើម ។ ធម៌ គឺសង្កិលេស មានកាមច្ឆន្ទៈជាដើម ឬអកុសលក្ខន្ធទាំង ៤ មានធម៌ គឺសង្កិលេស មានកាមច្ឆន្ទៈជាដើមនោះជាប្រធាន ។ មានការកាន់យក អារម្មណ៍ដោយអាការដែលដល់ព្រមដោយភាវៈ ដែលសម្រេចប្រយោជន៍នៃការងារ នោះឯង ឈ្មោះថា **ការដល់ព្រមនៃការធ្វើអារម្មណ៍** ។ នីវរណៈ មានកាមច្ឆន្ទៈ ជាដើម និងធម៌ គឺសង្កិលេស ដែលតាំងនៅដោយភាពតែមួយជាមួយនីវរណៈ មាន កាមច្ឆន្ទៈជាដើមនោះ ដែលបានពោលហើយ ឈ្មោះថា **កិលេស មាននីវរណៈ ដ៏សេសជាដើម** ។ ឈ្មោះថា **នាំមកនូវសេចក្តីជ្រះថ្លាក្នុងវត្ថុជាទីតាំងនៃសេចក្តីជ្រះថ្លា** ព្រោះជាហេតុនៃការប្រព្រឹត្តទៅបានដោយងាយ ព្រោះសង្កត់នូវធម៌ ដែលត្រូវគ្នា ចេញទៅ ។ ពាក្យថា **ដូចសភាពបរិសុទ្ធនៃមាស** សេចក្តីថា ការអស់មន្ទិលនៃមាស

គឺដែលប្រាសចាកមន្ទិលពណ៌ខ្មៅ គួរដល់ការប្រកបជាគ្រឿងអលង្ការផ្សេងៗ បានយ៉ាងណា សុប្បីកម្មញ្ញតាទាំង ២ នេះ គឺគួរដល់ការប្រកបក្នុងការធ្វើប្រយោជន៍បាន ព្រោះប្រាសចាកសង្កិលេសក៏យ៉ាងនោះដែរ ។ ការឈឺនៃកាយ និងចិត្ត បានដល់កិលេស មានអស្សទ្ធិយជាដើម និងបាបធម៌ទាំងឡាយដែលតាំងនៅជាមួយនឹងកិលេសមានអស្សទ្ធិយជាដើមនោះ ។ ធម៌ដែលបដិបក្ខចំពោះការឈឺ ឈ្មោះថា **អគេលញ្ញំ** ប្រែថាការមិនឈឺ សភាពមិនឈឺនោះជាលក្ខណៈរបស់បាគុញ្ញតា ហេតុនោះបាគុញ្ញតាទាំងនេះ ឈ្មោះថា **អគេលញ្ញភាវលក្ខណា** ប្រែថា មានភាវៈនៃការមិនឈឺជាលក្ខណៈ ។ ស័ព្ទថា **និរាទីនវបច្ចុប្បដ្ឋានា** កាត់បទថា **និរាទីនវ + បច្ចុប្បដ្ឋាន និរាទីនវា** មានវិគ្គហៈ ២ យ៉ាងគឺ **យថា វុត្ត គេលញ្ញ និម្មទ្ទុនេនេវ នត្ថិ ឯតាសំ អាទីនវោ ទោសោតិ និរាទីនវា** ប្រែថា **អាទីនវ** ដែលប្រែថា ទោសមិនមានដល់បាគុញ្ញតានេះ ព្រោះកម្ចាត់នូវការឈឺតាមដែលពោលហើយនោះឯង ព្រោះហេតុនោះ បាគុញ្ញតាទាំងនោះ ឈ្មោះថា **និរាទីនវា** ប្រែថា មិនមានទោស ម្យ៉ាងទៀត មានវិគ្គហៈថា **ន ឯតា អាទីនំ កបណំ វត្តិ បវត្តន្តីតិ និរាទីនវា** ប្រែថា បាគុញ្ញតាទាំងនេះមិនជា **អាទីន** ប្រែថា មិនជាកំព្រាប្រព្រឹត្តទៅ ហេតុនោះ បាគុញ្ញតាទាំងនេះ ទើបឈ្មោះថា **និរាទីនវា** ប្រែថា មិននិរាសប្រព្រឹត្តទៅ ស័ព្ទថា **និរាទីនវបច្ចុប្បដ្ឋានា** មានវិគ្គហៈថា **តេនាការេន បច្ចុប្បតិដ្ឋាន្តីតិ និរាទីនវបច្ចុប្បដ្ឋានា** ប្រែថា បាគុញ្ញតាពួកណា រមែងប្រាកដដោយអាការ គឺមិនមានទោស ឬមិនមានការនិរាសប្រព្រឹត្តទៅនោះ ហេតុនោះ បាគុញ្ញតានោះ ឈ្មោះថា **និរាទីនវបច្ចុប្បដ្ឋានា** ប្រែថា ប្រាកដដោយអាការដែលមិនមានទោស ឬមិនជាកំព្រាប្រព្រឹត្តទៅ ន័យម្យ៉ាងទៀត មានវិគ្គហៈថា **តំ សម្បយុត្តេសុ បច្ចុប្បដ្ឋបេន្តីតិ និរាទីនវបច្ចុប្បដ្ឋានា** ប្រែថា បាគុញ្ញតាពួកណា រមែងញុំាងអាការដែលមិនមានទោស ឬមិននិរាសឲ្យប្រព្រឹត្តទៅនោះ ឲ្យចូលទៅតាំងទុកចំពោះក្នុងសម្បយុត្តធម៌ទាំងឡាយ

ព្រោះហេតុនោះ បាគុញ្ញតាពួកនោះ ឈ្មោះថា **និរាទីនវបច្ចុបដ្ឋានា** ប្រែថា ញ៉ាំងអាការដែលមិនមានទោស ឬមិនទនិរាស ប្រព្រឹត្តទៅឲ្យចូលទៅតាំងទុកចំពោះ ។

**ឧជុកតា** មានសេចក្ដីត្រង់កាយ និងចិត្តជាលក្ខណៈ ព្រោះជាធម្មជាតិគប្បីកំណត់បានថា សេចក្ដីត្រង់អាស្រ័យដោយកាយ និងចិត្ត ។មានការសង្កត់នូវភាពកោងនៃកាយ និងចិត្តឲ្យអស់ទៅជារស ព្រោះសង្កត់សង្កិននូវការវៀច ពោល គឺសភាពកោងនៃយាមនង្គ័ល ចម្រៀកព្រះចន្ទ និងភាពកោងនៃមូត្រគោនៃកាយ និងចិត្ត ។ព្រោះហេតុនោះឯង ឧជុកតាទាំងនេះ រមែងប្រាកដដោយភាពមិនកោង សូម្បីដោយប្រការទាំងពួង ហេតុនោះ ទើបឈ្មោះថា **អជិម្ហតាបច្ចុបដ្ឋានា** ប្រែថា ប្រាកដដោយភាវៈដែលមិនកោង ន័យម្យ៉ាងទៀត រមែងមានការញ៉ាំងភាពមិនកោងឲ្យចូលទៅតាំងទុកចំពោះដល់សម្បយុត្តធម៌ទាំងឡាយ ហេតុនោះ ទើបឈ្មោះថា **អជិម្ហតាបច្ចុបដ្ឋានា** ប្រែថា ញ៉ាំងភាពមិនកោងឲ្យចូលទៅតាំងទុកចំពោះ ។ អកុសលក្ខន្ធ ដែលប្រព្រឹត្តទៅដោយអាការមិនកោងនោះ តាមដែលលោកពោលទុកយ៉ាងនេះថា **មាយា** មានការបិទបាំងទោស ដែលមានជាលក្ខណៈ **សាថេយ្យ** មានការលើកសរសើរគុណ ដែលមិនមានជាលក្ខណៈ សង្កិលេសធម៌ដែលតាំងនៅជាមួយអកុសលក្ខន្ធនោះ ឈ្មោះថា **ឧបក្កិលេស មានមាយា និងសាថេយ្យជាដើម** ។ ក្នុងអធិការនេះ ចិត្តនោះឯងជាធម្មជាតិស្ងប់ ស្រាល ទន់ភ្លន់ សម្រេចប្រយោជន៍ដល់ការងារស្ទាត់ជំនាញ និងជាធម្មជាតិត្រង់ដោយធម៌ទាំងឡាយ មានចិត្តបស្សទ្ធិជាដើម ។ម្យ៉ាងទៀត សូម្បីរូបកាយក៏រមែងជាធម្មជាតិ រម្ងាប់ដោយកាយបស្សទ្ធិជាដើម ។ ព្រោះហេតុនោះឯង ទើបក្នុងអធិការនេះ ព្រះមានព្រះភាគត្រាស់ធម៌ទាំងឡាយថា មាន ២ យ៉ាងមិនទូទៅឡើយ ។

សេចក្ដីពេញចិត្ត ឈ្មោះថា **ឆន្ទៈ** បានដល់ ធម្មជាតិមានសេចក្ដីត្រូវការដោយអារម្មណ៍ ។ ម្យ៉ាងទៀត សូម្បីតណ្ហាក៏លោកហៅថា ឆន្ទៈដូចគ្នា ដូចពាក្យថា

**ឆន្ទោកាមោ** ឆន្ទៈ គឺតណ្ហា ឈ្មោះថា កាមជាដើម សូម្បីវិរិយៈ លោកក៏ហៅដូចក្នុងពាក្យថា **ឆន្ទំ ជនេតិ វាយមតិ** ( រមែងញុំាងឆន្ទៈ គឺសេចក្តីព្យាយាមឲ្យកើតឡើងហើយព្យាយាម ) ជាដើម ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ពាក្យថា ឆន្ទៈនេះជាឈ្មោះរបស់ការប្រាថ្នានឹងធ្វើ** ដើម្បីនឹងហាមពាក្យថា ឆន្ទៈចេញពីអត្ថថា តណ្ហានិងវិរិយៈនោះ ។ សេចក្តីប្រាថ្នានឹងធ្វើ ហៅថា សេចក្តីត្រូវការនឹងធ្វើ ។ ឈ្មោះថាសេចក្តីប្រាថ្នានឹងធ្វើ រមែងមានដោយសេចក្តីត្រូវការនឹងទាញយកអារម្មណ៍ ព្រោះចេតសិកធម៌ជាធម្មជាតិប្រព្រឹត្តទៅ មួយអន្លើដោយអារម្មណ៍ ហេតុដូច្នោះ ឆន្ទៈដែលមានសេចក្តីប្រាថ្នានឹងធ្វើឲ្យជាអារម្មណ៍ជាលក្ខណៈ ទើបលោកពោលថា មានសេចក្តីប្រាថ្នានឹងធ្វើជាលក្ខណៈ ។ ព្រោះហេតុនោះឯង ទើបលោកអាចារ្យពោលថា **មានការស្វែងរកអារម្មណ៍ជារស** និង **មានសេចក្តីត្រូវការដោយអារម្មណ៍ជាបច្ចុប្បដ្ឋាន** ។ ឆន្ទៈដែលមានការស្វែងអារម្មណ៍របស់ខ្លួនជារសនេះដោយចំណែកណា រមែងមានដល់សម្បយុត្តធម៌ទាំងឡាយនោះឯង ដោយចំណែកនោះ ព្រោះហេតុនោះ សម្បយុត្តធម៌នោះជាឆន្ទៈ មានអារម្មណ៍តែមួយ ។ ព្រោះហេតុនោះឯង ទើបលោកអាចារ្យពោលថា ឆន្ទៈនេះក្នុងការទទួលអារម្មណ៍ គប្បីឃើញថា ដូចចិត្តឈរលាដៃចេញទៅ ។ ឆន្ទៈនេះកើតឡើងក្នុងកុសលទាំងឡាយ ហៅថា កុសលឆន្ទៈ ព្រោះមានយោនិសោម-នសិការជាសមុដ្ឋាន ។

ការសម្រេចចិត្ត គប្បីជ្រាបដោយអំណាចនៃការដាក់ចិត្តក្នុងអារម្មណ៍នោះឯង មិនមែនដោយអំណាចនៃសេចក្តីជ្រះថ្លាទេ ។ មែនពិត សេចក្តីវិនិច្ឆ័យក្នុងអារម្មណ៍ដោយអាការយ៉ាងណាមួយ ឈ្មោះថា **ការសម្រេចចិត្ត** ព្រោះបុគ្គលមិនបានចូលចិត្តក៏មិនមានការធ្វើបាណាតិបាតជាដើម ឬក្នុងការឲ្យទានជាដើម ចំណែកសទ្ធាជាបសា-ទាធិមោក្ខ គឺការកាត់សម្រេចចិត្តចំពោះសេចក្តីជ្រះថ្លាក្នុងវត្ថុ ដែលជាទីតាំងនៃសេចក្តី

ជ្រះថ្លា ព្រោះដូច្នោះ សទ្ធា និងអធិមោក្ខទាំងនេះ ទើបមានសេចក្ដីផ្សេងគ្នាដូច្នេះ ។ ចំណែកវោដ្ឋព្វនៈប្រព្រឹត្តទៅ ដោយអាការវិនិច្ឆ័យក្នុងសេចក្ដីតាមដែលបានពិចារណាហើយ រមែងជាបច្ច័យដល់ការធ្វើយ៉ាងនោះរបស់ធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅខាងមុខ ។ សួរថា បើដូច្នេះ វោដ្ឋព្វនៈនឹងមាននៅក្នុងចិត្តុប្បាទដែលសម្បយុត្តដោយវិចិកិច្ឆាដូចម្ដេច ? ឆ្លើយថា គប្បីជ្រាបថា សូម្បីចិត្តុប្បាទដែលសម្បយុត្តដោយវិចិកិច្ឆាទាំងនោះជាបច្ច័យដល់អាការដែលស្ទាក់ស្ទើរដោយចំណែកមួយនោះឯង ។

ការធ្វើដែលជាបដិបក្ខចំពោះការស្ទាក់ស្ទើរទៅខាងនោះ ទៅខាងនេះ ដូចក្មេងតូច គឺការមិនដាក់ចិត្តថា នឹងធ្វើ នឹងមិនធ្វើ ឈ្មោះថា ការមិនស្ទាក់ស្ទើរ អធិមោក្ខនេះមានការដាក់ចិត្តក្នុងចិត្តុប្បាទពួកណាជាលក្ខណៈ ធម៌ដែលជាអារម្មណ៍របស់ចិត្តុប្បាទនោះឯង ឈ្មោះថា **សន្និដ្ឋេយ្យ ធម្មោ** ប្រែថា ធម៌ដែលនឹងគប្បីកាត់សម្រេចចិត្ត ។

លោកអាចារ្យពោលថា **ការ** ស័ព្ទជាការសាធនថា **កិរិយា ការោ** ការធ្វើ ឈ្មោះថា **ការ** ។ ពាក្យថា **មនសិការ** បានដល់ ធ្វើអារម្មណ៍ទុកក្នុងចិត្ត ។ ចេតសិកធម៌ណារមែងធ្វើចិត្តទុកក្នុងអារម្មណ៍ ព្រោះចងចិត្តនោះទុកក្នុងអារម្មណ៍ ព្រោះហេតុនោះ ទើបចេតសិកធម៌នោះ ធ្វើអារម្មណ៍ទុកក្នុងចិត្ត ដូច្នេះ ។ ពាក្យថា **អំពីចិត្តដើម** បានដល់ភវង្គចិត្ត ។ ពាក្យថា **ចិត្តដែលផ្សេងគ្នា** គឺរមែងធ្វើចិត្តឲ្យស្ទុះទៅកាន់វិថី ព្រោះហេតុនោះ ទើបលោកអាចារ្យសម្ដែងមនសិការដែលចាត់ចែងក្នុងវិថីចិត្ត និងជវនចិត្តឲ្យជាមនសិការស្មើគ្នា ។

អារម្មណបដិបាទកមនសិការ រមែងញ៉ាំងសម្បយុត្តធម៌ទាំងឡាយឲ្យស្ទុះទៅចំពោះមុខនៃអារម្មណ៍ ព្រោះដូច្នោះ ទើបមនសិការលោកពោលថា មានការញ៉ាំងសម្បយុត្តធម៌ឲ្យស្ទុះទៅជាលក្ខណៈ ។ សតិ និងមនសិការនេះ មានសេចក្ដីផ្សេងគ្នាដូច្នេះ គឺសតិមានការបែរមុខចំពោះអារម្មណ៍ ដោយអំណាចការមិនវង្វេង ជាបច្-

ប្បដ្ឋាន ចំណែកមនសិការ មានភាពជាធម្មជាតិបែរមុខចំពោះអារម្មណ៍ដោយអំណាចការប្រកបទុកជាបច្ចុប្បដ្ឋាន ។ ការពោលអារម្មណបដិបាទកមនសិការ ជាធម៌ជាប់អាស្រ័យនឹងសង្ខារ រមែងបំភ្លឺនូវអត្ថត្រឹមតែមនសិការក្រៅអំពីនេះជាធម៌អាស្រ័យនឹងខន្ធដទៃទៀតអំពីសង្ខារក្ខន្ធនោះ ព្រោះដូច្នោះ លោកអាចារ្យមានបំណងនឹងសម្ដែងថា ជាធម៌ជាប់អាស្រ័យនឹងសង្ខារក្ខន្ធនោះ ដែលបំភ្លឺអត្ថ ដូច្នោះ ឲ្យឈោងចុះក្នុងវិញ្ញាណក្ខន្ធ ទើបពោលថា **វិថីបដិបាទកមនសិការ** ដូច្នេះជាដើម ។

ពាក្យថា **ក្នុងធម៌ទាំងនោះ** សេចក្ដីថា តត្រមជ្ឈត្តតាកើតឡើងដោយខ្លួនឯង ក្នុងធម៌ពួកណា ក្នុងធម៌ គឺចិត្ត និងចេតសិកដែលសម្បយុត្តជាមួយខ្លួនទាំងនោះ ។ សូម្បីជាធម្មជាតិដែលទទួលអារម្មណ៍មិនបាន ធម្មជាតិនេះ ក៏លោកហៅថា **តត្រមជ្ឈត្តតា** ព្រោះភាវៈដែលព្រងើយក្នុងធម៌ទាំងនោះដែលប្រព្រឹត្តទៅស្មើ ។ ពាក្យថា **មានការនាំទៅស្មើជាលក្ខណៈ** គឺបានដល់ការប្រព្រឹត្តទៅតាម កិច្ចរបស់ខ្លួននាំទៅស្មើ គឺមិនមែនមិនស្មើជាលក្ខណៈ ។ តត្រមជ្ឈត្តតានេះសូម្បីប្រព្រឹត្តទៅដោយភាវៈដែលព្រងើយ រមែងញុំាងសម្បយុត្តធម៌ទាំងឡាយឲ្យប្រព្រឹត្តទៅក្នុងកិច្ច តាមមុខនាទីរបស់ខ្លួន ដូចព្រះរាជា សូម្បីប្រថាប់នៅស្ងៀម ក៏រមែងញុំាងការកាត់ក្ដីឲ្យប្រព្រឹត្តទៅតាំងនៅក្នុងភាពយុត្តិធម៌ មិនប្រមាទក្នុងរាជកិច្ចរបស់ព្រះអង្គ ។ តត្រមជ្ឈត្តតាមានការប្រព្រឹត្តទៅមិនតក់ស្លុត និងមិនរាយមាយជាបច្ច័យ ឈ្មោះថា **មានការហាមនូវការខ្វះ និងការលើសជារស** ពាក្យនេះលោកពោលទុកដោយអំណាចនៃកិច្ច ។ សួរថា បើយ៉ាងនោះ តត្រមជ្ឈត្តតានឹង គប្បីជាអធិបតីនៃសហជាតធម៌បានដោយរបៀបណា ? ឆ្លើយថា សូម្បីសេចក្ដីនោះ ក៏ជាកិច្ចរបស់តត្រមជ្ឈត្តតានោះឯង ។ សេចក្ដីថា តត្រមជ្ឈត្តតាជាអធិបតីរបស់សហជាតធម៌ទាំងឡាយក៏ប្រព្រឹត្តទៅយ៉ាងនោះឯង សូម្បីតត្រមជ្ឈត្តតានោះ ក៏ប្រព្រឹត្តទៅដូច្នោះ ព្រោះហេតុនោះ ទើបពាក្យនេះមិនខុស ។ អធិប្បាយថា

សេចក្ដីប្រព្រឹត្តទៅទាក់ទងនឹងការធ្លាក់ទៅក្នុងចំណែកម្ខាងៗ យ៉ាងនេះថា នេះជាកិច្ចអាក្រក់ចូរលើកទុក នេះជាកិច្ចដែលល្អក្រៃលែង ឈ្មោះថា ការធ្លាក់ចុះក្នុងចំណែកម្ខាងៗ តត្រមជ្ឈត្តតា រមែងដូចជាការចូលទៅកាត់ចេញនូវការធ្លាក់ទៅក្នុងចំណែកម្ខាងៗ នោះ ដូច្នោះ ។ ដោយពាក្យថា **រមែងប្រាថ្នាទុកក្នុងអនិយតសង្ខារ** នេះ លោកសម្ដែងថា អាចារ្យពួកខ្លះ រមែងប្រាថ្នាដោយភាពជាចេតសិកដទៃ ។ អទោសៈនោះឯងឈ្មោះថា មេត្តា ។ ពិតយ៉ាងនោះ អទោសៈនោះឯងលោកសម្ដែងទុកដោយន័យថា មេត្រីភាព ការរាប់អាន ដូច្នេះជាដើម ។ ពាក្យថា **ឧបេក្ខា** សេចក្ដីថា លោកអាចារ្យរមែងកំណត់ឧបេក្ខាណាទុកជាមួយនឹងមេត្តា ឧបេក្ខានោះ គឺតត្រមជ្ឈត្តុបេក្ខានោះឯង ។

ពាក្យថា **វត្ថុនៃទុច្ចរិត មានកាយទុច្ចរិតជាដើម** បានដល់ បាណរបស់អ្នកដទៃ ទ្រព្យរបស់អ្នកដទៃ ស្រីរបស់អ្នកដទៃជាដើម ។ ការមិនញាំញី បានដល់ ភាវៈដែលជាបដិបក្ខចំពោះការញាំញី ។ គប្បីឃើញថា ការពោលកិរិយា គឺការបែរមុខចាកទុច្ចរិតមានកាយទុច្ចរិតជាដើមនោះឯង ដោយមានការអាងដល់កិរិយា គឺការបែរមុខចាកវត្ថុនៃទុច្ចរិត មានកាយទុច្ចរិតជាដើម ។ ព្រោះថា វិរតិមិនមានការធ្វើវត្ថុនៃទុច្ចរិតជាបច្ចុប្បន្នឡើយ ដោយពិតនោះ វិរតិ និងហិរិឱត្តប្បៈនេះ មានសេចក្ដីផ្សេងគ្នា ដូច្នេះទុច្ចរិតមានការរួញរាដោយអំណាចសោរច្ចធម៌របស់វិរតិ ការមិនធ្វើ មានសេចក្ដីតក់ស្លុតដោយអំណាចការខ្មាសបាបជាដើមនៃហិរិ និងឱត្តប្បៈ ។

លោកពោលសំដៅដល់ធម៌ គឺសង្ខារក្ខន្ធថា សង្ខារ ។ មែនពិត ធម៌ គឺសង្ខារក្ខន្ធទាំងនោះ លោកមានបំណងយកក្នុងទីនេះ កាលកាន់យកសេចក្ដីដោយប្រការដទៃក៏ប្រពៃ ដែលនឹងពោលថា សង្ខារ ៣៨ ។ ចិត្តយ៉ាងណា សូម្បីធម៌ដែលសម្បយុត្តនឹងកិច្ចនោះក៏យ៉ាងនោះ ក្នុងកាមាវចរកុសលចិត្តដួងទី ២ ទើបជាសង្ខារដូចគ្នា ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ក្នុងកាមាវចរកុសលចិត្តដួងទី ២ នេះផ្សេងគ្នា**

ត្រឹមតែជាសសង្ខារប៉ុណ្ណោះ ។ ពាក្យថា **អវសេសា យោគ បឋមេ វុត្តធម្មា** ប្រែថា ធម៌ដែលពោលហើយក្នុងកាមាវចរកុសលចិត្តដួងទី ១ ដ៏សេស ។

ក្នុងពាក្យថា ធម៌ដ៏សេសដល់នូវការសម្បយោគចូលជាមួយកាមាវចរកុសលចិត្តដួងទី ៥ នេះ មានពាក្យសួរថា ករុណា និងមុទិតា នឹងមាននៅក្នុងចិត្តដែលប្រកបព្រមដោយឧបេក្ខាបានដូចម្ដេច ? ឆ្លើយថា បាន ព្រោះជាបុព្វភាគ ។ លោកអាចារ្យទាំងឡាយពោលថា ព្រោះករុណា និងមុទិតាដែលដល់អប្បនាប៉ុណ្ណោះ ទើបមិនជាឧបេក្ខាសហគតៈ តែក្នុងចិត្តដទៃអំពីកាមាវចរកុសលចិត្តដួងទី ៥ នោះ រមែងជាឧបេក្ខាសហគតៈក៏មាន ។

បុគ្គលអ្នកមានកាយកម្មបរិសុទ្ធល្អហើយជាដើម នឹងកើតរូបាវចរកុសល និងអរូបាវចរកុសលបានដោយអំណាចតាំងចិត្តមាំ មិនមែនដោយអំណាចការជម្រះកាយកម្មជាដើមឲ្យបរិសុទ្ធ ទាំងមិនមែនដោយអំណាចការកាត់ផ្ដាច់បានដោយដាច់ខាត និងការរម្ងាប់នូវទុច្ចរិត និងមិច្ឆាជីវៈទេ ព្រោះដូច្នោះ ក្នុងចិត្តប្បាទជាមហគ្គតៈ ទើបមិនមានវិរតិ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **វៀរវិរតិទាំង ៣** ។ បទថា **តតោ យោគ រូបាវចរ បឋមេ វុត្តចេតសិកតោ** ប្រែថា ចាកចេតសិកដែលពោលក្នុងរូបាវចរកុសលចិត្តដួងទី ១ នោះ ។ បទថា **តេយេវ យោគ រូបាវចរបញ្ចមេ វុត្តចេតសិកា** នោះឯង ប្រែថា ចេតសិកដែលពោលទុកក្នុងរូបាវចរចិត្តដួងទី ៥ នោះឯង ។លោកអាចារ្យពោលថា **ក្នុងរូបាវចរកុសលចិត្តទាំង ៤ ដួងនេះ ផ្សេងគ្នាត្រឹមតែអរូបាវចរប៉ុណ្ណោះ** ដូច្នេះ ដើម្បីនឹងចៀសវាងនូវពាក្យសួរថា បើយ៉ាងដូច្នោះ ផ្សេងគ្នាដូចម្ដេចអំពីរូបាវចរៈ ។

បទថា **បឋមជ្ឈានិកេ** ប្រែថា មានបឋមជ្ឈាន ។ បទថា **មគ្គវិញ្ញាណេ** សេចក្ដីថា ក្នុងមគ្គចិត្តទាំង ៤ ដួង ភ្ជាប់សេចក្ដីបាលីថា **វុត្តន យេនេវ វេទិតព្វ** ប្រែថា គប្បីជ្រាប

តាមន័យដែលបានពោលទុកនោះឯង ។ ដោយ **អាទិ-**ស័ព្ទក្នុង ពាក្យថា **ទុតិយជ្ឈា-និកាទិភេទេ មគ្គវិញ្ញាណេ** ប្រែថា ក្នុងមគ្គចិត្តផ្សេងដែលមានទុតិយមគ្គជ្ឈានជាដើម លោកអាចារ្យសង្គ្រោះយកមគ្គចិត្ត មានតតិយជ្ឈាន ចតុត្ថជ្ឈាន និងបញ្ចមជ្ឈានចូលផង ។ ក្នុងសេចក្ដីជំទាស់ថា ដែលលោកនិយាយថា **តាមន័យដែលលោកពោលទុកហើយ** ដូច្នេះ នឹងមានប្រយោជន៍អ្វីដោយភាពមិនផ្សេងគ្នា លោកអាចារ្យកាលសម្ដែងសេចក្ដីផ្សេងគ្នានោះ ទើបពោលពាក្យថា **ករុណាមុទិតានំ** ជាដើម ។ ក្នុងពាក្យនោះថា មគ្គចិត្តមានព្រះនិព្វានជាអារម្មណ៍ ហើយករុណាមុទិតា មានសត្វជាអារម្មណ៍ ព្រោះហេតុនោះ ទើបករុណាមុទិតានោះ មិនមានក្នុងមគ្គចិត្តនោះ ។ ក្នុងមគ្គធម៌ទាំងឡាយក៏នឹងមានការវៀរចាកសម្មាសង្កប្បៈក្នុងគ្រាខ្លះ ដោយការកំណត់ធម៌ដែលជាបាទជាដើម តែមិនមានការវៀរចាកវិរតិ ព្រោះអរិយមគ្គនឹងកើតឡើងបានក៏ដោយអំណាចការកាត់ទុច្ចរិត មានកាយទុច្ចរិតជាដើមបាននោះឯង ព្រោះដូច្នោះ **ទើបជាវិរតិដែលជានិយត** ។

ឈ្មោះថា **អហិរិកោ** ដោយអត្ថថា មិនខ្មើម គឺមិនរង្កៀស ជាវិសេសនៈរបស់ **បុគ្គលោ** ប្រែថា បុគ្គលអ្នកមិនមានខ្មាស ជាវិសេសនៈរបស់ **ចិត្តំ** ប្រែថា ចិត្តដែលមិនខ្មើមក៏បាន ជាវិសេសនៈរបស់ **តំ សម្បយុត្តធម្មសមុទាយោ** ប្រែថា ប្រជុំនៃធម៌ដែលប្រកបនឹងចិត្តនោះ ដោយការមិនខ្មាសក៏បាន ។ កាលគួរនឹងពោលថា **អហិរិក្កំ** លោកពោលថា **អហិរិកំ** ព្រោះលុប **ក** អក្ខរៈចេញមួយតួ ។ លោកពោលធម៌ដែលជាបដិបក្ខនឹងឱត្តប្បៈថា**ន ឱត្តប្បំ** ប្រែថា មិនមែនឱត្តប្បៈ ។ **អជិគុច្ឆនំ** ប្រែថា មិនខ្មើមរអើម ។ **អលជ្ជា** ប្រែថា មិនរង្កៀស ។ បទថា **តេហេវ យោគ កាយទុច្ចរិតាទីហិ** នោះឯង ប្រែថា អំពីកាយទុច្ចរិតជាដើមទាំងនោះ នោះឯង ។ **អសារជ្ជំ** ប្រែថា មិនខ្លាច ។ **អនុត្តាសោ** ប្រែថា ការមិនតក់ស្លុត ។ ពាក្យថា **ដោយអំណាចនៃពាក្យជា**

បដិបក្ខដែលបានពោលទុកហើយ សេចក្ដីថា គប្បីជ្រាបសេចក្ដីពិស្ដារដោយអំណាចពាក្យបដិបក្ខដែលបានពោលទុកហើយយ៉ាងនេះថា **អហិរិក** មានការធ្វើបាបដោយអាការដែលមិនមានខ្មាសអៀនជារស **អនោត្តប្ប:** មានការធ្វើបាប ដោយអាការដែលមិនខ្លាចជារស **អហិរិក:** និង **អនោត្តប្ប:** មានការមិនថយអំពីបាប ដោយប្រការដែលបានពោលហើយនោះឯងជាបច្ចុប្បដ្ឋាន មានការមិនគោរពខ្លួនឯង និងអ្នកដទៃជាបទដ្ឋាន ។ សេចក្ដីមិនអៀនខ្មាសចំពោះភាពមិនស្អាត គឺកិលេស រមែងមានដោយអហិរិក: ដូចជ្រូកស្រុកមិនខ្ពើមវត្ថុដែលមិនស្អាត សេចក្ដីមិនតក់ស្លុតចំពោះបាប រមែងមានបានដោយអនោត្តប្ប: ដូចមមាចមិនខ្លាចភ្លើង ។

ពាក្យណាដែលគួរពោលក្នុងបទថា **លុព្ភន្តិ តេន** ជាដើម ពាក្យនោះគប្បីជ្រាបតាមលំអាននៃពាក្យមានន័យតាមដែលលោកពោលទុកមកហើយខាងដើម ។ពាក្យថា **រមែងលោភ** សេចក្ដីថា រមែងចង់បានក្រៃលែង ។ ពាក្យថា **រមែងវង្វេង** សេចក្ដីថា រមែងមិនដឹង ។ ការទាញអារម្មណ៍ បានដល់ ការមិនបណ្ដោយ អារម្មណ៍ដែលប្រកាន់ដោយអំណាចការប្រកាន់មាំ គឺតណ្ហាថា **នេះរបស់អញ** មិនមែនត្រឹមតែការធ្វើនូវអារម្មណ៍ទេ ។ ការប្រកាន់មាំ បានដល់ ការជាប់ជំពាក់ដោយការប្រឈមមុខចំពោះគ្នា ។ ការមិនលះបង់ បានដល់ ការមិនលះ ឬបានដល់សភាវៈ ដែលគប្បីដោះបានដោយលំបាក ។ បទថា **អស្សាទទស្សនំ** ប្រែថា សេចក្ដីឃើញថា គួរត្រេកអរ ។ សមដូចព្រះបាលីដែលបានត្រាស់ទុកថា **កាលភិក្ខុពិចារណាឃើញនូវសេចក្ដីត្រេកអរ ( ក្នុងឧបាទានិយធម៌ទាំងឡាយហើយ ) តណ្ហា រមែងចម្រើនឡើង** ។

ការមិនឃើញទៅតាមសេចក្ដីពិតនូវសភាវធម៌ ឈ្មោះថា ភាពងងឹតនៃចិត្ត ។ ការមិនដឹង បានដល់ ធម៌ដែលជាបដិបក្ខចំពោះសេចក្ដីដឹង ។ ការមិនអាចចាក់ធ្លុះបានឈ្មោះថា ការមិនចាក់ធ្លុះ ។ មោហ:ប្រព្រឹត្តទៅដោយប្រការដែលញាណនឹងចាក់ធ្លុះ

សភាវៈនៃអារម្មណ៍មិនបាន ទើបឈ្មោះថា មិនបាំងសភាវៈនៃអារម្មណ៍ ។ មោហៈមានសេចក្តីបដិបត្តិមិនប្រពៃជាបច្ចុប្បដ្ឋាន ដោយអត្ថថា ញុំាងការបដិបត្តិមិនប្រពៃឲ្យចូលទៅតាំងទុកចំពោះ ឬដោយអត្ថថា រមែងកាន់យកបានដោយបដិបក្ខចំពោះការប្រតិបត្តិប្រពៃ ។ មោហៈកើតឡើងដល់បុគ្គលណា ការធ្វើភាពងងឹតក៏មានដល់បុគ្គលនោះ ទើបឈ្មោះថា ងងឹត មោហៈរមែងចូលទៅតាំងទុក ចំពោះដោយប្រការនោះ ហេតុនោះ ទើបឈ្មោះថា **មានភាពងងឹតជាបច្ចុប្បដ្ឋាន** ។

បទថា **មិច្ឆា** បានដល់ វិបរិតនៃសភាវធម៌ អធិប្បាយថា អំពីការទៀងជាដើម ។ ការប្រកាន់មាំដោយភាពមិនឆ្លាត បានដល់ ការប្រកាន់មាំដោយមិនត្រូវឧបាយ គឺការប្រកាន់មាំក្នុងផ្លូវខុស ។ ការប្រកាន់យកក្រៅពីសភាវធម៌ ឈ្មោះថា ការប្រកាន់ខុស ។ ការប្រកាន់មាំថា លោកទៀង នេះឯងជាពាក្យពិត ពាក្យដទៃ ជាមោឃជាដើម ដោយអំណាចការប្រកាន់ខុស ឈ្មោះថា ការប្រកាន់មាំខុស ។

ចិត្តជាធម្មជាតិរាយមាយ ដោយអំណាចនៃធម៌ណា ឬធម៌ដែលប្រកបនឹងចិត្តទាំងឡាយនោះ ធម៌នោះ ឈ្មោះថា ឧទ្ធច្ចៈ ។ លោកអាចារ្យពោលសេចក្តីមិនស្ងប់ស្ងៀមនិងការមិនជ្រះថ្លាថាជាការមិនចូលទៅរកសេចក្តីស្ងប់ ។ ពាក្យថា **មានការមិនឈប់ស្ងៀមជារស** បានដល់ ការកម្រើកញាប់ញ័រជាកិច្ច ។ ពាក្យថា **ការវិលទៅ** បានដល់អាការវិលទៅជុំវិញ ។ ពីរបទថា **ចេតសោ អវូបសមេ** ជាសត្តមីវិភត្តចុះក្នុងអត្ថថាប្រកបដែលនឹងគប្បីឲ្យសម្រេច ម្យ៉ាងទៀត ជាអារម្មណ៍ដែលជាបច្ច័យមិនឲ្យចូលទៅស្ងប់ ដែលលោកពោលថា **អវូបសមោ** ប្រែថា ការមិនចូលទៅស្ងប់ ។ ពោលបានទៀតថា **នឹងជាសេចក្តីអាក្រក់គ្រោតគ្រាតដោយអំណាចនៃភាពជាអកុសល** ព្រោះអកុសលធម៌ទាំងឡាយ ជាសភាវៈអាក្រក់គ្រោតគ្រាតដោយចំណែកមួយ ។

ក្នុងអកុសលចិត្តដួងទី ២ នេះ ថីនមិទ្ធៈជាអនិយតចេតសិក មិនមែនមានៈ

ជាដើមទេ ព្រោះហេតុនោះ ការដែលថីនមិទ្ធៈជាអនិយតចេតសិកក្នុងអកុសលចិត្តជួនទី ២ នេះ ទើបជាសេចក្ដីផ្សេងគ្នាអំពីអកុសលចិត្តជួនទី ១ ។

ភាវៈដែលរួញរាដោយភាពជាអ្នកអស់ភាពឧស្សាហ៍ និងលិចចុះ ឈ្មោះថា ថីនៈ ព្រោះប្រកបដោយភាពរួញរានោះ ភាវៈនៃចិត្តដែលរួញរានោះ ទើបឈ្មោះថា **ថីនតា** ។ ភាពជាអ្នកមិនអង់អាចក្នុងការងារ ដោយអំណាចនៃការកម្ចាត់ចេញនូវភាពជាអ្នកអង់អាច ឈ្មោះថា មិទ្ធៈ ។ ព្រោះហេតុដែលសម្បយុត្តដោយមិទ្ធៈនេះជាធម៌ត្រូវកម្ចាត់ហើយ គឺមានភាពអង់អាចដែលកម្ចាត់ចេញហើយ ព្រោះជាធម្មជាតិមិនសម្រេចប្រយោជន៍ក្នុងការងារនោះៗ ឯង ដូច្នោះ ទើបលោកពោលថា **ការងោកងុយ ឈ្មោះថា មិទ្ធៈ** ។ ពាក្យថា **មានការឧស្សាហ៍ជាលក្ខណៈ** គឺមានភាពជាបដិបក្ខចំពោះឧស្សាហ៍ជាលក្ខណៈ ។ ការបន្ថយទៅ គឺការបោះបោលទៅនូវសេចក្ដីព្យាយាម ឈ្មោះថា ការបន្ថយនូវសេចក្ដីព្យាយាម ។ ថីនៈណា រមែងចូលទៅតាំងទុកចំពោះដោយអាការនៃការលិចចុះនូវសម្បយុត្តធម៌ទាំងឡាយ ឬថា ញ៉ាំងសេចក្ដីលិចចុះនៃសម្បយុត្តធម៌ទាំងនោះឲ្យចូលទៅតាំងទុកចំពោះ ហេតុនោះ ថីនៈនោះ ឈ្មោះថា មានការលិចចុះជាបច្ចុប្បដ្ឋាន ។ ក្នុងពាក្យថា **មានការមិនសម្រេចប្រយោជន៍ជាលក្ខណៈ** នេះ សូម្បីថីនៈក៏មានសភាវៈមិនសម្រេចប្រយោជន៍ក្នុងការងារដូចគ្នា ដោយពិត ថីនៈនោះសម្រាប់ចិត្ត មិទ្ធៈសម្រាប់ខន្ធ ៣ មានវេទនាខន្ធជាដើម ព្រោះដូច្នោះ ក្នុងថីនៈ និងមិទ្ធៈទាំង ២ នេះ ទើបមានសេចក្ដីប្លែកគ្នាដូចពោលមកនេះ ។ សមដូចនិទ្ទេសនៃថីនៈ និងមិទ្ធៈទាំង ២ នេះ ដែលប្រព្រឹត្តទៅក្នុងព្រះបាលី ដោយន័យមានជាអាទិ៍ថា បណ្ដាកិលេសវត្ថុទាំងនោះ ថីនៈតើដូចម្ដេច ? គឺការមិនអាច បានដល់ ការមិនសម្រេចប្រយោជន៍ក្នុងការងារនៃចិត្ត ។ ក្នុងធម៌ ២ យ៉ាងនោះ មិទ្ធៈតើដូចម្ដេច ? គឺការមិនអាច ការមិនសម្រេចប្រយោជន៍ ក្នុងការងារនៃកាយ ។ **ឱទហនំ** ប្រែថា បិទ បានដល់ បិទទ្វារ

នៃវិញ្ញាណ ។ ការរួញចូល គឺអាការទាញចូល បានដល់ ការរួញរាក្នុងការទទួលអារម្មណ៍ ។ ការរួញរានៃចិត្តនោះឯង រមែងមាន ព្រោះថីនៈ ចំណែកការរួញរានៃរូបកាយក៏ដូចគ្នានឹងខន្ធ ៣ មានវេទនាខន្ធជាដើម រមែងមានដោយមិទ្ធៈ ព្រោះដូច្នោះ មិទ្ធៈរមែងញុំាងការងងុយឲ្យប្រាកដ ទើបឈ្មោះថា មានការងងុយជាបច្ចុប្បដ្ឋាន ពាក្យថា **មិនត្រេកអរ** បានដល់ ការមិនពេញចិត្តក្នុងសេនាសនៈដែលស្ងាត់ និងក្នុងកុសលធម៌ដ៏ក្រៃលែង ។ ពាក្យថា **ការប្រអូសនៃកាយ** បានដល់ ការប្រព្រឹត្តទៅនៃសង្កិលេសដែលជាហេតុនៃសេចក្ដីអាក្រក់តាមផ្លូវកាយពោលគឺការខ្ជិលប្រអូសនៃកាយ ។ដោយ **អាទិ**-ស័ព្ទថា **អរតិ វិជម្ភិកាទីសុ** លោកកាន់យកស័ព្ទថា **តន្ទិ** ដែលប្រព្រឹត្តទៅ ក្នុងអត្ថថា ការដេកលក់ ការប្រមាទ ការមិនមានស្មារតីជាដើម ។ ស័ព្ទថា **អរតិវិជម្ភិកាទីសុ** នេះ ជាសត្តមីវិភត្តិ ប្រើក្នុងការប្រកបសេចក្ដីដែលនឹងគប្បីឲ្យសម្រេចប្រយោជន៍ ។

**អវសេសា យោគ សោឡស** ប្រែថា សង្ខារ ១៦ ដ៏សេស ។ ក្នុងអកុសលចិត្តដួងទី ៣ នេះ មានៈជាចេតសិកដែលជាអនិយត រួមនឹងមានៈនោះ ជាសង្ខារ ១៧ នោះឯង ។ មែនពិត ក្នុងគម្ពីរបដ្ឋានព្រះមានព្រះភាគទ្រង់ត្រាស់ថា **សំយោជនំ ធម្មំ បដិច្ច សំយោជនោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា** ប្រែថា សំយោជនធម៌អាស្រ័យសំយោជនធម៌កើតឡើង ព្រោះហេតុប្បច្ច័យ ព្រះសាស្ដាត្រាស់ថា **កាមរាគសំយោជនំ បដិច្ច មានសំយោជនំ អវិជ្ជាសំយោជនំ** ប្រែថា មានៈសំយោជនៈក្ដី អវិជ្ជាសំយោជនៈក្ដី អាស្រ័យនូវកាមរាគសំយោជនៈ ត្រាស់ថា **កាមរាគសំយោជនំ បដិច្ច អវិជ្ជាសំយោជនំ** ប្រែថា អវិជ្ជាសំយោជនៈអាស្រ័យនូវកាមរាគសំយោជនៈ និងត្រាស់ថា **មានសំយោជនំ បដិច្ច ភវរាគសំយោជនំ អវិជ្ជាសំយោជនំ** ប្រែថា ភវរាគសំយោជនៈក្ដី អវិជ្ជាសំយោជនៈក្ដី អាស្រ័យនូវមានៈសំយោជនៈ ត្រាស់យ៉ាងនេះទុកក្នុងធម៌ ១០ យ៉ាង ការប្រកបរាគសំយោជនៈរបស់ព្រះសកទាគាមីជាមួយសំយោជនៈមាន ១០ គឺ

សំយោជនៈ ៣ បានដល់ មានះ វិចិកិច្ឆា និងភវរាគៈប្រកបជាមួយកាមរាគៈ ៤ ដង និងប្រកបជាមួយបដិឃៈ ៣ ដង ហើយប្រកាសថា មានះ ជាអនិយតចេតសិក ដោយពាក្យប្រកបដែលមកហើយយ៉ាងនេះថា អវិជ្ជាសំយោជនៈអាស្រ័យភវរាគសំយោជនៈ ។ បើមានះគប្បីជាអនិយតចេតសិកសោត ការប្រព្រឹត្តទៅដោយវៀរចាកមានះ ក៏មិនគប្បីមានដល់កាមរាគៈ សម្រាប់ភវរាគៈក៏ដូចគ្នា ។ ហេតុដូច្នេះ បានជាក្នុងគម្ពីរបដ្ឋានមិនគប្បីមានពាក្យប្រកបនឹងកាមរាគៈ ៤ ដង មានត្រឹមតែពាក្យ ៣ ដងប៉ុណ្ណោះ ។ ការប្រកបដែលមានភវរាគៈជាមូល ក៏មិនគប្បីមាន ។ សំយោជនៈ គប្បីមានពាក្យប្រកបនឹងសំយោជនៈ ៨ ន័យយ៉ាងនេះ មិនមែន ១០ ន័យ ។ តែលោកបានសម្តែងទុក ១០ ន័យនោះឯង ដូច្នេះ ។ ការទឹងបង្អោនទៅក្នុងចំណែកខ្ពស់ដោយអំណាចការប្រកាន់ខ្លួនថា អញល្អជាងគេជាដើម ឈ្មោះថា **ឧណ្ណតិ** ប្រែថា ក្រៃលែង ឈ្មោះថា **មានការលើកខ្លួនជារស** ដោយអំណាចនៃភាពក្រៃលែងនោះឯង ។ មិនមែនដោយអំណាចការឧស្សាហ៍យ៉ាងក្រៃលែងក្នុងការញុំាងកិច្ចនោះៗ ឲ្យសម្រេចដូចសេចក្តីព្យាយាមទេ ។ សូម្បីការប្រកាន់ខ្លួនធ្វើឲ្យទាបចុះ របស់អវមានះក៏គប្បីឃើញថា ដោយអំណាចលើកខ្លួនដូចគ្នា ។ ទង់ដែលហូតឡើងទុកយ៉ាងខ្ពស់ ហៅថា **កេតុ** តែក្នុងទីនេះ ឈ្មោះថា **កេតុ** ព្រោះអត្ថថា ដូចជាទង់ បានដល់ ភាពដែលប្រកាន់ថា ជាអ្នកធំលើសលប់បំផុតជាដើម ។ ចិត្ត ឈ្មោះថា **កេតុកម្យំ** ព្រោះអត្ថថា ត្រូវការនូវទង់ ពោល គឺដូចជាទង់នោះ សេចក្តីត្រូវការនូវទង់ ដោយអំណាចរបស់ធម្មជាតិណា ធម្មជាតិនោះឈ្មោះថា **កេតុកម្យតា** ប្រែថា សេចក្តីត្រូវការឲ្យដូចជាទង់ ។ ព្រោះការប្រព្រឹត្តទៅដូច្នេះថា ខ្លួនអញ ទើបមានះមានការប្រព្រឹត្តទៅស្រដៀងនឹងទិដ្ឋិ ព្រោះដូច្នោះ ទើបមានះនោះមិនកើតក្នុងចិត្តុប្បាទតែមួយជាមួយនឹងទិដ្ឋិ និងអាស្រ័យការស្រឡាញ់ខ្លួន ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **មានលោភៈដែលមិនប្រកបជាមួយទិដ្ឋិ** ជា

បទដ្ឋាន ដោយ ច-ស័ព្ទថា **ឯត្ថាបិ ច** លោកទាញយកបីនៈ និងមិទ្ធៈ មកផង ។

ពាក្យថា **ការប្រទូស្ត** បានដល់ រមែងព្យាបាទ ។ **សភាពកាច** បានដល់ សេចក្តីក្រោធ ។ បទថា **វិសប្បនរសោ** ប្រែថា មានការហុយចេញប្របូកប្របល់ជារស ដោយអំណាចអាការនៃការប្រព្រឹត្តទៅរបស់ខ្លួន និងដោយអំណាចការញ៉ាំងរូបដែលរសាប់រសល់ទៅរហូតដល់ខុសប្រក្រតី និងមិនគួរប្រាថ្នាឲ្យតាំងឡើង ។ ឈ្មោះថា មានការដុតរោលទីអាស្រ័យរបស់ខ្លួនជារស ព្រោះធ្វើឲ្យដល់ភាពនៃកាយដែលត្រូវដុតរោល ។ ការប្រទូស្តលោកអាចារ្យសម្តែងថា ជាវត្ថុដែលមិនគួរកាន់យកដោយប្រការទាំងពួងថា ទោសៈ **គប្បីឃើញដូចទឹកមូត្រស្អុយ** ដែលលាយដោយថ្នាំពិស ព្រោះទោសៈនោះមិនគួរប្រាថ្នាក្នុងពេលដែលបរិភោគចូលទៅ ក្នុងពេលឲ្យផលដល់ខ្លួន និងអ្នកដទៃ ។

លោកអាចារ្យកាលនឹងសម្តែងថា ការធ្វើសេចក្តីប្រណែនក្នុងសម្បត្តិរបស់អ្នកដទៃណា ការធ្វើសេចក្តីប្រណែននោះ ឈ្មោះថា ឥស្សា ទើបពោលថា **សេចក្តីប្រណែន** ឈ្មោះថា **ឥស្សា** ដូច្នេះ ។ **ឧស្សូយនំ** ប្រែថា សេចក្តីទ្រាំមិនបាន ។ បទថា **តត្ថេវ យោគ បរសម្បត្តីសុ** ប្រែថា ក្នុងសម្បត្តិរបស់អ្នកដទៃទាំងនោះឯង ។ កិច្ចនៃឥស្សាជាបដិបក្ខចំពោះសេចក្តីត្រេកអរផង មិនមែនត្រឹមតែសេចក្តីមិនមាននូវការត្រេកអរផង ព្រោះហេតុនោះ ទើបលោកពោលថា “**អនភិរតិរសា**” ប្រែថា មានសេចក្តីមិនត្រេកអរជារស ។ លោកអាចារ្យកាន់យក **មច្ឆរិ**-ស័ព្ទដែលប្រព្រឹត្តទៅថា **មច្ឆរិ** ដូច្នេះ ដោយការប្រកប **មច្ឆរ**-ស័ព្ទ ទើបពោលថា **មច្ឆរភាវោ មច្ឆរិយំ** សេចក្តីកំណាញ់ឈ្មោះថា មច្ឆរិយៈ ។ ដោយនិរុត្តិន័យ បោរាណាចារ្យទាំងឡាយពោលថា **មា ឥទំ អច្ឆរិយំ អញ្ញេសំ ហោតុ មយ្ហំយេវ ហោតូតិ មច្ឆរិយន្តិ** ប្រែថា សេចក្តីអស្ចារ្យនេះ ចូរកុំមានដល់មនុស្សពួកដទៃ ចូរមានដល់យើងប៉ុណ្ណោះ ព្រោះហេតុនោះ ទើបឈ្មោះថា មច្ឆរិយៈ ។ មច្ឆរិយៈនោះ តាំងនៅគ្របដណ្តប់បកិណ្ណកៈ មានលក្ខណៈជាដើម

ដែលកំពុងពោលដល់ ។ បទថា **សង្កោចនបច្ចុប្បដ្ឋានំ** បានដល់ មានការបែរមុខជាបច្ចុប្បដ្ឋាន គឺមានការបែរមុខដោយធ្វើសម្បត្តិរបស់ខ្លួន មិនឲ្យជាសារណៈដល់អ្នកដទៃជាបច្ចុប្បដ្ឋាន ។ ទំនងដែលមានអាការ រួបរឹត ឈ្មោះថា **កដុកញ្ចុកតា** ប្រែថា ភាពជាអាវក្រោះដ៏ស្វិត ។ សម្បត្តិរបស់ខ្លួន បានដល់ ទីលំនៅជាដើម ។

ក្នុងបទថា **កុកតំ** នេះ សូម្បីការមិនធ្វើ ឈ្មោះថា **កុកតំ** ដូចគ្នា ប្រែថា អំពើដែលបណ្ឌិតស្អប់ខ្ពើម ។ កាលបើដូច្នេះ រមែងមានអ្នកពោលថា វត្តុណាអញមិនបានធ្វើ វត្តុនោះឈ្មោះថា កុកតំ ប្រែថា អំពើដែលបណ្ឌិតស្អប់ខ្ពើម ។ សមដូចពាក្យដែលលោកអាចារ្យពោលថា មានការសោកស្តាយចំពោះអំពើដែលបានធ្វើ និងមិនបានធ្វើជារស កាលបើដូច្នេះ ទុច្ចរិតដែលធ្វើហើយ និងសុចរិតដែលមិនទាន់បានធ្វើ ឈ្មោះថា កុកតំ ប្រែថា អំពើដែលបណ្ឌិតស្អប់ខ្ពើម ចិត្តដែលប្រព្រឹត្តទៅដោយអំណាចប្រារព្ធដល់ទុច្ចរិតដែលធ្វើហើយ និងសុចរិតដែលនៅមិនទាន់បានធ្វើនោះ មានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយ គប្បីឃើញថា លោកកាន់យកពាក្យថា **កុកតំ** ក្នុងទីនេះ ព្រោះប្រព្រឹត្តទៅរួមនឹងចិត្តនោះ ទើបពោលថា **ភាវៈរបស់កុកតៈនោះ** ឈ្មោះថា **កុក្កុច្ចៈ** ។ ការតាមដុតចិត្ត គឺធ្វើឲ្យលំបាកចិត្តក្នុងកាលខាងក្រោយ ឈ្មោះថា **បច្ឆានុតាបោ** ប្រែថា ការធ្វើចិត្តឲ្យក្តៅក្រហាយក្នុងកាលជាខាងក្រោយ ។ ការអាឡោះអាល័យទៅខុសប្រក្រតី ដោយអំណាចនៃការស្តាយក្រោយដល់ទុច្ចរិត និងសុចរិតដែលផ្សេងគ្នាដោយអាការដែលធ្វើហើយ និងមិនទាន់បានធ្វើ តាមដែលប្រព្រឹត្តទៅហើយ ឈ្មោះថា **វិប្បដិសារោ** ប្រែថា សេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយ ។ កុក្កុច្ចៈនេះ បណ្ឌិតគប្បីឃើញថា **ដូចភាពជាទាសៈ** ព្រោះជាហេតុនៃភាពជាអ្នកមានការអាស្រ័យនឹងអ្នកដទៃ ។ តួយ៉ាងដូចជាកាលភាពជាទាសៈមាន ទាសៈក៏រមែងអាស្រ័យមនុស្សដទៃ យ៉ាងណា កាលកុក្កុច្ចៈមាន មនុស្សក៏រមែងមានការប្រកបនឹង

កុក្កុច្ចៈនោះ ។ ព្រោះបុគ្គលអ្នកមានការប្រកបដោយកុក្កុច្ចៈនោះ រមែងមិនអាចដើម្បីនឹងញ៉ាំងកុសលធម៌ឲ្យប្រព្រឹត្តទៅ ដោយធម្មតារបស់ខ្លួន ។ ប្រការមួយទៀត ព្រោះភាវៈដែលអាស្រ័យសេចក្តីសៅហ្មងចិត្ត ដល់អកុសលធម៌ដែលបានធ្វើទុក និងកុសលធម៌ដែលមិនទាន់បានធ្វើ បុគ្គលអ្នកប្រកបដោយកុក្កុច្ចៈនោះ ទើបមានអ្នកដែលប្រកបដោយកុក្កុច្ចៈ ទាក់ទងនឹងការសៅហ្មងចិត្តទាំង ២ នោះ ព្រោះហេតុនោះ កុក្កុច្ចៈនោះទើបដូចជាទាសៈ ។

គប្បីនាំ ច-ស័ព្ទមកបញ្ជាក់ថា **ថីនមិទ្ធសម្ភវោ ច** ប្រែថា បណ្តាចេតសិកទាំងឡាយ មានឥស្សាជាដើមដែលជាអនិយត មានថីនមិទ្ធៈនោះឯងផង ។

ពាក្យថា **ជាអាការត្រឹមតែជាការឈប់នៃបវត្តិចិត្ត** គឺជាអាការត្រឹមតែស្ថិតនៅមួយខណៈ ។ មែនពិត ឈ្មោះថា ជាអាការត្រឹមតែការឈប់នៃបវត្តិចិត្ត ដោយត្រឹមតែជាបច្ច័យនៃចិត្តប្រព្រឹត្តទៅ ព្រោះការមិនឈប់ ដោយការមិនតក់ស្លុតនៃចិត្ត ដែលមិនអាចនឹងជាបច្ច័យដល់ការមិនជាប់តគ្នា ដូចនឹងការឈប់នៃចិត្ត ដែលលោកពោលទុកយ៉ាងនេះថា ប្រៀបដូចជាការឈប់នៃអណ្តាតប្រទីបក្នុងទីមិនមានខ្យល់ ដូច្នោះ។ ព្រោះហេតុនោះ ទើបលោកពោលថា បានដល់ សមាធិយ៉ាងខ្សោយ ។ ពាក្យថា ការប្រាកដក្នុងចិត្តប្រាសទៅ លោកអាចារ្យសម្តែងត្រឹមតែជាអត្ថរបស់វិចិកិច្ឆានោះថា ការពិតប្រាកដក្នុងចិត្តលោកពោលទុក ព្រោះជារឿងធ្វើបានដោយលំបាក មិនមែនព្រោះវិចិកិច្ឆាទេ មានការពិតប្រាកដក្នុងចិត្ត សូម្បីដោយប្រការទាំងពួង ។ ភាវៈ ឈ្មោះថាសង្ស័យដោយអត្ថថា ប្រព្រឹត្តទៅដោយអំណាចការសោប់សល់ ដោយន័យមានជាអាទិ៍ថា ជាយ៉ាងនេះឬ ? ឬថា មិនមែនដូច្នេះ ។ បទថា **កម្បនរសា** បានដល់ មានការញាប់ញ័រជារស គឺមានការញាប់ញ័រនៃចិត្តក្នុងអារម្មណ៍ផ្សេងៗ ជាកិច្ច ។ មែនហើយ ឧទ្ធច្ចៈតាំងនៅក្នុងការវិលទៅក្នុងអាការដែលខ្លួនកាន់យកនោះឯង ព្រោះ

ដូច្នោះ ទើបប្រព្រឹត្តទៅ ដោយអំណាចការបម្រះនទៀលនៅក្នុងអារម្មណ៍មួយនោះឯង ។ ចំណែកក្នុងវិចិកិច្ឆាសូម្បីកើតឡើងក្នុងអារម្មណ៍មួយប៉ុណ្ណោះ ក្នុងអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើម សូម្បីពិតដូច្នោះ ក៏ការសម្លឹងអាការដែលគួរនឹងកាន់យកដទៃថាយ៉ាងនេះឬ ? ឬថា មិនមែនបែបនេះឬ ? ឬថា បែបដទៃទេដឹង ? ព្រោះដូច្នោះ ទើបមានការញាប់ញ័រទៅក្នុងអារម្មណ៍ផ្សេងៗ ។ វិចិកិច្ឆាណារមែងញុំាងការមិនកាត់សម្រេចចិត្តសេចក្តីសង្ស័យឲ្យចូលទៅតាំងទុកចំពោះ ហេតុនោះ ទើបពោលថា **អនិច្ឆយបច្ចុប្បដ្ឋានា** ប្រែថា មានការមិនអាចសម្រេចបានជាបច្ចុប្បដ្ឋាន ។ វិចិកិច្ឆាណា រមែងចូលទៅតាំងទុកចំពោះដោយអាការដែលកាន់យកនូវសភាវៈផ្សេងៗ ក្នុងអារម្មណ៍ដែលមានច្រើនយ៉ាង ព្រោះហេតុនោះ វិចិកិច្ឆានោះ ទើបឈ្មោះថា **អនេកំ សគ្គាហបច្ចុប្បដ្ឋានា** ប្រែថា មានការកាន់យកច្រើនយ៉ាងជាបច្ចុប្បដ្ឋាន ។

ពាក្យថា **ព្រោះមានសត្វជាអារម្មណ៍** គឺមានសត្តបញ្ញត្តិជាអារម្មណ៍ ។ លោកអាចារ្យសំដៅដល់ពាក្យថា វិបាកសង្ខារសូម្បីមានបញ្ញត្តិជាអារម្មណ៍ ក៏មានមិនមែនឬ ទើបពោលថា **កាមាវចរវិបាកសង្ខារ មានកាមាវចរធម៌ជាអារម្មណ៍ដោយចំណែកមួយ** ។ ក្នុងពាក្យថា **សូម្បីវិរតិក៏មិនមាននៅក្នុងវិបាកសង្ខារ** នេះ លោកអាចារ្យត្រិះរិះក្នុងចិត្តថា សូម្បីវិរតិក៏មានក្នុងវិបាកសង្ខារពួកខ្លះមែនឬ ទើបពោលថា **សមដូចដែលលោកពោលទុកថា សិក្ខាបទទាំង ៥ ជាកុសលតែម្យ៉ាង** ដោយពាក្យនោះលោកអាចារ្យសម្តែងថា វិរតិមិនមាននៅក្នុងវិបាកសង្ខារដែលជាលោកិយឡើយ ។

បទថា **តេសំ យោគ រូបាវចរាទិវិបាកវិញ្ញាណំ** ប្រែថា នៃវិបាកចិត្ត មានរូបាវចរជាដើមនោះ ។ បទថា **តេសំ** នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថក្ខាប់ធម៌ដែលគប្បីកើត និងធម៌ដែលត្លួនធ្វើឲ្យកើត ។

បទថា **តេ** ប្រែថា សង្ខារដែលជាអហេតុកកិរិយាទាំងនោះ ។ ក្នុងពាក្យទាំង

នោះ លោកអាចារ្យកាលនឹងសម្តែងសេចក្តីនេះថា អហេតុកកិរិយាសង្ខារ ដែលស្មើនឹងសង្ខារដែលសម្បយុត្តដោយកុសលវិបាកមនោធាតុ ក៏ជាសង្ខារដែលសម្បយុត្តដោយអហេតុកកិរិយាមនោធាតុ ដែលស្មើនឹងសង្ខារដែលសម្បយុត្តដោយសន្តីរណៈ ដែលសហគតៈដោយសោមនស្ស ក៏ជាសង្ខារ ដែលសម្បយុត្តដោយហសិតុប្បាទចិត្ត ស្មើគ្នានឹងសង្ខារដែលសម្បយុត្តដោយសន្តីរណៈ ដែលសហគតៈដោយឧបេក្ខា ក៏ជាសង្ខារដែលសម្បយុត្តដោយវោដ្ឋព្វនៈ ទើបពោលថា **ស្មើដោយសង្ខារដែលសម្បយុត្តដោយកុសលវិបាកមនោធាតុ និងអហេតុកមនោវិញ្ញាណធាតុទាំង ២** បន្ទាប់នោះបំណងនឹងសម្តែងសេចក្តីដែលមាន ទើបពោលពាក្យថា **ចំណែកក្នុងមនោវិញ្ញាណធាតុទាំង ២ ។ សមាធិ រមែងជាសមាធិដែលមានកម្លាំង ព្រោះមានវិរិយៈរួមជាមួយផងដែរ** អធិប្បាយថា ពលៈមានវិរិយៈជាទីបំផុត ។

ព្រោះកិច្ច គឺការវៀររបស់ព្រះអរហន្តសម្រេចហើយ ដោយសមុច្ឆេទវិរតិនោះឯង ទើបវិរតិក្នុងកិរិយាចិត្តមិនមាន ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា វៀរវិរតិ ។ សង្ខារដែលជាសហេតុកកិរិយាខាងកាមាវចរៈ មានសេចក្តីផ្សេងអំពីកាមាវចរកុសលដែលវិរតិធ្វើហើយ ចំណែកក្នុងមហគ្គតចិត្ត មិនមានសេចក្តីផ្សេងគ្នាដូច្នោះទេ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **សូម្បីដោយប្រការទាំងពួង** អធិប្បាយថា សូម្បីដោយប្រការទាំងពួង គឺដោយធម៌ ដោយអារម្មណ៍ ដោយអាការប្រព្រឹត្តទៅ ។

ពណ៌នាកថាមុខយ៉ាងពិស្តារក្នុងសង្ខារក្ខន្ធ ចប់តែប៉ុណ្ណោះ ។

# វិសុទ្ធិមគ្គ

## ខន្ធវិភាគន័យម្យ៉ាងទៀត

## ចែកខន្ធដោយកាលតាមន័យព្រះសូត្រ

ឯខន្ធទាំងឡាយ ព្រះមានព្រះភាគ ( ទ្រង់ចែក ) ឲ្យពិស្តារយ៉ាងនេះថា រូបគ្រប់យ៉ាងដែលជាអតីត អនាគត និងបច្ចុប្បន្ន ជាខាងក្នុង ឬខាងក្រៅក៏ដោយ គ្រោតគ្រាត ឬល្អិតក៏ដោយ ថោកទាប ឬប្រណីតក៏ដោយ នៅក្នុងទីជិត ឬនៅក្នុងទីឆ្ងាយក៏ដោយ គំនររូបនេះហៅថា រូបក្ខន្ធ ព្រោះប្រមូលរួបរួមរូប ( ដែលចែកមក ) នោះចូលជាមួយគ្នា វេទនាគ្រប់យ៉ាងដែលជាអតីត អនាគត និងបច្ចុប្បន្ន ។បេ។ គំនរ វេទនានេះហៅថា វេទនាខន្ធ ព្រោះប្រមូលរួបរួមវេទនា ( ដែលចែកមក ) នោះ ចូលជាមួយគ្នា សញ្ញាគ្រប់យ៉ាងដែលជាអតីត អនាគត និងបច្ចុប្បន្ន ។បេ។ គំនរ សញ្ញានេះហៅថា សញ្ញាខន្ធ ព្រោះរួបរួមសញ្ញា ( ដែលចែកមក ) នោះចូលជាមួយគ្នា សង្ខារក្ខន្ធគ្រប់យ៉ាងដែលជាអតីត អនាគត និងបច្ចុប្បន្ន ។បេ។ គំនរ សង្ខារនេះហៅថា សង្ខារក្ខន្ធ ព្រោះរួបរួមសង្ខារ ( ដែលចែកមក ) នោះចូលជាមួយគ្នា វិញ្ញាណគ្រប់យ៉ាងដែលជាអតីត អនាគត និងបច្ចុប្បន្ន ជាខាងក្នុង និងខាងក្រៅក៏ដោយ ។បេ។ គំនរវិញ្ញាណនេះហៅថា វិញ្ញាណក្ខន្ធ ព្រោះរួបរួម វិញ្ញាណ ( ដែលចែកមក ) នោះចូលជាមួយគ្នា ដូច្នេះ។

## អត្ថាធិប្បាយ រូបវិភាគ

ក្នុងព្រះបាលីទាំងនោះ បទថា **យង្កិញ្ចិ**-គ្រប់យ៉ាង ជាពាក្យ ( សេចក្តីថា ) កាន់យកអស់មិនឲ្យសល់ បទថា **រូបំ**-រូប ជាពាក្យកំណត់វត្ថុដែលបំណងដោយ

ចំពោះដោយទាំង ២ ដូច្នេះ ក៏ឈ្មោះថាទ្រង់ធ្វើការកំណត់យករូបមិនឲ្យមានសេសសល់តពីនោះទៅ ទើបផ្ដើមចែករូបនោះដោយកាល មានអតីតជាដើម ពិតណាស់ រូបនោះខ្លះក៏ជាអតីត ខ្លះក៏ខុសគ្នាជាអនាគតជាដើម ន័យសូម្បីក្នុងខន្ធដ៏សេស មានវេទនាជាដើម ក៏ដូចន័យនេះ ។

## រូបក្ខន្ធ

ក្នុងខន្ធទាំងឡាយនោះ ដំបូងរូបចាត់ជាអតីតដោយចំណែក ៤ ដោយអំណាចនៃអទ្ធាសន្តតិ សម័យ និងខណៈ ជាអនាគត និងបច្ចុប្បន្នក៏យ៉ាងនោះ ។

ក្នុងចំណែក ៤ នោះ ពោលដោយ **អទ្ធា** មុន ក្នុងភពមួយ រូបរបស់បុគ្គលម្នាក់ក្នុងកាលមុនអំពីបដិសន្ធិ ចាត់ជាអតីត រូបក្នុងកាលបន្ទាប់ពីចុតិទៅជាអនាគត រូបក្នុងរវាងកាលទាំង ២ នោះ ចាត់ជាបច្ចុប្បន្ន ។

ពោលដោយ **សន្តតិ** រូបដែលមានឧតុ ដែលជាសភាគតែមួយជាសមុដ្ឋាន និងមានអាហារ ( ដែលជាសភាគ ) តែមួយជាសមុដ្ឋាន សូម្បីប្រព្រឹត្តទៅដោយអំណាចរយៈកាលជាខាងដើម និងខាងចុងក៏ដោយ ចាត់ជាបច្ចុប្បន្ន រូបដែលមានឧតុ និងអាហារជាវិសភាគជាមួយសមុដ្ឋានក្នុងកាលមុននោះ ចាត់ជាអតីត ខាងក្រោយនោះចាត់ជាអនាគត ចំណែករូបដែលកើតពីចិត្ត មានវិថីចិត្ត ១ ជវន ១ និងសមាបត្តិចិត្ត ១ ជាសមុដ្ឋាន ចាត់ជាបច្ចុប្បន្ន រូបក្នុងកាលមុនអំពីនោះចាត់ជាអតីត រូបក្នុងកាលជាខាងក្រោយអំពីនោះជាអនាគត សម្រាប់រូបដែលមានកម្មជាសមុដ្ឋាន មិនមានការញែកប្រភេទជាអតីតជាដើម ដោយអំណាចសន្តតិ ជាចំណែកមួយដោយឡែកឡើយ តែភាពជាអតីតជាដើមនៃរូបដែលមានកម្មជាសមុដ្ឋាន គប្បីជ្រាបថា ជាឧបត្ថម្ភកប្បច្ច័យរបស់រូបដែលមានឧតុ អាហារ និងចិត្តជាសមុដ្ឋាននោះឯង ។

ពោលដោយ **សម័យ** រូបមានសម័យនោះៗ ដែលប្រព្រឹត្តទៅតជាប់គ្នាក្នុងសម័យទាំងឡាយមានមួយរយៈ គឺពេលព្រឹក ពេលល្ងាច ពេលយប់ ពេលថ្ងៃជាដើម ចាត់ជាបច្ចុប្បន្ន រូបក្នុងសម័យមុនអំពីនោះចាត់ជាអតីត រូបក្នុងសម័យក្រោយអំពីនោះ ចាត់ជាអនាគត ។

ពោលដោយខណៈ រូបដែលទាក់ទងក្នុងខណៈ ៣ មានឧប្បាទក្ខណៈជាដើម ចាត់ជាបច្ចុប្បន្ន រូបខាងមុនអំពីនោះចាត់ជាអនាគត រូបក្រោយអំពីនោះចាត់ជាអតីត ន័យម្យ៉ាងទៀត រូបដែលមានហេតុកិច្ច និងបច្ចយកិច្ច កន្លងទៅហើយចាត់ជាអតីត រូបដែលមានហេតុកិច្ចសម្រេចហើយ តែបច្ច័យកិច្ចនៅមិនទាន់សម្រេចចាត់ជាបច្ចុប្បន្ន រូបដែលកិច្ចទាំង ២ នៅមិនទាន់ចូលដល់ចាត់ជាអនាគត ឬថារូប ក្នុងខណៈធ្វើកិច្ចរបស់ខ្លួនជាបច្ចុប្បន្ន រូបខាងមុនអំពីនោះ ចាត់ជាអនាគត រូបខាងក្រោយអំពីនោះជាអតីត ។

ក្នុងកថាចែករូបនេះ ខណាទិកថា ( ពោលដោយខណៈជាដើម ) តែម្យ៉ាងមិនមានបរិយាយកថាដ៏សេសមានបរិយាយ ។

ប្រភេទរូបខាងក្នុង និងរូបខាងក្រៅ មានន័យដូចពោលមកហើយនោះឯង តែថា ក្នុងសុត្តន្តន័យនេះ គប្បីជ្រាបថា សូម្បីរូបដែលនៅខាងក្នុងខ្លួនរបស់ខ្លួនក៏ចាត់ជាខាងក្នុង និងសូម្បីរូបដែលជារបស់បុគ្គលដទៃ ក៏ចាត់ជាខាងក្រៅដោយប្រភេទរូបគ្រោតគ្រាត និងរូបល្អិត ក៏មានន័យដូចពោលមកហើយដូចគ្នា ។

ប្រភេទរូបថោកទាប និងរូបប្រណីត ជា ២ គឺជារូបថោកទាប និងប្រណីតដោយបរិយាយ ( គឺញែកជាផ្នែកៗ ) ដោយនិប្បរិយាយ ១ ( គឺមិនញែកជាផ្នែក ) ក្នុងរូប ២ យ៉ាងនោះ ភាពជារូបថោកទាប និងរូបប្រណីតដោយបរិយាយ គប្បីជ្រាបដោយបរិយាយ គឺរូបរបស់ទេវតាពួកសុទស្សី ថោកទាបជាងរូបរបស់ទេវតាពួក

អកនិដ្ឋា រូបរបស់ទេវតាពួកសុទស្សីនោះឯង ប្រណីតជាងរូបរបស់ទេវតាពួកសុទស្សា ដូច្នេះ រហូតដល់រូបរបស់ពួកសត្វនរក ( ថោកទាបជាងរូបរបស់ពួកមនុស្ស ) ចំណែកភាពជារូបថោកទាប និងរូបប្រណីតដោយនិប្បរិយាយគប្បីជ្រាបថា អកុសលវិបាកវិញ្ញាណកើតឡើងក្នុងរូបណា រូបនោះក៏ជារូបថោកទាប កុសលវិបាកវិញ្ញាណកើតឡើងក្នុងរូបណា រូបនោះក៏ជារូបប្រណីត ។

សូម្បីដែលថា រូបឆ្ងាយ រូបជិតនេះ មានន័យដូចពោលមកហើយដូចគ្នា តែថាក្នុងសេចក្ដីនេះ គប្បីជ្រាបភាពជារូបឆ្ងាយ រូបជិត ដោយអាស្រ័យទាក់ទងគ្នា ដោយឱកាស ( គឺទីតាំងនៅរបស់រូបនោះៗ ) ផង ។

ក្នុងបាឋៈថា **តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា**-ព្រោះរួបរួមរូប ( ដែលបែកមក ) នោះចូលជាមួយគ្នានេះ មានសេចក្ដីដូច្នេះថា ពួករូបនេះ ហៅថា រូបក្ខន្ធ ព្រោះធ្វើរូបដែលទ្រង់សម្ដែងចេញជាចំណែកៗ ដោយបទទាំងឡាយ មានអតីតជាដើមទាំងអស់នោះចូលជាកងដោយបញ្ញា ក្នុងភាពតែមួយ បានដល់ រុប្បនលក្ខណៈ ( លក្ខណៈដែលបែកធ្លាយបាន ) ដោយបាឋៈនេះដែលសម្ដែងថា រូបទាំងអស់ ឈ្មោះថា រូបក្ខន្ធ ព្រោះចូលដល់ភាព ( រួមគ្នា ) ជាកងបានក្នុង **រុប្បនលក្ខណំ** ដោយដាក់ឈ្មោះថា រូបក្ខន្ធ នឹងជាយ៉ាងដទៃអំពីរូបមិនមាន ។

## វេទនាវិភាគ

រូប ( បានឈ្មោះថា រូបក្ខន្ធ ព្រោះចូលដល់ភាពជាកងក្នុងរុប្បនលក្ខណៈបាន ) យ៉ាងណា សូម្បីវេទនាជាដើមក៏បានឈ្មោះថា ខន្ធ មានវេទនាខន្ធជាដើម ព្រោះចូលដល់ភាពរួមគ្នាជាកងក្នុងលក្ខណៈទាំងឡាយ មានវេទយិតលក្ខណៈ ( លក្ខណៈដែលដឹងការសោយអារម្មណ៍ ) ជាដើមបាន ដូច្នោះ ទើបឈ្មោះថា ខន្ធទាំងឡាយ មានវេទនាខន្ធជាដើម នឹងមិនជាដទៃអំពីវេទនាជាដើមឡើយ ។

ចំណែកក្នុងការចែកដោយកាល មានអតីតជាដើមក្នុងវេទនាខន្ធនេះគប្បីជ្រាប ភាពជាអតីត អនាគត និងបច្ចុប្បន្ននៃវេទនា ដោយអំណាចសន្តតិ និងដោយអំណាចខណៈជាដើម ។

ក្នុងសន្តតិ និងខណៈជាដើមនោះ ពោលដោយសន្តតិ វេទនាដែលទាក់ទងក្នុងវិថីចិត្ត ១ ជវនចិត្ត ១ និងសមាបត្តិចិត្ត ១ និងវេទនាដែលប្រព្រឹត្តទៅ ដោយប្រកបជាមួយអារម្មណ៍តែម្យ៉ាងជាបច្ចុប្បន្ន វេទនាក្នុងកាលមុនអំពីនោះជាអតីត វេទនាក្នុងកាលខាងក្រោយអំពីនោះជាអនាគត ។

បើពោលខណៈជាដើម វេទនាដែលទាក់ទងក្នុងខណៈ ៣ និងវេទនាដ៏មានកម្លាំងធ្វើកិច្ចរបស់ខ្លួនដែលជាខាងដើម ចុង និងកណ្តាលជាបច្ចុប្បន្ន វេទនាក្នុងខណៈមុននោះជាអតីត វេទនាក្នុងខណៈក្រោយនោះជាអនាគត ។

ប្រភេទវេទនាខាងក្នុង ខាងក្រៅ គប្បីជ្រាបជាវេទនាខាងក្នុងខ្លួនរបស់ខ្លួន និងរបស់បុគ្គលដទៃ ប្រភេទវេទនាគ្រោតគ្រាត ល្អិតគប្បីជ្រាបដោយអំណាចនៃជាតិ សភាវៈ បុគ្គល លោកិយ និងលោកុត្តរ ដែលពោលទុកក្នុងគម្ពីរវិភង្គ ដោយន័យថា វេទនាដែលជាអកុសលជាវេទនាគ្រោតគ្រាត វេទនាដែលជាកុសល និងព្យាកតៈជាវេទនាល្អិត ដូច្នេះជាដើម ។

ជាបឋមពោលដោយ **ជាតិ** វេទនា ដែលជាអកុសលគ្រោតគ្រាតជាងវេទនាដែលជាកុសល ហេតុមានការប្រព្រឹត្តទៅមិនស្ងប់ ( មិនរៀបរយ ) ព្រោះជាហេតុនៃការធ្វើកម្មដែលមានទោស និងព្រោះមានភាពក្តៅដោយកិលេស គ្រោតគ្រាតជាងវេទនាដែលជាវិបាក អព្យាកតៈ ព្រោះប្រព្រឹត្តទៅជាមួយសេចក្តីព្យាយាម ( ដែលនឹងឲ្យមានវិបាក ) ព្រោះប្រព្រឹត្តទៅជាមួយឧស្សាហ៍ ( គឺភាពអាចដែលធ្វើវិបាកឲ្យកើត ) ព្រោះប្រព្រឹត្តទៅជាមួយវិបាក ( គឺមានវិបាក ) ព្រោះមានភាពក្តៅ ដោយកិលេស

ព្រោះប្រព្រឹត្តទៅជាមួយការលំបាក និងព្រោះប្រព្រឹត្តទៅជាមួយទោស គ្រោតគ្រាតជាងវេទនាដែលជាកិរិយាអព្យាកតៈ ព្រោះប្រព្រឹត្តទៅជាមួយវិបាក ព្រោះមានការក្តៅដោយអំណាចកិលេស ព្រោះប្រព្រឹត្តទៅជាមួយការលំបាក និងព្រោះប្រព្រឹត្តទៅជាមួយទោស ចំណែកវេទនាដែលជាកុសល និងវេទនាដែលជាអព្យាកតៈ ល្អិតជាងវេទនាដែលជាអកុសល ដោយបរិយាយផ្សេងអំពីបរិយាយដែលពោលហើយ ( គឺផ្ទុយគ្នា ) វេទនាដែលជាកុសល និងអកុសលទាំងឡាយគ្រោតគ្រាតជាងវេទនាដែលជាអព្យាកតៈទាំង ២ ផ្នែក ព្រោះប្រព្រឹត្តទៅជាមួយសេចក្តីព្យាយាម និងព្រោះប្រព្រឹត្តទៅជាមួយការឧស្សាហ៍ និងព្រោះប្រព្រឹត្តទៅជាមួយវិបាកតាមសមគួរ វេទនាដែលជាអព្យាកតៈទាំង ២ ផ្នែកនោះ ក៏ល្អិតជាងវេទនា ដែលជាកុសល និងវេទនាដែលជាអកុសលទាំង ២ នោះ ដោយបរិយាយផ្សេងគ្នាអំពីបរិយាយដែលពោលហើយ ( ផ្ទុយគ្នា ) ។

ភាពជាវេទនាគ្រោតគ្រាត ល្អិតដោយអំណាចជាតិ គប្បីជ្រាបដោយន័យដូចពោលមកនេះដែលជាលំដាប់ដំបូង ។

ចំណែកពោលដោយ **សភាវៈ** ទុក្ខវេទនាគ្រោតគ្រាតជាងវេទនា២ក្រៅអំពីនេះ ព្រោះមិនមានអស្សាទ ( មិនមានរសជាតិ ) ព្រោះប្រព្រឹត្តទៅជាមួយភាពកម្រើកខ្លួន ព្រោះជាទីតាំងនៃភាពតក់ស្លុត និងព្រោះសង្កត់សង្កិននូវវេទនា ២ ក្រៅអំពីនេះ ក៏នឹងល្អិតជាងទុក្ខវេទនា ព្រោះជាទីត្រេកអរ ព្រោះស្ងប់ ព្រោះប្រណីត ព្រោះជាទីពេញចិត្ត និងព្រោះជាកណ្តាលៗ តាមដែលដូចគ្នា ចំណែកសុខវេទនា និងទុក្ខវេទនាទាំង ២ គ្រោតគ្រាតជាងអទុក្ខមសុខវេទនា ព្រោះប្រព្រឹត្តទៅជាមួយភាពកម្រើកខ្លួន ព្រោះធ្វើភាពញ័រខ្លួន និងព្រោះភាពប្រាកដ អទុក្ខមសុខវេទនានោះល្អិតជាងសុខវេទនា និងទុក្ខវេទនាទាំង ២ នោះ ដោយបរិយាយផ្សេងអំពីបរិយាយ ដែលពោលមកហើយ

( គឺផ្ទុយគ្នា ) ។

កាពជាវេទនាគ្រោតគ្រាត ល្អិតដោយអំណាចនៃសភាវៈ គប្បីជ្រាបដោយន័យដូចពោលមក ដូច្នេះ ។

ចំណែកពោលដោយ **បុគ្គល** វេទនារបស់បុគ្គលអ្នកមិនបានចូលសមាបត្តិ គ្រោតគ្រាតជាងវេទនារបស់អ្នកចូលសមាបត្តិ ព្រោះវេទនារបស់អ្នកមិនចូលសមាបត្តិនោះ រសាត់ទៅក្នុងអារម្មណ៍ផ្សេងៗ វេទនាក្រៅអំពីនេះ ( គឺវេទនារបស់លោកអ្នកចូលសមាបត្តិ ) ក៏ល្អិត ( ជាងវេទនាមួយផ្នែកទៀត ) ដោយបរិយាយផ្សេងគ្នា ។

កាពជាវេទនាដែលល្អិតដោយអំណាចនៃបុគ្គល គប្បីជ្រាបដោយន័យដូចពោលមកនេះ ។

ចំណែកពោលដោយ **លោកិយ និង លោកុត្តរ** វេទនាដែលប្រព្រឹត្តទៅជាមួយអាសវៈ ជាលោកិយវេទនា វេទនាដែលប្រព្រឹត្តទៅជាមួយអាសវៈនោះគ្រោតគ្រាតជាងវេទនាដែលមិនមានអាសវៈ ព្រោះជាហេតុកើតអាសវៈ ព្រោះឧបការៈដល់ឱឃៈ ព្រោះឧបការៈដល់យោគៈ ព្រោះឧបការៈដល់នីវរណៈ ព្រោះឧបការៈដល់ឧបាទាន ព្រោះទាក់ទងដោយសង្កិលេស និងព្រោះមានទូទៅដល់បុថុជ្ជន វេទនាដែលមិនមានអាសវៈនោះ ល្អិតជាងវេទនាដែលប្រព្រឹត្តទៅជាមួយអាសវៈ ដោយបរិយាយផ្ទុយគ្នា ។

កាពជាវេទនាគ្រោតគ្រាត ល្អិតដោយអំណាចនៃលោកិយ និងលោកុត្តរ គប្បីជ្រាបដោយន័យដូចពោលនេះ ។

## គ្រោតគ្រាត ល្អិត ជាចំណែកៗ កុំឲ្យលាយឡំគ្នា

កាពលាយឡំគ្នាដោយអំណាចនៃជាតិជាដើម ក្នុងកាពគ្រោតគ្រាត ល្អិតតាមដែលពោលមកនោះ បណ្ឌិតគប្បីការពារ ( កុំឲ្យលាយឡំគ្នា ) ព្រោះថា វេទនាដែលសម្បយុត្តដោយកាយវិញ្ញាណ ដែលជាអកុសលវិបាក សូម្បីចាត់ជាវេទនាល្អិត ព្រោះ

ជាអព្យាកតៈដោយជាតិ តែគ្រោតគ្រាតដោយចំណែកដទៃ មានសភាវៈជាដើម សម នឹងព្រះបាលីថា អព្យាកតវេទនាជាវេទនាល្អិត ទុក្ខវេទនាជាវេទនាគ្រោតគ្រាត វេទនារបស់អ្នកមិនចូលសមាបត្តិជាវេទនាគ្រោតគ្រាត វេទនារបស់អ្នកចូលសមាបត្តិជាវេទនាល្អិត វេទនាដែលប្រព្រឹត្តទៅជាមួយអាសវៈជាវេទនាគ្រោតគ្រាត វេទនាដែលមិនមានអាសវៈ ជាវេទនាល្អិត ដូច្នេះ និងទុក្ខវេទនា យ៉ាងណា សុខវេទនាជាដើម ក៏ជាវេទនាគ្រោតគ្រាតដោយជាតិ និងល្អិតដោយសភាវៈជាដើម ដូច្នោះ ព្រោះហេតុនោះ ភាពលាយឡំគ្នាដោយអំណាចជាតិជាដើម នឹងមិនមានដោយប្រការណា ភាពគ្រោតគ្រាតល្អិតនៃវេទនាទាំងឡាយ បណ្ឌិតគប្បីជ្រាបដោយប្រការនោះចុះ គឺអព្យាកតវេទនាជាវេទនាល្អិតជាងកុសលវេទនា ហើយអកុសលវេទនា ដោយជាតិ ក៏មិនត្រូវទៅប៉ះពាល់ដល់ភាពផ្សេងគ្នាដោយចំណែកដទៃ មានសភាវៈជាដើម ដូច្នេះ ថា ក្នុងវេទនាទាំងនោះ អព្យាកតវេទនា យ៉ាងណា ជាទុក្ខឬ ជាសុខឬ ជារបស់អ្នកចូលសមាបត្តិឬ ជារបស់អ្នកមិនចូលសមាបត្តិឬ ជាសាសវៈឬ ជាអនាសវៈឬ ន័យក្នុងវេទនាទាំងពួង ក៏ដូចន័យនេះ ។

## ម្យ៉ាងទៀត គ្រោតគ្រាត ល្អិត ដោយប្រៀបគ្នា

ន័យម្យ៉ាងទៀតដោយព្រះបាលីថា វេទនាជាគ្រោតគ្រាត ល្អិតគប្បីឃើញដោយការប្រៀបធៀបទាក់ទងជាមួយវេទនានោះៗ ដូច្នេះ គប្បីជ្រាបថា ក្នុងវេទនាដទៃមានអកុសលវេទនាជាដើម វេទនាដែលជាទោសសហគតៈ ថោកទាបជាងវេទនាដែលជាលោភសហគតៈព្រោះទោសៈដុតទីអាស្រ័យរបស់ខ្លួនដូចជាភ្លើង វេទនាដែលជាលោភសហគតៈក៏ល្អិតទៅ ទោសសហគតវេទនាដែលជានិយត គ្រោតគ្រាតដែលជាអនិយតល្អិតទៅ និយតដែលជាកប្បដ្ឋិតិកៈ ( និយតដ៏ខ្លាំងក្លា ដូចជាទោសៈរបស់ទេវទត្តដែលអាចឲ្យផលអស់មួយកប្ប ) គ្រោតគ្រាត វេទនាក្រៅអំពីនេះល្អិត សុប្បី

ក្នុងពួកដែលជាកប្បដ្ឋិតិកៈ ដែលជាអសង្ខារិក គ្រោតគ្រាតក្រៅអំពីនេះ (គឺដែលជាសសង្ខារិក) ល្អិត ចំណែកវេទនាលោភសហគតៈដែលប្រកបដោយទិដ្ឋិគ្រោតគ្រាតក្រៅអំពីនេះ (គឺទិដ្ឋិវិប្បយុត្ត) ល្អិត សូម្បីទិដ្ឋិសម្បយុត្តទាំងនោះ ក៏ជានិយត ជាកប្បដ្ឋិតិកៈ ជាអសង្ខារិកគ្រោតគ្រាតក្រៅអំពីនេះ ( គឺដែលជាសសង្ខារិក ) ល្អិត ។

តែពោលដោយការមិនប្លែកគ្នា ( គឺមិនចែកជាទោសសហគតៈ ឬលោភ-សហគតៈ) អកុសលវេទនាដែលមានវិបាកច្រើនគ្រោតគ្រាត ដែលមានវិបាកតិចល្អិត ចំណែកកុសលវេទនាដែលមានវិបាកតិចគ្រោតគ្រាត ដែលមានវិបាកច្រើនល្អិត ។

ម្យ៉ាងទៀត កាមាវចរកុសលវេទនាគ្រោតគ្រាត រូបាវចរកុសលវេទនាល្អិត អរូបាវចរកុសលវេទនាល្អិតជាងរូបាវចរកុសលវេទនានោះ លោកុត្តរវេទនាល្អិតជាងអរូបាវចរកុសលវេទនានោះ កាមាវចរកុសលវេទនា ដែលជាទានមយៈ ចាត់ជាគ្រោតគ្រាត ដែលជាសីលមយៈល្អិត ដែលជាភាវនាមយៈល្អិតជាងសីលមយៈនោះ... សូម្បីភាវនាមយៈសោត ដែលជាទុហេតុកៈគ្រោតគ្រាត ដែលជាតិហេតុកៈល្អិត តិហេតុកៈសោត ដែលជាសសង្ខារិកគ្រោតគ្រាត ដែលជាអសង្ខារិកល្អិត ចំណែករូបាវចរវេទនា ដែលប្រព្រឹត្តទៅក្នុងបឋមជ្ឈានគ្រោតគ្រាត ដែលប្រព្រឹត្តទៅក្នុងទុតិយជ្ឈានល្អិត ដែលប្រព្រឹត្តទៅក្នុងតតិយជ្ឈានល្អិតជាង ដែលប្រព្រឹត្តទៅក្នុងទុតិយជ្ឈាន ដែលប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈានល្អិតជាងដែលប្រព្រឹត្តទៅក្នុងតតិយជ្ឈាន ដែលប្រព្រឹត្តទៅក្នុងបញ្ចមជ្ឈានល្អិតជាងដែលប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈាន ខាងអរូបាវចរវេទនា ដែលសម្បយុត្តដោយអាកាសានញ្ចាយតនៈគ្រោតគ្រាត ដែលសម្បយុត្តដោយវិញ្ញាណញ្ចាយតនៈល្អិត ដែលសម្បយុត្តដោយអាកិញ្ចញ្ញាយតនៈល្អិតជាង ដែលសម្បយុត្តដោយវិញ្ញាណញ្ចាយតនៈ ដែលសម្បយុត្តដោយនេវសញ្ញានាសញ្ញាយតនៈល្អិតជាង ដែលសម្បយុត្តដោយអាកិញ្ចញ្ញាយតនៈ ចំណែកលោកុត្តរវេទនាដែល

សម្បយុត្តដោយសោតាបត្តិមគ្គគ្រោតគ្រាត ដែលសម្បយុត្តដោយសកទាគាមិមគ្គល្អិត ដែលសម្បយុត្តដោយអនាគាមិមគ្គល្អិតជាង ដែលសម្បយុត្តដោយសកទាគាមិមគ្គ ដែលសម្បយុត្តដោយអរហត្តមគ្គល្អិតជាង ដែលសម្បយុត្តដោយអនាគាមិមគ្គ ដូច្នេះ ។

ន័យក្នុងវេទនាដែលជាវិបាក និងដែលជាកិរិយាក្នុងភូមិនោះៗ និងក្នុងវេទនាដែលពោលដោយអំណាចសភាវៈ មានទុក្ខវេទនាជាដើម ដោយអំណាចបុគ្គលមានអសមាបន្នវេទនា (វេទនារបស់អ្នកមិនបានចូលសមាបត្តិ) ជាដើម និងដោយអំណាចលោកិយ លោកុត្តរ មានសាសវវេទនា ( វេទនាដែលប្រព្រឹត្តទៅជាមួយអាសវៈ ) ជាដើម ក៏មានន័យដូចគ្នា ។

កាលពោលដោយឱកាស ទុក្ខវេទនាក្នុងនរកគ្រោតគ្រាត ទុក្ខវេទនាក្នុងកំណើតតិរច្ឆានល្អិត ទុក្ខវេទនាក្នុងកំណើតមនុស្សល្អិតជាង ទុក្ខវេទនាក្នុងកំណើតតិរច្ឆានទុក្ខវេទនា ក្នុងទេវតាជាន់ចាតុម្មហារាជិកា ល្អិតជាងទុក្ខវេទនាក្នុងកំណើតមនុស្សទុក្ខវេទនាក្នុងទេវតាជាន់តាវត្តិង្ស ល្អិតជាងទុក្ខវេទនាក្នុងទេវតាជាន់ចាតុម្មហារាជិកាទុក្ខវេទនាក្នុងទេវតាជាន់យាមា ល្អិតជាងទុក្ខវេទនាក្នុងទេវតាជាន់តាវត្តិង្ស ទុក្ខវេទនាក្នុងទេវតាជាន់តុសិត ល្អិតជាងទុក្ខវេទនាក្នុងទេវតាជាន់យាមា ទុក្ខវេទនាក្នុងទេវតាជាន់និម្មានរតី ល្អិតជាងទុក្ខវេទនាក្នុងទេវតាជាន់តុសិត ទុក្ខវេទនាក្នុងទេវតាជាន់បរនិម្មិត-វសវត្តី ល្អិតជាងទុក្ខវេទនាក្នុងទេវតាជាន់និម្មានរតី ឯទុក្ខវេទនាប្រកប ( សេចក្តី ) យ៉ាងណា សូម្បីសុខវេទនាក៏គប្បីជ្រាប (សេចក្តី) តាមគួរក្នុងភូមិទាំងពួង ដូច្នោះចុះ ។

ម្យ៉ាងទៀត ពោលដោយវត្ថុ វេទនាគ្រប់យ៉ាងដែលមានវត្ថុថោកទាប ជាវេទនាគ្រោតគ្រាត ដែលមានវត្ថុប្រណីតជាវេទនាល្អិត ។

ក្នុងប្រភេទថោកទាប ប្រណីត គប្បីជ្រាបថា វេទនាណាគ្រោតគ្រាត វេទនានោះក៏ថោកទាប និងវេទនាណាល្អិត វេទនានោះក៏ប្រណីត ។

ចំណែកទូរេបទ ( បទថា ឆ្ងាយ ) លោកចែកទុកក្នុងគម្ពីរវិភង្គ ដោយន័យថា វេទនាដែលជាអកុសលឆ្ងាយអំពីវេទនាដែលជាកុសល និងអព្យាកតៈ ដូច្នេះជាដើម សន្តិកេបទ ( បទថា ជិត ) លោកក៏ចែកទុកក្នុងគម្ពីរវិភង្គដោយន័យថា វេទនាដែលជាអកុសលជិតជាមួយវេទនាដែលជាអកុសល (ដូចគ្នា) ដូច្នេះជាដើម ព្រោះហេតុនោះ ទើបអកុសលវេទនាឈ្មោះថា ឆ្ងាយអំពីកុសលវេទនា និងអព្យាកតវេទនា ព្រោះជាវិសភាគគ្នា ព្រោះមិនទាក់ទងគ្នា និងព្រោះមិនសមគ្នា កុសលវេទនា និងព្យាកតវេទនា ឆ្ងាយអំពីអកុសលវេទនាក៏យ៉ាងនោះ ( គឺព្រោះហេតុដូចគ្នា ) ក្នុងវារៈទាំងពួងក៏ដូចន័យនេះ ចំណែកអកុសលវេទនាជិតជាមួយអកុសលវេទនា ( ដូចគ្នា ) ក៏ព្រោះជាសភាគគ្នា និងព្រោះសមគ្នាដោយពិត ។

នេះជាកថាមុខយ៉ាងពិស្តារក្នុងការចែកវេទនាខន្ធដោយចំណែកផ្សេងៗ ដែលជាអតីតជាដើម ។

សូម្បីកថាមុខយ៉ាងពិស្តារក្នុងការចែកសញ្ញាជាដើម ដែលសម្បយុត្តជាមួយវេទនានោះៗ ក៏គប្បីជ្រាបដោយន័យនេះចុះ ។

# មហាដីកា

## កថាពណ៌នាអំពីការចែកខន្ធមានចំណែក ដែលជាអតីតជាដើម

សុត្តន្តភាជនីយ៍ សូម្បីដែលចាត់ចូលក្នុងអភិធម្ម ក៏ជាសុត្តន្តន័យនោះឯង ចំណែកអភិធម្មន័យសុទ្ធៗ ចាត់ជាអភិធម្មភាជនីយ៍ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **តាមន័យនៃបទភាជនីយ៍ក្នុងអភិធម្ម** ។

ក្នុងសេចក្ដីព្រះបាលីថា **ភគវតា បន ឯវំ ខន្ធា វិត្ថារិតា** ប្រែថា ព្រះសាស្ដាទ្រង់ចែកខន្ធឲ្យពិស្ដារយ៉ាងនេះ ។ ព្រោះដូច្នោះ ទើបមានអធិប្បាយថា ខ្ញុំនឹងធ្វើការពណ៌នា ខន្ធទាំងឡាយដោយអំណាចព្រះបាលីនេះ ។ បទថា **យំ** ក្នុងបទថា **យង្កិញ្ចិ** នេះ ជាពាក្យសម្ដែងអនិយមដោយសាមញ្ញ ។ បទថា **កិញ្ចិ** ជាបទសម្ដែងអនិយមពឹងផ្អែកដល់ភាពផ្សេងនៃប្រការ ។ សូម្បីដោយបទដែលជាអនិយមទាំងពីរ ព្រះសាស្ដាទ្រង់រមែងកាន់យកគ្រប់កលាបរូបទាំងអស់ ដែលគួរនឹងជាទបុំសកនិទ្ទេស ដែលជាអតីត ឬបច្ចុប្បន្ន ទីជិត ឬទីឆ្ងាយ តិច ឬច្រើន ដូចម្ដេច ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ជាពាក្យកំណត់កាន់យកដោយមិនមានចំណែកសេសសល់** ។ ឯលោកអាចារ្យកាលឃើញបំណង ក្នុងពាក្យដែលគួរជាទបុំសកនិទ្ទេសដទៃៗ យ៉ាងនេះហើយ កាលនឹងសម្ដែងថា ព្រះមានព្រះភាគត្រាស់ថា រូប ដើម្បីទ្រង់សម្ដែងដល់ភាពជាបំណងដោយចំពោះ ព្រោះប្រព្រឹត្តទៅសំដៅដល់អត្ថដែលជាបំណងក្នុងពាក្យទាំងនោះ ទើបពោលថា ពាក្យថា **រូបជាពាក្យកំណត់ដល់ភាពជាបំណងដោយចំពោះ** ។ ឯបទថា **យង្កិញ្ចិ** លោកអាចារ្យកាន់យក **យំ**-ស័ព្ទថាជាបទមួយ និង **កិំ**-ស័ព្ទ ព្រមទាំងនិបាតថាជាបទមួយ ហើយទើបពោលថា **សូម្បីដោយបទទាំងពីរ ព្រោះសម្ដែង**

អត្ថដែលដូចគ្នាជាអនិយម ។ បទថា **អស្ស យោគ រូបស្ស** ។ ព្រះមានព្រះភាគ **ទ្រង់ផ្ដើមចែករូប ជាអតីតជាដើម** គឺជាអតីត អនាគត និងបច្ចុប្បន្នជាដើម ។

ក្នុងពាក្យថា **ដោយអំណាចអទ្ធា សន្តតិ សម័យ និងខណៈ** នេះ **អទ្ធា**-ស័ព្ទ រមែងប្រព្រឹត្តទៅក្នុងកាលដែលកំណត់ដោយចុតិ និងបដិសន្ធិ ព្រោះហេតុនោះ រមែងជ្រាបបានដោយអំណាចនៃសូត្រជាដើមថា **អហោសិ នុ ខោ អហំ អតីតមទ្ធានំ** ប្រែថា ក្នុងអតីតកាលយើងបានមានហើយឬហ្ន៎ ។ ពិតយ៉ាងនោះ សូម្បី **ក្នុងភទ្ទេរត្តិសូត្រ** ក៏បានត្រាស់ភាពជាអតីតជាដើម ដោយអំណាចនៃអទ្ធានោះឯង ដោយព្រះពុទ្ធវចនៈជាដើមថា **អតីតំ នាន្វាគមេយ្យ** ប្រែថា មិនគួររំពឹងដល់វត្ថុ ដែលកន្លងមកហើយ ។ ចំណែកអទ្ធាដែលកំណត់ដោយបរមត្ថថា **ម្នាលភិក្ខុទាំងឡាយ អទ្ធា ៣ នេះ អទ្ធា ៣ អ្វីខ្លះ ? គឺអទ្ធាដែលជាអតីត អទ្ធាដែលជាអនាគត អទ្ធាដែលជាបច្ចុប្បន្ន** លោកពោលថា អទ្ធាដែលកំណត់ដោយខណៈ **ដោយអំណាចនិរុត្តិបថសូត្រ** ។ ពិតណាស់ ក្នុងនិរុត្តិបថសូត្រនោះ ព្រះមានព្រះភាគត្រាស់រូប ដែលកំពុងមាន ថាជាបច្ចុប្បន្ន និងត្រាស់រូបមុន និងក្រោយអំពីនោះថា ជាអតីត និងអនាគតថា **ម្នាលភិក្ខុទាំងឡាយ រូបណាកើតហើយ ឧប្បត្តិហើយ ( រូបំ ជាតំ ភូតំ ) ។បេ។ ប្រាកដហើយ រូបនោះរាប់ថា មាន** ។ តែក្នុងសូត្រដទៃ អំពីនិរុត្តិបថសូត្រនោះ ដោយច្រើនត្រាស់អទ្ធាដែលជាអតីតជាដើម ដែលកំណត់ដោយចុតិ និងបដិសន្ធិ ព្រោះហេតុនោះ អទ្ធាដែលជាអតីតជាដើមនោះប៉ុណ្ណោះ លោកអាចារ្យពោលថា **ដោយអំណាចអទ្ធា** ក្នុងទីនេះ ។ ភាពត្រជាក់ចូលគ្នាបានជាមួយភាពត្រជាក់ ភាពក្ដៅក៏ចូលគ្នាបានជាមួយភាពក្ដៅដូចគ្នា ។ សភាពត្រជាក់ ឬសភាពក្ដៅណារួមចូលគ្នាក្នុងសរីរៈ ប្រព្រឹត្តទៅដោយអំណាចការបន្តគ្នា មិនជួរមិនតឹងជាងគ្នា មានអាការតែម្យ៉ាងជាមួយគ្នា ភាពត្រជាក់ ឬភាពក្ដៅ ហៅថា ឧតុដូចគ្នា ព្រោះហេតុនោះ ទើបលោកប្រើ **ឯក**-ស័ព្ទ ព្រោះភាព

ដែលឧតុ ជាសភាគៈនឹងគ្នា មានច្រើនយ៉ាង សូម្បីក្នុងអាហារក៏យ៉ាងនេះ ។ ពាក្យថា **មានវិថីចិត្តដូចគ្នា និងមានជវនចិត្តដូចគ្នាជាសមុដ្ឋាន** លោកពោលទុកដោយអំណាចនៃបញ្ចទ្វារ និងទ្វារទី ៦ ។ កថាពោលអំពីសន្តតិ និងសម័យ លោកពោលទុកក្នុងអដ្ឋកថាដើម្បីប្រយោជន៍ជាឧបការៈដល់អ្នកវិបស្សនាទាំងឡាយ ។ ហេតុជាតួឲ្យកើតបច្ច័យ ជាតួឧបត្ថម្ភ ហេតុ និងបច្ច័យទាំងនោះ មានកិច្ច គឺការធ្វើឲ្យកើតឡើង និងការឧបត្ថម្ភ ។ ប្រៀបដូចគ្រាប់ពូជ មានកិច្ចធ្វើឲ្យពន្លកកើតឡើង និងផែនដីជាដើម មានកិច្ចឧបត្ថម្ភពន្លកនោះ កម្ម មានកិច្ចធ្វើវិបាក គឺកដត្តារូបឲ្យកើតឡើងអាហារជាដើម មានកិច្ចឧបត្ថម្ភវិបាក គឺកដត្តារូបនោះ សេចក្តីនេះយ៉ាងណា គប្បីប្រកបកិច្ចរបស់ហេតុដែលធ្វើឲ្យកើតឡើងទាំងឡាយ ដែលជាបច្ច័យ មានកម្មប្បច្ច័យ និងអនន្តរប្បច្ច័យជាដើម និងរបស់បច្ច័យដែលជាតួឧបត្ថម្ភ ដែលជាសហជាតប្បច្ច័យ បុរេជាតប្បច្ច័យ និងបច្ឆាជាតប្បច្ច័យ ធ្វើឲ្យកលាបៈតែមួយកលាបៈកើតឡើង និងឧបត្ថម្ភចិត្តុប្បាទតាមសមគួរ ដូច្នោះ ។ រូបដែលមានឧតុនោះជាសមុដ្ឋាន លោកពោលចែកជាអតីតជាដើម ដោយអំណាចនៃសន្តតិ ព្រោះឧតុជាដើម មានភាពជាសភាគ និងវិសភាគដល់គ្នានឹងគ្នាយ៉ាងនេះ ចំណែកកម្មដែលធ្វើឲ្យកើតឡើងក្នុងភពជាមួយគ្នា មិនមានភាពជាសភាគ និងវិសភាគគ្នាឡើយ ព្រោះដូច្នោះ ទើបលោកមិនពោលការចែករូបដែលមានកម្មនោះ ជាសមុដ្ឋាន ជាអតីតជាដើម ដោយអំណាចសន្តតិ តែពោលដោយអំណាចនៃឧបត្ថម្ភកប្បច្ច័យប៉ុណ្ណោះ ។ ក្នុងកាលណាមានការត្រឡប់ភេទ ក្នុងកាលនោះ ភេទប្រុស រមែងអន្តរធានទៅ ព្រោះអកុសលមានកម្លាំង ភេទស្រីរមែងប្រាកដព្រោះកុសលខ្សោយកម្លាំង ម្យ៉ាងទៀត ភេទស្រីរមែងអន្តរធានទៅ ព្រោះអកុសលខ្សោយកម្លាំង ភេទប្រុសរមែងប្រាកដ ព្រោះកុសលមានកម្លាំង ព្រោះដូច្នោះ សូម្បីរូបដែលមានកម្មជាសមុដ្ឋាន ក៏មានភាពជាវិសភាគៈដូចគ្នា ព្រោះដូច្នោះ រូបដែលមាន

កម្ម ជាសម្មុដ្ឋានទាំងនោះ ទើបមានការចែកអតីតជាដើម ដោយអំណាចនៃសន្តតិ ការចែកជាអតីតជាដើមនោះ កុំកាន់យកឡើយ ព្រោះមិនប្រព្រឹត្តទៅសព្វកាលទាំងពួងនោះឡើយ ។

បទថា **តំតំសមយំ** មានរូបវិគ្គហៈដូច្នេះថា **ឯកមុហុត្តាទិកោ សោ សោ សមយោ ឯតស្សាតិ តំតំសមយំ** ជាវិគ្គហៈរបស់ **រូបំ** ប្រែវិគ្គហៈថា សម័យនោះៗ មានគ្រូម្នាក់ជាដើម មានដល់រូបនេះ ហេតុនោះ រូបនេះឈ្មោះថា **តំតំសមយំ** អធិប្បាយថា រូបដែលមានក្នុងសម័យនោះៗ ។

ពាក្យថា **អំពីមុននោះ** គឺមុនអំពីកាលទាក់ទងនឹងខណៈទាំង ៣ នោះ ។ ឈ្មោះថា **អនាគត** ព្រោះមិនទាន់កើតឡើង ។ បទថា **បច្ឆា** បន្ថែម **តតោ** ចូលជាមួយ **បច្ឆា** ប្រែថា ក្រោយអំពីនោះ ។ ឈ្មោះថា **អតីត** ព្រោះកន្លងខណៈទាំង ៣ ទៅហើយ ។ រូបណាមានហេតុកិច្ច និងបច្ចយកិច្ចកន្លងទៅហើយ ព្រោះសម្រេចទៅហើយ រូបនោះ **ជាអតីត** គប្បីឃើញថា មានហេតុកិច្ចនៅក្នុងឧប្បាទក្ខណៈ និងសម្រេចទៅហើយ ព្រោះមានផលកើតឡើងហើយ ។ បច្ចយកិច្ចមានក្នុងខណៈ ទាំង ៣ ។ កិច្ចរបស់ខ្លួននៃធាតុទាំងឡាយ មានបឋវីធាតុជាដើម មានការទទួលជាដើម និងកិច្ចរបស់ខ្លួនរបស់ធម៌ទាំងឡាយ មានផស្សៈជាដើម មានការពាល់ត្រូវជាដើម ឈ្មោះថា **សកិច្ចំ** ប្រែថា កិច្ចរបស់ខ្លួន ខណៈដែលធ្វើកិច្ចរបស់ខ្លួន ឈ្មោះថា **សកិច្ចក្ខណោ** ប្រែថា ខណៈធ្វើកិច្ចរបស់ខ្លួន ម្យ៉ាងទៀត វត្ថុដែលប្រព្រឹត្តទៅរួមជាមួយកិច្ច ឈ្មោះថា **សកិច្ចំ** រូប ឬអរូបដែលមានកិច្ច មានក្នុងខណៈណា ខណៈនោះឈ្មោះថា **សកិច្ចក្ខណោ** ប្រែថា ខណៈនៃរូប ឬអរូបដែលមានកិច្ច រូបក្នុងខណៈនោះជាបច្ចុប្បន្ន ។ ឯក្នុងកថាពោលដោយខណៈជាដើមនេះ ពាក្យថា **រូបមុននោះជាអនាគត រូបក្រោយនោះជាអតីត** ជាពាក្យនិប្បរិយាយ ព្រោះមិនមានសេចក្ដីផ្សេងគ្នាដូចគ្នាក្នុងអទ្ធាជាដើម ព្រោះថា

ដោយអទ្ធាជាដើម ក៏បានធម៌ដែលជាអតីតតែម្យ៉ាងនោះឯង ធម៌ដែលជាអនាគតម្យ៉ាង ធម៌ដែលជាបច្ចុប្បន្នម្យ៉ាង តែពោលដោយខណៈជាដើម មិនមានភាពផ្សេងគ្នាដោយធម៌ផ្សេងគ្នាតែដោយកាលប៉ុណ្ណោះ ។ មុនអំពីឧប្បាទក្ខណៈជាអនាគតដែលកំពុងប្រព្រឹត្តទៅក្នុងខណៈទាំង ៣ ជាបច្ចុប្បន្ន ក្រោយអំពីនោះជាអតីត ព្រោះដូច្នោះ ទើបជានិប្បរិយាយ ព្រោះមិនមានការៈដែលនឹងត្រូវពោលថា អតីត និងថា អនាគត ដោយបរិយាយណាមួយ ដូចជាអទ្ធាបច្ចុប្បន្នជាដើម ។

លោកអាចារ្យពោលថា **មានន័យដូចពោលមកហើយនោះឯង** សំដៅយកប្រភេទនៃអជ្ឈត្តិករូប គឺរូបខាងក្នុង និងពាហិររូប គឺរូបខាងក្រៅ ដែលពោលទុកហើយខាងដើម កាលមិនពេញចិត្តដោយន័យដែលពោលហើយនោះ ក្នុងរូបដែលមានន័យដែលពោលហើយនោះ ក៏គង់បានអត្ថរបស់ស័ព្ទថា **អជ្ឈត្តំ** នោះឯង គឺ **អជ្ឈត្តិកំ** ក៏ពិត សូម្បីយ៉ាងនោះ **អជ្ឈត្ត**-ស័ព្ទ និង **អជ្ឈត្តិក**-ស័ព្ទ និង **ពហិទ្ធា** ស័ព្ទ និង **ពាហិរ**-ស័ព្ទ ក៏គង់មានអត្ថផ្សេងគ្នានឹងគ្នានោះឯង ។ ពិតយ៉ាងនោះ **អជ្ឈត្តិក** ស័ព្ទ ស័ព្ទថា រូបខាងក្នុងប្រព្រឹត្តទៅក្នុងចក្ខុ មានរូបជាដើម ដែលប្រព្រឹត្តទៅក្នុងសន្តានរបស់ខ្លួន និងរបស់បុគ្គលដទៃ ដូចពាហិរ-ស័ព្ទ ប្រព្រឹត្តទៅក្នុងរូបជាដើម ចំណែកអជ្ឈត្ត-ស័ព្ទប្រព្រឹត្តទៅក្នុងចក្ខុ និងរូបជាដើម ដែលប្រព្រឹត្តទៅក្នុងសន្តានរបស់ខ្លួនតែម្យ៉ាង របស់សត្វនោះៗ ដូចគ្នានឹងពហិទ្ធា-ស័ព្ទ ប្រព្រឹត្តទៅក្នុងចក្ខុ និងរូបជាដើម ដទៃអំពីនោះ ។ ព្រោះដូច្នោះ ដើម្បីនឹងសម្តែងអត្ថ ទើបលោកអាចារ្យពោលថា **អបិច** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ បទថា **ឥធ** ប៉ុនគ្នានឹង **ឥមស្មឹ យោគ-សុត្តន្តនយេ** ប្រែថា ក្នុងសុត្តន្តន័យនេះ ។ អធិប្បាយថា សូម្បីរូបដែលជាខាងក្នុងដែលកើតក្នុងខ្លួន ក៏មិនមែនជារូបខាងក្នុងដែលពោលទុកហើយខាងដើមឡើយ សូម្បីរូបដែលជារបស់បុគ្គលដទៃ ក៏មិនមែនរូបដែលជាខាងក្រៅ ដែលពោលទុកហើយ

ខាងដើមឡើយ ។

សម្ពន្ធព្រះបាលីសេចក្តីថា **ហីនបណីតភេទោ បរិយាយតោ និប្បរិយាយតោ ច វេទិតព្វោ** ប្រែថា ប្រភេទរបស់រូបថោកទាប និងប្រណីត គប្បីជ្រាបដោយបរិយាយ និងនិប្បរិយាយ ។ **តទេវ យោគ សុទស្សនំ រូបំ** ប្រែថា រូបរបស់ទេវតាជាន់សុទស្សីនោះឯង ។ បទថា **យត្ថ** ប៉ុនគ្នានឹង **យស្មិំ យោគ អារម្មណភូតេ** ប្រែថា ក្នុងរូបឯណាដែលជាអារម្មណ៍ ។ អកុសលវិបាកចិត្តកើតឡើងធ្វើរូបណាឲ្យជាអារម្មណ៍ **រូបនោះ ឈ្មោះថា ជារូបថោកទាប** ព្រោះជារូបដែលមិនគួរប្រាថ្នា ។ **កុសលវិបាកចិត្ត** កើតឡើងធ្វើរូបណាឲ្យជាអារម្មណ៍ **រូបនោះ ឈ្មោះថា ជារូបប្រណីត** ព្រោះជារូបដែលគួរប្រាថ្នា ប្រៀបដូចអកុសលវិបាក ខ្ទួនឯងមិនគួរប្រាថ្នាកើតឡើង ក្នុងអនិដ្ឋារម្មណ៍តែម្យ៉ាង មិនកើតឡើងក្នុងឥដ្ឋារម្មណ៍ យ៉ាងណា សូម្បីកុសលវិបាកក៏ដូច្នោះ ខ្លួនឯងគួរប្រាថ្នា រមែងកើតឡើងក្នុងឥដ្ឋារម្មណ៍តែម្យ៉ាង មិនកើតឡើងក្នុងអនិដ្ឋារម្មណ៍ ។ សមដូចព្រះអដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថាថា

កាមគុណ ៥ ដែលជាអនិដ្ឋារម្មណ៍ លោកចែកទុកដោយអំណាចវិបាក ដែលកើតអំពីអកុសលកម្ម ចំណែកអារម្មណ៍ដែលកើតអំពីកុសលកម្ម ឈ្មោះថា ជាអនិដ្ឋារម្មណ៍មិនមាន ទាំងអស់ជាឥដ្ឋារម្មណ៍តែម្យ៉ាង ។ ហើយចែកកាមគុណ ៥ ដែលជាឥដ្ឋារម្មណ៍ ដោយអំណាចអារម្មណ៍ដែលកើតអំពីកុសលកម្ម ។ ព្រោះអារម្មណ៍ដែលកើតអំពីកុសល ឈ្មោះថា ជាអនិដ្ឋារម្មណ៍មិនមាន ទាំងអស់ជាឥដ្ឋារម្មណ៍តែម្យ៉ាង ។

បណ្ដាកុសលវិបាក និងអកុសលវិបាកទាំងនោះ រូបសូម្បីដែលគួរពេញចិត្តខ្លះមានរូបដំរីជាដើម ជារូបដែលកើតឡើងដោយអកុសលកម្មក៏មាន តែរូបទាំងនោះមិនដល់នូវភាពជាហេតុនៃសេចក្ដីសុខរបស់សត្វទាំងឡាយ មានដំរីជាដើមនោះឡើយ ។ ព្រោះថា រូបដែលកើតឡើងដោយកុសលដែលខ្លួនធ្វើទុករបស់សត្វនោះៗ នោះឯងរមែងជាបច្ច័យដល់សេចក្ដីសុខ ដែលកើតឡើងដោយអកុសលជាបច្ច័យដល់សេចក្ដីទុក្ខ ។ ព្រោះដូច្នោះ ភាពនៃរូបដែលកើតអំពីកម្មជាឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ គប្បីជាធម្មជាតិគួរដល់ការប្រកបដោយអំណាចសត្វដែលធ្វើកម្មទុក ។ ក្នុងសេចក្ដីនោះពាក្យណា ដែលព្រះអដ្ឋកថាចារ្យពោលទុកថា **រូបដែលកើតអំពីកុសលកម្មដែលឈ្មោះថា មិនគួរប្រាថ្នាមិនមាន** តែមិនបានពោលទុកថា **រូបដែលកើតអំពីអកុសលកម្មឈ្មោះថា គួរប្រាថ្នាក៏ទេ** ដូច្នេះ ដោយពាក្យនោះ គង់នឹង រមែងទទួលគ្នាថា សូម្បីរូបដែលកើតអំពីអកុសលកម្មដែលស្អាត ដែលគួរប្រាថ្នារបស់សត្វដទៃក៏មាន តែរូបដែលកើតអំពីកុសលកម្មជារូបដែលគួរប្រាថ្នាដល់សត្វ គ្រប់ជំពូកនោះឯង ដូច្នេះ ។ ឯរូបមនុស្សមិនជាទីពេញចិត្តរបស់សត្វតិរច្ឆានជំពូកខ្លះ ព្រោះកាលវាឃើញក៏គេចទៅ ហើយមនុស្សទាំងឡាយឃើញរូបទេវតាក៏ខ្លាច វិបាកចិត្តសូម្បីរបស់បុគ្គលទាំងនោះប្រារព្ធរូបនោះ ក៏ជាកុសលវិបាកនោះឯងកើតឡើង តែព្រោះបុណ្យដូច្នោះមិនមានទើបបុគ្គលនោះមិនមានការត្រេកអរក្រៃលែង ក្នុងរូបរបស់ទេវតានោះ ។ គួរពោលថា ការមិនមានរូបដែលកើតអំពីអកុសលកម្ម ដែលគួរប្រាថ្នា ដូចការមិនមានរូបដែលកើតអំពីកុសលកម្មដែលមិនគួរប្រាថ្នាផង ។ព្រោះរូបដែលកើតអំពីអកុសលកម្មរបស់

សត្វទាំងឡាយ មានដំរីជាដើម ជាអារម្មណ៍របស់អកុសលវិបាកតែម្យ៉ាង ចំណែករូបដែលកើតអំពីកុសលកម្ម ដែលតាំងឡើងក្នុងបវត្តិកាល ជាអារម្មណ៍របស់កុសលវិបាក ។ តែអាចជ្រាបបានថា រូបដែលកើតអំពីកុសលកម្មបន្តិចបន្តួច និងមិនជាហេតុនៃការកើតឡើងនៃអកុសលវិបាកច្រើនៗ ព្រោះនៅលាយឡំជាមួយឥដ្ឋារម្មណ៍ ចំណែកវិបាកណាមួយ មិនអាចធ្វើឲ្យប្រែប្រួលបាន ព្រោះដូច្នោះ ការកំណត់ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ដោយអំណាចវិបាកត្រឹមត្រូវល្អ ។ចំណែកពាក្យណាដែលព្រះអដ្ឋកថាចារ្យពោលទុកថា **កាមគុណ ៥ ដែលជាអនិដ្ឋារម្មណ៍** ពាក្យនោះ លោកពោលទុកដោយការបញ្ញត្តអនិដ្ឋារម្មណ៍នោះ ទុកក្នុងអារម្មណ៍ដែលដូចជាមួយកាមគុណ ៥ នោះ ព្រោះដូចគ្នានឹងកាមគុណដោយភាពស្មើគ្នា ដោយភាវៈដែលជាអារម្មណ៍ មានរូបជាដើម ។ ព្រោះអារម្មណ៍ មានរូបជាដើម ដែលជាឥដ្ឋារម្មណ៍នោះឯង ព្រះមានព្រះភាគត្រាស់ទុកក្នុងព្រះបាលីថា **ជាកាមគុណ** ។ ម្យ៉ាងទៀត រូបជាដើម ដែលជាវិសភាគចំពោះកាមគុណក៏ត្រាស់ថា **ជាកាមគុណ** ដូចការហៅក្នុងវត្ថុដែលមិនជាសិរៈថា ជាសិរៈ ដូច្នោះ ម្យ៉ាងទៀត រូបជាដើម ទាំងដែលជាឥដ្ឋារម្មណ៍ក្តី អនិដ្ឋារម្មណ៍ក្តី ទាំងអស់ក៏ឈ្មោះថា ជាកាមគុណនោះឯង ព្រោះជាទីតាំងនៃតណ្ហា ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា **រូបទាំងឡាយ ជាទីស្រឡាញ់ ជាទីត្រេកអរ ក្នុងលោក** ដូច្នេះជាដើម ។ តែព្រោះជាអារម្មណ៍ដែលគួរប្រាថ្នាដោយពិសេស **ក្នុងព្រះសូត្រទាំងឡាយ** ទើបត្រាស់រូបជាដើមដែលគួរប្រាថ្នាថា ជាកាមគុណ ។

ពាក្យថា **មានន័យដូចពោលហើយនោះឯង** សេចក្តីថា លោកអាចារ្យសម្តែង

រូបឆ្ងាយ និងរូបជិត ដោយលក្ខណៈតាមដែលនឹងសម្ដែងខាងមុខ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ក្នុងទីនេះគប្បីជ្រាបភាពជារូបឆ្ងាយ រូបជិត ដោយអាស្រ័យការប្រៀបធៀបគ្នា សូម្បីដោយឱកាស** ។ បណ្ដារូបឆ្ងាយ និងរូបជិតនោះ រូបចាប់ពីរយៈប៉ុនណា ឈ្មោះថា រូបជិតដោយឱកាស ម្យ៉ាងទៀត រូបចាប់ពីរយៈប៉ុនណា ឈ្មោះថា រូបឆ្ងាយ ? កាលបុគ្គលនិយាយដោយពាក្យសម្ដីតាមប្រក្រតីចម្ងាយ ១២ ហត្ថ ឈ្មោះថាជាដែនដែលល្មមនឹងឮបាន ខាងក្នុងរបស់ដែនដែលនឹងបានឮនោះ ឈ្មោះថា ជិត ខាងក្រៅចេញទៅ ឈ្មោះថា ឆ្ងាយ ។ ក្នុងបណ្ដារូប ទាំងនោះ **សុខុមរូប** កាលនៅឆ្ងាយចាត់ថាជារូបឆ្ងាយ ទាំងដោយលក្ខណៈ ទាំងដោយឱកាស តែបើនៅជិត ឈ្មោះថា រូបជិត ដោយឱកាសតែម្យ៉ាង មិនមែន ដោយលក្ខណៈ ។ **ឱឡារិករូប** កាលនៅជិត ចាត់ជារូបជិត ទាំងដោយលក្ខណៈ ទាំងដោយឱកាស កាលនៅឆ្ងាយ ចាត់ជារូបឆ្ងាយ ដោយឱកាសតែម្យ៉ាង មិនមែនដោយលក្ខណៈ ។ តែព្រោះពោលថា **អាស្រ័យការប្រៀបធៀប** រូបរបស់ខ្លួន ទើបឈ្មោះថា រូបជិត រូបរបស់អ្នកដទៃ សូម្បីនៅក្នុងឧទរ ឈ្មោះថា រូបឆ្ងាយ ។ រូបរបស់អ្នកដទៃដែលនៅក្នុងឧទរ ជារូបជិត រូបរបស់អ្នកដទៃដែលនៅខាងក្រៅជារូបឆ្ងាយ ព្រោះដូច្នោះគប្បីជ្រាបភាពជារូបឆ្ងាយ រូបជិត ទាក់ទងជាមួយរូបដែលនៅខាងក្នុងឧទរនោះ និងរូបដែលនៅខាងក្រៅ ក្នុងបណ្ដារូបដែលនៅក្នុងបន្ទប់ត្រង់យ៉មុខ ត្រង់បរិវេណ ដែលនៅត្រង់វត្ត ដែលនៅត្រង់ស្រុក នៅត្រង់វាល នៅត្រង់ជនបទ នៅត្រង់ព្រះរាជវាំង នៅត្រង់សមុទ្រ នៅត្រង់ចក្រវាល ដោយប្រការដូច្នេះ ។

បទថា **តទេកជ្ឈំ** កាត់ជា **តំ ឯកជ្ឈំ** សេចក្តីប៉ុនគ្នានឹង ឯកតោ ។ បទថា **អភិសញ្ញូហិត្វា** ប្រែថា រួបរួម ឬធ្វើឲ្យជាក្រុមតែមួយ ។ បទថា **អភិសង្ខិបិត្វា** បានដល់ បង្រួញទុក គឺធ្វើសង្ខេបទុក ។ ដោយពាក្យថា **រូបទាំងអស់ដែលសម្តែងថា** ឈ្មោះថា **រូបក្ខន្ធ ដោយចូលដល់ភាពជាគំនរដោយលក្ខណៈ គឺភាពប្រែប្រួល** នេះ លោកសម្តែងភាពដែលរូបសព្ទ និងខន្ធសព្ទជាសមាសដែលជាសមានាធិករណៈ ។ ព្រោះហេតុនោះៗ ឯង ទើបលោកអាចារ្យពោលថា **ពិតណាស់ ដែលបានឈ្មោះថា រូបក្ខន្ធនឹងជាដទៃអំពីរូបមិនមាន** ។

គប្បីនាំយកពាក្យមកផ្សារភ្ជាប់គ្នាថា **រាសិភាវូបគមនេន វេទនាក្ខន្ធោទយោតិ ទស្សិតា ហោន្តិ** ប្រែថា រមែងសម្តែងថា ឈ្មោះថា វេទនាខន្ធជាដើម ដោយចូលដល់នូវភាពជាគំនរ ។ ក្នុងពាក្យថា **ដោយអំណាចសន្តតិ និងដោយអំណាចខណៈជាដើម** នេះ មិនបានពោលចែកកាល មានអតីតជាដើម ដោយអំណាចអទ្ធា និងសម័យទុក ព្រោះពោលភាពជាអតីតជាដើមរបស់វេទនា ដែលចែកដោយអំណាចសុខវេទនាជាដើម ។ ពិតហើយសុខវេទនាតែម្យ៉ាងជាអតីតជាដើម ទាក់ទងនឹងអទ្ធា និងសម័យមិនមាន ទុក្ខតែម្យ៉ាង និងអទុក្ខមសុខតែម្យ៉ាង ក៏ដូចគ្នា ចែកទុកដោយភាពជាទុក្ខ និងអទុក្ខមសុខ តាមកាយ និងតាមចិត្តជាដើម ដោយហេតុនោះ វេទនារួមគ្នា រមែងគួរដល់នូវការៈដែលគប្បីពោលដោយភាពជាអតីតជាដើម ទាក់ទងនឹងអទ្ធា និងសម័យ ព្រោះការរួមគ្នានឹងគប្បីកំណត់បានដោយអទ្ធា និងសម័យទាំងនោះ តែឯកទេសនៃវេទនា កាលនឹងកាន់យករមែងគួរដល់នូវការកំណត់ដោយសន្តតិ និង

ខណៈ ព្រោះកំណត់យកយ៉ាងនោះហើយ ទើបគប្បីកាន់យកបាន ។

តែក្នុងបណ្ដាអរូបធម៌ទាំងឡាយ មានសុខជាដើម ក្នុងសន្តតិដូចគ្នា គប្បីចែកដោយប្រភេទមិនមែនតិច ប្រភេទណាដែលកាន់យកដោយភាពជាធម៌ ដែលគប្បីកំណត់បាន វេទនាដែលប្រព្រឹត្តទៅក្នុងទ្វារ និងអារម្មណ៍ ដែលប្រកបដោយសុខជាដើមនោះ និងដែលប្រព្រឹត្តទៅប្រកបដោយអារម្មណ៍តែម្យ៉ាង ដែលញ៉ាំងសុខជាដើមនោះឲ្យកើតឡើងដោយមិនដាច់ខ្សែ ដែលជាតួកំណត់ប្រភេទនោះ មានប្រការដូចប្រាកដហើយ រមែងគួរជាសន្តតិ ព្រោះដូច្នោះ ទើបលោកកំណត់កាន់យកដោយសភាវៈដែលកំណត់បានមិនពាល់ត្រូវប្រភេទយ៉ាងដទៃរបស់វេទនានោះ ន័យម្យ៉ាងទៀត អរូបធម៌មានប្រក្រតីប្រព្រឹត្តទៅរហ័ស រមែងគួរដល់នូវការកំណត់ដោយការកំណត់គឺការផ្លាស់ប្ដូរនោះឯង ព្រោះដូច្នោះ ទើបលោកពោលការកំណត់ទាក់ទងនឹងសន្តតិ និងខណៈទុកតែម្យ៉ាង ។ វេទនាដែលប្រកបដោយសទ្ធាជាដើម ដែលប្រព្រឹត្តទៅដល់បុគ្គលដែលមើលនូវព្រះពុទ្ធរូប ដែលស្ដាប់ធម៌រហូតមួយថ្ងៃ ដែលប្រព្រឹត្តទៅដោយប្រកបជាមួយអារម្មណ៍តែមួយ ចាត់ជា **បច្ចុប្បន្ន** ។ លោកអាចារ្យសម្ដែងន័យ ដែលពោលទុកដោយអំណាចកិច្ចដែលជាហេតុប្បច្ច័យដោយពាក្យនេះថា **វេទនា ដែលជាខាងដើម ខាងចុង និងកណ្ដាល** ។

ភាពជាវេទនាដែលមានការឧស្សាហ៍ គឺមានការខ្នះខ្នែង និងមានវិបាកទូទៅជាមួយវេទនាទាំង ៣ មានកុសលវេទនាជាដើម ព្រោះដូច្នោះ លោកអាចារ្យមានបំណងនឹងសម្ដែងវេទនាដែលមិនទូទៅប៉ុណ្ណោះ ទើបពោលពាក្យជាដើមថា **ព្រោះជាហេតុ**

ធ្វើកម្មដែលមានទោស ។ក្នុងពាក្យនោះ ពាក្យថា **ព្រោះជាហេតុធ្វើកម្មដែលមានទោស** គឺព្រោះជានិមិត្តនៃការធ្វើកម្ម ដែលបណ្ឌិតតិះដៀល មានបាណាតិបាតជាដើម ។ ពាក្យថា **ព្រោះមានការក្តៅក្រហាយដោយកិលេស** គឺព្រោះមានការក្រវល់ក្រវាយដោយការក្តៅរោលរាលព្រោះកិលេស ។ **គ្រោតគ្រាតជាង** កុសលវេទនា ដែលមានសភាពចូលទៅស្ងប់ហើយ ។ពាក្យថា **ព្រោះមានសេចក្តីព្យាយាម** គឺព្រោះមានភាពឧស្សាហ៍ ។ ដោយហេតុនោះ វិបាករបស់វេទនានោះ ដែលប្រព្រឹត្តទៅគប្បីមានដោយប្រការណា លោកអាចារ្យកាលនឹងពោលការប្រព្រឹត្តទៅដោយប្រការនោះ ទើបពោលភាពដែលវេទនានោះគួរដល់ការញ៉ាំងវិបាក ឲ្យកើតឡើង ។ ពាក្យថា **ព្រោះមានការឧស្សាហ៍** គឺព្រោះមានសមត្ថភាព ដោយហេតុនោះ ទើបលោកអាចារ្យពោលភាពដែលវេទនាមានភាពអាចក្នុងការញ៉ាំងវិបាកឲ្យកើតឡើង ។ បទថា **សវិបាកតោ** ប្រែថា ព្រោះមានវិបាក ដោយហេតុនោះ លោកអាចារ្យពោលដល់ភាពកើតឡើងនៃវិបាករបស់វេទនានោះ ដោយការព្រមព្រៀងនៃបច្ច័យដទៃ ។ ដោយបទទាំង ៣ លោកសម្តែងដល់ភាពដែលវេទនា មានវិបាកជាធម្មតានោះឯង ។ មយ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងបទទាំង ៣ នេះថា ឈ្មោះថា មានភាពឧស្សាហ៍ ក៏ព្រោះមានការខ្នះខ្នែងក្នុងកម្មមានកាយកម្មជាដើម ឈ្មោះថា **ព្រោះមានភាពឧស្សាហ៍** ដោយអំណាចឧស្សាហ៍នៃជវន ឈ្មោះថា **ព្រោះមានវិបាក** ដោយអំណាចភាពជាវិបាក ដោយអាចធ្វើវិបាកឲ្យកើតឡើង ។ កិរិយាសូម្បីមិនធ្វើវិបាកឲ្យកើតឡើង ក៏នៅមានភាពឧស្សាហ៍ និងមានភាពខ្នះខ្នែងនោះឯង ដូចកុសល ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា ព្រោះ

**មានវិបាក** ដូច្នេះនោះឯង ក្នុងភាវៈនៃវេទនាដែលជាកិរិយាព្យាកតៈ ដោយមិនអាស្រ័យធម៌ទាំង ២ នោះ ។ ពាក្យថា **ព្រោះមានការលំបាក** គឺព្រោះមានទុក្ខដោយទុក្ខព្រោះកិលេស ។ ពាក្យថា **ដោយបរិយាយផ្សេងអំពីដែលពោលហើយ** គឺដោយខុសអំពីបរិយាយដែលបានពោលទុកហើយ ក្នុងវេទនាដែលជាអកុសលយ៉ាងនេះថា មានការប្រព្រឹត្តទៅស្ងប់ ព្រោះជាហេតុនៃការធ្វើកម្មដែលមិនមានទោស ព្រោះមិនមានភាពក្តៅក្រហាយព្រោះកិលេស និងព្រោះមិនមានភាពលំបាក ។បទថា **យថាយោគំ** ប្រែថាសមគួរដល់ការប្រកប ។ អធិប្បាយថា ក្នុងបណ្តាហេតុទាំង ៣ យ៉ាង ហេតុណាមួយសមគួរដល់វេទនាណាមួយ ហេតុនោះៗ ក៏សមគួរដល់វេទនានោះៗ ។ឯកុសលវេទនានិងអកុសលវេទនា **គ្រោតគ្រាតជាង** ដោយហេតុទាំង ៣ ជាងវេទនាដែលមានវិបាកជាអព្យាកតៈ ។ ព្រោះមានវិបាក ឬព្រោះមានភាពខ្នះខ្នែង និងភាពឧស្សាហ៍ដែលពិសេស ដោយភាពជាវេទនាដែលមានវិបាកនៃវេទនា ដែលជាអព្យាកតៈ ដូច្នេះ ។ពាក្យថា **ដោយបរិយាយផ្សេងអំពីបរិយាយដែលបានពោលទុកហើយ** គឺដោយខុសអំពីបរិយាយដែលពោលទុកហើយ ក្នុងកុសលវេទនា និងអកុសលវេទនាយ៉ាងនេះគឺវេទនាដែលជាវិបាកអព្យាកតៈ ល្អិតជាងវេទនាដែលជាកុសល និងអកុសលទាំងនោះព្រោះមិនមានការព្យាយាម ព្រោះមិនមានភាពឧស្សាហ៍ និងព្រោះមិនមានវិបាក ។វេទនាដែលជាកិរិយា អព្យាកតៈល្អិត ព្រោះមិនមានវិបាក ឬព្រោះមានសេចក្តីព្យាយាមនិងមានភាពឧស្សាហ៍វិសេស ដោយជាវេទនាដែលមិនមានវិបាក ។ ពិតណាស់ វិបាកទាំងឡាយដែលត្រូវកម្លាំងនៃកម្មបន្សាត់ទៅហើយ និងមានរូបប្រៀបជាមួយកម្ម ឈ្មោះ

ថា មិនមានឧស្សាហ៍ ព្រោះវៀរចាកភាពព្យាយាមដោយកម្ម មានកាយកម្មជាដើម និងដោយកិរិយាទាំងឡាយដែលមានឧស្សាហ៍ ក៏មិនមានវិបាកជាធម្មតា ។ សភាវធម៌ដែលមានវិបាកជាធម្មតាទាំងឡាយ ដែលធូន់ដូចស្ត្រីដែលមានគភ៌ ។

បទថា **និរស្សាទតោ** ប្រែថា ព្រោះមិនមានអស្សាទ គឺបដិសេធសុខ ។ ពាក្យថា **ព្រោះមានការប្រព្រឹត្តទៅដោយភាពរំកិលខ្លួន** បានដល់ ព្រោះមានការនទៀលចេញទៅ អធិប្បាយថា ព្រោះមិនចូលទៅរកភាពស្ងប់ ។ ពាក្យថា **ព្រោះសង្កត់សង្កិនយក** បានដល់ ព្រោះគ្របសង្កត់ ។ ភាពដែលសុខវេទនាមិនមានភាពជាកណ្តាលៗ ឧបេក្ខាវេទនាមិនមានភាពសម្រាន្ត ។ ចំណែកសេចក្តីស្ងប់ជាដើម បានតាំងនៅក្នុងសុខវេទនា និងឧបេក្ខាវេទនាទាំងអស់ ព្រោះដូច្នោះ ទើបលោកពោលថា **តាមសមគួរ** ។ ពាក្យថា **ព្រោះការប្រាកដ** បានដល់ ព្រោះភាពជាវេទនាដែលជាក់ច្បាស់នូវហេតុដែលឃើញហើយ ក៏នឹងត្រូវដឹងថា បានទទួលសុខ ឬបានទទួលទុក្ខ ។ បទថា **សា យោគ អទុក្ខមសុខា វេទនា** ប្រែថា វេទនាដែលមិនទុក្ខមិនសុខនោះឯង ។

ក្នុងអធិការនេះ ដោយស័ព្ទថា **លោកដែលមិនបានចូលសមាបត្តិ និងលោកដែលចូលសមាបត្តិ** គប្បីជ្រាបថា លោកពោលភាពដែលវេទនាជាវេទនាគ្រោតគ្រាត និងល្អិត ដោយអំណាចភូមិក៏មាន ។ **ឥតរា យោគ សមាបន្នស្ស វេទនា** ប្រែថា វេទនារបស់អ្នកចូលសមាបត្តិក្រៅអំពីនេះ ។

បទថា **ឱឃនិយតោ** សេចក្តីថា ព្រោះគប្បីចងឱឃៈ ធ្វើឲ្យជាអារម្មណ៍ ដោយឈានកន្ទួង ។ ម្យ៉ាងទៀត សូម្បីក្នុងពាក្យថា **យោគនិយតោ** និង **គន្ថនិយតោ** នេះ

**គន្ថា** នោះឯងជា **គន្ថនិយំ** ធម្មជាតិឧបការៈដល់គន្ថនៈនោះ ដោយសម្ពន្ធគ្នាជាមួយការៈដែលជាអារម្មណ៍ ដូច្នោះ ទើបឈ្មោះថា **គន្ថនិយំ** ។ គប្បីជ្រាប **នីវរណិយំ** និង **ឧបាទានិយំ** យ៉ាងនេះ ។ វេទនាដែលប្រកបក្នុងសង្កិលេសឬគួរដល់នូវសង្កិលេស ព្រោះដូច្នោះ ទើបឈ្មោះថា **សង្កិលេសិកា** ប្រែថា ប្រកបក្នុងសង្កិលេស ឬគួរដល់ការសៅហ្មង ។ **សា យោគ អនាសវា** ប្រែថា វេទនាដែលមិនមានអាសវៈនោះ ។

បទថា **តត្ថ យោគ យថាវុត្តាយ ឱឡារិកសុខុមតាយ** ប្រែថា ក្នុងភាពជាវេទនាគ្រោតគ្រាត និងល្អិត តាមដែលពោលនោះ ។ ពាក្យថា **លាយឡំគ្នា** គឺភាពប្របល់គ្នា ។ បណ្ឌិតគប្បីកាន់យកដោយប្រការដែលនឹងមិនមានទោសនៃការដល់នូវភាពដែលវេទនាសូម្បីដែលបានពោលទុកថា **ជាវេទនាគ្រោតគ្រាត** និង **ជាវេទនាល្អិត** ជាវេទនាល្អិត និងគ្រោតគ្រាតទៀត ដោយជាតិជាដើម ។ ពាក្យថា **វុត្តញ្ចេតំ** ជាដើម លោកអាចារ្យពោលទុកដើម្បីសម្តែងភាពដែលវេទនាល្អិតដោយជាតិជាដើមជាវេទនាគ្រោតគ្រាតដោយសភាវៈ បុគ្គល និងលោកិយតាមព្រះបាលី ។ ក្នុងពាក្យថា **ឯវំ សុខាទយោបិ** នេះ អកុសលវេទនា **គ្រោតគ្រាតដោយជាតិ ល្អិតដោយសភាវៈ** ។ សុខវេទនាដែលសហគតៈដោយកុសលជ្ឈាន គ្រោតគ្រាតដោយជាតិ គប្បីប្រកបដោយពាក្យជាដើមយ៉ាងនេះថា ល្អិតដោយបុគ្គល ព្រោះអធិប្បាយថា ជាវេទនារបស់លោកអ្នកចូលសមាបត្តិ ដោយបទថា **ន បរាមសិតព្វា** នេះ គឺគប្បីកាន់យកចំណែកទាំង ៤ មានជាតិជាដើម មិនឲ្យលាយឡំដោយគ្នានឹងគ្នានោះឯង ។ លោកអាចារ្យរមែងសម្តែងថា ការលាយឡំនូវគ្នានឹងគ្នាយ៉ាងនេះ មិនមែនជាទៅឡើយ ។ គប្បីសម្តែង

សូម្បីដោយមាតិកាដែលជាកុសលវេទនា និងអកុសលវេទនា ដូចគ្នានឹងមាតិកាដែលជាអព្យាកតវេទនា និងគប្បីសម្តែងដោយមាតិកាដទៃ ដែលជាសភាវៈជាដើម ដូចគ្នានឹងដោយមាតិកា គឺជាតិ ព្រោះដូច្នោះ ទើបសេចក្តីនេះលោកអាចារ្យសម្តែងតទៅថា **ក្នុងវេទនាទាំងអស់ក៏ដូចន័យនេះនោះឯង** ។

ឥឡូវនេះ លោកអាចារ្យមានបំណងនឹងសម្តែងដល់វេទនាទាំងឡាយ មានអកុសលវេទនាជាដើម ជាវេទនាគ្រោតគ្រាត និងល្អិត ដោយប្រៀបធៀបគ្នានឹងគ្នា សូម្បីក្នុងចំណែករបស់បកិណ្ណកៈមានជាតិជាដើម ទើបផ្តើមពាក្យថា **ប្រការមួយទៀត** ដូច្នេះជាដើម ។ ដោយពាក្យថា **ព្រោះដុតទីអាស្រ័យ** នេះ លោកអាចារ្យសម្តែងការប្រព្រឹត្តទៅដែលគ្រោតគ្រាត ដែលប្រាកដរបស់វេទនាដែលសហគតៈដោយទោសៈ ។ ពាក្យថា **និយត** គឺជាវេទនាទៀង ដោយមិច្ឆត្តនិយាមដែលដល់នូវភាពជាអនន្តរិយកម្ម **ជាវេទនាកប្បដ្ឋិតិក** ព្រោះជាវេទនាតាំងនៅបានរហូតមួយកប្ប ដូចគ្នានឹងវេទនារបស់ភិក្ខុទេវទត្តជាដើម ។ **ជាអសង្ខារិក** ឈ្មោះថា **ជាវេទនាគ្រោតគ្រាត** ព្រោះមានភាពខ្លាំងក្លាដោយសភាវៈ ។ **ជាទិដ្ឋិសម្បយុត្ត** ឈ្មោះថា **ជាវេទនាគ្រោតគ្រាត** ព្រោះភាពជាវេទនាដែលមានទោសច្រើន ។ វេទនាដែលជាទិដ្ឋិសម្បយុត្តនោះ គឺទាំង ៣ យ៉ាង បានដល់ **ដែលជានិយត ជាវេទនាគ្រោតគ្រាត** ព្រោះជាវេទនាគ្រោតគ្រាតនោះ **ទើបជាកប្បដ្ឋិតិក** មានការតាំងនៅអស់មួយកប្ប ព្រោះមានការតាំងនៅអស់មួយកប្បនោះ **ទើបជាអសង្ខារិក** លោកពោលរួមគ្នាទុក ព្រោះមានន័យបានពោលទុកហើយក្នុងខាងដើមបណ្ឌិតគប្បីប្រកបជាចំណែកៗទៅនោះឯង។ដោយហេតុ នោះទើបលោកអាចារ្យពោលថា **វេទនាក្រៅអំពីនេះទើបជាវេទនាល្អិត** ។ ពាក្យថា **ដោយមិនផ្សេងគ្នា** គឺដោយមិនបែកផ្សេងគ្នាថា ជាវេទនាដែលសហគតៈដោយទោសៈ

ជាវេទនាដែលសហគតៈដោយលោភៈ ។ **វេទនាដែលជាអកុសលមានវិបាកច្រើន ជាវេទនាគ្រោតគ្រាត** ព្រោះមានទោសៈ ក្រាស់ណែន ។ **វេទនាដែលជាកុសល មានវិបាកតិច** ក៏ជាវេទនាគ្រោតគ្រាតដូចគ្នា ។ វេទនាដែលជាអកុសល **មានវិបាកតិច ជាវេទនាល្អិត** ព្រោះមានទោសៈតិច ។ វេទនាដែលជាកុសល **មានវិបាកច្រើន** ក៏ជាវេទនាល្អិតដូចគ្នា ។

វេទនាទាំងឡាយ មានកាមាវចរវេទនាជាដើម គ្រោតគ្រាត និងល្អិត ព្រោះភាពជាវត្ថុនៃទិកត្តិ ដែលគ្រោតគ្រាត និងល្អិត ចំណែកលោកុត្តរវេទនាល្អិត ដោយចំណែកមួយប៉ុណ្ណោះ ។ សូម្បីក្នុងលោកុត្តរវេទនាប៉ុណ្ណោះ នឹងពោលវិភាគខាងមុខ ។ ពាក្យថា **វេទនាដែលជាភាវនាមយ** ភាពផ្សេងគ្នានៃវេទនាដែលជាទានមយៈ និងសីលមយៈ ជាមួយនឹងភាពផ្សេងគ្នានឹងវេទនាដែលជាភាវនាមយៈ គប្បីជ្រាបថា លោកសម្តែងហើយដោយន័យ ។ ក្នុងវេលាដែលវេទនាជាភាវនាមយៈ មានភាពស្ងាត់ និងមានកម្លាំងជាដើម គ្រាខ្លះ មនសិការក៏មានបានដោយចិត្ត ដែលជាញាណវិប្បយុត្ត ព្រោះដូច្នោះ ទើបលោកពោលថា **សូម្បីវេទនាដែលជាភាវនាមយៈក៏ជាទុហេតុកៈ** ។ ក្នុងពាក្យថា **ក្នុងវេទនាដែលជាវិបាក** និង **កិរិយាក្នុងភូមិនោះៗ** នេះ គួរយល់ដោយន័យថា **វេទនាដែលជាកាមាវចរវិបាក ជាវេទនាគ្រោតគ្រាត វេទនាដែលជារូបាវចរៈ ជាវេទនាល្អិត** ដូច្នេះជាដើម ទៅរហូតដល់អរហត្តផល ។ គប្បីយល់ដោយន័យថា **វេទនាដែលជាកាមាវចរកិរិយា ជាវេទនាគ្រោតគ្រាត វេទនាដែលជារូបាវចរកិរិយា ជាវេទនាល្អិត** ជាដើម ដោយន័យថា វេទនាដែលជាកាមាវចរៈ ដែលប្រព្រឹត្តទៅដោយការឲ្យទាន ជាវេទនាគ្រោតគ្រាត ដែលប្រព្រឹត្តទៅដោយការរក្សាសីល ជាវេទនាល្អិត ដូច្នេះជាដើម ទៅរហូតដល់វេទនា ដែលជានេវសញ្ញានាសញ្ញាយតនៈ ។ លោកអាចារ្យមានបំណងនឹងសម្តែងថា ដូចជាក្នុងចំណែកនៃជាតិ មានការចែកនេះ យ៉ាងណា

សូម្បីក្នុងចំណែកនៃសភាវៈជាដើម ក៏មានការចែកដូចគ្នា ទើបពោលថា **ទុក្ខាទិ** ជាដើម ។

លោកអាចារ្យពោលពាក្យថា **សូម្បីដោយអំណាចឱកាសនោះ** ដូច្នេះជាដើម ព្រោះអធិប្បាយថា លោកបានពោលការចែកទាំងអស់នេះដែលអាស្រ័យលក្ខណៈ ។ ដោយ **បិ**-ស័ព្ទ ក្នុងពាក្យថា **សុខាបិ** ប្រែថា សូម្បីសេចក្តីសុខ លោកអាចារ្យរួមយកអទុក្ខមសុខទុកផង ។ បទថា **សព្វត្ថ** ប៉ុនគ្នានឹង **សព្វាសុ យោគ ភូមីសុ** ប្រែថា ក្នុងភូមិទាំងអស់ ។ ពាក្យថា **តាមសមគួរ** បានដល់វេទនាណាមួយ បាននៅក្នុងភូមិណាមួយ តាមសមគួរដល់វេទនានោះៗ ក្នុងភូមិនោះៗ ។ ពាក្យថា **ដោយអំណាចនៃវត្ថុ** សេចក្តីថា វេទនាប្រារព្ធវត្ថុណាប្រព្រឹត្តទៅដោយអំណាចនៃវត្ថុនោះ ។ ពាក្យថា **មានវត្ថុអាក្រក់** សេចក្តីថា វេទនារបស់អ្នកធ្វើវត្ថុអាក្រក់ឲ្យជាអារម្មណ៍បរិភោគថ្លៅ **ជាវេទនាគ្រោតគ្រាត** ព្រោះមានវត្ថុអាក្រក់ ។ វេទនាអ្នកបរិភោគស្រូវសាលី សាច់និងបាយ **ជាវេទនាល្អិត** ព្រោះមានវត្ថុប្រណីត ។ លោកអាចារ្យប្រារព្ធដល់គតិនៃព្រះបាលីទាំងអស់ថា **ដោយន័យមានពាក្យពោលដូច្នេះជាដើម** ។ ភាពដែលវេទនាមានចំណែកមិនស្មើគ្នា ដោយជាតិជាដើម ឈ្មោះថា **មានភាពជាវិសភាគគ្នា** ។ ភាពដែលវេទនាមានកិច្ចមិនដូចគ្នា ដោយជាវេទនាមានទុក្ខជាវិបាកជាដើម ឈ្មោះថា **ការមិនលាយឡំគ្នា** គឺមិនប្រកបជាមួយគ្នា ។ បើគប្បីកើតវេទនាក៏នឹងនៅជិតគ្នាដោយបរិយាយផ្ទុយអំពីវេទនាដែលនៅឆ្ងាយគ្នា ព្រោះដូច្នោះ ទើបត្រូវជាវេទនាដែលលាយឡំគ្នា ជាវេទនាដែលជិតគ្នា តែនឹងមានការប្រកបនៃវេទនាជាមួយវេទនាក៏ទេ ។ ហើយក្នុង

ការពណ៌នាសន្តិកបទ លោកអាចារ្យពោលតទៅថា **ដោយសភាគគ្នា និងដោយស្មើគ្នា** ព្រោះដូច្នោះ គប្បីជ្រាបសេចក្ដីតាមន័យដែលពោលហើយនោះឯង ។ ភាពជាវេទនាដែលមានសភាវៈមិនដូចគ្នា ឈ្មោះថា **ការមិនស្មើគ្នា** ។ ពាក្យថា **ក្នុងវារៈទាំងពួង** បានដល់ ក្នុងវារៈទាំងពួងដែលនឹងគប្បីពោលតាមគន្លងនៃពាក្យមានន័យបានពោលទុកហើយ ក្នុងប្រភេទវេទនាគ្រោតគ្រាត និងល្អិត ។ ភាពជាវេទនាមានចំណែកស្មើគ្នាដោយជាតិជាដើម ឈ្មោះថា **ភាពជាសភាគគ្នា** ចំណែកភាពជាវេទនាមានសភាវៈដូចគ្នាដោយភាពជាវេទនា ដែលមានវិបាកជាទុក្ខជាដើម ឈ្មោះថា **ភាពស្មើគ្នា** ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ឯវេទនាដែលជាអកុសលជាវេទនាជិត ។បេ។** ដូច្នេះ ។

បទថា **ឯតំ យោគ ឯវំ អតីតាទិវិភាគេ វិត្ថារកថាមុខំ** ប្រែថា កថាមុខ ដោយពិស្ដារ ក្នុងវិភាគនៃចំណែកដែលជាអតីតជាដើមយ៉ាងនេះ ។

ពណ៌នាកថាដោយពិស្ដារ

ក្នុងវិភាគ

នៃវេទនា មានវេទនាចំណែកជាអតីតជាដើម

នៃវេទនាខន្ធ ចប់ហើយ ដោយប្រការ

ដូច្នេះ

# វិសុទ្ធិមគ្គ

## ន័យសម្រាប់វិនិច្ឆ័យខន្ធ ៦ ប្រការ

*កាលជ្រាបយ៉ាងនេះហើយ ដើម្បីជំនាញនៃការដឹងក្នុងខន្ធទាំងឡាយនោះឯង បុគ្គលអ្នកមានបញ្ញា គប្បីជ្រាបន័យសម្រាប់វិនិច្ឆ័យដោយប្រពៃ គឺដោយលំដាប់ ដោយប្លែកគ្នា ដោយមិនខ្សោយ មិនខ្លាំង ដោយឧបមាដែលជាវត្ថុគប្បីឃើញដោយអាការ ២ យ៉ាង និងដោយភាពសម្រេច ជាប្រយោជន៍ដល់អ្នកឃើញយ៉ាងនោះ ដូចតទៅ ។*

## ន័យដោយលំដាប់

*ក្នុងន័យ ៦ ប្រការនោះ ក្នុងពាក្យថា ដោយលំដាប់នេះ មានវិនិច្ឆ័យថា លំដាប់មានច្រើនយ៉ាង គឺលំដាប់នៃការកើតឡើង លំដាប់នៃការលះ លំដាប់នៃការបដិបត្តិ លំដាប់នៃភូមិ លំដាប់នៃការសម្តែង ក្នុងលំដាប់ ៥ យ៉ាងនោះ លំដាប់ថា រូប ( កើត ) ដែលជាកលលៈមុន បន្ទាប់ពីកលលៈទៅ ជាអព្ពុទៈ... ដូច្នេះឈ្មោះថា លំដាប់ការកើតឡើង លំដាប់ថា ធម៌ទាំងឡាយដែលគប្បីលះ ដោយទស្សនៈ (គឺសោតាបត្តិមគ្គ) ធម៌ទាំងឡាយដែលគប្បីលះដោយភាវនា ( គឺសកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ )... ដូច្នេះ ឈ្មោះថា លំដាប់នៃការលះ លំដាប់ថា សីលវិសុទ្ធិ ចិត្តវិសុទ្ធិ... ដូច្នេះ ឈ្មោះថា លំដាប់នៃការបដិបត្តិ លំដាប់ថា ធម៌ទាំងឡាយដែលជាកាមាវចរៈ ធម៌ទាំងឡាយដែលជារូបាវចរៈ ដូច្នេះ ឈ្មោះថា លំដាប់នៃភូមិ លំដាប់ថា សតិប្បដ្ឋាន ៤ សម្មប្បធាន ៤... ឬថា ( ទ្រង់សម្តែង ) ទានកថា សីលកថា... ដូច្នេះ ឈ្មោះថា លំដាប់នៃការសម្តែង ។*

ក្នុងលំដាប់ទាំងនោះ មុនដំបូង លំដាប់នៃការកើត មិនមែនបានក្នុងទីនេះ ព្រោះខន្ធទាំងឡាយមិនបានកើតឡើង ដោយការកំណត់មុនក្រោយ ដូចកលលរូបជាដើម លំដាប់នៃការលះ ក៏ប្រើមិនបាន ព្រោះខន្ធដែលជាកុសល និងអព្យាកតៈមិនមែនជាវត្ថុដែលនឹងគប្បីលះ លំដាប់នៃការបដិបត្តិក៏ប្រើមិនបាន ព្រោះខន្ធទាំងឡាយ ដែលជាអកុសល មិនមែនជាវត្ថុដែលគប្បីបដិបត្តិ លំដាប់នៃភូមិក៏ប្រើមិនបាន ព្រោះខន្ធ ៤ មានវេទនាជាដើម ជាវត្ថុដែលទាក់ទងក្នុងភូមិទាំង ៤ តែលំដាប់នៃការសម្ដែងប្រើបាន ដោយព្រះមានព្រះភាគ ទ្រង់សង្ឃឹមប្រយោជន៍ តថាគតនឹងប្រោសវេនេយ្យជនអ្នកចូលទៅក្នុងអត្តគាហៈ (ការប្រកាន់ថា ជាតួខ្លួន) ក្នុងខន្ធទាំង ៥ ដោយមិនញែកគ្នា ឲ្យផុតចាកអត្តគាហៈផង ឲ្យឃើញការបែកធ្លាយទៅ ទើបទ្រង់សម្ដែងរូបក្ខន្ធដែលជាចំណែកគ្រោតគ្រាត ជាវិស័យសូម្បីចក្ខុទ្វារជាដើមមុន ដើម្បីឲ្យវេនេយ្យជននោះកំណត់ចាប់យកបានងាយ តពីនោះទៅ ទើបទ្រង់សម្ដែងវេទនាដែលជាចំណែកនៃការសោយ ក្នុងរូបដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា ទ្រង់សម្ដែងសញ្ញាដែលជាចំណែកការចាំអាការនៃអារម្មណ៍របស់វេទនា ដោយន័យតាមដែលពោលថា ដឹងវត្ថុណា ចាំវត្ថុនោះ ដូច្នេះ ទ្រង់សម្ដែងសង្ខារដែលជាចំណែកការតាក់តែង (នឹកគិត) ទៅតាមអំណាចនៃសញ្ញា និងទ្រង់សម្ដែងវិញ្ញាណដែលជាទីអាស្រ័យនៃខន្ធ ៤ មានវេទនាជាដើមនោះ និងអធិបតីនៃខន្ធ ៤ នោះផង ។

## ន័យសម្រាប់វិនិច្ឆ័យដោយលំដាប់

គប្បីជ្រាបដោយន័យដូចដែលពោលមកនេះជាប្រការដំបូង ។

## ន័យដោយការប្លែកគ្នា

ពាក្យថា ដោយការប្លែកគ្នា គឺដោយការប្លែកគ្នានៃខន្ធទាំងឡាយ និងនៃឧបាទាន

ខន្ធទាំងឡាយ ក៏ការប្លែកគ្នានៃខន្ធ និងឧបាទានក្ខន្ធទាំងឡាយ គឺអ្វី ? គឺក្នុងខន្ធ និងឧបាទានក្ខន្ធទាំង ២ នោះ ប៉ុន្តែខន្ធទាំងឡាយ ព្រះមានព្រះភាគទ្រង់ត្រាស់ទុក មិនមានអ្វីប្លែកទេ ចំណែកឧបាទានក្ខន្ធត្រាស់ទុកប្លែកដោយភាពជាខន្ធដែលប្រព្រឹត្តទៅជាមួយអាសវៈ និងដែលជាទីតាំងនៃឧបាទាន ដូចត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងខន្ធ ៥ និងឧបាទានក្ខន្ធ ៥ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្ដាប់រឿងខន្ធនោះ ម្នាលភិក្ខុទាំងឡាយ គឺខន្ធ ៥ ដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ រូបគ្រប់យ៉ាងទាំងដែលជាអតីត អនាគត និងបច្ចុប្បន្ន ។បេ។ នៅក្នុងទីឆ្ងាយ ឬនៅក្នុងទីជិតក៏ដោយ គំនររូបនេះហៅថា រូបក្ខន្ធ វេទនាគ្រប់យ៉ាង ទាំងដែលជាអតីត អនាគត និងបច្ចុប្បន្ន ។បេ។ គំនរវេទនានេះហៅថា វេទនាខន្ធ សញ្ញាគ្រប់យ៉ាង ទាំងដែលជាអតីត អនាគត និងបច្ចុប្បន្ន ។បេ។ គំនរសញ្ញានេះ ហៅថា សញ្ញាខន្ធ សង្ខារគ្រប់យ៉ាង ទាំងដែលជាអតីត អនាគត និងបច្ចុប្បន្ន ។បេ។ គំនរសង្ខារនេះ ហៅថា សង្ខារក្ខន្ធ វិញ្ញាណគ្រប់យ៉ាង ទាំងដែលជាអតីត អនាគត និងបច្ចុប្បន្ន ។បេ។ គំនរវិញ្ញាណនេះហៅថា វិញ្ញាណក្ខន្ធ ម្នាលភិក្ខុទាំងឡាយ គំនរទាំងនេះហៅថា ខន្ធ ៥ ។

ម្នាលភិក្ខុទាំងឡាយ ឧបាទានក្ខន្ធ ៥ ដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ រូបគ្រប់យ៉ាង ទាំងដែលជាអតីត អនាគត និងបច្ចុប្បន្ន ។បេ។ នៅក្នុងទីឆ្ងាយ ឬនៅក្នុងទីជិតក៏ដោយ ប្រព្រឹត្តទៅជាមួយអាសវៈ ជាទីតាំងនៃឧបាទាន នេះហៅថា រូបូបាទានក្ខន្ធ វេទនាគ្រប់យ៉ាង ទាំងដែលជាអតីត អនាគត និងបច្ចុប្បន្ន ។បេ។ ដែលប្រព្រឹត្តទៅជាមួយអាសវៈ ជាទីតាំងនៃឧបាទាន នេះហៅថា វេទនូបាទានក្ខន្ធ សញ្ញាគ្រប់យ៉ាង ។បេ។ ប្រព្រឹត្តទៅជាមួយអាសវៈ ជាទីតាំងនៃឧបាទាន នេះហៅថា សញ្ញូបាទានក្ខន្ធ សង្ខារគ្រប់យ៉ាង ។បេ។ ប្រព្រឹត្តទៅជាមួយអាសវៈ ជាទីតាំងនៃឧបាទាន នេះហៅថា សង្ខារូបាទានក្ខន្ធ វិញ្ញាណគ្រប់យ៉ាង ។បេ។ ប្រព្រឹត្តទៅជាមួយអាសវៈ ជាទីតាំង

នៃឧបាទាន នេះហៅថា វិញ្ញាណូបាទានក្ខន្ធ ម្នាលភិក្ខុទាំងឡាយ ទាំងនេះហៅថា ឧបាទានក្ខន្ធ ៥ ដូច្នេះ ។

ក្នុងខន្ធទាំងឡាយនេះ ខន្ធ ៤ មានវេទនាជាដើម ជាអនាសវៈខ្លះក៏មាន ជាសាសវៈខ្លះក៏មាន យ៉ាងណា រូបមិនមែនដូច្នោះឡើយ តែព្រោះហេតុដែលរូបនោះជាខន្ធក៏ត្រូវ ដោយអត្ថថា ជាគំនរ ហេតុនោះ ទើបត្រាស់ទុកក្នុងពួកខន្ធ និងព្រោះរូបនោះជាឧបាទានក្ខន្ធក៏ត្រូវ ដោយអត្ថថា ជាគំនរផង ដោយអត្ថថា ជាសាសវៈផង ហេតុនោះ ទើបត្រាស់ទុកក្នុងពួកឧបាទានក្ខន្ធ ចំណែកខន្ធ ៤ មានវេទនាជាដើម ដែលជាអនាសវៈ ត្រាស់ទុកក្នុងពួកខន្ធប៉ុណ្ណោះ ដែលជាសាសវៈត្រាស់ទុកក្នុងពួកឧបាទានក្ខន្ធ ។

អត្ថក្នុងពាក្យថា ឧបាទានក្ខន្ធនេះ បណ្ឌិតគប្បីឃើញថា ខន្ធទាំងឡាយដែលជាទីគោចរនៃឧបាទាន ឈ្មោះថា ឧបាទានក្ខន្ធ ដូច្នេះចុះ ។

តែក្នុងបករណ៍វិសុទ្ធិមគ្គនេះ សំដៅយកទាំងខន្ធ ទាំងឧបាទានក្ខន្ធ ទាំងអស់រួមចូលគ្នាថាជាខន្ធ ។

## ន័យដោយមិនតិចមិនច្រើន

ពាក្យថា ដោយមិនតិចមិនច្រើន មានវិនិច្ឆ័យថា សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ខន្ធតែ ៥ ប៉ុណ្ណោះ មិនតិចមិនច្រើន ? ឆ្លើយថា ព្រោះទ្រង់សង្គ្រោះសង្ខតធម៌ទាំងពួងចូលគ្នា ព្រោះជាសភាគគ្នា ១ ព្រោះវត្ថុនៃការប្រកាន់ថាជាខ្លួន ជារបស់ខ្លួន ១ ព្រោះរួមយកធម៌ដែលចាត់ជាខន្ធដទៃៗ ទុកក្នុងនោះបាន ១ ។

ក្នុងបណ្តាសង្ខតធម៌ទាំងឡាយ ដែលមានប្រភេទជាអនេក កាលសង្គ្រោះចូលតាមដែលជាសភាគគ្នា រូបចាត់ជាខន្ធ ១ ដែលសង្គ្រោះយកធម៌ជាសភាគជាមួយរូបចូលគ្នាផង វេទនាក៏ចាត់ជាខន្ធ ១ ដោយការសង្គ្រោះយកធម៌ ដែលជាសភាគជាមួយ

វេទនាចូលជាមួយគ្នាក្នុងខន្ធដ៏សេស មានសញ្ញាជាដើម ក៏ន័យនេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ខន្ធតែ ៥ ប៉ុណ្ណោះ ព្រោះទ្រង់សង្គ្រោះសង្ខតធម៌ទាំងពួងចូលគ្នាតាមដែលជាសភាគគ្នា ។

ម្យ៉ាងទៀត វត្ថុនៃការប្រកាន់ថា ជាខ្លួន ជារបស់ខ្លួននោះ មានប៉ុណ្ណោះនោះ គឺមាន ៥ មានរូបជាដើម សមដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ កាលរូបនេះ មានការឃើញ (ខុស) អាស្រ័យរូប ប្រកាន់រូប ទើបកើតឡើងយ៉ាងនេះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ កាលវេទនា... កាលសញ្ញា... កាលសង្ខារ... កាលវិញ្ញាណមាន ការឃើញខុសអាស្រ័យវេទនា... សញ្ញា... សង្ខារ... វិញ្ញាណ ប្រកាន់វេទនា... សញ្ញា... សង្ខារ... វិញ្ញាណទើបកើតឡើង យ៉ាងនេះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់តែខន្ធ ៥ ប៉ុណ្ណោះ ព្រោះវត្ថុនៃការប្រកាន់ថា ជាខ្លួន ជារបស់ខ្លួន មានប៉ុណ្ណោះ ប្រការ ១ ។

ម្យ៉ាងទៀត ធម្មក្ខន្ធ ៥ ដទៃ មានសីលជាដើម យ៉ាងណា ព្រះមានព្រះភាគត្រាស់ទុក សូម្បីធម្មក្ខន្ធទាំងឡាយនោះ ក៏ដល់នូវការសង្គ្រោះចូលក្នុងខន្ធ ៥ នេះឯងបាន ព្រោះធម្មក្ខន្ធទាំងឡាយនោះ រាប់ចូលក្នុងសង្ខារក្ខន្ធ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់តែខន្ធ ៥ ប៉ុណ្ណោះ ព្រោះរួមយកធម៌ដែលចាត់ជាខន្ធដទៃៗ ទុកក្នុងនោះបាន ប្រការ ១ ។

ន័យសម្រាប់វិនិច្ឆ័យដោយមិនតិចមិនច្រើន គប្បីជ្រាបដូចពោលមកនេះ ។

## ន័យដោយឧបមា

វិនិច្ឆ័យក្នុងពាក្យថា ដោយឧបមា នេះ បណ្ឌិតគប្បីជ្រាបដូច្នេះថា រូបូបាទានក្ខន្ធ ប្រៀបដូចរោងព្យាបាល ព្រោះជាទីអាស្រ័យនៅនៃវិញ្ញាណូបាទានក្ខន្ធ ដែលប្រៀបដូចអ្នកជំងឺ ដែលជាវត្ថុ ( ទីតាំង ) ជាទ្វារ និងជាអារម្មណ៍នៃវិញ្ញាណនោះ វេទនូ-

បាទានក្ខន្ធប្រៀបដូចជំងឺ ព្រោះជាធម្មជាតិអាពាធ សញ្ញុបាទានក្ខន្ធ ប្រៀបដូចសមុដ្ឋាន នៃជំងឺ ព្រោះជាដែនកើតនៃវេទនា ដែលប្រកបដោយកិលេស មានរាគៈជាដើម ដោយ ជាសញ្ញា ( អកុសល ) មានកាមសញ្ញាជាអាទិ សង្ខារុបាទានក្ខន្ធប្រៀបដូចការសេព របស់គួរតម ព្រោះជាហេតុនៃជំងឺ គឺវេទនា សមដូចព្រះបាលីថា សង្ខារទាំងឡាយ រមែងតាក់តែងវេទនាដើម្បីឲ្យគង់វង់ ជាវេទនាតាមសភាវៈ ។ ន័យដូចគ្នានោះដែរ វិញ្ញាណូបាទានក្ខន្ធប្រៀបដូចអ្នកឈឺ ព្រោះមិនផុតចាកការឈឺ គឺវេទនា ដូចព្រះបាលី ថា ព្រោះអកុសលកម្មដែលបុគ្គលធ្វើទុក សន្សំទុក កាយវិញ្ញាណដែលជាវិបាក ទើប កើតឡើងជាវិញ្ញាណដែលរួមទៅ ( ប្របូកប្របល់ទៅ ) ជាមួយទុក្ខ ដូច្នេះ ។

ន័យម្យ៉ាងទៀត ឧបាទានក្ខន្ធទាំងឡាយនោះ ប្រៀបដូចគុក ការដាក់ទោស ទោស អ្នកដែលដាក់ទោស និងអ្នកទោស ដូចនឹងភាជនៈ ភោជន ម្ហូប អ្នកធ្វើម្ហូប ( គឺចុងភៅ ) និងអ្នកបរិភោគ ( ក៏បាន ) ។

ន័យសម្រាប់វិនិច្ឆ័យដោយឧបមា បណ្ឌិតជ្រាបដូចពោលមកនេះ ។

## ន័យដោយភាពជាវត្ថុគប្បីឃើញដោយអាការ ២

ពាក្យថា ដោយភាពជាវត្ថុគប្បីឃើញដោយអាការ ២ សេចក្តីថា ន័យសម្រាប់ វិនិច្ឆ័យក្នុងពាក្យនេះ បណ្ឌិតគប្បីជ្រាបដោយភាពជាវត្ថុគប្បីឃើញដោយអាការ ២ យ៉ាងនេះ គឺដោយសង្ខេប ១ ដោយពិស្តារ ១ ។ ពិតណាស់ ដោយសង្ខេប ឧបា-ទានក្ខន្ធ ៥ គប្បីឃើញដោយភាពដូចជាសត្រូវអ្នកងារដាវ ( នឹងសម្លាប់ ) តាមន័យ ដែលត្រាស់ក្នុងអាសីវិសូបមសូត្រ ដោយភាពជារបស់ធ្ងន់ តាមដែលត្រាស់ទុកក្នុង ភារសូត្រ ដោយភាពជាអ្នកសម្លាប់ តាមដែលត្រាស់ក្នុងខជ្ជនីយបរិយាយ ដោយភាព ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ជាសង្ខតៈ និងជាអ្នកសម្លាប់ តាមដែលត្រាស់ទុក ក្នុងយមកសូត្រ បើពោលដោយពិស្តារក្នុងទីនេះ រូបគប្បីឃើញដូចដុំពពុះទឹក ព្រោះ

មិនអត់ធន់ក្នុងការប្រេបាច់ វេទនាគប្បីឃើញដូចក្រពេញទឹក ព្រោះជាវត្ថុគួរជាទីត្រេកអរ (គឺស្អាត) នៅបានមួយស្របក់ សញ្ញាគប្បីឃើញដូចថ្ងៃ បណ្ដើរកូន ព្រោះបញ្ឆោតចិត្ត សង្ខារគប្បីឃើញដូចដើមចេក ព្រោះមិនមានខ្លឹម វិញ្ញាណគប្បីឃើញដូចកលមាយា ព្រោះជាវត្ថុបោកបញ្ឆោត ។

ពោលដោយពិសេសន័យម្យ៉ាងទៀត អជ្ឈត្តិករូប (រូបខាងក្នុង គឺរូបរបស់ខ្លួន) សូម្បីល្អ ក៏គប្បីឃើញថា ជារបស់មិនស្អាត វេទនាគប្បីឃើញថាជាទុក្ខ ព្រោះមិនផុតចាកភាពជាទុក្ខ ៣ សញ្ញាគប្បីឃើញថា ជាអនត្តា ព្រោះមិនស្ដាប់បង្គាប់ វិញ្ញាណគប្បីឃើញថា ជាអនិច្ចំ ព្រោះមានសភាវៈកើតឡើងហើយរលត់ទៅ ។

## ន័យពោលដោយការសម្រេចប្រយោជន៍ដល់អ្នកឃើញយ៉ាងនោះ

ពាក្យថា ដោយការសម្រេចប្រយោជន៍ដល់អ្នកឃើញយ៉ាងនោះ សេចក្ដីថា ការសម្រេចប្រយោជន៍ឯណា រមែងមានដល់អ្នកឃើញដោយអាការ ២ ដោយសង្ខេប និងយ៉ាងពិស្ដារដូចពោលមកនោះ បណ្ឌិតគប្បីជ្រាបន័យសម្រាប់វិនិច្ឆ័យដោយការសម្រេចប្រយោជន៍នោះខ្លះទៀត សេចក្ដីនេះដូចម្ដេច ? គឺពាក្យដំបូងដោយសង្ខេប ព្រះយោគាវចរអ្នកឃើញឧបាទានក្ខន្ធ ៥ ដោយភាពជាសត្រូវ អ្នកងារដាវ ( បំណងនឹងសម្លាប់ ) ជាដើម រមែងមិនក្ដៅក្រហាយព្រោះខន្ធទាំងឡាយ ។ ឯដោយពិស្ដារ គប្បីឃើញខន្ធទាំងឡាយ មានរូបជាដើម ដោយភាពដូចជាដុំពពុះទឹកជាអាទិ ក៏ឈ្មោះថា មិនជាអ្នកឃើញសារៈ ក្នុងវត្ថុដែលមិនជាសារៈទាំងឡាយ ។

ពោលដោយពិសេសន័យម្យ៉ាងទៀត អ្នកឃើញអជ្ឈត្តិករូប ដោយភាពជារបស់មិនស្អាត ឈ្មោះថា កំណត់ដឹងកពឡិង្ការាហារ រមែងលះវិបល្លាសថា ស្អាត ក្នុងរបស់ដែលមិនស្អាតបាន រមែងឆ្លងកាមោឃៈបាន រមែងវៀនចេញចាកកាមោឃៈបាន រមែងជាអ្នកមិនមានអាសវៈ ផ្លូវកាមាសវៈ រមែងទម្លាយកាយគន្ថៈ (គ្រឿងចង

រិតនាមកាយ ) គឺអភិជ្ឈាចេញបាន រមែងមិនប្រកាន់មាំដោយកាមុបាទាន អ្នកឃើញវេទនាដោយភាពជាទុក្ខ ឈ្មោះថា កំណត់ដឹងផស្សាហារ រមែងលះវិបល្លាសថាជាសុខក្នុងវត្ថុដែលជាទុក្ខចេញបាន រមែងឆ្លងភវឱឃៈ រមែងវៀរចេញចាកភវយោគៈបាន រមែងជាអ្នកមិនមានអាសវៈ ផ្លូវភវាសវៈ រមែងទម្លាយកាយគន្ថៈ គឺព្យាបាទបាន រមែងមិនប្រកាន់មាំដោយសីលព្វតុបាទាន អ្នកឃើញសញ្ញា និងសង្ខារទាំងឡាយដោយភាពជាអនត្តា ឈ្មោះថា កំណត់ដឹងមនោសញ្ចេតនាហារ រមែងលះវិបល្លាសថាជាខ្លួនក្នុងវត្ថុដែលមិនមែនជាខ្លួនចេញបាន រមែងឆ្លងទិដ្ឋោឃៈបាន រមែងវៀរចេញចាកទិដ្ឋិយោគៈបាន រមែងជាអ្នកមិនមានអាសវៈ ផ្លូវទិដ្ឋាសវៈ រមែងទម្លាយកាយគន្ថៈ គឺឥទំសច្ចាភិនិវេស ( ការផ្តោតចិត្តថា នេះប៉ុណ្ណោះពិត ) ចេញបាន រមែងមិនប្រកាន់មាំដោយអត្តវាទុបាទាន អ្នកឃើញវិញ្ញាណ ដោយភាពជាអនិច្ចំ ឈ្មោះថា កំណត់ដឹងវិញ្ញាណាហារ រមែងលះវិបល្លាសថា ទៀងក្នុងរបស់ដែលមិនទៀងចេញបាន រមែងឆ្លងអវិជ្ជោឃៈបាន រមែងវៀរចេញចាកអវិជ្ជាយោគៈបាន រមែងជាអ្នកមិនមានអាសវៈ ផ្លូវអវិជ្ជាសវៈ រមែងទម្លាយកាយគន្ថៈ គឺសីលព្វតបរាមាសបាន រមែងមិនប្រកាន់មាំដោយទិដ្ឋុបាទាន ។

ព្រោះហេតុដែលឃើញ ( ខន្ធ ) ដោយភាពជាពេជ្ឈឃាតជាដើម មានអានិសង្សច្រើន ដូច្នេះ ព្រោះហេតុនោះ អ្នកមានបញ្ញាគប្បីឃើញខន្ធទាំងឡាយ ដោយភាពជាពេជ្ឈឃាតជាដើមហោង ។

បរិច្ឆេទទី ១៤ ឈ្មោះខន្ធនិទ្ទេស

ក្នុងអធិការនៃបញ្ញាភាវនា ក្នុងបករណ៍វិសុទ្ធិមគ្គ

ដែលខ្ញុំធ្វើដើម្បីប្រយោជន៍ដល់ភាពជាបាមោជ្ជនៃសាធុជន ដូច្នេះ ។

# មហាដីកា

## ពណ៌នាពាក្យវិនិច្ឆ័យបកិណ្ណកៈមានលំដាប់ជាដើម

*ពាក្យថា **ដើម្បីភាពបែកធ្លាយនៃញាណ** គឺដើម្បីប្រភេទនៃញាណមានប្រការផ្សេងៗ ។ ពាក្យថា **ដោយលំដាប់** បានដល់ ដោយលំដាប់នៃទេសនា អធិប្បាយថា ព្រះមានជោគ ទ្រង់ធ្វើលំដាប់នៃទេសនានេះទុកដោយហេតុណា គឺដោយហេតុនោះ ។ ពាក្យថា **ដោយប្លែកគ្នា** គឺដោយភាពផ្សេងគ្នា អធិប្បាយថា ដោយចែកជាខន្ធ និងជាឧបាទានក្ខន្ធ ។ ពាក្យថា **ដោយមិនតិចមិនច្រើន** គឺដោយភាពជា ៥ យ៉ាង ។ ពាក្យថា **ដោយឧបមា** បានដល់ដោយប្រការដែលគប្បីប្រៀបធៀបដោយឧបមាទាំងឡាយ ។ ពាក្យថា **ដោយសភាវៈដែលចែកជា ២ យ៉ាង** គឺដោយសភាវៈដែលគប្បីមើលបានដោយញាណ ដោយអាការ ២ យ៉ាង ។ ពាក្យថា **ដោយសម្រេចជាប្រយោជន៍ដល់អ្នកឃើញ** គឺដោយសម្រេចប្រយោជន៍តាមដែលបំណងដល់អ្នកឃើញយ៉ាងណា ។ បទថា **វិភាវិនា** ប្រែថា បុគ្គលមានបញ្ញា ។*

*ពាក្យថា **លំដាប់នៃការកើត** បានដល់ លំដាប់នៃការកើតរបស់ខន្ធទាំងឡាយដែលកើតតាមបច្ច័យ ។ ខន្ធដែលនឹងគប្បីលះជាលំដាប់ដំបូង លោកពោលទុកជាលំដាប់ដំបូង ខន្ធដែលគប្បីលះជាលំដាប់ទី ២ លោកពោលទុកជាលំដាប់ទី ២ ដោយពាក្យថា **ធម៌ទាំងឡាយដែលសោតាបត្តិមគ្គគប្បីលះ** ដូច្នេះជាដើម ព្រោះដូច្នោះនេះឈ្មោះថា **លំដាប់នៃការលះ** ។ បដិបត្តិសីលវិសុទ្ធិហើយ ទើបគួរបដិបត្តិចិត្តវិសុទ្ធិ សូម្បីវិសុទ្ធិដទៃតអំពីចិត្តវិសុទ្ធិនោះក៏ដូចគ្នា ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **លំដាប់មានអាទិ៍យ៉ាងនេះថា សីលវិសុទ្ធិ ចិត្តវិសុទ្ធិ ឈ្មោះថា លំដាប់នៃការបដិបត្តិ** ភូមិដែលប្រណីតដោយលំដាប់ លោកកំណត់ទុកដោយលំដាប់ ព្រោះ*

ដូច្នោះ លំដាប់នេះ ឈ្មោះថា **លំដាប់នៃភូមិ** ។ លំដាប់មានអាទិ៍ថា **សតិប្បដ្ឋាន ៤** ឈ្មោះថា **លំដាប់នៃការសម្ដែង** ព្រោះធម៌ មានសតិប្បដ្ឋានជាដើម មានសូម្បីក្នុងខណៈជាមួយគ្នា ។ កថា មានទានកថាជាដើម ត្រាស់ទុកដោយខ្ពស់ឡើងជាលំដាប់ តែការពោលធម៌ មានទានជាដើម ថាជាលំដាប់នៃទេសនា ក្នុងទីនេះ ព្រោះមិនមានការកំណត់ការកើតឡើងជាដើម ។ សូម្បីការសម្ដែងភាវៈ ដែលមានការកំណត់ការកើតឡើងជាហេតុ មានជាដើមថា **ដំបូងជាកលលៈ** លោកពោលដោយភាវៈ មានលំដាប់ មានការកើតឡើងនោះឯង ។ ម្យ៉ាងទៀត លំដាប់របស់រឿងគ្រាន់តែជាការទេសនា ដោយភាពជាបំណងនោះៗ ឯង ព្រោះនឹងត្រូវសម្ដែង ដោយមុនក្រោយឯណានីមួយ ព្រោះពាក្យសម្ដីដ៏ច្រើនមិនមានការប្រព្រឹត្តទៅរួមគ្នា ដោយមិនមានការកំណត់តាមដែលពោលហើយ គប្បីឃើញថា **ជាលំដាប់នៃការសម្ដែង** ។ ពាក្យថា **ដោយកំណត់មុនក្រោយ** ព្រោះមិនកើតឡើងដោយកំណត់មុនក្រោយយ៉ាងនេះថារូបក្ខន្ធដំបូង តអំពីនោះ វេទនាខន្ធ ។ ពាក្យថា **ព្រោះមិនចាំបាច់លះ** សេចក្ដីថា ក្នុងបណ្ដាខន្ធទាំងឡាយ ខន្ធពួកខ្លះមិនមានភាវៈដែលចាំបាច់លះឡើយ លំដាប់នៃការលះនឹងមកអំពីណា ។ ព្រោះថា កាលខន្ធទាំងអស់ជាភាវៈ ដែលត្រូវលះមាន ក៏នឹងគប្បីមានការសម្ដែងខន្ធទាំងនោះតាមលំដាប់របស់ការលះ ។ ពាក្យថា **ព្រោះមិនត្រូវបដិបត្តិ** គឺព្រោះមិនមែននឹងគប្បីបដិបត្តិ ដោយអំណាចនៃសម្មាបដិបត្តិ ។ ដោយពាក្យថា **ព្រោះទាក់ទងដោយភូមិ ៤** នេះ លោកអាចារ្យសម្ដែងដល់ភាពដែលខន្ធ មានវេទនាខន្ធជាដើម ជាខន្ធមានភូមិដែលមិនពិតប្រាកដ ។ ពិតណាស់ លំដាប់នៃភូមិនឹងគប្បីមានដល់ខន្ធដែលមានភូមិពិតប្រាកដ (ប៉ុណ្ណោះ)។

ពាក្យថា **ដោយមិនញែកគ្នា** បានដល់ ដោយមិនបានធ្វើការញែក គឺការចែកខន្ធមានរូបជាដើម គឺរួមជាមួយគ្នា ។ ពាក្យថា **ដែលធ្លាក់ទៅក្នុងអត្តគ្គាហ** គឺដែលធ្លាក់ទៅ

ក្នុងទិដ្ឋោឃៈ ដែលហៅថា អត្តគាហៈ ។ ពាក្យថា **ដោយការឃើញ ដោយញែកក្រុមចេញទៅ** សេចក្តីថា ការលះអរូបទៅអំពីរូប គឺឃើញដោយញែកភាពជាដុំក្នុងក្រុមរបស់រូប និងអរូប ។ ពាក្យថា **ជាអារម្មណ៍សូម្បីនៃចក្ខុទ្វារជាដើម** លោកអាចារ្យពោលដល់រូបក្ខន្ធដែលជាចំណែករួមទុកដោយឯកទេស ។ភ្ជាប់សេចក្តីថា ទ្រង់សម្តែងវេទនាដែលជាចំណែកនៃការសោយអារម្មណ៍នូវរូបដែលគួរប្រាថ្នា និងមិនគួរប្រាថ្នាថា ក្នុងបណ្តាអារម្មណ៍ទាំងនេះ វេទនាណាសោយនូវរូបដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា វេទនានេះជាវេទនាខន្ធ ។ ក្នុងខន្ធទាំងពួងក៏យ៉ាងនេះ ។ គប្បីឃើញការកាន់យកដោយស័ព្ទថា គួរប្រាថ្នា និងមិនគួរប្រាថ្នាប៉ុណ្ណោះ ព្រោះឥដ្ឋមជ្ឈត្តារម្មណ៍ក៏មានសភាវៈដែលគួរប្រាថ្នា និងអនិដ្ឋមជ្ឈត្តារម្មណ៍ ក៏មានសភាវៈដែលមិនគួរប្រាថ្នា ។ បទថា **ឯវំ** ប្រែថា ដោយន័យតាមដែលបានពោលហើយ ។ ការប្រព្រឹត្តទៅនៃការតាក់តែងនឹកគិត ក៏នៅក្នុងអារម្មណ៍ដែលមានអាការ ដែលកាន់យកបានដោយសញ្ញា ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **សង្ខារដែលជាចំណែកនៃការតាក់តែងនឹកគិតទៅតាមអំណាចនៃសញ្ញា** ដូច្នេះ ។ ភាពដែលវិញ្ញាណជាទីអាស្រ័យ សូម្បីរបស់សម្បយុត្តធម៌ទាំងឡាយជាក់ច្បាស់ហើយ យ៉ាងណា របស់ខន្ធ ៤ មានវេទនាខន្ធជាដើម មិនជាដូច្នោះឡើយ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា ទ្រង់សម្តែងសញ្ញា **ដែលជាទីអាស្រ័យរបស់ខន្ធ ៤ មានវេទនាខន្ធជាដើម** ។ **វិញ្ញាណ** ជាអធិបតី ព្រោះមានព្រះបាលីថា **មនោបុព្វង្គមា ធម្មា** ធម៌ទាំងឡាយ មានចិត្តជាប្រធាន **ចិត្តានុបរិវត្តិនោ ធម្មា** ធម៌ទាំងឡាយ មានការប្រែប្រួលទៅតាមចិត្ត **ឆទ្វារាធិបតី រាជា** រាជាជាអធិបតីនៃទ្វារទាំង ៦ ដូច្នេះ ។

ពាក្យថា **មានអាសវៈជាទីតាំងនៃឧបាទានក្ខន្ធ** ក្នុងរូបក្ខន្ធ ដើម្បីនឹងហាមឃាត់ភាពដែលរូបក្ខន្ធមានសភាវៈដូច្នោះ ព្រោះធម៌ទាំងឡាយដែលមិនមានអាសវៈក៏មាន

មិនមែនដើម្បីនឹងហាមឃាត់រូបដែលមិនមានអាសវៈឡើយ ។

ឯវ-ស័ព្ទ ក្នុងពាក្យថា **អនាសវាវ ខន្ធេសុ វុត្តា** នេះ ជាអដ្ឋានសម្បយុត្ត សេចក្តីប៉ុនគ្នានឹងពាក្យថា **អនាសវា ខន្ធេស្វេវវុត្តា** ប្រែថា ដែលមិនមានអាសវៈ លោកពោលទុកក្នុងខន្ធតែម្យ៉ាង ។ **ឥធ យោគ វិសុទ្ធិមគ្គេ សព្វេបេតេ យោគ ខន្ធាបិ ឧបាទានក្ខន្ធាបិ** ប្រែថា ចំណែកក្នុងវិសុទ្ធិមគ្គ ទាំងខន្ធ ទាំងឧបាទានក្ខន្ធទាំងអស់នេះ ។

ការសង្គ្រោះសង្ខតធម៌ទាំងពួង រួមចូលជាមួយគ្នា តាមដែលជាសភាគគ្នា ឈ្មោះថា **ការសង្គ្រោះសង្ខតធម៌ទាំងពួងចូលជាមួយគ្នាតាមដែលជាសភាគគ្នា** ។ ពិតណាស់ សង្ខតធម៌ទាំងពួងដែលសង្គ្រោះទុកដោយសភាវៈ ដែលជាសភាគគ្នា ចាត់ជាខន្ធ ៥ ។ ក្នុងសេចក្តីនោះ កោដ្ឋាសដែលស្មើគ្នា ដោយភាពស្មើគ្នា មានការប្រែប្រួលជាដើម គប្បីជ្រាបថា ជាសភាគគ្នា ។ កិច្ច គឺការតាក់តែងសង្ខតធម៌ ក្នុងកោដ្ឋាសទាំងនោះរបស់ចេតនា ដែលមានការប្រមូលជាកិច្ចមានកម្លាំង ព្រោះដូច្នោះ ចេតនានោះទើបលោកហៅថា **សង្ខារក្ខន្ធ** ។ ចំណែកសភាវធម៌ទាំងឡាយ មានផស្សៈជាដើម ដែលវៀរចាកលក្ខណៈពិសេស មានការប្រែប្រួលជាដើមដទៃទៀត គប្បីឃើញថា ជាសង្ខារក្ខន្ធ ដោយភាពស្មើគ្នា គឺការតាក់តែងសង្ខតធម៌ ម្យ៉ាងទៀត សភាវធម៌ទាំងឡាយ មានការពាល់ត្រូវជាដើម មិនជាឋានៈដែលគួរនឹងពោលដោយខន្ធស័ព្ទមួយផ្នែក ព្រោះដូច្នោះ គប្បីជ្រាបថា ព្រះតថាគតទ្រង់ដឹងសភាវៈនៃធម៌ ទើបមិនត្រាស់ខន្ធទាំងឡាយ មានផស្សក្ខន្ធជាដើម ម្យ៉ាងទៀត គប្បីឃើញភាពដែលការប្រកាន់ថា ខ្លួន និងថាជារបស់ខ្លួន ថាមានខន្ធ ៥ នេះ យ៉ាងក្រៃលែង ដោយអំណាចនៃព្រះសូត្រ មានអាទិយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ពួកណានីមួយ ដែលកាន់លទ្ធិថាទៀង រមែងបញ្ញត្តអត្តា និងលោក ថាទៀង សមណៈ ឬព្រាហ្មណ៍ទាំងនោះ រមែងបញ្ញត្តដោយអាស្រ័យឧបាទានក្ខន្ធទាំង ៥ នេះឯង ឬ

**អាស្រ័យខន្ធ ៥ នេះ ខន្ធឯណានីមួយ** ។ អធិប្បាយថា ព្រោះសភាវធម៌ដែលវៀរចាកខន្ធ និងព្រះនិព្វានមិនមាន ទើបរមែងកើតទិដ្ឋិ ( ការយល់ខុស ) ដែលគប្បីពោលមិនបាន ដោយអំណាចនៃអារម្មណ៍ មានបរិត្តារម្មណ៍ជាដើម ដោយអាស្រ័យអំពីខន្ធតែម្យ៉ាង ដោយអំណាចនៃព្រះសូត្រនេះ និងព្រះសូត្រដែលពោលតទៅ ។ ព្រះមានព្រះភាគត្រាស់ដល់ធម្មជាតិដែលមានការប្រែប្រួលទៅជា សភាវៈថា **រូប** ។ សូម្បីក្នុងពាក្យថា **វេទនា** ជាដើម ក៏ដូចន័យនេះឯង ។ លោកអាចារ្យពោលថា **ព្រោះរួបរួមយកធម៌ដែលចាត់ជាខន្ធដទៃៗ ទុកក្នុងនោះបាន** ដូច្នេះ ។ ដើម្បីនឹងហាមឃាត់នូវពាក្យចោទសួរថា ខន្ធមាន ៥ ប៉ុណ្ណោះក៏ទេ ព្រោះមានព្រះបាលីថា **សីលក្ខន្ធ សមាធិក្ខន្ធ** ដូច្នេះជាដើម និងព្រោះមានខន្ធដទៃៗ ដូចជាសីលក្ខន្ធជាដើម ដែលគួរនឹងពោលទុក ដោយខន្ធសព្ទ ។

រូបូបាទានក្ខន្ធ រមែងដូចជាទីលំនៅដែលជាទីតាំងនៃការប្រព្រឹត្តទៅ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ព្រោះជាទីនៅអាស្រ័យ** ។ គប្បីឃើញភាពដែលវេទនាជាដើមជាតួអាពាធ ដោយជាទុក្ខទុក្ខ ( គឺទុក្ខពិត ) វិបរិណាមទុក្ខ ទុក្ខ ព្រោះការប្រែប្រួល និងសង្ខារទុក្ខ ទុក្ខប្រចាំសង្ខារ ។ សញ្ញាដែលកាន់យកដោយអាការថាជាស្រី ជាប្រុសជាដើម ដែលជាមូលនៃការត្រិះរិះនោះៗ **ជាសមុដ្ឋាន** របស់ទុក្ខ មានវិបរិណាមទុក្ខជាដើម ដែលប្រកបដោយកិលេស មានរាគៈជាដើម ។ហេតុជិត ឈ្មោះថា **ជាសមុដ្ឋាន** របស់រោគ ដូចជាអាការ មានប្រមាត់ជាដើម ។ ហេតុដើម ឈ្មោះថា **ជាដើមហេតុ** ប្រៀបដូចការដែលខតុ និងភោជនមិនស្មើគ្នា និងការបរិហារដែលមិនស្មើ **ជាដើមហេតុ** របស់រោគ ។ លោកពោលវិញ្ញាណថា ប្រៀបដូចអ្នកជំងឺ ព្រោះចេតសិកជាអង្គប្រកបរបស់ចិត្ត ។ ការប្រព្រឹត្តទៅទាក់ទងនឹងអភិសង្ខារ មានបុញ្ញាភិសង្ខារជាដើមរបស់បុគ្គលពាលនាំមកនូវទុក្ខ គឺវេទនា ដូចជាការបរិភោគចំណីទាស់ ប្រៀប

ដូចការអេះរបស់បុគ្គលដែលកើតរោគឃ្លង់ ក៏ដើម្បីឲ្យបុគ្គលដែលកើតរោគឃ្លង់នោះរាលច្រើនឡើង ។ ពាក្យថា **ដើម្បីឲ្យកើតវេទនា** បានដល់ ដើម្បីមានសភាពរបស់វេទនា អធិប្បាយថា ដើម្បីការបានភាពជាវេទនា ។រូប ឈ្មោះថា **ប្រៀបដូចគុក** ព្រោះជាសភាវៈដែលដាក់ទោស និងឈ្មោះថា **ប្រៀបដូចភាជនៈ** ព្រោះជាទីទទួលទ្រ ។ សញ្ញា **ប្រៀបដូចកំហុស** ព្រោះជាហេតុនៃទោស គឺវេទនា ដោយអំណាចនៃសញ្ញាមានសុភសញ្ញាជាដើម និងឈ្មោះថា **ប្រៀបដូចម្ហូប** ព្រោះធ្វើឲ្យចង់បានភោជន គឺវេទនា សង្ខារក្ខន្ធ **ប្រៀបដូចចៅហ្វាយដែលដាក់ទោស** និង**ប្រៀបដូចអ្នកចិញ្ចឹម** ( ចុងភៅ) ដោយជាហេតុនៃវេទនា ចុងភៅនោះឯងរមែងចិញ្ចឹមដោយច្រើន ព្រោះដូច្នោះ ទើបលោកប្រើស័ព្ទថា **ប្រៀបដូចអ្នកចិញ្ចឹម** ។ លោកពោលវិញ្ញាណថា **ប្រៀបដូចការខុស** ព្រោះគប្បីត្រូវវេទនាបៀតបៀន និងពោលថា **ប្រៀបដូចអ្នកបរិភោគ** ព្រោះគប្បីត្រូវវេទនាឃ្លាំចាំអនុគ្រោះ ។

ឧបាទានក្ខន្ធ ៥ ត្រាស់ថា ជាពេជ្ឈឃាត **ក្នុងអាសីវិសូបមសូត្រ** ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ពេជ្ឈឃាតទាំង ៥ ដែលជាសត្រូវងារដាវនេះឯង ជាឈ្មោះនៃឧបាទានក្ខន្ធ ៥ ត្រាស់ថា ជាភារៈធ្ងន់ **ទុកក្នុងភារសូត្រថា** ម្នាលភិក្ខុទាំងឡាយ ពាក្យថា របស់ធ្ងន់នេះ ជាឈ្មោះនៃឧបាទានក្ខន្ធ ៥ ត្រាស់ថា ជាអ្នកទំពាស៊ី **ទុកក្នុងខជ្ជនីយបរិយាយសូត្រ** ដោយន័យជាដើមថា សូម្បីក្នុងអតីតកាល យើងត្រូវរូបទំពាស៊ីដូចក្នុងបច្ចុប្បន្ន យើងត្រូវរូបបច្ចុប្បន្នទំពាស៊ី ។ ម្យ៉ាងទៀត យើងនេះឯងមិនគប្បីសរសើររូបដែលជាអនាគត សូម្បីក្នុងអនាគតកាល យើងក៏ត្រូវរូបទំពាស៊ី ដូចក្នុងបច្ចុប្បន្ន យើងត្រូវរូបបច្ចុប្បន្នទំពាស៊ី ។បេ។ ត្រាស់ថា ជារបស់មិនទៀងជាដើម **ទុកក្នុងយមកសូត្រ** ដោយន័យជាដើមថា បុថុជ្ជននោះ រមែងមិនដឹងច្បាស់នូវរូបដែលមិនទៀងតាមសេចក្តីពិតថា រូបមិនទៀង ។ សូម្បីលោកបានពោលទុកថា ក្នុង

ទីនេះ ឧបាទានក្ខន្ធ ៥ នេះ លោករួមគ្នាបំណងយកថាជាខន្ធ ដូច្នេះក៏ពិត សូម្បីយ៉ាងនោះ ដោយច្រើនក៏គប្បីជ្រាបភាពដែលឧបាទានក្ខន្ធដែលចាត់ចូលនៅក្នុងខន្ធនោះថាជាវត្ថុដែលគប្បីឃើញ ។ នេះជាការពិចារណាភូមិនៃវិបស្សនា ដូច្នេះ ។

ក្នុងពាក្យថា ដូចដុំពពុះទឹក ជាដើម មានវិនិច្ឆ័យដូច្នេះ គប្បីឃើញភាពដែលឧបាទានក្ខន្ធ ៥ មានរូបជាដើម ដូចគ្នានឹងដុំពពុះទឹកជាដើមយ៉ាងនេះ ដុំពពុះទឹកជាវត្ថុដែលមិនមានខ្លឹម ទុព្វលដោយជុំវិញ កាន់យកមកមិនបាន សូម្បីកាន់យកហើយក៏មិនញុំាងប្រយោជន៍អ្វីឲ្យសម្រេចជាបំពង់តូចបំពង់ធំបាន តគ្នាដោយទីតដ៏ច្រើនជាទីលំនៅរបស់ពពួកសត្វតូចៗ ជាចំនួនច្រើន សន្សំចូលមកដោយលំដាប់ មានការធ្លាក់ទៅ ដោយមិនមានសេសសល់ក្នុងអាការគ្រប់យ៉ាង មានការបែកធ្លាយដោយពិតប្រាកដ យ៉ាងណា សូម្បីរូបក៏ដូច្នោះ ជាវត្ថុមិនមានខ្លឹម ព្រោះវៀរចាកសារៈ គឺភាពទៀងជាដើម ដូចក្រមរឈើ ជាវត្ថុមិនមានខ្លឹម ជាវត្ថុដែលទុព្វល ព្រោះនឹងគប្បីបាក់បានងាយ មិនគួរនឹងប្រកាន់ថា ទៀង ឬថា ស្ថិតស្ថេរ ឬថា ជាអញ ឬថា ជារបស់អញ សូម្បីប្រកាន់យក ក៏មិនទៅជាយ៉ាងនោះ មានប្រហោងដ៏ច្រើន តគ្នាដោយទីត ៨ ពាន់កន្លែង ដែលជាលំនៅរបស់ត្រកូលជន្តុវដ៏ច្រើន សន្សំឡើងដោយលំដាប់ដោយជាកលលៈជាដើម វិនាសទៅក្នុងអាការគ្រប់យ៉ាង តាំងអំពីជាកលលៈទៅ និងរមែងបែកធ្លាយពិតប្រាកដនោះឯង ។តែក្នុងអដ្ឋកថាលោកពោលការភ្ជាប់ពាក្យឧបមា និងឧបមេយ្យទុក គឺការអត់ធន់មិនបាន ដោយការគ្របសង្កត់ប៉ុណ្ណោះ ។

ក្រពេញទឹកជារបស់មិនមានខ្លឹម ទុព្វលដោយជុំវិញ កាន់យកមិនបាន សូម្បីកាន់យក ក៏មិនញុំាងប្រយោជន៍អ្វីឲ្យសម្រេច មានការតាំងនៅមិនយូរ យ៉ាងណា សូម្បីវេទនាក៏ដូច្នោះ ម្យ៉ាងទៀត ក្រពេញទឹករមែងកើតឡើង ព្រោះអាស្រ័យហេតុ ៤ យ៉ាង គឺផ្ទៃទឹក ១ តំណក់ទឹក ១ ក្រាមទឹក ១ និងខ្យល់ដែលបាញ់ឡើងមក ធ្វើ

ឲ្យប៉ោង ១ យ៉ាងណា សុខវេទនាក៏យ៉ាងនោះ រមែងកើតឡើងព្រោះអាស្រ័យហេតុ ៤ ប្រការដូចគ្នា គឺវត្ថុ ១ អារម្មណ៍ ១ ការដេកត្រាំរបស់កិលេស ១ និងការប៉ះខ្ទប់នៃផស្សៈ ១ ដូចជាខ្យល់ដែលកើតព្រោះការធ្លាក់ចុះរបស់តំណក់ទឹកលើផ្ទៃទឹក ក៏នឹងទាញយកកករទឹក ដែលហៅថា ក្រាមរបស់ទឹកមកធ្វើឲ្យប៉ោង និងធ្វើឲ្យបានឈ្មោះថា ក្រពេញទឹក យ៉ាងណា ផស្សៈដែលកើតឡើងដោយការមកដល់គន្លងនៃអារម្មណ៍ក្នុងវត្ថុ ក៏នឹងទាញយកភាពដេកត្រាំរបស់កិលេស ដែលមិនទាន់កាត់បានដោយភាពជាបច្ច័យ ដែលមានការធ្វើរួមគ្នាហើយ ធ្វើឲ្យបានឈ្មោះថា ជាវេទនាដូច្នោះ ។ពាក្យនេះលោកពោលសំដៅយកវេទនា ដែលនៅក្នុងវដ្ដៈដែលកើតឡើងដោយកិលេសដែលជាហេតុដើម និងជាតួពេញចិត្តក្នុងអារម្មណ៍ ។ ម្យ៉ាងទៀត ដោយកំណត់បរិច្ឆេទយ៉ាងខ្ពស់ លោកពោលដល់បច្ច័យ ៤ តែដោយបច្ច័យ ៤ នឹងតិចទៅខ្លះក៏កើតឡើងបាននោះឯង ។ក្នុងទីនេះលោកពោលការភ្ជាប់គ្នារបស់ពាក្យឧបមា និងពាក្យឧបមេយ្យ គឺភាពដែលវេទនាជាធម្មជាតិដែលគប្បីត្រេកអរមួយជួរខណៈនោះឯង ។

ម្យ៉ាងទៀត **ថ្ងៃបណ្ដើរកូន** ជាវត្ថុដែលមិនមានខ្លឹម កាន់យកមិនបាន ។ ព្រោះមិនអាចកាន់យកថ្ងៃបណ្ដើរកូននោះ មកផឹក ឬងូត ឬធ្វើភាជនៈឲ្យពេញបាន យ៉ាងណា សុខសញ្ញាក៏ដូចគ្នា ជាវត្ថុដែលមិនមានខ្លឹម កាន់យកមិនបាន ។ម្យ៉ាងទៀត ថ្ងៃបណ្ដើរកូន ប្រែប្រួលប្រាកដដូចគ្នានឹងក្រសែទឹករលកដែលកើតឡើងឯង រមែងបញ្ឆោតចិត្តមហាជន យ៉ាងណា សុខសញ្ញាក៏យ៉ាងនោះ កាលកំពុងប្រព្រឹត្តទៅក្នុងអារម្មណ៍ដោយន័យថា **ខៀវ លឿង វែង ខ្លី** ជាដើម មិនតាំងនៅក្នុងឋានៈ សុខជាសភាវៈរមែងបញ្ឆោតចិត្តសត្វលោក ដោយសភាវៈដែលជាហេតុនៃការប្រកាន់ខុសជាដើមថា **ស្អាត ជាសុខ ទៀង** ដូច្នោះ ។

**ដើមចេក** ជាវត្ថុដែលមិនមានខ្លឹមសារចូលដល់សភាវៈ ដែលនឹងគប្បីប្រកាន់

យកមិនបាន ។ ព្រោះមិនអាចកាន់យកដើមចេកនោះ នាំចូលទៅដើម្បីជាប្រយោជន៍ជាទព្វសម្ភារៈ មានរនូតផ្ទះជាដើម សូម្បីនាំចូលទៅប្រើក៏មិនកើតយ៉ាងនោះ និងជាទីប្រជុំនៃស្រទបចេកជាច្រើនរួមគ្នា យ៉ាងណា សូម្បីសង្ខារក្ខន្ធ ក៏ដូច្នោះ មិនមានខ្លឹមចូលដល់ភាវៈដែលនឹងគប្បីកាន់យកមិនបាន ។ ព្រោះមិនអាចកាន់យកសង្ខារក្ខន្ធនោះដោយជារបស់ទៀងជាដើម សូម្បីកាន់យកហើយ ក៏មិនទៅជាយ៉ាងនោះ និងជាទីរួមនៃធម៌ដ៏ច្រើន ។ ព្រោះលក្ខណៈរបស់ផស្សៈមានតែមួយលក្ខណៈរបស់ធម៌ទាំងឡាយមានចេតនាជាដើមក៏ត្រឹមតែម្យ៉ាង តែលោករួមយកធម៌ទាំងអស់នោះចូលជាមួយគ្នាហៅថា សង្ខារក្ខន្ធ ។

ដូចជា **កលមាយា** ជារឿងមិនមានសារៈ ចូលដល់ភាវៈដែលនឹងគប្បីប្រកាន់យកមិនបាន ព្រោះមិនអាចកាន់យកកលមាយានោះធ្វើឲ្យសម្រេចកិច្ច ដែលជាប្រយោជន៍ណាមួយបាន កលមាយាជារឿងបន្តិចបន្តួចប្រាកដរហ័ស សម្តែងវត្ថុដែលមិនមែនជាកែវមណីជាដើមឲ្យឃើញជារូបកែវមណីបោកបញ្ឆោតបុគ្គលមួយចំណែកធំបាន យ៉ាងណា សូម្បីវិញ្ញាណក៏ដូច្នោះ ជាវត្ថុដែលមិនមានសារៈសូម្បីបន្តិចបន្តួចប្រាកដរហ័ស ដោយចិត្តនោះឯង ធ្វើឲ្យប្រកាន់ដូចជាកំពុងមក ដូចជាកំពុងទៅ ដូចជាកំពុងឈរ និងដូចជាកំពុងអង្គុយ ក្នុងការមកជាចិត្ត ១ ដួងនោះឯង ក្នុងការទៅជាដើមក៏ជាចិត្ត ១ ដួង ។ វិញ្ញាណក៏ដូចគ្នានឹងកលមាយាដោយប្រការដូចពោលមកដូច្នេះ ។

ឧបាទានក្ខន្ធ ៥ មានការមិនស្អាតជាដើមជាសភាវៈប៉ុណ្ណោះ និងជាទីតាំងនៃសេចក្តីសៅហ្មង ព្រោះការមិនស្អាតជាដើម ដូច្នោះ ទើបគប្បីឃើញថាដោយភាពជាវត្ថុដែលមិនស្អាតជាដើមនោះឯង សូម្បីយ៉ាងនោះ ក្នុងកន្លែងខ្លះក៏គង់មានភាពផ្សេងគ្នាខ្លះ ដែលនឹងគប្បីកាន់យកបានដោយងាយ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលពាក្យថា **និងដោយភាពផ្សេងគ្នា** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ សតិប្បដ្ឋាន

ទាំង ៤ ជាធម៌ធ្វើការលះវិបល្លាស ៤ យ៉ាងបាន ព្រោះដូច្នោះ ទើបលោកពោលថា ជាវត្ថុដែលគប្បីឃើញដោយភាពជារបស់មិនស្អាតជាដើម ក្នុងខន្ធទាំងឡាយ មានរូបក្ខន្ធជាដើម ដោយជាអារម្មណ៍របស់សតិប្បដ្ឋាន ៤ នោះ ។

ឈ្មោះថា **រមែងមិនក្តៅក្រហាយព្រោះខន្ធទាំងឡាយ** ព្រោះជាបុគ្គលមានសភាវៈដែលបានកំណត់ដឹងហើយ ។ បុគ្គលចម្រើនវិបស្សនាក៏រមែងមិនដល់នូវទុក្ខក្នុងវិបត្តិនៃខន្ធទាំងនោះ ចំណែកក្នុងព្រះខីណាស្រពទាំងឡាយ មិនមានពាក្យដែលត្រូវនិយាយដល់នោះឯង ។ព្រោះព្រះខីណាស្រពទាំងនោះរមែងមិនត្រូវខន្ធបៀតបៀនសូម្បីក្នុងកាលតទៅ ដូច្នេះ ។

ពាក្យថា **រមែងកំណត់ដឹងកពឡិង្ការាហារ** សេចក្តីថា កាលលះឆន្ទរាគៈ ក្នុងអជ្ឈត្តិករូប ឈ្មោះថា រមែងលះឆន្ទរាគៈ សូម្បីក្នុងកពឡិង្ការាហារ ដែលជាទីកើតរបស់អជ្ឈត្តិករូបនោះ ដោយព្រះបាលីថា **ព្រោះអាហារកើត ទើបរូបកើត** ។ នេះឈ្មោះថា **បហានបរិញ្ញា** ។ បណ្ឌិតគប្បីប្រកប **ញាតបរិញ្ញាថា** កាលកំណត់កាន់យកអជ្ឈត្តិករូប ក៏រមែងកំណត់កាន់យកកពឡិង្ការាហារ ដែលជាបច្ច័យនៃអជ្ឈត្តិករូបនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **ញាតបរិញ្ញា** ។ និងគប្បីប្រកប **តីរណប្បរិញ្ញា** ថា នឹងរមែងជាទុក្ខ តាមឃើញការកើតឡើង និងការវិនាសទៅ របស់អជ្ឈត្តិករូបនោះ ។ កាលបរិញ្ញាទាំង ៣ សម្រេចយ៉ាងនេះ ព្រះយោគីក៏រមែងឈ្មោះថា កម្ចាត់វិបល្លាសជាដើមនេះឯង ព្រោះដូច្នោះ ទើបលោកអាចារ្យពោលពាក្យថា **រមែងលះវិបល្លាសថា ស្អាតក្នុងរបស់ដែលមិនស្អាត** ដូច្នេះជាដើម ក្នុងពាក្យនេះលោកអាចារ្យពោលថា **អភិជ្ឈាកាយគន្ថ** ដូច្នេះ សំដៅដល់អភិជ្ឈាដែលជាកាមរាគៈ ។ ពិតណាស់ ការលះកាមរាគៈរមែងមានបានដោយការតាមឃើញថា មិនស្អាត ម្យ៉ាងទៀត លោកអាចារ្យពោលដល់ការលះលោភៈទាំងពួង ដោយពាក្យដែលជាប្រធាន គឺកាមរាគៈ ។ ឈ្មោះ

ថា **មិនប្រកាន់** បានដល់ មិនកាន់យក គឺមិនធ្វើឲ្យកើតឡើង ។ ព្រោះបានត្រាស់ទុកថា ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ដូច្នេះ បណ្ឌិតគប្បីប្រកបការកំណត់ដឹងផស្សៈ តាមន័យដែលបានពោលទុកហើយ ក្នុងការកំណត់ដឹងអាហារ ដោយពាក្យជាដើមថា **ការលះឆន្ទរាគៈក្នុងវេទនា** ឈ្មោះថា **រមែងលះឆន្ទរាគៈក្នុងផស្សាហារ** ដែលជាបច្ច័យ **ដល់វេទនានោះ ។ រមែងលះវិបល្លាស ថាជាសុខ** ក្នុងវេទនានោះ ដោយការឃើញវេទនាជាទុក្ខ កាលលះតណ្ហាក្នុងវេទនាបាន ឈ្មោះថា **រមែងឆ្លងឱឃៈ គឺភព** ព្រោះសេចក្តីប្រាថ្នាភពនឹងមានបាន ក៏ដើម្បីសេចក្តីសុខប៉ុណ្ណោះ ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា **រួចចេញអំពីភវយោគៈ** ។ និងឈ្មោះថា **ជាបុគ្គលមិនមានអាសវៈ ដោយភវាសវៈ** ។ កាលឃើញវេទនាទាំងពួងដោយភាពជាទុក្ខ រមែងមិនគិតដល់ទុក្ខ ដែលមិនធ្លាប់មានមកអំពីមុន ដែលបុគ្គលដទៃធ្វើឲ្យកើតឡើងដល់ខ្លួន ឬសេចក្តីសុខរបស់ខ្លួនដែលមិនធ្លាប់មានមកអំពីមុន ដែលបុគ្គលដទៃធ្វើឲ្យវិនាសទៅ ព្រោះដូច្នោះ ទើបឈ្មោះថា **រមែងទម្លាយកាយគន្ថៈ គឺព្យាបាទ** ព្រោះលះបង់បាននូវអាឃាតវត្ថុជាដើមថា អ្នកនេះបានប្រព្រឹត្តការវិនាសដល់អញ ។ បុគ្គលកាលមិនបានប្រកាន់ថា **សេចក្តីបរិសុទ្ធមានក្នុងសុគតិភពដែលច្រើនទៅដោយសេចក្តីសុខ** ប្រកាន់តែសេចក្តីបរិសុទ្ធដោយគោសីល និងគោវត្តជាដើម ឈ្មោះថា **រមែងប្រកាន់មាំដោយអំណាចសេចក្តីប្រាថ្នាសេចក្តីសុខ** នោះឯង ព្រោះដូច្នោះ សូម្បីការលះតណ្ហាក្នុងវេទនាបាន ក៏ឈ្មោះថា **មិនប្រកាន់មាំក្នុងសីលព្វតុបាទាន** ។

មនោសញ្ចេតនាជាសង្ខារក្ខន្ធ ចំណែកសញ្ញាប្រកបជាមួយមនោសញ្ចេតនានោះ ព្រោះដូច្នោះ បុគ្គលកាលឃើញសញ្ញា និងសង្ខារ ដោយភាពជាអនត្តា ឈ្មោះថា រមែងលះឆន្ទរាគៈក្នុងមនោសញ្ចេតនា និងរមែងកំណត់ ឬពិចារណាមនោសញ្ចេតនានោះ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **កាលឃើញសញ្ញា និងសង្ខារ ដោយ**

**ភាពជាអនត្តា រមែងកំណត់ដឹងមនោសញ្ចេតនាសង្ខារ** ។ លោកអាចារ្យកាលសម្ដែងថា បុគ្គលកាលឃើញសញ្ញា និងសង្ខារថា ជាអនត្តា ក៏ឈ្មោះថា រមែងទម្លាយទិដ្ឋិទាំងអស់ ដូចទម្លាយអត្តទិដ្ឋិបាន ព្រោះទិដ្ឋិទាំងអស់ មានអត្តទិដ្ឋិជាមូល ទើបពោលថា **រមែងធ្វូងផុតឱឃៈ គឺទិដ្ឋិ រមែងរើខ្លួនបានអំពីយោគៈ គឺទិដ្ឋិ រមែងជាអ្នកមិនមានអាសវៈដោយទិដ្ឋាសវៈ ទម្លាយកាយគន្ថៈ គឺឥទំសច្ចាភិនិវេស មិនប្រកាន់មាំក្នុងអត្តវាទុបាទាន** ។

**កាលឃើញវិញ្ញាណ ដោយភាពជារបស់មិនទៀង** ញុំាងអនុបស្សនាទាំង ៣ ឲ្យឈានទៅមុខដោយមាតិកា គឺអនិច្ចានុបស្សនា ឈ្មោះថា **រមែងកំណត់ដឹងវិញ្ញាណាហារ** ដោយបរិញ្ញាទាំង ៣ ។ តែក្នុងទីនេះពោលដោយភាពផ្សេងគ្នា **រមែងលះវិបល្លាសថា ទៀងក្នុងរបស់ដែលមិនទៀង** ។ ក្នុងសេចក្ដីនោះ ការប្រកាន់ថា ជាក្រុមជាដុំក្នុងវិញ្ញាណ រមែងមានបានដោយអវិជ្ជា ព្រោះច្រើនទៅដោយសេចក្ដីប្រកាន់ថាទៀង ដូច្នោះ ។ បុគ្គលកាលធ្វើការបំបែកភាពជាដុំជាក្រុមហើយ ឃើញវិញ្ញាណនោះដោយភាពជារបស់មិនទៀង ឈ្មោះថា **រមែងធ្វូងផុតឱឃៈ គឺអវិជ្ជា** ។ ព្រោះហេតុនោះឯង ទើបជាបុគ្គលរើខ្លួនចេញអំពីអវិជ្ជាយោគៈ **និងជាអ្នកមិនមានអាសវៈដោយអវិជ្ជាសវៈ** ។ សីលព្វតបរាមាសរមែងមានដោយកម្លាំងនៃមោហៈនោះឯង ព្រោះដូច្នោះកាលលះអវិជ្ជានោះបាន ទើបឈ្មោះថា ទម្លាយកាយគន្ថៈ គឺសីលព្វតបរាមាស ។

ដោយមានព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ឯធម្មជាតិណាដែលហៅថា ចិត្តក្ដី មនោក្ដី វិញ្ញាណក្ដី បុថុជ្ជនដែលមិនបានស្ដាប់ មិនអាចនឿយណាយ មិនអាចប្រាសចាកតម្រេក មិនអាចរួចផុតក្នុងធម្មជាតិនោះ ។ សេចក្ដីនោះ ព្រោះហេតុអ្វី ? ម្នាលភិក្ខុទាំងឡាយ ព្រោះថា ធម្មជាតិនេះ បុថុជ្ជនដែលមិនបានស្ដាប់ រមែងងប់ជ្រប់ប្រកាន់ថាជារបស់អញ ប្រកាន់មាំដោយភាពស្និតស្នេហថា នេះជារបស់អញ អញជារបស់នុ៎ះ

ទុំះជាខ្លួនរបស់អញ ដូច្នេះជាដើម ។ បុគ្គលកាលឃើញវិញ្ញាណដោយភាពជារបស់ទៀត រមែងប្រកាន់មាំក្នុងទិដ្ឋុបាទាន ដោយប្រការណា កាលឃើញវិញ្ញាណនោះ ជារបស់មិនទៀត **ក៏មិនប្រកាន់មាំក្នុងទិដ្ឋុបាទាន** ដោយប្រការ ដូច្នោះ ។

ពាក្យថា **មានអានិសង្សច្រើនយ៉ាងនេះ** គឺមានភាពបរិបូណ៌កើតឡើងយ៉ាងនេះ ព្រោះជាឧបាយកម្ចាត់សង្កិលេសទាំងអស់ មានវិបល្លាសជាដើមដោយប្រការដែលបានពោលហើយ ។ ពាក្យថា **ដោយអំណាចជាពេជ្ឈឃាតជាដើម** គឺដោយអំណាចជាពេជ្ឈឃាតដែលឆាវឆាវជាដើម ។ ពាក្យថា **គប្បីឃើញ** គឺគប្បីឃើញដោយប្រចក្សដោយញាណទស្សនៈ ។

ពណ៌នាខន្ធនិទ្ទេស ចប់

ពណ៌នាបរិច្ឆេទទី ១៤ ចប់ហើយ

ដោយប្រការ ដូច្នេះ

# វិសុទ្ធិមគ្គ

## អាយតនធាតុនិទ្ទេស

## អាយតននិទ្ទេស

*អាយតនៈ ១២ គឺចក្ខាយតនៈ រូបាយតនៈ សោតាយតនៈ សទ្ទាយតនៈ ឃានាយតនៈ គន្ធាយតនៈ ជិវ្ហាយតនៈ រសាយតនៈ កាយាយតនៈ ផោដ្ឋព្វាយតនៈ មនាយតនៈ ធម្មាយតនៈ ឈ្មោះថា អាយតនៈទាំងឡាយ ។*

*វិនិច្ឆ័យក្នុងអាយតនៈទាំងនោះបណ្ឌិតគប្បីជ្រាបដោយអត្ថនិងដោយលក្ខណៈ ដោយការមានត្រឹមប៉ុណ្ណោះ ដោយលំដាប់ ដោយសង្ខេប ដោយពិស្តារ ម្យ៉ាងទៀត ដោយភាពជាវត្ថុគប្បីឃើញផងដែរ ។*

## ដោយអត្ថ

## អធិប្បាយ ចក្ខុស័ព្ទជាដើម

*ក្នុងបទទាំងនោះ ពោលដោយអត្ថ ( នៃស័ព្ទ ) ដែលប្លែកមុន*

*ធម្មជាតិណារមែងឃើញ ហេតុនេះ ទើបធម្មជាតិនោះឈ្មោះថា ចក្ខុ ព្រោះ ( នៃស័ព្ទចក្ខតិឃើញ ) ថា រមែងត្រេកអរក្នុងរូប និងរមែងប្រាប់ ( ឲ្យដឹង ) រូប វត្ថុណារមែងសម្តែងពណ៌ ហេតុនោះ ទើបវត្ថុនោះឈ្មោះថា រូប ព្រោះ ( នៃស័ព្ទ រូបយតិ-សម្តែងនូវពណ៌ ) ថា រូបកាលដល់ភាពផ្លាស់ប្តូរពណ៌ រមែងប្រកាសភាព ក្នុងចិត្ត ។*

*ធម្មជាតិណារមែងបានឮ ហេតុនេះ ធម្មជាតិនោះ ឈ្មោះថា សោត វត្ថុណាត្រូវ ( បច្ច័យរបស់ខ្លួន ) បញ្ចូន ( ផ្ញើ ) ចេញទៅ ហេតុនេះ ទើបវត្ថុនោះ ឈ្មោះថា សទ្ទៈ ។*

ព្រោះ ( នៃស័ព្ទ **សប្បតិ** ត្រូវបញ្ជូនផ្ញើចេញទៅ ) ថា ត្រូវបន្ទីឡើង ( ឲ្យជាវត្ថុគប្បីដឹងតាមសោតៈ ) ។

ធម្មជាតិណា រមែងស្រូប ( យកក្លិន ) បាន ហេតុនេះ ទើបធម្មជាតិនោះ ឈ្មោះថា ឃានៈ វត្ថុណារមែងកាយទៅបាន ហេតុនេះ ទើបវត្ថុនោះឈ្មោះថា គន្ធៈ ( ក្លិន ) ព្រោះ ( នៃស័ព្ទ **គន្ធយតិ**-កាយទៅ ) ថា ប្រាប់ទីនៅរបស់ខ្លួន ។

ធម្មជាតិណារមែងហៅជីវិត ហេតុនេះ ទើបធម្មជាតិនោះ ឈ្មោះថា ជិវ្ហា សត្វទាំងឡាយរមែងពេញចិត្តនូវវិស័យនោះ ហេតុនេះ ទើបវិស័យនោះឈ្មោះថា រស ( វិស័យជាទីពេញចិត្តនៃសត្វទាំងឡាយ ) ព្រោះ ( នៃស័ព្ទ **រសន្តិ**-ពេញចិត្ត ) ថា ត្រេកអរ ( ជឹងឆ្ងាញ់ ) ។

ធម៌ដែលឈ្មោះថា កាយ ព្រោះជាអាយ ( ដែលមក ) នៃកុច្ឆិតធម៌ ( ថោកទាប ) គឺសាសវធម៌ ( ធម៌ដែលប្រព្រឹត្តទៅជាមួយអាសវៈ ) ទាំងឡាយ ពាក្យថា អាយ ( ដែលមក ) បានដល់ ទីកើត ។

វត្ថុណាត្រូវបាន ( ដោយកាយ ) ហេតុនេះ ទើបវត្ថុនោះឈ្មោះថា ផោដ្ឋព្វៈ ។

សភាវៈណា រមែងដឹង ហេតុនេះ ទើបសភាវៈនោះឈ្មោះថា មនៈ សភាវៈទាំងឡាយណា រមែងទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ហេតុនេះ ទើបសភាវៈទាំងឡាយនោះ ឈ្មោះថា ធម្មៈ ។

## អធិប្បាយ អាយតនស័ព្ទដោយចែកអវយវៈ

តែបើពោលដោយមិនប្លែកគ្នា គប្បីជ្រាបថា ទ្វារ និងអារម្មណ៍ មានចក្ខុ និងរូបជាដើមនោះ បានឈ្មោះថា អាយតនៈ ព្រោះជាទីបន្ត ១ ព្រោះបង្ហូរ អាយៈទាំងឡាយ ១ ព្រោះនាំអាយតៈទៅ ១ ។

( អត្ថន័យទី ១ គឺ **អាយតនតោ**-ព្រោះជាទីបន្ត ) អធិប្បាយថា ចិត្ត និង ចេតសិកធម៌ទាំងឡាយរមែងបន្ត គឺព្យាយាមទៅតាមកិច្ច ( គឺនាទី ) របស់ខ្លួនរៀងៗ ខ្លួន មានការសោយ ( សេអារម្មណ៍ ) ជាអាទិ ក្នុងទ្វារ និងអារម្មណ៍នោះៗ មានចក្ខុ និងរូបជាដើម ( ព្រោះហេតុនោះ ទ្វារ និងអារម្មណ៍នោះៗ ទើបឈ្មោះថា អាយតនៈ ) ប្រែថា ជាទីបន្តនៃចិត្ត និងចេតសិកធម៌ទាំងឡាយ ) ។

( អត្ថន័យទី ២ គឺ **អាយានំ តននតោ**-ព្រោះបង្ហូរអាយៈទាំងឡាយ ) អធិប្បាយ ថា ទ្វារ និងអារម្មណ៍ទាំងឡាយនោះ រមែងផ្សាយ គឺពង្រីក (ចិត្ត ចេតសិក) ធម៌ ទាំងនោះដែលជាអាយៈ ( អ្នកមក ) ព្រោះហេតុនោះ ទើបទ្វារ និងអារម្មណ៍ទាំងនោះ ឈ្មោះថា អាយតនៈ ( ប្រែថា បង្ហូរពង្រីកអាយៈ គឺចិត្ត និងចេតសិកធម៌ ) ។

( អត្ថន័យទី ៣ គឺ **អាយតស្ស នយនតោ**-ព្រោះនាំអាយតៈទៅ ) មាន អធិប្បាយថា ទ្វារ និងអារម្មណ៍ទាំងឡាយនោះនៅមិនត្រឡប់ ( គឺនៅមិនរលត់ ) ត្រឹមណា ក៏រមែងនាំទៅ គឺញុំាងសង្សារទុក្ខដែលប្រព្រឹត្តទៅក្នុងសង្សារ ដែលមិនមាន ទីបំផុតខាងដើម និងខាងចុង ជាអាយតៈ ( គឺយឺតយូរ ) ច្រើនណាស់ទៅហើយ ឲ្យប្រព្រឹត្តទៅដរាបនោះ ( ព្រោះហេតុនោះ ទើបទ្វារ និងអារម្មណ៍ទាំងឡាយនោះ ឈ្មោះថា អាយតនៈ ប្រែថា នាំអាយតនៈ គឺសង្សារទុក្ខ ដែលយឺតយូរទៅហើយ)។

ធម៌ទាំងពួងនេះបានឈ្មោះថា អាយតនៈៗ ព្រោះជាទីបន្ត ( នៃចិត្ត ចេតសិក ) ១ ព្រោះកាយអាយៈ ( គឺចិត្ត និងចេតសិកដែលមកក្នុងទ្វារ និងអារម្មណ៍នោះៗ ) ១ ព្រោះនាំអាយតៈ ( គឺសង្សារទុក្ខដែលយឺតយូរហើយ ) ទៅ ១ ដោយន័យដូចពោល មក ដូច្នេះ ។

## អធិប្បាយ អាយតនស័ព្ទដោយបរិយាយ

ន័យម្យ៉ាងទៀត **អាយតន**-ស័ព្ទ គប្បីជ្រាបដោយអត្ថថាជាស្ថានទីនៅ ១ ដោយ

អត្ថថា ជាអណ្ដូងកំណើត ១ ដោយអត្ថថា ជាទីប្រជុំ ១ ដោយអត្ថថា ជាទីកន្លែងកើត ១ ដោយអត្ថថា ជាហេតុ ១ ។

ពិតហើយ ស្ថានទីនៅ ហៅថា អាយតនៈបាន ក្នុងពាក្យថា **ឥស្សរាយតនំ**-កន្លែងព្រះឥស្វរ **វាសុទេវាយតនំ**-កន្លែងព្រះវាសុទេពជាដើម អណ្ដូងកើតក៏ហៅអាយតនៈបាន ក្នុងពាក្យថា **សុវណ្ណាយតនៈ**-អណ្ដូងមាស **រតនាយតនំ**-អណ្ដូងកែវ ( ត្បូងពេជ្រ ) ជាដើម ចំណែកក្នុងព្រះសាសនានេះ ស្ថានទីដែលប្រជុំក៏ហៅអាយតនៈបាន ក្នុងពាក្យថា **មនោរមេ អាយតនេសេវន្តិ នំ វិហង្គមា**-ពួកវិហគក្នុងព្រៃដែលជាទីប្រជុំពេញចិត្ត រមែងសេពដើមឈើធំនោះជាដើម លំនៅ ( ឬប្រភព ) កំណើតក៏ហៅអាយតនៈបាន ក្នុងពាក្យថា **ទក្ខិណាបថោ គុន្នំអាយតនំ**-ប្រទេសទក្ខិណាបថ ( តំបន់ខាងត្បូង ) ជាលំនៅកំណើត នៃគោទាំងឡាយជាដើម ហេតុក៏ហៅអាយតនៈបាន ក្នុងពាក្យថា **តត្រ តត្រេ វ សក្ខិ ភព្វតំ បាបុណាតិ សតិ សតិ អាយតនេ**-កាលហេតុមាន ភិក្ខុនោះរមែងដល់ភាពជាអ្នកធ្វើឲ្យប្រចក្សក្នុងធម៌នោះៗ តែម្យ៉ាងជាដើម ។

បរិយាយម្យ៉ាងទៀត ចិត្ត និងចេតសិកធម៌នោះៗ ក៏ ( ដូច ) អាស្រ័យនៅក្នុងទ្វារ និងអារម្មណ៍ទាំងឡាយ មានចក្ខុជាដើម ព្រោះមានការប្រព្រឹត្តទៅទាក់ទងជាមួយចក្ខុជាដើមនោះ ហេតុនោះ ទើបទ្វារ និងអារម្មណ៍ មានចក្ខុជាដើមបាន ឈ្មោះថា ជាទីនៅនៃចិត្ត និងចេតសិកទាំងនោះប្រការ ១ ។

ម្យ៉ាងទៀត ចិត្ត ចេតសិកទាំងនោះ ដេរដាសនៅក្នុងចក្ខុជាដើម ព្រោះអាស្រ័យចក្ខុជាដើមនោះ ( ជាទ្វារ ) និងព្រោះមានរូបជាដើមនោះជាអារម្មណ៍ ហេតុនោះ ទើបទ្វារ និងអារម្មណ៍ មានចក្ខុជាដើមបានឈ្មោះថា ជាអណ្ដូងកើតនៃចិត្ត និងចេតសិកទាំងនោះប្រការ ១ ។

ទ្វារ និងអារម្មណ៍ មានចក្ខុជាដើម បានឈ្មោះថា ជាទីប្រជុំនៃចិត្ត និងចេតសិក

ទាំងនោះ ព្រោះចិត្ត និងចេតសិកនោះ ហាក់ដូចជាប្រជុំគ្នាក្នុងទ្វារ និងអារម្មណ៍នោះៗ ដោយមានចក្ខុជាដើមនោះជាវត្ថុ ( ទីតាំង ) ជាទ្វារ និងជាអារម្មណ៍ប្រការ ១ ។

ទ្វារ និងអារម្មណ៍ មានចក្ខុជាដើម បានឈ្មោះថា ជាប្រភពកើតនៃចិត្ត ចេតសិកទាំងនោះ ព្រោះចិត្ត និងចេតសិកទាំងនោះកើតឡើងតែក្នុងចក្ខុជាដើមនោះប៉ុណ្ណោះ ដោយមានចក្ខុជាដើមនោះជាទីអាស្រ័យ និងមានរូបជាដើមជាអារម្មណ៍ ប្រការ ១ ។

ទ្វារ និងអារម្មណ៍ មានចក្ខុជាដើម បានឈ្មោះថា ជាហេតុនៃចិត្ត និងចេតសិកទាំងឡាយនោះ ព្រោះកាលទ្វារ និងអារម្មណ៍ទាំងនោះមិនមាន ចិត្ត និងចេតសិកក៏មិនមាន ប្រការ ១ ។

ធម៌ទាំងឡាយ មានចក្ខុ និងរូបជាដើមនោះ បានឈ្មោះថា អាយតនៈៗ សូម្បីដោយហេតុទាំងនេះ គឺដោយអត្ថថា ជាស្ថានទីនៅ ១ ដោយអត្ថថា ជាអណ្តូងកើត ១ ដោយអត្ថថា ជាទីប្រជុំ ១ ដោយអត្ថថា ជាប្រភព ( ឬកន្លែង ) កំណើត ១ ដោយអត្ថថា ជាហេតុ ១ ដោយន័យដូចពោលមកនេះឯង ។

ព្រោះហេតុនោះ វិនិច្ឆ័យក្នុងអាយតនៈទាំងនេះ គប្បីជ្រាបដោយអត្ថយ៉ាងនេះមុនថា ចក្ខុផង ចក្ខុនោះជាអាយតនៈ ដោយអត្ថតាមដែលពោលហើយផង ហេតុនោះទើបឈ្មោះថា ចក្ខាយតនៈ ។បេ។ ធម៌ទាំងឡាយផង ធម៌ទាំងនោះជាអាយតនៈ ដោយអត្ថតាមដែលពោលហើយផង ហេតុនោះ ទើបឈ្មោះថា ធម្មាយតនៈ ។

## ដោយលក្ខណៈ

ពាក្យថា *លក្ខណៈ* គឺវិនិច្ឆ័យក្នុងអាយតនៈទាំងនេះ គប្បីជ្រាបដោយលក្ខណៈនៃចក្ខុជាដើមផង លក្ខណៈទាំងឡាយនៃចក្ខុជាដើមទាំងនោះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយក្នុងខន្ធនិទ្ទេសចុះ ។

## ដោយមានត្រឹមប៉ុណ្ណោះ

ពាក្យថា **តាវត្វតោ** គឺ **តាវភាវតោ** ប្រែថា ដោយមានត្រឹមប៉ុណ្ណោះនោះ មានព្រះពុទ្ធាធិប្បាយនេះថា បើមានពាក្យចោទសួរថា ធម៌ទាំងឡាយ មានចក្ខុជាដើម គឺធម៌នោះឯង កាលដូច្នោះ ហេតុអ្វី ទើបមិនត្រាស់ថា ធម្មាយតនៈតែប៉ុណ្ណោះ តែត្រាស់អាយតនៈដល់ ១២ ទៅវិញ ? ពាក្យឆ្លើយ គប្បីមានថា ព្រោះក្នុងទីនេះញែកជាទ្វារ ១ ផ្នែក ជាអារម្មណ៍ ១ ផ្នែក នៃកងវិញ្ញាណ ៦ ដោយទ្រង់កំណត់ ( ចក្ខុ និងរូបជាដើមនោះទុក ) ជាឧប្បត្តិទ្វារ និងជាអារម្មណ៍នៃកងវិញ្ញាណ ៦ នេះឯងជាភាពផ្សេងគ្នានៃធម៌ទាំងនោះ ព្រោះហេតុនេះ ទើបត្រាស់អាយតនៈដល់ ១២ ពិតហើយ ចក្ខាយតនៈប៉ុណ្ណោះជាឧប្បត្តិទ្វារ និងរូបាយតនៈប៉ុណ្ណោះជាអារម្មណ៍នៃកងវិញ្ញាណ ដែលទាក់ទងក្នុងវិថីរបស់ចក្ខុវិញ្ញាណដូចគ្នានោះ អាយតនៈក្រៅអំពីនោះក៏ជាឧប្បត្តិទ្វារ និងជាអារម្មណ៍ នៃកងវិញ្ញាណដែលទាក់ទងក្នុងវិថីរបស់វិញ្ញាណក្រៅអំពីនេះ ចំណែកមនាយតនៈជាឯកទេស ( ចំណែក ១ ) បានដល់ ភវង្គមនៈប៉ុណ្ណោះជាឧប្បត្តិទ្វារ និងធម្មាយតនៈជាអារម្មណ៍នៃកងវិញ្ញាណទី ៦ មិនទូទៅ ( ដល់វិញ្ញាណដទៃ មានចក្ខុវិញ្ញាណជាដើម ) ។

អាយតនៈ ១២ ព្រះមានព្រះភាគត្រាស់ដោយទ្រង់កំណត់ទុកជាឧប្បត្តិទ្វារ និងជាអារម្មណ៍នៃកងវិញ្ញាណ ៦ ដូច្នេះឯង ។

វិនិច្ឆ័យដោយមានត្រឹមប៉ុណ្ណោះ ក្នុងអាយតនៈទាំងនេះ បណ្ឌិតគប្បីជ្រាបដូចពោលមក ដូច្នេះ ។

## ដោយលំដាប់

ពាក្យថា ដោយលំដាប់ សេចក្ដីថា បណ្ដាលំដាប់ទាំងឡាយ មានលំដាប់នៃការ

កើតជាដើម ដែលពោលហើយក្នុងនិទ្ទេសមុន សូម្បីក្នុងទីនេះក៏លំដាប់នៃការសម្តែងប៉ុណ្ណោះឯងប្រើបាន ពិតណាស់ ក្នុងបណ្តាអាយតនៈខាងក្នុងចក្ខាយតនៈ ជាអាយតនៈដែលប្រាកដ ព្រោះជាវិស័យដែលឃើញបាន និងប៉ះខ្ទប់បាន ហេតុនេះ ទើបទ្រង់សម្តែងជាប្រការដំបូងមុន តពីនោះ ទើបទ្រង់សម្តែងអាយតនៈដ៏សេស មានសោតាយតនៈជាដើមជាវិស័យដែលឃើញមិនបានតែប៉ះខ្ទប់បាន ។ន័យម្យ៉ាងទៀតក្នុងបណ្តាអាយតនៈខាងក្នុងចក្ខាយតនៈ និងសោតាយតនៈទ្រង់សម្តែងមុន ព្រោះជាវត្ថុមានឧបការច្រើនដោយភាពជាហេតុនៃទស្សនានុត្តរិយៈ និងសវនានុត្តរិយៈ បន្ទាប់អំពីនោះ ទើបទ្រង់សម្តែងអាយតនៈ ៣ មានឃានាយតនៈជាដើម មនាយតនៈទ្រង់សម្តែងទុកក្នុងទីបំផុត ព្រោះជាគោចរវិស័យនៃអាយតនៈ ៥ មានចក្ខាយតនៈជាដើម ចំណែកក្នុងពួកអាយតនៈខាងក្រៅអាយតនៈ ៦ មានរូបាយតនៈជាដើម ទ្រង់សម្តែងទុកជាលំដាប់ៗ នៃអាយតនៈខាងក្នុងនោះៗ ព្រោះជាគោចរនៃអាយតនៈខាងក្នុង មានចក្ខាយតនៈជាដើម ។

ន័យម្យ៉ាងទៀត លំដាប់របស់អាយតនៈទាំងឡាយនេះ បណ្ឌិតគប្បីជ្រាបដោយកំណត់ ( បែកទៅតាមលំដាប់ ) ហេតុកើតនៃវិញ្ញាណក៏បាន ពិតណាស់ ពាក្យនេះព្រះមានព្រះភាគក៏បានត្រាស់ទុកថា អាស្រ័យចក្ខុ និងរូប កើតចក្ខុវិញ្ញាណ ។បេ។ អាស្រ័យមនៈ និងធម៌ទាំងឡាយ កើតមនោវិញ្ញាណ ដូច្នេះ ។

វិនិច្ឆ័យដោយលំដាប់ក្នុងអាយតនៈទាំងនេះ បណ្ឌិតគប្បីជ្រាបដូចពោលមកនេះចុះ ។

## ដោយសង្ខេប និង ដោយពិស្តារ

ពាក្យថា ដោយសង្ខេប និងដោយពិស្តារ សេចក្តីថា កាលពោលដោយសង្ខេបអាយតនៈទាំង ១២ ក៏ជានាមរូបប៉ុណ្ណោះ ព្រោះមនាយតនៈ និងធម្មាយតនៈជាចំណែក ១ សង្គ្រោះចូលជាមួយនាម និងអាយតនៈដ៏សេសនោះ សង្គ្រោះចូលជាមួយរូប

តែពោលដោយពិស្តារ ក្នុងអាយតនៈខាងក្នុងមុន ចក្ខាយតនៈដោយជាតិក៏ត្រឹមតែចក្ខុបសាទប៉ុណ្ណោះ តែចែកចេញទៅដោយបច្ច័យ គតិ និកាយ និងបុគ្គលក៏មានប្រភេទជាអនន្តៈ អាយតនៈ ៤ មានសោតាយតនៈជាដើមក៏យ៉ាងនោះ មនាយតនៈមាន ៨៩ ប្រភេទ ដោយចែកជាកុសលវិញ្ញាណ អកុសលវិញ្ញាណ វិបាកវិញ្ញាណ និងកិរិយាវិញ្ញាណ និង ( ន័យម្យ៉ាងទៀត ) មានដល់ ១២១ ប្រភេទ តែកាលចែកជាវត្ថុ និងបដិបទាជាដើម ក៏មានប្រភេទជាអនន្តៈ ។

រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ និងរសាយតនៈក៏មានប្រភេទជាអនន្តៈ ដោយចែកជាសភាគ វិសភាគ និងបច្ច័យជាដើម ផោដ្ឋព្វាយតនៈមាន ៣ ប្រភេទ ដោយអំណាចនៃបឋវីធាតុ តេជោធាតុ និងវាយោធាតុ តែដោយភាពផ្សេងគ្នានៃបច្ច័យជាដើម ក៏មានប្រភេទជាអនេក ធម្មាយតនៈមានប្រភេទជាអនេកដោយភាពផ្សេងគ្នានៃសភាវៈ និងដោយភាពផ្សេងគ្នានៃវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ សុខុមរូប និងព្រះនិព្វាន ។

វិនិច្ឆ័យដោយសង្ខេប និងដោយពិស្តារ បណ្ឌិតគប្បីជ្រាបដូចពោលមកដូច្នេះ ។

## ដោយភាពជាវត្ថុគប្បីឃើញ

ចំណែកក្នុងពាក្យថា ដោយភាពជាវត្ថុគប្បីឃើញនេះ មានវិនិច្ឆ័យថា អាយតនៈទាំងឡាយដែលជាសង្ខតៈទាំងអស់ គប្បីឃើញដោយភាពមិនមក និងដោយភាពមិនប្រាសទៅ ។ ពិតហើយ អាយតនៈទាំងនោះ មុននឹងកើតក៏មិនបានមកពីទីណាខាងមុខអំពីរលត់ទៅ ក៏មិនបានទៅក្នុងទីណាមួយ ដោយពិត មុននឹងកើតឡើងនោះវាក៏មិនបានមានសភាវៈចំពោះមុខ តែវិនាសទៅ វាក៏ជាវត្ថុដែលមានសភាវៈ ដែលបែកធ្លាយទៅហើយ ត្រង់កណ្តាល ( រវាង ) ខាងដើម និងចុងក៏ជាវត្ថុមិនមានអំណាចប្រព្រឹត្តទៅ ព្រោះមានការប្រព្រឹត្តទៅទាក់ទងដោយបច្ច័យ ព្រោះហេតុនោះ អាយតនៈ

ទាំងនោះ បណ្ឌិតគប្បីឃើញដោយភាពមិនមក និងដោយភាពមិនប្រាសទៅ ដូច្នេះ ។

ន័យម្យ៉ាងទៀតនោះ គប្បីឃើញដោយភាពមិនមានការតម្រិះ និងដោយភាពមិនមានការខ្វល់ខ្វាយ ។ ពិតហើយ ភាពត្រិះរិះយ៉ាងនេះរមែងមិនមានដល់ចក្ខុ និងរូប ជាដើមថា ឱ ឈ្មោះថា វិញ្ញាណ គប្បីកើតឡើងព្រោះការព្រមព្រៀងរបស់យើងទាំងឡាយចុះ ទាំងចក្ខុ និងរូបជាដើមទាំងនោះក៏មិនត្រិះរិះ មិនដល់នូវការខ្វល់ខ្វាយដោយភាពជាទ្វារក្តី ដោយភាពជាវត្ថុក្តី ដោយភាពជាអារម្មណ៍ក្តី ដើម្បីឲ្យវិញ្ញាណកើតឡើង ដែលពិត វាជាធម្មតានេះឯង ដែលវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើមកើតឡើងក្នុងការព្រមព្រៀងនៃចក្ខុ និងរូបជាដើម ព្រោះហេតុនោះ អាយតនៈទាំងនោះ បណ្ឌិតគប្បីឃើញដោយភាពមិនមានការត្រិះរិះ និងដោយមិនមានការខ្វល់ខ្វាយចុះ ។

ន័យម្យ៉ាងទៀត អាយតនៈខាងក្នុងគប្បីឃើញដូចផ្ទះដែលគេបោះបង់ចោល ព្រោះប្រាសចាកការស្ថិតស្ថេរ ភាពស្អាត សេចក្តីសុខ និងភាពជាតួខ្លួន អាយតនៈខាងក្រៅគប្បីឃើញដូចចោរប្លន់អ្នកស្រុក ព្រោះអាយតនៈខាងក្រៅនោះ ជាផ្នែកអភិឃាត ( ប៉ះពាល់ បៀតបៀន ) នូវអាយតនៈខាងក្នុង សមដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ចក្ខុឃើញរូបទាំងឡាយដែលជាទីពេញចិត្ត និងមិនជាទីពេញចិត្តបៀតបៀន ដូច្នេះជាដើម សេចក្តីពិស្តារបណ្ឌិតគប្បីជ្រាប ( តាមព្រះបាលីនោះចុះ )។

ន័យម្យ៉ាងទៀត អាយតនៈខាងក្នុងគប្បីឃើញដូចសត្វ ៦ ជំពូក អាយតនៈខាងក្រៅ គប្បីឃើញទីគោចរនៃសត្វ ៦ ជំពូកនោះ ។

វិនិច្ឆ័យដោយភាពជាវត្ថុគប្បីឃើញក្នុងអាយតនៈទាំងនេះ បណ្ឌិតគប្បីជ្រាបដូចពោលមកនេះចុះ ។

នេះជាកថាមុខយ៉ាងពិស្តារនៃអាយតនៈទាំងឡាយ ដែលជាលំដាប់ដំបូង ។

# មហាដីកា

## ពណ៌នាអាយតននិទ្ទេស និង ធាតុនិទ្ទេស
## កថាពណ៌នាដោយពិស្តារនៃអាយតនៈ

*លោកអាចារ្យកាលពោលពាក្យដែលលើកឡើងសម្តែងទុកខាងដើម ដោយពាក្យមានពាក្យជាដើមថា* ***ទ្វ អាយតនៈ*** *ថា* ***អាយតនៈទាំងឡាយ*** *ដោយអំណាចការពង្រីកបទ ហើយពោលថា* ***អាយតនៈ ១២*** *ដោយការកំណត់ចំនួន ។ ពាក្យដែលគប្បីពោលក្នុងអាយតនៈទាំងនោះ លោកអាចារ្យពោលដល់ខ្លួនឯងនោះឯង ក្នុងខាងមុខ ។ ពាក្យថា* ***ចក្ខាយតនៈ*** *ជាដើម ជាពាក្យសម្តែងរូបរបស់ខ្លួននៃអាយតនៈទាំងនោះ ។*

*អត្ថនៃសព្ទ ឈ្មោះថា* ***អត្ថ*** *។ ចំណែកអត្ថនៃសភាវៈ បានដល់* ***លក្ខណៈនោះឯង*** *។ អត្ថនៃសព្ទនោះមាន ២ យ៉ាង គឺជាអត្ថមិនទូទៅ ១ ជាអត្ថដែលទូទៅ ១ ។ ក្នុងអត្ថ ២ យ៉ាងនោះ អត្ថដែលមិនទូទៅ បានដល់អត្ថនៃសព្ទ មានចក្ខុជាដើម អត្ថដែលទូទៅ បានដល់ អត្ថនៃសព្ទថា អាយតនៈ ព្រោះជាអត្ថ ដែលស្មើគ្នានៃអាយតនៈទាំង ១២ ។*

*ក្នុងអត្ថ ២ យ៉ាងនោះ កាលនឹងសម្តែងអត្ថដែលមិនទូទៅមុន ទើបពោលពាក្យថា* ***ពោលដោយអត្ថដែលផ្សេងគ្នាមុន*** *ដូច្នេះជាដើម ។ ក្នុងពាក្យនោះ* ***ពោលដោយអត្ថដែលផ្សេងគ្នា*** *គឺដោយអត្ថដែលប្លែកគ្នា អធិប្បាយថា ដោយអត្ថនៃសព្ទមានចក្ខុជាដើម ។ បទថា* ***អស្សាទេតិ*** *សេចក្តីថា សព្ទថា* ***ចក្ខតិ*** *ប្រាប់ដល់អត្ថន័យដោយអំណាចនៃចក្ខតិសព្ទនោះ ព្រោះមានអត្ថថា ត្រេកអរក្នុងរស ដូចពាក្យថា* ***មធុំចក្ខតិ*** *ប្រែថា ត្រេកអរក្នុងទឹកឃ្មុំ* ***ព្យញ្ជនំ ចក្ខតិ*** *ប្រែថា ត្រេកអរក្នុងម្ហូបក្រៀម ។ ទើបចក្ខុឈ្មោះថា* ***ត្រេកអរនូវរូប*** *ព្រោះមានព្រះបាលីថា* ***ចក្ខុំ ខោ បន មាគន្ទិយ***

**រូបារម្មំ រូបរតំ រូបសម្មុទិតំ** ប្រែថា ម្នាលមាគន្ទិយៈ ចក្ខុនេះ មានរូបជាទីមក ត្រេកអរៗ ក្នុងរូប រីករាយត្រេកអរហើយក្នុងរូប ។ បណ្ឌិតគប្បីឃើញថា សូម្បីកាល ដែលអាយតនៈដទៃ មានសោតៈជាដើម និងមានកាវៈជាដើមថា មានភាពជាអាយតនៈ ដែលមានសំឡេងជាទីនាំមកនូវការត្រេកអរ ភាពផ្សេងគ្នានៃអត្ថឯណា ដែលត្រាស់ ទុកក្នុងព្រះបាលី ដោយពាក្យជាដើមថា **យំ ចក្ខុំ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ** ប្រែថា ចក្ខុណាជាបសាទរូប អាស្រ័យមហាភូតរូប ៤ ដែលពោលទុក ក្នុងអដ្ឋកថាដោយពាក្យជាដើមថា **រូបាភិឃាតារហភូតប្បសាទលក្ខណំ** ប្រែថា ចក្ខុ មានភាពថ្លានៃភូតរូប ដែលគួរដល់ការប៉ះខ្ទប់នូវរូបជាលក្ខណៈ ក្នុងភាពផ្សេងនៃអត្ថ នោះឯង ព្រោះចក្ខុស័ព្ទជាស័ព្ទជាប់មាត់ ចក្ខុស័ព្ទរមែងប្រព្រឹត្តទៅក្នុងភ្នែកប៉ុណ្ណោះ ដូចស័ព្ទ មានគោស័ព្ទជាដើម រមែងប្រព្រឹត្តទៅក្នុងសត្វ មានគោជាដើម ។

បទថា **វិភាវេតិ ច** សេចក្តីថា **ចក្ខតិ**-ស័ព្ទ រមែងប្រាប់ដល់អត្ថន័យដោយ អំណាចនៃចក្ខតិស័ព្ទដែលសម្រេចដោយលក្ខណៈនៃស័ព្ទ ( វេយ្យាករណ៍ ) ។ បទថា **ចក្ខតិ** សេចក្តីប៉ុនគ្នានឹង **អាចិក្ខតិ** ដែលប្រែថា រមែងប្រាប់ អធិប្បាយថា រមែងប្រាប់ យ៉ាងច្បាស់លាស់ ។ លោកអាចារ្យពោលថា **អធិប្បាយថា រមែងធ្វើឲ្យជាក់ច្បាស់** ដូច្នេះ ព្រោះអធិប្បាយថា ការញុំាងទីស្មើ និងមិនស្មើ ឲ្យជាក់ច្បាស់នោះឯង ឈ្មោះ ថា ការប្រាប់នៃភ្នែក ដូចជាកំពុងប្រាប់ ន័យម្យ៉ាងទៀត បណ្ឌិតគប្បីឃើញចក្ខតិស័ព្ទ មានអត្ថន័យថា ធ្វើឲ្យជាក់ច្បាស់ ព្រោះធាតុទាំងឡាយមាន អត្ថមិនមែនតិច ។ ក្នុង វេលាដែលស្រឡាញ់ និងខឹងក្រោធជាដើម រូបដែលដល់នូវការប្រែប្រួលរបស់ពណ៌ ក៏ដូចរូបរបស់សត្វបក្ខីយ និងដូចរូបរបស់នាគ រមែងសម្តែងភាវៈដែលនៅក្នុងចិត្ត រមែងធ្វើការប្រកាសដូចរូបរាង អធិប្បាយថា រមែងសម្តែងធ្វើឲ្យដូចគ្នានឹងរូបរាង ន័យម្យ៉ាងទៀត រមែងខ្នះខ្នែង ជាអត្ថរបស់រូបស័ព្ទ និងការពង្រីក គឺការប្រកាស

នោះឯង ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **បកាសេតីតិ អត្ថោ** សេចក្តីថា រមែងប្រកាស ។ ន័យម្យ៉ាងទៀត ព្រោះធាតុទាំងឡាយមានអត្ថមិនមែនតិច ទើបគប្បីឃើញរូបសព្ទថា មានអត្ថថា ប្រកាសទុកនោះឯង ។ រូបសព្ទដែលប្រាប់ដល់វណ្ណៈ មានពាក្យលម្អិតថា **រូបយតិ** ប្រែថា ប្រកាស ដែលប្រាប់ដល់រូបក្ខន្ធ មានអត្ថផ្សេងចេញទៅដូច្នេះថា **រុប្បតិ** ប្រែថា រមែងបែកធ្លាយ ។ ក្នុងអត្ថរបស់បទថា **ឧទាហរិយតិ** ថា **វុច្ចតិ** ដែលប្រែថា ដែលបុគ្គលពោលគួរនឹងកាន់យកចំពោះសំឡេង គឺពាក្យសម្តីប៉ុណ្ណោះហើយ សំឡេងក្នុងទីនេះមិនគួរនឹងកាន់យកសំឡេងរបស់ពាក្យពោលប៉ុណ្ណោះដោយពិតនោះ កាន់យកសំឡេងទាំងអស់ ដែលសោតៈគប្បីដឹងបានដូច្នេះ ។ បទថា **សប្បតិ** ប្រែថា ដែលបច្ច័យរបស់ខ្លួនបញ្ជូនទៅ អធិប្បាយថា ឲ្យដល់នូវភាវៈ ដែលសោតៈគប្បីដឹងបាន ។

ពាក្យថា **រមែងប្រាប់បង្ហាញ** អធិប្បាយថា គឺរមែងប្រកាសទីនៅរបស់ខ្លួន ដែលមិនប្រាកដដោយអំណាចក្លិនថា ទីនេះមានក្លិនក្រអូប ទីនេះមានក្លិនស្អុយ ឬរមែងដូចជាធ្វើការប្រាប់នូវទីលំនៅរបស់ផ្កាឈើជាដើម ដែលបិទបាំងទុកថា ក្នុងទីត្រង់នេះមានផ្កាឈើ ក្នុងទីត្រង់នេះមានផ្លែឈើ មានផ្កាចម្ប៉ាជាដើម ក្នុងទីត្រង់នេះមានផ្លែស្វាយជាដើម ធម្មជាតិឈ្មោះថា **ជិវ្ហា** ព្រោះអត្ថថា **ហៅមកនូវជីវិត** ដោយលក្ខណៈនៃនិរុត្តិ ព្រោះភាពដែលធម្មជាតិនោះបង្អោនទៅក្នុងរសរបស់អាហារ ដែលមានជីវិតជាហេតុ ព្រោះការលេបមានការកាន់យករសជាមូល ។លោកពោលដល់ **កាយ** ដោយពិសេស **ព្រោះជាទីមកនៃធម៌ដែលបណ្ឌិតស្អប់ទាំងឡាយ** ដែលបានដល់ **សាសវធម៌** ព្រោះបណ្តាជិវ្ហា និងកាយដែលត្រូវកម្ម មានកាមរាគៈជាដើមហេតុឲ្យកើតហើយ មិនទាន់ដល់នូវភាពជាហេតុនៃអនុត្តរិយៈ និងជាបច្ច័យពិសេសរបស់កាមរាគៈ សម្រាប់កាយជាបច្ច័យដល់សាសវធម៌ដែលពិសេសក្រៃលែង ។ដោយហេតុនោះឯង សត្វទាំងឡាយ

ដែលនៅពេញចិត្តក្នុងសុខ ដែលកើតអំពីផោដ្ឋព្វៈ ទើបសេពមេថុនបាន ។ ពាក្យថា **ដែលកើត** សេចក្តីថា ទីឋានកើតឡើង ម្យ៉ាងទៀត ខន្ធ ៤ ដែលមានកាយិន្ទ្រិយជាទីតាំង លោកពោលថា សាសវធម៌ដោយពិសេស ព្រោះជាហេតុនៃអាសវៈ មានកាមាសវៈ ជាដើម ដែលមានកម្លាំង ព្រោះដូច្នោះ ទើបមានអត្ថថា ជាកន្លែងដែលកើតឡើងរបស់ សាសវធម៌ទាំងនោះ ។

ពាក្យថា **រមែងដឹង** សេចក្តីថា រមែងដឹងច្បាស់នូវអារម្មណ៍ ដូចជាវាល់ដោយ នាឡិ និងដូចថ្លឹងដោយជញ្ជីងធំ ។ ម្យ៉ាងទៀត ឈ្មោះថា **មនៈ** ព្រោះអត្ថថា ដឹង អធិប្បាយថា រមែងដឹងអារម្មណ៍នោះៗ ដោយអំណាចការកំណត់ ។ ពាក្យថា **រមែងទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន** សេចក្តីថា ធម៌ពួកណាដែលគប្បីពោលសំដៅយក អាយតនសព្ទ ដោយលក្ខណៈពិសេស ធម៌ទាំងនោះលោកក៏ពោលទុកយ៉ាងនោះ ដូចជាធម៌ មានចក្ខុជាដើម លោកក៏ហៅយ៉ាងនោះដូចគ្នា ព្រោះដូច្នោះ ទើបលោក ហៅធម៌ដែលជាអារម្មណ៍របស់ចិត្តដទៃអំពីធម៌ មានចក្ខុជាដើម ដោយនាំចូលទៅ កាន់ភាពជាអាយតនៈតែម្យ៉ាង ដូចគ្នានឹងលក្ខណៈសាមញ្ញប៉ុណ្ណោះ ។ ដូចជានិយាយ ថា អាយតនៈមុនៗ ជាក់ច្បាស់ហើយដោយភាពជាសភាវធម៌ដែលជាអារម្មណ៍ និង សភាវធម៌ដែលទទួលអារម្មណ៍ ពោល គឺជាតួដឹងវត្ថុ និងអារម្មណ៍ដែលគ្រោតគ្រាត យ៉ាងណា ឯធម៌ដទៃដែលជាអារម្មណ៍របស់មនោ ដែលមិនជាក់ច្បាស់យ៉ាងនោះ និង ទ្រទ្រង់ទុកនូវសភាវៈរបស់ខ្លួន ព្រោះដូច្នោះ **ធម្ម**-សព្ទ ទើបប្រព្រឹត្តទៅក្នុងអត្ថថា សម្តែងដល់អត្ថ ។ ម្យ៉ាងទៀត សភាវៈទាំងឡាយ ឈ្មោះថា **ធម្មៈ** ដោយអត្ថថា សភាវៈ ដែលមានរូបស្មើគ្នា រមែងទ្រទ្រង់ទុក គឺរមែងពិចារណា ។ ដូចជាសភាវធម៌ទាំងឡាយ មានរូបជាដើម និងដែលសភាវធម៌ទាំងឡាយ មានចក្ខុវិញ្ញាណជាដើម ក៏រមែងដឹងដោយ សភាវៈដែលសមគួរដល់ខ្លួន ព្រោះជាអសាធារណៈនោះឯង យ៉ាងណា សភាវធម៌

ទាំងនេះនឹងទៅជាដូច្នោះក៏ទេ តែសភាវធម៌ទាំងនេះដែលមានៅរមែងដឹង ព្រោះភាពជាធម៌មិនមែនតិច ព្រោះជាធម៌សាធារណៈ ព្រោះភាពស្មើគ្នាដោយសភាវៈ ដូច្នេះ ។

ពីរបទថា **សេន សេន** ប្រែថា របស់ខ្លួនរៀងៗ ខ្លួន ។ បទថា **ឧដ្ឋហន្តិ** សេចក្ដីថា រមែងធ្វើសេចក្ដីព្យាយាម ។ បទថា **វាយមន្តិ** ប្រែថា រមែងឧស្សាហ៍ សេចក្ដីថា រមែងធ្វើកិច្ចរបស់ខ្លួននោះឯង ។ ឯក្នុងអត្ថនេះ ឈ្មោះថា អាយតនៈ ព្រោះអត្ថថា ជាទីបន្ត ដូច្នោះ **អាយតន-ស័ព្ទ** ទើបមានអត្ថថា **អធិករណ** ក្នុងអត្ថទី ២ និងទី ៣ **អាយតន-ស័ព្ទ** មានអត្ថជាកត្តុ ។ បទថា **តេ ច យោគ ចិត្តចេតសិកេធម្មេ** ប្រែថា នូវធម៌ គឺចិត្ត និងចេតសិកទាំងនោះ ។ ពិតណាស់ ធម៌ គឺចិត្ត និងចេតសិកទាំងនោះឈ្មោះថា **អាយ** ព្រោះអត្ថថា ទៅគឺដល់នូវការប្រព្រឹត្តទៅក្នុងទ្វារនិងអារម្មណ៍នោះៗ។ បទថា **វិត្ថារេន្តិ** សេចក្ដីថា រមែងពង្រីកធម្មជាតិដែលកំបាំងមិនបានប្រាកដ ព្រោះមិនបានកើតមកអំពីមុនក្រៃលែងឡើងជាងចំណែកដើម គឺធ្វើឲ្យប្រាកដ អធិប្បាយថាធ្វើឲ្យកើតឡើង ។ **ឥទញ្ច យោគ សំសារទុក្ខំ** ប្រែថា សង្សារទុក្ខនេះ ។ បទថា **ន និវត្តន្តិ** សេចក្ដីថា នៅមិនទាន់រលត់ដោយអំណាចការរលត់ ដោយមិនកើតឡើង ។ ពាក្យដែលថា **អាយតនំ អាយតនំ** ដើម្បីនឹងសម្ដែងដល់ឈ្មោះនោះ ជាឈ្មោះដែលជាប់មាត់ ប្រើក្នុងអាយតនៈទាំងឡាយ មានចក្ខុជាដើម ។

លោកអាចារ្យកាលពោលអត្ថរបស់ **អាយតន-ស័ព្ទ** ដោយអំណាចការចែកជាចំណែកៗ យ៉ាងនេះហើយ ឥឡូវនេះ គិតនឹងសម្ដែងដោយបរិយាយក្នុងអាយតនស័ព្ទនោះ ទើបផ្ដើមពាក្យថា **ប្រការមួយទៀត** ។ ឈ្មោះថា **ជាទីត្រេកអរនៃចិត្ត** ព្រោះជាព្រៃដែលពេញទៅដោយផ្លែឈើ សម្រេចប្រយោជន៍ និងព្រោះជាព្រៃដែលមិនមានអន្តរាយ ។

ក្នុងបណ្ដាបទទាំងនោះ បទថា **និវសន្តិ** សេចក្ដីថា រមែងហាក់ដូចនៅអាស្រ័យ។

ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះមានការប្រព្រឹត្តទៅទាក់ទងដោយទ្វារ និងអារម្មណ៍ មានចក្ខុជាដើម** ។ លោកអាចារ្យកាលសម្តែងថា មាស និងរតនៈជាដើម រមែងតាំងនៅដេរដាស អាស្រ័យនៅក្នុងប្រទេសណា ប្រទេសនោះ ឈ្មោះថា **ជាអណ្តូងកើត** នៃមាស និងរតនៈជាដើមនោះ ចិត្ត និងចេតសិកតាំងនៅដេរដាសក្នុងទ្វារ និងអារម្មណ៍ មានចក្ខុជាដើមយ៉ាងនោះដែរ ព្រោះដូច្នោះ ទ្វារ និងអារម្មណ៍មានចក្ខុជាដើមនោះ ទើបឈ្មោះថា ជាអណ្តូងកើតរបស់ចិត្ត និងចេតសិកទាំងនោះ ទើបពោលថា **ម្យ៉ាងទៀត ចិត្ត និងចេតសិកទាំងនោះ រមែងពពាក់ពពូន ក្នុងទ្វារ និងអារម្មណ៍ មានចក្ខុជាដើម ព្រោះអាស្រ័យទ្វារ មានចក្ខុជាដើមនោះឯង ព្រោះមានរូបជាដើមនោះជាអារម្មណ៍ ដូច្នោះ ទ្វារ និងអារម្មណ៍ មានចក្ខុជាដើម ទើបឈ្មោះថាជាប្រភពកើតនៃចិត្ត និងចេតសិកទាំងនោះ** ។ ក្នុងពាក្យថា **ព្រោះអាស្រ័យចក្ខុជាដើម** នេះមនោរមែងមិនជានិស្សយប្បច្ច័យដល់ចិត្ត និងចេតសិក មានមនោវិញ្ញាណជាដើម ដូច្នោះ មនោនោះជាទ្វាររបស់ចិត្ត និងចេតសិកទាំងនោះ ទើបបណ្ឌិតគប្បីឃើញថា ជាភាវៈជាទីអាស្រ័យ ។ ចិត្ត និងចេតសិកសូម្បីមិនបានកើតឡើយ ក៏កើតឡើងបាន ដោយអំណាចការព្រមព្រៀងដោយបច្ច័យ ទើបហាក់ដូចជាច្រើនដួង បានជាពួកក្រុម រួមគ្នានៅក្នុងទ្វារ និងអារម្មណ៍ មានចក្ខុជាដើមនោះ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ព្រោះចិត្ត និងចេតសិកទាំងនោះ ហាក់ដូចជាប្រជុំគ្នានៅ ដោយមានចក្ខុជាដើមនោះ ជាទ្វារ និងជាអារម្មណ៍** ។ ព្រោះសូម្បីការអាងជាលេសនូវភាពដែលធម៌ទាំងឡាយថា មាននៅក្នុងកាលដែលជាអនាគតមិនមាន ដោយហេតុនោះ ទើបព្រះធម្មសេនាបតីសារីបុត្រ ពោលថា **គំនរនៃខន្ធមិនមានក្នុងអនាគត** ។ ពីរបទថា **តត្ថេវ ឧប្បត្តិតោ** ប្រែថា ព្រោះការកើតឡើង ក្នុងទ្វារ និងអារម្មណ៍ មានចក្ខុជាដើមនោះប៉ុណ្ណោះ ។ ពីរបទនេះលោកអាចារ្យពោលទុក ដោយអំណាចឧបចារវោហារ ព្រោះ

ធ្វើទ្វារ និងអារម្មណ៍ មានចក្ខុជាដើម ដែលជាបច្ច័យដល់ការកើតឡើង ឲ្យដូចជាទីកន្លែងកើតឡើង ។ ព្រោះថា ដែលឈ្មោះថា ប្រភពកើតឡើង ដោយនិប្បរិយាយរបស់អរូបធម៌ទាំងឡាយមិនមាន ។ ម្យ៉ាងទៀត ទ្វារ និងអារម្មណ៍ មានចក្ខុជាដើមនោះ ជាទីអាស្រ័យ និងជាអារម្មណ៍របស់ចិត្ត និងចេតសិកនោះ ដោយចំណែកណា **ក៏ជាដែនកំណើត** ដោយចំណែកនោះ ។ សូម្បីរូបធម៌ជាភាវៈដែលមានទីទទួលទ្រ និងគួរតាំងទុកដោយវាងបច្ច័យមិនមាន ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ដោយចក្ខុជាដើម ជាទីអាស្រ័យ និងមានរូបជាដើមជាអារម្មណ៍** ។ លោកអាចារ្យពោលថា **ព្រោះកាលទ្វារ និងអារម្មណ៍នោះមិនមាន ចិត្ត និងចេតសិកក៏មិនមាន** ដូច្នេះប៉ុណ្ណោះ មិនមែនពោលថា **ព្រោះកាលទ្វារ និងអារម្មណ៍មាន ចិត្ត និងចេតសិក ទើបមាន** ព្រោះលក្ខណៈនៃហេតុជាប្រធាន ដោយពិសេសក្រៃលែង ។ ពាក្យថា **ដោយអត្ថតាមដែលពោលហើយ** សេចក្តីថា ដោយអត្ថ មានប្រការដូចពោលហើយ ដោយពាក្យថា **ចក្ខុតិ** ជាដើម ដោយពាក្យថា **អាយតនតោ អាយានំ តននតោ** ជាដើម និងដោយពាក្យថា **និវាសនដ្ឋានំ** ជាដើម ។ ឯចិត្ត និងចេតសិកទាំងនោះមានច្រើននោះឯង ទើបឈ្មោះថា ធ្វើកិច្ចទុកដោយច្រើន ព្រោះធម៌ទាំងឡាយ ដែលទាក់ទងក្នុងធម្មាយតនៈមានច្រើន ព្រោះដូច្នោះ ទើបមាននិទ្ទេស ជាពហុវចនៈថា **ធម្មា ច តេ អាយតនញ្ច** ដូច្នេះ ។ ឈ្មោះថា **លក្ខណៈ** ព្រោះគប្បីកំណត់បានដោយប្រការនោះៗ ឬព្រោះអត្ថថា ជាគ្រឿងកំណត់ បានដល់ សភាវៈ ។ បទថា **តាវភាវតោ** សេចក្តីប៉ុនគ្នានឹង **តត្តកតោ** ប្រែថា ដោយមានត្រឹមប៉ុណ្ណោះ ដោយបទនោះ លោកអាចារ្យសម្តែងដល់ភាពមិនតិចមិនច្រើន ។ ក្នុងបណ្តាធម៌ទាំងឡាយ មានចក្ខុជាដើមនោះ ព្រោះធម៌ណាមួយ ដែលផុតទៅអំពីអាយតនៈ ១២ មិនមាន ទើបមិនមានពាក្យចោទសួរដល់អាយតនៈហួសប្រមាណ តែការទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ជាលក្ខណៈសាមញ្ញរបស់ធម៌ មាន

ចក្ខុជាដើមនោះ ព្រោះដូច្នោះ ទើបមានពាក្យចោទសួរតិចពេកទៅ ហេតុនោះ លោកអាចារ្យកាលនឹងសម្តែងពាក្យចោទសួរតិចពេកនោះ ទើបពោលពាក្យជាដើមថា **ពិតណាស់ សូម្បីធម៌ទាំងឡាយ មានចក្ខុជាដើម** ។ ពាក្យថា **ពោល គឺភវង្គចិត្ត** បានដល់ពោល គឺភវង្គចិត្តដែលញ័រ ២ ខណៈប្រព្រឹត្តទៅ ។ កាលមានការប្រព្រឹត្តទៅនៃភវង្គដោយអំណាចការញ័រនោះឯង ទើបអាវជ្ជនៈកើតឡើង មិនមែនដោយប្រការដទៃឡើយ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ឯកទេសនៃមនាយតនៈ ពោល គឺភវង្គចិត្តនោះឯង ជាឧប្បត្តិទ្វាររបស់ពពួកវិញ្ញាណទី ៦** ដូច្នេះ ព្រោះអធិប្បាយថា ជាហេតុនៃអាវជ្ជនៈ ។ ពាក្យថា **មិនទូទៅ** សេចក្តីថា មិនទូទៅដល់ចក្ខុវិញ្ញាណជាដើម កាលភាពមិនទូទៅមាន បណ្ឌិតគប្បីឃើញការមិនកាន់យកដោយធម្មាយតនៈ ព្រោះធម៌ទាំងឡាយ មានចក្ខុជាដើម ដែលលោកកាន់យកថាជាទ្វារ ។ ន័យម្យ៉ាងទៀត អាចារ្យសំដៅយកធម៌ដែលមិនទូទៅ ដោយជាទ្វារ និងអារម្មណ៍ ទើបពោលថា **មិនទូទៅ** ។

គប្បីប្រកបសេចក្តីដែលមិនសមក្នុងលំដាប់ទាំងឡាយ មានលំដាប់នៃការកើតឡើងជាដើម ដោយហេតុទាំងឡាយ មានការកើតឡើងព្រមគ្នាដោយច្រើនជាដើម ។ ពិតណាស់ ដោយច្រើន អាយតនៈទាំងឡាយ មានចក្ខាយតនៈជាដើម សម្រាប់បុគ្គលពួកខ្លះ ជួនកាលក៏កើតរួមគ្នា ។ ពិតយ៉ាងនោះ ទើបអាចារ្យពោលទុកថា អាយតនៈ ១១ រមែងប្រាកដដល់បុគ្គលពួកខ្លះ ក្នុងខណៈដែលកាមធាតុកើតឡើងដូច្នេះជាដើម ព្រោះដូច្នោះ ទើបលំដាប់របស់ការកើតនៃអាយតនៈ មិនសមគួរជាបឋម លំដាប់នៃការលះក៏មិនសម ព្រោះកុសល និងអព្យាកតៈមិនត្រូវលះ លំដាប់នៃការបដិបត្តិក៏មិនសម ព្រោះអកុសល និងអព្យាកតៈខ្លះ មិនជាទីតាំងនៃការបដិបត្តិ លំដាប់នៃភូមិក៏មិនសម ព្រោះអាយតនៈ ១០ កន្លះ ជាកាមាវចរដោយចំណែកមួយ និងព្រោះអាយតនៈក្រៅអំពីនេះទាក់ទងក្នុងភូមិទាំង ៤ និងព្រោះអាយតនៈខ្លះ ជាលោកុត្តរ

ដូច្នេះ ។ លោកអាចារ្យសម្តែងអាយតនៈខាងក្នុងទាំងឡាយ ជាអាយតនៈដែលព្រះមានព្រះភាគគប្បីសម្តែងមុន ដោយអាយតនៈខាងក្នុង និងដោយជាសភាវធម៌ដែលទទួលអារម្មណ៍បាន ដោយពាក្យថា **បណ្តាអាយតនៈខាងក្នុង** នេះ ក្នុងបណ្តាអាយតនៈខាងក្នុងដែលទ្រង់គប្បីសម្តែងមុននោះ ទ្រង់ក៏សម្តែងចក្ខាយតនៈមុន ព្រោះជាអាយតនៈដែលប្រាកដ ដូច្នេះ ។

ក្នុងពាក្យថា **តអំពីនោះ ទ្រង់សម្តែងឃានាយតនៈ** នេះ អធិប្បាយថា ទ្រង់សម្តែងតាមលំដាប់នៃឃានាយតនៈជាដើម ព្រោះមិនគួរនឹងសម្តែងមុនចក្ខុ និងសោតៈ ដោយមិនមានអាយតនៈដែលមានឧបការៈច្រើន គួរនឹងសម្តែងតាមលំដាប់ ដូចគ្នា ព្រោះមិនអាចពោលរួមគ្នាបាន ។ ព្រោះកាលសម្តែងដោយប្រការដទៃ បុគ្គលណាក៏អាចចោទសួរបាន ហើយអាយតនៈដែលនឹងធ្វើឲ្យយល់ចូលចិត្ត ព្រះអង្គ ក៏ទ្រង់អាចសម្តែងបាន ។ ម្យ៉ាងទៀត អាយតនៈ មានចក្ខុជាដើមត្រាស់ទុកមុន ព្រោះមានអារម្មណ៍ជាបច្ចុប្បន្នក៏ប្រាកដច្បាស់ដោយអារម្មណ៍ ដូច្នេះ ចំណែកមនាយតនៈខ្លះជាបច្ចុប្បន្នារម្មណ៍ ។បេ។ ខ្លះក៏ជានវត្តព្វារម្មណ៍ដោយកំណត់ ព្រោះដូច្នោះ ទើបត្រាស់ទុកខាងក្រោយ ក្នុងបណ្តាអាយតនៈដែលជាបច្ចុប្បន្នារម្មណ៍ អាយតនៈ ៤ មានឧបាទាយរូបជាអារម្មណ៍ត្រាស់មុន តអំពីនោះ ទើបត្រាស់អាយតនៈដែលមានភូតរូបជាអារម្មណ៍ ។ សូម្បីក្នុងអាយតនៈដែលមានឧបាទាយរូបជាអារម្មណ៍ កាលសម្តែងការទទួលអារម្មណ៍ដែលឆ្ងាយជាង ដែលឆ្ងាយ ដែលរហ័សជាង និងដែលរហ័សទើបមានលំដាប់ការសម្តែងអាយតនៈ មានចក្ខុជាដើម ។ សូម្បីចក្ខុ និងសោតៈទាំង ២ ព្រោះទទួល ( អារម្មណ៍ ) ក្នុងទីឆ្ងាយបាន ដូច្នោះ ទើបត្រាស់ទុកមុន សូម្បីក្នុងពីរយ៉ាងនោះ ចក្ខុទទួលអារម្មណ៍ដែលឆ្ងាយជាងបាន ដូច្នោះ ទើបត្រាស់មុនគេទាំងអស់ ។ ពិតហើយ បុគ្គលកាលឃើញ រមែងឃើញក្រសែទឹកក្នុងទីឆ្ងាយជាងបាន

តែមិនបានឮសំឡេងការប៉ះខ្ទប់គ្នារបស់ក្រសែទឹកនោះ ក្នុងបណ្តាឃានៈ និងជិវ្ហា ឃានៈមានការប្រព្រឹត្តទៅរហ័សជាង ព្រោះដូច្នោះ ទើបទ្រង់សម្តែងមុន គឺភោជន តែកាលដាក់ទុកត្រង់មុខ ក៏ទទួលក្លិនបាន ដូច្នេះ ។ ម្យ៉ាងទៀត លំដាប់ការសម្តែងរបស់អាយតនៈទាំងនោះតាមទីតាំងដូចម្តេច ? ពិតណាស់ ក្នុងរាងកាយនេះ ចក្ខុតាំងនៅខាងលើនៃអាយតនៈទាំងអស់ សោតៈនៅទាបជាងចក្ខុនោះ ឃានៈក៏នៅទាបជាងសោតៈ ជិវ្ហាក៏នៅទាបជាងឃានៈនោះផង កាយតាំងនៅតាមនោះដោយច្រើន ចំណែកមនោទ្រង់ត្រាស់ទុកក្រោយអាយតនៈទាំងអស់ ព្រោះជាអរូបធម៌ ។ ទ្រង់ត្រាស់អាយតនៈខាងក្រៅក្នុងលំដាប់របស់អាយតនៈខាងក្នុងនោះៗ ព្រោះអាយតនៈខាងក្រៅជាអារម្មណ៍របស់អាយតនៈខាងក្នុងនោះៗ ដូច្នោះ ទើបអាចារ្យបានពោលតាមសេចក្តីនេះទុក នោះឯង គប្បីជ្រាបលំដាប់របស់អាយតនៈទាំងនេះដោយប្រការ ដូច្នេះ ។ មនោ ឈ្មោះថា **គោចរវិស័យ** ព្រោះមានគោចរជាវិស័យ ។ គោចររបស់អាយតនៈណាជាវិស័យរបស់មនោនេះ ? បានដល់ គោចររបស់អាយតនៈ ៥ មានចក្ខុជាដើម ។ ពាក្យថា **ដោយកំណត់ហេតុកើតឡើងនៃវិញ្ញាណ** បានដល់ ដោយសភាវៈដែលមានការកំណត់ គឺដោយភាវៈដែលមានការចែកហេតុកើតឡើង របស់ចក្ខុវិញ្ញាណជាដើម ។ ដោយពាក្យនេះ លោកអាចារ្យពោលដល់លំដាប់របស់អាយតនៈ មានចក្ខុជាដើម និងហេតុរបស់ពាក្យ មានរូបជាដើម ។

ពាក្យថា **ព្រោះសង្គ្រោះចូល** គឺព្រោះសង្គ្រោះចូលដោយអំណាចការសង្គ្រោះក្នុងការរាប់ ។ ពាក្យថា **ដោយអំណាចនៃជាតិ** គឺដោយអំណាចអាយតនៈស្មើគ្នាជាបច្ច័យ ។ **ភាពផ្សេងគ្នានៃបច្ច័យ** បានដល់ ភាពផ្សេងគ្នានៃបច្ច័យ មានកម្មជាដើម ។ ពិតហើយ ពោលដោយប្រភេទនៃកុសលកម្ម និងអកុសលកម្មដែលផ្សេង ដោយប្រភេទនៃកម្ម មានទានជាដើម និងកម្ម មានបាណាតិបាតជាដើម និងពោលដោយ

ប្រភេទនៃបច្ច័យខាងក្នុង និងខាងក្រៅ ដែលជាហេតុធ្វើរួមគ្នានៃកម្មនោះ ចក្ខាយតនៈក៏រមែងជាធម្មជាតិផ្សេងគ្នា គឺមិនដូចគ្នា ដូច្នេះ ។ អបាយ មាននរកជាដើម និងហេតុដែលធ្វើឲ្យផ្សេងគ្នារបស់គតិនៃសត្វ មានសត្វឥតជើងជាដើម ឈ្មោះថា **ភាពផ្សេងគ្នានៃគតិ** ព្រោះអធិប្បាយថា ភាពផ្សេងគ្នានៃគតិទាំងឡាយ ឬភាពផ្សេងគ្នាក្នុងគតិទាំងឡាយ ។ ពពួកសត្វតិរច្ឆាន មានដំរី សេះជាដើម និងពពួកមនុស្ស មានក្សត្រជាដើម ឈ្មោះថា **ភាពផ្សេងគ្នានៃនិកាយ** ។ ភាពផ្សេងគ្នានៃសន្តានរបស់សត្វនោះៗ ឈ្មោះថា **ភាពផ្សេងគ្នានៃបុគ្គល** ។ វត្ថុទាំងឡាយ មានចក្ខុជាដើម មានប្រភេទមិនមានទីបំផុតឯណា លោកពោលទុកហើយនោះឯង ជាភាពផ្សេងគ្នានៃហទយវត្ថុ ព្រោះមិនប្រព្រឹត្តកន្លងនូវភាពផ្សេងគ្នាដូច្នោះទៅបាន ។ ព្រោះដូច្នោះ ទើបគប្បីប្រកបមនាយតនៈ មានប្រភេទមិនមានទីបំផុត ។ ព្រោះលោកុត្តរដែលឈ្មោះថា វៀរចាកឈានរមែងមិនមាន ដូច្នោះ លោកុត្តរចិត្ត ៨ ដួង ទើបរួមជា ៤០ ដួង ដោយអំណាចឈានទាំង ៥ ព្រោះដូច្នោះ ទើបអាចារ្យបន្ថែមលោកុត្តរចិត្ត ៤០ ដួងនោះចូលក្នុងលោកិយចិត្ត ៨១ ដួង ពោលថា **និងមានប្រភេទជា ១២១ ដួង** ។ ពាក្យថា **វត្ថុ** បានដល់ វត្ថុ មានចក្ខុជាដើម ។ វិញ្ញាណឈ្មោះថា **មានប្រភេទមិនមានទីបំផុតក៏ដោយប្រភេទនៃវត្ថុ មានចក្ខុជាដើម** ។ **បដិបទា** បានដល់ បដិបទា មានទុក្ខាបដិបទាជាដើម ។ ដោយ **អាទិ-ស័ព្ទ** គប្បីឃើញការសង្គ្រោះឈាន អធិបតី ភូមិ និងអារម្មណ៍ជាដើមចូលផង ។ រូបពណ៌ខៀវក៏ជាសភាគនៃរូបពណ៌ខៀវពណ៌ដទៃក៏ជា**វិសភាគគ្នា** ។ **បច្ច័យ** បានដល់ បច្ច័យ មានកម្មជាដើម ។ ក្នុងបច្ច័យ មានកម្មជាដើមនោះ ក៏គប្បីជ្រាបភាពផ្សេងគ្នា គឺដែលមានកុសលជាសមុដ្ឋានជាដើម និងអាយតនៈ មានត្រជាក់ និងរដូវជាសមុដ្ឋានជាដើម ។ ដោយ **អាទិ-ស័ព្ទ** គប្បីជ្រាបភាពផ្សេងគ្នានៃគតិ និងនិកាយ ។ ពាក្យថា **ដោយញែកភាពផ្សេងគ្នារបស់សភាវធម៌**

បានដល់ ការញែកមានអាទិយ៉ាងនេះ គឺសុខ ទុក្ខ អទុក្ខមសុខ ឈ្មោះថា **ការចែកសភាវៈ** ។ ភាពផ្សេងគ្នា មានអាទិយ៉ាងនេះថា កើតអំពីចក្ខុសម្ផស្ស កើតអំពីសោតសម្ផស្ស ឈ្មោះថា **ភាពផ្សេងគ្នា** ។

លោកអាចារ្យបំណងនឹងពង្រីកសេចក្ដីដែលពោលទុកដោយសង្ខេបថា ដោយការមិនមក និងដោយការមិនចេញទៅ ទើបពោលពាក្យថា **ន ហិ** ជាដើម ។ មុនអំពីការកើតឡើងនៃអាយតនៈទាំងឡាយ ក៏មិនបានមកអំពីទីណា និងខាងមុខអំពីរលត់ទៅក៏មិនបានទៅក្នុងទីណា ព្រោះអាយតនៈទាំងឡាយ មានសភាវៈមិនមានក្នុងចំណែកខាងដើម និងចំណែកខាងចុង ទើបអាយតនៈទាំងឡាយ មិនទៀងជាទុក្ខ មានការប្រែប្រួលជាធម្មតា ព្រោះមានកាលបន្តិចបន្តួច សូម្បីក្នុងខណៈដែលមាន ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ដោយពិត** ជាដើម ។ សេចក្ដីព្យាយាមឈ្មោះថា **ឱហាត** ដោយអំណាចកិរិយា មានការប្រឹងប្រែង សេចក្ដីខ្នះខ្នែង ឈ្មោះថា **ព្យាបារ** ដោយអំណាចការគិត ក្នុង ២ យ៉ាងនោះ អាចារ្យកាលនឹងសម្ដែងសេចក្ដីខ្នះខ្នែង ទើបពោលថា **ព្រោះចក្ខុ និងរូបជាដើមមិនមានការខ្នះខ្នែងយ៉ាងនោះ** ។ កាលនឹងសម្ដែងសេចក្ដីព្យាយាម ទើបពោលពាក្យថា **ន ច តានិ** ជាដើម ។ ពាក្យទាំងពីរជាពាក្យលំដាប់លំដោយគ្នាថា **ឦហា ច ហោតិ ព្យាបារោ ច** ប្រែថា សេចក្ដីព្យាយាម និងសេចក្ដីឱហាត ។ បទថា **ធម្មតាវ** បានដល់ សភាវៈនោះឯង ម្យ៉ាងទៀត ជាធម៌អាចក្នុងហេតុ គឺនៃអាយតនៈដែលវៀរចាកសេចក្ដីព្យាយាម និងសេចក្ដីខ្នះខ្នែងជាទ្វារជាដើម ឈ្មោះថា **ធម្មតា** ។ ក្នុងអត្ថនេះ សេចក្ដីរបស់បទថា **យំ** នេះ ប៉ុនគ្នានឹង **យស្មា** ។ **យំ**-សព្ទ ជាពាក្យដែលធ្វើការមានឲ្យផ្សេងចេញទៅក្នុងអត្ថមុន ។

អាយតនៈទាំងឡាយ **គប្បីឃើញប្រៀបដូចស្រុកចាស់ដែលគេបោះបង់** ព្រោះព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ស្រុកដែលគេបោះបង់ នេះជាឈ្មោះនៃអាយតនៈ

ខាងក្នុង ៦ ។ ភាជនៈណាមួយនោះឯង ក្នុងស្រុកដែលគេបោះបង់ ដែលបុគ្គលប្រកាន់ថា ប្រកបទៅដោយបាយ និងទឹក ដែលបុគ្គលកំពុងប្រកាន់ភាជនៈនោះៗ ក៏ជារបស់ទទេនោះឯង យ៉ាងណា អាយតនៈទាំងនេះ ដែលបុគ្គលប្រកាន់ដោយភាពជារបស់ស្ថិតស្ថេរជាដើម កាលចូលទៅពិចារណាដោយឧបាយ រមែងប្រាកដជារបស់ទទេនោះឯង ដូច្នោះឯង ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះវៀរចាកភាពទៀង ភាពស្អាត ភាពសុខ និងភាពជាតួខ្លួន** ។ អាយតនៈខាងក្រៅ មានរូបជាដើម លោកពោលថា ជាគ្រឿងប៉ះខ្ទប់នូវអាយតនៈខាងក្នុង មានចក្ខុជាដើម ដោយសភាវៈដែលធ្វើអភិជ្ឈា និងទោមនស្សឲ្យកើតឡើងក្នុងទ្វារ មានចក្ខុជាដើម ។ ពស់ ក្រពើ បក្សី ឆ្កែស្រុក ឆ្កែព្រៃ និងស្វា ឈ្មោះថា **សត្វ ៦ ពួក** ។ ដែលមិនស្មើ ក្នុងទឹក អាកាស ស្រុក ព្រៃខ្មោច និងព្រៃ **ដែលជាទីគោចររបស់សត្វទាំងឡាយនោះ** ។ ក្នុងបណ្ដាទីគោចរទាំងនោះ គប្បីប្រកបភាពដែលអាយតនៈខាងក្រៅ មានរូបជាដើម ដូចទីដែលមិនស្មើជាដើម ព្រោះអាយតនៈខាងក្នុង មានចក្ខុជាដើម ដែលចូលចិត្តទីដែលមិនស្មើជាដើម ត្រេកអរហើយ ក្នុងទីដែលមិនស្មើម្យ៉ាង ដោយភាពជាអន្លង់ទឹកម្យ៉ាង ដោយភាពជាអាកាសម្យ៉ាង ដោយភាពជាស្រុកម្យ៉ាង ដោយភាពជាព្រៃខ្មោចម្យ៉ាង និងដោយភាពជាព្រៃម្យ៉ាង ដែលបុគ្គលចូលទៅប្រកាន់ដូចគ្នានឹងទីអាស្រ័យ ។

ការពណ៌នាកថាមុខដោយពិស្ដារ
នៃអាយតនៈទាំងឡាយ ចប់ហើយ
ដោយប្រការ ដូច្នេះ

# វិសុទ្ធិមគ្គ

## ធាតុនិទ្ទេស

*ចំណែកធាតុដែលពោលទុកតពីអាយតនៈនោះទៅ មានវិនិច្ឆ័យថា ធាតុ ១៨ គឺ ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ឈ្មោះថា ធាតុទាំងឡាយ។*

*វិនិច្ឆ័យក្នុងធាតុទាំងនោះ បណ្ឌិតគប្បីជ្រាបដោយអត្ថ ដោយលក្ខណៈជាដើម ដោយលំដាប់ ដោយមានត្រឹមតែប៉ុណ្ណោះ ដោយការរាប់ ( ចំនួន ) ដោយបច្ច័យ និងដោយភាពជាវត្ថុគប្បីឃើញ ។*

## ដោយអត្ថ

*ក្នុងពាក្យទាំងនោះ ពាក្យថា ដោយអត្ថ សេចក្តីថា វិនិច្ឆ័យដោយអត្ថដែលប្លែកគ្នា នៃចក្ខុស័ព្ទជាដើម បណ្ឌិតគប្បីជ្រាបដោយន័យនេះថា ធម្មជាតិណារមែងប្រាប់ ហេតុនេះ ទើបធម្មជាតិនោះឈ្មោះថា ចក្ខុ វត្ថុណារមែងសម្តែងពណ៌ ហេតុនេះ ទើបវត្ថុនោះ ឈ្មោះថា រូប ការដឹងច្បាស់នៃចក្ខុ ឈ្មោះថា ចក្ខុវិញ្ញាណ ដូច្នេះជាដើមមុន ចំណែក ការពោលវិនិច្ឆ័យដោយអត្ថដែលមិនប្លែកគ្នា គប្បីជ្រាបដូច្នេះ ។*

*ធម៌ណារមែងរៀបចំ ( ធ្វើទុក្ខឲ្យកើតឡើង ) ហេតុនេះ ទើបធម៌នោះឈ្មោះថា ធាតុ ( ប្រែថា ធម៌អ្នកតាក់តែង) ។*

*ឬថា ធម៌ទាំងឡាយណាដែលសត្វទាំងឡាយទ្រទ្រង់ទុក ( គឺប្រកាន់ទុក ) ហេតុនេះ ទើបធម៌ទាំងឡាយនោះ ឈ្មោះថា ធាតុ ( ធម៌ដែលសត្វទ្រទ្រង់ទុក ) ។*

*ឬថា* **វិធាន**-*ការតាំងទុក ( គឺក្រិតក្រម ) ឈ្មោះថា ធាតុ ។*

ឬថា ទុក្ខដែលសត្វទាំងឡាយទ្រទ្រង់ទុក ( គឺប្រកាន់ទុក ) ដោយធម្មជាតិនោះ ( ជាហេតុ ) ហេតុនេះ ទើបធម្មជាតិនោះឈ្មោះថា ធាតុ ( ប្រែថា ធម្មជាតិ ដែលជាហេតុទ្រទ្រង់ < ទុក្ខ > ទុកនៃសត្វទាំងឡាយ ) ។

ឬថា ទុក្ខដែលសត្វទាំងឡាយទ្រទ្រង់ទុក ( គឺតាំងទុក ) ក្នុងធម្មជាតិនោះ ហេតុនេះ ទើបធម្មជាតិនោះឈ្មោះថា ធាតុ ( ប្រែថា ធម្មជាតិសត្វទាំងឡាយ ទ្រទ្រង់ < ទុក្ខ > ទុក ) ។

ពិតណាស់ ធាតុទាំងឡាយដែលជាលោកិយ ជាវត្ថុដែលធម្មតាកំណត់ទុក ដោយភាពជាតួមូលហេតុ រមែងចាត់ចែងសង្សារទុក្ខឡើងជាអនេកកប្បកា ដូចធាតុ ( រ៉ែ ) ទាំងឡាយ មានធាតុមាស ធាតុប្រាក់ជាដើម បែងចែកលោហ: មានមាស និងប្រាក់ជាដើមឡើង ដូច្នេះ ។

ម្យ៉ាងទៀត លោកិយធាតុទាំងឡាយនោះ ដែលសត្វទាំងឡាយទ្រទ្រង់ទុក សេចក្តីថា ប្រកាន់ទុក ដូចជាការ: ( របស់ធ្ងន់ ) ដែលមនុស្សទាំងឡាយអ្នកទូលការ: អ្នកលីដែលទៅ ដូច្នោះ ។

ម្យ៉ាងទៀត លោកិយធាតុនោះ មានទុក្ខវិធាន ( ក្រិត្យក្រមនៃទុក្ខ ) ប៉ុណ្ណោះ ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាចរបស់បុគ្គលណាមួយ ។

ម្យ៉ាងទៀត សង្សារទុក្ខ ដែលសត្វទាំងឡាយតាមប្រកាន់ទុក ក៏ដោយធាតុទាំងឡាយ ជាហេតុ ។

ម្យ៉ាងទៀត សង្សារទុក្ខដែលត្រូវចាត់ទុកហើយយ៉ាងនោះ សត្វទាំងឡាយក៏ទ្រទ្រង់ទុក សេចក្តីថា តាំងទុកក្នុងធាតុទាំងឡាយនោះឯង ។

ក្នុងធម៌ទាំងឡាយមានចក្ខុជាដើម ធម៌តែមួយទ្រង់ហៅថា ធាតុ ក៏ដោយអំណាចនៃអត្ថ សេចក្តីថា **វិទហតិ**-នឹងឡើង **វិធីយតេ**-ដែលសត្វទាំងឡាយទ្រទ្រង់ទុកជាដើម

តាមការកើតឡើងបាន ដូចពោលមកនេះ ។

ន័យម្យ៉ាងទៀត ធាតុនេះមិនមែនដូចអត្តារបស់ពួកតិរ្ថិយ ដែលមិនបានមាន ដោយសភាវៈ តែធាតុនេះបានឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវសភាវៈរបស់ខ្លួន ។

ម្យ៉ាងទៀត សេលាវយវ ( បន្ទះថ្ម ) ទាំងឡាយ មានហរតាល និងមនោសិលាជាដើម ដែលវិចិត្រ ( ប្លែកៗ ) ក្នុងលោកក៏ហៅថា ធាតុ យ៉ាងណា សូម្បីធាតុទាំងឡាយនេះ ក៏ដូចធាតុទាំងឡាយនោះ ព្រោះវាក៏ជាអវយវៈនៃការដឹង និងវត្ថុដែលគួរដឹងដ៏វិចិត្រដូច្នោះឯង ឬប្រៀបដូចការសន្មតថា ធាតុ រមែងមានក្នុងកោដ្ឋាសទាំងឡាយដែលកំណត់លក្ខណៈផ្សេងគ្នានឹងគ្នា ដូចរស និងលោហិតជាដើម ដែលជាអវយវៈនៃដុំនៃក្រុម ពោល គឺសរីរៈ យ៉ាងណា ការសន្មតថាធាតុ ធាតុ ក៏គប្បីជ្រាប ( ថាមាន ) ក្នុងអវយវៈទាំងឡាយនៃអត្តភាព ពោល គឺបញ្ចក្ខន្ធនេះ ដូច្នោះ ព្រោះអវយវៈមានចក្ខុជាដើមនោះ ក៏កំណត់លក្ខណៈផ្សេងគ្នានឹងគ្នាបាន ដូច្នេះ ។

ន័យម្យ៉ាងទៀត ពាក្យថា **ធាតុ** នោះ ជាពាក្យហៅសភាវៈដែលជានិជ្ជីវ ( មិនមានជីវិត ) ប៉ុណ្ណោះឯង ពិតហើយ ព្រះមានព្រះភាគទ្រង់ក៏បានធ្វើធាតុនិទ្ទេស ដើម្បីដកជីវសញ្ញា ( សេចក្តីសម្គាល់ថា ជីវៈ ) ទុកក្នុងព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ បុរសនេះមានធាតុ ៦ ដូច្នេះជាដើម ។

ព្រោះហេតុនោះឯង ដោយអត្ថតាមដែលពោលមក ( បណ្ឌិតគប្បីជ្រាបវិគ្រោះថា ) ចក្ខុផង ចក្ខុនោះជាធាតុផង ទើបឈ្មោះថា ចក្ខុធាតុ ។បេ។ មនោវិញ្ញាណផង មនោវិញ្ញាណនោះជាធាតុផង ទើបឈ្មោះថា មនោវិញ្ញាណធាតុ ។

វិនិច្ឆ័យដោយអត្ថក្នុងធាតុទាំងនោះ បណ្ឌិតគប្បីជ្រាបដូចពោលមកនេះដែលជាលំដាប់ដំបូង ។

## ដោយលក្ខណៈជាដើម

*ពាក្យថា ដោយលក្ខណៈជាដើម សេចក្តីថា វិនិច្ឆ័យដោយលក្ខណៈជាដើម នៃធាតុ មានចក្ខុជាអាទិក្នុងនិទ្ទេសនេះ បណ្ឌិតក៏គប្បីជ្រាបផង តែលក្ខណៈជាដើមនោះ នៃធាតុទាំងឡាយនោះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងខន្ធនិទ្ទេសចុះ ។*

## ដោយលំដាប់

*ប្រការថា ដោយលំដាប់ សេចក្តីថា ក្នុងទីនេះ បណ្តាលំដាប់ទាំងឡាយ មានលំដាប់នៃការកើតឡើងជាដើម ដែលពោលហើយក្នុងនិទ្ទេសមុន លំដាប់នៃការសម្តែងប៉ុណ្ណោះប្រើបាន ឯលំដាប់នៃការសម្តែងនេះ លោកពោលដោយការកំណត់លំដាប់នៃហេតុ និងផល ពិតហើយ ធាតុទាំង ២ នេះ គឺចក្ខុធាតុ រូបធាតុជាហេតុ ធាតុ ១ គឺចក្ខុវិញ្ញាណធាតុជាផល លំដាប់យ៉ាងនេះ បណ្ឌិតគប្បីជ្រាបក្នុងធាតុដ៏សេសទាំងពួង ។*

## ដោយមានត្រឹមតែប៉ុណ្ណោះ

*ពាក្យថា **តាវត្វតោ** គឺ **តាវតាវតោ**-ដោយមានត្រឹមតែប៉ុណ្ណោះ មានពុទ្ធាធិប្បាយនេះថា បើមានពាក្យសួរថា សូម្បីធាតុទាំងឡាយដទៃ ដូចជាអាភាធាតុ សុភធាតុ អាកាសានញ្ចាយតនធាតុ វិញ្ញាណញ្ចាយតនធាតុ អាកិញ្ចញ្ញាយតនធាតុ នេវសញ្ញានាសញ្ញាយតនធាតុ សញ្ញាវេទយិតនិរោធធាតុ កាមធាតុ ព្យាបាទធាតុ វិហិង្សាធាតុ នេក្ខម្មធាតុ អព្យាបាទធាតុ អវិហិង្សាធាតុ សុខធាតុ ទុក្ខធាតុ សោមនស្សធាតុ ទោមនស្សធាតុ ឧបេក្ខាធាតុ អវិជ្ជាធាតុ អារម្ភធាតុ និក្កមធាតុ បរក្កមធាតុ ហីនធាតុ មជ្ឈិមធាតុ បណីតធាតុ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ វិញ្ញាណធាតុ សង្ខតធាតុ អសង្ខតធាតុ លោកមានធាតុជាអនេក មានធាតុផ្សេងៗ*

ដូច្នេះជាដើម ប្រាកដក្នុងទីខ្លះនៃព្រះសូត្រ និងព្រះអភិធម្មនោះៗ កាលបើដូច្នេះ ហេតុម្ដេចទើបព្រះមានព្រះភាគទ្រង់មិនធ្វើបរិច្ឆេទ ( កំណត់ចិត្តចូលជាពួក ) ដោយអំណាចនៃធាតុទាំងអស់ ទ្រង់ធ្វើបរិច្ឆេទ ត្រឹមតែធាតុទាំង ១៨ នេះ ដូច្នេះសោត ពាក្យឆ្លើយគប្បីមានថា ព្រោះធាតុទាំងពួងដែលមានដោយសភាវៈក៏ធ្លាក់នៅក្នុងធាតុទាំង ១៨ នោះហើយ ។

ពិតហើយ អាភាធាតុ ក៏គឺរូបធាតុ ចំណែកសុភធាតុ ក៏ទាក់ទងនៅក្នុងរូបធាតុជាដើម ព្រោះហេតុអ្វី ? ព្រោះសុភធាតុ គឺសុភនិមិត្ត ពិតហើយ សុភធាតុ គឺសុភនិមិត្ត ហើយសុភនិមិត្តនោះក៏មិនផុតទៅពីរូបជាដើមឡើយ ន័យមួយទៀត សុភធាតុ គឺធម៌ទាំងឡាយ មានរូបជាដើម ដែលជាអារម្មណ៍នៃកុសលវិបាក ព្រោះហេតុនោះ សុភធាតុនោះ គឺរូបធាតុជាដើមទាំងនោះឯង ។

ចិត្តក្នុងអរូបធាតុ ៤ មានអាកាសានញ្ចាយតនធាតុជាដើម ជាមនោវិញ្ញាណធាតុ ធម៌ទាំងឡាយដ៏សេសជាធម្មធាតុ ចំណែកសញ្ញាវេទយិតនិរោធធាតុមិនមាន ដោយសភាវៈ ព្រោះសញ្ញាវេទយិតនិរោធធាតុនោះ គ្រាន់តែការរលត់នៃធាតុ ២ ( គឺមនោ-វិញ្ញាណធាតុ និងធម្មធាតុ ) ប៉ុណ្ណោះ ។

កាមធាតុគ្រាន់តែធម្មធាតុ ដូចព្រះបាលីថា ក្នុងធាតុទាំងនោះ កាមធាតុដូចម្ដេច ? កាមធាតុ គឺការគិត ការត្រិះរិះ ។បេ។ ភាពត្រិះរិះខុសដែលទាក់ទងដោយកាម ដូច្នេះ ឬមិនដូច្នោះក៏ជាធាតុទាំង ១៨ ដូចព្រះបាលីថា ខាងក្រោមធ្វើអវិចីនរកឲ្យជាទីបំផុត ខាងលើធ្វើពួកទេវតាបរនិម្មិតវសវត្តីទុកខាងក្នុងខន្ធ ធាតុ អាយតនៈ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលត្រាច់នៅក្នុងកពទាំងឡាយនោះ ដែលទាក់ទងនៅក្នុងកពទាំងឡាយនោះ ក្នុងរវាង ( ដែលកំណត់ ) នោះ យ៉ាងណា នេះហៅថា កាមធាតុ ដូច្នេះ ។

នេក្ខម្មធាតុ ជាធម្មធាតុពិត សូម្បីនឹងជាមនោវិញ្ញាណធាតុក៏បានដូចគ្នា ព្រោះ

មានព្រះបាលីថា ធម៌ទាំងឡាយដែលជាកុសលទាំងពួង ឈ្មោះនេក្ខម្មធាតុ ។

ព្យាបាទធាតុ វិហិង្សាធាតុ អព្យាបាទធាតុ អវិហិង្សាធាតុ សុខធាតុ ទុក្ខធាតុ សោមនស្សធាតុ ទោមនស្សធាតុ ឧបេក្ខាធាតុ អវិជ្ជាធាតុ អារម្ភធាតុ និក្កមធាតុ បរក្កមធាតុ ក៏ជាធម្មធាតុដូចគ្នា ។

ហីនធាតុ មជ្ឈិមធាតុ បណីតធាតុ ក៏គឺធាតុ ១៨ នោះឯង ពិតណាស់ ធាតុមានចក្ខុធាតុជាដើមដែលអាក្រក់ក៏ជាហីនធាតុ ដែលកណ្តាល និងដែលប្រណីតក៏ជាមជ្ឈិមធាតុ និងបណីតធាតុ តែ ( បើពោល ) ដោយនិប្បរិយាយ ធម្មធាតុ និងមនោវិញ្ញាណធាតុទាំងឡាយផ្នែកអកុសល ចាត់ជាហីនធាតុ ធាតុទាំង ២ នោះ ផ្នែកអកុសល និងអព្យាកតៈ និងចក្ខុធាតុជាដើមផងដែលជាលោកិយ ចាត់ជាមជ្ឈិមធាតុ ចំណែកធម្មធាតុ និងមនោវិញ្ញាណធាតុដែលជាលោកុត្តរ ចាត់ជាបណីតធាតុ ។

បឋវីធាតុ តេជោធាតុ វាយោធាតុ ក៏បានដល់ផោដ្ឋព្វធាតុ អាបោធាតុ និងអាកាសធាតុ ចាត់ជាធម្មធាតុ វិញ្ញាណធាតុដោយសង្ខេប គឺវិញ្ញាណធាតុ ៧ មានចក្ខុវិញ្ញាណជាដើមនោះឯង ។

ធាតុ ១៧ ( វៀរធម្មធាតុ ) ឯកទេសនៃធម្មធាតុ ជាសង្ខតធាតុ ចំណែកអសង្ខតធាតុ បានដល់ ឯកទេសនៃធម្មធាតុតែម្យ៉ាង ។

ចំណែកអនេកធាតុ នានាធាតុលោក ក៏គឺការបែកចេញទៅ ( ជាច្រើនផ្នែក ) នៃធាតុ ១៨ ទាំងនោះឯង ។

ព្រះមានព្រះភាគត្រាស់ធាតុតែ ១៨ ព្រោះធាតុទាំងពួងដែលមានដោយសភាវៈធ្លាក់នៅក្នុងធាតុ ១៨ នោះហើយ ដូចពោលមកនេះឯង ។

ន័យម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់តែធាតុ ១៨ ដើម្បីដកសញ្ញារបស់បុគ្គលជំពូកជីវសញ្ញី ( មានការសម្គាល់ថា មានជីវៈ ) ក្នុងវិញ្ញាណដែលមានការ

ដឹងដោយសភាពផង ពិតហើយ បុគ្គលជំពូកជីវសញ្ញីក្នុងវិញ្ញាណដែលមានការដឹងជាសភាវៈមាន ព្រះមានព្រះភាគមានព្រះពុទ្ធបំណងទ្រង់ប្រកាសភាពដែលវិញ្ញាណនោះមានជាអនេក ដោយចែកជាចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុ មនោធាតុ និងមនោវិញ្ញាណធាតុដូចពោលមកនោះ និងភាពដែលវិញ្ញាណនោះជារបស់មិនទៀង ព្រោះមានការប្រព្រឹត្តទៅដោយទាក់ទងបច្ច័យ មានចក្ខុ និងរូបជាដើម ទ្រង់ដកជីវសញ្ញាដែលក្រៅសេចក្តី ( នៅក្នុងសន្តាន ) មកដោយយូររបស់បុគ្គលទាំងនោះចេញ ទើបទ្រង់ប្រកាសធាតុ ១៨ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ប្រកាសធាតុ ១៨ ទាំងនោះ ក៏ដោយអំណាចអធ្យាស្រ័យរបស់សត្វដែលគប្បីប្រៀនប្រដៅបាន ដោយប្រការដូចដែលពោលមកនោះ ប្រការ ១ ប៉ុន្តែ សត្វណាជាសត្វជំពូកដែលនឹងគប្បីប្រៀនប្រដៅបានដោយទេសនាដែលមិនសង្ខេប និងមិនពិស្តារបានដូច្នេះ ក៏ដោយអំណាចនៃអធ្យាស្រ័យរបស់សត្វជំពូកនោះ ប្រការ ១ ផង ។

ពិតហើយ ភាពងងឹតក្នុងហឫទ័យរបស់វេនេយ្យសត្វទាំងឡាយ ដែលគេជះនៃព្រះសទ្ធម្មរបស់ព្រះអង្គកម្ចាត់ហើយ រមែងដល់នូវការវិនាសទៅ ដោយរហ័សដោយប្រការណា ព្រះអង្គរមែងទ្រង់ប្រកាសធម៌ ដោយន័យសង្ខេបខ្លះ ពិស្តារខ្លះដោយប្រការនោះៗ ឯង ។

វិនិច្ឆ័យដោយមានត្រឹមតែប៉ុណ្ណោះក្នុងធាតុទាំងឡាយនោះ បណ្ឌិតគប្បីជ្រាបដូចពោលមកនេះ ។

## (ដោយការរាប់ ចំនួន)

ពាក្យថា ដោយការរាប់ សេចក្តីថា ដំបូង ចក្ខុធាតុ ពោលដោយជាតិក៏ដល់នូវការរាប់ថា ជាធម៌ចំនួន ១ គឺជាចក្ខុបសាទ សោតធាតុ ឃានធាតុ ជិវ្ហាធាតុ

កាយធាតុ រូបធាតុ សទ្ទធាតុ គន្ធធាតុ និងរសធាតុក៏យ៉ាងនោះ គឺដល់នូវការរាប់ថា ជាធម៌ចំនួន ១ ដោយភាពជាសោតបសាទជាដើម តែផោដ្ឋព្វធាតុដល់នូវការរាប់ថា ជាធម៌ចំនួន ៣ ដោយអំណាចនៃបឋវីធាតុ តេជោធាតុ និងវាយោធាតុ ចក្ខុវិញ្ញាណធាតុ ដល់នូវការរាប់ថា ជាធម៌ចំនួន ២ ដោយភាពជាកុសលវិបាកវិញ្ញាណ និងអកុសលវិបាកវិញ្ញាណ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ និងកាយវិញ្ញាណធាតុក៏យ៉ាងនោះ ចំណែកមនោធាតុដល់ការរាប់ថា ជាធម៌ចំនួន ៣ ដោយភាពជាបញ្ចទ្វារាវជ្ជនៈ កុសលាកុសលវិបាក និងសម្បដិច្ឆនៈ ធម្មធាតុដល់នូវការរាប់ថា ជាធម៌ចំនួន ២០ ដោយអំណាចនៃអរូបក្ខន្ធ ៣ សុខុមរូប ១៦ និងអសង្ខតធាតុ មនោវិញ្ញាណធាតុដល់ការរាប់ថា ជាធម៌ចំនួន ៧៦ ដោយអំណាចនៃកុសលវិញ្ញាណ អកុសលវិញ្ញាណ និងអព្យាកតវិញ្ញាណដ៏សេស ។

សូម្បីវិនិច្ឆ័យដោយការរាប់ចំនួន ក្នុងធាតុទាំងឡាយនោះ បណ្ឌិតគប្បីជ្រាបដូចពោលមកនេះ ។

## ដោយបច្ច័យ

ក្នុងសេចក្តីថា បច្ច័យ នេះ មានវិនិច្ឆ័យថា មុនដំបូងចក្ខុធាតុជាបច្ច័យដោយបច្ច័យ ៦ ដោយភាពជាវិប្បយុត្តប្បច្ច័យ ១ បុរេជាតប្បច្ច័យ ១ អត្ថិប្បច្ច័យ ១ អវិគតប្បច្ច័យ ១ និស្សយប្បច្ច័យ ១ ឥន្ទ្រិយប្បច្ច័យ ១ រូបធាតុជាបច្ច័យដោយបច្ច័យ ៤ ដោយភាពជាបុរេជាតប្បច្ច័យ ១ អត្ថិប្បច្ច័យ ១ អវិគតប្បច្ច័យ ១ អារម្មណប្បច្ច័យ ១ នៃចក្ខុវិញ្ញាណធាតុ ធាតុដ៏សេស ៤ គូ មានសោតធាតុ សទ្ទធាតុជាដើម ក៏ជាបច្ច័យនៃវិញ្ញាណធាតុដ៏សេស មានសោតវិញ្ញាណធាតុជាអាទិយ៉ាងនោះ ចំណែកអាវជ្ជនមនោធាតុ ជាបច្ច័យដោយបច្ច័យ ៥ ដោយភាពជាសមនន្តរប្បច្ច័យ ១ អនន្តរប្បច្ច័យ ១ អត្ថិប្បច្ច័យ ១ វិគតប្បច្ច័យ ១ អនន្តរូបនិស្សយប្បច្ច័យ ១ នៃ

វិញ្ញាណធាតុទាំង ៥ នោះ វិញ្ញាណធាតុទាំង ៥ នោះក៏ជាបច្ច័យនៃសម្បដិច្ឆន្នមនោធាតុ ដោយទាក់ទងគ្នានោះ សម្បដិច្ឆន្នមនោធាតុក៏ជាបច្ច័យនៃសន្តីរណមនោវិញ្ញាណធាតុ សន្តីរណមនោវិញ្ញាណធាតុនោះក៏ជាបច្ច័យនៃវោដ្ឋព្វនមនោវិញ្ញាណធាតុ វោដ្ឋព្វនមនោវិញ្ញាណធាតុនោះ ក៏ជាបច្ច័យនៃជវនមនោវិញ្ញាណធាតុ ចំណែកជវនមនោវិញ្ញាណធាតុជាបច្ច័យដោយបច្ច័យ ៦ គឺដោយបច្ច័យ ៥ នោះ និងអនន្តរប្បច្ច័យ ១ នៃជវនមនោវិញ្ញាណធាតុជាលំដាប់ៗ ទៅ នេះជាន័យក្នុងបញ្ចទ្វារមុន ។ ចំណែកក្នុងមនោទ្វារ ភវង្គមនោវិញ្ញាណធាតុជាបច្ច័យនៃអាវជ្ជនមនោវិញ្ញាណធាតុ និងអាវជ្ជនមនោវិញ្ញាណធាតុជាបច្ច័យនៃជវនមនោវិញ្ញាណធាតុដោយបច្ច័យ ៥ ( មានសមនន្តរ-ប្បច្ច័យជាដើម ) ដែលពោលមកមុននោះឯង ចំណែកធម្មធាតុជាបច្ច័យច្រើនយ៉ាងជាបច្ច័យជាដើមថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្ត-ប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យនៃវិញ្ញាណធាតុទាំង ៧ ចំណែកធាតុទាំងឡាយ ១៧ មានចក្ខុធាតុជាដើម និងធម្មធាតុប្រភេទខ្លះជាបច្ច័យសូម្បីដោយបច្ច័យ មានអារម្មណប្បច្ច័យជាដើមនៃមនោវិញ្ញាណធាតុប្រភេទខ្លះ ។ មយ៉ាងទៀត មិនមែនមានតែចក្ខុ និងរូបតែប៉ុណ្ណោះជាដើមទេដែលជាបច្ច័យនៃចក្ខុវិញ្ញាណធាតុជាដើមនោះ ដែលពិតសូម្បីវត្ថុដទៃ មានពន្លឺជាដើមក៏ជាបច្ច័យផងដែរ ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា អាស្រ័យចក្ខុ រូប ពន្លឺ និងមនសិការ ( គឺអាវជ្ជនៈ ) កើតចក្ខុវិញ្ញាណឡើង អាស្រ័យសោត សំឡេង ប្រហោង ( ត្រចៀក ) និងមនសិការ កើតសោតវិញ្ញាណឡើង អាស្រ័យឃានៈ ក្លិន ខ្យល់ និងមនសិការ កើតឃានវិញ្ញាណឡើង អាស្រ័យជិវ្ហា រស ទឹក និងមនសិការ កើតជិវ្ហាវិញ្ញាណឡើង អាស្រ័យកាយ ផោដ្ឋព្វៈ បឋវីធាតុ ( ទីអាស្រ័យរបស់កាយបសាទ ) និងមនសិការ កើតកាយវិញ្ញាណឡើង អាស្រ័យភវង្គមនៈ ( គឺភវង្គចិត្តដែលញ័រហើយ ២ ដង ) ធម៌ និង

មនសិការ កើតមនោវិញ្ញាណឡើង ដូច្នេះ ។

នេះជាសេចក្តីសង្ខេបក្នុងពាក្យថា **បច្ច័យ** នេះ ចំណែកប្រភេទបច្ច័យ ដោយពិស្តារ ដែលមានជាក់ច្បាស់ក្នុងនិទ្ទេសនៃបដិច្ចសមុប្បាទ ។

សូម្បីវិនិច្ឆ័យដោយបច្ច័យ ក្នុងធាតុទាំងឡាយនោះ បណ្ឌិតគប្បីជ្រាបដូចពោលមក ដូច្នេះ ។

## ដោយភាពជាវត្ថុគប្បីឃើញ

ពាក្យថា **ទដ្ឋព្វា** សេចក្តីថា មួយទៀត គប្បីជ្រាបដោយភាពជាវត្ថុ គប្បីឃើញក្នុងធាតុទាំងឡាយនោះ ពិតហើយ សង្ខតធាតុទាំងឡាយ បណ្ឌិតគប្បីឃើញជារបស់សូន្យចាកចំណែកខាងដើម ( គឺអតីត ) និងចំណែកខាងចុង ( គឺអនាគត ) ដោយភាពជារបស់ទទេចាកការស្ថិតស្ថេរ ភាពស្អាត សេចក្តីសុខជាដើម និងដោយមានការប្រព្រឹត្តទៅទាក់ទងដោយបច្ច័យតែ ( បើពោល ) ដោយភាពប្លែកគ្នាក្នុងធាតុទាំងឡាយនោះ ចក្ខុធាតុគប្បីឃើញដូចផ្ទៃស្គរ រូបធាតុដូចអន្ទង ( វាយស្គរ ) ចក្ខុវិញ្ញាណធាតុដូចសំឡេង ( ស្គរ ) ដោយន័យនោះ ចក្ខុធាតុដូចកញ្ចក់ឆ្លុះមើលមុខ រូបធាតុដូចមុខ ចក្ខុវិញ្ញាណធាតុដូចស្រមោលមុខ ន័យម្យ៉ាងទៀត ចក្ខុធាតុដូច ( កំណាត់ ) អំពៅ និងគ្រាប់ល្ង រូបធាតុដូចគ្រឿងកៀបអំពៅ និងឈើកៀបល្ង ចក្ខុវិញ្ញាណធាតុដូចទឹកអំពៅនិងប្រេងល្ងមានន័យដូចគ្នានោះដែរ ចក្ខុធាតុដូចឈើពួតភ្លើងខាងក្រោម រូបធាតុដូចឈើពួតភ្លើងខាងលើ ចក្ខុវិញ្ញាណធាតុដូចភ្លើង ក្នុងធាតុ ៤ ដ៏សេស មានសោតធាតុជាដើមក៏ដូចន័យនេះ ។ ចំណែកមនោធាតុ គប្បីឃើញដូចបុរេចរ ( អ្នកនាំមុខ ) និងអនុចរ ( អ្នកដើរតាមក្រោយ ) នៃវិញ្ញាណធាតុទាំងឡាយ មានចក្ខុវិញ្ញាណធាតុជាដើម ដោយភាពតាមដែលវាកើតបាន ក្នុងធម្មធាតុ វេទនាខន្ធ គប្បីឃើញដូចព្រួញ និងដូចលំពែងសញ្ញាខន្ធនិងសង្ខារក្ខន្ធដូចមនុស្សដែលរងទុក្ខសោកព្រោះត្រូវសរនិង

លំពែង គឺវេទនាចូល ន័យម្យ៉ាងទៀត សញ្ញារបស់បុថុជ្ជនទាំងឡាយ ដូចបាតដៃទទេ ហេតុធ្វើទុក្ខ ព្រោះការសង្ឃឹមឲ្យកើត ដូចម្រឹគព្រៃ ព្រោះធ្វើឲ្យកាន់យកនិមិត្តដោយភាពមិនពិតសង្ខារក្ខន្ធដូចបុរសអ្នកបន្សាត់ ( ប្រានអ្នកដទៃ ) ឲ្យធ្លាក់ចុះក្នុងរណ្ដៅរងើកភ្លើង ព្រោះបន្សាត់ (សត្វ) ទៅក្នុងបដិសន្ធិ ដូចចោរដែលរាជបុរសតាមចាប់ ព្រោះត្រូវជាតិទុក្ខជាប់តាម ដូចដើមឈើមានពិស ព្រោះជាហេតុនៃខន្ធសន្តានដែលនាំអនត្ថៈទាំងពួងមកឲ្យ រូបគប្បីឃើញដូចកងចក្រដ៏មុត ព្រោះជាហេតុនៃឧបទ្ទវច្រើនប្រភេទ ចំណែកអសង្ខតធាតុទាំងឡាយ បណ្ឌិតគប្បីឃើញដោយភាពជាអមតៈ ជាសន្តៈ (ស្ងប់រម្ងាប់) ជាខេមៈ ( ផុតភ័យ ) ព្រោះហេតុអ្វី ព្រោះជាចំណែកផ្ទុយអំពីអនត្ថៈទាំងពួង មនោវិញ្ញាណធាតុ គប្បីឃើញដូចស្វាក្នុងព្រៃ ព្រោះមិនមានការឈប់នៅក្នុងអារម្មណ៍ទាំងឡាយ ដូចសេះអាក្រក់ ព្រោះបង្វឹកបានដោយលំបាក ដូចកំណាត់ឈើដែលបោះឡើងលើ ព្រោះវាធ្លាក់ទៅតាមដែលវាប្រាថ្នា ដូចអ្នករបាំក្នុងរោងរបាំ (តាក់តែងខ្លួនផ្សេងៗ) ព្រោះប្រកបដោយភេទ ( គ្រឿងតែងកាយ ) គឺកិលេសមានប្រការផ្សេងៗ មានលោភៈ និងទោសៈជាដើម ។

បរិច្ឆេទទី ១៥ ឈ្មោះអាយតនធាតុនិទ្ទេស

ក្នុងអធិការនៃបញ្ញាភាវនា ក្នុងបករណ៍វិសុទ្ធិមគ្គ

ដែលខ្ញុំធ្វើដើម្បីប្រយោជន៍ដល់បាមោជ្ជនៃសាធុជន ដូច្នេះ ។

# មហាដីកា

## កថាពណ៌នាដោយពិស្តារនៃធាតុ

ពីរបទថា **ចក្ខុស្ស វិញ្ញាណំ** បានដល់ វិញ្ញាណនៃចក្ខុដែលជាហេតុ សូម្បីរូប ពន្លឺ និងមនសិការជាដើមជាហេតុនៃវិញ្ញាណនោះដោយពិត សូម្បីដូច្នោះ រូប ពន្លឺ និងមនសិការជាដើមនោះ ក៏ជាហេតុទូទៅ ចក្ខុជាហេតុមិនទូទៅ ព្រោះដូច្នោះ និទ្ទេសនេះ មានដោយហេតុដែលមិនទូទៅ ដូចជាសំឡេងស្គរ ពន្លកស្រូវជំណើប ដូច្នេះ ពិតយ៉ាងនោះ ចក្ខុជាហេតុមិនទូទៅរបស់បុគ្គលដទៃ និងជាហេតុទូទៅដល់រូបទាំងអស់ មានរូបពណ៌ខៀវជាដើម ព្រោះដូច្នោះ ទើបលោកសម្តែងលម្អិតទុក ដោយភាពជាឆដ្ឋីវិភត្តិ ។

បទថា **វិទហតិ** សេចក្តីថា រមែងធ្វើឲ្យកើតឡើង ដូចបង្គាប់ថា អ្នកត្រូវប្រព្រឹត្តទៅយ៉ាងនោះយ៉ាងនេះ ។ បទថា **វិទហតិ** អត្ថរបស់ធាតុនោះឯងដទៃទៀត លោកសម្តែងទុកដោយឧបសគ្គ ព្រោះដូច្នោះ សូម្បីវៀរចាកឧបសគ្គ **ធាតុ** នេះ គប្បីឃើញថាប្រាប់អត្ថដូច្នោះ ។ និងសេចក្តីសម្រេចនៃធាតុស័ព្ទ ក៏រមែងមានក្នុងកត្តុ កម្ម ភាវៈ ករណៈ និងអធិករណៈ ព្រោះដូច្នោះ ទើបលោកពោលអត្ថទាំង ៥ នោះទុក ។ លោកធ្វើឲ្យផ្សេងចេញទៅថា **លោកិយធាតុ** ព្រោះអធិប្បាយថា លោកុត្តរធាតុរមែងមិនចាត់ចែងសង្សារទុក្ខ រមែងទម្លាយដោយពិត ។ បទថា **វវត្ថិតា** ប្រែថា កំណត់ ឬប្រែថា មិនលាយឡំគ្នានឹងគ្នា ។ **ធាតុមានមាស និងប្រាក់ជាដើម** បានដល់ ថ្មជាដើម ដែលជាពូជរបស់មាសជាដើម ។ ក្នុងបទថា **យថាសម្ភវំ** នេះ អាចារ្យពួកខ្លះរមែងពោលអត្ថទុកថា អត្ថណាមួយ មានក្នុងធាតុទាំងឡាយដែលជាលោកិយ និងលោកុត្តរ ក៏សមគួរដល់អត្ថនោះៗ ពាក្យរបស់អាចារ្យពួកខ្លះនោះមិនត្រឹមត្រូវ ព្រោះលោកអាចារ្យពោលឲ្យផ្សេងចេញទៅថា មែនពិត ធាតុទាំងឡាយដែលជាលោកិយ ។

លោកធ្វើស័ព្ទថា **យថាសម្ភវំ** នេះទុក ទាក់ទងនឹងអត្ថ មិនមែនទាក់ជាមួយធាតុ ។ ធាតុគ្រប់ធាតុ មានចក្ខុធាតុជាដើម នឹងត្រូវប្រាថ្នាអត្ថទាំង ៥ នេះក៏ពិតយ៉ាងនោះ បណ្ដាធាតុ មានចក្ខុធាតុជាដើម កាលណាត្រូវការនឹងនិយាយធម៌ណាមួយ ជាកត្តុ កាលនោះក៏ជាកម្មមិនបាន ។ តែកាលណាត្រូវការនឹងនិយាយជាកម្ម កាលនោះ ក៏ជាកត្តុមិនបាន ។ សូម្បីក្នុងធាតុដ៏សេសក៏ដូចគ្នា ព្រោះដូច្នោះ ទើបលោកប្រើស័ព្ទ ថា **យថាសម្ភវំ** ទុក ។ ដោយហេតុនោះ ទើបអាចារ្យពោលពាក្យថា **ក្នុងបណ្ដាធាតុ មានចក្ខុជាដើម ដោយប្រការដូច្នេះ** ជាដើម ។

សូម្បីក្នុងពាក្យថា ឈ្មោះថា **ធាតុ ព្រោះអត្ថថា ទ្រទ្រង់ទុកនូវសភាវៈរបស់ខ្លួន** នេះក៏គប្បីជ្រាបការសម្រេចនៃបទថា **ធាតិ** ថា **ធាតុ** ព្រោះធ្វើអធិប្បាយថា **ធា**-ស័ព្ទ មានអត្ថថា ទ្រទ្រង់ទុក ។ ឯធាតុស័ព្ទនេះ សូម្បីមានអត្ថជាកត្តុក៏មិនដូចគ្នានឹងពាក្យ ដំបូង ព្រោះអត្ថ គឺវិធាន កាលចាត់ចែង និងធារណៈ ការទ្រទ្រង់ទុក ជាអត្ថមាន សភាវៈផ្សេងគ្នា ។ម្យ៉ាងទៀត ការទ្រទ្រង់ទុកគ្រាន់តែជាសភាវៈដែលមិនមែនសត្វ ជាអត្ថដែលជាប្រធានរបស់ធាតុស័ព្ទ ព្រោះដូច្នោះ ទើបលោកពោលទុកមួយផ្នែក ។ ក្នុងពាក្យថា **ធាតុទាំងឡាយ ដូចជាធាតុ** ទើបឈ្មោះថា **ធាតុ** នេះ **ធាតុ**-ស័ព្ទ ដែល ប្រើជាប់មាត់ក្នុងបុរសក្នុងចំណែកតូចតាចរបស់ភ្នំទាំងឡាយ គប្បីជ្រាបថា ប្រើហៅ បញ្ចិតៗ ក្នុងធាតុទាំងឡាយ មានចក្ខុជាដើម ដូចជា **សីហ**-ស័ព្ទ ប្រើជាពាក្យជាប់ មាត់ក្នុងកេសរសីហៈ ដូច្នោះ ។ ការដឹងផង វត្ថុដែលគួរដឹងផង ឈ្មោះថា ការដឹង និង វត្ថុដែលគួរដឹងផង ធាតុទាំងឡាយដែលជាចំណែកតូចតាចរបស់ការដឹង និងវត្ថុដែល គួរដឹងទាំងនោះ គឺជាប្រភេទរបស់ការដឹង និងវត្ថុដែលគួរដឹងទាំងនោះ ឈ្មោះថា ជា ចំណែកតូចតាចនៃការដឹង និងវត្ថុដែលគួរដឹង ។ ក្នុងសេចក្ដីនេះ **ប្រភេទរបស់ញាណ** បានដល់ឯកទេស របស់ធម្មធាតុ **ប្រភេទរបស់វត្ថុដែលគួរដឹង** បានដល់ ធាតុទាំង ១៨

*ព្រោះដូច្នោះ ទើបរមែងមានធាតុ ត្រឹមតែជាចំណែកតូចតាចរបស់ញាណ និងវត្ថុដែលគួរដឹង ដូច្នេះ ។ ប្រការមួយទៀត សភាវៈដែលគប្បីដឹងបានដោយញាណ ជាវត្ថុដែលមិនវិបរិតដែលលោកពោលទុកដោយធាតុសព្ទ ឈ្មោះថា* ***ការដឹង និងវត្ថុដែលគួរដឹង*** *អធិប្បាយថា មិនមែនវត្ថុដែលគប្បីដឹងដោយការដឹងដែលប្រកាន់វិបរិត មានទិដ្ឋិជាដើម* ***ចំណែកបន្តិចបន្តួចទាំងឡាយនៃការដឹង និងវត្ថុដែលគួរដឹងនោះ*** *បានដល់ធាតុ មានចក្ខុជាដើម* ***ធាតុ-សព្ទ*** *ដែលប្រើជាប់មាត់ក្នុងធាតុ មានរសជាដើម ដែលជាចំណែកបន្តិចបន្តួចរបស់លក្ខណៈដែលផ្សេងគ្នា គប្បីឃើញថា លោកប្រើពាក្យបញ្ចិតៗក្នុងធាតុ មានចក្ខុជាដើម ដែលជាចំណែកតូចតាចរបស់ធាតុដទៃ ដូច្នោះ ។ម្យ៉ាងទៀត* ***ធាតុ-សព្ទ*** *ដែលប្រើជាប់មាត់ក្នុងធាតុ មានចក្ខុជាដើម ក៏ដូចគ្នានឹងធាតុសព្ទ ដែលប្រើជាប់មាត់ក្នុងធាតុ មានរសជាដើម ដូច្នោះ ។ ដោយពាក្យថា* ***ធាតុនេះជាឈ្មោះរបស់សភាវធម៌ គ្រាន់តែជានិជ្ជីវធម៌ប៉ុណ្ណោះ*** *នេះ លោកអាចារ្យរមែងសម្តែងភាពដែលធាតុសព្ទជាពាក្យប្រើជាប់មាត់ ក្នុងអត្ថនៃបទរបស់សភាវធម៌ គ្រាន់តែជានិជ្ជីវធម៌ ។ ធាតុ ៦ មានដល់បុរសនេះ ហេតុនោះ បុរសនេះឈ្មោះថា* ***ឆធាតុរោ*** *ប្រែថា មានធាតុ ៦ អធិប្បាយថា ក្រុមធម៌ណា លោកហៅថា បុរសក្នុងលោក ក្រុមធម៌នោះមានធាតុ ៦ គឺគ្រាន់តែជាក្រុមនៃសភាវធម៌ទាំងឡាយ គ្រាន់តែជានិជ្ជីវធម៌ទាំង ៦ យ៉ាង មានបឋវីជាដើម ជីវៈ ឬបុរសមិនមាននៅក្នុងពពួកធម៌នេះឡើយ ។*

*លំដាប់នៃធាតុ មានចក្ខុជាដើម លោកពោលទុកហើយក្នុងកាលមុន ព្រោះដូច្នោះ លោកអាចារ្យកាលនឹងសម្តែងលំដាប់នៃធាតុទាំង ៣ ក្នុងតិកៈតែម្យ៉ាង ក្នុងទីនេះ ទើបពោលថា* ***ដោយអំណាចការកំណត់លំដាប់របស់ហេតុ និងផល*** *។ ការកំណត់លំដាប់របស់ហេតុ និងផល ក៏គឺជាហេតុ និងផលនោះឯង ភាពដែលមនោធាតុ និងធម្មធាតុជាហេតុរបស់មនោវិញ្ញាណធាតុ បណ្ឌិតគប្បីប្រកបតាមសមគួរ ។ ម្យ៉ាង*

ទៀត គប្បីប្រកបដោយអំណាចនៃមនោដែលជាទ្វារថា មនោធាតុដែលជាកិរិយាជាបច្ច័យដល់មនោវិញ្ញាណ ដោយភាពជាឧបនិស្សយប្បច្ច័យខាងចុង ( បកតូបនិស្សយ-ប្បច្ច័យ ) មនោធាតុដែលជាវិបាកជាបច្ច័យដល់មនោវិញ្ញាណធាតុដែលជាវិបាក សូម្បីដោយបច្ច័យ មានអនន្តរប្បច្ច័យជាដើម មនោធាតុទាំងអស់ជាបច្ច័យដល់វិញ្ញាណក្រៅអំពីនេះ ដោយភាពជាឧបនិស្សយប្បច្ច័យខាងចុង ( បកតូបនិស្សយ ) ចំណែកធម្មធាតុ មានវេទនាជាដើមដែលកើតរួមគ្នាជាបច្ច័យដល់មនោវិញ្ញាណធាតុ ដោយជាសហជាតប្បច្ច័យជាដើមដែលមិនបានកើតរួមគ្នា ក៏ជាបច្ច័យដោយភាពជាបច្ច័យ មានអនន្តរប្បច្ច័យជាដើម ដោយឧបនិស្សយប្បច្ច័យ និងដោយបច្ច័យ មានអារម្មណប្បច្ច័យជាដើម ។ ពិតហើយ សូម្បីមនោដែលជាទ្វារ លោកក៏ហៅថា មនោធាតុ ក្នុងព្រះសូត្រទាំងឡាយ ព្រោះដូច្នោះ មនោធាតុនោះ ជាហេតុនៃមនោវិញ្ញាណ បណ្ឌិតគប្បីប្រកបតាមគួរក៏មាន ។ ក្នុងបណ្ដាពាក្យទាំងនោះ បច្ច័យ លោកមានបំណងយក **ហេតុ** នៃវត្ថុដែលកើតអំពីបច្ច័យ គឺលោកមានបំណងយក **ផល** ព្រោះដូច្នោះ ទើបអាចារ្យពោលពាក្យ មានពាក្យថា **ចក្ខុធាតុ** ជាដើម ។

ពាក្យថា **ដោយអំណាចនៃធាតុទាំងពួង** គឺដោយអំណាចនៃធាតុ ៣៥ មាន **អាភាធាតុ** ជាដើម តាមដែលបានពោលទុកហើយ ។ លោកអាចារ្យពោលថា **ដែលមានដោយសភាវៈ** ដូច្នេះ ព្រោះសភាវៈដែលមិនជាបរមត្ថ និងឈោងចុះខាងក្នុងក្នុងសភាវៈបរមត្ថទាំងឡាយ មិនមានសូម្បីក្នុងកាលណាមួយឡើយ ។

លោកអាចារ្យពោលថា **ពិតហើយ អាភាធាតុ ក៏គឺរូបធាតុនោះឯង** ដូច្នេះ ព្រោះរស្មីនៃព្រះចន្ទ និងរស្មីនៃព្រះអាទិត្យជាដើមក៏ដូចគ្នានឹងរូបនោះឯង ។ ពាក្យថា **ទាក់ទងដោយរូបជាដើម** លោកមិនបានពោលថា មានរូបជាដើមប៉ុណ្ណោះ ( នោះទេ ) តែពោលពាក្យថា ទាក់ទងដោយ ព្រោះអធិប្បាយថា អាការដែលគប្បីកាន់យកដោយ

ជាទីតាំងនៃរាគៈ ជាសុភនិមិត្ត ។ សូម្បីកាលមិនមានទីតាំងនៃរាគៈ អកុសលវិបាក ក៏ចាត់ជាសុភធាតុ ព្រោះដូច្នោះ ទើបលោកពោលវិកប្បទី ២ ទុក ។ ពាក្យថា **ធាតុដ៏សេស** បានដល់ ធាតុដែលប្រកបដោយមនោវិញ្ញាណធាតុ ។ ពាក្យថា **ត្រឹមតែជាការរលត់នៃធាតុទាំង ២** គឺត្រឹមតែជាការរលត់នៃមនោវិញ្ញាណធាតុ ព្រោះត្រឹមតែជាការរលត់នៃចិត្តុប្បាទក្នុងអរូបជ្ឈានទី ៤ ។ លោកប្រើសព្ទថា ធាតុទាំង ២ ព្រោះអធិប្បាយថា ឯការរលត់នៃវិញ្ញាណធាតុ និងមនោធាតុដែលសម្រេចដោយកម្លាំងនៃសមាបត្តិ ក៏ដូចជាការរលត់នៃវិញ្ញាណដទៃក្រៅអំពីនោះ ។

ពាក្យថា **ត្រឹមតែជាធម្មធាតុ** នេះ លោកពោលទុកព្រោះកាមធាតុ ដែលទាក់ទងនៅក្នុងធម្មធាតុ ។ ពាក្យថា **ដែលទាក់ទងនឹងកាម** បានដល់ ដែលប្រកបដោយកាមរាគៈ ឬប្រកបដោយកាមគុណ ដោយធ្វើឲ្យជាអារម្មណ៍ ។ ច្រើនបទថា **យំ ឯតស្មឹ អន្តរេ** សេចក្ដីថា ធម៌ពួកណាក្នុងឱកាសនេះ ដែលកំណត់ដោយអវីចីនរក និងទេវតាជាន់បរនិម្មិតវសវត្តី ។ ឈ្មោះថា **ឯត្ថា វចរា** ព្រោះអត្ថថា ជាសភាវៈដែលចុះកាន់ហើយត្រាច់ទៅ ក្នុងឱកាសដែលជាចំណែកខាងក្រោមផង ។ ឈ្មោះថា **ឯត្ថ បរិយាបន្នា** ព្រោះអត្ថថា សូម្បីត្រាច់ទៅក្នុងទីដទៃក៏នៅទាក់ទងក្នុងទីតាមដែលពោលហើយនោះឯង ។

**នេក្ខម្មធាតុ** ឈ្មោះថា **ធម្មធាតុ** នោះឯង ចាត់ចូលក្នុងចំណែកនៃវិតក្ក ។ ពាក្យថា **ធម៌ទាំងឡាយដែលជាកុសលទាំងពួង** បានដល់ ធម៌ដែលមិនមានទោសទាំងពួងដែលប្រព្រឹត្តទៅចាប់ផ្ដើមអំពីទានមយបុញ្ញកិរិយា សីលមយបុញ្ញកិរិយា និងចាប់ផ្ដើមអំពីបព្វជ្ជា ។ រហូតដល់ការសម្រេចមគ្គដ៏លើស ។ **វិហិង្សធាតុ** បានដល់ ចេតនា ឬបានដល់ ការពេញចិត្តក្នុងការបៀតបៀនអ្នកដទៃ ។ **អវិហិង្សា** បានដល់ ករុណា ។ ពាក្យថា **ហីនធាតុ** បានដល់ ធាតុដែលបណ្ឌិតតិះដៀល ។ **បណីតធាតុ** បានដល់

ធាតុដែលបណ្ឌិតសរសើរ ។ **មជ្ឈិមធាតុ** គប្បីជ្រាបថា លោកពោលដោយនាំចេញមកអំពីហីនទុកៈនោះឯង ដែលមក **ក្នុងខន្ធនិទ្ទេស** ថា ធាតុដែលបណ្ឌិតមិនតិះដៀលពេក មិនសរសើរពេក ឈ្មោះថា **មជ្ឈិមធាតុ** ។ ពាក្យថា **ធាតុទាំង ២** បានដល់ធម្មធាតុ និងមនោវិញ្ញាណធាតុ ។

វិញ្ញាណធាតុ សូមបីបែកជាវិញ្ញាណធាតុ ៦ ក៏ពិត ដូច្នោះ ក៏រមែងត្រូវកាន់យកមនោធាតុនោះឯង ព្រោះមនោធាតុនោះជាបុរេចារិក និងបច្ឆាចារិកនៃវិញ្ញាណធាតុនោះដោយការកាន់យកវិញ្ញាណធាតុ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **វិញ្ញាណធាតុក៏ជាសង្ខេបនៃវិញ្ញាណធាតុ ៧ មានចក្ខុជាដើម** ។ លោកពោល ដល់លោកថា **មានធាតុមិនមែនតិច** ដោយអំណាចនៃធាតុមិនមែនតិច គឺមានចក្ខុធាតុជាដើម និងថា **មានធាតុផ្សេងៗ គ្នា** ដោយអំណាចនៃធាតុផ្សេងៗ គ្នា ព្រោះបណ្ដាធាតុមិនមែនតិចនោះ ធាតុតែមួយក៏មានប្រការផ្សេងៗ គ្នា ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ត្រឹមតែជាប្រភេទនៃធាតុ ១៨ ប៉ុណ្ណោះ** ។

ក្នុងគម្ពីរដែលបានចារទុកជាច្រើនថា **ចក្ខុសោតឃានជិវ្ហាកាយមនោធាតុមនោ-វិញ្ញាណធាតុភេទេន** តែក្នុងគម្ពីរខ្លះរបនាទុកថា **ចក្ខុសោតឃានជិវ្ហាកាយមនោមនោ-វិញ្ញាណធាតុភេទេន** ។ ក្នុងគម្ពីរទាំងនោះ លោកមានបំណងយកការភ្ជាប់ស័ព្ទទាំងឡាយ មានចក្ខុជាដើមជាមួយធាតុស័ព្ទសុទ្ធៗ ក៏ទេ ព្រោះពោលដល់ប្រភេទនៃសភាវៈគឺការដឹងច្បាស់ ។ ការធ្វើការភ្ជាប់ជាមួយពាក្យថា វិញ្ញាណធាតុក៏មិនគួរ នឹងធ្វើស័ព្ទថា **មនោ** ទាំងពីរស័ព្ទ ។ ព្រោះមិនមានមនោវិញ្ញាណធាតុដល់ទៅ ២ នោះឡើយ ។ ម្យ៉ាងទៀត លោកមិនបានធ្វើស័ព្ទថា **មនោធាតុ** ទុកក្នុងចន្លោះ ក៏គួរពោលថា **ចក្ខុ ។បេ។ កាយមនោវិញ្ញាណធាតុមនោធាតុ** ព្រោះកាលប្រកបជាមួយស័ព្ទដែលមិនស្មើគ្នាក៏នឹងមានការបែកសមាសមិនបាន ។ ម្យ៉ាងទៀត ក្នុងទីនេះគួរនឹងជាបាឋៈដូច្នេះ

ចក្ខុ ។បេ។ កាយវិញ្ញាណមនោមនោវិញ្ញាណធាតុភេទេន ។ ការប្រកាសភាពដែលជាវិញ្ញាណ **នោះជាច្រើនយ៉ាង** និងជាធម្មជាតិមិនទៀង រមែងមានដើម្បីនឹងដកចោលនូវជីវសញ្ញារបស់សត្វទាំងនោះ ព្រោះដោយច្រើនពួកអត្តវាទីទាំងឡាយ រមែងប្រកាសភាពដែលជាអត្តាតែម្យ៉ាងៗ នោះមិនជា ២ និងជាធម្មជាតិទៀង ។ទេសនាខន្ធនិងអាយតនៈ **ជាទេសនាដោយសង្ខេប** ទេសនា ឥន្ទ្រិយ **ជាទេសនាដោយពិស្តារ** ទេសនាធាតុនេះ សំដៅដល់ទេសនាទាំងពីរយ៉ាងនោះ **ជាទេសនាដែលមិនសង្ខេបនិងមិនពិស្តារពេក** ។ ម្យ៉ាងទៀត ទេសនាធាតុ ដែលត្រាស់ **ទុកក្នុងសុត្តន្តភាជនីយ៍** ក្នុងព្រះអភិធម្មជាទេសនាដោយសង្ខេបពេក ទេសនាដោយពិស្តារពេក គប្បីសម្តែងដោយអំណាចនៃធាតុទាំងឡាយ ដែលមានអាកាធាតុជាដើម មានធាតុមិនមែនតិចនិងធាតុផ្សេងៗ ជាទីបំផុតទេសនានេះ ប្រារព្ធដល់ទេសនាទាំងពីរយ៉ាងនេះ ទើបជាទេសនាដែលមិនសង្ខេប និងពិស្តារពេក ។

អស្ស យោគ ភគវតោ ដែលគេជះនៃព្រះសទ្ធម្មទម្លាយហើយ ។ឈ្មោះថា **សទ្ធម្មតេជវិហតំ** ។

បទថា **សន្តតោ** ប្រែថា ដោយការរាប់ ។ ពាក្យថា **ដោយជាតិ** បានដល់ ដោយភាពស្មើគ្នា គឺភាពជាចក្ខុ ។ ម្យ៉ាងទៀត ពាក្យថា **ដោយជាតិ** គឺដោយសភាវៈនៃចក្ខុ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **គឺចក្ខុបសាទ** ។ ឈ្មោះថា **ដល់នូវការរាប់ថា ជាធម៌ ២០** ព្រោះកាន់យកមិនបានញែកអរូបក្ខន្ធ មានវេទនាជាដើមចេញទៅ ។ ក្នុងពាក្យថា **ដោយអំណាចកុសលចិត្ត អកុសលចិត្ត និងអព្យាកតចិត្តដ៏សេស** នេះ លោកប្រើស័ព្ទថា ដ៏សេសទុក ដោយប្រារព្ធដល់អព្យាកតចិត្ត ។ ចំណែកកុសលចិត្តនិងអកុសលចិត្ត លោកមិនបានកាន់យកដោយប្រការទាំងពួងនោះឡើយ ។

តា ច យោគ ចក្ខុវិញ្ញាណធាតុ អាទយោ បញ្ចបិ ប្រែថា ធាតុទាំង ៥ មាន

ចក្ខុវិញ្ញាណធាតុជាដើមនោះ ។

បទថា **បុរិមោហោរ** គឺដោយបច្ច័យ មានអនន្តរប្បច្ច័យជាដើមនោះឯង ។ លោកពោលសេចក្តីនេះទុកថា ឯជវនមនោវិញ្ញាណធាតុ ជាបច្ច័យដោយអាសេវនប្បច្ច័យក៏មានដល់ជវនមនោវិញ្ញាណធាតុ ។ មានវេទនាខន្ធជាដើមដែលកើតរួមគ្នា លោកហៅថា **ធម្មធាតុ** ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ជាបច្ច័យច្រើនយ៉ាង** **ដោយបច្ច័យ មានសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្ប-យុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យជាដើម** ។ ដោយ **អាទិ**-ស័ព្ទ ក្នុងបទថា **អវិគតាទីហិ** នេះ លោករមែងសង្រ្គោះភាពជា **ហេតុប្បច្ច័យ អធិបតិប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្រ្ទិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ** តាមសមគួរដល់មនោវិញ្ញាណធាតុ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ជាបច្ច័យច្រើនយ៉ាង** ។ **ចំណែកធម្មធាតុខ្លះ** បានដល់ មានប្រការជាសុខុមរូប និងនិព្វាន ដែលសមគួរក្នុងការធ្វើឲ្យជាអារម្មណ៍ ព្រោះការមិនមានសម្បយោគ និងជាអនន្តរប្បច្ច័យជាដើម ។ លោកពោលថា **ដល់មនោវិញ្ញាណធាតុខ្លះ** ដើម្បីនឹងវៀរបង់នូវវិបាកដែលប្រព្រឹត្តទៅក្នុងបញ្ចទ្វារ វិបាកដែលប្រព្រឹត្តទៅក្នុងមនោទ្វារជាតទាលម្ពណៈក៏រមែងប្រារព្ធធម្មធាតុខ្លះប្រព្រឹត្តទៅ ដូច្នេះ ។ ន័យម្យ៉ាងទៀត ពាក្យថា **ដល់មនោ-វិញ្ញាណធាតុខ្លះ** នេះ លោកពោលសំដៅយកមនោវិញ្ញាណធាតុបែបនេះ គឺកាមាវចរកុសលទាំងអស់ កាមាវចរកិរិយា អភិញ្ញា ទាំងពីរ អរូបទាំងពីរ ម្យ៉ាងទៀត ធម្មធាតុខ្លះជាអារម្មណប្បច្ច័យដល់មនោវិញ្ញាណធាតុដែលជាលោកុត្តរ ព្រោះដូច្នោះ ទើបសេចក្តីនេះជាក់ច្បាស់ហើយ ។ លោកអាចារ្យផ្តើមពាក្យថា **មិនមែនត្រឹមតែប៉ុណ្ណោះឡើយ** ដូច្នេះជាដើម ដើម្បីនឹងសម្តែងបច្ចយធម៌ ដែលច្រើនជាងបច្ចយធម៌តាមដែលពោលហើយ នៃចក្ខុវិញ្ញាណធាតុជាដើម នៃចក្ខុជាដើម ។ ក្នុងពាក្យនោះ ពាក្យថា **ពន្លឺជាដើម**

សេចក្តីថា ពន្លឺ មានពន្លឺនៃព្រះអាទិត្យជាដើម ឈ្មោះថា **ពន្លឺ** ។ គប្បីជ្រាបភាពដែលពន្លឺនៃព្រះអាទិត្យនោះជាឧបនិស្សយប្បច្ច័យតាមន័យនៃព្រះសូត្រ សូម្បីពាក្យដ៏សេសក៏យ៉ាងនេះ ។

ឈ្មោះថា **ប្រហោង** បានដល់ ប្រហោងត្រចៀកដោយពិសេស **ខ្យល់** បានដល់ ខ្យល់ដែលបក់យកក្លិនទៅបាន ។ **អាបោ** បានដល់ ទឹកដែលធ្វើអាហារដាក់ក្នុងមាត់ឲ្យសើម ។ **បឋវី** បានដល់ បឋវីធាតុដែលជាទីអាស្រ័យនៃកាយបសាទ ។ **ភវង្គមន** បានដល់ ភវង្គចិត្តដែលញ័រហើយ ២ ដង ។ **មនសិការ** ក្នុងគ្រប់បទ បានដល់ មនសិការ គឺអាវជ្ជនៈ ។

លោកអាចារ្យពោលថា **ទាំងអស់នោះឯង** ដូច្នេះ ព្រោះកំពុងពោលដល់អាការដែលនឹងគប្បីឃើញដោយការមិនប្លែកគ្នា ។ពោលឲ្យផ្សេងចេញទៅថា**សង្ខត** ព្រោះនេះជាការពិចារណាភូមិនៃវិបស្សនា ដោយភាពប្លែកគ្នា ។ ក្នុងបទថា **បុព្វន្តាបរន្តវិវិត្តតោ** នេះ អតីតកាល ឈ្មោះថា **បុព្វន្ត** អនាគតកាល ឈ្មោះថា **អបរន្ត** ។ ឯសង្ខតធាតុក្នុងកាលទាំង ២ វៀរចាកសភាវៈ ព្រោះមានសភាពដែលមិនបាន ។ ន័យដែលមិនបាន ។ ន័យម្យ៉ាងទៀត ការកើតឡើងនៃសភាវធម៌ ឈ្មោះថា **បុព្វន្ត** ព្រោះមិនមានមុនអំពីនោះ ។ ការវិនាស ( នៃសភាវធម៌ ) ឈ្មោះថា **អបរន្ត** ព្រោះក្រោយអំពីនោះក៏មិនមាន ព្រោះដូច្នោះ បទថា **បុព្វន្តាបរន្តវិវិត្តតោ** ទើបមានអធិប្បាយថា ព្រោះការមិនមានផល គឺព្រោះមិនមានការខ្វាត់ខ្វាយ ។

**ចក្ខុធាតុ** ប្រៀបដូចមុខស្គរ និងព្រោះជាទីអាស្រ័យនៃវិញ្ញាណ ដែលប្រៀបដូចនឹងសំឡេងស្គរ ។ សូម្បីក្នុងមុខកញ្ចក់ជាដើមក៏ដូចន័យនេះឯង គ្រឿងគាបអំពៅឈ្មោះថា **យន្តគាប** លោកហៅឈើកិនល្ងថា **ចក្កយដ្ឋិ** ។ ពិតហើយ ឈើកិនល្ងនោះសូម្បីមិនបានជាប់គ្រឿងចក្រទុក លោកក៏ហៅថា **ចក្កយដ្ឋិ** ព្រោះជាគ្រឿងចក្រនោះ

ឯង ម្យ៉ាងទៀត លោកពោលយ៉ាងនោះ សំដៅយកឈើកិនល្ងនោះឯង ។ ដោយឧបមា ទាំងនេះ លោកអាចារ្យសម្តែងផលនៃហេតុថាគ្រាន់តែជាធាតុ នឹងវៀរចាកអ្នកសាង និងអ្នកសោយ ព្រោះកាលការប៉ះខ្ទប់គ្នានៃចក្ខុ នឹងរូបជាដើម ដែលមិនមានជីវៈ ក៏កើតចក្ខុវិញ្ញាណជាដើមដែលមិនមានជីវៈបាន ដូចកាលការប៉ះខ្ទប់របស់មុខស្គរ នឹងឈើអន្ទូងជាដើម ដែលមិនមានជីវៈក៏កើតសំឡេងជាដើម ដែលមិនមានជីវៈបាន ។

ពាក្យថា **ដូចអ្នកនាំមុខ និងអ្នកតាមក្រោយ** សេចក្តីថា ដូចអ្នកនាំមុខ និងអ្នកតាមក្រោយដែលមិនមានជីវៈពួកខ្លះ របស់ធម៌ណាមួយ ដែលមិនមានជីវៈ ។ ន័យម្យ៉ាងទៀត មនោធាតុនោះឯង មិនទាន់កន្លងខណៈរបស់ខ្លួន គប្បីឃើញដូចអ្នកនាំមុខ និងតាមក្រោយរបស់វិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ដែលមិនទាន់កន្លងខណៈរបស់ខ្លួននោះឯង ក្នុងកាលសូម្បីខាងដើម និងកាលខាងក្រោយដែលជាលំដាប់ ក្នុងគោលដៅរបស់អ្នកនាំមុខ និងអ្នកដើរតាមក្រោយ ។

ពិតហើយ វិញ្ញាណធាតុទាំង ៦ ព្រោះមានអនន្តរប្បច្ច័យជាច្រើនព្រមគ្នា ទើបមានការកើតឡើងជាលំដាប់គ្នា ដោយភាពជាអញ្ញមញ្ញប្បច្ច័យ និងអនន្តរប្បច្ច័យដូចគ្នា មិនមានការកើតឡើងព្រមគ្នា ។ បើគប្បីមានការបានអារម្មណ៍ ៦ សូម្បីវៀរមនសិការចេញក៏គប្បីមានបាន ព្រោះសន្សំអារម្មណ៍ទាំង ៦ តែដូច្នេះមិនមាន ព្រោះដូច្នោះ ទើបកិច្ច មានទស្សនកិច្ចជាដើម មិនមានក្នុងលំដាប់នៃមនោវិញ្ញាណធាតុ ដូចការមិនមាននៃសវនកិច្ចក្នុងលំដាប់នៃកិច្ច មានទស្សនកិច្ចជាដើម និងមនោវិញ្ញាណធាតុក៏មិនមានក្នុងលំដាប់នៃកិច្ច មានទស្សនកិច្ចជាដើមឡើយ ។ ក្នុងមនោធាតុនោះ ព្រោះភាពដែលកវត្ត និងកិច្ច មានទស្សនៈជាដើមជាធម៌មានអារម្មណ៍ផ្សេងគ្នា កិច្ច មានទស្សនកិច្ចជាដើម ទើបមិនកើតក្នុងលំដាប់នៃមនោវិញ្ញាណធាតុ និងកិច្ច មានសវនកិច្ចជាដើម ក៏មិនកើតក្នុងលំដាប់នៃកិច្ច មានទស្សនកិច្ចជាដើម ព្រោះដូច្នោះ ទើបសេចក្តី

នេះត្រឹមត្រូវហើយ ។ សួរថា តែព្រោះកិច្ច មានទស្សនកិច្ចជាដើម និងសន្តីរណៈជាធម៌មានអារម្មណ៍មិនផ្សេងគ្នា ទើបមិនមានមនោវិញ្ញាណធាតុក្នុងលំដាប់នៃកិច្ច មានទស្សនកិច្ចជាដើម ព្រោះដូច្នោះ ទើបសេចក្តីនេះមិនត្រឹមត្រូវ ? ឆ្លើយថា សេចក្តីនេះមិនដូច្នោះទេ ព្រោះធម៌ មានអារម្មណ៍ពិតប្រាកដ និងមិនពិតប្រាកដ ចូលដល់ភាពជាធម៌ មានអារម្មណ៍ផ្សេងគ្នា ។ ប្រសិនបើវិញ្ញាណធាតុខ្លះ នឹងគប្បីកើតឡើងក្នុងលំដាប់នៃកិច្ច មានទស្សនកិច្ចជាដើម សូម្បីវិញ្ញាណធាតុនោះក៏គប្បីជាវិញ្ញាណធាតុរបស់កិច្ច មានទស្សនកិច្ចជាដើមនោះឯង ព្រោះភាពជាទ្វារនៃកិច្ច មានទស្សនៈជាដើម មិនមែនជាមនោវិញ្ញាណធាតុនោះទេ ព្រោះហេតុនោះ វិញ្ញាណធាតុរបស់ទស្សនៈក៏នឹងត្រូវមិនលះកិច្ច គឺទស្សនៈ ដូចជាធម៌ដែលប្រព្រឹត្តទៅក្នុងមនោធាតុមិនលះបង់កិច្ច គឺការទឹកគិត ព្រោះការគិតដែលផ្សេងអំពីកិច្ច មានទស្សនៈជាដើម ជាការទឹកគិត ។ ម្យ៉ាងទៀត ព្រោះវិញ្ញាណធាតុនៃទស្សនៈទាំងអស់ជាទស្សនវិញ្ញាណ ក៏នឹងមិនគប្បីជាវិញ្ញាណ ៦ ពួក ព្រោះមានវិញ្ញាណដែលជាលំដាប់របស់វិញ្ញាណនោះៗ ប្រសិនបើមានពាក្យសួរជ្រៀតចូលមកថា មនោធាតុក៏កើតក្នុងលំដាប់នៃទស្សនវិញ្ញាណធាតុ តអំពីនោះ ទើបកើតសោតវិញ្ញាណជាដើម ដូចគ្នានឹងមនោធាតុដែលកើតក្នុងលំដាប់នៃមនោវិញ្ញាណធាតុ តអំពីនោះ ទើបកើតចក្ខុវិញ្ញាណជាដើមឬ ? ឆ្លើយថា មិនមែនទេ ព្រោះមនោធាតុដែលប្រែថា ធាតុដឹង មិនទាក់ទងនឹងភាពជាទស្សនធាតុ គឺធាតុឃើញ ( នោះឡើយ ) ដូចជាមនោធាតុ ព្រោះគ្រាន់តែដឹង មានអាការមិនផ្សេងគ្នាអំពីចិត្តយ៉ាងណា ទស្សនធាតុ គឺធាតុឃើញ ក៏គប្បីមាន ព្រោះភាពជាទស្សនៈ ដែលមានអាការមិនផ្សេងគ្នារបស់ការឃើញ ដូច្នោះ ។ ហើយចក្ខុវិញ្ញាណនោះ ក៏មានរូបជាអារម្មណ៍ ព្រោះដូច្នោះ ចំណែកវិញ្ញាណជាដើមក៏កើតឡើងមិនបាន ព្រោះការមិនមានការទឹកដល់អារម្មណ៍ មានសំឡេងជាដើម ។ ព្រោះដូច្នោះ ទើបគប្បីមានបាន

អំពីវិញ្ញាណចំពោះដែលកើតអំពីរូបារម្មណ៍ប៉ុណ្ណោះ ព្រោះវិញ្ញាណទាំងឡាយ មានទស្សនវិញ្ញាណជាដើម មិនទាក់ទងនឹងវត្ថុដែលស្មើគ្នា ដូចជាមនោវិញ្ញាណនឹងមិនគប្បីមានវិញ្ញាណដែលអាស្រ័យវត្ថុដទៃ សេចក្តីនេះទើបមិនត្រឹមត្រូវ ។ ព្រោះដូច្នោះគប្បីឃើញ **មនោធាតុ** ជាគ្រឿងរាំងវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើម និងមនោវិញ្ញាណ ដូចជាឧបេក្ខាដែលជាសុខ និងទុក្ខ មិនគួរឃើញមនោធាតុនោះជាធម៌ដែលមិនឃើញជាដើម និងជាធម៌ ដែលមិននឹកគិត ដូចភាពដែលឧបេក្ខាជាអទុក្ខមសុខ ដែលប្រែថា សុខក៏មិនមែន ទុក្ខក៏មែន ដោយពិត គប្បីឃើញថាមនោធាតុនោះជាសភាគគ្នាជាមួយមនោវិញ្ញាណ ព្រោះមិនមានភាពផ្សេងគ្នានៃកិច្ច គឺការនឹកគិត ។ ពិតហើយ មនោដែលកើតនៅក្នុងហទយវត្ថុក៏បង្ហាញអារម្មណ៍របស់វិញ្ញាណ ដែលអាស្រ័យវត្ថុដទៃហើយ ទើបឈប់រមែងតាំងនៅក្នុងអាការត្រឹមតែនឹកគិត ហើយក៏ឈប់ ដូចភ្លើងតាំងនៅក្នុងអាការគ្រាន់តែជាភាពក្តៅ ដូច្នោះ និងកាលតាំងឡើងក្នុងការរលត់នៃវិញ្ញាណ ដែលអាស្រ័យវត្ថុដទៃហើយ ក៏រមែងឈប់ក្នុងអាការគ្រាន់តែនឹកគិត ហើយតាំងឡើង ដូចភ្លើងតាំងនៅក្នុងអាការគ្រាន់តែជាកម្តៅដូច្នេះ ។ ហេតុគ្រាន់តែការនឹកគិតដែលមានការប្រព្រឹត្តទៅសមគួរដល់បច្ច័យ រមែងជាទីបំផុតនៃមនោវិញ្ញាណធាតុ ។ ព្រោះវិញ្ញាណទាំង ៥ ដែលសហគតៈដោយបដិឃសញ្ញាជាធម្មជាតិកើតអំពីការប៉ះខ្ទប់នៃឥន្ទ្រិយជាមួយអារម្មណ៍ ទើបមានកិច្ចត្រឹមតែការយល់ព្រមចំពោះមុខ និងព្រោះមនោវិញ្ញាណដែលកើតអំពីឥន្ទ្រិយ មានការនឹកគិតជាលក្ខណៈ ជាធម្មជាតិកើតអំពីការគិតអារម្មណ៍ ទើបមានការគិតដែលសមគួរដល់មនោវិញ្ញាណនោះ ។ ព្រោះដូច្នោះ ចិត្តដែលមានកវគ្គជាលក្ខណៈដោយកម្លាំងនៃការប៉ះខ្ទប់ និងការថ្នាំងថ្នាក់ ដែលមានការយល់ព្រមចំពោះមុខជាបច្ច័យ ជាធម្មជាតិមានអាការញាប់ញ័រ កាលឈប់នៅ រមែងញុំាងកិច្ចត្រឹមតែការនឹកគិត ដែលមានការគិត

ជាទីបំផុត មានគុណដែលសមគួរដល់ការយល់ព្រមចំពោះមុខឲ្យកើតឡើង ព្រោះវៀរចាកការគិតពិសេស ។

កិច្ចត្រឹមតែការយល់ព្រមចំពោះមុខ សូម្បីមានការឃើញជាដើម រមែងមិនទាន់កន្លងខណៈទី ២ ក៏រមែងញុំាងកិច្ចត្រឹមតែការនឹកគិត ដែលមានការគិតជាដើម ដែលស្មើគ្នាជាមួយភាពជាចិត្តជាដើម ដែលវិចិត្រទៅដោយភាពផ្សេងគ្នារបស់ការធ្លាក់ចុះចំពោះមុខ មានការឃើញជាដើមឲ្យកើតឡើងក្នុងវត្ថុដទៃ ព្រោះវៀរចាក ឈ្មោះថាការនឹកគិត និងញាណដែលមានគុណសមគួរដល់ខ្លួន ព្រោះដូច្នោះ មនោធាតុសូម្បីសង្គ្រោះដោយពួកនៃមនោវិញ្ញាណ ដោយភាវៈដែលមានចំណែកស្មើគ្នាជាមួយវត្ថុ និងកិច្ចទាំងនោះ ដោយភាវៈដែលមានការតាំងឡើង ដែលមានការវៀរចាកវត្ថុ និងកិច្ចទាំងនោះ និងដោយភាវៈដែលមានវត្ថុ និងកិច្ចទាំងនោះ ជាទីបំផុតជាដើម ដោយវត្ថុ និងកិច្ចទាំងឡាយក៏ជាធម្មជាតិចេញ និងចូលក្នុងមនោទ្វារ ទើបលោកហៅថា **បុរេចរ** អ្នកនាំមុខ និង **អនុចរ** អ្នកតាមក្រោយតាមលំដាប់នៃវិញ្ញាណធាតុទាំង ៥ ដោយភាវៈដែលជាទ្វារដទៃ ជាមនសិការ ជាអារម្មណ៍របស់មនសិការនោះ និងជាសម្បដិច្ឆនៈក្នុងអារម្មណ៍ដទៃ ។ ក្នុងមនោធាតុនេះ សូម្បីកាលមានភាពជាវិញ្ញាណ ក៏គ្រាន់តែជាមនោធាតុដោយភាពស្មើគ្នា ភាពជាធាតុ ព្រោះមិនមានកិច្ច គឺការនឹកគិតពិសេសកើតឡើងតាមផ្លូវចិត្ត ទើបលោកហៅថា **មនោធាតុ** ។

ដោយហេតុតាមដែលពោលហើយនោះឯង វិញ្ញាណគ្រាន់តែជាមនោ ព្រោះការប្រកបដោយអត្ថថា ការដឹងច្បាស់ ដោយលុប **មត្ត**-ស័ព្ទចេញ ព្រោះដូច្នោះ ទើបការរួមធាតុនោះចូលជាមួយពពួកមនោវិញ្ញាណ រមែងសមគួរនោះឯង ។ ម្យ៉ាងទៀតលោកពោលថា **មនោធាតុ** ដើម្បីនឹងឲ្យផ្សេងទៅអំពីវិញ្ញាណដទៃ និងផ្សេងអំពីទ្វារ និងអារម្មណ៍ដូច្នេះ ។ ម្យ៉ាងទៀត ពាក្យថា **មនោវិញ្ញាណធាតុ** លោកកាន់យកថា

មនោដែលធ្វើឲ្យវិញ្ញាណធាតុផ្សេងចេញទៅ ។ សព្ទថា មនោវិញ្ញាណដែលមានអត្ថថា ធ្វើឲ្យធាតុផ្សេងចេញទៅ ធម៌ដែលធ្វើឲ្យវិញ្ញាណទៅជាផ្សេងៗ ជាពាក្យសម្តែងមនោដែលជាទ្វារប៉ុណ្ណោះ ព្រោះដូច្នោះ ទើបលោកមិនហៅថាមនោធាតុ ព្រោះសមគួរដល់ឈ្មោះថា ទ្វារ ។ ពិតហើយ ពាក្យដែលឲ្យវិញ្ញាណទៅជាផ្សេងៗ នោះជាពាក្យដែលចុះកាន់ក្នុងមនោទ្វារតែមិនបានជាពាក្យនាំមុខនិងតាមក្រោយ កិច្ចមានទស្សនកិច្ចជាដើម ព្រោះដូច្នោះ ពាក្យថា មនោវិញ្ញាណធាតុ និងពាក្យថា មនោវិញ្ញាណ ទើបគួរដល់ឈ្មោះថា មនោទ្វារ ជាពាក្យដែលមានសេចក្តីផ្សេងចេញទៅ ជាកិច្ច គឺការដឹងរបស់មនោទ្វារនោះ និងជាកិច្ចរបស់វិញ្ញាណផងដែរ ព្រោះដូច្នោះ ទើបលោកហៅថា **មនោវិញ្ញាណ** ដោយលុប **មត្ត-សព្ទ**ចេញក្នុងចន្លោះ និងហៅថា **មនោវិញ្ញាណធាតុ** ដើម្បីសម្តែងភាពជានិជ្ជីវធម៌ ដូច្នេះ ។

**គប្បីឃើញដូចលំពែង និងដូចព្រួញ** ព្រោះប្រកបដោយសេចក្តីទុក្ខ ៣ យ៉ាង ។ ពាក្យថា **ព្រោះត្រូវព្រួញ និងលំពែង គឺវេទនា** គឺព្រោះត្រូវព្រួញ និងលំពែង ពោលគឺវេទនា ។ ពាក្យថា **ដូចបុគ្គលដែលឈឺចាប់** គឺដូចបុគ្គលដែលមានការចុកចាប់ដោយការត្រូវព្រួញ និងលំពែង គឺវេទនានោះ ។ ទុក្ខ គឺការរំពឹងទុកនោះឯង ឈ្មោះថា **ទុក្ខព្រោះសង្ស័យ** ម្យ៉ាងទៀត បានដល់ ទុក្ខដែលទម្លាយ សេចក្តីសង្ស័យ ។ ពិតហើយ សញ្ញាកាលចាំវត្ថុដែលមិនស្អាតជាដើមថាជារបស់ស្អាតជាដើម រមែងញ៉ាំងភាពសង្ស័យឲ្យកើត និងរមែងញ៉ាំងការទម្លាយសេចក្តីសង្ស័យនោះឲ្យកើត ព្រោះភាពស្អាតដែលសង្ស័យទុកជាដើម មិនសម្រេចដូច្នេះ ។ ម្រឹគក្នុងព្រៃរមែងសម្គាល់គុម្ពស្មៅថា ជាមនុស្ស ទើបឈ្មោះថា **ប្រកាន់និមិត្តតាមសេចក្តីមិនពិត** សូម្បីសញ្ញាក៏ដូចគ្នា ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ដូចម្រឹគក្នុងព្រៃ** ។ សង្ខារមានកម្មជាប្រធាន ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ព្រោះបន្សាត់ទៅក្នុងបដិសន្ធិជាដើម** ។

ពាក្យថា **ត្រូវជាតិទុក្ខជាប់តាម** គឺព្រោះត្រូវជាតិទុក្ខដែលខ្វនឲ្យកើតឡើងជាប់តាម ។ ពិតហើយជាតិ ព្រោះមានភពជាបច្ច័យ ទើបឈ្មោះថា **ជាតិទុក្ខ** ដូច្នេះ ។ សូម្បីរូបដែលប្រាកដ ដោយភាពស្រីជាដើម ក៏រមែងញុំាងឧបទ្ទវច្រើនប្រភេទឲ្យកើត ដូចជាកងចក្រដ៏មុតដែលប្រាកដដូចផ្កាឈូក ។ អនត្ថៈទាំងពួង បានដល់ កិលេស មានរាគៈជាដើម និងបានដល់ធម៌ មានជាតិជាដើម ដែលជាអារម្មណ៍ជាសភាវៈដែលមិនចូលទៅស្ងប់ និងមានភ័យ ចំពោះមុខ ដូច្នេះ ។ អសង្ខតធាតុ បណ្ឌិតគប្បីឃើញ ដូច **អមតៈ** ជាដើម ព្រោះជាសត្រូវចំពោះអនត្ថៈនោះ ។

ការមិនឈប់នៅ បានដល់ ការមិនមានការកំណត់ថា **នេះឯងជាអារម្មណ៍របស់ធម៌នេះ** ដោយការមិនមានការឈប់នៅនោះ លោកអាចារ្យរមែងសម្តែងឧបមាដូចស្វាព្រៃ មិនមាននរណាហាមវា រមែងលែងមែកឈើមួយទៅចាប់មែកឈើមួយ សូម្បីមែកនោះលែងហើយ ក៏ចាប់មែកដទៃតទៅ ព្រោះដូច្នោះ ទើបវាមិនឈប់នៅត្រង់មែកណា រមែងត្រាច់ទៅ សេចក្តីនេះយ៉ាងណា មនោវិញ្ញាណ ក៏ដូច្នោះ លែងអារម្មណ៍មួយដែលចាប់ទុកហើយ ទៅចាប់អារម្មណ៍ដទៃ សូម្បីអារម្មណ៍នោះលែងហើយ ក៏ទៅចាប់អារម្មណ៍ដទៃ ព្រោះដូច្នេះ ទើបជាការមិនឈប់នៅ និងជាការមិនអាចដែលនឹងមិនចាប់អារម្មណ៍ប្រព្រឹត្តទៅ ទើបឈ្មោះថា ដូចជាស្វា និងសេះកាច សូម្បីត្រូវចាក់រហូតដល់ឆ្អឹង ក៏នៅតែទៅក្រៅផ្លូវ ឈ្មោះថា **សេះអាក្រក់** ។ ពាក្យថា **ព្រោះធ្លាក់ទៅតាមដែលវាប្រាថ្នា** សេចក្តីថា ភាវៈដែលធ្លាក់ទៅក្នុងអារម្មណ៍ដែលវាប្រាថ្នាឯណានីមួយៗ អ្នករបាំដែលតែងកាយច្រើន ឈ្មោះថា **អ្នកច្រៀងរាំក្នុងរោងច្រៀងរាំ** ។

ពណ៌នាអាយតនធាតុនិទ្ទេស ចប់

ពណ៌នាបរិច្ឆេទទី ១៥ ចប់ហើយ ដោយប្រការដូច្នេះ ។

# វិសុទ្ធិមគ្គ

## ឥន្ទ្រិយ សច្ចនិទ្ទេស

## ឥន្ទ្រិយនិទ្ទេស

ចំណែកថា ឥន្ទ្រិយ ២២ គឺចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ មនិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ អនញ្ញតញ្ញស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ អញ្ញាតាវិន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយ ដែលលើកឡើងសម្តែងទុកបន្ទាប់អំពីធាតុមក ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងឥន្ទ្រិយទាំងឡាយនោះដោយអត្ថ ដោយលក្ខណៈជាដើម និងដោយលំដាប់ ម្យ៉ាងទៀត ដោយញែកប្រភេទ និងមិនញែកប្រភេទ ដោយកិច្ច និងដោយភូមិ ។

### ដោយអត្ថ

ក្នុងឥន្ទ្រិយទាំងឡាយនោះ ជាបឋមអត្ថនៃឥន្ទ្រិយទាំងឡាយ មានចក្ខុជាដើម ចាត់ចែងតាមន័យ ( ដែលពោលមកហើយក្នុងអាយតននិទ្ទេស ) ថា ធម្មជាតិណា រមែងឃើញ ហេតុនេះ ធម្មជាតិនោះ ទើបឈ្មោះថា ចក្ខុ ដូច្នេះជាដើម ។

ចំណែកក្នុងឥន្ទ្រិយ ៣ ខាងចុង ពាក្យដំបូងត្រាស់ហៅថា អនញ្ញតញ្ញស្សាមី-តិន្ទ្រិយ ព្រោះកើតដល់បុគ្គលអ្នកបដិបត្តិដោយបំណងយ៉ាងនេះថា អញនឹងដឹងនូវអមតបទ ឬថា នូវសច្ចធម៌ ៤ ដែលនៅមិនទាន់ដឹងក្នុងបុព្វភាគ ( គឺមុនសោតាបត្តិមគ្គ ) និងព្រោះមានអត្ថ ( គឺសភាវៈ ) នៃភាពជាឥន្ទ្រ ( ធំក្រៃលែង ) នៅព្រមផងដែរ ពាក្យទី ២ ត្រាស់ហៅថា អញ្ញិន្ទ្រិយ ព្រោះដឹងច្បាស់ ( ដោយមគ្គ ) និងព្រោះមាន

អត្ថនៃភាពជាឥន្ទ្រ នៅព្រមផង ពាក្យទី ៣ ត្រាស់ហៅថា អញ្ញាតាវិន្ទ្រិយ ព្រោះកើតដល់ព្រះខីណាស្រពអ្នកដឹងទូទៅ គឺមានញាណកិច្ចក្នុងសច្ចៈ ៤ សម្រេចហើយ និងព្រោះមានអត្ថនៃភាពជាឥន្ទ្រនៅព្រមផង ។

សួរថា ហេតុអ្វី ឈ្មោះថា អត្ថនៃភាពជាឥន្ទ្រ នៃឥន្ទ្រិយទាំងនោះ ? ឆ្លើយថា អត្ថនៃការសម្គាល់វត្ថុដែលជាធំក្រៃលែង ( គឺកម្ម ) ឈ្មោះថា អត្ថនៃភាពជាឥន្ទ្រ អត្ថនៃវត្ថុដែលលោកអ្នកជាធំក្រៃលែង ( គឺព្រះពុទ្ធ ) សម្តែងទុកឈ្មោះថា អត្ថនៃភាពជាឥន្ទ្រ អត្ថនៃវត្ថុដែលលោកអ្នកជាធំក្រៃលែង (គឺព្រះពុទ្ធ ) បានឃើញ ( គឺដឹង ) ឈ្មោះថា អត្ថនៃភាពជាឥន្ទ្រ អត្ថនៃវត្ថុដែលវត្ថុជាធំក្រៃលែង គឺកម្មបានបង្កើតឡើង ឈ្មោះថា អត្ថនៃភាពជាឥន្ទ្រ អត្ថនៃវត្ថុដែលលោក អ្នកជាធំក្រៃលែង ( គឺព្រះពុទ្ធ ) ប្រើប្រាស់ ឈ្មោះថា អត្ថនៃវត្ថុជាឥន្ទ្រ អត្ថទាំងពួងនោះ ប្រើបានតាមដែលប្រើក្នុងឥន្ទ្រិយនិទ្ទេសនេះ ។

ពិតហើយ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា ឥន្ទ្រ ព្រោះទ្រង់មានភាពជាធំក្រៃលែង ។ ម្យ៉ាងទៀត កុសលាកុសលកម្មក៏ឈ្មោះថា ឥន្ទ្រ ព្រោះមិនមានបុគ្គលណាមួយជាធំក្នុងកម្មទាំងឡាយ ( តែកម្មជាធំក្រៃលែង ) ព្រោះហេតុនោះ ក្នុងឥន្ទ្រិយទាំងឡាយនោះ ( ពោលដល់ ) ឥន្ទ្រិយដែលកម្មឲ្យកើតមុន ( ឥន្ទ្រិយដែលកម្មឲ្យកើតនោះ ) រមែងបង្ហាញ ( ឲ្យដឹង ) កម្មដែលជាកុសល និងអកុសល វាក៏ជាវត្ថុដែលកម្មនោះ ចាត់ចែង ( ឲ្យកើត ) ឡើងផង ព្រោះហេតុនោះ ទើបឈ្មោះឥន្ទ្រិយ ព្រោះអត្ថថា បង្ហាញ ( ឲ្យដឹងដល់ ) វត្ថុជាធំក្រៃលែង ( គឺកម្ម ) ផង ព្រោះអត្ថថា ជាវត្ថុដែលវត្ថុជាធំក្រៃលែង ( គឺកម្ម ) ចាត់ចែង ( ឲ្យកើត ) ឡើងផង ដែលឥន្ទ្រិយទាំងអស់នោះឯង ជាវត្ថុដែលព្រះមានព្រះភាគទ្រង់ប្រកាសឡើង និងជាវត្ថុ ដែលព្រះអង្គបានត្រាស់ដឹង ដោយព្រះអង្គឯងទៅតាមសេចក្តីពិត ព្រោះ

ហេតុនោះ ទើបឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថា ជាវត្ថុដែលលោកអ្នកជាធំក្រៃលែង (គឺព្រះពុទ្ធ) សម្តែងឡើងទុកផង ព្រោះអត្ថថា ជាវត្ថុដែលលោកអ្នកជាធំក្រៃលែង (គឺព្រះពុទ្ធ) បានឃើញ (គឺត្រាស់ដឹង) ផង ។ មយ៉ាងទៀត ឥន្ទ្រិយទាំងឡាយប្រភេទខ្លះ ព្រះមានព្រះភាគ ព្រះអង្គជាមុនីធំក្រៃលែងអង្គនោះ ទ្រង់ប្រើដោយភាពជាគោចរ (គឺជាអារម្មណ៍) ជួនកាល ទ្រង់ប្រើប្រាស់ដោយប្រើផ្លូវភាវនា (គឺទ្រង់ធ្វើឲ្យមានឡើង ដូចសទ្ធិន្ទ្រិយជាដើម) ព្រោះហេតុនោះ ទើបឈ្មោះឥន្ទ្រិយ ព្រោះអត្ថថា ជាវត្ថុ ដែលលោកអ្នកជាធំក្រៃលែង ប្រើដោយប្រការ ១ ។

ន័យម្យ៉ាងទៀត ចក្ខុជាដើមនោះឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថនៃភាពជាធំ ដែលបានដល់ភាពជាអធិបតី (គឺជាឥន្ទ្រិយប្បច្ច័យ-ឧបការៈដោយភាពជាធំ) ពិតហើយ ភាពជាអធិបតីនៃចក្ខុវិញ្ញាណជាដើម ឈ្មោះថា សម្រេចផលក្នុងការប្រព្រឹត្តទៅនៃចក្ខុវិញ្ញាណជាដើម ព្រោះកាលឥន្ទ្រិយខ្លាំងក្លា វិញ្ញាណក៏ខ្លាំងក្លា កាលឥន្ទ្រិយទន់ខ្សោយ វិញ្ញាណក៏ទន់ខ្សោយ ដូច្នេះ ។

នេះជាការវិនិច្ឆ័យដោយអត្ថក្នុងឥន្ទ្រិយទាំងឡាយនោះ ដែលជាលំដាប់ដំបូង។

## ដោយលក្ខណៈជាដើម

ពាក្យថា ដោយលក្ខណៈជាដើម សេចក្តីថា គប្បីជ្រាបវិនិច្ឆ័យនៃចក្ខុជាដើម ដោយលក្ខណៈ រស បច្ចុប្បដ្ឋាន និងបទដ្ឋានផង ឯលក្ខណៈជាដើមរបស់ចក្ខុជាអាទិនោះបានពោលទុកហើយក្នុងខន្ធនិទ្ទេស ចំណែកឥន្ទ្រិយ ៤ (ខាងចុង) មានបញ្ញិន្ទ្រិយជាដើម ដោយអត្ថ គឺអមោហៈនោះឯង ឥន្ទ្រិយដ៏សេសមកហើយ ដោយសរុបក្នុងខន្ធនិទ្ទេសនោះដូចគ្នា ។

## ដោយលំដាប់

លំដាប់ក្នុងសេចក្តីថា ដោយលំដាប់នេះ ក៏ជាលំដាប់នៃការសម្តែងដូចគ្នា ។

ក្នុងឥន្ទ្រិយទាំងឡាយនោះ ឥន្ទ្រិយ ៦ មានចក្ខុន្ទ្រិយជាដើម ដែលរាប់ចូលក្នុងអត្តភាព ព្រះមានព្រះភាគទ្រង់សម្តែងមុន ព្រោះថា ការបានអរិយភូមិរមែងមានព្រោះកំណត់ដឹងធម៌ខាងក្នុង ( ខ្លួនរបស់ខ្លួន ) អត្តភាពនោះដល់នូវការរាប់ថា ស្រីក្តីប្រុសក្តី ព្រោះអាស្រ័យធម៌ឯណាដើម្បីទ្រង់ប្រកាសថា នេះជាធម៌នោះ ទើបទ្រង់សម្តែងឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយជាលំដាប់តទៅ បន្ទាប់អំពីនោះ ទ្រង់សម្តែងជីវិតិន្ទ្រិយដើម្បីឲ្យជ្រាបថា សូម្បីធម៌ទាំងពីរយ៉ាងនោះក៏មានការប្រព្រឹត្តទៅ ដោយទាក់ទងដោយជីវិតិន្ទ្រិយ បន្ទាប់ទៅទ្រង់សម្តែងឥន្ទ្រិយ ៥ មានសុខិន្ទ្រិយជាដើម ដើម្បីឲ្យជ្រាបថា ការប្រព្រឹត្តទៅនៃឥន្ទ្រិយនោះមាននៅដរាបណា ការមិនត្រឡប់ (គឺមិនរលត់) នៃការសោយអារម្មណ៍ទាំងនោះក៏នៅមានដរាបនោះ និងការសោយអារម្មណ៍គ្រប់យ៉ាងនោះក៏សុទ្ធជាទុក្ខ តពីនោះទ្រង់សម្តែងឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាអាទិ ដើម្បីចង្អុលបង្ហាញគោលបដិបត្តិថា ដែលធម៌ ( មានសទ្ធាជាដើម) នោះ គប្បីបំពេញឡើងដើម្បីការរលត់នៃការសោយអារម្មណ៍នោះ លំដាប់នោះ ទ្រង់សម្តែងអនញ្ញតញ្ញស្សាមីតិន្ទ្រិយ ដើម្បីសម្តែងភាពមិនសូន្យចាកប្រយោជន៍នៃការបដិបត្តិថា ដោយការបដិបត្តិនេះ ទើបធម៌នោះកើតប្រាកដឡើងក្នុងខ្លួនជាបឋម បន្ទាប់អំពីនោះ ទ្រង់សម្តែងអញ្ញិន្ទ្រិយ ព្រោះជាផលរបស់អនញ្ញតញ្ញស្សាមីតិន្ទ្រិយនោះឯង និងព្រោះជាធម៌គប្បីបំពេញតជាប់គ្នាទៅផង ក្នុងទីបំផុត ទ្រង់សម្តែងអញ្ញាតាវិន្ទ្រិយ ដែលជាបរមអស្សាសៈ

( ដែលស្រឡះចិត្តយ៉ាងក្រៃលែង ) ដើម្បីឲ្យជ្រាបថា ការសម្រេចធម៌នេះរមែងមានបានដោយការនាបន្ទាប់អំពីនេះទៅ ឯធម៌ទាំងនេះ ព្រះយោគីបានសម្រេចហើយ ក៏មានកិច្ចដែលនឹងធ្វើក្រៃលែងឡើងទៅអ្វីទៀត ។

នេះជាលំដាប់ក្នុងឥន្ទ្រិយទាំងនេះ ។

## ដោយចែកប្រភេទ និង មិនចែកប្រភេទ

ក្នុងសេចក្តីថា ដោយការចែកប្រភេទ និងមិនចែកប្រភេទនេះ ជីវិតិន្ទ្រិយ តែម្យ៉ាងមានការចែកប្រភេទ ព្រោះជីវិតិន្ទ្រិយនោះមាន ២ គឺរូបជីវិតិន្ទ្រិយ អរូបជីវិតិន្ទ្រិយ ឥន្ទ្រិយដ៏សេសមិនមានការចែកប្រភេទឡើយ ។

គប្បីជ្រាបវិនិច្ឆ័យដោយការចែកប្រភេទ និងមិនចែកប្រភេទក្នុងឥន្ទ្រិយទាំងឡាយនេះ ដូចពោលមកនេះឯង ។

## ដោយកិច្ច

ពាក្យថា ដោយកិច្ច សេចក្តីថា មានពាក្យសួរថា អ្វីជាកិច្ចនៃឥន្ទ្រិយទាំងឡាយដូច្នេះសោត ? ពាក្យឆ្លើយគប្បីមានថា ដោយព្រះបាលីថា ចក្ខាយតនៈជាបច្ច័យ ( គឺជាឧបការធម៌ ) ដោយភាពជាឥន្ទ្រិយប្បច្ច័យនៃចក្ខុវិញ្ញាណធាតុ និងនៃធម៌ទាំងឡាយដែលសម្បយុត្តជាមួយចក្ខុវិញ្ញាណធាតុនោះ ដូច្នេះ ការដែលញុំាងធម៌ទាំងឡាយ មានចក្ខុវិញ្ញាណជាអាទិឲ្យប្រព្រឹត្តទៅតាមអាការរបស់ខ្លួនដែលបានដល់អាការក្លា និងទន់ខ្សោយជាដើម ដែលនឹងគប្បីឲ្យសម្រេចដោយភាព ជាឥន្ទ្រិយប្បច្ច័យ និងដោយភាពដែលខ្លួនមានអាការក្លា និងទន់ខ្សោយជាដើមផង យ៉ាងណា នេះជាកិច្ចនៃចក្ខុន្ទ្រិយដែលជាការរលត់ដំបូង កិច្ចនៃសោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ និងកាយិន្ទ្រិយ

ក៏មានន័យយ៉ាងនោះ តែការញុំាងសហជាតធម៌ទាំងឡាយឲ្យប្រព្រឹត្តទៅ ក្នុងអំណាចរបស់ខ្លួន ជាកិច្ចនៃមនិន្ទ្រិយ ការដែលឃ្លាំរក្សាសហជាតធម៌ទុកជាកិច្ច នៃជីវិតិន្ទ្រិយ ការដែលចាំ និងចាត់ចែងគ្រឿងសម្គាល់ភេទ និងអាការនៃចរិត និងការតាក់តែងកាយនៃស្ត្រី និងបុរស ជាកិច្ចនៃឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ការដែលឃ្លាំគ្រប់គ្រងសហជាតធម៌ទាំងឡាយទុក ( មិនឲ្យប្រាកដ ) ហើយញុំាងសហជាតធម៌នោះ ឲ្យដល់នូវអាការគ្រោតគ្រាត ( គឺប្រាកដច្បាស់ចេញមក ) តាមកិច្ចខ្លួនរៀងៗ ខ្លួន ជាកិច្ចនៃសុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ និងទោមនស្សិន្ទ្រិយ ការដែលធ្លាប់ញុំាងសហជាតធម៌ទាំងឡាយ ឲ្យដល់នូវអាការជាកណ្ដាលៗ ដែលជាអាការដែលល្អិត និងប្រណីត ជាកិច្ចនៃឧបេក្ខិន្ទ្រិយ ការដែលគ្រប់គ្រងនូវបដិបក្ខធម៌ ( ធម៌ផ្ទែកផ្ទុយ មានអសទ្ធិយជាដើម ) និងញុំាងសម្បយុត្តធម៌ទាំងឡាយឲ្យដល់នូវភាពមានអាការជ្រះថ្លាជាដើម ជាកិច្ចនៃឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើម កាលលះសំយោជនៈ ៣ ( ខាងដើម ) និងការធ្វើសម្បយុត្តធម៌ទាំងឡាយឲ្យមានការបែរមុខដល់ការលះសំយោជនៈ ៣ នោះផង ជាកិច្ចនៃអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ការលះដែលធ្វើសំយោជនៈដ៏សេស មានកាមរាគៈព្យាបាទជាដើម ឲ្យស្រាលស្តើងទៅ និងការញុំាងសហជាតធម៌ទាំងឡាយ ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនផង ជាកិច្ចនៃអញ្ញិន្ទ្រិយ ការលះបង់ភាពខ្វល់ខ្វាយក្នុងកិច្ច ( លះសំយោជនៈ ) ទាំងពួង និងភាពជាបច្ច័យឲ្យសម្បយុត្តធម៌ទាំងឡាយ មានការបែរមុខឆ្ពោះអមតធម៌ផង ជាកិច្ចនៃអញ្ញាតាវិន្ទ្រិយ ។

គប្បីជ្រាបវិនិច្ឆ័យដោយកិច្ចក្នុងឥន្ទ្រិយទាំងឡាយនេះ ដូចពោលមកនេះ ។

## ដោយភូមិ

ពាក្យថា ដោយភូមិ សេចក្តីថា ក្នុងឥន្ទ្រិយទាំងឡាយនេះ ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ

និងទោមនស្សិន្ទ្រិយ ( ១០ ) ជាកាមាវចរៈសុទ្ធ មនិន្ទ្រិយ ជីវិតិន្ទ្រិយ ឧបេក្ខិន្ទ្រិយ និងសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ( ៨ ) ទាក់ទងទៅក្នុងភូមិទាំង ៤ សោមនស្សិន្ទ្រិយទាក់ទងទៅក្នុងភូមិ ៣ ដោយភាពជាកាមាវចរៈក៏មាន រូបាវចរៈក៏មាន លោកុត្តរក៏មាន ឥន្ទ្រិយ ៣ ខាងចុង ជាលោកុត្តរសុទ្ធ ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយភូមិ ក្នុងឥន្ទ្រិយទាំងឡាយនេះ ដូចពោលមកនេះ ព្រោះថា

ភិក្ខុអ្នកជ្រាបយ៉ាងនេះ ឈ្មោះថា ជាអ្នកច្រើនទៅដោយភាពសង្វេគ តាំងនៅក្នុងឥន្ទ្រិយសំវរៈ កំណត់ដឹងឥន្ទ្រិយទាំងឡាយ ហើយធ្វើទីបំផុតទុក្ខបាន ។

នេះជាកថាមុខយ៉ាងពិស្តារនៃឥន្ទ្រិយទាំងឡាយ ។

# មហាដីកា

## ពណ៌នាឥន្ទ្រិយសច្ចនិទ្ទេស

## កថាពណ៌នាដោយពិស្តារនៃឥន្ទ្រិយ

*ពាក្យថា **២២** ជាពាក្យកំណត់ចំនួន ។ ពាក្យថា **ឥន្ទ្រិយ** ជាពាក្យសម្តែងលម្អិតពាក្យដែលបានកំណត់ទុក ។ ពាក្យថា **ចក្ខុន្ទ្រិយ** ជាដើម ជាធម៌សម្តែងសរុបនៃឥន្ទ្រិយទាំងនោះ ។ ក្នុងបណ្តាឥន្ទ្រិយទាំងនោះ ធម្មជាតិឈ្មោះថា **ចក្ខុន្ទ្រិយ** ព្រោះអត្ថថា ទ្រទ្រង់ភាពជាធំក្នុងចក្ខុទ្វារ គឺគ្រប់គ្រងភាវៈដែលជាធំ បានដល់ ឥស្សរភាពយ៉ាងក្រៃលែងរបស់ខ្លួនជាងធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងទ្វារនោះ ក្នុងភាពជាចក្ខុទ្វារ ។ ពិតហើយ ចក្ខុន្ទ្រិយនោះ រមែងញ៉ាំងធម៌ទាំងនោះដែលប្រព្រឹត្តទៅតាមទ្វារនោះ ឲ្យប្រព្រឹត្តទៅតាមខ្លួន ក្នុងកាលដែលកាន់យកនូវរូបធម៌ ដែលប្រព្រឹត្តទៅក្នុងទ្វារទាំងនោះ  ក៏រមែងទៅតាមចក្ខុន្ទ្រិយនោះ ។ សូម្បីក្នុងឥន្ទ្រិយដ៏សេសក៏មានន័យនេះឯង ។ ព្រោះដូច្នោះ ទើបឈ្មោះថា **សោតិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងសោតទ្វារ ឈ្មោះថា **ឃានិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងឃានទ្វារ ឈ្មោះថា **ជិវ្ហិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងជិវ្ហាទ្វារ ឈ្មោះថា **កាយិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងកាយទ្វារ ។ ឈ្មោះថា **មនិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈការដឹងច្បាស់ ។ ឈ្មោះថា **ឥត្ថិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈជាស្រី ឈ្មោះថា **បុរិសិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈជាបុរស ឈ្មោះថា **ជីវិតិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈការតាមរក្សា ឈ្មោះថា **សុខិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈសុខ ឈ្មោះថា **ទុក្ខិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈទុក្ខ ឈ្មោះថា*

**សោមនស្សិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈសោមនស្ស ឈ្មោះថា **ទោមនស្សិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈទោមនស្ស ឈ្មោះថា **ឧបេក្ខិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈឧបេក្ខា ឈ្មោះថា **សទ្ធិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈការបង្អោនចិត្តជឿ ឈ្មោះថា **វីរិយិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈផ្គង ឈ្មោះថា **សតិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈការប្រាកដ ឈ្មោះថា **សមាធិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈមិនរាយមាយ ឈ្មោះថា **បញ្ញិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈនៃការចាក់ធ្លុះ ឈ្មោះថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈនៃការដែលប្រព្រឹត្តទៅហើយថា យើងនឹងដឹងវត្ថុដែលមិនទាន់ដឹង ឈ្មោះថា **អញ្ញិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងការដឹងទូទៅទៀតនូវធម៌ដែលបានដឹងហើយនោះឯង ឈ្មោះថា **អញ្ញាតាវិន្ទ្រិយ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងភាពជាអ្នកដឹងទូទៅ ។

បទថា **វិជានិយា** សេចក្ដីប៉ុនគ្នានឹង **វិជានេយ្យ** ប្រែថា គប្បីជ្រាប ច-ស័ព្ទក្នុងពាក្យថា **ភូមិតោ ច** មានអត្ថរួមយកសេចក្ដីដែលមិនបានពោលទុកដោយ ច-ស័ព្ទនោះ លោកអាចារ្យរមែងរួបរួមយកភាពដែលមានប៉ុណ្ណោះទុកផង ចំណែកការមានប៉ុណ្ណោះខ្ញុំនឹងពណ៌នាខាងមុខ ព្រោះភាពដែលឥន្ទ្រិយមិនទាន់ដល់លំដាប់ គួរនឹងពិចារណាក៏មាន ទើបលោកមិនបានកាន់យកការៈដែលគួរឃើញទុកក្នុងទីនេះ ។

បទថា **បុព្វភាគេ** ប្រែថា ក្នុងចំណែកខាងដើមអំពីអរិយមគ្គ ។ បទថា **អនញ្ញាតំ** សេចក្ដីថា ដែលនៅមិនទាន់ដឹងដល់ គឺនៅមិនទាន់បានសម្រេច ។ ការស្លាប់ គឺការបែកធ្លាយមិនមានដល់ធម្មជាតិនេះ ព្រោះជារបស់ទៀង ហេតុនោះ ធម៌នេះឈ្មោះថា **អមត** ម្យ៉ាងទៀត ឈ្មោះថា **អមត** ព្រោះអត្ថថា កាលបានសម្រេចដល់ធម្មជាតិនេះ

ហើយ មិនស្លាប់ និងឈ្មោះថា ជាបទ ព្រោះភាពជាធម្មជាតិដែលបុគ្គលគួរដល់ ព្រោះដូច្នោះ ទើបឈ្មោះថា **អមតបទ** បានដល់ ព្រះនិព្វាន ។ ដោយពាក្យថា **ព្រោះកើតឡើងដល់បុគ្គលដែលបដិបត្តិយ៉ាងនេះ** នេះលោកអាចារ្យរមែងសម្តែងថា ឥន្ទ្រិយនេះលោកហៅយ៉ាងនេះ ព្រោះជាចំណែកខាងដើម ។ បទថា **អជាននតោ** សេចក្តីថា ព្រោះដឹងមិនហួសព្រំដែន ដែលសោតាបត្តិមគ្គឃើញហើយនោះឯង ។ ពាក្យថា **ព្រោះការកើតឡើងដល់ព្រះវីណាស្រេព** លោកពោលទុក ព្រោះជាអ្នកដឹងទូទៅ ដែលជាហេតុឲ្យបុគ្គលមានការដល់ព្រមដោយឥន្ទ្រិយនោះ ឬធម៌ដែលប្រកបដោយឥន្ទ្រិយនោះ នេះជាធម៌ដែលដឹងទូទៅ ជាសភាវៈដែលដល់នូវការកើតឡើង ដល់ព្រះវីណាស្រេពដែលមានញាណជាកិច្ចសម្រេចហើយ ។

ធម្មជាតិណា រមែងឲ្យទៅ គឺរមែងឲ្យដល់ បានដល់ ឲ្យដឹង ហេតុនោះធម្មជាតិនេះ ឈ្មោះថា **លិង្គំ** ប្រែថា ឲ្យទៅ ( បានដល់ ទិសដៅ ) ។ មយ៉ាងទៀត សភាវៈដែលបុគ្គលរមែងឲ្យទៅ ដោយធម្មជាតិនេះ ហេតុនោះ ធម្មជាតិនេះ ឈ្មោះថា **លិង្គំ** ប្រែថា គ្រឿងឲ្យទៅ ( គ្រឿងចំណាំ ) ។ សួរថា ឲ្យទៅកាន់អ្វី ឬអ្វីដែលត្រូវឲ្យទៅ ? ឆ្លើយថា ឲ្យទៅកាន់ **ឥន្ទ** ភាពជាធំ ឬ **ឥន្ទ** ដែលជាធំ ត្រូវឲ្យទៅ ។ គ្រឿងចំណាំរបស់បុគ្គលជាធំ ឈ្មោះថា **ឥន្ទលិង្គំ** អត្ថនៃគ្រឿងចំណាំរបស់បុគ្គលជាធំ គឺសភាវៈរបស់បុគ្គលជាធំនោះ ឈ្មោះថា **ឥន្ទលិង្គដ្ឋោ** មយ៉ាងទៀត គ្រឿងចំណាំនៃភាពជាធំនោះឯង ជាអត្ថនៃស័ព្ទថា **ឥន្ទ្រិយ** ព្រោះដូច្នោះ ទើបឈ្មោះថា **ឥន្ទលិង្គដ្ឋោ** ប្រែថា អត្ថនៃគ្រឿងចំណាំនៃភាពជាធំ ។ ដែលកម្មចាត់ចែងហើយ គឺធ្វើឲ្យកើតឡើងហើយ ព្រោះដូច្នោះ ឈ្មោះថា **សិដ្ឋំ** ដែលកម្មជាធំចាត់ចែងហើយ ឈ្មោះថា **ឥន្ទសិដ្ឋំ** ។ ដែលព្រះសម្ពុទ្ធដ៏ជាធំ **ទ្រង់ប្រើប្រាស់ហើយ គឺទ្រង់សេពហើយ** ។ គ្រឿងចំណាំនៃវត្ថុដែលជាធំ ពោល គឺកម្ម និងដែលកម្មនោះចាត់ចែងហើយ

ព្រោះដូច្នោះ បណ្ឌិតគប្បីប្រកបឥន្ទ្រិយដែលកើតអំពីកម្ម មិនគប្បីប្រកបឥន្ទ្រិយដទៃ តែអត្ថទាំង ២ នោះ គប្បីប្រកបក្នុងកម្មតែម្យ៉ាងប៉ុណ្ណោះ ចំណែកអត្ថក្រៅអំពីនេះ គប្បីប្រកបក្នុងព្រះមានព្រះភាគតែម្យ៉ាង ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **តាមគួរដល់ការប្រកប** ។ បទថា **តេន** សេចក្តីថា ព្រោះហេតុដែលព្រះមានព្រះភាគ និងកម្មជាធំ ។ បទថា **ឯត្ថ** ប៉ុន្មា **ឯតេសុ យោគ ឥន្ទ្រិយេសុ** ។ **ឧល្លិង្គេន្តិ** ប្រែថា ស.ឲ្យដឹង គឺឲ្យដឹង បានដល់ រមែងប្រកាស ព្រោះធ្វើឲ្យឈោងចុះនូវការដល់ព្រមនៃហេតុ និងវិបត្តិនៃហេតុ ដោយការដល់ព្រមនៃផល និងវិបត្តិនៃផល សូម្បីការធ្វើឲ្យជាអារម្មណ៍ លោកក៏ពោលថា ជា **អាសេវនា** ដែលប្រែថា ការប្រើប្រាស់ ដូចមានអាទិ៍ថា **សោ តំ និមិត្តំ អាសេវតិ** ប្រែថា ភិក្ខុនោះ រមែងសេពនិមិត្តនោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **គ្រាខ្លះទ្រង់ប្រើប្រាស់ដោយប្រើជាអារម្មណ៍** ។ ក្នុងសេចក្តីនោះ កាលឥន្ទ្រិយទាំងអស់គួរធ្វើឲ្យជាអារម្មណ៍ ពាក្យថា **គ្រាខ្លះ** ក៏ព្រោះឥន្ទ្រិយ ដែលមិនគួរនឹងប្រើជាវិបស្សនា មិនគួរប្រើដោយការដាក់ចិត្តទុកក្នុងចំណែកច្រើន ។ ព្រោះក្នុងឥន្ទ្រិយទាំងនោះ នឹងមានក៏គ្រាន់តែជាការពិចារណាប៉ុណ្ណោះ ។ ភាវនា លោកពោលថា **ជាអាសេវនា** ការប្រើប្រាស់ ដូចជាក្នុងពាក្យមានអាទិ៍ថា **តស្ស តំ មគ្គំ អាសេវតោ** កាលភិក្ខុនោះចម្រើនមគ្គនោះ ដូច្នោះ ទើបលោកអាចារ្យពោលថា **កាលខ្លះទ្រង់ប្រើប្រាស់ដោយប្រើក្នុងភាវនា** ដូច្នេះ សំដៅយកឥន្ទ្រិយ មានសទ្ធាជាដើមដែលគប្បីភាវនា ។

**ភាពជាអធិបតី** បានដល់ ភាពជាឥន្ទ្រិយប្បច្ច័យ សូម្បីកាលមិនមានឥន្ទ្រិយប្បច្ច័យ ភាពដែលឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ជាធម្មជាតិត្រូវគ្រឿងចំណាំជាដើម ដែលមិនបានប្រព្រឹត្តទៅដោយអាការដទៃក្នុងសន្តានដែលប្រកបដោយឥន្ទ្រិយទាំង ២ នោះ ដែលប្រព្រឹត្តទៅដោយបច្ច័យរបស់ខ្លួន រៀងៗ ខ្លួន គប្បីបណ្តោយតាមក៏ជា

ភាពជាធំ ៗនិងក្នុងអត្ថនេះ ឈ្មោះថា **ឥន្ទ្រិយទាំងឡាយ** ដោយអត្ថថា ជាធំដោយគ្រប់គ្រងភាពជាធំនោះឯង ។ ដែលគប្បីប្រកបធម៌ទាំងឡាយ មានជីវិតជាដើមឲ្យធំក្នុងការបណ្ដោយតាមឥន្ទ្រិយនោះៗ បានតាមគួរ តាមន័យដែលបានសម្ដែងទុកហើយក្នុងធម៌ទាំងឡាយ មានចក្ខុជាដើម ។

អធិប្បាយថា **អមោហៈនោះឯង** មិនមែនជាធម៌ ៤ យ៉ាងមួយផ្នែក ព្រោះដូច្នោះ បកិណ្ណកៈ មានលក្ខណៈជាដើម ដែលបានធ្វើឲ្យជាក់ច្បាស់ទុកហើយ ក្នុងកថាពោលដោយសង្ខារក្ខន្ធនៃអមោហៈនោះ ទើបគប្បីជ្រាបដល់ធម៌ទាំង ៤ យ៉ាងនោះ ។ ឥន្ទ្រិយដ៏សេស **មកហើយដោយសរុបនោះឯង** ដោយលក្ខណៈជាដើមក្នុងខន្ធនិទ្ទេស ។

ការបានអរិយភូមិរបស់សត្វទាំងឡាយ ជាប្រយោជន៍ទូទៅ និងជាប្រធាននៃទេសនារបស់ព្រះមានព្រះភាគ ព្រោះហេតុនោះ ទើបអាចារ្យពោលថា **ដោយការកំណត់ដឹងធម៌ខាងក្នុង** ដូច្នេះជាដើម ។ សូម្បីកាលឥន្ទ្រិយដទៃជាធម្មជាតិទាក់ទងដោយអត្តភាពកំពុងមាន ព្រោះហេតុដែលឥន្ទ្រិយទាំងឡាយ មានចក្ខុជាដើមជាមូលនៃការបញ្ញត្តថា អត្តភាព ទើបជាធម៌ដែលរាប់ថា ជាអត្តភាព ជាពិសេស ដូច្នោះ ទើបអាចារ្យពោលថា **ឥន្ទ្រិយ ៦ មានចក្ខុជាដើម ទាក់ក្នុងអត្តភាព** ។ **ក្នុងអដ្ឋកថាព្រះអភិធម្ម** លោកពោលលំដាប់ការសម្ដែងជីវិតិន្ទ្រិយទុកបន្ទាប់អំពីឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ព្រោះហេតុនោះ ទើបក្នុងទីនេះ លោកអាចារ្យពោលថា **តអំពីនោះទើបសម្ដែងជីវិតិន្ទ្រិយ** ។ ពាក្យនោះ រមែងសមជាមួយទេសនាក្នុងឥន្ទ្រិយយមកៈ ។ ចំណែកក្នុង **ឥន្ទ្រិយវិភង្គ** ត្រាស់ដល់ជីវិតិន្ទ្រិយទុកបន្ទាប់អំពីមនិន្ទ្រិយ ជីវិតិន្ទ្រិយនោះ គប្បីជ្រាបថា ត្រាស់ទុកក្នុងចំណោមកណ្ដាលនៃឥន្ទ្រិយទាំង ២ នោះ ដើម្បីសម្ដែងការៈដែលតាមរក្សាឥន្ទ្រិយ ដែលជាខាងក្នុង និងខាងក្រៅ ទាំងខាងដើម ខាងចុង ។ ដើម្បីនឹងឲ្យជ្រាបថា **ការសោយអារម្មណ៍ទាំងឡាយឯណានីមួយនោះ សុទ្ធ**

តែជាទុក្ខ គឺជីវិតិន្ទ្រិយដែលឃ្លាំតាមរក្សាអត្តភាព ២ យ៉ាង នៅប្រព្រឹត្តទៅជរាបណា ការសោយអារម្មណ៍ទាំងនេះ ជាតួទុក្ខ ក៏នៅមិនទាន់រលត់ដរាបនោះ ដោយហេតុនោះ ទើបគប្បីជ្រាបថា ឥន្ទ្រិយទាំង ៥ មានចក្ខុជាដើម ជាធម្មជាតិ ដែលគប្បីកំណត់ដឹង ព្រោះជាធម្មជាតិជាប់តាមទៅដោយទុក្ខ ។ ពាក្យថា **ដើម្បីសម្តែងដល់ការបដិបត្តិ** គឺដើម្បីសម្តែងដល់ការបដិបត្តិដែលជាបុព្វភាគ ។ បទថា **តស្សេវ យោគ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយស្ស** នោះឯង ។ ពាក្យថា **ព្រោះជាធម៌គួរចម្រើនជាប់បន្តគ្នាទៅ** លោកពោលសំដៅយកអញ្ញិន្ទ្រិយដែលប្រកបជាមួយមគ្គ គឺភាវនា ។ ព្រោះភាវនានៅបន្ទាប់អំពីទស្សនៈទៅ ដូច្នេះ ។

ក្នុងពាក្យថា **ញែកប្រភេទ** នេះ លោកមានបំណងយកការញែកប្រភេទដោយសភាវៈ មិនមែនដោយភូមិ និងបុគ្គលជាដើម ព្រោះហេតុនោះ ទើបអាចារ្យពោលថា **ឥន្ទ្រិយដ៏សេសមិនមានការញែកប្រភេទឡើយ** ។មានសំណួរជ្រៀតចូលមកថា លក្ខណៈគឺការតាមរក្សាជាសភាវៈរបស់ជីវិតិន្ទ្រិយមិនមែនឬ ដោយហេតុនោះ ទើបមិនមានការញែកប្រភេទជីវិតិន្ទ្រិយទាំង ២ យ៉ាងនោះ ? ឆ្លើយថា សេចក្តីនេះពិត តែលោកកាន់យកការញែកប្រភេទនូវសភាវៈដែលជារូប និងអរូបរបស់ជីវិតិន្ទ្រិយនោះធ្វើទុក ឥន្ទ្រិយដ៏សេស មិនមានការញែកប្រភេទអ្វីដូច្នោះឡើយ ព្រោះដូច្នោះ ទើបឥន្ទ្រិយទាំងនោះ មិនមានការញែកប្រភេទ ព្រោះដូច្នោះ ទើបលោកពោលភាពមិនមានការញែកប្រភេទទុក ។ មានពាក្យសួរថា ក្នុងសេចក្តីនេះ វេទនា និងបញ្ញា លោកពោលញែកគ្នាទុកមិនមែនឬ ? ឆ្លើយថា មិនមែនទេ ព្រោះលោកមានបំណងយកការញែកប្រភេទ និងមិនញែកប្រភេទក្នុងឥន្ទ្រិយ ២២ តាមដែលទ្រង់សម្តែងទុក ។

សូម្បីកាលឥន្ទ្រិយទាំង ៥ មានចក្ខុន្ទ្រិយជាដើមជាបច្ច័យ មានបុរេជាតប្បច្ច័យជាដើមមានកិច្ចដែលគប្បីឲ្យសម្រេច ដោយភាពជាឥន្ទ្រិយប្បច្ច័យតែម្យ៉ាង ហៅថា

ឈ្មោះថា **ជាកិច្ច** ព្រោះភាវៈនៃឥន្ទ្រិយប្បច្ច័យនោះ ជាកិច្ចដែលមិនទូទៅដល់បច្ច័យដទៃ និងព្រោះទ្រង់ធ្វើឲ្យក្រៃលែងហើយក្នុងឥន្ទ្រិយកថា ។ អាការមានទទន់ រឹងជាដើមរបស់ខ្លួន ឈ្មោះថា **អាការរបស់ខ្លួន** ការញ៉ាំងធម៌ មានចក្ខុវិញ្ញាណ ជាដើមឲ្យប្រព្រឹត្តទៅតាមអាការរបស់ខ្លួននោះ ឈ្មោះថា **អត្តាការានុវត្តាបនំ** ប្រែថា ការញ៉ាំងធម៌ មានចក្ខុវិញ្ញាណជាដើមឲ្យប្រព្រឹត្តទៅតាមអាការរបស់ខ្លួន ។ ដោយហេតុនោះ ទើបអាចារ្យពោលថា **តិក្ខមន្ទាទិសង្ខាតអត្តាការានុវត្តាបនំ** ប្រែថា ការញ៉ាំងធម៌ មានចក្ខុវិញ្ញាណជាដើមឲ្យប្រព្រឹត្តទៅតាមអាការរបស់ខ្លួន ពោល គឺរឹង និងទន់ជាដើម ។ ន័យម្យ៉ាងទៀត ការញ៉ាំងធម៌ មានចក្ខុវិញ្ញាណជាដើមឲ្យប្រព្រឹត្តទៅតាមអាការ ពោល គឺរឹង និងទន់ជាដើម និងអាការរបស់ខ្លួន ឈ្មោះថា **តិក្ខ** ។បេ។ **វត្តាបនំ** ប្រែថា ការញ៉ាំងធម៌ មានចក្ខុវិញ្ញាណជាដើមឲ្យប្រព្រឹត្តទៅតាមអាការ ពោល គឺរឹង និងទន់ជាដើម និងអាការរបស់ខ្លួន ។ ដោយសំពួថា អាការរបស់ខ្លួនចំណែកមួយ គប្បីឃើញការសង្គ្រោះយកអាការ មានការចុះបញ្ចាំងរូបឲ្យជាក់ច្បាស់ជាដើម ។ ពិតហើយ កាលភាពអាចចុះបញ្ចាំងរូបឲ្យជាក់ច្បាស់ ពោល គឺសមគួរប៉ះខ្ទប់រូបបាន មិនមានដល់ចក្ខុន្ទ្រិយ កិច្ច គឺការឃើញរបស់ចក្ខុវិញ្ញាណ នឹងមានមកពីណា ? សូម្បីក្នុងសោតិន្ទ្រិយជាដើមក៏ដូចន័យនេះ ។ **ការញ៉ាំងសហជាតធម៌ឲ្យប្រព្រឹត្តទៅក្នុងអំណាច** រមែងមានដល់មនិន្ទ្រិយ និងដោយជាប្រធានមិនមានដល់ឥន្ទ្រិយដទៃឡើយ ។ ពិតហើយ ឥន្ទ្រិយទាំងឡាយ សូម្បីសម្បយុត្តដោយមនិន្ទ្រិយ ក៏កើតដោយអំណាចរបស់មនិន្ទ្រិយ រមែងញ៉ាំងកិច្ចនៃឥន្ទ្រិយរបស់ខ្លួន រៀងៗ ខ្លួនឲ្យសម្រេច ព្រោះជាចេតសិក មិនមែនមនិន្ទ្រិយនឹងញ៉ាំងកិច្ចនៃឥន្ទ្រិយ របស់ខ្លួនឲ្យសម្រេចដោយអំណាចឥន្ទ្រិយទាំងនោះឡើយ នេះឯង គឺភាពជាប្រធានរបស់មនិន្ទ្រិយនោះ ។ ក្នុងទីគ្រប់កន្លែង មនិន្ទ្រិយក៏គប្បីញ៉ាំងកិច្ចនៃឥន្ទ្រិយឲ្យសម្រេច ដោយជាឥន្ទ្រិយប្បច្ច័យ ព្រោះដូច្នោះ ការធ្វើ

ឲ្យក្រៃលែង ទើបគប្បីឃើញថា រមែងប្រព្រឹត្តទៅតាម ។ ហេតុក្នុងការញ៉ាំងអាការនោះៗ ឲ្យប្រព្រឹត្តទៅនៃធម៌ទាំងឡាយដែលមានឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយជាបច្ច័យឈ្មោះថា **ការចាត់ចែង** សូម្បីក្នុងកាលមានការដែលនៅមិនទាន់ធ្វើឲ្យកើតឡើង និងការដែលនៅមិនទាន់ឧបត្ថម្ភ ។

សុខវេទនា និងទុក្ខវេទនាដែលកើតឡើងបិទបាំង ( និង ) ផ្សាយទៅ រមែងគ្របសង្កត់សហជាតធម៌ទាំងឡាយ ប្រាកដចេញមកខ្លួនឯងនោះឯងហើយ សហជាតធម៌ទាំងឡាយ ហាក់ដូចជាដល់នូវសុខ និងទុក្ខ ដោយអំណាចសុខវេទនា និងទុក្ខ-វេទនានោះៗ ព្រោះដូច្នោះ ទើបអាចារ្យពោលថា **ញុំាងសហជាតធម៌នោះឲ្យដល់នូវការគ្រោតគ្រាតតាមកិច្ចរបស់ខ្លួន រៀងៗ ខ្លួន** ដូច្នេះ ។ បណ្ឌិតគប្បីប្រកបការធ្វើធម៌ដែលសម្បយុត្តជាមួយអកុសល និងវិបាកនៃអកុសលនោះជាដើមដែលមិនល្អិតមិនប្រណីត **ឲ្យដល់នូវអាការជាកណ្តាលៗ** តាមសមគួរ ។ ម្យ៉ាងទៀត គប្បីឃើញ**ការដែលធ្វើសម្បយុត្តធម៌ឲ្យដល់នូវអាការល្អិត និងប្រណីត** ជាងសុខ និងទុក្ខ ដែលមានជាតិស្មើគ្នាផង ។ ពាក្យថា **ការគ្របសង្កត់នូវបដិបក្ខធម៌** បានដល់ ការគ្របសង្កត់នូវបដិបក្ខធម៌ មានអស្សទ្ធិយជាដើម ។ ពាក្យថា **ការជ្រះថ្លាជាដើម** បានដល់ ការធ្វើសម្បយុត្តធម៌ឲ្យដល់នូវអាការផូរផង់ អាការថ្លង់ អាការប្រាកដ អាការតាំងចិត្តមាំ និងអាការដែលឃើញនៃឥន្ទ្រិយ មានសទ្ធាជាដើមដោយលំដាប់ ។ ដោយ **អាទិ-ស័ព្ទ** ក្នុងបទថា **ព្យាបាទាទិ** លោកកាន់យកឧទ្ធម្ភាគិយសំយោជនៈ លោកសម្តែងកិច្ចនៃអញ្ញិន្ទ្រិយ ដែលសម្បយុត្តដោយមគ្គនោះឯង ។ និងដោយ **អាទិ-ស័ព្ទ**នោះឯង រមែងត្រូវសម្តែងដល់អញ្ញិន្ទ្រិយ ដែលសម្បយុត្តដោយផល មានការស្ងប់រម្ងាប់ និងការលះសំយោជនៈនោះៗ ជាកិច្ចផង ដូច្នេះ ។ អញ្ញាតាវិន្ទ្រិយរបស់លោកដែលមានកិច្ចទាំងពួងបានធ្វើហើយ រមែងបែរមុខចំពោះអមតៈតែម្យ៉ាង និងជាបច្ច័យដល់ការៈដែល

បែរមុខ ចំពោះអមតៈនោះ ព្រោះមិនមានកិច្ចដទៃដែលគប្បីធ្វើ មិនមានការខ្វល់ខ្វាយ ក្នុងកិច្ចដទៃ ដូចឥន្ទ្រិយក្រៅអំពីនេះឡើយ ដោយហេតុនោះ ទើបលោកអាចារ្យពោល ថា **នឹងជាបច្ច័យឲ្យសម្បយុត្តធម៌ទាំងឡាយ មានការបែរមុខចំពោះអមតធម៌** ។

វិនិច្ឆ័យ **ដោយភូមិ** មានអត្ថងាយហើយ ។ ឯក្នុងអធិការនេះ មានបុគ្គល សង្ស័យសួរថា ព្រោះហេតុអ្វី ទើបលោកពោលចំពោះឥន្ទ្រិយប៉ុណ្ណេះ និងពោលចំពោះ ឥន្ទ្រិយទាំងនេះ ? ឆ្លើយថា ពោលដោយអំណាចអត្ថជាអធិបតីថា ដែលឈ្មោះថា **ភាពជាអធិបតី** នេះ លោកពោលថា បានដល់ ភាពជាធំនោះឯង ។ សួរតទៅទៀតថា ភាពជាអធិបតីនេះ ព្រោះហេតុអ្វី ទើបមិនបានដល់ សភាវធម៌ដទៃ គឺក្នុងកិច្ច និង ក្នុងផលរបស់ខ្លួន ? ព្រោះថា បច្ចយុប្បន្នធម៌ទាំងឡាយ មានការប្រព្រឹត្តទៅអាស្រ័យ បច្ច័យ ព្រោះដូច្នោះ ទើបគួរមានសភាវៈដែលប្រព្រឹត្តទៅតាម និងគួរប្រព្រឹត្តទៅតាម ក្នុងធម៌ដែលជាផល និងហេតុទាំងឡាយ ? ឆ្លើយថា សេចក្ដីនេះពិតហើយ សូម្បី យ៉ាងនោះ បច្ចយុប្បន្នធម៌ទាំងឡាយក៏នៅមានភាពផ្សេងគ្នា ។ ភាពផ្សេងគ្នានេះ លោក ក៏បានសម្ដែងទុកហើយ **ក្នុងអដ្ឋកថានោះឯង** ដោយន័យមានជាដើមថា ភាពជាអធិបតី របស់ឥន្ទ្រិយ មានចក្ខុជាដើមសម្រេចបាន ព្រោះការប្រព្រឹត្តទៅនៃចក្ខុវិញ្ញាណជាដើម ។ ម្យ៉ាងទៀត សត្តបញ្ញត្តិនេះ ក្នុងខន្ធបញ្ចកៈដែលអាស្រ័យភាពផ្សេងរបស់សត្វបញ្ញត្តិ នោះ ក៏គឺ **អាយតនៈខាងក្នុង ៦** ព្រោះដូច្នោះ ភាពផ្សេងគ្នានៃអាយតនៈខាងក្នុង ៦ នោះ ទើបលោកពោលទុកអំពីខាងដើមថា ចក្ខុន្ទ្រិយ ។បេ។ មនិន្ទ្រិយ ដោយកាន់យក ភាពជាអធិបតីទុកមុន ។ ត្រាស់សភាវៈទាំង ២ ដើម្បីសម្ដែងថា អត្តភាពនេះ រមែង បាន ឈ្មោះថា **ស្រី ប្រុស** ដោយអំណាចនៃឥន្ទ្រិយទាំង ២ នេះ ។ ត្រាស់ជីវិតិន្ទ្រិយ ដើម្បីសម្ដែងថា ធម៌ដែលមានវិញ្ញាណគ្រប់គ្រងនេះ រមែងប្រព្រឹត្តទៅដោយធម៌ណា ធម៌នោះជាហេតុនៃការតាំងនៅរបស់ធម៌ មានវិញ្ញាណគ្រប់គ្រងទាំងនោះ ។ ត្រាស់

វេទនា ៥ ដើម្បីសម្តែងថា គំនរធម៌ដែលស្គាល់ថា សត្វនេះ កាលប្រព្រឹត្តទៅដោយអំណាចនៃការបន្តជាប់គ្នា នឹងសៅហ្មងដោយវេទនាទាំងនេះ ។ តអំពីនោះ ត្រាស់ធម៌ ៥ យ៉ាង មានសទ្ធាជាដើម ដើម្បីនឹងសម្តែងអង្គនៃភាពផូរផង់របស់បុគ្គលដែលប្រាថ្នានូវភាពបរិសុទ្ធទាំងឡាយ ។ ត្រាស់ឥន្ទ្រិយ ៣ មានអនញ្ញាតញ្ញស្សាមីតិន្ទ្រិយជាដើម ដើម្បីនឹងសម្តែងថា អង្គនៃភាពផូរផង់ រមែងបរិសុទ្ធដោយធម៌ ៥ នេះ បុគ្គលដែលដល់នូវភាពបរិសុទ្ធហើយ រមែងជាអ្នកមានកិច្ចដែលធ្វើសម្រេចហើយនោះឯង ។គប្បីប្រកបបទថា **ចូលទៅកាន់យកជាអធិបតីក្នុងគ្រប់បទ** ។ ដោយលំដាប់នៃពាក្យត្រឹមប៉ុណ្ណោះ លោកមិនបានកាន់យកធម៌ដទៃថា ជាការសម្រេចប្រយោជន៍ដែលមានបំណងទុក ។

ន័យម្យ៉ាងទៀត លោកពោលចំពោះឥន្ទ្រិយទាំងនេះទុក ដើម្បីសម្តែងធម៌ដែលជាទីអាស្រ័យជាដើមនៃការកើត ( បវត្តិ ) និងការរលត់ ( និវត្តិ ) ពិតហើយ អាយតនៈខាងក្នុង ៦ ជាទីអាស្រ័យខាងដើម ដោយពិសេសនៃការកើត ។ ដូចជាព្រះសាស្តាត្រាស់ទុកថា លោកកើតឡើងព្រមក្នុងអាយតនៈខាងក្នុង ៦ ជាដើម ។ ការឧប្បត្តិនៃលោកនោះ ជាការកើតឡើងនៃពពួកសត្វដោយច្រើន ព្រោះឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយជាហេតុនៃតម្រេករួមគ្នានៃវិសភាគវត្ថុ ។ សមដូចព្រះមុនីត្រាស់ទុកថា មហាបពិត្រព្រោះបច្ច័យ ៣ យ៉ាងប្រជុំគ្នា ទើបមានការតាំងគភ៌ គឺមាតាមានរដូវ ១ សត្វដែលកើតមកប្រាកដ ១ មាតាបិតានៅរួមគ្នា ១ ដូច្នេះជាដើម ។ ការតាំងនៅបានក៏ដោយជីវិតិន្ទ្រិយ ព្រោះជីវិតិន្ទ្រិយនោះឃ្លាំតាមរក្សា ។ ដោយហេតុនោះ ទើបព្រះសាស្តាត្រាស់ពាក្យជាដើមថា អាយុការតាំងនៅ ការប្រព្រឹត្តទៅ កិរិយាដែលឲ្យប្រព្រឹត្តទៅ ។ ការសោយ ក៏ដោយវេទនាទាំងឡាយ ។ ពិតហើយ ការសោយអារម្មណ៍ទាំងពួងមានអារម្មណ៍ដែលគួរប្រាថ្នាជាដើម ដោយអំណាចនៃវេទនា ។ដូចព្រះតម្រាស់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ព្រោះជាធម្មជាតិដែលសោយអារម្មណ៍ ដូច្នោះ ទើបហៅ

ថា វេទនា ។ ទ្រង់សម្ដែងឥន្ទ្រិយ ១៤ យ៉ាង គឺចក្ខុន្ទ្រិយ រហូតដល់ឧបេក្ខិន្ទ្រិយ ដើម្បីសម្ដែងទីអាស្រ័យការកើតឡើង ការតាំងនៅ និងការសោយនៃការកើតដោយប្រការដូច្នេះ ។ ឯឥន្ទ្រិយទាំងឡាយ ១៤ នេះ ជាទីអាស្រ័យជាដើមរបស់ការកើតយ៉ាងណា ឥន្ទ្រិយក្រៅអំពីនេះ ក៏ជាទីអាស្រ័យជាដើមនៃការរលត់ ដូច្នោះដែរ ។ ពិតហើយ ឥន្ទ្រិយ ៥ មានសទ្ធាជាដើម ដែលបុគ្គលអាស្រ័យវិវដ្ដៈឲ្យកើតឡើង ហើយជាទីអាស្រ័យនៃការរលត់ ការកើតឡើងដោយអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ក៏ព្រោះកើតឡើងមុន ដោយអំណាចរលត់ការកើតនោះ ។ ការនៅបានដោយអញ្ញិន្ទ្រិយ ការសោយដោយអញ្ញាតាវិន្ទ្រិយ ក៏ព្រោះការសោយផលដ៏លើស ។ ពិតហើយ ព្រះខីណាស្រពទាំងឡាយ រមែងសោយសុខនៃការរលត់កិលេស ព្រោះជាអ្នកមានសមត្ថភាព ។ ទ្រង់សម្ដែងចំពោះឥន្ទ្រិយទាំងនេះទុក ដោយប្រការដូច្នេះ ។ ដោយលំដាប់នៃពាក្យមានប្រមាណប៉ុណ្ណេះ ក៏បានសម្រេចប្រយោជន៍តាមដូចបំណងហើយ ដូច្នោះ ទើបមិនកាន់យកឥន្ទ្រិយដទៃ ។ សូម្បីលំដាប់ការសម្ដែងឥន្ទ្រិយទាំងនោះ ក៏គប្បីជ្រាបថា បានពណ៌នាទុកហើយ ដោយពាក្យនេះឯង ដូច្នេះ ។

ការពណ៌នាឥន្ទ្រិយនិទ្ទេស

ចប់ហើយ

# វិសុទ្ធិមគ្គ

## សច្ចនិទ្ទេស

*អរិយសច្ច ៤ គឺទុក្ខអរិយសច្ច ទុក្ខសមុទយអរិយសច្ច ទុក្ខនិរោធអរិយសច្ច ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ឈ្មោះថា សច្ចៈ ដែលមកក្នុងលំដាប់នៃឥន្ទ្រិយ នោះ ។*

## មាតិកាវិនិច្ឆ័យ

*វិនិច្ឆ័យក្នុងអរិយសច្ចដែលជាការប្រព្រឹត្តទៅនៃព្រះសាសនានោះ បណ្ឌិតគប្បី ជ្រាបដោយវិភាគ ( ចំណែកអត្ថនៃអរិយសច្ច ៤ ) ១ ដោយការសម្តែង ( ចែកពាក្យ ) ១ ដោយប្រភេទនៃលក្ខណៈជាដើម ១ ដោយអត្ថ ( នៃសច្ចស័ព្ទ ) ១ ដោយអត្ថុទ្ធារ ( ប្រារព្ធអត្ថដែលជាបំណាំង ) ១ ដោយមានចំនួនមិនតិចមិនច្រើន ១ ដោយលំដាប់ ១ ដោយវិនិច្ឆ័យពាក្យថាជាតិជាដើម ១ ដោយកិច្ចនៃញាណ ១ ដោយប្រភេទនៃធម៌ ទាំងឡាយដែលមាននៅខាងក្នុង ( គឺរាប់បញ្ចូលក្នុងអរិយសច្ច ) ១ ដោយឧបមា ១ ដោយចតុក្កៈ ( និងមិនជាអរិយសច្ច ៤ ន័យ ) ១ ដោយភាពសោះសូន្យ ១ ដោយ បែបផ្សេងៗ មានតែមួយជាដើម ១ ដោយសភាគ និងវិសភាគ មានចំណែកស្មើគ្នា និងមិនស្មើគ្នា ១ ។*

## ដោយវិភាគ

*មាតិកាទាំងនោះ ពាក្យថា ដោយវិភាគ សេចក្តីថា អត្ថនៃអរិយសច្ច មានទុក្ខ ជាដើម លោកចែកជាបួនៗ ( គឺសច្ចៈមួយ ៤ ) ជាអត្ថពិត មិនមុសា មិនជាដទៃ ដែលព្រះយោគាវចរទាំងឡាយអ្នកត្រាស់ដឹងអរិយសច្ច មានទុក្ខជាដើមគប្បីដឹងបាន*

ដូចព្រះបាលីថា អត្ថនៃទុក្ខ គឺការបៀតបៀន ១... ភាពជាសង្ខត: ១... ភាពដុតរោល ១... ភាពប្រែប្រួល ១ អត្ថ ៤ ប្រការនេះ ជាអត្ថថា ទុក្ខនៃទុក្ខសច្ច ជាអត្ថពិត មិនមុសាវាទ មិនជាយ៉ាងដទៃ ។

អត្ថនៃសមុទយ: គឺការប្រមូលទុក ១... បង្កហេតុទុក ១... ចងទុក ១... កង្វល់ ១ អត្ថ ៤ ប្រការនេះ ជាអត្ថថា សមុទយ:នៃសមុទយសច្ច ជាអត្ថពិត មិនមុសា មិនជាដទៃ ។

អត្ថនៃនិរោធ គឺការរលាស់ចោល ១... ការស្ងប់ ១... ភាពជាអសង្ខត: ១... ភាពជាអមត: ១ អត្ថ ៤ ប្រការនេះ ជាអត្ថថា និរោធនៃនិរោធសច្ច ជាអត្ថពិត មិនមុសា មិនជាដទៃ ។

អត្ថនៃមគ្គ គឺការនាំចេញ ១... ភាពជាហេតុ ១... ការឃើញ ( ទៅតាមសេចក្តីពិត ) ១... ភាពជាអធិបតី ១ អត្ថ ៤ ប្រការនេះ ជាអត្ថថា មគ្គនៃមគ្គសច្ច ជាអត្ថពិត មិនមុសា មិនជាដទៃ ។

ព្រះបាលីដែលពោលទុកក្នុងទីដទៃថា អត្ថនៃទុក្ខ គឺការបៀតបៀន... ភាពជាសង្ខត:... ការដុតរោល... ការប្រែប្រួល... ភាពជាវត្ថុគប្បីត្រាស់ដឹង ដូច្នេះ ជាដើម ក៏ដូចគ្នា ។

អរិយសច្ច មានទុក្ខជាដើម បណ្ឌិតគប្បីជ្រាបដោយអំណាចនៃអត្ថ ៤ ដែលលោកចែកទុកដូចពោលមកនេះ ។

នេះជាការវិនិច្ឆ័យដោយវិភាគ ក្នុងអរិយសច្ចនេះជាលំដាប់ដំបូង ។

## ដោយការសម្តែង

ចំណែកក្នុង ២ មាតិកា គឺ និព្វចនលក្ខណាទិប្បភេទតោ-ដោយការសម្តែង

និងប្រភេទ មានលក្ខណៈជាដើមនេះ គប្បីជ្រាបវិនិច្ឆ័យដោយការសម្តែង ( ចែកពាក្យ ) មុន ។

## ចែកពាក្យស័ព្ទ-ទុក្ខំ

ក្នុងពាក្យថា **ទុក្ខំ** នេះ ស័ព្ទថា **ទុ** នេះ លោកកាន់យកក្នុងអត្ថ គឺគួរស្អប់ បានដល់អាក្រក់ថោកទាប ។ ពិតណាស់ ជនទាំងឡាយរមែងហៅបុត្រ ដែលគួរឲ្យស្អប់ ( គឺអាក្រក់ ) ថា **ទុរបុត្រ** ចំណែកស័ព្ទ-**ខំ** កាន់យកក្នុងអត្ថ ដែលទទេ ។ ពិតហើយដែលទទេ គឺអាកាស គេក៏ហៅថា **ខំ** ឯសច្ចៈទី ១ នេះ ចាត់ថា គួរឲ្យស្អប់ ព្រោះជាទីតាំងនៃវត្ថុដែលថោកទាប មានឧបទ្រវជាដើមជាអនេក ចាត់ថា ជាទទេ ព្រោះវៀរចាកភាពស្ថិតស្ថេរ ភាពស្អាត ភាពសុខ និងភាពជាខ្លួនដែលពាលជនស្មានយក ហេតុនោះ ទើបហៅថា ទុក្ខ ព្រោះគួរឲ្យស្អប់ និងព្រោះសូន្យទទេផងដែរ ។

## ចែកពាក្យស័ព្ទ-សមុទយៈ

ចំណែកក្នុងពាក្យថា **សមុទយ**-ស័ព្ទថា **សំ** នេះ សំដៅយកការប្រកបចូលគ្នា ( គប្បីឃើញ ) ក្នុងពាក្យថា **សមាគម សមេត** ( ប្រជុំគ្នា ) ជាដើម ស័ព្ទថា **ឧ** នេះ សំដៅដល់ការកើតឡើង ( គប្បីឃើញ ) ក្នុងពាក្យថា **ឧប្បន្ន ឧទិត** ( កើតឡើង **ឧប្បត្តិ** ) ជាដើម ស័ព្ទថា **អយ** សំដៅដល់ហេតុដែលជាសច្ចៈទី ២ នេះ កាលមានការប្រកបចូលគ្នាជាមួយបច្ច័យដ៏សេស ក៏ជាហេតុកើតឡើងនៃទុក្ខ ហេតុនោះ ទើបហៅថា ទុក្ខសមុទយៈ ព្រោះកាលមានការប្រកបចូលគ្នា ( នៃបច្ច័យ ) ក៏ជាហេតុកើតឡើងនៃទុក្ខ ។

## ចែកពាក្យស័ព្ទនិរោធ

ចំណែកសច្ចៈទី ៣ ព្រោះហេតុដែល **និ**-ស័ព្ទ សំដៅដល់ការមិនមាន និង

រោធ-ស័ព្ទ សំដៅដល់គុក ហេតុនោះ ការមិនមាននៃគុកឃាំងទុកដែលរាប់ថា គុកសង្សារ ( វដ្ដៈ ) ក្នុងសច្ចៈនេះ ទើបហៅថា **ទុក្ខនិរោធ** ព្រោះប្រាសចាកគតិទាំងពួង ឬថា កាលសច្ចៈនេះ ព្រះយោគាវចរបានសម្រេចហើយ ក៏ជាការដែលមិនមានគុកឃាំងទុក ដែលរាប់ថាគុកសង្សារ ( វដ្ដៈ ) ព្រោះសច្ចៈនេះជាបដិបក្ខចំពោះទុក្ខនោះ ហេតុនេះប្រការ ១ ទើបហៅថា ទុក្ខនិរោធ ឬមិនដូច្នោះ ហៅថា ទុក្ខនិរោធ ព្រោះជាបច្ច័យនៃការរលត់ គឺមិនកើតឡើងនៃទុក្ខ ។

## ចែកពាក្យស័ព្ទនិរោធគាមិនីបដិបទា

ចំណែកសច្ចៈទី ៤ ហៅថា ទុក្ខនិរោធគាមិនីបដិបទា ហេតុដែលសច្ចៈនេះឈ្មោះថា ( ដំណើរ ) ទៅកាន់ទុក្ខនិរោធ ព្រោះជាធម៌បែរមុខឆ្ពោះទុក្ខនិរោធនោះ ដោយភាពដែល ( មានទុក្ខនិរោធនោះ ) ជាអារម្មណ៍ និងជាបដិបទានៃការសម្រេចទុក្ខនិរោធផង ។

## ចែកពាក្យស័ព្ទអរិយសច្ច

សច្ចៈទាំងឡាយនេះ ព្រះមានព្រះភាគត្រាស់ហៅថា អរិយសច្ច ព្រោះជាធម៌ដែលព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើមចាក់ធ្លុះហើយ ដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះ អរិយសច្ច ៤ គឺអ្វីខ្លះ ។បេ។ នេះឯង ភិក្ខុទាំងឡាយ អរិយសច្ច ៤ ព្រះអរិយៈទាំងឡាយរមែងចាក់ធ្លុះនូវសច្ចៈទាំងនេះ ហេតុនោះទើបសច្ចៈទាំងឡាយនេះ ហៅថា អរិយសច្ច ។

ន័យមួយទៀត ហៅថា អរិយសច្ច ព្រោះជាសច្ចៈរបស់ព្រះអរិយៈក៏បាន ដូចព្រះបាលីថា តថាគតជាព្រះអរិយៈក្នុងលោក ព្រមទាំងទេវលោក ។បេ។ ក្នុងពួកសត្វនិងសមណៈ ព្រាហ្មណ៍ ទាំងពួកទេវតា និងមនុស្ស ព្រោះហេតុ ( តថាគត ជាព្រះ

អរិយៈ ) នោះ សច្ចៈទាំងឡាយនេះ ( របស់តថាគត ) ទើបហៅអរិយសច្ច ។

ឬន័យមួយទៀត ហៅអរិយសច្ចដោយការសម្រេចជាព្រះអរិយៈ ( មិនបាន ) ក៏ព្រោះបានត្រាស់ដឹងសច្ចៈទាំងឡាយនោះក៏បាន ដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ព្រោះបានត្រាស់ដឹងអរិយសច្ច ៤ នេះតាមពិត ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទើបបាននាមថា ព្រះអរិយៈ ។

មួយទៀតសោត ហៅអរិយសច្ច ព្រោះជាសច្ចៈដូចអរិយៈក៏បាន ពាក្យថា **អរិយៈ** ( ក្នុងអត្ថនេះ ) មានអត្ថថា ពិតមិនមុសា មិនបោកបញ្ឆោត ដូចព្រះបាលីថា នេះឯង ភិក្ខុទាំងឡាយ អរិយសច្ច ៤ ជាការពិតមិនមុសា មិនជាដទៃ ព្រោះហេតុនោះ ទើបសច្ចៈទាំងឡាយនេះ ហៅថា **អរិយសច្ច** ។

វិនិច្ឆ័យដោយការចែកពាក្យ ( ញែកពាក្យ ) ក្នុងអរិយសច្ចនេះ បណ្ឌិតគប្បីជ្រាបដូចពោលមកនេះ ។

## ដោយប្រភេទនៃលក្ខណៈជាដើម

សួរថា វិនិច្ឆ័យដោយប្រភេទនៃលក្ខណៈជាដើមដូចម្ដេច ? ឆ្លើយថា ក្នុងសច្ចៈ ៤ នេះ ទុក្ខសច្ច មានការបៀតបៀនជាលក្ខណៈ មានការដុតពេលជារស មានបវត្តិ ( ការប្រព្រឹត្តទៅមិនចប់ ) ជាបច្ចុប្បដ្ឋាន ។

សមុទយសច្ច មានការធ្វើឲ្យកើតឡើងជាលក្ខណៈ មានការមិនធ្វើឲ្យដាច់ខ្សែជារស មានភាពកង្វល់ជាបច្ចុប្បដ្ឋាន ។

និរោធសច្ច មានភាពស្ងប់ជាលក្ខណៈ មានការមិនកម្រើក (គឺមិនប្តូរសភាព) ជារស មានការមិនមាននិមិត្ត ( គ្រឿងសម្គាល់នៃទុក្ខ ) ជាបច្ចុប្បដ្ឋាន ។

មគ្គសច្ច មានការនាំចេញ ( ចាកគុកសង្សារវដ្ដ ) ជាលក្ខណៈ មានការធ្វើការលះកិលេសជារស មានការចេញ ( ចាកនិមិត្ត និងបវត្តិ ) ជាបច្ចុប្បដ្ឋាន ។

ន័យមួយទៀត សច្ចៈ ៤ មានបវត្តិ ( ការវិលទៅ ) **បវត្តន** ( ហេតុឲ្យវិលទៅ ) និង **និវត្តិ** ( ការវិលមក ) **និវត្តន** ( ហេតុឲ្យវិលមក ) ជាលក្ខណៈ ដោយលំដាប់ ។ម្យ៉ាងទៀតមានភាពជាសង្ខតៈតណ្ហា(ការស្រេកឃ្លាន)និងភាពជាអសង្ខតៈ ទស្សនៈ ( ការឃើញទៅតាមសេចក្ដីពិត ) ជាលក្ខណៈដោយលំដាប់គ្នាយ៉ាងនោះ ។

វិនិច្ឆ័យដោយប្រភេទនៃលក្ខណៈជាដើម ក្នុងអរិយសច្ចនេះ គប្បីជ្រាបដូចពោលមកនេះ ។

## ដោយអត្ថ

ចំណែកក្នុង ២ មាតិកា គឺ **អត្ថត្ថុទ្ធារតោ ចេវ**-ដោយអត្ថ និងដោយវត្ថុធារណៈនេះ បណ្ឌិតគប្បីជ្រាបដោយអត្ថ ( នៃសច្ចស័ព្ទ ) មុន ។

បើមានពាក្យសួរថា អ្វីជាអត្ថនៃសច្ចៈ ដូចនេះសោត ? ពាក្យឆ្លើយក៏គប្បីមានថា សភាវៈណា កាលព្រះយោគាវចរទាំងឡាយចូលដល់ការពិចារណាដោយបញ្ញាចក្ខុ ក៏មិនជាសភាវៈដែលវិបរិត ( ខុសការពិត ) ទៅដូចកលមាយា មិនជាសភាវៈដែលបញ្ឆោត ដូចថ្ងៃបណ្ដើរកូន និងមិនជាសភាវៈដែលបុគ្គលណាមួយ រកមិនបាន ( គឺមិនមាន ) ដូចអត្តារបស់ពួកតិត្ថិយ តែជាគោចរ (គឺជាអារម្មណ៍) នៃអរិយញ្ញាណដោយភាពជាសភាវៈដោយពិត មិនវិបរិត និងជាការពិតដែលមានប្រការ ( គឺអាការ ) ញុំាងឲ្យកើត ស្ងប់ និងនាំចេញទៅប៉ុណ្ណោះ ភាពជាសភាវៈដែលពិត មិនវិបរិត និងពិត ដូចលក្ខណៈរបស់ភ្លើង និងដូចប្រក្រតីរបស់លោកនោះ បណ្ឌិតគប្បីជ្រាបថាជាអត្ថរបស់សច្ចៈ ដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះទុក្ខ ទុំះជាពាក្យពិត ទុំះជាពាក្យមិនកុហក ទុំះជាពាក្យមិន ( ប្រែប្រួល ) ទៅជាប្រការដទៃឡើយ ដូច្នេះជាដើម សេចក្ដីពិស្ដារ បណ្ឌិតគប្បីនាំមកពោលចុះ ។

ម្យ៉ាងទៀត ហេតុណា ទុក្ខមិនបៀតបៀនមិនមាន វត្ថុដទៃ ( ក្រៅ ) ពីទុក្ខបៀតបៀនក៏មិនមាន ព្រោះហេតុនោះ ទើបទុក្ខនេះធ្លាក់ចុះជាសច្ចៈ ព្រោះពិតប្រាកដក្នុងភាពជាធម្មជាតិដែលបៀតបៀន ។

ហេតុណា វៀរធម្មជាតិនោះ ( គឺតណ្ហា ) ចេញ ទុក្ខ ( កើត ) អំពីហេតុដទៃមិនមាន ហើយធម៌នោះមិនមាន ទុក្ខនោះក៏មិនមាន ព្រោះហេតុនោះ វិសត្តិកា ( គឺតណ្ហា ) ទើបធ្លាក់ចុះជាសច្ចៈ ព្រោះពិតក្នុងភាពជាហេតុនៃទុក្ខ ។

ហេតុណា សេចក្តីស្ងប់ដទៃចាកនិព្វានមិនមាន និងសន្ត ( គឺនិព្វាន ) មិនមានភាពស្ងប់នោះក៏មិនមាន ព្រោះហេតុនោះ ទើបនិព្វាននេះធ្លាក់ចុះជាសច្ចៈ ព្រោះពិតក្នុងភាពជាធម៌ស្ងប់ ។

ហេតុណា ជាគ្រឿងនាំចេញដទៃចាកមគ្គមិនមាន និងនិយ្យាន ( គឺមគ្គ ) មិនមាន សូម្បីធម៌ដែលជាគ្រឿងនាំចេញនោះក៏មិនមាន ព្រោះហេតុនោះ ទើបមគ្គនោះធ្លាក់ចុះ ជាសច្ចៈ ព្រោះភាពជាធម៌ដែលជាគ្រឿងនាំចេញដោយពិត ។

បណ្ឌិតទាំងឡាយពោលការពិត ការមិនឃ្លាត និងជាការពិតក្នុងសច្ចៈទាំង ៤ មានទុក្ខជាដើមដោយប្លែកគ្នា ថាជាអត្ថនៃសច្ចស័ព្ទ ដោយប្រការដូច្នេះ ។

វិនិច្ឆ័យដោយអត្ថ ( នៃសច្ចស័ព្ទ ) គប្បីជ្រាបដូចពោលមក ដូច្នេះ ។

## ដោយអត្ថុទ្ធារ

វិនិច្ឆ័យដោយអត្ថុទ្ធារ ( អធិប្បាយអត្ថដែលជាបំណាង ) ដូចម្តេច ក្នុងសេចក្តីនេះ សច្ចស័ព្ទនេះ កាន់យកក្នុងអត្ថបានច្រើនយ៉ាង គឺអ្វីខ្លះ ? គឺសច្ចស័ព្ទក្នុងពាក្យទាំងឡាយ មានពាក្យថា **សច្ចំ ភណេ ន កុជ្ឈេយ្យ**-បុគ្គលគប្បីនិយាយ ពាក្យពិត មិនគប្បីក្រោធជាដើម កាន់យកក្នុង ( អត្ថគឺ ) វាចាសច្ចៈ ( ពិតតាមផ្លូវវាចា ) **សច្ច**-សព្ទក្នុងពាក្យ

ទាំងឡាយ មានពាក្យថា សច្ចេឋិតា សមណព្រាហ្មណា វា សមណព្រាហ្មណ៍ទាំងឡាយអ្នកតាំងនៅក្នុងសច្ចៈក្តី ជាដើម កាន់យកក្នុងវិរតិសច្ចៈ ( ពិតតាមផ្លូវវិរតិ ) សច្ចស័ព្ទក្នុងពាក្យទាំងឡាយ មានពាក្យថា

កស្មា នុ សច្ចានិ វទន្តិ នានា បវាទិយាសេ កុសលាវទានា

ហេតុអ្វីហ្ន៎ ម្ចាស់លទ្ធិទាំងឡាយ អ្នកសម្គាល់ថាខ្លួន ជាអ្នកមានវាទៈជាកុសលគឺត្រឹមត្រូវ ទើបពោលសច្ចៈទាំងឡាយផ្សេងៗ គ្នា ជាដើម កាន់យកក្នុងទិដ្ឋិសច្ចៈ ( ពិតតាមការយល់ឃើញ ) សច្ចសព្ទក្នុងពាក្យទាំងឡាយ មានពាក្យថា ឯកំ ហិ សច្ចំ នទុតិយំ-សច្ចៈមានតែ ១ មិនមានសច្ចៈទី ២ ជាដើម កាន់យកក្នុងព្រះនិព្វាន និងមគ្គផង ដែលជាបរមត្ថសច្ចៈ ( ពិតដោយបរមត្ថ ) សច្ចសព្ទក្នុងពាក្យទាំងឡាយ មានពាក្យថា ចតុន្នំ សច្ចានំ កតី កុសលា-បណ្តាសច្ចៈទាំង ៤ សច្ចៈប៉ុន្មានជាកុសលជាដើម កាន់យកក្នុងអរិយសច្ចៈ ( ពិតបែបយ៉ាងអរិយៈ ) សូម្បីសច្ចសព្ទនេះក្នុងសេចក្តីនេះ ក៏ប្រព្រឹត្តទៅក្នុង ( អត្ថគឺ ) អរិយសច្ច ដូច្នេះ ។

វិនិច្ឆ័យសូម្បីដោយអត្ថជាក្នុងអរិយសច្ចនេះ គប្បីជ្រាបដូចពោលមកនេះ ។

## ដោយមានចំនួនមិនខ្វះមិនលើស

ពាក្យថា ដោយមានចំនួនមិនតិចមិនច្រើន សេចក្តីថា បើពាក្យសួរគប្បីមានថា ព្រោះហេតុដូចម្តេច ទើបព្រះមានព្រះភាគត្រាស់អរិយសច្ចតែ ៤ ប៉ុណ្ណោះ មិនលើសមិនខ្វះ ដូច្នេះសោត ? ពាក្យឆ្លើយគប្បីមានថា ព្រោះមិនមានអរិយសច្ចដទៃប្រការ ១ ព្រោះលុបចេញណានីមួយក៏មិនបានប្រការ ១ ពិតណាស់ អរិយសច្ចដទៃពីសច្ចៈ ៤ នោះ ជាចំណែកក្រៅលែង (គឺលើស) ក្តី ដោយអរិយសច្ច៤នោះសូម្បី ១ គប្បីបន្ថយចេញបានក្តីក៏មិនមាន ដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍

ក្នុងលោកនេះ មកពោលថា នេះមិនមែនទុក្ខអរិយសច្ច ទុក្ខអរិយសច្ចជាយ៉ាងដទៃ ខ្ញុំនឹងលើកទុក្ខអរិយសច្ចនេះចេញ ហើយបញ្ញត្តទុក្ខអរិយសច្ចដទៃ ( ឡើងថ្មី ) ដូច្នេះ នេះមិនមែនជាផ្លូវប្រព្រឹត្តទៅបានដូច្នេះជាដើម និងដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ណាមួយក៏ដោយ គប្បីពោលយ៉ាងនេះថា ទុក្ខអរិយសច្ចដែលព្រះសមណគោតមសម្តែងទុកនេះ មិនមែនជាអរិយសច្ចទី ១ ខ្ញុំបដិសេធទុក្ខអរិយសច្ចដែលជាអរិយសច្ចទី ១ នោះចេញហើយ បញ្ញត្តទុក្ខអរិយសច្ចដទៃ ជាអរិយសច្ចទី ១ ( ជាថ្មី ) ដូច្នេះ នេះមិនមែនផ្លូវដែលប្រព្រឹត្តទៅបាន ដូច្នេះជាដើម ។

ម្យ៉ាងទៀត ព្រះមានព្រះភាគកាលត្រាស់ប្រាប់បវត្តិ (ការវិលទៅ) គឺត្រាស់ប្រាប់ព្រមទាំងហេតុ កាលត្រាស់ប្រាប់និវត្តិ ( ការវិលមក ) ក៏ត្រាស់ប្រាប់ព្រមទាំងឧបាយផង ដូច្នេះ ទើបត្រាស់តែ ៤ ប៉ុណ្ណោះ ព្រោះមានបវត្តិ និវត្តិ និងហេតុនៃបវត្តិ និវត្តិទាំង ២ នោះត្រឹមតែប៉ុណ្ណោះ ន័យដូចគ្នា ត្រាស់តែ ៤ ប៉ុណ្ណោះ សូម្បីដោយអំណាចនៃធម៌ដែលគប្បីកំណត់ដឹង ធម៌ដែលគប្បីលះ ធម៌ដែលគប្បីធ្វើឲ្យជាក់ច្បាស់ និងធម៌ដែលគប្បីធ្វើឲ្យមានឡើង ១ នៃវត្ថុរបស់តណ្ហា ( គួ ) តណ្ហា ការរលត់តណ្ហា និងឧបាយរលត់តណ្ហា ១ នៃអាល័យការត្រេកអរក្នុងអាល័យ ការដកអាល័យចេញបាន និងឧបាយដកអាល័យ ១ ។

វិនិច្ឆ័យដោយមានចំនួនមិនតិចមិនច្រើន ក្នុងអរិយសច្ចនេះ គប្បីជ្រាបដូចពោលមកនេះ ។

## ដោយលំដាប់

សូម្បីលំដាប់ក្នុងពាក្យថា ដោយលំដាប់នេះ ក៏បានដល់លំដាប់នៃការសម្តែងដូចគ្នា ក្នុងអរិយសច្ច ៤ នេះ ទុក្ខសច្ចព្រះសាស្តាត្រាស់ទុកជាប្រការដំបូង ព្រោះថាដឹងបានងាយ ព្រោះជារបស់គ្រោតគ្រាត និងជារបស់សាធារណៈដល់សត្វទាំងពួង

សមុទយសច្ចត្រាស់ទុកក្នុងលំដាប់នោះ ដើម្បីសម្តែងហេតុនៃទុក្ខសច្ចនោះឯង និរោធសច្ចត្រាស់បន្ទាប់អំពីនោះទៅដើម្បីឲ្យដឹងថា ការរលត់នៃផលរមែងមាន ព្រោះការរលត់នៃហេតុ មគ្គសច្ចត្រាស់ទុកក្នុងទីបំផុត ដើម្បីសម្តែងឧបាយសម្រេចនិរោធសច្ចនោះ ន័យមួយទៀត ត្រាស់ទុក្ខមុនដើម្បីញុំាងភាពសង្វេគឲ្យកើតដល់សត្វទាំងឡាយ អ្នកជាប់ចិត្តក្នុងរសជាតិនៃសេចក្តីសុខក្នុងភព ត្រាស់សមុទយៈក្នុងលំដាប់នោះ ដើម្បីឲ្យជ្រាបថា ទុក្ខនោះ តណ្ហាមិនបានតាក់តែងឡើងក៏មិនមាន មានឡើងព្រោះមានហេតុខាងក្រៅ មានព្រះឥស្សរបង្កើតជាដើមក៏ទេ តែទុក្ខមានឡើង ព្រោះតណ្ហានេះ បន្ទាប់អំពីនោះ ត្រាស់និរោធដើម្បីត្រាស់លួងលោមចិត្ត ដោយបានឃើញនិស្សរណៈឲ្យកើតដល់បុគ្គលទាំងឡាយអ្នកមានចិត្តសង្វេគ ព្រោះត្រូវទុក្ខ និងហេតុគ្របសង្កត់ ហើយស្វែងរកភាពចេញចាកទុក្ខ បន្ទាប់អំពីនោះ ទើបត្រាស់មគ្គដែលជាធម៌ញុំាងនិរោធឲ្យដល់ព្រមដើម្បីសម្រេចនិរោធ ដូច្នេះ ។

វិនិច្ឆ័យដោយលំដាប់ក្នុងអរិយសច្ចនេះ គប្បីជ្រាបដូចពោលមកនេះ ។

## វិនិច្ឆ័យពាក្យថា ជាតិជាដើម

ពាក្យថា ដោយវិនិច្ឆ័យពាក្យថា ជាតិជាដើម សេចក្តីថា ធម៌ទាំងឡាយ មានជាតិជាដើមនោះ ព្រះមានព្រះភាគកាលទ្រង់ចែកអរិយសច្ចទាំងឡាយ បានត្រាស់ទុកក្នុងនិទ្ទេសនៃអរិយសច្ច ៤ ដូច្នេះ គឺធម៌ ១២ ប្រការ ត្រាស់ទុកក្នុងនិទ្ទេសនៃទុក្ខសច្ចថា ការកើតក៏ជាទុក្ខ ១ ការចាស់ក៏ជាទុក្ខ ១ សេចក្តីស្លាប់ក៏ជាទុក្ខ ១ ភាពសោកភាពបរិទេវៈ ការមិនសប្បាយកាយ ការមិនសប្បាយចិត្ត ការចង្អៀតចង្អល់ចិត្ត ក៏ជាទុក្ខ (រាប់បាន ៥) ការបាននូវវត្ថុដែលមិនជាទីស្រឡាញ់ទាំងឡាយក៏ជាទុក្ខ ១ ការ

ប្រាសចាកវត្ថុដែលជាទីស្រឡាញ់ទាំងឡាយក៏ជាទុក្ខ ១ ការប្រាថ្នាតែមិនបានក៏ជាទុក្ខ ១ ដោយបង្រួញឧបាទានក្ខន្ធ ៥ ក៏ជាទុក្ខ តណ្ហា ៣ ប្រការត្រាស់ទុកក្នុងនិទ្ទេសនៃសមុទយសច្ចថា តណ្ហាណាមានការប្រកបក្នុងភពថ្មីជាប្រក្រតី ដែលទាក់ទងជាមួយគ្នានឹងនន្ទរាគៈ មានប្រក្រតីត្រេកអរទៅក្នុងអត្តភាពនោះ តណ្ហានេះ គឺអ្វីខ្លះ គឺកាមតណ្ហា ភវតណ្ហា វិភវតណ្ហា ព្រះនិព្វានដែលមានប្រការដូចបំណាងដែលត្រាស់ទុកក្នុងនិទ្ទេសនៃនិរោធសច្ចដូច្នេះថា ការរលត់ដោយភាពខ្វាក់ចោល មិនឲ្យមានសេសសល់នៃតណ្ហានោះឯណា ការលះបង់ទៅ ការរលាស់ចោលទៅ ការរួចផុតទៅចាកសេចក្ដីអាល័យនៃតណ្ហានោះឯង យ៉ាងណា ។ ធម៌ ៨ ប្រការត្រាស់ទុកក្នុងនិទ្ទេសនៃមគ្គសច្ចដូច្នេះថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចដូចម្ដេច គឺអរិយមគ្គ មានអង្គ ៨ នេះឯង អរិយមគ្គមានអង្គ ៨ នេះ គឺអ្វីខ្លះ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ដូច្នេះ ដោយវិនិច្ឆ័យធម៌ទាំងឡាយ មានជាតិជាដើមនោះ ។

# មហាដីកា

## កថាពណ៌នាដោយពិស្តារនៃសច្ចៈ

*លោកអាចារ្យកាលសម្តែងសច្ចៈដែលលើកឡើងសម្តែង ដោយ **សច្ច-ស័ព្ទ** តែម្យ៉ាង ក៏គឺអរិយសច្ចនោះឯង មិនបានធ្វើពាក្យផ្សេងទុកដោយ **អរិយ**-ស័ព្ទ ទើបពោលថា **ពាក្យថា សច្ចៈ បានដល់ អរិយសច្ច ៤** ។ ពិតហើយ ការចុះបញ្ចាំងភាពស្មើគ្នារមែងប្រើបានក្នុងភាពស្មើគ្នា បុគ្គលមានសេចក្តីត្រូវការភាពផ្សេងគ្នា ក៏គប្បីតាមប្រកបយកភាពផ្សេងគ្នានោះឯង ។ ម្យ៉ាងទៀត កាលបានពិចារណាអរិយសច្ចហើយ សូម្បីសច្ចៈក្រៅអំពីនេះ ក៏ឈ្មោះថាបានពិចារណាហើយដូចគ្នា ដោយអត្ថ ព្រោះដូច្នោះ លោកអាចារ្យសូម្បីលើកពាក្យថា **សច្ចៈ** ឡើងមក ហើយក៏ពោលថា **បានដល់អរិយសច្ច ៤** ព្រោះធ្វើពាក្យអធិប្បាយថា សច្ចៈជាភូមិរបស់វិបស្សនាផង និងថា សច្ចៈ ក៏គឺអរិយសច្ចនោះឯងផង ។*

*អរិយសច្ច ឬការសម្តែងអរិយសច្ច លោកហៅថា **សាសនក្កមោ** ប្រែថា លំដាប់របស់ពាក្យប្រៀនប្រដៅ ។ ពិតហើយ ពាក្យប្រៀនប្រដៅ គឺព្រះតម្រាស់របស់ព្រះមានព្រះភាគទាំងអស់ដែលផុតទៅអំពីសច្ចៈមិនមាន ព្រោះប្រព្រឹត្តទៅ ដោយអំណាចការបង្អួលបង្ហាញ ការកើត ការរលត់ និងហេតុនៃការកើត និងការរលត់ទាំង ២ នោះ ។ ព្រោះដូច្នោះ ទើបពាក្យប្រៀនប្រដៅ ចុះទៅក្នុងសច្ចៈទាំងឡាយ ម្យ៉ាងទៀត ពាក្យប្រៀនប្រដៅ ពោល គឺសីល សមាធិ បញ្ញា រមែងចុះទៅក្នុងសច្ចៈទាំងនេះ គឺរមែងប្រព្រឹត្តទៅដោយអំណាចការធ្វើកិច្ច មានបរិញ្ញាកិច្ចជាដើមឲ្យសម្រេច ព្រោះដូច្នោះ ទើបឈ្មោះថា **កម** ព្រោះអត្ថថា ជាទីឈានទៅ អ្វីឈានទៅ ? ពាក្យប្រៀនប្រដៅឈានទៅ លំដាប់នៃពាក្យប្រៀនប្រដៅ ឈ្មោះថា **សាសនក្កមោ***

ព្រោះដូច្នោះ សច្ចៈដែលជាទីតាំងនៃការប្រព្រឹត្តទៅរបស់ពាក្យប្រៀនប្រដៅ ទើបហៅថា **សាសនក្កមោ** ហើយការសម្តែងសច្ចៈនោះ ក៏ហៅ ដោយវោហារនោះឯង ។

បទថា **តថា** គឺមានសភាវៈដូច្នោះ បានដល់ មានសភាវៈជាទុក្ខជាដើម ។ បទថា **អវិតថា** សេចក្តីថា មានសភាវៈមិនកុហក គឺមានសភាវៈកើតពិត ដោយជាសភាវៈដែលបៀតបៀនជាដើម ។ បទថា **អនញ្ញថា** គឺវៀរចាកអាការដទៃ បានដល់ ទទេចាកអាការដែលមិនបៀតបៀនជាដើម ។ អារម្មណ៍ដែលមិនគួរប្រាថ្នា ព្រោះជាទុក្ខពិត និងមានទុក្ខពិតៗ ជានិមិត្ត ឈ្មោះថា **អត្ថ គឺការបៀតបៀន** ។ ភាវៈដែលត្រូវបច្ច័យប្រជុំគ្នា គឺរួមគ្នាធ្វើ ឈ្មោះថា **អត្ថ** ថាជាសង្ខតៈ ។ ការក្តៅក្រហាយ ព្រោះជាទុក្ខពិតៗ និងការមានទុក្ខពិតៗ នោះជានិមិត្ត ឬការប្រកបដោយការក្តៅក្រហាយ គឺកិលេស ឈ្មោះថា **គឺការក្តៅក្រហាយជាអត្ថ** ភាពដែលត្រូវប្រែប្រួលទៅដោយហេតុ ២ ប្រការ គឺការចាស់ និងការស្លាប់ ឈ្មោះថា **គឺការប្រែប្រួលជាអត្ថ** ។ ក្នុងអធិការនេះ អត្ថទាំង ៤ យ៉ាង មានសេចក្តីផ្សេងគ្នានេះ គឺអត្ថ គឺការបៀតបៀនជាអាការដែលធ្វើទុក្ខឲ្យជាក់ច្បាស់តាមសភាវៈនោះឯង អត្ថក្រៅអំពីនេះ ជាអាការដែលធ្វើទុក្ខឲ្យជាក់ច្បាស់ដោយការសម្តែងសមុទយៈ មគ្គ និងនិរោធតាមលំដាប់ ។ ការខ្វល់ខ្វាយដែលជ្រួតជ្រាបទៅដោយអំណាចការត្រេកអរក្នុងអារម្មណ៍នោះៗ គឺធ្វើឲ្យជាគំនរ បានដល់ ការកើតឡើងនៃទុក្ខ ឈ្មោះថា **អាយូហនំ** (ប្រែថា ប្រមូលទុក) ព្រោះអត្ថថា ធ្វើអាការឲ្យជ្រួតជ្រាបទៅ ។ ម្យ៉ាងទៀត ទុក្ខ ឈ្មោះថា **អាយ** ព្រោះអត្ថថា មកអំពីសមុទយៈ ការកើត គឺការប្រព្រឹត្តទៅនៃទុក្ខនោះ ឈ្មោះថា **អាយូហនំ** (ប្រែថា ការកើតឡើងរបស់ទុក្ខ) នេះជាអាការដែលធ្វើសមុទយៈឲ្យជាក់ច្បាស់ដោយសភាវៈនោះឯង ។ ឈ្មោះថា **និទានំ** ព្រោះអត្ថថា បង្កទុក្ខឡើង អធិប្បាយថា ធ្វើទុក្ខឲ្យតាំងឡើង ដូចជាធ្វើឲ្យព្រមទទួលថា **នេះ គឺទុក្ខ** ។ អត្ថថា **និទាន គឺបង្កហេតុ** នេះ

ជាអាការធ្វើសមុទយៈឲ្យ ជាក់ច្បាស់ដោយការបង្ហាញទុក្ខ ។ ការចងទុកដោយទុក្ខ គឺសង្សារ ឈ្មោះថា **អត្ថ គឺការចងទុក** ។ ការហាមឃាត់ការសម្រេចមគ្គ ឈ្មោះថា **អត្ថថា រួបរឹត** ។ ឯអត្ថថា ចងទុក និងអត្ថថា ចងរួបរឹតនេះ ឈ្មោះថា ជាអាការធ្វើសមុទយៈឲ្យជាក់ច្បាស់ដោយការបង្ហាញដល់និរោធ និងមគ្គ ។ ឈ្មោះថា **និស្សរណំ** ព្រោះអត្ថថា ជាទីរលាស់ចេញទៅរបស់សត្វទាំងឡាយ ន័យម្យ៉ាងទៀត ព្រោះអត្ថថា ខ្ទួនឯង នោះឯង រលាស់ចេញទៅ គឺមិនជាប់ជំពាក់ជាមួយសង្ខតធម៌ទាំងពួង ព្រោះជាធម៌ រលាស់នូវឧបធិទាំងពួង ។នេះជាអាការធ្វើនិរោធនេះឲ្យជាក់ច្បាស់ដោយសភាវៈ អត្ថថា **ទទេ** អត្ថថា **សង្ខត** និងអត្ថថា **អមតៈ** ឬការអស់ទៅនៃសមុទយៈ ការមិនមានបច្ច័យ ការដែលមិនត្រូវធ្វើឲ្យវិនាសក្រៅអំពីនេះ ជាអាការធ្វើនិរោធនេះឲ្យជាក់ច្បាស់ ដោយការបង្ហាញដល់សមុទយៈ មគ្គ និងទុក្ខ ។ ការចេញទៅអំពីសង្សារ ឈ្មោះថា **និយ្យានំ** ប្រែថា ការចេញទៅ ។ អាការនេះជាការធ្វើមគ្គនេះ ឲ្យជាក់ច្បាស់ដោយសភាវៈ ។ ការសម្រេចព្រះនិព្វាននោះឯង គឺការដែលមគ្គជាហេតុនៃព្រះនិព្វាន **ជាអត្ថនៃហេតុ** របស់មគ្គ ដោយអាការចូលទៅកាត់ក្តីកង្វល់ ការឃើញព្រះនិព្វាន ឬការឃើញសច្ចៈ ៤ **ជាអត្ថនៃការឃើញ** ព្រោះមគ្គមានបញ្ញាជាប្រធាន ។ ក្នុងបណ្តាសម្បយុត្តធម៌ទាំងឡាយ ធម៌ គឺមគ្គ រមែងធ្វើភាពជាអធិបតីក្នុងការឃើញសច្ចៈ ៤ និងក្នុងការចូលទៅរម្ងាប់ការក្តៅក្រហាយ គឺទុក្ខដែលកើតអំពីកិលេស ព្រោះដូច្នោះទើបឈ្មោះថា **ជាអត្ថ គឺជាអធិបតីនៃមគ្គ** ។ ន័យម្យ៉ាងទៀត ពោលដោយពិសេស ធម៌ គឺមគ្គ ដែលជាអារម្មណាធិបតីរមែងកើតដោយព្រះបាលីថា **មគ្គាធិបតិនោ** ប្រែថា ធម៌មានមគ្គជាអធិបតី ព្រោះដូច្នោះ អាការនៃធម៌ គឺមគ្គទាំងនោះ ទើបឈ្មោះថា **ជាអត្ថ គឺភាពជាអធិបតី** ។ អត្ថ គឺភាពជាហេតុ អត្ថ គឺការឃើញ អត្ថ គឺភាពជាអធិបតីទាំងឡាយ ជាអាការធ្វើមគ្គឲ្យជាក់ច្បាស់ ដោយការបង្ហាញសមុទយៈ និរោធ

និងទុក្ខ ។ ក្នុងសេចក្តីព្រះបាលីថា **ឯវមាទិ អាហ** ។ បទថា **អភិសមយដ្ឋោ** ប្រែថា អត្ថ គឺភាពជាវត្ថុគប្បីត្រាស់ដឹង ន័យម្យ៉ាងទៀត អត្ថដែលជាវិស័យនៃការត្រាស់ដឹង ឈ្មោះថា **អភិសមយដ្ឋោ** ប្រែថា អត្ថដែលជាវិស័យនៃការត្រាស់ដឹង ។ ន័យម្យ៉ាងទៀត អាការដែលប្រព្រឹត្តទៅនៃការត្រាស់ដឹង ឈ្មោះថា **អភិសមយដ្ឋោ** ប្រែថា អត្ថដែលជាអាការប្រព្រឹត្តទៅនៃការត្រាស់ដឹង ។ ក៏ក្នុងអធិការនេះ អត្ថ គឺការត្រាស់ដឹងនោះ បណ្ឌិតគប្បីឃើញថា លោកសម្តែងដោយអត្ថ គឺការបៀតបៀនជាដើម ដែលនឹងគប្បីត្រាស់ដឹង ។ វិគ្គហៈ **ទុក្ខ** ថា **កុច្ឆិតំ ខំ ទុក្ខំ** ប្រែថា ភាពទទេដែលគួរខ្ពើមរអើម ឈ្មោះថា ទុក្ខ សេចក្តីថា ដែលបណ្ឌិតគប្បីតិះដៀល មិនមានសារៈ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សមាគមោ សមេតំ** ដូច្នេះជាដើម អាចារ្យពោលថា **សំយោគំ ទីបេតិ** រមែងសម្តែងការប្រកបចូលគ្នា ព្រោះកាលប្រើ **អាគម** ស័ព្ទ និង **ឯត**-ស័ព្ទសុទ្ធៗ ក៏មិនបានន័យថា សំយោគ និងព្រោះកាលប្រកប **សំ** ស័ព្ទចូលទៅ ទើបមានន័យ ព្រោះសម្រេចជាធម៌ចុះបញ្ចាំងអត្ថរបស់ពាក្យនោះដោយន័យដែលអនុលោមតាម និងដោយន័យដែលជាពាក្យមានអត្ថន័យផ្សេងចេញទៅ ។ សូម្បីក្នុងពាក្យថា **ឧប្បន្នំ ឧទិតំ** ក៏មានន័យនេះដូចគ្នា ។ **អយ**-ស័ព្ទ ប្រើក្នុងអត្ថនៃ **គតិ**-ស័ព្ទ រមែងចុះបញ្ចាំងដល់ហេតុ ដូចហេតុស័ព្ទ ។ ឈ្មោះថា **អយ** ព្រោះអត្ថថា កើត គឺប្រព្រឹត្តទៅដោយការញ៉ាំងផលរបស់ខ្លួនឲ្យសម្រេច ម្យ៉ាងទៀត ឈ្មោះថា **អយ** ព្រោះអត្ថថា ជាដែនកើតនៃផល ព្រោះដូច្នោះ **ហេតុដែលកើតឡើងក្នុងកាលមានការប្រកបចូលគ្នា** ទើបឈ្មោះថា **សមុទយ** ដូច្នេះ ។ ស័ព្ទ **ឧបសគ្គ** សូម្បីប្រកបញែកគ្នាក្នុងបទថា **សមុទយោ** នេះ បណ្ឌិតគប្បីជ្រាបថា រមែងសម្តែងអត្ថថា ប្រកប និងអត្ថថា កើតឡើងព្រមជាមួយធាតុ ព្រោះជាកិរិយាវិសេស ។ ដោយពាក្យថា ឈ្មោះថា **និរោធ** ព្រោះអត្ថថា **មិនមានគុកក្នុងសង្សារ** នេះ លោកអាចារ្យសម្តែងដល់

ព្រះនិព្វានជាធម្មជាតិទទេចាកទុក្ខ ។ **កាលសម្រេច** សច្ចៈនោះហើយ បុគ្គលដែលមានការសម្រេចសច្ចៈនោះ ក៏មិនមានគុក ព្រោះបានសម្រេចនូវការរលត់ដែលជាបដិបក្ខចំពោះគុក គឺការកើត ។ ក្នុងអត្ថនេះ មានការសង្ខេបបទថា **និរោធោ** ព្រោះអត្ថថា **ការមិនមាននៃគុកក្នុងសច្ចៈ** នេះ ។ ឯក្នុងពាក្យនេះ ការមិនមានទុក្ខ ជារបស់បុគ្គល មិនមែនជារបស់និព្វានឡើយ ។ ការរលត់ គឺការមិនកើតឡើងនោះឯង ឈ្មោះថា **អនុប្បាទនិរោធោ** ប្រែថា ការរលត់ដែលមិនកើតឡើង ។ គឺបានដល់ ការមិនកើតក្នុងភពជាដើមតទៅ សូម្បីមិនមែនជាគន្ធៈ ព្រោះដូច្នោះ ទើបអាចារ្យហាមនិរោធស័ព្ទដែលប្រាប់សេចក្តីថា គន្ធៈ កាន់យកនិរោធស័ព្ទដែលប្រាប់ដល់អនុប្បាទ ។ ក្នុងអត្ថនេះ បច្ច័យនៃនិរោធ លោកក៏ហៅថា **និរោធ** ព្រោះធ្វើពាក្យពោលដែលពឹងផ្អែកផលព្រោះហេតុ ។

**និងជាបដិបទា** នៃការសម្រេចទុក្ខនិរោធរបស់បុគ្គលផង ។ សួរថា បដិបទានោះឯង ជាហេតុសម្រេចទុក្ខនិរោធ ព្រោះដូច្នោះ ទើបមិនគួរពោលថា បដិបទានោះជាបដិបទានៃការសម្រេចទុក្ខនិរោធនោះៗ ឯង មិនមែនឬ ? ឆ្លើយថា មិនមែនព្រោះបដិបទានោះលោកពោលទុក ដោយជាហេតុសម្រេចនៃការចាក់ធ្លុះរបស់បុគ្គល និងដោយជាបដិបទានៃធម៌ ដែលជាហេតុឲ្យបុគ្គលនោះសម្រេច ។ សូម្បីកាលការដែលធ្វើឲ្យជាក់ច្បាស់ក្នុងធម៌ដែលធ្វើឲ្យជាក់ច្បាស់ មិនមានភាពជាដទៃ ទើបលោកធ្វើនិទ្ទេសឲ្យមានសេចក្តីផ្សេងគ្នា ដោយភាពជាការធ្វើឲ្យជាក់ច្បាស់របស់បុគ្គល និងធម៌ដែលធ្វើឲ្យជាក់ច្បាស់ ដូច្នេះ ។ ន័យម្យ៉ាងទៀត ធម្មជាតិណាជាផលដែលសម្រេចការចាក់ធ្លុះទុក្ខនិរោធ និងជាគ្រឿងសម្រេចទុក្ខនិរោធខ្លួនឯងផង បណ្ឌិតគប្បីជ្រាបភាពដែលធម្មជាតិនោះ ជាបដិបទានៃការសម្រេចទុក្ខនិរោធ ដែលជាការត្រាស់ដឹង ។

ក្នុងពាក្យថា **ព្រះអរិយៈទាំងឡាយ មានព្រះសម្ពុទ្ធជាដើម រមែងចាក់ធ្លុះ** នេះ

លោកអាចារ្យពោលថា **មានព្រះសម្ពុទ្ធជាដើម** ដោយលើកយកវោហារ មានព្រះមានជោគជាដើម ដែលប្រើក្នុងកាលបានត្រាស់ដឹងហើយ ទាំងក្នុងកាលមុនត្រាស់ដឹង ព្រោះជាឧបចារវោហារសម្រាប់ហៅ ក្នុងព្រះសម្ពុទ្ធ ដូចជាក្នុងលោកដែលរស់នៅហើយ ដូចក្នុងពាក្យមានអាទិ៍ថា **អគមា រាជគហំ ពុទ្ធោ** ប្រែថា ព្រះសម្ពុទ្ធ ទ្រង់បានយាងដល់ក្រុងរាជគ្រឹះ ពិតហើយ ព្រះអរិយៈទាំងឡាយ មានព្រះសម្ពុទ្ធជាដើមនោះ រមែងចាក់ធ្លុះដោយមគ្គទាំង ៤ ដូច្នេះ ។ ក្នុងពាក្យថា **តស្មា អរិសច្ចានីតិ វុច្ចន្តិ** នេះ បណ្ឌិតគប្បីឃើញការលុបបទខាងចុង ព្រោះបទខាងដើមថា **អរិយបដិវិជ្ឈិតព្វានិ សច្ចានិ អរិយសច្ចានិ** ប្រែថា សច្ចៈទាំងឡាយ ដែលព្រះអរិយៈគប្បីចាក់ធ្លុះ ឈ្មោះថា **អរិយសច្ចានិ** ។ បទថា **តស្មា** សេចក្ដីថា ព្រោះព្រះតថាគតជាព្រះអរិយៈ ទើបលោកហៅថា អរិយសច្ច ព្រោះជាសច្ចៈរបស់ព្រះតថាគតនោះ ។ ពិតហើយ សច្ចៈទាំងនោះ រមែងជារបស់ព្រះតថាគតនោះ ព្រោះជាសច្ចៈដែលព្រះតថាគតទ្រង់បានត្រាស់ដឹងឯង ព្រោះជាសច្ចៈដែលព្រះតថាគតទ្រង់បានប្រកាសហើយ ព្រោះហេតុនោះឯង ទើបបុគ្គលដទៃគប្បីសម្រេចបាន ដូច្នេះ ។ ក្នុងបទថា **អរិយភាវសិទ្ធិតោបិ** នេះ ប្រែថា ព្រោះសម្រេចជាអរិយៈ បណ្ឌិតគប្បីឃើញការលុបបទខាងចុង ដូចក្នុងបទមុនថា **អរិយសាធកានិ សច្ចានិ អរិយសច្ចានិ** ប្រែថា សច្ចៈទាំងឡាយដែលញុំាងភាពជាអរិយៈឲ្យសម្រេច ឈ្មោះថា អរិយសច្ចានិ ។ ក្នុងពីរបទថា **អរិយានិ សច្ចានីតិបិ** នេះ ឈ្មោះថា **អរិយានិ** ព្រោះបុគ្គលគប្បីដល់ គឺគប្បីសម្រេចដោយភាវៈដែលពិត ម្យ៉ាងទៀត ឈ្មោះថា **អរិយៈ** គប្បីឃើញថា ជាពាក្យដែលជាប់មាត់ក្នុងការដែលមិនឃ្លៀងឃ្លាត គឺក្នុងភាពដែលពិត ។

ក្នុងពាក្យថា **មានការបៀតបៀនជាលក្ខណៈ** នេះ ជាទុក្ខពិត និងជានិមិត្តនៃទុក្ខពិតៗ នោះក្ដី ដែលត្រូវការកើតឡើង និងការវិនាសទៅ គ្របសង្កត់ដោយចំពោះក្ដី

ឈ្មោះថា **ការបៀតបៀន** ។ ការកើតនៃទុក្ខជាអនេកប្រការនោះឯងដោយអំណាចទុក្ខមានការកើតឡើងក្នុងកពជាដើម និងដោយអំណាចរោគ មានចក្ខុរោគជាដើម ឈ្មោះថា ការធ្វើបុគ្គលឲ្យក្តៅក្រហាយ ការធ្វើឲ្យក្តៅក្រហាយនោះជាកិច្ច គឺជារសនៃទុក្ខសច្ចនោះ ហេតុនោះ ទុក្ខសច្ចនោះ ឈ្មោះថា **មានការធ្វើឲ្យក្តៅក្រហាយជារស** ។ ទុក្ខសច្ចរមែងកាន់យកបាន ដោយជាធម្មជាតិប្រព្រឹត្តទៅក្នុងការកើត និងការរលត់ គឺក្នុងសង្សារវដ្ត និងវិមោក្ខ គឺនិព្វាន ព្រោះហេតុនោះ ទើបទុក្ខសច្ចនោះ ឈ្មោះថា **មានការប្រព្រឹត្តទៅជាបច្ចុប្បដ្ឋាន** ទុក្ខឈ្មោះថា **ជាការបន្តឲ្យកើត** ព្រោះអត្ថថា ទុក្ខរមែងបន្តឲ្យកើតឡើង គឺកើតឡើងអំពីសមុទយៈនេះ គឺទាក់ទងនឹងកពក្រោយភពមុនប្រព្រឹត្តទៅ ។ ការកើតឡើងរឿយៗ យ៉ាងនេះថា កាលតណ្ហានុស័យមិនទាន់បានដកឡើង ទុក្ខនេះក៏រមែងកើតឡើងរឿយៗ យ៉ាងនោះ ដូច្នេះ ឈ្មោះថា **ការធ្វើមិនឲ្យដាច់ខ្សែ** ។ ការហាមឃាត់ ការចេញទៅអំពីកព ឈ្មោះថា **បលិពោធ** ។ ធម្មជាតិស្ងប់ទុក្ខទាំងពួងដោយសភាវៈដែលជាទីអស់ទៅ នៃតណ្ហា ឈ្មោះថា **សន្តិ** ។ បទថា **អច្ចុតិ រសំ** ប្រែថា មានការមិនចុតិជាសម្បត្តិ ឬប្រែថា មានការមិនឃ្លាតជាកិច្ចក៏បាន ។ ពាក្យថា **កិច្ច** លោកពោលទុកដោយជាពាក្យបរិយាយ ព្រោះធ្វើការមិនមានការឃ្លាតឲ្យដូចជាកិច្ច និងការមិនឃ្លាតរបស់និរោធសច្ច ក៏គឺការមិនលះសភាវៈ គប្បីឃើញថា ជាការមិនប្រែប្រួល ។ និរោធសច្ចនោះ បណ្ឌិតគប្បីកាន់យកដោយជាធម្មជាតិមិនមានរូបរាង ព្រោះជាធម្មជាតិ ទទេអំពីនិមិត្ត គឺខន្ធ ៥ ព្រោះដូច្នោះ ទើបឈ្មោះថា **អនិមិត្តបច្ចុប្បដ្ឋានំ** ប្រែថា មានភាពជាធម្មជាតិមិនមាននិមិត្តជាបច្ចុប្បដ្ឋាន ។ ភាវៈដែលជាឧបាយចេញទៅអំពីគុក គឺសង្សារវដ្ត ដោយការកាត់អនុស័យបានជាសមុច្ឆេទ ឈ្មោះថា **និយ្យានំ** ប្រែថា ការចេញទៅ ។ ការកាត់កិលេសទាំងពួងមិនឲ្យកើតឡើង ឈ្មោះថា **កិលេសប្បហានករណំ** ប្រែថា ធ្វើការលះកិលេស ។

មគ្គសច្ចដែលបណ្ឌិត រមែងកាន់យកដោយជាធម្មជាតិចេញទៅនៃចិត្តអំពីនិមិត្ត និង អំពីបវត្ត ព្រោះដូច្នោះ មគ្គសច្ច ឈ្មោះថា **វុដ្ឋានបច្ចុប្បដ្ឋានំ** ប្រែថា មានការចេញទៅជាបច្ចុប្បដ្ឋាន ។

លោកពោលថា **កលមាយា** នោះ ជាការវិបរិតដែលមានសភាវៈជាវត្ថុថា វត្ថុមិនមែនជាមាសជាដើម សម្ដែងឲ្យឃើញថា ដូចជាមាសជាដើម ចំណែក **ថ្ងៃបណ្ដើរកូន** សម្លឹងឃើញដូចទឹក តែកាលចូលទៅជិត ក៏ជារបស់ទទេ ។ សូម្បីតែវត្ថុ គឺទីតាំងរបស់ថ្ងៃបណ្ដើរកូននោះ ក៏មើលមិនឃើញ ព្រោះដូច្នោះ ទើបលោកពោល **ថ្ងៃបណ្ដើរកូនថាជារបស់បោកបញ្ឆោត** ភាវៈដែលផ្ទុយគ្នាអំពីថ្ងៃបណ្ដើរកូន កលមាយា អត្ថា ឈ្មោះថា **ជាភាវៈដែលមិនវិបរិត និងជាការពិត** ។ ពាក្យថា **នៃអរិយញ្ញាណ** គឺនៃញាណដែលជាអរិយៈ ដែលបានដល់ប្រកាន់យកសភាវៈដែលពិត ដោយពាក្យនោះរមែងកាន់យកបច្ចវេក្ខណញ្ញាណក៏ដូចជាបដិវេធញ្ញាណផងដែរ បណ្ឌិតគប្បីឃើញសច្ចៈទាំងនោះជាគោចរ និងជាអារម្មណ៍ថា ជាធម៌ដែលគប្បីចាក់ធ្លុះ ។ **លក្ខណៈរបស់ភ្លើង គឺក្ដៅ** ។ ពិតហើយ លក្ខណៈរបស់ភ្លើងនោះ ទោះនៅទីណា កាលមានពូជ ដូចជាឧសជាដើមនៅជាមួយ នឹងមិនជាវត្ថុដែលកន្លង មិនជាវត្ថុដែលមិនវិបរិត ឬមិនជាការពិតក្នុងកាលណាមួយទៅបានឡើយ ។ ធម្មជាតិដែលមានការកើតជាដើម ដែលត្រាស់ទុកដូច្នេះថា សត្វទាំងឡាយ មានការកើតជាធម្មតា មានការចាស់ជាធម្មតា ឬមានការស្លាប់ជាធម្មតា ដូច្នេះ ឈ្មោះថា **ប្រក្រតីរបស់លោក** ។ លោកអាចារ្យទាំងឡាយពោលថា ធម្មជាតិមានអាទិ៍យ៉ាងនេះថា សត្វតិរច្ឆានពួកខ្លះ មានសភាពវែងទៅតាមទទឹង សត្វទាំងឡាយ មានមនុស្សជាដើម មានសភាពវែងទៅតាមកម្ពស់ កាលធំចម្រើនក៏មិនរីកខ្លួនតទៅ ឈ្មោះថា **ប្រក្រតីរបស់លោក** ។ ក្នុងបណ្ដាសេចក្ដីពិត មិនវិបរិត ការពិត ភាវៈរឹងមាំ ជា **តថតា** ជាភាវៈដែលពិត ។ ភាវៈដំបូងជា **អវិតថតា**

ប្រែថា មិនកុហក ភាវៈ កណ្តាលជា **អនញ្ញថតា** ប្រែថា មិនជាដទៃ ព្រោះដូច្នោះ ទើបនេះជាការបែកផ្សេងគ្នារបស់ពាក្យទាំងនេះ ។

មានពាក្យសួរជ្រៀតចូលមកថា ព្រោះហេតុអ្វី ទើបលោកអាចារ្យពោលថា **វត្ថុដទៃក្រៅអំពីទុក្ខបៀតបៀនមិនមាន** សូម្បីតណ្ហាក៏ជាគ្រឿងបៀតបៀន ព្រោះជាហេតុនៃទុក្ខ ដូចជាជាតិមិនមែនឬ ? ឆ្លើយថា មិនមែន ព្រោះតណ្ហា លោកកាន់យកទុកមួយផ្នែក ដោយជាដែនកើតនៃទុក្ខដែលជាគ្រឿងបៀតបៀន ។ ការប្រព្រឹត្តទៅ និងហេតុនៃការប្រព្រឹត្តទៅ រមែងត្រូវលោកធ្វើឲ្យយល់ដោយមិនច្រឡំ ដោយអាការយ៉ាងនេះ ។ ន័យម្យ៉ាងទៀត ទីតាំងនៃទុក្ខ ដូចជាជាតិជាដើម ជាទុក្ខពិត ជាការបៀតបៀន មិនមែនជាដែនកើតនៃទុក្ខ ព្រោះដូច្នោះ កាលតណ្ហាលោកកាន់យកទុកមួយផ្នែកដោយជាដែនកើត ក៏មិនមានការទាក់ទង និងការបៀតបៀន ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា វត្ថុដទៃដែលបៀតបៀនក្រៅអំពីទុក្ខមិនមាន ។ បទថា **ពាធកត្តនិយាមេន** សេចក្តីថា ដោយការហាមឃាត់នូវធម្មជាតិដែលបៀតបៀននោះ ដោយប្រការទាំង ២ យ៉ាង គឺទុក្ខជាគ្រឿងបៀតបៀនប៉ុណ្ណោះ ទុក្ខប៉ុណ្ណោះជាគ្រឿងបៀតបៀន ។ បទថា **ពាធកត្តនិយាមេន** ប្រែថា ដោយភាពពិតប្រាកដនៃទុក្ខ និងជាគ្រឿងបៀតបៀន និងដោយភាពពិតប្រាកដ ក្នុងភាពដែលទុក្ខជាគ្រឿងបៀតបៀន ។ ភាពដែលទុក្ខជាធម្មជាតិដែលកំណត់ពិតប្រាកដ ជាធម្មជាតិដែលបៀតបៀន ក៏ដូចគ្នា នឹងជាធម្មជាតិដែលបៀតបៀន ជាធម្មជាតិដែលពិតប្រាកដក្នុងទុក្ខ ។

ពាក្យថា **វៀរតណ្ហានោះ ទុក្ខនឹងកើតអំពីវត្ថុដទៃមិនមាន** សេចក្តីថា សូម្បីកាលកិលេសដ៏សេស អកុសលធម៌ និងកុសលមូល ដែលមានអាសវៈដ៏សេស កុសលធម៌ ដែលមានអាសវៈដ៏សេសជាហេតុនៃទុក្ខមាន វៀរចាកតណ្ហាហើយ ធម៌ទាំងនោះនឹងជាហេតុនៃទុក្ខមិនមាន សូម្បីវៀរចាកធម៌ទាំងនេះ តណ្ហាជាហេតុនៃទុក្ខ

ក៏មាន ព្រោះវៀរចាកកុសល វៀរចាកអកុសល ចាកកុសល មានរូបាវចរជាដើម និងចាកធម៌ដែលជាកាមាវចរជាដើម តណ្ហាក៏ញ៉ាំងទុក្ខឲ្យកើតឡើងបាន ។ សេចក្តីពិតប្រាកដនៃធម្មជាតិស្ងប់ឬក្នុងភាពជាធម្មជាតិស្ងប់ឈ្មោះថា សេចក្តីពិតជាធម្មជាតិស្ងប់ **ដោយសេចក្តីពិតថា ជាធម្មជាតិស្ងប់នោះ** ។ ពាក្យថា **ព្រោះជាធម៌នាំចេញទៅដោយពិត** មានន័យថា មគ្គនេះជាធម៌នាំចេញទៅដោយពិត ដោយសច្ចៈទាំង ២ ប្រការ មិនមែនមិនពិត ព្រោះជាការវិបរិត ដូចជាផ្លូវខុស ឬមិនមែនមិនពិត ព្រោះមិនបានជាធម៌ដែលប្រព្រឹត្តទៅដោយចំណែកមួយ ដូចជាផ្លូវ ដែលជាលោកិយ ព្រោះដូច្នោះ ធម៌ជាគ្រឿងនាំចេញទៅតាមពិត ក៏បានដល់មគ្គ ភាវៈរបស់មគ្គនោះ ឈ្មោះថា គ្រឿងនាំចេញទៅដោយពិត ព្រោះជាធម៌នាំចេញទៅ យ៉ាងពិតនោះ ។ ក្នុងសច្ចៈគ្រប់ប្រការលោកអាចារ្យពោលថា ជាធម៌ពិតមិនឃ្លៀងឃ្លាត និងជាការពិត ដោយកំណត់ទាំង ២ ប្រការ ដូច្នោះ ទើបលោកអាចារ្យពោលថា **ព្រោះសេចក្តីពិតមិនឃ្លៀងឃ្លាត ដោយប្រការដូច្នេះ** ជាដើម ។

ការលើកអត្ថដែលមានរបស់ **សច្ច-ស័ព្ទ** ឬការពោលអត្ថដែលមាន ហើយលើកឡើង គឺពង្រីកអត្ថដែលបំណងចេញទៅ ឈ្មោះថា **អត្ថុទ្ធារោ** ប្រែថា ការលើកអត្ថឡើង ឬការពង្រីកអត្ថចេញទៅ ។ ពាក្យថា **ក្នុងវិរតិសច្ច** បានដល់ ក្នុងការវៀរចាកការពោលកុហក ។ ព្រោះថា **សច្ច-ស័ព្ទ** មិនជាពាក្យជាប់មាត់ក្នុងវិរតិដទៃៗឡើយ ។ ចំណែកអាចារ្យពួកណាពោលថា **វិរតិសច្ច** បានដល់ **សមាទានវិរតិ** វិរតិសច្ចៈរបស់លោកអាចារ្យទាំងនោះ មិនមែនគ្រាន់តែជាសមាទាននោះឡើយ ដោយពិតជាសច្ចៈដែលធ្វើការសមាទានមិនឲ្យឃ្លៀងឃ្លាត ។ ម្យ៉ាងទៀត វិរតិសច្ចៈនោះ បានដល់សច្ចៈតាមបដិញ្ញា ជាការវៀរចាកការពោលកុហកនោះឯង ។ ទិដ្ឋិដែលប្រព្រឹត្តទៅថា នេះប៉ុណ្ណោះពិត ដទៃមិនពិត ឈ្មោះថា **ទិដ្ឋិសច្ចៈ** ព្រោះប្រព្រឹត្តទៅដោយការប្រកាន់មាំ

ថា ពិត ។ និព្វានឈ្មោះថា **បរមត្ថសច្ចៈ** ព្រោះជាធម៌ដែលមិនកុហក សេចក្តីនេះ សមដូចព្រះបាលីដែលត្រាស់ទុកថា **អមោសធម្មំ និព្វានំ តំ អរិយា សច្ចតោ វិទូ** ប្រែថា និព្វានជាធម៌ដែលមិនកុហក ព្រះអរិយៈទាំងឡាយដឹងនិព្វាននោះថា ជាសេចក្តីពិតដូច្នេះ ម្យ៉ាងទៀត ការដឹងច្បាស់ គឺការបាក់ធ្លុះនូវនិព្វាននោះ និងនូវមគ្គដែលញ៉ាំងនិព្វាននោះឲ្យដល់ព្រម ជាហេតុនៃការមិនជំទាស់គ្នា ព្រោះដូច្នោះ និព្វាន និងមគ្គទាំង ២ ទើបព្រះមានព្រះភាគត្រាស់ថា **សច្ចៈ** ដោយព្រះគាថានេះថា **ឯកំ ហិ សច្ចំ ន ទុតិយមត្ថិ យស្មិំ បជា នោ វិវទេ បជានំ** ប្រែថា សច្ចៈមានម្យ៉ាង មិនមានពីរ ដែលបុគ្គលដឹងច្បាស់ មិនជំទាស់គ្នា ។

ដោយពាក្យថា គប្បីមានសមណៈ ឬព្រាហ្មណ៍មកពោលថា នេះមិនមែនទុក្ខអរិយសច្ច នេះមិនមែនឋានៈដែលនឹងមានបាន នេះព្រះមានព្រះភាគទ្រង់សម្តែងថា ទុក្ខ មានជាតិជាដើមជារបស់ ( ពិត ) មិនខុស ក្នុងប្រការដែលនឹងចាត់ជាទុក្ខអរិយសច្ច ព្រោះមានតែបៀតបៀនដោយចំណែកមួយប៉ុណ្ណោះ ។ ដោយពាក្យថា សមណៈ ឬព្រាហ្មណ៍គប្បីមកពោលថា ទុក្ខអរិយសច្ចដទៃគប្បីមាន នេះក៏មិនមែនឋានៈដែលនឹងមានបាន នេះព្រះមានព្រះភាគទ្រង់សម្តែងថា ទុក្ខអរិយសច្ចជាវត្ថុដែលពិតប្រាកដ ទៀងពិត ក្នុងកាលមានជាតិជាដើម ព្រោះជាតិជាដើម មិនមានក្នុងធម៌ដទៃ គឺសមុទយៈ និរោធ មគ្គ ព្រោះចាត់ចូលក្នុងទុក្ខអរិយសច្ចប៉ុណ្ណោះ ។ ព្រះមុនីត្រាស់ពាក្យថា **បើមានសមណៈ ឬព្រាហ្មណ៍មកពោលថា យើងនឹងលើកទុក្ខអរិយសច្ចប្រការនេះទុកសិន ហើយបញ្ញត្តទុក្ខអរិយសច្ចប្រការទី ១ ដទៃៗ នេះក៏មិនមែនឋានៈនឹងមានបាន** ដើម្បីសម្តែងថា សូម្បីបុគ្គលណាមួយ គប្បីមានការគិតយ៉ាងនេះបាននោះ ក៏មិនមានបុគ្គលអាចក្នុងការបញ្ញត្ត គឺនឹងឲ្យបុគ្គលណាមួយទទួលដឹងជាមួយផង គឺឲ្យទទួលវាទៈរបស់ខ្លួនបាន ។ ធម៌មានជាតិជាដើមមិនជាដទៃ អរិយសច្ច

ដទៃយ៉ាងនោះក៏មិនមានឡើយ ( ក្នុងប្រការដែលនឹងបញ្ញត្តអរិយសច្ចទី ១ ឲ្យទៅជាដទៃក្រៅអំពីទុក្ខអរិយសច្ច ) នេះ ជាការប្រព្រឹត្តទៅមិនបាននោះឯង ។ អត្ថរបស់ព្រះសូត្រក្នុងប្រការនេះ ដូច្នេះថា ប្រសិនបើបុគ្គលណាមកពោលក៏ចូរមកចុះ ក៏មិនមានឋានៈដែលប្រព្រឹត្តទៅបាន ។ ក្នុងព្រះសូត្រទី ២ ក៏មានន័យនេះដូចគ្នា ។ ក្នុងព្រះសូត្រទី ២ នោះ អធិប្បាយថា សត្វទាំងឡាយបានដល់នូវធម៌ មានជាតិជាដើម និងការមានចំពោះ រមែងមានបានដោយការបានអត្តភាពនោះឯង ព្រោះដូច្នោះ គប្បីឃើញថា ការដល់ព្រមនិងការប្រចក្សជាអរិយសច្ចប្រការទី ១ ព្រោះអរិយសច្ចនោះ ព្រះមានព្រះភាគទ្រង់សម្ដែងប្រការដំបូង ហេតុនៃធម៌ មានជាតិជាដើម ជាអរិយសច្ចប្រការទី ២ ការចូលទៅស្ងប់ធម៌ មានជាតិជាដើមនោះ ជាអរិយសច្ចប្រការទី ៣ ធម៌ដែលធ្វើឲ្យដល់នូវសេចក្ដីស្ងប់ធម៌ មានជាតិជាដើមនោះ ជាអរិយសច្ចប្រការទី ៤ ។ ដោយបទថា **ឯតបរមតោ** ដែលប្រែថា មានប្រការក្រៃលែងយ៉ាងនេះ លោកអាចារ្យពោលដល់ការកំណត់ដែលកាន់យកមិនមានសេសសល់នៃបវត្តិជាដើម ដោយអរិយសច្ចទាំង ៤ ។ ព្រះមានព្រះភាគត្រាស់អរិយសច្ចទុក៤ ប្រការប៉ុណ្ណោះ ព្រោះកិច្ចណាៗ ដទៃអំពីកិច្ច មានការកំណត់ដឹងជាដើមដែលបុគ្គលប្រាថ្នាព្រះនិព្វាន នឹងគប្បីធ្វើមិនមាន ម្យ៉ាងទៀត កិច្ច គឺការដឹងធម៌ដទៃអំពីកិច្ច មានការកំណត់ដឹងជាដើមនេះក៏មិនមាន ហើយអរិយសច្ច មានទុក្ខដែលគប្បីកំណត់ដឹងជាដើម ក៏មានកិច្ច គឺការកំណត់ដឹងជាដើមនេះ យ៉ាងក្រៃលែងនោះឯង ។ លោកអាចារ្យពោលថា ព្រោះវត្ថុនៃតណ្ហាជាដើម មានប្រការនេះយ៉ាងក្រៃលែង ដោយអំណាចនៃបុគ្គលដែលឃើញទោសរបស់តណ្ហា ។ ម្យ៉ាងទៀត លោកអាចារ្យពោលថា ព្រោះការអាល័យជាដើម មានប្រការនេះយ៉ាងក្រៃលែងដោយអំណាចនៃបុគ្គល ដែលឃើញទោសក្នុងសេចក្ដីអាល័យ គឺក្នុងទុក្ខ ពោល គឺកាមគុណ ៥ ពោល គឺវត្ថុកាមទាំងអស់ ឬពោល គឺវត្ថុកាមកត

ទាំង ៣ ។

ពាក្យថា **ព្រោះជារបស់គ្រោតគ្រាត** នេះ លោកអាចារ្យពោលសំដៅយកត្រឹមតែការៈរបស់ធម៌ មានជាតិជាដើមជាទុក្ខ ជាវត្ថុដែលប្រាកដដល់ជនច្រើន មិនបានពោលសំដៅដល់អារម្មណ៍ ដែលព្រះអរិយៈគប្បីចាក់ធ្លុះដោយញាណ ។ បទថា **តំ យោគ ទុក្ខំ** ប្រែថា ទុក្ខនោះ ពាក្យថា **តណ្ហាមិនបានតាក់តែងឡើង** គឺមិនបានធ្វើឲ្យកើតឡើង អធិប្បាយថា មិនបានមានហេតុដែលតណ្ហាធ្វើឲ្យសម្រេចហើយ ។ ពិតហើយ កាលហេតុសម្រេចហើយ ផលក៏រមែងសម្រេចហើយដែរនោះឯង ។

ដោយពាក្យថា **ទុក្ខដែលតណ្ហាមិនបានតាក់តែងឡើងក៏មិនកើតឡើង** នេះ លោកអាចារ្យបដិសេធអហេតុកវាទ ( គឺលទ្ធិដែលប្រកាន់ថា មិនមានហេតុ ) ។ ដោយពាក្យថា **មានឡើងព្រោះហេតុខាងក្រៅ មានព្រះឥស្សរជប់ជាដើមក៏ទេ** នេះ លោកអាចារ្យរមែងបដិសេធវាទៈ គឺលទ្ធិ មានលទ្ធិបជាបតីជាធំក្រៃលែងរបស់ពួកសត្វ លទ្ធិបុរស លទ្ធិបកតិ និងលទ្ធិកលៈជាដើម ។ ពាក្យណាដែលគួរពោលក្នុងអធិការនេះ ពាក្យនោះមានច្បាស់ខាងមុខ ។ ដោយពាក្យថា **ត្រូវទុក្ខព្រមទាំងហេតុ** នេះ លោកអាចារ្យពោលបន្ថែមការសង្វេគដែលកើតឡើងព្រោះឃើញទុក្ខ ។ ពិតហើយ ការសង្វេគដ៏ខ្លាំងរមែងកើត ព្រោះបានស្តាប់ភាពដែលទុក្ខប្រកបទៅ ដោយហេតុថា ហេតុនេះមានដរាបណា ទុក្ខនេះក៏ប្រព្រឹត្តទៅដោយមិនដាច់ខ្សែដរាបនោះ ។ ពាក្យថា **ត្រាស់និរោធដើម្បីញុំាងការល្ហួងលោមចិត្តឲ្យកើត** សេចក្តីថា ព្រះមានព្រះភាគត្រាស់និរោធសច្ច ដើម្បីញុំាងការល្ហួងលោមចិត្តឲ្យកើតដល់បុគ្គល ដែលសង្វេគហើយ ។ ពិតហើយ និរោធកថា ដែលព្រះមានព្រះភាគសម្តែងដល់បុគ្គល ដែលមានទុក្ខក្នុងសង្សារវដ្តនឿយណាយហើយ រមែងញុំាងភាពល្ហួងលោមចិត្តឲ្យកើតហួសនឹងប្រៀបបាន ។ ក្អាប់សេចក្តីព្រះបាលីថា **យេ តេ ជាតិ អាទយោ ធម្មា ភគវតា វុត្តា** ប្រែថា

ធម៌មានជាតិជាដើមនោះ ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ មានពាក្យសួរថា ក្នុងធម៌ទាំងនេះ ព្រោះហេតុអ្វី ទើបទ្រង់មិនកាន់យកព្យាធិ ? ឆ្លើយថា ព្រោះព្យាធិជាអនេកន្តធម៌ គឺមិនពិតប្រាកដ ។ ពិតហើយ ព្យាធិនោះ កាលខ្លះក៏មិនមានសម្រាប់បុគ្គលពួកខ្លះក៏មិនមាន ។ ដូចដែលត្រាស់ទុកថា **រោគ ៣ យ៉ាងបានមានហើយ គឺការប្រាថ្នា ១ ការឃ្លាន ១ ការចាស់ ១** ។ បុគ្គលមានព្រះពាកុលត្ថេរ ជាដើមក៏មិនមានព្យាធិនោះឡើយ ប្រការមួយទៀត គប្បីឃើញថា ទ្រង់កាន់យកព្យាធិទុកក្នុងទីនេះដូចគ្នា ដោយស័ព្ទថា **ទុក្ខ** ។ ពិតហើយ ពោលដោយបរមត្ថ ទុក្ខផ្លូវកាយដែលមានការកម្រើកនៃធាតុជាបច្ច័យ ឈ្មោះថា **ព្យាធិ** ។ លោកអាចារ្យពោលថា **ធម៌ ១២ យ៉ាង** ព្រោះចាត់ឧបាទានក្ខន្ធ ៥ ជាចំណែក ១ ។ តណ្ហាដែលលោកប្រកាន់ទុកដោយរូប ១ ព្រោះរួមជាពួក ១ ទុក ដោយជាកាមតណ្ហាស្មើគ្នា មិនបានពឹងផ្អែកដល់ប្រភេទធម៌ដែលចាត់នៅខាងក្នុងដទៃថា **ទុក្ខសមុទយអរិយសច្ច** លោកក៏ពោលចែកទុកជា ៣ យ៉ាង គឺតណ្ហាដែលសហគតៈដោយសស្សតទិដ្ឋិ ១ ដែលសហគតៈដោយឧច្ឆេទទិដ្ឋិ និងដែលវៀរចាកទិដ្ឋិ ១ ការពេញចិត្តក្នុងកាមតែម្យ៉ាង ១ ។ លោកអាចារ្យពោលថា **ធម៌ ៨ យ៉ាង** ដូច្នេះ ព្រោះធម៌ទាំងនោះ សូម្បីពោលរួមទុកដោយជាមគ្គសច្ចថា **នេះឯងអរិយមគ្គមានអង្គ ៨** ក៏នៅចែកដោយសភាវៈ ។

# វិសុទ្ធិមគ្គ

## ទុក្ខនិទ្ទេស

### វិនិច្ឆ័យស័ព្ទថា ជាតិ

*វិនិច្ឆ័យក្នុងទុក្ខធម៌ទាំងឡាយ មានជាតិជាដើមនេះ បណ្ឌិតគប្បីជ្រាបដូចតទៅ វិនិច្ឆ័យនេះដូចម្តេច ?*

*ស័ព្ទថា ជាតិនេះ មានអត្ថច្រើនយ៉ាង ពិតយ៉ាងនោះ ស័ព្ទថា ជាតិនោះ ក្នុងពាក្យថា រឭកជាតិបាន ១ ជាតិ ២ ជាតិក៏មាន ជាដើមនេះ មកក្នុង ( អត្ថ គឺ ) ភព ក្នុងពាក្យថា ម្នាលវិសាខា សមណជាតិឈ្មោះនិគណ្ឋនាថ នេះមកក្នុងអត្ថ គឺនិកាយ ( ពួក ) ក្នុងពាក្យថា ជាតិសង្គ្រោះចូលជាមួយខន្ធ ២ នេះ មកក្នុងអត្ថ គឺ* ***សង្ខតលក្ខណំ*** *ក្នុងពាក្យថា ចិត្តដួងដំបូងកើតឡើង វិញ្ញាណដួងដំបូងប្រាកដឡើង ក្នុងផ្ទៃរបស់មាតាយ៉ាងណា ជាតិនោះឯង អាស្រ័យចិត្តដួងដំបូងនោះ ទើបមាន នេះមកក្នុងអត្ថ គឺបដិសន្ធិ ក្នុងពាក្យថា ម្នាលអានន្ទ ដែលថាព្រះពោធិសត្វ ជាតិ នេះមកក្នុងអត្ថ គឺប្រសូត ក្នុងពាក្យថា ជាអ្នកមិនត្រូវជំទាស់ មិនត្រូវតិះដៀលដោយជាតិវាទ ( ពាក្យប្រារព្ធជាតិ ) នេះមកក្នុងអត្ថ គឺត្រកូល ក្នុងពាក្យថា ម្នាលប្អូនស្រី អាត្មា កើតហើយដោយជាតិជាអរិយៈ ក្នុងកាលណា នេះមកក្នុងអត្ថ គឺអរិយសីល*

*ស័ព្ទថា ជាតិនេះ ក្នុងទីនេះ គប្បីឃើញថា មកក្នុងខន្ធទាំងឡាយដែលប្រព្រឹត្តទៅ តាំងពីបដិសន្ធិ រហូតប្រសូតចាកគភ៌មាតា សម្រាប់សត្វជំពូកដែលអាស្រ័យនៅក្នុងគភ៌ ( គឺអណ្ឌជៈ និងជលាពុជៈ ) មកក្នុងបដិសន្ធិក្ខន្ធទាំងឡាយប៉ុណ្ណោះ សម្រាប់សត្វជំពូកក្រៅពីនេះ(គឺសំសេទជៈ និងឱបបាតិកៈ) សូម្បីវិនិច្ឆ័យកថា ដែលពោលមកនេះក៏នៅជាបរិយាយកថា ( ពោលដោយអម ) នៅឡើយ បើពោលដោយនិប្បរិយាយ*

( ដោយត្រង់ ) ខន្ធទាំងឡាយណាមួយ ប្រាកដឡើងដល់សត្វទាំងឡាយ ដែលកើតក្នុងភពនោះៗ ការប្រាកដឡើងគ្រាដំបូងនៃខន្ធនោះៗ ឈ្មោះថា **ជាតិ** ។

ជាតិនោះ មានការកើតគ្រាដំបូងក្នុងភពនោះៗ ជាលក្ខណៈ មានការប្រគល់ឲ្យជារស មានការកើតឡើងក្នុងភពនេះចាកអតីតភពជាបច្ចុប្បដ្ឋាន ន័យម្យ៉ាងទៀតមានការវិចិត្រទៅដោយទុក្ខជាបច្ចុប្បដ្ឋាន ។

## ជាតិទុក្ខ

ពាក្យសួរគប្បីមានថា ហេតុដូចម្ដេច ទើបជាតិជាទុក្ខ ដូច្នេះសោត ? ពាក្យឆ្លើយគប្បីមានថា ព្រោះភាពជាវត្ថុ ( គឺជាឫសគល់ ឬជាទីតាំង ) របស់ទុក្ខជាអនេកពិតហើយ ទុក្ខទាំងឡាយមានជាអនេក ដូចម្ដេចខ្លះ ? ដូចទុក្ខទុក្ខ វិបរិណាមទុក្ខ សង្ខារទុក្ខ បដិច្ឆន្នទុក្ខ អប្បដិច្ឆន្នទុក្ខ បរិយាយទុក្ខ និប្បរិយាយទុក្ខ ។

ក្នុងទុក្ខទាំងនោះ ទុក្ខវេទនាតាមផ្លូវកាយ និងតាមផ្លូវចិត្ត ហៅថា ទុក្ខទុក្ខ ព្រោះជាទុក្ខទាំងដែលជាសភាវៈ និងដោយឈ្មោះ សុខវេទនា ហៅថា វិបរិណាមទុក្ខ ព្រោះជាហេតុកើតទុក្ខដោយភាពប្រែប្រួលទៅ ឧបេក្ខាវេទនា និងសង្ខារទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេស ហៅថា សង្ខារទុក្ខ ព្រោះត្រូវការកើតឡើង និងការវិនាសទៅបៀតបៀន ភាពឈឺចាប់ទាំងតាមផ្លូវកាយ និងតាមផ្លូវចិត្ត មានត្រចៀកឈ្មោះ និងភាពក្រហល់ក្រហាយកើតអំពីរាគៈ ភាពក្ដៅក្រហាយកើតអំពីទោសៈជាដើមហៅបដិច្ឆន្នទុក្ខ ព្រោះត្រូវសួរ ទើបដឹង និងព្រោះការមិនប្រាកដ ការធ្វើ ការឈឺចាប់មានទុត្តឹសកម្មករណៈ ( ការដាក់អាជ្ញា ៣២ ប្រការ ) ជាដើមជាសមុដ្ឋាន ហៅថាអប្បដិច្ឆន្នទុក្ខ ព្រោះមិនបាច់សួរក៏ដឹង និងព្រោះការប្រាកដការធ្វើផង វៀរទុក្ខចេញទុក្ខដ៏សេសមានជាតិជាដើម ដែលមកក្នុងវិភង្គនៃទុក្ខសច្ចទាំងអស់ ហៅថា បរិយាយទុក្ខ ព្រោះជាវត្ថុនៃទុក្ខនោះៗ ចំណែកទុក្ខទុក្ខ ហៅថា និប្បរិយាយទុក្ខ ។

## គព្ភោក្កន្តិមូលកទុក្ខ

ក្នុងទុក្ខទាំងនោះ ជាតិចាត់ជាទុក្ខ ព្រោះជាវត្ថុនៃទុក្ខមានក្នុងអបាយ ដែលព្រះមានព្រះភាគ ទ្រង់ក៏បានប្រកាសទុកក្នុងព្រះសូត្រទាំងឡាយ មានពាលបណ្ឌិតសូត្រជាដើម ដោយជាសេចក្តីឧបមា ( មានឧបមាដោយរណ្តៅរងើកភ្លើងជាដើម ) នៃទុក្ខដែលផ្សេងដោយទុក្ខ មានការចុះកាន់កគ៌ជាមូលជាដើមក្នុងមនុស្សលោក ដែលកើតឡើងក្នុងសុគតិ ។

ក្នុងទុក្ខទាំងនោះ ( តទៅ ) នេះ ជាទុក្ខដែលផ្សេងដោយទុក្ខ មានការចុះកាន់កគ៌ជាមូលជាដើម ។

សត្វនេះ កាលកើតក្នុងផ្ទៃមាតា ក៏មិនមែនកើតក្នុងត្របកផ្កា មានឧប្បលបទុមនិងបុណ្ឌរិកជាដើមទេ ដែលពិត រមែងកើតក្នុងកុច្ឆិប្រទេស ( ចំណែកមួយរបស់ផ្ទៃ ) ក្រោមក្រពះអាហារថ្មី សង្កត់លើក្រពះអាហារចាស់ កណ្តាលនៃផ្ទៃ និងឆ្អឹងខ្នងជាទីចង្អៀតយ៉ាងក្រៃលែង ងងឹតស្លុប ជ្រាបដោយក្លិន ដែលស្អុយក្រៃលែង នូវក្លិនសាកសពសត្វ ( ដែលលេបចូលទៅ ) ផ្សេងៗ ធ្វើឲ្យកើតឡើង គួរខ្ពើមរអើម ក្រៃពេកដូចសត្វដង្កូវកើតនៅក្នុងត្រីស្អុយ នំផ្អូម និងរណ្តៅទឹកជ្រាំជាដើម ដូច្នោះ សត្វដែលកើតនៅក្នុងផ្ទៃមាតានោះ ក្តៅធំ ដោយសម្ភវៈ ( ទឹកកំណើត ទឹកចិញ្ចឹម) ក្នុងផ្ទៃរបស់មាតា ស្មើនឹងត្រូវស្ងោរដូចបុដបាកៈ ( នំអន្សម ) ស្មើនឹងត្រូវចំហុយ ដូចបិដ្ឋបិណ្ឌិ ( នំដុំម្សៅ ) ប្រាសចាកការកម្រើកកាយ មានបត់លា ( អវយវៈ ) ជាដើម សោយទុក្ខធ្ងន់ នៅរហូតទសមាស នេះឯងជាគព្ភោក្កន្តិមូលកទុក្ខ ( ទុក្ខ មានការចុះកាន់គភ៌ជាមូល ) ដែលជាលំដាប់ដំបូង ។

## គព្ភបរិហារណមូលកទុក្ខ

ម្យ៉ាងទៀត សត្វនោះបានសោយទុក្ខដ៏ពន្លឹក ព្រោះការរអិលដួល ការដើរ ការអង្គុយចុះ ការក្រោកឡើង និងការប្រាសខ្លួនដោយរហ័សរបស់មាតាជាដើម ( ក្តី ) ព្រោះការធ្វើ (របស់អ្នកដទៃ) មានការទាញកន្ត្រាក់ ត្រដុស ការទន្លិច និងការប្រានជាដើម ដូចកូនចៀមនៅក្នុងដៃអ្នកលេងសុរា និងដូចកូនពស់នៅក្នុងដៃ គ្រូពស់ ( ក្តី ) ម្យ៉ាងទៀត សត្វនោះបានសោយទុក្ខខ្លាំងក្លា ក្នុងវេលាដែលមាតាផឹកទឹកត្រជាក់ ដូចជាសត្វដែលធ្លាក់នរករងាក្នុងវេលាដែលមាតាហុតបបរ និងបាយក្តៅចូលទៅ ដូចត្រូវព្រាចគ្រាប់ភ្លៀងរងើកភ្លើង ក្នុងវេលាមាតាលេបអាហារសប្រៃខ្លាំង និងជូរជាដើមចូលទៅ ដូចបានទទួលការដាក់ទោស មានវិធីខារាវតច្ឆិក ( ចិញ្ច្រាំរាងកាយ ហើយជះដោយទឹកក្រូត) ជាដើម ទុក្ខនេះជាគព្ភបរិហារណមូលកទុក្ខ (ទុក្ខមានការបរិហារគភ៌ជាមូល ) ។

## គព្ភវិបត្តិមូលកទុក្ខ

ម្យ៉ាងទៀត ទុក្ខណាកើតឡើងដល់សត្វនោះ ព្រោះវេជ្ជកម្ម មានការកាត់ និងការវះជាដើម ត្រង់ទីដែលកើតទុក្ខ ( គឺស្បូន ) របស់មាតាដែលគភ៌វង្វេង ( គឺសម្រាលមិនរួច ) ដែលជាទីមិនគួរមើលសូម្បីនៃជនអ្នកស្និទ្ធស្នាល មានមិត្តសម្លាញ់ និងមនុស្សរាប់អានគ្នាជាដើម ទុក្ខនេះជាគព្ភវិបត្តិមូលកទុក្ខ ( ទុក្ខមានវិបត្តិជំទាស់នៃគភ៌ជាមូល ) ។

## វិជាយនមូលកទុក្ខ

( ប្រការមួយទៀត ) ទុក្ខដែលកើតឡើងដល់សត្វនោះ អ្នកត្រូវ ( ខ្យល់ ) កម្មជវាតរបស់មាតាកាលនឹងប្រសូត បក់ផាត់ (ក្បាល) ឲ្យត្រឡប់ចុះត្រង់ចន្លោះ

ត្រង់ទ្វារប្រសូតដែលគួរខ្លាចក្រៃលែង ដូចប្រហោងជ្រោះ ត្រូវប្រជៀតចេញតាមទ្វារ ប្រសូតដែលចង្អៀតក្រៃលែង ដូចដំរីធំត្រូវចេញតាមប្រហោងរនុកទ្វារ និងត្រូវសង្កត់ ដោយក្នុំ គឺវទ្ធត ( ដើងប្រាន ) ដូចសត្វនរកត្រូវកិនដោយសង្ឃាតបព៌ត ទុក្ខនេះ ជាវិជាយនមូលកទុក្ខ ( ទុក្ខមានការប្រសូតជាមូល ) ។

## ពហិនិក្ខមនមូលកទុក្ខ

( ប្រការមួយទៀត ) ទុក្ខដូចជាការចាក់ និងពុះដោយចុងម្ជុល និងកាំបិតកោរ ដ៏មុត ក្នុងវេលាដែលគេទទួលដោយដៃឲ្យផូតទឹក លាង ( គព្ភមន្ទិល ) និងជូត ដោយ សំពត់ជាដើម កើតឡើងដល់សត្វអ្នកកើតហើយ ដែលមានរាងកាយនៅទន់ខ្ចី ដូច ដំបៅថ្មី ទុក្ខនេះជាមាតុកុច្ឆិតោ ពហិនិក្ខមនមូលកទុក្ខ ( ទុក្ខមានការចេញមកក្រៅ ផ្ទៃមាតាជាមូល ) ។

## អត្តុបក្កមមូលកទុក្ខ

( មួយប្រការទៀត ) ក្នុងកាលប្រព្រឹត្តតអំពីនោះទៅ ទុក្ខដែលកើតមានដល់ សត្វនោះ អ្នកធ្វើបាបខ្លួនឯងក្តី អ្នកប្រកបអាតាបនបរិតាបនានុយោគ ( ប្រកបការ ធ្វើបាបខ្លួនដើម្បីឆ្អើរកិលេស ) តាមទំនងវត្តរបស់តិរ្ថិយ មានអចេលកវត្ត ( វត្តរបស់ អ្នកអាក្រាត ) ជាដើមក្តី អ្នកមិនស៊ី ( អាហារ ) និងចង.កស្លាប់ ដោយអំណាច ការក្រោធក្តី ទុក្ខនេះជាអត្តុបក្កមមូលកទុក្ខ ( ទុក្ខមានការធ្វើខ្លួនឯងជាមូល ) ។

## បរុបក្កមមូលកទុក្ខ

ប្រការមួយទៀត ទុក្ខដែលកើតឡើងដល់សត្វនោះ អ្នកបានទទួលអំពើ មាន សម្លាប់និងចាប់ចងជាដើមអំពីអ្នកដទៃ ទុក្ខនេះជាបរុបក្កមមូលកទុក្ខ ( ទុក្ខមានការ

ត្រូវអ្នកដទៃបៀតបៀនជាមូល ) ។

## សរូបជាតិទុក្ខ

ជាតិនេះជាផែនដី ( ទីតាំង ) នៃទុក្ខទាំងពួង ដូចពោលមក ព្រោះហេតុនោះ ទើបអ្នកប្រាជ្ញពោលពាក្យប្រពន្ធនេះទុកថា

ជាយេថ នោ ចេ នរកេសុ សត្តោ

។បេ។

ទុក្ខាតិ សព្វបឋមំ ឥមមាហ ជាតឹ

បើសត្វមិនគប្បីកើតក្នុងនរកទាំងឡាយទេ គេក៏មិនគប្បីបានទទួលទុក្ខហួសទ្រាំ មានដុតដោយភ្លើងជាដើមក្នុងនរកនោះ ( បើមិនកើត ) ទុក្ខនឹងគប្បីបានទីតាំងពីណាមក ព្រោះហេតុនោះ ទើបព្រះមុនីត្រាស់ការកើតក្នុងនរកនេះថាជាទុក្ខ ។

ទុក្ខក្នុងពួកសត្វតិរច្ឆានជាច្រើន កើតព្រោះសម្លាប់ដោយខ្សែតី ជន្លួញ និងកំណាត់ឈើជាដើមណា ទុក្ខនោះវៀរការកើតក្នុងពួកតិរច្ឆាននោះ នឹងគប្បីមានដូចម្ដេច ហេតុដូច្នោះ ទើបសូម្បីការកើតក្នុងពួកតិរច្ឆាននោះជាទុក្ខ ។

ម្យ៉ាងទៀត ទុក្ខក្នុងពួកប្រេតច្រើនប្រភេទ កើតព្រោះការស្រេកឃ្លាន និងខ្យល់កម្ដៅថ្ងៃជាដើម រមែងមិនមានដល់សត្វអ្នកមិនកើតក្នុងពួកប្រេតនោះ ហេតុណា ព្រោះហេតុនោះ ទើបព្រះមុនីត្រាស់ការកើត ( ក្នុងពួកប្រេតនោះ ) ថាជាទុក្ខ ។

ម្យ៉ាងទៀត ទុក្ខណា ក្នុងពួកអសុរក្នុងលោកន្តរ ដែលជាទីងងឹតសូន្យឈឹង និងត្រជាក់ហួសទ្រាំ បើការកើតក្នុងលោកន្តរនោះមិនមានសោត ទុក្ខនោះក៏មិនគប្បី

មាន ដោយហេតុណា ព្រោះហេតុនោះ ទើបការកើតនេះជាទុក្ខ ។

ម្យ៉ាងទៀត សត្វអ្នកនៅក្នុងគភ៌មាតា ដែលដូចជាគូថនរក ជាវេលាយូរ និងចេញមកក្រៅគភ៌នោះ រមែងបានទទួលទុក្ខដ៏កាចសាហាវណា សូម្បីទុក្ខនេះ វៀរការកើតចេញក៏មិនមាន ហេតុដូច្នោះ ទើបការកើតនេះជាទុក្ខពិត ។

ត្រូវការអ្វីដែលនឹងពោលទៅច្រើន ទុក្ខណាសូម្បីតិចតួច មាននៅក្នុងទីណាមួយក្នុងលោកនេះក្តី ទុក្ខនេះព្រោះវៀរការកើតចេញ ក៏មិនមានក្នុងកាលណាឡើយ ហេតុណា ព្រោះហេតុនោះ ទើបព្រះមហាឥសីត្រាស់ការកើតនេះថា ជាទុក្ខមុន ទុក្ខទាំងពួង ។

នេះជាវិនិច្ឆ័យក្នុងជាតិលំដាប់ដំបូង ។

# មហាដីកា

## កថាពណ៌នាអំពីទុក្ខនិទ្ទេស

## ពណ៌នាជាតិនិទ្ទេស

*ពាក្យថា **ក្នុងភព** សេចក្តីថា ការបន្តគ្នានៃធម៌ដែលកំណត់ដោយការកើតដំបូង និងស្លាប់ជាទីបំផុត ឈ្មោះថា **ភព** ក្នុងភពនោះ ។ ពិតហើយ ភពនោះ ហៅថា ជាតិ ព្រោះជាទីកើតនៃការបែកកំណើត និងគតិជាដើម និកាយក៏ឈ្មោះថា **ជាតិ** ព្រោះជាទីកើតរបស់ពពួកសត្វដែលមានការប្រព្រឹត្តស្រដៀងៗគ្នា ។ពាក្យថា **ក្នុងសន្ធតលក្ខណៈ** បានដល់ ក្នុងការកើតឡើងឯណានីមួយ ។ ពិតហើយ ការកើតឡើងនោះក៏ឈ្មោះថា ជាតិ ព្រោះអត្ថថា ជាការកើត ។ ពាក្យថា **ក្នុងបដិសន្ធិ** បានដល់ ក្នុងខណៈនៃបដិសន្ធិចិត្ត ។ ក្នុងបទថា **សម្បតិជាតោ** នេះ លោកអាចារ្យពោលថា **ក្នុងការប្រសូតិ** សំដៅដល់អត្ថថា **កើត** ពោល គឺការចេញចាកផ្ទៃមាតា ដែលបានដោយជាតិ-ស័ព្ទ អធិប្បាយថា ក្នុងការកើតចំពោះមុខ ។ ត្រកូលក៏ឈ្មោះថា **ជាតិ** ព្រោះអត្ថថា ជាហេតុកើតនៃឈ្មោះ មានឈ្មោះថា ក្សត្រជាដើម ។*

*ឈ្មោះថា **សេយ្យា** ព្រោះអត្ថថា ទីដេក **គព្ភ** ពោល គឺពោះរបស់មាតាជាទីដេករបស់សត្វទាំងនេះ ហេតុនោះ ទើបសត្វទាំងនេះឈ្មោះថា **គព្ភសេយ្យកា** ប្រែថា មានគភ៌ជាទីដេក បានដល់ សត្វជំពូកអណ្ឌជៈ ពួកដែលកើតក្នុងស៊ុត និងជលាពុជៈ ពួកដែលកើតក្នុងស្បូន ។ បទថា **ឥតរេសំ យោគ សំសេទជានំ និង ឱបបាតិកានំ** ប្រែថា សម្រាប់សត្វពួកសំសេទជៈ ពួកដែលកើតក្នុងញើសក្អែល និងពពួកសត្វជាឱបបាតិកៈ ដែលផុសឡើងមួយរំពេចក្រៅអំពីនេះ បទថា **អយម្បិ ច** ប្រែថា កថាដែលពោលទុកក្នុងលំដាប់ថា ក្នុងបដិសន្ធិក្ខន្ធនោះឯង ក្នុងកថាដែលពោលថា តាំង*

អំពីបដិសន្ធិទៅ មិនចាំបាច់និយាយដល់ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ការប្រាកដដំបូងរបស់ខន្ធទាំងនោះ** ឈ្មោះថា **ជាតិ** ។

ជាតិណា ដែលបុគ្គលរមែងកាន់យក ដោយអំណាចការផុសឡើង ហេតុនោះ ជាតិនោះឈ្មោះថា **ឧម្មុជ្ជនបច្ចុប្បដ្ឋានា** ប្រែថា មានការផុសឡើងជាអាការប្រាកដ ។ ជាតិណារមែងញ៉ាំងធម្មជាតិមានការវិចិត្រទៅដោយទុក្ខ ដែលមានវិភាគ នឹងពោលដល់ឲ្យចូលទៅតាំងទុកចំពោះ ហេតុនោះ ជាតិនោះឈ្មោះថា **ទុក្ខវិចិត្តតាបច្ចុប្បដ្ឋានា** ប្រែថា មានធម្មជាតិវិចិត្រទៅដោយទុក្ខជាអាការប្រាកដ ។ លោកអាចារ្យអ្នកចោទពោលថា **ព្រោះហេតុអ្វី** មានបំណងដូច្នេះ ជាតិ គឺការកើតក្នុងនរកដែលជាទុក្ខដោយចំណែកមួយ ឬក្នុងទុគ្គតិទាំងឡាយដទៃ ព្រោះមានបាបកម្មជាសមុដ្ឋាន ប្រការដែលលើកទុកសិន តែជាតិ គឺការកើតក្នុងសុគតិទាំងឡាយដែលមានកម្មនឹងញ៉ាំងសុខឲ្យប្រព្រឹត្តទៅជាសមុដ្ឋានជាទុក្ខបានដូចម្តេច ? លោកអាចារ្យមួយពួកទៀត កាលសម្តែងថា ជាតិ គឺការកើតនេះ លោកហៅថា ទុក្ខ ដោយអំណាចនៃសភាវទុក្ខក៏ទេ ព្រោះថាបដិសន្ធិណាមួយ ដែលសម្បយុត្តដោយទុក្ខវេទនានឹងមានក៏ទេ ដោយពិត ជាតិ ឈ្មោះថា ជាទុក្ខ ព្រោះជាទីទទួលរងរបស់ទុក្ខ ទើបពោលពាក្យជាដើមថា **ជាតិ** ឈ្មោះថា **ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខទាំងឡាយដ៏ច្រើន** ។ សភាវៈដែលជាទុក្ខ លោកអាចារ្យពោលឲ្យប្លែកទុក ដោយទុក្ខស័ព្ទថា **ទុក្ខទុក្ខំ** ដែលប្រែថា ទុក្ខពិតៗ ដូចពាក្យថា **រូបរូបំ** ដែលប្រែថា រូប ដែលប្រែប្រួល ដូច្នេះ ក៏ព្រោះសភាវៈដែលមិនជាទុក្ខ លោកក៏ហៅថា **ទុក្ខ** ដោយបរិយាយ ។

ពាក្យថា **ព្រោះជាហេតុកើតទុក្ខ** បានដល់ ព្រោះជាហេតុកើតទុក្ខផ្លូវចិត្តថា មានដល់យើងហ្ន៎ ឬថា វត្ថុនោះមិនមានហើយហ្ន៎ ។

សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា សង្ខារទុក្ខ ព្រោះមានព្រះបាលីថា

*វត្ថុណាមិនទៀង វត្ថុជានោះជាទុក្ខ លោកពោលហេតុក្នុងសង្ខារទុក្ខនោះថា **ព្រោះត្រូវការកើតឡើង និងវិនាសទៅគ្របសង្កត់ដោយចំពោះ** ។ ពិតហើយ វត្ថុណាដែលត្រូវគ្របសង្កត់ដោយចំពោះរឿយៗ វត្ថុនោះឈ្មោះថា ទុក្ខ ព្រោះភាវៈ គឺអត់ធន់បានលំបាក លោកប្រើស័ព្ទថា ប្រព្រឹត្តទៅក្នុងភូមិ ៣ ព្រោះសំដៅយកការប្រព្រឹត្តទៅនៃវិបស្សនា ។*

*លោកអាចារ្យពោលដល់ទុក្ខទោមនស្ស និងឧបាយាសថា **ទុក្ខទុក្ខ** ។ ទុក្ខទុក្ខមក **ក្នុងវិភង្គនៃទុក្ខសច្ច** ដោយន័យមានអាទិថា **ជាតិបិទុក្ខា** ជាតិក៏ជាទុក្ខ ។*

*ពាក្យថា **សូម្បីព្រះមានព្រះភាគ** សេចក្តីថា សូម្បីដែលព្រះមានព្រះភាគទ្រង់មានព្រះអនាវរណញ្ញាណ ទ្រង់ជាបុគ្គលឈ្លាសក្នុងទេសនាដ៏គួរអស្ចារ្យ និងប្រមាណមិនបាន ។ ពាក្យថា **ដោយអំណាចនៃឧបមា** គឺដោយអំណាចឧបមា មានឧបមាដោយរណ្តៅរងើកភ្លើងជាដើម ។*

*ដោយ **អាទិ**-ស័ព្ទ ក្នុងបទថា **បុណ្ណរិកាទីសុ** គប្បីឃើញការរួមយកពាក្យទាំងឡាយជាដើមយ៉ាងនេះថា មិនមែនកើតឡើងក្នុងទីដែលសន្សំនៃរតនៈ មានកែវមណីមាស ប្រាក់ និងកែវប្រវាឡជាដើម ទាំងមិនមែនកើតឡើងលើទីដេកដ៏ស្រស់ស្អាតដែលគួរប្រាថ្នាជាដើមថា ទីដេកធ្វើដោយរោមបក្សី រោមចៀម និងសំពត់ដែលត្បាញជាដើម ទាំងមិនមែនកើតលើផ្ទៃប្រាសាទ ដែលនាំមកនូវសេចក្តីត្រេកអរនៃចិត្ត ត្រង់បុស្បុកដែលសម្រេចរតនៈ មិនមែនកើតត្រង់ឧបចារៈនៃប្រាសាទ ដែលស្រោចទឹករាបស្មើហើយ និងរោយដោយផ្កាឈើ ទាំងមិនមែនកើតលើទីវាល ដែលដេរដាសទៅដោយខ្សាច់ ដូចគ្នានឹងសំណាញ់នៃកែវមុក្តា ទាំងមិនបានកើតឡើង លើផ្ទៃដីដែលរួបរួមទុកដោយស្បូវក្លាំងដ៏ទន់ ដូចគ្នានឹងសំពត់កម្ពលខៀវ ។ ពាក្យថា **ចង្អៀតក្រៃពេក** គឺចង្អៀតហួសប្រមាណ ។ ពាក្យថា **ងងឹតស្អុប** គឺងងឹតឈឹង ។ **ចង្អៀតទៅដោយ***

**សាកសពផ្សេងៗ** មានប្រមាត់ ស្លេស្ម ខ្ទុះ ឈាម អាហារចាស់ និងអាហារថ្មីជាដើម ។ ប្រសិនបើមាតាមានអាយុ ២០ ឆ្នាំ ឬមានអាយុ ៣០ ឆ្នាំ ៤០ ឆ្នាំជាដើម **ក្នុងចំណែកនៃពោះ ឈ្មោះថា គួរខ្ពើមពន់ពេក** ព្រោះដូចរណ្តៅវច្ចៈ ដែលមិនបានជម្រះរហូតមកមានប្រមាណប៉ុណ្ណោះ ។ ពាក្យទាំងអស់ មានពាក្យថា **ត្រីស្អុយ** ជាដើម មិនមែនជាពាក្យប្រៀបធៀបដែលដូចគ្នា ព្រោះពាក្យថា ត្រីស្អុយជាដើមនោះ នៅមានការប្រាសចាកក្លិនស្អុយបានក្នុងចំណែកខ្លះដោយអំណាចរបស់ខ្យល់ជាដើម ។ បទថា **ទសមាសេ** ជាទុតិយាវិភត្តចុះក្នុងអត្ថ **អច្ចន្តសំយោគ** ពាក្យនោះលោកពោលទុកដោយចំណែកច្រើន ព្រោះមានបុគ្គលពួកខ្លះនៅក្នុងគភ៌នោះ បានជាង ១០ ខែនោះ ។ កាលខ្លួនដាក់ដៃដែលអែនទាំងពីរទុក ផ្កាប់មុខ អង្គុយ សំយុងក្បាលនោះឯង សត្វនេះក៏ឈ្មោះថា វៀរចាកអាការ មានបត់ចូល និងលាចេញជាដើម ។

ការទាញមកខាងមុខ ឈ្មោះថា **អាកឌ្ឍនំ** ប្រែថា ការទាញកន្ត្រាក់ ។ ការទាញទៅជុំវិញ គឺដោយជុំវិញ ឈ្មោះថា **បរិកឌ្ឍនំ** ប្រែថា ការទាញដោយជុំវិញ ។ ការសង្កត់ចុះទៅខាងក្រោម ឈ្មោះថា **ឱធូននំ** ប្រែថា ការសង្កត់សម្រុញ ។ ការរុញហើយរុញទៀត ឈ្មោះថា **និទ្ធូននំ** ប្រែថា ការប្រាន ។ ឯការធ្វើដូចគ្នានឹងការទាញអូសជាដើម លោកហៅថា **អូសទាញជាដើម** ក្នុងទីនេះ ។ សរីរៈដែលនៅក្នុងគភ៌ល្អិតទន់ក្រៃពេកណាស់ ដូចជាមុខដំបៅ រមែងអត់ធន់មិនបាននូវភាពរឹងជាដើម ដែលមានប្រមាណតិច ព្រោះដូច្នោះ ទើបលោកសម្តែងឧបមា មានបុគ្គលឧប្បត្តិក្នុងសីតនរក ( នរកត្រជាក់ជាដើម ) ។ ពិតហើយ ភាពត្រជាក់ជាដើមក៏ប្រាកដថា ជាភាពត្រជាក់យ៉ាងក្រៃពេកដល់សត្វនោះ និងប្រាកដថា ក្តៅយ៉ាងក្រៃលែង ។ ការដាក់ទោសដោយការពុះសរីរៈដោយកាំបិតជាដើម ហើយស្រោចទឹកក្រុត ឈ្មោះថា **ការដាក់ទោសគឺវះរាងកាយហើយស្រោចដោយទឹកក្រុត** ។ ពាក្យថា **ក្នុងទីដែលកើតទុក្ខ** លោក

ពោលសំដៅដល់ចំណែកវត្ថុមូលស្រទាប់ទី ៣ ដែលតែងហៅថា ស្បូន ។ ពាក្យថា **បក់ផាត់** បានដល់ បក់ផាត់ដោយយកជើងឡើងលើយកក្បាលចុះក្រោម ។ ទុក្ខស្មើរស្លាប់ ដែលជាហេតុឲ្យសត្វទាំងឡាយ ត្រូវក្រហល់ក្រហាយ ដល់នូវភាពជាវេទនាទ្រហោយំរហូតដល់ពេលបច្ចុប្បន្ន សូម្បីកន្លងទៅ ២-៣ ខែ ក៏មាន ដូចជារសាត់ទៅកាន់ផ្លូវលំបាកធំដ៏ធំងងឹតច្រើន **នេះ** ឈ្មោះថា **ទុក្ខមានការប្រសូតិជាមូល** ។

ពាក្យថា **ធ្វើអាក្រក់** បានដល់ បៀតបៀនខ្លួនដោយការសោយសោក យំរៀបរាប់បោកក្បាលជាដើម ។ ឈ្មោះថា **អាតាបន** ការធ្វើឲ្យក្តៅក្រហាយទូទៅ ដោយការស្រេកឃ្លាន និងដោយការឈរហាលថ្ងៃជាដើម ។ ឈ្មោះថា **បរិតាបន** ការដុតកិលេសដោយជុំវិញ ដោយការធ្វើខ្លួនឲ្យក្តៅដោយភ្លើង ៥ កងជាដើម ។

បទថា **ឥមស្ស** សេចក្តីថា ទាំង ៧ យ៉ាងតាមដែលពោលមកហើយ ។ បទថា **សព្វស្សាបិ** ប្រែថា ទាំងអស់ ដែលឲ្យកើតហើយ ដោយការសង្កត់ និងការប្របាច់ក្នុងវេលាដែលនៅក្នុងគភ៌ជាដើម និងដោយការដុតដោយភ្លើងនរកជាដើម ឈ្មោះថា **ជាទីតាំងនោះឯង** ព្រោះកាលជាតិនោះមិនមាន សេចក្តីទុក្ខក៏មិនមាន ដោយហេតុនោះទើបលោកអាចារ្យពោលពាក្យជាដើមថា **ប្រសិនបើសត្វមិនកើត ក្នុងនរកសោត** ដូច្នេះ ។

បទថា **វិចិត្តំ** ប្រែថា មានប្រការផ្សេងៗ ឬគួរអស្ចារ្យ ។

ពណ៌នាជាតិនិទ្ទេស

ចប់ហើយ

ដោយប្រការ ដូច្នេះ ។

# វិសុទ្ធិមគ្គ

## ជរាទុក្ខ

*ក្នុងពាក្យថា ជរាក៏ជាទុក្ខនេះ មានវិនិច្ឆ័យថា ជរាមាន ២ យ៉ាង គឺសង្ខតលក្ខណៈ ១ ការចាស់ទៅនៃខន្ធ ដែលជាប់នៅក្នុងភពមួយ ( ក្នុងរូប ) សន្តតិ ដែលដឹងដោយអាការ មានធ្មេញបាក់ជាដើម ១ ជរា ( ដែលប្រាកដ ) គឺការចាស់ទៅនៃខន្ធនោះ ( ឯង ) សំដៅយកក្នុងទីនេះ ។*

*ជរានេះ មានការចាស់ទៅនៃខន្ធជាលក្ខណៈ មានការនាំចូលទៅរកសេចក្តីស្លាប់ជារស មានការសាបសូន្យទៅនៃភាពក្មេងជាបច្ចុប្បដ្ឋាន ឈ្មោះថា ជាទុក្ខ ព្រោះជាសង្ខារទុក្ខ និងព្រោះជាទីតាំងនៃទុក្ខផង ។ ពិតណាស់ ទុក្ខដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងតាមផ្លូវចិត្តនេះ មានបច្ច័យជាអនេក ដូចការយុរយារនៃអវយវៈធំតូច ការពិការនៃឥន្ទ្រិយ ការមានរូបរាងវិកលទៅ ភាពក្មេងវិនាសទៅ ការព្យាយាម ( សេចក្តីតស៊ូ ) ធ្លាក់ទៅ សតិ ( ការចាំ ) និងមតិ ( ការគិត ) ឃ្លាតទៅ និងជាទីមើលងាយរបស់អ្នកដទៃជាដើមកើតឡើង ជរាជាទីតាំងនៃទុក្ខនោះ ព្រោះហេតុនោះ ទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធនេះទុកថា*

**អង្គានំ សថិលីភាវា ។បេ។ យស្មា តស្មា ជរាទុក្ខា**

*មច្ចៈ ( សត្វដែលនឹងត្រូវស្លាប់ ) បានទទួលទុក្ខតាមផ្លូវកាយ និងតាមផ្លូវចិត្ត ព្រោះការយុរយារទៅនៃអង្គាវយវៈ ព្រោះការវិកលទៅនៃឥន្ទ្រិយទាំងឡាយ ព្រោះ*

ការសោបសូន្យទៅនៃភាពក្មេង ព្រោះការថមថយទៅនៃកម្លាំង ព្រោះការឃ្លាតទៅនៃសតិជាដើម ព្រោះត្រូវកូនប្រពន្ធរបស់ខ្លួនឯង ក៏មិនយកចិត្តទុកដាក់ និងព្រោះ ( មានតែនឹង ) ដល់នូវការទន់ខ្សោយក្រៃលែងឡើង ព្រោះហេតុដែលទុក្ខ ( ដែលពោលមក ) នោះ សុទ្ធតែមានជរាជាហេតុ ព្រោះហេតុ ដូច្នោះ ទើបជរាជាទុក្ខ ។

នេះជាវិនិច្ឆ័យក្នុងជរា ។

# មហាដីកា

## ពណ៌នាជរានិទ្ទេស

*ពាក្យថា **សន្តតលក្ខណៈ** ពោលសំដៅដល់ជរាគ្រប់ខណៈ ដែលត្រាស់ទុកថា វត្ថុដែលតាំងនៅហើយដទៃទៅ ។ ពាក្យថា **ដែលតែងហៅថា ធ្មេញបាក់ជាដើម** គឺ ដែលដឹងដោយអាការ មានធ្មេញបាក់សក់ស្កូវ និងស្បែកក៏យារជាដើម ។ បទថា **សា យោគ ខន្ធ បុរាណភាវសញ្ញិតា បាកដជរា** ប្រែថា ជរាដែលមិនកំបាំង ដែលដឹងបានថា ជាការចាស់នៃខន្ធនោះ ។ **ការឆ្អិននៃខន្ធ** បានដល់ ការចាស់នៃខន្ធដែលទាក់ទងក្នុងភពតែមួយ ។*

*ពណ៌នាជរានិទ្ទេស ចប់ហើយ*

*ដោយប្រការ ដូច្នេះ ។*

# វិសុទ្ធិមគ្គ

## មរណទុក្ខ

ក្នុងពាក្យថា មរណៈក៏ជាទុក្ខនេះ មរណៈក៏មាន ២ គឺសង្ខតលក្ខណៈ ដែលលោកពោលទុកថា ជរាមរណៈ សង្គ្រោះដោយខន្ធ ២ ដូច្នេះ ១ ការដាច់ការជាប់តគ្នាទៅនៃជីវិតិន្ទ្រិយដែលជាប់នៅក្នុងភពមួយ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកថា ការខ្លាចស្លាប់មានជានិច្ច ដូច្នេះ ១ មរណៈ គឺការដាច់ជីវិតិន្ទ្រិយនោះ ( ឯង ) បំណងយកក្នុងទីនេះ ។ សូម្បីពាក្យថា ជាតិបច្ចយាមរណៈ ( ការស្លាប់ព្រោះមានការកើតជាបច្ច័យ ) ឧបក្កមមរណៈ ( ការស្លាប់ព្រោះការធ្វើ ) សរសមរណៈ ( ការស្លាប់ដោយសភាវៈ គឺស្លាប់ខ្លួនឯង ) អាយុក្ខយមរណៈ ( ការស្លាប់ព្រោះអស់អាយុ ) បុញ្ញក្ខយមរណៈ ( ការស្លាប់ ព្រោះអស់បុណ្យ ) ដូច្នេះ ក៏ជាឈ្មោះរបស់មរណៈ គឺការដាច់ជីវិតិន្ទ្រិយនោះឯង ។

មរណៈនេះ មានចុតិ ( ការឃ្លាតទៅអំពីបច្ចុប្បន្នភព ) ជាលក្ខណៈ មានវិយោគ ( ការព្រាត់ទៅចាកសត្វ និងសង្ខារតាមដែលខ្លួនបាន ) ជារស មានគតិវិបល្លាស ( មានការព្រាត់ចាកគតិ តាមដែលខ្លួនចូលដល់ហើយ ) ជាបច្ចុប្បដ្ឋាន ចំណែក ( មរណៈ ) ជាទុក្ខ គប្បីជ្រាបថា ព្រោះភាពជាទីតាំងនៃទុក្ខ ហេតុនោះ ទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធនេះទុកថា

បាបស្ស បាបកម្មាទិ- ។បេ។ ទុក្ខមិច្ចេវ ភាសិតំ

ទុក្ខតាមផ្លូវចិត្តដែលមានឡើង ដោយមិនប្លែកគ្នា ដល់មនុស្សដែលកំពុងស្លាប់ ដែលជាមនុស្សអាក្រក់ ឃើញនិមិត្ត មានកម្មនិមិត្តផ្អែកបាបជាដើម សូម្បីដែលជាមនុស្សល្អ តែទ្រាំការព្រាត់ប្រាស មានរបស់ជាទីស្រឡាញ់ ជាទីតាំងមិនបាន ម្យ៉ាងទៀត ទុក្ខតាមផ្លូវកាយ មានសន្ទាក់ និងសរសៃធ្លីងដាច់ជាដើម មានដល់បុគ្គលគ្រប់គ្នា អ្នកមានមម្មដ្ឋាន ( ទីសម្គាល់របស់រាងកាយ ) ត្រូវខ្យល់កាចចាក់ដោត ទុក្ខនេះជាទុក្ខដែលមនុស្សមិនអាចទ្រាំបាន កែខៃក៏មិនបាន ព្រោះហេតុ ដែលមរណៈជាទីតាំងនៃទុក្ខ ( ដែលពោលមកទាំងអស់ ) នោះ ព្រោះហេតុនោះ មរណៈនេះ ព្រះមានព្រះភាគត្រាស់ថា ជាទុក្ខពិត ។

នេះជាវិនិច្ឆ័យក្នុងមរណៈ ។

# មហាដីកា

## ពណ៌នាមរណានិទ្ទេស

ពាក្យថា **សន្តតិលក្ខណ** លោកអាចារ្យពោលដល់ការស្លាប់គ្រប់ខណៈ ដែលសម្គាល់បានថា ជាការវិនាសរបស់សង្ខារ ។ បទថា **យំ សន្ធាយ** សេចក្តីប៉ុនគ្នានឹង **យំ ខណិកមរណំ សន្ធាយ** ប្រែថា ទ្រង់សំដៅដល់ការស្លាប់គ្រប់ខណៈ ក្នុងពាក្យថា ជរា និងមរណៈ សង្គ្រោះដោយខន្ធ ២ នេះ សេចក្តីថា លោកពោលថា ការស្លាប់ ។ បទថា **តំ យោគ ជីវិតិន្ទ្រិយុបច្ឆេទសញ្ញិតំ បាកដមរណំ** ប្រែថា ការស្លាប់ដោយមិនកំបាំងដែលសម្គាល់បានថា ការដាច់នៃជីវិតិន្ទ្រិយ ។ ឈ្មោះថា **មានចុតិជាលក្ខណៈ** ព្រោះគប្បីកំណត់ថា ជាការឃ្លាតទៅ ។ ពាក្យថា **មានការប្រាសទៅជារស** គឺមានការព្រាត់ទៅអំពីសត្វ និងសង្ខារតាមដែលខ្លួនព្រាត់ទៅជាកិច្ច ។ មរណៈណាដែលបុគ្គលរមែងកាន់យក ដោយការប្រាសទៅអំពីគតិ តាមដែលខ្លួនបានចូលដល់ហើយ ហេតុនោះ មរណៈនោះ ឈ្មោះថា **មានការប្រាសទៅចាកគតិជាបច្ចុប្បដ្ឋាន** ។

ពាក្យថា **ជាបុគ្គលអាក្រក់** គឺជាបុគ្គលអាក្រក់ដោយការធ្វើបាប អធិប្បាយថា បានសន្សំបាបកម្មទុក ។ ពាក្យថា **ឃើញនិមិត្ត មានកម្មនិមិត្តចំណែកខាងបាបកម្មជាដើម** សេចក្តីថា ឃើញអារម្មណ៍ដែលជាអកុសលវិបាកប្រាកដក្នុងវេលាជិតស្លាប់ពោល គឺកម្មារម្មណ៍ កម្មនិមិត្តអារម្មណ៍ និងគតិនិមិត្តអារម្មណ៍ចំណែកមិនល្អ ។ ពិតហើយ មហាទុក្ខ រមែងមានដល់បុគ្គលពួកខ្លះដែលឃើញអារម្មណ៍ ជាអកុសលវិបាកនោះឯង ហាក់ដូចជាកំពុងសោយ ។ ពាក្យថា **ជាបុគ្គលល្អ** គឺដែលមានកម្មល្អ

អធិប្បាយថា ដែលធ្វើកុសលទុក ។ អារម្មណ៍ដែលគួរប្រាថ្នាតែម្យ៉ាង រមែងប្រាកដ ដល់បុគ្គលល្អនោះដោយពិត សូម្បីដូច្នោះ ក៏គង់កើតទុក្ខធំ ព្រោះមានការព្រាត់ប្រាស អំពីសត្វ និងសង្ខារដែលជាទីស្រឡាញ់ជាទីតាំង ព្រោះដូច្នោះ ទើបអាចារ្យពោលថា **អត់ធន់មិនបាននូវការព្រាត់ប្រាស ដែលមានរបស់ស្រឡាញ់ជាទីតាំង** ។ ពាក្យថា **ដោយមិនប្លែកគ្នា** បានដល់ ដោយភាពស្មើគ្នា របស់បុគ្គលអាក្រក់ និងបុគ្គលល្អ ។ លោកអាចារ្យពោលថា **ដោយមិនប្លែកគ្នា** ដូច្នេះហើយ ក៏គង់ពោលថា **ដល់បុគ្គលគ្រប់គ្នា** ដើម្បីសម្តែងថា ទុក្ខនេះរមែងមាននោះឯង ដល់ព្រះខីណាស្រពទាំងឡាយ ពួកខ្លះ ដែលញាំញីសង្ខារបានហើយ ។ បទថា **វិតុជ្ជមានមម្មានំ** ប្រែថា បុគ្គលមានមម្មដ្ឋានត្រូវខ្យល់កាត់ត្រង់សន្ទាក់ និងសរសៃកំពុងចោះទម្លុះ ។

ពណ៌នាមរណនិទ្ទេស ចប់ហើយ

ដោយប្រការ ដូច្នេះ ។

# វិសុទ្ធិមគ្គ

## សោកៈ

ក្នុងបកិណ្ណកទុក្ខ មានសោកជាដើម ការក្តៅចិត្តនៃបុគ្គលអ្នកត្រូវទុក្ខ មានវិនាសញ្ញាតិទៅជាដើមពាល់ត្រូវ ឈ្មោះថា សោក សោកនោះ ដោយអត្ថ ក៏ជាទោមនស្សនោះឯង ដូច្នេះ ទោះបីយ៉ាងនោះ ក៏ ( មានលក្ខណៈប្រចាំខ្លួនគឺ ) មានការព្រួយខាងក្នុងជាលក្ខណៈ មានការក្រៀមក្រំចិត្តជារស មានការដង្ហោយហៅជាបច្ចុប្បដ្ឋាន ចំណែកសោកជាទុក្ខ គប្បីជ្រាបថា ព្រោះជាទុក្ខទុក្ខ ( គឺជាតួទុក្ខ ) និងព្រោះជាទីតាំងនៃទុក្ខផង ហេតុដូច្នោះ ទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធនេះទុកថា

**សត្តានំ ហទយំ សោកោ ។បេ។ តស្មា ទុក្ខោតិ វុច្ចតិ**

សោករមែងចាក់ដោតហឫទ័យរបស់សត្វទាំងឡាយ ដូចព្រួញលាបថ្នាំពិសចាក់ទម្លុះ និងដុតហឫទ័យយ៉ាងកាចសាហាវទៀតផង ដូចលំពែងដែកដ៏ក្រហមដោយភ្លើង ( ចាក់ចូលទៅ ) ឆេះពេលរាល និងនាំវិវិធទុក្ខផ្សេងដោយការឈឺថ្កាត់ការចាស់និងការស្លាប់មកទៀតផង ហេតុណា ព្រោះហេតុនោះ សោកនោះ ទើបព្រះមានជោគត្រាស់ថា ជាទុក្ខ ។

នេះជាវិនិច្ឆ័យក្នុងសោក ។

# មហាដីកា

## ពណ៌នាសោកនិទ្ទេស

*បទថា **សោ យោគ សោកោ** ប្រែថា សេចក្ដីសោកនោះ ។ **ដោយអត្ថ** ក៏ឈ្មោះថា **ទោមនស្សនោះឯង** ព្រោះមិនមានចេតសិកដទៃ ។ តែសេចក្ដីផ្សេងនៃទោមនស្សក៏ឈ្មោះថា មាន ព្រោះមានភាពផ្សេងនៃអាការដែលប្រព្រឹត្តទៅ ក្នុងការផ្សេងគ្នានៃអារម្មណ៍ ព្រោះដូច្នោះ លោកអាចារ្យមានបំណងនឹងសម្ដែងសេចក្ដីផ្សេងគ្នានោះ ដោយបកិណ្ណកៈ មានលក្ខណៈជាដើម ទើបពោលពាក្យជាដើមថា **កាលបើយ៉ាងនេះ ។ ការក្ដៅខាងក្នុង** បានដល់ ការក្ដៅក្រហាយនៃចិត្ត ។ **ការក្រៀមក្រំ** បានដល់ការដុតដែលផ្សេងពីការក្ដៅក្រហាយ គឺរាគៈ និងទោសៈ ។ ការដង្ហោយរកដែលប្រព្រឹត្តទៅដោយអាការ គឺការក្ដៅក្រហាយចិត្តជាខាងក្រោយដល់អារម្មណ៍ គឺកុសល និងអកុសលដែលធ្វើហើយ និងមិនទាន់បានធ្វើ ឈ្មោះថា **កុក្កុច្ចៈ** ការដង្ហោយរកដែលជាការក្ដៅក្រហាយចិត្តតែម្យ៉ាង ព្រោះមានការវិនាសញាតិជាដើម ជាអារម្មណ៍ ឈ្មោះថា **សោក** កុក្កុច្ចៈ និងសោកនេះ មានភាពផ្សេងគ្នា ក្នុងអត្ថថា មានការដង្ហោយរកជាបច្ចុប្បន្នដូចពោលមក ដូច្នេះ ។*

*ព្រួញដែលលាបថ្នាំពិស ឈ្មោះថា **ព្រួញជ្រលក់ថ្នាំពិស** សូម្បីការឈឺចាប់មាន រោគចុះរាគជាដើម ក៏មានដោយអំណាចនៃសេចក្ដីសោក សរីរៈរបស់បុគ្គលច្រើនទៅដោយសេចក្ដីសោករមែងទ្រុឌទ្រោមទៅមិនយូរឡើយ បុគ្គលដែលត្រូវសេចក្ដីសោកមានកម្លាំងគ្របសង្កត់រមែងដល់នូវសេចក្ដីស្លាប់បាន ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **នាំទុក្ខផ្សេងៗ ដោយភាពជាជំងឺតម្កាត់ ការចាស់ និងការស្លាប់មកដែរ** ។*

*ពណ៌នាសោកនិទ្ទេស ចប់ហើយ ដោយប្រការ ដូច្នេះ ។*

# វិសុទ្ធិមគ្គ

## បរិទេវៈ

ការខ្សឹកខ្សួលនៃបុគ្គលអ្នកត្រូវទុក្ខ មានការវិនាសញាតិទៅជាដើមពាល់ត្រូវ ឈ្មោះថា បរិទេវៈ ។ បរិទេវៈនោះ មានការយំរៀបរាប់ជាលក្ខណៈ មានការប្រាប់ (រៀបរាប់)សេចក្ដីល្អនិងសេចក្ដីវិនាសជារសមានការបម្រះនទៀលទៅជាបច្ចុប្បដ្ឋាន ចំណែកបរិទេវៈជាទុក្ខ គប្បីជ្រាបថា ព្រោះជាសង្ខារទុក្ខ និងជាទីតាំងនៃទុក្ខផង ព្រោះហេតុដូច្នោះ ទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធនេះទុកថា

យំ សោកសល្លវិហតោ បរិទេវមានោ

។បេ។

ទុក្ខោតិ តេន ភគវា បរិទេវមាហ

បុគ្គលត្រូវសរ គឺសោក ប្រហារយកហើយ តែងយំរៀបរាប់ ( ទៀត ) រមែងបានទទួលទុក្ខធ្ងន់ក្រៃលែងឡើងទៅ ដែលជាទុក្ខកើតអំពីការស្ងួតករីមបបូរមាត់ ក្រអូមមាត់ និងពិតានហួសពណ៌នា ហេតុណា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ បរិទេវៈ ថាជាទុក្ខ ។

នេះជាវិនិច្ឆ័យក្នុងបរិទេវៈ ។

# មហាដីកា

## ពណ៌នាបរិទេវនិទ្ទេស

*បទថា **វចីបលាបោ** ប្រែថា និយាយផ្តេសផ្តាសតាមផ្លូវវាចា ការយំរៀបរាប់តាមផ្លូវ វាចានោះ ដោយអត្ថ ក៏គឺសំឡេងនោះឯង ។ ពាក្យថា **ក្រែលែងឡើងទៅ** គឺហួសប្រមាណជាងសេចក្តីទុក្ខ គឺសេចក្តីសោក ។ ព្រោះ **បរិទេវៈ** មានសេចក្តីសោកជា សមុដ្ឋាន ។*

*ពណ៌នាបរិទេវនិទ្ទេស ចប់ហើយ*

*ដោយប្រការ ដូច្នេះ ។*

# វិសុទ្ធិមគ្គ

## ទុក្ខ

សេចក្តីទុក្ខដែលប្រព្រឹត្តទៅក្នុងកាយ ឈ្មោះថា ទុក្ខ ទុក្ខនោះមានការបៀតបៀនកាយជាលក្ខណៈ មានការធ្វើទោមនស្សដល់បុគ្គលអ្នកខ្វះបញ្ញាទាំងឡាយ ជារស មានការឈឺចាប់ផ្លូវកាយជាបច្ចុប្បដ្ឋាន ។ ចំណែកទុក្ខជាទុក្ខ គប្បីជ្រាបថា ព្រោះជាទុក្ខ ( គឺជាតួទុក្ខ ) និងព្រោះនាំសេចក្តីទុក្ខផ្លូវចិត្តមកឲ្យផង ព្រោះហេតុនោះ ទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធនេះទុកថា

បីឡេតិ កាយិកមិទំ ។បេ។ ទុក្ខន្តិ វិសេសតោ វុត្តំ

ទុក្ខផ្លូវកាយនេះ រមែងបៀតបៀន ( កាយ ) ដដែលហើយដដែលទៀត ហើយនៅធ្វើទុក្ខផ្លូវចិត្តឲ្យកើតផង ដោយហេតុណា ព្រោះហេតុនោះ ទុក្ខផ្លូវកាយនេះ ទើបព្រះមានព្រះភាគត្រាស់ថា ជាទុក្ខដោយពិសេស ( គឺជាទុក្ខមួយបែបដោយឡែក )។

នេះជាវិនិច្ឆ័យក្នុងទុក្ខ ។

# មហាដីកា

## ពណ៌នាទុក្ខនិទ្ទេស

កាលធម៌ទាំងឡាយ មានជាតិជាដើមជាទុក្ខ ដោយជាទីតាំងនៃទុក្ខ និងជាទុក្ខពិតៗ តាមសមគួរដល់ទុក្ខផ្លូវកាយនេះ ក៏ឈ្មោះថា ទុក្ខដែលមានភាពពិសេស ទាក់ទងជាមួយការបៀតបៀនដល់កាយ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា ព្រះសាស្ដាព្រះភាគត្រាស់ថា ជាទុក្ខដោយពិសេស ។

ពណ៌នាទុក្ខនិទ្ទេស ចប់ហើយ

ដោយប្រការ ដូច្នេះ ។

# វិសុទ្ធិមគ្គ

## ទោមនស្ស

សេចក្តីទុក្ខដែលប្រព្រឹត្តទៅក្នុងចិត្ត ឈ្មោះថា ទោមនស្សៗ នោះ មានការបៀតបៀនចិត្តជាលក្ខណៈ មានការបង្អៀតចិត្តជារស មានការឈឺចាប់ផ្លូវចិត្ត ជាបច្ចុប្បដ្ឋាន ចំណែកទោមនស្សជាទុក្ខ គប្បីជ្រាបថា ព្រោះជាទុក្ខទុក្ខ និងព្រោះនាំទុក្ខផ្លូវកាយមកឲ្យផងដែរ ។ ពិតណាស់ មនុស្សទាំងឡាយដែលពេញដោយសេចក្តីទុក្ខក្នុងចិត្តហើយ រមែងសោយទុក្ខមានប្រការផ្សេងៗ ដូចជាំសោយសក់ ស្រែកយំ គក់ទ្រូង បោកខ្លួនទៅមក យកជើង ( គងឡើងចុះ ) ចាប់សស្ត្រា ( ធ្វើបាបខ្លួនឯង ) ផឹកថ្នាំពិស ចង (ក) ដោយខ្សែ (លោត) ចូល (គំនរ) ភ្លើង ព្រោះហេតុនោះ ទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធទុកថា

បីឡេតិ យតោ ចិត្តំ ។បេ។ តតោ អាហុ

ទោមនស្ស រមែងបៀតបៀនចិត្ត និងនាំសេចក្តីលំបាកកាយមកឲ្យផង ដោយហេតុណា ព្រោះហេតុនោះ ទើបព្រះពុទ្ធទាំងឡាយ អ្នកប្រាសចាកទោមនស្ស ត្រាស់ទោមនស្ស ថាជាទុក្ខ ។

នេះជាវិនិច្ឆ័យក្នុងទោមនស្ស ។

# មហាដីកា

## ពណ៌នាទោមនស្សនិទ្ទេស

*ពាក្យថា **មានការចង្អៀតចង្អល់ចិត្តជារស** គឺមានការចង្អៀតចិត្ត ដោយប្រកបជាមួយព្យាបាទជាកិច្ច ។ ពាក្យថា **បុគ្គលទាំងឡាយដែលដល់ព្រមដោយទុក្ខផ្លូវចិត្ត** គឺដែលមានការព្រមព្រៀង ដោយទុក្ខដែលកើតតាមផ្លូវចិត្ត ។ បទថា **អាវដ្ដន្តិ** ប្រែថា វិលមកខាងមុខ គឺផ្ដួលខ្លួនចុះបែរមុខទៅទិសណា ក៏បង្វិលខ្លួនទៅទិសនោះតែម្យ៉ាង ។ បទថា **វិវដ្ដន្តិ** ប្រែថា វិលទៅក្នុងការផ្លាស់ប្ដូរឥរិយាបថផ្សេងៗ ។ ពីរបទថា **ឧទ្ធំបាទំ បបតន្តិ** ប្រែថា ដួលផ្ងារពោះលើកជើងឡើងលើ ។ ពាក្យថា **ចាប់សស្ត្រា** គឺនាំសស្ត្រាចូលទៅចាក់ និងទម្លាយសរីរៈរបស់ខ្លួន ។*

*ពណ៌នាទោមនស្សនិទ្ទេស ចប់ហើយ*

*ដោយប្រការ ដូច្នេះ ។*

# វិសុទ្ធិមគ្គ

## ឧបាយាស

*ទោសៈ ដែលជាសេចក្តីទុក្ខចិត្តយ៉ាងធ្ងន់បណ្តាលឡើង នៃបុគ្គលដែលត្រូវទុក្ខមានការវិនាសញាតិជាដើមពាល់ត្រូវនោះឯង ឈ្មោះថា ឧបាយាស អាចារ្យមួយពួកពោលថា ឧបាយាសជា ( ចេតសិក ) ធម៌មួយ រាប់ចូលនៅក្នុងសង្ខារក្ខន្ធ ឧបាយាសនោះ មានការដុតកោលចិត្តជាលក្ខណៈ មានការគានគឹងជារស មានការព្រួយជាបច្ចុប្បដ្ឋាន ដែលថា ឧបាយាសជាទុក្ខ គប្បីជ្រាបថា ព្រោះជាសង្ខារទុក្ខ ព្រោះដុតកោលចិត្ត និងព្រោះធ្វើរាងកាយឲ្យស្ទេកស្ទាំងផង ព្រោះហេតុនោះ ទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធនេះទុកថា*

*ចិត្តស្ស ច បរិទហនា ។បេ។ ទុក្ខោ តតោ វុត្តោ*

*ឧបាយាស រមែងញុំាងទុក្ខណាឲ្យកើតឡើង ទុក្ខនោះ ចាត់ថា មានប្រមាណក្រៃលែង ព្រោះដុតកោលចិត្តផង ធ្វើកាយឲ្យស្គាំងស្គម ហេតុនោះ ទើបឧបាយាសព្រះមានព្រះភាគត្រាស់ថា ជាទុក្ខ ។*

*នេះជាវិនិច្ឆ័យក្នុងឧបាយាស ។*

## ប្រៀបធៀបសោក បរិទេវៈ ឧបាយាស

*ក្នុងសោក បរិទេវៈ និងឧបាយាសនេះ លោកគប្បីឃើញដូចការដែល (ទឹក) ក្តៅនៅក្នុងភាជនៈដោយភ្លើងឧណ្ហៗ បរិទេវៈគប្បីឃើញដូចការ ( ហៀរ ) ចេញក្រៅភាជនៈនៃទឹកដែលក្តៅដោយភ្លើងខ្លាំង ឧបាយាសគប្បីឃើញដូចការក្តៅ រហូតស្ងួតទៅក្នុងភាជនៈនោះឯង នៃទឹកដែលសល់អំពី ( ហៀរ ) ចេញខាងក្រៅហើយ មិនគ្រប់គ្រាន់ហើយ ( ហៀរ ) ចេញទៀត ។*

# មហាដីកា

## ពណ៌នាឧបាយាសនិទ្ទេស

ពាក្យថា *ទោសៈនោះឯង* បានដល់ អាការនៃការប្រព្រឹត្តទៅរបស់ទោសៈនោះឯង ដោយអំណាចការចង្អៀតចង្អល់នៃកាយ និងចិត្ត ព្រោះដែលលោកហៅថា ឧបាយាស ដោយអត្ថថា ជាការចង្អៀតចង្អល់យ៉ាងធ្ងន់ដូចគ្នាជាមួយពាក្យថា **កុសមាទានំ ឧបាទានំ** ការប្រកាន់យ៉ាងមាំ ឈ្មោះថា ឧបាទាន ។ ពាក្យថា **ធម៌មួយ** បានដល់ចេតសិកធម៌តែម្យ៉ាង ដែលផ្សេងអំពីអកុសលចេតសិក ១៤ ដួង ដែលលោកអាចារ្យទាំងឡាយហៅថា **មានការសង្រេងសង្រែ** ឈ្មោះថា **មានការស្រយុតស្រយង់ជារស** ព្រោះដល់ព្រមដោយអំណាចការតានតឹង ឬការធ្វើភាពតានតឹងក្នុងកាយជាកិច្ច លោកអាចារ្យកាលពោលថា ព្រោះជាសង្ខារទុក្ខ ដូច្នេះហើយ កាលសម្តែងថា ឧបាយាសនោះជាកំពូលក្នុងបកិណ្ណកទុក្ខទាំងនេះ ទើបពោលថា ព្រោះដុតចិត្ត និងព្រោះធ្វើរាងកាយឲ្យរីងស្ងួត ។ លោកអាចារ្យកាលធ្វើពាក្យជាដើមថា **ក្នុងបណ្តាសោក បរិទេវៈ និងឧបាយាសនេះ** ដើម្បីសម្តែងថា សោក បរិទេវៈ និងឧបាយាសនេះ ជាអាការពិសេសនៃការកើតឡើងរបស់ទោមនស្សចិត្តតាមបច្ច័យ ដោយវៀរចាកវិញ្ញត្តិ និងរួមជាមួយវិញ្ញត្តិ ។ ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **ដូចទឹកល័ខ** បានដល់ទឹកល័ខនៃវត្ថុដែលគប្បីជ្រលក់ មានគ្រឿងជ្រលក់ជាដើម ។

ពណ៌នាឧបាយាសនិទ្ទេស ចប់ហើយ

ដោយប្រការ ដូច្នេះ ។

# វិសុទ្ធិមគ្គ

## អប្បិយសម្បយោគទុក្ខ

ការរួមចូលជាមួយសត្វ និងសង្ខារទាំងឡាយដែលមិនពេញចិត្ត ឈ្មោះថា អប្បិយសម្បយោគៗ នោះ មានការជួបប្រសព្វជាមួយសត្វ និងសង្ខារដែលមិនប្រាថ្នា ជាលក្ខណៈ មានការបង្អៀតចិត្តជារស មានការកើតអនត្ថជាបច្ចុប្បដ្ឋាន ចំណែក អប្បិយសម្បយោគដែលជាទុក្ខ គប្បីជ្រាបថា ព្រោះជាទីតាំងនៃទុក្ខ ហេតុនោះ ទើប អ្នកប្រាជ្ញពោលពាក្យប្រព័ន្ធនេះទុកថា

ទិស្វាន អប្បិយេ ទុក្ខំ ។បេ។ អប្បិយេហិ សមាគមោ

ព្រោះជួបមនុស្សដែលស្អប់ ដំបូងទុក្ខក៏មានឡើងក្នុងចិត្ត តទៅទុក្ខដែលកើត អំពីការប្រទូស្ត ( ដោយកាយ និងវាចា ) ក៏មានឡើងក្នុងកាយ ( នៃបុគ្គល ) ក្នុង លោកនេះ ( ដោយ ) ហេតុណា ព្រោះហេតុនោះ ការជួបប្រសព្វវត្ថុ ដែលស្អប់នោះ គប្បីជ្រាបថា ព្រះមហាឥសីត្រាស់ថា ជាទុក្ខ ព្រោះថា ជាទីតាំងនៃទុក្ខទាំង ២ ( គឺ ទាំងតាមផ្លូវចិត្ត និងតាមផ្លូវកាយ ) ។

នេះជាវិនិច្ឆ័យក្នុងអប្បិយសម្បយោគទុក្ខ ។

# មហាដីកា

## ពណ៌នាអប្បិយសម្បយោគនិទ្ទេស

*ការរួមចូល បានដល់ ការសមាគម ។ ការប្រកបដោយរបស់អនត្ថៈ មានទុក្ខផ្លូវកាយ និងការចង្អៀតចង្អល់ផ្លូវចិត្តជាដើម ឈ្មោះថា* ***អនត្ថការបច្ចុប្បដ្ឋានោ*** *ប្រែថា មានអនត្ថៈជាបច្ចុប្បដ្ឋាន ។*

*ការចូលទៅប្រទូស្ត ពោល គឺបយោគផ្លូវកាយ និងផ្លូវវាចាចំពោះសត្វ និងសង្ខារដែលមិនជាទីស្រឡាញ់ទាំងឡាយ ឈ្មោះថា* ***តទុបក្កមសម្ភូតោ*** *ប្រែថា ដែលកើតអំពីការប្រទូស្តនោះ ។*

*ពណ៌នាអប្បិយសម្បយោគនិទ្ទេស ចប់ហើយ*

*ដោយប្រការ ដូច្នេះ ។*

# វិសុទ្ធិមគ្គ

## បិយវិប្បយោគទុក្ខ

ការព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយដែលទីស្រឡាញ់ ឈ្មោះថា បិយវិប្បយោគៗ នោះ មានការព្រាត់ប្រាសចាកវត្ថុដែលពេញចិត្តជាលក្ខណៈ មានការញ៉ាំងសេចក្តីសោកឲ្យកើតឡើងជារស មានការវិនាសទៅជាបច្ចុប្បដ្ឋាន ចំណែកបិយវិប្បយោគទុក្ខ គប្បីជ្រាបថា ព្រោះជាទីតាំងនៃទុក្ខ គឺសេចក្តីសោក ហេតុនោះទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធនេះទុកថា

ញាតិធានាទិវិយោគា ។បេ។ មតោ បិយវិប្បយោគោ

មនុស្សល្ងង់ទាំងឡាយដែលពេញដោយសរ គឺសោក ព្រោះព្រាត់ប្រាសចាកសត្វ និងសង្ខារដែលជាទីស្រឡាញ់ មានញាតិ និងទ្រព្យជាដើម រមែងឈឺចាប់ ( ចិត្ត ) ហេតុណា ព្រោះហេតុនោះ ទើបបិយវិប្បយោគនេះ ព្រះមានព្រះភាគត្រាស់ថា ជាទុក្ខ ។

នេះជាវិនិច្ឆ័យក្នុងវិប្បយោគទុក្ខ ។

# មហាដីកា

## ពណ៌នាបិយវិប្បយោគនិទ្ទេស

*បិយវិប្បយោគ រមែងចូលទៅប្រាកដដោយភាពជាអន្តរាយ ព្រោះហេតុនោះ ទើបឈ្មោះថា មានការវិនាសជាបច្ចុប្បដ្ឋាន ។*

*ពណ៌នាបិយវិប្បយោគនិទ្ទេស ចប់ហើយ*

*ដោយប្រការ ដូច្នេះ ។*

# វិសុទ្ធិមគ្គ

## ឥច្ឆិតាលាភទុក្ខ

ក្នុងពាក្យថា យម្បិច្ឆំ ន លភតិ... នេះ មានវិនិច្ឆ័យថា ការប្រាថ្នាក្នុង ( អលព្ភ-នេយ្យវត្ថុ ) វត្ថុដែលមិនមានផ្លូវនឹងបានទាំងឡាយ ដូចប្រាថ្នាថា ឱហ្ន៎ ! យើងទាំងឡាយនឹងមិនជាអ្នកមានការកើតជាធម្មតាជាដើម នុ៎ះឯងដែលព្រះសាស្តាត្រាស់ថា យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ-ប្រាថ្នារបស់ណា តែមិនបានរបស់នោះឯណា ការមិនបានវត្ថុដែលជាទីប្រាថ្នានោះក៏ជាទុក្ខ ដូច្នេះ ការប្រាថ្នានោះ មានការត្រូវការវត្ថុដែលមិនមានផ្លូវនឹងបានជាលក្ខណៈ មានការស្វែងរកវត្ថុដែលមិនមានផ្លូវនឹងបាននោះជារស មានការមិនបានវត្ថុទាំងនោះជាបច្ចុប្បដ្ឋាន ចំណែកការប្រាថ្នានោះជាទុក្ខ គប្បីជ្រាបថា ព្រោះជាទីតាំងនៃទុក្ខ ហេតុនោះ ទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធទុក

តំ តំ បត្ថយមានានំ ។បេ។ ឥច្ឆិតាលាភមព្រវិ

ទុក្ខ ដែលប្រកបទៅដោយការអាក់អន់ចិត្តណា កើតដល់សត្វទាំងឡាយក្នុងលោកនេះ ព្រោះកាលសត្វទាំងឡាយប្រាថ្នាវត្ថុនោះៗ នៅតែមិនបានវត្ថុនោះៗ ការប្រាថ្នាវត្ថុដែលមិនមានផ្លូវនឹងបានទាំងឡាយ ( នុ៎ះឯង ) ជាហេតុរបស់ទុក្ខនោះ ដោយហេតុណា ព្រោះហេតុនោះ ទើបព្រះជិនស្រីត្រាស់ការមិនបានវត្ថុដែលប្រាថ្នាថាជាទុក្ខ ។

នេះជាវិនិច្ឆ័យក្នុងឥច្ឆិតាលាភទុក្ខ ។

# មហាដីកា

## ពណ៌នាឥច្ឆិតាលាភនិទ្ទេស

*ការមិនបានវត្ថុដែលខ្លួនប្រាថ្នាឯណានីមួយ ឈ្មោះថា* ***ឥច្ឆិតាលាភ*** *។ សេចក្តីនេះសមដោយព្រះបាលីត្រាស់ទុកថា* ***យម្បិច្ឆំ ន លភតិ*** *ប្រាថ្នារបស់ណា មិនបានរបស់នោះ ។ តែដើម្បីនឹងសម្តែងឥច្ឆិតាលាភឲ្យក្រៃលែងឡើង ទើបលោកលម្អិតទុកដោយពាក្យថា* ***នៃសត្វទាំងឡាយ ដែលមានការកើតជាធម្មតា*** *ដូច្នេះជាដើមក្នុងព្រះបាលី ព្រោះហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា* ***ឱហ្ន៎*** *ជាដើម ដើម្បីសម្តែងដល់ឥច្ឆិតាលាភឲ្យដល់កំពូលនោះឯង ។ ក្នុងបទថា* ***ឥច្ឆាវ*** *ប្រែថា ការប្រាថ្នានេះ លោកអាចារ្យទាំងឡាយពោលថា មិនទាន់បានមកនូវវត្ថុដែលគួរប្រាថ្នា ។ បទថា* ***តប្បរិយេសនរសា*** *ប្រែថា មានការស្វែងរកវត្ថុដែលមិនមានផ្លូវ នឹងបាននោះជាកិច្ច ។* ***អប្បត្តិ*** *ប្រែថា ការមិនបាន ។*

*ពណ៌នាឥច្ឆិតានិទ្ទេស ចប់ហើយ*

*ដោយប្រការ ដូច្នេះ ។*

# វិសុទ្ធិមគ្គ

## បញ្ចុបាទានក្ខន្ធទុក្ខ

ចំណែកក្នុងពាក្យថា ដោយសង្ខេបឧបាទានក្ខន្ធ ៥ ជាទុក្ខ នេះមានវិនិច្ឆ័យថា

ទុក្ខ តាំងអំពីជាតិទុក្ខមក យ៉ាងណា ដែលព្រះមានព្រះភាគជាម្ចាស់ទ្រទ្រង់តាទិគុណ ត្រាស់ទុកក្នុងទុក្ខនិទ្ទេសនេះហើយក្តី ទុក្ខណាដែលមិនបានត្រាស់ទុកក្នុងទុក្ខនិទ្ទេសនេះក្តី ទុក្ខទាំងពួងនោះ វៀរឧបាទានក្ខន្ធ ៥ នោះចេញក៏គ្មាន ដោយហេតុណា ព្រោះហេតុនោះ ឧបាទានក្ខន្ធទាំងឡាយនេះ ព្រះមហាឥសីអ្នកបង្ហាញទីបំផុតទុក្ខ ទើបត្រាស់ថា ជាទុក្ខដោយសង្ខេប ។

ពិតហើយ ទុក្ខធម៌ទាំងឡាយ មានជាតិជាដើមដែលបៀតបៀនឧបាទានក្ខន្ធទាំង ៥ នេះឯង ដោយប្រការផ្សេងៗ ដូចភ្លើងបៀតបៀនពូជ គឺឧស ដូចគ្រឿងប្រហារបៀតបៀនក្តារប៉ាយ ដូចសត្វល្អិតទាំងឡាយ មានរបោម និងមូសជាដើមបៀតបៀនគោ ដូចមនុស្សប្រូតស្រូវទាំងឡាយបៀតបៀនស្រែ ដូចពួកចោរប្លន់អ្នកស្រុក បៀតបៀនអ្នកស្រុក ក៏កើតត្រង់ឧបាទានក្ខន្ធទាំងឡាយនេះឯង ដូចស្មៅ និងវល្លិ៍ជាដើម កើតត្រង់ផែនដី ដូចផ្កាផ្លែ និងពន្លកកើតត្រង់ដើមឈើទាំងឡាយដូច្នោះ ។ ម្យ៉ាងទៀត ទុក្ខក្នុងខាងដើមរបស់ឧបាទានក្ខន្ធទាំងឡាយ ក៏គឺជាតិ ទុក្ខក្នុងកណ្តាល គឺជរា ទុក្ខក្នុងទីបំផុត គឺមរណៈ ទុក្ខ គឺការក្តៅ ( ចិត្ត ) ព្រោះប៉ះខ្ទប់មរណន្តិកទុក្ខ ( ទុក្ខ កាលជិតស្លាប់ ) ជាសោក ទុក្ខ គឺការខ្សឹកខ្សួល ព្រោះទ្រាំចំពោះទុក្ខនោះមិនបាន ជាបរិទេវៈ តទៅ ទុក្ខ គឺការឈឺកាយ ព្រោះប្រសព្វអនិដ្ឋផោដ្ឋព្វៈ ពោល គឺការកម្រើកនៃធាតុជាទុក្ខ ទុក្ខ គឺការឈឺចិត្ត ព្រោះកើតបដិឃៈក្នុងទុក្ខកាយនោះ នៃបុថុជ្ជនទាំងឡាយអ្នកដែលត្រូវសេចក្តីឈឺចាប់កាយនោះបៀតបៀន ជាទោមនស្ស ទុក្ខ គឺការអន្ទះអន្ទែង

របស់បុគ្គលទាំងឡាយ អ្នកដែលមានសេចក្តីសោកសង្រេង ដែលជាការបន្ថែមច្រើនឡើង នៃទុក្ខដែលពោលហើយ មានសោកជាដើមធ្វើឲ្យកើតឡើង ជាឧបាយាស ទុក្ខ គឺការមិនសមប្រាថ្នារបស់បុគ្គលទាំងឡាយ អ្នកបានទទួលការខុសសង្ឃឹមជាឥច្ឆិតាលាភ ព្រោះហេតុនោះ ឧបាទានក្ខន្ធទាំងឡាយនោះឯង ដែលកាលពិចារណាមើលដោយប្រការផ្សេងៗ ដូចពោលមកនេះ រមែងជាទុក្ខពិតមែន ។

បុគ្គលណាមួយ មិនអាចពោលទុក្ខតែម្យ៉ាងនេះ ដែលព្រះមានព្រះភាគត្រាស់សម្តែងទុកមិនឲ្យសេសសល់ ដោយកាលសូម្បីច្រើនកប្បបាន ព្រោះហេតុនោះ ព្រះសាស្តាជាម្ចាស់ទ្រង់សម្តែង ( ដោយ ) បង្រួញទុក្ខទាំងពួងនោះចូលក្នុងឧបាទានក្ខន្ធ ៥ គ្រប់យ៉ាង ដូចបង្រួញទឹកទន្លេទាំងអស់ ជាតំណក់ទឹកមួយតំណក់ ទើបបានត្រាស់ថា ដោយបង្រួញឧបាទានក្ខន្ធ ៥ ជាទុក្ខ ដូច្នេះ ។

នេះជាវិនិច្ឆ័យក្នុងឧបាទានក្ខន្ធទាំងឡាយ

នេះជាន័យក្នុងទុក្ខនិទ្ទេសជំបូង ។

# មហាដីកា

## ពណ៌នាបញ្ហាធាតុក្នុងនិទ្ទេស

ពាក្យថា **យំ វុត្តមិធ** ប្រែថា ទុក្ខណាព្រះមានព្រះភាគត្រាស់ទុកដោយសរុបក្នុងសច្ចនិទ្ទេសនេះ ។ បទថា **អវុត្តំ** សេចក្តីថា ត្រាស់ទុកក្នុង **ព្រះសូត្រទាំងឡាយមានទុក្ខក្ខន្ធសូត្រ** និង **ពាលបណ្ឌិតសូត្រជាដើម** តែមិនបានត្រាស់ទុកដោយសរុបក្នុងសច្ចនិទ្ទេសនេះ ។ ទុក្ខទាំងឡាយនោះ វៀរឧបាទានក្ខន្ធនេះចេញ រមែងមិនមាន ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា ដូចភ្លើងបៀតបៀនឧស ដើម្បីសម្តែងថា ទុក្ខមានខន្ធជាទីអាស្រ័យក្នុងឧបាទានក្ខន្ធនោះឯង ក៏រមែងបៀតបៀនខន្ធ ។ ប្រការមួយទៀត លោកអាចារ្យពោលថា ដូចគ្រឿងប្រហារបៀតបៀនក្តារប៉ាយជាដើម ដើម្បីនឹងសម្តែងក្តារប៉ាយជាវត្ថុនៃការប្រហារ ដោយគ្រឿងប្រហារ យ៉ាងណា ខន្ធក៏ជាទីតាំងនៃសង្ខារទុក្ខ យ៉ាងនោះ ។ មួយវិញទៀត គោជាទីតាំងនៃការរុកកួនរបស់របោម មូសជាដើម យ៉ាងណា ខន្ធក៏ជាទីតាំងនៃទុក្ខ មានជាតិទុក្ខជាដើម យ៉ាងនោះ ។ មួយវិញទៀត ស្រែជាទីតាំងនៃការច្រូតកាត់ ដែលសម្រេចហើយ យ៉ាងណា ខន្ធក៏ជាទីតាំងនៃសេចក្តីទុក្ខ មានជាតិទុក្ខជាដើម យ៉ាងនោះ ។ មួយវិញទៀត ស្រុកក៏ជាទីតាំងនៃការបៀតបៀនរបស់ចោរ យ៉ាងណា ខន្ធក៏ជាទីតាំងនៃទុក្ខ មានជាតិទុក្ខជាដើម យ៉ាងនោះដែរ ។ លោកអាចារ្យពោលថា **ស្មៅ និងវល្លិ៍ជាដើម** ក៏ដើម្បីសម្តែងថា ដោយច្រើនបុគ្គលបៀតបៀនក្នុងលោក វៀរវត្ថុដែលគប្បីបៀតបៀនមិនមាន តែខន្ធទាំងនេះក៏នៅអាស្រ័យវត្ថុដែលគប្បីបៀតបៀននោះឯង ។ ឈ្មោះថា ខាងដើម ក្នុងសង្សារដែលមិនមានខាងដើម រមែងមិនមានដល់បុគ្គលណាម្នាក់ ដោយពិត សូម្បីយ៉ាងនោះ លោកអាចារ្យពោលថា **ទុក្ខក្នុងខាងដើម ក៏គឺជាតិ** ដោយអំណាចនៃការបន្តរបស់ខន្ធ

ដែលកំណត់ដោយកពតែម្យ៉ាង ។ ដោយហេតុនោះ ទើបអាចារ្យពោលថា **ទុក្ខក្នុងទីបំផុត គឺមរណៈ** ។ ក្នុងពាក្យនេះលោកមិនមានបំណងយកសមុច្ឆេទមរណៈឡើយ ។ ទុក្ខដែលកើតក្នុងទីបំផុត គឺក្នុងវេលាជិតនឹងមរណៈ ឈ្មោះថា **ទុក្ខក្នុងកាលជិតស្លាប់** ។ **ការធេះរោលរាល** បានដល់ ការក្ដៅក្រហាយចិត្ត ។ **ការយំរៀបរាប់** បានដល់ ការកន្ទក់កន្ទេញហួសប្រមាណ ។ **ការឈឺចិត្ត** បានដល់ ការក្រៀមក្រំខាងក្នុង ។ពាក្យថា **ទុក្ខតែម្យ៉ាង** បានដល់ បណ្ដាទុក្ខដែលផ្សេងដោយប្រភេទក្នុងចន្លោះនៃជាតិទុក្ខជាដើម ឬទុក្ខ គឺឧបាទានក្ខន្ធទាំង ៥ មានជាតិទុក្ខជាដើមនោះឯង ជាទុក្ខម្យ៉ាងៗ ។ បទថា **សង្ខិបិត្វា** ប្រែថា សង្ខេប ឬទ្រង់ធ្វើការសង្ខេបដោយសាមញ្ញនិទ្ទេស ។

កថាពណ៌នាដោយទុក្ខនិទ្ទេស ចប់ហើយ

ដោយប្រការ ដូច្នេះ ។

# វិសុទ្ធិមគ្គ

## ទុក្ខសមុទយនិទ្ទេស

ចំណែកក្នុងសមុទយនិទ្ទេសមានវិនិច្ឆ័យថា ពាក្យថា **យាយំ តណ្ហា** សេចក្តីថា តណ្ហានេះ ពាក្យថា **បោនោព្ភវិកា** សេចក្តីថា កាលសាងភព ( ថ្មី ) ទៀត ឈ្មោះថា បុនព្ភវៈ ។ ការសាងភព ( ថ្មី ) ទៀតជាប្រក្រតីរបស់តណ្ហានោះ ហេតុនេះ ទើបតណ្ហានោះឈ្មោះថា **បោនោព្ភវិកា** ( មានការសាងភព < ថ្មី > ទៀត ជាប្រក្រតី ) តណ្ហានោះឈ្មោះថា **នន្ទិរាគសហគតា** ព្រោះទៅព្រមជាមួយនន្ទិរាគៈ អធិប្បាយថា ដល់នូវភាពជាមួយគ្នានឹងនន្ទិរាគៈដោយអត្ថ ។ ពាក្យថា **តត្រតត្រាភិនន្ទិនី** សេចក្តីថា តណ្ហាកើតក្នុងអត្តភាពណាមួយ ក៏មានប្រក្រតីត្រេកអរទៅក្នុងអត្តភាពនោះៗ ។ ពាក្យថា **សេយ្យថីទំ** ជានិបាត នេះជាអត្ថរបស់និបាតនោះ គឺបើសួរថា តណ្ហានោះដូចម្តេច ធម៌ទាំងឡាយនេះ គឺកាមតណ្ហា ភវតណ្ហា វិភវតណ្ហា នឹងមានច្បាស់ក្នុងបដិច្ច-សមុប្បាទនិទ្ទេស ចំណែកក្នុងទីនេះ តណ្ហាទាំង ៣ នេះ គប្បីជ្រាបថា ព្រះសាស្តាទ្រង់បញ្ចូលជាមួយគ្នា ត្រាស់ថាជាទុក្ខសមុទយអរិយសច្ច ដោយអត្ថថា ជាហេតុញុំាងទុក្ខសច្ចឲ្យកើត ។

# មហាដីកា

## កថាពណ៌នាអំពីសមុទយនិទ្ទេស

*បុនព្ភវករណំ* ជា *បុនព្ភវោ* ប្រែថា ការបង្កភពថ្មី ឈ្មោះថា *បុនព្ភវោ* ដោយការលុបបទខាងចុង តណ្ហា ឈ្មោះថា **បោនោព្ភវិកា** ព្រោះអត្ថថា មានការបង្កភពថ្មីជាប្រក្រតី ដូចគ្នានឹងបុគ្គលដែលមានការបរិភោគនំជាប្រក្រតី ឈ្មោះថា **អាបូបិកោ** នេះជាន័យមួយ តណ្ហាឈ្មោះថា **បោនោព្ភវិកា** ព្រោះអត្ថថា គួរដល់ផល គឺការបង្កភពថ្មី នេះជាន័យមួយ តណ្ហាឈ្មោះថា **បោនោព្ភវិកា** ព្រោះអត្ថថា មានការបង្កភពថ្មីនោះជាប្រយោជន៍ នេះជាន័យមួយ ។ តណ្ហាឈ្មោះថា **ប្រព្រឹត្តទៅដោយនន្ទិរាគៈ** ព្រោះប្រព្រឹត្តទៅមិនលះបង់នូវនន្ទិរាគៈ ព្រោះថា ត្រេកអរ និងព្រោះថា តម្រេកក្នុងអាការជាទីតាំងចុះក្នុងទីទាំងពួង ។ ដោយតណ្ហានោះ សត្វទាំងឡាយ រមែងត្រេកអរក្នុងភពជាដើមនោះៗ ក្នុងអត្តភាព មានជង្គរ សត្វល្អិត ជង្គរមេអំបៅជាដើម ហើយរមែងត្រេកអរដោយតណ្ហា ដែលជាគ្រឿងត្រេកអរក្នុងរូប ព្រោះដូច្នោះ ទើបតណ្ហាឈ្មោះថា **តត្រតត្រាភិនន្ទិនី** ប្រែថា មានការត្រេកអរនៅក្នុងភពនោះៗ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា ទៅជាមួយនន្ទិរាគៈ ។ ឯសហគតស័ព្ទនេះ មានតព្ភាវជាអត្ថ ។ គប្បីជ្រាបកាមតណ្ហា ភវតណ្ហា និងវិភវតណ្ហា ដោយការប្រព្រឹត្តទៅដោយអំណាចភាពផ្សេងគ្នានៃកាមភព និងវិភព ។តណ្ហាទាំង ៣ នេះ ឈ្មោះថា **ទុក្ខសមុទយអរិយសច្ច** ព្រោះជាហេតុនៃទុក្ខទាំងអស់ ព្រោះមានសភាពវិចិត្រយ៉ាងក្រៃលែង ដោយឲ្យសម្រេចកម្មឲ្យកើតការវិចិត្រនៃទុក្ខនោះៗ ព្រោះសត្វប្រភេទខ្លះ ក៏មានការៈដូចគ្នានឹងសត្វប្រភេទខ្លះ ដោយពពួកស្នេងដូចគ្នា ដោយការ

កាន់យកភាពដែលដូចគ្នា ដោយភាពជាតណ្ហាតែម្យ៉ាងប៉ុណ្ណោះ មិនបានកំណត់ដល់សេចក្ដីផ្សេងគ្នានៃតណ្ហា មានកាមតណ្ហាជាដើម ។

សួរថា ព្រោះហេតុអ្វី ទើបក្នុងអរិសច្ចទាំង ៤ នេះ លោកពោលតណ្ហាតែម្យ៉ាងថាជាសមុទយសច្ចទៅវិញ ? ឆ្លើយថា ព្រោះតណ្ហាជាហេតុពិសេស ។ ពិតហើយ អវិជ្ជាបិទបាំងទោសក្នុងភពទាំងឡាយ ហើយឧបាទាន មានទិដ្ឋុបាទានជាដើម ដែលប្រកាន់មាំក្នុងភពនោះ ក៏ញ៉ាំងតណ្ហាឲ្យចម្រើនក្រៃលែងឡើង សូម្បីកិលេស មានទោសៈជាដើម ក៏រមែងជាហេតុនៃកម្ម តែតណ្ហាប្រាថ្នាក្រៃលែងនូវធម្មជាតិវិចិត្រទៅដោយភពនោះៗ កំណើតនោះៗ គតិនោះៗ វិញ្ញាណដ្ឋិតិនោះៗ សត្តាវាសនោះៗ សត្តនិកាយនោះៗ ត្រកូលនោះៗ ភោគៈនោះៗ និងឥស្សរិយៈនោះៗ ជាដើម ចូលដល់នូវភាពជាឧបនិស្ស័យនៃភាពជាធម្មជាតិវិចិត្រដោយកម្ម និងភាពជាសម្ភារបស់កម្មរមែងកំណត់ភាពវិចិត្រដោយភពជាដើម ព្រោះដូច្នោះ គប្បីជ្រាបថា កាលមានហេតុនៃទុក្ខដទៃដែលត្រាស់ទុកក្នុងព្រះសូត្រមានអវិជ្ជា ឧបាទាននិងកម្មជាដើមដែលត្រាស់ទុកក្នុងព្រះអភិធម្ម មានកិលេសដ៏សេស និងអកុសលមូលជាដើម លោកក៏ពោលតណ្ហាប៉ុណ្ណោះថា ជាសមុទយសច្ច ព្រោះជាហេតុពិសេសនៃទុក្ខ ។

កថាពណ៌នាអំពីទុក្ខសមុទយនិទ្ទេស ចប់ហើយ

ដោយប្រការ ដូច្នេះ ។

# វិសុទ្ធិមគ្គ

## ទុក្ខនិរោធនិទ្ទេស

ក្នុងទុក្ខនិរោធនិទ្ទេស មានវិនិច្ឆ័យថា ដោយន័យថា យោ តស្សាយេវ តណ្ហាយ ជាដើម ជាការត្រាស់ការរលត់នៃសមុទ័យ ។ បើសួរថា ហេតុអ្វី ទើបត្រាស់ការរលត់នៃសមុទ័យ ? គប្បីមានពាក្យឆ្លើយថា ការរលត់នៃទុក្ខរមែងមាន ព្រោះការរលត់នៃសមុទ័យ មែនពិត ទុក្ខរមែងរលត់ ព្រោះការរលត់ទៅនៃសមុទ័យ មិនមែនហេតុដទៃឡើយ ហេតុនោះ ទើបត្រាស់ទុក ( ក្នុងធម្មបទ ) ថា

**ដើមឈើកាលគល់នៅមាំ មិនមានឧបទ្ទវ សូម្បីត្រូវកាត់ ( ចំណែកលើ ) ហើយ ក៏ដុះបានទៀត យ៉ាងណាក្តី សូម្បីទុក្ខនេះក៏ដូច្នោះ កាលតណ្ហានុស័យ ដែលមិនទាន់បានត្រូវដកចោល ក៏កើតបានទៀតទៅ ។**

ព្រោះហេតុដែលទុក្ខរមែងរលត់ ព្រោះការរលត់ទៅនៃសមុទ័យដូចពោលមកនោះឯង ព្រះមានព្រះភាគកាលទ្រង់សម្តែងការរលត់នៃទុក្ខ ទើបទ្រង់សម្តែងដោយការរលត់នៃសមុទ័យនោះឯង ។

ព្រះតថាគតទាំងឡាយ ជាអ្នកមានការប្រព្រឹត្តស្មើដូចសីហៈ លោកនឹងរលត់ទុក្ខ និងសម្តែងការរលត់នៃទុក្ខ រមែងបដិបត្តិក្នុងហេតុ មិនបានបដិបត្តិក្នុងផល ចំណែកតិរ្ថិយទាំងឡាយ មានការប្រព្រឹត្តស្មើដូចសុនខ គេនឹងរលត់ទុក្ខ និងសម្តែងការរលត់នៃទុក្ខ រមែងបដិបត្តិក្នុងផល ដោយសម្តែងអត្តកិលមថានុយោគជាដើម មិនមែនបដិបត្តិក្នុងហេតុទេ ដោយប្រការដូច្នេះ ។

ប្រយោជន៍ ( បំណង ) នៃការសម្តែងការរលត់នៃទុក្ខ ដោយអំណាចការរលត់នៃសមុទ័យ បណ្ឌិតគប្បីជ្រាបដោយន័យដូច្នេះសិន ។

# អធិប្បាយ អត្ថចាលី ទុក្ខនិរោធ

នេះជាអត្ថ ( នៃបាលីទុក្ខនិរោធ ) ។

ពាក្យថា **តស្សាយេវ តណ្ហាយ** សេចក្តីថា នៃតណ្ហាដែលព្រះមានព្រះភាគត្រាស់ ( លក្ខណៈ ) ថា **បោនោព្ភវិកា**-មានការសាងភព ( ថ្មី ) ទៀតជាប្រក្រតីជាដើម ហើយទ្រង់ចែកដោយប្រភេទ មានកាមតណ្ហាជាដើមនោះ ។

មគ្គ ហៅថា **វិរាគៈ**-ការប្រាសចាកតម្រេក ព្រោះព្រះបាលីថា **វិរាគា វិមុច្ចតិ**-រមែងរួចផុតព្រោះវិរាគៈ ការរលត់ដោយខ្ជាក់ចេញ ឈ្មោះថា វិរាគនិរោធ ការរលត់ដោយខ្ជាក់ចេញដោយមិនមានសេសសល់ ព្រោះអនុស័យបាន ឈ្មោះថា អសេសវិរាគនិរោធ ។ ន័យម្យ៉ាងទៀត ការលះ ក៏ហៅថា វិរាគៈ ព្រោះដូច្នោះក្នុងបទថា អសេសវិរាគនិរោធោនេះ បណ្ឌិតគប្បីឃើញ ( ថា ) ប្រកបសេចក្តីថា ការលះមិនមានសេសសល់ ការរលត់មិនមានសេសសល់ ដូច្នេះក៏បានតែ ( កាលពោល ) ដោយសេចក្តីពិត បទទាំងពួងនោះជាវេវចនៈរបស់និព្វានទាំងអស់ ព្រោះព្រះនិព្វានព្រះមុនីត្រាស់ហៅថា ទុក្ខនិរោធអរិយសច្ច ដោយបរមត្ថ ក៏ហេតុណាតណ្ហាខ្ជាក់ចេញ និងរលត់ទៅបាន ក៏ព្រោះ ( ព្រះយោគាវចរ ) អាស្រ័យព្រះនិព្វាននោះ ( ជាអារម្មណ៍ ) ព្រោះហេតុនោះ ទើបព្រះនិព្វាននោះ ត្រាស់ហៅថា វិរាគៈ និងថា និរោធផង ម្យ៉ាងទៀត ហេតុណា ធម៌ទាំងឡាយ មានការលះបង់ទៅនៃតណ្ហានោះជាដើម រមែងមានឡើងបាន ក៏ព្រោះអាស្រ័យព្រះនិព្វាននោះៗ ឯងម្យ៉ាងទៀតសោត បណ្តាអាល័យទាំងឡាយ មានកាមគុណាល័យជាដើម អាល័យសូម្បីតែម្យ៉ាងរមែងមិនមានក្នុងព្រះនិព្វាននោះ ព្រោះហេតុនោះ ទើបព្រះនិព្វាននោះត្រាស់ហៅថា **ចាគ បដិនិស្សគ្គ វិមុត្តិ អនាលយ** ។

ព្រះនិព្វានេះ មានការស្ងប់ជាលក្ខណៈ មានការមិនឃ្លាត ( គឺមិនប្រែសភាព ) ជារស ឬថា មានការធ្វើការលួងលោមចិត្តជារស ( ក៏បាន ) មានការមិនមាននិមិត្ត ( គឺមិនមានគ្រឿងសម្គាល់នៃទុក្ខ ) ជាបច្ចុប្បដ្ឋាន ឬមានការមិនមានគ្រឿងជាប់ជំពាក់ស្អិតនៃចិត្តជាបច្ចុប្បដ្ឋាន ។

## បញ្ហាកំចាំងក្នុងរឿងព្រះនិព្វាន

បើមានពាក្យអះអាងថា មិនមានទេព្រះនិព្វានហ្នឹង ព្រោះមិនមែនជាវត្ថុដែលនឹងគប្បី ( រកបាន ) ដូចស្នែងទន្សាយ ដូច្នោះ ដូច្នេះសោត គប្បីមានពាក្យឆ្លើយថា ព្រះនិព្វានមិនមែនមិនមានទេ ព្រោះព្រះនិព្វាននោះ ជាធម្មជាតិដែលគប្បី ( រក ) បានដោយឧបាយ មែនពិត ព្រះនិព្វាននោះ ( រមែងរក ) បានដោយឧបាយ ពោល គឺការបដិបត្តិដ៏សមគួរដល់ព្រះនិព្វាននោះ ដូចលោកុត្តរចិត្តរបស់បុគ្គលដទៃៗ ព្រះអរិយៈរមែងដឹងបានដោយចេតោបរិយញ្ញាណដូច្នោះ ហេតុនោះ ទើបមិនគួរពោលថា ព្រះនិព្វានមិនមាន ព្រោះមិនមែនវត្ថុដែលគប្បីបាន ដែលបុថុជ្ជនល្ងង់ខ្លៅមិនបាន ( ប្រទះ ) វត្ថុណា វត្ថុនោះរមែងមិនមាន ដូច្នេះ មិនគួរនឹងពោល ( ព្រោះលោកអ្នកបានប្រទះមានពិត )។ ម្យ៉ាងទៀត មិនគួរពោលថាព្រះនិព្វានមិនមានព្រោះអ្វី ? ព្រោះត្រូវមិនមានសារៈ ក្នុងការបដិបត្តិ ។ ពិតហើយ កាលព្រះនិព្វានមិនមានការបដិបត្តិប្រពៃដែលសង្គ្រោះក្នុងធម្មក្ខន្ធ ៣ មានសីលក្ខន្ធជាដើម ដែលមានសម្មាទិដ្ឋិនាំមុខ ក៏ត្រូវឥតសារៈ តែការបដិបត្តិប្រពៃនេះ មិនទទេឡើយ ព្រោះជាហេតុឲ្យដល់ព្រះនិព្វានបានពិត ។

បើមានពាក្យជំទាស់ថា ព្រោះត្រូវភាពមិនមានសារៈនៃការបដិបត្តិមិនមានទេ ព្រោះការបដិបត្តិនោះ ក៏ជាហេតុឲ្យដល់នូវការមិនមាន ដូច្នោះសោត គប្បីមានពាក្យឆ្លើយថា ( ការមិនមានព្រះនិព្វាន ) មិនមែនទេ ព្រោះមិនមានការសម្រេចព្រះនិព្វាន

ព្រោះការមិន មាន ( ខន្ធ ) អតីត និងអនាគត មិនមានខន្ធអតីត អនាគតក៏សម្រេចព្រះនិព្វានបាន ។

បើជំទាស់ទៀតថា ( មិនមែនតែខន្ធអតីត អនាគតប៉ុណ្ណោះទេ ) សូម្បីមិនមានវត្តមានក្ខន្ធ ( គឺខន្ធបច្ចុប្បន្ន ) ទាំងឡាយ ក៏ជានិព្វានផង ដូច្នេះសោត គប្បីមានពាក្យឆ្លើយថា មិនមែនទេ ព្រោះព្រះនិព្វានមិនមែនមានបានព្រោះការមិនមានវត្តមានក្ខន្ធទាំងនោះទេ ។ ម្យ៉ាងទៀត ព្រោះកាលវត្តមានក្ខន្ធមិនមាន ព្រះនិព្វានក៏ដល់នូវការមិនប្រព្រឹត្តទៅ ( ផង ) ( មិនមែនមិនមានវត្តមានក្ខន្ធហើយជានិព្វានទេ ) និងព្រោះទោសគឺមិនមានការសម្រេចសឧបាទិសេសនិព្វានធាតុក្នុងខណៈនៃមគ្គចិត្ត ដែលអាស្រ័យវត្តមានក្ខន្ធផង ( គឺថា ក្នុងខណៈនៃមគ្គនឹងសម្រេចព្រះនិព្វានមិនបាន ) ។

បើជំទាស់ទៀតថា ទោសមិនមាន ព្រោះក្នុងខណៈ ( នៃមគ្គ ) នោះ កិលេសទាំងឡាយក៏មិនប្រព្រឹត្តទៅ ( ហើយ ) ដូច្នោះសោត គប្បីមានពាក្យឆ្លើយថា មិនមែនទេ ព្រោះ ( បើក្នុងខណៈនៃមគ្គ កិលេសមិនប្រព្រឹត្តទៅទេ ) អរិយមគ្គក៏ដល់នូវការមិនមានប្រយោជន៍ ពិតហើយ កាលបើយ៉ាងនោះ កិលេសទាំងឡាយក៏ ( ជាការ ) មិនមានមកសោះអំពីមុនខណៈនៃអរិយមគ្គ ព្រោះដូច្នោះ អរិយមគ្គក៏ត្រូវដល់ការមិនមានប្រយោជន៍ ។

ព្រោះហេតុដូចពោលមកនោះ ពាក្យថា ( ព្រះនិព្វានមិនមាន ព្រោះជាវត្ថុ ដែលមិនមានដូចស្នែងទន្សាយ និងថា ការបដិបត្តិមិនមានសារៈ ព្រោះការបដិបត្តិនោះ ជាហេតុឲ្យដល់ការមិនមាន និងថា ទោស គឺសម្រេចព្រះនិព្វានក្នុងខណៈនៃមគ្គមិនបាននោះមិនមាន ព្រោះក្នុងខណៈនៃមគ្គ កិលេសក៏មិនប្រព្រឹត្តទៅឡើយ ) នោះ មិនមែនជាហេតុ ( គឺមិនប្រពៃដល់ហេតុ ) ។

បើមានពាក្យអះអាងទៀតថា **ខយោ**-ការអស់ទៅជាព្រះនិព្វានដោយព្រះបាលី

ថា **យោ ខោ អាវុសោ រាគក្ខយោ**-ម្នាលអាវុសោ ការអស់ទៅនៃរាគៈណាជាដើម ដូច្នេះ សោត គប្បីមានពាក្យឆ្លើយថា មិនមែនដូច្នោះឡើយ ព្រោះត្រឹមតែការអស់ សំដៅដល់ព្រះអរហត្តក៏បាន ព្រោះព្រះអរហត្តនោះ លោកក៏សម្តែងទុក ដោយន័យថា **យោ ខោ អាវុសោ រាគក្ខយោ** ជាដើមដូចគ្នា នៅមាន ( ខុស ) អ្វីៗ តទៅទៀត គឺ ( ការពោលត្រឹមតែថា ការអស់កិលេសជានិព្វាននោះមិនប្រពៃ ) ព្រោះទោស គឺព្រះនិព្វាន ក្លាយជាធម្មជាតិមានគ្រប់កាលដ៏ខ្លីជាដើមទៅ ពិតហើយ កាលបើដូច្នោះ ព្រះនិព្វាន ក៏ដល់នូវភាពជាធម្មជាតិមានរហូតកាលដ៏ខ្លី ភាពជាធម្មជាតិមានលក្ខណៈនៃសង្ខតធម៌ និងភាពជាធម្មជាតិដែលនឹងគប្បីសម្រេចបាន ដោយមិនអើពើដល់សម្មាវាយាមៈទៅសោះផង ម្យ៉ាងទៀត ព្រោះភាពជាធម្មជាតិមាន លក្ខណៈនៃសង្ខតធម៌នោះឯង ព្រះនិព្វានក៏ ( ហួស ) ដល់នូវភាវៈ គឺជាធម្មជាតិ រាប់ចូលក្នុងសង្ខតធម៌ទៅ ព្រោះជាធម្មជាតិរាប់ចូលក្នុងសង្ខតធម៌ ក៏ ( ហួស ) ដល់នូវភាវៈ គឺជាធម្មជាតិត្រូវភ្លើង គឺរាគៈជាដើមដុតយកបាន ព្រោះជាធម្មជាតិត្រូវដុត ក៏ ( ហួស) ដល់នូវភាវៈ គឺជាទុក្ខទៅទៀតផង បើមានពាក្យជំទាស់ទៀតថា ទោសមិនមាន ព្រោះការប្រព្រឹត្តទៅ ( នៃកិលេស ) ឈ្មោះថា មិនមានតទៅទៀត ចាប់ដើមអំពីការអស់ ( គ្រាចុងក្រោយ ) ណា ការអស់នោះជានិព្វាន ដូច្នេះសោត គប្បីមានពាក្យឆ្លើយថា មិនមែនទេ ព្រោះមិនមានការអស់ ដូច្នោះ ។ ប្រការមួយទៀត ព្រោះសូម្បីមានការអស់នោះ ក៏មិនកន្លងទោសមានប្រការដូចពោលហើយ និងព្រោះអរិយមគ្គនឹងក្លាយជានិព្វានទៅដែរ ។ ពិតហើយ អរិយមគ្គរមែងញ៉ាំងទោសទាំងឡាយឲ្យអស់ ព្រោះដូច្នោះ ទើបលោកហៅ **ខយោ** ( ផង ) និងតាំងអំពីនោះទៅ ការប្រព្រឹត្តទៅ ( នៃទោស ) ក៏មិនមានតទៅទៀត តែព្រោះព្រះនិព្វាននោះជាឧបនិស្ស័យ ( គឺជាទីអាស្រ័យមាំ ) ដោយបរិយាយនៃខយៈ ( គឺមគ្គ ) ដែលបានដល់អនុប្បត្តិនិរោធ ( និរោធ គឺការ

មិនកើតឡើង ) ទើបព្រះនិព្វាននោះលោកហៅថា **ខយោ** ( ផង ) ដោយវោហារដែលជាឧបចារៈ ( គឺទាក់ទងគ្នាជាមួយ ) វត្ថុដែលមានព្រះនិព្វានជាឧបនិស្ស័យ ។

បើមានពាក្យសួរថា ព្រោះហេតុអ្វី ទើបព្រះនិព្វាននោះ ព្រះមានព្រះភាគមិនត្រាស់ដោយសរុបតែម្តងទៅ ដូច្នេះសោត គប្បីមានពាក្យឆ្លើយថា ព្រោះព្រះនិព្វានជាធម៌សុខុមក្រៃលែង ការដែលព្រះនិព្វាននោះជាធម៌សុខុមក្រៃលែង ជាការដែលសម្រេច ( គឺប្រាកដទូទៅ ) ហើយ ព្រោះជាហេតុនាំមកនូវភាពជាអ្នកខ្វល់ខ្វាយតិចនៃព្រះមានព្រះភាគ និងព្រោះជាធម៌ដែលត្រូវឃើញដោយអរិយចក្ខុ ព្រោះហេតុនោះទើបព្រះនិព្វាននោះ ជាធម្មជាតិមិនទូទៅ ព្រោះជាធម៌ដែលបុគ្គល អ្នកប្រកបព្រមដោយមគ្គ ( ប៉ុណ្ណោះ ) នឹងគប្បីដល់បាន ជាធម្មជាតិមិនមានដែនកើត ព្រោះមិនមានខាងដើមខាងចុង ។

បើមានពាក្យជំទាស់ថា ព្រះនិព្វាន មិនមែនធម្មជាតិ មិនមានដែនកើតទេ ព្រោះកាលមានមគ្គ ទើបមានបាន ដូច្នេះសោត គប្បីមានពាក្យឆ្លើយថា មិនមែនដូច្នោះឡើយ ព្រោះព្រះនិព្វាន មិនមែនជាធម្មជាតិដែលមគ្គគប្បីធ្វើឲ្យកើតឡើងបាន ។ មែនពិតព្រះនិព្វាននោះ ជាធម្មជាតិដែលបុគ្គលដល់ដោយមគ្គប៉ុណ្ណោះ មិនមែនមគ្គឲ្យកើតឡើងបាន ព្រោះដូច្នោះ ទើបព្រះនិព្វានមិនមានដែនកើតពិត ព្រោះមិនមានដែនកើតទើបមិនមានជរាមរណៈ ព្រោះមិនមានដែនកើត និងជរាមរណៈ ទើបទៀង ។

បើមានពាក្យជ្រៀតទៀតថា សូម្បីអណូជាដើមក៏ដល់នូវភាវៈដ៏ទៀង ដូចព្រះនិព្វាន ដូច្នេះសោត គប្បីមានពាក្យឆ្លើយតបថា អណូជាដើមនោះ មិនបានឈ្មោះថាទៀងទេ ព្រោះមិនមានហេតុ ( ដែលនឹងឲ្យចូលដល់ ) បើមានពាក្យជ្រៀតបញ្ជាក់ទៀតថា ព្រោះព្រះនិព្វានទៀង វត្ថុទាំងនោះក៏ទៀង ដូច្នេះសោត គប្បីមានពាក្យឆ្លើយតបថា មិនមែនទេ ព្រោះវត្ថុទាំងនោះ មិនចូលលក្ខណៈនៃហេតុ ( មានភាពជាធម៌

ដែលគប្បីប្រាថ្នាបានជាដើម បើមានពាក្យជ្រៀតទៀតថា វត្ថុទាំងនោះចាត់ជារបស់ទៀង ព្រោះមិនមានហេតុឲ្យកើតឡើងជាដើម ដូចព្រះនិព្វាន ដូច្នេះសោត គប្បីមានពាក្យឆ្លើយតបថា មិនមែនទេ ព្រោះអណូជាដើម មិនសម្រេចផល ( គឺមិនឲ្យផលឲ្យប្រាកដ ) ។

ព្រះនិព្វាននេះប៉ុណ្ណោះទៀងពិត ព្រោះមានសភាវៈ គឺភាពត្រឹមត្រូវ ( ប្រពៃដោយហេតុផល ) ដូចពោលហើយ ជាអរូប ព្រោះកន្លងបង់នូវសភាវៈនៃរូប ( មានការទ្រុឌទ្រោមជាដើម ) មិនមែនវត្ថុ មិនមានដោយបរមត្ថ ព្រោះជាវត្ថុដែលគប្បីសម្រេចបានដោយញាណពិសេស ដែលសម្រេចដោយការប្រឹងប្រែងដ៏មិនធូរថយ និងព្រោះជាព្រះតម្រាស់របស់ព្រះសព្វញ្ញូផង ពិតហើយ ព្រះសព្វញ្ញូជាម្ចាស់ បានត្រាស់ពាក្យនេះទុកថា ម្នាលភិក្ខុទាំងឡាយ មានពិត ធម្មជាតិដែលមិនកើត មិនឧប្បត្តិ ដែលហេតុណាមួយមិនបានធ្វើឡើង ដែលបច្ច័យណាមួយ មិនបានតាក់តែងឡើង ដូច្នេះ ។

នេះជាពាក្យវិនិច្ឆ័យដែលសំខាន់ក្នុងទុក្ខនិរោធនិទ្ទេស ។

# មហាដីកា

## កថាពណ៌នាអំពីទុក្ខនិរោធនិទ្ទេស

បទថា **តស្សាយេវ** សេចក្តីថា តណ្ហា លោកហៅថា **សមុទយសច្ច** ដោយចំណែកណា ចុះអវធារណៈថា **តស្សាយេវ** ដោយចំណែកនោះ ។ កាលមានការលត់ហេតុដែលជាប្រធាន ហេតុដទៃក្រៅអំពីហេតុដែលជាប្រធាននោះក៏រមែងត្រូវលត់ទៅនោះឯង ព្រោះដូច្នោះ ការរលត់ផល ដោយការរលត់ហេតុ ដូចគ្នានឹងការចូលទៅស្ងប់ព្យាធិ រមែងមានបានដោយការចូលទៅស្ងប់ហេតុនៃព្យាធិ ព្រោះដូច្នោះទើបលោកអាចារ្យពោលថា **ការលត់ទុក្ខបាន ក៏ដោយការរលត់សមុទយៈ** ។ ពាក្យថា **មិនមែនដោយប្រការដទៃ** លោកអាចារ្យសម្តែងដល់ផល តាមដែលបានពោលទុកហើយ ប្រព្រឹត្តទៅដោយចំណែកមួយ ។

ពាក្យថា **មិនមានអន្តរាយ** គឺវៀរចាកអន្តរាយ មានសត្វល្អិតចោះ និងការទម្លាយដោយសស្ត្រាជាដើម ។ ព្រោះហេតុនោះឯង ឈ្មោះថា **មាំទាំ** គឺជាថាវរៈ ។ សូម្បីត្រូវកាត់ដោយការលះមែកជាដើម ។ ពាក្យថា កាល **តណ្ហានុស័យ** បានដល់ កាមរាគានុស័យ និងភវរាគានុស័យ ។ ពាក្យថា **ដែលមិនទាន់ដកចេញ** គឺនៅមិនទាន់ដកចេញជាសមុច្ឆេទ ។ លោកអាចារ្យពោលពាក្យមានជាដើមថា **មានការប្រព្រឹត្តស្មើដោយសីហៈ** ដូច្នេះ ដើម្បីនឹងសម្តែងសេចក្តីនេះថា ឧបមាដូចសីហៈ ត្រូវបុគ្គលណាបាញ់ព្រួញចូលទៅត្រង់ខ្លួន ក៏រមែងសម្តែងកម្លាំងរបស់ខ្លួនក្នុងបុគ្គលនោះប៉ុណ្ណោះ មិនសម្តែងកម្លាំងក្នុងព្រួញ ព្រះសាស្តាទាំងឡាយ ទ្រង់ក៏បដិបត្តិក្នុងហេតុ មិនមែនបដិបត្តិក្នុងផល ដូច្នោះដែរ ។ ចំណែកពួកសុនខ កាលបុគ្គលណាម្នាក់ គប់វែងដោយដុំដី ក៏ព្រុសខាំដុំដី មិនបានព្យាយាមទៅត្រង់បុគ្គលគប់វែង យ៉ាងណា ពួកអន្យតិត្ថិយ

ក៏ដូច្នោះ ត្រូវការនឹងរំលត់សេចក្ដីទុក្ខ រមែងខ្វល់ខ្វាយក្នុងការកាត់ កាយមិនខ្វល់ខ្វាយក្នុងការរំលត់កិលេស ។

**មគ្គហៅថា វិរាគៈ** ព្រោះអត្ថថា ជាហេតុខ្ទាក់ គឺទម្លាយសមុទយៈ ។ ការខ្ទាក់ ការទម្លាយ ការកាត់ ជាសមុច្ឆេទ ឈ្មោះថា វិរាគៈ **បហាន ហៅថា វិរាគៈ** ។ ឈ្មោះថា **ព្រោះហេតុនោះ** សេចក្ដីថា **វិរាគ-ស័ព្ទ** និង **និរោធ-ស័ព្ទ** ជាបរិយាយនៃ **បហាន** ព្រោះហេតុណា ហេតុនោះ ពាក្យដែលគួរនឹងភ្ជាប់គ្នាថា ការខ្ទាក់មិនសេសសល់ គឺការរលត់មិនមានសេសសល់ ព្រោះដកអនុស័យបានជាសមុច្ឆេទ ។ លោកអាចារ្យកាន់យកបទថា ចាគៈជាដើម ពោលថា **ពាក្យទាំងអស់នោះឯង** ។ ព្រោះលោក**ពោលដល់និព្វាន** មិនមែនពោលត្រឹមតែការរំលត់ទុក្ខ ដូច្នោះ សូម្បីបទជាដើមថា ការរលត់ គឺការខ្ទាក់មិនមានសេសសល់នៃតណ្ហា ក៏ជាវេវចនស័ព្ទនៃនិព្វាន ។ បទថា **យស្មា បទ** ជាដើមជាពាក្យដែលបានធ្វើអត្ថ ដែលបានពោលទុកហើយនោះឯងឲ្យច្បាស់ឡើង ។ ជាពាក្យសម្ដែងដល់ប្រការដែលបទថា វិរាគៈជាដើម ប្រើនៅក្នុងនិទាន ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **ព្រោះអាស្រ័យនិព្វាននោះ** គឺព្រោះសម្រេចនិព្វាននោះដោយអំណាចការធ្វើឲ្យជាអារម្មណ៍ ។ ពាក្យថា **តណ្ហា** រមែងខ្ទាក់ទៅ សេចក្ដីថា តណ្ហារមែងត្រូវអរិយមគ្គខ្ទាក់ចេញទៅ ដោយអំណាចការខ្ទាក់យ៉ាងពិត ។ ពាក្យថា **រមែងរលត់ទៅ** គឺរមែងត្រូវអរិយមគ្គធ្វើឲ្យរលត់ទៅ ដោយហេតុនោះ ទើបលោកអាចារ្យពោលវិរាគស័ព្ទ និងនិរោធស័ព្ទជាអធិករណសាធន ។ បទថា **តទេវ** ប្រែថា និព្វាននោះឯង ។ ពាក្យថា **ធម៌ទាំងឡាយមានការលះបង់ជាដើមរមែងមាន** លោកអាចារ្យរមែងពោលដល់ហេតុ មានការលះបង់ជាដើមដោយវោហារថា ជាផល ។ក្នុងគម្ពីរទាំងឡាយរចនាទុកថា **កាមគុណាលយេសុ** តែបាឋៈថា **កាមគុណាលយាទីសុ** ។

ពាក្យថា **តយិទំ** ជាដើម មិនមែនបាឋៈចាស់ ។ តែបានអំណាចមកអំពីនោះ

តាំងទុកខាងក្រោយ ដោយទំនងដែលបានពោលទុក **ក្នុងវគ្គដែលសម្តែងអត្ថរបស់សច្ចៈ** ។ ពិតហើយ បកិណ្ណកៈមានលក្ខណៈជាដើម សូម្បីបានពោលទុកខាងដើម លោកក៏បានពោលទុកទៀត ។ ឈ្មោះថា **មានការធ្វើការលួងលោមចិត្តជារស** ព្រោះដូចជាបុគ្គលធ្វើការលួងចិត្តដល់បុគ្គល ដែលមានចិត្តនឿយណាយអំពីសង្សារទុក្ខ ឈ្មោះថា **ជាធម្មជាតិមិនយឺតយូរជាបច្ចុប្បដ្ឋាន** ព្រោះញ៉ាំងធម្មជាតិមិនយឺតយូរ ឲ្យចូលទៅតាំងនៅចំពោះ ដោយភាវៈជាហេតុនៃការចូលទៅស្ងប់ ធម៌ជាហេតុយឺតយូរទាំងឡាយ មានរាគៈជាដើម ។ ពាក្យថា **និព្វានមិនមាន** សេចក្តីថា បើប្តេជ្ញាដោយសន្និដ្ឋាន និព្វានដែលខ្លួនមានបំណងក៏មិនមាន បើដូច្នោះក៏នឹងខុសប្តេជ្ញា ។ ប្រសិនបើសំដៅដល់និព្វានដែលអ្នកដទៃបានដល់ កាលបើយ៉ាងនេះក៏នឹងមិនសម្រេចត្រឹមត្រូវតាមធម៌ ព្រោះហេតុនោះ ក៏ជាហេតុដែលមិនសម្រេចដោយធម៌ជាទីអាស្រ័យ ពាក្យថា **ព្រោះជាវត្ថុដែលមិនមាន** សេចក្តីថា វត្ថុដែលមិនមាន ដោយប្រចក្ស ឬពោលដោយអនុមានក្នុងចំណែកដំបូងក៏ត្រូវមានដោយចំណែកមិន មែនតិចក្នុងទ្វារ មានចក្ខុទ្វារជាដើម ក្នុងចំណែកទី ២ ក៏ជាហេតុមិនសម្រេចបាន ដោយសំដៅដល់អ្នកដទៃ ។ ដោយហេតុនោះឯង ទើបលោកអាចារ្យពោលពាក្យជាដើមថា **មិនមែនមិនមាន ព្រោះព្រះនិព្វាន ជាវត្ថុដែលរកបានដោយឧបាយ** ។ ក្នុងពាក្យនោះមានឧបមាថា ព្រះអរិយៈទាំងឡាយ ដែលបានចេតោបរិយញ្ញាណនោះ រមែងដឹងលោកុត្តរចិត្តរបស់ព្រះអរិយៈដទៃ ឯក្នុងព្រះអរិយៈទាំងនោះ ព្រះអរហន្តប៉ុណ្ណោះ ទើបដឹងលោកុត្តរចិត្តរបស់ព្រះអរិយៈទាំងឡាយ មិនមែនព្រះអរិយៈទាំងអស់ដឹងនោះទេ សេចក្តីនេះយ៉ាងណា សូម្បីព្រះនិព្វានក៏ដូច្នោះ រមែងបានដោយឧបាយដែលជាសម្មាបដិបត្តិ គឺសីល សមាធិ បញ្ញា ព្រោះដូច្នោះ ទើបសេចក្តីនេះគប្បីឃើញថាជាពាក្យដែលសម្តែងដល់អត្ថ មិនមែនពាក្យសម្តីដែលសម្តែងដល់ប្រយោគ ។ ពាក្យនោះនឹងមានច្បាស់ខាងមុខ ។

ពាក្យថា **និព្វានមិនមាន បុគ្គលណាម្នាក់មិនគួរពោល** អធិប្បាយថា ព្រះនិព្វាន ដែលព្រះអរិយៈទាំងឡាយគប្បីបាន ន័យនេះសម្រេចបានដោយលទ្ធិទាំងអស់ថា បុគ្គលទាំងអស់ដែលមានចិត្តស្វែងគេហើយអំពីសង្សារវដ្ត រមែងចាក់ធ្លុះនិព្វានបាន ដោយសម្មាបដិបត្តិ ។ ក្នុងចម្លើយនោះលោកអាចារ្យពោលថា **ព្រោះការបដិបត្តិនឹងត្រូវឥតប្រយោជន៍** ដូច្នេះ ព្រោះអាស្រ័យការបដិបត្តិផ្លូវសាសនានោះឯង ។ ដោយហេតុនោះទើបលោកអាចារ្យពោលពាក្យមានអាទិ៍ថា **ព្រោះកាលនិព្វានមិនមាន** ដូច្នេះ ។ បទថា **សម្មាទិដ្ឋិបុរេជវាយ** ប្រែថា មានសម្មាទិដ្ឋិជាខាងមុខ ។ សម្មាទិដ្ឋិនោះជាខាងមុខ ព្រោះសម្មាទិដ្ឋិនោះជាប្រធាន ។ ពិតយ៉ាងនោះ សម្មាទិដ្ឋិនោះ ព្រះសាស្តាទ្រង់លើកឡើងកាន់ទេសនាមុន មិនមែនព្រោះកើតមុនធម៌ទាំងឡាយនោះទេ ។ **ម្យ៉ាងទៀត** សម្មាបដិបត្តិ **នេះមិនឥតប្រយោជន៍ឡើយ ព្រោះធ្វើឲ្យដល់និព្វាន** គឺព្រោះញ៉ាំងនិព្វានឲ្យដល់ព្រមមានពាក្យប្រកបថា តែតាមមតិរបស់លោកក៏ត្រូវឥតប្រយោជន៍ ព្រោះនិព្វាននោះឯងមិនមាន ។ ពាក្យថា **ព្រោះធ្វើឲ្យដល់នូវការមិនមាន** អធិប្បាយថា បើអាចារ្យអ្នកចោទពោលថា ព្រោះសម្មាបដិបត្តិជាកិរិយាដែលឲ្យដល់ព្រមនូវការមិនមាននៃខន្ធទាំងឡាយដោយការដកកិលេសបានជាសមុច្ឆេទជាសំខាន់ មិនមែនត្រូវឥតប្រយោជន៍ឡើយ ។ ស័ព្ទថា ន ប្រព្រឹត្តទៅក្នុងការបដិសេធ ។ គឺថា ប្រការណា ដែលលោកពោលថា ព្រោះការបដិបត្តិធ្វើឲ្យដល់នូវការមិនមាន ដូច្នេះ ក៏ដោយព្រមទទួលថា ការមិនមានខន្ធ ឈ្មោះថា និព្វាន សេចក្តីនោះមិនមែនទេ ។ ព្រោះអ្វី ? **ព្រោះកាលមិនមានខន្ធអតីត និងខន្ធអនាគត ការសម្រេចនិព្វានក៏មិនមាន** ។ ពិតហើយ ខន្ធដែលជាអតីត និងអនាគតរមែងមិនមាន ព្រោះដូច្នោះ និព្វាន ក៏គប្បីឈ្មោះថាជាការត្រូវបានសម្រេចហើយ ព្រោះការមិនមាននោះ តែការមិនមាននោះ មិនមែនដូច្នេះឡើយ ។ មិនមែនតែខន្ធអតីត អនាគត តែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត សូម្បីខន្ធបច្ចុប្បន្នផងដែរ ព្រោះ

ដូច្នោះ ការមិនមាននៃខន្ធទាំងឡាយ មាននៅក្នុងអទ្ធាទាំង ៣ ទើបឈ្មោះថា **និព្វាន** ។ ពិតហើយ និព្វាននោះសមគួរជាការមិនមាន ក្នុងចំណែកខ្លះក៏មិនមែន ព្រោះដូច្នោះ បើជាបច្ចុប្បន្នក្ខន្ធនឹងមិនមានក៏ទេ បើមិនមាន ក៏មិនជាបច្ចុប្បន្នក្ខន្ធ ព្រោះដូច្នោះ សេចក្តីនេះ បច្ចុប្បន្នក្ខន្ធផង មិនមានផង ទើបជាប្រការដែលជំទាស់គ្នា ព្រោះដូច្នោះ ទើបអាចារ្យអ្នកឆ្លើយពោលថា **មិនមែន ព្រោះបច្ចុប្បន្នក្ខន្ធទាំងនោះក៏មានការមិនមាន កាលមិនមានជាបច្ចុប្បន្នក្ខន្ធមិនបាន** ។

នឹងពោលបន្ថែមបន្តិចទៀត: ប្រសិនបើមិនមានបច្ចុប្បន្នជានិព្វានសោត ការមិនមាននិព្វានក៏នឹងគប្បីមានក្នុងកាលនោះ ព្រោះអធិប្បាយថា អរិយមគ្គប្រព្រឹត្តទៅក្នុងកាលណា ខន្ធដែលជាទីអាស្រ័យរបស់អរិយមគ្គនោះ ក្នុងកាលនោះ ក៏ជាខន្ធបច្ចុប្បន្ន ។ លោកអាចារ្យកាលសម្តែងថា បើដូច្នោះ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានក្នុងខណៈនៃមគ្គក៏ត្រូវមិនមាន ទើបពោលថា **ព្រោះជាបដិបក្ខត្រង់ដែលមិនមានការសម្រេចសឧបាទិសេសនិព្វានធាតុ ក្នុងខណៈនៃមគ្គ ដែលអាស្រ័យបច្ចុប្បន្នក្ខន្ធ** ។ ខ្ញុំពោលដល់និព្វានព្រោះខន្ធទាំងអស់នោះឯងមិនជាបច្ចុប្បន្នក៏ទេ ។ បើមានពាក្យសួរថា ព្រោះហេតុអ្វី ? ក៏មានពាក្យឆ្លើយថា **ព្រោះកិលេសមិនប្រព្រឹត្តទៅ ក្នុងវេលានោះ** គឺក្នុងខណៈនៃមគ្គ ទើបសួរតទៅថា **នឹងមិនជំទាស់គ្នា** គឺមិនមានការជំទាស់គ្នាជាមួយពាក្យតាមដែលបានពោលហើយ ព្រោះហេតុដូច្នោះ សេចក្តីនេះ ឆ្លើយថា បើមិនមានពោល គឺកិលេសមិនប្រព្រឹត្តទៅ ជានិព្វានសោត បើដូច្នេះ អរិយមគ្គក៏ត្រូវឥតប្រយោជន៍ ព្រោះមុនខណៈនៃមគ្គក៏សម្រេច ការមិនមាននៃកិលេសនោះ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **អរិយមគ្គក៏ត្រូវឥតប្រយោជន៍** ដូច្នេះជាដើម ។ ពាក្យថា **ព្រោះហេតុនោះ សេចក្តីនេះ ទើបមិនមែនហេតុដែលគួរដល់** សេចក្តីថា ព្រោះនិព្វានជាវត្ថុដែលមិនមានក៏ទេ និងគ្រាន់តែជាការមិនមានក៏ទេ ហើយការបដិបត្តិនឹងឥតប្រយោជន៍

ក៏ទេ ហើយកាលមិនមានខន្ធជាអតីត និងអនាគត ក៏នឹងត្រូវសម្រេចព្រះនិព្វានក៏ទេ ទាំងការមិនមាននៃខន្ធ ដែលជាបច្ចុប្បន្នក៏មិនសម្រេចនឹងពោលថាដល់កិលេសដែលមិនប្រព្រឹត្តទៅ និងអរិយមគ្គក៏ត្រូវឥតប្រយោជន៍នោះ ដូច្នោះ ហេតុនេះ ដែលលោកពោលទុកថា ព្រោះនិព្វានជាវត្ថុដែលមិនមាន ព្រោះការបដិបត្តិ ធ្វើឲ្យដល់នូវការមិនមាន ព្រោះកិលេសមិនប្រព្រឹត្តទៅក្នុងវេលានោះ ដើម្បីឲ្យសម្រេចការមិនមាននៃនិព្វាន ហេតុនេះមិនមែនហេតុដែលគួរ អធិប្បាយថា សេចក្ដីនេះមិនសមគួរ ។ ដោយ **អាទិ**-ស័ព្ទក្នុងពាក្យថា **អាទិវចនតោ** លោកអាចារ្យរមែងសង្គ្រោះយកចំណែកខ្លះរបស់ជម្ពុខាទកសូត្រដ៏សេស និងសង្គ្រោះយកទាំងព្រះបាលីដែលជានិទ្ទេសនៃអសង្ខតធាតុ ។ ពិតយ៉ាងនោះ ព្រះធម្មសង្គាហកាចារ្យពោលទុក **ក្នុងជម្ពុខាទកសូត្រ** ថា ជម្ពុខាទកបរិព្វាជកសួរថា នែអាវុសោ សារីបុត្រ ពាក្យដែលលោកពោលថា និព្វាន និព្វាននេះ នែអាវុសោ និព្វានដូចម្ដេចហ្ន៎ ? ព្រះសារីបុត្រឆ្លើយថា នែអាវុសោ ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈឯណា នេះហៅថា និព្វាន ព្រះមានព្រះភាគក៏ត្រាស់ទុកក្នុង **អាយតនវិភង្គ** ថា ក្នុងសេចក្ដីនោះ អសង្ខតធាតុ ដូចម្ដេច ? គឺការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ។ក្នុងព្រះបាលីនោះមានអត្ថដូចតទៅនេះ និព្វាន បានដល់ អសង្ខតធាតុ គឺធម៌ដែលមានសភាវៈដែលបច្ច័យ ប្រជុំតាក់តែងមិនបាន ។ ព្រោះកិលេស មានរាគៈជាដើមរមែងអស់ទៅ ព្រោះមកដល់និព្វាននោះ ដូច្នោះ ទើបនិព្វានហៅថា **រាគក្ខយោ** ការអស់រាគៈថា **ទោសក្ខយោ** ការអស់ទោសៈ និងថា **មោហក្ខយោ** ការអស់មោហៈ ។ ឯពាក្យថា **ព្រោះមកដល់** សេចក្ដីថា ព្រោះធ្វើឲ្យជាក់ច្បាស់ដោយមគ្គ ដែលអរហត្តផល ដែលគោត្រភូបើកឲ្យហើយ ដែលនឿយណាយចាកសង្ខារទាំងពួង បង្អោនទៅក្នុងវិសង្ខារ ។ ពិតហើយ មគ្គដែលហៅថា **ខយ** គឺការអស់ទៅ រមែងញ៉ាំងកិលេស មានរាគៈជាដើមឲ្យអស់ទៅ ព្រោះដល់

*និព្វានទោះ ដែលការកបុគ្គលធ្វើឲ្យជាក់ច្បាស់ គឺព្រោះអាស្រ័យនិព្វានដែលជាអារម្ម-ណប្បច្ច័យ និងព្រោះតាំងនៅចំពោះក្នុងនិព្វាននោះ ដែលអធិបតិប្បច្ច័យ ដែលជាទីតាំងអាស្រ័យ ដោយការៈដែលលួងលោមចិត្តយ៉ាងកំពូល និងដោយជាផ្លូវ ដើរយ៉ាងកំពូលរបស់លោកអ្នក ដែលមានសង្ខាររួចផុតហើយ ព្រោះដូច្នោះ ទើបកិលេសមានរាគៈជាដើម លោកពោលថា រមែងអស់ទៅ ព្រោះមិនមានការធ្វើឲ្យជាក់ច្បាស់នូវនិព្វាននោះ ការដល់នូវការរលត់ គឺការកើតឡើងមិនបានរបស់កិលេស មានរាគៈជាដើម ក៏មិនមាន ។ ឯនិព្វាននេះ បណ្ឌិតគួរទទួលយកយ៉ាងនេះដោយចំណែកមួយកាលទឹងកាន់យកអត្ថនៃព្រះបាលីដោយប្រការក្រៅអំពីនេះ ទាក់ទងនឹងពាក្យសួរដែលបានពោលហើយ ក៏ជាប្រការខុសច្រើនយ៉ាង ព្រោះដូច្នោះ លោកអាចារ្យបំណងសម្តែងប្រការខុសទាំងនោះ ទើបពោលពាក្យជាដើមថា* ***មិនមែនព្រោះអរហត្ត គ្រាន់តែជាការអស់ទៅប៉ុណ្ណោះ*** *។ ពិតហើយ អរហត្ត បានដល់ ខន្ធទាំង ៤ ដែលមានផលដ៏លើសជាប្រមុខ ព្រោះដូច្នោះ ភាពដែលអរហត្តនោះ គ្រាន់តែជាការអស់ទៅនៃកិលេស មានរាគៈជាដើម មិនសមគួរឡើយ ។* ***ពិតហើយ អរហត្តនោះ លោកបានសម្តែងលម្អិតទុកដោយន័យជាដើមថា នៃអាវុសោ ការអស់រាគៈឯណា*** *ដូច្នេះ ។ ក្នុងពាក្យរបស់លោកអាចារ្យទាំងនោះ ដែលព្រះសូត្រមានអត្ថគួរដឹងថា អរហត្ត លោកសម្តែងលម្អិតទុកដោយន័យជាដើមថា* ***រាគក្ខយោ*** *ព្រោះជាគុណជាតិកើតក្នុងទីបំផុតនៃកិលេសមានរាគៈជាដើមបានអស់ទៅហើយ សេចក្តីនេះឯណា ។ គប្បីជ្រាបព្រះសូត្រនេះមានអត្ថគួរដឹងថា និព្វាន លោកសម្តែងលម្អិតទុកដោយន័យជាដើមថា* ***រាគក្ខយោ*** *ព្រោះកិលេស មានរាគៈជាដើម រមែងអស់ទៅ ព្រោះមកដល់និព្វាន ក៏ដូច្នោះ ។ លោកអាចារ្យមានបំណងនឹងសម្តែងថា និព្វាន ត្រូវមានប្រការខុសច្រើន ព្រោះត្រឹមតែជាការអស់កិលេស មានរាគៈជាដើម ទើបផ្តើមពាក្យជាដើមថា* ***នៅមានពាក្យដែល***

គួរពោលក្រៃលែងឡើងទៅទៀតបន្តិចបន្តួច ។

ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **ព្រោះនិព្វានទឹងមានប្រការខុស ទាក់ទងដល់ភាពជាធម្មជាតិមានកាលដ៏ខ្វី** អធិប្បាយថា ព្រោះនិព្វានមានប្រការខុស ទាក់ទងដល់ភាពជាធម្មជាតិមានកាលដ៏ខ្វី អធិប្បាយថា ព្រោះនិព្វានទឹងត្រូវ មានប្រការតិចចុះមានអាទិ៍យ៉ាងនេះ គឺជាធម្មជាតិមានកាលដ៏ខ្វី ១ ភាពជាធម្មជាតិមានលក្ខណៈជាសង្ខតៈ ១ ភាពជាធម្មជាតិវៀរចាកសេចក្តីខ្ជះខ្ជែង ក៏ទឹងគប្បីបានដោយសភាពប៉ុណ្ណោះ ១ ជាធម្មជាតិដែលមិនផុតទៅអំពីកិលេស មានរាគៈជាដើម ១ ជាធម្មជាតិត្រូវភ្លើងមានរាគៈជាដើមជាប់តាម ១ជាទុក្ខ ១ជាធម្មជាតិមិនចូលទៅកាន់សេចក្តីស្ងប់ ១ មានច្រើន ១ ជាធម្មជាតិគ្រោតគ្រាត ១ មិនជាអារម្មណ៍របស់គោត្រភូ និងមគ្គ ១ ព្រោះគ្រាន់តែជាការអស់ទៅនៃកិលេស មានរាគៈជាដើមប៉ុណ្ណោះ ។ ការអស់ទៅនៃរាគៈតែម្យ៉ាង ឈ្មោះថា **រាគក្ខយោ** មិនមែនជាការអស់ទៅរបស់កិលេស មានទោសៈជាដើមនោះទេ ។ សូម្បីការអស់ទៅ នៃទោសៈជាដើមក៏ដូចគ្នា ព្រោះដូច្នោះ ការអស់រាគៈក៏ម្យ៉ាង ការអស់ទោសៈក៏ម្យ៉ាង ការអស់មោហៈក៏ម្យ៉ាង ព្រោះដូច្នោះ ទើបនិព្វានមានដល់ ៣ យ៉ាង ដែលជាការអស់ទៅរបស់អកុសលមូលទាំង ៣ មាន ៤ យ៉ាង ព្រោះអស់ទៅនៃឧបាទាន ៤ មាន ៥ យ៉ាង ព្រោះអស់ទៅនៃនីវរណៈ ៥ មាន ៦ យ៉ាង ព្រោះអស់ទៅនៃគំនរតណ្ហាទាំង ៦ មាន ៧ យ៉ាង ព្រោះការអស់ទៅនៃអនុស័យ ៧ មាន ៨ យ៉ាង ព្រោះអស់ទៅនៃមិច្ឆត្ត ៨ មាន ៩ យ៉ាង ព្រោះការអស់ទៅនៃតណ្ហាមូលកៈ ៩ មាន ១០ យ៉ាង ព្រោះការអស់ទៅនៃសំយោជនៈ ១០ និព្វាន ទឹងមានតែម្យ៉ាង ព្រោះការអស់ទៅនៃកិលេស ១៥០០ ព្រោះដូច្នោះ និព្វានក៏ទឹងមានច្រើន ។ធម្មតាការអស់រាគៈជាដើម ជាក់ច្បាស់ដល់បុគ្គលល្ងង់ ដោយហោចសូម្បីសត្វតិរច្ឆាន មានខ្លា ម្រឹគ និងស្វាជាដើម ក៏គប្បីដឹងច្បាស់បានងាយ ព្រោះ

ដូច្នោះ ទើបនិព្វានជារបស់គ្រោតគ្រាត ។ ម្យ៉ាងទៀត ព្រោះការអស់កិលេសមិនមាន ក្នុងខណៈនៃគោត្រភូ និងព្រោះកិលេសមិនអស់ទៅ សូម្បីក្នុងខណៈនៃមគ្គ ទើបមិន មានការធ្វើនិព្វានឲ្យជាអារម្មណ៍នោះឯង ។ ពាក្យថា **ព្រោះការអស់ទៅនោះ ក៏ជា និព្វាន** សេចក្តីថា ព្រោះការអស់កិលេស មានរាគៈជាដើម ដែលជាទីបំផុតរបស់ធម៌ ទាំងពួង ក៏នឹងជានិព្វានផង ។ ចាប់ផ្តើមអំពីការអស់ទៅឯណា ការអស់ទៅនៃកិលេស មានរាគៈជាដើមរមែងមិនមាន ការអស់ទៅនោះគួរកំណត់ពិតទៅថា **ឈ្មោះនេះ** ជា អារម្មណ៍នៃមគ្គញ្ញាណ និងផលញ្ញាណ រមែងមិនមាន ព្រោះដូច្នោះ ទើបលោកអាចារ្យ ពោលថា មិនមែនព្រោះការអស់ទៅ ដូច្នោះឡើយ ។

មានពាក្យដែលគួរពោលក្រៃលែងឡើងបន្តិចទៀត

បុគ្គលណា ឃើញទោសក្នុងកិលេស មានរាគៈជាដើមក្នុងអត្តភាពទី ៣ អំពី ភពចុងក្រោយនោះឯង សង្កត់កិលេសទាំងនោះដោយឈានការនាហើយ មានឈាន មិនសាបសូន្យ ស្លាប់ទៅហើយ ចូលដល់ព្រហ្មលោក នៅក្នុងព្រហ្មលោកនោះ រហូត អស់អាយុ សូម្បីមកក្នុងលោកនេះ ក៏ជាអ្នកប្រាសចាករាគៈក្នុងកាមទាំងឡាយនោះឯង បួសហើយសម្រេចអរហត្ត ម្យ៉ាងទៀត បុគ្គលណា នឿយណាយចាករាគៈជាដើម ក្នុងបឋមវ័យនោះឯង ហើយសង្កត់រាគៈជាដើមនោះដោយឈាន និងសម្រេចអរហត្ត ក្នុងបច្ឆិមវ័យ ព្រោះកិលេសមានរាគៈជាដើមនោះមិនកើតតាំងអំពីការសង្កត់កិលេសទុក ការមិនកើតឡើងនោះឯង ក៏ឈ្មោះថា ជាការរលត់ ព្រោះហាក់ដូចជានិរោធ ។ បុគ្គល ទាំងនោះ ក៏គួរបានឈ្មោះថា ដល់និព្វាន តែមិនមែនដូច្នោះឡើយ ព្រោះដូច្នោះ ការ ដែលអស់ទៅនោះជានិព្វានក៏ទេ ។ ការអស់ទៅនោះ ក៏ប្រកបទៅដោយប្រការខុស មាននិព្វានមានកាលដ៏វែងនោះឯង ដូច្នោះ ទើបលោកអាចារ្យពោលថា **ព្រោះកាល មានការអស់ទៅនោះ** ដូច្នេះជាដើម ។ បើការមិនប្រព្រឹត្តទៅនៃកិលេស មានរាគៈ

ជាដើម ចាប់ផ្តើមអំពីការអស់ទៅឯណា ដោយព្រះបាលីថា **ខយោ** លោកក៏រមែង សម្គាល់ត្រឹមតែការអស់ទៅនោះ ថាជានិព្វាន កាលបើយ៉ាងនេះ ក៏ចាប់ផ្តើមអំពី កាលអស់ទៅនោះកើតឡើង កិលេស មានរាគៈជាដើមក៏មិនកើតឡើង ព្រោះលោក ពោលទុកថា **ខយោ** ដូចក្នុងពាក្យថា **ខយេ ញាណំ** ញាណ គឺការដឹងក្នុងការអស់ទៅ ព្រោះដូច្នោះ លោកអាចារ្យកាលនឹងសម្តែងថា សូម្បីមគ្គក៏នឹងត្រូវជានិព្វានដែរ ដូច្នេះ ទើបពោលពាក្យជាដើមថា **ព្រោះអរិយមគ្គ** ដូច្នេះ ។

វត្ថុដែលរលត់ទៅហើយ រមែងមិនមាន យ៉ាងណា សូម្បីវត្ថុដែលមិនកើតឡើង ក៏ដូច្នោះ ព្រោះដូច្នោះ ការមិនកើតឡើងនោះឯង ក៏ជាការរលត់ ព្រោះដូចគ្នា នឹង និរោធដោយភាពមិនមានដូចគ្នា ទើបឈ្មោះថា **អនុប្បត្តិនិរោធ** ប្រែថា ការរលត់ គឺ ការមិនកើតឡើង ។ ពិតហើយ **អនុប្បត្តិនិរោធ** នេះ ជាអាការរបស់ធម៌ ដែលមគ្គ គប្បីធ្វើឲ្យអស់ទៅ ទើបជាការធ្វើវត្ថុដែលគួរកើតឡើងឲ្យដល់នូវការកើតឡើងមិនបាន ជាធម្មតា ព្រោះដូច្នោះ ទើបលោកហៅថា **ខយោ** ផង ។ កាលលោកធ្វើអនុប្បត្តិ-និរោធនោះឲ្យផ្សេងទៅអំពី **ខយ** ក្រៅអំពីនេះ ទើបពោលថា **ម្យ៉ាងទៀត ព្រោះ និព្វាននោះជាឧបនិស្ស័យនៃខយៈដែលហៅថា អនុប្បត្តិនិរោធ** ។ លោកពោលថា ឯនិព្វានជាអនិប្ផន្នធម៌ **ព្រោះភាពជាឧបនិស្ស័យ ដោយបរិយាយ** នៃខយៈនោះ ។ ពិតហើយ និព្វានដែលជាអារម្មណ៍នៃមគ្គ ដែលធ្វើការអស់ទៅ គឺអនុប្បត្តិនិរោធ ដោយអត្ថថា រមែងបានភាវៈដែលនឹងពោលដូចជាឧបនិស្ស័យនៃមគ្គនោះ ។ បទថា **តទុបចារេន** ប្រែថា ដោយការពោលដល់ខយៈដែលជាផលដោយអត្ថ ។ ពិតហើយ ហេតុ លោកហៅដោយឧបចារវោហារដល់ផល ដូចជាពាក្យថា **អាយុ ឃតំ** ប្រែថា អាយុទឹកដោះជូរ និងថា **សេម្ហោ គុឡោ** ប្រែថា ស្លេស្មទឹកអំពៅ ( ស្លេស្មដែលមាន សណ្ឋានខាប់ដូចទឹកអំពៅ ដូចពាក្យខ្មែរយើងថា ស្ករជើងអង្ក្រងជាដើម ) ។ បទថា

**អសង្ខ យោគ និព្វានស្ស** ព្រោះនាំមកនូវភាពជាអ្នកខ្វល់ខ្វាយតិចដល់ព្រះសាស្តា ដែលទ្រង់ពិចារណាដោយន័យជាដើមថា **ឋានៈនេះឯងឃើញបានលំបាក** ។ ឈ្មោះថា គប្បីឃើញដោយចក្ខុដែលជាអរិយៈ ដោយមានព្រះបាលីថា ម្នាលមាគណ្ឌិយៈ អ្នកមិនមានចក្ខុដែលជាអរិយៈ ដែលនឹងជាហេតុឲ្យអ្នកគប្បីដឹងភាពជាអ្នកមិនមានរោគ ឲ្យអ្នកគប្បីឃើញនិព្វាននោះ ។

លោកអាចារ្យពោលថា និព្វាន ឈ្មោះថា **ជាធម្មជាតិមិនទូទៅ ព្រោះលោកមានការដល់ព្រមដោយមគ្គគប្បីសម្រេច** ដូច្នេះ ដើម្បីចៀសវាងនូវពាក្យសួរថា បើមានសភាវធម៌ និងធម៌ដែលទាក់ទងនៅក្នុងសន្តានរបស់សត្វ ឈ្មោះថា និព្វានសោត បើដូច្នោះ ព្រោះហេតុអ្វី ទើបមិនបានធម៌ដែលទូទៅដល់វត្ថុគ្រប់យ៉ាង ដូចជាទីប្រជុំក្នុងផ្លូវធំដែលមានមុំ ៤ ទៅវិញ ? និព្វានឈ្មោះថា **មិនមានដែនកើត** ព្រោះមិនមានទីបំផុតខាងដើមយ៉ាងនេះថា **និព្វានកើតក្នុងកាលនៃព្រះសម្ពុទ្ធអង្គនោះៗ** ។ ពាក្យថា **កាលមានមគ្គ** គឺកាលអរិយមគ្គ ។ **ព្រោះមាន** គឺព្រោះកំពុងមាន ព្រោះគប្បីបាន ។ ពាក្យថា **សភាវៈមានអណ្ហូជាដើម** បានដល់ សភាវៈ មានអណ្ហូ បកតិ កាល និងបុរសជាដើម ។ ពាក្យថា **ជាភាពទៀង** គឺសម្រេចភាវៈដែលទៀង ។ ឯសភាវៈទៀងដែលតាំងនៅក្នុងចំណែកក្លែងក្លាយ លោកមានបំណងយកក្នុងទីនេះ ។ ពាក្យថា **ព្រោះមិនមានហេតុ** គឺព្រោះមិនមានហេតុដែលឲ្យសម្រេចនៃការចូលដល់ ។ **តេ យោគ អណុ អាទយោ** ប្រែថា សភាវៈ មានអណ្ហូជាដើមនោះ **ទៀង** ។ ពាក្យថា **ព្រោះនិព្វានជាធម្មជាតិទៀង** សេចក្តីថា មិនចូលដល់លក្ខណៈនៃហេតុ មានភាពជាធម៌ដែលមិនចាំបាច់សម្ងឹងជាដើម ។ ព្រោះថា **ដោយសភាវៈ មានអណ្ហូជាដើម មិនសម្រេចផល** នេះ លោកអាចារ្យរមែងសម្តែងថា ប្រការបញ្ជាក់ដែលថា សភាវៈមានអណ្ហូជាដើមទៀង មិនជាការសម្រេចដែលត្រឹមត្រូវ និងព្រោះហេតុនោះឯង ទើប

ជាហេតុដែលមិនសម្រេចផលដោយធម៌ជាទីអាស្រ័យ ។

ពាក្យថា **ព្រោះមានការត្រឹមត្រូវតាមដែលពោលទុកហើយ** លោកអាចារ្យពោលសំដៅដល់ហេតុដែលខ្លួនបានពោលទុកថា **ព្រោះមិនមានដែនកើត** ។ ឯនិព្វាននោះមិនមានដែនកើត បណ្ឌិតគប្បីឃើញបានដោយការៈដែលនិព្វាននោះ មិនមានបច្ច័យ ព្រោះការៈដែលនិព្វាននោះមិនមានបច្ច័យនោះ ទើបនិព្វាននោះមិនមានទីបំផុតខាងដើម ។ ដោយពាក្យថា **ព្រោះឈានកន្លងបង់នូវសភាវៈនៃរូប** នេះ លោកអាចារ្យរមែងសម្តែងថា រូបធម៌ទាំងឡាយ មានភាពប្រែប្រួល និងមានភាពដែលសម្ពន្ធនឹងទីកន្លែង ព្រោះមានការប្រព្រឹត្តទៅដោយកលាបៈ ដោយហេតុដែលមានការប៉ះខ្ទប់សេចក្តីនេះយ៉ាងណា និព្វានមិនមានការប៉ះខ្ទប់ក្នុងទីណាមួយ និងជាធម្មជាតិមិនមានទីកន្លែង ដូច្នោះ ។ ព្រោះថា និព្វាន ឈ្មោះថា **នៅក្នុងទិសនោះ** ឬថា **នៅក្នុងប្រទេសនោះ** ដូច្នេះមិនមាន ព្រោះនិព្វាននោះមិនមានទីតាំងអាស្រ័យនោះឯង ដូច្នេះ។

ពាក្យថា **ព្រោះនិព្វាននឹងគប្បីដល់បានដោយញាណវិសេស ដែលសម្រេចបានដោយសេចក្តីព្យាយាមមិនធូរថយ** នេះ លោកអាចារ្យរមែងសម្តែងនិព្វានជាធម្មជាតិដែលព្រះអរិយៈទាំងឡាយដឹងបានដោយប្រចក្ស ។ ដោយពាក្យថា **ព្រោះព្រះតម្រាស់របស់ព្រះសព្វញ្ញូ** នេះ លោកក៏សម្តែងដល់បុគ្គលដទៃក្រៅអំពីព្រះសព្វញ្ញូនោះ ដឹងបានដោយអនុមាន ( ដឹងដោយការគិតគ្នេរ ) ដោយពាក្យទាំង ២ នោះ លោកសម្តែងដល់បទថា **ព្រោះព្រះនិព្វានជាធម្មជាតិមិនមាន** ជាវត្ថុដែលដឹងមិនបានដោយហេតុ ។ និព្វាន **មានដោយបរមត្ថ** ក៏គឺមាននោះឯង ព្រោះដូច្នោះ ទើបលោកអាចារ្យបន្ថែមអត្ថតាមដែលបានផ្តើមទុក ហើយសម្តែងព្រះបាលីដែលជាទីមកជាឧបមារបស់សេចក្តីនោះ ទើបពោលពាក្យជាដើមថា **វុត្តញ្ហេតំ** ដូច្នេះ ។ ក្នុងបណ្តាពាក្យទាំងនោះ បទទាំង ៤ គឺ **អជាតំ អភូតំ អកតំ អសង្ខតំ** ក៏ជាវេវចនៈរបស់គ្នា

នឹងគ្នា ។ ប្រការមួយទៀត និព្វានឈ្មោះថា **អជាតំ** ព្រោះមិនកើតទៀត គឺមិនកើតឡើង ព្រោះការដល់ព្រមនៃហេតុ ពោល គឺដល់ព្រមនៃហេតុប្បច្ច័យ ដូចជាវេទនាជាដើមនោះទេ ។ និព្វានវៀរចាកហេតុក៏មិនកើត គឺមិនប្រាកដ មិនកើតឡើងឯងៗ ដូចគ្នា ព្រោះដូច្នោះ ទើបឈ្មោះថា **អភូតំ** ប្រែថា មិនកើតទៀត ។ ព្រោះមិនកើតយ៉ាងនេះ និងព្រោះមិនជាយ៉ាងនេះ ទើបនិព្វានមិនត្រូវហេតុឯណានីមួយធ្វើឡើង ព្រោះដូច្នោះ ទើបឈ្មោះថា **អកតំ** ប្រែថា ដែលហេតុណាមួយ មិនធ្វើឲ្យកើតឡើង ។ លោកពោលថា **អសង្ខតំ** ដើម្បីនឹងសម្ដែងថា ឈ្មោះថា ធម្មជាតិកើត ( មានជីវិត ) រស់នៅ និងដែលហេតុណាមួយ ធ្វើឡើង រមែងមានដល់សង្ខតធម៌ទាំងឡាយ មានរូបជាដើម តែមិនមានដល់និព្វានដែលមានសភាវៈជាអសង្ខតៈ ។ន័យម្យ៉ាងទៀត ពោលដោយបដិលោម គឺបញ្ច្រាស់លំដាប់ ធម្មជាតិ ឈ្មោះថា **សង្ខតំ** ព្រោះបច្ច័យទាំងឡាយមកប្រជុំ គឺរួមគ្នាតាក់តែងឡើង តែនិព្វាន ឈ្មោះថាជា **អសង្ខតំ** ប្រែថា ដែលបច្ច័យណាមួយ មិនបានតាក់តែងឡើង ព្រោះអត្ថថា មិនបានត្រូវបច្ច័យណាមួយតាក់តែងឡើងយ៉ាងនោះ និងព្រោះអត្ថថា វៀរចាកសង្ខតលក្ខណៈ ព្រោះហេតុនោះ កាលនឹងយល់ចូលចិត្តថា និព្វានជាធម្មជាតិដែលហេតុជាច្រើនធ្វើឲ្យកើតឡើងយ៉ាងនេះ ទើបព្រះសព្វញ្ញូត្រាស់ថា **អកតំ** ដើម្បីបង្ហាញថា មិនត្រូវហេតុណាមួយធ្វើឡើង ក្នុងកាលមានការសង្ស័យថា **និព្វាននេះគង់មានហេតុតិចតួចធ្វើឡើងដូចប្រក្រតីរបស់ពួកលទ្ធិបកតិទាំងឡាយហ្ន៎** ។និព្វានជាធម្មជាតិមិនមានបច្ច័យយ៉ាងនេះ ព្រះសព្វញ្ញូក៏ត្រាស់ថា **អភូតំ** ដើម្បីទ្រង់បដិសេធនិព្វាននោះក្នុងកាលមានការសង្ស័យថា **និព្វាននេះកើតហើយប្រាកដហើយខ្លួនឯងឬហ្ន៎** ។ ទ្រង់ត្រាស់ថា **អជាតំ** មិនកើត ដើម្បីទ្រង់សម្ដែងថា និព្វាននេះមិនមានបច្ច័យណាមួយ តាក់តែងឡើង មិនមានហេតុណាមួយ ធ្វើឡើង និងមិនកើតនេះ ក៏ព្រោះនិព្វានមានការមិនកើតគ្រប់វត្ថុគ្រប់យ៉ាងជាធម្មតា ។

ព្រះសាស្តា ទ្រង់ប្រកាសនិព្វានមានដោយបរមត្ថ ក្នុងអធិការនេះយ៉ាងនេះ និង កាលទ្រង់ប្រកាសក៏មិនបានប្រកាសដោយត្រឹមតែប្រើអំណាចរបស់ព្រះអង្គថា **តថាគតជាធំក្នុងធម៌ជាម្ចាស់នៃធម៌ទាំងនោះ** ។ តែទ្រង់អនុគ្រោះពពួកសត្វថ្នាក់ **បទបរម** ទើបទ្រង់ប្រកាសតាមការសមគួរ ដូចដែលត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ បើធម្មជាតិដែលមិនកើត មិនឧប្បត្តិ ដែលហេតុណាមួយមិនបាន ធ្វើឡើង ដែលបច្ច័យណាមួយ មិនបានតាក់តែងឡើងនេះ មិនមានសោត ការរលាស់ចេញនូវធម្មជាតិដែលកើត ដែលឧប្បត្តិ ដែលហេតុណាមួយធ្វើឡើង ដែលបច្ច័យណាមួយតាក់តែងឡើង ក៏មិនគប្បីប្រាកដក្នុងលោកនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ តែព្រោះធម្មជាតិដែលមិនកើត មិនឧប្បត្តិ ដែលហេតុណាមួយ មិនបានធ្វើឡើង ដែលបច្ច័យណាមួយ មិនបានតាក់តែងឡើងមាន ដូច្នោះ ការរលាស់ចេញនូវធម្មជាតិដែលកើត ដែលឧប្បត្តិ ដែលហេតុណាមួយធ្វើឡើង ដែលបច្ច័យណាមួយតាក់តែងឡើង ទើបប្រាកដ ដូច្នេះ ។ សេចក្តីនៃព្រះបាលីនោះថា ម្នាលភិក្ខុទាំងឡាយ បើអសង្ខតធាតុដែលមានសភាវៈ មិនកើតជាដើម មិនមានហើយ ឬនឹងមិនគប្បីមាន សោត ការរលាស់ចេញ គឺការចូលទៅស្ងប់ មិនមានចំណែកសេសសល់នូវធម្មជាតិដែលបច្ច័យណាមួយ តាក់តែងឡើង ពោល គឺខន្ធ ៥ មានរូបក្ខន្ធជាដើម ដែលមានសភាវៈកើតហើយជាដើម ក៏មិនគប្បីប្រាកដ គឺគប្បីរកមិនបាន បានដល់ មិនគប្បីមានក្នុងលោកនេះឡើយ ។ ពិតហើយ ធម៌ គឺអរិយមគ្គ មានសម្មាទិដ្ឋិជាដើម ដែលធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ប្រព្រឹត្តទៅ រមែងកាត់ផ្តាច់សន្និលេសបានជាសមុច្ឆេទ មិនមានចំណែកសេសសល់ ដោយហេតុនោះ ក្នុងអធិការនេះ ការបម្រះ គឺការរលាស់ចេញនូវវដ្តទុក្ខទាំងឡាយ ទើបប្រាកដ ។ ព្រះសាស្តា កាលទ្រង់សម្តែងភាពដែលនិព្វានមានដោយជាពិសេស ចេញទៅយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់មានបំណងនឹងសម្តែង

និព្វានដដែលនោះដោយទ្រង់អនុលោមតាម ទើបបានត្រាស់ព្រះពុទ្ធវចនៈមានពាក្យថា **យស្មា ច ខោ** ជាដើម អត្ថនៃព្រះពុទ្ធវចនៈនេះ បណ្ឌិតគប្បីជ្រាបតាមន័យដែលបានពោលទុកហើយនោះឯង ។ ក្នុងអធិការនេះ ព្រោះហេតុដែលព្រះសម្មាសម្ពុទ្ធ ទ្រង់អនុគ្រោះសត្វលោកទាំងពួង ទ្រង់ប្រកាសការមានដោយបរមត្ថនៃនិព្វានធាតុទុក ព្រោះបទព្រះសូត្រដ៏ច្រើន **អបច្ចយា ធម្មា អសង្ខតា ធម្មា**... ធម៌ដែលមិនមានបច្ច័យ ធម៌ដែលបច្ច័យណាមួយមិនតាក់តែង... ថា **អត្ថិ ភិក្ខវេ តទាយតនំ យត្ថ នេវ បឋវី**... ម្នាលភិក្ខុទាំងឡាយ អាយតនៈ មិនមែនដី... មាន ។ **ឥទម្បិ ខោ ឋានំ សុទុទ្ទសំ យទិទំ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ**... ឋានៈដែលបុគ្គលគប្បីឃើញបានដ៏លំបាកនេះ គឺការស្ងប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង... ។ **អសង្ខតញ្ច វោ ភិក្ខវេ ធម្មំ ទេសេស្សាមិ អសង្ខតគាមិញ្ច បដិបទំ**... ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងអសង្ខតធម៌និងបដិបទាដែលឲ្យដល់អសង្ខតធម៌...និងដោយបទព្រះសូត្រនេះថា **អត្ថិ ភិក្ខវេ អជាតំ** ម្នាលភិក្ខុទាំងឡាយ ធម្មជាតិដែលមិនកើតមាន... ដូច្នោះ វិញ្ញូជនដែលជ្រះថ្លាក្រៃលែងក្នុងព្រះសាសនា សូម្បីមិនទាន់ធ្វើឲ្យប្រចក្សក្នុងនិព្វាននោះមិនមានការសង្ស័យឡើយដោយពិត ។

តែទោះជាដូច្នោះ ដើម្បីនឹងបន្ទោបង់សេចក្ដីសន្ទិះសង្ស័យរបស់បុគ្គល ដែលមានការដឹង ដែលបុគ្គលដទៃគប្បីដឹកនាំបាន ទើបមានបទពិចារណាដ៏សមគួរដោយពាក្យអធិប្បាយចេញមកពង្រីកសេចក្ដីក្នុងនិព្វាននោះដូចតទៅនេះ

ព្រោះកាម និងរូប ព្រមទាំងវត្ថុដែលច្រើនឡើងទៅ ជាធម្មជាតិ ដែលគប្បីកំណត់ដឹងបាន ទើបប្រាកដការលាស់ចេញនូវបដិបក្ខចំពោះកាម និងរូប មានសភាពផ្សេងអំពីកាម និងរូបនោះ យ៉ាងណា សង្ខតធម៌ទាំងអស់ ដែលមានសភាព ដូច្នោះ ចាំបាច់មានការលាស់ចេញ ដែលមានសភាពជាប់គ្នា និងសង្ខតធម៌នោះ ដែលជា

បដិបក្ខដល់គ្នានឹងគ្នា ។ ឯការរលាស់ចេញនោះ អសង្ខតធាតុក៏គឺដូច្នោះ ។ និងពោលឲ្យក្រៃលែងឡើងទៅបន្តិចទៀត

វិបស្សនាញាណ ដែលមានសង្ខតធម៌ជាអារម្មណ៍ និងអនុលោមញ្ញាណ រមែងលះកិលេសបាន ដោយជាតទង្គប្បហាន រមែងមិនអាចលះបានដោយសមុច្ឆេទប្បហាន ។ ម្យ៉ាងទៀត ញាណក្នុងបឋមជ្ឈានជាដើមដែលមានសម្មតិសច្ច ជាអារម្មណ៍ រមែងលះកិលេសបានដោយវិក្ខម្ភនប្បហានប៉ុណ្ណោះ មិនលះដោយសមុច្ឆេទប្បហានឡើយ ។ ដោយប្រការដូចពោលមកនេះ ញាណដែលមានសង្ខតធម៌ជាអារម្មណ៍ និងមានសម្មតិសច្ចជាអារម្មណ៍ មិនអាចលះកិលេសបានជាសមុច្ឆេទ អរិយមគ្គញ្ញាណដែលធ្វើកិច្ចលះកិលេសទាំងនោះបានជាសមុច្ឆេទ ទើបត្រូវមានអារម្មណ៍ដែលមានសភាវៈខុសផ្ទុយគ្នាអំពីញាណទាំងពីរនោះ អសង្ខតធាតុ ក៏ដូច្នោះ ។

ម្យ៉ាងទៀត ពាក្យថា **ម្នាលភិក្ខុទាំងឡាយ ធម្មជាតិដែលមិនកើត មិនឧប្បត្តិ ដែលហេតុណាមួយ មិនបានធ្វើឡើង ដែលបច្ច័យណាមួយ មិនបានតាក់តែងឡើង មាន** ជាពាក្យផ្ទុះបញ្ចាំងថា និព្វានមានដោយបរមត្ថ ឈ្មោះថា មានអត្ថមិនវិបរិត ព្រោះជាពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។ ពិតហើយ ពាក្យណាដែលព្រះមានព្រះភាគត្រាស់ទុក ពាក្យនោះមានអត្ថមិនខុស ដូចពាក្យដែលទ្រង់ត្រាស់ទុកថា សង្ខារទាំងពួងមិនទៀង សង្ខារទាំងពួងជាទុក្ខ ធម៌ទាំងឡាយជាអនត្តា ។ ម្យ៉ាងទៀត **និព្វាន**-ស័ព្ទ ជាអារម្មណ៍របស់បរមត្ថតាមសេចក្ដីពិតក្នុងអារម្មណ៍ខ្លះ ព្រោះមានការប្រព្រឹត្តទៅដោយជាឧបចារវោហារ ។ បណ្ឌិតគប្បីជ្រាបអសង្ខតធាតុមាន ដោយបរមត្ថ សូម្បីដោយ **យុតិ** ដោយន័យទាំងឡាយ យ៉ាងនេះថា ដូចគ្នានឹង **សីហ**-ស័ព្ទ ជាដើម ។

ន័យម្យ៉ាងទៀត បើនិព្វានគ្រាន់តែជាការមិនមានប៉ុណ្ណោះសោត និព្វាននោះ

ក៏មិនចូលចិត្តដែលពោលថា ធម៌ដែលជ្រាលជ្រៅជាដើមថា ធម៌ដែលជ្រាលជ្រៅ ឃើញបានដោយលំបាក ដឹងតាមបានដោយលំបាក ស្ងប់ ប្រណីត មិនមែនវិស័យនៃការគិតស្មានបាន ជាធម៌ដ៏ល្អិត បណ្ឌិតគប្បីដឹងបាន មិនពេញចិត្តដែលនឹងពោលថាជាអសង្ខតធម៌ជាដើម ដោយន័យថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងអសង្ខតធម៌ដល់អ្នកទាំងឡាយ និងមិនពេញចិត្តដែលនឹងពោលថា ជាអព្យាកតធម៌ ដោយន័យជាដើមថា ធម៌ទាំងឡាយជាអព្យាកតៈ ធម៌ទាំងឡាយមិនមានបច្ច័យ ឯការមិនមានសភាវៈណាមួយ ដែលជាហេតុឲ្យដឹងការមិនមាននោះ ដោយអាការជាធម៌ជ្រាលជ្រៅ និងជាអសង្ខតធម៌ជាដើម មិនមានឡើយ ។ ព្រោះថា ការមិនមាន ក៏ជាការមិនមាននោះឯង ការមិនមាននោះ មានការជាប់ទាក់ទងនឹងភាវៈដែលជាធម៌ជ្រាលជ្រៅ និងជាអសង្ខតធម៌ជាដើមមកអំពីណា ។ កិលេសទាំងពួងដែលនៅក្នុងសន្តានរបស់សត្វទាំងឡាយ គួរនឹងមានភាពមិនមាននេះតែម្យ៉ាងក៏បាន ឬច្រើនយ៉ាងក៏បាន ។ បើមានម្យ៉ាងក៏ប្រើមគ្គមួយប៉ុណ្ណោះ ធ្វើកិលេសទាំងពួងឲ្យមិនមានបាន និងធ្វើឲ្យជាក់ច្បាស់បាន ព្រោះដូច្នោះ មគ្គដទៃក៏ជាវត្ថុដែលមិនមានប្រយោជន៍ ព្រោះដូច្នោះ ទើបមិនចាំបាច់មានមគ្គច្រើន ហើយសត្វទាំងពួងក៏នឹងដល់នូវការសម្រេចព្រះនិព្វានរួមគ្នាបាន ។ បើដូច្នោះ ការមិនមានកិលេសដែលហៅថា និព្វាននោះ ក៏មានតែម្យ៉ាងប៉ុណ្ណោះ ឯការមិនមានកិលេសនោះ មិនចាំបាច់ប្រើមគ្គសាងឡើង ក៏គួរធ្វើឲ្យជាក់ច្បាស់បានដោយពិត ។ កាលបើដូច្នេះ ពោលដោយពិសេស មគ្គក៏ត្រូវជាវត្ថុដែលមិនមានប្រយោជន៍ ព្រោះមិនបានលះកិលេសទាំងឡាយ ព្រោះដូច្នោះ សូម្បីមគ្គមួយក៏មិនត្រូវមាន កាលមិនមានការលះកិលេស ក៏ចូលទៅកាត់បង់នូវទុក្ខមិនបាន ដូច្នោះ ការធ្វើឲ្យជាក់ច្បាស់នូវការមិនមានកិលេស គប្បីមានប្រយោជន៍អ្វីទៅ ម្យ៉ាងទៀត កាលបើដូច្នោះ មគ្គទាំងឡាយ មានកិច្ចពិតប្រាកដ ដោយចំពោះការលះសំយោជនៈទាំង ៣ ជាដើម

ដែលនៅក្នុងសន្តាន ដូច្នោះ ក្នុងមគ្គទាំង ៤ ណាមួយ ក៏មិនមានកិលេសឡើយ ។ កាលបើដូច្នេះ វៀរការចែកសភាវៈ ក៏មិនមានមគ្គច្រើនយ៉ាង ព្រោះដូច្នោះ ការមិនមាននោះ ក៏គួរជាសភាវធម៌ ដែលពោលដល់ដោយបរិយាយនូវការអស់ទៅនៃកិលេសនោះឯង ។

បើមានពាក្យសួរថា ធម៌ពួកណាមិនមាន ក៏ជាការពោលអះអាងដល់ការចែកក្នុងការមិនមានតាមប្រភេទរបស់ធម៌នោះទៅ ? ពាក្យឆ្លើយថា ធម៌ពួកណា មិនមានធម៌ទាំងនោះ ក៏ជាធម្មជាតិដែលនៅមានសភាវៈ ដូច្នោះ សូម្បីការពោលអាស្រ័យដល់សភាវៈរបស់ការមិនមាននោះ ក៏គួរនឹងមានបាន កាលបើដូច្នោះ សូម្បីការពោលអាស្រ័យដល់សង្កិលេស និងភាពជាសង្ខតធម៌ជាដើម ដោយធម៌ទាំងនោះជាកិលេស និងជាសង្ខតធម៌ជាដើម ក៏គួរនឹងមានបាន ។ បើមិនប្រាថ្នាធម៌ទាំងនោះ ទើបមិនចាំបាច់ប្រាថ្នា សូម្បីការពោលអាស្រ័យដល់ការចែកដោយប្រភេទរបស់ធម៌ទាំងនោះ ។ និងជាវត្ថុសន្នឹកសន្ធាប់ដែលពោលអាស្រ័យដល់ក៏មិនអាចជាវត្ថុដែលច្រើនតាមអត្ថបាន ។ វត្ថុដែលពោលអាស្រ័យដល់ទឹក ខ្យល់ រមែងនឹងឆេះ ឬរមែងនឹងឆ្អិនទៅក៏ទេ ។ បញ្ហាជាផ្នែកមួយ គឺការមិនមាននេះ មិនអាចដើម្បីនឹងមិនជាសភាវៈ ព្រោះដូច្នោះ ទើបមិនអាចពោលបានថា ការបញ្ញត្តដល់ការមិនចែកទៅ ជាការសមគួរហើយ ដោយជាការស្មើគ្នានឹងភាពមិនមាន ។ម្យ៉ាងទៀត ក្នុងសេចក្តីមួយទៀត មានពាក្យជំទាស់ដែលបានពោលទុកហើយខាងដើមនោះឯង តែកាលមានសេចក្តីច្រើនយ៉ាង ជាសភាវធម៌ ក៏យល់បាន តាមន័យដែលបានពោលទុកហើយនោះឯង ។បើមានពាក្យចោទថា សូម្បីក្នុងសភាវធម៌ និព្វានក៏គួរមានការទាក់ទងនឹងវត្ថុច្រើន ព្រោះការមិនមានក៏មិនគួរនឹងជំទាស់ជាមួយវត្ថុច្រើន ដូចគ្នានឹងភាពជាវត្ថុច្រើន មិនគួរជំទាស់នឹងការមាន ? មិនដូច្នោះទេ ព្រោះភាពជាវត្ថុច្រើននោះឯង មិនទាក់ទងនឹងការមិនមាន ។បើភាពជារបស់

គ្រោតគ្រាត មិនគប្បីនាំភាវៈមកបាន យ៉ាងណា សូម្បីភាវៈក៏មិនគប្បីនាំភាពជារបស់គ្រោតគ្រាតមកបានដូច្នោះ កាលបើដូច្នេះ ភាពមាននឹងជាវត្ថុច្រើនបានអំពីណា ព្រោះភាពមានទាំងពួងក៏នឹងត្រូវដល់នូវភាពជាបថវីទៅ ព្រោះដូច្នោះ ភាពជាវត្ថុច្រើនសំដៅការមាន ដោយវោហាររបស់អ្នកស្រុក មានការបែកផ្សេងគ្នាក៏ដោយ សូម្បីដូច្នោះភាវៈ គឺការមាន ក៏មិនសំដៅដល់ភាពជារបស់ច្រើននោះឡើយ ព្រោះដូច្នោះ និព្វានទើបជាការមាន នឹងជាវត្ថុច្រើនក៏ទេ ដោយព្រះបាលីថា វត្ថុមួយសម្រេចហើយ មិនមែនវត្ថុច្រើនសម្រេច ។ ហើយក្នុងនិព្វានដែលជាវត្ថុមួយប៉ុណ្ណោះ រមែងមានទស្សនៈនិងភាវនាទាំង ២ យ៉ាង ។

ក្នុងភាពជានិព្វាន ចំពោះតែម្យ៉ាង របស់បុគ្គលដែលបរិនិព្វានហើយ គួរនឹងមាននិព្វានដែលឈ្មោះថា ពិតប្រាកដ ចំពោះសន្តានរបស់សត្វ ។ ហើយកាលបើដូច្នោះនិព្វាននោះ ក៏មិនផុតអំពីពាក្យជំទាស់ មានភាពជាសង្ខតធម៌ជាដើមនោះឯង ម្យ៉ាងទៀត ការលះកិលេសដែលជាកិច្ចរបស់មគ្គ ក៏ជាការមិនមានកិលេសទាំងឡាយ ។ ហើយក្នុងប្រការដែលនិព្វាននោះជាម្យ៉ាង ក៏មិនមែនជាមគ្គមានច្រើនយ៉ាង ព្រោះកិច្ចដទៃដែលនឹងត្រូវធ្វើមិនមាន ។ ភាវៈដែលមគ្គមានច្រើនយ៉ាង ក៏រមែងមានដោយការចែកដល់ការលះកិលេសទាំងឡាយ ដោយភាពផ្សេងនៃការធ្វើឲ្យជាក់ច្បាស់ដោយឥន្ទ្រិយទាំងឡាយ ជាធម្មជាតិមិនឈ្លាស ឈ្លាសធម្មតា ឈ្លាសជាង និងឈ្លាសជាទីបំផុត ក្នុងធម៌ប្រការជាមួយគ្នា ដែលមគ្គទាំងឡាយនឹងគប្បីធ្វើឲ្យជាក់ច្បាស់ ព្រោះដូច្នោះ ទើបគួរនឹងមានបាន ព្រោះនិព្វានជាសភាវធម៌នោះឯង ។ សូម្បីការមិនមានកិលេសទាំងឡាយក៏ប្រពៃ ដែលនឹងជារឿងដែលមគ្គគប្បីសាងឡើង ដោយភាពជាកិច្ចរបស់ខ្លួននោះឯង មិនមែនគប្បីធ្វើឲ្យជាក់ច្បាស់ ឯសភាវៈរបស់ការមិនមានដូចម្តេច ? ធម៌ណាប្រពៃដែលនឹងធ្វើឲ្យជាក់ច្បាស់ ប្រសិនបើធម៌នោះជានិព្វាន ក៏ត្រូវ

ជាធម៌ដែលមគ្គមួយប៉ុណ្ណោះ គប្បីធ្វើឲ្យជាភាពមិនមាននៃកិលេសទាំងពួង ជាធម៌ឯកញែកចេញមិនបាន ។ កាលបើប្រកាន់សេចក្ដីដទៃទៅក្នុងប្រការដែលនិព្វានជា ៤ យ៉ាង តាមអំណាចរបស់មគ្គ ក៏នឹងត្រូវមិនទាក់ទងនឹងភាពជា ៤ យ៉ាង និងមិនទាក់ទងដល់ភាពផ្សេងរបស់និព្វាន ព្រោះដូច្នោះ មគ្គមានច្រើនក៏គួរមានបាន ដោយកិច្ចរបស់មគ្គតែម្យ៉ាង ។ តែក្នុងការដែលមគ្គទាំងនោះមានច្រើន ការមិនមាននោះ ក៏ដោយភាពផ្សេងគ្នានៃការធ្វើឲ្យជាក់ច្បាស់ក្នុងធម៌មួយ តាមន័យដែលបានពោលទុកហើយ ព្រោះដូច្នោះ ទើបចន្លុលបង្ហាញបានថា និព្វានជាសភាវធម៌ ។ ម្យ៉ាងទៀត និព្វាននោះលោកហៅថា **ខយោ** ការអស់ទៅ ព្រោះជាធម្មជាតិដែលគប្បីត្រាស់ដឹងបាន ដោយការអស់ទៅ ។ ព្រោះថា អរិយមគ្គក៏ឈ្មោះថា **ខយោ** ការអស់ទៅ ដោយមានព្រះបាលីថា **ខយេ ញាណំ** ការដឹងក្នុងការអស់ទៅ ។ ដោយហេតុនោះ ទើបនិព្វាននេះជាធម្មជាតិដែលគប្បីធ្វើឲ្យជាក់ច្បាស់ ព្រោះដូច្នោះ ទើបលោកហៅថា **ខយោ** ការអស់ទៅ ដូច្នេះ ។

កថាពណ៌នាពោលអំពីទុក្ខនិរោធនិទ្ទេស ចប់ហើយ

ដោយប្រការដូច្នេះ ។

# វិសុទ្ធិមគ្គ

## ទុក្ខនិរោធគាមិនីបដិបទានិទ្ទេស

ធម៌ ( គឺអរិយមគ្គ ) ៨ ដែលត្រាស់ទុកក្នុងនិទ្ទេសនៃទុក្ខនិរោធគាមិនីបដិបទា ( នេះ ) ជាក់ច្បាស់ហើយ ក្នុងខន្ធនិទ្ទេសក៏ពិត តែក្នុងទីនេះ ខ្ញុំនឹងពោលដើម្បីឲ្យជ្រាបសេចក្តីប្លែកគ្នានៃធម៌ទាំង ៨ នោះ ដែលប្រព្រឹត្តទៅក្នុងខណៈជាមួយគ្នា ។

## សម្មាទិដ្ឋិ

ពិតហើយ ( ពោល ) ដោយសង្ខេប បញ្ញាចក្ខុដែលមានព្រះនិព្វានជាអារម្មណ៍ ជកអវិជ្ជានុស័យឡើងបាននៃព្រះយោគីអ្នកបដិបត្តិដើម្បីចាក់ធ្លុះនូវសច្ចៈ៤ (នោះឯង) ឈ្មោះថា សម្មាទិដ្ឋិៗ នោះ មានការឃើញប្រពៃជាលក្ខណៈ មានការប្រកាសសេចក្តីពិតជារស មានការទម្លាយភាពងងឹត គឺអវិជ្ជាចេញបានជាបច្ចុប្បដ្ឋាន ។

## សម្មាសង្កប្ប

ការលើកចិត្តឡើងឆ្ពោះកាន់ផ្លូវទៅព្រះនិព្វាន ដែលសម្បយុត្តដោយសម្មាទិដ្ឋិនោះ កម្ចាត់មិច្ឆាសង្កប្បចេញបាននៃព្រះយោគី អ្នកមានទិដ្ឋិដែលដល់ព្រម ហើយយ៉ាងនេះ ឈ្មោះថា សម្មាសង្កប្ប ។ សម្មាសង្កប្បនោះ មានការលើកចិត្តឡើងត្រូវផ្លូវជាលក្ខណៈ មានអប្បនា ( ការត្រិះរិះត្រង់ក្នុងផ្លូវ ) ជារស មានការលះមិច្ឆាសង្កប្បបានជាបច្ចុប្បដ្ឋាន ។

## សម្មាវាចា

ការវៀរចាកមិច្ឆាវាចា ដែលសម្បយុត្តដោយសម្មាសង្កប្បនោះឯង ជកវចីទុច្ចរិតឡើងចោលបាន នៃព្រះយោគីអ្នកឃើញ ( ដោយសម្មាទិដ្ឋិ ) និងត្រិះរិះ ( ដោយ

សម្មាសង្កប្ប ) យ៉ាងនោះ ឈ្មោះថា សម្មាវាចាៗ នោះ មានការកំណត់យក ( គឺប្រមូលសម្បយុត្តធម៌ទុក ) ជាលក្ខណៈ មានការវៀរចាកជារស មានការលះមិច្ឆាវាចាបានជាបច្ចុប្បដ្ឋាន ។

## សម្មាកម្មន្តៈ

ការវៀរចាកកាយទុច្ចរិត មានបាណាតិបាតជាដើម ដែលសម្បយុត្តដោយសម្មាវាចានោះឯង កាត់ផ្តាច់មិច្ឆាកម្មន្តៈបាននៃព្រះយោគីអ្នកវៀរចាក ( ដោយសម្មាវាចា ) យ៉ាងនោះ ឈ្មោះថា សម្មាកម្មន្តៈៗ នោះ មានការទ្រ ( សម្បយុត្តធម៌ ) ទុកជាលក្ខណៈ មានការវៀរចាកជារស មានការលះមិច្ឆាកម្មន្តៈបានជាបច្ចុប្បដ្ឋាន ។

## សម្មាអាជីវៈ

ចំណែកការវៀរចាកមិច្ឆាអាជីវៈ ដែលសម្បយុត្តដោយការលះបង់ ដែលជាសភាពល្អស្អាតនៃសម្មាវាចា និងសម្មាកម្មន្តៈនោះ ចូលទៅកាត់ផ្តាច់បាននូវអនេសនា មានការឆបោកជាដើមនៃព្រះយោគីណា ការវៀរចាកនោះ ឈ្មោះថា សម្មាអាជីវៈៗ នោះ មានភាពស្អាត ( នៃអាជីវៈ ) ជាលក្ខណៈ មានការញុំាងអាជីវៈដ៏ប្រពៃតាមធម៌ឲ្យប្រព្រឹត្តទៅជារស មានការលះបង់មិច្ឆាអាជីវៈបានជាបច្ចុប្បដ្ឋាន ។

## សម្មាវាយាមៈ

លំដាប់នោះ វីរិយារម្ភដែលអនុរូបដល់សម្មាអាជីវៈនោះ សម្បយុត្តដោយសម្មាអាជីវៈនោះឯង កាត់បង់កោសជ្ជៈចោលបាននៃព្រះយោគីនោះ អ្នកតាំងមាំហើយក្នុងភូមិនៃសីល ពោល គឺសម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈនោះឯណា វីរិយារម្ភនោះ ឈ្មោះថា សម្មាវាយាមៈៗ នោះ មានការផ្គង ( ចិត្ត ) ទុកជាលក្ខណៈ មានសម្មប្បធាន ៤ ដែលញុំាងអកុសលធម៌ដែលនៅមិនទាន់កើតមិនឲ្យកើតឡើងជាដើម

ជារស មានការលះបង់មិច្ឆាវាយាមៈបានជាបច្ចុប្បដ្ឋាន ។

## សម្មាសតិ

ការមិនភ្លេចនៃចិត្តដែលសម្បយុត្តដោយសម្មាវាយាមៈនោះឯង កម្ចាត់មិច្ឆាសតិចេញបាននៃព្រះយោគីនោះ អ្នកព្យាយាមយ៉ាងនោះ ឈ្មោះថា សម្មាសតិៗ នោះ មានការតាំង ( សតិ ) ទុកមាំជាលក្ខណៈ មានការមិនភ្លេចជារស មានការលះមិច្ឆាសតិបានជាបច្ចុប្បដ្ឋាន ។

## សម្មាសមាធិ

ឯកគ្គតានៃចិត្ត ដែលសម្បយុត្តដោយសម្មាសតិនោះឯង ទម្លាយមិច្ឆាសមាធិចោលបាននៃព្រះយោគីនោះ អ្នកមានចិត្តដែលសតិថ្នាក់កំពូលនៅរក្សាយ៉ាងនោះ ឈ្មោះថា សម្មាសមាធិៗ នោះ មានការមិនរសាត់ទៅ ( នៃចិត្ត ) ជាលក្ខណៈ មានការតាំង ( ចិត្ត ) ទុកមាំជារស មានការលះមិច្ឆាសមាធិបានជាបច្ចុប្បដ្ឋាន ។

នេះជាន័យក្នុងទុក្ខនិរោធគាមិនីបដិបទានិទ្ទេស

វិនិច្ឆ័យពាក្យថា **ជាតិ** ជាដើម ក្នុងអរិយសច្ចនេះ បណ្ឌិតគប្បីជ្រាប ដូចពោលមក ដូច្នេះ ។

## ដោយកិច្ចនៃញាណ

ពាក្យថា ដោយកិច្ចនៃញាណ សេចក្តីថា បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយកិច្ចនៃសច្ចញាណ ( ការដឹងអរិយសច្ច ) ផង សច្ចញាណមាន ២ គឺអនុពោធញាណ ( ការដឹងដោយដឹងតាម ) ១ បដិវេធញាណ ( ការដឹងដោយត្រាស់ដឹង ) ១ ក្នុងញាណ ២ យ៉ាងនោះ អនុពោធញាណជាលោកិយ ប្រព្រឹត្តទៅក្នុងនិរោធ និងមគ្គដោយអំណាចការបានស្តាប់មកជាដើម បដិវេធញាណជាលោកុត្តរ ធ្វើនិរោធឲ្យជា

អារម្មណ៍ ហើយត្រាស់ដឹងសច្ចៈទាំង ៤ បាន ដោយកិច្ច ( មានកំណត់ដឹងសច្ចៈជាដើម ) ដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាឃើញទុក្ខ បុគ្គលនោះ រមែងឃើញទុក្ខសមុទយៈផង រមែងឃើញទុក្ខនិរោធផង រមែងឃើញទុក្ខនិរោធគាមិនីបដិបទាផង ដូច្នេះជាដើម ពាក្យបាលីទីនេះបណ្ឌិតគប្បី ( នាំមក ) ពោលឲ្យអស់ចុះ ក៏កិច្ចនៃបដិវេធញ្ញាណនោះ នឹងមានច្បាស់ក្នុង (វគ្គដែលពោលដោយ) ញាណទស្សនវិសុទ្ធិ ។ សច្ចញ្ញាណដែលជាលោកិយណា ក្នុងលោកិយញ្ញាណនោះ ទុក្ខញ្ញាណ (ការដឹងក្នុងទុក្ខ) រមែងញ៉ាំងសក្កាយទិដ្ឋិ ដែលប្រព្រឹត្តទៅដោយអំណាចការគ្របសង្កត់ហាក់ដូចជារូបរឹតឲ្យត្រឡប់ សមុទយញ្ញាណ ( ការដឹងក្នុងសមុទយៈ) រមែងញ៉ាំងឧច្ឆេទទិដ្ឋិឲ្យត្រឡប់ និរោធញ្ញាណ ( ការដឹងក្នុងនិរោធ ) រមែងញ៉ាំងសស្សតទិដ្ឋិឲ្យត្រឡប់ មគ្គញ្ញាណ ( ការដឹងក្នុងមគ្គ ) រមែងញ៉ាំងអកិរិយទិដ្ឋិឲ្យត្រឡប់ ន័យម្យ៉ាងទៀត ទុក្ខញ្ញាណ ញ៉ាំងការបដិបត្តិខុសក្នុងផល ពោល គឺការសម្គាល់ថា ស្ថិតស្ថេរ ថាស្អាត ថាសុខ ថាជាតួខ្លួន ក្នុងខន្ធទាំងឡាយ ដែលប្រាសចាកភាពស្ថិតស្ថេរ ភាពស្អាត ភាពជាសុខ ភាពជាតួខ្លួនឲ្យត្រឡប់ សមុទយញ្ញាណ ញ៉ាំងការបដិបត្តិខុសក្នុងហេតុ ដែលប្រព្រឹត្តដោយការប្រកាន់ក្នុងវត្ថុដែលមិនមែនហេតុថា ជាហេតុ ដូចជាថា លោករមែងប្រព្រឹត្តទៅដោយលោកអ្នកជាធំ ( ព្រះឥស្សរ ) ដោយវត្ថុដែលជាប្រធាន ដោយ ( ព្រះ ) កាល និងដោយសភាវៈ ( ភាពជាខ្លួនឯង ) ជាដើមឲ្យត្រឡប់ និរោធញ្ញាណ ញ៉ាំងការបដិបត្តិខុសក្នុងនិរោធ ដែលបានដល់ការប្រកាន់ថា ការរួចផុត ( មាន ) ក្នុងអរូបលោក និងក្នុងលោកថូបិកា ( ភូមិដែលប្រកាន់ថា ជាកំពូលលោក ) ជាដើមឲ្យត្រឡប់ មគ្គញ្ញាណញ៉ាំងការបដិបត្តិខុសក្នុងឧបាយ ដែលប្រព្រឹត្តទៅដោយអំណាចការប្រកាន់ក្នុងវត្ថុ ដែលមិនមែនផ្លូវនៃវិសុទ្ធិផ្សេងៗ មានដោយកាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ ថាជាផ្លូវនៃវិសុទ្ធិឲ្យត្រឡប់

ព្រោះហេតុនោះ ទើបលោកពោលពាក្យប្រព័ន្ធនេះទុកថា

នរជននៅមិនទាន់ដឹងសច្ចៈទាំងឡាយដរាបណា នរជននោះ ក៏នៅវង្វេងក្នុងរឿងលោក ក្នុងហេតុកើតនៃលោក ក្នុងនិព្វានដែលជាទីរលត់នៃលោក និងក្នុងឧបាយ ( គ្រឿងចូលដល់ ) និព្វាននោះ ដរាបនោះ ។

វិនិច្ឆ័យដោយកិច្ចនៃញាណក្នុងអរិយសច្ចនេះ បណ្ឌិតគប្បីជ្រាបដូចពោលមកដូច្នេះ ប្រការ ១ ។

## ដោយប្រភេទនៃធម៌ដែលរាប់ចូលក្នុងអរិយសច្ច

ពាក្យថា ដោយប្រភេទនៃធម៌ទាំងឡាយ ដែលនៅខាងក្នុង ( គឺរាប់ចូលក្នុងអរិយសច្ច ) សេចក្ដីថា វៀរតណ្ហា និងអនាសវធម៌ទាំងឡាយចេញ ( លោកិយ ) ធម៌ដ៏សេសទាំងពួងរាប់ចូលក្នុងទុក្ខសច្ច តណ្ហាវិចរិត ៣៦ រាប់ចូលក្នុងសមុទយសច្ច និរោធសច្ចមិនលាយគ្នា ( នឹងអ្វីៗ ) ដោយមុខ ( ប្រធាន ) គឺសម្មាទិដ្ឋិ វីមង្សិទ្ធិបាទ បញ្ញិន្ទ្រិយ បញ្ញាពលៈ និងធម្មវិចយសម្ពោជ្ឈង្គ រាប់ចូលក្នុងមគ្គសច្ច ដោយអបទេស ( គោលអាង ) គឺសម្មាសង្កប្ប វិតក្ក ៣ មាននេក្ខម្មវិតក្កជាដើម រាប់ចូលក្នុងមគ្គសច្ច ដោយអបទេស គឺសម្មាវាចា វចីសុចរិត ៤ រាប់ចូលក្នុងមគ្គសច្ច ដោយអបទេស គឺសម្មាកម្មន្តៈ កាយសុចរិត ៣ រាប់ចូលក្នុងមគ្គសច្ច ដោយមុខ គឺសម្មាអាជីវៈ ការប្រាថ្នាតិច និងការសន្តោស រាប់ចូលក្នុងមគ្គសច្ច ។ ម្យ៉ាងទៀត សទ្ធិន្ទ្រិយ សទ្ធាពលៈ និងឆន្ទិទ្ធិបាទក៏រាប់ចូលក្នុងមគ្គសច្ច ព្រោះសម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈទាំងអស់នោះជាអរិយកន្តសីល និងព្រោះអរិយកន្តសីល ជាធម៌ដែលគប្បីទទួលទុកដោយដៃ គឺសទ្ធា ព្រោះហេតុដែលសទ្ធិន្ទ្រិយ សទ្ធាពលៈ និងឆន្ទិទ្ធិបាទមាន ទើបសីលមាន ដោយអបទេស គឺសម្មាវាយាមៈ សម្មប្បធាន ៤ វិរិយិទ្ធិបាទ វិរិយិន្ទ្រិយ វិរិយពលៈ និងវិរិយសម្ពោជ្ឈង្គ រាប់ចូលក្នុងមគ្គសច្ច ដោយអបទេស គឺសម្មាសតិ

សតិប្បដ្ឋាន ៤ សតិន្ទ្រិយ សតិពលៈ និងសតិសម្ពោជ្ឈង្គ រាប់ចូលក្នុងមគ្គសច្ច ដោយអបទេស គឺសម្មាសមាធិ សមាធិ ៣ គឺសវិតក្កសវិចារសមាធិជាដើម ចិត្តសមាធិ ( គឺចិត្តិទ្ធិបាទ ) សមាធិន្ទ្រិយ សមាធិពលៈ បីតិសម្ពោជ្ឈង្គ បស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គ រាប់ចូលក្នុងមគ្គសច្ច ដូច្នេះ ។

វិនិច្ឆ័យដោយប្រភេទនៃធម៌ទាំងឡាយដែលនៅខាងក្នុងអរិយសច្ចនេះ បណ្ឌិតជ្រាបដូចពោលមក ដូច្នេះ ប្រការ ១ ។

## ដោយឧបមា

ពាក្យថា ដោយឧបមា សេចក្តីថា ទុក្ខសច្ចគប្បីឃើញដូចរបស់ធ្ងន់ សមុទយសច្ចដូចការកាន់យករបស់ធ្ងន់ និរោធសច្ចដូចការដាក់របស់ធ្ងន់ មគ្គសច្ចដូចឧបាយ ( គឺវិធី ) ដាក់របស់ធ្ងន់ ។ ម្យ៉ាងទៀត ទុក្ខសច្ចដូចរោគ សមុទយសច្ចដូចហេតុរបស់រោគ និរោធសច្ចដូចការជារោគ មគ្គសច្ចដូចថ្នាំ ឬទុក្ខសច្ច ដូចការខ្វះខាតអាហារ សមុទយសច្ចដូចភ្លៀងមិនល្អ និរោធសច្ចដូចមានអាហារសម្បូរ មគ្គសច្ចដូចភ្លៀងល្អ។

សច្ចៈ ៤ នេះ បណ្ឌិតគប្បីជ្រាបដោយប្រកប ( សេចក្តី ) ឧបមាដោយមនុស្សមានពៀរ មូលនៃពៀរ ការដកពៀរ និងឧបាយដកពៀរ ដោយដើមឈើមានពិស ឫសរបស់ដើមឈើ ការកាត់ឫស និងឧបាយកាត់ឫសនោះ ដោយភ័យ មូលនៃភ័យ ការប្រោសចាកភ័យ និងឧបាយសម្រេចការប្រោសចាកភ័យនោះ ដោយត្រើយអាយ អន្លង់ទឹកធំ ត្រើយនាយ និងការព្យាយាមដែលឲ្យ ( ឆ្លងអន្លង់ទឹកទៅ ) ដល់ត្រើយនាយនោះ ដូច្នេះ ក៏បាន ។

វិនិច្ឆ័យដោយឧបមាក្នុងអរិយសច្ចនេះ បណ្ឌិតគប្បីជ្រាបដូចពោលមក ដូច្នេះ ។

## ដោយចតុក្កៈ-ជាអរិយសច្ច និងមិនជាអរិយសច្ច ៤

ពាក្យថា ដោយចតុក្កៈ សេចក្តីថា ក្នុងអរិយសច្ច ៤ នេះ វត្ថុដែលជាទុក្ខ ( តែ ) មិនជាអរិយសច្ចក៏មាន វត្ថុដែលជាអរិយសច្ច ( តែ ) មិនជាទុក្ខក៏មាន វត្ថុដែលទាំងជាទុក្ខ ទាំងជាអរិយសច្ចក៏មាន វត្ថុដែលមិនជាទុក្ខ មិនជាអរិយសច្ចក៏មាន ក្នុងអរិយសច្ចដ៏សេស មានសមុទយៈជាដើមក៏ដូចន័យនេះ ។

ក្នុងចតុក្កៈនោះ ធម៌ទាំងឡាយដែលសម្បយុត្តជាមួយនឹងមគ្គ និងសាមញ្ញផល ទាំងឡាយ ឈ្មោះថា ជាទុក្ខ ព្រោះជាសង្ខារទុក្ខ តាមព្រះបាលីថា វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ តែមិនជាអរិយសច្ច និរោធជាអរិយសច្ច តែមិនជាទុក្ខ ចំណែកអរិយសច្ច ២ ក្រៅអំពីនេះ ( គឺសមុទយៈ និងមគ្គ ) គប្បីជាទុក្ខក៏បាន ព្រោះមិនទៀង តែព្រះយោគាវចរ (ប្រព្រឹត្ត) ព្រហ្មចរិយៈក្នុងព្រះមានព្រះភាគនោះដើម្បីកំណត់ដឹងទុក្ខណា មិនមែនជាទុក្ខដោយភាពជាទុក្ខយ៉ាងនោះ ( គឺជាទុក្ខ ព្រោះមិនទៀង មិនមែនជាទុក្ខដោយបរិញ្ញេយ្យធម ) ចំណែកឧបាទានក្ខន្ធ ៥ វៀរតែតណ្ហា ទាំងជាទុក្ខ ទាំងជាអរិយសច្ចដោយអាការទាំងពួង ធម៌ទាំងឡាយ ដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផលទាំងឡាយ មិនជាទុក្ខដោយភាពជាទុក្ខសម្រាប់កំណត់ដឹងនៃព្រះយោគាវចរអ្នក ( ប្រព្រឹត្ត ) ព្រហ្មចរិយៈក្នុងព្រះមានព្រះភាគ ( គឺមិនជាទុក្ខដោយបរិញ្ញេយ្យធម៌ តែជាទុក្ខដោយសង្ខារទុក្ខ ដូចពោលក្នុងបទដំបូង ) ទាំងមិនជាអរិយសច្ច ។

វិនិច្ឆ័យក្នុងអរិយសច្ចនេះ ដោយចតុក្កៈ ដោយប្រកបសេចក្តីចូលតាមសមគួរក្នុងអរិយសច្ចដទៃ មានសមុទយៈជាដើមផង បណ្ឌិតគប្បីជ្រាបដូចន័យដែលបានពោលមក ដូច្នេះ ប្រការ ១ ។

# ដោយសុញ្ញតទេ

ក្នុងពាក្យពីរថា ដោយសុញ្ញតទេ និងដោយប្រភេទផ្សេងៗ មានតែម្យ៉ាងជាដើមនេះ គប្បីជ្រាបវិនិច្ឆ័យដោយសុញ្ញតទេមុន ព្រោះ ( កាលពោល ) ដោយបរមត្ថសច្ចៈទាំងអស់បណ្ឌិតគប្បីជ្រាបថា ជារបស់សុញ្ញតទេ ព្រោះមិនមានអ្នកដឹង អ្នកធ្វើ ( គឺអ្នកសាង ) អ្នករំលត់ និងអ្នកដើរ ព្រោះហេតុនោះ ទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធទុកថា

ទុក្ខមានពិត តែបុគ្គលណាមួយ អ្នកទទួលទុក្ខមិនមាន អ្នកធ្វើមិនមាន តែការធ្វើមានពិត ការរលត់មានពិត តែមនុស្សអ្នករំលត់មិនមាន ផ្លូវមាន តែអ្នកដើរមិនមាន ។

ន័យម្យ៉ាងទៀត

ការសូន្យក្នុងសច្ចៈ ៤ នោះ គប្បីជ្រាបដូច្នេះ គឺសច្ចៈ ២ ខាងដើមសូន្យចាកភាពស្ថិតស្ថេរ ភាពស្អាត សុខ និងភាពជាតួខ្លួន អមតបទ ( គឺនិរោធ ) សូន្យចាកភាពជាតួខ្លួន មគ្គវៀរចាកភាពស្ថិតស្ថេរ សុខ និងភាពជាតួខ្លួន ។

ឬថា សច្ចៈ ៣ សូន្យចាកនិរោធ និងនិរោធក៏សូន្យចាកសច្ចៈ ៣ ដ៏សេស ឬថាក្នុងសច្ចៈ ៤ សច្ចៈដែលជាហេតុ សូន្យចាកសច្ចៈដែលជាផល ព្រោះមិនមានទុក្ខក្នុងសមុទយៈ និងមិនមាននិរោធក្នុងមគ្គ ( ហេតុ ) មិនមែនរួមគភ៌ជាមួយនឹងផលដូចជាបកតិ ( ឬប្រក្រតី ) របស់ពួកបកតិវាទីទេ និងផលសោតក៏សូន្យចាកហេតុ

ព្រោះទុក្ខជាមួយនឹងសមុទយៈ និងនិរោធជាមួយនឹងមគ្គ រួមក្រុមគ្នាមិនបាន ( ផល ) មិនមែនរួមនៅក្នុងហេតុ ជាហេតុផល-ផលរួមហេតុ ដូចជាទ្វិអណុកផល ( ផលកើតអំពីអណូ ២ ) ជាដើម របស់ពួកសមវាយវាទីទេ ព្រោះហេតុនោះ ទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធនេះទុកថា

**ក្នុងសច្ចៈ ៤ នេះ សច្ចៈ ៣ សូន្យចាកនិរោធ និព្វុតិ ( គឺនិរោធ ) សោតក៏សូន្យចាកសច្ចៈ ៣ នោះ សច្ចៈដែលជាហេតុសូន្យចាកសច្ចៈដែលជាផល សច្ចៈដែលជាផលនោះសោត ក៏សូន្យចាកសច្ចៈដែលជាហេតុ ។**

គប្បីជ្រាបវិនិច្ឆ័យដោយសូន្យទទេដូចពោលមកដូច្នេះសិន ។

# មហាដីកា

## កថាពណ៌នាដោយ ទុក្ខនិរោធគាមិនីបដិបទានិទ្ទេស

ពាក្យថា ធម៌ ៨ ប្រការ អធិប្បាយថា ធម៌ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម ដែលបានផ្ដើមទុកថា **កតមំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ** បដិបទាដែលឲ្យដល់នូវការរលត់ទុក្ខជាអរិយសច្ចដូចម្ដេច មកហើយក្នុងនិទ្ទេសនៃទុក្ខនិរោធគាមិនី-បដិបទា **ក្នុងព្រះបាលី** ដោយន័យជាដើមថា សម្មាទិដ្ឋិ និងដែលទ្រង់នាំយកព្រះបាលីនោះឯងមកត្រាស់ទុកក្នុងទីនេះ ដោយអំណាចនៃឧទ្ទេស ខ្ញុំបានប្រកាសទុកហើយ ដោយអត្ថមិនមែនបានប្រកាសទុកដោយអំណាចនិទ្ទេសនៃមគ្គសច្ច ។ កាលនឹងចៀសវាងនូវពាក្យសួរថា បើបានប្រកាសទុកដោយអត្ថហើយ ឯការពោលក្នុងទីនេះនឹងមានប្រយោជន៍ដូចម្ដេច ទើបលោកអាចារ្យពោលពាក្យមានអាទិថា **តែក្នុងទីនេះ** ដូច្នេះជាដើម ។ ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា **ដែលកំពុងប្រព្រឹត្តទៅក្នុងខណៈជាមួយគ្នា** នេះ លោកអាចារ្យពោលទុក ព្រោះអធិប្បាយថា វិរតិទាំងឡាយក្នុងចិត្តុប្បាទ ដែលជាលោកិយកុសល រមែងជាធម្មជាតិដែលប្រព្រឹត្តទៅក្នុងខណៈផ្សេងគ្នានោះឯង ។ តែធម៌ គឺមគ្គដ៏សេសសូម្បីក្នុងចិត្តុប្បាទទាំងនោះ រមែងកើតឡើងរួមគ្នានោះឯង ។ ពាក្យថា **ដើម្បីស្គាល់ដឹង** នូវសេចក្ដីផ្សេងគ្នា គឺដើម្បីពិចារណាដឹងនូវភាពផ្សេងគ្នា នៃអាការប្រព្រឹត្តទៅ មានការដកធម៌ដែលជាបដិបក្ខបានជាដើម ។ កថាពោលដោយមគ្គដោយពិស្ដារនឹងជាក់ច្បាស់ខាងមុខ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ដោយសង្ខេប** ។

## អធិប្បាយ សម្មាទិដ្ឋិ

ពាក្យថា **បុគ្គលបដិបត្តិដើម្បីការចាក់ធ្លុះសច្ចៈទាំង ៤** សេចក្ដីថា បុគ្គលបដិបត្តិ

ដោយអំណាចការបំពេញគោលបដិបត្តិដែលជាបុព្វភាគ ដោយប្រការទាំងពួង ដោយប្រការដែលមានការត្រាស់ដឹងសច្ចៈទាំង ៤ បាន ។ លោកដែលឈ្មោះថា **យោគី** ព្រោះមានយោគៈដែលហៅថា អរិយមគ្គ ។ លោកអាចារ្យពោលថា **ដកអវិជ្ជានុស័យឡើងបាន** ដូច្នេះ ដើម្បីនឹងសម្ដែងថា ក្នុងការដកអវិជ្ជានុស័យឡើង កិលេសដែលតាំងនៅដូចគ្នានឹងអវិជ្ជានុស័យនោះ ក៏នឹងមិនសល់សូម្បីបន្តិចបន្តួច ដោយពិត សូម្បីយ៉ាងនោះ អវិជ្ជាក៏ជាធម៌បដិបក្ខចំពោះវិជ្ជា ។ ក្នុងស័ព្ទថា មិច្ឆាសង្កប្បជាដើមខាងមុខក៏មានន័យនេះដូចគ្នា ។ ពាក្យថា **មានការប្រកាសសេចក្ដីពិតជារស** គឺមានការប្រកាសបរមត្ថជារស អធិប្បាយថា មានការធ្វើសច្ចៈ ៤ ឲ្យជាក់ច្បាស់ជាកិច្ច ។ អាការកម្ចាត់បដិបក្ខនៃធម៌ គឺមគ្គទាំងឡាយរមែងប្រាកដជាអាការ ដែលជាក់ច្បាស់ដ៏កំពូល ព្រោះដូច្នោះ លោកអាចារ្យបានពោលថា សម្មាទិដ្ឋិជាធម្មជាតិដកអវិជ្ជានុស័យឡើងបានហើយ ក៏គង់ពោលថា **សម្មាទិដ្ឋិមានការទម្លាយភាពងងឹត គឺអវិជ្ជាជាបច្ចុប្បដ្ឋាន** ។

## អធិប្បាយ សម្មាសង្កប្ប

ពីរបទថា **យថា សម្បន្នទិដ្ឋិនោ** នៃយោគីដែលមានទិដ្ឋិដល់ព្រមហើយយ៉ាងនោះ សេចក្ដីថា នៃយោគីដែលមានទិដ្ឋិដល់ព្រមហើយ ដោយការឃើញប្រពៃ ក្នុងមគ្គ ដោយប្រការដែលនឹងមានការដកអវិជ្ជានុស័យឡើងបាន ។ **តថា**-ស័ព្ទ រមែងសង្គ្រោះយកសេចក្ដីប្រការនេះចូលមកថា នៃយោគីដែលបដិបត្តិដើម្បីការចាក់ធ្លុះសច្ចៈទាំង ៤ យ៉ាងនេះផង ។ ឯសម្មាសង្កប្បមាននិព្វានជាអារម្មណ៍ ក៏ដឹងបាន ដោយពាក្យថា ប្រកបជាមួយសម្មាទិដ្ឋិនោះឯង ។ ពាក្យថា **កម្ចាត់មិច្ឆាសង្កប្បចេញបាន** គឺកាត់មិច្ឆាសង្កប្ប មានការត្រិះរិះក្នុងកាមជាដើមបានជាសមុច្ឆេទ ។ ពាក្យថា **មានអប្បនាការពិតប្រាកដជារស** គឺមានអប្បនាការពិតប្រាកដជាកិច្ច ព្រោះប្រព្រឹត្តទៅ

ដោយអំណាចការញ៉ាំងមគ្គចិត្តឲ្យកើតឡើងក្នុងអារម្មណ៍ គឺនិព្វាន។

## អធិប្បាយ សម្មាវាចា

ពាក្យថា របស់យោគីដែលកំពុងឃើញ និងកំពុងត្រិះរិះយ៉ាងនោះ គឺរបស់យោគីដែលកំពុងឃើញដោយសម្មាទិដ្ឋិ មានប្រការដូចពោលហើយ បុគ្គលលើកចិត្តឡើងដោយសម្មាសង្កប្បក្នុងអារម្មណ៍ គឺនិព្វាន ។ ពាក្យថា **ដកវចីទុច្ចរិតឡើងបាន** គឺកាត់វចីទុច្ចរិតទាំង ៤ យ៉ាងបានជាសមុច្ឆេទ ។ សម្មាវាចាមានសភាវៈ កំណត់កាន់យកសម្បយុត្តធម៌ទាំងឡាយ ដោយការស្និទ្ធចិត្ត ព្រោះជាបដិបក្ខចំពោះមិច្ឆាវាចាទាំងឡាយ មានមុសាវាទជាដើម ដែលជាការសៅហ្មង មានការកំណត់ កាន់យក ព្រោះការដែលមានមិច្ឆាវាចា មានកិច្ចជាដើមថា ពោលឲ្យឃ្លៀងឃ្លាត ព្រោះដូច្នោះទើបលោកអាចារ្យពោលថា សម្មាវាចានោះមានការកំណត់កាន់យកជាលក្ខណៈ ។

## អធិប្បាយ សម្មាកម្មន្តៈ

កិរិយាផ្លូវកាយរមែងញ៉ាំងកិច្ចដែលគប្បីធ្វើខ្លះឲ្យតាំងឡើងការតាំងឡើងបានឯងក៏រមែងជាការប៉ះខ្ទប់គ្នា ព្រោះដូច្នោះ វិរតិដែលហៅថា សម្មាកម្មន្តៈ លោកក៏ពោលថាមានសភាវៈតាំងឡើង ។ម្យ៉ាងទៀត ការលើកសម្បយុត្តធម៌ទាំងឡាយឡើង ក៏ឈ្មោះថា ការធ្វើឲ្យតាំងឡើង ដូចលើករបស់ធ្ងន់ឡើងដោយអាកប្បកិរិយាផ្លូវកាយ ដូច្នោះ។

## អធិប្បាយ សម្មាអាជីវៈ

បទថា **អស្ស យោគ យោគិនោ** ប្រែថា នៃព្រះយោគីនោះ ។ ការវៀរចាកមិច្ឆាអាជីវៈ ក៏ **ជាភាពបរិសុទ្ធ** ព្រោះបរិសុទ្ធក្នុងកាលមានសម្មាកម្មន្តៈនោះ ។ សេចក្តីបរិសុទ្ធរបស់សត្វដែលនៅមានជីវិត ឬរបស់សម្បយុត្តធម៌ទាំងឡាយ ឈ្មោះថា **ភាព**

ផូរផង់ ម្យ៉ាងទៀត សេចក្តីបរិសុទ្ធរបស់អាជីវៈនោះឯង គឺរបស់ការប្រព្រឹត្តទៅនៃជីវិតិន្ទ្រិយ ឈ្មោះថា **ភាពផូរផង់** ។ សម្មាអាជីវៈនោះ ឈ្មោះថា **មានការញុំាងសម្មាអាជីវធម៌ឲ្យប្រព្រឹត្តទៅជារស** ព្រោះភាពជាហេតុនៃការប្រព្រឹត្តទៅរបស់សម្មា-អាជីវធម៌ គឺការចិញ្ចឹមជីវិតត្រូវ ដែលព្រះសម្ពុទ្ធទ្រង់មិនតិះដៀល ។

## អធិប្បាយ សម្មាវាយាមៈ – សម្មាសតិ – សម្មាសមាធិ

សម្មាវាយាមៈ សូម្បីទម្លាយអកុសលទាំងឡាយបាន លោកក៏ពោលថា **កាត់កោសជ្ជៈបានជាសមុច្ឆេទ** ដោយអំណាចសម្តែងធម៌ដែលជាបដិបក្ខដោយត្រង់ ។ ការផ្គងចិត្តនោះអំពីធម៌ដែលជាចំណែកនៃសង្កិលេស ឈ្មោះថា **ការផ្គង** ។ អកុសលក្ខន្ធទាំងឡាយ មានសុភសញ្ញាជាដើមជាប្រធាន ប្រព្រឹត្តទៅដោយអំណាចការចូលទៅទ្រទ្រង់ទុកនូវអាការថា ស្អាតក្នុងកាយជាដើម ឈ្មោះថា **មិច្ឆាសតិ** ការមិនភ្លេចភ្លាំងដែលកម្ចាត់មិច្ឆាសតិនោះ ឈ្មោះថា **មិច្ឆាសតិវិនិទ្ធុននោ** ប្រែថា កម្ចាត់មិច្ឆាសតិចេញបាន ។ ពាក្យថា **ការមិនភ្លេច** បានដល់ ធម៌ដែលជាបដិបក្ខចំពោះការភ្លេចនោះ ព្រោះកម្ចាត់ការភ្លេចភ្លាំងបាន ។ ការកំណត់សភាវៈតាមសេចក្តីពិតនូវអារម្មណ៍ ឈ្មោះថា **ឧបដ្ឋាន** ប្រែថា ការតាំងមាំ ។ សតិជាគ្រឿងរក្សាកុសលចិត្ត ដោយពិសេស ព្រោះមានបាលីថា **អារក្ខបច្ចុប្បដ្ឋានា** ប្រែថា សតិមានការរក្សាជាបច្ចុប្បដ្ឋាន និង **សតារក្ខេនចេតសា** ប្រែថា មានចិត្តដែលសតិរក្សា ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **នៃយោគីដែលមានចិត្តត្រូវសតិរក្សា** ។

ពាក្យថា **នៃសច្ចញ្ញាណ** បានដល់ នៃញាណដែលប្រារព្ធសច្ចៈទាំងឡាយប្រព្រឹត្តទៅ អនុពោធញ្ញាណរមែងត្រាស់ដឹងតែម្តងប៉ុណ្ណោះ ដូចបដិវេធញ្ញាណក៏ទេ ដោយពិត ជាការត្រាស់ដឹងតាមៗ គ្នាទៅ ព្រោះកើតឡើងរឿយៗ ទើបឈ្មោះថា

**អនុពោធ** ន័យម្យ៉ាងទៀត ការត្រាស់ដឹងដែលទៅតាមការបានឮ បានស្តាប់មក ការនឹកគិតទៅតាមអាការ ការឃើញ ការសម្ងឹង និងការត្រូវចិត្ត ក៏ឈ្មោះថា **អនុពោធ** ឈ្មោះថា **អនុពោធញ្ញាណ** ក៏ព្រោះអត្ថថា ជាញាណនោះឯង ។ អនុពោធញ្ញាណនោះរមែងត្រាស់ដឹងដោយប្រចក្សក៏ទេ តែត្រាស់ថា ដោយការនឹកគិតជាលំដាប់ ដោយអំណាចការបានឮ បានស្តាប់មកជាដើម ។ ពាក្យថា **ដោយកិច្ច** បានដល់ ដោយកិច្ចមានការកំណត់ដឹងជាដើម ។ ពិតហើយ ដោយការធ្វើកិច្ចនោះឯង កិច្ចទាំងនោះ ក៏រមែងប្រាកដដល់អនុពោធញ្ញាណនោះ ដូចទុក្ខសច្ច ដែលគប្បីកំណត់ដឹងជាដើម ។ ឯមគ្គញ្ញាណ ដែលកើតឡើងដល់លោក ដែលមានចិត្តដកចេញអំពីសង្ខារទាំងឡាយ ដោយវិវដ្តាវិបស្សនា រមែងកំណត់ដឹងទុក្ខ ធ្វើវិសង្ខារដែលជាទីរលត់ចេញនៃទុក្ខឲ្យជាអារម្មណ៍ រមែងលះតណ្ហាដែលជាហេតុនៃសេចក្តីទុក្ខ និងរមែងធ្វើឲ្យជាក់ច្បាស់គឺសម្មុស្សនិរោធ ។ មគ្គញ្ញាណនោះ ដែលកើតព្រមនឹងអង្គមគ្គដទៃ មានសម្មាសង្កប្បជាដើម រមែងញ៉ាំងមគ្គឲ្យកើត ដូចជាព្រះអាទិត្យកើតព្រមជាមួយរស្មី ដូច្នោះ ញាណដែលមិនទាន់លះបង់សង្ខារប្រព្រឹត្តទៅ មិនអាចធ្វើកិច្ចទាំងអស់នេះបាន ព្រោះមិនទាន់ចេញទៅអំពីនិមិត្ត និងបវត្ត ។ ព្រោះដូច្នោះ ទើបញាណនោះធ្វើកិច្ចនេះបាន រមែងញ៉ាំងទុក្ខសច្ចជាដើម បានដោយការកម្ចាត់នូវសម្មោហៈ ក្នុងសច្ចៈទាំងនោះ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **រមែងចាក់ធ្លុះសច្ចៈទាំង ៤** អធិប្បាយថា ដោយការចាក់ធ្លុះតែម្តង ។ បើមានពាក្យសួរថា ពាក្យថា **បុគ្គលនោះរមែងឃើញទុក្ខសមុទយៈ** ដូច្នេះ លោកពោលសំដៅដល់ការឃើញក្នុងកាលដទៃទេដឹង ? ឆ្លើយថា មិនមែនទេ ការពិចារណាដែលបុគ្គលអ្នកឃើញសច្ចៈមួយ នឹងជាអ្នកឃើញសច្ចៈ ៣ ដទៃទៀត ដោយព្រះបាលីថា **ម្នាលអាវុសោ បុគ្គលណាហ្ន៎ា រមែងឃើញទុក្ខ បុគ្គលនោះ រមែងឃើញសមុទយៈផងដែរ** ដូច្នេះជាដើម ព្រោះ **ព្រះគវម្បតិត្ថេរ** បានលើកយក ព្រះ

សូត្រ នេះមក ដើម្បីញុំាងសេចក្តីនោះឲ្យសម្រេច និងព្រោះកាលបុគ្គលឃើញសច្ចៈ ណាមួយ ក៏ប្រកបយកការឃើញសច្ចៈ ៣ ដទៃទៀតផងដែរ ។ កាលកាន់យកអត្ថដទៃ ក៏មិនគួរប្រកបភាពដែលបុគ្គលអ្នកឃើញសច្ចៈ មានសមុទយៈជាដើម ជាអ្នកឃើញ សច្ចៈ មានទុក្ខជាដើម ព្រោះក្នុងការត្រាស់ដឹងតាមលំដាប់សច្ចៈដែលបានឃើញមុន ខាងក្រោយនឹងមិនឃើញទៀត ភាពដែលបុគ្គលឃើញសច្ចៈ មានសមុទយៈជាដើម ជាអ្នកឃើញសច្ចៈ មានទុក្ខជាដើមនោះ លោកប្រកបទុកដោយព្រះបាលីជាដើមថា **បុគ្គលណាឃើញទុក្ខសមុទយៈ បុគ្គលនោះរមែងឃើញទុក្ខ** ។ **លោកិយំ យោគ សច្ចញ្ញាណំ** សច្ចញ្ញាណដែលជាលោកិយ ។ **តត្ថ យោគ លោកិយញ្ញាណេ** ប្រែថា ក្នុងលោកិយញ្ញាណនោះ ។ ការគ្រេបសង្កត់ ពោល គឺការរួបរឹត ឈ្មោះថា **បរិយុ-ដ្ឋានាភិភវោ** ប្រែថា ការគ្របសង្កត់ គឺការរួបរឹត ដោយអំណាចនៃការគ្របសង្កត់ គឺ ការរួបរឹតនោះ ។ ទុក្ខញ្ញាណ រមែងហាមការរួបរឹត គឺសក្កាយទិដ្ឋិ ព្រោះឃើញត្រឹម តែគំនរនៃសង្ខារសុទ្ធៗ ។ ការឃើញសមុទយៈ រមែងហាមឧច្ឆេទទិដ្ឋិដែលប្រព្រឹត្តទៅ ដោយអំណាចការគ្របសង្កត់គឺការរួបរឹត ព្រោះឃើញតំណរបស់ហេតុនិងផល ដែល ទាក់ទងគ្នា ដោយព្រះបាលីថា ម្នាលកច្ចានៈ កាលបុគ្គលឃើញដោយបញ្ញាដ៏ប្រពៃ តាមសេចក្តីពិតនូវហេតុកើតរបស់លោក រមែងមិនមានក្នុងលោកណា ការមិនមាន ក្នុងលោកនោះ ក៏រមែងមិនមាន ។ ការឃើញនិរោធក៏រមែងហាមសស្សតទិដ្ឋិ ព្រោះ ឃើញការរលត់នៃផល ព្រោះការរលត់នៃហេតុ ដោយព្រះបាលីថា កាលបុគ្គលឃើញ ដោយបញ្ញាដ៏ប្រពៃ តាមសេចក្តីពិតនូវការរលត់របស់លោក ការមានក្នុងលោកឯណា ការមាននោះមិនមាន ។ ការឃើញមគ្គ ព្រោះឃើញដោយប្រចក្សនូវការធ្វើរបស់ខ្លួន ក៏រមែងលះអកិរិយទិដ្ឋិ មានការធ្វើរបស់ខ្លួនរមែងមិនមាន ការធ្វើរបស់បុគ្គលដទៃ រមែងមិនមាន ការធ្វើរបស់បុរសក៏មិនមានជាដើម ។ មិនមានហេតុ មិនមានបច្ច័យ

ដើម្បីការសៅហ្មងនៃសត្វទាំងឡាយ សត្វទាំងឡាយមិនមានហេតុ មិនមានបច្ច័យ រមែងសៅហ្មងខ្លួនឯង មិនមានហេតុ មិនមានបច្ច័យដើម្បីការបរិសុទ្ធនៃសត្វទាំងឡាយ សត្វទាំងឡាយមិនមានហេតុ ។បេ។ រមែងបរិសុទ្ធខ្លួនឯង គប្បីឃើញថា លោកកាន់យកហើយ ដោយស័ព្ទថា **អកិរិយទិដ្ឋិនោះឯង** ក្នុងទីនេះ ។ អហេតុកទិដ្ឋិនោះ រមែងលះបានដោយការឃើញផ្លូវនៃភាពបរិសុទ្ធ ដូច្នេះ ។ ទុក្ខញ្ញាណ ក៏រមែងហាមឃាត់ **ការបដិបត្តិខុសក្នុងផល** ព្រោះរមែងឃើញទុក្ខ ដែលជាផលរបស់សមុទយៈ ជាវត្ថុដែលមិនមានភាពស្ថិតស្ថេរជាដើម ។បុគ្គលដែលប្រកាន់លទ្ធិថា **លោកមានព្រះឦស្វរជាហេតុ** រមែងពោលថា ព្រះឦស្វររមែងញុំាងលោកឲ្យប្រព្រឹត្តទៅ រមែងចាត់ចែងលោក រមែងហាមលោក រមែងរួបរួមលោក ។ បុគ្គលដែលប្រកាន់លទ្ធិថា **លោកមានវត្ថុដែលជាប្រធានជាហេតុ** រមែងពោលថា លោករមែងកើតស្វាងដោយវត្ថុដែលជាប្រធាន និងរមែងវិនាស ព្រោះវត្ថុដែលជាប្រធាននោះឯង ។ **បុគ្គលដែលប្រកាន់លទ្ធិព្រះកាល** រមែងពោលថា

ព្រះកាលរមែងសាងសត្វទាំងឡាយ ព្រះកាលរមែងបណ្តាលសត្វទាំងឡាយ ព្រះកាលរមែងដាស់សត្វដែលនិទ្រាទាំងឡាយ ព្រះកាលមិនមានបុគ្គលណាឈានកន្លងបាន ។

**បុគ្គលដែលប្រកាន់លទ្ធិសភាវៈ គឺការកើតឯង** រមែងពោលថា លោករមែងកើតនិងវិនាសទៅដោយសភាវៈ គឺការកើតឯងនោះឯង ដូចជាបន្លាស្រួចឯង ដូចជាផ្លែឈើមានផ្លែខ្វិតជាដើមមូលឯង និងដូចសត្វតិរច្ឆាន មានម្រឹគ បក្សី និងសត្វលូនវារជាដើម មានសរីរៈផ្សេងៗ ។ ដោយ **អាទិ-ស័ព្ទ** ពួកប្រកាន់លទ្ធិអណូ ក៏រមែងពោលថា លោកប្រព្រឹត្តទៅដោយអណូទាំងឡាយ ពួកប្រកាន់លទ្ធិ មានហេតុអំពីការធ្វើក្នុងកាលមុន រមែងពោលថា វត្ថុគ្រប់យ៉ាង មានវត្ថុដែលធ្វើមកអំពីមុនជាហេតុ **ពួកអ្នកប្រកាន់លទ្ធិ**

ជាទៀង រមែងពោលថា លោកទៀង ដូចជាកែវមណីមិនមានការបាក់បែក ត្រូវដោត ទុកដោយអំបោះដែលមិនដាច់ ក្នុងលោកនេះមិនមានការធ្វើរបស់បុរសនៃបុគ្គលណា មួយឡើយ ។

ចំណែកពួកប្រកាន់លទ្ធិថា ប្រព្រឹត្តទៅតាមប្រាថ្នា ដែលហៅថា **លទ្ធិវត្ថុគ្រប់យ៉ាងកើតឡើងបានអណ្តែតត្រសែត** រមែងពោលថា **វត្ថុគ្រប់យ៉ាងរមែងប្រព្រឹត្តទៅតាមប្រាថ្នា រមែងឈប់តាមប្រាថ្នា សុខទុក្ខក៏មានបានតាមប្រាថ្នា ព្រោះដូច្នោះពពួកសត្វក៏ប្រាថ្នាតាមពេញចិត្ត** ។ បណ្ឌិតគប្បីឃើញការរួមយកលទ្ធិថា មិនមានហេតុជាដើមយ៉ាងនេះ ។ ការប្រកាន់ថា អប្បវគ្គ គឺការរួចផុតនៅត្រង់អរូបលោក ដូចជាលទ្ធិរបស់រាមតាបសឧទកតាបស និងអាឡារតាបសជាដើម និងនៅត្រង់លោក-ថូបិកា គឺកំពូលលោក ដូចជាលទ្ធិរបស់ពួកនិគ្រន្ថ ឈ្មោះថា **អប្បវគ្គគ្គាហ** ប្រែថា ទិដ្ឋិក្នុងការរួចផុត ។ ដោយ **អាទិ**-ស័ព្ទ គប្បីឃើញការប្រកាន់របស់ពួកលទ្ធិ មានលទ្ធិដែលប្រកាន់ការប្រព្រឹត្តទៅរបស់ប្រធាន ១ លទ្ធិដែលប្រកាន់ថា អត្តាដែលមិនប្រកបដោយគុណតាំងចុះក្នុងអត្តារបស់ខ្លួន ១ លទ្ធិដែលប្រកាន់ថា ព្រហ្មប្រព្រឹត្តទៅជាមួយលោក ១ លទ្ធិដែលប្រកាន់ថា ព្រហ្មនៅជិតលោក ១ លទ្ធិដែលប្រកាន់ថា ព្រហ្មប្រកបគ្នា ១ លទ្ធិដែលឈ្មោះថា ទិដ្ឋធម្មនិព្វានវាទ ប្រកាន់ថានិព្វានជាបច្ចុប្បន្ន ១ ជាដើម ។ ក្នុងបណ្តាលទ្ធិទាំងនេះ **លទ្ធិដែលប្រកាន់ការមិនប្រព្រឹត្តទៅរបស់ប្រធាន** បានដល់ លទ្ធិដែលប្រកាន់ថា មិនមានការផ្លាស់ប្តូរ ឬលទ្ធិដែលប្រកាន់ថា មិនមានការប្រកបដោយការៈ មានភាពដែលជាប្រធានជាវត្ថុដែលធំជាដើម បានឮថា កាលបានបដិសេធការកាន់យកដោយ មិនមានការបែកក្នុងអត្តា សុខ ទុក្ខ និងមោហៈ ដោយការដឹងប្រក្រតី និងបុរសដទៃ ដែលប្រព្រឹត្តទៅយ៉ាងនេះថា អញម្យ៉ាង ប្រក្រតីម្យ៉ាង ដូច្នេះ ពួកអ្នកប្រកាន់លទ្ធិកបិលទាំងឡាយ រមែងពោលថា ប្រធានរមែងមិនប្រព្រឹត្ត

ទៅតាមន័យ ដែលបានពោលហើយ នុ៎ះជាវិមោក្ខ គឺនិព្វាន ។ ពាក្យថា **មិនប្រកប ដោយគុណ** មានសេចក្ដីថា ពួកអ្នកប្រកាន់លទ្ធិដែលអណ្ដែតតាមមតិរបស់ឥសីកណាទ រមែងពោលថា មិនប្រកបដោយគុណនៃអត្តា ៩ យ៉ាង គឺពុទ្ធិ សុខ ទុក្ខ សេចក្ដីប្រាថ្នា អទោសៈ បយត្តៈ (សេចក្ដីព្យាយាម) ធម្មៈ អធម្មៈ និងសង្ខារ ។ លទ្ធិដែលប្រកាន់ថា ព្រហ្ម **ប្រព្រឹត្តទៅជាមួយលោក** បានដល់ លទ្ធិដែលប្រកាន់ថា ព្រហ្មមានលោកស្មើគ្នា **លទ្ធិដែលឈ្មោះថា ព្រហ្មនៅជិតលោក** បានដល់ លទ្ធិដែលឈ្មោះថា ព្រហ្មនោះប្រព្រឹត្តទៅក្នុងទីជិត ។ **លទ្ធិដែលប្រកាន់ថា ព្រហ្មប្រកបនៅជាមួយលោក** បានដល់ លទ្ធិដែលប្រកាន់ការចូលដល់ភាពជាមួយនឹងព្រហ្មនោះ ។ ការប្រកាន់ថា អបវគ្គ គឺការរួចផុត ប្រព្រឹត្តទៅអំពីការបម្រុងឥន្ទ្រិយឲ្យឆ្អែតស្កប់ស្កល់ និងការឃើញមុខបុត្រជាដើម រមែងមិនមាន ដោយប្រព្រឹត្តទៅតាមនោះ ឈ្មោះថា **កាមសុខល្លិកានុយោគ** ការប្រកាន់ថា មោក្ខ គឺការរួចផុត រមែងមានបានដោយការធ្វើខ្លួនឲ្យក្ដៅដោយការបំពេញតបៈ មានការអត់អាហារ និងដកសក់ជាដើម និងដោយសីល មាននគ្គសីល ការអាក្រាតកាយ គោសីល ការប្រព្រឹត្តដូចគោ និងកុក្កុរសីល ការប្រព្រឹត្តដូចឆ្កែជាដើម ហើយប្រព្រឹត្តទៅតាមនោះ ឈ្មោះថា **អត្តកិលមថ** ការធ្វើខ្លួនឲ្យលំបាក ។

លោកអាចារ្យកាលសង្គ្រោះអត្ថ ដែលបានពោលទុកហើយនោះឯងថា ការប្រកាន់ខុសទាំងអស់នេះ កាលមានសច្ចញ្ញាណ រមែងមិនបានទីតាំងអាស្រ័យ ទើបពោលគាថាថា **លោកេ លោកប្បភវេ** ប្រែថា ក្នុងលោក ក្នុងហេតុកើតរបស់លោក ដូច្នេះឯង ។

ពណ៌នាការវិនិច្ឆ័យដោយកិច្ចញ្ញាណ ចប់ហើយ ។

ពាក្យថា **ធម៌ទាំងពួងដ៏សេស** បានដល់ លោកិយធម៌ដ៏សេស ៨១ តណ្ហា ៣ ពួក ១២ ជង គឺកាមតណ្ហា ភវតណ្ហា និងវិភវតណ្ហា ក្នុងអាយតនៈ ១២ ទាំងខាងក្នុង

និងក្រៅ ឈ្មោះថា **តណ្ហាវិចរិត ៣៦** ឬតណ្ហាវិចរិតដែលមិនបានពោលដល់ ការបែកកាល ត្រាស់ទុកតាមន័យដែលមានមកក្នុងគម្ពីរខុទ្ទកវិភង្គ ព្រោះក្នុងការប្រារព្ធដល់ការបែកកាលនោះ ក៏ជាតណ្ហាវិចរិត ១០៨ ។ ពាក្យថា **និរោធសច្ចមិន លាយឡំ** គឺមិនលាយឡំជាមួយអ្វីៗ ព្រោះនិរោធសច្ចជាពួកមួយ អធិប្បាយថា ប្រភេទដែលចុះកាន់ខាងក្នុងនិរោធសច្ចនោះ នឹងមានមកអំពីណា ។ សូម្បីកាលពោធិបក្ខិយធម៌ មានវិមង្សិទ្ធិបាទជាដើម នឹងផ្សេងគ្នាដោយកិច្ច ដោយអត្ថក៏រួមចូលដោយសម្មាទិដ្ឋិ ព្រោះជាភាពដូចគ្នា ដូច្នោះ លោកអាចារ្យពោលពោធិបក្ខិយធម៌ មានវិមង្សិទ្ធិបាទជាដើម ជាធម៌ដែលចុះកាន់ក្នុងមគ្គសច្ចនោះ ដោយមុខ គឺសម្មាទិដ្ឋិ ។

ពាក្យថា **វិតក្ក ៣ មានទេក្ខម្មវិតក្កជាដើម** សេចក្ដីថា ក្នុងខណៈដែលជាលោកិយវិតក្កបែកដោយអំណាចការប្រកបជាមួយអលោភៈ មេត្តា និងករុណា ក្នុងខណៈនៃមគ្គវិតក្កមាន ៣ យ៉ាងដោយអំណាចការកាត់លោភៈ ព្យាបាទ និងវិចិកិច្ឆាបានជាសមុច្ឆេទ ព្រោះដូច្នោះ ទើបលោកពោលថា វិតក្កសូម្បីមួយក៏មាន ។ **ក្នុងសម្មាវាចា** ជាដើមក៏ដូចន័យនេះ ។ ព្រោះកាលការប្រាថ្នាតិច និងការសន្ដោសមាន ទើបសម្មាអាជីវៈមាន ទើបបណ្ឌិតគប្បីឃើញ ការសង្គ្រោះយកការប្រាថ្នាតិច និងការសន្ដោសនោះ ចូលជាមួយសម្មាអាជីវៈនោះ ។ អរិយកន្តសីលទាំងឡាយ គប្បីកាន់យកដោយដៃ គឺសទ្ធា ព្រោះការកាន់យកសីលដែលឈ្មោះថា **អរិយកន្ត** ហេតុដែលព្រះអរិយៈទាំងឡាយមិនកន្លងល្មើសសូម្បីក្នុងកពដទៃ សូម្បីព្រោះហេតុនៃជីវិត ដែលបានដល់សីល មានសម្មាវាចាជាដើម ដៃ គឺសទ្ធានោះក៏រមែងកាន់យកហើយនោះឯង ព្រោះដូច្នោះ សទ្ធិន្ទ្រិយ និងសទ្ធាពលៈ ដែលមិនមែនដទៃក្រៅអំពីអរិយកន្តសីលនោះ ទើបលោកពោលថា ចុះកាន់ខាងក្នុង ក្នុងមគ្គសច្ចនោះ ។ លោកពោលថា សូម្បីឆន្ទិទ្ធិបាទចុះកាន់ខាងក្នុង ក្នុងមគ្គសច្ចនោះ ព្រោះអធិប្បាយថា ឆន្ទៈជាគុណមានដំណើរតាមសទ្ធា ។ ពីរបទថា

**តេសំ អត្ថិតាយ** សេចក្តីថា ព្រោះភាពដែលសីលមានដោយហេតុសទ្ធិន្ទ្រិយ សទ្ធាពលៈ និងឆន្ទិទ្ធិបាទមាន ទើបលោកកាន់យកធម៌ទាំង ៣ យ៉ាងនោះ ដោយសីលទាំង ៣ យ៉ាង ព្រោះដូច្នោះ ទើបធម៌ទាំង ៣ យ៉ាង ចុះកាន់ខាងក្នុង ក្នុងមគ្គសច្ចនោះ ។ លោកអាចារ្យពោលចិត្តិទ្ធិបាទថា **ចិត្តសមាធិ** ។ ពិតហើយ សមាធិ លោកពោលដោយមាតិកាថា **ចិត្ត** ដូចក្នុងពាក្យថា **ចិត្តំ បញ្ញញ្ច ភាវយំ** ព្រោះដូច្នោះ ចិត្តក៏គួរដល់ការៈដែលគប្បីពោលដោយមាតិកា គឺសមាធិ ។ ឯសមាធិ រមែងជាធម៌មានប្រមាណក្រៃលែង ដោយការចម្រើនចិត្តិទ្ធិបាទ ព្រោះដូច្នោះ ទើបលោកមិនពោលថា ជាចិត្តិទ្ធិបាទ ដូចជាពោលវិមង្សិទ្ធិបាទជាដើម ហើយពោលថា **ចិត្តសមាធិ** ក្នុងទីនេះ ។ **បីតិ** និង **បស្សទ្ធិ** ជាឧបការៈដល់សមាធិ ដោយព្រះបាលីថា កាយរបស់បុគ្គលដែលមានចិត្តប្រកបដោយបីតិ រមែងស្ងប់រម្ងាប់ បុគ្គលដែលមានកាយស្ងប់រម្ងាប់ហើយ រមែងសោយសុខ ចិត្តរបស់បុគ្គលដែលមានសេចក្តីសុខ រមែងជាសមាធិ ព្រោះដូច្នោះ ទើបលោកកាន់យកដោយស័ព្ទថា **សមាធិ** ។ ចំណែកឧបេក្ខាក៏កាន់យកដោយស័ព្ទថា **សមាធិ** ព្រោះមានឧបការៈដល់សមាធិ និងព្រោះមានកិច្ចដូចសមាធិនោះ ។ ព្រោះដូច្នោះ គប្បីឃើញធម៌ទាំងនេះជាសភាវៈដែលចុះកាន់ខាងក្នុង ដោយស័ព្ទជាប្រធាន គឺសមាធិ ។

ពណ៌នាការវិនិច្ឆ័យប្រភេទនៃធម៌ដែលឈោងចុះខាងក្នុង

ចប់ហើយ ។

**ទុក្ខសច្ច** ឈ្មោះថា **ដូចរបស់ធ្ងន់** ព្រោះជាធម្មជាតិដែលបៀតបៀន អធិប្បាយថា ព្រោះជាធម្មជាតិដែលនាំទៅដោយពិសេស ដោយអំណាចជាវត្ថុត្រូវនាំទៅព្រម ។ ឈ្មោះថា **ដូចការកាន់របស់ធ្ងន់** ព្រោះជាហេតុនៃការបៀតបៀនដែលកើតឡើងក្នុងភពនោះៗ ។ ឈ្មោះថា **ដូចដាក់របស់ធ្ងន់** ព្រោះជាធម្មជាតិចូលទៅរកសេចក្តីស្ងប់ទុក្ខក្នុងបច្ចុប្បន្ន ។ **រោគោ វិយ** ( ប្រៀបដូចរោគភ័យ ) **ទុព្ភិក្ខមិវ** ( ប្រៀបដូចទុព្ភិក្ស )

បានដល់ ព្រោះធ្វើឲ្យលំបាកគ្រប់សង្កត់ **រោគនិទានំ វិយ** ( ប្រៀបដូចប្រភពកើតនៃរោគភ័យ ) **ទុព្ភិក្ខំ វិយ** ( ប្រៀបដូចគ្មានភ្លៀង ) បានដល់ ធម្មជាតិ មានហេតុឲ្យកើតជាលក្ខណៈ ។ ឯបទថា **ទុព្ភិក្ខំ** បានដល់ ភ្លៀងមិនធ្លាក់ ឬភ្លៀង ធ្លាក់ច្រើនពេកទៅ ( កើតឧទកភ័យ ) ។ បទថា **រោគវូបសមោ វិយ** ( ប្រៀបដូចការស្ងប់រោគ) និងបទថា **សុភិក្ខមិវ** (មានអាហារបរិបូណ៌) បានដល់ ធម្មជាតិ មានការស្ងប់ជាលក្ខណៈ ព្រោះមានសេចក្ដីសុខ ។ សេចក្ដីនេះ សមដូចព្រះបាលីត្រាស់ទុកថា **និព្វានំ បរមំ សុខំ** ប្រែថា និព្វានជាបរមសុខ ។ **ភេសជ្ជមិវ សុវុដ្ឋិ វិយ** ( ប្រៀបដូចថ្នាំរក្សារោគ និងភ្លៀងធ្លាក់ល្អ ) ព្រោះកាត់ហេតុនៃទុក្ខ និងព្រោះដូចជាឧបាយឲ្យផុតទុក្ខនោះ ។ ពិតហើយ មគ្គសច្ច មានការនាំចេញទៅអំពីទុក្ខជាលក្ខណៈ ។ **ទុក្ខ** ឈ្មោះថា ឧបមាដូចបុគ្គលមានពៀរ ដើមឈើពុល ភ័យ និងត្រើយអាយ ព្រោះជាវត្ថុដែលមិនគួរប្រាថ្នា និងព្រោះជាវត្ថុដែលមានសេចក្ដីរង្កៀស មានភ័យចំពោះមុខ **វេរំ** ( ពៀរ ) បានដល់ ការព្យាបាទ ឬជាសត្រូវ ។ **វេរសមុគ្ឃាត** ( ការរម្ងាប់ពៀរ ) បានដល់ ការស្ងប់រម្ងាប់ពៀរ គឺមេត្តា ។ **វេរសមុគ្ឃាតុបាយោ** ( ឧបាយដកពៀរ ) បានដល់ សង្គហវត្ថុ ។

ពណ៌នាការវិនិច្ឆ័យដោយឧបមា

ចប់ហើយ ។

ពាក្យថា **ក្នុងអរិយសច្ចដ៏សេស មានសមុទយសច្ចជាដើមក៏ន័យនេះ** សេចក្ដីថា ក្នុងអរិយសច្ចទាំង ៤ នេះ វត្ថុដែលជាសមុទយៈ មិនជាអរិយសច្ចក៏មាន ជាអរិយសច្ចតែមិនជាសមុទយៈក៏មាន ទាំងជាសមុទយៈ ទាំងជាអរិយសច្ចក៏មាន មិនជាសមុទយៈ មិនជាអរិយសច្ចក៏មាន ។ សូម្បីក្នុងសច្ចៈទាំង ២ ដ៏សេស ក៏ន័យនេះដូចគ្នា ។ ឈ្មោះថា **មិនជាអរិយសច្ច** ព្រោះមិនមានភាពជាបរិញ្ញេយ្យធម៌ ភាពជាបហាតព្វធម៌ ភាពជាអសង្ខតធម៌ ភាពជានិយ្យានធម៌ ។ ពាក្យថា **ចំណែកអរិយសច្ចទាំង ២ ក្រៅ**

**អំពីនេះ** លោកអាចារ្យពោលដល់សច្ចៈទាំង ២ គឺសមុទយៈ និងមគ្គ ។ ឈ្មោះថា ជាទុក្ខ ព្រោះជាសង្ខារទុក្ខ ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រោះមិនទៀង** ។ បទថា **តថត្តេន** ប្រែថា ដោយសភាវៈយ៉ាងនោះ សេចក្តីថា ដោយភាពជាបរិញ្ញេយ្យធម៌ ។ ដោយបទនោះ លោកអាចារ្យរមែងសម្តែងសេចក្តីនេះថា អរិយសច្ចទាំង ២ នោះ ជាទុក តែមិនមែនអរិយសច្ច ជាអរិយសច្ច តែមិនមែនទុក្ខ ។ ពិតហើយ ស័ព្ទមាន ទុក្ខ ជាដើម ដែលមានស័ព្ទថា **អរិយសច្ចក្រោយ** រមែងប្រាប់ដល់បរិញ្ញេយ្យធម៌ដែលគួរកំណត់ដឹង ។ ដោយហេតុនោះឯង ទើបលោកពោលការរួមបទដើមនៃធម៌ដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផល ដោយសំដៅដល់ទុក្ខស័ព្ទ ដែលមិនបានសំដៅដល់អរិយសច្ចស័ព្ទ តែលោកពោលការរួមបទទ ៤ សំដៅដល់ទុក្ខ-ស័ព្ទ ដែលសំដៅដល់អរិយសច្ច-ស័ព្ទ ។

ពាក្យថា **ដោយអាការទាំងពួង** គឺដោយប្រការទាំងពួង ។ អធិប្បាយថា ធម៌មានធម៌ដែលសម្បយុត្តដោយមគ្គជាដើមជាភាពវិកលនៃអង្គចំណែកមួយ យ៉ាងណា អរិយសច្ចមិនដូច្នោះឡើយ ព្រោះឈ្មោះថា ទុក្ខ និងព្រោះជាអរិយសច្ច ក៏ត្រូវប្រកបដោយអង្គគ្រប់ៗ ចំណែកនោះឯង ។ កាលពោលថា **ឧបាទានក្ខន្ធ ៥** ក៏គប្បីរួមយកតណ្ហាចូលផង ព្រោះដូច្នោះ ដើម្បីបដិសេធសេចក្តីនោះ ទើបលោកពោលថា **វៀរលែងតែតណ្ហា** ព្រោះតណ្ហានោះជាអរិយសច្ចមួយផ្នែក ។ អធិប្បាយថា ធម៌ទាំងឡាយមានកិលេសដ៏សេសជាដើមក្នុងអរិយសច្ចទាំងឡាយ មានសមុទយៈជាដើម ឈ្មោះថា **សមុទយៈ** ព្រោះអត្ថថា ជាដែនកើត មិនឈ្មោះថា ជាអរិយសច្ចនេះ ជាការ

ពណ៌នាតាមព្រះសូត្រ ។ និរោធជាអរិយសច្ច មិនមែនជាសមុទយៈ ។ ចំណែកអរិយសច្ចទាំង ២ ក្រៅអំពីនេះ គប្បីជាសមុទយៈ ដោយអត្ថថា ជាបច្ច័យដល់ផលរបស់ខ្លួន តែយោគាវចរមែងនៅប្រព្រឹត្តព្រហ្មចរិយៈក្នុងព្រះមានព្រះភាគ ដើម្បីលះសមុទយៈណា មិនជាសមុទយៈ ដោយភាពជាសមុទយៈយ៉ាងនោះ តែតណ្ហាជាសមុទយៈ និងជាអរិយសច្ចដោយអាការទាំងពួង យោគាវចរមែងប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីលះសមុទយៈណា ធម៌ដែលសម្បយុត្តដោយមគ្គទាំងឡាយ និងសាមញ្ញផលទាំងឡាយមិនជាសមុទយៈ មិនជាអរិយសច្ច ដោយភាពជាសមុទយៈយ៉ាងនោះ ។ សង្ខារនិរោធ ( ការរលត់សង្ខារ ) និងនិរោធសមាបត្តិ ( ការចូលនិរោធ ) ជានិរោធ តែមិនជាអរិយសច្ច ។ សមុទយៈជាអរិយសច្ច មិនជានិរោធ ។ ចំណែកអរិយសច្ច ២ ក្រៅអំពីនេះដែលជានិរោធ ព្រោះមានការរលត់ទៅដោយខណៈ តែយោគាវចរមែងនៅប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវនិរោធណា ក៏មិនជានិរោធដោយភាពជានិរោធយ៉ាងនោះ ។ ឯអសង្ខតធាតុជានិរោធ និងជាអរិយសច្ច ដោយប្រការទាំងពួង ។ ធម៌ដ៏សេសមានន័យដូចបានពោលទុកហើយនោះឯង ។ មគ្គដទៃក្រៅអំពីអរិយមគ្គជាមគ្គ តែមិនមែនអរិយសច្ច ។ និរោធជាអរិយសច្ច តែមិនមែនមគ្គ ។ ចំណែកសច្ចៈទាំង ២ ក្រៅអំពីនេះ ជាមគ្គ ព្រោះជាបដិបទាឲ្យប្រព្រឹត្តទៅកាន់ភព តែព្រះយោគាវចរមែងនៅប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីធ្វើមគ្គណាឲ្យកើត មិនជាមគ្គដោយភាពជាមគ្គយ៉ាងនោះ ឯនិរោធគាមិនីបដិបទាជាមគ្គ និងជាអរិយសច្ចដោយ

អាការទាំងពួង ។ ធម៌ដ៏សេសមានន័យបានពោលហើយនោះឯង ។

ពណ៌នាការវិនិច្ឆ័យដោយចតុក្កៈ ចប់ហើយ ។

## វិនិច្ឆ័យអរិយសច្ចដោយភាពជារបស់ទទេ

ពាក្យថា **ទទេ** អធិប្បាយថា ទទេចាកអ្នកសោយជាដើម ដែលពួកលទ្ធិខាងក្រៅសន្មត ។ រមែងមានត្រឹមតែបញ្ញត្តិថា ទុក្ខ ជាធម្មជាតិដែលគប្បីត្រូវសោយ ក៏វៀរចាកអ្នកសោយ ម្យ៉ាងទៀត កាលទុក្ខនោះកំពុងប្រព្រឹត្តទៅដោយបច្ច័យរបស់ខ្លួន តែម្យ៉ាងទុក្ខក៏រមែងសោយឯង ។ សូម្បីក្នុងសច្ចៈក្រៅអំពីនេះក៏ដូចន័យនេះ។

លោកអាចារ្យពោលថា **ន កោចិ ទុក្ខិតោ** បុគ្គលណាមួយដែលដល់នូវទុក្ខមិនមាន ដូច្នេះ ដើម្បីនឹងសម្តែងអត្ថដែលបដិសេធទុក ដោយអវធារណៈថា **ទុក្ខមេវ** ដែលប្រែថា ទុក្ខប៉ុណ្ណោះមាន ។ លោកអាចារ្យពោលសំដៅដល់សមុទយសច្ចថា **កិរិយា វ វិជ្ជតិ** ប្រែថា កិរិយាប៉ុណ្ណោះមាន ។ ម្យ៉ាងទៀត លោកអាចារ្យពោលដល់សភាវៈរបស់ទុក្ខសច្ចនៃខ្លួនបុគ្គលដែលធ្វើ ព្រោះសច្ចៈ ២ ខាងដើម រួមទុកដោយវិបាកវដ្តៈ និងកម្មវដ្តៈ ។ ទើបមានត្រឹមតែបញ្ញត្តិថា កិរិយាត្រូវធ្វើ វៀរចាកអ្នកធ្វើក៏រមែងធ្វើកិរិយាក្នុងសភាវៈដែលទាក់ទងដោយធម៌ ដែលតែងយល់ថា ទុក្ខដោយកិរិយានោះ ដែលប្រព្រឹត្តទៅដោយបច្ច័យរបស់ខ្លួនតែម្យ៉ាង ។សូម្បីក្នុងបុគ្គលរលត់និងបុគ្គលដើរក៏មានន័យនេះដូចគ្នា ។ គប្បីឃើញថា គួរនឹងពោលថា **មគ្គោ អត្ថិ** លោកធ្វើការលុប ឱ អក្ខរៈ ជា **មគ្គមត្ថិ** ។ ពាក្យថា **បុគ្គលដើរ** គឺបុគ្គលដើរទៅកាន់ការរលត់ ។

និរោធ និងមគ្គ ឈ្មោះថា ស្អាតតែម្យ៉ាង ព្រោះជាធម៌ដែលមិនមានអាសវៈ អធិប្បាយថា ជាធម៌ដែលប្រកបទៅដោយអាសវៈ ឈ្មោះថា **ជាការមិនស្អាត** ដោយអត្ថថា ហូរចេញនូវរបស់មិនស្អាត គឺកិលេស ។ ឯសច្ចៈ មានទុក្ខជាដើម និងសច្ចៈមានសមុទយៈជាដើម ដោយបរិយាយក៏មាន តែជានិរោធមិនមាន ន័យម្យ៉ាងទៀត និរោធជាសច្ចៈ មានទុក្ខជាដើមក៏ទេ ព្រោះដូច្នោះ សច្ចៈទាំង ៣ ដ៏សេសអំពីនិរោធ ជាធម៌ដែលមានការអាស្រ័យគ្នានឹងគ្នាក៏ទេ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **សច្ចៈទាំង ៣ ទទេចាកនិរោធ** ។

ពាក្យថា **ព្រោះក្នុងសមុទយៈមិនមានទុក្ខ** សេចក្ដីថា ព្រោះក្នុងតណ្ហាដែលជាតួបង្កឲ្យមានភពថ្មី មិនមានភពថ្មី ។ ន័យម្យ៉ាងទៀត វិការ គឺវត្ថុច្រើនយ៉ាងរបស់ពួកបកតិវាទ ព្រោះជាវត្ថុដែលមិនមានវិការ និងវត្ថុដែលផ្លាស់ប្ដូរទៅមុន ក៏រមែងតាំងនៅដោយប្រក្រតីនោះឯង យ៉ាងណា ទុក្ខសូម្បីសម្បយុត្តដោយសមុទយៈ ក៏មិនតាំងនៅដោយភាពជាសមុទយៈដូច្នោះឡើយ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ព្រោះក្នុងសមុទយៈមិនមានទុក្ខ** ។ ក្នុងសេចក្ដីថា ព្រោះក្នុងមគ្គមិនមាននិរោធ ។ អធិប្បាយថា ពួកម្ចាស់លទ្ធិបកតិវាទប្រាថ្នាប្រក្រតីឲ្យរួមគក៏គ្នាជាមួយវិការទាំងឡាយដែលមិនបានចែកទុក ដែលមានភាពផ្សេងគ្នានូវឥន្ទ្រិយពិសេស គ្រាន់តែជាមហាអហង្ការដែលតាំងនៅ ដោយភាពជាបកតិតែម្យ៉ាង យ៉ាងណា សច្ចៈមិនជាហេតុរួមគក៏គ្នាជាមួយសច្ចៈដែលជាផលដូច្នោះឡើយ ។ លោកអាចារ្យ កាលនឹងពង្រីកពាក្យនេះថា **ព្រោះទុក្ខសមុទយៈ និរោធ និងមគ្គ មិនរួមគ្នា** ទើបពោលពាក្យ

ជាដើមថា សច្ចៈដែលជាផលរបស់សច្ចៈដែលជាហេតុរួមគ្នានឹងសច្ចៈ ដែលជាហេតុមិនបាន ។ ពាក្យនោះ ពួកអាចារ្យលទ្ធិសមវាយ ពោលថា ការចងសម្ពន្ធគ្នារបស់វត្ថុដែលសម្រេចមិនបានញែកគ្នា ដែលធ្វើឲ្យកើតមានការសោយអារម្មណ៍ និងបញ្ញត្តិក្នុងលោកនេះ ដោយន័យជាដើមថា ក្នុងលោកនេះសំពត់រួមនៅក្នុងសរសៃអំបោះ ថ្នាំងរួមនៅក្នុងដីដែលដុត កន្ទេលរួមនៅក្នុងកក់ ទ្វិអណុកផលរួមនៅក្នុងអណូពីរដូច្នេះឈ្មោះថា ការរួបរួមព្រោះការរួមគ្នានោះ ទើបទ្វិអណុកផលរួម គឺជាប់ដូចជាមួយគ្នានៅក្នុងអណូពីរដែលជាតួហេតុ តិអណុកផលក៏រួមនៅក្នុងអណូ ៣ ដោយប្រការដូចពោលមកដូច្នេះ ផលដែលមានផែនដីធំ មានទឹកធំ មានភ្លើងធំ និងមានគំនរខ្យល់ធំជាទីបំផុតទើបរួមនៅក្នុងហេតុទាំងឡាយ ។ ម្យ៉ាងទៀត ពួកម្ចាស់លទ្ធិសមវាយដែលពោលយ៉ាងនេះ អធិប្បាយថា ផលមួយដែលមានបរិមាណធំក្រៃលែងរួមនៅក្នុងហេតុ ដែលមិនមានប្រមាណ ទើបរួមគកិមិនទទេទៅអំពីហេតុដែលចុះកាន់ខាងក្នុងរបស់ខ្លួន ។ អធិប្បាយថា សច្ចៈដែលជាហេតុ ទើបមិនមាននៅក្នុងសច្ចៈដែលជាផល ព្រោះដូច្នោះទើបសច្ចៈ ដែលជាផលទទេចាកសច្ចៈដែលជាហេតុ ដោយប្រការដូចពោលមកនេះ ។

ពណ៌នាការវិនិច្ឆ័យអំពីភាពទទេ

ចប់ហើយ ។

# វិសុទ្ធិមគ្គ

## ដោយប្រភេទផ្សេងៗ មានតែម្យ៉ាងជាដើម

ពាក្យថា ដោយប្រភេទផ្សេងៗ មានតែម្យ៉ាងជាដើម សេចក្តីថា ក្នុងសច្ចៈ ៤ នេះ ទុក្ខទាំងអស់មានតែម្យ៉ាងដោយបវត្តិ ( ការវិលទៅនៃសង្សារ ) ជា ២ ដោយនាម និងរូប ជា ៣ ដោយផ្សេងនៃឧបបត្តិភព គឺកាមភព រូបភព អរូបភព ជា ៤ ដោយចែកតាមអាហារ ៤ ( ដែលជាបច្ច័យ ) ជា ៥ ដោយបែកជាឧបាទានក្ខន្ធ ៥ ។

ចំណែកសមុទយៈមានតែម្យ៉ាងដោយបវត្តកៈ ( អ្នកញ៉ាំងសង្សារឲ្យវិលទៅ ) មាន ២ ដោយសម្បយុត្តជាមួយទិដ្ឋិ និងមិនសម្បយុត្តជាមួយទិដ្ឋិ មាន ៣ ដោយផ្សេងគ្នានៃកាមតណ្ហា ភវតណ្ហា វិភវតណ្ហា មាន ៤ ដោយទោសដែលគប្បីលះដោយមគ្គ ៤ មាន ៥ ដោយចែកជាចំណង់ត្រេកអរក្នុងអារម្មណ៍ ៥ មានចំណង់ត្រេកអរ ក្នុងរូបជាដើម មាន ៦ ដោយបំបែកជាកងតណ្ហា ៦ ។

ចំណែកនិរោធមានតែម្យ៉ាង ដោយអសង្ខតធាតុ តែដោយបរិយាយ មាន ២ ដោយសឧបាទិសេស និងអនុបាទិសេស មាន ៣ ដោយការស្ងប់ទៅនៃភព ៣ មាន ៤ ដោយធម៌ដែលគប្បីសម្រេចដោយមគ្គ ៤ មាន ៥ ដោយការវិនាសទៅនៃចំណង់ត្រេកអរ ៥ មាន ៦ ដោយការទម្លាយទៅនៃកងតណ្ហា ៦ ។

ចំណែកមគ្គមានតែម្យ៉ាង ដោយភាវេតព្វធម៌ មាន ២ ដោយចែកជាសមថៈ និងវិបស្សនា ឬដោយចែកជាទស្សនៈ ( គឺសោតាបត្តិមគ្គ ) និងភាវនា ( គឺសកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ ) មាន ៣ ដោយផ្សេងគ្នានៃ ( ធម្មៈ ) ខន្ធ ៣ ការពិតមគ្គនេះ ព្រោះហេតុដែលមានអង្គជាចំណែកតូច ទើបលោកសង្គ្រោះ ដោយធម្មក្ខន្ធ ៣ ដែលជាចំណែករួម ដូចក្រុងរួមចូលដោយដែន ដូច្នោះ ដូចព្រះធម្មទិន្នាថេរីពោល

( ឆ្លើយបញ្ហារបស់វិសាខឧបាសក ) ថា នៃអាវុសោវិសាខ ខន្ធ ៣ លោកមិនបាន សង្គ្រោះចូលដោយអរិយមគ្គមានអង្គ ៨ ទេ តែអរិយមគ្គមានអង្គ ៨ ផ្សេងដោយឡែក លោកសង្គ្រោះចូលដោយខន្ធ ៣ នៃអាវុសោវិសាខ សម្មាវាចាណាផង សម្មាកម្មន្តៈ ណាផង សម្មាអាជីវៈណាផង ធម៌ ( ៣ ) នេះ លោកសង្គ្រោះដោយសីលក្ខន្ធ សម្មាវាយាមៈណាផង សម្មាសតិណាផង សម្មាសមាធិណាផង ធម៌ ( ៣ ) នេះ លោកសង្គ្រោះដោយសមាធិក្ខន្ធ សម្មាទិដ្ឋិណាផង សម្មាសង្កប្បណាផង ធម៌ ( ២ ) នេះ លោកសង្គ្រោះដោយបញ្ញាខន្ធ ដូច្នេះ ។

ព្រោះក្នុងអរិយមគ្គនេះ ធម៌ ៣ មានសម្មាវាចាជាដើម ជាសីលពិត ព្រោះហេតុ នោះ ទើបធម៌ ៣ នោះ លោកសង្គ្រោះចូលដោយសីលក្ខន្ធ ដោយមានជាតិស្មើគ្នា ។

ក្នុងព្រះបាលីលោកធ្វើនិទ្ទេសទុកដោយកម្មវចនៈថា **សីលក្ខន្ធេ** ក៏ពិត តែក៏គប្បី ជ្រាបសេចក្ដីដោយករណវចនៈ ( គឺជាសីលក្ខន្ធេន ) ចុះ ។

ចំណែកក្នុងធម៌ ៣ មានសម្មាវាយាមៈជាដើម សមាធិមិនអាចអែបនែប ដោយ ភាពតែមួយក្នុងអារម្មណ៍ដោយធម្មតារបស់ខ្លួនបាន លុះតែកាលវិរិយៈធ្វើកិច្ច គឺផ្គង ( ចិត្ត ) ទុកឲ្យសម្រេច និងសតិធ្វើកិច្ច គឺមិនក័ន្តប្រឡំទៅឲ្យសម្រេច (សមាធិ ) ជាធម៌បានទទួលឧបការៈ ( ដូច្នោះ ) ហើយ ទើបអាច ( ចុះស៊ប់បាន ) ។

( តទៅ ) នេះ ជាឧបមាក្នុងធម៌ ៣ នោះ ដូចពោលក្នុងសម្លាញ់ ៣ នាក់ ចូលទៅកាន់ឧទ្យាន ដោយបំណងថានឹងលេងនក្ខត្តឫក្ស ឧបមាថា សម្លាញ់ម្នាក់ ឃើញដើមចម្ប៉ាមានផ្ការីកល្អក៏ឈោងដៃឡើងទៅ តែបេះមិនដល់មនុស្សទី ២ ទើប ឱនខ្លួនចុះឲ្យខ្នងដល់សម្លាញ់នោះៗ សូម្បីឈរនៅលើខ្នងសម្លាញ់ទី ២ ហើយ តែខ្លួន នៅទ្រេតទ្រោត ក៏នៅបេះមិនបាន សម្លាញ់ម្នាក់ទៀត ទើបផ្ដៀងស្មាឲ្យសម្លាញ់នោះៗ ជាន់ស្មាសម្លាញ់ម្នាក់ ទើបបេះផ្កាឈើតាមចិត្តមកប្រដាប់កាយលេងនក្ខត្តឫក្សបាន

យ៉ាងណា កាលឧបមេយ្យនេះក៏គប្បីឃើញដូច្នោះ ឯធម៌ ៣ មានសម្មាវាយាមៈជាដើម ជាធម៌កើតរួមគ្នា ប្រៀបដូចសម្លាញ់ ៣ នាក់ចូលទៅកាន់ឧទ្យាន ជាមួយគ្នា អារម្មណ៍ ( របស់សមាធិ ) ដូចដើមចម្ប៉ាមានផ្ការីកល្អ សមាធិដែលមិនអាចចុះស៊ប់ដោយភាពប្រាកដតែមួយក្នុងអារម្មណ៍ ដោយធម្មតារបស់ខ្លួនបាន ដូចសម្លាញ់អ្នកសូម្បីឈោងដៃឡើងទៅហើយ តែបេះមិនដល់ វាយាមៈ ដូចសម្លាញ់ឱនខ្នងឲ្យសតិដូចសម្លាញ់អ្នកឈរផ្អៀងស្មាឲ្យ កាលវីរិយៈញុំាងកិច្ច គឺការផ្គង ( ចិត្ត ) ឲ្យសម្រេច និងកាលសតិញុំាងកិច្ច គឺមិនក័ន្ទប្រឡំទៅឲ្យសម្រេច សមាធិជាធម៌បានទទួលឧបការៈ ( ដូច្នោះ ) ហើយ ទើបអាចចុះស៊ប់ ដោយភាពជាអារម្មណ៍តែមួយបាន ប្រៀបដូចក្នុងសម្លាញ់ទាំង ៣ នាក់នោះ ម្នាក់ឈរលើម្នាក់ ជាន់ស្មារបស់សម្លាញ់ម្នាក់ ទើបអាចបេះផ្កាឈើបានតាមពេញចិត្ត ដូច្នោះ ព្រោះហេតុនោះ ក្នុងធម៌ ៣ នោះ សមាធិតែមួយ លោកសង្គ្រោះចូលដោយសមាធិក្ខន្ធ ដោយមានជាតិស្មើគ្នា ចំណែកវាយាមៈ និងសតិ ជាធម៌ដែលលោកសង្គ្រោះចូលដោយកិរិយា ( គឺជាធម៌ឧបការៈសមាធិ ) ។

សូម្បីក្នុងសម្មាទិដ្ឋិ និងសម្មាសង្កប្បសោត បញ្ញាក៏មិនអាចកាត់ក្តីអារម្មណ៍ថាមិនទៀង ជាទុក្ខ ជាអនត្តា ដោយធម្មតារបស់ខ្លួនបាន លុះតែកាលវិតក្ក ត្រិះរិះឲ្យទើបអាច ។ សេចក្តីនេះយ៉ាងណា ដូចហេរញ្ញិកដាក់រូបិយចុះត្រង់បាតដៃហើយ សូម្បីមានអ្នកណានឹងពិនិត្យមើលក្នុងគ្រប់ចំណែក ( របស់រូបិយ ) ក៏មិនអាចប្រើត្របកភ្នែកត្រឡប់ ( មើល ) បានឡើយ លុះតែប្រើម្រាមដៃ ( ចាប់ ) ត្រឡប់ទៅមក ទើបអាចមើលចំណែកនោះចំណែកនេះបាន យ៉ាងណា បញ្ញាក៏ដូច្នោះដូចគ្នា មិនអាចកាត់ក្តីអារម្មណ៍ថាមិនទៀងជាដើម ដោយធម្មតារបស់ខ្លួនបាន លុះកាលវិតក្កដែលមានការផ្ចាត ( ចិត្ត ) ចុះទៅឆ្ពោះ ( ក្នុងអារម្មណ៍ ) ជាលក្ខណៈ មានការប៉ះខ្ទប់ ( អារម្មណ៍ ) ទៅមកជារស ដូចថា ឆ្កឹះយកមកឲ្យ និងដូចប្រមៀលយកមកឲ្យនោះឯង ទើបអាច

កាត់ក្តីបាន ព្រោះហេតុនោះ ក្នុងអង្គមគ្គ ២ នេះ សម្មាទិដ្ឋិប៉ុណ្ណោះ លោកសង្គ្រោះចូលដោយបញ្ញាខន្ធ ដោយមានជាតិស្មើគ្នា ចំណែកសម្មាសង្កប្បជាធម៌ដែលលោកសង្គ្រោះចូលជាកិរិយា ( គឺជាអង្គឧបការៈ ) ។

មគ្គដល់នូវការសង្គ្រោះចូលដោយ ( ធម្ម ) ខន្ធ ៣ ដោយប្រការ ដូច្នេះ ព្រោះដូច្នោះ ទើបខ្ញុំពោលថា មគ្គជា ៣ ដោយផ្សេងគ្នានៃ ( ធម្ម ) ខន្ធ ៣ មគ្គនោះជា ៤ ដោយអំណាចនៃមគ្គ ៤ មានសោតាបត្តិមគ្គជាដើម ។

ន័យម្យ៉ាងទៀត គ្រប់សច្ចៈចាត់ថាមានតែ ១ ព្រោះជាធម៌មិនក្លាយជាមិនពិត ឬព្រោះជាអភិញ្ញេយ្យធម៌ ជា ២ ដោយភាពជាលោកិយ និងលោកុត្តរ ឬដោយសង្ខតៈ និងអសង្ខតៈ ជា ៣ ដោយធម៌ដែលត្រូវលះដោយទស្សនៈ និងភាវនា និងដោយធម៌ដែលមិនត្រូវលះ ជា ៤ ដោយផ្សេងគ្នានៃកិច្ច មានជាធម៌ដែលគប្បីកំណត់ដឹងជាដើម ។

វិនិច្ឆ័យដោយប្រភេទផ្សេងៗ មានតែម្យ៉ាងជាដើម ក្នុងអរិយសច្ចនេះគប្បីជ្រាបដូចពោលមកនេះ ។

## ដោយមានចំណែកស្មើគ្នា និង មិនស្មើគ្នា

ពាក្យថា ដោយ ( សភាគៈ និងវិសភាគៈ ) មានចំណែកស្មើគ្នា មិនស្មើគ្នា សេចក្តីថា គ្រប់សច្ចៈមានចំណែកស្មើគ្នានឹងគ្នា ដោយភាពជាធម៌មិនក្លាយជាមិនពិត ១ ដោយភាពជាធម៌សូន្យចាកអត្តា ១ ដោយមានការត្រាស់ដឹងដែលធ្វើបានលំបាក ១ ដូចព្រះមានព្រះភាគត្រាស់ ( សួរព្រះអានន្ទ ) ថា ម្នាលអានន្ទ អ្នកនឹងសម្គាល់សេចក្តីនោះដូចម្តេចការដែលបុគ្គលនឹងគប្បីបាញ់កូនសរជ្រែក ចូលប្រហោងរន្ធកូនទ្វារតូចៗ អំពីទីឆ្ងាយមិនឲ្យភ្លាត់ ឬការដែលបុគ្គលនឹងគប្បីប្រើចុងរោមសត្វពុះជា ៧ បាញ់ទៅឲ្យត្រូវចុងរោមសត្វ ( ត្រង់ក្តារប៉ាយ ) មួយណាធ្វើបានលំបាកជាង សម្រេចបាន

លំបាកជាង ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលបុគ្គលនឹង គប្បីប្រើចុងរោមសត្វពុះជា ៧ បាញ់ទៅឲ្យត្រូវចុងរោមសត្វ (ត្រង់ក្តារប៉ោយ) នោះឯង ធ្វើបានលំបាកជាង សម្រេចបានលំបាកជាង ត្រាស់ថា ម្នាលអានន្ទ បុគ្គលដែល ចាក់ធ្លុះតាមសេចក្តីពិតថា នេះទុក្ខ ។បេ។ នេះទុក្ខនិរោធគាមិនីបដិបទា គង់ចាក់ឲ្យធ្លុះ បានលំបាកក្រៃលែងជាងបាញ់រោមសត្វដោយរោមសត្វនោះទៅទៀត ដូច្នេះ តែគ្រប់ សច្ចៈនោះមានចំណែក មិនស្មើគ្នាដោយកំណត់ផ្សេងគ្នា ទៅតាមលក្ខណៈរបស់ខ្លួន រៀងៗ ខ្លួន ។ម្យ៉ាងទៀត សច្ចៈ ២ ខាងដើមចាត់ថាមានចំណែកស្មើគ្នា ព្រោះជាសភាវៈ ជ្រាលជ្រៅ ព្រោះអត្ថថា លំបាកនឹងស្ទាបស្ទង់ ព្រោះជាលោកិយធម៌ និងជាសាសវ ធម៌ដូចគ្នា (តែ) មានចំណែកមិនស្មើគ្នា ដោយញែកគ្នា ជាផល (មួយផ្នែក) ជាហេតុ (មួយផ្នែក) និងដោយ (មួយផ្នែក) ជាបរិញ្ញេយ្យធម៌ (មួយផ្នែក) ជាបហាតព្វធម៌ ។ សច្ចៈ ២ ខាងចុងរាប់ថាមានចំណែកស្មើគ្នា ព្រោះជាធម៌ស្ទង់បានលំបាក ព្រោះជាធម៌ ជ្រៅ ព្រោះជាលោកុត្តរធម៌ និងជាអនាសវធម៌ ដូចគ្នា (តែ) មានចំណែកមិនស្មើគ្នា ដោយញែកគ្នាជាវិស័យ (គឺដែនរលត់ទុក្ខមួយផ្នែក) និងជាវិសយី (គឺផ្លូវទៅកាន់ ដែននោះមួយផ្នែក) និងដោយ (មួយផ្នែក) ជាសច្ឆិកាតព្វធម៌ (មួយផ្នែក) ជា ភាវេតព្វធម៌ ។ ម្យ៉ាងទៀត សច្ចៈទី ១ និងទី ៣ មានចំណែកស្មើគ្នា ដោយជាប្រការ ដែលត្រូវបង្ហាញថាជាផលដូចគ្នា (តែ) មានចំណែកមិនស្មើដោយ (មួយផ្នែក) ជាសង្ខតធម៌ និង (មួយផ្នែក) ជាអសង្ខតធម៌ ។ឯសច្ចៈទី ២ និងទី ៤ មានចំណែក ស្មើគ្នា ព្រោះត្រូវបង្ហាញថា ជាហេតុដូចគ្នា (តែ) មានចំណែកមិនស្មើគ្នា ព្រោះ (ម្ខាង) ជាកុសលដោយចំណែកមួយ និង (ម្ខាងទៀត) ជាអកុសលដោយចំណែក មួយ ។សច្ចៈទី ១ និងទី ៤ មានចំណែកស្មើគ្នាដោយសង្ខតធម៌ ដូចគ្នា (តែ) មាន ចំណែកមិនស្មើគ្នា ដោយ (ម្ខាង) ជាលោកិយ និង (ម្ខាង) ជាលោកុត្តរធម៌ សូម្បី

សច្ចៈទី ២ និងទី ៣ ក៏មានចំណែកស្មើគ្នា ដោយនៅសេក្ខានាសេក្ខធម៌ ( ធម៌របស់ព្រះសេក្ខៈ ក៏មិនមែនរបស់ព្រះអសេក្ខៈ ក៏មិនមែន ) ដូចគ្នា ( តែ ) មានចំណែកមិនស្មើគ្នាដោយ ( ម្ខាង ) ជាសារម្មណធម៌ ( ធម៌មានអារម្មណ៍ ) និងម្ខាងជាអនារម្មណធម៌ ( ធម៌មិនមានអារម្មណ៍ ) ។

អ្នកមានសតិបញ្ញា គប្បីជ្រាបសេចក្ដីដែលអរិយសច្ច មានចំណែកស្មើគ្នា និងមិនស្មើគ្នាដោយប្រការ និងដោយន័យ ដូចពោលមកដូច្នេះឯង ។

បរិច្ឆេទទី ១៦ ឈ្មោះឥន្ទ្រិយសច្ចនិទ្ទេស

ក្នុងអធិការនៃបញ្ញាភាវនា

ក្នុងបករណ៍ឈ្មោះវិសុទ្ធិមគ្គ

ដែលខ្ញុំធ្វើដើម្បីប្រយោជន៍ដល់បាមោជ្ជនៃសាធុជន ដូច្នេះ ។

# មហាដីកា

## កថាពណ៌នាដោយការវិនិច្ឆ័យដោយប្រភេទផ្សេងៗ មានតែមយ៉ាងជាដើម

ពាក្យថា **ដោយភាពជាបវត្តិ** បានដល់ ដោយការប្រព្រឹត្តទៅនៃសង្សារ ។ ពាក្យថា **ដោយចែកជាអាហារ ៤** គឺដោយអាហារបច្ច័យ ៤ ។ ដោយពាក្យនេះ លោកអាចារ្យរួមដល់ភាពផ្សេងគ្នានៃអាហារ មានកពឡិង្ការាហារ ៤ ជាដើម និងភាព ផ្សេងគ្នានៃធម៌ដែលជាបច្ច័យដល់អាហារទាំង៤នោះពោលគឺវត្ថុដែលគប្បីទំពាលេប ១ សឡាយតនៈ ១ អវិជ្ជា ១ អភិសង្ខារ ១ និងសង្គ្រោះភាពផ្សេងគ្នា នៃធម៌ដែល កើតអំពីអាហារទាំង ៤ នោះ ពោល គឺឱជដ្ឋមករូប ១ វេទនា ១ បដិសន្ធិវិញ្ញាណ ១ នាមរូប ១ ។

**ដោយភាព** ដែលញុំាងទុក្ខក្នុងបវត្តិកាល **ឲ្យប្រព្រឹត្តទៅ** ។ លោកអាចារ្យ ទាំងឡាយពោលថា **សភាពផ្សេងគ្នានៃការត្រេកអរក្នុងរូបជាដើម** បានដល់ ភាពផ្សេង នៃការត្រេកអរក្នុងរូបជាដើម សូម្បីទាក់ទងនឹងរូបារម្មណ៍ជាដើម ។ **គំនរតណ្ហា** ឈ្មោះ ថា **មាន ៦** ព្រោះតណ្ហាទាំងឡាយ មានរូបតណ្ហាជាដើមចំពោះតែមយ៉ាងៗ ក៏មានភាព ផ្សេងគ្នាមិនមែនតិច **ដោយការចែក** គំនរតណ្ហាទាំង ៦ នោះ ។

ឧបាទានក្ខន្ធ ៥ ឈ្មោះថា **ឧបាទិ** ព្រោះអត្ថថា ដែលឧបាទានចូលទៅប្រកាន់ ។ ព្រះនិព្វាន ឈ្មោះថា ជាដែនរលាស់ចេញនូវឧបាទិនោះ ព្រោះអធិប្បាយថា ចូលទៅ រម្ងាប់ឧបាទិនោះ ស្ងប់ឧបាទិនោះ បញ្ញត្តជា ២ ថា **សឧបាទិសេសនិព្វានធាតុ** ព្រោះ អាស្រ័យឧបាទានក្ខន្ធ ៥ នោះនៅសល់ រហូតដល់ចិត្តដួងចុងក្រោយ និង **និរុបាទិ-សេសនិព្វានធាតុ** ព្រោះអាស្រ័យភាពដែលឧបាទានក្ខន្ធ ៥ នោះ មិនមានសល់

ខាងមុខអំពីនោះ ។ លោកអាចារ្យពោលថា ជា ៣ យ៉ាង ជាដើម ដើម្បីសម្តែង បកិណ្ណកៈទាំងនោះថា ពោលដោយបញ្ញត្តិយ៉ាងណា សូម្បីប្រភេទក្រៅអំពីនេះក៏ដូច្នោះ ដូចគ្នា ។ កាលកាន់យកដោយអត្ថ ដោយប្រការដទៃ និព្វានដែលជាធម៌មានតែម្យ៉ាង នឹងមានការបែកបានអំពីណាហ្ន៎ ។

ក្នុងពាក្យថា **ដោយចែកជាសមថៈ និងវិបស្សនា** នេះ អាចារ្យទាំងឡាយ ពោលថា សម្មាទិដ្ឋិ និងសម្មាសង្កប្បជាវិបស្សនា អង្គមគ្គក្រៅអំពីនេះជាសមថៈ។ សេចក្តីអធិប្បាយរបស់លោកអាចារ្យទាំងនោះ សូម្បីសីលលោកក៏កាន់យកដោយ ស័ព្ទថា **សមថៈ** ព្រោះជាគុណជាតិមានឧបការៈដល់សមថៈ ។ ន័យម្យ៉ាងទៀត មគ្គ ដែលបានដោយយានទាំង ២ គប្បីឃើញថា លោកពោលទុកដោយអំណាចដែលបាន មកថា **សមថវិបស្សនា** ។បទថា **អយំ យោគ អរិយមគ្គោ** ប្រែថា អរិយមគ្គនេះ ។ បទ ថា **សប្បទេសត្តា** សេចក្តីថា ព្រោះធម៌ទាំងឡាយ មានសីលក្ខន្ធជាដើមជាឯកទេស ( គឺចំណែកមួយ ) ។ ពិតហើយ ឯកទេស ឈ្មោះថា **បទេស** ព្រោះថា លោកសម្តែង គឺសម្តែងអាងជាចំណែកៗ ហៅថា **សប្បទេស** ព្រោះប្រព្រឹត្តទៅជាមួយនឹងការសម្តែង អាង ត្រោះទៅក្នុងការរួមរបស់ខ្លួន ដូចពាក្យថា **សនិទស្សនា ធម្មា** ប្រែថា សភាវធម៌ ដែលមានការឃើញបាន និងធម៌ទាំងឡាយ មានសីលក្ខន្ធជាដើម ក៏រួមក្នុងសីល ដែល ជាលោកិយ និងលោកុត្តរទាំងអស់ជាដើម អរិយមគ្គជាលោកុត្តរតែម្យ៉ាង ព្រោះដូច្នោះ ទើបជាឯកទេសរបស់ខន្ធទាំង ៣ នោះ ។

បទថា **សជាតិតោ** ប្រែថា ដោយភាពមានជាតិស្មើគ្នា អធិប្បាយថា ដោយ ជាតិនៃសីលដែលស្មើគ្នាក្នុងប្រភេទនៃសីល មានការវៀរចាកវចីទុច្ចរិតជាដើម ។

**វាយាមៈ** ឈ្មោះថា **ប្រៀបដូចសម្លាញ់ដែលឱនខ្នង** ព្រោះមានកិច្ច គឺការផ្គង ស្មើគ្នា ។ **សតិ** ឈ្មោះថា **ប្រៀបដូចសម្លាញ់ដែលឈរបែរស្មាឲ្យ** ព្រោះមានការធ្វើ

ភាវៈ ដែលមិនញាប់ញ័រដោយអំណាចការមិនក័ន្តប្រឡំស្មើគ្នា ។ ពាក្យថា **ដោយភាពមានជាតិស្មើគ្នា** សេចក្តីថា ដោយភាពមានជាតិនៃសមាធិ ព្រោះតាំងចិត្តមាំក្នុងសមាធិដែលផ្សេងដោយសមាធិ មានវិតក្ក និងវិចារៈជាដើម ។ ពាក្យថា **ដោយកិរិយា** គឺដោយកិរិយាដែលសមគួរដល់សមាធិ ។ ព្រោះហេតុនោះឯង ទើបធម្មទិន្នាភិក្ខុនីបានពោលសតិ និងវាយាមៈជានិមិត្ត និងជាគ្រឿងឧបការៈរបស់សមាធិទុកថា សតិប្បដ្ឋាន ៤ ជានិមិត្តរបស់សមាធិ សម្មប្បធាន ៤ ជាគ្រឿងឧបការៈរបស់សមាធិ ។

បទថា **អាកោដ្តេន្តេន វិយ** សេចក្តីថា បញ្ញារមែងចាក់ធ្លុះអារម្មណ៍ដែលវិតក្កបានមក ដូចគ្នានឹងហេរញ្ញិកគោះដោយជុំវិញ ដោយកិច្ច ដូចគ្នានឹងកិច្ចរបស់បញ្ញាជាដើមថា មិនទៀង មិនទៀង និងដូច **ប្រមៀលទៅមកដោយកិច្ចជាដើម** ឈ្មោះថា ជាអនិច្ចំ ព្រោះអត្ថថា អស់ទៅ ឈ្មោះថា ជាទុក្ខ ព្រោះអត្ថថា ជាភ័យ ( ហាក់ដូចជា ) កាន់យកមកប្រគល់ឲ្យនោះឯង សូម្បីស័ព្ទទាំង ២ មាន កាលដែលស្មើគ្នា លោកធ្វើនិទ្ទេសរបស់សម្មាសង្កប្បទុក ដូចជាបុរិមកាល ដោយភាវៈដែលជាបច្ច័យ ។ ពាក្យថា **ដោយមានជាតិស្មើគ្នា** គឺដោយជាតិនៃបញ្ញាដែលស្មើគ្នា ដូចក្នុងព្រះបាលីថា **ទុក្ខេ ញាណំ** ជាដើម ។ កិច្ចដែលដូចគ្នានឹងបញ្ញា លោកពោលថា **ជាកិរិយា** ក្នុងពាក្យថា **ដោយជាកិរិយា** នេះ តែក្នុងខាងដើម កិច្ចដែលជាឧបការៈដល់សមាធិ ជាកិច្ចដែលសមគួរដល់សមាធិនោះ ដែលពោលមកនេះ ជាសេចក្តីផ្សេងគ្នាក្នុងអធិការនេះ ។

សច្ចៈទាំង ៤ ឈ្មោះថា **ជាអភិញ្ញេយ្យធម៌** ព្រោះអត្ថថា ជាធម៌ដែលគប្បីដឹងចំពោះមុខ គឺដោយប្រចក្ស ឬព្រោះអត្ថថា ជាធម៌ដែលគប្បីដឹងដោយញាណដ៏វិសេសក្រៃលែង ដោយព្រះបាលីថា **ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងជាអភិញ្ញេយ្យធម៌** ។

បទថា **អញ្ញមញ្ញសភាគានិ** ប្រែថា មានចំណែកស្មើគ្នានឹងគ្នា អធិប្បាយថា មានរូបដូចគ្នា ។

ពាក្យថា **សម្រេចបានលំបាកជាង** គឺបុគ្គលណាមួយ មិនអាចដើម្បីឲ្យសម្រេច គឺឲ្យសម្រេចផលក្រៃលែងជាង អធិប្បាយថា លំបាកសម្រេចបាន ព្រោះកាត់ភាពអាចចេញ ។ បទថា **អសនំ** ប្រែថា ព្រួញ ។ បទថា **អតិបាតេយ្យ** ប្រែថា គប្បីបាញ់ ។ បទថា **កោដិយា** ប្រែថា ចុងព្រួញ និងចុងរោមទ្រាយ ។ បទថា **កោដី** ប្រែថា ចុងរោមទ្រាយតែម្យ៉ាង ។ បទថា **បដិវិជ្ឈេយ្យ** ប្រែថា បាញ់ឲ្យត្រង់ក្តារប៉ុយ ។

ការកំណត់តាមលក្ខណៈ គឺបៀតបៀន ជាដែនកើតមុន ស្ងប់ និងនាំចេញទៅអំពីទុក្ខ ឈ្មោះថា **កំណត់ទៅតាមលក្ខណៈរបស់ខ្លួន** ។ ពាក្យថា **ព្រោះជាសភាវៈជ្រាលជ្រៅ ដោយអត្ថថា លំបាកស្ទង់ដឹងបាន** សេចក្តីថា ទុក្ខ និងសមុទយៈ ជាវត្ថុដែលគ្រោតគ្រាត ។ ព្រោះថា សេចក្តីទុក្ខ និងភាពគ្រោតគ្រាតក្នុងអាហារជាដើម ក៏នៅប្រាកដ សូម្បីដល់ពួកសត្វតិរច្ឆាន ។ តែឈ្មោះថា ជ្រាលជ្រៅ ព្រោះមិនអាចស្ទង់ដឹងបានតាមសេចក្តីពិតថា **នេះជាទុក្ខ នេះជាហេតុរបស់ទុក្ខនោះ** ដោយអំណាចមានការគ្របសង្កត់ជាដើម និងអាការមានការប្រមូលមកជាដើម និរោធនិងមគ្គ ឈ្មោះថា **លំបាកស្ទង់ដឹងបាន ដោយអត្ថថា ជ្រាលជ្រៅ** ដោយសភាវៈនោះឯង ព្រោះជាធម៌ដែលល្អិតសុខុម ។ ដោយហេតុនោះឯង កាលមគ្គកើតឡើងហើយ ការឈានចុះកាន់មគ្គ និងនិរោធ មិនមាន ដូច្នេះ ។ សូម្បីនិព្វាន ក៏រមែងត្រូវចង្អុលបង្ហាញថា ជាផលរបស់មគ្គនោះ ព្រោះជាធម្មជាតិ ដែលនឹងគប្បីសម្រេចបាន ដោយមគ្គ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ដោយជាប្រការដែលត្រូវចង្អុល បង្ហាញថា ជាផលចូលជាមួយគ្នា** ។ សេចក្តីនេះសមដូចព្រះតម្រាស់ ដែលព្រះមហាមុនីត្រាស់ទុកថា ញាណក្នុងទុក្ខនិរោធ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។ សូម្បីមគ្គក៏រមែងត្រូវចង្អុលបង្ហាញថា **ជាហេតុ** ព្រោះជាធម្មជាតិ ញុំាងនិរោធឲ្យដល់ព្រម ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដោយជាប្រការត្រូវចង្អុលបង្ហាញថា ជាហេតុជាមួយគ្នា** ។ សេចក្តី

នេះសមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា **ញាណក្នុងបដិបទាដែលឲ្យដល់ទុក្ខនិរោធ ឈ្មោះថា ធម្មប្បដិសម្ភិទា** ។

ពាក្យថា **ឥតិ ឯវំ បការេហិ** ភ្ជាប់បាលីថា **ឥតិ វិជញ្ញា** ប្រែថា គប្បីជ្រាបដោយប្រការដូចពោលមក ដូច្នេះ ។ ក្នុងពាក្យនោះ លោកអាចារ្យសម្ដែងលំដាប់នៃការជ្រាបដោយ **ឥតិ**-ស័ព្ទ ។ ពីរបទថា **ឯវំ បការេហិ** សេចក្ដីថា ដោយ **ឯវំ**-ស័ព្ទ ដែលជាហេតុនៃការជ្រាបនោះឯង ។

ពណ៌នាការវិនិច្ឆ័យដោយសភាគ និងវិសភាគ ចប់

ពណ៌នាឥន្ទ្រិយសច្ចនិទ្ទេស ចប់

ពណ៌នាបរិច្ឆេទទី ១៦

ចប់ហើយ

ដោយប្រការ ដូច្នេះ ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយន្ត៍សុផាត

# ឈ្មោះសប្បុរសប្រគេនសម្ភារៈ មានកុំព្យូទ័រជាដើម ក្នុងកិច្ចការងារជាធម្មទាន

❋ឧបាសិកា ហម យិម

ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក បួ ស៊ីផូ ឧបាសិកា ថៃ ស៊ីវន ព្រមទាំងបុត្រ

ឧបាសិកា បួ ចន្ថា និងស្វាមី ព្រមទាំងបុត្រ

កញ្ញា បួ ដារី កញ្ញា អ៊ឹង មុយហៀក

❋លោកម្ចាស់ សោម ហួន

លោកគ្រូធម្មាចារ្យ អឿ សៅ ( ទក្ខប្បញ្ញោ )

ឧបាសក ប៊ូ ហោនាង ឧបាសិកា អ៊ឹង វិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យឹម សំណាង ឧបាសិកា យឹម ច័ន្ទបូ(LAURA) +បុត្រធីតា

ឧបាសិកា លីប៉ុលីន ស៊ីមប៉ូ កូនក្មួយ ប៊ុន ឡុង,សេង ឈិនដានេត

លោកអាចារ្យ ផាត សារឿយ ឧបាសិកា វ៉ាត់ អម +បុត្រធីតា

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស មូនីកា +បុត្រធីតា

ឧបាសក សួស ចាន់ធី ឧបាសិកា ឡុង សេង +បុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ឆាន់ កាន់ជួន +បុត្រធីតា

ឧបាសក ម៉ៅ ផុន+សាបូរ៉ាក់ សុខ( SABOREAK SOK )

ឧបាសក យក់ ស៊ីមូរ៉ា ឧបាសិកា តាន់ វ៉ាណា

ឧបាសក អ៊ឹង រិទ្ធី ឧបាសិកា ជូធារី

ឧបាសក មាស សារ៉េត

ឧបាសក លឹម ស៊ាង

ឧបាសក ឈុន គឹមអេង

❋ឧបាសក ឈុំ គីម គឹមហោ ឧបាសិកា គួ ប៊ុនគាង

ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ

ឧបាសក សារុន សេងហួរ ឧបាសិកា ឈុំ សុរីណែត

ឧបាសក ឈុំ សុរិណា (ហៅប៊ុន ឃីម) ឧបាសិកា ណៃ គឹមហុង

ឧបាសក ឈុំ សុបូរី ឧបាសិកា កើត កុលាប

❋ឧបាសិកា ច័ន្ទ បុប្ផាណា

ឧបាសក ស្ងួន សុធីរ

ឧបាសិកា ស្ងួន កល្យាណ

ឧបាសិកា ស្ងួន ចរណៃ

ឧបាសិកា ស្ងួន កញ្ញារ័ត្ន

❋ឧបាសិកា ម៉ក់ នាង ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមថៃ និងភរិយា ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមលន់ និងភរិយា ព្រមទាំងកូនចៅ

ឧបាសិកា តាំង លាងនិម និងស្វាមី ព្រមទាំងកូនចៅ

❋ពុទ្ធសាសនបណ្ឌិត្យ អ្នកគ្រូ ម៉ម សុខហេង+ពុទ្ធបរិស័ទ+សៀមរាប

ឧបាសក រស់ សុខ ឧបាសិកា សោម ផាន

ឧបាសិកា នួង ឈុំ សោភ័ណ រស្មី

ឧបាសក ជោគ ឌី ឧបាសិកា ដុះ ចំណាន

ឧបាសិកា វិញ ពូន

❋ឧបាសក ឡាំ ធៀន ឧបាសិកា សឺន ចន្ថា

ឧបាសក លឹម សេងយូ ឧបាសិកា ឡាំ ចាន់សុគី

ឧបាសក ឡាំ ចាន់ណា ឧបាសិកា ទុច ចាន់សាក់គ្រីយ៉ា

ឧបាសក ឡាំ ដាវណ្ណ ឧបាសិកា ឡាំ ចាន់ភារី

❋ឧបាសក ជុំ លាង ឧបាសិកា ចៀម អ៊ុន ព្រមទាំងបុត្រ

ញោម ឥន្ទុទ្ធីនិងជូ ញោម ហាន ញោម រ៉ែន ញោម ភ័ណ្ឌ ញោម សុមនា ញោម ជោត ញោម មាស សុភា ញោម ឡៃ លី កញ្ញា នា ញោម ធាង ញោម ធីង ឡេង ញោម អៀម ញោម ភួង ញោម អុំភា ញោម សុភា ញោម វល័ក្ខ ញោម ធាលី លីណា ញោម ថាក ញោម ផារិន ញោម ឈឿន ញោម ឡាង ញោម ស៊ិន ញោម គាព សាវឿន ញោម ហ៊ន ញោម ប៊ូ សៀកលីវ ញោម យក់ វ៉ាន់ថា ។

❋ឧបាសិកា អ៊ុន ខាត់ណា ឧបាសិកា អ៊ុន ញ៉ាណ ឧបាសក អ៊ុន សេរី

លោក ដែង រស្មី និងអ្នកស្រី ជុង កុយយ៉ា ព្រមទាំងបុត្រ

❋ឧបាសក អ៊ឹង ហ្គេចឡេង ឧបាសិកា តាំង ប៉ោជីង ព្រមទាំងបុត្រ

លោក ឆៃ ហេង អ្នកស្រី អ៊ឹង ស៊ីវគៀង ព្រមទាំងបុត្រ

លោក ភូ ពុយ អ្នកស្រី អ៊ឹង ណាងពិន ព្រមទាំងបុត្រ

លោក អ៊ឹង វណ្ណម៉ៅ អ្នកស្រី ហេង ហ៊ុយទៀង ព្រមទាំងបុត្រ

លោក ប៊ី ទី អ្នកស្រី តាំង ប៉ោគិម ព្រមទាំងបុត្រ

ឧបាសិកា ជា នាង និងស្វាមី ព្រមទាំងបុត្រ

❋ឧបាសិកា ង៉ែត យូអេង ព្រមទាំងបុត្រ

ឧបាសិកា គង់ ង៉ោ និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ច័ន្ទនី និងស្វាមី ព្រមទាំងបុត្រ

✵ឧបាសិកា សាម៉ុល គឹមធន និងអ្នកម្ដាយ

ឧបាសិកា គី វណ្ណហាក់ ព្រមទាំងបុត្រ

លោក សេង យុវនាថ ឧបាសិកា គុជ ឡាំងអេង

ឧបាសិកា ឈន សុភនី ឧបាសក ជីវ និងភរិយា

ឧបាសក សុខ សំ និងភរិយា ព្រមទាំងបុត្រ

ឧបាសក នុត កុសល និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា អៀន ភី + អ៊ុំ សុភាព + ឈិត ស្រស់ + សឹម ឡាយ

ញោម ហ៊ុ ជាង + ជាមុយហាង + គុយ លឹម + សេង មុយនី

ញោម ចៅ ជីវ ស៊ុយលៀប+ប៉ៃ អេង+គឹម ធី+ខៀវ វ៉ន+ គឹម

ញោម នឿង+យាយ ធីង+គួង កាង+សើន គា+សឿង+គឹម អាង

ញោម សេង ឆេង+ផាន់ វ៉ាន់+យាយ រុ+ឡាំម៉ាលី+ជាន សុផាត

យាយ ម៉ៅ + ពៅ + ឈួន+ ក. កាវ៉ាឡែន+ ហ៊ុង+ ប៉ៃ ង៉ា+ រី វុទ្ធ

ញោមអ្នកគ្រូ វ៉ាន់ + យុវសិស្ស អ៊ុំ រតនា + សាមណោរ អ៊ុំ វីរៈ

ញោមប៉ៃ ង៉ាថុគោល+អ្នកស្រី លេង យ៉ុង+តី លី+នាង ឈឿត

ញោម ហ៊ុង+នាង មឿន+អូន ប៉ុច+ ឡាត វ៉ាន់យិន+ ម៉ម សុខហេង

ញោម គឹម ឡេង+ តាំង វេន+ យុន+ យាយ ធុច + យាយ យន

ញោម ហ៊ន ស៊ឹម ញោម អៀន ភី+វ៉ាន់ ស៊ុនឡាយ+ផល្លី+សវ៉ាមី

ញោម ឡុង សាវី+ជា សុខហ៊ាង+គុយ លឹម+សេង ទូច+ស៊ីវ ទី

ញោម ណោ ហ្គេចណៃ+វ៉ាន់ សុផានី+សា វឿន+សំ គី+ចាន់ ណាវ៉ា

ញោម ធារ៉ា+ឃឿត និងស្វាមី+ហួត អេង+អាវ សុវណ្ណី+ណា ស៊ី
ញោម យាយ នៅ+ឈុន គាវ+ យាយ ឌី+ សំ វ៉ាន់នី+ គីម អ៊ី
ញោម អៀប សាទួន+ យាយ ហឿន+យាយ ឡាំ+កេន សេងមុំ
ស ខាន់ថង+ស៊ី ណាត+ឃឿន+ចាន់ នី+ផន សារ៉ែន+កោ ហុង ។

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

លោកម្ចាស់ សោម ហួន

លោកគ្រូធម្មបណ្ឌិត ( ទក្ខប្បញ្ញោ ) អឿ សៅ

| | |
|---|---|
| ឧបាសិកា ធឹក ស្រ៊ីន | ព្រមទាំងកូនប្រុស អ៊ឹង រិទ្ធី និងភរិយា |
| ឧបាសក ប៊ូហោ នាង | ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា |
| ឧបាសក យេម សំណាង | ឧបាសិកា យេម ឡារ៉ា ព្រមទាំងបុត្រ |
| ឧបាសក សៅ ហ៊ិន | ឧបាសិកា មាស ម៉ូនីកា ព្រមទាំងបុត្រ |
| ឧបាសក ឈៀងសារឿន | ឧបាសិកា ឈុំ ធដា ព្រមទាំងបុត្រធីតា |
| ឧបាសក ម៉ៅ វង្ស | ឧបាសិកា ឆាន់ កាន់ជួង ព្រមទាំងបុត្រ |
| ឧបាសក និន ហាក់ | ឧបាសិកា លុយ ចាន់ថន ព្រមទាំងបុត្រ |
| ឧបាសិកា មុី ចាន់រ៉ាវី | ព្រមទាំងបុត្រធីតា |
| ឧបាសិកា យ៉ក់ ស៊ីមូរ៉ា | ព្រមទាំងបុត្រ |
| ឧបាសិកា វ៉ាន់ចាន់ | ព្រមទាំងបុត្រធីតា |
| ឧបាសិកា ខៀវ ណាត | ព្រមទាំងបុត្រធីតា |

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ធាយ អ៊ីវស៊ាង ឧបាសិកា ហុង គីមសែ កូន+ចៅ
ឧបាសិកា យូ ស៊ាងនន្ទលី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅអូស្ត្រាលីមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

| | |
|---|---|
| ឧបាសក ប៊ុន ហេង | ឧបាសិកា ជុំ សុខុម |
| ឧបាសិកា ហេង ស្រីជា | ឧបាសិកា ហេង ស្រីចន្ទ |
| ឧបាសិកា ហេង គន្ធា | ឧបាសក ហេង សុភក្រ្ត |

## នាមពុទ្ធបរិស័ទនៅខេត្តបាត់ដំបងមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឈុំ គីមហោ ឧបាសិកា គួ ប៊ុនគាង ព្រមទាំងកូនចៅ
ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ ព្រមទាំងកូន
ឧបាសក អ៊ឹង ហ្គិចឡេង ឧបាសិកា តាំង ប៉េងជីង ព្រមទាំងកូនចៅ
ឧបាសក វៀម ឈើន ឧបាសិកា ប៊ូ ម៉ុន ព្រមទាំងកូនចៅ
ឧបាសក ញ៉ែម មឿន ឧបាសិកា វៀម ថុល ព្រមទាំងកូនចៅ
ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ
ឧបាសក នាង រ៉ា ឧបាសិកា តែម ធារីម ព្រមទាំងកូនចៅ
ឧបាសក សៅ ស៊ុទ្ធរា ឧបាសិកា ប៊ុន មុំ ព្រមទាំងកូនចៅ

ឧបាសក ណូ ស្វែង ឧបាសិកា សោម គឹមលួន ព្រមទាំងកូនចៅ

ឧបាសិកា ងិន យ៉ុន ឧបាសិកា សួស សុខា ព្រមទាំងកូនចៅ

ឧបាសិកា សោម គឹមលៀម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា គឹម ធរី និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ទាវ គឹមយក់ ឧបាសិកា អ៊ឹម គឹមជីវ

ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ឡាំ ម៉ាលី

ឧបាសិកា ហួត អេង ឧបាសិកា ឡៅ សាយហ៊ួច

ឧបាសិកា ង៉ែត យូអេង ព្រមទាំងកូនក្មួយ

ឧបាសិកា ហោ ភាព ព្រមទាំងកូនក្មួយ

ឧបាសិកា អ៊ុក នៅ ព្រមទាំងបុត្រ

ឧបាសិកា សៀង ព្រមទាំងបុត្រ

## នាមពុទ្ធបរិស័ទនៅស្ទឹងមានជ័យភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសិកា ឆេង ស៊ីម ព្រមទាំងបុត្រ ធីតា និងចៅ

លោក លី ហុង អ្នកស្រី ជាណារី ព្រមទាំងបុត្រ ធីតា

លោក ផូ ចាន់ថន អ្នកស្រី ជា ណារី ព្រមទាំងបុត្រ ធីតា

លោក លីម ចាន់ឌី អ្នកស្រី ទេព ចិន្តា ព្រមទាំងបុត្រ ធីតា

កញ្ញា ហុង លីដា

លោក ហុង សុវណ្ណតារា អ្នកស្រី លីម ចាន់មុនីរ័ត្ន ព្រមទាំងបុត្រ

ឧបាសក ហុង សុវណ្ណារិទ្ធ

ឧបាសក ហុង សុវណ្ណារ៉េត

លោក ហុង ប៊ុនឡុង

ឧបាសក ហ៊ុន ហេងគង់ ឧបាសិកា ទូច សារុន ព្រមទាំងកូនចៅ

ឧបាសិកា ធុយ ឈីវអូន ព្រមទាំងកូនចៅ

ឧបាសក យ៉ែម យ៉ន ឧបាសិកា យ៉ង់ ទូច ព្រមទាំងកូនចៅ

ឧបាសក មិន ម៉ាង ឧបាសិកា ឈិន គីមហ៊ាន ព្រមទាំងកូនចៅ

ឧបាសិកា ជា សុផល ព្រមទាំងកូនចៅ

ឧបាសិកា មៀច យ៉ន ព្រមទាំងកូនចៅ

ឧបាសិកា មុំ សុន ព្រមទាំងកូនចៅ

លោក លន់ វ៉ាន់ថា អ្នកស្រី មុំ ដាន់ ព្រមទាំងបុត្រ ធីតា

លោក ចាប សោភ័ត អ្នកស្រី មុំ ដា ព្រមទាំងបុត្រ ធីតា

ឧបាសិកា ប៉ោ យេកលៀង ព្រមទាំងបុត្រ ធីតា និងចៅ

លោក រស់ ប៊ុនឡេង អ្នកស្រី ឡេង ស៊ីនី ព្រមទាំងបុត្រ ធីតា

ឧបាសិកា ឈួន សុ ព្រមទាំងកូនចៅ

ឧបាសិកា ថ្វាង តាំងគៀន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ែន នាង ព្រមទាំងកូនចៅ

ឧបាសិកា អៀង នីម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ិន ដារ៉ុង ព្រមទាំងកូនចៅ

ឧបាសិកា គីម សេង ព្រមទាំងកូនចៅ

ឧបាសិកា ហួយ ជន ព្រមទាំងកូនចៅ

ឧបាសិកា រ័ត្ន សុផល ព្រមទាំងកូនចៅ

អ្នកស្រី ជុន បូណ៌មី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ជា ព្រមទាំងកូនចៅ

ឧបាសិកា គីម អាន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ស៊ីយន ព្រមទាំងកូនចៅ

លោក កេត ចាន់តារា

លោក កេត សំបូរ និងកុមារី សុជាតា

ឧបាសិកា ជា រ៉ូបទៀង ព្រមទាំងកូនចៅ

ឧបាសក ជី សុខអៀម ឧបាសិកា តាំង ស៊ូអេង ព្រមទាំងកូនចៅ

ឧបាសិកា តាំង ស៊ូហៀង ព្រមទាំងកូនចៅ

ឧបាសិកា ជី ញ៉ៀ ព្រមទាំងកូនចៅ

ឧបាសិកា ខៀវ សុធី ហៅ អ៊ឹម៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ទូច ព្រមទាំងកូនចៅ

ឧបាសក ឡាយ ឧបាសិកា លន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ហ៊ុន ព្រមទាំងកូនចៅ

ឧបាសិកា មិល មម ព្រមទាំងកូនចៅ

ឧបាសក រស់ ស្រេង ឧបាសិកា ឡា ហ៊ុយឡេង ព្រមទាំងកូនចៅ

ឧបាសិកា ឡា ស៊ីវឡេង ព្រមទាំងកូនចៅ

ឧបាសិកា គី ប៊ួយ ព្រមទាំងកូនចៅ

លោក យឹម សារ៉ាវិទ្ធ អ្នកស្រី រស់ ចិន្តា ព្រមទាំងបុត្រ

កុមារា យាន ពិសិដ្ឋ

ឧបាសិកា យន សាក ព្រមទាំងកូនចៅ

ឧបាសិកា ហោ យិចឡាំង ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ុន ចាន់ថា ព្រមទាំងកូនចៅ

ឧបាសិកា ជី ជុន ព្រមទាំងកូនចៅ

ឧបាសិកា ស៊ិន ឡាច ព្រមទាំងកូនចៅ

ឧបាសក ប៊ុន បួន ឧបាសិកា ឃុត សួរ ព្រមទាំងកូនចៅ

លោក ផាន សុបិន អ្នកស្រី សំ សុវណ្ណមល្លិកា ព្រមទាំងបុត្រ

បងស្រី ណៅ សុភី និងប្អូនស្រី ណៅ សុផល

ឧបាសិកា ឈឹន សុន ព្រមទាំងកូនចៅ

លោក ម៉ាន់ រិទ្ធី អ្នកស្រី អួន សារ៉េត ព្រមទាំងបុត្រ

លោក ឱម ឡូត អ្នកស្រី ស៊ុំ ស្រីពៅ ព្រមទាំងបុត្រ

លោក ម៉ាន់ សារឿន អ្នកស្រី ម៉ម សុជា ព្រមទាំងបុត្រ

លោក ស៊ឹម សាក់ន់ អ្នកស្រី លី សុខរ៉េត ព្រមទាំងបុត្រ

ឧបាសក ទិត្យ លី ឧបាសិកា ហេងវណ្ណា ព្រមទាំងកូនចៅ

ឧបាសិកា ថោង គឹមលន់ ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូ ប៉ុក ព្រមទាំងកូនចៅ

ឧបាសិកា ប៉េ សារ៉ា ឧបាសក ម៉ើ ធារី ឧបាសិកា ម៉ៅ ណារី ព្រមទាំងកូនចៅ

ឧបាសក ប៉ៃ ស៊ីថា ឧបាសិកា ងួន សាលីន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូច សាមុត ព្រមទាំងកូនចៅ

ឧបាសក សៅ ម៉េង ឧបាសិកា ថោង វង្ស ព្រមទាំងកូនចៅ

ឧបាសិកា ថោង វ៉េត ព្រមទាំងកូនចៅ

ឧបាសិកា សេក ម៉ាន ព្រមទាំងកូនចៅ

ឧបាសិកា ច័ន្ទ សោភ័ណ្ឌ

ឧបាសក ជូ ប៊ូរិន ឧបាសិកា ហែម យ៉ានី ព្រមទាំងកូនចៅ

ឧបាសក ឃោក ម៉ាន ឧបាសិកា ផូ ឡា ព្រមទាំងកូនចៅ

ឧបាសក ហាន គង់ ឧបាសិកា តេង លីគាង ព្រមទាំងកូនចៅ

ឧបាសិកា ឱម សុផាត ព្រមទាំងកូនចៅ

ឧបាសិកា មៅ សុផានី ព្រមទាំងកូនចៅ

លោក លីម លី អ្នកស្រី ជាវ ប៊ួយ ព្រមទាំងបុត្រ

ឧបាសិកា សោម សូត្រ ព្រមទាំងកូនចៅ

ឧបាសិកា អ៊ុយ សុខុន និងកូន ឈុន ពុធជាវី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ហុក តាំងអ៊ន់ ឧបាសិកា ជួន ស៊ីមយន់ ព្រមទាំងកូនចៅ

ឧបាសិកា យិន មួយឡាង ឧបាសិកា យិន មួយហួ ព្រមទាំងកូនចៅ

ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ាល់ ជីតា ព្រមទាំងកូនចៅ

ឧបាសិកា កាំង ប៉ោទៀង និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា យ៉ា សុខគីម ព្រមទាំងកូនចៅ

ឧបាសិកា តឹក អេងគី ព្រមទាំងកូនចៅ

ឧបាសិកា ទី សុធី +បុត្រ ហែម តុលា

## នាមពុទ្ធបរិស័ទនៅស្រុកថ្មគោលមានសទ្ធាជ្រះថ្លា
## ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក តាំង ម៉េង ឧបាសិកា លី ហ៊ុយស៊ីម ព្រមទាំងកូនចៅ

ឧបាសក លី ប៊ុនយូរ ឧបាសិកា យ៉ាន ស៊ី ព្រមទាំងកូនចៅ

លោក លី ប៊ុនហាក់ អ្នកស្រី តាំង ស៊ីវទៀង ព្រមទាំងបុត្រ

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈក្នុងការវេរធម្មទាន

| | |
|---|---|
| ១- ឧបាសក ប៉េង តាំងហៃ | ឧបាសិកា ហ៊ួ គីមហៀក |
| ២- ឧបាសក ស្រេង ស្រ៊ាង | ឧបាសិកា គិម ចន្ថា |
| ៣- ឧបាសក ឡាយ សុខុម | ឧបាសិកា គី គីមហាប់ |
| ៤- ឧបាសិកា បួ ម៉ាឡា | ឧបាសក បញ្ញា |
| ៥- ឧបាសិកា ង៉ែង យូអេង | ឧបាសិកា មាស ម៉ូនីកា |
| ៦- ឧបាសក លឹម ខូង | ឧបាសិកា កែវ អុន |
| ៧- ឧបាសិកា កែវ កល្យាណ | ឧបាសិកា ឡឹក ពេញចិត្ត |
| ៨- ឧបាសិកា ស៊ឺន ចន្ថា | លោក ឡាំ ដាវណ្ណ |
| ៩- ឧបាសិកា គួ ប៊ុនគាង | ឧបាសិកា ឈុំ គីមហួយ |
| ១០- ឧបាសិកា នេត្រ នរិន្ទ | ឧបាសិកា តាំង ប៉ោងជីង ( ហៅ ទន់ ) |
| ១១-ឧបាសិកា ឳម លក្ខណា | ឧបាសិកា ហេង ច័ន្ទបុញ្ញវត្តី |
| ១២-ឧបាសិកា គី យក់បួយ | ឧបាសិកា ឈុន ណាត |
| ១៣-ឧបាសិកា អ៊ុង រិទ្ធារី | ឧបាសិកា សៀក ឆាយគីម |
| ១៤-ឧបាសិកា វៀម ថុល | ឧបាសិកា ម៉ៅ នី |

| | |
|---|---|
| ១៥-ឧបាសិកា សន ឈៀត | ឧបាសក ឡាន សុខុម |
| ១៦-ឧបាសិកា គី វណ្ណហាក់ | ឧបាសិកា ប៉ុន ណាម |
| ១៧-ឧបាសិកា សួន កល្យាណ | ឧបាសិកា ភួង ភក្តី |
| ១៨-ឧបាសក អ៊ុង វ៉ៃយ៉ា | ឧបាសក កុយ សាមន |
| ១៩-ឧបាសក ហុង សុវណ្ណារិទ្ធ | ឧបាសក ហុង សុវណ្ណារ៉េត |

តម្លៃបោះពុម្ពក្នុង ១ ក្បាល ២$ × ១០០០ ក្បាល = ២០០០ $

ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងបោះពុម្ពសៀវភៅព្រះធម៌ជាច្រើនមុខទៀត ដើម្បីចែកជាធម្មទាន បើញាតិញោមពុទ្ធបរិស័ទ មានបំណងចង់ចូលរួមបោះពុម្ពសៀវភៅជាធម្មទាននោះ សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទនេះ ០៧៧ ៦៦ ៦៦ ៣៨, ០៨៨៨ ៧៧ ៩៩ ៦៦, ០១២ ៣០៥ ៧៦៦ ចំពោះសៀវភៅដែលត្រូវបោះពុម្ពនោះ ដូចមានខាងក្រោមនេះ គឺ

**-ជីវប្រវត្តិពុទ្ធឧបាសិកា** មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

**-វចនានុក្រមព្រះអភិធម្ម ៧ គម្ពីរ** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៨៣៣ ទំព័រ ។

**-គម្ពីរអភិធម្មត្ថសង្គហៈ** និង **វិភាវិនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៦៥០ ទំព័រជាង ។

**-អភិធម្មត្ថសង្គហៈ** និង **បរមត្ថទីបនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៩៨៩ ទំព័រជាង ។

-គម្ពីរអភិធម្មាវតា សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ពាពរហើយ គឺវាយកុំព្យូទ័ររូបជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥៩៧ ទំព័រ ។

-មិលិន្ទបញ្ហា សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ពាពរហើយ គឺវាយកុំព្យូទ័ររូបជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥០០ ទំព័រ ។

-ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងរាបចំធ្វើ គម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថា បញ្ចូលជាមួយគ្នា ដោយដាក់ព្រះត្រៃបិដកហើយ ដាក់ព្រះអដ្ឋកថាពីខាងក្រោមព្រះត្រៃបិដក ក្នុងការបញ្ចូលគម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថាជាមួយគ្នានោះព្រះត្រៃបិដកយកតាមបិដកខ្មែរយើង ដែលមាន ១១០ ក្បាល ។

-ព្រះត្រៃបិដកខ្មែរយើងដែលមាន ១១០ ក្បាល បានវាយ កុំព្យូទ័រចប់ហើយ ( ០១.០៥.២០១០, ២៧.០៣.២០១១ ) ។

-ការដាក់ព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ ដែលធ្វើសម្រេចជាស្ពាពរនោះ មានដូចខាងក្រោមនេះ គឺ

-គម្ពីរវិន័យបិដក បានធ្វើរូបជាស្រេចហើយ មានចំនួន ១៤ ភាគ

-គម្ពីរទីឃនិកាយ បានធ្វើរូបជាស្រេចហើយ មានចំនួន ៦ ភាគ

-គម្ពីរមជ្ឈិមនិកាយ បានធ្វើរូបជាស្រេចហើយ មានចំនួន ៩ ភាគ

-គម្ពីរសំយុត្តនិកាយ បានធ្វើរូបជាស្រេចហើយ មានចំនួន ១១ ភាគ

-គម្ពីរអង្គុត្តរនិកាយ បានធ្វើរូបជាស្រេចហើយ មានចំនួន ១៣ ភាគ

-គម្ពីរខុទ្ទកនិកាយ ប្រែបាន ៣៧ ភាគហើយ

សរុបការប្រែព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ សព្វថ្ងៃនេះបានចំនួន ៩០ ក្បាលជាងហើយ ។

# សៀវភៅដែលប្រមូលរៀបរៀង និងបោះពុម្ពហើយដោយ
## ខ្ញុំព្រះករុណា អាត្មាភាព
## ✍ យង់ សុផាត ✍

-ជីវប្រវត្តិព្រះអសីតិមហាសាវក មាន ៨ ភាគ ពីភាគ ១ ដល់ភាគ ៨

-ជីវប្រវត្តិព្រះអសីតិមហាសាវក **មាន ៤ ភាគ** ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា មាន ៤ ភាគ ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសក មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-ជីវប្រវត្តិព្រះពុទ្ធឧបាសក **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-រឿងរ៉ាវដែលទាកទងនឹងពុទ្ធស្ថាន **មាន ៥ ភាគ** ពីភាគ ១ ដល់ភាគ ៥

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេស មាន ១ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស មាន ៤ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស មាន ៣ ភាគ

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា ភាគ ១-២

-ធម៌សូធ្យនមស្ការបែបសម័យទំនើប

-គម្ពីរសារត្ថសង្គហៈ ភាគ ១

-គម្ពីរមហាសតិប្បដ្ឋានភាវនា

-ពុទ្ធប្បវត្តិ

សូមអនុមោទនាធម្មទាន !!!

## នាមពុទ្ធបរិស័ទដែលមានសទ្ធាបរិច្ចាគប្រាក់នៅសហរដ្ឋអាមេរិក ជួយបោះពុម្ពសៀវភៅនេះ

ឧបាសក ជឹម អេងស្រ៊ិន ឧបាសិកា រ៉ា សុខគីន ព្រមទាំងបុត្រ
លោក ជឹម មុនីបុត្រ អ្នកស្រី មាស ច័ន្ទនារី ព្រមទាំងបុត្រ
លោក ជឹម កុលវុឌ្ឍ អ្នកស្រី ម៉ាង សូលីដា ព្រមទាំងបុត្រ
លោក ជឹម សុភរោ អ្នកស្រី ប៉េង វិចិត្តា ព្រមទាំងបុត្រ
អ្នកស្រី ជឹម ពន្ធរក្ខ ព្រមទាំងបុត្រ
អ្នកស្រី ជឹម ពុទ្ធារី លោក ឈុន ហ៊ី ព្រមទាំងបុត្រ
អ្នកស្រី ជឹម ឧសភា លោក ឡៅ ជួយ ព្រមទាំងបុត្រ
លោក តាន់ សុផាណា អ្នកស្រី លី គន្ធា ព្រមទាំងបុត្រ
... ២១០០ $

ឧបាសក ឡឹក ច័ន្ទជេត ព្រមទាំងបុត្រ
ឧបាសិកា ឡឹក ពេញចិត្ត
ឧបាសិកា អ៊ាប គីមអ៊ុន ព្រមទាំងបុត្រ
ឧបាសក អ៊ាប ហៃសាន និងភរិយា ព្រមទាំងបុត្រ
ឧបាសិកា សៀក ឆាយគីម
ឧបាសក អ៊ាប គីមស៊ុន ព្រមទាំងបុត្រ
.... ១៥០០ $

ឧបាសិកា ឃី គីមលាង ព្រមទាំងកូនចៅ
លោក ធន គីមហួន ព្រមទាំងកូនចៅ
... ១៥០០ $

ឧបាសិកា គីម ឡុំ ព្រមទាំងបុត្រ ........................................ ៥០០ $

ឧបាសិកា គីម ប៊ុម ព្រមទាំងបុត្រ .................................... ១០០ $

ឧបាសិកា ព្រាម ណៃទាង ព្រមទាំងបុត្រ ........................... ១០០ $

ឧបាសិកា រ៉ាយ យ៉ានីន ព្រមទាំងបុត្រវណ្ណ ធន ...................... ៦០ $

ឧបាសិកា រ៉ា សុខគីន ឧបាសក ជឹម អេងស្រ៊ន ព្រមទាំងបុត្រ .... ៥០ $

ឧបាសិកា អូន ញ៉ ព្រមទាំងបុត្រ ........................................... ៥០ $

ឧបាសិកា វង គីមឆេង ព្រមទាំងបុត្រ ..................................... ៥០ $

ឧបាសិកា ព្រាម ទាង ព្រមទាំងបុត្រ ....................................... ៥០ $

ឧបាសិកា គីម ឡុំ ព្រមទាំងបុត្រ ........................................... ៥០ $

ឧបាសិកា អុំ ច័ន្ទជួង ( អបរ្សរា ) ព្រមទាំងបុត្រ ........................ ៥០ $

ឧបាសិកា ឱន ទូច ព្រមទាំងកូនចៅ ....................................... ៥០ $

ឧបាសក មុត សក់ ឧបាសិកា សន្ធា វ៉ែនមាសសុខ+ក្រុមគ្រួសារ . ៥០ $

ឧបាសិកា ង៉ូវ មួយឡាយ ព្រមទាំងបុត្រ .................................. ៣០ $

ឧបាសិកា សួស កន ព្រមទាំងបុត្រ ....................................... ៣០ $

ឧបាសិកា គឹម ឡាង ព្រមទាំងបុត្រ ....................................... ៣០ $

ឧបាសិកា គឹម ម៉ាលីស ព្រមទាំងបុត្រ .................................... ២០ $

ឧបាសិកា សា អ៊ុត ព្រមទាំងបុត្រ ......................................... ១០ $


**បោះពុម្ពជាធម្មទាន ១000 ក្បាល**

**ក្នុងតម្លៃ ១ ក្បាល ២ ដុល្លារ**

**រោងពុម្ព រមណីយ**

TEL : 012597431

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត